# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ
# និង
# បរមត្ថមញ្ជូសាមហាដីកា
# បញ្ញានិទ្ទេស
# ភាគទី ៣

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព **យង់ សុជាត**

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៥

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# បញ្ញានិទ្ទេស

# ភាគទី ៣

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៥

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ២២៥ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី...០៤...ខែ...តុលា...ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
### ពិតថេរដីកា
### ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***វិចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# និទានវចនៈ

*វិសុទ្ធិមគ្គ* ជាបករណ៍វិសេស ដែលព្រះថេរៈ **អ្នកស្រុកជម្ពូទ្វីប** មានឈ្មោះ ពោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនាកន្លងទៅហើយបាន ប្រមាណ ១.០០០ ឆ្នាំ **នៅកោះលង្កាទ្វីប** ព្រះថេរៈរូបនេះ គឺព្រះពុទ្ធឃោសៈ ឯលោកក៏បានរចនាគម្ពីរទុកជាច្រើន នៅក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារ ដ៏ធំ និងជាមរតក រហូតមកដល់សព្វថ្ងៃ ។ ការប្រែ **គម្ពីរព្រះត្រៃបិដក អដ្ឋកថា** ពី **ភាសាសីហឡៈ** មកជា **ភាសាមគធៈ** ឬ **ភាសាបាលី** ព្រះពុទ្ធឃោសៈបាន ប្រមូលធម៌នៅក្នុងព្រះត្រៃបិដក មកសម្ដែងទុកជាពួកៗ តាំងពី **សីល សមាធិ** និង **បញ្ញា** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬលំដាប់នៃការឆ្លើយសំណួរធម៌ក្នុង បច្ចុប្បន្ន គឺអធិប្បាយសេចក្ដីសង្ខេបឲ្យពិស្ដារ បទសំណួររបស់ **វិសុទ្ធិមគ្គ** ពោលដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំង អស់ គឺជាបេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈ បានអធិប្បាយ ដោយវិចិត្រពិស្ដារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋាន ទុកក្នុងទីនោះៗ ទូទៅ នេះសម្ដែងឲ្យដឹងថា លោកមានការបែកធ្លាយក្នុងព្រះ ត្រៃបិដក អាចលើកយកធម៌ ដែលពោលដោយសីល មករួបរួមទុកក្នុងពួក សីល លើកយកធម៌ដែលទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែលទាក់ទងជាមួយបញ្ញា មករួមទុកជាមួយពួកបញ្ញា ដោយ

បែកជានិទ្ទេសៗ រួមទាំងអស់មាន ២៣ និទ្ទេស, រីឯប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡូងដេញដោល, ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡៈ បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើលោកធ្វើបានជាទីពេញចិត្ត នឹងលើក **គម្ពីរអដ្ឋកថាភាសាសីហឡៈ** ឲ្យលោកប្រែជាភាសាមគធៈតទៅ ព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និងល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡៈទាំងពួង, ដូច្នោះ **គម្ពីរវិសុទ្ធិមគ្គនេះ** ជាវិជ្ជានិពន្ធ ដើម្បីសាកល្បងចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ ។

ព្រះពុទ្ធឃោសៈ មានដើមកំណើតនៅ **ប្រទេសឥណ្ឌា នាតំបន់ពុទ្ធគយា** បានសិក្សាជំនាញនៅក្នុងព្រះពុទ្ធវចនៈ ទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាដ៏ក្រៃលែង លោកបានធ្វើដំណើរទៅ **លង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ហើយបានរចនាគម្ពីរវិសុទ្ធិមគ្គនៅទីនោះ និងប្រែ **ព្រះបាលីអដ្ឋកថា** ពីភាសាសីហឡៈមកជាភាសាមគធៈ ( ភាសាបាលី ) ។

ព្រះថេរៈ មានឈ្មោះដែលគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោសៈ** ជាអ្នកមានភាពបរិសុទ្ធបរិបូណ៌ ប្រដាប់ដោយសទ្ធា វិជ្ជា និងសេចក្ដីព្យាយាមដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាបុគ្គលរុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្ដីល្អ មានសីលាចារៈទៀងត្រង់ និងការឱនលំទោនជាដើម អាចឈោងចុះកាន់ជដៈ គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់បុគ្គលដទៃ ប្រកបដោយការមុតស្រួចនៃបញ្ញា មានចំណេះដឹង មិនទើសទាក់ក្នុងសត្ថុសាសនៈ ដោយបរិយត្តិផ្សេងៗ គឺព្រះ

ត្រៃបិដក ព្រមទាំង **អដ្ឋកថា** ជា មហាវេយ្យាករណ៍ ប្រកបដោយកាពវិចិត្រនៃពាក្យសម្ដី ទាំងទន់ភ្លន់ទូលំទូលាយ បន្ទឹចេញបានស្អាត់ជំនាញ សន្សំឲ្យកើតករណសម្បត្តិ មានវាទៈប្រសើរត្រឹមត្រូវ បុគ្គលជទៃយល់បានងាយ ជាមហាកវី ហែហាមដោយបដិសម្ភិទាដែលបែកធ្លាយ ជាអលង្ការនៃវង្ស ព្រះថេរៈដែលនៅក្នុងមហាវិហារទាំងឡាយ ដែលជាប្រទីបនៃថេរវង្ស មានការដឹងតាំងមាំល្អហើយ ក្នុង **ឧត្តរិមនុស្សធម្ម** ដែលប្រដាប់ដោយគុណផ្សេងៗ មាន **អភិញ្ញា ៦** ជាដើម ហែហាមដោយ **បដិសម្ភិទា** បានរចនាវិសុទ្ធិមគ្គនេះចប់ហើយ ។

វិសុទ្ធិមគ្គនេះ តាំងនៅក្នុងលោក សម្ដែងន័យដល់កុលបុត្រទាំងឡាយដែលស្វែងរកធម៌ ជាគ្រឿងដកចេញនូវលោក ដរាបប៉ុនដែលព្រះនាមថា **ពុទ្ធោ** របស់ព្រះលោកជេដ្ឋៈ ដែលស្វែងរកគុណដ៏ធំ មានព្រះទ័យដ៏បរិសុទ្ធ ជាតាទិបុគ្គលប្រព្រឹត្តទៅក្នុងលោក ។

គម្ពីរវិសុទ្ធិមគ្គនេះបានរចនាដោយ

**ព្រះពុទ្ធឃោសាចារ្យ**

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនា

## ព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាឋានាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទា ព្រះពុទ្ធជាម្ចាស់ប្រៀបដូចជាព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាកួងរស្មី ទ្រង់កម្ចាត់ងងឹត គឺមោហៈធំអស់ហើយ ទ្រង់ញ៉ាំងពួកវេនេយ្យសត្វ ដែលប្រៀបដូចជាផ្កាឈូកឲ្យរីកវិសេស ទ្រង់មានព្រះបញ្ញាគុណដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មងរះឡើងក្នុងលោក គួរដល់ការបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោករុងរឿងដោយរស្មី គឺព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃ ដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជះនៃបុណ្យ ចំពោះការថ្វាយវន្ទាព្រះរតនត្រ័យដែលកើតឡើងហើយ ដោយប្រការនោះៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបោរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារនៃបករណ៍វិសេស ឈ្មោះ **វិសុទ្ធិមគ្គ** ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាងប្រណីត ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោលដើម្បីជាឧបាយក្នុងការសម្រេចភាពបរិសុទ្ធិដែលលោកជា **នាថ** មានព្រះចរិយាបរិសុទ្ធ មានហឫទ័យ

ដែលព្រះករុណាឲ្យឧស្សាហ៍ហើយ លោកបានសម្រេចហើយ សម្ដែងទុកមិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈឯសម្នាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយ មានវិនិច្ឆ័យសេចក្ដីដ៏សុខុម ឲ្យបរិសុទ្ធ និងប្រកបដោយរបៀបរៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គនេះឲ្យបានល្អ ខ្ញុំប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរ ដោយប្រការដូច្នេះចុះ ។

**ព្រះធម្មបាលត្ថេរ** ជាជនជាតិស្រីលង្កា លោកបានសិក្សានៅក្នុងសំណាក់**មហាវិហារ** នាក្រុង **អនុរាធបុរៈ** ក្នុង **លង្កាទ្វីប** បានចូលរួមរចនា **គម្ពីរអដ្ឋកថា** ជាមួយព្រះពុទ្ធឃោសាចារ្យដែរ, លោកបានរចនាអដ្ឋកថា និងមហាដីកា ទើបបានទទួលការលើកសរសើរថាជា **ព្រះអដ្ឋកថាចារ្យ** និង **ព្រះដីកាចារ្យ** នៅ**កោះលង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ។

គម្ពីរបរមត្ថមញ្ជូសាមហាដីកានេះរចនាដោយ

**ព្រះធម្មបាលត្ថេរ**

# អារម្ភកថា

ការបកប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ភាគ ៣** ដែលជាភាគបញ្ចប់នេះ យើងខ្ញុំបានរៀបរៀងដោយល្អមក ជាខេមរភាសា និងរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់ បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លា ក្នុងព្រះរតនត្រ័យ និងជាពិសេសដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តភក្តីចំពោះព្រះរតនត្រ័យនោះ **អនុមោទនា** នូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាម **ខេត្ត ក្រុង** ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា អាត្មាភាពបានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥០** ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ **៦៤៥ ដុល្លារសហរដ្ឋអាមេរិក** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះ ករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា** ដែលមានពុទ្ធបរិស័ទទៅ **ប្រមាណ ៦៥ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ១០** ព្រះអង្គផងដែរ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុង

ការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅថ្វាយបង្គំបាន ៥១ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសិកា ឱម លក្ខណា នៅក្នុង ព.ស. ២៥៥០ ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស. ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥០ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល ) និងប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការជួយជ្រោមជ្រែងឧបត្ថម្ភអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ុប វណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលន្ទា

| | | |
|---|---|---|
| នឹកឃើញលង្កា | នឹកឃើញកាលណា | ជ្រះថ្លាក្រៃលែង |
| នៅពុទ្ធស្ថាន | ១៩ កន្លែង | ដែលខ្ញុំបានស្វែង |
| | ទៅថ្វាយបង្គំ ។ | |
| ១២១ អង្គា | គាល់ព្រះបាទា | នាស្ថានមនោរម |
| លើសុមនកូដ | ជេស្ថាឧត្ដម | ជាកំពូលភ្នំ |
| | ក្នុងប្រវត្តិពុទ្ធ ។ | |
| ទឹកដីលង្កា | ទឹកដីអស្ចារ្យ | ពេញពោរដោយឫទ្ធិ |
| នឹកឃើញកាលណា | ជ្រះថ្លាក្រៃពិត | ធម្មយាត្រាប្រណីត |
| | ក្នុង ព.ស. ២៥៥១ ។ | |

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្ដែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥១ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់

រៀល ) និងប្រាក់ដុល្លារ **១៩៥** ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺ បុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង **ប្រទេសឥណ្ឌាជាលើកទីពីរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជា ប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧** នាក់ ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥** ព្រះអង្គផងដែរ បានការឧបត្ថម្ភមក អំពីឧបាសក **ឃឹត សូណាត** ឧបាសិកា **ហ៊ុន ម៉ារ៉ានី** M.SUSOKUNORAetMmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **អ៊ុំង វិទ្ធារី** ឧបាសិកា **ស្ងួន កល្យាណ** ឧបាសិកា **ស្ងួន ចរណៃ** នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ ! ព្រះសាសនា ។

នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នាទស្សនា
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្តង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៣៦ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៣** ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក **ឆាយ អ៊ីវស៊ាង** ឧបាសិកា **ហុង គឹមសែ** ក្រោមការជ្រោមជ្រែងរបស់ឧបាសក **យន្ត សួន** នៅក្នុង **ព.ស. ២៥៥២** ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៣** ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង **ព.ស. ២៥៥២** ដែរ ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥៣** ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( **១៣ លាន ០ សែន ៨ ម៉ឺន** ) និងប្រាក់ដុល្លារ **២០៨ ដុល្លារ** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងអំពីឧបាសក **ឡាយ សុខុម** នៅក្នុង **ព.ស. ២៥៥៣** ( ២៥.០១.២០១០ ) ។

## ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅទស្សនា ស្រប់ស្រែងអស្ចារ្យ
ឱះ ឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន ) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងមកពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

# គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាន
ប្រៀបបានព្រៃស្ងាត់ ។
២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៥ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥៤ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៥ ប្រាក់ខ្មែរបាន ៣៥,២៨២០០០ រៀល ( **៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់រៀល** ) និងប្រាក់ដុល្លារ **២៧៥៨ ដុល្លារ** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌា ជាលើកទី ៥ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៨ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គ**ផងដែរ ដោយទៅថ្វាយបង្គំបាន **១៤ កន្លែងធំៗ** បានការជ្រោមជ្រែងមកពីឧបាសិកា **អ៊ឹង រិទ្ធារី** នៅក្នុង ព.ស. **២៥៥៥** ( ០២.០២.២០១២ ) ។

*នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណាអាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង ប្រទេសស្រីលង្កាជាលើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១៤០** នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩ កន្លែងធំៗ បានការឧបត្ថម្ភមកអំពីឧបាសិកា **អ៊ឹង វិទ្ធារី** នៅក្នុង ព.ស. **២៥៥៥** ( ២៧.០៣.២០១២ ) ។*

## បានយល់ស្រុកព្រះ

*ជ្រះថ្លាខ្លាំងណាស់ បានយល់ស្រុកព្រះ ជាតិភូមិសាស្តា*
*១៤ កន្លែង ៦៨ អង្គា បានក្រាបវន្ទា*
*បូជាគ្រប់ប្រាណ ។*
*សិរីលង្កា ១៤០ អង្គា ៩ ពុទ្ធស្ថាន*
*ជ្រះថ្លាខ្លាំងណាស់ ដែលពួកខ្ញុំបាន នមស្ការពុទ្ធស្ថាន*
*ក្នុងពុទ្ធសករាជ ២៥៥៥ ។*

*ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យង់ សុង** ( ស្លាប់ ) និងញោមស្រី **ឈឹម ហាយ** ( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ត ជាពិសេស*

នោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីវ** ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះស្មើនឹងអាត្មាភាពផងដែរ សូម **អនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗគ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគត កុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ **អង្គណានីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១** ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយន្តសុផាត

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គីម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ប៊ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន វណ្ណនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម រ៉ៃយ៉ា ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ជិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ប៊ូ ស៊ីជួ ជួយពិនិត្យអក្ខរាវិរុទ្ធ

# សមាជិកសមាគមធម្មទានអរិយទ្រព្យចំរុងផាត

សម្តេចព្រះសង្ឃរាជគណមហានិកាយ ននួ ង៉ែត ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ យង់ សុផាត ជាប្រធានសមាគម

លោកអភិបាលស្រុក ស្រេង ស្រ៊ាង ជាទីប្រឹក្សាសមាគម

ឧបាសក អ៊ឹម វ៉ៃយ៉ា ជាអនុប្រធានសមាគម

ឧបាសិកា ង៉ែត យូអេង ជាអនុប្រធានសមាគម

សាមណេរ ម៉ី សាលួន ជាលេខាធិការ

ឧបាសក ឡាន សុខុម ជាលេខាធិការរង

ឧបាសិកា តាំង ប៉េងជីង ជាហេរញ្ញិក

ឧបាសិកា ជា នាង ជាបេឡា

លោកគ្រូធម្មបណ្ឌិត អៀ សៅ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ឡាយ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា អ៊ឹង វិទ្ធារី សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោ ភាព សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា គួ ប៊ុនគាង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឈុំ គីមហួយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ប៉ែន រមណីយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អុឹង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា បួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មាស មូ៉នីកា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឡឹក ពេញចិត្ត សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា សៀក ឆាយគីម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក បញ្ញា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា កែវ កល្យាណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារ៉េត ជាសមាជិកសកម្ម

# មាតិកាធម៌

មាតិកា | លេខទំព័រ

មគ្គាមគ្គញាណទស្សនវិសុទ្ធិ ............................................ ១
អធិប្បាយ មគ្គាមគ្គញាណទស្សនវិសុទ្ធិ ............................ ១០
របៀបធ្វើសម្មសនៈ ( ត ) ............................................ ២៥
អធិប្បាយរបៀបធ្វើសម្មសនៈ ( ត ) ................................ ៣២
ធ្វើឥន្ទ្រិយឲ្យចាស់ក្លាដោយអាការ ៩ ................................ ៤២
អធិប្បាយ ធ្វើឥន្ទ្រិយឲ្យចាស់ក្លាដោយអាការ ៩ ................ ៤៣
រូបសម្មសនៈ-ពិចារណារូបតាមកាល ................................ ៤៧
អធិប្បាយ រូបសម្មសនៈ-ពិចារណារូបតាមកាល ................ ៥៥
អរូបសម្មសនៈ ............................................................ ៦៦
អធិប្បាយ អរូបសម្មសនៈ ............................................ ៦៨
ពិចារណារូប និងអរូបដោយអាការ ៧ ............................... ៧០
អធិប្បាយ ពិចារណារូប និងអរូបដោយអាការ ៧ ............... ៨៨
អរូបសត្តកៈ .............................................................. ១០៤
មហាវិបស្សនា ១៨ ..................................................... ១០៩
អធិប្បាយ អរូបសត្តកៈ ................................................ ១១៣
ឧទយព្វយានុបស្សនាញាណ ........................................... ១២៤

អធិប្បាយ ឧទយព្វយានុបស្សនាញាណ ........................ ១៣១
វិបស្សនូបក្កិលេស ១០ ................................................ ១៤៩
អធិប្បាយ វិបស្សនូបក្កិលេស ១០ ................................ ១៥៨
ឧបក្កិលេស ១០ ចែកជា ៣០ ក៏បាន ( ត ) .................. ១៧១
អធិប្បាយ ឧបក្កិលេស ១០ ចែកជា ៣០ ក៏បាន ( ត ) ... ១៧៤
បដិបទាញាណទស្សនវិសុទ្ធិ .......................................... ១៧៧
អធិប្បាយ បដិបទាញាណទស្សនវិសុទ្ធិ ......................... ១៨០
ភង្គានុបស្សនាញាណ ..................................................... ១៨៩
អធិប្បាយ ភង្គានុបស្សនាញាណ .................................. ១៩៨
ភយតុបដ្ឋានញ្ញាណ ...................................................... ២១២
អធិប្បាយ ភយតុបដ្ឋានញ្ញាណ .................................... ២១៧
អាទីនវានុបស្សនាញាណ .............................................. ២២១
អធិប្បាយ អាទីនវានុបស្សនាញាណ ............................. ២២៧
និព្វិទានុបស្សនាញាណ ................................................ ២៣៦
អធិប្បាយ និព្វិទានុបស្សនាញាណ ................................ ២៣៨
មុញ្ចិតុកម្យតាញាណ .................................................... ២៤០
អធិប្បាយ មុញ្ចិតុកម្យតាញាណ .................................. ២៤២
បដិសង្ខានុបស្សនាញាណ ............................................. ២៤៤

អធិប្បាយ បដិសង្ខានុបស្សនាញាណ .................................. ២៥០

សង្ខារុបេក្ខាញាណ ........................................................ ២៥៥

អធិប្បាយ សង្ខារុបេក្ខាញាណ ........................................ ២៨៩

អនុលោមញ្ញាណ ............................................................ ៣៣៣

អធិប្បាយ អនុលោមញ្ញាណ ............................................ ៣៣៦

វុដ្ឋានគាមិនីវិបស្សនា ..................................................... ៣៤០

អធិប្បាយ វុដ្ឋានគាមិនីវិបស្សនា .................................... ៣៤២

ញាណទស្សនវិសុទ្ធិ ........................................................ ៣៤៥

អធិប្បាយ ញាណទស្សនវិសុទ្ធិ ......................................... ៣៥១

ទុតិយមគ្គញ្ញាណ ............................................................ ៣៥៨

កថាពណ៌នាដោយសោតាបន្នបុគ្គល .................................. ៣៦១

រំកិលភូមិ ....................................................................... ៣៦៣

អធិប្បាយ ទុតិយមគ្គញ្ញាណ ............................................ ៣៦៤

តតិយមគ្គញ្ញាណ ............................................................ ៣៦៦

អធិប្បាយ តតិយមគ្គញ្ញាណ ............................................ ៣៦៧

ចតុត្ថមគ្គញ្ញាណ ............................................................ ៣៦៨

អធិប្បាយ ចតុត្ថមគ្គញ្ញាណ ........................................... ៣៦៩

អរហន្តបុគ្គល .................................................................. ៣៧០

អធិប្បាយ អរហន្តបុគ្គល ................................................ ៣៧១
អានុភាពនៃមគ្គញាណ ................................................ ៣៧២
អធិប្បាយ អានុភាពនៃមគ្គញាណ ................................................ ៣៧៨
វុដ្ឋាន និង ពលសមាយោគ ................................................ ៣៨៧
អធិប្បាយ វុដ្ឋាន និង ពលសមាយោគ ................................................ ៣៩១
បហាន ................................................ ៣៩៤
កថាពណ៌នាដោយការលះបហាតព្វធម៌ ................................................ ៤១១
កិច្ចក្នុងអរិយសច្ច ................................................ ៤២៧
កថាពណ៌នាដោយកិច្ច មានបរិញ្ញាកិច្ច ................................................ ៤៣៣
អធិប្បាយ កិច្ច ៤ ក្នុងអរិយសច្ច ................................................ ៤៤២
អធិប្បាយ ដោយប្រភេទនៃបរិញ្ញា ................................................ ៤៥៣
បញ្ញាភាវនានិសង្ស ................................................ ៤៦២
អធិប្បាយ បញ្ញាភាវនានិសង្ស ................................................ ៤៦៣
នានាកិលេសវិទ្ធំសនៈ ................................................ ៤៦៤
អធិប្បាយ នានាកិលេសវិទ្ធំសនៈ ................................................ ៤៦៥
អរិយផលរសានុភវនៈ ................................................ ៤៦៦
អធិប្បាយ អរិយផលរសានុភវនៈ ................................................ ៤៧៣
និរោធសមាបត្តិសមាបជ្ជនសមត្ថតា ................................................ ៤៨៧

អធិប្បាយ និរោធសមាបត្តិសមាបជ្ជនសមត្ថតា ..................... ៥០៣
អាហុនេយ្យភាវាទិសិទ្ធិ ..................................................... ៥២១
អធិប្បាយ អាហុនេយ្យភាវាទិសិទ្ធិ ..................................... ៥២៤
គាថាចុងបករណ៍នៃវិសុទ្ធិមគ្គ ............................................ ៥៣១
កថាពណ៌នាគាថាចុងបករណ៍ ............................................ ៥៣៣
គាថាចុងបករណ៍នៃបរមត្ថមញ្ជូសា ..................................... ៥៣៣
គុណសម្បត្តិរបស់ព្រះពុទ្ធឃោសៈ ១១ ប្រការ .................. ៥៣៥
ប្រវត្តិព្រះពុទ្ធឃោសៈ ....................................................... ៥៣៦
បរិយោសានកថា ............................................................. ៥៤២

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

## មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនិទ្ទេស

ចំណែកញាណដែលដឹងធម៌ជាផ្លូវ និងធម៌ដែលមិនមែនផ្លូវថា **នេះជាផ្លូវ នេះមិនមែនផ្លូវ** ដូច្នេះហើយ តាំងនៅ ឈ្មោះថា **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** ។

## នយវិបស្សនា ឬកលាបសម្មសនៈ

ព្រះយោគាវចរ ដែលប្រាថ្នានឹងធ្វើមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនោះ ឲ្យដល់ព្រម គប្បីធ្វើយោគៈក្នុង **នយវិបស្សនា** ដែលហៅថា **កលាបសម្មសនៈ** មុន ព្រោះហេតុអ្វី ? គប្បីដោះស្រាយថា ព្រោះសម្រាប់បុគ្គលផ្ដើមវិបស្សនាហើយ ក្នុងកាលវិបស្សនូបក្កិលេស មានឱកាសជាដើមកើតឡើង មគ្គាមគ្គញ្ញាណទស្សនៈ ទើបកើត ។ ពិតហើយ វិបស្សនូបក្កិលេសទាំងឡាយ មានឱកាសជាដើមកើតឡើង ហើយមគ្គាមគ្គញ្ញាណ ទើបមានដល់ព្រះយោគាវចរដែលផ្ដើមធ្វើវិបស្សនា ព្រោះកលាបសម្មសនៈជាខាងដើមរបស់វិបស្សនា ព្រោះហេតុនោះ ទើបមគ្គាមគ្គញ្ញាណ លោកសម្ដែងឡើងទុកជាលំដាប់នៃកង្ខាវិតរណញ្ញាណ ។ ម្យ៉ាងទៀត ហេតុណា កាលតីរណបរិញ្ញាកំពុងប្រព្រឹត្តទៅ មគ្គាមគ្គញ្ញាណ ទើបកើតឡើង ហើយតីរណបរិញ្ញាក៏មានក្នុងលំដាប់នៃញាតបរិញ្ញា ព្រោះហេតុនោះ ព្រះយោគីដែលប្រាថ្នានឹងធ្វើមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនោះឲ្យដល់ព្រម ទើបត្រូវធ្វើយោគៈក្នុងកលាបសម្មសនៈមុន ។

## បរិញ្ញា ៣

នេះជាវិនិច្ឆ័យក្នុងបរិញ្ញាទាំងឡាយនោះ ឯលោកិយបរិញ្ញា មាន ៣ គឺ **ញាតបរិញ្ញា តីរណបរិញ្ញា** និង **បហានបរិញ្ញា** ដែលលោកសំដៅយក ពោលថា

**អភិញ្ញាបញ្ញា** ( បញ្ញាដែលប្រែមុខដឹងញេយ្យធម៌ ) ចាត់ជាញាណ ព្រោះអត្ថ គឺដឹងបាន **បរិញ្ញាបញ្ញា** ( បញ្ញាដែលកំណត់ដឹងបរិញ្ញេយ្យធម៌ ) ចាត់ជាញាណ ព្រោះអត្ថ គឺកាត់បង់បាន **បហានបញ្ញា** ( បញ្ញាដែលលះបហាតព្វធម៌ ) ចាត់ជាញាណ ព្រោះអត្ថគឺលះបង់បាន ដូច្នេះ ។

ក្នុងបរិញ្ញា ៣ នោះ បញ្ញាដែលប្រព្រឹត្តទៅ ដោយកំណត់បច្ចត្តលក្ខណៈ ( លក្ខណៈចំពោះខ្លួន ) នៃធម៌ទាំងឡាយនោះៗ ដោយន័យថា **រូបមានការបែកធ្លាយទៅបានជាលក្ខណៈ វេទនាមានការសោយ ( សេអារម្មណ៍ ) បានជាលក្ខណៈ** ដូច្នេះ ជាដើម ឈ្មោះថា **ញាតបរិញ្ញា** ។ ចំណែក **លក្ខណារម្មណិយវិបស្សនាបញ្ញា** ( វិបស្សនាបញ្ញាដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ ) ដែលប្រព្រឹត្តទៅ ដោយលើកឡើងកាន់សាមញ្ញលក្ខណៈនៃធម៌ទាំងឡាយនោះឯង ដោយន័យថា **រូបមិនទៀង វេទនាមិនទៀង** ជាដើម ឈ្មោះថា **តីរណបរិញ្ញា** ចំណែកលក្ខណារម្មណិយវិបស្សនាបញ្ញានោះឯង ដែលប្រព្រឹត្តទៅ ដោយអំណាចលះវិបល្លាសសញ្ញា មានការសម្គាល់ថា ទៀងជាដើម ក្នុងធម៌ទាំងឡាយនោះឯងបាន ឈ្មោះថា **បហានបរិញ្ញា** ។

## ភូមិរបស់បរិញ្ញា

ភូមិរបស់ញាតបរិញ្ញា ផ្តើមតាំងអំពីសង្ខារបរិច្ឆេទ ទៅរហូតដល់បច្ចយបរិគ្គហៈ ព្រោះថា ក្នុងចន្លោះនេះ ភាពជាធំ រមែងមានដល់ការចាក់ធ្លុះបច្ចត្តលក្ខណៈរបស់ធម៌ទាំងឡាយប៉ុណ្ណោះ ។

ភូមិរបស់ **តីរណបរិញ្ញា** ផ្តើមតាំងអំពីកលាបសម្មសនៈ ទៅរហូតដល់ឧទយព្វយានុបស្សនា គឺឃើញទាំងកើត ទាំងរលត់ ព្រោះថា ក្នុងចន្លោះនេះ ភាពជាធំ រមែងមានដល់ការចាក់ធ្លុះសាមញ្ញលក្ខណៈប៉ុណ្ណោះ ។

ភូមិរបស់ បហានបរិញ្ញា ចាប់អំពីភង្គានុបស្សនា ( ឃើញតែការរលត់ ) ជាដើមខ្ពស់ឡើងទៅ ព្រោះថា តាំងអំពីនោះទៅ ភាពជាធំ រមែងមានដល់អនុបស្សនា ៧ ដែលញុំាងការលះបហាតព្វធម៌ មាននិច្ចសញ្ញាជាដើមឲ្យសម្រេច ដូច្នេះ គឺព្រះយោគាវចរតាមឃើញ ( សង្ខារ ) ដោយអាការមិនទៀង រមែងលះនិច្ចសញ្ញាបាន តាមឃើញដោយអាការជាទុក្ខ រមែងលះសុខសញ្ញាបាន តាមឃើញដោយអាការជាអនត្តា រមែងលះអត្តសញ្ញាបាន នឿយណាយ រមែងលះនន្ទិបាន ប្រាសចាកតម្រេក រមែងលះរាគៈបាន រំលត់ គឺបិទផ្លូវកើតរបស់សង្ខារតទៅ រមែងលះសមុទយៈ លះបង់ គឺរលាស់ចោល រមែងលះសេចក្តីប្រកាន់បាន ក្នុងបរិញ្ញា ៣ ដូចពោលមកនេះ ញាតបរិញ្ញាតែម្យ៉ាង ដែលព្រះយោគីអង្គនេះ សម្រេចហើយ ចំណែកបរិញ្ញាក្រៅអំពីនេះ គឺតីរណបរិញ្ញា និងបហានបរិញ្ញា ក៏គប្បីបានចាក់ធ្លុះផងដែរ ព្រោះសង្ខារបរិច្ឆេទ និងបច្ចយបរិគ្គហៈធ្វើឲ្យសម្រេចបាន ហេតុនោះ ទើបខ្ញុំពោលទុក ( ខាងដើម ) ថា ហេតុណា កាលតីរណបរិញ្ញាប្រព្រឹត្តទៅ ទើបមគ្គាមគ្គញាណកើតឡើង ហើយតីរណបរិញ្ញាសោត ក៏កើតឡើងក្នុងលំដាប់នៃញាតបរិញ្ញា ព្រោះហេតុនោះ ព្រះយោគីដែលប្រាថ្នា នឹងធ្វើមគ្គាមគ្គញាណទស្សនវិសុទ្ធិនោះឲ្យដល់ព្រម ទើបត្រូវធ្វើយោគៈក្នុងកលាបសម្មសនៈមុន ដូច្នេះ ។

## បាលីសម្មសនញ្ញាណ

នេះជាបាលីក្នុងកលាបសម្មសនៈនោះថា បញ្ញាក្នុងការកំណត់ដោយសង្ខេបធម៌ទាំងឡាយ ទាំងអតីត អនាគត និងបច្ចុប្បន្ន ឈ្មោះថា **សម្មសនញ្ញាណ** ( ញាណក្នុងការពិចារណា ) ដូចម្តេច ?

រូបគ្រប់យ៉ាង ទាំងអតីត អនាគត និងបច្ចុប្បន្ន ជាខាងក្នុង ឬខាងក្រៅក៏ដោយ ។បេ។ នៅក្នុងទីឆ្ងាយ ឬក្នុងទីជិតក៏ដោយ ភិក្ខុកំណត់រូបទាំងឡាយ ( នោះ ) ដោយ

អាការមិនទៀង ជាសម្មសនៈ ១ កំណត់ដោយអាការជាទុក្ខ ជាសម្មសនៈ ១ កំណត់ដោយអាការជាអនត្តា ជាសម្មសនៈ ១ វេទនាគ្រប់យ៉ាង ។បេ។ វិញ្ញាណគ្រប់យ៉ាង ។បេ។ កំណត់ដោយអាការដែលជាអនត្តា ជាសម្មសនៈ ១ កិច្ចកំណត់ចក្ខុ ។បេ។ ជរាមរណៈទាំងអតីត អនាគត និងបច្ចុប្បន្ន ដោយអាការមិនទៀង ជាសម្មសនៈ ១ កំណត់ដោយអាការជាទុក្ខ ជាសម្មសនៈ ១ កំណត់ ដោយអាការជាអនត្តា ជាសម្មសនៈ ១ ។

បញ្ញាក្នុងការកំណត់ដោយសង្ខេបថា រូបដែលជាអតីត អនាគត និងបច្ចុប្បន្ន មិនទៀង ព្រោះអត្ថ គឺអស់ទៅ ជាទុក្ខ ព្រោះអត្ថ គឺជាភ័យ ជាអនត្តា ព្រោះអត្ថ គឺមិនមានសារៈ ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ដោយសង្ខេបថា វេទនា ។បេ។ វិញ្ញាណដែលជាអតីត អនាគត និងបច្ចុប្បន្នមិនទៀង ។បេ។ ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ ដោយសង្ខេបថា ចក្ខុ ។បេ។ ជរាមរណៈដែលជាអតីត អនាគត និងបច្ចុប្បន្នមិនទៀង ។បេ។ ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ដោយសង្ខេបថា រូបដែលជាអតីត អនាគត និងបច្ចុប្បន្នជារបស់មិនទៀង ជារបស់ដែលបច្ច័យប្រជុំតាក់តែងឡើង អាស្រ័យហេតុកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតា មានការរលត់ទៅជាធម្មតា ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ដោយសង្ខេបថា វេទនា ។បេ។ វិញ្ញាណដែលជាអតីត អនាគត និងជាបច្ចុប្បន្ន ជារបស់មិនទៀង ។បេ។ មានការរលត់ទៅជាធម្មតា ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ដោយសង្ខេបថា ចក្ខុ ។បេ។ ជរាមរណៈ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ជារបស់មិនទៀង ។បេ។ មានការរលត់ទៅ ជាធម្មតា ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ដោយសង្ខេបថា ជរាមរណៈមាន

ព្រោះបច្ច័យ គឺជាតិ កាលជាតិមិនមាន ជរា និងមរណៈក៏មិនមាន ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ដោយសង្ខេបថា ជរាមរណៈមាន ព្រោះបច្ច័យ គឺជាតិ កាលជាតិមិនមាន ជរា និងមរណៈក៏មិនមាន សូម្បីក្នុងអតីតកាល អនាគតកាល ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ដោយសង្ខេបថា ជាតិមាន ព្រោះបច្ច័យ គឺភព ។បេ។ សង្ខារទាំងឡាយមាន ព្រោះបច្ច័យ គឺអវិជ្ជា កាលអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ឈ្មោះថា សម្មសនញ្ញាណ ។ បញ្ញាក្នុងការកំណត់ ដោយសង្ខេបថា សង្ខារទាំងឡាយមាន ព្រោះបច្ច័យ គឺអវិជ្ជា កាលអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន សូម្បីក្នុងអតីតកាល អនាគតកាល ឈ្មោះថា សម្មសនញ្ញាណ ។

ការដឹងនោះ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹងបាន ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងទូទៅ ហេតុនោះ ទើបខ្ញុំពោលទុកថា បញ្ញាក្នុងការកំណត់ដោយសង្ខេបធម៌ទាំងឡាយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ឈ្មោះថា សម្មសនញ្ញាណ ។

ឯក្រុមធម៌ទាំងឡាយនេះ គឺធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងទ្វារ ព្រមទាំងតួទ្វារ និងអារម្មណ៍ ខន្ធ ៥ ទ្វារ ៦ អារម្មណ៍ ៦ វិញ្ញាណ ៦ ផស្សៈ ៦ វេទនា ៦ សញ្ញា ៦ ចេតនា ៦ តណ្ហា ៦ វិតក្ក ៦ វិចារៈ ៦ ធាតុ ៦ កសិណ ១០ កោដ្ឋាស ៣២ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ ធាតុ ៣ ភព ៣ ភពដទៃទៀត ៣ ភពដទៃទៀត ៣ ឈាន ៤ អប្បមញ្ញា ៤ សមាបត្តិ ៤ អង្គនៃបដិច្ចសមុប្បាទ ១២ បណ្ឌិតគប្បីជ្រាបថា លោកសង្ខេបទុកដោយបេយ្យាល គឺ ចក្ខុំ ។បេ។ ជរាមរណំ ចក្ខុ ។បេ។ ជរាមរណៈនេះ ក្នុងបាលីសម្មសនញ្ញាណនេះ ។

## អភិញ្ញេយ្យនិទ្ទេស

ពិតហើយ សេចក្តីនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងអភិញ្ញេយ្យនិទ្ទេស

ថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួង ជាវត្ថុគប្បីដឹងក្រៃលែង ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងឡាយ ដែលគប្បីដឹងក្រៃលែង ម្នាលភិក្ខុទាំងឡាយ ចក្ខុ ជាវត្ថុគប្បីដឹងក្រៃលែង រូបទាំងឡាយ ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខុវិញ្ញាណ ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខុសម្ផស្ស ជាវត្ថុគប្បីដឹងក្រៃលែង សុខវេទនាការសោយ ជាសុខខ្ញុំ ជាទុក្ខៈ មិនទុក្ខមិនសុខខ្ញុំ ដែលកើតព្រោះបច្ច័យ គឺចក្ខុសម្ផស្ស សុខវេទនាការសោយនោះ ក៏ជាវត្ថុគប្បីដឹងក្រៃលែង សោតៈ ជាវត្ថុគប្បីដឹងក្រៃលែង ។បេ។ សុខវេទនាការសោយ ជាសុខខ្ញុំ មិនទុក្ខមិនសុខខ្ញុំ នេះកើតឡើងព្រោះបច្ច័យ គឺមនោសម្ផស្ស សុខវេទនាការសោយនោះ ក៏ជាវត្ថុគប្បីដឹងក្រៃលែង ។

រូប... វិញ្ញាណ ជាវត្ថុគប្បីដឹងក្រៃលែង រូបទាំងឡាយ... ធម៌ទាំងឡាយ ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខុវិញ្ញាណ...មនោវិញ្ញាណ ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខុសម្ផស្ស... មនោសម្ផស្ស ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខុសម្ផស្សជាវេទនា...មនោសម្ផស្សជាវេទនា ជាវត្ថុគប្បីដឹងក្រៃលែង រូបសញ្ញា... ធម្មសញ្ញា ជាវត្ថុគប្បីដឹងក្រៃលែង រូបសញ្ចេតនា... ធម្មសញ្ចេតនា ជាវត្ថុគប្បីដឹងក្រៃលែង រូបតណ្ហា... ធម្មតណ្ហា ជាវត្ថុគប្បីដឹងក្រៃលែង រូបវិតក្ក... ធម្មវិតក្ក ជាវត្ថុគប្បីដឹងក្រៃលែង រូបវិចារៈ... ធម្មវិចារៈ ជាវត្ថុគប្បីដឹងក្រៃលែង បឋវីធាតុ... វិញ្ញាណធាតុ ជាវត្ថុគប្បីដឹងក្រៃលែង បឋវីកសិណ... វិញ្ញាណកសិណ ជាវត្ថុ គប្បីដឹងក្រៃលែង សក់... ខួរក្នុងក្បាល ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខាយតនៈ រូបាយតនៈ... មនាយតនៈ ធម្មាយតនៈ ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ... មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ជាវត្ថុគប្បីដឹងក្រៃលែង ចក្ខុន្ទ្រិយ... អញ្ញាតាវិន្ទ្រិយ ជាវត្ថុគប្បីដឹងក្រៃលែង កាមធាតុ រូបធាតុ អរូបធាតុ ជាវត្ថុគប្បីដឹងក្រៃលែង កាមភព រូបភព អរូបភព ជាវត្ថុគប្បីដឹងក្រៃលែង សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ជាវត្ថុគប្បីដឹងក្រៃលែង ឯកវោការភព

ចតុវោការភព បញ្ចវោការភព ជាវត្ថុគប្បីដឹងក្រៃលែង បឋមជ្ឈាន...ចតុត្ថជ្ឈាន ជាវត្ថុគប្បីដឹងក្រៃលែង មេត្តាចេតោវិមុត្តិ... ឧបេក្ខាចេតោវិមុត្តិ ជាវត្ថុគប្បីដឹងក្រៃលែង អាកាសានញ្ចាយតនសមាបត្តិ... នេវសញ្ញានាសញ្ញាយតនសមាបត្តិ ជាវត្ថុគប្បីដឹងក្រៃលែង អវិជ្ជា... ជរាមរណៈ ជាវត្ថុគប្បីដឹងក្រៃលែង ដូច្នេះ ។

វត្ថុទាំងពួង ដែលគប្បីដឹងក្រៃលែងនោះ ឈ្មោះថា លោកបានសង្ខេបទុកដោយបេយ្យាលទាំងពួង ក្នុងបាលីសម្មសនញ្ញាណនេះ ព្រោះព្រះមានព្រះភាគបានត្រាស់ទុកយ៉ាងពិស្តារក្នុងអភិញ្ញេយ្យនិទ្ទេសនោះ ដូចពោលមក ដូច្នេះ ។

តែធម៌ពួកណា ជាលោកុត្តរធម៌ មកក្នុងអភិញ្ញេយ្យនិទ្ទេស ដែលសង្ខេបទុកយ៉ាងនេះ ធម៌ទាំងនោះ មិនគប្បីកាន់យកក្នុងអធិការ ( នៃសម្មសនៈ ) នេះ ព្រោះមិនចូល ( កេណ្ឌ ) សម្មសនៈ សូម្បីធម៌ពួកណាចូល ( កេណ្ឌ ) សម្មសនៈសោតក្នុងធម៌ទាំងនោះ ធម៌ទាំងឡាយណាប្រាកដច្បាស់ដល់នូវការកំណត់យកបានដោយងាយ ដល់ព្រះយោគីអង្គណា ព្រះយោគីអង្គនោះ គប្បីផ្តើមចម្រើនសម្មសនៈ ក្នុងធម៌ទាំងឡាយនោះឯង ។

# របៀបចម្រើនសម្មសនៈ

នេះជាអាវុត្តិវិធានយោជនាផ្នែកខន្ធថា រូបគ្រប់យ៉ាង ភិក្ខុកំណត់រូបទាំងពួង **អាការមិនទៀង ជាសម្មសនៈ ១ កំណត់ដោយអាការជាទុក្ខ ជាសម្មសនៈ ១ កំណត់ដោយអាការជាអនត្តា ជាសម្មសនៈ ១** ត្រឹមប៉ុណ្ណេះ ភិក្ខុនេះរាប់ថា បានកំណត់រូបទាំងពួងដែលនិទ្ទេសទុក ដោយពាក្យមិនចោះចំពោះដូច្នេះថា **យង្កិញ្ចិ រូបំ-រូបគ្រប់យ៉ាង** ដោយឱកាស ១១ គឺដោយអតីតតិកៈ និងដោយទុកៈ ៤ មានអជ្ឈត្តទុកៈជាដើម ហើយកំណត់រូបទាំងពួង ដោយអាការមិនទៀង គឺសម្មសនៈ ( ពិចារណា )

ជាមិនទៀង សួរថា សម្មសនៈដូចម្តេច ? ឆ្លើយថា សម្មសនៈដោយន័យដែលពោលក្នុងវគ្គតទៅនោះឯង ព្រោះលោកពោលទុកដូច្នេះថា **រូបំ អតីតាណាគតប្បច្ចុប្បន្នំ អនិច្ចំ ខយដ្ឋេន**... រូបដែលជាអតីត អនាគត បច្ចុប្បន្ន មិនទៀង ដោយអត្ថ គឺ **អស់ទៅ** ដូច្នេះ ព្រោះហេតុនោះ ទើបភិក្ខុនោះសម្មសនៈថា រូបណាជាអតីត រូបនោះក៏អស់ទៅហើយ ក្នុងអតីតនោះឯង មិនមកដល់ភពនេះឡើយ ហេតុណា ហេតុនោះទើបឈ្មោះថា **មិនទៀង** ព្រោះអត្ថ គឺអស់ទៅ រូបណាជាអនាគត និងកើតក្នុងភពបន្ទាប់ទៅ សូម្បីរូបនោះ នឹងអស់ទៅក្នុងភពដែលកើតនោះឯង មិនទៅកាន់ភពបន្តអំពីភពនោះឡើយ ហេតុនោះ ទើបឈ្មោះថា **មិនទៀង** ព្រោះអត្ថ គឺអស់ទៅ រូបណាជាខាងក្នុង រូបនោះ ក៏អស់នៅខាងក្នុងនោះឯង មិនទៅកាន់ខាងក្រៅឡើយ ហេតុនោះ ទើបឈ្មោះថា **មិនទៀង** ព្រោះអត្ថ គឺអស់ទៅ រូបណាជាខាងក្រៅ ។បេ។ ... ជារូបគ្រោតគ្រាត... រូបល្អិត... រូបថោកទាប... រូបប្រណីត... រូបក្នុងទីឆ្ងាយ... រូបក្នុងទីជិត សូម្បីរូបនោះ ក៏អស់នៅក្នុងទីជិតនោះឯង មិនទៅកាន់ភាពជារូបក្នុងទីឆ្ងាយឡើយ ព្រោះហេតុនោះ ទើបឈ្មោះថា **មិនទៀង** សម្មសនៈទាំងពួងនេះចាត់ជាសម្មសនៈ ១ ដោយអំណាចបទថា **អនិច្ចំ ខយដ្ឋេន** ឈ្មោះថា **មិនទៀង** ព្រោះអត្ថ គឺអស់ទៅនោះ តែដោយចែកចេញទៅ ក៏ជាសម្មសនៈ ១១ យ៉ាង ( មានអតីតសម្មសនៈ ពិចារណារូបដែលជាអតីតជាដើម ) ។

ម្យ៉ាងទៀត រូបទាំងពួងនោះឯង ឈ្មោះថា **ជាទុក្ខ** ព្រោះអត្ថ គឺជាភ័យ ពាក្យថា **ព្រោះអត្ថ គឺជាភ័យ** សេចក្តីថា ព្រោះជាវត្ថុគួរតក់ស្លុត ព្រោះថា វត្ថុណាមិនទៀង វត្ថុនោះ រមែងនាំសេចក្តីតក់ស្លុតមកឲ្យ ដូចសេចក្តីខ្លាចកើតឡើង ដល់ទេវតាទាំងឡាយ ព្រោះ ( បានស្តាប់ ) សីហោបមសូត្រដូច្នោះ សូម្បីសម្មសនៈ ដូចពោលមកនេះ ក៏ចាត់ជាសម្មសនៈ ១ ដោយអំណាចបទថា **ទុក្ខំ ខយដ្ឋេន**-ឈ្មោះថា **ជាទុក្ខ** ព្រោះអត្ថ

**គឺជាភ័យ** នោះ តែដោយញែកបំបែកទៅ ក៏ជាសម្មសនៈ ១១ យ៉ាង ។ ម្យ៉ាងទៀត រូបទាំងពួងនោះ ឈ្មោះថា ជាទុក្ខ យ៉ាងណា ក៏ឈ្មោះថា ជាអនត្តា ព្រោះអត្ថ គឺមិនមានសារៈ ដូច្នោះ ពាក្យថា **ព្រោះអត្ថ គឺមិនមានសារៈ** សេចក្តីថា ព្រោះមិនមានសារៈ គឺអត្តា ដែលពួកអត្តវាទីគិតស្មានយកដូច្នេះថា **រូបមានអត្តាគ្រប់គ្រង ជាអ្នកសាង អ្នកសោយ អ្នកមានអំណាចក្នុងខ្លួន** ព្រោះរូបណាមិនទៀង រូបនោះរមែងជាទុក្ខ មិនអាចឃាត់ការមិនទៀង ឬការកើតសេចក្តីវិនាស ដែលត្រូវបៀតបៀនរបស់ខ្លួនឯងបាន ភាពជាអ្នកសាងជាដើមនៃរូបនោះ នឹងមានអំពីណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ បើរូបនេះ នឹងបានជាអត្តាហើយសោត រូបនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ** ដូច្នេះជាដើម ។ សូម្បីសម្មសនៈដូចពោលមកនេះ ក៏ជាសម្មសនៈ ១ ដោយអំណាចបទថា **អនត្តា អសារកដ្ឋេន ឈ្មោះថា ជាអនត្តា ព្រោះអត្ថ គឺមិនមានសារៈ** នោះ តែដោយញែកចេញទៅ ក៏ជាសម្មសនៈ ១១ យ៉ាង ន័យក្នុងខន្ធដ៏សេស មានវេទនាខន្ធជាដើម ក៏ន័យដូចនេះ ។

ម្យ៉ាងទៀត រូបណាមិនទៀង រូបនោះ ក៏រមែងជាប្រភេទសង្ខតៈជាដើមដោយពិត ហេតុណា ព្រោះហេតុនោះ ដើម្បីសម្តែងបរិយាយ គឺពាក្យវេវចនៈនៃអនិច្ចសព្ទនោះ ឬដើម្បីសម្តែងការប្រព្រឹត្តទៅនៃមនសិការ ដោយអាការផ្សេងៗ ទើបព្រះបាលីពោលទុកទៀតថា... **រូបទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ជារបស់មិនទៀង ជារបស់ដែលបច្ច័យតាក់តែងឡើង អាស្រ័យហេតុកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតា មានការរលត់ទៅ ជាធម្មតា** ដូច្នេះ ន័យក្នុងខន្ធដ៏សេស មានវេទនាខន្ធជាដើម ក៏ន័យដូចនេះឯង ។

# មហាដីកា

## ពណ៌នាមគ្គាមគ្គញ្ញាណទស្សន
## វិសុទ្ធិនិទ្ទេស
### កថាពណ៌នាដោយសម្មសនញ្ញាណ

ពាក្យថា ញាណជឹងធម៌ ដែលជាផ្លូវ និងធម៌ដែលមិនមែនផ្លូវយ៉ាងនេះ តាំងនៅ សេចក្ដីថា ញាណកំណត់ធម៌ ដែលជាផ្លូវ និងធម៌ដែលមិនមែនផ្លូវ តាមសេចក្ដីពិត យ៉ាងនេះថា វិបស្សនាបញ្ញាដែលប្រព្រឹត្តទៅតាមវិថី ផុតអំពីឧបក្កិលេស នេះជាផ្លូវ ចំណែកខាងដើមនៃអរិយមគ្គ ឧបក្កិលេស ១០ ប្រការ មានប្រភេទជាឱភាសជាដើមនេះ មិនមែនផ្លូវដូច្នេះ ហើយតាំងនៅ ។

ការពិចារណាដោយសង្ខេបធម៌ទាំងឡាយ ដែលផ្សេងដោយប្រភេទមិនមែន តិច ទាក់ទងជាមួយអតីតជាដើម ចូលជាកលាបៈ ឈ្មោះថា **កលាបសម្មសនៈ** ន័យថា វោហារនេះ ជាពាក្យហៅរបស់អ្នកជម្ពូទ្វីប ។ ការចម្រើនវិបស្សនាពិចារណាធម៌ ទាំងឡាយ ដោយន័យជាដើមថា **រូបឯណានីមួយ** ដូច្នេះ ឈ្មោះថា **នយវិបស្សនា** ន័យថា វោហារនេះ ជាពាក្យហៅរបស់អ្នកតម្ពបណ្ណិទ្វីប ។ ដោយហេតុនោះឯង ទើប លោកអាចារ្យពោលថា **ក្នុងនយវិបស្សនាដែលហៅថា កលាបសម្មសនៈ** ។ **តាវ** ស័ព្ទ មានអត្ថថា លំដាប់ ដោយ **តាវ**-ស័ព្ទនោះ លោកអាចារ្យរមែងសម្ដែងប្រការ នៃសម្មសនៈ មានប្រភេទដ៏ច្រើន ។ ព្រោះសម្មសនៈ ទាំងនោះមានច្រើន ចំណែក អាចារ្យ ទើបប្រៀនប្រដៅការផ្ដើមយោគៈ ក្នុងនយវិបស្សនាមុនថា **គប្បីធ្វើយោគៈ ក្នុងនយវិបស្សនាមុន** ។ ពាក្យថា **ព្រោះហេតុអ្វី** ជាពាក្យរបស់អាចារ្យអ្នកសួរ ។

ពាក្យនោះ មានអធិប្បាយដូច្នេះ ប្រសិនបើមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ដែលព្រះយោគាវចរគប្បីឲ្យដល់ព្រមសោត កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបលោកពោលថា **យោគាវចរគួរធ្វើយោគៈតាំងអំពីដើម ក្នុងនយវិបស្សនាទៅវិញ** ? អាចារ្យក្រៅអំពីនេះ កាលនឹងសម្ដែងថា សេចក្ដីនេះជាឧបាយសម្រេចមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនោះ ទើបពោលថា **សម្រាប់បុគ្គលផ្ដើមធ្វើវិបស្សនាហើយ** ដូច្នេះជាដើម ។ ដោយហេតុនោះឯង ទើបលោកអាចារ្យសម្ដែងសេចក្ដីនេះទុកថា **កាលមានការចម្រើនវិបស្សនា ឧទយព្វយញ្ញាណ ទើបកើតឡើង កាលឧទយព្វយញ្ញាណមាន ទើបមានឧបក្កិលេស មានឱភាសជាដើម តអំពីនោះ ទើបកំណត់ធម៌ដែលជាផ្លូវ និងធម៌ដែលមិនមែនផ្លូវ ព្រោះហេតុនោះ ទើបមិនមានផ្ដើមការកំណត់ធម៌ដែលជាផ្លូវ និងធម៌ដែលមិនមែនផ្លូវនោះ អំពីខាងដើមនោះឯង ព្រោះហេតុនោះ ទើបព្រះយោគាវចរត្រូវផ្ដើមការចម្រើនវិបស្សនាមុន** ។ លោកអាចារ្យពោលថា **ឯកលាបសម្មសនៈជាខាងដើមរបស់វិបស្សនា** ដូច្នេះ ដើម្បីឆ្លើយពាក្យសួរថា កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបព្រះយោគាវចរ ផ្ដើមនយវិបស្សនាប៉ុណ្ណោះមុនទៅវិញ ។ កលាបសម្មសនៈឈ្មោះថា **ជាខាងដើម** ព្រោះការពិចារណាធ្វើបានងាយ សម្រាប់យោគាវចរដែលផ្ដើមកម្មដ្ឋាន ហេតុដែលធម៌ទាំងឡាយ ដែលផ្សេងដោយប្រភេទជាអតីតជាដើម ប្រព្រឹត្តទៅបានដោយអំណាចការកំណត់សង្ខេបទុក ។

ពាក្យថា **ព្រោះហេតុនោះ** គឺព្រោះហេតុដែលកលាបសម្មសនៈជាខាងដើម ។ ម្យ៉ាងទៀត ពាក្យថា **ព្រោះហេតុនោះ** សេចក្ដីថា ព្រោះសម្រាប់បុគ្គលអ្នកផ្ដើមធ្វើវិបស្សនាហើយ ក្នុងកាលវិបស្សនូបក្កិលេស មានឱភាសជាដើមមានឡើង ទើបមគ្គាមគ្គញ្ញាណទស្សនៈមាន ពិតហើយ កាលវិបស្សនូបក្កិលេសទាំងឡាយ មានឱភាសជាដើមកើតឡើងហើយ ទើបមគ្គាមគ្គញ្ញាណមានដល់យោគាវចរ ដែលផ្ដើមធ្វើ

វិបស្សនា ក៏ព្រោះកលាបសម្មសនៈជាខាងដើមរបស់វិបស្សនា ។ បទថា **ឯតំ** យោគ **កលាបសម្មសនំ** ប្រែថា កលាបសម្មសនៈនេះ ។ ពាក្យថា **ម្យ៉ាងទៀត** ជាដើម ជាពាក្យសម្តែងឧបចយហេតុ ក្នុងកលាបសម្មសនៈតែម្យ៉ាង ជាខាងដើមរបស់វិបស្សនា ។ **តីរណបរិញ្ញា** មានឧទយព្វយញ្ញាណជាទីបំផុត កាលមិនទាន់ដល់ឧទយព្វយញ្ញាណនោះឯង ទើបមានការកំណត់ធម៌ដែលជាផ្លូវ និងធម៌ដែលមិនមែនផ្លូវ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា កាលតីរណបរិញ្ញាកំពុងប្រព្រឹត្តទៅ ។ សូម្បីក្នុងពាក្យថា **ត្រូវធ្វើយោគៈក្នុងកលាបសម្មសនៈមុន** នេះ បណ្ឌិតគប្បីជ្រាបហេតុក្នុងការផ្តើមកលាបសម្មសនៈនោះៗ ឯងមុនតាមន័យដែលពោលហើយនោះឯង ។ ព្រោះឈ្មោះថា **កលាបសម្មសនៈមិនឈោងចុះខាងក្នុង** សូម្បីក្នុងវិសុទ្ធិ ១ ហើយ អាចារ្យពួកខ្លះ ក៏មិនបានប្រារព្ធដល់កលាបសម្មសនៈនោះឡើយ ពណ៌នាការប្រព្រឹត្តទៅនៃវិបស្សនា ។ សូម្បីកាលបើយ៉ាងនេះ កលាបសម្មសនៈនោះ លោកក៏បានសម្តែងទុកដោយឯកទេស និងដោយសព្វគ្រប់ ក្នុងព្រះសូត្រទាំងឡាយ ។ ក្នុង **គម្ពីរបដិសម្ភិទា** ព្រះធម្មសេនាបតីសារីបុត្របានតាំងទុកខាងដើមនៃវិបស្សនា ព្រោះជាការធ្វើបានងាយដល់មនសិការនៃបុគ្គលអ្នកផ្តើម ធ្វើកម្មដ្ឋានទាំងឡាយ ។ កាលឧបក្កិលេសទាំងឡាយមានឱកាសជាដើម កើតដល់ព្រះយោគាវចរ ដែលកំពុងចម្រើនវិបស្សនា ក៏នឹងមានមគ្គាមគ្គញ្ញាណឡើង ព្រោះហេតុនោះ គប្បីឃើញថា ការវិភាគនេះ លោកអាចារ្យបានធ្វើហើយ ដោយពាក្យជាដើមថា **យោគាវចរដែលប្រាថ្នានឹងធ្វើមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនោះឲ្យដល់ព្រម** ។

បទថា **តត្រ** សេចក្តីប៉ុន្មាននឹង **តស្មិំ** យោគ **តីរណបរិញ្ញាយ ញាតប្បរិញ្ញានន្តរភាវេ** ប្រែថា ក្នុងតីរណបរិញ្ញា ក្នុងលំដាប់នៃញាតបរិញ្ញានោះ ឬប៉ុន្មា នឹង **តាសុ** យោគ **បរិញ្ញាសុ** ប្រែថា ក្នុងបណ្តាបរិញ្ញាទាំងនោះ ។ ពាក្យថា **វិនិច្ឆ័យ**

បានដល់ ការសន្និដ្ឋានដោយសរុប ដោយកិច្ច និងដោយភូមិ ។ បរិញ្ញា ទាំង ៣ យ៉ាង ដែលប្រកបដោយមគ្គក្នុងសច្ចៈ ២ ខាងដើម សូម្បីជាលោកុត្តរ លោកបានដោយអំណាចកិច្ច ព្រោះហេតុនោះ ទើបលោកអាចារ្យពោលឲ្យផ្សេងចេញទៅថា **លោកិយប្បរិញ្ញា** ។ បញ្ញាដែលបែរមុខចំពោះញេយ្យធម៌ ព្រោះកំណត់លក្ខណៈនៃសភាវធម៌ទាំងឡាយ ឈ្មោះថា **អភិញ្ញាបញ្ញា** ។ ពាក្យថា **ព្រោះអត្ថ** គឺដឹង គឺព្រោះមានភាវៈគឺដឹងនិមិត្ត ។ ដែលលោកហៅថា **ញាណ** ព្រោះហេតុ គឺដឹងអភិញ្ញេយ្យធម៌ ។ ពាក្យថា **បរិញ្ញាបញ្ញា** បានដល់ បញ្ញាកំណត់ដឹងលក្ខណៈ មានការមិនទៀងជាដើម ។ ពាក្យថា **ព្រោះអត្ថ គឺពិចារណា** បានដល់ ព្រោះមានភាវៈ គឺការពិចារណាជាហេតុ ។ ពាក្យថា **បហានប្បញ្ញា** បានដល់ បញ្ញាដែលលះបហាតព្វធម៌ ។ លោកពោល **រូបដែលមានការបែកធ្លាយបានជាលក្ខណៈ** ថាជាលក្ខណៈចំពោះខ្លួន ព្រោះប្លែកគ្នាអំពីលក្ខណៈមានការសោយរសអារម្មណ៍ជាដើម នៃធម៌ដែលលោកកាន់យក ដោយអំណាចការកំណត់លក្ខណៈ ចំពោះខ្លួន **នោះឯង** ។ លក្ខណៈ មានការរឹង និងការពាល់ត្រូវជាដើម នៃបឋវីធាតុ និងធម៌ គឺផស្សៈជាដើម គប្បីកំណត់បានក្នុងខណៈទាំង ៣ ជាធម្មជាតិដែលសម្រេចដោយសភាវៈនោះឯងគឺយកបានព្រោះជាធម្មជាតិដែលមានរូបពិតប្រាកដដោយចំពោះ យ៉ាងណា លក្ខណៈ មានការមិនទៀងជាដើម ដូច្នោះ មិនមាន ។ ឯលក្ខណៈ មានភាពជារបស់មិនទៀងជាដើមនោះ លោកកាន់យកដូចរូបដែលលើកឡើង ព្រោះគប្បីកាន់យកដោយមាតិកា គឺអាការ គឺបែកធ្លាយកើតឡើងវិនាសទៅ និងមិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះហេតុនោះ ទើបលោកពោលថា **លើកឡើងកាន់សាមញ្ញលក្ខណៈ** ដូច្នេះ ។ វិបស្សនាដែលមានលក្ខណៈជាអារម្មណ៍នោះឯង លោកហៅថា **បហានប្បរិញ្ញា** ព្រោះលោកមានបំណងយកលោកិយប្បរិញ្ញានោះឯង ។ ពាក្យថា **អំពីសង្ខារប្បរិច្ឆេទ គឺការកំណត់សង្ខារ** គឺអំពីការកំណត់ចែកនាមរូបបាន ដែល

លោកហៅថា **ទិដ្ឋិវិសុទ្ធិ** តែអាចារ្យពួកខ្លះពោលថា **ការពិចារណាធម៌ មានខន្ធជាដើម ទាំងអស់** ឈ្មោះថា **សង្ខារបរិច្ឆេទ** ការកំណត់សង្ខារ ព្រោះជាភូមិនៃការចម្រើនវិបស្សនាឃើញធម៌ មានខន្ធជាដើម ។ ពាក្យថា **ភាពជាធំ រមែងមានដល់ការចាក់ធ្លុះលក្ខណៈចំពោះខ្លួនប៉ុណ្ណោះ** នេះ លោកអាចារ្យ រមែងសម្តែងសមត្ថភាពនៃតីរណៈ ការពិចារណា និងបហានៈ ការលះរបស់បញ្ញា ដែលកំណត់បច្ច័យនៃនាមរូប ។ សូម្បីបញ្ញាដែលកំណត់បច្ច័យនៃនាមរូបទាំងនោះ និងប្តូរជាតីរណៈ គឺពិចារណាដោយអាការឯណានីមួយនៃការប្រព្រឹត្តទៅ ដោយអំណាចការកំណត់អាការទូទៅនៃអរូប និងរូបថា **នាមមានការបង្អោនទៅជាលក្ខណៈ រូបមានការបែកធ្លាយទៅជាលក្ខណៈ** ដូច្នេះក៏បាន និងផ្លាស់បហានៈ គឺការលះ និងដោយការរម្ងាប់ទិដ្ឋិ និងសេចក្តីសង្ស័យក៏បាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ភាពជាធំ គប្បីមានសូម្បីក្នុងតីរណៈ និងបហានៈ ។ តែដោយនិទ្ទេសយ៉ាងខ្ពស់ ទិដ្ឋិវិសុទ្ធិប៉ុណ្ណោះជាសង្ខារបរិច្ឆេទ ការកំណត់សង្ខារឯណា គប្បីជ្រាបវិបស្សនាដែលមានលក្ខណៈជាអារម្មណ៍ប៉ុណ្ណោះ មានតីរណៈ គឺការពិចារណា និងបហានៈ គឺការលះជាកិច្ច ដូច្នោះ ។ ឯបរិញ្ញាទាំង ៣ រមែងបែកគ្នាដោយប្រការ ដូច្នេះ កាលកាន់យកសេចក្តីដោយប្រការដទៃ ក៏គប្បីលាយឡំគ្នា ។ ឈ្មោះថា **ភូមិរបស់តីរណបរិញ្ញានោះ** ព្រោះក្នុងតីរណបរិញ្ញានោះ បញ្ញាពិចារណាលក្ខណៈ មានជារបស់មិនទៀងជាដើម ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះថា **ក្នុងចន្លោះនេះ ភាពជាធំរមែងមានដល់ការចាក់ធ្លុះសាមញ្ញលក្ខណៈប៉ុណ្ណោះ** ។ សូម្បីឧទយព្វយញ្ញាណ រមែងលះការប្រកាន់ខុសយ៉ាងមាំខ្លះ យ៉ាងណាក៏ពិត សូម្បីយ៉ាងនោះ ព្រោះឧទយព្វយញ្ញាណនោះ មិនទាន់មានកម្លាំង ទើបមិនមែនជាការលះបានដ៏កំពូល ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ភូមិរបស់បហានបរិញ្ញា ផ្តើមអំពីភង្គានុបស្សនាខ្ពស់ឡើងទៅ** ។ពាក្យថា **ឃើញតាមដោយភាពជារបស់**

**មិនទៀង** សេចក្ដីថា **ឃើញតាម** គឺពិចារណាឃើញសង្ខារ ដោយអាការមិនទៀង ។ ពាក្យថា **និច្ចសញ្ញា** បានដល់ ការសម្គាល់ខុស ដែលប្រព្រឹត្តទៅថា **សង្ខារទាំងនោះទៀង ស្ថិតស្ថេរ** ដូច្នេះ បណ្ឌិតគប្បីឃើញការកាន់យកទិដ្ឋិ និងចិត្តដល់សត្វដែលជាប្រធាន គឺសញ្ញា ។ សូម្បីក្នុងបទដទៃក្រៅអំពីនេះ ក៏មានន័យនេះឯង ។ ពាក្យថា **និព្វិទា** គឺឃើញដោយអំណាចការនឿយណាយក្នុងសង្ខារទាំងឡាយ ដោយនិព្វិទានុ-បស្សនា ដែលកើតអំពីអនិច្ចានុបស្សនាជាខាងដើម ។ ពាក្យថា **នន្ទិ** បានដល់ តណ្ហាមានបីតិ ពាក្យថា **ប្រាសចាកតម្រេក** សេចក្ដីថា តាមឃើញដោយប្រការ ដែលតម្រេកក្នុងសង្ខារទាំងឡាយមិនកើតឡើង ដោយអំណាចការប្រាសចាកតម្រេក ដោយវិរាគានុបស្សនា ។ ពិតហើយ បុគ្គលយ៉ាងនោះ លោកហៅថា **រមែងលះរាគៈបាន** ។ ពាក្យថា **រលត់** សេចក្ដីថា តាមឃើញដោយប្រការដែលសង្ខារទាំងឡាយ រមែងរលត់ទៅ តែម្យ៉ាង មិនកើតឡើងដោយអំណាចភពថ្មីតទៅ ដោយនិរោធានុបស្សនា ។ ពិតហើយ បុគ្គលយ៉ាងនោះ ឈ្មោះថា រមែងលះសមុទយៈនៃសង្ខារទាំងឡាយ ព្រោះឲ្យដល់នូវការមិនកើតឡើងជាធម្មតា ។ ពាក្យថា **លះបង់** សេចក្ដីថា លះបង់ដោយប្រការ ដែលមិនប្រកាន់សង្ខារតទៅ ដោយបដិនិស្សគ្គានុបស្សនា ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងលះសេចក្ដីប្រកាន់បាន** អធិប្បាយថា ម្យ៉ាងទៀត រមែងលះបង់ការប្រកាន់ដោយអំណាចថាជារបស់ទៀងជាដើម ។ ពាក្យថា **ព្រោះធ្វើឲ្យសម្រេចហើយ** គឺព្រោះធ្វើឲ្យដល់ព្រមហើយ ។ ពាក្យថា **បរិញ្ញាក្រៅអំពីនេះ** បានដល់ តីរណបរិញ្ញា និងបហានបរិញ្ញា ។ លោកអាចារ្យ កាលអធិប្បាយបរិញ្ញាយ៉ាងនេះហើយ កាលត្រឡប់មកនាំយកអត្ថ ដែលលោកបានពោលដូច្នេះថា **គប្បីធ្វើយោគៈក្នុងកលាបសម្មសនៈ** ដូច្នេះ ក្នុងលំដាប់នៃការឆ្លងសេចក្ដីសង្ស័យ ដោយអំណាចលំដាប់នៃបរិញ្ញានោះ មកពោលដោយអំណាចជាពាក្យបញ្ជាក់ ទើបពោលពាក្យថា

ដើមថា ដោយហេតុនោះ ទើបខ្ញុំពោលទុក ពាក្យនោះ មានអត្ថដែលបានពោលហើយនោះឯង ។

បទថា តត្រ សេចក្តីប៉ុនគ្នានឹង តស្មឹ យោគ កលាបសម្មសនេ វិភាវេតព្វ ប្រែថា ក្នុងកលាបសម្មសនៈនោះ ដែលគួរធ្វើឲ្យជាក់ច្បាស់ ម្យ៉ាងទៀត យោគ តស្ស កលាបសម្មស្សនស្ស អាទិភាវេ ប្រែថា ក្នុងកលាបសម្មសនៈជាខាងដើមនោះ ។ លោកអាចារ្យពោលព្រះបាលីបដិសម្ភិទាមគ្គញ្ញាណ ដែលលោកកំពុងសម្តែងថា នេះជាព្រះបាលី ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា បញ្ញាក្នុងការកំណត់សង្ខេប បានដល់ បញ្ញាដែលឲ្យសម្រេចការកាត់ផ្តាច់នោះក្នុងកាល គប្បីញ៉ាំងការកាត់សម្រេចឲ្យសម្រេចដោយអំណាចជារបស់មិនទៀងជាដើម ដោយរួមយកធម៌ដែលផ្សេងគ្នាដោយប្រភេទ ជាអតីតជាដើមចូលជាមួយគ្នា ។ ដែលលោកហៅថា ញាណក្នុងការពិចារណា ដោយអំណាចជារបស់មិនទៀងជាដើម ក្នុងសម្មសនៈ អធិប្បាយថា បញ្ញានោះដូចម្តេច ។ បទថា វវដ្ឋានេ និងបទថា សម្មសនេ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថដែលគប្បីឲ្យសម្រេច ។ បទទាំងឡាយថា រូបឯណាមួយ ជាដើម មានអត្ថដែលបានពោលទុកហើយខាងដើមនោះឯង ។ចំណែកបទទាំងឡាយ មានពាក្យថា រមែងកំណត់រូបទាំងអស់ ដោយជារបស់មិនទៀង ជាដើម ព្រោះលោកទាំងឡាយនឹងពណ៌នាតទៅដូច្នោះ អត្ថរបស់បទទាំងនោះ ខ្ញុំនឹងធ្វើឲ្យជាក់ច្បាស់ក្នុងទីនោះ នុ៎ះឯង ។

ឯការកំណត់ព្រះបាលី បណ្ឌិតគប្បីជ្រាបយ៉ាងនេះ ក្នុងអធិការនេះ ព្រះសាស្តាទ្រង់កាន់យកខន្ធ ៥ ដោយមាតិកា គឺការចែកជាអតីតជាដើម ជាដំបូងមុន ដោយពាក្យថារូបឯណានីមួយជាដើមដើម្បីងាយស្រួលដល់ការផ្តើមនសិការក្នុងការចម្រើនវិបស្សនារបស់បុគ្គលដែលផ្តើមកម្មដ្ឋានទាំងឡាយ និងខន្ធទាំងនោះ ព្រោះលោកបានចែកទាក់ទងដោយធម៌ ដែលប្រព្រឹត្តទៅក្នុងទ្វារ ព្រមជាមួយទ្វារ និងអារម្មណ៍ ដូច្នោះ

ទើបទ្រង់កាន់យកចក្កុះ ១០ ប្រការ ទាក់ទងនឹងទ្វារចក្កុះជាដើម ទុកក្នុងលំដាប់នៃខន្ធ ៥ នោះ ។ ម្យ៉ាងទៀត ព្រោះក្នុងបណ្ដាលក្ខណៈទាំងឡាយ អនត្តលក្ខណៈ ចែកទុកដោយទុក្ខ ដូច្នោះ ទើបទ្រង់កាន់យកធាតុ ៦ ដើម្បីញ៉ាំងអនត្តលក្ខណៈឲ្យជាក់ច្បាស់ ។ បន្ទាប់អំពីនោះ ទ្រង់កាន់យកកសិណ ១០ ដើម្បីសម្ដែងថា ការប្រកាន់អត្តារបស់លទ្ធិខាងក្រៅព្រះពុទ្ធសាសនានេះ រមែងមាន ព្រោះកសិណណា កសិណនោះ ត្រឹមតែជាអាការប្រាកដ ដោយជាអារម្មណ៍របស់ឈានទាំងនេះ ។ បន្ទាប់អំពីនោះ ទ្រង់កាន់យកកោដ្ឋាស ៣២ ដោយអាការជាបដិកូល ដោយជាបរិវាររបស់ទុក្ខានុបស្សនា ។ ទ្រង់កាន់យកអាយតនៈ ១២ និងធាតុ ១៨ ដើម្បីសម្ដែងថា ធម៌ដែលទ្រង់កាន់យកដោយសង្ខេប ដោយអំណាចខន្ធ ក្នុងកាលមុន គួរធ្វើមនសិការដោយន័យមិនសង្ខេប និងពិស្ដារពេក និងន័យដែលពិស្ដារ ។ ក្នុងបណ្ដាធម៌ទាំងនោះ ទ្រង់កាន់យកឥន្ទ្រិយទាំងឡាយ ដើម្បីញ៉ាំងអនត្តលក្ខណៈឲ្យជាក់ច្បាស់ថា ធម៌ទាំងនេះ សូម្បីមានភាពជាធម៌ទេ មិនមានការខ្នះខ្នែង និងមិនមានសេចក្ដីព្យាយាម ក៏រមែងប្រព្រឹត្តទៅដោយអំណាចភាពជាធំ ដោយសភាវៈនៃធម៌ ។ ទ្រង់កាន់យកធាតុ ៣ ទុក ដើម្បីសម្ដែងថា ធម៌ទាំងនេះ សូម្បីផ្សេងគ្នាដោយប្រភេទដ៏ច្រើន យ៉ាងនេះ ក៏មាន ៣ យ៉ាងប៉ុណ្ណោះ ព្រោះជា ធម៌ទាក់ទងក្នុងភូមិ ៣ ។

កាលទ្រង់សម្ដែងនិមិត្ត ដោយពាក្យត្រឹមប៉ុណ្ណោះហើយ ទ្រង់ព្រះបំណងសម្ដែងបវត្តៈតទៅ ទើបទ្រង់កាន់យកភព ៩ មានកាមភពជាដើម ។ ទ្រង់កាន់យកឈាន និងអប្បមញ្ញា ដើម្បីសម្ដែងថា គួរឲ្យមនសិការប្រព្រឹត្តទៅក្នុងមហគ្គតធម៌ ដែលឲ្យកើតឡើងហើយ ដែលល្អិតសុខុម ដោយជាបុគ្គលឈ្លាសក្នុងមនសិការ ដែលប្រព្រឹត្តទៅក្នុងភាពផ្សេងនៃអភិញ្ញេយ្យធម៌ត្រឹមប៉ុណ្ណោះ ។ ក្នុងបណ្ដាឈាន និងអប្បមញ្ញាទាំងនោះ ដែលឈ្មោះថា **ឈាន** បានដល់ រូបាវចរជ្ឈានដែលមានអារម្មណ៍សល់អំពី

ដែលពោលហើយ ។ ទ្រង់កាន់យកអង្គនៃបដិច្ចសមុប្បាទ ដើម្បីសម្តែងថា គប្បីចែកមនសិការធម៌ទាំងនេះដោយចែកជាបច្ចយធម៌និងបច្ចយុប្បន្នធម៌ ។ ឯការធ្វើមនសិការបច្ចយាការរមែងញ៉ាំងលក្ខណៈឲ្យជាក់ច្បាស់ដោយងាយ និងល្អក្រៃលែង ព្រោះហេតុនោះ ទើបទ្រង់កាន់យកទុកខាងក្រោយ ។ ធម៌ទាំងនេះ ទ្រង់កាន់យកដោយភាពជាធម៌ដែលគប្បីពិចារណាយ៉ាងនេះ មាន ២៥ យ៉ាង ដោយកោដ្ឋាស ដោយអំណាចខន្ធជាដើម ។ បើពោលដោយប្រភេទ កាលកាន់យកមិនប្រាវព្ធដល់ប្រភេទ មានអតីតជាដើមក៏មាន ២០០ ខ្វះ ២ ប្រភេទ ។ ក្នុងបណ្តាពាក្យទាំងនោះ វារៈនៃការកំណត់លក្ខណៈដំបូង មានពាក្យថា **កំណត់ជារបស់មិនទៀងជាដើម** ។ វារៈនៃហេតុប្រការទី ២ មានពាក្យថា **មិនទៀង ព្រោះអត្ថ គឺអស់ទៅ** ដូច្នេះជាដើម ព្រោះប្រាវព្ធហេតុនៃលក្ខណៈទាំងឡាយ ។ ចំណែកវារៈនៃការញ៉ាំងហេតុឲ្យតាំងចុះ មានពាក្យថា **ជារបស់ដែលបច្ច័យប្រជុំតាក់តែងឡើង** ដូច្នេះជាដើម ព្រោះការកំណត់ភាពជាក់ច្បាស់ ។ ឯពាក្យថា **ព្រោះអត្ថ គឺអស់ទៅ** បានដល់ ព្រោះសភាវៈ គឺការអស់ទៅ អធិប្បាយថា ព្រោះរូបមានការអស់ទៅជាសភាវៈ កើតឡើងហើយ រមែងដល់នូវការអស់ទៅ សូន្យទៅ បែកទៅ ដូច្នោះ ទើបឈ្មោះថា **មិនទៀង** ។ ពាក្យថា **ព្រោះអត្ថ គឺជាភ័យ** បានដល់ ព្រោះភាវៈ គឺជារបស់ដែលគប្បីខ្លាច ។ អធិប្បាយថា ព្រោះរូបជារបស់ដែលនាំមកនូវភ័យ ព្រោះជាធម្មជាតិមានការពុកផុយទៅ ដូច្នោះ ទើបឈ្មោះថា **ជាទុក្ខ** ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ** ។ ពាក្យថា **ព្រោះអត្ថ គឺមិនមានសារៈ** ព្រោះភាវៈដែលមិនមានសារៈ អធិប្បាយថា ព្រោះវៀរចាកសារៈ គឺខ្លួន ។ តែក្នុងវារៈទី ៣ ព្រះអង្គត្រាស់ថា **រូបមិនទៀង** ដូច្នេះហើយ ទ្រង់ព្រះបំណងបញ្ជាក់ហេតុរបស់រូបនោះ ទើបត្រាស់ថា **ជារបស់ដែលបច្ច័យតាក់តែងឡើង** ដូច្នេះជាដើម ។ ព្រោះរូបនោះ ត្រូវបច្ច័យទាំងឡាយប្រជុំគ្នា គឺរួមគ្នាតាក់តែង

ឡើងនិងអាស្រ័យបច្ច័យដែលសមគួរតាក់តែងឡើងមិនមែនវៀរចាកបច្ច័យទាំងនោះ ក៏កើតឡើងជានិច្ច និងដោយប្រពៃឡើយ ដូច្នោះ ទើបឈ្មោះថា **មានការអស់ទៅ ការវិនាសទៅ ការបែកធ្លាយទៅ និងការរលត់ទៅជាធម្មតា** ដូច្នេះ ។ ព្រោះរូបកើតឡើងអំពីបច្ច័យ ឈ្មោះថា **មិនរលត់** មានក៏ទេ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វត្ថុណាកើតហើយ ឧប្បត្តិហើយ** ជារបស់ដែលបច្ច័យតាក់តែងឡើង មានការបែកធ្លាយទៅជាធម្មតា ប្រការដែលថា **រូបនោះ កុំបែកធ្លាយឡើយ នេះមិនមែនជាឋានៈ ដែលនឹងមានបាន** ។ ដោយពាក្យនេះ លោកអាចារ្យរមែងសម្តែងបថវីធាតុ ឈ្មោះថា **មិនទៀង** ព្រោះកើតឡើងអំពីបច្ច័យ របស់ដទៃក្រៅអំពីបថវីធាតុនោះ ក៏ដូចជាកើតឡើងអំពីបច្ច័យ ។ សូម្បីក្នុងធម៌ដ៏សេស ក៏មានន័យនេះដូចគ្នា ឥឡូវនេះ លោកអាចារ្យបញ្ជាក់សេចក្តីដែលសន្និដ្ឋធម៌ ជារបស់មិនទៀង ដោយការស្របតាម និងដោយប្រការពិសេស ទើបពោលពាក្យថា **ព្រោះជាតិជាបច្ច័យ** ដូច្នេះ ជាដើម ។ ឯការបញ្ជាក់អនិច្ចលក្ខណៈតែម្យ៉ាង ក្នុងទីនេះ ព្រោះកាលបញ្ជាក់អនិច្ចលក្ខណៈនោះហើយ សូម្បីលក្ខណៈ ២ ដ៏សេស ក៏សម្រេចការបញ្ជាក់ផងដែរ ។ ក្ឋាប់សេចក្តីបាលីថា **ឥមិនា បេយ្យាលេន ឥមេ ធម្មាសយោ សន្និដ្ឋា** ប្រែថា គំនរធម៌ទាំងឡាយ ដែលលោកសង្ខេបទុកដោយបេយ្យាលនេះ ។ ពាក្យថា **ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងទ្វារ ព្រមទាំងទ្វារ និងអារម្មណ៍ ១ ខន្ធប្រាំ ១** នេះ លោកអាចារ្យបានពោលទុក ព្រោះជាពាក្យមកហើយថា រូបជាវត្ថុគប្បីដឹងក្រៃលែង ។បេ។ វិញ្ញាណជាវត្ថុគប្បីដឹងក្រៃលែង ដូច្នេះ ដើម្បីសម្តែងធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងទ្វារព្រមទាំងតួទ្វារ និងអារម្មណ៍ ដោយពាក្យថា **ម្នាលភិក្ខុទាំងឡាយ ចក្ខុជាវត្ថុគួរដឹងក្រៃលែង** ជាដើម ទុកក្នុងអភិញ្ញេយ្យនិទ្ទេស ហើយសម្តែងធម៌ទាំងនោះ សង្គ្រោះចូលដោយខន្ធ ៥ ។ **តែក្នុងគម្ពីរបដិសម្ភិទា** ព្រះធម្មសេនាបតីសារីបុត្របានសម្តែងខន្ធ ៥

មុន ដោយពាក្យថា **រូបឯណានីមួយ** ជាដើម ហើយទើបសម្តែងធម៌ដែលប្រព្រឹត្តទៅក្នុងទ្វារ ព្រមទាំងទ្វារ និងអារម្មណ៍ ដោយពាក្យថា **ចក្ខុ** ជាដើម ។ ក្នុងការសម្តែងយ៉ាងនោះ ខ្ញុំបានពោលទុកហើយ ខាងដើមនោះឯង ។

លោកអាចារ្យកាលសម្តែងថា សួរថា ក្នុងអធិការនេះ ព្រោះហេតុអ្វី ទើបលោកសង្ខេបក្រុមធម៌ទាំងនេះទុក ? ឆ្លើយថា ព្រោះមកហើយដោយពិស្តារ ក្នុងព្រះបាលី ទើបពោលពាក្យថា **សមដូចពាក្យព្រះធម្មសេនាបតីសារីបុត្រពោលទុក ដូច្នេះ** ជាដើម ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលថា **វត្ថុទាំងឡាយ ដែលគប្បីដឹងក្រៃលែងនោះ លោកបានសង្ខេបទុក ដោយបេយ្យាលទាំងពួង ក្នុងបាលីសម្មសនញ្ញាណនេះ ព្រោះធម្មសេនាបតីសារីបុត្រ ពោលទុកដោយពិស្តារ ក្នុងអភិញ្ញេយ្យនិទ្ទេសនោះ** ។ ក្នុងបណ្តាពាក្យទាំងនោះ បទថា **តំ យោគ អភិញ្ញេយ្យំ** ប្រែថា វត្ថុដែលគប្បីដឹងក្រៃលែងនោះ ។ បទថា **ឯត្ថ យោគ អភិញ្ញេយ្យនិទ្ទេសេ** ប្រែថា ក្នុងអភិញ្ញេយ្យនិទ្ទេសនេះ ។ លោកុត្តរធម៌ពួកណា មកហើយក្នុងកោដ្ឋាសនោះៗ ដោយពាក្យថា **វិញ្ញាណំ មនោ ធម្មា** ធម៌ទាំងឡាយជាដើម ។ អាចារ្យពួកខ្លះពោលថា **បទថា ឯត្ថ យោគ បដិសម្ភិទាយំ** ប្រែថា ក្នុងគម្ពីរបដិសម្ភិទានេះ ពាក្យនោះមិនល្អ ។ ព្រោះធម៌ទាំងឡាយ ដែលចូលកេណ្ឌសម្មសនៈប៉ុណ្ណោះ លោកកាន់យកក្នុងគម្ពីរបដិសម្ភិទា ព្រោះលោកមានបំណងយកភារៈនៃសម្មសនៈ មិនមែនកាន់យកធម៌ដែលគប្បីដឹងក្រៃលែងទាំងអស់ ដូចក្នុងអភិញ្ញេយ្យនិទ្ទេសទេ ។ **យេ យោគ រូបារូបធម្មា** ប្រែថា រូបធម៌ និងអរូបធម៌ពួកណា ។ **យស្ស យោគ យោគិនោ** ប្រែថា ដល់យោគីណា ។ ឈ្មោះថា **យោគីនោះ គប្បីផ្តើមសម្មសនៈ ក្នុងរូបធម៌ និងអរូបធម៌ទាំងនោះ** ព្រោះធ្វើពាក្យអធិប្បាយថា ជាការប្រាថ្នាវិបស្សនាតាមដែលជាក់ច្បាស់ ។ តែខាងក្រោយ សូម្បីកាលមិនប្រាកដ ក៏គប្បីធ្វើឲ្យប្រាកដដោយឧបាយសម្មសនៈ

ដោយមិនមានចំណែកសេសសល់នោះឯង ។

ការបែកជាអតីតជាដើម នៃការពិចារណាដោយរបស់មិនទៀង ដោយពាក្យថា **រូបអតីតមិនទៀង រូបអនាគតក៏មិនទៀង** ជាដើម ជាឋានៈ ជាទីតាំងនៃការប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយអាការ ១១** ។ ការសម្រេចកិច្ច ឈ្មោះថា **ការកំណត់** ។ ឯការកំណត់ ដោយរបស់មិនទៀង ក្នុងទីនេះ ជាការឃើញច្បាស់ថា **មិនទៀង** នោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងពិចារណាថា មិនទៀង** ដូច្នេះ ។

លោកអាចារ្យសួរអាការ គឺសម្មសនៈថា **សម្មសនៈដូចម្តេច** ព្រោះហេតុនោះ ទើបលោកវិសជ្ជនាសម្មសនៈនោះ ដោយសង្ខេបថា ដោយន័យដែលពោលទុកក្នុងវគ្គតទៅ គឺក្នុងវារៈទី ២ នៃព្រះបាលីក្នុងទីនោះឯង ។ ឥឡូវនេះ លោកអាចារ្យមានបំណងធ្វើអត្ថនោះឲ្យជាក់ច្បាស់ក្រៃលែងឡើង ទើបពោលពាក្យជាដើមថា **វុត្តញ្ហេតំ** ព្រោះលោកពោលពាក្យនេះទុក ។ ក្នុងពាក្យនោះ ស័ព្ទថា **ហិ** ជានិបាត ចុះក្នុងអត្ថនៃហេតុ ។ប្រកបសេចក្តីថា **រូបអតីត អនាគត និងបច្ចុប្បន្ន មិនទៀង ដោយអត្ថ គឺអស់ទៅ** ហេតុនោះ ទើបភិក្ខុពិចារណាថាមិនទៀង តាមន័យដែលពោលហើយនេះ។

សូម្បីយ៉ាងនេះ ក៏នៅសង្ខេបនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យមានបំណងសម្តែងបែក ទើបពោលពាក្យជាដើមថា **ភិក្ខុនេះ** ។ ពាក្យថា **ក្នុងអតីត** គឺក្នុងអតីតភព ។ ឯសេចក្តីនេះ ជាបែបការពិចារណានៃយោគី ដែលផ្តើមកម្មដ្ឋាន ព្រោះហេតុនោះ ទើបលោកមានបំណងយកការបែកអទ្ធា ទាក់ទងនឹងភព ។ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **នយិមំ ភវំ សម្បត្តន្តិ** ប្រែថា មិនមកដល់ភពនេះ ។ **ឥតិ** ស័ព្ទ ក្នុងពាក្យនេះ មានអត្ថថា **ហេតុ** ។ សេចក្តីនេះ មានអធិប្បាយថា រូបណាទាក់ទងក្នុងអតីតភព រូបនោះ ក៏អស់ទៅក្នុងអតីតភពនោះឯង មិនមកដល់ភពនេះ

អំពីអតីតកពនោះឡើយ ព្រោះហេតុនោះ ទើបសម្ផសនៈថា មិនទៀង ដោយអត្ថ គឺអស់ទៅ ព្រោះមានការអស់ទៅជាសភាវៈ ដូច្នេះ ។ សូម្បីក្នុងពាក្យថា **យំ អនាគតំ** ជាដើម ក៏មានន័យនេះ ។

គប្បីប្រកបពាក្យដោយន័យជាដើមថា **រូបណាជាខាងក្រៅ រូបនោះក៏អស់ទៅខាងក្រៅនោះឯង មិនដល់នូវភាពជាខាងក្នុងឡើយ** ហេតុនោះ ទើបមិនទៀង ដោយអត្ថ គឺអស់ទៅ រូបណា ជារូបគ្រោតគ្រាត រូបនោះ ក៏អស់ទៅក្នុងទីនោះៗ ឯង ព្រោះហេតុនោះ ទើបមិនទៀង ដោយអត្ថ គឺអស់ទៅ ។

ពាក្យថា **សម្ផសនៈទាំងពួងនេះ** សេចក្តីថា សម្ផសនៈទាំងពួង គឺទាំង ១១ យ៉ាងនេះ ព្រោះពិចារណារូបដែលចែកជាអតីតជាដើម ចាត់ជាសម្ផសនៈ ១ ព្រោះធ្វើពាក្យអធិប្បាយថា ជាការពិចារណាដោយរបស់មិនទៀង ។

បទថា **តំ** សេចក្តីថា រូបទាំង ១១ យ៉ាងនោះ ។ ពាក្យថា **ព្រោះជាវត្ថុដែលមានភ័យចំពោះមុខ** គឺព្រោះជាវត្ថុនាំមកនូវការភ័យខ្លាច ។ ពាក្យថា **រមែងនាំភាពខ្លាចមកឲ្យ** សេចក្តីថា ព្រោះមិនទាន់លះវិបល្លាសបាន ទើបរូបជាវត្ថុឲ្យកើតការខ្លាចដល់បុគ្គលដែលគិតថា **យើងនឹងវិនាស វត្ថុរបស់យើងនឹងវិនាស** ។ ពាក្យថា **ដូចការតក់ស្លុត កើតដល់ទេវតាទាំងឡាយ ក្នុងសីហោបមសូត្រ** សេចក្តីថា ដូចការតក់ស្លុតកើតដល់ទេវតា ក្នុងកាលព្រះមានព្រះភាគ ទ្រង់សម្តែងសីហោបមសូត្រ ។ ពិតហើយ ក្នុងសីហោបមសូត្រនោះ ការតក់ស្លុតកើតឡើងដល់ទេវតាទាំងឡាយមកហើយយ៉ាងនេះថា

កាលព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។បេ។ទ្រង់ឧប្បត្តិឡើងក្នុងលោក ព្រះអង្គសម្តែងធម៌ថា **រូបដូច្នេះ ហេតុកើតនៃរូបដូច្នេះ ការរលត់នៃរូបដូច្នេះ វេទនាដូច្នេះ សញ្ញាដូច្នេះ សង្ខារដូច្នេះ វិញ្ញាណដូច្នេះ ហេតុកើតនៃវិញ្ញាណដូច្នេះ ការរលត់នៃវិញ្ញាណ**

ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយ ដែលមានអាយុវែង មានពណ៌សម្បុរល្អ ច្រើនដោយសេចក្ដីសុខ ជាអ្នកតាំងនៅបានយូរក្នុងវិមានដ៏ខ្ពស់ បានស្ដាប់ព្រះធម៌ទេសនារបស់តថាគតហើយ ដោយច្រើន ក៏ដល់នូវការតក់ស្លុត ការសង្វេគ និងការរន្ធត់ថា អ្នកដ៏ចម្រើនទាំងឡាយ បានឮថា ពួកយើង ជាអ្នកមិនទៀង តែយល់ថា ទៀង យើងទាំងឡាយ ជាអ្នកមិនស្ថិតស្ថេរឡើយ តែបានយល់ថា ស្ថិតស្ថេរ ។បេ។ លោកដ៏ចម្រើនទាំងឡាយ បានឮថា យើងទាំងឡាយ មិនទៀងទាត់ តែបានយល់ថា ទៀងទាត់ លោកដ៏ចម្រើនទាំងឡាយ បានឮថា ពួកយើងទាំងឡាយ ក៏ជាអ្នកមិនទៀង មិនស្ថិតស្ថេរ មិនពិតប្រាកដ ទាក់ទងហើយក្នុងកាយខ្លួន ដូច្នេះ។

ខន្ធ ៥ ឬចំណែក ១ របស់ខន្ធ ៥ នោះ ពួកអត្តវាទីគិតដោយកថា ជាអត្តា ឯខន្ធ ៥ នោះ មិនទៀង និងជាទុក្ខ ដោយចំណែកមួយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះវត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ដូច្នេះជាដើម ។ សេចក្ដីទុក្ខប្រចាំសង្ខារ ផ្សព្វផ្សាយទៅក្នុងទុក្ខទាំង ៣ យ៉ាង លោកមានបំណងយកថា វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ដូច្នេះ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា មិនអាចហាមឃាត់ការមិនទៀង ឬការកើត ការវិនាស និងការបៀតបៀន បានឡើយ ។ ពាក្យថា បើរូបនេះជាអត្តាសោត អធិប្បាយថា បើបានជាអត្តាយ៉ាងនេះ គឺ ជាអ្នកសាង អ្នកសោយ អ្នកមានអំណាចក្នុងខ្លួន ។ បើយ៉ាងនេះ ការប្រព្រឹត្តទៅដើម្បីអាពាធរបស់រូប ក៏គប្បីជារឿងមិនគួរ ។ សម្មសនៈ ៣ យ៉ាងដោយមិនបែកគ្នា ក្នុងរូបក្ខន្ធចាត់ជា ៣៣ យ៉ាង ដោយបែកគ្នា យ៉ាងណា សូម្បីក្នុងខន្ធដ៏សេស មានវេទនាជាដើមក៏ដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្ដែងតទៅដល់អត្ថនេះថា មានន័យនេះ ។ ព្រោះហេតុនោះ ទើបលោកសម្ដែងវារៈនៃសម្មសនៈបាន ១៦៥ វារៈ ដោយបំបែកគ្នា ដោយអំណាចខន្ធមុន ។ បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានៃសម្មសនៈ

តាមគួរ ក្នុងទ្វារចក្ខុះជាដើម តាមន័យនេះ ។

ពាក្យថា **រូបនោះក៏ជាប្រភេទសន្ធតៈជាដើម ដោយពិតប្រាកដ** សេចក្តីថា រូបនោះក៏មានការផ្សេងគ្នាជាសន្ធតៈជាដើម ដោយចំណែកមួយ ព្រោះក្នុងសភាវៈនៃអសន្ធតៈជាដើម ក៏មិនមានភាពជារបស់មិនទៀង ។ បទថា **អស្ស យោគ និច្ចស្ស** ប្រែថា នៃ **អនិច្ច-ស័ព្ទនោះ** ។ ពាក្យថា **ដើម្បីសម្តែងបរិយាយ** គឺដើម្បីសម្តែងវេវចនៈ ។ ឯការសម្តែងវេវចនៈនោះ គប្បីជ្រាបដោយអំណាចនៃពាក្យថា **ខយធម្មំ** មានការអស់ទៅជាធម្មតាជាដើម មិនមែនដោយអំណាចនៃពាក្យទាំង ៣ ខាងដើមឡើយ ។ ឯពាក្យទាំង ៣ នោះឯង មិនជាពាក្យបរិយាយនៃអនិច្ចស័ព្ទនោះទេ ព្រោះមិនមែនជាសន្ធតបទ ឯបដិច្ចសមុប្បន្នបទ សម្តែងការមិនមាន ព្រោះសម្តែងភាពជាផល ។ ឯបទទាំងឡាយ រមែងតាំងនៅក្នុងចំណែកដែលឲ្យសម្រេចភាពជារបស់មិនទៀង ដោយការសម្តែងភាពជាផល ។ ដោយហេតុនោះឯង ទើបលោកកាន់យកវិកប្បដទៃថា **ដោយអាការផ្សេងៗ** ព្រោះភាវៈ គឺបទទាំងពួង ជាពាក្យបរិយាយ ។ ពាក្យថា **ដើម្បីសម្តែងការប្រព្រឹត្តទៅនៃមនសិការ** សេចក្តីថា ដើម្បីសម្តែងការប្រព្រឹត្តទៅនៃមនសិការ គឺការធ្វើឲ្យចម្រើន ក្នុងភាពជារបស់មិនទៀង ។

# វិសុទ្ធិមគ្គ

## របៀបធ្វើសម្មសនៈ (ត)

ដើម្បីប្រយោជន៍ដល់ការមាំមួននៃ **អនិច្ចសម្មសនៈ ទុក្ខសម្មសនៈ និងអនត្តា-សម្មសនៈ** ក្នុងបញ្ចក្ខន្ធនោះឯង ព្រះយោគាវចរភិក្ខុនោះ រមែងពិចារណា បញ្ចក្ខន្ធបែប **អនិច្ចាទិសម្មសនៈ** ដែលព្រះមានព្រះភាគ ទ្រង់ចែកអនុលោមញ្ញាណត្រាស់ដោយចែកទុកក្នុងវិភង្គនៃបាឋៈថា **ភិក្ខុរមែងបានខន្តិ** ដែលជាអនុលោមដោយអាការ ៤០ ដូចម្តេចខ្លះ **រមែងឈោងចុះកាន់សម្មត្តនិយាម** ដោយអាការ ៤០ ដូចម្តេចខ្លះ នោះដោយន័យថា ភិក្ខុឃើញបញ្ចក្ខន្ធដោយអាការមិនទៀង រមែងបានខន្តិដែលជាអនុលោម ឃើញថា **ការរលត់នៃបញ្ចក្ខន្ធជាការទៀង ជានិព្វាន** រមែងឈោងចុះកាន់សម្មត្តនិយាម ដោយអាការ ៤០ គឺ

**អនិច្ចតោ** ដោយអាការមិនទៀង, **ទុក្ខតោ** ដោយអាការជាទុក្ខ, **រោគតោ** ដោយអាការជារោគ, **គណ្ឌតោ** ដោយអាការជាបូស, **សល្លតោ** ដោយអាការជាសរ, **អឃតោ** ដោយអាការជារបស់លំបាក, **អាពាធតោ** ដោយអាការអាពាធ, **បរតោ** ដោយអាការជាចំណែកដទៃ, **បលោកតោ** ដោយអាការវិនាស, **ឦតិតោ** ដោយអាការជាចង្រៃ, **ឧបទ្ទវតោ** ដោយអាការជាឧបទ្រព, **ភយតោ** ដោយអាការជាភ័យ, **ឧបសគ្គតោ** ដោយអាការជាឧបសគ្គ, **ចលតោ** ដោយអាការញាប់ញ័រ, **បភង្គុតោ** ដោយអាការបែកធ្លាយ, **អទ្ធុវតោ** ដោយអាការមិនស្ថិតស្ថេរ, **អតាណតោ** ដោយអាការមិនមានទីជ្រកកោន, **អលេណតោ** ដោយអាការមិនមានទីពួន, **អសរណតោ** ដោយអាការមិនមានទីពឹង, **រិត្តតោ** ដោយអាការជាទីវាល, **តុច្ឆតោ** ដោយអាការទទេ, **សុញ្ញតោ** ដោយអាការសោះសូន្យ, **អនត្តតោ** ដោយអាការមិនមែនខ្លួន, **អាទីនវតោ** ដោយអាការជាទោស,

**វិបរិណាមធម្មតោ** ដោយអាការមានការប្រែប្រួលជាធម្មតា, **អសារកតោ** ដោយអាការមិនមានខ្លឹមសារ, **អឃមូលតោ** ដោយអាការជាឫសគល់នៃសេចក្ដីលំបាក, **វធកតោ** ដោយអាការជាអ្នកសម្លាប់, **វិភវតោ** ដោយអាការប្រាសចាកសេចក្ដីចម្រើន, **សាសវតោ** ដោយអាការប្រកបដោយអាសវៈ, **សង្ខតតោ** ដោយអាការជាសង្ខតៈ, **មារាមិសតោ** ដោយអាការជាអាមិសនៃមារ **ជាតិធម្មតោ** ដោយអាការមានជាតិជាធម្មតា, **ជរាធម្មតោ** ដោយអាការមានជរាជាធម្មតា **ព្យាធិធម្មតោ** ដោយអាការមានព្យាធិជាធម្មតា, **មរណធម្មតោ** ដោយអាការមានការស្លាប់ជាធម្មតា, **សោកធម្មតោ** ដោយអាការមានសេចក្ដីសោកជាធម្មតា, **បរិទេវធម្មតោ** ដោយអាការមានបរិទេវៈជាធម្មតា, **ឧបាយាសធម្មតោ** ដោយអាការមានឧបាយាសជាធម្មតា, **សង្កិលេសិកធម្មតោ** ដោយអាការជារបស់មានសេចក្ដីសៅហ្មងជាធម្មតា ដូច្នេះក៏បាន ។

សួរថា ការពិចារណាបញ្ចក្ខន្ធ តាមបែប **អនិច្ចាទិសម្មសន** ដូចម្ដេច ? ឆ្លើយថា យោគាវចរភិក្ខុនោះ រមែងពិចារណាខន្ធឯណានីមួយតាមគន្លង **អនិច្ចាទិសម្មសនៈ** ដែលត្រាស់ដោយចែកទុកដូច្នេះ គឺ

**អនិច្ចតោ** ដោយអាការ ឈ្មោះថា **មិនទៀង** ព្រោះខន្ធនោះមិនជារបស់មានរហូតទៅ និងព្រោះខន្ធ មានខាងដើមខាងចុង ។

**ទុក្ខតោ** ដោយអាការ ឈ្មោះថា **ជាទុក្ខ** ព្រោះភាវៈ គឺត្រូវការកើតឡើងការវិនាសទៅបៀតបៀន និងព្រោះជាទីសម្រាប់ទ្រសេចក្ដីទុក្ខ ។

**រោគតោ** ដោយអាការ ឈ្មោះថា **ជារោគ** ព្រោះគប្បីតាំងនៅបានដោយបច្ច័យ និងព្រោះជាមូលរបស់រោគ ។

**គណ្ឌតោ** ដោយអាការ ឈ្មោះថា **ជាបូស** ព្រោះជាវត្ថុដែលប្រកបដោយការឈឺ គឺភាពជាទុក្ខ ព្រោះជាទីហូរចេញនៃខ្ទុះ គឺកិលេស និងព្រោះហើមឡើង និងបែក

ដោយការកើតឡើង ការចាស់ និងការបែកធ្លាយទៅ ។

**សល្លតោ** ដោយអាការ ឈ្មោះថា **ជាសរ** ព្រោះជាវត្ថុញ៉ាំងការឈឺចាប់ឲ្យកើត ព្រោះដោតជាប់នៅខាងក្នុង និងព្រោះគប្បីដកចេញបានលំបាក ។

**អឃតោ** ដោយអាការ ឈ្មោះថា **ជារបស់លំបាក** ព្រោះជាទីតាំងនៃការតិះដៀល ( នៃអរិយជន ) ព្រោះនាំការមិនចម្រើនមកឲ្យ និងព្រោះជាទីធ្លាក់ចុះនៃការលំបាក ។

**អាពាធតោ** ដោយអាការ ឈ្មោះថា **អាពាធ** ព្រោះជាវត្ថុដែលញ៉ាំងភាពមិនជាសេរីឲ្យកើត និងព្រោះជាបទដ្ឋាននៃជំងឺតម្កាត់ ។

**បរតោ** ដោយអាការ ឈ្មោះថា **ជាចំណែកដទៃ** ព្រោះមិននៅក្នុងអំណាច និងព្រោះមិនស្តាប់បង្គាប់ ។

**បលោកតោ** ដោយអាការ ឈ្មោះថា **វិនាស** ព្រោះបែកទៅដោយជរា ព្យាធិ មរណៈ ។

**ឦតិតោ** ដោយអាការ ឈ្មោះថា **ចង្រៃ** ព្រោះនាំអន្តរាយមកឲ្យជាអនេក ។

**ឧបទ្ទវតោ** ដោយអាការ ឈ្មោះថា **ឧបទ្រព** ព្រោះជាទីធ្លាក់ចុះនូវឧបទ្រពទាំងពួង ជាហេតុនាំមកនូវអនត្ថផលធំៗ ដែលមិនដឹង ។

**ភយតោ** ដោយអាការ ឈ្មោះថា **ជាភ័យ** ព្រោះជាប្រភពកើតនៃភ័យទាំងពួង និងព្រោះជាចំណែកបដិបក្ខចំពោះបរមអស្សាសៈ (ការក្សេមដ៏ក្រៃលែង) ដែលបានដល់ការស្ងប់ទុក្ខ ។

**ឧបសគ្គតោ** ដោយអាការ ឈ្មោះថា **ជាឧបសគ្គ** ព្រោះត្រូវអនត្ថៈច្រើនយ៉ាងរួបរឹត ព្រោះត្រូវវត្ថុដែលជាទោសរារាំង និងព្រោះគួរដល់ការមិនគប្បីទទួលយកដូចឧបសគ្គ ។

ចលតោ ដោយអាការ ឈ្មោះថា ញាប់ញ័រ ព្រោះញាប់ញ័រដោយជរា ព្យាធិ មរណៈ និងដោយលោកធម៌ទាំងឡាយ មានលាភ និងអត់លាភជាដើម ។

បភង្គុតោ ដោយអាការ ឈ្មោះថា បែកធ្លាយ ព្រោះមានប្រក្រតីចូលដល់ការបែកធ្លាយដោយការធ្វើ ( របស់ខ្លួន ឬអ្នកដទៃ ) ខ្លះ ដោយកើតឯងខ្លះ ។

អទ្ធុវតោ ដោយអាការ ឈ្មោះថា មិនស្ថិតស្ថេរ ព្រោះមានប្រក្រតីធ្លាក់ទៅបានគ្រប់កាល និងព្រោះមិនមានស្ថិរភាព ។

អតាណតោ ដោយអាការ ឈ្មោះថា មិនមានទីជ្រកកោន ព្រោះមិនមានទីរក្សា និងព្រោះមិនមានការផុតភ័យ ។

អលេណតោ ដោយអាការ ឈ្មោះថា មិនមានទីពួន ព្រោះមិនមានទីកំបាំងដែលល្មមនឹងពួនបាន និងព្រោះមិនធ្វើកិច្ចដែលកំបាំងឲ្យ សូម្បីដល់សត្វទាំងឡាយដែលលាក់ខ្លួន ។

អសរណតោ ដោយអាការ ឈ្មោះថា មិនមានទីពឹង ព្រោះមិនមានទីកម្ចាត់ភ័យឲ្យដល់អ្នកអាស្រ័យទាំងឡាយ ។

រិត្តតោ ដោយអាការ ឈ្មោះថា ជាទីវាល ព្រោះទទេចាកការស្ថិតស្ថេរ ការស្អាត និងសេចក្តីសុខ តាមដែលបុគ្គលល្ងង់ខ្លៅ ដៅស្មានយក ។

តុច្ឆតោ ដោយអាការ ឈ្មោះថា ទទេ ព្រោះជារបស់ទទេនោះឯង ឬព្រោះជារបស់បន្តិចបន្តួចក៏បាន ព្រោះថា របស់បន្តិចបន្តួច លោកក៏ហៅថា ទទេបានក្នុងលោក។

សុញ្ញតោ ដោយអាការ ឈ្មោះថា សោះសូន្យ ព្រោះទទេអំពីជាម្ចាស់ អ្នកគ្រប់គ្រង អ្នកសាង អ្នកសោយ និងអ្នកថែរក្សា ។

អនត្តតោ ដោយអាការ ឈ្មោះថា មិនមែនខ្លួន ព្រោះតែខ្លួនឯងមិនបានជាម្ចាស់នៃខ្លួនឯង ។

*អាទីនវតោ* ដោយអាការ ឈ្មោះថា **ជាទោស** ព្រោះជាបវត្តិទុក្ខ និងព្រោះសេចក្តីទុក្ខជាតួទោស ន័យម្យ៉ាងទៀត បុគ្គលណា រមែងទៅកាន់ភាពលំបាក រមែងដល់នូវសេចក្តីលំបាក សេចក្តីលំបាកចិត្តរមែងប្រព្រឹត្តទៅដល់បុគ្គលណា ហេតុនោះទើបបុគ្គលនោះ ឈ្មោះថា **អាទីនវ** ពាក្យថា **អាទីនវ** នោះ ជាពាក្យហៅបុគ្គលលំបាក សូម្បីខន្ធទាំងឡាយ ក៏ជាសភាវៈលំបាកពិត ហេតុនោះ ដោយអាការឈ្មោះថា ជាអាទីនវ ព្រោះដូចជាបុគ្គលលំបាក ។

*វិបរិណាមធម្មតោ* ដោយអាការ ឈ្មោះថា **មានការប្រែប្រួលទៅជាធម្មតា** ព្រោះមានការប្រែប្រួលទៅជាប្រក្រតី ដោយអាការ ២ គឺដោយជរា និងមរណៈ ។

*អសារកតោ* ដោយអាការ ឈ្មោះថា **មិនមានខ្លឹម** ព្រោះជាវត្ថុទុព្វល និងព្រោះជាវត្ថុបាក់បានងាយ ដូចក្រមរឈើ ។

*អឃមូលតោ* ដោយអាការ ឈ្មោះថា **ជាឫសគល់នៃសេចក្តីលំបាក** ព្រោះជាហេតុនៃសេចក្តីទុក្ខលំបាក ។

*វធកតោ* ដោយអាការ ឈ្មោះថា **ជាអ្នកសម្លាប់** ព្រោះរមែងទម្លាយសេចក្តីសង្ឃឹម ដូចសត្រូវមានមុខជាមិត្ត ។

*វិភវតោ* ដោយអាការ ឈ្មោះថា **មិនមានសេចក្តីចម្រើន** ព្រោះប្រាសចាកសេចក្តីចម្រើន និងព្រោះជាហេតុនៃសេចក្តីវិនាស ។

*សាសវតោ* ដោយអាការឈ្មោះថា **ប្រព្រឹត្តទៅជាមួយអាសវៈ** ព្រោះជាបទដ្ឋាននៃអាសវៈ ។

*សង្ខតតោ* ដោយអាការ ឈ្មោះថា **ជាសង្ខតៈ** ព្រោះជារបស់ដែលហេតុបច្ច័យតាក់តែងឡើង ។

*មារាមិសតោ* ដោយអាការ ឈ្មោះថា **ជាអាមិសរបស់មារ** ព្រោះជានុយរបស់

មច្ចុមារ និងកិលេសមារ ។

**ជាតិជរាព្យាធិមរណធម្មតោ** ដោយអាការ ឈ្មោះថា **មានជាតិ... ជរា... ព្យាធិ... មរណៈ ជាធម្មតា** ព្រោះមានការកើត... ការចាស់... ជំងឺតម្កាត់... ការស្លាប់ជាប្រក្រតី ។

**សោកបរិទេវឧបាយាសធម្មតោ** ដោយអាការ ឈ្មោះថា **មានការខ្សឹកខ្សួល... កន្ទក់កន្ទេញ... ចង្អៀតចង្អល់ជាធម្មតា** និងព្រោះមានសេចក្ដីសោកសង្រេង... ការយំរៀបរាប់... និងការតានតឹងក្នុងចិត្តជាប្រក្រតី ។

**សង្កិលេសិកធម្មតោ** ដោយអាការ ឈ្មោះថា **ជាវត្ថុដែលមានសេចក្ដីសៅហ្មងជាធម្មតា** ព្រោះមានភាពជាវិស័យនៃសង្កិលេស គឺតណ្ហា ទិដ្ឋិ និងទុច្ចរិតជាធម្មតា ។

## សង្គ្រោះសម្មសនៈ ៤០ ចុះក្នុងអនុបស្សនា ៣

ក្នុងសម្មសនៈ ៤០ នេះ សម្មសនៈដោយអាការ ១០ គឺដោយអាការមិនទៀង ដោយអាការវិនាស ដោយអាការញាប់ញ័រ ដោយអាការបែកធ្លាយ ដោយអាការមិនស្ថិតស្ថេរ ដោយអាការមានការប្រែប្រួលទៅជាធម្មតា ដោយអាការមិនមានខ្លឹម ដោយអាការមិនមានសេចក្ដីចម្រើន ដោយអាការជាសង្ខតៈ ដោយអាការមានមរណៈជាធម្មតា **ជាអនិច្ចានុបស្សនា ៥០** ដោយធ្វើខន្ធ ១ ឲ្យជា ១០ ។

សម្មសនៈដោយអាការ ៥ គឺដោយអាការជារបស់ដទៃ ដោយអាការជាទីវាល ដោយអាការជារបស់ទទេ ដោយអាការសោះសូន្យ ដោយអាការមិនមែនខ្លួន **ជាអនត្តានុបស្សនា ២៥** ដោយធ្វើខន្ធ ១ ឲ្យជា ៥ ។

សម្មសនៈដ៏សេសជាដើមថា ដោយអាការជាទុក្ខ ដោយអាការជារោគ **ជាទុក្ខានុបស្សនា ១២៥** ដោយធ្វើខន្ធ ១ ឲ្យជា ២៥ ដូច្នេះ ។

កាលព្រះយោគាវចរពិចារណាបញ្ចក្ខន្ធដោយ **អនិច្ចាទិសម្មសនៈ** ដែលចែកជា ២០០ ដោយអាការដូចពោលមកនេះ អនិច្ចសម្មសនៈ ទុក្ខសម្មសនៈ និងអនត្តសម្មសនៈ ដែលហៅថា **នយវិបស្សនា** នោះ រមែងមាំទាំ ។

នេះជាវិធីធ្វើសម្មសនៈ ក្នុងអធិការនៃសម្មសនញ្ញាណនេះ ដោយប្រព្រឹត្តតាមន័យព្រះបាលីមុន ។

# មហាដីកា

## កថាពណ៌នាដោយការពិចារណា

## តាមដោយអាការ ៤០

បទថា **សោ យោគ យោគាវចរោ** ប្រែថា យោគាវចរនោះ ។ បទថា **តស្ស យោគ យថាវុត្តភេទស្ស អនិច្ចាទិសម្មសនស្ស** ប្រែថា នៃការពិចារណាជារបស់មិនទៀង ដែលមានប្រភេទតាមដែលពោលហើយនោះ ។ បទថា **ថិរភាវត្ថាយ** ប្រែថា ដើម្បីប្រយោជន៍ដល់ការមាំទាំ ព្រោះភាវៈ គឺការធ្វើឲ្យច្រើន ដូចជាការធ្វើមនសិការរឿយៗ នូវអាការ មានជារបស់មិនទៀងជាដើម ។ សម្ពន្ធព្រះបាលីថា **យំ តំ ភគវតា ឯតស្ស វិភង្គេ អនិច្ចាទិ សម្មសនំ វុត្តំ** ប្រែថា **អនិច្ចាទិសម្មសនៈ** នោះ ព្រះសាស្ដាត្រាស់ទុកក្នុងវិភង្គនៃបាឋៈនោះ ។ ពាក្យថា **ដែលជាអនុលោម** គឺដែលអនុគោលដល់ការសម្រេចអរិយមគ្គ ។ ពាក្យថា **ខន្តិ** បានដល់ **ខន្តី** គឺញាណ ។ ពិតហើយញាណ លោកហៅថា ខន្តី ព្រោះអត្ថថា អត់ធន់ គឺធន់ក្នុងការកំណត់ ឈោងចុះកាន់ភាពជាអារម្មណ៍ ។ ពាក្យថា **សម្មត្តនិយាម** បានដល់ អរិយមគ្គ ពិតហើយ អរិយមគ្គនោះ លោកពោលជាការត្រឹមត្រូវ គឺមានសម្មាទិដ្ឋិជាដើមផង ជាការពិតប្រាកដ ព្រោះមានការមិនវិលត្រឡប់ជាធម្មតាផង ។ ដោយពាក្យថា **ដោយន័យជាដើមថា** នេះ បណ្ឌិតគប្បីពង្រីកសេចក្ដីបាឋៈដ៏សេសជាដើមយ៉ាងនេះថា **ភិក្ខុកាលឃើញបញ្ចក្ខន្ធដោយអាការជាទុក្ខ រមែងបានអនុលោមខន្តី កាលឃើញថា ការរលត់នៃបញ្ចក្ខន្ធជាសេចក្ដីសុខ ជានិព្វាន រមែងឈោងចុះកាន់សម្មត្តនិយាម** ដូច្នេះ គប្បីឲ្យពិស្ដារដោយទាក់ទងនឹងពាក្យប្រកបធម៌ដែលជាបដិបក្ខ មានភាពជារោគជាដើម ។ ពាក្យថា **ការរលត់នៃខន្ធ ជាភាពទៀង ជានិព្វាន** លោកបានសម្ដែងនិព្វានជាសុខ និងការ

មិនមានភេទជាដើម ដែលជាបដិបក្ខចំពោះសង្ខារជាសេចក្តីទុក្ខ និងជាអាការជាភេទជាដើម ដោយការកាន់យកន័យក្នុងពាក្យថា **ដោយន័យជាដើមថា** នេះ ព្រោះហេតុនោះ ទើបការប្រកាសបាឋៈទាំងអស់ដ៏សេសនោះឯង ។

ឯសម្មសនៈដោយអាការ ៤០ នេះ ជាពិធីដែលគប្បីចម្រើនក្នុងអនុលោមញ្ញាណ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដែលព្រះមានព្រះភាគទ្រង់ចែកអនុលោមញ្ញាណ ។បេ។ ទុក** ដូច្នេះ ពិតហើយ សូម្បីយ៉ាងនោះ តាំងអំពីនេះទៅ គប្បីឃើញថា លោកពោលទុកក្នុងបទនេះ ព្រោះសម្មសនៈនេះ ជារឿងនាំកិច្ចមកឲ្យដល់យោគាវចរដែលធ្វើការសេពហើយនោះឯង ។ បទថា **តស្សាបិ** សេចក្តីថា មិនមែននៃកលាបសម្មសនៈតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សូម្បីនៃអនិច្ចាទិសម្មសនៈដែលមានប្រភេទ ៤០ តាមដែលបានសម្តែងទុកហើយ ឯអនិច្ចាទិសម្មសនៈនោះ ចាំបាច់ដោយចំណែកមួយ ព្រោះប្រព្រឹត្តទៅដើម្បីការបានអនុលោមិកខន្តិញ្ញាណ និងដើម្បីការឈានចុះកាន់សម្មត្តនិយាម ។ សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកថា

ម្នាលភិក្ខុទាំងឡាយ ប្រការដែលភិក្ខុនុះហ្ន៎ ពិចារណាឃើញសង្ខារណាមួយថាជារបស់ទៀង ជាអ្នកប្រកបដោយអនុលោមិកខន្តិញ្ញាណនេះ មិនមែនឋានៈ ដែលនឹងមានបាន ប្រការដែលថា ភិក្ខុដែលមិនប្រកបអនុលោមិកខន្តិញ្ញាណ និងឈានចុះកាន់សម្មត្តនិយាមនេះ មិនមែនឋានៈដែលនឹងមានបាន ប្រការដែលភិក្ខុមិនឈានចុះកាន់សម្មត្តនិយាម និងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។បេ។ ឬនូវអរហត្តផលនេះ មិនមែនឋានៈដែលមានបាន ។ ម្នាលភិក្ខុទាំងឡាយ ប្រការដែលភិក្ខុនោះ ពិចារណាឃើញសង្ខារទាំងពួងថា ជារបស់មិនទៀង ដូច្នេះ ។ បណ្ឌិតគប្បីពណ៌នាបាឋៈដែលជាសុក្កបក្ខឲ្យពិស្តារ ។ ម្យ៉ាងទៀត គប្បីពណ៌នាបាឋៈថា ម្នាលភិក្ខុទាំងឡាយ ប្រការដែលភិក្ខុនោះ ពិចារណាឃើញសង្ខារណាមួយ ថាជាសុខ ថាជាទុក្ខ ពិចារណាឃើញ

ធម៌ណាមួយ ថាជាអត្តា ថាជាអនត្តា ដូច្នេះ ឲ្យពិស្តារ ។ សម្ពន្ធសេចក្តីបាលីថា **ឯកេកំ ខន្ធំ អនិច្ចាទិសម្មសនស្ស វសេន សម្មសតិ** ប្រែថា យោគាវចរភិក្ខុរមែងពិចារណាខន្ធតែម្យ៉ាង ដោយអំណាចអនិច្ចាទិសម្មសនៈ ។ ក៏ព្រោះសម្មសនៈនោះជាកិច្ចទូទៅដល់បញ្ចក្ខន្ធ ទើបលោកអាចារ្យពោលថា **ខន្ធតែម្យ៉ាង** ។ បទថា **អនច្ចន្តិកតាយ** សេចក្តីថា ព្រោះមិនមានភាព ពិតប្រាកដ សេចក្តីថា ព្រោះជាការមិនស្ថិតស្ថេរ ។ ព្រោះថា វត្ថុដែលស្ថិតស្ថេរ បានដល់ វត្ថុដែលពិតប្រាកដ ព្រោះមិនមានចំណែកបំផុតខាងចុង ។ បទថា **អាទិអន្តវន្តតាយ** សេចក្តីថា ព្រោះខន្ធមានទីបំផុតខាងដើមខាងចុង អធិប្បាយថា ព្រោះមានការកើតឡើង និងការវិនាសទៅជាធម្មតា ។ ភ្ជាប់សេចក្តីបាលីថា **អនិច្ចតោសម្មសតិ** ប្រែថា រមែងពិចារណាដោយអាការ ឈ្មោះថា **មិនទៀង** ។ គ្រប់បទក៏មានន័យនេះឯង ។

បទថា **អនិច្ចតោ** ប្រែថា ដោយអាការមិនស្ថិតស្ថេរ ។ ឯខន្ធនេះ ឈ្មោះថា **អនិច្ចំ** ព្រោះមានអត្ថថា **មិនមែនវត្ថុដែលទៀង** ម្យ៉ាងទៀត ឈ្មោះថា **អនិច្ចំ** ព្រោះមានអត្ថថា ដែលបុគ្គលមិនគប្បីដល់ គឺមិនគប្បីចូលដល់ ព្រោះខន្ធជារបស់មួយរយៈ គឺព្រោះខន្ធមិនមែនមានគ្រប់កាល ។ ពាក្យថា **ព្រោះភាវៈ** គឺការបៀតបៀន ដោយការកើតឡើង និងការវិនាសទៅ សេចក្តីថា ព្រោះខន្ធមានការដល់ ព្រមដោយទុក្ខនោះមានសភាពបៀតបៀនគ្រប់ៗ ខណៈ ដោយចំពោះៗ ដោយការកើតឡើង និងដោយការវិនាសទៅ ឬព្រោះខន្ធត្រូវការកើតឡើង និងការវិនាសទៅនោះបៀតបៀននោះឯង ។ ពិតហើយ ធម៌ទាំងឡាយ ដែលមានការកើតឡើង និងការវិនាសទៅ រមែងជាសភាវៈត្រូវការកើតឡើង និងការវិនាសទៅបៀតបៀន ដោយចំពោះរឿយៗ នោះឯង ដែលលោកហៅការបៀតបៀននោះថា ជាសង្ខារទុក្ខ គឺជាសេចក្តីទុក្ខប្រចាំសង្ខារ ។

ពាក្យថា **ព្រោះជាទីតាំងនៃទុក្ខ** គឺព្រោះភាវៈ គឺជាទីធ្លាក់ចុះនៃទុក្ខ ៣ យ៉ាង

និងនៃសង្ខារទុក្ខ ។ ពាក្យថា **ព្រោះគប្បីតាំងនៅបានដោយបច្ច័យ** សេចក្ដីថា ព្រោះភាពជាវត្ថុដែលគប្បីឲ្យប្រព្រឹត្តទៅ ដោយបច្ច័យទាំងឡាយតាមសមគួរ ។ ពាក្យថា **ព្រោះភាពជាមូលនៃរោគ** សេចក្ដីថា ព្រោះជាមូលនៃព្យាធិជាប់តាម ដូចជាព្យាធិដែលជាមូល សូម្បីដោយបទទាំង ២ លោកអាចារ្យរមែងសម្ដែងថា ព្រោះដូចជារោគដែលពុំរ៉ៃ ។ ឯព្យាធិដែលពុំរ៉ៃចាត់ជារោគ ព្យាធិក្រៅអំពីនេះ ចាត់ជាអាពាធ ។ ពាក្យថា **ព្រោះជារបស់ដែលប្រកបដោយសេចក្ដីឈឺចាប់ គឺភាពជាទុក្ខ** បានដល់ព្រោះភាវៈ គឺការប្រកបដោយការចាក់ដោត ពោល គឺសេចក្ដីទុក្ខ ៣ យ៉ាង ។ពាក្យថា **ព្រោះជាទីហូរចេញនៃរបស់មិនស្អាត គឺកិលេស** សេចក្ដីថា ព្រោះជាទីហៀរចេញនៃវត្ថុមិនស្អាត គឺកិលេស មានរាគៈជាដើម ដោយអំណាចអារម្មណ៍ និងដោយអំណាចការប្រកបតាមគួរ ឈ្មោះថា **ការហើមឡើង ដោយការកើតឡើង ព្រោះការមិនមានហើយក៏មានឡើង** ។ បទថា **អន្ដោតុទនតាយ** ប្រែថា ព្រោះចាក់ដោតខាងក្នុង ។ ពិតហើយ សង្ខារទាំងនេះក៏ដូចទុក្ខវេទនាជាដើមនៅខាងក្នុងអត្តភាពនោះឯង ។ ចាក់ទម្លុះដោយអំណាចការកើតឡើង និងការវិនាសទៅ ។ ឈ្មោះថា **ជាវត្ថុដែលដកបានលំបាក** ព្រោះវៀរចាកដង្កាប់ គឺអរិយមគ្គ បុគ្គលណាម្នាក់ មិនអាចនឹងទាញចេញបាន ព្រោះជាវត្ថុប្រកាន់ស្អិតដោយតណ្ហា ភិនិវេស និងទិដ្ឋាភិនិវេស ។ បទថា **អឃំ** ប្រែថា ដូចជារបស់លំបាក គឺអរិយជនទាំងឡាយ គប្បីតិះដៀល ។ ខន្ធ ៥ នាំសេចក្ដីមិនចម្រើនមក ព្រោះធ្វើឲ្យកើត សេចក្ដីវិនាសដល់សត្វទាំងឡាយ ជាទីតាំងនៃរបស់លាមក ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដោយអាការឈ្មោះថា **ជាសេចក្ដីលំបាកព្រោះជាទីតាំងនៃការតិះដៀល** ដូច្នេះ ។ ពាក្យថា **ព្រោះជាវត្ថុដែលញុំាងការមិនមានសេរីឲ្យកើត** សេចក្ដីថា ព្រោះញុំាងការទាក់ទងដោយបុគ្គលដទៃឲ្យកើត ។ ប្រៀបដូចមនុស្សឈឺ មានការប្រព្រឹត្តទៅទាក់ទងដោយអ្នកដទៃ ដោយបុគ្គលដទៃបញ្ចុកបាយ

និងគ្រាប់ឲ្យក្រោកឡើងជាដើម មិនមានសេរី យ៉ាងណា សូម្បីសង្ខារទាំងនេះក៏ដូច្នោះ ព្រោះញ៉ាំងភាពមិនមានសេរីឲ្យកើត ។ ពាក្យថា **ព្រោះមិននៅក្នុងអំណាច** បានដល់ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ បុរសច្រើនជាងរយនាក់ជាទីបំផុត រមែងមិនទៅកាន់អំណាចរបស់អ្នកដទៃ យ៉ាងណា ព្រោះបុគ្គលណាម្នាក់ មិនអាចឲ្យប្រព្រឹត្តទៅក្នុងអំណាចដោយជារបស់ស្អាត និងជាសុខជាដើម ដូច្នោះ ។ ពាក្យថា **ព្រោះមិនស្តាប់បង្គាប់** សេចក្តីថា ព្រោះបុគ្គលណាម្នាក់ មិនអាចនឹងបង្គាប់បញ្ជាដោយពាក្យថា **អ្នកកុំចាស់ឡើយ កុំស្លាប់ឡើយ** ដូច្នេះជាដើមបានឡើយ ។ បទថា **បលុជ្ជនតាយ** សេចក្តីថា ព្រោះដាច់ទៅ គឺព្រោះវិនាសទៅដោយប្រការទាំងឡាយ មានព្យាធិជាដើម ។ ម្យ៉ាងទៀត ព្រោះវិនាសយ៉ាងក្រៃលែង ដោយប្រការទាំងឡាយ មានព្យាធិជាដើមនោះ ។ ឯ **លោក-ស័ព្ទ** មានអត្ថថា វិនាស **ប-ស័ព្ទ** គប្បីឃើញថា មានអត្ថថា យ៉ាងក្រៃលែង ។ ឯខន្ធទាំងឡាយវិនាសទៅ ដោយប្រការទាំងឡាយ មានព្យាធិជាដើម ។ ឈ្មោះថា **ឦតិ** ( ចង្រៃ ) ដោយអត្ថថា មកដល់ដោយការៈនាំមកនូវសេចក្តីវិនាស ពាក្យថា **ឦតិ** នេះ ជាឈ្មោះហេតុនៃសេចក្តីវិនាសដែលប្រព្រឹត្តទៅក្នុងចំណែកអកុសល ដែលត្រាច់មក ។ ឯខន្ធទាំងឡាយ ក៏ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយអាការ ឈ្មោះថាជាចង្រៃ ព្រោះនាំមកនូវសេចក្តីវិនាសជាអនេក** ។

ឈ្មោះថា **ឧបទ្ទវ** ព្រោះមានអត្ថថា រមែងចូលទៅបៀតបៀន អធិប្បាយថា ញ៉ាំងសេចក្តីវិនាសឲ្យកើត គ្របសង្កត់ លិចលង់ ពាក្យថា **ឧបទ្ទវ** នេះ ជាឈ្មោះនៃការអន្តរាយ មានរាជទណ្ឌជាដើម ។ ហើយខន្ធទាំងឡាយ ក៏ដូច្នេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយអាការឈ្មោះថា ជាឧបទ្ទវ** ព្រោះនាំអនត្ថផលធំៗ ដែលមិនដឹងមក និងព្រោះជាទីតាំងនៃឧបទ្ទវទាំងពួង ។ ខន្ធទាំងឡាយ ឈ្មោះថា

ជាភ័យ ព្រោះនាំភ័យដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងប្រព្រឹត្តទៅក្នុងសម្បរាយភពមកឲ្យ និងព្រោះផ្ទុយនឹងវត្ថុដែលមិនជាភ័យ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយអាការឈ្មោះថាជាភ័យ** ព្រោះជាប្រភពកើតនៃភ័យទាំងពួង ។បេ។ ឈ្មោះថា **ឧបសគ្គ** ព្រោះអត្ថថា **រារាំង** ដោយអនត្ថៈទាំងឡាយ មានការវិនាសជាដើមខាងក្រៅ និងមានរាគៈជាដើមខាងក្នុង និងព្រោះដូចជាឧបសគ្គ ។ ពាក្យថា **ឧបសគ្គ** បានដល់ អនត្ថៈដែលប្រព្រឹត្តទៅ ដោយអំណាចទេវតាបណ្ដាល ។ ឧបសគ្គនោះ ជាវត្ថុដែលអ្នកប្រាថ្នាសេចក្ដីចម្រើន មិនគប្បីព្រងើយកន្ដើយ សូម្បីមួយខណៈ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយអាការឈ្មោះថា ជាឧបសគ្គ** ព្រោះត្រូវអនត្ថៈច្រើនយ៉ាងជាប់តាម ។បេ។ ពាក្យថា **ព្រោះត្រូវវត្ថុដែលជាទោសរារាំង** បានដល់ ព្រោះប្រកបដោយវត្ថុដែលជាទោស មានរាគៈជាដើម ដោយជាអារម្មណ៍ និងដោយសម្បយោគ ។ លោកធម៌ទាំងឡាយ មានលាភជាដើមហេតុ ទាំងសេចក្ដីត្រេកអរ និងមិនត្រេកអរ ភាពដែលខន្ធមិនឈប់ដោយលោកធម៌ទាំងនោះ និងដោយប្រការមានព្យាធិជាដើម ឈ្មោះថា **ការញាប់ញ័រ** ។

ពាក្យថា **ដោយការផ្ញើ** បានដល់ ដោយការខ្នះខ្នែងរបស់ខ្លួន ឬរបស់អ្នកដទៃ ។ ពាក្យថា **ដោយកើតឯង** គឺដោយសភាវៈ ។ **ការមានប្រក្រតីចូលដល់ការបែកធ្លាយ** បានដល់ ការបែកធ្លាយ ។ ពាក្យថា **ព្រោះមានប្រក្រតីធ្លាក់ទៅគ្រប់អាការ** សេចក្ដីថា ព្រោះមានប្រក្រតីធ្លាក់ទៅក្នុងអាការគ្រប់យ៉ាង តាំងអំពីកាលដែលជាកុមារ ដូចជាផ្លែរបស់ដើមឈើ ។ ឈ្មោះថា **ព្រោះមិនមានភាវៈដែលស្ថិតស្ថេរ** ព្រោះវត្ថុដែលមិនបានធ្លាក់ទៅ ក៏ជាវត្ថុមិនមានខ្លឹមសារ គ្រប់វត្ថុ គ្រប់យ៉ាង ។ វត្ថុដែលមាំទាំ រមែងជាវត្ថុឈ្មោះថា **ស្ថិតស្ថេរ** ។ សភាវៈណា មិនមែនបុគ្គលគ្រប់គ្រង ព្រោះមិនអាចគ្រប់គ្រងគឺរក្សាទុក ហេតុនោះ ទើបសភាវៈនោះ ឈ្មោះថា **អតាយនោ** ប្រែថា មិនគ្រប់គ្រង

ការៈរបស់សការៈដែលមិនគ្រប់គ្រងនោះ ឈ្មោះថា **អតាយនតា** ប្រែថា ការមិនមានទីគ្រប់គ្រង ។ វត្ថុដែលចូលដល់ដោយការសង្ឃឹមមិនបាន វត្ថុដែលគ្រប់គ្រងមិនបាន **ជាវត្ថុដែលមិនផុតភ័យបាន** ។ ឈ្មោះថា **មានទីពួនបាន** ដោយបំណងនឹងចូលទៅពួន ព្រោះខ្លាចសេចក្តីទុក្ខ ។ ការឃាត់សេចក្តីទុក្ខ ឈ្មោះថា **ធ្វើកិច្ចកំបាំង** ។ ការបៀតបៀន គឺការកម្ចាត់ភ័យ មានជាតិជាដើម ឈ្មោះថា **ជាទីកម្ចាត់ភ័យ** ។ ពាក្យថា **តាមដែលបុគ្គលល្ងង់ខ្លៅដៅស្មាន** សេចក្តីថា ដោយប្រការដែលបុគ្គលល្ងង់ខ្លៅទាំងឡាយមិនមានដោយបរមត្ថ គិតស្មានយក ។ បទថា **រិត្តតាយ** ប្រែថា ព្រោះជាទីវាល អធិប្បាយថា ព្រោះជាការវៀរ ។ ការមិនសារៈខាងក្នុង ឈ្មោះថា **ទីវាល** ។ ឯទីវាលនោះឯងជារបស់ទទេ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ឈ្មោះថា **ដោយអាការជាទីវាល** ព្រោះជារបស់ទទេនោះឯង ។ បទថា **អប្បកត្តា** ប្រែថា ព្រោះជារបស់បន្តិចបន្តួច ឬប្រែថា ព្រោះជារបស់ថោកទាប ។ លោកអាចារ្យកាលសម្តែងការមិនមានសារៈ គឺអត្តា ព្រមជាមួយការមិនមានសារៈ គឺការស្ថិតស្ថេរជាដើម ដោយបទថា **ទីវាលហើយ** បំណងសម្តែងការមិនមានសារៈ ត្រឹមតែធ្វើឲ្យកើតប៉ុណ្ណោះ ដោយបទថា **ជារបស់សូន្យ** ទើបពោលថា **ដោយអាការឈ្មោះថា សូន្យ** ព្រោះទំនេរចាកភាពជាម្ចាស់របស់អ្នកគ្រប់គ្រង អ្នកសាង អ្នកសោយ និងអ្នកថែរក្សា ។ ខន្ធទាំងនេះជារបស់សូន្យចាកខ្លួន ដែលមានភាពជាម្ចាស់របស់ជាដើមជាលក្ខណៈ ដោយប្រការណា សូម្បីខ្លួនឯងក៏មិនមានសការៈ គឺខ្លួននោះ ហេតុនោះ ទើបពោលថា **ដោយអាការឈ្មោះថា មិនមែនខ្លួន ព្រោះខ្លួនឯងក៏មិនបានជាម្ចាស់** ជាដើម ។ ឯសការៈឈ្មោះថា **អនត្តា** ព្រោះអត្ថថា **មិនមែនអត្តា** ។

ពាក្យថា **ព្រោះជាបវត្តិទុក្ខ** គឺព្រោះជាទុក្ខ ដោយនៅប្រព្រឹត្តទៅក្នុងភព ។ ការនៅប្រព្រឹត្តទៅក្នុងភព គឺការប្រព្រឹត្តទៅដោយអាការ មានការមិនទៀងជាដើមនៃខន្ធ

៥ នោះឯង ទុ៎ះជាតួទោស ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធ ៥ មិនទៀង ជាទុក្ខ មានការប្រែប្រួលជាធម្មតា យ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសក្នុងឧបាទានក្ខន្ធ ៥ ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះទុក្ខជាតួទោស** ។ បទថា **អាទីនំ** ជាបទសម្ដែងភាវៈនបុំសកៈ អត្ថថា លំបាកហួសពណ៌នា ដូចពាក្យថា **ឯកម្មន្តំ** ។ **អា** អក្ខរៈ នេះមានអត្ថថា **ក្រៃលែង** ។ **វិ**-ស័ព្ទ ប្រព្រឹត្តទៅក្នុងអត្ថនៃ **ទ្វិ**-ស័ព្ទ ដូចក្នុង ពាក្យថា **ទ្វិធា ធិន្ទកំ វិច្ឆិន្ទកំ** កាត់ចេញជា ២ កំណាត់ ឈ្មោះថា **វិច្ឆិន្ទកំ** នេះ យ៉ាងណា សូម្បីក្នុងពាក្យថា **វិបរិណាមធម្មតោ** នេះ ក៏ដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទ្វេធា បរិណាមបកតិតាយ វិបរិណាមធម្មតោ** ប្រែថា ដោយអាការជាវិបរិណាមធម៌ ព្រោះមានការប្រែប្រួលជាប្រក្រតី ដោយអាការ ២ យ៉ាង ដូច្នេះ ។ ឯការប្រែប្រួល បានដល់ ការដល់សភាវៈដែលវិបរិត ។ បទថា **ទុព្វលតាយ** សេចក្ដីថា ព្រោះការមិនមានកម្លាំង ព្រោះមានការបែកធ្លាយទៅដោយសភាវៈ ។ ឯរបស់ខ្លះ ដូចជាមិនមានកម្លាំង ក៏ជាវត្ថុដែលត្រូវកម្ចាត់បានលំបាក ព្រោះជារបស់ទុព្វល និងមិនមានភាពជារបស់គួរដល់ការងារ ។ ចំណែកខន្ធទាំងនេះ ត្រូវកម្ចាត់បានងាយនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះជាវត្ថុគប្បីបាក់បានងាយ ដូចក្រមរឈើ** ។ ហេតុនៃសេចក្ដីលំបាក គឺបាប ឈ្មោះថា **អឃហេតុកា** ប្រែថា ហេតុនៃសេចក្ដីលំបាក ។ វត្ថុដែលទាក់ទងដោយខន្ធទាំងអស់នោះឯង អាក្រក់ក្រៃពេក ដូច្នេះ ។ ព្រោះភាវៈ មានការបែកធ្លាយ ការដាក់ចិត្តដែលធ្វើឲ្យកើតថា ខន្ធទាំងឡាយ មានរូបជាដើមនេះ ជាហេតុនៃសុខ មិនមែនហេតុនៃទុក្ខ សត្វទាំងឡាយ ទើបដល់នូវការវិនាស ឬបែកធ្លាយ ការធ្វើទុកក្នុងចិត្តដោយអំណាចការប្រកាន់ក្នុងខន្ធទាំងឡាយថា **នេះរបស់អញ** ហេតុនោះ ទើបសត្វទាំងនោះ ឈ្មោះថា **វិស្សាសឃាតិនោ** បុគ្គលមានប្រក្រតីទម្លាយការទុកចិត្ត ព្រោះភាវៈ

នៃសត្វមានប្រក្រតីទម្លាយការទុកចិត្តនោះ ។

បទថា **វិគតករតាយ** សេចក្ដីថា ព្រោះមានសេចក្ដីចម្រើនប្រាសទៅហើយ ។ **វិករតណ្ហា** និង **វិករទិដ្ឋិ** ឈ្មោះថា **វិករោ** ដោយការលុបបទខាងចុង ដោយអាការជា **វិករ** នោះ ។ ម្យ៉ាងទៀត ដោយអាការ **ជាវិករ** នៃហេតុរបស់សការៈដែលហាក់ដូចជាបិតា ព្រោះជារបស់កើតមកអំពីសេចក្ដីវិនាស ។ ភាពជាបច្ច័យដោយជាអារម្មណប្បច្ច័យជាដើម ដល់អាសវៈទាំងឡាយ ឈ្មោះថា **ជាបទដ្ឋាននៃអាសវៈ** ។ហេតុដែលមិនទូទៅ មានពូជជាដើម ឈ្មោះថា **ហេតុ** ហេតុដែលទូទៅ មានភូត ( វត្ថុមានជីវិត ) ទឹកជាដើម ឈ្មោះថា **បច្ច័យ** ។សូម្បីក្នុងរបស់ខាងក្នុងក៏មានន័យនេះ ធម៌ដែលត្រូវហេតុ-បច្ច័យទាំងនោះប្រជុំគ្នា គឺរួមគ្នាតាក់តែងឡើង ឈ្មោះថា **សង្ខតៈ** ។ឈ្មោះថា **ជាអាមិស** ព្រោះធ្វើឲ្យចម្រើនឡើង ដោយជាទីធ្លាក់ចុះ **របស់មច្ចុមារ** និងដោយភាពជាបច្ច័យ **ដល់កិលេសមារ** ។ ខន្ធទាំងឡាយ ឈ្មោះថា **ជានុយរបស់ខន្ធទាំងឡាយ** ព្រោះធ្វើឲ្យធំចម្រើនឡើង ដោយជាបច្ច័យសការៈទាំងឡាយដែលឈោងចុះខាងក្នុងខន្ធទាំងនោះ ជា **អភិសង្ខារ** ។ ខន្ធដែលជានុយរបស់ **ទេវបុត្តមារ** ដោយអំណាចអធិមានៈថា **នេះជារបស់អញ** ព្រោះហេតុនោះ បណ្ឌិតគប្បីពោលខន្ធទាំងនេះថាជានុយតាមគួររបស់មារ មានខន្ធមារជាដើម ។ **ធម្ម-ស័ព្ទ** មានអត្ថថា **បកតិ** ដូចក្នុងពាក្យថា **ជាតិធម្មានំ** មានការកើតជាប្រក្រតីជាដើម និងមានអត្ថថា **ហេតុ** ដូចក្នុងពាក្យថា **ធម្មប្បដិសម្ភិទា** ការបែកធ្លាយ ក្នុងហេតុជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាតិជរាព្យាធិមរណបកតិតាយ** ព្រោះមានជាតិ ជរា ព្យាធិ និងមរណៈជាប្រក្រតី **សោកបរិទេវឧបាយាសហេតុតាយ ច** ព្រោះជាហេតុនៃសោក បរិទេវៈ និងឧបាយាស ។ **ការកាន់យកសង្កិលេសទាំង ៣** គប្បីឃើញការសង្គ្រោះសូម្បីកិលេសវត្ថុ ១០ យ៉ាងដែលតាំងនៅជាមួយសង្កិលេសទាំង ៣ នោះ ។ ធម៌មាន

កិលេសវត្ថុទាំងនោះ ជាអារម្មណ៍ ក៏ឈ្មោះថា **មានសេចក្តីសៅហ្មងនោះឯង** ព្រោះមិនប្រព្រឹត្តទៅ កន្លងកិលេសវត្ថុទាំងនោះទៅបាន ។ មួយវិញទៀត គប្បីឃើញការសង្គ្រោះយកសរីរៈ និងសង្កិលេសចូលទុកក្នុងពាក្យជាដើមថា **ទុក្ខ** ការស្រេក **តណ្ហា** ការចង់បាន **ជរា** ភាពស្គុកជាដើម ។

សម្មសនៈទាំង ៤០ យ៉ាង បន្ថែមចូលខាងក្នុងអនុបស្សនាទាំង ៣ នោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងសម្មសនៈ ៤០ នេះ** ជាដើម ដើម្បីសម្តែងការៈដែលបន្ថែមចូលខាងក្នុងអនុបស្សនានោះ ឈ្មោះថា **អនិច្ចានុបស្សនា** ព្រោះសម្តែងភាពជារបស់មិនទៀងដោយសរុប និងដោយបរិយាយ ។ សូម្បីក្នុងបទក្រៅអំពីនេះ ក៏មានន័យនេះឯង ។ ពាក្យថា **ដោយអាការមិនមានខ្លឹម** នេះ ជាពាក្យសម្តែងការមិនមានខ្លឹមសារជានិច្ច ។

ដោយលំដាប់នៃពាក្យត្រឹមប៉ុណ្ណេះ លោកអាចារ្យបានសង្គ្រោះធម៌ទាំងឡាយដោយជាកលាបៈ ហើយសម្តែងត្រឹមតែសម្មសនៈដោយន័យ មិនបានរៀបចំធម្មវិបស្សនាតាមលំដាប់បទមុន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **នេះជាវិធីធ្វើសម្មសនៈ** ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ធ្វើឥន្ទ្រិយឱ្យចាស់ក្លាដោយអាការ ៩

កាលយោគាវចរភិក្ខុអង្គណា ធ្វើយោគៈដោយនយវិបស្សនាដូចពោលមកនេះ នយវិបស្សនាក៏មិនដល់ព្រម យោគាវចរភិក្ខុអង្គនោះ គប្បីធ្វើឥន្ទ្រិយឲ្យចាស់ក្លា ដោយអំណាចនៃអាការ ៩ ដែលពោលទុកយ៉ាងនេះថា ឥន្ទ្រិយទាំងឡាយ រមែងចាស់ក្លាដោយអាការ ៩ គឺពិចារណាការអស់ទៅនៃសង្ខារទាំងឡាយ ដែលកើតឡើងតែម្យ៉ាង ១ ក្នុងការពិចារណាការអស់ទៅនោះ ញុំាងវិបស្សនាញាណឲ្យដល់ព្រមដោយសច្ចកិរិយា ១ ញុំាងវិបស្សនាឲ្យដល់ព្រមដោយសាតច្ចកិរិយា ១ ញុំាងវិបស្សនាញាណឲ្យដល់ព្រមដោយសប្បាយកិរិយា ១ ញុំាងវិបស្សនាឲ្យដល់ព្រមដោយកំណត់និមិត្តរបស់សមាធិ ( ក្នុងវិបស្សនា ) ឲ្យបាន ១ ញុំាងវិបស្សនាញាណឲ្យដល់ព្រមដោយកិរិយា ដែលញុំាងពោជ្ឈង្គឲ្យប្រព្រឹត្តទៅតាមសមគួរ ១ ចូលទៅតាំងទុកនូវការមិនត្រេកអរក្នុងរាងកាយ និងជីវិត ១ ក្នុងការចូលទៅតាំងទុកនូវការមិនត្រេកអរក្នុងរាងកាយ និងជីវិតនោះ ញុំាងការនាឲ្យដល់ព្រម ដោយសង្កត់ ( សេចក្តីទុក្ខដែលកើតឡើង ) ចេញទៅ ១ ញុំាងការនាឲ្យដល់ព្រម ដោយមិនលះបង់ក្នុងចន្លោះ ១ ហើយវៀរអសប្បាយ ៧ សេពសប្បាយ ៧ ដោយន័យដែលពោលហើយក្នុងបឋវីកសិណនិទ្ទេស ពិចារណារូបតាមកាល ពិចារណាអរូបតាមកាលចុះ ។

# មហាដីកា

## កថាពណ៌នាដោយហេតុធ្វើឥន្ទ្រិយឱ្យចាស់ក្លា ៩ ប្រការ

*ឧទយព្វយញ្ញាណ រមែងកើតឡើងដោយអំណាចនយវិបស្សនានោះឯងដល់យោគីអង្គខ្លះ ដែលមានឥន្ទ្រិយចាស់ក្លា មានបញ្ញាច្រើន រមែងមិនកើតឡើងដល់ព្រះយោគីក្រៅអំពីនេះ ។ លោកអាចារ្យសំដៅដល់សេចក្តីនោះ ទើបពោលថា* ***កាលព្រះយោគាវចរណា ស្ទូឡឺយោគៈដោយនយវិបស្សនាយ៉ាងនេះ នយវិបស្សនាមិនទាន់សម្រេច*** *ដូច្នេះ ។ ឯការកើតឡើងនៃឧទយព្វយញ្ញាណ លោកមានបំណងថា ជាការសម្រេចរបស់នយវិបស្សនាក្នុងទីនេះ ។ សម្ពន្ធបាលីថា* ***តេន នវហាការេហិ ឥន្ទ្រិយានិ តិក្ខានិ ភវន្តិ ។បេ។ អន្តរា ច អញ្ញេសានេនា តិ ឯវំ វុត្តានំ នវន្នំ អាការានំ វសេន ឥន្ទ្រិយានិ តិក្ខានិ កត្វា សប្បាយានិ សេវមានេន សម្មសិតព្វំ*** *ប្រែថា ព្រះយោគីនោះគប្បីធ្វើឥន្ទ្រិយឲ្យចាស់ក្លាដោយអំណាចអាការ ៩ យ៉ាង ដែលពោលទុកយ៉ាងនេះថា ឥន្ទ្រិយទាំងឡាយ រមែងចាស់ក្លាដោយអាការ ៩ គឺ ។បេ។ ញ៉ាំងការនៃការឲ្យដល់ព្រមដោយមិនលះបង់ក្នុងចន្លោះៗ ដូច្នេះ ហើយសេពសប្បាយ ពិចារណាចុះ ។*

*បទថា* ***តេន យោគ យោគិនា*** *ប្រែថា យោគីនោះ ពាក្យថា* ***ដោយអាការ ៩*** *គឺដោយអាការ ៩ យ៉ាង ដែលកំពុងពោលតទៅ ។ ពាក្យថា* ***ឥន្ទ្រិយ*** *បានដល់មានសទ្ធិន្ទ្រិយជាដើម ។ ពាក្យថា* ***ចាស់ក្លា*** *គឺមុតស្រួច ស្ទាត់ជំនាញ អាចហ៊ាន ។ ពាក្យថា* ***ដែលកើតឡើងហើយ*** *បានដល់ ដែលកើតឡើងហើយ គ្រប់ៗ ខណៈ ។ ពាក្យថា* ***នៃសង្ខារទាំងឡាយ*** *គឺនៃរូបធម៌ និងអរូបធម៌ ដែលព្រះយោគីកំពុងចម្រើនវិបស្សនា ។ ពាក្យថា* ***ការអស់ទៅតែម្យ៉ាង*** *គឺរមែងឃើញការកើតឡើងមុនហើយអនុលោមតាមការកើតឡើងនោះ ឃើញការអស់ទៅតែម្យ៉ាង គឺរលត់តែម្យ៉ាង ។*

វិបស្សនាបញ្ញារបស់យោគីនោះ ដែលឧស្សាហ៍ក្នុងការឃើញការអស់ទៅយ៉ាងនេះ រមែងចាស់ក្លា អាចហ៊ាននាំទៅហើយ ឥន្ទ្រិយក្រៅអំពីនេះក៏ដូចគ្នា ។ បទថា **តត្ថ យោគ ខយទស្សនេ** ប្រែថា ក្នុងការឃើញការអស់ទៅ ។ ពាក្យថា **ដោយសច្ចិកិរិយា** គឺដោយភាពជាអ្នកធ្វើដោយអើពើ គឺយោគីរមែងជាអ្នកអើពើ ញុំាងវិបស្សនានោះឲ្យដល់ព្រម ដោយប្រការដែលវិបស្សនាញាណ នឹងប្រព្រឹត្តទៅដោយអាការ មានការឃើញការអស់ទៅយ៉ាងក្រៃលែងប៉ុណ្ណោះ ។ ពាក្យថា **ដោយសាតច្ចកិរិយា** គឺដោយការធ្វើមិនដាច់ខ្សែ គឺព្រះយោគីជាអ្នកឧស្សាហ៍ហើយ ប្រកបហើយ ញុំាងវិបស្សនានោះឲ្យដល់ព្រម ដោយប្រការដែលវិបស្សនាញាណ នឹងប្រព្រឹត្តទៅដោយអំណាចឃើញការអស់ទៅជាប់តគ្នានោះឯង ។ ពាក្យថា **ដោយសប្បាយកិរិយា** គឺដោយកិរិយាដែលសមគួរ បានដល់ ដោយកិរិយា គឺការសេពសប្បាយ ៧ យ៉ាង មានអាវាសសប្បាយជាដើម ។ ពាក្យថា **ដោយការកំណត់និមិត្តរបស់សមាធិ** ភ្ជាប់សេចក្តីថា កាលព្រះយោគីញុំាងមនសិការដោយអាការណា ទើបវិបស្សនាសមាធិកើតឡើង ព្រះយោគីរមែងញុំាងវិបស្សនាញាណឲ្យដល់ព្រម ដោយការកំណត់សមថនិមិត្ត ដោយអំណាចការកំណត់អាការនោះ ។ ពាក្យថា **ដោយកិរិយាញុំាងពោជ្ឈង្គឲ្យប្រព្រឹត្តទៅតាមសមគួរ** សេចក្តីថា ដោយការញុំាងពោជ្ឈង្គឲ្យប្រព្រឹត្តទៅដោយសមគួរ គឺកាលភាវនាចិត្តរួញរា ក៏ដោយការចម្រើនបីតិសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងធម្មវិចយសម្ពោជ្ឈង្គ កាលភាវនាចិត្តរាយមាយ ក៏ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ពាក្យថា **ភាពជាអ្នកមិនត្រេកអរក្នុងរាងកាយ និងជីវិត** គឺបូលទៅតាំងទុកនូវចិត្ត មិនមានការត្រេកអរក្នុងរាងកាយរបស់ខ្លួន ដែលប្រៀបដូចជាសាកសពមិនមានវិញ្ញាណខាងក្រៅ ដោយជារបស់មិនស្អាត ជីវិតដែលប្រៀបដូចសត្រូវនាំវត្ថុមិនជាប្រយោជន៍មកឲ្យ ។ ពាក្យថា **ដោយការសង្កត់ចេញទៅក្នុងកាយ និងចិត្តនោះ**

សេចក្តីថា ព្រះយោគីរមែងសង្កត់ទុក្ខដែលកើតហើយដោយវីរិយៈ ដោយការឲ្យដល់នូវភាពចាស់ក្លានៃឥន្ទ្រិយទាំងឡាយ ញ៉ាំងការនាឲ្យដល់ព្រមដោយមិនត្រេកអរក្នុងរាងកាយ និងជីវិតនោះ ។ ពាក្យថា **ក្នុងចន្លោះ** គឺក្នុងចន្លោះនៃការសម្រេចការនាតាមដែលប្រាថ្នា ។ ពាក្យថា **ដោយមិនលះបង់** គឺដោយមិនរារែក ។

បទថា **ឯវំ វុត្តានំ** ប្រែថា ដែលពោលទុកយ៉ាងនេះ គឺដែលពោលទុកក្នុងអដ្ឋកថាដោយន័យជាដើមថា **ឥន្ទ្រិយរមែងចាស់ក្លា ដោយអាការ ៩ យ៉ាង** ដូច្នេះ ។ ក្នុងអធិការនេះ ប្រៀបដូចក្នុងការបោះកែវមុក្តា និងកែវប្រវាឡជាដើម ដែលប្រណីតត្រូវមានគ្រឿងបោះដែលល្អិតក្រៃពេក យ៉ាងណា ក្នុងការកំណត់រូបធម៌ និងអរូបធម៌ដែលល្អិតសុខុម និងក្នុងការកំណត់បច្ច័យនៃរូបធម៌ និងអរូបធម៌ ដែលចាំបាច់ត្រូវមានញាណដែលចាស់ក្លា ដូច្នោះដែរ តែក្នុងការឃើញការអស់ទៅ និងសូន្យទៅរបស់រូបធម៌ និងអរូបធម៌ទាំងនោះ ចាំបាច់មានញាណដែលចាស់ក្លាក្រៃលែង ។ ឯញាណនោះ ជាធម្មជាតិចាស់ក្លាក្រៃលែង ដែលបណ្ឌិតគប្បីឲ្យសម្រេច ដោយការធ្វើឲ្យឥន្ទ្រិយដល់នូវភាពចាស់ក្លា ដោយការឲ្យដល់នូវភាពស្រួចទុក ដូចការមុតនៃពូថៅជាវត្ថុដែលមុតដោយធ្វើការសំលៀងត្រង់ថ្មសំលៀង ដូច្នោះ ។ ឯការញ៉ាំងឥន្ទ្រិយឲ្យដល់នូវភាពចាស់ក្លានោះ រមែងមានដោយអាការ ៩ ណា ក្នុងអាការ ៩ នោះលោកអាចារ្យពោលការឃើញអាការបែកធ្លាយគ្រប់ៗ ខណៈនៃសង្ខារដែលមាននៅក្នុងខណៈដំបូងថា **ព្រះយោគីរមែងឃើញការអស់ទៅ តែម្យ៉ាងរបស់សង្ខារ ដែលកើតឡើងហើយ កើតឡើងទៀត** ។ កាលញាណដែលជាធម្មជាតិចាស់ក្លាក្រៃលែងមិនមាន លោកក៏ពោលឥន្ទ្រិយដ៏សេសដែលចាស់ក្លា ព្រោះជាអង្គប្រកបរបស់ញាណនោះខ្លះ ព្រោះការមិនប្រាសគ្នាខ្លះ ដោយមិនមានញាណចាស់ក្លាក្រៃលែងនោះ ។ ស័ព្ទថា **សក្កច្ចកិរិយា** ជាដើម ជាការសម្តែងឧបាយរបស់នាមនោះ ។ **វៀរអសប្បាយ** មាន

គោជនជាដើម ដោយអំណាចការមិនចូលទៅប្រកបជាដើម **សេចសប្បាយ** តែល្មមប្រមាណ ។ ព្រោះមិនត្រូវសម្ពន្ធរួមគ្នា ដោយហេតុដែលរូបធម៌ និងអរូបធម៌ មានការផ្សេងគ្នាយ៉ាងពិតប្រាកដ ហើយព្រោះក្នុងទីនេះ លោកមិនបានប៉ងយកសម្ពន្ធៈយ៉ាងនោះ ទើបលោកអាចារ្យពោលថា **ពិចារណារូបតាមកាល ពិចារណាអរូបតាមកាល** ដូច្នេះ សូម្បីក្នុងរូប និងអរូបទាំងនោះ ព្រោះភាពដែលរូបជាវត្ថុគប្បីយល់បានងាយ ព្រោះជារបស់គ្រោតគ្រាត ទើបលោកពោលថា គួរពិចារណាមុន ។ ពាក្យថា **គួរមើលការកើត** សេចក្តីថា គួរមើលដោយការគិតយកតាមគន្លងព្រះបាលី ដែលមកខាងដើមមុន ។ បន្ទាប់អំពីនោះ ទើបប្រាកដដោយប្រចក្ស ក្នុងការនាញាណ ដែលដល់កម្លាំងដោយលំដាប់ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## រូបសម្មសនៈ-ពិចារណារូបតាមកាល

## ការកើតរបស់រូប

ព្រះយោគាវចរដែលពិចារណារូប គួរមើលការកើតរបស់រូប ការកើតរបស់រូបនេះដូចម្តេច ? រូបនេះ រមែងកើតអំពីហេតុ ៤ ប្រការ ដោយអំណាចហេតុ មានកម្មជាដើម ។ ក្នុងហេតុ ៤ ប្រការនោះ រូបរបស់សត្វទាំងឡាយ កាលកើត រមែងកើតអំពីកម្មជាដំបូង ។

ក្នុងបដិសន្ធិក្ខណៈនោះឯង ( ពោល ) សម្រាប់ពួកគព្ភសេយ្យកសត្វមុន រូប ៣០ បានដល់ វត្ថុទសកៈ កាយទសកៈ និងភាវទសកៈ រមែងកើតដោយអំណាចសន្តតិ ៣ ។ រូបទាំងនោះឯង ក៏កើតក្នុងឧប្បាទក្ខណៈ នៃបដិសន្ធិចិត្តនោះឯង សូម្បីក្នុងឋិតិក្ខណៈ ក្នុងភង្គក្ខណៈ ក៏ដូចគ្នាក្នុងឧប្បាទក្ខណៈនោះដែរ ។ ក្នុងរូប និងចិត្តនោះ រូបជាធម្មជាតិរលត់យឺត ប្រែប្រួលយឺតយូរ ចិត្តជាធម្មជាតិរលត់រហ័ស ប្រែប្រួលរហ័ស ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញធម្មជាតិដទៃត្រឹមតែ ១ ដែលប្រែប្រួលរហ័ស ដូចចិត្តនេះឡើយ** ដូច្នេះ ព្រោះកាលរូបកំពុងតាំងនៅនោះឯង ភវង្គចិត្តកើត ហើយរលត់ដល់ទៅ ១៦ ដង សូម្បីឧប្បាទក្ខណៈ ឋិតិក្ខណៈ ភង្គក្ខណៈនៃចិត្តក៏ដូចគ្នា តែឧប្បាទក្ខណៈ និងភង្គក្ខណៈនៃរូបនោះឯង ជាខណៈរហ័ស ដូចគ្នានឹងឧប្បាទក្ខណៈ និងភង្គក្ខណៈនៃចិត្តដែរ ចំណែកឋិតិក្ខណៈ ( នៃរូប ) ជាខណៈធំ រមែងប្រព្រឹត្ត ទៅប៉ុនវេលាចិត្ត ១៦ ដួងកើត ហើយរលត់ទៅ ភវង្គចិត្តដួងទី ២ រមែងអាស្រ័យ វត្ថុរូបដែលកើតមុន ដែលកើតឡើងក្នុងឧប្បាទក្ខណៈនៃបដិសន្ធិចិត្ត ដល់នូវការតាំងនៅ គឺឋិតិក្ខណៈ ហើយ

*កើតឡើង កវេគ្គចិត្តដួងទី ៣ រមែងអាស្រ័យវត្ថុរូប ដែលកើតមុន ដែលកើតឡើងព្រមជាមួយកវេគ្គចិត្តដួងទី ២ នោះ ដល់នូវការតាំងនៅ កើតឡើង ការប្រព្រឹត្តទៅនៃចិត្តរហូតអស់អាយុ គប្បីជ្រាបដោយន័យនេះឯង ។*

*តែសម្រាប់សត្វដែលជិតស្លាប់ ចិត្ត ១៦ ដួង អាស្រ័យវត្ថុរូបដែលកើតមុនដល់នូវការតាំងនៅហើយដូចគ្នានោះឯង កើតឡើងបាន រូបដែលកើតក្នុងឧប្បាទក្ខណៈនៃបដិសន្ធិចិត្ត រមែងរលត់ទៅព្រមជាមួយចិត្តដួងទី ១៦ បន្ទាប់អំពីបដិសន្ធិចិត្តទៅ រូបដែលកើតក្នុងឋានខណៈ គឺឋិតិក្ខណៈនៃបដិសន្ធិចិត្ត រមែងរលត់ទៅព្រមជាមួយនឹងឧប្បាទក្ខណៈនៃចិត្តដួងទី ១៧ រូបដែលកើតក្នុងភង្គក្ខណៈនៃបដិសន្ធិចិត្ត ដល់ឋានខណៈនៃចិត្តដួងទី ១៧ រមែងរលត់ ឈ្មោះថា* ***បវត្តិ*** *នៅមានដរាបណា រូបក៏រមែងប្រព្រឹត្តទៅយ៉ាងនេះ ដរាបនោះឯង ។*

*សូម្បីសម្រាប់ពួកឱបបាតិកសត្វ រូប ៧០ រមែងប្រព្រឹត្តទៅដោយអំណាចសន្តតិ ៧ យ៉ាងនោះដូចគ្នា ។*

## វិភាគនៃកម្មជរូប

*ក្នុងការប្រព្រឹត្តទៅ នៃរូបដែលកើតអំពីកម្មនោះ បណ្ឌិតគប្បីជ្រាបវិភាគនេះ គឺកម្ម ១ រូបដែលមានកម្មជាសមុដ្ឋាន ១ រូបដែលមានកម្មជាបច្ច័យ ១ រូបដែលមានចិត្ត និងកម្មជាបច្ច័យជាសមុដ្ឋាន ១ រូបដែលមានអាហារ និងកម្មជាបច្ច័យជាសមុដ្ឋាន ១ រូបដែលមានឧតុ និងកម្មជាបច្ច័យជាសមុដ្ឋាន ១ ។*

*ក្នុងវិភាគទាំងនោះ កុសលចេតនា និងអកុសលចេតនា ឈ្មោះថា កម្ម ។*

*វិបាកក្ខន្ធទាំងឡាយ និងរូប ៧០ មានចក្ខុទសកៈជាដើម ឈ្មោះថា រូបមានកម្មជាសមុដ្ឋាន ។*

វិបាកក្ខន្ធ និងរូប ៧០ នោះឯង ឈ្មោះថា **រូបមានកម្មជាបច្ច័យ** ព្រោះថា កម្មរមែងជាឧបត្ថម្ភកប្បច្ច័យនៃរូបដែលមានកម្មជាសមុដ្ឋានផងដែរ ។

រូបដែលមានវិបាកចិត្តជាសមុដ្ឋាន ឈ្មោះថា **រូបមានចិត្តដែលមានកម្មជាបច្ច័យជាសមុដ្ឋាន** ។

ឱជា ដែលដល់នូវការតាំងនៅហើយ ក្នុងរូបដែលមានកម្មជាសមុដ្ឋានទាំងឡាយ រមែងញុំាងឱជដ្ឋមករូបដទៃឲ្យតាំងឡើង ឱជាក្នុងឱជដ្ឋមករូបនោះឯង ដែលដល់នូវការតាំងនៅហើយ ក៏ញុំាងឱជដ្ឋមករូបដទៃឲ្យតាំងឡើង បន្តការប្រព្រឹត្តទៅ ៤-៥ តំណាក់ ដោយន័យដូចពោលមក ដូច្នេះ ឈ្មោះថា **រូបមានអាហារដែលមានកម្ម ជាបច្ច័យជាសមុដ្ឋាន** ។

តេជោធាតុដែលកើតអំពីកម្ម ដល់នូវការតាំងនៅហើយ រមែងញុំាងឱជដ្ឋមករូបដែលមានឧតុជាសមុដ្ឋានឲ្យតាំងឡើង ឧតុក្នុងឱជដ្ឋមករូបនោះឯង ក៏ញុំាងឱជដ្ឋមករូបដទៃឲ្យតាំងឡើង បន្តការប្រព្រឹត្តទៅ ៤-៥ តំណាក់ ដោយន័យដូចពោលមក ដូច្នេះ ឈ្មោះថា **រូបមានឧតុដែលមានកម្មជាបច្ច័យជាសមុដ្ឋាន** ។

ការកើតនៃកម្មជរូប បណ្ឌិតគប្បីឃើញដូចពោលមក ដូច្នេះ ជាលំដាប់ដំបូង ។

## វិភាគនៃចិត្តជរូប

សូម្បីក្នុងចិត្តជរូបទាំងឡាយ គប្បីជ្រាបវិភាគ ( ដូច ) នេះ គឺចិត្ត ១ រូបដែលមានចិត្តជាសមុដ្ឋាន ១ រូបដែលមានចិត្តជាបច្ច័យ ១ រូបដែលមានអាហារ និងចិត្តជាបច្ច័យជាសមុដ្ឋាន ១ រូបដែលមានឧតុ និងចិត្តជាបច្ច័យជាសមុដ្ឋាន ១ ។

ក្នុងវិភាគទាំងនេះ ចិត្ត ៨៩ ដួង ឈ្មោះថា **ចិត្ត** ក្នុងចិត្តទាំងនោះ ចិត្ត ៣២ ( ចំណែក ១ ) ចិត្ត ២៦ ( ចំណែក ១ ) ចិត្ត ១៩ ( ចំណែក ១ ) ចិត្ត ១៦ ( ចំណែក ១ )

បណ្ឌិតជ្រាបថា ជាចិត្តញុំាងរូប ឥរិយាបថ និងវិញ្ញត្តិឲ្យកើត ( ក៏មាន ) មិនញុំាង រូបឥរិយាបថ និងវិញ្ញត្តិឲ្យកើត ( ក៏មាន ) ។

ពង្រីកសេចក្តីថា ដោយកាមាវចរចិត្ត ចិត្ត ៣២ គឺកុសលចិត្ត ៨ អកុសលចិត្ត ១២ កិរិយាចិត្ត ១០ ( វៀរមនោធាតុ ) អភិញ្ញាចិត្ត ២ ដែលជាកុសល និងកិរិយា ញុំាងរូបឥរិយាបថ និងវិញ្ញត្តិឲ្យកើតបាន ។

ចិត្ត ២៦ គឺកាមាវចរចិត្ត ១០ ដ៏សេស វៀរវិបាកចិត្ត អរូបាវចរចិត្ត ៨ និង លោកុត្តរចិត្ត ៨ ទៀត ញុំាងរូប និងឥរិយាបថឲ្យកើតបាន តែមិនញុំាងវិញ្ញត្តិឲ្យ កើតឡើយ ។

ចិត្ត ១៩ គឺភវង្គចិត្ត ១០ ក្នុងកាមាវចរ ភវង្គចិត្ត ៥ ក្នុងរូបាវចរ មនោធាតុ ៣ អហេតុកវិបាកមនោវិញ្ញាណធាតុដែលជាវិបាកជាសោមនស្សសហគតៈ ១ ញុំាង រូបឯណា នីមួយឲ្យកើត មិនញុំាងឥរិយាបថឲ្យកើត មិនញុំាងវិញ្ញត្តិឲ្យកើត ។

ចិត្ត ១៦ គឺបញ្ចវិញ្ញាណ ២ ( ជា ១០ ) បដិសន្ធិចិត្តនៃសត្វទាំងឡាយ ១ ចុតិចិត្តនៃព្រះខីណាស្រពទាំងឡាយ ១ អរូបវិបាកចិត្ត ៤ មិនញុំាងរូបឲ្យកើត មិនញុំាងឥរិយាបថឲ្យកើត មិនញុំាងវិញ្ញត្តិឲ្យកើតឡើយ ។

ម្យ៉ាងទៀត ក្នុងចិត្តទាំងនេះ ចិត្តណាញុំាងរូបឲ្យកើតបាន ចិត្តនោះ ក៏មិនបាន ញុំាងរូបឲ្យកើតក្នុងឋិតិក្ខណៈ ឬភង្គក្ខណៈ ព្រោះចិត្តក្នុងខណៈ ( ទាំង ២ ) នោះ ជាចិត្តខ្សោយកម្លាំង តែចិត្តក្នុងឧប្បាទក្ខណៈ ជាចិត្តមានកម្លាំង ព្រោះហេតុនោះ ចិត្តដែលអាស្រ័យវត្ថុរូបដែលកើតមុន ក្នុងខណៈនោះ ទើបញុំាងរូបឲ្យកើតបាន ។

អរូបក្ខន្ធ ៣ និងរូប ១៧ យ៉ាង គឺសទ្ទនវករូប ៩ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ លហុតា មុទុតា កម្មញ្ញតា ឧបចយ សន្តតិ ឈ្មោះថា រូបមានចិត្ត ជាសមុដ្ឋាន ។

រូបមានសមុដ្ឋាន ៤ ដែលពោលទុក ដូច្នេះថា ចិត្ត ចេតសិកធម៌ទាំងឡាយ ដែលកើតខាងក្រោយ រមែងជាបច្ច័យដោយបច្ឆាជាតប្បច្ច័យនៃកាយនេះ ដែលកើតមុន ឈ្មោះថា **រូបមានចិត្តជាបច្ច័យ** ។

ឱជារូប ដែលដល់នូវការតាំងនៅហើយ ក្នុងរូបដែលមានចិត្តជាសមុដ្ឋានទាំងឡាយ ញ៉ាំងឱជដ្ឋមករូបដទៃឲ្យតាំងឡើង បន្តការប្រព្រឹត្តទៅដោយន័យដូច្នេះ ២-៣ តំណាក់ ឈ្មោះថា **រូបមានអាហារដែលមានចិត្តជាបច្ច័យ** ជាសមុដ្ឋាន ។

ឧតុដែលមានចិត្តជាសមុដ្ឋានដល់នូវការតាំងនៅហើយ ញ៉ាំងឱជដ្ឋមករូបដទៃឲ្យតាំងឡើង បន្តការប្រព្រឹត្តទៅដោយន័យដូច្នេះ ២-៣ តំណាក់ ឈ្មោះថា **រូប មានឧតុដែលមានចិត្តជាបច្ច័យ** ជាសមុដ្ឋាន ។

ការកើតនៃចិត្តជរូប បណ្ឌិតគប្បីឃើញដូចពោលមក ដូច្នេះ ។

## វិភាគនៃអាហារជរូប

សូម្បីក្នុងអាហារជរូបទាំងឡាយ ក៏គប្បីជ្រាបវិភាគដូច្នេះ គឺអាហារ ១ រូបដែលមានអាហារជាសមុដ្ឋាន ១ រូបដែលមានអាហារជាបច្ច័យ ១ រូបដែលមានអាហារដែលមានអាហារ ( ជាមួយគ្នា ) ជាបច្ច័យជាសមុដ្ឋាន ១ រូបដែលមានឧតុ និងអាហារជាបច្ច័យជាសមុដ្ឋាន ១ ។

ក្នុងវិភាគទាំងនោះ កពឡិង្ការាហារ ឈ្មោះថា **អាហារ** ។

រូប ១៤ យ៉ាង គឺឱជដ្ឋមករូប ដែលឱជាបានកម្មជរូប មានចិត្តគ្រប់គ្រងជាបច្ច័យហើយ តាំងនៅក្នុងកម្មជរូបនោះ ដល់នូវការតាំងនៅ ហើយឲ្យតាំងឡើង ( ជាគម្រប់ ៨ ) អាកាសធាតុ លហុតា មុទុតា កម្មញ្ញតា ឧបចយ សន្តតិ ឈ្មោះថា **រូបមានអាហារជាសមុដ្ឋាន** ។

រូបមានសមុដ្ឋាន ៤ ដែលពោលទុក ដូច្នេះថា **កពឡិង្ការាហារ ជាបច្ច័យ ដោយជាអាហារប្បច្ច័យនៃកាយនេះ** ឈ្មោះថា **រូបមានអាហារជាបច្ច័យ** ។

ឱជា ដែលដល់នូវការតាំងនៅ ហើយក្នុងរូបដែលមានអាហារជាសមុដ្ឋានទាំងឡាយ រមែងញ៉ាំងឱជដ្ឋមករូបដទៃឲ្យតាំងឡើង ឱជាក្នុងឱជដ្ឋមករូបនោះឯងក៏ញ៉ាំងឱជដ្ឋមករូបដទៃឲ្យតាំងឡើង បន្តការប្រព្រឹត្តទៅ ១០-១២ តំណាក់ ដោយន័យដូចពោលមកដូច្នេះ ឈ្មោះថា **រូបមានអាហារដែលមានអាហារ ( ជាមួយគ្នា ) ជាបច្ច័យ ជាសមុដ្ឋាន** ព្រោះអាហារដែលបរិភោគចូលទៅក្នុងមួយថ្ងៃ រមែងឧបការៈបានមួយសប្តាហ៍ ចំណែកឱជាដែលជាទិព្វឧបការៈបានមួយខែ ឬពីរខែ សូម្បីអាហារដែលមាតាបរិភោគចូលទៅ ក៏ផ្សាយទៅដល់សរីរៈរបស់ទារក (ក្នុងគភ៌) ញ៉ាំងរូបរបស់ទារកឲ្យតាំងឡើងបានសូម្បីអាហារដែលលាបត្រង់សរីរៈក៏ញ៉ាំងរូបឲ្យតាំងឡើងបាន ។ អាហារដែលកើតអំពីកម្ម ឈ្មោះថា **ឧបាទិន្នកាហារ** សូម្បីឧបាទិន្នកាហារនោះដែលដល់នូវការតាំងនៅហើយ រមែងញ៉ាំងរូប ឲ្យតាំងឡើង ឱជាក្នុងរូបនោះសោតក៏ញ៉ាំងរូបដទៃឲ្យតាំងឡើងតទៅ បន្តការប្រព្រឹត្តទៅ ៤-៥ តំណាក់ ដោយន័យដូចពោលមកដូច្នេះ ក៏ឈ្មោះថា **រូបមានអាហារដែលមានអាហារជាបច្ច័យ** ជាសមុដ្ឋាន ។

តេជោធាតុ ដែលមានអាហារជាសមុដ្ឋាន ដល់នូវការតាំងនៅហើយ រមែងញ៉ាំងឱជដ្ឋមករូប ដែលមានឧតុជាសមុដ្ឋានឲ្យតាំងឡើង ឈ្មោះថា **រូបមានឧតុ ដែលមានអាហារ ជាបច្ច័យ** ជាសមុដ្ឋាន ។

ក្នុងសមុដ្ឋានទាំងនោះ អាហារនេះជាបច្ច័យនៃរូប ដែលមានអាហារជាសមុដ្ឋានទាំងឡាយ ដោយជាសភាវៈដែលឲ្យកើតជាបច្ច័យនៃរូបដ៏សេស ( គឺរូបដែលមានកម្ម ចិត្ត ឧតុ ជាសមុដ្ឋាន ) ដោយជានិស្សយប្បច្ច័យ អាហារប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដូច្នេះ ។

ការកើតនៃអាហារជរូប បណ្ឌិតគប្បីឃើញដូចពោលមក ដូច្នេះ ។

## វិភាគនៃឧតុជរូប

សូម្បីក្នុងឧតុជរូបទាំងឡាយ ក៏គប្បីជ្រាបវិភាគដូច្នេះ គឺឧតុ ១ រូបដែលមានឧតុជាសមុដ្ឋាន ១ រូបដែលមានឧតុជាបច្ច័យ ១ រូបដែលមានឧតុមានឧតុ ( ជាមួយគ្នា ) ជាបច្ច័យជាសមុដ្ឋាន ១ រូបដែលមានអាហារ និងឧតុជាបច្ច័យ ជាសមុដ្ឋាន ១ ។

ក្នុងវិភាគទាំងនោះ តេជោធាតុដែលមានសមុដ្ឋាន ៤ ឈ្មោះថា **ឧតុ** ឯឧតុនោះមាន ២ យ៉ាង ដូច្នេះ គឺឧណ្ហឧតុ សីតឧតុ ។

ឧតុដែលមានសមុដ្ឋាន ៤ បានឧបាទិន្នករូបជាបច្ច័យ ដល់នូវការតាំងនៅ ហើយរមែងញ៉ាំងរូបឲ្យតាំងឡើងក្នុងសរីរៈ ( រូបនោះ ) ឈ្មោះថា **រូបមានឧតុជាសមុដ្ឋាន** រូបមានឧតុជាសមុដ្ឋាននោះ មាន ១៥ យ៉ាង ( គឺសទ្ទនវករូប ៩ ) អាកាស លហុតា មុទុតា កម្មញ្ញតា ឧបចយ សន្តតិ ។

ឧតុរមែងជាបច្ច័យនៃការប្រព្រឹត្តទៅ និងការវិនាសរបស់រូប ដែលប្រកបដោយសមុដ្ឋានទាំងឡាយ ៤ ( រូបដែលប្រកបដោយសមុដ្ឋាន ៤ នោះ ) ឈ្មោះថា **រូបមានឧតុជាបច្ច័យ** ។

តេជោធាតុ ដែលមានឧតុជាសមុដ្ឋាន ដល់នូវការតាំងនៅ ហើយរមែងញ៉ាំងឱជដ្ឋមករូបដទៃឲ្យតាំងឡើង ឧតុក្នុងឱជដ្ឋមករូបនោះឯង ក៏ញ៉ាំងឱជដ្ឋមករូបដទៃឲ្យតាំងឡើង ( តទៅទៀត ) រូបដែលមានឧតុជាសមុដ្ឋាន សូម្បីតាំងនៅក្នុងចំណែកអនុបាទិន្នករូប ហើយក៏នៅប្រព្រឹត្តទៅនោះបានយូរៗ ដោយន័យដូចពោលមកដូច្នេះ ឈ្មោះថា **រូបមានឧតុដែលមានឧតុ ( ដូចគ្នា ) ជាបច្ច័យ ជាសមុដ្ឋាន** ។

ឱជា ដែលមានឧតុជាសមុដ្ឋាន ដល់នូវការតាំងនៅ ហើយរមែងញ៉ាំងឱជដ្ឋមក

រូបជាទីទេឲ្យតាំងឡើងមករូបនោះឯងក៏ញុំាងឱជដ្ឋមករូបជាទីទេឲ្យតាំងឡើង (តទៅទៀត) បន្តការប្រព្រឹត្តទៅ ១០-១២ តំណាក់ ដោយន័យដូចពោលដូច្នេះ ឈ្មោះថា **រូបមានអាហារដែលមានឧតុជាបច្ច័យ** ជាសមុដ្ឋាន ។

ក្នុងសមុដ្ឋានទាំងនោះ ឧតុនេះ ជាបច្ច័យនៃរូបដែលមានឧតុជាសមុដ្ឋានទាំងឡាយ ព្រោះជាសភាវៈដែលឲ្យកើតជាបច្ច័យនៃរូបដ៏សេស ( គឺរូបដែលមានកម្ម ចិត្ត អាហារ ជាសមុដ្ឋាន ) ដោយជានិស្សយបច្ច័យ អត្ថិបច្ច័យ និងអវិគតបច្ច័យ ដូច្នេះ ការកើតនៃឧតុជរូប បណ្ឌិតគប្បីឃើញដូចពោលមកដូច្នេះ ។

ព្រះយោគាវចរ ពិចារណាការកើតរបស់រូប ដោយន័យដូចពោលមកនេះឯង ឈ្មោះថា **ពិចារណារូបតាមកាល** ។

# មហាដីកា

## កថាពណ៌នាដោយអាការពិចារណា

## ការកើតរបស់រូប

ពាក្យថា **ទាំងពួង** គឺរបស់សត្វទាំងឡាយ ដែលផ្សេងដោយប្រភេទ មានកាមាវចរជាដើម និងមានសត្វអណ្ឌជកំណើតជាដើម ។ ឈ្មោះថា **រមែងកើតអំពីកម្មជាដំបូង** ព្រោះរូប មានឧតុជាដើម មានកម្មជរូបនោះជាមូល ។ លោកអាចារ្យពោលថា **ដោយអំណាចសន្តតិ ៣** ដូច្នេះ សំដៅយកការបន្ត ៣ យ៉ាង ដែលបានដោយអំណាចកាយទសកៈជាដើម ដែលប្រព្រឹត្តទៅខាងមុខ ឬសំពួដែលជាប្រធានគឺសន្តតិ ។

ការរលត់នៃរូបនេះ យឺត គឺខ្សោយ យឺតយូរ ហេតុនោះ រូបនេះ ឈ្មោះថា **ទន្ធនិរោធំ** ប្រែថា មានការរលត់យឺត ព្រោះរូបមានអាយុ ១៧ ខណៈចិត្ត ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ផ្លាស់ប្តូរធ្ងន់** ។ ពាក្យថា **ដោយហេតុនោះ** គឺព្រោះហេតុនោះ អធិប្បាយថា ព្រោះរូបធម៌ទាំងឡាយ មានកាលបន្តិចបន្តួចប៉ុណ្ណោះ ដោយមានព្រះបាលីថា **ម្នាលភិក្ខុទាំងឡាយ អាយុសង្ខារ រមែងអស់ទៅរហ័សក្រៃលែងជាងនោះឯង** ដូច្នេះ តែអរូបធម៌ទាំងឡាយ នៅមានកាលបន្តិចបន្តួចក្រៃលែងជាងរូបធម៌ទាំងនោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ទុក ។ ពាក្យដែលគួរពោលក្នុងរឿងនេះ ពាក្យនោះ ខ្ញុំធ្វើឲ្យពិស្តារហើយខាងដើមនោះឯង ។ ពីរបទថា **តេហិ សទិសា** ប្រែថា ដូចគ្នានឹងឧប្បាទក្ខណៈ និងភង្គក្ខណៈនៃចិត្តនោះ ។ ឯសង្ខារទាំងពួងមិនមានការប្លែកគ្នា ក្នុងឧប្បាទក្ខណៈ និងភង្គក្ខណៈ សង្ខារទាំងនោះ មានកាលប៉ុណ្ណោះនោះឯង ។ បទថា **ឋានប្បត្តំ** សេចក្តីថា ដល់ឋិតិក្ខណៈ ។ បទថា **តេន**

**យោគ ទុតិយកង្គចិត្តេន** ប្រែថា ដោយកង្គចិត្តដួងទី ២ នោះ ។ វត្ថុរូបជាទីអាស្រ័យរបស់ចិត្ត ១ ដួងហើយ រមែងមិនជាទីអាស្រ័យរបស់ចិត្តដួងដទៃឡើយ វៀរតែបុគ្គលដែលជិតស្លាប់ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ជាមួយដោយកង្គចិត្តដួងទី ២ នោះ** ជាដើម ។

លោកអាចារ្យកាលសម្តែងការកើតរបស់រូបនោះ ផ្តើមអំពីបដិសន្ធិរហូតដល់ការកើតនៃចុតិចិត្តយ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងសម្តែងការរលត់ ទើបផ្តើមពាក្យថា **នៃបដិសន្ធិចិត្ត** ជាដើម ។ ពាក្យថា **ក្នុងឋានខណៈ** គឺក្នុងឋិតិក្ខណៈនៃបដិសន្ធិចិត្តនោះ ។ ពាក្យថា **ឈ្មោះថា បវត្តិមានដរាបណា** សេចក្តីថា ឈ្មោះថា **សន្តានប្បវត្តិ** មានដរាបណា ឬឈ្មោះថា **បវត្តិនៃចិត្តមានដរាបណា** ។ ក្នុងការឧប្បត្តិរបស់អសញ្ញសត្ត មិនមានចិត្តប្បវត្តិ ដូច្នេះ ។ ក្នុងការឧប្បត្តិរបស់រូបាវចរសត្វពួកដែលជាសំសេទជៈ ក៏ដូចគ្នានឹងឱបបាតិកៈ ហេតុនោះ ទើបលោកកាន់យកពួកឱបបាតិកៈតែម្យ៉ាង ។ ម្យ៉ាងទៀត ដោយ បិ-ស័ព្ទ ក្នុងស័ព្ទថា **ឱបបាតិកានម្បិ** ( សម្រាប់ពួកឱបបាតិកសត្វ ) លោកអាចារ្យរមែងប្រមូលយកជំពូកសំសេទជៈផងដែរ ។ ពាក្យថា **ដោយអំណាចសន្តតិ ៧ យ៉ាង** គឺដោយអំណាចស័ព្ទ ដែលជាប្រធាន គឺសន្តតិ ៧ យ៉ាង មានចក្ខុទសកៈជាដើម ។

បទថា **តត្ថ យោគ កម្មតោ រូបប្បវត្តិយំ** ប្រែថា ក្នុងការប្រព្រឹត្តទៅនៃរូបអំពីកម្មនោះ ។ កម្មដែលជាបច្ច័យមានក្នុងខណៈផ្សេងៗ គ្នានោះឯង លោកមានបំណងយកថា **កម្ម** ក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **កុសលចេតនានិងអកុសលចេតនា** ឈ្មោះថា **កម្ម** ។ លោកអាចារ្យពោលថា **រូប ៧០** ដូច្នេះ ព្រោះធ្វើជីវិតនវករូបឲ្យឈមចុះក្នុងចក្ខុទសកៈជាដើមនោះឯង ។ ម្យ៉ាងទៀត ជីវិតនវករូបនោះមិនជារូបដែលកំណត់បានងាយ ដូចចក្ខុទសកៈជាដើមឡើយ ។ លោកអាចារ្យ

ពោលដល់វិបាកក្ខន្ធ និងកដត្តារូបតាមដែលពោលហើយថា **តទេវ** ។ ព្រោះថា កម្មជាធម្មជាតិញ៉ាំងកម្មជរូបឲ្យកើត ទាំងជួយកម្ចាជីវិតិន្ទ្រិយផង ព្រោះមានការតាមរក្សាដោយអំណាចភ្លើង ដែលកើតអំពីកម្ម និងព្រោះជានិមិត្តនៃឧបត្ថម្ភកប្បច្ច័យ ដោយជាហេតុនៃការបានអាហារជាដើម ដោយហេតុនោះ ទើបលោកអាចារ្យពោលថា រមែងជាឧបត្ថម្ភកប្បច្ច័យ ។ គប្បីជ្រាបភាពដែលកម្មនោះ ជាឧបត្ថម្ភកប្បច្ច័យ ដោយជាឧបនិស្សយប្បច្ច័យនោះឯង ។ កម្មជាបច្ច័យដល់ធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះឈ្មោះថា **កម្មប្បច្ចយំ** ប្រែថា មានកម្មជាបច្ច័យ បានដល់ ចិត្តដែលមានកម្មជាបច្ច័យនោះឯង ចិត្តមានកម្មជាបច្ច័យនោះជាសមុដ្ឋាននៃរូបនោះ ហេតុនោះ រូបនេះ ឈ្មោះថា **កម្មប្បច្ចយចិត្តសមុដ្ឋានំ** ប្រែថា រូបដែលមានចិត្ត មានកម្មជាសមុដ្ឋានជាបច្ច័យ បណ្ឌិតគប្បីពោលចេតសិក ដែលជាវិបាកទាំងឡាយថា មានចិត្តដែលមានកម្មជាបច្ច័យជាសមុដ្ឋាន ឬមិនគប្បីពោលខ្លះ ព្រោះលោកកាន់យក ដោយសព្ទថា **រូបមានកម្មជាសមុដ្ឋាន** និង **រូបមានកម្មជាបច្ច័យ** បណ្ឌិតគប្បីកាន់យកថា **ឱជារូបដែលដល់នូវការតាំងនៅ រមែងញ៉ាំងឱជដ្ឋមករូបដទៃឲ្យតាំងឡើង** ក្នុងសរីរៈ ដែលមានអាហារជ្រួតជ្រាបទៅតាម ។ បទថា **តត្រាបិ យោគ ឱជដ្ឋមកេ** ប្រែថា ក្នុងឱជដ្ឋមករូបនោះ គឺដែលមានកម្មជាសមុដ្ឋាន និងមានអាហារជាសមុដ្ឋាន ។ ពាក្យថា **បន្តការប្រព្រឹត្តទៅ ៤-៥ វារៈ** សេចក្តីថា បន្តការប្រព្រឹត្តទៅនៃរូបកលាបៈ ៤-៥ វារៈ ដោយអំណាចសន្តតិដែលដូចគ្នា ។ អាចារ្យទាំងឡាយ រមែងពោលថា តែងបន្តការប្រព្រឹត្តទៅសូម្បីច្រើន ដែលផ្សេងគ្នា ដោយការប្លែកគ្នានៃបច្ច័យខាងក្រៅ ។ ការបន្តដោយខ្សែស្រឡាយដោយបវេណី ក្នុងរូបដែលមានអាហារ ដែលមានកម្មជាបច្ច័យជាសមុដ្ឋានយ៉ាងណា សូម្បីក្នុងរូបដែលមានឧតុ ដែលមានកម្មជាបច្ច័យជាសមុដ្ឋាន ក៏មានការបន្តដោយបវេណីដូច្នោះដែរ ហេតុនោះ លោកអាចារ្យមានបំណងសម្តែងការបន្តដោយ

បវេណីក្នុងរូប ដែលមានឧតុ ដែលមានកម្មជាបច្ច័យជាសមុដ្ឋាននោះ ទើបពោលពាក្យជាដើមថា **ឈ្មោះថា រូបមានឧតុដែលមានកម្មជាបច្ច័យជាសមុដ្ឋាន** ដូច្នេះ ។ ហើយក្នុងអធិការនេះ អាចារ្យទាំងឡាយពោលថា អាចារ្យកាលសម្តែងការប្រព្រឹត្តទៅតៗ គ្នាក្នុងកោដ្ឋាសក្នុងរូបនោះៗ បានសម្តែងការប្រព្រឹត្តទៅនៃរូប មានលើកទី ២ ជាដើម ដែលមិនបានកើតអំពីកម្ម ដោយមិនលាយឡំគ្នាដោយប្រការណា ក៏គប្បីសម្តែងការប្រព្រឹត្តទៅនៃរូប ដោយអំណាចការលាយឡំគ្នាជាមួយឧតុ ដែលមានអាហារ ដែលកើតអំពីកម្មជាសមុដ្ឋាន ទាក់ទងជាមួយអាហារដែលមានឧតុ ដែលកើតអំពីកម្មជាសមុដ្ឋាន និងទាក់ទងជាមួយឧតុ និងអាហារ ដែលមានអាហារ និងឧតុដែលកើតអំពីចិត្ត ដែលមានកម្មជាបច្ច័យជាសមុដ្ឋាន ។ ក្នុងបណ្តារូបទាំងនោះ អាហារដែលប្រព្រឹត្តទៅអំពីកម្មជរូប ដែលមានការបានបច្ច័យដែលផ្សេងចេញទៅ បុគ្គលណាម្នាក់មិនអាចពោលបានថា មិនបន្តការប្រព្រឹត្តទៅក្រៃលែងឡើងជាងការប្រព្រឹត្តទៅ ដែលមានបរិមាណតាមដែលពោលហើយ ។ ពិតហើយ លោកអាចារ្យពោលតទៅថា **បន្តការប្រព្រឹត្តទៅ ១០-១២ វារៈ** ដូច្នេះ និងថា រូបមានឧតុជាសមុដ្ឋាន សូម្បីតាំងនៅក្នុងចំណែកអនុបាទិន្នករូប ហើយក៏នៅប្រព្រឹត្តទៅយូរៗ បាន តាមន័យដូចពោលមកដូច្នេះ ។ ពីរបទថា **ជនកាជនកា មតា** សេចក្តីថា ចិត្តដែលសង្គ្រោះដោយ ៣ ចំណែកខាងដើម បណ្ឌិតជ្រាបហើយ គឺដឹងហើយថា ជាចិត្តញ៉ាំងរូបឥរិយាបថ និងវិញ្ញត្តិឲ្យកើត ចិត្តដែលនៅក្នុងចំណែកខាងក្រោយ ដែលលោកពោលទុកថា **ចិត្ត ១៦ ដួង** បណ្ឌិតជ្រាបហើយ គឺដឹងហើយថា មិនញ៉ាំងរូបឥរិយាបថ និងវិញ្ញត្តិឲ្យកើតឡើង ។ បទថា **កុសលកិរិយតោ** ប្រែថា ដោយជាកុសល និងដោយជាកិរិយា ។ ឈ្មោះថា **ឥរិយាបថ** ព្រោះជាផ្លូវដោយជាទីតាំងនៃការទៅរបស់ការកម្រើករំកិល គឺកិរិយាផ្លូវកាយ បានដល់ ការដើរជាដើម ដោយអត្ថ បានដល់ ការប្រព្រឹត្តទៅរបស់រូបដែលកំណត់ចុះ

ដោយការកម្រើករំកិល មានការដើរជាដើមនោះ ។ ក្នុងការប្រព្រឹត្តទៅរបស់រូបនេះ ឥរិយាបថ និងវិញ្ញត្តិ មិនផុតទៅអំពីរូបឡើយ ដោយពិត សូម្បីយ៉ាងនោះ មិនមែនចិត្តដែលញ៉ាំងរូបឲ្យតាំងឡើងទាំងអស់ និងជាធម្មជាតិឧបត្ថម្ភឥរិយាបថ និងញ៉ាំងវិការគឺវិញ្ញត្តិឲ្យកើតនោះឡើយ ។ ចិត្តដួងណាញ៉ាំងវិញ្ញត្តិឲ្យកើត ចិត្តដួងនោះក៏ញ៉ាំងឥរិយាបថក្រៅអំពីនេះ ឲ្យកើតដោយចំណែកមួយ ព្រោះមិនប្រាសអំពីគ្នា ចិត្តដែលឧបត្ថម្ភឥរិយាបថ ក៏ញ៉ាំងរូបឲ្យកើតយ៉ាងនោះ ។ ដើម្បីសម្តែងការផ្សេងគ្នាក្នុងប្រការនេះ ទើបលោកអាចារ្យធ្វើការរួបរួមទុកថា **រូប ឥរិយាបថ** និង **វិញ្ញត្តិ** ។ ក្នុងពាក្យថា **វៀរវិបាកចិត្ត** នេះ គួរនឹងពោលថា វៀរវិបាកចិត្ត និងអភិញ្ញាចិត្តទាំង ២ ព្រោះចិត្តដទៃអំពីវិបាកចិត្ត និងអភិញ្ញាចិត្តទាំង ២ នោះឯង គប្បីកាន់យកដោយសព្ទថា **ចិត្តដ៏សេស** ។ ម្យ៉ាងទៀត ក៏មិនគួរពោល ព្រោះអភិញ្ញាចិត្ត ក៏គប្បីត្រូវបដិសេធទុកដោយសព្ទថា **ចិត្តដ៏សេសនោះឯង** ។ ឈ្មោះថា **មិនញ៉ាំងវិញ្ញត្តិឲ្យកើត** ព្រោះមហគ្គតកុសលជាដើម ជាធម្មជាតិមិនផ្សាយទៅ ដោយជាធម្មជាតិស្ងប់ ។ ឯចិត្តមានកាមាវចរកុសល ជាដើមដែលផ្សាយទៅប៉ុណ្ណោះ រមែងញ៉ាំងវិញ្ញត្តិឲ្យតាំងឡើង សូម្បីកាលមានភាព ជាធម្មជាតិស្ងប់ ចិត្តដែលជាធម្មជាតិឧបត្ថម្ភឥរិយាបថបាន ព្រោះមានឥស្សាហ៍ ដោយកម្លាំងរបស់ឈានទាំងនេះ ព្រោះជាជវនកិច្ចរបស់ចិត្តទាំងនោះ ។ សម្ពន្ធ សេចក្តីបាលីថា **បញ្ច ភវង្គចិត្តានិ** ប្រែថា ភវង្គចិត្ត ៥ ។ ឈ្មោះថា **ញ៉ាំងរូបតែម្យ៉ាងឲ្យកើត មិនញ៉ាំងឥរិយាបថឲ្យកើត** ព្រោះជាចិត្តខ្សោយកម្លាំងដោយជុំវិញ ព្រោះជាធម្មជាតិស្ងប់ មិនមានឧស្សាហ៍ ។ ជាទីតាំងចុះដោយការមិនញាប់ញ័រនៃអវយវៈរបស់សរីរៈ មាន.កជាដើម ក្នុងកាលដែលភវង្គប្រព្រឹត្តទៅមិនលាយឡំជាមួយចិត្តដែលសម្រេចដោយកិរិយា ។ ពិតហើយ កាលភវង្គដែលទុព្វលកំពុងប្រព្រឹត្តទៅ អវយវៈទាំងឡាយ រមែងលិចចុះដូចចូលទៅហើយ ។ តែកាលចិត្តភ្ញាក់ដែលពោលទុកដោយ

ពាក្យជាដើមថា **ចិត្ត ៣២** ដូច្នេះ កំពុងប្រព្រឹត្តទៅ អវយវៈទាំងឡាយ រមែងរឹងប៉ឹងប្រព្រឹត្តទៅជាឥរិយាបថតាមដែលប្រព្រឹត្តទៅហើយនោះឯង ដូច្នេះ ។ **បញ្ចវិញ្ញាណ ២ ចំណែក** មិនញ៉ាំងរូបឲ្យកើត ព្រោះជាចិត្តខ្សោយកម្លាំងជាងចិត្តទាំងឡាយ ។ បដិសន្ធិចិត្តក៏មិនញ៉ាំងរូបឲ្យកើត ព្រោះជាចិត្តខ្សោយកម្លាំងដោយវត្ថុ ។ ក្នុងពាក្យថា **ចុតិចិត្តរបស់ព្រះខីណាស្រពទាំងឡាយ** នេះ រមែងធ្វើឲ្យយល់ថា ចុតិចិត្តសូម្បីរបស់សត្វដទៃ ក៏មិនញ៉ាំងរូបឲ្យតាំងឡើង ដោយព្រះបាលីថា វចីសង្ខាររបស់សត្វទាំងនោះដែលកើតក្នុងកាមាវចរភូមិ ក្នុងឧប្បាទក្ខណៈនៃបច្ឆិមចិត្ត អ្នកកើតក្នុងកាមាវចរភូមិដែលនឹងមានបច្ឆិមចិត្តកើតឡើងក្នុងលំដាប់នៃចិត្តណា បុគ្គលជាបច្ឆិមកភវិកសត្វ ក្នុងរូបាវចរភូមិ-អរូបាវចរភូមិ និងអ្នកចូលដល់រូបាវចរភូមិ អរូបាវចរភូមិហើយ នឹងបរិនិព្វាន ដែលកំពុងចុតិ និងរលត់ទៅ តែកាយសង្ខាររបស់សត្វទាំងនោះ មិនរលត់ទៅឡើយ ដូច្នេះ ។ ពិតហើយ ក្នុងកាលចិត្តដែលញ៉ាំងរូបឲ្យតាំងឡើង មិនមានការរាំងរបស់សត្វ ដែលនៅក្នុងគភ៌ជាដើម មិនមានហេតុក្នុងការ ដែលមិនញ៉ាំងកាយសង្ខារឲ្យតាំងឡើងបានឡើយ ហើយហេតុសមគួរក៏ទេ បុគ្គលចុតិហើយ និងរូបដែលមានចិត្តជាសមុដ្ឋានរបស់បុគ្គលនោះ ក៏រមែងប្រព្រឹត្តទៅ ដូចព្រះបាលីថា **ចុតិចិត្តរមែងញ៉ាំងរូបឲ្យតាំងឡើង** ដូច្នេះ នឹងមានក៏ទេ ចំណែកពាក្យដែលធ្វើឲ្យផ្សេងថា **របស់ព្រះខីណាស្រពទាំងឡាយ** ដូច្នេះ គប្បីឃើញថា លោកបានធ្វើទុក ព្រោះធ្វើអធិប្បាយថា ការញ៉ាំងរូបឲ្យតាំងឡើងនៃចុតិចិត្តរបស់ព្រះខីណាស្រពនោះដែលរលត់ទៅ ដោយការរលត់មិនមានបដិសន្ធិ ជាក់ច្បាស់ហើយ ។ ការកំណត់កាន់យកថា **ចិត្ត ១៦ ដួង** ដូច្នេះ ព្រោះចិត្ត ១៦ ដួងនោះ គប្បីត្រូវកំណត់ទុកដោយចំណែកមួយ ក្នុងការញ៉ាំងរូបឲ្យកើត ចំណែកចិត្តដទៃៗ ច្រើនដួង ដែលកើតក្នុងអរូប មិនញ៉ាំងរូបឲ្យកើតឡើយព្រោះជាធម្មជាតិមិននៅក្នុងឱកាស ។ភ្ជាប់សេចក្តីបាលីថា

ន ឋិតិក្ខណេ ភង្គក្ខណេ វា រូបំ ជនេន្តិ ប្រែថា មិនញ៉ាំងរូបឲ្យកើតក្នុងឋិតិក្ខណៈ ឬក្នុងភង្គក្ខណៈ ។ តែចិត្តក្នុងឧប្បាទក្ខណៈ ជាចិត្តមានកម្លាំង ព្រោះការបានបច្ច័យ មានអនន្តរប្បច្ច័យជាដើម ។ រូបធម៌ទាំងឡាយ មានបឋវីធាតុជាដើម មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន យ៉ាងណា សូម្បីអរូបធម៌ទាំងឡាយ មានវេទនាជាដើម ក៏ដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ធម្មជាតិដែលឈ្មោះថា មានចិត្តជាសមុដ្ឋាន** បានដល់ អរូបក្ខន្ធ ៣ និងរូប ១៧ គឺសទ្ទនវករូប ដូច្នេះជាដើម ។ ដោយហេតុនោះឯង ទើបព្រះសាស្តាត្រាស់ថា ធម៌អ្វីខ្លះ ឈ្មោះថា មានចិត្តជាសមុដ្ឋាន ។ បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ កាយវិញ្ញត្តិ វចីវិញ្ញត្តិ ដូច្នេះ ។ ក្នុងព្រះបាលីនោះ រូប មានកាយវិញ្ញត្តិជាដើម ជារូបមានចិត្តជាសមុដ្ឋាន គប្បីជ្រាបថា លោកពោលទុកដោយបរិយាយ ព្រោះកាយវិញ្ញត្តិជាដើមនោះមិនជានិប្ផន្នរូប ។ដោយពាក្យថា **រូបមានសមុដ្ឋាន ៤ ដែលលោកពោលទុកយ៉ាងនេះ** នេះ លោកអាចារ្យសម្តែងចិត្តជរូបដែលមិនមែនមានសមុដ្ឋាននោះៗ ឯង ជារូបដែលមានចិត្តជាបច្ច័យ ។ ឯរូបដែលមានកម្មជាបច្ច័យ លោកសម្តែងទុកដោយប្រការណា កាលលោកកាន់យករូប ដែលមានចិត្តជាបច្ច័យ ក៏គប្បីមានរូប ដែលមានចិត្តនោះជាសមុដ្ឋាន និងអរូបក្ខន្ធមានវេទនាដែលកើតរួមជាដើម ជាធម្មជាតិដែលមានចិត្តជាបច្ច័យផងដែរ ។ តែដើម្បីសម្តែងរូបដែលមានចិត្តជាសមុដ្ឋាន និងមានចិត្តជាបច្ច័យ ដោយមិនលាយឡំគ្នា គប្បីឃើញថា លោកលើកយករូបដែលមានចិត្តជាបច្ច័យឡើង ដោយបច្ឆាជាតប្បច្ច័យតែម្យ៉ាង ។ ឧតុ និងអាហារ ដែលមានកម្មជាសមុដ្ឋាន រមែងជាវត្ថុមានកម្លាំងជាងឧតុ និងអាហារ ដែលមានចិត្តជាសមុដ្ឋាន ព្រោះហេតុនោះ ទើបលោកពោលការបន្តការប្រព្រឹត្តទៅ ៤-៥ វារៈ ដោយអំណាចនៃឧតុ និងអាហារ ដែលមានកម្មជាសមុដ្ឋានទាំងនោះ ម្យ៉ាងទៀត លោកពោលការបន្តការប្រព្រឹត្តទៅ ២-៣ វារៈ ដោយអំណាច

ឧតុ និងអាហារ ដែលមានចិត្តជាសមុដ្ឋាន ដោយទាក់ទងនឹងចិត្តដែលប្រព្រឹត្តទៅដោយប្រក្រតីនោះ ម្យ៉ាងទៀត បណ្ឌិតគប្បីប្រាថ្នាការប្រព្រឹត្តទៅ សូម្បីក្រៃលែងជាង ដោយអំណាចមហគ្គតចិត្ត និងលោកុត្តរចិត្ត ។ ព្រោះចិត្តជរូប ដែលកើតអំពីមហគ្គតចិត្ត និងលោកុត្តរចិត្តនោះ ជាចិត្តប្រណីតឱឡារិក ដោយពាក្យថា **ដែលបានកម្មជរូប ដែលកម្មក្កិលេសចូលទៅ ប្រកាន់ហើយជាបច្ច័យ** នេះ លោកអាចារ្យរមែងសម្ដែងថា ឱជាដែលកម្មក្កិលេស មិនបានចូលទៅប្រកាន់ខាងក្រៅ រមែងមិនធ្វើកិច្ច គឺការនាំរូបមក ។ និងការបានបច្ច័យក៏ដោយអំណាចនៃការដែលមានភូតរូប ដែលកើតអំពីកម្មជាទីអាស្រ័យ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **តាំងនៅក្នុងកម្មជរូបនោះ** ។ ក្នុងពាក្យនោះ ព្រោះរូបដែលមានកម្មជាបច្ច័យ និងមានចិត្តជាសមុដ្ឋានជាដើម ដែលមានកម្មជាមូល ក៏គប្បីមានការផ្ទាស់ជាកម្មជរូបបាន ព្រោះហេតុនោះ ដើម្បីបដិសេធការផ្ទាស់នោះ ទើបលោកអាចារ្យពោលឲ្យផ្សេងទុកថា **ឧបាទិន្នំ** ប្រែថា ដែលកម្មក្កិលេស ចូលទៅប្រកាន់ លោកអាចារ្យពោលថា **រូបមានសមុដ្ឋាន ៤** ដើម្បីសម្ដែងថា រូប ដែលមានអាហារជាបច្ច័យ មិនមែនមានអាហារជាគ្រឿងឧបការៈតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិតនោះ ជាគ្រឿងធ្វើឲ្យកើតផងដែរ លោកអាចារ្យកាលពោលថា ១០-១២ វារៈ ដូច្នេះហើយ បានពោលពាក្យជាដើមថា **អាហារដែលបរិភោគចូលទៅក្នុងមួយថ្ងៃ** ដូច្នេះ សំដៅដល់ការសាកសួរថា ការបន្តការប្រព្រឹត្តទៅ ១០-១២ វារៈនៃរូប ដែលមានអាហារដូចគ្នា ជាបច្ច័យជាសមុដ្ឋាននេះឯង ដូចម្ដេចពាក្យថា **ផ្សាយទៅ ក្នុងសរីរៈរបស់ទារក** សេចក្ដីថា ផ្សាយទៅដោយអវយវៈដែលនាំរសទៅតាមទងផ្ចិត កាលកាន់យកដោយប្រការដទៃ ការប្រកបយ៉ាងត្រឹមត្រូវ រមែងមិនមានដល់អាហារ ដោយអំណាចការលាបទៅត្រង់កាយ ដែលមានស្បូនរារាំង ។

ក្នុងបណ្ដាអាហារ ២ យ៉ាង គឺអាហារដែលជាឧបាទិន្នក អាហារដែលជា

អនុបាទិន្នក អាហារដែលមានអាហារដូចគ្នាជាបច្ច័យ ដែលជាអនុបាទិន្នក លោកអាចារ្យបានសម្តែងទុកហើយអំពីមុន ព្រោះហេតុនោះ ដើម្បីសម្តែងអាហារក្រៅអំពីនេះ ទើបលោកពោលពាក្យជាដើមថា **អាហារដែលកើតអំពីកម្ម** ។ ពាក្យនោះ មានន័យបានពោលទុកហើយ ក្នុងរូបដែលមានកម្មជាបច្ច័យ និងមានអាហារជាសមុដ្ឋាន ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បន្តការប្រព្រឹត្តទៅ ៤-៥ វារៈ** ។ បណ្ឌិតគប្បីជ្រាបការបន្តការប្រព្រឹត្តទៅ ១០-១២ វារៈ សូម្បីរបស់ឧតុដែលមានអាហារជាបច្ច័យ ដូចជារបស់អាហារដែលមានឧតុជាបច្ច័យ អាចារ្យទាំងឡាយរមែងពោលថា លោកមិនបានលើកឡើងអធិប្បាយ ព្រោះមានន័យបានពោលទុកហើយ ។ ពាក្យថា **ដល់រូបដ៏សេស** បានដល់ ដល់រូបដែលមានសន្តតិ ៣ ដែលមានកម្ម ចិត្ត និងឧតុជាសមុដ្ឋានពិតហើយ កពឡិង្ការាហារ រមែងជាបច្ច័យដែលជាធម្មជាតិធ្វើរូបដែលខ្លួនធ្វើឲ្យកើតឡើងហើយឲ្យកើតដោយជាគ្រឿងឧបការៈដល់រូបដែលតាំងឡើង ដោយអាហារដទៃ និងដល់រូបដែលមានសន្តតិ ៣ ។ កាលជាអាហារប្បច្ច័យយ៉ាងនេះឯង រមែងជាបច្ច័យដោយអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ តែជានិស្សយប្បច្ច័យរមែងមិនមាន តាមន័យនៃបដ្ឋាន ។ រូបទាំងឡាយដែលប្រព្រឹត្តទៅ ព្រោះអាហារប្បច្ច័យ ឈ្មោះថា **មានអាហារជាទីអាស្រ័យ** ព្រោះហេតុនោះ គប្បីឃើញថា លោកពោលទុកដោយសុត្តន្តន័យ ។ សូម្បីក្នុងការ ធ្វើបញ្ចាំងភាពជានិស្សយប្បច្ច័យនៃឧតុខាងមុខ ក៏មានន័យនេះឯង ។

លោកពោលពាក្យថា **តេជោធាតុ មានសមុដ្ឋាន ៤ ឈ្មោះថា ឧតុ** ដូច្នេះ ព្រោះតេជោធាតុទាំង ៤ យ៉ាង ជាធម្មជាតិអាចក្នុងការញុំាងរូបឲ្យកើតបាន ទាក់ទងដោយរូបដែលមានកម្មជាសមុដ្ឋានជាដើម ។ ពាក្យថា **ឧតុមាន ២ យ៉ាង** សេចក្តីថា ឧតុមាន ២ យ៉ាង គឺក្តៅ ១ ត្រជាក់ ១ ទាក់ទងដោយការមិនផ្សេងគ្នា នៃតេជោធាតុ ក៏មិនទាក់ទងជាមួយការផ្សេងគ្នានៃភាពរឹង និងភាពទន់ក៏មាន ។ ឯពាក្យណាដែល

គួរពោលក្នុងរឿងនេះ ពាក្យនោះ ខ្ញុំធ្វើឲ្យពិស្តារហើយ ខាងដើមនោះឯង ។ ឧតុ សូម្បី វៀរចាកឧបាទិន្នករូប ក៏រមែងញ៉ាំងរូបឲ្យកើតឡើង បានដោយពិត សូម្បីយ៉ាងនោះ ក្នុងរូបដែលទាក់ទងដោយឥន្ទ្រិយ វៀរចាកឧបាទិន្នករូបនោះ កាលញ៉ាំងរូបឲ្យកើតឡើង របស់រូប ដែលទាក់ទងដោយឥន្ទ្រិយនោះមិនមាន ព្រោះហេតុនោះ ទើបលោកអាចារ្យ ពោលថា **បានឧបាទិន្នករូបជាបច្ច័យ** ដូច្នេះ ។ ដោយហេតុនោះ ទើបលោកអាចារ្យ ពោលថា **ឧតុមានសមុដ្ឋាន ៤** ដូច្នេះ ព្រោះថា ឧតុ មានឧតុជាសមុដ្ឋាននោះឯង វៀរចាកឧបាទិន្នករូបរមែងញ៉ាំងរូបឲ្យ តាំងឡើងបាន ។ រូបមានសមុដ្ឋាន ៤ ឈ្មោះថា **រូបមានឧតុជាបច្ច័យ** ។ រូប ១៥ យ៉ាង មានឧតុជាសមុដ្ឋានឯណា និងរូបមានសន្តតិ ៣ ដទៃអំពីនោះឯណា ឧតុដែលជាសភាគគ្នា រមែងជាបច្ច័យឧបការៈដល់រូបទាំងអស់ នោះ ។ ព្រោះឧតុដែលជាវិសភាគ ដូចរូប មានហិមជាដើម ជាហេតុកើតនៃរូប ដែល ផ្សេងគ្នារបស់ធម្មជាតិ មានឈូកជាដើម រមែងហាក់ដូចញ៉ាំងរូបចាស់ឲ្យវិនាសទៅ ដូច្នោះ ទើបលោកអាចារ្យកាន់យកឧតុដែលជាសភាគគ្នា និងជាវិសភាគគ្នា មក បញ្ចូលគ្នា ពោលថា **ឧតុ រមែងជាបច្ច័យដល់ការប្រព្រឹត្តទៅ និងការវិនាសនៃរូប ដែលមានសមុដ្ឋានទាំងឡាយ ៤** ដូច្នេះ ។

ពាក្យថា **សូម្បីយូរៗ ក៏បាន** គឺអស់កាលយូរជាងកំណត់ដែលពោលទុករបស់ រូបដទៃថា **១០-១២ វារៈ** ( ដំណាក់ ) ។ ពិតហើយ ឧតុ ដែលបានបច្ច័យដោយអំណាច សន្តតិដែលជាសភាគគ្នា វៀរចាកការអាស្រ័យឧបាទិន្នករូប ក៏រមែងបន្តចំពោះការ ប្រព្រឹត្តទៅនៃរូបដែលមានអាការដូចគ្នា អស់កាលយូរក្រៃលែង ពោលថ្វីដល់ប្រការ ក្រៅអំពីនេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សូម្បីតាំងនៅក្នុងចំណែក អនុបាទិន្នករូប** ដូច្នេះ អធិប្បាយថា ក្នុងសរីរៈរបស់សត្វដែលនៅរស់ ទាក់ទងនឹង សក់ រោម ក្រចក រោគឫស ការក្រិនស្បែក ដែលផុតទៅអំពីសាច់ជាដើម ក្នុងទីដទៃ

ទាក់ទងនឹងសាកសពរបស់សត្វជាដើម ។ កាលព្រះយោគាវចរឃើញការកើតរបស់រូបហើយ រមែងឃើញការរលត់របស់រូបដូចគ្នា ព្រោះការប្រព្រឹត្តទៅនៃធម៌មានកាលបន្តិចបន្តួច ព្រោះហេតុនោះ ទើបលោកពោលថា **យោគាវចរកាល ពិចារណាការកើត ក៏ឈ្មោះថា ពិចារណារូបតាមកាល** ព្រោះការឃើញត្រឹមតែការកើត មិនឈ្មោះថាជាការពិចារណាឡើយ ការឃើញការកើតឡើង និងការវិនាសទៅ ក៏ជារឿងសំខាន់ដូច្នេះ សូម្បីក្នុងស័ព្ទថា កើតជទៃអំពីនេះ ក៏មានន័យនេះ ។

# វិសុទ្ធិមគ្គ

## អរូបសម្មសនៈ

## ការពិចារណាអរូបតាមកាល

ម្យ៉ាងទៀត ការកើតនៃរូប ព្រះយោគាវចរដែលពិចារណាមើលរូប គប្បីឃើញបាន យ៉ាងណា ការកើតនៃអរូប សូម្បីព្រះយោគាវចរ ដែលពិចារណាមើលអរូប ក៏គប្បីឃើញបានដូច្នោះ ឯការកើតឡើងនៃអរូបនោះ គប្បីឃើញបានដោយអំណាចលោកិយចិត្តុប្បាទ ៨១ ដួងនោះឯង លោកិយចិត្តុប្បាទនេះដូចម្តេច ? ឯអរូបនេះ ដំបូងកើតជាចិត្តុប្បាទ ១៩ ប្រភេទ ក្នុងបដិសន្ធិដោយអំណាចកម្មដែលសន្សំទុកក្នុងភពមុន ឯអាការកើតនៃអរូបនោះ គប្បីជ្រាបតាមន័យ ដែលពោលហើយក្នុងបដិច្ចសមុប្បាទនិទ្ទេសនោះចុះ ។ អរូប ( គឺចិត្ត ១៩ ប្រភេទ ) នោះឯង តាំងអំពីចិត្តដែលជាលំដាប់នៃបដិសន្ធិចិត្តទៅ រមែងកើតដោយអំណាចនៃភវង្គ ក្នុងទីបំផុតអាយុ រមែងកើតដោយអំណាចចុតិ ក្នុងចិត្តទាំងនោះ ចិត្តណាជាកាមាវចរចិត្តនោះ រមែងកើតក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារ ៦ ដោយអំណាចតទាលម្ពណៈ ចំណែកក្នុងបវត្តិកាល ព្រោះចក្ខុមិនទាន់បែកធ្លាយ ព្រោះរូបទាំងឡាយ មកកាន់គន្លងចក្ខុវិញ្ញាណដែលអាស្រ័យពន្លឺ មានមនសិការជាហេតុ រមែងកើត ព្រមជាមួយសម្បយុត្តធម៌ទាំងឡាយ ។ ពិតហើយ ក្នុងឋិតិក្ខណៈនៃចក្ខុបសាទរូប ដែលដល់នូវការតាំងនៅដូចគ្នា រមែងប៉ះខ្ទប់ចក្ខុបាន កាលចក្ខុនោះត្រូវប៉ះខ្ទប់ហើយ ភវង្គកើតឡើងរលត់ទៅ ២ វារៈ បន្ទាប់អំពីនោះ កិរិយាមនោធាតុញុំាងអាវជ្ជនកិច្ចឲ្យសម្រេច កើតឡើងក្នុងអារម្មណ៍នោះឯង លំដាប់នោះ ចក្ខុវិញ្ញាណជាកុសលវិបាក ឬអកុសលវិបាកក៏ដោយ សម្លឹងរូបនោះឯងកើតឡើង បន្ទាប់អំពីនោះ វិបាកមនោធាតុក៏ទទួលយករូបនោះឯងកើតឡើងតទៅ

វិបាកអហេតុកមនោវិញ្ញាណធាតុ ពិចារណាមើលរូបនោះឯងកើតឡើង បន្ទាប់មក កិរិយាអហេតុកមនោវិញ្ញាណធាតុ ជាឧបេក្ខាសហគតៈ កំណត់យករូបនោះឯងកើត ឡើង បន្ទាប់អំពីនោះ បណ្តាកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្តផ្នែកកាមាវចរ ទាំងឡាយ ចិត្តជាអហេតុកឧបេក្ខាសហគតៈ ១ ដួង ឬជវន ៥ ដល់ ៧ ដួងកើត ឡើង បន្ទាប់អំពីនោះ បណ្តាតទាលម្ពណចិត្ត ១១ ដួង នៃកាមាវចរចិត្តទាំងឡាយ តទាលម្ពណចិត្តដួងណានីមួយ ដែលគួរដល់ជវនកើតឡើង ដូច្នេះ សូម្បីក្នុងទ្វារដ៏សេស ក៏មានន័យនេះ តែក្នុងមនោទ្វារ សូម្បីមហគ្គតចិត្តទាំងឡាយក៏កើតឡើងបានដែរ ការ កើតនៃអរូបក្នុងទ្វារ ៦ បណ្ឌិតគប្បីឃើញដូចពោលមក ដូច្នេះ ។

ព្រះយោគាវចរពិចារណាការកើតនៃអរូប ដោយន័យដូចពោលមកដូច្នេះឯង ឈ្មោះថា **ពិចារណាអរូបតាមកាល** ។

ព្រះយោគាវចរអង្គណានីមួយ ពិចារណារូបតាមកាល អរូបតាមកាល ដូច ពោលមកនេះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ បដិបត្តិទៅដោយលំដាប់ ក៏ញុំាង បញ្ញាភាវនាឲ្យដល់ព្រមបាន ។

# មហាដីកា

## កថាពណ៌នាដោយអាការពិចារណា

## ការកើតរបស់អរូប

អវធារណៈថា **លោកិយចិត្តុប្បាទវសេនេវ** ដូច្នេះ ព្រោះមិនមែនជាវិស័យរបស់លោកុត្តរចិត្តក្រៅអំពីនេះឡើយ ។

**រមែងកើតឡើង** ដោយអំណាចភពនោះៗ ។ ក្នុងសេចក្ដីថា ចិត្ត ១៩ ប្រភេទនោះៗ ឯង រមែងកើតឡើងដោយអំណាចភវង្គ ។ សូម្បីក្នុងពាក្យពីរនេះថា **ដោយអំណាចចុតិ ដោយអំណាចតទាលម្ពណៈ** ក៏យ៉ាងនោះ ។ បទថា **តត្ថ** សេចក្ដីប៉ុន្មានឹង **តេសុ យោគ ឯកូនវីសតិចិត្តុប្បាទេសុ** ប្រែថា ក្នុងបណ្ដាចិត្តុប្បាទ ១៩ ដួងនោះ ។ សូម្បីដោយពាក្យថា **តាំងអំពីចិត្តដែលជាលំដាប់ជាដើម** លោកអាចារ្យពោលដល់បវត្តិកាលតែម្យ៉ាង ។

ឯអាការនោះ ជាអាការប្រព្រឹត្តទៅក្នុងបវត្តិកាលរបស់បដិសន្ធិចិត្តទាំងឡាយនោះឯង ព្រោះហេតុនោះ លោកអាចារ្យកាលសម្ដែងការកើតឡើងរបស់ចិត្ត ដែលមានការប្រព្រឹត្តទៅស្មុទ្ធៗ ទើបពោលពាក្យជាដើមថា **ចំណែកក្នុងបវត្តិកាល** ។ ពាក្យថា **ព្រោះចក្ខុមិនទាន់បែកធ្លាយ** គឺព្រោះមិនទាន់វិនាសទៅ ។ ដើម្បីនឹងបើកផ្សារអត្ថដែលលោកពោលទុកដោយសង្ខេប ដោយពាក្យថា **ព្រោះចក្ខុមិនទាន់បែកធ្លាយ** ដូច្នេះជាដើម ទើបលោកអាចារ្យពោលពាក្យថា **ពិតហើយ ក្នុងឋិតិក្ខណៈ នៃចក្ខុបសាទ** ដូច្នេះជាដើម ។ ដោយពាក្យថា **រូបដែលដល់នូវការតាំងនៅ** នេះ លោកអាចារ្យរមែងសម្ដែងថា រូបដែលកំពុងរលត់ រមែងមិនជាបច្ច័យដល់របស់ណាមួយ យ៉ាងណា សូម្បីរូបដែលកំពុងកើតឡើង ក៏ដូច្នោះ ។ ក្នុងសេចក្ដីបាលីថា **ចក្ខុវិញ្ញាណំ ឧប្បជ្ជតិ**

ប្រែថា ចក្ខុវិញ្ញាណរមែងកើតឡើង ។ ក្នុងបទដ៏សេស ក៏យ៉ាងនេះ ។ ភ្ជាប់សេចក្តីបាលីថា **កាមាវចរកុសលាកុសលកិរិយចិត្តេសុ ឯកំ វា បញ្ច សត្ត វា ជវនានិ ហុត្វា ឧប្បជ្ជតិ** ប្រែថា ក្នុងបណ្តាកាមាវចរកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្ត រមែងកើតជាឧបេក្ខាសហគតអហេតុកចិត្ត ១ ដួងខ្លះ កើតជវន ៥ ដួង ៧ ដួងខ្លះ។ គប្បីនាំយក **វា**-ស័ព្ទ មកភ្ជាប់ថា **ឧបេក្ខាសហគតាហេតុកំ ចិត្តំ វា** ដូច្នេះ ។ ឯលោកពោលទុកយ៉ាងនេះ សំដៅដល់វារៈដូច្នេះ ឯវារៈដូច្នេះនោះ គប្បីជ្រាបដោយអំណាចមោឃវារៈទី ២ ។ ជវន ៥ គប្បីជ្រាបក្នុងកាលដែលបុគ្គលនិទ្រា និងសន្លប់ជាដើម ជវន ៧ គប្បីជ្រាបក្នុងកាលដែលបុគ្គលនៅប្រក្រតី ។ ពាក្យថា **សមគួរដល់ជវន និងអារម្មណ៍** សេចក្តីថា សមគួរដល់ជវនដោយន័យជាដើមថា **បើជាតិហេតុកជវន ក៏ជាតិហេតុកចិត្ត ឬជាទុហេតុកចិត្ត** ដូច្នេះ និងសមគួរដល់អារម្មណ៍ ដោយន័យជាដើមថា **បើជាឥដ្ឋារម្មណ៍ ក៏ជាសោមនស្សសហគតចិត្ត** ដូច្នេះ ។ ពាក្យថា **ក្នុងទ្វារដ៏សេស** បានដល់ ក្នុងទ្វារដ៏សេស មានសោតទ្វារជាដើម ។

ពាក្យថា **ដោយលំដាប់** សេចក្តីថា **រមែងញុំាងបញ្ញាភាវនាឲ្យដល់ព្រម** គឺសម្រេចអរហត្តដោយលំដាប់នៃការចាក់ធ្លុះឧទយព្វយញ្ញាណ ។

# វិសុទ្ធិមគ្គ

## ពិចារណារូប និងអរូបដោយអាការ ៧

ព្រះយោគាវចរអង្គណាមួយ ពិចារណាសង្ខារទាំងឡាយ ដោយលើកឡើងកាន់ត្រៃលក្ខណ៍តាមគន្លង រូបសត្តក និង អរូបសត្តក ។

## រូបសត្តកៈ

ក្នុងសត្តកៈ ២ យ៉ាងនោះ ព្រះយោគាវចរកាលពិចារណាលើកឡើង ( កាន់ត្រៃលក្ខណ៍ ) ដោយអាការទាំងនេះ គឺ

| | |
|---|---|
| អាទាននិក្ខេបនតោ | ដោយការកាន់យក និងរលាស់ទៅ |
| វយោវុឌ្ឍត្ថគមតោ | ដោយការធ្លាក់ទៅនៃរូប ដែលចម្រើនឡើងតាមវ័យ |
| អាហារមយតោ | ដោយជារូបសម្រេចដោយអាហារ |
| ឧតុមយតោ | ដោយជារូបសម្រេចដោយឧតុ |
| កម្មជតោ | ដោយជារូបកើតអំពីកម្ម |
| ចិត្តជសមុដ្ឋានតោ | ដោយជារូបដែលមានចិត្តជាសមុដ្ឋាន |
| ធម្មតារូបតោ | ដោយជារូបធម្មតា ។ |

ឈ្មោះថា ពិចារណាដោយលើកឡើង ( កាន់ត្រៃលក្ខណ៍ ) ដោយអំណាចរូបសត្តកៈ ហេតុនោះ ទើបព្រះបុរាណាចារ្យទាំងឡាយពោលទុក ( ជាគាថា ) ថា

ព្រះយោគាវចរ រមែងឃើញច្បាស់យ៉ាងវិសាល ( ដោយអាការ ) ៧ គឺដោយការកាន់យក និងរលាស់ចោល ១ ដោយការបែកទៅនៃរូប ដែលចម្រើនឡើងតាមវ័យ ១ ដោយអាហារ ( ជាបច្ច័យ ) ១ ដោយឧតុ ( ជាបច្ច័យ ) ១ ដោយកម្ម ( ជាបច្ច័យ ) ១ ដោយចិត្ត ( ជាបច្ច័យ ) ១ ដោយជាធម្មតារូប ១ ។

# ពង្រីកសេចក្តី

# អាទាននិក្ខេបតោ

ក្នុងបទទាំងនោះ បទថា **អាទាន** កាន់យក បានដល់ បដិសន្ធិ បទថា **និក្ខេបន** លះបង់ចោល បានដល់ ចុតិ ព្រះយោគាវចរកំណត់ ( ជាវគ្គ ) ១០០ ឆ្នាំ ដោយកាន់យក និងលះបង់ចោលទៅនេះ លើកឡើងកាន់ត្រៃលក្ខណ៍ក្នុងសង្ខារ គឺរូបធម៌ទាំងឡាយនេះ ដូចម្តេច ? គឺសង្ខារទាំងពួង ក្នុងរវាងការកាន់យក និងការលះបង់ចោលនេះ ឈ្មោះថា **មិនទៀង** ព្រោះអ្វី ? ព្រោះប្រព្រឹត្តទៅដោយអំណាចការកើតឡើង និងការវិនាសទៅ ព្រោះផ្លាស់ប្តូរបាន ព្រោះជារបស់មួងម្កាល និងព្រោះប្រជែងដោយការទៀង ម្យ៉ាងទៀត ហេតុណា សង្ខារទាំងឡាយ ដែលកើតឡើងហើយ ដល់នូវការតាំងនៅក្នុង ( ខណៈ ) តាំងនៅ រមែងលំបាកដោយជរា ដល់ជរាហើយ ក៏បែកធ្លាយដោយពិត ហេតុនោះ សង្ខារទាំងឡាយនោះ ទើបឈ្មោះថា ជាទុក្ខ ព្រោះបៀតបៀនរឿយៗ មកទល់ឥឡូវនេះ ព្រោះលំបាក ព្រោះទ្រាំបានដោយលំបាក ព្រោះជាទីតាំងនៃទុក្ខ និងព្រោះប្រជែង ចំពោះសេចក្តីសុខ ។ ម្យ៉ាងទៀត ហេតុណា ការប្រើអំណាច ( បង្គាប់ ) បាន រមែងមិនមានដល់បុគ្គលណាម្នាក់ ក្នុងឋានៈ ៣ នេះ គឺសង្ខារទាំងឡាយ ដែលកើតឡើងហើយ ចូរកុំដល់នូវការតាំងនៅឡើយ ដែលដល់នូវការតាំងនៅហើយ ចូរកុំជរាឡើយ ដែលដល់ជរាហើយ ចូរកុំបែកធ្លាយឡើយ ដូច្នេះ សង្ខារទទេចាកការប្រើអំណាចនោះឯង ហេតុនោះ ទើបសង្ខារទាំងឡាយនោះ ឈ្មោះថា ជាអនត្តា ព្រោះជារបស់ទទេ ព្រោះមិនមានម្ចាស់ ព្រោះប្រើអំណាចមិនបាន និងព្រោះប្រជែងចំពោះអត្តា ដូច្នេះ ។

## វយោវុឌ្ឍត្ថគមតោ

ព្រះយោគាវចរកាលលើកឡើងកាន់ត្រៃលក្ខណ៍ក្នុងរូបដែលកំណត់ (បរិច្ឆេទ) ១០០ ឆ្នាំ ដោយអំណាចនៃអាទាន និងនិក្ខេបនៈយ៉ាងនេះហើយ បន្ទាប់អំពីនោះទៅ លើកឡើងដោយវយោវុឌ្ឍត្ថគម ។

## ១០០ ឆ្នាំជា ៣ ចំណែក

ការដាក់ទៅនៃរូបដែលចម្រើនឡើង គឺចម្រើនឡើង ដោយអំណាចវ័យ ឈ្មោះថា **វយោវុឌ្ឍត្ថគម** ក្នុងពាក្យនោះ ការលើកឡើងកាន់ត្រៃលក្ខណ ដោយអំណាចវយោវុឌ្ឍត្ថគមនោះ លើកឡើងដូចម្ដេច ? គឺព្រះយោគាវចរនោះ កំណត់ ១០០ ឆ្នាំនោះឯង ចែកដោយវ័យ ៣ គឺដោយបឋមវ័យ ដោយមជ្ឈិមវ័យ ដោយបច្ឆិមវ័យ ក្នុង ៣ វ័យនោះ ៣៣ ឆ្នាំដំបូង ចាត់ជាបឋមវ័យ ៣៤ ឆ្នាំបន្ទាប់ទៅ ចាត់ជាមជ្ឈិមវ័យ បន្ទាប់អំពីនោះ ៣៣ ឆ្នាំ ចាត់ជាបច្ឆិមវ័យ កាលកំណត់ដោយវ័យ ៣ នេះ យ៉ាងនេះហើយ ក៏លើកឡើងកាន់ត្រៃលក្ខណ៍ថា រូបដែលប្រព្រឹត្តទៅ ក្នុងបឋមវ័យ ក៏រលត់ទៅក្នុងបឋមវ័យនោះឯង មិនទៅដល់មជ្ឈិមវ័យ ហេតុនោះ រូបដែលប្រព្រឹត្តទៅក្នុងបឋមវ័យនោះ ទើបឈ្មោះថា **មិនទៀង** វត្ថុណាមិនទៀង វត្ថុនោះក៏ឈ្មោះថា **ជាទុក្ខ** កាលវត្ថុណាជាទុក្ខ វត្ថុនោះក៏ឈ្មោះថា **ជាអនត្តា** រូប ដែលប្រព្រឹត្តទៅក្នុងមជ្ឈិមវ័យសោត ក៏រលត់ទៅក្នុងមជ្ឈិមវ័យនោះឯង មិនដល់បច្ឆិមវ័យ ហេតុនោះ សូម្បីរូបដែលប្រព្រឹត្តទៅក្នុងមជ្ឈិមវ័យនោះ ក៏ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ដល់រូបដែលប្រព្រឹត្តទៅ ៣៣ ឆ្នាំ ក្នុងបច្ឆិមវ័យ ដែលមានអំណាចប្រព្រឹត្តទៅចំពោះតែមរណៈក៏ទេ ហេតុនោះ សូម្បីរូបដែលប្រព្រឹត្តទៅក្នុងបច្ឆិមវ័យនោះ ក៏ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នេះ ។

## ១០០ ឆ្នាំ ជា ១០ ចំណែក

*ព្រះយោគាវចរ កាលលើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគម ដោយអំណាចវ័យ មានបឋមវ័យជាដើមយ៉ាងនេះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគម ដោយអំណាចទសកៈ ១០ នេះទៀត គឺ*

| | |
|---|---|
| *មន្ទទសកៈ* | *១០ ឆ្នាំ នៃកុមារ* |
| *ខិឌ្ឌាទសកៈ* | *១០ ឆ្នាំ នៃការលេង* |
| *វណ្ណទសកៈ* | *១០ ឆ្នាំ នៃពណ៌សម្បុរ* |
| *ពលទសកៈ* | *១០ ឆ្នាំ នៃកម្លាំង* |
| *បញ្ញាទសកៈ* | *១០ ឆ្នាំ នៃបញ្ញា* |
| *ហានិទសកៈ* | *១០ ឆ្នាំ នៃការវិនាស* |
| *បព្ភារទសកៈ* | *១០ ឆ្នាំ នៃការកោង* |
| *វង្កទសកៈ* | *១០ ឆ្នាំ នៃការអែន* |
| *មោមូហទសកៈ* | *១០ ឆ្នាំ នៃការភ្លេច* |
| *សយនទសកៈ* | *១០ ឆ្នាំ នៃការដេក ។* |

## ពន្យល់សេចក្តី

*ក្នុងទសកៈទាំងនោះ ១០ ដំបូង របស់បុគ្គលដែលមានជីវិតដល់ ១០០ ឆ្នាំ ឈ្មោះថា **មន្ទទសកៈ** ព្រោះថា ក្នុងដំណាក់ការនោះ បុគ្គលនោះ នៅជាកុមារតូចនៅឡើយ ១០ ឆ្នាំ បន្ទាប់អំពីនោះទៅ **ឈ្មោះខិឌ្ឌាទសកៈ** ព្រោះក្នុងដំណាក់ការនោះ បុគ្គលនោះច្រើនទៅដោយការត្រេកអរក្នុងការលេង ១០ ឆ្នាំ អំពីនោះទៅ **ឈ្មោះវណ្ណទសកៈ** ព្រោះក្នុងពេលនោះ ចំណែកពណ៌សម្បុររបស់បុគ្គលនោះ រមែងដល់នូវភាពបរិបូណ៌*

១០ ឆ្នាំ បន្ទាប់អំពីនោះទៅ **ឈ្មោះពលទសក:** ព្រោះក្នុងពេលនោះ កម្លាំង និងភាពខ្លាំងរបស់បុគ្គលនោះ រមែងដល់នូវការពេញបរិបូណ៌ ១០ ឆ្នាំបន្ទាប់អំពីនោះ **ឈ្មោះបញ្ញាទសក:** ព្រោះក្នុងជំណាក់ការនោះ បញ្ញារបស់បុគ្គលនោះ រមែងមាំមួនល្អ បានឮថា បញ្ញាសូម្បីបន្តិចបន្តួចរបស់បុគ្គលដែលធម្មតា ជាមនុស្សល្ងង់ក៏កើតឡើងបានក្នុងកាលនោះដូចគ្នា ១០ ឆ្នាំតអំពីនោះទៅ **ឈ្មោះហានិទសក:** ព្រោះក្នុងសម័យនោះ ការត្រេកអរក្នុងការលេងពណ៌សម្បុរ កម្លាំង និងបញ្ញារបស់បុគ្គលនោះ រមែងវិនាសថយទៅ ១០ ឆ្នាំតអំពីនោះទៅ **ឈ្មោះ បព្ភារទសក:** ព្រោះក្នុងពេលនោះ រាងកាយរបស់បុគ្គលនោះ រមែងកោងទៅខាងមុខ ១០ ឆ្នាំតអំពីនោះទៅ **ឈ្មោះវង្កទសក:** ព្រោះក្នុងជំណាក់ការនោះ រាងកាយរបស់បុគ្គលនោះ រមែងអែនចុះ ដូចយាមនង្គ័ល ១០ ឆ្នាំតអំពីនោះទៅ **ឈ្មោះ មោមូហទសក:** ព្រោះក្នុងពេលនោះ ជាបុគ្គលច្រើនដោយការវង្វេងភ្លេច រមែងភ្លេចការងារដែលធ្វើហើយ ១០ ឆ្នាំតអំពីនោះទៅ **ឈ្មោះសយនទសក:** ព្រោះបុគ្គលមានអាយុដល់ ១០០ ឆ្នាំ ក៏ច្រើនទៅដោយការដេកនោះឯង ។

ព្រះយោគីអង្គនេះ រមែងពិចារណាដើម្បីលើកឡើងកាន់ត្រៃលក្ខណ៍ ដោយ **វយោវុឌ្ឍត្ថគម** ដោយអំណាចទសក:ទាំងនោះក្នុងរូបនោះ ដូច្នេះ ឈ្មោះថា រូបដែលប្រព្រឹត្តទៅក្នុងទសក:ដំបូង រមែងរលត់ទៅក្នុងទសក:ដំបូងនោះឯង មិនមកដល់ទសក:ទី ២ ឡើយ ហេតុនោះ រូបដែលប្រព្រឹត្តទៅក្នុងទសក:ដំបូងនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា រូបដែលប្រព្រឹត្តទៅក្នុងទសក:ទី ២ ។បេ។ រូបដែលប្រព្រឹត្តទៅក្នុងទសក:ទី ៩ ក៏រលត់ទៅក្នុងទសក:ទី ៩ នោះឯង មិនដល់ទសក:ទី ១០ ឡើយ... រូបដែលប្រព្រឹត្តទៅក្នុងទសក:ទី ១០ ក៏រលត់ទៅក្នុងទសក:ទី ១០ នោះឯង មិនទៅដល់ភពថ្មីឡើយ ហេតុនោះ រូបដែលប្រព្រឹត្តទៅក្នុងទសក:ទី ១០ នោះ ក៏ឈ្មោះ

ថា មិនទៀង ជាទុក្ខ ជាអនត្តា លោករមែងលើកឡើងកាន់ត្រៃលក្ខណ៍ដូចពោលមក ដូច្នេះ ។

## ១០០ ឆ្នាំ ជា ២០ ចំណែក

ព្រះយោគីនោះ កាលលើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគម ដោយអំណាចទសកៈ ១០ យ៉ាងនេះហើយ ធ្វើ ១០០ ឆ្នាំនោះឯង ឲ្យជា ២០ ចំណែក ដោយចែក ៥ ឆ្នាំៗ លើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគមទៀត លើកដូចម្តេច ? គឺព្រះយោគីនោះ ពិចារណាឃើញដូច្នេះថា រូបដែលប្រព្រឹត្តទៅក្នុង ៥ ឆ្នាំដំបូង ក៏រមែងរលត់ទៅក្នុង ៥ ឆ្នាំដំបូងនោះឯង មិនទៅដល់ ៥ ឆ្នាំទី ២ ហេតុនោះ រូបក្នុង ៥ ឆ្នាំដំបូងនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា រូបដែលប្រព្រឹត្តទៅក្នុង ៥ ឆ្នាំទី ២ ក៏រលត់ទៅក្នុង ៥ ឆ្នាំទី ២ នោះឯង មិនទៅដល់ ៥ ឆ្នាំទី ៣ ។បេ។ រូបដែលប្រព្រឹត្តទៅក្នុង ៥ ឆ្នាំទី ១៩ ក៏រលត់ទៅក្នុង ៥ ឆ្នាំទី ១៩ នោះឯង មិនទៅដល់ ៥ ឆ្នាំទី ២០ រូបដែលប្រព្រឹត្តទៅក្នុង ឆ្នាំទី ២០ ដែលអាចប្រព្រឹត្តទៅតអំពីមរណៈក៏ទេ ហេតុនោះ សូម្បីរូបដែលប្រព្រឹត្តទៅក្នុង ៥ ឆ្នាំ ទី ២០ នោះ ក៏ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## ១០០ ឆ្នាំ ជា ២៥-៣៣-៥០-១០០ ចំណែក

កាលលើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគម ដោយបែងចែកជា ២០ យ៉ាងនេះហើយ ធ្វើ ( ១០០ ឆ្នាំ ) ឲ្យជា ២៥ ចំណែក លើកឡើងដោយបែងចែក ៤ ឆ្នាំៗ នោះដូចគ្នា ធ្វើឲ្យជា ៣៣ ចំណែក ដោយបែងចែកជា ៣ ឆ្នាំៗ ហើយធ្វើឲ្យជា ៥០ ចំណែក ដោយបែងចែកជា ២ ឆ្នាំៗ ហើយធ្វើឲ្យជា ១០០ ចំណែក ដោយបែងចែក ១ ឆ្នាំៗ ។

## ១ ឆ្នាំ ឲ្យជា ៣ ចំណែក

បន្ទាប់អំពីនោះ ធ្វើ ១ ឆ្នាំៗ ឲ្យជា ៣ ចំណែក លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវ័យោវុឌ្ឍគ្គមរូបនោះ ដោយចែកជារដូវ ៣ គឺរដូវភ្លៀង រដូវរងា រដូវក្តៅ ឯមួយ រដូវៗ លើកឡើងដូចម្តេច ? គឺព្រះយោគីនោះពិចារណាឃើញដូច្នេះថា រូបដែល ប្រព្រឹត្តទៅ ៤ ខែ ក្នុងរដូវភ្លៀងក៏រលត់ទៅហើយ ក្នុងរដូវភ្លៀងនោះឯង មិនមកដល់ រដូវរងា រូបដែលប្រព្រឹត្តទៅក្នុងរដូវរងា ក៏រលត់ទៅហើយក្នុងរដូវរងានោះឯង មិនមក ដល់រដូវក្តៅ រូបដែលប្រព្រឹត្តទៅក្នុងរដូវក្តៅ ក៏រលត់ទៅហើយក្នុងរដូវក្តៅនោះឯង មិនមកដល់រដូវភ្លៀងទៀត ទើបរូបនោះ ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## ១ ឆ្នាំ ឲ្យជា ៦ ចំណែក

កាលលើកឡើងយ៉ាងនេះហើយ ធ្វើ ១ ឆ្នាំ ឲ្យជា ៦ ចំណែកទៀត លើកឡើង កាន់ត្រៃលក្ខណ៍ ក្នុងវ័យោវុឌ្ឍគ្គមរូបនោះ ដូច្នេះថា រូបដែលប្រព្រឹត្តទៅ ២ ខែ ក្នុង រដូវវស្សាក៏រលត់ទៅក្នុងរដូវវស្សានោះឯង មិនមកដល់សរទរដូវ រូបដែលប្រព្រឹត្តទៅ ក្នុងសរទរដូវ ក៏រលត់ទៅក្នុងសរទរដូវនោះឯង មិនមកដល់ហេមន្តរដូវ រូបដែលប្រព្រឹត្ត ទៅក្នុងហេមន្តរដូវ ក៏រលត់ទៅក្នុងហេមន្តរដូវនោះឯង មិនមកដល់សិសិររដូវ រូបដែល ប្រព្រឹត្តទៅក្នុងសិសិររដូវ ក៏រលត់ទៅក្នុងសិសិររដូវនោះឯង មិនមកដល់វសន្តរដូវ រូបដែលប្រព្រឹត្តទៅក្នុងវសន្តរដូវ ក៏រលត់ទៅក្នុងវសន្តរដូវនោះឯង មិនមកដល់ គិម្ហរដូវ រូបដែលប្រព្រឹត្តទៅក្នុងគិម្ហរដូវ ក៏រលត់ទៅក្នុងគិម្ហរដូវនោះឯង មិនមកដល់ វសន្តរដូវទៀតឡើយ ហេតុនោះ ទើបរូបនោះឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## ១ ខែ ជា ២ ចំណែក

កាលលើកឡើងយ៉ាងនេះហើយ បន្ទាប់អំពីនោះ លើកឡើងកាន់ត្រៃលក្ខណ៍

ដោយបែងជាខាងរនោច ខាងខ្វើតថា រូបដែលប្រព្រឹត្តទៅខាងរនោច ក៏រលត់ទៅក្នុងខាងរនោចនោះឯង មិនមកដល់ខាងខ្វើត រូបដែលប្រព្រឹត្តទៅក្នុងខាងខ្វើត ក៏រលត់ទៅក្នុងខាងខ្វើតនោះឯង មិនមកដល់ខាងរនោច ហេតុនោះ ទើបរូបនោះឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## ចែក ១ ថ្ងៃ ជា ២ ចំណែក

បន្ទាប់អំពីនោះ លើកឡើងកាន់ត្រៃលក្ខណ៍ ដោយបែងចែកពេលយប់ ពេលថ្ងៃថា រូបដែលប្រព្រឹត្តទៅក្នុងពេលយប់ ក៏រលត់ទៅក្នុងពេលយប់នោះឯង មិនមកដល់ពេលថ្ងៃ រូបដែលប្រព្រឹត្តទៅក្នុងពេលថ្ងៃសោត ក៏រលត់ទៅក្នុងពេលថ្ងៃនោះឯង មិនមកដល់ពេលយប់ ហេតុនោះ ទើបរូបនោះឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## ចែក ១ ថ្ងៃ ជា ៦ ចំណែក

បន្ទាប់អំពីនោះ ធ្វើយប់ និងថ្ងៃនោះឯង ឲ្យជា ៦ ចំណែក ដោយបែង ចំណែករបស់ថ្ងៃ មានពេលព្រឹកជាដើម លើកឡើងកាន់ត្រៃលក្ខណ៍ថា រូបដែលប្រព្រឹត្តទៅក្នុងពេលព្រឹក ក៏រមែងរលត់ទៅក្នុងពេលព្រឹកនោះឯង មិនមកដល់ថ្ងៃត្រង់ រូបដែលប្រព្រឹត្តទៅក្នុងថ្ងៃត្រង់ ក៏រលត់ទៅក្នុងថ្ងៃត្រង់នោះឯង មិនមកដល់ពេលល្ងាច រូបដែលប្រព្រឹត្តទៅក្នុងពេលល្ងាច ក៏រលត់ទៅក្នុងពេលល្ងាចនោះឯង មិនមកដល់បឋមយាម រូបដែលប្រព្រឹត្តទៅក្នុងបឋមយាម ក៏រលត់ទៅក្នុងបឋមយាមនោះឯង មិនមកដល់មជ្ឈិមយាម រូបដែលប្រព្រឹត្តទៅក្នុងមជ្ឈិមយាម ក៏រលត់ទៅក្នុងមជ្ឈិមយាមនោះឯង មិនមកដល់បច្ឆិមយាម រូបដែលប្រព្រឹត្តទៅក្នុងបច្ឆិមយាម ក៏រលត់ទៅក្នុងបច្ឆិមយាមនោះឯង មិនមកដល់ពេលព្រឹកទៀតឡើយ ព្រោះហេតុនោះ ទើបរូបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## ចែកដោយអាការ ៦ នៃរូប

កាលលើកឡើងយ៉ាងនេះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ដោយបែងដោយចែកជា ( អាការ ៦ គឺ ) ឈានទៅមុខ ឈានថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលឆ្វេង-ស្តាំ បត់អង្គុញ លាតសណ្តូក ទៀតថា រូបដែលប្រព្រឹត្តទៅក្នុងការឈានទៅមុខ ក៏រលត់ទៅក្នុងពេលឈានទៅមុខនោះឯង មិនមកដល់ពេលឈានថយក្រោយ រូបដែលប្រព្រឹត្តទៅក្នុងពេលឈានថយក្រោយ ក៏រលត់ទៅក្នុងពេលឈានថយក្រោយនោះឯង មិនទៅដល់ពេលមើលទៅមុខ រូបដែលប្រព្រឹត្តទៅក្នុងពេលមើលទៅមុខ ក៏រលត់ទៅក្នុងពេលមើលទៅមុខនោះឯង មិនទៅដល់ពេលក្រឡេកមើលឆ្វេង-ស្តាំ រូបដែលប្រព្រឹត្តទៅក្នុងពេលក្រឡេកមើលឆ្វេង-ស្តាំ ក៏រលត់ទៅក្នុពេលក្រឡេកមើលឆ្វេង-ស្តាំងនោះឯង មិនមកដល់ពេលបត់អង្គុញ រូបដែលប្រព្រឹត្តទៅ ក្នុងពេលបត់អង្គុញ ក៏រលត់ទៅ ក្នុងពេលបត់អង្គុញនោះឯង មិនមកដល់ពេលលាតសណ្តូកឡើយ ព្រោះហេតុនោះ ទើបរូបនោះឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## ចែក ១ ជំហានជា ៦ ចំណែក

បន្ទាប់អំពីនោះ ធ្វើជំហាន ១ ឲ្យជា ៦ ចំណែក ដោយបែងចែកជា ៦ ចំណែក គឺលើកបោះទៅមុខ ផ្លាស់ ដាក់ចុះ ជាន់ ជាន់សឹប់ ក្នុង ៦ ចំណែកនោះ លើកជើងឡើងអំពីផែនដី ហៅថា **លើក** នាំជើងទៅខាងមុខ ហៅថា **បោះទៅមុខ** ឃើញដង្គត់ បន្លា ពស់ ជាដើមណាមួយ ផ្លាស់ជើងទៅខាងនោះខាងនេះ ហៅថា **ផ្លាស់** ដាក់ជើងចុះក្រោម ហៅថា **ដាក់ចុះ** ដាក់ជើងដល់ផែនដី ហៅថា **ជាន់** សង្កត់ជើងលើផែនដីក្នុងវេលាឈានម្ខាងទៀត ហៅថា **ជាន់សឹប់** ។

ក្នុង ៦ ចំណែកនោះ ក្នុងចំណែកលើក ធាតុ ២ គឺបឋវីធាតុ អាបោធាតុ មានប្រមាណតិច គឺទន់ខ្សោយ ធាតុ ២ ក្រៅអំពីនេះ មានប្រមាណច្រើន ( គឺ ) កម្លាំង, ក្នុងចំណែកបោះទៅមុខ និងផ្លាស់ ក៏យ៉ាងនោះ ក្នុងចំណែកដាក់ចុះ ធាតុ ២ គឺតេជោធាតុ វាយោធាតុ ក៏មានប្រមាណតិច គឺទន់ខ្សោយ ធាតុ ២ ក្រៅអំពីនេះ មានប្រមាណច្រើន គឺកម្លាំង, ក្នុងចំណែកជាន់ និងជាន់សង្កត់ក៏យ៉ាងនេះ កាលធ្វើជា ៦ ចំណែកយ៉ាងនេះហើយ ទើបលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោរូបគ្គមរូបនោះ តាមបែបនៃការចែកទាំង ៦ នោះ លើកឡើងដូចម្តេច ? គឺព្រះយោគីនោះពិចារណាឃើញដូច្នេះថា ធាតុទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងចំណែកលើកឯណាក្តី ឧបាទាយរូបនៃធាតុទាំងនោះឯណាក្តី ធម៌ទាំងពួងនោះ ក៏រមែងរលត់ទៅក្នុងចំណែកលើកនោះឯង មិនទៅដល់ចំណែកបោះទៅមុខ ហេតុនោះ ធម៌ទាំងពួងនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។ ដូចគ្នានោះ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងចំណែកបោះទៅមុខ ក៏រលត់ទៅក្នុងចំណែកឈានទៅមុខនោះឯង មិនទៅដល់ចំណែកផ្លាស់ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងចំណែកផ្លាស់ ក៏រលត់ទៅក្នុងចំណែកផ្លាស់នេះឯង មិនមកដល់ចំណែកដាក់ចុះ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងចំណែកដាក់ចុះ ក៏រលត់ទៅក្នុងចំណែកដាក់ចុះនេះឯង មិនទៅដល់ចំណែកជាន់ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងចំណែកជាន់ ក៏រលត់ទៅក្នុងចំណែកជាន់នេះឯង មិនទៅដល់ចំណែកជាន់សង្កត់ សង្ខារទាំងឡាយ ដែលកើតឡើងក្នុងចំណែកនោះៗ ក៏បែកធ្លាយទៅក្នុងចំណែកនោះៗ ឯងជាដំណាក់ៗ ជាកំណាត់ៗ ជាបណ្តើរៗ មិនដល់ចំណែកក្រៅអំពីនេះ ដូចគ្រាប់ល្ងទាំងឡាយ ដែលដាក់ចុះក្នុងអំបែងដ៏ក្តៅបែកឮ តដៈ តដៈ ដូច្នេះ ហេតុនោះ ទើបសង្ខារទាំងឡាយនោះ ឈ្មោះថា **មិនទៀង** ព្រោះមិនទៀង ទើបឈ្មោះថា **ជាទុក្ខ** ព្រោះជាទុក្ខ ទើបឈ្មោះថា **អនត្តា** ។

# ឧបមាភាពសុខុមនៃរូបសម្មសនៈ

កាលព្រះយោគីនោះ ឃើញច្បាស់នូវសង្ខារទាំងឡាយ ជាជំណាក់ៗ យ៉ាងនេះ រមែងល្អិតឡើង ក្នុងការៈល្អិតសុខុមនៃរូបសម្មសនៈនោះ មានសេចក្តីឧបមាដូច្នេះ ។

ឧបមាដូចអ្នកជនបទម្នាក់ ជាអ្នកធ្វើការស្និទ្ធស្នាលតែក្នុងគប់ភ្លើង គឺគប់ឈើ និងគប់ស្មៅជាដើម មិនធ្លាប់ឃើញប្រទីប ពេលមកព្រះនគរឃើញប្រទីបចាំងពន្លឺក្នុងទីផ្សារ ទើបសួរបុរសម្នាក់ថា **អ្នកដ៏ចម្រើន នុ៎ះហៅអ្វី គួរពេញចិត្តយ៉ាងនោះ** បុរសនោះពោលនឹងអ្នកជនបទនោះថា **គួរពេញចិត្តអ្វីនឹងវា នុ៎ះគេហៅថា ប្រទីប ព្រោះអស់ប្រេង និងព្រោះអស់ប្រឆេះផង** សូម្បីផ្លូវទៅរបស់វាក៏មិនប្រាកដដែរ ។

បុរសដទៃ (ម្នាក់ទៀត) ពោលជាមួយបុរសនោះថា **ការមិនប្រាកដនៃពន្លឺប្រទីប ព្រោះអស់ប្រេង និងប្រឆេះ នេះនៅជាការគ្រោតគ្រាត** ដែលពិត អណ្តាតភ្លើងនឹងរលត់ទៅក្នុងចំណែកទី ៣ នៃប្រឆេះ ដែលកំពុងឆេះដោយលំដាប់នេះ មិនដល់ចំណែកក្រៅអំពីនេះទេ ។ បុរសដទៃម្នាក់ទៀត ពោលនឹងបុរសនោះ យ៉ាងនេះថា **ការរលត់ទៅនៃអណ្តាតភ្លើងក្នុងចំណែកទី ៣ របស់ប្រឆេះនេះ ក៏នៅគ្រោតគ្រាត** ដែលពិតនោះ អណ្តាតភ្លើងនឹងរលត់ទៅក្នុងទីមួយអង្គុលីរបស់ប្រឆេះនេះ មិនដល់អង្គុលីក្រៅអំពីនេះទេ... នឹងរលត់ទៅក្នុងរវាងកន្ទះអង្គុលីរបស់ប្រឆេះនោះ មិនដល់កន្ទះអង្គុលីដទៃក្រៅអំពីនេះទេ... នឹងរលត់ទៅក្នុងសរសៃអំបោះតែ ១ សរសៃរបស់ប្រឆេះនោះ មិនដល់អំបោះសរសៃដទៃក្រៅអំពីនោះទេ... នឹងរលត់ទៅក្នុងជួងអំបោះតែ ១ ជួងរបស់ប្រឆេះនោះ មិនដល់ជួងដទៃក្រៅអំពីនេះទេ តែផុតជួងអំបោះទៅ បុគ្គលណាម្នាក់ ក៏មិនអាចញ៉ាំងអណ្តាតភ្លើង ( ឲ្យប្រាកដ ) បាន ។

# ប្រៀបធៀបសេចក្ដីឧបមាឧបមេយ្យ

ក្នុងឧបមានោះ គប្បីជ្រាបថា ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់ដោយ ១០០ ឆ្នាំ ដោយអាទាន និងនិក្ខេបនៈនៃព្រះយោគី ប្រៀបដូចការដឹងរបស់បុរស ( ដំបូង ) ថា ព្រោះអស់ប្រេង និងប្រឆេះ សូម្បីផ្លូវទៅរបស់ប្រទីប ក៏មិនប្រាកដ ។

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោវុឌ្ឍគតមរូប ដែលកំណត់បរិច្ឆេទដោយចំណែក ៣ ៗ នៃ ១០០ ឆ្នាំ របស់ព្រះយោគី ប្រៀបដូចការដឹងរបស់បុរស ( ទី ២) ថា អណ្ដាតភ្លើងនឹងរលត់ទៅក្នុងចំណែកទី ៣ របស់ប្រឆេះ មិនទៅដល់ត្រង់ចំណែកដទៃឡើយ ។

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់បរិច្ឆេទ ដោយ ១០ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ នៃព្រះយោគីប្រៀបដូចការដឹងរបស់បុរស ( ទី ៣) ថា អណ្ដាតភ្លើងនឹងរលត់ទៅក្នុងចន្លោះអង្គុលីមួយៗ មិនដល់អង្គុលីដទៃក្រៅអំពីនេះឡើយ ។

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់បរិច្ឆេទ ដោយ ៤ ខែ ២ ខែ ដោយបែងឆ្នាំមួយជា ៣ ចំណែក និង ៦ ចំណែក ដោយចែករដូវមួយៗ នៃព្រះយោគី ប្រៀបដូចការដឹងរបស់បុរស (ទី ៤) ថា អណ្ដាតភ្លើង នឹងរលត់ទៅក្នុងចន្លោះកន្លះអង្គុលីៗ មិនទៅដល់កន្លះអង្គុលីក្រៅអំពីនេះឡើយ ។

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់បរិច្ឆេទ ដោយចែកខាងរនោច ខាងខ្នើត ដោយចែកពេលយប់ ពេលថ្ងៃ និងដោយចែកចំណែករបស់ថ្ងៃមានពេលព្រឹកជាដើម ដោយធ្វើយប់ និងថ្ងៃ ១ ឲ្យជា ៦ ចំណែកនៃព្រះយោគីប្រៀបដូចការដឹងរបស់បុរស ( ទី ៥ ) ថា អណ្ដាតភ្លើងនឹងរលត់ទៅក្នុងសរសៃប្រឆេះតែ ១ សរសៃ មិនដល់សរសៃប្រឆេះដទៃក្រៅអំពីនេះឡើយ ។

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់ដោយបែងចែកអាការ ៦ មានការឈានជាដើម និងដោយបែងចែកកិរិយា ៦ មានលើកជើងជាដើមតែ ១ ចំណែកនៃព្រះយោគី ប្រៀបដូចការដើររបស់បុរស (ទី ៦) ថា អណ្តាតភ្លើងនឹងរលត់ទៅក្នុងធ្នង់អំបោះតែ ១ ធ្នង់ ( របស់ប្រទេះ ) មិនដល់ធ្នង់ដទៃក្រៅអំពីនេះឡើយ ។

## មនសិការដោយបែងចែកសមុដ្ឋាន ៤

ព្រះយោគីនោះ កាលលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោវុឌ្ឍគមរូប ដោយអាការផ្សេងៗ យ៉ាងនេះហើយ ពង្រីករូបនោះឯងចេញ ធ្វើឲ្យជា ៤ ចំណែក ដោយបែងចែកសមុដ្ឋាន ៤ មានអាហារមយរូបជាដើម លើកឡើងកាន់ត្រៃលក្ខណ៍ ១ ចំណែកទៀត ។

## មនសិការអាហារមយរូប

ក្នុងរូប ៤ ចំណែកនោះ អាហារមយរូប រមែងប្រាកដដល់ព្រះយោគីនោះដោយអំណាចឃ្លាន និងឆ្អែត ពិតហើយ រូបដែលតាំងឡើងក្នុងពេលឃ្លាន ជារូបស្វិតស្រពោន ថមថយពណ៌សម្បុរ ទ្រង់ទ្រាយប្រែប្រួលទៅ បីដូចដង្គត់ភ្លើងឆេះ និងហាក់ដូចក្អែកញាត់ក្នុងកន្ត្រកធ្យូង រូបដែលតាំងឡើងក្នុងពេលឆ្អែត រមែងជារូបស្រស់បស់ ទន់ភ្លន់ មានសម្ផស្ស ។

ព្រះយោគីនោះ កំណត់យកអាហារមយរូបនោះ លើកឡើងកាន់ត្រៃលក្ខណ៍ក្នុងរូបនោះយ៉ាងនេះថា រូបដែលប្រព្រឹត្តទៅក្នុងពេលឃ្លាន រមែងរលត់ទៅក្នុងពេលឃ្លាននោះឯង មិនទៅដល់ពេលឆ្អែត រូបដែលតាំងឡើងក្នុងពេលឆ្អែតសោត ក៏រលត់ទៅក្នុងពេលឆ្អែតនោះឯង មិនទៅដល់ពេលឃ្លាន ហេតុនោះ សូម្បីអាហារមយរូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។

## មនសិការឧតុមយរូប

ឧតុមយរូប រមែងប្រាកដដោយអំណាចត្រជាក់ និងក្តៅ ពិតហើយ រូបដែលតាំងឡើងក្នុងពេលក្តៅ រមែងជារូបក្រៀមស្រពោន ពណ៌សម្បុរថមថយទៅ រូបដែលតាំងឡើងដោយរដូវត្រជាក់ ( ល្មម ) រមែងជារូបស្រស់ស្រទន់ ។

ព្រះយោគីនោះ កំណត់យកឧតុមយរូបនោះ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះយ៉ាងនេះថា រូបដែលប្រព្រឹត្តទៅក្នុងពេលក្តៅ ក៏រលត់ទៅក្នុងពេលក្តៅនោះឯង មិនទៅដល់ពេលត្រជាក់ រូបដែលប្រព្រឹត្តទៅក្នុងពេលត្រជាក់ ក៏រលត់ទៅក្នុងពេលត្រជាក់នោះឯង មិនទៅដល់ពេលក្តៅឡើយ ហេតុនោះ ឧតុមយរូបនោះ ទើបឈ្មោះថា **មិនទៀង ជាទុក្ខ ជាអនត្តា** ។

## មនសិការកម្មជរូប

កម្មជរូប រមែងប្រាកដដោយអំណាចអាយតនទ្វារ ពិតហើយ ក្នុងចក្ខុទ្វារ មានកម្មជរូប ៣០ ដោយជាចក្ខុទសកៈ ១០ កាយទសកៈ ១០ និងភាវទសកៈ ១០ម្យ៉ាងទៀត រូបឧបការៈកម្មជរូបទាំងនោះ មានឧតុ ចិត្ត និងអាហារជាសមុដ្ឋាន ២៤ ទៀត ដូច្នោះ ទើបជារូប ៥៤ ក្នុងសោតទ្វារ ឃានទ្វារ និងជិវ្ហាទ្វារ ក៏យ៉ាងនោះ ក្នុងកាយទ្វារ មានរូប ៤៤ ដោយជាកាយទសកៈ ១០ ភាវទសកៈ ១០ និងដោយជារូបឧបការៈមានឧតុជាសមុដ្ឋានជាដើម ២៤ ទៀត ក្នុងមនោទ្វារ មានរូប ៥៤ ដូចគ្នា ដោយជាហទយវត្ថុទសកៈ ១០ កាយទសកៈ ១០ ភាវទសកៈ ១០ និងដោយជារូបឧបការៈមានឧតុសមុដ្ឋានរូបជាដើម ២៤ ទៀត ។

ព្រះយោគីនោះ កំណត់យករូបទាំងនោះ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះយ៉ាងនេះថា រូបដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារ ក៏រលត់ទៅក្នុងចក្ខុទ្វារនោះឯង មិនទៅ

ដល់សោតទ្វារ រូបដែលប្រព្រឹត្តទៅក្នុងសោតទ្វារ ក៏រលត់ទៅក្នុងសោតទ្វារនោះឯង មិនទៅដល់ឃានទ្វារ រូបដែលប្រព្រឹត្តទៅក្នុងឃានទ្វារ ក៏រលត់ទៅក្នុងឃានទ្វារនោះឯង មិនទៅដល់ជិវ្ហាទ្វារ រូបដែលប្រព្រឹត្តទៅក្នុងជិវ្ហាទ្វារ ក៏រលត់ទៅក្នុងជិវ្ហាទ្វារនោះឯង មិនទៅដល់កាយទ្វារ រូបដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ក៏រលត់ទៅក្នុងកាយទ្វារនោះឯង មិនទៅដល់មនោទ្វារ ហេតុនោះ ទើបរូបនោះ ឈ្មោះថា **មិនទៀង ជាទុក្ខ ជាអនត្តា** ។

## មនសិការចិត្តសមុដ្ឋានរូប

រូបមានចិត្តជាសមុដ្ឋាន រមែងប្រាកដដោយអំណាចពេលសប្បាយចិត្ត ខូចចិត្ត ពិតហើយ រូបដែលកើតឡើងក្នុងពេលសប្បាយចិត្ត រមែងជារូបស្រស់ស្រាយទន់ភ្លន់ មានសម្ផស្ស រូបដែលកើតឡើងក្នុងគ្រាខូចចិត្ត រមែងជារូបក្រៀមស្រពោន ពណ៌សម្បុរស្លេកស្លាំងទៅ ។

ព្រះយោគីនោះ កំណត់យកចិត្តសមុដ្ឋានរូបនោះ លើកឡើងកាន់ត្រៃលក្ខណ៍ក្នុងរូបនោះយ៉ាងនេះថា រូបដែលប្រព្រឹត្តទៅក្នុងពេលសប្បាយចិត្ត ក៏រលត់ទៅក្នុងពេលសប្បាយចិត្តនោះឯង មិននៅដល់ពេលខូចចិត្ត រូបដែលប្រព្រឹត្តទៅក្នុងពេលខូចចិត្ត ក៏រលត់ទៅក្នុងពេលខូចចិត្តនោះឯង មិននៅដល់ពេលសប្បាយចិត្ត ហេតុនោះ ទើបចិត្តសមុដ្ឋានរូបនោះ ឈ្មោះថា **មិនទៀង ជាទុក្ខ ជាអនត្តា** ។

កាលព្រះយោគីនោះ កំណត់យករូបដែលមានចិត្តជាសមុដ្ឋាន លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះយ៉ាងនេះ អត្ថតទៅនេះ រមែងនឹងប្រាកដឡើងថា

**ជីវិត អត្តភាព និងសុខ ទុក្ខទាំងអស់ ប្រកបទុកនឹងចិត្តមួយខណៈ រមែងប្រព្រឹត្តទៅឆាប់រហ័ស សូម្បីទេវតាដែលមានអាយុវែង តាំងនៅបានរហូត ៨៤ ពាន់កប្ប ក៏មិនមែនរស់នៅជាមួយចិត្ត ២ ដួងឡើយ ។**

ខន្ធពួកណា ដែលរលត់ហើយ របស់សត្វដែលស្លាប់ ឬដែលកំពុងតាំងនៅក្នុងបវត្តិកាលនេះក៏ដោយ ខន្ធទាំងនោះ ក៏ដូចគ្នាទាំងអស់ ( គឺរលត់ ) ទៅមិនតគ្នា ។

ខន្ធទាំងឡាយ ដែល ( ជាបច្ចុប្បន្ន ) រលត់ទៅក្នុងចន្លោះនៃខន្ធ ( អតីត ) ខន្ធអតីតដែលរលត់មកហើយមិនដាច់រយៈ ហើយខន្ធដែលរលត់ក្នុងអនាគត មិនមានការផ្សេងគ្នាក្នុងលក្ខណៈដែលរលត់នោះឡើយ ។

ព្រោះចិត្តមិនកើត សត្វលោកក៏ឈ្មោះថា មិនកើត ព្រោះចិត្តកើតឡើង ចំពោះសត្វលោកក៏ឈ្មោះថា រស់នៅ ព្រោះការបែកធ្លាយនៃចិត្ត សត្វលោកក៏ឈ្មោះថាស្លាប់ នេះជាបញ្ញត្តិទៅលើបរមត្ថ ។

សង្ខារធម៌ទាំងឡាយ ដែលបែកធ្លាយហើយ ក៏មិនបានតាំងនៅ ( ក្នុងទីណា ) គំនរ ( សង្ខារ ) ក្នុងអនាគតមិនមាន សង្ខារទាំងឡាយណា ដែលកើតហើយ តាំងនៅសោត សង្ខារទាំងនោះ ក៏ឧបមាដូចគ្រាប់ស្ពៃ ( ដែលដាក់ចុះ ) លើចុងម្ជុល ( លុះប៉ះចុងម្ជុល ) ក៏ធ្លាក់ទៅមួយរំពេច ។

ម្យ៉ាងទៀត កាលសង្ខារធម៌ទាំងឡាយ កើតហើយ ការបែកធ្លាយ ក៏ចោមរោមធម៌ទាំងនោះទុក ទើបមានការបែកធ្លាយ ជាធម្មតា មិនលាយឡំនឹងធម៌មុនៗ ។

សង្ខារទាំងនោះ មកដោយមិនឃើញ បែកធ្លាយហើយ ក៏ដល់នូវការមិនឃើញកើតឡើង និងវិនាសទៅ ដូចការកើតឡើងនៃផ្លេកបន្ទោរក្នុងអាកាស ដូច្នោះ ។

## ធម្មតារូប

ព្រះយោគីនោះ កាលលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបទាំងឡាយ មានអាហារមយរូបជាដើមយ៉ាងនេះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ក្នុងធម្មតារូបទៀត

រូបដែលកើតឡើង ចាប់ផ្តើមតាំងអំពីវិវដ្តកប្ប មានប្រភេទផ្សេងៗ ដូចជាដែកលោហៈ ( ទង់ដែង ) សំណប៉ាហាំង សំណ មាស ប្រាក់ មុក្តា មណី ពិទូរ្យ ស័ង្ខ

សិលាពណ៌ បវាឡ ទទឹម កែវមានធ្នូត ផែនដី ថ្ម ភ្នំ ស្មៅ ដើមឈើ វល្លិ៍ ដែលជារូបខាងក្រៅ មិនទាក់ទងដោយឥន្ទ្រិយ ឈ្មោះថា ធម្មតារូប ។

ធម្មតារូបនោះ រមែងប្រាកដដល់ព្រះយោគីនោះដោយ ( ជាឧទាហរណ៍ ) ត្រួយអសោកជាដើម ។ ឯត្រួយអសោកនោះ ដំបូងក៏ជាពន្លកក្រហមតិចៗ បន្ទាប់ពីនោះ កន្លងទៅ ២-៣ ថ្ងៃ ក៏ក្រហមចាស់ឡើង កន្លងទៅ ២-៣ ថ្ងៃទៀត ក្រហមចាស់ឡើង កន្លងទៅ ២-៣ ថ្ងៃទៀត ក្រហមពញាក់ តអំពីនោះ ( ជាស្លឹកខ្ចី ) មានពណ៌ដូចស្លឹកខ្ចីដំបូង ( របស់ឈើដទៃៗ មានស្វាយជាដើម ) តទៅទៀត មានពណ៌ជាស្លឹកខ្ចីដែលចាស់ឡើងបន្តិច តទៅទៀត ជាស្លឹកពណ៌ខៀវខ្ចី ហើយជាពណ៌ខៀវចាស់ តាំងអំពីកាលដែលជាស្លឹកពណ៌ខៀវចាស់នោះទៅ ឈើនេះធ្វើការបន្តនៃរូប (ស្លឹក) ដែលស្មើគ្នាឲ្យបន្តរឿយៗ ទៅ (មិនផ្លាស់ប្តូរពណ៌) ដោយកាលប្រមាណមួយឆ្នាំ ទើបជាស្លឹកលឿង ជ្រុះចាកទងទៅ ។

ព្រះយោគីនោះ កំណត់កាន់យកស្លឹកអសោកនោះ លើកឡើងកាន់ត្រៃលក្ខណ៍ក្នុងធម្មតារូបនោះ យ៉ាងនេះថា រូបដែលប្រព្រឹត្តទៅក្នុងកាលដែលវា មានពណ៌ក្រហមព្រឿងៗ រមែងរលត់ទៅ មិននៅមកដល់កាលដែលស្លឹកនេះ មានពណ៌ក្រហមចាស់ឡើយ រូបដែលប្រព្រឹត្តទៅក្នុងកាលដែលស្លឹកនេះ មានពណ៌ក្រហមចាស់ ក៏រលត់ទៅមិនមកដល់កាលដែលស្លឹកមានពណ៌ក្រហមពញាក់ឡើយ រូបដែលប្រព្រឹត្តទៅក្នុងកាលដែលស្លឹកពណ៌ក្រហមពញាក់ ក៏រលត់ទៅមិនមកដល់កាលដែលមានពណ៌ដូចពន្លកស្លឹកខ្ចីឡើយ រូបដែលប្រព្រឹត្តទៅក្នុងកាលដែលមានពណ៌ដូចពន្លកស្លឹកខ្ចី ក៏រលត់ទៅមិនមកដល់កាលដែលស្លឹកមានពណ៌ជាស្លឹកខ្ចី ដែលចាស់ឡើងឡើយ រូបដែលប្រព្រឹត្តទៅក្នុង កាលដែលស្លឹកមានពណ៌ជាស្លឹកខ្ចី ដែលចាស់ឡើង ក៏រលត់ទៅមិនមកដល់កាលដែលវាជាស្លឹកពណ៌ខៀវខ្ចីឡើយ រូបដែលប្រព្រឹត្តទៅក្នុងកាលដែល

វាជាស្ទឹកពណ៌ខៀវខ្ចីក៏រលត់ទៅមិនមកដល់កាលដែលវាជាស្ទឹកពណ៌ខៀវចាស់ឡើយ រូបដែលប្រព្រឹត្តទៅក្នុងកាលដែលស្ទឹក មានពណ៌ខៀវចាស់ ក៏រលត់ទៅមិននៅមកដល់កាលដែលវាជាស្ទឹកលឿងឡើយ រូបដែលប្រព្រឹត្តទៅក្នុងកាលដែលវាជាស្ទឹកពណ៌លឿង ក៏រលត់ទៅ មិននៅមកដល់កាលដែលរោយចាកទងស្វិតទៅឡើយ ហេតុនោះ ទើបស្ទឹកឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា ។ ដូច្នេះហើយ ការពិចារណាធម្មតារូបទាំងពួង ក៏ដោយន័យនេះ ។

ព្រះយោគីពិចារណាសង្ខារទាំងឡាយ លើកឡើងកាន់ត្រៃលក្ខណ៍ ផ្នែករូបសត្តកៈដូចពោលមកដូច្នេះ ជាលំដាប់ដំបូង ។

# មហាដីកា

## កថាពណ៌នាដោយការពិចារណារូប

## ដោយអាការ ៧

ការធ្វើមនសិការក្នុងរូប ៧ ប្រការ ឈ្មោះថា **រូបសត្តកៈ** ។ សេចក្តីថា មនសិការក្នុងរូបធម៌ ដោយអាការ ៧ យ៉ាង ។ គប្បីជ្រាបសូម្បីអរូបសត្តកៈយ៉ាងនេះ ។ ពាក្យថា **ដោយអាការទាំងនេះ** គឺដោយប្រការ មានការធ្វើមនសិការការកាន់យក និងការលះបង់ចោលទៅជាដើមនេះ មួយ៉ាងទៀត ដោយចំណែកតាមដែលពោលហើយនេះ ។ ពាក្យថា **លើកឡើង** គឺលើកឡើងកាន់ត្រៃលក្ខណ៍ ។

ពាក្យថា **ដោយការកាន់យក និងលះបង់ចោលទៅ** បានដល់ ដោយការកាន់យកកត និងលះបង់កតចោលទៅ អធិប្បាយថា ដោយការកើត និងការស្លាប់ បទថា **វយោវុឌ្ឍត្ថគាមិតោ** ប្រែថា ដោយការៈដែលធ្លាក់ទៅ អធិប្បាយថា ដោយការដល់នូវការតាំងនៅមិនបាននៃរូបដែលធំឡើងតាមវ័យ ។ បទថា **អាហារតោ** ប្រែថា ព្រោះមានអាហារជាហេតុ អធិប្បាយថា ព្រោះអាហារដែលជាបច្ច័យដល់រូប ។ រូបដែលសម្រេចដោយសភាវៈ មិនបានសម្ព័ន្ធដល់កម្ម មានពណ៌ និងសណ្ឋានផ្សេងៗ ផ្សេងដោយជាដែក ជាលោហៈ ជាដើម ជាផែនដី ជាថ្មជាដើម ឈ្មោះថា **រូបធម្មតា** ។ ពាក្យថា **៧** គឺ ៧ ប្រការ បានដល់ ដោយអាការ ៧ យ៉ាង ។ ពាក្យថា **រមែងឃើញច្បាស់** គឺរមែងលើកចំណែកនោះៗ ឡើងកាន់ត្រៃលក្ខណ៍ ឃើញច្បាស់ គឺពិចារណា ។

លោកអាចារ្យបានពោលថា បទថា **អាទានំ ការកាន់យក** បានដល់ **បដិសន្ធិ** ព្រោះធ្វើអធិប្បាយថា បានដល់ ការកាន់យកអំពីខាងដើមនូវការៈ គឺខន្ធដោយមាន

ព្រះបាលីថា **ភារាទានំ ទុក្ខំ លោកេ** ការកាន់យកភារៈ ជាទុក្ខក្នុងលោក ដូច្នេះ ។ ម្យ៉ាងទៀត លោកអាចារ្យពោលថា បទថា **និក្ខេបនំ** ការលះបង់ចោលទៅ បានដល់ **ចុតិ** ព្រោះធ្វើអធិប្បាយថា បានដល់ ការលះបង់ចោលភារៈ គឺខន្ធ ដោយមានព្រះបាលីថា **សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ** ប្រែថា សត្វទាំងឡាយរមែងចោលរាងកាយទុកក្នុងលោក ដូច្នេះ ។

ពាក្យថា **កំណត់ ១០០ ឆ្នាំ** លោកពោលទុក ព្រោះការបន្ទូរ និងក្រៃលែងជាង ១០០ ឆ្នាំនោះមិនជាប្រមាណ ដោយព្រះបាលីថា **បុគ្គលណា នៅបានយូរ បុគ្គលនោះក៏នៅបាន ១០០ ឆ្នាំ** ។ ពាក្យថា **សង្ខារទាំងឡាយក្នុងចន្លោះនេះ** គឺសង្ខារទាំងឡាយបានដល់ ដែលផ្សេងដោយប្រភេទ ជាភូតរូប និងឧបាទាយរូបប្រព្រឹត្តទៅហើយក្នុងចន្លោះនេះ គឺចន្លោះការកាន់យក និងការលះបង់ចោលទៅ ។ សេចក្តីនេះ ជាវិធីពិចារណាក្នុងរូបធម៌ទាំងឡាយនោះឯង ។ លោកពោលពាក្យថា **ព្រោះហេតុអ្វី** ជាដើម ដើម្បីបញ្ជាក់អត្ថ ដែលកាន់យកថា **មិនទៀង** ទុកក្នុងចិត្ត ដោយត្រឹមត្រូវ ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ព្រោះប្រព្រឹត្តទៅដោយអំណាចការកើតឡើង និងការវិនាសទៅ** គឺព្រោះប្រព្រឹត្តទៅដោយអំណាចការកើតឡើង និងដោយអំណាចការរលត់ទៅ អធិប្បាយថា ព្រោះមិនមាន ហើយមានឡើង ព្រោះមានហើយ ដល់នូវការវិនាសទៅ ។ ពាក្យថា **ព្រោះប្រែប្រួលបាន** លោកអាចារ្យទាំងឡាយពោលថា ព្រោះការបន្តគ្នា ហាក់ដូចជាព្រះអាទិត្យនាទិសព្វស្សាន អធិប្បាយថា ពាក្យនោះគប្បីជាពាក្យដែលលោកពោលដោយបំណងថា សេចក្តីនេះ ជាការពិចារណាក្នុងរូបដែលកំណត់ ១០០ ឆ្នាំ ដូច្នេះនោះឯង ព្រោះជារូបដែលនឹងត្រូវជរា និងមរណៈឲ្យប្រែប្រួលទៅ ។ កាលមិនមានការបែកធ្លាយនៃធម៌ ក៏គប្បីប្រាថ្នាការបែកនៃកិរិយាដែលតាំងចុះ ។ ព្រោះកិរិយាដែលតាំងចុះ គឺការកើតតែម្យ៉ាង នឹងគួរជាកិរិយាដែលតាំងចុះ គឺការរលត់

ក៏ទេ ។ ពិតហើយ លោកអាចារ្យបានពោលទុកថា **ព្រោះមានការប្រែប្រួលបានជាប្រក្រតី ដោយអាការ ២ គឺដោយជរា និងដោយមរណៈ** ។ ម្យ៉ាងទៀត ការប្រាសទៅនៃសភាវៈនោះឯង គឺការប្រែប្រួលបានក្នុងទីនេះ ។ ភាពជារបស់មួងម្កាល ឈ្មោះថា **ភាពជារបស់មួងម្កាល** ។ ការមិនមានសភាវៈដែលទៀងនោះឯង ឈ្មោះថា **ប្រដែងចំពោះការទៀង** ឯធម៌ដែលមិនទៀងទាំងឡាយ ឈ្មោះថា **រមែងប្រដែងភាពជារបស់ទៀង** នៃបុគ្គលអ្នកដឹងដោយសភាវៈរបស់ខ្លួននោះឯង ។ ព្រោះថា វត្ថុណាមិនមែនជារបស់ទៀង ហេតុនោះ វត្ថុនោះឈ្មោះថា **មិនទៀង** ។ សង្ខារ មានកិរិយាតាំងចុះណាក្នុងខណៈកើតឡើង កិរិយាតាំងចុះនោះ មិនទៅក្នុងខណៈតាំងនៅឡើយ ព្រោះហេតុនោះ អាការលំបាករបស់សង្ខារទាំងនោះ ទើបដឹងបានដោយការប្រព្រឹត្តទៅក្នុងរវាងកិរិយាតាំងចុះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងខណៈតាំងនៅរមែងលំបាកដោយជរា** ដូច្នេះ សេចក្តីនេះ បណ្ឌិតគប្បីជ្រាបដោយជរាដែលមិនកំបាំង ។ ចំណែកអាចារ្យពួកណា មិនទទួលការតាំងនៅរបស់សង្ខារទាំងឡាយ ពាក្យដែលគប្បីពោលក្នុងប្រការនោះ បានពោលទុកហើយខាងដើមនោះឯង ។ ធម្មតាសភាវៈរបស់ធម៌ទាំងឡាយ ឈានកន្លងបានលំបាក ត្រូវបែកធ្លាយទៅក្នុងលំដាប់នៃជរា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដល់ជរាហើយ ក៏នឹងបែកមែនពិត** ។ ពាក្យថា **ព្រោះហេតុនោះ** សេចក្តីថា សង្ខារជាសភាវៈដែលត្រូវបៀតបៀនជានិរន្តរ៍ ដោយអំណាចការកើត ការចាស់ និងការបែកធ្លាយ ព្រោះហេតុនោះ សង្ខារទាំងនោះ ជាសភាវៈដែលមានទុក្ខ ដោយការៈដែលអត់ធន់បានលំបាក ទាំងសភាវៈជាទីតាំងនៃទុក្ខ ព្រោះជាទីធ្លាក់ចុះនៃទុក្ខទាំង ៣ ប្រការ និងនៃសង្ខារទុក្ខផង ព្រោះហេតុណា គឺព្រោះហេតុនោះ ។ មានពាក្យប្រកបថា សង្ខារទាំងឡាយ ឈ្មោះថា **ជាទុក្ខ** ព្រោះបៀតបៀនរឿយៗ មកទល់ឥឡូវនេះ ។

ពាក្យថា **ព្រោះប្រជែងចំពោះសុខ** នេះ មានន័យដូចបានពោលទុកហើយ ។ **ចូរកុំដល់នូវការតាំងនៅឡើយ** អធិប្បាយថា ចូរប្រព្រឹត្តទៅដោយអាការដែលកើតឡើងតែម្យ៉ាងចុះ ។ ដោយពាក្យថា **ដែលកើតឡើងហើយ** នេះ លោកអាចារ្យពោលការដល់ព្រមដោយខណៈដែលកើតឡើង ។ សួរថា លោកពោលថា **ដែលដល់នូវការតាំងនៅហើយ សូមកុំជរាឡើយ** ដូច្នេះ ព្រោះហេតុអ្វី ការតាំងនៅនោះឯង ដោយអត្ថ ក៏គឺជរាមិនមែនឬ ? ឆ្លើយថា សេចក្តីនេះពិត គប្បីឃើញថា ការលំបាកណាដោយអំណាចជរា ការលំបាកនោះលោកកាន់យកដោយស័ព្ទថា **ជរាក្នុងទីនេះ** ។ បុគ្គលរមែងសង្ឃឹមការទៀងថា **សូមកុំបែកធ្លាយឡើយ** ។ ការប្រើអំណាចបង្គាប់បញ្ជាបានរមែងមិនមានដល់បុគ្គលណាម្នាក់ គឺសូម្បីដល់ព្រះសាស្តាដ៏ជាធំក្នុងធម៌ ។ ព្រោះថាបុគ្គលណាម្នាក់ មិនអាចធ្វើភាពជាដទៃនៃលក្ខណៈបាន ។ ព្រោះថា ភាពដទៃនៃភាវៈនោះឯង ជាវិស័យនៃឫទ្ធិ ។ សង្ខារទាំងឡាយ **ទទេចាកអាការប្រើអំណាច** ក្នុងឋានៈទាំង ៣ **នោះ** ។ បទថា **តស្មា** ជាពាក្យប្រារព្ធដល់ហេតុដែលពោលទុកហើយ ។ ពាក្យថា **ព្រោះជារបស់ទទេ** សេចក្តីថា ព្រោះជារបស់ទទេអំពីវត្ថុនោះ ដោយវៀរចាកអ្នកគ្រប់គ្រង អ្នកសាង អ្នកសោយផល និងអ្នកថែរក្សា មិនមែនព្រោះមិនមានសភាវៈ ព្រោះហេតុនោះ ទើបឈ្មោះថា ព្រោះជារបស់ទទេចាកសភាវៈ ដែលបុគ្គលខ្លះគិតស្មាននោះឯង ។ ពាក្យថា **ព្រោះមិនមានម្ចាស់របស់** គឺព្រោះមិនមានបុគ្គលណាជាម្ចាស់របស់ ។ ដោយពាក្យនេះ លោកអាចារ្យរមែងសម្តែងដល់របស់ដែលមិនមែនជារបស់ខ្លួន ។ ពាក្យថា **ព្រោះប្រើអំណាចមិនបាន** គឺព្រោះមិនមានការប្រើអំណាចតាមដែលពោលហើយ ។ ពាក្យថា **ព្រោះប្រជែងចំពោះអត្តា** គឺព្រោះប្រជែងចំពោះអត្តា ដែលលទ្ធិដទៃគិតដៅស្មានយកខ្លួនឯង ។ ដោយពាក្យថា **ព្រោះជារបស់ទទេ** ជាដើម លោកអាចារ្យពោលការវៀរចាកអត្តា ដែលលទ្ធិខាងក្រៅគិតដៅស្មានយក

ម្យ៉ាងទៀត ដោយពាក្យនេះ អត្តាមែនមិនមាន ព្រោះមិនមែនមានអត្តានោះជាសភាវៈឡើយ ។

ក្នុងអធិការនេះ សង្ខារទាំងឡាយ ឈ្មោះថា មិនទៀង ក៏ដោយហេតុ ៤ យ៉ាង ដោយពាក្យជាដើមថា **ព្រោះប្រព្រឹត្តទៅដោយការកើតឡើង និងការវិនាសទៅ** ឈ្មោះថា **ជាទុក្ខ** ដោយហេតុ ៤ យ៉ាង ដោយពាក្យជាដើមថា **ព្រោះបៀតបៀនរឿយៗ** មករហូតឥឡូវនេះ ឈ្មោះថា **ជាអនត្តា** ដោយហេតុ ៤ យ៉ាង ដោយពាក្យជាដើមថា **ព្រោះជារបស់ទទេ** ហេតុនោះ ព្រះយោគាវចរកាលកំណត់ពិចារណាលក្ខណៈទាំង ៣ ដែលមាននៅជាប្រចាំក្នុងរូបធម៌ ដែលខ្លួនមិនបានកំណត់ទុកមុន ទើបលោកហៅថា លើកលក្ខណៈទាំង ៣ នោះទុកក្នុងរូបធម៌នោះ ។ ព្រោះព្រះយោគាវចរនោះពិចារណាដោយអំណាចអាទាន គឺការកាន់យក និងនិក្ខេបនៈការលះបង់ចោលទៅយ៉ាងនោះ ទើបលោកអាចារ្យពោលថា **លើកឡើងកាន់ត្រៃលក្ខណ៍ក្នុងរូប** ដូច្នេះ ។

ក្នុងត្រៃលក្ខណ៍នោះ ព្រោះការកាន់យកទុក្ខលក្ខណៈ មានការកាន់យកអនិច្ចលក្ខណៈជាខាងដើម ឬកាន់យកអនត្តលក្ខណៈ ក៏មានការកាន់យកទុក្ខលក្ខណៈជាខាងដើម ។ ហើយក្នុងត្រៃលក្ខណ៍នេះ អនិច្ចលក្ខណៈ កាលសម្តែងដោយការផ្សេងនៃរូប ក៏គួរសម្តែងតាមគួរដល់រូបដែលគ្រោតគ្រាត ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងអនិច្ចលក្ខណៈនោះអំពីដំបូង ដោយការកំណត់ ១០០ ឆ្នាំ ទើបបានផ្តើមវិធីពិចារណារូបទាក់ទងដោយវ័យ ដោយពាក្យជាដើមថា **១០០ ឆ្នាំនោះឯង** ដូច្នេះដើម្បីសម្តែងថា ការបែកដោយពាក្យថា **១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ** ជាដើម សម្រាប់បុគ្គលដែលនៅបាន ១០០ ឆ្នាំហើយ ឃើញការបែកធ្លាយរបស់រូប ដោយអំណាចកោដ្ឋាស មានការលើកជាដើម ជាកំណត់ដោយលំដាប់តអំពីនោះ ក៏លើកឡើងកាន់ត្រៃលក្ខណ៍ គឺ **មិនទៀង ជាទុក្ខ ជាអនត្តា** ជាការពិចារណា ដោយការផ្លាក់ទៅ

នៃរូប ដែលធំចម្រើនឡើង ដោយអំណាចវ័យ ។ ក្នុងអនិច្ចលក្ខណៈនោះ ព្រោះលោកកាន់យកភាពផ្សេងនៃរូបអំពីដើមនេះ ដោយអំណាចរូប ដែលគ្រោតគ្រាត ដូច្នោះ ទើបលោកមិនបានចែកទុកដោយអំណាចចំណែកដែលស្មើគ្នា រហូត ១០០ ឆ្នាំ ឬបន្ថែមឡើង ១ ឆ្នាំ ក្នុងមជ្ឈិមវ័យ ព្រោះការកំណត់មជ្ឈិមវ័យ យ៉ាងនោះ ។

១០ ឆ្នាំ ដែលប្រព្រឹត្តទៅដោយភាពជាកុមារជាចំណែកច្រើន ឈ្មោះថា **មន្ទទសកៈ** ប្រែថា ១០ ឆ្នាំ នៃកុមារភាព ។ សូម្បីក្នុងទសកៈដ៏សេស ក៏មានន័យនេះ។

ពាក្យថា **ក្នុងពេលនោះ** គឺក្នុង ១០ ឆ្នាំដំបូង ។ បទថា **សោ យោគ បុគ្គលោ** ប្រែថា បុគ្គលនោះ ។ ពាក្យថា **ឃ្លេងឃ្លោង** បានដល់ ឃ្លេងឃ្លោង ដោយកិរិយាដែលមិនឈប់ស្ងៀម ។ ដោយពាក្យនោះ លោកអាចារ្យធ្វើឲ្យផ្សេងទៅអំពីភាពជាបុគ្គលវង្វេង ។ ព្រោះថា កុមារតូចនេះ មិនមែនជាបុគ្គលទន់ខ្សោយ ដោយភាពជាបុគ្គលវង្វេង ដូចក្នុងទសកៈទី ៩ ឡើយ ដោយពិត ជាបុគ្គលទន់ខ្សោយ ព្រោះជាបុគ្គលឃ្លេងឃ្លោង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ជាកុមារតូច** ។ ក្នុងទសកៈទី ៣ ពណ៌សម្បុរផូរផង់តាមគួរ ព្រោះការបរិបូណ៌នៃសាច់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ពណ៌សម្បុររមែងដល់នូវភាពបរិបូណ៌** ។ ក្នុងទសកៈទី ៤ **កម្លាំង និងសមត្ថភាព រមែងដល់នូវការពេញបរិបូណ៌** ព្រោះឆ្អឹង និងសរសៃដល់នូវការរឹងមាំ ។ ក្នុងទសកៈទី ៥ បញ្ញារមែងជាធម្មជាតិស្រស់បំព្រងតាមគួរ ព្រោះការស្រើនក្នុងភាពជាកំលោះក្រមុំនៅឆ្ងាយ និងព្រោះភាពដែលកិលេសស្រោលស្តើងដោយច្រើន ។ ការត្រេកអរក្នុងការលេង ឈ្មោះថា **ខិឌ្ឌារតិ** ប្រែថា ការត្រេកអរក្នុងការលេង ។ បណ្ឌិតគប្បីជ្រាបការចម្រើន និងការវិនាសដល់បញ្ញាក្នុងទសកៈទី ៥ និងទី ៦ ដោយការផ្សេងគ្នានៃទីអាស្រ័យ ប្រៀបដូចភាពបរិសុទ្ធជាដើមរបស់ពន្លឺប្រទីបដោយភាពផ្សេងគ្នានៃទីអាស្រ័យបានដាក់ប្រេងជាដើម ។ **រាងកាយរមែងកោងទៅ**

**ខាងមុខ** សម្រាប់បុគ្គលទាប ទាក់ទងនឹងទី.តនៃចង្កេះ និងទី.តនៃ.ក នឹងពោលទៅថ្វី ដល់បុគ្គលខ្ពស់ ។ ពាក្យថា **កោងទៅ** បានដល់ សំយុងទៅ ដោយភាពជាអវយវៈ ធូន់ ។ ឈ្មោះថា **ជាបុគ្គលច្រើនដោយការវង្វេង** ព្រោះប្រាសចាកសតិ និងបញ្ញា ។ ជាបុគ្គលច្រើនទៅដោយ **ការដេក** គឺមិនអាចនឹងនាំការៈ គឺសរីរៈទៅបាន ទាក់ទង ជាមួយឥរិយាបថ មានការឈរជាដើម ។

ពាក្យថា **៣ ឆ្នាំៗ** លោកអាចារ្យពោលទុកដោយភាវៈ ដែលជាចំណែកច្រើន ។ ព្រោះថា មួយចំណែក មាន ៤ ឆ្នាំ ក៏រមែងមានដូច្នេះ ។ គប្បីជ្រាបថា ធ្វើជា ២០០ ចំណែក ដោយអំណាចការប្រព្រឹត្តទៅតែមួយចំណែកៗ ដូច្នេះក៏មាន ។

ក្លាប់សេចក្តីបាលីថា ***វស្សានេ បវត្តរូបំ*** រូបដែលប្រព្រឹត្តទៅក្នុងរដូវភ្លៀង ។

ឯរដូវនោះមានរយៈត្រឹម ២ ប៉ុណ្ណោះ មិនមែន ៤ ខែដូចខាងដើម ហេតុនោះ ទើបលោកពោលថា **ទ្វេមាសំ** ប្រែថា ២ ខែ ដូច្នេះ ។ បទថា **ទ្វេមាសំ** នេះ ជា ទុតិយាវិភត្តិ ចុះក្នុងអច្ចន្តសំយោគ ។ ឯរដូវនោះ គប្បីជ្រាបថា **វស្សានរដូវ** ( រដូវភ្លៀង ) បានដល់ ខែស្រាពណ៍ និងខែភទ្របទ ( រាប់អំពី ១ រោចខែអាសាឍដល់ ១៥ កើតខែភទ្របទ ) **សរទរដូវ** ( រដូវស្ទឹកឈើជ្រុះ ) បានដល់ ខែអស្សុជ និង ខែកត្តិក ( រាប់អំពី ១ រោចខែភទ្របទដល់ ១៥ កើត ខែកត្តិក ) **ហេមន្តរដូវ** ( រដូវសន្សើមធ្លាក់ ) បានដល់ ខែមិគសិរ និងខែបុស្ស ( រាប់អំពី ១ រោចខែកត្តិកដល់ ១៥ កើតខែបុស្ស ) **សិសិររដូវ** ( រដូវរងា ) បានដល់ ខែមាឃ និងខែផល្គុណ ( រាប់អំពី ១ រោចខែបុស្សដល់ ១៥ កើតខែផល្គុណ ) **វសន្តរដូវ** ( រដូវស្ទឹកឈើលាស់ ) បានដល់ ខែចេត្រ និងខែពិសាខ ( រាប់អំពី ១ រោចខែផល្គុណដល់ ១៥ ខែពិសាខ ) **គិម្ហរដូវ** ( រដូវក្តៅ ) បានដល់ ខែជេស្ឋ និងខែអាសាឍ (រាប់អំពី ១ រោចខែពិសាខដល់ ១៥ កើតខែអាសាឍ ) ។

ពាក្យថា **ធ្វើឲ្យជា ៦ ចំណែក** គឺធ្វើឲ្យជា ៦ ចំណែក ទាក់ទងជាមួយនឹងអ្នកវេបំ ១០៧ នាក់ ។

ការឈានទៅចំពោះមុខ គឺខាងមុខ ឈ្មោះថា **ការឈានទៅមុខ** ។ ការឈានទៅទាក់ទងនឹងការត្រឡប់ ឈ្មោះថា **ការឈានថយក្រោយ** ។ ការក្រឡេកមើលទៅមុខ ឈ្មោះថា **ការក្រឡេកមើលទៅមុខ** ។ ការក្រឡេកមើលទៅទិសផ្សេងៗ គឺខាងនោះខ្លះ ខាងនេះខ្លះ ឈ្មោះថា **ការក្រឡេកមើលឆ្វេង-ស្តាំ** ។ ការបត់ដៃ-ជើង ឈ្មោះថា **ការបត់អង្គុញ** ។ ការលាទៅ ឈ្មោះថា **ការលាតសណ្តូក** ពាក្យថា **ក្នុងពេលលើកជើង** គឺក្នុងវេលាលើកជើងទី ២ ។ ពាក្យថា **ជើង** បានដល់ ជើងដែលលើកឡើង ។ ពាក្យថា **មានប្រមាណតិច** គឺមានប្រមាណតិចជាងសមត្ថភាព ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ទន់ខ្សោយ** ។ ពាក្យថា **ធាតុ ២ ក្រៅអំពីនេះ** បានដល់ តេជោធាតុ និងវាយោធាតុ ។ ការលើកជើងនឹងសម្រេចបានដោយប្រការណា ក៏ចាំបាច់មានតេជោធាតុ និងវាយោធាតុ ដែលជាធម្មជាតិមានប្រមាណក្រៃលែងដោយចំណែក ១ ក្នុងរូបដែលមានចិត្តជាសមុដ្ឋានប្រព្រឹត្តទៅដោយប្រការនោះ ព្រោះតេជោធាតុ និងវាយោធាតុទាំងនោះ ជាសភាវៈស្រាល ។ ព្រោះហេតុនោះឯង បឋវីធាតុ និងអាបោធាតុក្រៅអំពីនេះ ជាធម្មជាតិ មានប្រមាណតិច ក៏ព្រោះមានសភាវៈធ្ងន់ ។ ឯរូបដែលមានសមុដ្ឋាន ៣ ដ៏សេស ក៏មានគតិដូច្នោះនោះឯង ព្រោះសម្ពន្ធគ្នាជាមួយធាតុទាំង ៤ នោះ ។ គប្បីឃើញថា បឋវី និងវាយោ មានប្រមាណក្រៃលែងក្នុងការប្រព្រឹត្តទៅរបស់កាយវិញ្ញត្តិ និងវចីវិញ្ញត្តិ ជាគំរូក្នុងសេចក្តីនេះ ។ ក្នុងការនាំជើងទៅខាងមុខ និងក្នុងការនាំជើងទៅខាងក្រោយ ក៏មានការប្រព្រឹត្តទៅ នៃរូបដែលមានសភាវៈស្រាល ដូចក្នុងការលើកជើង ព្រោះហេតុនោះ ទើបគប្បីប្រាថ្នា ធាតុទាំង ២ នោះឯង មានប្រមាណក្រៃលែង ព្រោះហេតុនោះ ទើបលោក

អាចារ្យពោលថា ក្នុងចំណែកការបោះទៅមុខ និងចំណែកផ្លាស់ ក៏យ៉ាងនោះ ។ លោកអាចារ្យកាលសម្តែងថា ក្នុងចំណែកលើកជាដើម កិច្ចនៃធាតុទាំង ២ ខាងចុង មានប្រមាណច្រើន ព្រោះមានសភាវៈស្រាល កិច្ចនៃធាតុក្រៅអំពីនេះ មានប្រមាណតិច ដោយប្រការណា ក្នុងចំណែកទាំង ៣ មានការដាក់ជើងចុះជាដើម កិច្ចនៃធាតុទាំង ២ ខាងដើម មានប្រមាណច្រើន ព្រោះមានសភាពធ្ងន់ កិច្ចនៃធាតុក្រៅអំពីនេះ មានប្រមាណតិច ដូច្នេះ ទើបពោលពាក្យថា **ក្នុងការដាក់ជើងចុះ** ដូច្នេះជាដើម ។

បទថា **តទុបាទាយរូបានិ** ប្រែថា ឧបាទាយរូបដែលប្រព្រឹត្តទៅអាស្រ័យធាតុទាំងនោះ ។ បទថា **ឯត្ថេវ យោគ ឧទ្ធរណេយេវ** ប្រែថា ក្នុងចំណែកលើកជើងនេះឯង ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មិនទៅដល់ចំណែកបោះទៅមុខ** ។ បទថា **ឥតិ** ប៉ុនគ្នានឹង **ឯវំ** ប្រែថា យ៉ាងនេះ ។ ពីរបទថា **តត្ថ តត្ថ** សេចក្តីប៉ុនគ្នានឹង **តស្មិំ តស្មិំ យោគ ឧទ្ធរណាទិកោដ្ឋាសេ** ប្រែថា ក្នុងចំណែកមានការលើក ជើងជាដើមនោះៗ ។ ពាក្យថា **ជាដំណាក់** ជាដើម ជាពាក្យសម្តែងការមិនមាននូវការលាយឡំគ្នានៃចំណែកដទៃរបស់ធម៌ទាំងនោះ ។ ពាក្យថា **បែកឮតដៈ តដៈ** គឺឮដូចសំឡេង តដៈ តដៈ ដោយពាក្យនោះ លោកអាចារ្យរមែងសម្តែងខណៈ ប្រព្រឹត្តទៅនៃធម៌ទាំងនោះ មានប្រមាណតិច ។

បទថា **អស្ស យោគ សម្មសនស្ស** ប្រែថា នៃសម្មសនៈនោះ ។ បទថា **ទារុតិណុក្កាទីសុ** សេចក្តីប៉ុនគ្នានឹង **ទារុឧក្កាតិណុក្កាទីសុ** ប្រែថា ក្នុងគប់ភ្លើង មានគប់ឈើ និងគប់ស្មៅជាដើម ។ បុរសនោះពោលថា **គួរពេញចិត្តអ្វីក្នុងវា** អធិប្បាយថា ហៃ មនុស្សល្ងង់ខ្លៅ ហេតុអ្វី ទើបអ្នកសម្គាល់វត្ថុដែលតាំងនៅមួយរយៈ ថាមាននៅគ្រប់កាល ដោយការជាប់តគ្នាថា ដូចគ្នាទៅវិញហ្ន៎ ។ បទថា **ឥទម្បិ** សេចក្តីថា ការមិនប្រាកដនៃពន្លឺប្រទីប ព្រោះអស់ប្រេង និងប្រឆេះនោះ ។ ពាក្យថា **ក្នុងរវាង**

**តែមួយអង្គុលី** សេចក្ដីថា ក្នុងចំណែក មានប្រមាណមួយថ្នាំងដៃ ( ស្មើនឹង ៧ ធញ្ញមាស ) ថា ១ អង្គុលី ប្រមាណប៉ុនគ្នានឹង ១ ធ្នាប់ ។ លោកអាចារ្យពោល ថា **តែផុតជួងអំបោះទៅ** ដូច្នេះ សំដៅជួងអំបោះដែលដល់នូវភាពជារបស់ល្អិតបំផុត ដែលជាចំណែកបន្តិចបន្តួចរបស់សរសៃអំបោះ ។

បទថា **តត្ថ** ជាដើម ជាពាក្យប្រៀបធៀបពាក្យឧបមា ។ ក្នុងពាក្យនោះ មិនមាន ការផ្សេងគ្នានៃកាលប្រាកដក្នុងពាក្យឧបមា ដូចជាក្នុងពាក្យឧបមេយ្យក៏ពិត សូម្បី យ៉ាងនោះ ក៏គប្បីជ្រាបសេចក្ដីនៃពាក្យឧបមា ដោយពាក្យត្រឹមប៉ុណ្ណេះថា មិនដល់ ចំណែកដទៃដែលដល់ចំណែក ១ ។ម្យ៉ាងទៀត សូម្បីក្នុងពាក្យឧបមា ក៏បានត្រឹមតែ ការផ្សេងគ្នានៃកាលថា ត្រឹមនោះ ត្រឹមណាប៉ុណ្ណោះ ព្រោះហេតុនោះ ក្នុងការកាន់ យកត្រឹមភាពផ្សេងគ្នានៃកាលនោះ គប្បីប្រកបពាក្យឧបមាសូម្បីទាក់ទងជាមួយភាព ផ្សេងគ្នានៃកាលក៏បាន ។ លោកអាចារ្យបានរួបរួមសម្ដែងរូប មានសន្តតិ ៤ ដោយ អំណាចអាការ មានអាទាន ( ការបដិសន្ធិ ) និងនិក្ខេបនៈ ( ការរលាស់ទៅ ) ជាដើម ក្នុងកាលមុន ឥឡូវនេះ ដើម្បីសម្ដែងចែកដោយអំណាចជារូបដែលមានអាហារជា សមុដ្ឋានជាដើម ទើបពោលពាក្យជាដើមថា **តទេវ រូបំ វិសង្ខរិត្វា** ប្រែថា ពង្រីករូប នោះឯងចេញជាដើម ។ ក្នុងពាក្យនោះ **វិសង្ខរិត្វា** សេចក្ដីប៉ុនគ្នានឹង **វិកជិត្វា** ប្រែថា ពង្រីក ឬចែក ។ ម្យ៉ាងទៀត បាឋៈថា **វិសង្ឃរិត្វា** ដូច្នេះក៏មាន សេចក្ដីក៏ដូចគ្នា ។ ពាក្យថា **អាហារមយរូប** ប្រែថា រូបកើត ដោយអាហារ ។ ពាក្យថា **ស្វិតស្រពោន** គឺក្រៀមស្វិត ។ ពាក្យថា **ថមថយ** គឺលំបាក ។ ពាក្យថា **ឆ្អែត** គឺឆ្អែតស្កប់ស្កល់ ។ ពាក្យថា **ពេញ** គឺបរិបូណ៌ដោយសាច់ ។ ព្រោះហេតុនោះឯង **ទើបជារូបទន់** ។ ពាក្យថា **ទន់ភ្លន់** គឺស្រស់ស្រាយ ព្រោះមានពណ៌សម្បុរល្អ ។ ព្រោះហេតុនោះឯង ទើបមានសម្ផស្ស ។ ពាក្យថា **រូបដែលតាំងឡើងក្នុងពេលក្ដៅ** លោកពោលសំដៅ

ដល់រូបដែលក្តៅក្រហាយ ព្រោះការក្តៅដោយកម្តៅ ។ ពាក្យថា **ដោយឧតុត្រជាក់** គឺដោយរដូវដែលជាទីសប្បាយ ។

ពាក្យថា **ដោយអំណាចអាយតនទ្វារ** បានដល់ ដោយអំណាចទ្វារ គឺអាយតនៈ លោកប្រើស័ព្ទថា **អាយតន** ដើម្បីបដិសេធកម្មទ្វារ ។ ពាក្យថា **ក្នុងកាយទ្វារ** បានដល់ ក្នុងទ្វារ គឺបសាទកាយ ។ ភវង្គ ព្រមទាំងអាវជ្ជនៈ ឈ្មោះថា **មនោទ្វារ** ។ លោកអាចារ្យពោលថា **ក្នុងមនោទ្វារ** ដូច្នេះ ដោយនិស្សិតវោហារ សំដៅដល់ ហទយវត្ថុ ព្រោះជាទីអាស្រ័យរបស់ភវង្គនោះ ដែលមានមនោទ្វារជាដែនកើត ។ បទថា **សោមនស្សិតទោមនស្សិតវសេន** ប្រែថា ដោយអំណាចបុគ្គលដែលសប្បាយចិត្ត និងខូចចិត្តក៏បាន ឬប្រែថា ដោយអំណាចពេលសប្បាយចិត្ត ខូចចិត្តក៏បាន ។ ពាក្យថា **អត្តនេះ** សេចក្តីថា អត្តនេះ គឺដែលកំពុងពោលក្នុងឥឡូវនេះ ពោល គឺសង្ខារទាំងឡាយជាវត្ថុដែលមានខណៈបន្តិចបន្តួចក្រៃលែង ។

ពាក្យថា **ជីវិត** បានដល់ ជីវិតិន្ទ្រិយ ។ ពាក្យថា **សុខ និងទុក្ខ** បានដល់ សុខវេទនា និងទុក្ខវេទនា ។ សេចក្តីពិត ឧបេក្ខាក៏ឈោងចុះខាងក្នុងសុខ និងទុក្ខនោះឯង ព្រោះកើតបានទាំងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ ពាក្យថា **អត្តភាព** លោកពោលដល់ធម៌ដ៏សេស វៀរជីវិត វេទនា និងវិញ្ញាណ ។ អាចារ្យពួកខ្លះ ពោលថា បានដល់ សញ្ញា ។ ពាក្យថា **ទាំងមូល** គឺលាយឡំដោយអត្តា ឬជាមួយភាវៈដែលទៀង ។ ពាក្យថា **ប្រកបទុកជាមួយចិត្តដួង ១** គឺប្រព្រឹត្តទៅព្រមជាមួយចិត្តតែ ១ ដួងៗ ។ ពាក្យថា **ខណៈរមែងប្រព្រឹត្តទៅឆាប់រហ័ស** សេចក្តីថា ខណៈនៃជីវិតជាដើមរមែងប្រព្រឹត្តទៅឆាប់រហ័ស គឺរហ័សក្រៃលែង ព្រោះមាននៅក្នុងខណៈចិត្ត ១ តាមន័យដែលពោលហើយ ។

ពីរបទថា **ចុល្លាសីតិសហស្សានិ កប្បំ** សេចក្តីប៉ុនគ្នានឹង **ចតុរាសីតិ-**

**សហស្សបរិមាណំ កប្បំ** ប្រែថា អស់កប្បប្រមាណ ៨៤ ពាន់កប្ប ។ ពាក្យនេះជាទុតិយាវិភត្តិ ចុះក្នុងអច្ចន្តសំយោគ ។ ហើយបទថា **កប្បំ** ជាឯកវចនៈ ដោយអំណាចជាពាក្យសាមញ្ញ ។ បទថា **មរូ** ប្រែថា ពួកទេវតា ។ ច្រើនបទថា **ទ្វីហិ ចិត្តេហិ សមោហិតា** សេចក្តីថា ទេវតាទាំងនោះ សូម្បីរស់បានយូរយ៉ាងនេះ ក៏ជាអ្នកប្រកបដោយចិត្ត ២ ដួងមិនមាន ។ សេចក្តីនេះ មានអធិប្បាយថា ជីវិតជាដើមក្នុងសន្តានរបស់ទេវតាទាំងនោះ រមែងមិនតាំងនៅដោយចិត្ត ២ ដួងឡើយ កើតព្រមជាមួយចិត្ត ១ ដួង ក៏មិនបានតាំងនៅរហូតដល់ចិត្តដួងទី ២ ព្រោះរលត់ទៅព្រមនឹងចិត្តដួងនោះៗ ឯង ។

ច្រើនបទថា **យេ និរុទ្ធា មរន្តស្ស** សេចក្តីថា ខន្ធពួកណាដែលគប្បីពោលថារលត់ទៅហើយ ព្រមជាមួយចុតិរបស់សត្វដែលកំពុងចុតិ ។ ពីរបទថា **តិដ្ឋមានស្ស វា ឥធ** សេចក្តីថា ឬខន្ធដែលរលត់ទៅហើយ ព្រោះដល់ភង្គក្ខណៈនៃសត្វដែលរស់នៅ គឺនៅទ្រទ្រង់ក្នុងបវត្តិកាល ក្នុងលោកនេះ ។ ខន្ធទាំងនោះ **ក៏ដូចគ្នាទាំងអស់** គឺដូចគ្នាទាំងអស់ ដល់នូវការតាំងនៅមិនបាន **មិនជាប់តគ្នា** គឺត្រឡប់មកហើយ ក៏ប្រាសទៅព្រោះមិនមានការតគ្នា ។ អធិប្បាយថា ដូចជាចុតិខន្ធ រមែងមិនកើត យ៉ាងណា សូម្បីខន្ធទាំងឡាយ មុនចុតិចិត្តនោះ ក៏មិនកើតដូចគ្នា ដូច្នោះ ព្រោះហេតុនោះ ទើបជីវិតរបស់សត្វទាំងឡាយ មានខណៈចិត្ត ១ ប៉ុណ្ណោះ ។

ច្រើនបទថា **អន្តរា ច យេ ភគ្គា** ប្រែថា សង្ខារពួកណាបែកធ្លាយហើយ គឺរលត់ហើយក្នុងលំដាប់នោះឯង ។ ច្រើនបទថា **យេ ច ភគ្គា អនាគតេ** ប្រែថា សង្ខារពួកណាបែកធ្លាយហើយក្នុងអនាគតគឺមានការនឹងបែកជាប្រក្រតីនឹងបែកទៅ ។ ពីរបទថា **តទន្តរា និរុទ្ធានំ** សេចក្តីថា នៃសង្ខារទាំងឡាយដែលដល់នូវភាពជាបច្ចុប្បន្នហើយរលត់ទៅ គឺបែកធ្លាយក្នុងចន្លោះ គឺក្នុងកណ្តាលនៃសង្ខារ ដែលជាអតីត និង

អនាគតទាំងនោះ ។ ត្រើនបទថា **វេសមំ នត្ថិ លក្ខណេ** សេចក្តីថា ការផ្សេងគ្នា គឺការប្លែកគ្នា ព្រោះមានការកំណត់ការបែកធ្លាយជានិមិត្តនៃសង្ខារទាំង ៣ យ៉ាងនោះ មិនមាន ។

ពីរបទថា **អនិព្វត្តេន ន ជាតោ** ប្រែថា ព្រោះចិត្តមិនកើត សត្វលោកក៏មិនកើត គឺជាបុគ្គលឈ្មោះថា មិនកើត ។ ព្រោះចិត្ត **កើតឡើងចំពោះមុខ** គឺកំពុងប្រព្រឹត្តទៅ សត្វលោកក៏ **រស់នៅ** គឺជាបុគ្គលឈ្មោះថា **កំពុងរស់នៅ** ។ ត្រើនបទថា **ចិត្តភង្គ មតោ លោកោ** សេចក្តីថា ព្រោះចិត្តនោះៗ គ្រប់ដួងដល់ភង្គក្ខណៈ ដូចចុតិចិត្ត សត្វលោកនេះក៏ជាបុគ្គលឈ្មោះថា **ស្លាប់** ដោយបរមត្ថ ព្រោះចិត្តដែលរលត់ហើយ មិនមានការបដិសន្ធិ ។ សូម្បីដូច្នេះ ក៏ **ជាបញ្ញត្តិតាមបរមត្ថ** គឺការបញ្ញត្តការបន្តគ្នា ដែលជាវិស័យ នៃការប្រព្រឹត្តទៅរបស់ការពោលយ៉ាងនេះថា **តិស្សៈ** រស់នៅ **ផុស្សៈ** រស់នៅ ដូច្នេះ ដោយអាស្រ័យចិត្ត ព្រមទាំងហទយវត្ថុ ដែលអាស្រ័យ ដែលមាន នៅនោះៗ ការបញ្ញត្តការបន្តគ្នានោះ ជាបញ្ញត្តិតាមបរមត្ថ ក្នុងទីនេះ ។ សេចក្តីនេះ នឹងឃើញបានដូចអ្នកប្រាជ្ញទាំងឡាយពោលថា **នាមគោត្តំ ន ជីរតិ** ប្រែថា ឈ្មោះ និងគោត្រ មិនជរា ដូច្នេះ ។

ពីរបទថា **អនិធានគតា ភគ្គា** សេចក្តីថា សង្ខារពួកណាដែលបែកធ្លាយហើយ សង្ខារទាំងនោះ ក៏មិនទៅតាំងនៅក្នុងទីណាឡើយ ដោយពិត ក៏ដល់នូវការមិនមាន នោះឯង ។គំនរសង្ខារក្នុងអនាគតក៏មិនមាន ព្រោះសង្ខារទាំងឡាយគប្បីមកកាន់ភាវៈ ដែលកំពុងប្រព្រឹត្តទៅ ។ ពីរបទថា **និព្វត្តា យេបិ** សេចក្តីថា សង្ខារពួកណាដែល បានអត្តភាពហើយជាបច្ចុប្បន្ន សង្ខារទាំងនោះ **រមែងតាំងនៅ** ឧបមាដូចគ្រាប់ស្ពៃ លើចុងដែកស្រួច ។ អធិប្បាយថា សូម្បីគ្រាប់ស្ពៃដែលបុគ្គលដាក់លើម្ជុលដែល តាំងនៅ លុះត្រូវចុងនៃម្ជុលនោះ រមែងធ្លាក់ទៅ តាំងនៅមិនបាន យ៉ាងណា សង្ខារ

ទាំងឡាយកើតឡើងហើយ ក៏រមែងបែកធ្លាយទៅ ការតាំងចុះនៃសង្ខារទាំងនោះ ទឹង មានទៅក៏ទេ ។ ពាក្យថា **ភង្គោ នេសំ បុរក្ខតោ** សេចក្តីថា ការបែកធ្លាយរបស់ធម៌ ដែលកើតទាំងនោះ ត្រូវធ្វើទុកខាងមុខនោះឯង អធិប្បាយថា នឹងដោយចំណែកមួយ រមែងមិនថយក្រោយឡើយ ។ បទថា **បុរាណេហិ** ប្រែថា ជាមួយធម៌មុនៗ គឺ ជាមួយធម៌អតីតទាំងឡាយ ។

បទថា **អទស្សនតោ** ប្រែថា ដោយជារបស់មិនគប្បីឃើញ ។ បទថា **អាយន្តិ** ប្រែថា មក សូម្បីដោយបទថា **ឧប្បជ្ជន្តិ** ប្រែថា កើតឡើងនេះ ព្រះសារីបុត្រក៏ពោល ទុកដោយការមិនមានការមកអំពីគំនរសង្ខារណាមួយ ។ ពាក្យថា **ភគ្គា គច្ឆន្ត្យទស្សនំ** សេចក្តីថា សង្ខារទាំងឡាយសូម្បីបែកធ្លាយហើយ ក៏ដល់នូវការមិនឃើញ គឺមិនមាន ទាំងអស់ ព្រោះមិនមានការចូលទៅនៅក្នុងទីណាមួយ ។ ព្រះសារីបុត្រពោលឧទាហរណ៍ ក្នុងពាក្យនោះថា សង្ខារកើតឡើង និងវិនាសទៅ ដូចការកើតឡើងនៃផ្លេកបន្ទោរក្នុង អាកាស ដូច្នោះ ។

ដោយពាក្យថា **រូបដែលកើតចាប់ផ្តើមអំពីវិវដ្តកប្ប** នេះ លោកអាចារ្យរមែង សម្តែងវត្ថុនាម ( ឈ្មោះដែលស្របតាមអត្ថ ) ថា **ធម្មតារូប** ព្រោះមានការកើតឡើង នោះឯង ជាធម្មតា ។ នឹងវិនិច្ឆ័យក្នុងបណ្តាដែក និងលោហៈជាដើមតទៅ ដែល ឈ្មោះថា **ដែក** បានដល់ លោហៈពណ៌ខ្មៅ ឈ្មោះថា **លោហៈ** មាន ៤ ប្រភេទ គឺជាតិលោហៈ ( ទង់ដែង ) ១ វិជាតិលោហៈ ( ទង់ដែងផ្សំ ) ១ កិត្តិមលោហៈ ( ទង់ដែងធ្វើឡើងមក ) ១ បិសាចលោហៈ ( ទង់ដែងក្នុងក្រុងបិសាច ) ១ ក្នុង លោហៈទាំង ៤ ប្រភេទនោះ **ជាតិលោហៈ** មាន ៧ យ៉ាង ដូច្នេះគឺ **អយ** ( ដែក) ១ **រជត** ( ប្រាក់ ) ១ **សុវណ្ណ** ( មាស ) ១ **តិបុ** ( សំណប៉ាហាំង ) ១ **សីសៈ** ( សំណ ) ១ **តម្ពលោហៈ** ( ទង់ដែង ) ១ **វេកន្តកលោហៈ** ១ ។ **នាគសិកលោហៈ**

ឈ្មោះថា **វិជាតិលោហៈ** ។ **កិត្តិមលោហៈ** ( លោហៈដែលធ្វើឡើង ) មាន ៣ យ៉ាងគឺ **កង្សលោហៈ** ( ដែកបទុះ ) ១ **វដ្ដលោហៈ** (ដែលមូល) ១ **អារកូដ** ( ដែកស្រេច ) ១ ។ លោហៈមាន ប្រភេទឈ្មោះថា **មោរក្ខកៈ** ជាដើម ឈ្មោះថា **បិសាចលោហៈ** ។ ក្នុងបណ្ដាលោហៈទាំងនោះ លោហៈដ៏សេសទាំងអស់ រួមជាមួយជាតិលោហៈ ២ ប្រភេទនេះ គឺ **តម្ពលោហៈ វេកន្តលោហៈ** លោកកាន់យកថា **លោហៈ** ក្នុងទីនេះ ។ ពាក្យថា **សំណប៉ាហាំង** បានដល់ សំណពណ៌ស ។ ពាក្យថា **សំណ** បានដល់ សំណពណ៌ខ្មៅ ។ ពាក្យថា **មាស** បានដល់ មាស ប្រភេទផ្សេងៗ ដែលកើតក្នុងអណ្ដូង ធ្វើជាខ្សែបាន ។ **មុត្តា** បានដល់ មុត្តាដែលកើតក្នុងសមុទ្រជាដើម ។ ពាក្យថា **មណី** បានដល់ ប្រភេទនៃកែវមណីដ៏សេស ទាំងអស់ វៀរពិទូរ្យ ទទឹម និងកែវមានឆ្នូត ។ **ពិទូរ្យ** បានដល់ កែវមណី មានពណ៌ ដូចដើមឫស្សី ។ **ស័ង្ខ** បានដល់ ស័ង្ខដែលកើតក្នុងសមុទ្រ ។ ពាក្យថា **សិលា** បានដល់ សិលាដែលសន្មតថាជារតនៈ ទាំងអស់ច្រើនប្រភេទ ជាសិលាខ្មៅ និងសិលាលឿងជាដើម ។ ដែលឈ្មោះថា **កែវប្រវាឡ** បានដល់ ថ្មក្ដាំងមូល ។ **ទទឹម** បានដល់ កែវមណីក្រហម ។ **កែវមានឆ្នូត** បានដល់ កែវមណីមានឆ្នូត ។ **ផែនដី** ជាដើម ប្រាកដជាក់ច្បាស់ហើយ ។ បទថា **តទស្ស** កាត់បទជា **តំ អស្ស, តំ យោគ ធម្មតារូបំ** ប្រែថា ធម្មតារូបនោះ **អស្ស យោគ យោគិនោ** ប្រែថា ដល់យោគីនោះ ។

ពាក្យថា **មានពណ៌ដូចស្លឹកខ្ទឹដំបូង** សេចក្ដីថា មានពណ៌ដូចស្លឹកខ្ទឹដំបូងនៃស្វាយជាដើម ។ ពាក្យថា **ការបន្តនៃរូបដែលស្មើគ្នា** គឺការបន្តនៃរូបដែលមានចំណែកស្មើគ្នានឹងពណ៌ជាដើម ។ ពាក្យថា **ឲ្យបន្តទៅ** គឺឲ្យប្រព្រឹត្តទៅដោយអំណាចការសម្ពន្ធគ្នា ដោយការតៗ គ្នានៃហេតុ និងផល ។

បទថា **សោ យោគ យោគី** ប្រែថា ព្រះយោគីនោះ ។ បទថា **តំ យោគ**

**អសោករុក្ខបណ្ណំ** ប្រែថា ស្លឹកដើមអសោកនោះ ។ បទថា **បរិគ្គហេត្វា** ប្រែថា កំណត់កាន់យកដោយញាណ ។ ពាក្យថា **ដោយន័យនេះ** គឺដោយន័យដែលពោលហើយ ក្នុងស្លឹកអសោកនេះ ។ **ធម្មតារូបទាំងពួង** គឺប្រភេទផ្សេងៗ ដូចជាដែក និងលោហៈជាដើម ។ ឯធម្មតារូបនោះ ត្រជាក់ក្នុងកាលដែលត្រជាក់ រមែងជារបស់ក្ដៅក្រៃលែង ដោយកម្ដៅរបស់ព្រះអាទិត្យក្នុងកាលដែលក្ដៅ ។ រូបដែលប្រព្រឹត្តទៅដោយការត្រជាក់ក្នុងធម្មតារូបនោះ មិនទៅដល់ពេលក្ដៅ រូបដែលប្រព្រឹត្តទៅដោយកម្ដៅ ក៏មិនទៅដល់ពេលត្រជាក់ ។ គប្បីប្រកបដោយពាក្យជាដើមថា រមែងបែកសំឡេងព្រួ តដះ តដះ ក្នុងទីនោះៗ ឯង ។

# វិសុទ្ធិមគ្គ

## អរូបសត្តកៈ

ចំណែកប្រការណា ដែលខ្ញុំបានពោលទុកថា **គន្លងអរូបសត្តកៈ** ដូច្នេះ នេះជាមាតិកាក្នុងសេចក្ដីនោះ គឺ

**កលាបតោ** ដោយជាកលាបៈ

**យមកតោ** ដោយជាគូ

**ខណិកតោ** ដោយជាខណៈ

**បដិបាដិតោ** ដោយលំដាប់

**ទិដ្ឋិឧគ្ឃាដនតោ** ដោយបើកទិដ្ឋិ

**មានសមុគ្ឃាដនតោ** ដោយបើកមានះ

**និកន្តិបរិយាទានតោ** ដោយសង្កត់សេចក្ដីត្រេកអរទុកបាន ។

## កលាបតោ-ដោយជាកលាបៈ

ក្នុង ៧ មាតិកានោះ ពាក្យថា **កលាបតោ-ដោយជាកលាបៈ** ( គប្បីជ្រាបដូច្នេះ ) ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ ( ឈ្មោះថា កលាបៈ ) ពិចារណាដោយកលាបៈដូចម្ដេច ? ភិក្ខុក្នុងធម្មវិន័យនេះ រមែងពិចារណាឃើញ ដូច្នេះថា ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ ដែលកើតឡើងក្នុងសម្មសនៈថា **សក់ទាំងឡាយមិនទៀង ជាទុក្ខ ជាអនត្តា** នេះ និងធម៌ទាំងឡាយ មានផស្សៈ ជាគម្រប់ ៥ ដែលកើតឡើងក្នុងសម្មសនៈថា **រោមទាំងឡាយ ។បេ។ ខួរក្នុងក្បាល មិនទៀង ជាទុក្ខ ជាអនត្តា** នេះ ធម៌ទាំងឡាយនោះ វិនាសទៅជាដំណាក់ៗ ជាបណ្ដើរៗ មិន ( ទៅដល់ ) ដំណាក់ក្រៅអំពីនេះ ដូចគ្រាប់ល្ងទាំងឡាយ ដែលដាក់ចុះលើអំបែងក្ដៅ ( ផុះ ) ឮតដៈ

គដ: ដូច្នោះ ហេតុនោះ ធម៌ទាំងឡាយ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា នេះជាន័យក្នុង វិសុទ្ធិកថា ។

ចំណែកក្នុងអរិយវង្សកថាពោលទុកថា កាលពិចារណាចិត្តដួងដែលប្រព្រឹត្តទៅថា រូបក្នុងឋានៈទាំង ៧ ក្នុងរូបសត្តកៈខាងដើមមិនទៀង ជាទុក្ខ ជាអនត្តា ដោយចិត្ត ១ ដួងទៀតថា ចិត្តដួងមុននោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នេះ ឈ្មោះថា ពិចារណាដោយកលាបៈ ពាក្យដែលពោលក្នុងអរិយវង្សកថានោះ ត្រឹមត្រូវជាង ព្រោះហេតុនោះ ខ្ញុំនឹងចែកប្រការដ៏សេសដោយន័យនោះដូចគ្នា ។

## យមកតោ–ដោយជាគូ

ពាក្យថា **យមកតោ** សេចក្តីថា ភិក្ខុក្នុងធម្មវិន័យនេះពិចារណាអាទាននិក្ខេបរូបថា មិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាដដែលនូវចិត្ត ( ដួងដែលពិចារណារូប ) នោះ ដោយចិត្ត ១ ដួងទៀតថា ចិត្ត ( ដែលពិចារណាមុន ) នោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ពិចារណាវយោវុឌ្ឍត្ថគមរូប... អាហារមយរូប... ឧតុមយរូប... កម្មជរូប... ចិត្តសមុដ្ឋានរូប... ធម្មតារូបថា មិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាចិត្ត (ដួងដែលពិចារណារូប ) នោះ ដោយចិត្ត ១ ដួង ទៀតថា ចិត្ត ( ដែលពិចារណាមុន ) នោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នេះ ឈ្មោះថា **ពិចារណាដោយជាគូ** ( គឺពីរត្រួត ) ។

## ខណិកតោ–ដោយជាខណៈ

ពាក្យថា **ខណិកតោ** សេចក្តីថា ភិក្ខុក្នុងព្រះធម្មវិន័យនេះពិចារណាអាទាននិក្ខេបរូបថា មិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាចិត្តដួងដំបូង ( ដែលពិចារណារូប ) នោះ ដោយចិត្តដួងទី ២ ថា សូម្បីចិត្តដួងដំបូងនោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ។ ពិចារណាចិត្តដួងទី ២ ដោយចិត្តដួងទី ៣... ពិចារណាចិត្ត

ជួនទី ៣ ដោយចិត្តជួនទី ៤... ពិចារណាចិត្តជួនទី ៤ ដោយចិត្តជួនទី ៥ ថា សូម្បីចិត្តជួនទី ២... ចិត្តជួនទី ៣... ចិត្តជួនទី ៤ នោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ភិក្ខុពិចារណាវយោវុឌ្ឍត្ថគមរូប... អាហារមយរូប... ឧតុមយរូប... កម្មជរូប... ចិត្តសមុដ្ឋានរូប... ធម្មតារូប ថាមិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាចិត្តជួនដំបូង ( ដែលពិចារណារូប ) នោះ ដោយចិត្តជួនទី ២... ពិចារណាចិត្តជួនទី ២ ដោយចិត្តជួនទី៣...ពិចារណាចិត្តជួនទី៣ដោយចិត្តជួនទី៤...ពិចារណាចិត្ត ជួនទី ៤ ដោយចិត្តជួនទី ៥ ថាចិត្តជួនទី ១... ទី ២... ទី ៣... ទី ៤ នោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ភិក្ខុពិចារណាចិត្ត ១ នីមួយៗ ៤ ជួន តាំងអំពីចិត្តដែលកំណត់កាន់យករូប ( ជាអារម្មណ៍ ) ទៅ ដូចពោលមកដូច្នេះ ឈ្មោះថា ពិចារណាដោយជាខណៈ ( គឺពិចារណាចិត្ត ៤ ខណៈ ឬ ៤ ជាន់ ) ។

## បដិបាដិតោ-ដោយលំដាប់

ពាក្យថា **បដិបាដិតោ** សេចក្ដីថា ភិក្ខុពិចារណាអាទាននិក្ខេបរូបថា មិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាចិត្តជួនដំបូង ( ដែលពិចារណារូប ) នោះ ដោយចិត្តជួនទី ២... ពិចារណាចិត្តជួនទី ២ ដោយចិត្តជួនទី ៣... ពិចារណាចិត្តជួនទី ៣... ដោយចិត្តជួនទី ៤ ។បេ។ ពិចារណាចិត្តជួនទី ១០ ដោយចិត្តជួនទី ១១ ថា សូម្បីចិត្តជួនដំបូង ។បេ។ ចិត្តជួនទី ១០ នោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ពិចារណាវយោវុឌ្ឍត្ថគមរូប...អាហារមយរូប...ឧតុមយរូប...កម្មជរូប...ចិត្តសមុដ្ឋានរូប... ធម្មតារូប ថាមិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាចិត្តជួនដំបូង ( ដែលពិចារណារូប ) នោះ ដោយចិត្តជួនទី ២... ពិចារណាចិត្តជួនទី ២ ដោយចិត្តជួនទី ៣... ។បេ។ ពិចារណាចិត្តជួនទី ១០ ដោយចិត្តជួនទី ១១ ថា សូម្បីចិត្តជួនដំបូង ។បេ។ ចិត្តជួនទី ១០ នោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា គប្បីពិចារណាសាឡើងចុះ ពិចារណា

ទៅតាមលំដាប់វិបស្សនា ដូច្នេះ រហូតមួយថ្ងៃក៏បាន តែព្រោះត្រឹមពិចារណាចិត្តជួន ទី ១០ ( មិនថា ) រូបកម្មដ្ឋានក្តី អរូបកម្មដ្ឋានក្តី ក៏ជាការស្ទាត់ជំនាញ ( គឺប្រាកដច្បាស់ហើយ ) ហេតុនោះ ( ក្នុងអរិយវង្សកថា ) ទើបលោកប្រាប់ទុកថា **គប្បីឈប់ត្រឹមចិត្តជួន ទី ១០ ប៉ុណ្ណោះចុះ** ។

ពិចារណាដូចពោលមកនេះ ឈ្មោះថា **ពិចារណាដោយលំដាប់** ។

## ទិដ្ឋិឧគ្ឃាដនតោ-ដោយបើកទិដ្ឋិ ។បេ។

ក្នុង ៣ ប្រការ គឺ **ទិដ្ឋិឧគ្ឃាដនតោ**-ដោយបើកទិដ្ឋិ **មានសមុគ្ឃាដនតោ**ដោយបើកមានះ **និក្កន្តិបរិយាទានតោ**-ដោយសង្កត់សេចក្តីត្រេកអរទុកបាននេះ មិនមែនមានសម្រាប់ពិចារណាមួយបែបម្យ៉ាងឡើយ ពិតណាស់ រូប ( ដែលពោល) ខាងដើមនោះក្តី អរូបដែលកំណត់កាន់យកក្នុងពេលនេះក្តី កាលពិចារណារូប និងអរូបនោះទៅ រមែងមិនឃើញវត្ថុដទៃ ដែលបានឈ្មោះថា សត្វក្រៅអំពីរូប និងអរូបតាំងអំពីមិនឃើញ ( ជា ) សត្វទៅ សត្តសញ្ញាក៏ត្រូវលោកដកបាន កាលព្រះយោគាវចរកំណត់កាន់យក ( ជា ) សង្ខារ ដោយចិត្តដែលដកសត្តសញ្ញាបានហើយ ទិដ្ឋិរមែងមិនកើតឡើង កាលទិដ្ឋិមិនកើតឡើង ទិដ្ឋិក៏ឈ្មោះថា ត្រូវដកទៅ កាលកំណត់កាន់យក ( ជា ) សង្ខារ ដោយចិត្តដែលបើកទិដ្ឋិ ហើយមានះរមែងមិនកើតឡើង កាលមានះមិនកើតឡើង មានះក៏ឈ្មោះថា ត្រូវដកទៅ កាលកំណត់កាន់យក ( ជា ) សង្ខារ ដោយចិត្តដែលបើកមានះហើយ តណ្ហារមែងមិនកើតឡើង កាលតណ្ហាមិនកើតឡើង សេចក្តីត្រេកអរក៏ឈ្មោះថា ត្រូវលោកសង្កត់ទុកហើយ ដូច្នេះត្រឹមនេះជាពាក្យពោលទុកក្នុងវិសុទ្ធិកថា ។

ចំណែកក្នុងអរិយវង្សកថា រៀបរៀងមាតិកាថា **ទិដ្ឋិឧគ្ឃាដនតោ មានសមុគ្ឃា-ជនតោ និក្កន្តិបរិយាទានតោ** ហើយសម្តែងន័យដូច្នេះ ។

ឯកាលប្រកាន់ថា អញឃើញច្បាស់ ការឃើញច្បាស់របស់អញ ដូច្នេះ មិនឈ្មោះថា បើកទិដ្ឋិ តែប្រកាន់ថា សង្ខារទាំងឡាយនោះឯង ឃើញច្បាស់សង្ខារទាំងឡាយ សង្ខារទាំងឡាយនោះឯងពិចារណា... វិគ្រោះមើល... ចាប់មើល... កំណត់ចែកសង្ខារទាំងឡាយ ដូច្នេះ ទើបឈ្មោះថា បើកទិដ្ឋិ ។ កាលប្រកាន់ថា អញឃើញច្បាស់យ៉ាងល្អ អញឃើញច្បាស់យ៉ាងគួរពេញចិត្ត ដូច្នេះ មិនឈ្មោះថា បើកមានះ លុះយល់ឃើញថា សង្ខារទាំងឡាយនោះឯង ឃើញច្បាស់សង្ខារទាំងឡាយ សង្ខារទាំងឡាយនោះឯងពិចារណា... វិគ្រោះមើល... ចាប់មើល... កំណត់ញែកមើលសង្ខារទាំងឡាយ ដូច្នេះ ទើបឈ្មោះថា បើកមានះ ។ កាលពេញចិត្តក្នុងវិបស្សនា ដោយគិតថា អញអាចឃើញច្បាស់បាន ដូច្នេះ មិនឈ្មោះថា សង្កត់ការប្រាថ្នាបាន លុះយល់ឃើញថា សង្ខារទាំងឡាយនោះឯងឃើញច្បាស់សង្ខារទាំងឡាយ សង្ខារទាំងឡាយនោះឯងពិចារណា... វិគ្រោះមើល... ចាប់មើល... កំណត់ញែកមើលសង្ខារទាំងឡាយ ដូច្នេះ ទើបឈ្មោះថា សង្កត់សេចក្តីត្រេកអរទុកបាន ។

កាលឃើញថា បើសង្ខារទាំងឡាយ គប្បីជាអត្តាសោត នឹងកាន់យកថា សង្ខារជាអត្តាក៏គួរ តែសង្ខារមិនមែនអត្តាឡើយ មកប្រកាន់យកថា ជាអត្តា ព្រោះហេតុនោះ ទើបសង្ខារទាំងឡាយនោះជាអនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាចមិនទៀង ព្រោះអត្ថថា មានហើយក៏មិនមាន ជាទុក្ខ ព្រោះអត្ថថា ត្រូវ ការកើត និងការវិនាសគ្របសង្កត់ ដូច្នេះ ឈ្មោះថា បើកទិដ្ឋិ ។ កាលឃើញថា បើសង្ខារទាំងឡាយ គប្បីជារបស់ទៀងសោត នឹងកាន់យកថា សង្ខារទាំងឡាយទៀងក៏គួរ តែសង្ខារទាំងឡាយមិនទៀងឡើយ មកប្រកាន់ថា ទៀង ព្រោះហេតុនោះ ទើបសង្ខារទាំងឡាយនោះ ជារបស់មិនទៀង ព្រោះអត្ថថា មានហើយ ក៏មិនមាន ជាទុក្ខ ព្រោះអត្ថថា ត្រូវការកើត និងវិនាសគ្របសង្កត់ ជាអនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ដូច្នេះ ឈ្មោះ

ថា **បើកមានះ** ។ កាលយល់ឃើញថា បើសង្ខារទាំងឡាយ គប្បីជាសុខសោត នឹងប្រកាន់ថា សង្ខារទាំងឡាយជាសុខក៏គួរ តែសង្ខារទាំងឡាយ ជាទុក្ខពិតៗ មកប្រកាន់ថា ជាសុខ ព្រោះហេតុនោះ ទើបសង្ខារទាំងឡាយជាទុក្ខ ព្រោះអត្ថថា ត្រូវការកើតនិងការវិនាសគ្របសង្កត់ មិនទៀង ព្រោះអត្ថថា មានហើយក៏មិនមាន ជាអនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ដូច្នេះ ឈ្មោះថា សង្កត់សេចក្ដីត្រេកអរទុកបាន ។

ឈ្មោះថា **ការបើកទិដ្ឋិ** រមែងមានដល់ព្រះយោគីដែលឃើញសង្ខារទាំងឡាយដោយជាអនត្តា ឈ្មោះថា **ការបើកមានះ** រមែងមានដល់ព្រះយោគីដែលឃើញសង្ខារទាំងឡាយថា មិនទៀង ឈ្មោះថា រមែងសង្កត់សេចក្ដីត្រេកអរទុកបាន រមែងមានដល់ព្រះយោគី ដែលឃើញសង្ខារទាំងឡាយថា ជាទុក្ខ ដូចពោលមក ដូច្នេះ វិបស្សនានេះទើបឈ្មោះថា តាំងនៅក្នុងទីរបស់ខ្លួនរៀងៗ ខ្លួនពិត ។

ព្រះយោគីពិចារណាសង្ខារទាំងឡាយ លើកឡើងកាន់ត្រៃលក្ខណ៍ តាមបែបអរូបសត្តកៈ ដូចពោលមក ដូច្នេះ ។

ឯការនានុយោគត្រឹមប៉ុណ្ណេះ រូបកម្មដ្ឋានក្តី អរូបកម្មដ្ឋានក្តី របស់ព្រះយោគីនោះរមែងស្ទាត់ជំនាញ ។

## មហាវិបស្សនា ១៨

ព្រះយោគីដែលមានរូបកម្មដ្ឋាន និងអរូបកម្មដ្ឋានស្ទាត់ជំនាញយ៉ាងនេះ មហាវិបស្សនា គឺអនុបស្សនា ១៨ ពួកណា ដែលគប្បីដល់បានដោយអាការទាំងពួង ដោយអំណាចបហានបរិញ្ញា តាំងអំពីភង្គានុបស្សនាញាណខាងមុខទៅ កាលចាក់ធ្លុះចំណែកមួយនៃមហាវិបស្សនាទាំងនោះក្នុង (ថ្នាក់) សម្មសនញ្ញាណ គឺតីរណបរិញ្ញានេះឯងមុនក៏រមែងលះបដិបក្ខធម៌ ( មាននិច្ចសញ្ញាជាដើម ) នៃមហាវិបស្សនានោះបាន ។

បញ្ញា មានអនិច្ចានុបស្សនាជាដើម ឈ្មោះថា មហាវិបស្សនា ១៨ ក្នុងអនុបស្សនាទាំងឡាយនោះ ១ កាលចម្រើនអនិច្ចានុបស្សនា រមែងលះនិច្ចសញ្ញាបាន ២ កាលចម្រើនទុក្ខានុបស្សនា រមែងលះសុខសញ្ញាបាន ៣ កាលចម្រើនអនត្តានុបស្សនា រមែងលះអត្តសញ្ញាបាន ៤ កាលចម្រើននិព្វិទានុបស្សនា រមែងលះនន្ទិ ( ការត្រេកត្រអាល ) បាន ៥ កាលចម្រើនវិរាគានុបស្សនា រមែងលះរាគៈបាន ៦ កាលចម្រើននិរោធានុបស្សនា (បញ្ញាពិចារណាឃើញនិរោធ) រមែងលះសមុទយៈបាន ៧ កាលចម្រើនបដិនិស្សគ្គានុបស្សនា ( បញ្ញាពិចារណាដោយការលះបង់ចោល ) រមែងលះអាទាន ( ការប្រកាន់មាំ ) បាន ៨ កាលចម្រើនខយានុបស្សនា ( បញ្ញាពិចារណាឃើញការអស់ទៅ) រមែងលះ ឃនសញ្ញា (ការសម្គាល់ថា ជាដុំ គឺជារាងកាយ) បាន ៩ កាលចម្រើនវយានុបស្សនា ( បញ្ញាពិចារណាឃើញការសូន្យទៅ ) រមែងលះអាយូហនៈ (ការប្រមូលមក) បាន ១០ កាលចម្រើនវិបរិណាមានុបស្សនា (បញ្ញាពិចារណា ឃើញការប្រែប្រួល ) រមែងលះធុវសញ្ញា ( ការសម្គាល់ថាមាំមួន ) បាន ១១ កាលចម្រើនអនិមិត្តានុបស្សនា ( បញ្ញាពិចារណាឃើញការមិនមាននិមិត្ត ) រមែងលះនិមិត្តបាន ១២ កាលចម្រើនអប្បណិហិតានុបស្សនា ( បញ្ញាពិចារណាឃើញជាវត្ថុមិនគួរប្រាថ្នា ) រមែងលះបណិធិ (ការប្រាថ្នាដោយអំណាចតណ្ហា) បាន ១៣ កាលចម្រើនសុញ្ញតានុបស្សនា ( បញ្ញាពិចារណាឃើញការសោះសូន្យ ) រមែងលះអភិនិវេស (ការប្រកាន់មាំថាជាខ្លួន) បាន ១៤ កាលចម្រើនអធិបញ្ញាធម្មវិបស្សនា ( បញ្ញាឃើញច្បាស់ក្នុងធម៌ដែលជាអធិបញ្ញា ) រមែងលះសារាទានាភិនិវេស ( ការប្រកាន់មាំថាមានសារៈ ) បាន ១៥ កាលចម្រើនយថាភូតញ្ញាណទស្សនៈ ( ការឃើញតាមសេចក្ដីពិត ) រមែងលះសម្មោហាភិនិវេស (ការប្រកាន់មាំដោយអំណាចការវង្វេង ) បាន ១៦ កាលចម្រើនអាទីនវានុបស្សនា ( បញ្ញាពិចារណាឃើញទោស )

រមែងលះអាលយាភិនិវេស ( ការប្រកាន់មាំដោយអំណាចសេចក្ដីអាល័យ ) បាន ១៧ កាលចម្រើនបដិសង្ខានុបស្សនា (បញ្ញាពិចារណារកផ្លូវរួចផុត) រមែងលះអប្បដិសង្ខា ( ការមិនពិចារណារកផ្លូវរួចផុត ) បាន ១៨ កាលចម្រើនវិវដ្ដានុបស្សនា ( បញ្ញាពិចារណាឃើញផ្លូវផុតចាកវដ្ដៈ ) រមែងលះសំយោគាភិនិវេស ( ការប្រកាន់មាំដោយអំណាចសំយោគ ) បាន ។

ក្នុងមហាវិបស្សនា ១៨ នេះ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលព្រះយោគីអ្នក ( ចម្រើនសម្មសនញ្ញាណ ) នេះបានហើយ ព្រោះហេតុដែលសង្ខារទាំងឡាយ លោកឃើញហើយដោយអំណាចត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ។ ម្យ៉ាងទៀត ហេតុដែលលោកពោលទុកថា អនិច្ចានុបស្សនាឯណាក្ដី អនិមិត្តានុបស្សនាឯណាក្ដី ធម៌ ២ នេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។ ន័យដូចគ្នានោះដែរ ទុក្ខានុបស្សនាឯណាក្ដី អប្បណិហិតានុបស្សនាឯណាក្ដី ធម៌ ២ នេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។ អនត្តានុបស្សនាឯណាក្ដី សុញ្ញតានុបស្សនាឯណាក្ដី ធម៌ ២ នេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ដូច្នេះ ហេតុនោះ សូម្បីអនិមិត្តានុស្សនា អប្បណិហិតានុបស្សនា និងសុញ្ញតានុបស្សនាទាំងនោះ ក៏ឈ្មោះថាព្រះយោគីអង្គនេះបានហើយ ។ ចំណែកអធិបញ្ញាធម្មវិបស្សនា គឺវិបស្សនាទាំងពួងយថាភូតញ្ញាណទស្សនៈក៏សង្គ្រោះចូល ជាមួយកង្ខាវិតរណាវិសុទ្ធិនោះឯង ព្រោះដូច្នោះ សូម្បីអធិបញ្ញាធម្មវិបស្សនា និងយថាភូតញ្ញាណទស្សនៈទាំង ២ នេះ ក៏ឈ្មោះថាព្រះយោគីអង្គនេះបានហើយដូចគ្នា ។ ក្នុងវិបស្សនាញាណដ៏សេស ( មាននិព្វិទានុបស្សនាជាដើម ) ចំណែកខ្លះ ក៏លោកបានហើយ ចំណែកខ្លះក៏លោកមិនទាន់បាន ខ្ញុំនឹងអធិប្បាយវិភាគនៃវិបស្សនាញាណទាំងនោះឲ្យជាក់ច្បាស់ទៅខាងក្រោយ ឯពាក្យថា ព្រះយោគីដែលមានរូបកម្មដ្ឋាន និងអរូបកម្មដ្ឋានស្ទាត់ជំនាញយ៉ាងនេះ មហា

វិបស្សនា ១៨ ពួកណា ដែលគប្បីដល់បានដោយអាការទាំងពួង ដោយអំណាចបហានប្បរិញ្ញា តាំងអំពីភង្គានុបស្សនាញាណខាងដើមទៅ កាលចាក់ធ្លុះចំណែកមួយនៃមហាវិបស្សនាទាំងនោះ ក្នុង ( ថ្នាក់ ) សម្មសនញ្ញាណ គឺតីរណប្បរិញ្ញានេះឯងមុន ក៏រមែងលះបដិបក្ខធម៌ នៃមហាវិបស្សនានោះបាន ដូច្នេះ ខ្ញុំពោលទុកសំដៅយកវិបស្សនាញាណ ដែលព្រះយោគីអង្គនេះបានហើយនោះឯង ។

# មហាដីកា

## កថាពណ៌នាពោលដោយការពិចារណាអរូប ដោយអាការ ៧

*ពាក្យថា* ***ដោយជាកលាបៈ*** *គឺដោយជាកលាបៈនៃអរូបធម៌ ។*

*ព្រោះក្នុងអរូបធម៌ទាំងនោះ ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ ទូទៅដល់ចិត្តុប្បាទគ្រប់ដួងជាក់ច្បាស់ល្អ និងគប្បីយល់បានងាយ ដូច្នោះ លោកអាចារ្យកាលនឹងសម្តែងទាក់ទងជាមួយអរូបធម៌ទាំងនោះ ទើបពោលថា* ***ពាក្យថា ដោយកលាបៈ មានអធិប្បាយដូច្នេះ ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ ឈ្មោះថា កលាបៈ*** *ដូច្នេះ ភ្ជាប់សេចក្តីថា ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ ដែលកើតឡើងក្នុងសម្មសនៈទាំងនេះឯណា ធម៌ទាំងឡាយទាំងពួងនោះ វិនាសសាបសូន្យទៅ ដូច្នេះ ។*

*ពាក្យថា* ***ចិត្តដួងដែលប្រព្រឹត្តទៅ*** *គឺចិត្តដួងដែលប្រព្រឹត្តទៅដោយអំណាចការពិចារណា ក្នុងឋានៈទាំង ៧ ។ ពាក្យថា* ***កាលពិចារណា*** *គឺកាលពិចារណាកាន់យករួមគ្នា ។ ពាក្យថា* ***ពាក្យនោះត្រឹមត្រូវជាង*** *សេចក្តីថា ពាក្យដែលលោកពោលទុកក្នុងអរិយវង្សកថានោះត្រឹមត្រូវជាង គឺជាក់ច្បាស់ជាង ដោយជាពាក្យចូលជិតជាង ព្រោះលោកពោលសម្មសនៈ កាន់យកសម្មសនៈរួមទុកក្នុងរូបសត្តកៈ ។ ប្រការមួយទៀត អរូបសម្មសនៈ ដែលមានរូបសម្មសនៈនោះជាអារម្មណ៍ រមែងប្រព្រឹត្តទៅដើម្បីការចាក់ធ្លុះលក្ខណៈ មានអនិច្ចលក្ខណៈជាដើម បានយ៉ាងកំពូល ព្រោះការពិចារណាក្នុងរូបសត្តកៈប្រព្រឹត្តទៅ ដោយធ្វើការចែកភាពជាដុំ បានយ៉ាងកំពូល ក្នុងរូបធម៌ទាំងឡាយ ព្រោះហេតុនោះ ទើបពាក្យនោះ ត្រឹមត្រូវជាង ។ តែមិនមែនញ៉ាំងអរូបសម្មសនៈដែលមានរូបសម្មសនៈនោះជាអារម្មណ៍ ឲ្យប្រព្រឹត្តទៅ*

ដោយធ្វើការពិចារណាកោដ្ឋាសជាដើម ដែលមិនធ្លាប់ពិចារណា ។ កាលបើដូច្នេះ កម្មដ្ឋានក៏គប្បីជារឿងថ្មីៗ នោះឯង ព្រោះបានលោស់ចោលអារម្មណ៍នៃសម្មសនៈ ដែលទទួលទុកមុន ហើយទទួលយកអារម្មណ៍នៃសម្មសនៈដទៃ ។ ពាក្យថា **សូម្បីប្រការដ៏សេស** បានដល់ ប្រការមានសម្មសនៈ ដោយជាគូជាដើម ។ ពាក្យថា **ដោយន័យនោះដូចគ្នា** គឺដោយន័យក្នុងអរិយវង្សក្រដូចគ្នា ។

ពាក្យថា **ចិត្តនោះ** សេចក្តីថា ចិត្តុប្បាទដែលប្រព្រឹត្តទៅ ដោយអំណាចការពិចារណាតាមបែបអាទាននិក្ខេបរូប ។ ឯពាក្យនេះ ជាពាក្យលម្អិតដោយលើកចិត្តជាប្រធាន ។ គ្រប់បទក៏មានន័យនេះ ។ ដែលឈ្មោះថា **ពិចារណាដោយជាគូ** ព្រោះការពិចារណាប្រព្រឹត្តទៅទាក់ទងដោយជាគូ ប្រារព្ធនាមធម៌ និងរូបធម៌ ។ ឯព្រះយោគីនេះ សូម្បីពិចារណាដោយរូបសត្តកៈមុន ហើយតាំងនៅ ឥឡូវនេះ រមែងពិចារណាសម្មសនៈ ដែលបានពិចារណា តាំងនៅ ដោយជាអាទាននិក្ខេបរូបជាដើម នោះឯង ។ សូម្បីក្នុងការពិចារណាដោយជាខណៈជាដើម ក៏មានន័យនេះ ។

បទថា **ឯតម្បិ** ប្រែថា សូម្បីចិត្តពិចារណាជួងទី ៤ នេះ ។ ពាក្យថា **ចិត្តជួងដំបូង** បានដល់ ចិត្តដែលពិចារណារូបដោយជាអាទាននិក្ខេបរូបជាដើម ដែលលោកមានបំណងយកថា ជាចិត្តដែលកំណត់កាន់យករូប ។ ការពិចារណានេះ លោកពោលថា **ជាការពិចារណាដោយជាខណៈ** ព្រោះជាការធ្វើឲ្យជាក់ច្បាស់នូវអរូបធម៌ទាំងនោះជារបស់មួងម្កាល ដោយការពិចារណាចិត្តដែលបានពិចារណាហើយ ។

ឯការពិចារណានេះឯង បន្ថែមជាពីរត្រួត លោកហៅថា **ជាការពិចារណាដោយលំដាប់** ព្រោះមានលំដាប់នៃការពិចារណាច្រើនយ៉ាង ។ បទថា **វដ្ដេយ្យ** សេចក្តីថា គប្បីមាន ។ កាលបើដូច្នោះ ក៏គប្បីមានការភាវនាដែលកើតអំពីការពិចារណាដោយលំដាប់នោះឯង តែមិនមែនគប្បីមានភាវនាដែលជាឧបការៈដល់មូលកម្មដ្ឋាន និងមិន

គប្បីមានការប្រព្រឹត្តទៅនៃសមាបត្តិនេះ ។ ព្រោះលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ក្នុងរូបធម៌ និងអរូបធម៌ រមែងជាការជាក់ច្បាស់ល្អ ដោយពាក្យត្រឹមប៉ុណ្ណោះ ដូច្នោះ ទើបលោកពោលទុកថា **តែព្រោះត្រឹមតែពិចារណាចិត្តដួងទី ១០ រូបកម្មដ្ឋានក្តី អរូប-កម្មដ្ឋានក្តី រមែងស្ទាត់ជំនាញ** ហេតុនោះ ទើបលោកប្រាប់ទុកថា **គប្បីឈប់ក្នុងចិត្តដួងទី ១០ ប៉ុណ្ណោះចុះ** ។ ពាក្យថា **គប្បីឈប់** បានដល់ មិនគប្បីពិចារណា ចិត្តដួងទី ១១ ដោយចិត្តដួងទី ១២ ព្រោះហេតុនោះ គប្បីពិចារណាចិត្តដែលមានការឃើញដែនកំណត់របស់ការពិចារណាយ៉ាងក្រៃលែង មិនគប្បីពិចារណាចិត្តដែលមិនមានការឃើញទាបជាងការពិចារណានោះ យ៉ាងក្រៃលែង ព្រោះហេតុនោះ ព្រះយោគីរមែងកំណត់រូបទៀត ហើយតាមប្រកបការភាវនារហូតដល់ការពិចារណាចិត្តដួងទី ១០ នោះឯង ។ ពាក្យថា **លោកពោលទុក** គឺលោកពោលទុកក្នុងអរិយវង្សកថា ។

ពាក្យថា **មិនមានន័យសម្រាប់ពិចារណាមួយបែបម្យ៉ាង** បានដល់ ការធ្វើមនសិការ វិបស្សនាដទៃដែលក្រៅអំពីការធ្វើមនសិការលក្ខណៈ មានអនិច្ចលក្ខណៈជាដើមមិនមាន ។ ក្នុងវិបស្សនា ការសង្កត់សង្កិនទិដ្ឋិជាដើម លោកមានបំណងយកការបើកទិដ្ឋិក្នុងទីនេះ ។ លោកអាចារ្យកាលសម្តែងការបើកទិដ្ឋិជាដើម រមែងសម្រេចបានដោយការផ្សេងគ្នានៃការប្រព្រឹត្តទៅក្នុងវិបស្សនានោះឯង ទើបពោលពាក្យជាដើមថា **យម្បនេតំ** ប្រែថា រូបក្នុងខាងដើមនេះ ។ ក្នុងពាក្យនោះ ពាក្យថា **សត្តសញ្ញា** បានដល់ ការសម្គាល់ ដែលកើតឡើងថា សត្វទាំងឡាយមាន ។ អាចារ្យទាំងឡាយពោលថា បានដល់ ការសម្គាល់ ដែលសហគតៈដោយអត្តទិដ្ឋិយ៉ាងទន់ ដូច្នេះក៏មាន ។ ពាក្យថា **ដោយចិត្តដែលដកសត្តសញ្ញាបានហើយ** សេចក្តីថា ទិដ្ឋិ រមែងមិនកើតឡើងដោយចិត្តដែលប្រព្រឹត្តទៅ ដោយអំណាចការសង្កត់សង្កិនសត្តសញ្ញាទុកបាន ចិត្ត-វិបល្លាស និងទិដ្ឋិវិបល្លាស ដែលកើតឡើងព្រោះសញ្ញាវិបល្លាសជាហេតុ រមែងមាន

ដោយការមាននៃសញ្ញាវិបល្លាសនោះឯង ។ ដែលឈ្មោះថា **មានះ** បានដល់ មានះដែលមានទិដ្ឋិជាឧបនិស្ស័យ ញុំាងសត្វឲ្យទៅកាន់អបាយ កាលសង្កត់ទិដ្ឋិបានហើយ រមែងបានសង្កត់សង្កិនទៅផងដូចគ្នា ព្រោះកាត់ផ្តាច់បាន កាលទិដ្ឋិបានកាត់ផ្តាច់ ហេតុនោះ ទើបលោកអាចារ្យពោលថា **កាលកំណត់កាន់យកសង្ខារដោយចិត្តដែលបើកទិដ្ឋិបានហើយ មានះរមែងមិនកើតឡើង** ដូច្នេះ ។ មានះដែលត្រូវសង្កត់ទុក រមែងហាមឃាត់ការប្រព្រឹត្តទៅនៃតណ្ហា ព្រោះតណ្ហាប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលប្រកាន់ខ្លួនក្រៃលែង ហេតុនោះ ទើបលោកអាចារ្យពោលថា **កាលកំណត់កាន់យកសង្ខារដោយចិត្តដែលបើកមានះបានហើយ តណ្ហារមែងមិនកើតឡើង** ដូច្នេះ ។ លោកមានបំណងយកសេចក្តីត្រេកអរយ៉ាងល្អិតថា **តណ្ហា** ក្នុងទីនេះ ហេតុនោះ ទើបលោកអាចារ្យពោលថា **កាលតណ្ហាមិនកើតឡើង ការត្រេកអរ ក៏ឈ្មោះថា ត្រូវសង្កត់ទុកបាន** ដូច្នេះ ។

ពាក្យថា **ន័យនេះ** គឺពិធីពិចារណាដែលកំពុងពោលឥឡូវនេះ ។

លោកអាចារ្យពោលថា **ឯកាលប្រកាន់ មិនឈ្មោះថា បើកទិដ្ឋិ** ដូច្នេះ ដោយប្រការនោះ ព្រោះពាក្យថា **ការឃើញច្បាស់របស់អញ** នេះ ជាការប្រកាន់ដោយទិដ្ឋិ ព្រោះបុគ្គលនោះ ប្រកាន់អត្តាដែលជាម្ចាស់នៃវិបស្សនា ដែលសម្គាល់ថា ជារបស់នៃខ្លួន ។ ឯព្រះយោគីនេះជាអ្នកមានទិដ្ឋិបរិសុទ្ធក៏ដោយការសម្រេចទិដ្ឋិវិសុទ្ធិ និងកង្ខាវិតរណវិសុទ្ធិ ដោយពិត សូម្បីយ៉ាងនោះ លោកអាចារ្យពោលទុកយ៉ាងនេះ ក៏ដោយអំណាចទិដ្ឋិដែលមិនគ្រោតគ្រាត ព្រោះមិនទាន់បានបើកដោយមគ្គ ។

ពាក្យថា **យ៉ាងល្អ** គឺដោយប្រពៃ ។ ចំណែកពាក្យថា **យ៉ាងគួរពេញចិត្ត** ជាកិរិយាវិសេសនៈ ដោយអត្ថថា ដោយអាការដែលជាទីត្រេកអរនៃចិត្ត ។ ដោយពាក្យទាំង ២ លោកអាចារ្យពោលដល់អធិមានះ ដែលជាវិស័យនៃវិបស្សនា ដោយ

ហេតុនោះ ទើបលោកអាចារ្យពោលថា **មិនឈ្មោះថា បើកមានះ** ។

ពាក្យថា **អាត្មាអញអាចឃើញច្បាស់បាន** ប្រកបសេចក្ដីថា ព្រះយោគីរមែងសម្ដែងភាពដែលវិបស្សនា ជារឿងដែលខ្ទួនគប្បីត្រេកអរ ព្រោះប្រកបដោយគុណវិសេស ដោយអំណាចការអាស្រ័យភាពជាអ្នកមានសមត្ថភាព ក្នុងវិបស្សនានោះ កាលត្រេកអរក្នុងវិបស្សនា ដោយគិតថា អាត្មាអញអាចឃើញច្បាស់នូវចិត្តបាន ។ ព្រោះហេតុនោះ អាត្មាអញកំពុងឃើញច្បាស់នូវហេតុនោះឯងហើយ រង់ចាំវេលាដូច្នេះ ។

ព្រោះឈ្មោះថា ការបើកទិដ្ឋិក្នុងទីនេះ រមែងមានបានដោយអនត្តានុបស្សនាដោយពិសេស ដូច្នោះ លោកអាចារ្យកាលនឹងសម្ដែងអនត្តានុបស្សនានោះ បានពោលវិធីពិចារណាអនត្តាដោយពាក្យជាដើមថា **បើកសង្ខារទាំងឡាយ** ដូច្នេះ តែព្រោះយោគីពិចារណាឃើញដោយភាពជាអនត្តា ក៏គប្បីពិចារណាឃើញសង្ខារទាំងឡាយដោយជារបស់មិនទៀង និងដោយជាទុក្ខ ដោយចូលទៅចម្រើននូវភាពជាអនត្តានោះ ហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះអត្ថថា មានហើយមិនមាន** ជាដើម ។

ព្រោះឈ្មោះថា **ការបើកមានះ** រមែងមានបានដោយអនិច្ចានុបស្សនា ។ កាលឃើញសង្ខារទាំងឡាយបែកធ្លាយទៅគ្រប់ៗ ខណៈ ការឈោងចុះរបស់មានះ នឹងមានអំពីណា ។ សេចក្ដីនេះ សមដូចពាក្យដែលលោកពោលទុកថា គប្បីចម្រើនអនិច្ចសញ្ញា ដើម្បីការបើកអស្មិមានះ ។

ព្រោះឈ្មោះថា **ការឃុំគ្រងសេចក្ដីត្រេកអរទុកបាន** រមែងមានបានដោយទុក្ខានុបស្សនា ។ កាលព្រះយោគីឃើញសង្ខារទាំងឡាយដែលជាទុក្ខដោយសភាវៈ ឬដោយជាទីតាំងនៃសេចក្ដីទុក្ខ នឹងមានសេចក្ដីត្រេកអរបេក្ខិចបន្ទួចក្នុងសង្ខារនោះ ក៏មិនមាន ។ ព្រោះថា តណ្ហាក្នុងសង្ខារនោះ គប្បីកើតឡើងដល់បុគ្គលដែលតាមឃើញ

សេចក្ដីត្រេកអរ ។ ពាក្យដ៏សេសក៏មានន័យដូចបានពោលហើយ ក្នុងអនត្តលក្ខណៈនោះឯង ។ ចំណែកសេចក្ដីសង្ខេបក្នុងអធិការនេះ មានដូចតទៅនេះ ។

កាលណា អនត្តានុបស្សនា រមែងប្រព្រឹត្តទៅយ៉ាងរឹងមាំ ក្លាហាន ស្ទាត់ជំនាញដល់ព្រះយោគីដែលខ្នះខ្នែង ការពិចារណាដោយលំដាប់តាមន័យដែលបានពោលហើយ អនុបស្សនា ២ ប្រការទៀតក្រៅអំពីនេះ រមែងទៅតាមអនត្តានុបស្សនានោះ កាលនោះ ព្រះយោគីនោះរមែងធ្វើការបើកទិដ្ឋិបាន ។ ព្រោះថា ទិដ្ឋិទាំងឡាយ មានអត្តទិដ្ឋិជាមូល ។ ហើយអនត្តានុបស្សនា ជាបដិបក្ខចំពោះអត្តទិដ្ឋិ ។

ម្យ៉ាងទៀត កាលណា អនិច្ចានុបស្សនារមែងប្រព្រឹត្តទៅយ៉ាងរឹងមាំ ក្លាហានស្ទាត់ជំនាញ អនុបស្សនាទាំង ២ ប្រការក្រៅអំពីនេះ ក៏ទៅតាមអនិច្ចានុបស្សនានោះ កាលនោះ ព្រះយោគីនោះរមែងធ្វើការបើកមានះបាន ។ ព្រោះកាលមានការប្រកាន់ថា **ទៀង** ក៏នឹងមានការក្រសោបយករបស់មានះ ដោយន័យជាដើមថា **នេះទៀង នេះស្ថិតស្ថេរ** ដូចជាមានះរបស់ពកាព្រហ្ម ។ ឯអនិច្ចានុបស្សនា ជាបដិបក្ខចំពោះការប្រកាន់ថា **ទៀង** ។

ម្យ៉ាងទៀត កាលណា ទុក្ខានុបស្សនារមែងប្រព្រឹត្តទៅយ៉ាងរឹងប៉ឹងថា ក្លាហានស្ទាត់ជំនាញ អនុបស្សនាទាំង ២ ក្រៅអំពីនេះ ក៏ទៅតាមទុក្ខានុបស្សនានោះ កាលនោះ ព្រះយោគីនោះ រមែងជាអ្នកធ្វើការឃុំគ្រងសេចក្ដីត្រេកអរទុកបាន ។ ព្រោះកាលមានការសម្គាល់ថា **ជាសុខ** ក៏មានការប្រកាន់ គឺតណ្ហានោះឯង ហើយទុក្ខានុបស្សនាជាបដិបក្ខចំពោះសេចក្ដីត្រេកអរ កាលបើកទិដ្ឋិជាដើម រមែងមានបានដោយអំណាចការផ្សេងគ្នានៃកិច្ចរបស់អនុបស្សនាទាំង ៣ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទើបវិបស្សនានេះ ឈ្មោះថា តាំងនៅក្នុងទីរបស់ខ្លួន រៀងៗ ខ្លួនពិត** ។ អធិប្បាយថា ពិតហើយ ការធ្វើកិច្ចរបស់ខ្លួន តាមគួរ

នៃអនុបស្សនាទាំងឡាយ ជាឋានៈក្នុងទីរបស់ខ្លួននោះឯង ព្រោះហេតុនោះ ន័យនៃការពិចារណាជាផ្នែក ទើបមិនមាន ព្រោះហេតុនោះ ទើបមិនចាំបាច់ពោលទុក ។

ពាក្យថា **ដោយអាការទាំងពួង** គឺដែលគប្បីដល់បានដោយអាការទាំងពួង គឺដោយមិនមានចំណែកដ៏សេស ដោយសរុប និងដោយកិច្ច មិនមែនពោលដោយចំណែកមួយ ដូចក្នុងទីនេះ ។ បទថា **ឥធេវ យោគ តីរណបរិញ្ញាយមេវ** ប្រែថា ក្នុងតីរណបរិញ្ញានេះឯង ។ ក្នុងទីនេះ ជាការបានចំពោះនូវអនុបស្សនាខ្លះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **កាលចាក់ធ្លុះចំណែកមួយ** ដូច្នេះ ។ ឯអនុបស្សនាទាំងនោះ លោកអាចារ្យរមែងសម្តែងដោយសរុបនោះឯង ដូច្នេះ ។ ពាក្យថា **ធម៌ដែលជាបដិបក្ខចំពោះអនុបស្សនានោះ** សេចក្តីថា **រមែងលះ** គឺសង្កត់ធម៌ដែលជាបដិបក្ខចំពោះអនុបស្សនា ដែលមាននៅក្នុងទីនេះ បានដល់ ធម៌ មាននិច្ចសញ្ញាជាដើម ។

ពាក្យថា **ខយានុបស្សនា** បានដល់ ការពិចារណាឃើញការរលត់ទៅគ្រប់ខណៈនៃសង្ខារ ។ បទថា **ឃនវិនិព្ភោគ** ប្រែថា ចម្រើន ពាក្យថា **ឃនសញ្ញា** បានដល់ ការប្រកាន់ថា ជារបស់ដូចគ្នា ដោយអំណាចសន្តតិ សមូហៈ កិច្ច និងអារម្មណ៍ ។ អាចារ្យទាំងឡាយរមែងពោលថា ពាក្យថា **ខយានុបស្សនា** បានដល់ ការពិចារណាឃើញការមាន ហើយមិនមាន ។ បញ្ញាដែលជាហេតុធ្វើការញែកភាពជាដុំ ហើយឃើញថា **មិនទៀង ដោយអត្ថថា អស់ទៅ** ឈ្មោះថា **ខយានុបស្សនា** ។ តាំងអំពីភង្គានុបស្សនាទៅ ទើបមានការលះឃនសញ្ញាបាន ព្រោះជាការធ្វើភង្គានុបស្សនានោះឲ្យបរិបូណ៌មុនអំពីនោះ កាលលះឃនសញ្ញានោះមិនទាន់បាន ព្រោះភង្គានុបស្សនានោះមិនទាន់បរិបូណ៌ ។ សូម្បីក្នុងអនុបស្សនាដទៃ ក៏យ៉ាងនេះ ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញវិបស្សនាបញ្ញា ជាធម្មជាតិបរិបូណ៌ និងមិនបរិបូណ៌ក្នុងបហានបរិញ្ញា និង

តីរណាបរិញ្ញា ។ ការបានឃើញការរលត់នៃសង្ខារទាំងឡាយ ដោយប្រចក្សនិងដោយអនុលោមតាម និងបង្អោនទៅក្នុងនិរោធ ពោល គឺការរលត់ក្នុងសង្ខារនោះឯង ឈ្មោះថា **វយានុបស្សនាយោគីរមែងលះអាយូហនៈ** ( ការប្រមូលមក ) ដោយវយានុបស្សនានោះ ។ ព្រះយោគីរមែងព្យាយាមដើម្បីប្រយោជន៍ណា និងដោយអនុបស្សនាណា កាលប្រយោជន៍និងអនុបស្សនានោះប្រព្រឹត្តទៅហើយ ចិត្តរបស់ព្រះយោគីនោះរមែងមិនបង្អោនទៅក្នុងតណ្ហាឡើយ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **កាលចម្រើនវយានុបស្សនា រមែងលះអាយូហនៈ** ( ការប្រមូលមក ) បាន ។ ការឃើញសេចក្ដីប្រែប្រួល ២ ប្រការ គឺដោយជរា និងមរណៈរបស់សត្វដែលកើតហើយ ឬការឃើញដទៃតអំពីការកំណត់នោះៗ របស់ព្រះយោគីដែលកំណត់បាន ដោយជារូប ៧ ប្រការជាដើម ឈ្មោះថា **វិបរិណាមានុបស្សនា** ( បញ្ញាពិចារណាឃើញការប្រែប្រួល ) ព្រះយោគី **រមែងលះធុវសញ្ញា** គឺការប្រកាន់ថា ជាការមាំទាំ ដោយវិបរិណាមានុបស្សនានោះ ។

អនុបស្សនាទាំងឡាយ មានអនិមិត្តានុបស្សនាជាដើម គឺអនិច្ចានុបស្សនានោះឯង ។ ពាក្យថា **និមិត្ត** បានដល់ អាការត្រឹមតែការប្រាកដដូចជាមានរាងកាយ ព្រោះភាពដែលសង្ខារទាំងឡាយ មានការកំណត់ដោយកិច្ចរបស់ខ្លួន ដោយការៈ ដែលជាការតាំងចុះក្នុងចន្លោះនៃកាល និងដោយការៈដែលជារបស់ទៀង ដែលប្រកាន់យកដោយសម្គាល់ថា ដូចគ្នា ក្នុងការបន្ត និងក្នុងការប្រជុំ ។ ពាក្យថា **បណិធិ** បានដល់ការប្រាថ្នាសេចក្ដីសុខ ឬការតាំងមាំនៃកិលេស មានរាគៈជាដើម ដោយអត្ថ បានដល់ការដែលបង្អោនទៅក្នុងសង្ខារ ដោយអំណាចតណ្ហា ។ ពាក្យថា **អភិនិវេស** បានដល់ការប្រកាន់មាំនូវអត្តា ។ ឯអនិច្ចានុបស្សនាជាដើម លោកពោលទុកដោយឈ្មោះថា អនិមិត្តជាដើម ដោយជាបដិបក្ខចំពោះនិមិត្តជាដើមនេះ ព្រោះហេតុនោះ ការកាន់យក

ដោយជានិមិត្តជាដើមនោះឯង គប្បីឃើញថា ជាបដិបក្ខគ្នា ដូចក្នុងនិច្ចសញ្ញាជាដើម ឯអនិច្ចានុបស្សនាជាដើម គប្បីលះដូច្នោះ ។ វិបស្សនាដែលប្រព្រឹត្តទៅដោយដឹងអារម្មណ៍មានរូបជាដើម ឃើញការរលត់របស់ចិត្តដែលមានរូបជាដើមនោះជាអារម្មណ៍ ហើយប្រកាន់យកភាពសោះសូន្យ ដោយអំណាចការរលត់ថា សង្ខារប៉ុណ្ណោះបែកធ្លាយទៅ ការស្លាប់របស់សង្ខារមិនមានអ្វីដទៃឡើយ ដូច្នេះ វិបស្សនា គឺការឃើញច្បាស់ក្នុងធម៌ទាំងឡាយនោះផង ជាអធិបញ្ញាផង ព្រោះហេតុនោះ ទើបឈ្មោះថា **អធិបញ្ញាធម្មវិបស្សនា** ព្រះយោគីរមែងលះសេចក្ដីប្រកាន់មាំដែលប្រព្រឹត្តទៅដោយអំណាចការប្រកាន់ថា មានសារៈជានិច្ចជាដើម គឺទិដ្ឋិ ព្រមទាំងតណ្ហា ដោយអធិ-បញ្ញាធម្មវិបស្សនានោះ ។ ដែលឈ្មោះថា **យថាភូតញ្ញាណទស្សនៈ** បានដល់ ការឃើញនាម និងរូប ព្រមទាំងបច្ច័យ ។ ដោយយថាភូតញ្ញាណទស្សនៈនោះ ព្រះយោគីរមែងលះសម្មោហាភិនិវេស (ការប្រកាន់មាំដោយការវង្វេង ) ជាដើមយ៉ាងនេះថា **ក្នុងអតីតកាល អាត្មាអញបាន មានហើយឬហ្ន៎ ឬ លោក គឺព្រះឥសូរសាងឡើងទើបមាន** ដូច្នេះជាដើម ។ ញាណដែលឃើញទោសក្នុងភពទាំងពួងជាដើម ដែលកើតឡើង ដោយអំណាចការប្រាកដដោយជារបស់គួរខ្លាច ឈ្មោះថា **អាទីនវានុបស្សនា** ព្រះយោគី **រមែងលះអាលយាភិនិវេស** ( ការប្រកាន់មាំដោយការអាល័យ )គឺតណ្ហាដែលប្រព្រឹត្តទៅយ៉ាងនោះ ព្រោះមិនឃើញទីអាស្រ័យរបស់សេចក្ដីអាល័យ សូម្បីរបស់បុគ្គលណាម្នាក់ដោយអាទីនវានុបស្សនានោះ។ញាណពិចារណាដែលជាឧបាយរកផ្លូវរួចផុតអំពីសង្ខារ ឈ្មោះថា **បដិសង្ខានុបស្សនា** ព្រះយោគីរមែងលះអវិជ្ជាដែលជាបដិបក្ខចំពោះការពិចារណារកផ្លូវរួចផុត ព្រោះមិនបានពិចារណាក្នុងភាពជារបស់មិនទៀងជាដើម ដោយបដិសង្ខានុបស្សនានោះ ។ សង្ខារុបេក្ខា និងអនុលោមញ្ញាណ ឈ្មោះថា **វិវដ្ដានុបស្សនា** (បញ្ញាពិចារណាឃើញវិវដ្ដៈ គឺផ្លូវរួចផុតអំពីវដ្ដៈ ) ។ដោយ

អំណាចនៃវិវដ្ដានុបស្សនានោះ ចិត្តរបស់ព្រះយោគីនោះ រមែងចៀសចេញ ថយចេញ អំពីសង្ខារទាំងពួង ដូចតំណក់ទឹកលើស្លឹកឈូក ដូច្នោះ ព្រោះហេតុនោះ ព្រះយោគី **ទើបលះសំយោគាភិនិវេស** (ការប្រកាន់មាំដោយអំណាចសំយោគៈ) គឺការប្រព្រឹត្តទៅនៃកិលេស មានកាមសំយោគៈជាដើម ដោយវិវដ្ដានុបស្សនានោះ ។ អនុបស្សនាទាំង ៧ មានអនិច្ចានុបស្សនាជាដើម ខ្ញុំបានចែកទុកហើយ ដោយអត្ថខាងដើម ហើយនឹងពណ៌នាតទៅ ដូច្នោះ ទើបពោលទុកក្នុងទីនេះ ។

បទថា **តាសុ យោគ អដ្ឋារសសុ មហាវិបស្សនាសុ** ប្រែថា ក្នុងមហាវិបស្សនា ១៨ នោះ ។ បទថា **ឥមិនា យោគ យោគិនា** ប្រែថា ព្រះយោគីនេះ ។ បទថា **តស្មា យោគ អនិច្ចាទិលក្ខណត្តយវសេន សង្ខារានំ ទិដ្ឋត្តា** ប្រែថា ព្រោះហេតុដែលសង្ខារទាំងឡាយ លោកឃើញហើយ ដោយអំណាចលក្ខណៈទាំង ៣ មានអនិច្ចលក្ខណៈជាដើម ។ពិតហើយ ការឃើញនោះជាអនុបស្សនា មានអនិច្ចានុបស្សនាជាដើម ដូច្នេះ ។ បទថា **បដិវិទ្ធា** សេចក្ដីថា បានចំពោះហើយ ។ ពិតហើយ ធម៌ ព្រមទាំងវិន័យ ដែលព្រះយោគីចាក់ធ្លុះដោយញាណ ដោយចំណែកណា ក៏ឈ្មោះថា ជាការចាក់ធ្លុះនូវញាណនោះ ដោយចំណែកនោះ ។ **ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ** ដូចពាក្យថា **រុក្ខា បាទបា តរុ** ប្រែថា ដើមឈើដូចគ្នា ។ **តាបិ យោគ អនិមិត្តាបណិហិតសុញ្ញតានុបស្សនា** ប្រែថា សូម្បីអនិមិត្តានុបស្សនា បណិហិតានុបស្សនា និងសុញ្ញតានុបស្សនា ទាំងនោះ ។

អធិប្បាយថា **វិបស្សនាទាំងអស់** គឺព្រះយោគីចាក់ធ្លុះហើយ ដោយចំណែកមួយ ព្រោះហេតុនោះ ។ ឈ្មោះថា **សង្គ្រោះដោយកង្ខាវិតរណវិសុទ្ធិនោះឯង** អធិប្បាយថា ព្រោះហេតុនោះ យថាភូតញ្ញាណទស្សនៈនោះសម្រេចហើយមុននោះឯង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **សូម្បីអធិបញ្ញាធម្មវិបស្សនា និងយថាភូត-**

ញ្ញាណទស្សនៈទាំង ២ នេះ គឺព្រះយោគីចាក់ធ្លុះហើយដូចគ្នា ។ ក្នុងវិបស្សនាញាណទាំងឡាយ ដ៏សេស គឺក្នុងវិបស្សនាញាណ ១០ មាននិព្វិទានុបស្សនាជាដើម ។ ដោយពាក្យថា ចំណែកខ្លះក៏ជាការចាក់ធ្លុះ ចំណែកខ្លះមិនទាន់ចាក់ធ្លុះបាន នេះ លោកអាចារ្យពោលការចាក់ធ្លុះឯកទេសនៃវិបស្សនាញាណទាំងនោះ ។ ព្រោះថា កាលអនិច្ចានុបស្សនាសម្រេចហើយ និព្វេធានុបស្សនា ខយានុបស្សនា វយានុបស្សនា និងវិបរិណាមានុបស្សនា ក៏ឈ្មោះថា បានសម្រេចដោយឯកទេស កាលទុក្ខានុបស្សនាសម្រេចហើយ និព្វិទានុបស្សនា និងអាទីនវានុបស្សនា ក៏បានសម្រេចដោយឯកទេស កាលអនត្តានុបស្សនាសម្រេចហើយ អនុបស្សនាក្រៅអំពីនេះ ក៏ត្រូវបានសម្រេចដោយឯកទេស ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ឧទយព្វយានុបស្សនាញាណ

ព្រះយោគីនោះ ជាអ្នកមានញាណបរិសុទ្ធ ព្រោះលះនិច្ចសញ្ញាជាដើម ដែលជាបដិបក្ខធម៌របស់វិបស្សនា មានអនិច្ចានុបស្សនាជាដើម បានដល់ត្រើយនៃសម្មសនញ្ញាណយ៉ាងនេះហើយ រមែងផ្តើមធ្វើសេចក្តីព្យាយាមដើម្បីសម្រេចឧទយព្វយានុបស្សនាញាណដែលលោកពោលទុកក្នុងលំដាប់សម្មសនញ្ញាណថា បញ្ញាក្នុងការពិចារណាឃើញការប្រែប្រួលនៃធម៌ទាំងឡាយ ដែលកើតឡើងចំពោះមុខ ឈ្មោះថា ឧទយព្វយានុបស្សនាញាណ ( ញាណក្នុងការពិចារណាឃើញការកើតឡើង និងការវិនាសទៅ ) ដូច្នេះ ។ កាលផ្តើមធ្វើ រមែងផ្តើមធ្វើដោយសង្ខេបមុននេះ ជាបាលីក្នុងការផ្តើមធ្វើដោយសង្ខេបនោះ ។

សួរថា បញ្ញាក្នុងការពិចារណាឃើញការប្រែប្រួលនៃធម៌ទាំងឡាយ ដែលកើតឡើងចំពោះមុខ ឈ្មោះថា **ឧទយព្វយានុបស្សនាញាណ** ដូចម្តេច ? ឆ្លើយថា រូបកើតឡើងជាបច្ចុប្បន្ន លក្ខណៈដែលកើតឡើងនៃរូបនោះ ជាឧទយៈ លក្ខណៈដែលប្រែប្រួលទៅនៃរូបនោះ ជាវយៈ បញ្ញាពិចារណាឃើញ ( ឧទយៈ និងវយៈនោះ ) ជាញាណ វេទនា... សញ្ញា... សង្ខារ... វិញ្ញាណកើតឡើងជាបច្ចុប្បន្ន លក្ខណៈដែលកើតឡើងនៃវេទនា...សញ្ញា...សង្ខារ...វិញ្ញាណនោះ ជាឧទយៈ ហើយលក្ខណៈដែលប្រែប្រួលទៅនៃវេទនា... សញ្ញា... សង្ខារ... វិញ្ញាណនោះ ជាវយៈ បញ្ញាពិចារណាឃើញ ( ឧទយៈ និងវយៈនោះ ) ជាញាណ ចក្ខុកើតឡើងជាបច្ចុប្បន្ន ភពកើតឡើងជាបច្ចុប្បន្ន លក្ខណៈដែលកើតឡើងនៃចក្ខុ ។បេ។ ភពនោះ ជាឧទយៈ

លក្ខណៈដែលប្រែប្រួលទៅនៃចក្ខុ ។បេ។ ភពនោះជាវយៈ បញ្ញាពិចារណាឃើញ ( ឧទយៈ និងវយៈនោះ ) ជាញាណ ។

ព្រះយោគីនោះ ពិចារណាឃើញនិព្វត្តិលក្ខណៈ គឺការកើតឡើង ការឧប្បត្តិឡើង អាការដែលកើតឡើងថ្មី នៃនាមរូបដែលកើតហើយ ជាឧទយៈ ពិចារណាឃើញ វិបរិណាមលក្ខណៈ គឺការអស់ទៅ ការលត់ទៅនៃនាមរូបដែលកើតហើយ ជាវយៈ តាមន័យបាលីនេះ លោករមែងដឹងទូទៅ យ៉ាងនេះថា ក្នុងកាលមុនអំពីការកើតឡើង នៃនាមរូបនេះ គំនរ ឬពួកក្រុមរបស់នាមរូបដែលមិនទាន់កើតក៏មិនមាន ឈ្មោះថា ការមកអំពីគំនរ ឬមកអំពីពួកក្រុមនៃនាមរូបដែលកំពុងកើតសោត ក៏មិនមាន ឈ្មោះ ថា ការទៅកាន់ទិសធំ-តូច នៃនាមរូប ដែលកំពុងរលត់សោត ក៏មិនមាន ឈ្មោះថា ការតាំងចុះដោយ ( រួមគ្នា ) ជាគំនរ ជាពួកក្រុម ជាប្រកពក្នុងទីឯណាមួយនៃនាមរូប ដែលរលត់ហើយសោត ក៏មិនមាន ដូចជាពិណដែលបុគ្គលកំពុងលេង ប្រជុំរបស់ សំឡេងដែលកើតឡើងមិនមានមុនការកើតឡើងឡើយ កំពុងកើត សំឡេងក៏មិនបាន មកអំពីប្រជុំ គឺខ្សែជាដើម ការទៅកាន់ទិសធំ-តូចនៃសំឡេង ដែលកំពុងរលត់ក៏ មិនមាន សំឡេងរលត់ហើយ ក៏មិនបានប្រជុំនៅក្នុងទីណាមួយ ដោយពិតនោះសំឡេង ពិណនោះមិនមាន បែរជាមានឡើង ព្រោះអាស្រ័យតួពិណ ដងពិណ និងការព្យាយាម ដែលគួរដល់ការងាររបស់បុគ្គលនោះ កាលមានហើយ ក៏ត្រឡប់បាត់ទៅ យ៉ាងណា សូម្បីធម៌ទាំងឡាយ ទាំងដែលមានរូប និងមិនមានរូបទាំងពួង ក៏មិនមាន បែរជាមាន ឡើង កាលមានហើយ ក៏ត្រឡប់វិនាសទៅ ដូច្នោះឯង ។

ព្រះយោគី កាលធ្វើឧទយព្វយមនសិការដោយសង្ខេបដូច្នេះហើយ ទើបធ្វើ មនសិការដោយពិស្តារ ដោយបច្ច័យ និងដោយខណៈទៀត ជាដើមថា ការកើត ឡើងនៃរូបរមែងមាន ( ព្រោះការកើតឡើងនៃបច្ច័យ ) យ៉ាងនេះខ្លះ ការវិនាសទៅ

នៃរូប រមែងមាន ( ព្រោះការរលត់នៃបច្ច័យ ) យ៉ាងនេះខ្លះ រូបរមែងកើត ( ដោយខណៈ ) យ៉ាងនេះខ្លះ រូបរមែងត្រឡប់សូន្យទៅ ( ដោយខណៈ ) យ៉ាងនេះខ្លះ តាមគេណ្ឌលក្ខណៈ ៥០ ដោយធ្វើជាជប់ៗ ដោយឃើញការកើត ការរលត់នៃខន្ធនីមួយៗ ដែលលោកពោលទុកក្នុងវិភង្គ នៃឧទយព្វយញ្ញាណនោះឯង ដូច្នេះថា ភិក្ខុរមែងឃើញការកើតឡើងនៃរូបក្ខន្ធ ដោយអត្ថ គឺការកើតឡើងនៃបច្ច័យថា **ការកើតឡើងនៃរូបរមែងមានព្រោះការកើតឡើងនៃអវិជ្ជា** រមែងឃើញការកើតឡើងនៃរូបក្ខន្ធ ដោយអត្ថ គឺការកើតឡើងនៃបច្ច័យថា **ការកើតឡើងនៃរូប រមែងមានព្រោះការកើតឡើងនៃតណ្ហា... ព្រោះការកើតឡើងនៃកម្ម... ព្រោះការកើតឡើងនៃអាហារ** សូម្បីឃើញនិព្វត្តិលក្ខណៈ គឺលក្ខណៈដែលកើតឡើងនៃរូប ក៏ឈ្មោះថា ឃើញការកើតឡើងនៃរូបក្ខន្ធ កាលឃើញការកើតឡើងនៃរូបក្ខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ ៥ នេះ ។ ភិក្ខុរមែងឃើញការវិនាសទៅនៃរូបក្ខន្ធ ដោយអត្ថ គឺការរលត់នៃបច្ច័យថា **ការរលត់នៃរូបរមែងមាន ព្រោះការរលត់នៃអវិជ្ជា** រមែងឃើញការវិនាសទៅនៃរូបក្ខន្ធ ដោយអត្ថ គឺការរលត់នៃបច្ច័យថា **ការរលត់នៃរូបរមែងមាន ព្រោះការរលត់នៃតណ្ហា... ព្រោះការរលត់នៃកម្ម... ព្រោះការរលត់នៃអាហារ** សូម្បីឃើញវិបរិណាមលក្ខណៈ គឺលក្ខណៈដែលប្រែប្រួលទៅនៃរូប ក៏ឈ្មោះថា ឃើញការវិនាសនៃរូបក្ខន្ធ កាលឃើញការវិនាសនៃរូបក្ខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ ៥ នេះ ។

ន័យដូចគ្នានោះដែរ ភិក្ខុរមែងឃើញការកើតឡើងនៃវេទនាខន្ធ ដោយអត្ថគឺការកើតឡើងនៃបច្ច័យថា **ការកើតឡើងនៃវេទនារមែងមាន ព្រោះការកើតឡើងនៃអវិជ្ជា** រមែងឃើញការកើតឡើងនៃវេទនាខន្ធ ដោយអត្ថ គឺការកើតឡើងនៃបច្ច័យថា **ការកើតឡើងនៃវេទនារមែងមាន ព្រោះការកើតឡើងនៃតណ្ហា... ព្រោះការកើតឡើងនៃកម្ម... ព្រោះការកើតឡើងនៃផស្សៈ** សូម្បីឃើញនិព្វត្តិលក្ខណៈ ( នៃវេទនា )

ក៏ឈ្មោះថា ឃើញការកើតឡើងនៃវេទនាខន្ធ កាលឃើញការកើតឡើងនៃវេទនាខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ ៥ នេះ ភិក្ខុរមែងឃើញការវិនាសទៅនៃវេទនាខន្ធដោយអត្ថ គឺការរលត់នៃបច្ច័យថា ការរលត់នៃវេទនារមែងមាន ព្រោះការរលត់នៃអវិជ្ជា... ព្រោះការរលត់នៃតណ្ហា... ព្រោះការរលត់នៃកម្ម... ព្រោះការរលត់នៃផស្សៈ សូម្បីឃើញវិបរិណាមលក្ខណៈ ( នៃវេទនា ) ក៏ឈ្មោះថា ឃើញការវិនាសនៃវេទនាខន្ធ កាលឃើញការវិនាសនៃវេទនាខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ ៥ នេះ ។

សម្រាប់សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ក៏ដូចវេទនាខន្ធដែរ ប្លែកតែវិញ្ញាណក្ខន្ធ គឺប្រែកបពាក្យថា **នាមរូបសមុទយា**-ព្រោះការកើតឡើងនៃនាមរូប **នាមរូបនិរោធា**-ព្រោះការរលត់នៃនាមរូប ( ជំនួស ) ក្នុងទីនៃពាក្យ **ផស្សៈ** ។

កាលព្រះយោគីនោះ ធ្វើមនសិការទៅយ៉ាងនេះ ញាណ គឺ **ធម៌ទាំងនេះ មិនមាន ក៏មានឡើង កាលមានហើយ ក៏ត្រឡប់វិនាសទៅ** ដូច្នេះនេះឯង នឹងមុតស្រួចឡើង។

កាលព្រះយោគាវចរនោះឃើញការកើតឡើង និងការរលត់ទៅដោយចំណែក ២ គឺដោយបច្ច័យ ១ ដោយខណៈ ១ យ៉ាងនោះ ការផ្សេងគ្នានៃសច្ចៈ បដិច្ចសមុប្បាទន័យ និងលក្ខណៈ រមែងប្រាកដ ។

ព្រះយោគីនោះ ឃើញការកើតឡើងនៃខន្ធទាំងឡាយ ព្រោះការកើតឡើងនៃបច្ច័យ មានអវិជ្ជាជាដើម និងការរលត់នៃខន្ធទាំងឡាយ ព្រោះការរលត់នៃបច្ច័យ មានអវិជ្ជាជាដើម នេះជាការឃើញការកើតឡើង និងការរលត់ទៅដោយបច្ច័យរបស់លោក កាលឃើញលក្ខណៈដែលកើតឡើង និងលក្ខណៈដែលប្រែប្រួលទៅ ទើបឃើញការកើត និងការរលត់នៃខន្ធទាំងឡាយឯណា នេះជាការឃើញការកើតឡើង និងការរលត់ដោយខណៈរបស់លោក ព្រោះថា លក្ខណៈដែលកើតឡើង រមែងមានក្នុងឧប្បត្តិក្ខណៈប៉ុណ្ណោះ ហើយលក្ខណៈដែលប្រែប្រួលទៅ ក៏រមែងមានក្នុងភង្គក្ខណៈ ។

## សច្ចៈប្រាកដ

*ហេតុនេះ កាលព្រះយោគីនោះឃើញការកើត និងការរលត់ដោយចំណែក ២ គឺដោយបច្ច័យ ១ ដោយខណៈ ១ ដូចពោលមកដូច្នេះ ដោយការឃើញការកើតឡើងដោយបច្ច័យ សមុទយសច្ច ក៏ជាការប្រាកដ ព្រោះកំណត់ដឹងបច្ច័យ ដែលឲ្យកើត ដោយការឃើញការកើតឡើងដោយខណៈ ទុក្ខសច្ចក៏ជាការប្រាកដ ព្រោះកំណត់ដឹងជាតិទុក្ខ ដោយឃើញការវិនាសទៅដោយបច្ច័យ និរោធសច្ចក៏ជាការប្រាកដ ព្រោះដឹងការមិនកើតឡើងនៃវត្ថុដែលមានបច្ច័យទាំងឡាយ ព្រោះការមិនកើតឡើងនៃបច្ច័យ ដោយការឃើញការវិនាសដោយខណៈ ទុក្ខសច្ចក៏ជាការប្រាកដទៀត ព្រោះពិចារណាដឹងមរណទុក្ខ ចំណែកការឃើញការកើតឡើង និងការវិនាសទៅ ( ដោយបច្ច័យ និងដោយខណៈ ) នៃព្រះយោគីនោះឯណា នេះជាលោកិយមគ្គ ព្រោះហេតុនោះ មគ្គសច្ចក៏ជាការប្រាកដ ព្រោះកម្ចាត់សម្មោហៈក្នុងមគ្គនោះចេញបាន ។*

## បដិច្ចសមុប្បាទ និង បដិច្ចសមុប្បន្នធម៌ប្រាកដ

*ម្យ៉ាងទៀត ដោយការឃើញការកើតឡើងដោយបច្ច័យ អនុលោម បដិច្ចសមុប្បាទក៏ជាការប្រាកដដល់ព្រះយោគីនោះ ព្រោះពិចារណាដឹងថា* ***កាលវត្ថុនេះមាន ទើបវត្ថុនេះមាន*** *ដោយការឃើញការរលត់ទៅដោយបច្ច័យ បដិលោមបដិច្ចសមុប្បាទ ក៏ជាការប្រាកដ ព្រោះពិចារណាដឹងថា* ***ព្រោះការរលត់នៃវត្ថុនេះ ទើបវត្ថុនេះរលត់*** *តែដោយការឃើញ ទាំងការកើត និងការរលត់ដោយខណៈ បដិច្ចសមុប្បន្នធម៌ទាំងឡាយ រាប់ថា ប្រាកដ ព្រោះបញ្ញាដឹងសង្ខតលក្ខណៈថា ធម៌ទាំងឡាយ ដែលមានការកើត និងរលត់ទៅបាន រមែងជាសង្ខតធម៌ ហើយសង្ខតធម៌ទាំងនោះ ក៏ជាបដិច្ចសមុប្បន្នធម៌នោះឯង ។*

## ន័យទាំង ៤ ប្រាកដ

ម្យ៉ាងទៀត ដោយការឃើញការកើតឡើងដោយបច្ច័យឯកត្តន័យ ក៏ជាការប្រាកដ ដល់ព្រះយោគីនោះ ព្រោះពិចារណាដឹងការមិនដាច់ខ្សែនៃសន្តាន ដោយការសម្ពន្ធគ្នា នៃហេតុ និងផល ដូច្នោះ លោកក៏លះឧច្ឆេទទិដ្ឋិបានល្អក្រៃលែងឡើង ដោយឃើញ ការកើតឡើងដោយខណៈ នានត្តន័យក៏ជាការប្រាកដ ព្រោះពិចារណាដឹងការកើតឡើង នៃរបស់ថ្មីៗ ដូច្នោះ លោកក៏លះសស្សតទិដ្ឋិបាន ល្អក្រៃលែងឡើង ។ ម្យ៉ាងទៀត ដោយការឃើញ ទាំងការកើតឡើង និងវិនាសទៅដោយបច្ច័យអព្យាបារន័យ ក៏ជា ការប្រាកដដល់លោក ព្រោះពិចារណាដឹងធម៌ទាំងឡាយ ជាសភាវៈមិនប្រព្រឹត្តទៅ ក្នុងអំណាច ដូច្នោះ លោកក៏លះអត្តទិដ្ឋិបានល្អក្រៃលែងឡើង ម្យ៉ាងទៀត ដោយការ ឃើញការកើតឡើងដោយបច្ច័យ ឯវំធម្មតាន័យជាការប្រាកដ ព្រោះពិចារណាដឹង ការកើតឡើងនៃផល ដោយអនុរូបដល់បច្ច័យ ដូច្នោះ លោកក៏លះអកិរិយទិដ្ឋិបាន ល្អក្រៃលែងឡើង ។

## លក្ខណៈប្រាកដ

ម្យ៉ាងទៀត ដោយការឃើញការកើតឡើងដោយបច្ច័យ អនត្តលក្ខណៈក៏ជា ការប្រាកដដល់ព្រះយោគីនោះ ព្រោះពិចារណាដឹងធម៌ទាំងឡាយជាសភាវៈ មានការ ប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ ដោយមិនឃ្លៀងឃ្លាត ព្រោះការឃើញទាំងការ កើតឡើង និងការវិនាសទៅដោយខណៈ អនិច្ចលក្ខណៈ រមែងជាការប្រាកដ ព្រោះ ពិចារណាដឹងធម៌ទាំងឡាយជាសភាវៈ មានហើយ ក៏ទៅជាមិនមាន និងព្រោះពិចារណា ដឹងការសោះសូន្យ (នៃសង្ខារធម៌ទាំងឡាយ) ទាំងក្នុងចំណែកមុន និងចំណែកក្រោយ គឺក្នុងអតីត និងអនាគត ទាំងទុក្ខលក្ខណៈ ក៏ជាការប្រាកដ ព្រោះពិចារណាដឹងការ

បៀតបៀន ដោយការកើត និងការរលត់ សូម្បីសភាវលក្ខណៈក៏ជាការប្រាកដ ព្រោះពិចារណាដឹងថា ជាធម៌ដែលកំណត់ទុកដោយការកើត និងការវិនាស សូម្បីសង្ខតលក្ខណៈដែលប្រព្រឹត្តទៅមួយជួរខណៈ ក៏ប្រាកដក្នុងសភាវលក្ខណៈ ព្រោះពិចារណាដឹងការមិនមាននៃការវិនាសក្នុងខណៈកើត និងនៃការកើតក្នុងលក្ខណៈរលត់ ដូច្នេះៗ

សង្ខារទាំងឡាយ រមែងប្រាកដជារបស់ថ្មីជានិច្ច ដល់ព្រះយោគីនោះ ដែលមានប្រភេទនៃសច្ចៈ បដិច្ចសមុប្បាទន័យ និងលក្ខណៈដែលកើតប្រាកដហើយយ៉ាងនោះ ដោយពិចារណាដឹងថា **ឯធម៌ទាំងនេះ មិនមែនមិនធ្លាប់កើត ក៏កើតឡើង ( តែ ) កើតឡើងហើយ រមែងរលត់យ៉ាងនេះឯង** ។ ម្យ៉ាងទៀត សង្ខារមិនមែនប្រាកដជារបស់ថ្មីជានិច្ចប៉ុណ្ណោះទេ គង់ប្រាកដជារបស់មួយជួរខណៈដ៏ខ្លីដោយប្រក្រតី ដូចតំណក់ទឹកសន្សើមកាលព្រះអាទិត្យរះឡើង ដូចពពុះទឹក ដូចគំនូសក្នុងទឹក ដូចគ្រាប់ស្ពៃត្រង់ចុងដែកស្រួច និងដូចផ្លេកបន្ទោរ ទាំងនៅប្រាកដថាជារបស់មិនមានសារៈ គឺមិនពិតប្រាកដ និងមិនមានខ្លឹម ដូចកលមាយា ថ្ងៃបណ្ដើរកូន ការយល់សប្ដិ វង្វង់ភ្លើង ក្រុងគន្ធព្វ ក្រពេញទឹក និងដើមចេកជាដើម ។

ដោយការនៅវិធីត្រឹមប៉ុណ្ណោះ តរុណវិបស្សនាញាណ គឺវិបស្សនាញាណយ៉ាងទន់ ដំបូងឈ្មោះថា ឧទយព្វយានុបស្សនា ដែលចាក់ធ្លុះលក្ខណៈ ៥០ តាំងនៅដោយអាការនោះថា **វត្ថុដែលមានការរលត់ជាធម្មតានោះឯងកើតឡើង កាលកើតឡើងហើយ ក៏ចូលដល់ការរលត់** រមែងត្រូវបានព្រះយោគីនោះបានសម្រេច ហើយព្រោះបានជាក់ច្បាស់តរុណវិបស្សនាញាណ ទើបព្រះយោគីនោះ បានឈ្មោះថា **អារទ្ធវិបស្សក-អ្នកផ្ដើមឃើញច្បាស់** ។

# មហាដីកា

## កថាពណ៌នាដោយឧទយព្វយញ្ញាណ

នឹងវិនិច្ឆ័យក្នុងកថាពោលដោយបដិបទាញាណទស្សនៈខាងមុខតទៅ ញាណបរិសុទ្ធបាន ក៏ដោយការប្រាសចាកសង្កិលេស ប្រៀបដូចអាកាសបរិសុទ្ធបាន ក៏ដោយការប្រាសចាកពពកជាដើម ប្រៀបដូចទឹកបរិសុទ្ធបាន ក៏ដោយការប្រាសចាកមន្ទិលគឺភក់ ប្រៀបដូចមាស បរិសុទ្ធបាន ក៏ដោយការប្រាសចាកស្និម ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រះយោគីនោះ មានញាណបរិសុទ្ធ ព្រោះលះនិច្ចសញ្ញាជាដើម** ។ លោកអាចារ្យពោលថា **ដល់ត្រើយនៃសម្មសនញ្ញាណ** ដូច្នេះ ព្រោះព្រះយោគីនោះបានធ្វើការពិចារណា គឺកំណត់លក្ខណៈទាំង ៣ ក្នុងសង្ខារនៃខន្ធ ដែលមានអាការមិនមែនតិច ។ ក្នុងពាក្យនោះ ពាក្យថា **នៃសម្មសនញ្ញាណ** គឺនៃញាណពិចារណាកលាបៈ ពោល គឺនយវិបស្សនា ។ អាចារ្យទាំងឡាយពោលថា ប្រភេទនៃការពិចារណាទាំងឡាយក្រៅអំពីនេះ ក៏ដើម្បីការមាំទាំនៃសម្មសនញ្ញាណនោះឯង ។ ម្យ៉ាងទៀត ពាក្យថា **នៃសម្មសនញ្ញាណ** បានដល់ នៃញាណដែលពិចារណា មានកលាបៈជាដើម ។ ឯអនុបស្សនានោះ ដូចគ្នានឹងការឃើញច្បាស់នូវធម៌ដែលប្រព្រឹត្តទៅតាមលំដាប់បទ ។ ពិតហើយ ការបើកទិដ្ឋិជាដើម រមែងមានបានក៏ដោយអនុបស្សនានោះឯង ។ លោកអាចារ្យមានបំណងពោលវិធីការនាដោយពិស្ដារខាងមុខ ទើបពោលថា **រមែងផ្ដើមធ្វើដោយសង្ខេបមុន** ។ ឯការផ្ដើមធ្វើដោយសង្ខេប ជាការធ្វើបានងាយដល់ព្រះយោគី ដែលផ្ដើមបំពេញព្យាយាម បទថា **តត្រ យោគ សង្ខេបេនអារម្ភ** ប្រែថា ក្នុងការផ្ដើមធ្វើដោយសង្ខេបនោះ ។

បទថា **កថំ** ជា **កថេតុកម្យតាបុច្ឆា** អធិប្បាយថា បើមានពាក្យសួរថា ពាក្យណា

ដែលលោកពោលទុក **បញ្ញាក្នុងការពិចារណាឃើញការប្រែប្រួលនៃធម៌ទាំងឡាយ ដែលកើតឡើងចំពោះមុខ ឈ្មោះថា ឧទយព្វយញ្ញាណ** ពាក្យនោះ នឹងគប្បីជ្រាបបានដូចម្ដេច ។ ព្រះយោគីគប្បីធ្វើការទាញទុកក្នុងការឃើញការកើតឡើង និងការវិនាសទៅនូវធម៌ទាំងឡាយ ដែលជាបច្ចុប្បន្ន ដោយសន្តតិ ឬដែលជាបច្ចុប្បន្នដោយខណៈ មិនគប្បីធ្វើការប្រកាន់ក្នុងការឃើញការកើតឡើង និងការរលត់ទៅនូវធម៌ទាំងឡាយ ដែលជាអតីត និងអនាគត ព្រោះហេតុនោះ ទើបលោកពោលថា **នៃធម៌ទាំងឡាយ ដែលកើតឡើងចំពោះមុខ** ។ ឯការឃើញការកើតឡើងក្នុងទីនេះ ក៏ត្រឹមតែដើម្បីឃើញការរលត់ទៅប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះធម្មសេនាបតីសារីបុត្របំណងសម្ដែងការឃើញការរលត់ទៅជាប្រធាន ទើបពោលថា **បញ្ញាក្នុងការពិចារណាឃើញការប្រែប្រួល** ដូច្នេះ ។ម្យ៉ាងទៀត ការឃើញ ការរលត់ទៅនោះ ក៏មានការឃើញការកើតឡើងជាខាងដើម ព្រោះហេតុនោះ ទើបពោលថា ឈ្មោះថា **ឧទយព្វយានុបស្សនាញាណ** ។

បទថា **ជាតំ** សេចក្ដីថា កើតឡើង គឺមានអត្តភាពដែលបានហើយ ។ ឯ **ជាត** ស័ព្ទនេះ លោកពោលសំដៅយកការដល់ព្រមដោយខណៈទាំង ៣ ដូចជាក្នុងពាក្យជាដើមថា **យេ ធម្មា ជាតា ភូតា** ប្រែថា ធម៌ទាំងឡាយណា កើតមានមិនបានពោលសំដៅយកអតីត ដូចក្នុងពាក្យជាដើមថា

**យេ តេ ជាតា ន តេ សន្តិ　　យេ ន ជាតា តត្ថេវ តេ**
**លទ្ធត្តការា នោ ភគ្គា　　តេវ សន្តិ សភាវតោ ។**

ប្រែថា ធម៌ពួកនោះកើតហើយ ធម៌ទាំងនោះមិនកំពុងមាននៅឡើយ ធម៌ពួកណាមិនទាន់កើត ធម៌ទាំងនោះ ក៏នឹងបានអត្តភាពនៅក្នុងទីនោះឯង មិនទាន់បែកធ្លាយទៅឡើយ ធម៌ទាំងនោះឯង នឹងមាននៅដោយសភាវៈ ដូច្នេះ ។

ទាំងមិនបានពោលសំដៅដល់ត្រឹមតែការៈដែលជាការកើត ដូចក្នុងពាក្យជាដើមថា **យន្តំ ជាតំ ភូតំ សន្ខតំ** ប្រែថា **វត្ថុនោះកើតហើយ មានហើយ បច្ច័យតាក់តែងហើយ** ដោយហេតុនោះ ទើបលោកពោលថា **រូបដែលកើតហើយ ជាបច្ចុប្បន្ន** ដែលឈ្មោះថា រូបបច្ចុប្បន្ន បានដល់ រូបដែលកើតឡើង អធិប្បាយថា រូបដែលទាក់ទងដោយខណៈទាំង ៣ ។ ឯរូបបច្ចុប្បន្ននោះ កំណត់កាន់យកបាន លំបាកអំពីខាងដើម ព្រោះហេតុនោះ ព្រះយោគីគប្បីធ្វើការទាញទុកដោយការឃើញច្បាស់ដោយអំណាចសន្តតិបច្ចុប្បន្ន ។ បទថា **តស្ស យោគ រូបស្ស** ប្រែថា នៃរូបនោះ ។ ពាក្យថា **លក្ខណៈដែលកើតឡើងជាឧទយៈ** បានដល់ លក្ខណៈដែលបច្ច័យប្រជុំតាក់តែងដែលតែងស្គាល់ថា ការកើតឡើងជាឧទយៈ គឺការកើតឡើងដោយមិនបានពឹងផ្អែកភាពពិស្តារនៃលក្ខណៈរបស់បច្ច័យ ពាក្យថា **លក្ខណៈដែលប្រែប្រួលទៅជាវយៈ** គឺលក្ខណៈដែលបច្ច័យតាក់តែង ពោល គឺការប្រែប្រួលទៅជាវយៈ គឺការវិនាសទៅ ។ ពាក្យថា **បញ្ញាពិចារណា ឃើញជាញាណ** សេចក្តីថា បញ្ញាដែលសម្លឹងឃើញឧទយៈនិងវយៈឯណា នុ៎ះជាញាណ ។ ក្នុងការពិចារណាកលាបៈជាដើម ព្រះសារីបុត្របានពោលធម៌ទាំងឡាយ ដែលមានជាតិ ជរា និងមរណៈជាទីបំផុត ដោយមាតិកា គឺជាតិជរា និងមរណៈ ដោយពិតសូម្បីយ៉ាងនោះក្នុងទីនេះកាលនិទ្ទេសនៃឧទយព្វយញ្ញាណ ព្រះសារីបុត្រពោលទុកដោយពាក្យជាដើមថា **ជាតិជាបច្ចុប្បន្ន លក្ខណៈដែលកើតឡើងនៃជាតិនោះ ជាឧទយៈ លក្ខណៈដែលប្រែប្រួលទៅជាវយៈ** ដូច្នេះ រមែងដូចជាព្រមទទួលភាពដែលជាតិ ជរា និងមរណៈ ជាធម៌មានជាតិ ជរា និងមរណៈជាធម៌ ដែលសម្រេចហើយ ព្រោះហេតុនោះ ដើម្បីនឹងចៀសវាងនូវបញ្ហានោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើទេសនា មានភពជាទីបំផុតនោះឯង ក្នុងអង្គបដិច្ចសមុប្បាទទាំងឡាយ ។ បទថា **សោ យោគ យោគី** ប្រែថា ព្រះយោគីនោះ ។ ពាក្យថា

**តាមន័យបាលីនេះ** បានដល់ តាមគតិនៃបាលីនេះ គឺដែលលោកបានសម្ដែងទុកដោយពាក្យជាដើមថា **រូបកើតឡើងជាបច្ចុប្បន្ន** ។ ពាក្យថា **កើត** សេចក្ដីថា មិនមែនការប្រសូតិ និងមិនមែនត្រឹមតែការកើតឡើងចំពោះគ្រាដំបូង ដោយពិតនោះ បានដល់ការកើតឡើង ការប្រែប្រួលនៃការកើតឡើង ។ ការប្រែប្រួលនេះ ព្រោះការប្រាសចាកអាការដែលកើតថ្មីឡើង ដូចគ្នានឹងជរា គឺការតាំងចុះនៃអាការដែលកើតថ្មីរបស់សង្ខារទាំងឡាយ ដូច្នោះ ទើបលោកអាចារ្យពោលថា **អាការដែលកើតថ្មីឡើង** ។ ភ្ជាប់ជាមួយពាក្យថា **សមនុបស្សតិ រមែងពិចារណាឃើញ** ។ ឈ្មោះថា **គំនរ** ឬ**ពួក ក្រុមរបស់នាមរូបដែលមិនទាន់កើតនឹងមានក៏ទេ** ព្រោះនាមរូបដែលកើតឡើង ទើបគប្បីមកបាន ព្រោះសភាវៈដែលមិនបានអត្តភាព ក៏ជាសភាវៈដែលមិនមានវត្ថុគ្រប់ប្រការ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា ឈ្មោះថា **ការមកអំពីគំនរ ឬមកអំពីពួកក្រុមនៃនាមរូប ដែលកំពុងកើតសោត ក៏មិនមាន** ដូច្នេះ ។ លោកអាចារ្យកាលសម្ដែងថា ធម៌ទាំងនេះក្នុងអនាគតកាល មិនមានដោយប្រការទាំងពួង យ៉ាងណា សូម្បីក្នុងអតីតកាល ក៏ដូច្នោះ ទើបពោលពាក្យជាដើមថា **សូម្បីនៃនាមរូបដែលកំពុងរលត់** ដូច្នេះ ហើយពោលពាក្យថា **ឧបមាដូចជា** ជាដើម ។ ដើម្បីញ៉ាំងអត្ថនេះ ដែលជាការសង្គ្រោះឲ្យជាក់ច្បាស់ដោយឧបមា ដែលជាចំណែកមួយរបស់សេចក្ដីនោះថា កាលហេតុ-បច្ច័យរបស់រូបធម៌ និងអរូបធម៌ដែលមិនមាននោះឯងមករួមចូលគ្នាក៏មានការកើតឡើង កាលកើតឡើងហើយ ក៏ចូលដល់ការមិនមានដោយប្រការទាំងពួង ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ដោយរួមគ្នាជាគំនរ** អធិប្បាយថា ក្រុមដែលតាំងឡើងដោយជាគំនរ ឈ្មោះថា **គំនរ** ។ ក្រុមដែលជាដុំដោយប្រការឯណានីមួយ ឈ្មោះថា **ពួកក្រុម** ទឹកន្លែងតាំងចុះក្នុងផែនដី តាំងនៅឈ្មោះថា **រណ្ដៅ** ។ បុគ្គលរមែងចូលទៅលេងពិណាដោយវត្ថុនេះ ហេតុនោះ វត្ថុនេះ ឈ្មោះថា **ឧបវីណំ** ប្រែថា ដងពិណា

គឺគ្រឿងលេងពិណ ។

លោកអាចារ្យកាលសម្តែងវិធីនៃឧទយព្វយមនសិការ ដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះ មានបំណងនឹងសម្តែងដោយពិស្តារ ទើបពោលពាក្យថា **បុន យានិ** ជាដើម ។ ក្នុងពាក្យនោះ បទថា **អវិជ្ជាសមុទយា** ប្រែថា ព្រោះការកើតឡើងនៃអវិជ្ជា អធិប្បាយថា ព្រោះការមាននៃអវិជ្ជា ។ ឯការកើតឡើងដែលខុសទៅអំពីការរលត់ជាសភាវៈប្រាប់ដល់ការមានក៏មាន ព្រោះហេតុនោះ សេចក្តីនេះ ខ្ញុំបានពោលទុកហើយ ។ អធិប្បាយថា ព្រោះហេតុនោះ កាលកពនេះមាន ព្រោះអវិជ្ជាដែលសម្រេចមកអំពីភពមុន ការកើតឡើងនៃរូបក៏រមែងមាន ។ បទថា **បច្ចយសមុទយដ្ឋេន** សេចក្តីថា ដោយភាវៈដែលបច្ច័យកើតឡើង អធិប្បាយថា ដោយការមាននៃបច្ច័យ។ គប្បីឃើញថា ធម្មជាតិដែលប្រព្រឹត្តទៅក្នុងអតីតកាល លោកកាន់យកដោយធម៌ទាំង ៣ មានអវិជ្ជាជាដើម សូម្បីធម្មជាតិទាំងឡាយ មានឧបាទានជាដើម ក៏ជាហេតុធ្វើរួមគ្នានៃធម៌ទាំងនោះ លោកក៏កាន់យកផងដូចគ្នា ។

ក្នុងបណ្តាបច្ច័យក្នុងបវត្តិកាលទាំងឡាយ ព្រោះហេតុដែលកពឡិង្ការាហារជាធម៌មានកម្លាំង ទើបលោកកាន់យកកពឡិង្ការាហារនោះឯងថា **ព្រោះការកើតឡើងនៃអាហារ** ។ ក៏កាលកាន់យកកពឡិង្ការាហារនោះហើយ រមែងជាការកាន់យកឧតុនិងចិត្ត ដោយជាបច្ច័យក្នុងបវត្តិកាលស្មើគ្នា ដូចគ្នា ព្រោះហេតុនោះ គប្បីឃើញថា លោកបានធ្វើការឃើញការកើតឡើងដោយបច្ច័យនៃរូប ដែលមានសមុដ្ឋាន ៤ ឲ្យជាក់ច្បាស់ហើយនោះឯង ។ ការកើតឡើងនៃរូបកាយ រមែងមានដោយកម្ម ដែលប្រកបដោយឧបនិស្ស័យ គឺអវិជ្ជា និងតណ្ហានោះឯង ។ កាលសេចក្តីត្រេកអរក្នុងភពដែលមានអវិជ្ជាជាឧបនិស្ស័យមិនមាន ជាតិមិនមានដូចគ្នា ដូច្នេះឯង ។ គប្បីឃើញភាពដែលរូបមានអវិជ្ជា និងតណ្ហា ជាឧបនិស្ស័យ យ៉ាងណា ក៏គប្បីឃើញវេទនា

ជាដើម ដូច្នោះដែរ ឯអាហារជាគ្រឿងទំនុកបម្រុងរូបដែលកើតឡើងមកហើយ ព្រោះលោកមានបំណងយកកពឡិង្ការាហារ និងព្រោះទេសនា មានកាមធាតុជាទីតាំង ។ម្យ៉ាងទៀត លោកកាន់យកអាហារដោយការសម្តែងលំដាប់ខ្ពស់ ។ ដោយពាក្យថា **និព្វត្តិលក្ខណៈ** ជាដើម លោកអាចារ្យពោលការឃើញការកើតឡើងដោយអំណាចកាល ។ ក្នុងសេចក្តីនោះ ព្រះយោគីឃើញការកើតឡើងមុននោះឯង ដោយអំណាចកាលតាំងនៅ ឃើញដោយអំណាចសន្តតិក្នុងទីនេះហើយ ទើបឃើញដោយអំណាចខណៈ ដោយលំដាប់ ។ ពាក្យថា **លក្ខណៈ ៥** បានដល់ លក្ខណៈទាំង ៥ នេះ គឺលក្ខណៈ ពោល គឺការមាននៃបច្ច័យទាំងនេះ គឺអវិជ្ជា តណ្ហា កម្ម អាហារ និងនិព្វត្តិលក្ខណៈ គឺលក្ខណៈដែលកើតឡើងនៃរូប ។ ពិតហើយ ការកើតឡើងនៃរូបរមែងកំណត់បាន ដោយធម្មជាតិ ទាំងនេះ ព្រោះមានទូវបច្ច័យទាំងនោះ ហេតុនោះធម្មជាតិទាំងនោះ ទើបហៅថា **លក្ខណៈ** ។ ចំណែកនិព្វត្តិជាសង្ខតលក្ខណៈនោះឯងដូច្នេះឯង ។

ពាក្យថា **ការរលត់នៃរូបរមែងមាន ព្រោះការរលត់នៃអវិជ្ជា** សេចក្តីថា ការរលត់ដោយមិនកើតឡើងនៃរូបដែលជាអនាគត រមែងមានព្រោះការរលត់ ដោយមិនកើតឡើងនៃអវិជ្ជា ដោយអរហត្តមគ្គញាណ ព្រោះកាលបច្ច័យមិនមាន ក៏ឈ្មោះថា **មិនមាន** ។ ពាក្យថា **ដោយអត្ថ គឺការរលត់នៃបច្ច័យ** សេចក្តីថា ដោយការៈដែលបច្ច័យនៃរូបដែលនឹងកើតឡើងក្នុងអនាគត ពោល គឺអវិជ្ជារលត់ទៅ ។ សូម្បីក្នុងពាក្យនេះថា **ព្រោះការរលត់នៃតណ្ហា ព្រោះការរលត់នៃកម្ម** ក៏មានន័យនេះឯង ។ពាក្យថា **ព្រោះការរលត់នៃអាហារ** គឺព្រោះការមិនមាននៃកពឡិង្ការាហារ ដែលជាបច្ច័យក្នុងបវត្តិកាល ។ ពាក្យថា **ការរលត់នៃរូប** គឺការមិនមាននៃសមុដ្ឋានរូប ។ពាក្យដ៏សេស គប្បីជ្រាបតាមគន្លងនៃពាក្យមានន័យដែលពោលហើយខាងដើម ។ពាក្យថា

**វិបរិណាមលក្ខណៈ** គឺលក្ខណៈដែលប្រែប្រួល បានដល់ ការឃើញសេចក្ដីវិនាស នៃធម៌ទាំងនោះ ដោយអំណាចកន្លកាល គឺវេលារលត់ ព្រោះហេតុនោះ ព្រះយោគី ឃើញការ រលត់នោះមុននោះឯង ដោយអំណាចកាល ហើយតាំងទៅ ឃើញដោយ អំណាចសន្តតិក្នុងទីនេះ ហើយឃើញដោយអំណាចខណៈតាមលំដាប់ ។ ពាក្យថា **លក្ខណៈ ៥** បានដល់ លក្ខណៈទាំង ៥ នេះ គឺការរលត់ដោយមិនកើតឡើងនៃបច្ច័យ ទាំង ៤ មានអវិជ្ជាជាដើមក្នុងទីនេះ និងការរលត់ដោយខណៈនៃរូប ។ ពិតហើយ ការរលត់យ៉ាងពិតប្រាកដនៃរូបរមែងកំណត់បានដោយធម្មជាតិទាំងនេះ ព្រោះការរលត់ ដោយមិនកើតឡើងនៃបច្ច័យទាំងនោះ ហេតុនោះ ទើបធម្មជាតិនេះ លោកហៅថា **លក្ខណៈ** ។

**វិបរិណាម** ក៏គឺសង្ខតលក្ខណៈនោះឯង ។ ក្នុងវេទនាខន្ធជាដើម ក៏មានន័យ នេះឯង ។ ចំណែកការផ្សេងគ្នា មានដូច្នេះថា ផស្សៈ ជាបច្ច័យក្នុងបវត្តិកាលដល់ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ដោយមានព្រះបាលីថា **ផុដ្ឋោ វេទេតិ ផុដ្ឋោ សញ្ជានាតិ ផុដ្ឋោ ចេតេតិ** បុគ្គលដែលផស្សៈប៉ះខ្ទប់ហើយ រមែងសោយអារម្មណ៍ ដែលផស្សៈប៉ះខ្ទប់ហើយ រមែងចាំបាន ដែលផស្សៈប៉ះខ្ទប់ហើយ រមែងគិត និងដោយ ព្រះបាលីថា **ផស្សប្បច្ចយា វេទនា ចក្ខុសម្ផស្សជាវេទនា សញ្ញា ចេតនា** ព្រោះ ផស្សៈជាបច្ច័យ ទើបមានវេទនា គឺវេទនាកើតអំពីចក្ខុសម្ផស្ស សញ្ញា ចេតនា ដូច្នេះ ហើយការរលត់នៃវេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធទាំងនោះ ក៏រមែងមានបាន ព្រោះ រលត់ផស្សៈនោះ នាមរូបជាបច្ច័យក្នុងបវត្តិកាលដល់វិញ្ញាណ ដោយមានព្រះបាលី ក្នុង **មហាបទានសូត្រ មហានិទានសូត្រ** និងក្នុង **អញ្ញមញ្ញប្បច្ចយវារៈ គម្ពីរព្រះអភិធម្ម** ថា **នាមរូបបច្ចយាវិញ្ញាណំ** វិញ្ញាណមាន ព្រោះនាមរូបជាបច្ច័យ និងការរលត់វិញ្ញាណ នោះ ក៏ព្រោះរលត់នាមរូបនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា

ដើមថា ការកើតឡើងនៃវេទនា រមែងមានព្រោះការកើតឡើងនៃផស្សៈ ដូច្នេះ ។

ក្នុងអធិការនេះ អាចារ្យពួកខ្លះពោលទុកថា ការឃើញការកើតឡើង និងការរលត់ទៅនៃអរូបក្ខន្ធទាំងឡាយ ក៏ដោយអំណាចអទ្ធា និងសន្តតិនោះឯង មិនមែនដោយអំណាចខណៈ ។ តាមមតិរបស់អាចារ្យពួកខ្លះទាំងនោះ មិនគប្បីមានការឃើញការកើតឡើង និងការសូន្យទៅដោយខណៈ ។ ចំណែកអាចារ្យមួយពួកទៀត ពោលថា ព្រះយោគីរមែងឃើញការមានវេទនា គឺភាវៈដែលបានព្រោះអវិជ្ជាជាដើមជាបច្ច័យដោយទូទៅដល់ធម៌ទាំងឡាយ មិនបានប្រារព្ធដល់ការចែកជាអតីតជាដើម ក្នុងការឃើញការកើតឡើង និងការសូន្យទៅដោយបច្ច័យ មិនឃើញការកើតឡើងនោះឡើយ ។ ម្យ៉ាងទៀត ព្រះយោគីរមែងឃើញការមិនមាននៃវេទនានោះ គឺភាវៈដែលមិនបានក្នុងកាលមិនមានអវិជ្ជាជាដើម មិនឃើញការបែកធ្លាយនោះឡើយ ។ ព្រះយោគីរមែងឃើញការកើតឡើង និងការបែកធ្លាយនៃធម៌ទាំងឡាយដែលកើតឡើងចំពោះមុខ ព្រោះឃើញការកើតឡើង និងការសូន្យទៅដោយខណៈ ពាក្យរបស់អាចារ្យពួកនោះត្រឹមត្រូវហើយ ។ ពិតហើយ កាលព្រះយោគីធ្វើមនសិការដោយការកើតឡើង និងដោយការវិនាសទៅនូវរូបធម៌ និងអរូបធម៌ ដោយអំណាចសន្តតិការកើតឡើង និងការសូន្យទៅដោយខណៈ រមែងប្រាកដ ព្រោះញាណដល់ភាវៈដ៏មុតស្រួច និងស្ទាត់ជំនាញក្នុងកាលដែលភាវនាដល់នូវការមានកម្លាំងដោយលំដាប់ ដូច្នេះ ។ ព្រោះថា ព្រះយោគីនេះធ្វើមនសិការនូវការកើតឡើង និងការសូន្យទៅដោយបច្ច័យមុន អនុលោមធម៌ដែលជាបច្ច័យទាំងឡាយ មានអវិជ្ជាជាដើម ហើយទាញយកខន្ធទាំងឡាយ ដែលមានការកើតឡើង និងការសូន្យទៅ ហើយរមែងធ្វើមនសិការដល់ការកើតឡើង និងការសូន្យទៅសូម្បីដោយខណៈ ដោយមាតិកា គឺការឃើញការកើតឡើង និងការសូន្យទៅដោយបច្ច័យនៃខន្ធទាំងនោះ ។

ញាណរបស់ព្រះយោគីនោះ ជាធម្មជាតិមុតស្រួច ស្ទាត់ជំនាញរមែងប្រព្រឹត្ត ទៅក្នុងកាលណា រូបធម៌ និងអរូបធម៌ ក៏រមែងប្រាកដជាធម្មជាតិកើតឡើង និងបែក ធ្លាយទៅ គ្រប់ៗ ខណៈ ក្នុងកាលនោះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោល ថា **ការកើតឡើងនៃរូប រមែងមានយ៉ាងនេះខ្លះ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ពាក្យ ថា **ការកើតឡើងនៃរូប រមែងមានយ៉ាងនេះខ្លះ** សេចក្តីថា រមែងមានព្រោះការកើត ឡើងនៃអវិជ្ជា តាមន័យដែលពោលហើយយ៉ាងនេះខ្លះ ។ ការមាននៃរូប រមែងមាន ព្រោះការកើតឡើងនៃតណ្ហាខ្លះ ការមាននៃរូប រមែងមាន ព្រោះការកើតឡើងនៃកម្មខ្លះ ការមាននៃរូប រមែងមានព្រោះការកើតឡើងនៃអាហារខ្លះ ។ ពាក្យថា **ការវិនាស នៃរូប រមែងមានយ៉ាងនេះខ្លះ** សេចក្តីថា ព្រះយោគាវចរ **រមែងធ្វើមនសិការយ៉ាងពិស្តារ ដោយបច្ច័យ** ជាដើមថា ការរលត់ គឺការមិនកើតឡើងនៃរូប ព្រោះការរលត់នៃអវិជ្ជាខ្លះ ព្រោះការរលត់នៃតណ្ហាខ្លះ ព្រោះការរលត់នៃអាហារខ្លះ តាមន័យដែលពោលហើយ យ៉ាងនេះនោះឯង ។ ពាក្យថា **រូបរមែងកើតឡើងយ៉ាងនេះខ្លះ** មានពាក្យប្រកប សេចក្តីថា ព្រះយោគីសូម្បីកាលឃើញនិព្វត្តិលក្ខណៈ តាមន័យដែលពោលហើយ យ៉ាងនេះ រមែងធ្វើមនសិការយ៉ាងពិស្តារ ដោយខណៈថា សូម្បីរូបដែលមានកម្មជា សមុដ្ឋាន សូម្បីរូបដែលមានអាហារ ឧតុ និងចិត្តជាសមុដ្ឋាន រមែងកើតឡើង គឺរមែង សម្រេច ។ ព្រះយោគីកាលឃើញវិបរិណាមលក្ខណៈតាមន័យដែលពោលមកហើយ យ៉ាងនេះនោះឯង រមែងធ្វើមនសិការយ៉ាងពិស្តារ ដោយខណៈថា សូម្បីរូបដែលមាន កម្មជាសមុដ្ឋាន សូម្បីរូបដែលមានអាហារ ឧតុ និងចិត្តជាសមុដ្ឋាន **រមែងវិនាសទៅ** គឺរមែងរលត់ទៅ ។

លោកអាចារ្យពោលថា **ធម៌ទាំងនេះ មិនមាន ក៏មានឡើង កាលមានហើយ ក៏ត្រឡប់វិនាសទៅ** ដូច្នេះព្រោះធ្វើអធិប្បាយថាកាលព្រះយោគីធ្វើមនសិការយ៉ាងនេះ

ឧទយព្វយញ្ញាណ មិនទាន់កើតឡើងដរាបណា ការកើតឡើង និងការវិនាសទៅ ក៏មិនប្រាកដខ្លួនដោយល្អដរាបនោះ ។ម្យ៉ាងទៀត លោកអាចារ្យពោលយ៉ាងនេះដោយអំណាចការសម្តែងន័យ ។ សេចក្តីពិត ព្រះយោគីឃើញការកើតឡើង និងការរលត់ទៅនៃធម៌ ដែលជាបច្ចុប្បន្នទាំងឡាយមុនក្រោយ ទើបនាំយកធម៌ទាំងឡាយដែលជាអតីត និងអនាគតទៅកាន់ន័យផង ។ ប្រភេទនៃសច្ចៈ មានទុក្ខជាដើម ប្រភេទនៃបដិច្ចសមុប្បាទ មានបដិច្ចសមុប្បាទ ដែលជាអនុលោមជាដើម ប្រភេទនៃន័យមានឯកត្តន័យជាដើម និងប្រភេទនៃលក្ខណៈ មានអនិច្ចតាជាដើម ឈ្មោះថា **ប្រភេទនៃសច្ចៈ បដិច្ចសមុប្បាទន័យ និងលក្ខណៈ** ។ ឯក្នុងទីនេះ លោកកាន់យកបដិច្ចសមុប្បន្នធម៌ ដោយស័ព្ទថា **បដិច្ចសមុប្បាទ** នោះឯង ព្រោះបដិច្ចសមុប្បន្នធម៌ទាំងនោះ ក៏បានអាស្រ័យ គឺពឹងផ្អែកផលរបស់ខ្លួនកើតឡើង ។

បទថា **យំ** ជាបឋមាវិភត្តិ ចុះក្នុងករណៈ លោកអាចារ្យទាំងឡាយ រមែងពោលអត្ថថា ប៉ុន្តែគួរនឹង **យេន ញាណេន** ប្រែថា ដោយញាណណា ។ ម្យ៉ាងទៀត បទថា **យំ** ជាកិរិយាបរាមាសនៈ ។ សេចក្តីថា ការឃើញនេះ ក្នុងពាក្យថា ព្រះយោគី **ឃើញការកើតឡើងនៃខន្ធទាំងឡាយ ឃើញការរលត់នៃខន្ធទាំងឡាយ** ។ សូម្បីក្នុងបទថា **យំ បទ** នេះ ក៏មានន័យនេះដូចគ្នា ។ ក្នុងអធិការនេះ ព្រះធម្មសេនាបតីសារីបុត្របានធ្វើការផ្សេងគ្នានៃវចនៈជាដើមថា **ការកើតឡើងនៃរូប រមែងមានព្រោះការកើតឡើងនៃអវិជ្ជា** ដូច្នេះ ព្រោះការរលត់ការកើតឡើងនៃខន្ធទាំងឡាយដទៃអំពីការរលត់នៃការកើតឡើងរបស់អវិជ្ជាជាដើម ការផ្សេងគ្នានៃការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយ ដោយលក្ខណៈដែលកើតឡើង និងលក្ខណៈដែលប្រែប្រួលទៅ ព្រោះមានអធិករណៈមិនផ្សេងគ្នា នឹងមានដូច្នោះនោះ ក៏មិនមាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលទុក មិនបានធ្វើការផ្សេងគ្នានៃវចនៈឡើយថា **កាលឃើញ**

លក្ខណៈដែលកើតឡើង និងលក្ខណៈដែលប្រែប្រួលទៅ រមែងឃើញការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយ ដូច្នេះ ។ **ហិ**-ស័ព្ទ ក្នុងពាក្យថា **ឧប្បត្តិក្ខណេយេវ ហិ** មានហេតុជាអត្ថ ។ លោកអាចារ្យរមែងធ្វើអត្ថ ដែលពោលទុកដោយពាក្យជាដើមថា លក្ខណៈដែលកើតឡើង រមែងមានក្នុងឧប្បាទក្ខណៈនោះឯង ហើយលក្ខណៈដែលប្រែប្រួលទៅ ក៏រមែងមានក្នុងភង្គក្ខណៈនោះឯង ព្រោះហេតុណា ព្រោះហេតុនោះ ព្រះយោគីកាលឃើញលក្ខណៈដែលកើតឡើង និងលក្ខណៈដែលប្រែប្រួលទៅទាំងនោះ ទើបឈ្មោះថា **រមែងឃើញការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយដោយខណៈ** ដូច្នេះនោះឯង ឲ្យប្រាកដក្រៃលែងឡើង ។

**ឥតិ**-ស័ព្ទ ក្នុងបទថា **ឥច្ចស្សេវំ** នេះ ក៏មានហេតុជាអត្ថ ។ សេចក្តីថា ពាក្យថា **ព្រោះការកើតឡើងនៃអវិជ្ជា** ជាដើម ជាការឃើញការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយដោយបច្ច័យ ពាក្យថា **លក្ខណៈដែលកើតឡើង** ជាដើម ជាការឃើញការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយ ដោយខណៈ ព្រោះហេតុណា ព្រោះហេតុនោះ ។ បទថា **អស្ស យោគ យោគិនោ** ។ បទថា **ឯវំ** ជាពាក្យប្រារព្ធដល់ប្រការដែលបានពោលហើយ ។ ចំណែកអាចារ្យពួកណា រមែងពោលថា **ឥច្ចស្ស បច្ចយតោ** បទថា **ឥតិ** របស់អាចារ្យទាំងនោះ ជាពាក្យប្រារព្ធដល់ប្រការដែលបានពោលហើយ ។ ពាក្យថា **ព្រោះពិចារណាដឹងបច្ច័យ ដែលឲ្យកើត** សេចក្តីថា ព្រោះពិចារណាដឹងបច្ច័យ មានអវិជ្ជាជាដើម ដែលឲ្យកើតខន្ធទាំងឡាយ ។ ពាក្យថា **ព្រោះពិចារណាដឹងជាតិទុក្ខ** គឺព្រោះពិចារណាដឹង ទុក្ខ ពោល គឺការកើត ។ ឈ្មោះថា **ទុក្ខសច្ច** ជាការដែលប្រាកដ ក៏ដោយការឃើញចំណែកមួយ ដូចជាការឃើញរបស់បុគ្គលដែលឃើញភ្នំ និងសមុទ្រជាដើម ។ សូម្បីក្នុងពាក្យថា **ព្រោះពិចារណាដឹងមរណទុក្ខ** នេះ ក៏មានន័យនេះដូចគ្នា ។ ដោយពាក្យថា **ព្រោះការមិនកើតឡើង**

**នៃបច្ច័យ** នេះ លោកអាចារ្យរមែងសម្ដែងថា ការលត់ដោយមិនកើតឡើងនៃបច្ច័យទាំងឡាយ ជាការរលត់នៃបច្ច័យក្នុងទីនេះ ។ ពាក្យថា **នៃវត្ថុដែលមានបច្ច័យទាំងឡាយ** គឺនៃវត្ថុទាំងឡាយដែលកើតអំពីបច្ច័យ ។ ច្រើនបទថា **យញ្ចស្ស ឧទយព្វយទស្សនំ** ប្រែថា ការឃើញ ការកើតឡើង និងការសូន្យទៅទាំងបច្ច័យ និងខណៈនៃយោគីនោះឯណា ។ ក្នុងការឃើញនោះ ក៏មានអសម្មោហៈ ឬគំនរធម៌ មានវិតក្កជាដើមដែលមានអសម្មោហៈនោះជាប្រធាន ។ ពាក្យថា **នេះជាលោកិយមគ្គ** សេចក្ដីថា នេះជាលោកិយមគ្គ ដោយអនុលោមដល់ការចេញទៅអំពីវដ្ដៈ ។ **ឥតិ** ប្រែថា ព្រោះហេតុនោះ **មគ្គសច្ចក៏ជាការប្រាកដ** ព្រោះពិចារណាដឹងសភាវៈ ។ ដោយហេតុនោះឯងទើបលោកអាចារ្យពោលថា **ព្រោះកម្ចាត់សម្មោហៈក្នុងមគ្គនោះចេញបាន** អធិប្បាយថា កម្ចាត់បានដោយអំណាចតទង្គប្បហាន ។ ម្យ៉ាងទៀត មគ្គ ពោល គឺសម្មាទិដ្ឋិតាមដែលបានពោលហើយ ជាឧបាយនៃអរិយមគ្គ មានអសម្មោហៈជាសភាវៈ រមែងប្រកាសខ្លួនឯង ដូចប្រទីប ព្រោះហេតុនោះ ទើបមគ្គសច្ចជាការប្រាកដ ។ ភាវៈដែលប្រាកដនោះសោត ក៏ដោយការកម្ចាត់ភាពងងឹង គឺមោហៈ ហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះកម្ចាត់សម្មោហៈក្នុងមគ្គនោះចេញបាន** ។

បដិច្ចសមុប្បាទ មានពាក្យថា **អវិជ្ជាបច្ចយា** ជាដើម ឈ្មោះថា **អនុលោមបដិច្ចសមុប្បាទ** ព្រោះអនុលោមដល់ការប្រព្រឹត្តទៅ ដោយពាក្យថា **ដោយការកើតឡើងនៃអវិជ្ជា** ជាដើម លោកពោលសេចក្ដីនេះថា កាលធម៌ទាំងឡាយ មានអវិជ្ជាជាដើមមាន ហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះពិចារណាដឹងថា កាលវត្ថុនេះមាន ទើបវត្ថុនេះមាន** ។ បដិច្ចសមុប្បាទ មានពាក្យថា **អវិជ្ជាយត្វេវ អសេសវិរាគនិរោធា** ជាដើម ឈ្មោះថា **បដិលោមបដិច្ចសមុប្បាទ** ព្រោះបញ្ច្រាសដល់ការប្រព្រឹត្តទៅ ។ ហើយសន្ទតធម៌ទាំងនោះ ក៏ជាបដិច្ចសមុប្បន្នធម៌នោះឯង ព្រោះព្រះ

បាលីជាដើមថា ម្នាលភិក្ខុទាំងឡាយ ជរាមរណៈជារបស់មិនទៀង ត្រូវបច្ច័យតាក់តែង អាស្រ័យគ្នាកើតឡើង ដូច្នេះ ។ ឯបដិច្ចសមុប្បន្នធម៌ជាវត្ថុប្រាកដ ក៏ព្រោះការប្រាកដដោយបច្ចយាការនោះឯង ព្រោះពិចារណាដឹងថា **នេះជាផលនៃវត្ថុនេះ** ។

សេចក្ដីប្រការនេះថា ការរលត់នៃវត្ថុទាំងឡាយ មុនៗ ជាប់តាមការកើតនៃវត្ថុទាំងឡាយ ដែលខ្ពស់ឡើងៗ ទៅ ដូច្នេះ សម្រេចបានដោយការឃើញការកើតឡើងដោយបច្ច័យ រមែងមានបានដោយការយល់ឯកត្តន័យ ។ ព្រោះថា ការសម្រេចនៃវោហារដែលថា **អ្នកដទៃធ្វើ អ្នកដទៃសោយ** ដូច្នេះជាដើម មិនជាឱកាសដល់ឧច្ឆេទទិដ្ឋិ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយការសម្ពន្ធនៃហេតុនិងផល** ដូច្នេះជាដើម ។ សេចក្ដីប្រការនេះថា សង្ខារទាំងឡាយ រមែងកើតឡើងគ្រប់ៗ ខណៈ ដូច្នេះ សម្រេចដោយការឃើញការកើតឡើងដោយខណៈ រមែងមានព្រោះយល់នានត្តន័យ ។ ព្រោះមិនជាឱកាសដល់សស្សតទិដ្ឋិ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **បុគ្គលនោះធ្វើ បុគ្គលនោះសោយ** ព្រោះការពិចារណាដឹងសេចក្ដីផ្សេងគ្នានៃសភាវៈរបស់បច្ចយធម៌ និងបច្ចយុប្បន្នធម៌ទាំងឡាយ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយការឃើញការកើតឡើងដោយខណៈ** ដូច្នេះជាដើម **ដោយការឃើញការកើតឡើង និងការវិនាសទៅ ដោយបច្ច័យអព្យាបារន័យ ក៏ជាការប្រាកដ** ថា ធម៌ទាំងនោះជាហេតុ ដោយត្រឹមតែការមានប៉ុណ្ណោះ ព្រោះការសម្រេចនៃសេចក្ដីប្រការនេះថា កាលបច្ច័យមាន ផលក៏មាន កាលបច្ច័យមិនមាន ផលក៏មិនមាន ដូច្នេះ ។ ព្រោះមិនជាឱកាសដល់ អត្តទិដ្ឋិ ព្រោះមិនគប្បីបានភាវៈដែលធម៌ប្រព្រឹត្តទៅក្នុងអំណាច ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះពិចារណាដឹងធម៌ទាំងឡាយ ជាសភាវៈមិនប្រព្រឹត្តទៅក្នុងអំណាច** ជាដើម ។ **ភាវៈដែលធម៌ ជាសភាវៈមិនប្រព្រឹត្តទៅក្នុងអំណាច** គឺជាធម៌ដែលទាក់ទងដោយធម៌ដទៃ

ឯធម៌ដែលទាក់ទងដោយធម៌ដទៃនោះ គប្បីជ្រាបព្រោះជាធម៌ដែលមានបច្ច័យ ។ **ដោយការឃើញការកើតឡើង ដោយបច្ច័យ** ក៏មិនជាឱកាសដល់អកិរិយទិដ្ឋិនោះឯង ព្រោះផលនៃហេតុសម្រេច ដោយសមគួរដល់ហេតុថា ធម៌ទាំងនេះរមែងកើតឡើងដោយបច្ច័យទាំងឡាយនោះៗ និងកាលកើតឡើង ក៏រមែងកើតឡើងតាមសមគួរដល់បច្ច័យនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មួយទៀតសោត ដោយការឃើញការកើតឡើង ដោយបច្ច័យ** ដូច្នេះជាដើម ។ កាលការណៈមានអកិរិយវាទនឹងមានមកអំពីណា ។ ឯធម្មជាតិឈ្មោះថា **ការណៈ** ព្រោះមានអត្ថថា ធ្វើ ។

កាលព្រះយោគីឃើញការកើតឡើងដោយបច្ច័យ ការៈដែលសន្មតធម៌ទាំងឡាយមិនឃៀងឃាត ព្រោះជាធម៌ដែលជាឧបការៈគ្នា ដោយត្រឹមតែការមានថា កាលមានបច្ច័យ កាលមានសការៈ ទើបផលមានឡើងបាន ដែលព្រះយោគីកំពុងយល់ និងជាធម៌ដែលមានការប្រព្រឹត្តទៅអាស្រ័យបច្ច័យថា កាលមិនមានបច្ច័យ មិនមានសការៈ ផលក៏មិនមាន ដូច្នេះ ដែលព្រះយោគីកំពុងយល់ រមែងញ៉ាំងអត្តសុញ្ញតាឲ្យជាក់ច្បាស់បាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ម្យ៉ាងទៀត ដោយការឃើញការកើតឡើង ដោយបច្ច័យ អនត្តលក្ខណៈក៏ជាការប្រាកដដល់ព្រះយោគីនោះ ព្រោះពិចារណាដឹងធម៌ទាំងឡាយជាសការៈ មានការប្រព្រឹត្តទៅទាក់ទង ដោយបច្ច័យ ដោយមិនឃៀងឃាត ។ អនិច្ចលក្ខណៈរមែងជាការប្រាកដ** ព្រោះយោគីយល់ការដែលកំណត់ទុក ដោយការកើតឡើង និងការសូន្យទៅនៃសង្ខារទាំងឡាយ ដោយការឃើញការកើតឡើង និងការរលត់ទៅដោយខណៈ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះពិចារណាដឹងនូវធម៌ទាំងឡាយ ជាសការៈមាន ហើយក៏មិនមាន** ។ ឯការកើតឡើងហើយ រលត់ទៅ ឈ្មោះថា **មានហើយ ក៏មិនមាន** ។ **ការសោះសូន្យទាំងក្នុងចំណែកមុន និងចំណែកក្រោយ** បានដល់ ការទទេនៃសការៈ

ទាំងអតីត និងអនាគត ។ ដោយពាក្យថា **សង្ខារទាំងឡាយ មានមុន និងក្រោយខណៈទាំង ៣ ក៏មិនមាន** ព្រោះហេតុនោះ ពាក្យថា **ការពិចារណាដឹងការសោះសូន្យទាំងក្នុងចំណែកមុន និងចំណែកក្រោយ** ទើបមានសេចក្ដីថា ព្រោះចាក់ធ្លុះនូវធម៌ទាំងឡាយជាសភាវៈមានខាងដើម និងទីបំផុត ។ ភ្ជាប់សេចក្ដីថា **សូម្បីទុក្ខលក្ខណៈ** ក៏ជាការប្រាកដដោយការឃើញការកើតឡើង និងការសូន្យទៅ ។ សង្ខារទាំងឡាយដែលកើតឡើងហើយ បែកធ្លាយទៅ រមែងត្រូវបំផ្លាញ មិនមានចន្លោះតែម្យ៉ាង ព្រោះក្រោយអំពីកើតឡើង ក៏ដល់នូវចន្លោះការតាំងចុះក្នុងការចាស់ និងការបែកធ្លាយ ។ ការដែលសង្ខារទាំងនោះ ជាសភាវៈត្រូវបំផ្លាញនោះឯង រមែងជាការជាក់ច្បាស់ ដោយការឃើញការកើតឡើង និងការសូន្យទៅដោយប្រពៃ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទាំងទុក្ខលក្ខណៈ ជាការប្រាកដ ព្រោះពិចារណាដឹងការដែលត្រូវបៀតបៀនដោយការកើត និងការវិនាស** ដូច្នេះ ។

ពាក្យថា **សូម្បីភាវលក្ខណៈ** សេចក្ដីថា ដោយការឃើញការកើតឡើង និងការវិនាសទៅ នឹងប្រាកដចំពោះតែអនិច្ចលក្ខណៈ និងទុក្ខលក្ខណៈតែម្យ៉ាងប៉ុណ្ណោះក៏ទេ ដោយពិតនោះ រមែងប្រាកដសូម្បីលក្ខណៈ ពោល គឺសភាវៈដែលចំណាំ មានការពាល់ត្រូវត្រង់សភាពរឹងជាដើមនៃផស្សៈរបស់បឋវីជាដើម ដែលចោះចំពោះទុកដោយភាពជាផល កាត់ផ្ដាច់ដោយសភាវៈ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះពិចារណាដឹងធម៌ ដែលកំណត់ទុកដោយការកើតឡើង និងការសូន្យទៅ** ។ ពាក្យថា **ក្នុងសភាវលក្ខណៈ** គឺក្នុងលក្ខណៈដែលចាំបានថា ជាសភាវៈ បានដល់ ក្នុងការកំណត់ធម៌នោះៗ ពាក្យថា **សូម្បីសង្ខតលក្ខណៈ ជាធម៌ប្រព្រឹត្តទៅមួយជួរខណៈ** សេចក្ដីថា សូម្បីសង្ខតលក្ខណៈ មានការកើតឡើងជាដើម ក៏ប្រព្រឹត្តទៅមួយជួរខណៈ មានឧប្បាទក្ខណៈជាដើម ព្រោះសង្ខតលក្ខណៈនោះ មិនបានតាំង

ចុះក្នុងចន្លោះនៃខណៈ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ក្នុងខណៈដែលកើតឡើង** ។ ឯការប្រើសព្ទត្រឹមតែ **ការកើតឡើង និងការរលត់ទៅ** ក្នុងទីនេះ ព្រោះញាណនេះប្រព្រឹត្តទៅដោយអំណាចឃើញការកើតឡើង និងការសូន្យទៅ មិនមែនព្រោះមិនមានឋិតិក្ខណៈនោះទេ ។

**ម្យ៉ាងទៀត ពិតមែនតែ សង្ខារប្រាកដជារបស់ថ្មីជានិច្ចប៉ុណ្ណោះ ក៏មិនមាន** ដោយពិតនោះ សង្ខារគង់ប្រាកដជារបស់តាំងនៅមួយជួរខណៈ ដោយប្រក្រតី ។ លោកអាចារ្យពោលថា **កាលព្រះអាទិត្យរះឡើង** ដូច្នេះ ដើម្បីនឹងចៀសវាងបញ្ហាថា ដូចម្ដេច ។ ក្នុងបណ្ដាពាក្យទាំងនោះ គំនូសដែលមែកឈើធ្វើទុកក្នុងទឹក ឈ្មោះថា **គំនូសឈើក្នុងទឹក** ។ ឧបមាទាំង ៥ **មានតំណក់ទឹកសន្សើម** ជាដើម លោកអាចារ្យសម្ដែងលម្អិតទុក ដើម្បីសម្ដែងភាវៈជាធម៌ មានការតាំងនៅមួយជួរខណៈ តិចតួចយ៉ាងក្រៃលែងៗ ឡើងទៅ ដោយពិតនោះ សូម្បីយ៉ាងនោះ ឧបមាទាំងនោះ ដែលលោកសម្ដែងខែទុក ក៏គង់រលត់យឺតនោះឯង ព្រោះសង្ខារទាំងឡាយ មានការរលត់រហ័សក្រៃលែងជាងនោះ ។ ពិតហើយ លោកពោលការរលត់នៃរូបធម៌ទាំងឡាយ ដែលរហ័សក្រៃលែងជាងការបង្រួមខ្លួនរបស់ខ្សែទឹក ដែលមុតដូចកាំបិតកោរដែលចងនៅត្រង់ក្បាល និងជើងរបស់ទេវបុត្រទាំងឡាយ ដែលពេញចិត្តក្នុងការទៅ ដែលកំពុងស្ទុះទៅខាងលើ និងខាងក្រោម នឹងពោលទៅថ្វីដល់ការរលត់នៃអរូបធម៌ទាំងឡាយនោះ ។ ម្យ៉ាងទៀត សង្ខារមិនមែនប្រាកដជារបស់ថ្មីជានិច្ចនោះឡើយផង រមែងប្រាកដជារបស់តាំងនៅមួយជួរខណៈ ដោយប្រក្រតីផង ដោយពិតនោះ សង្ខារជារបស់មិនមានសារៈ ។ លោកអាចារ្យពោលពាក្យថា **មាយា** ជាដើម ដើម្បីចៀសវាងពាក្យសួរថា ដូចម្ដេច ។ សេចក្ដីពិត មាយាជាដើមដែលប្រាកដដូចជាកែវមណីជាដើម ឈ្មោះថា **មិនជាសារៈ** ព្រោះមិនមានសភាវៈកើត ដូច្នេះ ។ ក្នុងសេចក្ដីនោះ គល

ជាដើមដែលកើតដោយមន្ត និងឱសថ ឈ្មោះថា **មាយា** ។ ថ្ងៃបណ្ដើរកូន ឈ្មោះថា **មរីចិ** ។ **សុបិនំ** ទុះឯង ជា **សុបិនន្តំ** ប្រែថា ការយល់សប្ដិ ។ ដុំឧសដែលចងខ្វែង ជារង្វង់មូល ឈ្មោះថា **រង្វង់ភ្លើង** ។ ទីក្រុងដែលត្រឹមតែប្រាកដឡើងក្នុងអាកាស ដូចក្រុងដែលមានដោយអំណាចការប៉ង និងការលេងរបស់ពួកគន្ធព្វទេវបុត្រទាំងឡាយ ឈ្មោះថា **ក្រុងគន្ធព្វ** ។

បទថា **ឯត្តាវតា** សេចក្ដីថា ការនាំវិធីដែលផ្ដើមទុកតាមគន្លងន័យនៃព្រះបាលីមានពាក្យថា **រូបដែលកើតហើយ ជាបច្ចុប្បន្ន** ដូច្នេះជាដើម ឬតាមគន្លងនៃព្រះបាលីថា **រូបឯណាមួយដែលជាអតីត អនាគត និងបច្ចុប្បន្ន** ដូច្នេះជាដើម រហូតដល់ការចាក់ចុះការកើតឡើង និងការវិនាសទៅនេះ ដោយការនាំវិធីត្រឹមប៉ុណ្ណោះ ។ ឯការនាំវិធីទាំងអស់ មានកលាបសម្មសនៈជាដើម រមែងមានដល់ការកើតឡើងនៃឧទយព្វយញ្ញាណប៉ុណ្ណោះ មិនមែនជាការចងដៃក្នុងសរីរៈដោយជុំវិញរបស់បរិស័ទប៉ុណ្ណោះឡើយ ។ ពាក្យថា **វត្ថុដែលមានការសូន្យជាធម្មតានោះឯង** គឺវត្ថុដែលមានការបែកធ្លាយទៅជាសភាវៈនោះឯង ។ **រមែងចូលដល់ការវិនាស** ដោយធម្មតារបស់ខ្លួន ។ ឯវត្ថុណាលោកពោលថា **វិនាសទៅ** ដោយការចូលទៅទម្លាយ វត្ថុនោះក៏ឈ្មោះថា **វិនាសទៅដោយធម្មតារបស់ខ្លួន** ព្រោះការវិនាសទៅមិនមានហេតុ ។ ឯហេតុនៃការព្យាយាមមានការកើតឡើងផ្សេងគ្នា ។ ពាក្យថា **ដោយអាការនេះ** សេចក្ដីថា ព្រោះព្រះសាស្ដាត្រាស់ទុកថា **វត្ថុណានីមួយ មានការកើតឡើង ជាធម្មតា វត្ថុទាំងអស់នោះ មានការរលត់ទៅជាធម្មតា** ដូច្នេះ ហេតុនោះ សូម្បីមិនបាននាំយកការវិនាសទៅ ក៏ដោយអាការគឺការធ្វើការកើតឡើងឲ្យប្រចក្សថា **វត្ថុដែលមានការវិនាសទៅជាធម្មតានោះឯង រមែងកើតឡើង** និងធ្វើការវិនាសទៅឲ្យប្រចក្សថា **វត្ថុនេះដែលកើតឡើងហើយ រមែងចូលដល់ការវិនាសទៅ** ដូច្នេះ តាមដែលពោលទុកហើយនេះ ។ ញាណដែលកើតឡើង

ឥឡូវនេះ មិនទាន់ដល់ថ្នាក់ មានកម្លាំង ហេតុនោះ ទើបលោកអាចារ្យពោលថា **តរុណវិបស្សនាញាណ** ។ សម្មសនៈ ដែលប្រព្រឹត្តទៅដោយអំណាចកលាបសម្មសនៈជាដើម មិនបានឈ្មោះថា ជាវិបស្សនា ដោយនិប្បរិយាយបានឡើយ សម្មសនៈដែលប្រព្រឹត្តទៅដោយអំណាចឧទយព្វយានុបស្សនាជាដើមនោះឯងទើបបាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះបានសម្រេចតរុណវិបស្សនាញាណណាសោត ទើបព្រះយោគីបាន ឈ្មោះថា អារទ្ធវិបស្សកៈ អ្នកផ្ដើមឃើញច្បាស់** ។

# វិសុទ្ធិមគ្គ

## វិបស្សនូបក្កិលេស ១០

លំដាប់នោះ ដោយ ( អំណាចនៃ ) តរុណវិបស្សនានេះ វិបស្សនូបក្កិលេស ១០ រមែងកើតឡើងដល់ព្រះយោគីអារទ្ធវិបស្សកៈនោះ ឯវិបស្សនូបក្កិលេសទាំងឡាយ មិនកើតឡើងដល់អរិយសាវក ដែលដល់បដិវេធហើយ និងដល់បុគ្គលដែលបដិបត្តិខុសផ្លូវ ខ្ជិលច្រអូស បោះបង់កម្មដ្ឋានចោលហើយ តែរមែងកើតដល់កុលបុត្រដែលបដិបត្តិប្រពៃ ប្រកបការនាដែលត្រឹមត្រូវ ជាអារទ្ធវិបស្សកៈប៉ុណ្ណោះ ។

សួរថា ឯឧបក្កិលេស ១០ នោះ ដូចម្ដេច ? ឆ្លើយថា **ឧបក្កិលេស ១០ នោះ** គឺ **ឱភាស** ( ពន្លឺ ) **ញាណ បីតិ បស្សទ្ធិ** គឺសេចក្ដីស្ងប់ **សុខ អធិមោក្ខ** គឺការបង្អោនចិត្តជឿ **បគ្គាហ** គឺសេចក្ដីព្យាយាម **ឧបដ្ឋាន** គឺសតិ **ឧបេក្ខា និកន្តិ** គឺការពេញចិត្ត ។ ពិតហើយ ពាក្យនេះ ព្រះធម្មសេនាបតី ក៏បានពោលទុកថា សួរថា ចិត្តដែលកាន់យកខុសដោយធម្មឧទ្ធច្ចៈ ( ការរាយមាយ គឺសម្គាល់ឧបក្កិលេសថាជាធម៌ ) ដូចម្ដេច ? ឆ្លើយថា កាលភិក្ខុធ្វើមនសិការដោយការមិនទៀង ឱភាសកើតឡើង លោកសម្គាល់យកឱភាសថា **ឱភាស ជាធម៌** ការរាយមាយទៅ ព្រោះឱភាសនោះជាឧទ្ធច្ចៈ លោកជាបុគ្គលមានចិត្តប្រកាន់យកខុសដោយឧទ្ធច្ចៈនោះ រមែងមិនដឹងការប្រាកដដោយភាពមិនទៀង តាមសេចក្ដីពិត រមែងមិនដឹងការប្រាកដដោយជាទុក្ខ...ដោយភាពជាអនត្តាតាមសេចក្ដីពិត ន័យដូចគ្នានោះដែរកាលភិក្ខុធ្វើមនសិការដោយភាពមិនទៀង ញាណកើតឡើង... បីតិ... បស្សទ្ធិ... សុខ... អធិមោក្ខ... បគ្គាហៈ... ឧបដ្ឋាន... ឧបេក្ខា... និកន្តិកើតឡើង លោកសម្គាល់យកនិកន្តិថា **និកន្តិជាធម៌** ។ ការរាយមាយទៅ ព្រោះនិកន្តិនោះ ជាឧទ្ធច្ចៈ លោកជាអ្នកមានចិត្តកាន់

យកខុស ដោយឧទ្ទច្ចៈនោះ រមែងមិនដឹងការប្រាកដដោយភាពមិនទៀង តាមសេចក្តីពិត រមែងមិនដឹងការប្រាកដ ដោយជាទុក្ខ... ដោយជាអនត្តាតាមសេចក្តីពិត ។

# អធិប្បាយ វិបស្សនូបក្កិលេស

## ឱភាស

ក្នុងឧបក្កិលេស ១០ នោះ ពាក្យថា ឱភាស បានដល់ វិបស្សនោភាស (ពន្លឺក្នុងវិបស្សនា ឬពន្លឺកើតអំពីវិបស្សនា) កាលឱភាសនោះ កើតឡើងហើយ ព្រះយោគាវចរគិត (ស្មាន) ថា មុនអំពីនេះ ឱភាសបែបនេះ មិនធ្លាប់កើតឡើង ដល់អាត្មាអញឡើយ អាត្មាអញជាអ្នកសម្រេចមគ្គ ជាអ្នកសម្រេចផលហើយ ដោយពិតដូច្នេះ ហើយកាន់យកវត្ថុដទៃដែលមិនមែនមគ្គថា ជាមគ្គ និង (កាន់យក) វត្ថុដែលមិនមែនផល ថាជាផល កាលលោកកាន់យកវត្ថុដែលមិនមែនមគ្គ ថាជាមគ្គ វត្ថុដែលមិនមែនផល ថាជាផល យ៉ាងនេះ វិបស្សនាវីថិក៏អាក់ខានទៅ លោកក៏បោះបង់មូលកម្មដ្ឋានរបស់ខ្លួនចោល អង្គុយសេពឱភាសនោះឯង ។

ឯឱភាសនេះ កើតឡើងដល់ភិក្ខុអង្គខ្លះ ឲ្យភ្លឺត្រឹមទីអង្គុយពត់ភ្នែនប៉ុណ្ណោះ អង្គខ្លះឲ្យភ្លឺខាងក្នុងបន្ទប់ អង្គខ្លះឲ្យភ្លឺរហូតក្រៅបន្ទប់ អង្គខ្លះឲ្យភ្លឺទៅពេញវិហារ អង្គខ្លះឲ្យភ្លឺដល់មួយគាវុត (១០០ សិន)... ដល់កន្លះយោជន៍ ១ យោជន៍... ២ យោជន៍ ៣ យោជន៍ ។បេ។ អង្គខ្លះ (ឱភាសកើត) ធ្វើឲ្យមានពន្លឺពេញផែនដី រហូតដល់ព្រហ្មលោកជាន់អកនិដ្ឋៈ តែឱភាសបានកើតឡើងដល់ព្រះមានព្រះភាគ ឲ្យភ្លឺទៅរហូតមួយម៉ឺនលោកធាតុ ។ ឯរឿងតទៅនេះ ជារឿងនៃការមានប្រមាណផ្សេងគ្នានៃឱភាសនោះ ដូច្នេះ

បានឮថា ព្រះថេរៈ ២ អង្គ គង់ (ធ្វើសេចក្តីព្យាយាម) នៅក្នុងកុដិ ២ ជាន់

ត្រង់ចិត្តលបពិត ឯថ្ងៃនោះ ជាថ្ងៃឧបោសថកាឡបក្ខ ទិសទាំងឡាយត្រូវបិទដោយពិតានពពក ការងងឹតប្រកបដោយអង្គ ៤ ប្រព្រឹត្តទៅក្នុងពេលរាត្រី ព្រះថេរៈមួយអង្គពោលឡើងថា ទានប្រុស ផ្កាបញ្ចពណ៌លើសីហាសនៈ (គ្រែជើងសិង្ហ) ត្រង់លានព្រះចេតិយ ប្រាកដដល់ខ្ញុំ មួយអង្គទៀត ក៏ពោលឡើងថា លោកម្ចាស់ លោកម្ចាស់ប្រាប់ខ្ញុំ មិនទាន់អស្ចារ្យឡើយ តែឥឡូវនេះ ត្រី និងអណ្ដើក ក្នុងទីមួយយោជន៍ក្នុងមហាសមុទ្រប្រាកដដល់ខ្ញុំនេះ ទើបគួរអស្ចារ្យ !

វិបស្សនូបក្កិលេសនេះ រមែងកើតដល់សមថវិបស្សនាលាភីបុគ្គល ( អ្នកបានសមថៈ និងវិបស្សនា ) ដោយច្រើន សមថវិបស្សនាលាភីបុគ្គលនោះ ព្រោះមិនប្រាកដឡើងនៃកិលេសទាំងឡាយ ដែលសមាបត្តិសង្កត់សង្កិនទុក ទើបញុំាងចិត្តឲ្យកើតឡើងថា **អាត្មាអញ ជាព្រះអរហន្ត** ដូចព្រះមហានាគត្ថេរ ដែលនៅនាឧច្ចង្កវាលិក ( វិហារ ) ដូចព្រះមហាទត្តត្ថេរដែលនៅក្នុងហង្កនក ( វិហារ ) និងដូចព្រះចូឡសុមនត្ថេរ ដែលនៅត្រង់ផ្ទះ ជាទីធ្វើសេចក្ដីព្យាយាម ឈ្មោះ និង្កបេណ្ណក ដូច្នោះ ។

នេះជាការពោលរឿង ១ ក្នុងសេចក្ដីប្រកាន់ខុនរបស់វិបស្សនាលាភីបុគ្គលនោះ

មានរឿងពោលថា ព្រះទីណាស្រេព មានបដិសម្ភិទាបែកធ្លាយមួយអង្គ ឈ្មោះធម្មទិន្នត្ថេរ នៅត្រង់តលង្គរ ( វិហារ ) ជាអ្នកឲ្យឱវាទដល់ពួកភិក្ខុសង្ឃ ថ្ងៃមួយលោកគង់នៅក្នុងអាសនៈពេលថ្ងៃរបស់លោក ហើយប្រមើលមើលដល់ ( អាចារ្យ ) ថា កិច្ចនៃភាពជាសមណៈរបស់ព្រះមហានាគត្ថេរ ដែលនៅនាឧច្ចង្កវាលិក ជាអាចារ្យរបស់អញដល់នូវទីបំផុតហើយ ឬនៅហ្ន៎ ក៏ឃើញព្រះមហានាគត្ថេរនោះនៅជាបុថុជ្ជននៅឡើយ ហើយជ្រាបដែរថា កាលអាត្មាអញមិនទៅ លោកនឹងធ្វើកាលកិរិយាទាំងដែលជាបុថុជ្ជន មែនពិត ទើបហោះឡើង កាន់វេហាស៍ដោយឫទ្ធិ ( អណ្ដែតត្រសែតទៅ ) ចុះក្នុងទីជិតព្រះថេរៈ ដែលអង្គុយនៅនាអាសនៈពេលថ្ងៃ ។ ថ្វាយបង្គំហើយ

សម្តែងអាចរិយវត្តហើយ គង់នៅចំណែកម្ខាង ត្រូវព្រះថេរៈសួរថា អាវុសោ ធម្មទិន្ន ហេតុអ្វី ទើបមកខុសកាលវេលា ក៏ពិតថា មកដើម្បីសាកសួរបញ្ហា តអំពីនោះ កាល ព្រះថេរៈ អនុញ្ញាតថា សួរចុះអាវុសោ ខ្ញុំនឹងពោលដោះស្រាយឲ្យ ទើបសួរបញ្ហា ( រហូតដល់ ) មួយពាន់ប្រការ ព្រះថេរៈក៏ពោល ( ដោះស្រាយ ) បញ្ហាដែលសួរ បានមិនទើសទាក់ឡើយ ពេលនោះ ( ព្រះធម្មទិន្ន ) កាលសរសើរថា ញាណរបស់ លោកម្ចាស់មុតស្រួចក្រៃលែង ធម៌នេះ លោកម្ចាស់បានសម្រេចពីថ្ងៃណា ព្រះថេរៈ ក៏ប្រាប់ថា កាលពី ៦០ ឆ្នាំមុននេះ ទើបសូមឲ្យលោកប្រើ ( អភិញ្ញា ) សមាធិ ( ឲ្យមើល ) លោកក៏ពោលថា ការប្រើសមាធិនេះ មិនជាការៈ ( អ្វីឡើយ ) ទើប ពោលថា បើដូច្នោះ សូមឲ្យលោកម្ចាស់ធ្វើដំរីឡើងមួយក្បាល លោកក៏និម្មិតដំរី សព្វសេត ( ដំរីសសព្វសព៌ាង្គ ) ឡើង ទើបពោលថា ឥឡូវ សូមឲ្យលោកម្ចាស់ ធ្វើវាឲ្យជាដំរីដែលមានស្លឹកត្រចៀកទៅក្រោយ កន្ទុយចង្អុលទៅក្រោយ មូរប្រមោយ ទុកក្នុងមាត់ ធ្វើសំឡេងកោញ្ចនាទដ៏គួរខ្លាច ( ស្ទុះ ) មកចំពោះមុខ លោកម្ចាស់ ព្រះថេរៈក៏ធ្វើដូច ( ដែលសុំឲ្យធ្វើ ) នោះ ហើយឃើញអាការដ៏គួរខ្លាចរបស់ដំរីដែល ( ស្ទុះ ) មកដោយរហ័ស ក៏ ( កើតការខ្លាច ) សម្តែងអាកប្បកិរិយានឹងក្រោកគេច ព្រះថេរៈខីណាស្រព ទើបលាតដៃទាញជាយចីវរលោកទុក ហើយពិតថា លោក ( អាចារ្យ ) ដែលឈ្មោះថា ការខ្លាចរបស់ព្រះខីណាស្រពមិនមាន ទើបលោកដឹង ភាពដែលខ្លួននៅជាបុថុជ្ជនក្នុងកាលនោះ ហើយពោលថា អាវុសោ ធម្មទិន្ន សូម អ្នកជាទីពឹងរបស់ខ្ញុំផងចុះ ហើយលុតជង្គង់ទៀបបាទជើង ទើបព្រះខីណាស្រពពោល ថា លោក ( អាចារ្យ ) ខ្ញុំមក ក៏ដោយតាំងចិត្តថា នឹងជាទីពឹងពុំនាក់របស់លោកម្ចាស់ នោះឯង លោកម្ចាស់កុំគិតប្តីឡើយ ហើយប្រាប់កម្មដ្ឋាន ។ ព្រះថេរៈទទួលកម្មដ្ឋាន ហើយ ឡើងកាន់ទីចង្ក្រម ឈានជំហានទី ៣ ក៏បានសម្រេចអគ្គផល គឺព្រះអរហត្ត

បានពួមកថា ព្រះថេរៈ ជាបុគ្គលទោសចរិត ។ ភិក្ខុ ( យោគាវចរ ) ទាំងឡាយជាអ្នក ( តម្កើងខ្លួន ) ប្រភេទនេះ ( ឯង ) រមែងញាប់ញ័រក្នុងឱកាស ។

## ញាណ

ពាក្យថា **ញាណ** បានដល់ វិបស្សនាញាណ ន័យថា **ញាណដែលមុតស្រួចក្រៃលែង** មិនមានកម្លាំងអ្វីរាំងបាន ដូចវជិរាវុធរបស់ព្រះឥន្ទ្រ ដែលលែងចេញទៅហើយ ( មិនមានអ្វីនឹងរាំងបាន ) ដូច្នោះ រមែងកើតដល់ព្រះយោគី ( ដែលបានឧទយព្វយញ្ញាណ ) នោះ ដែលពិចារណារូបធម៌ និងអរូបធម៌ទាំងឡាយ ។

## បីតិ

ពាក្យថា **បីតិ** ក៏បានដល់វិបស្សនាបីតិ ន័យថា ក្នុងសម័យ គឺពេលកើតឧទយព្វយញ្ញាណនោះ បីតិទាំង ៥ យ៉ាង គឺ **ខុទ្ទកាបីតិ ខណិកាបីតិ ឱក្កន្តិកាបីតិ ឧព្វេគ្គាបីតិ ផរណាបីតិ** រមែងកើតដល់ព្រះយោគីនោះពេញសរីរៈ ។

## បស្សទ្ធិ

ពាក្យថា **បស្សទ្ធិ** បានដល់ វិបស្សនាបស្សទ្ធិ ន័យថា ក្នុងសម័យនោះ សេចក្តីក្រវល់ក្រវាយនៃកាយ និងចិត្ត រមែងមិនមានដល់ព្រះយោគីនោះ ដែលអង្គុយក្នុងអាសនៈ នារាត្រីកាល ឬក្នុងទីអាសនៈ នាពេលថ្ងៃក៏ដោយ ការធ្ងន់នៃកាយ និងចិត្ត ក៏មិនមានការរឹង...ការមិនគួរដល់ការងារ... ការអាពាធ... ការប្រែអួសនៃកាយ និងចិត្ត ក៏មិនមានដល់កាយ និងចិត្តរបស់ព្រះយោគីនោះ រមែងស្ងប់រម្ងាប់ ស្រាលទន់គួរដល់ការងារ ស្រស់ថ្លា ត្រង់ ដោយពិតនោះឯង ព្រះយោគីនោះ មានកាយ និងចិត្ត ដែលធម៌ មានបស្សទ្ធិជាដើមទាំងឡាយនេះ អនុគ្រោះហើយ ក្នុងសម័យនោះ រមែងបានសោយការត្រេកអរ ឈ្មោះអមានុសី ( មិនមែនរបស់មនុស្សសាមញ្ញ )

ដែលព្រះមានព្រះភាគទ្រង់សំដៅដល់ត្រាស់ទុកថា

សេចក្តីត្រេកអរ ប្រភេទអមានុសី រមែងមានដល់ភិក្ខុ ដែលចូលទៅកាន់សុញ្ញាគារ មានចិត្តស្ងប់ ឃើញច្បាស់នូវធម៌ដោយប្រពៃ ភិក្ខុពិចារណាឃើញការកើតឡើង និងការសូន្យទៅ នៃខន្ធទាំងឡាយ ផ្លូវណាមួយ ( តាមរូបក្ខន្ធ ឬតាមអរូបក្ខន្ធ ) ក៏ដោយ លោករមែងបានបីតីបាមោជ្ជ បីតិបាមោជ្ជនោះ ជាទឹកអមតៈរបស់លោកអ្នកប្រាជ្ញទាំងឡាយ ។

បស្សទ្ធិ ដែលសម្បយុត្តដោយយុគលធម៌ មានលហុតាជាដើម ដែលញុំាងការត្រេកអរប្រភេទអមានុសីឲ្យសម្រេច រមែងកើតឡើងដល់ព្រះយោគីនោះ ដូចពោលមក ដូច្នេះ ។

## សុខ

ពាក្យថា **សុខ** ក៏បានដល់ វិបស្សនាសុខ គឺចេតសិកសុខ ដែលសម្បយុត្តដោយវិបស្សនាចិត្ត សេចក្តីថា ក្នុងសម័យនោះ សេចក្តីសុខដ៏ប្រណីតក្រៃលែងដែលផ្សាយទៅពេញរាងកាយ រមែងកើតឡើងដល់ព្រះយោគីនោះ ។

## អធិមោក្ខ

ពាក្យថា **អធិមោក្ខ** បានដល់ សទ្ធា ព្រោះថា សទ្ធាដែលសម្បយុត្តជាមួយវិបស្សនានោះឯង ជាសទ្ធាមានកម្លាំង ញុំាងចិត្ត និងចេតសិកជូរផង់យ៉ាងក្រៃលែង រមែងកើតឡើងដល់ព្រះយោគីនោះ ។

## បគ្គាហៈ

ពាក្យថា **បគ្គាហ** បានដល់ វីរិយៈ ព្រោះថា វីរិយៈដែលសម្បយុត្តជាមួយវិបស្សនានោះឯង ជាវីរិយៈដែលបានផ្គងទុកយ៉ាងល្អ មិនធូរពេក មិនតឹងពេក រមែង

កើតឡើងដល់ព្រះយោគីនោះ ។

## ឧបដ្ឋាន

ពាក្យថា **ឧបដ្ឋាន** បានដល់ សតិ ព្រោះថា សតិដែលសម្បយុត្តជាមួយវិបស្សនានោះឯង ដែលចូលទៅតាំងនៅយ៉ាងល្អ តាំងនៅយ៉ាងមាំទាំ ជាគោលមិនញាប់ញ័រ ដូចស្តេចភ្នំ រមែងកើតឡើងដល់ព្រះយោគីនោះ លោកពិចារណាកំណត់ក្នុងចិត្តមើលឋានៈណាៗ ឋានៈនោះៗ ក៏ស្ទុះហូរចូលទៅ ប្រាកដដល់លោកដោយសតិ ដូចលោកដទៃប្រាកដដល់លោកដែលមានទិព្វចក្ខុ ដូច្នោះ ។

## ឧបេក្ខា

ពាក្យថា **ឧបេក្ខា** សំដៅយក វិបស្សនូបេក្ខា និងអាវជ្ជនូបេក្ខា ( ឧបេក្ខាក្នុងអាវជ្ជនចិត្ត ) ព្រោះថា ក្នុងសម័យនោះ ទាំងវិបស្សនូបេក្ខាដែលជាភាពកណ្តាល ( គឺព្រងើយកន្តើយ ) ក្នុងសង្ខារទាំងពួងដ៏មានកម្លាំងក៏កើតឡើង ទាំងអាវជ្ជនូបេក្ខាក្នុងមនោទ្វារ ក៏កើតឡើងដល់ព្រះយោគីនោះ ។ ឯឧបេក្ខានោះ កាលព្រះយោគីនោះអាវជ្ជនាការដល់ឋានៈនោះៗ រមែងនាំទៅយ៉ាងខ្លាំងក្លា ដូចវជិរាវុធរបស់ព្រះឥន្ទ្រដែលលែងទៅហើយ ដូចលំពែងដ៏ក្តៅដែលដោតចុះទៅក្នុងកញ្ចប់ស្លឹកឈើ ដូច្នោះ ។

## និកន្តិ

ពាក្យថា **និកន្តិ** បានដល់ វិបស្សនានិកន្តិ ព្រោះថា ការពេញចិត្តដ៏សុខុមមានអាការស្ងប់ ធ្វើការត្រេកអរក្នុងវិបស្សនាដែលលម្អទៅដោយវិបស្សនូបក្កិលេសទាំងឡាយ មានឱភាសជាដើម ដូចពោលមកនោះ រមែងកើតឡើងដល់ព្រះយោគីនោះ ជាវត្ថុដែលលោកមិនអាចសូម្បីតែនឹងកំណត់បានថា នុ៎ះជាកិលេស ។

ឯកាលឱភាសកើតឡើងយ៉ាងណា សូម្បីកាលឧបក្កិលេសដ៏សេសនោះឯណា

នីមួយកើតឡើងដូច្នេះ ព្រះយោគាវចរក៏គិត ( ស្មាន ) ថា មុនអំពីនេះ ញាណបែប នេះមិនធ្លាប់កើតឡើងដល់អាត្មាអញឡើយ... បីតិ... បស្សទ្ធិ... សុខ... អធិមោក្ខ... បគ្គាហៈ... ឧបដ្ឋាន... ឧបេក្ខា... និកន្តិបែបនេះ មិនធ្លាប់កើតឡើងដល់អាត្មាអញឡើយ អាត្មាអញជាអ្នកសម្រេចមគ្គ ជាអ្នកសម្រេចផលហើយ ហ្ន៎ ដូច្នេះហើយ កាន់យក វត្ថុដែលមិនមែនមគ្គ ថាជាមគ្គ និងវត្ថុដែលមិនមែនផល ថាជាផល កាលបើលោក កាន់យកវត្ថុដែលមិនមែនមគ្គ ថាជាមគ្គ ដែលមិនមែនផល ថាជាផល វិបស្សនា វិថីក៏អាក់ខានទៅ លោកក៏លះបង់មូលកម្មដ្ឋានរបស់ខ្លួនចោល អង្គុយសេពនិកន្តិ នោះឯង ដូច្នេះ ។

## ឧបក្កិលេស ១០ ចែកជា ៣០ ក៏បាន

ឯក្នុងវិបស្សនូបក្កិលេស ១០ នេះ វិបស្សនូបក្កិលេស ៩ មានឱភាសជាដើម លោកហៅថា **ឧបក្កិលេស** ព្រោះជាវត្ថុ ( គឺជាទីតាំងដែលកើត ) នៃឧបក្កិលេស មិនមែនព្រោះជាអកុសល តែនិកន្តិ ជាតួឧបក្កិលេសផង ជាវត្ថុនៃឧបក្កិលេសផង ។ ម្យ៉ាងទៀត ពោលដោយវត្ថុ វិបស្សនូបក្កិលេសទាំងឡាយនោះក៏ជា ១០ តែពោល ដោយ **គាហៈ** ( ការប្រកាន់ ) ជា ៣០ ដូចម្តេច ? ឧបក្កិលេស ៣០ ដោយអំណាច គាហៈដូច្នេះ គឺកាលប្រកាន់ថា **ឱភាសកើតឡើងដល់អាត្មាអញ** ដូច្នេះ ក៏ជាទិដ្ឋិគាហៈ កាលប្រកាន់ថា **ឱភាសគួរពេញចិត្តហ្ន៎កើតឡើង** ដូច្នេះ ក៏ជាមានះគាហៈ កាល ត្រេកត្រអាលក្នុងឱភាស ក៏ជាតណ្ហាគាហៈ ក្នុងឱភាស មានគាហៈ ៣ ដោយអំណាច ទិដ្ឋិ មានះ និងតណ្ហា ដូចពោលមកដូច្នេះ សូម្បីក្នុងឧបក្កិលេសដ៏សេសទាំងឡាយ ក៏យ៉ាងនោះ ។

ព្រះយោគាវចរ ដែលមិនឈ្លាស មិនមានបរិយត្តិ រមែងញាប់ញ័រទៅ រមែង

រាយមាយទៅក្នុងឧបក្កិលេស មានឱភាសជាដើម ដោយអំណាចនៃគាហៈ ៣ នោះ រមែងតាមឃើញឧបក្កិលេស មានឱភាសជាដើមតែម្យ៉ាងថា នុ៎ះជារបស់អញ អញជានុ៎ះ នុ៎ះជាអត្តារបស់អញ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលទុកថា

ព្រះយោគាវចរ ( ដែលមិនឈ្លាស ) រមែងញាប់ញ័រ ទៅផ្សេងៗ ក្នុងឱភាស... ញាណ... បីតិ... បស្សទ្ធិ... សុខ... អធិមោក្ខ... បគ្គាហៈ... ឧបដ្ឋាន... ឧបេក្ខា និងឧបេក្ខាក្នុងអាវជ្ជនៈ... និកន្តិ ដែលជាគ្រឿងញាប់ញ័រនៃចិត្ត ។

# មហាដីកា

## កថាពណ៌នាពោលដោយវិបស្សនូបក្កិលេស

*ដោយអំណាច **នៃតរុណវិបស្សនានេះ** ពោល គឺឧទយព្វយានុបស្សនា អធិប្បាយថា មិនមែនដោយអំណាចនៃតរុណវិបស្សនា ពោល គឺញាណ មានកង្ខានុបស្សនាជាដើមរបស់កុលបុត្រ ដែលផ្ដើមចម្រើនវិបស្សនាទាំងឡាយ ទាំងមិនមែនដោយអំណាចនៃពលវវិបស្សនា ពោល គឺញាណ មាននិព្វិទានុបស្សនាជាដើម ព្រោះថា វិបស្សនូបក្កិលេសមិនកើតឡើងក្នុងវេលានោះឡើយ ដូច្នេះឯង ។ ឯបទថា **អារទ្ធវិបស្សកស្ស** ឯវ-អក្ខរៈ ក្នុងពាក្យថា **អារទ្ធវិបស្សកស្សេវ** សម្ដែងថា ត្រូវលុបទៅ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះថា វិបស្សនូបក្កិលេស** ដូច្នេះជាដើម ។ ធម៌ទាំងឡាយ ឈ្មោះថា **វិបស្សនូបក្កិលេស** ព្រោះមានអត្ថថា ធ្វើវិបស្សនាឲ្យសៅហ្មង ដោយការៈជាទីតាំងនៃការប្រកាន់ គឺទិដ្ឋិជាដើម ពាក្យថា **ដល់ព្រះអរិយសាវក** នេះ លោកអាចារ្យពោលទុកដោយនិទ្ទេស យ៉ាងឧក្រិដ្ឋ ព្រោះមិនកើតឡើងដល់បុគ្គលដែលសម្រេចពលវវិបស្សនា ។ ពាក្យថា **ដល់បុគ្គលដែលបដិបត្តិខុស** គឺដល់បុគ្គលដែលបដិបត្តិខុស ដោយប្រការណាទីមួយ ដោយអំណាចដែលមានសីលវិបត្តិជាដើម ។ ឯលោកអាចារ្យ កាលនឹងសម្ដែងភាពដែលបុគ្គលអ្នកបដិបត្តិខុសនោះ ជាបុគ្គលគប្បីត្រូវតិះដៀលដោយការបដិបត្តិ ទើបពោលថា **ដល់បុគ្គលដែលបដិបត្តិខុស** ។ ច-ស័ព្ទ បណ្ឌិតគប្បីប្រកបក្នុងបទទាំង ២ ខាងមុខផង ។ ពាក្យថា **បុគ្គលបោះបង់កម្មដ្ឋានចោល** គឺអ្នកផ្ដើម វិបស្សនាហើយ ដល់នូវការឈប់ក្នុងចន្លោះ ។ ពាក្យថា **ជាបុគ្គលខ្ជិលច្រអូស** សេចក្ដីថា ជាអ្នកដល់ព្រមដោយសីលនោះឯង តែមិនប្រកបភាវនា ព្រោះការខ្ជិលច្រអូស ។ម្យ៉ាងទៀត ពាក្យថា **ដល់បុគ្គលដែល***

**បដិបត្តិខុស** បានដល់ បុគ្គលដែលមានការបដិបត្តិដែលបណ្ដិតតិះដៀល ព្រោះមិនមានសម្មាបដិបត្តិ ពោល គឺវិបស្សនាភាវនា ។ សេចក្ដីពិត ការបដិបត្តិវិបស្សនានោះឯង ដែលប្រកបដោយអង្គជាសម្មាបដិបត្តិក្នុងបុព្វភាគ ការបដិបត្តិដទៃក្រៅអំពីនោះ ជាការបដិបត្តិខុស ហើយការបដិបត្តិខុសនោះ រមែងមានដល់បុគ្គលដែលដាក់ធុរៈ ។ ហើយភាពជាបុគ្គលដាក់ចុះនូវធុរៈ ក៏ដោយការខ្ជិលច្រអូស ព្រោះហេតុនោះទើបលោកអាចារ្យពោលថា **បុគ្គលបោះបង់កម្មដ្ឋាន ជាបុគ្គលខ្ជិលច្រអូស** ។ ពាក្យថា **ប្រកបភាវនា ដែលត្រឹមត្រូវ** គឺប្រកបភាវនាដោយយោគៈ គឺដោយញាណ ។ ឯភាពជាបុគ្គល ប្រកបភាវនាដែលត្រឹមត្រូវនោះ រមែងមានដោយអំណាចសមថៈក៏មាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាអារទ្ធវិបស្សកៈ** ។ ( វិបស្សនូបក្កិលេសទាំងឡាយ ) **រមែងកើតឡើងតែម្យ៉ាង** គឺរមែងមិនកើតឡើង ព្រោះមគ្គាមគ្គញាណមិនមានដោយប្រការដទៃ ។

ឧទ្ធច្ចៈ គឺការរាយមាយដែលប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយ មានឱភាសជាដើមថា **ជាធម៌របស់ព្រះអរិយៈ** ឈ្មោះថា **ធម្មុទ្ធច្ចៈក្នុងការកាន់យក** គឺឲ្យប្រព្រឹត្តទៅខុសដោយឈានចេញអំពីវិបស្សនាវិថី ដោយធម្មុទ្ធច្ចៈនោះ ឈ្មោះថា **ចិត្តដែលកាន់យកខុសដោយធម្មុទ្ធច្ចៈ** ។ ព្រះសារីបុត្រពោលដោយឧបចារវោហារដល់ហេតុថា **ឱភាសជាធម៌** អធិប្បាយថា អរិយមគ្គរបស់អាត្មាអញបញ្ចេញឱភាស ដូច្នេះ ។ ព្រះយោគីរមែងដោយកឱភាសថា **និព្វាន** ខ្លះ ថា **មគ្គ** ខ្លះ ថា **ផល** ខ្លះ ។ កាលប្រកាន់ថា **និព្វាន** រមែងកាន់យកធម៌ ដែលប្រព្រឹត្តទៅក្នុងឱភាសនោះ ដោយជាមគ្គ និងផលម្យ៉ាងទៀត រមែងកាន់យកឧបក្កិលេស មានញាណជាដើម ថាជាមគ្គ និងផល ។ ពាក្យថា **ការរាយមាយទៅក្នុងឱភាសនោះ ជាឧទ្ធច្ចៈ** សេចក្ដីថា ការរាយមាយឯណាព្រោះឱភាសជាហេតុនោះ នុ៎ះជាឧទ្ធច្ចៈ ព្រះធម្មសេនាបតីបំណាងនឹងបើកអត្ថ ដែល

លោកពោលទុកដោយសង្ខេបថា **មានចិត្តកាន់យកខុស ដោយឧទ្ធច្ចៈ** ទើបពោលពាក្យជាដើមថា **ដោយការមិនទៀង** ។

ក្នុងពាក្យនោះ ភិក្ខុ ឈ្មោះថា **រមែងមិនដឹងការប្រាកដដោយការមិនទៀង** ព្រោះមិនមានមនសិការ ដោយអំណាចជារបស់មិនទៀងជាដើម ដោយសម្គាល់ថា **អញជាអ្នកសម្រេចមគ្គនោះឯង** ។ ឯសេចក្ដីនេះ បណ្ឌិតគប្បីជ្រាបដោយបទព្រះសូត្រនេះថា

ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយជាភិក្ខុក្ដី ភិក្ខុនីក្ដី រមែងព្យាករការសម្រេចអរហត្តក្នុងសម្នាក់របស់តថាគត ដោយមគ្គ ៤ ដោយប្រការទាំងពួង ឬឯណានីមួយ បណ្ដាមគ្គ ៤ ប្រការនេះ ។ មគ្គ ៤ ដូចម្ដេច ? ម្នាលអាវុសោទាំងឡាយភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនវិបស្សនា មានសមថៈជាខាងមុខ កាលលោកចម្រើនវិបស្សនា មានសមថៈជាខាងមុខ មគ្គរមែងកើត លោករមែងសេព ចម្រើនធ្វើឲ្យច្រើននូវមគ្គនោះ ។បេ។ រមែងលះសំយោជនៈទាំងឡាយបានអនុស័យរមែងអស់ទៅ ។ ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត ភិក្ខុរមែងចម្រើនសមថៈ មានវិបស្សនាជាខាងមុខ ។បេ។ ភិក្ខុរមែងចម្រើនសមថៈ និងវិបស្សនាជាគូគ្នាទៅ ។បេ។

ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត ចិត្តរបស់ភិក្ខុកាន់យកខុសទៅ ដោយធម្មុទ្ធច្ចៈ ម្នាលអាវុសោទាំងឡាយ សម័យនោះ ចិត្តនោះបានស្ងប់ ក្នុងខាងក្នុងជាចិត្តកើតឡើង ១ ដួង តាំងមាំថា មគ្គនោះ កើតឡើងដល់លោក ។បេ។ អនុស័យរមែងអស់ទៅ ដូច្នេះ ។

ក្នុងព្រះបាលីនេះ ធម៌ គឺមគ្គ ផល និព្វាន តាមដែលពោលហើយ ក្នុងការវិសជ្ជនាមគ្គទី ៤ ឈ្មោះថា **ធម្មៈ** ។ **ឧទ្ធច្ចៈ** ក្នុងធម៌នោះ បានដល់ ការរាយមាយក្នុងធម៌ដែលមិនមែនមគ្គជាដើមថា **អាត្មាអញ ជាអ្នកមានមគ្គសម្រេចហើយ** ជាដើម

ឈ្មោះថា **ធម្មុទ្ធច្ចៈ** ចិត្តដែលត្រូវធម្មុទ្ធច្ចៈបៀតបៀន **ជាចិត្តដែលកាន់យកខុស** ។ និកន្តិ បានដល់ តណ្ហា ដែលមានរូបដ៏ល្អិតកំពុងសម្ងំក្នុងធម៌ទាំងឡាយ មានឱកាសជាដើម ។ តណ្ហានោះ កាលប្រាកដដោយអាការត្រេកអរក្រៃលែងក្នុងវិបស្សនា ដែលភិក្ខុមានអធិមានះ ( ការសម្គាល់ថា បានសម្រេចមគ្គផល ) រមែងកាន់យកថា **ជាធម៌** ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីពោលថា **លោកដៅយកនិកន្តិថា និកន្តិជាធម៌** ដូច្នេះ ។

ពាក្យថា **វិបស្សនោភាស** បានដល់ រូបដែលចិញ្ចាចចិញ្ចែង ដែលតាំងឡើងអំពីវិបស្សនាចិត្ត និងដែលធ្លាក់ចុះទៅក្នុងសន្តតិរបស់ខ្លួន មានឧតុជាសមុដ្ឋាន ។ អាចារ្យទាំងឡាយរមែងពោលថា **ក្នុងប្រការនោះ រូបដែលតាំងឡើងអំពីវិបស្សនាចិត្ត** តាំងនៅក្នុងសរីរៈរបស់ព្រះយោគីនោះឯង ជារូបផូរផង់តាំងនៅ អណ្តែតចេញអំពីសរីរៈក្រៅអំពីនេះ ផ្សាយទៅដោយជុំវិញ សមគួរដល់អានុភាពនៃញាណ រូបនោះរមែងប្រាកដដល់ព្រះយោគីនោះឯង ព្រះយោគីរមែងឃើញសូម្បីរូបក្នុងឱកាសដែលរូបនោះពាល់ត្រូវ ហើយកាលឃើញ រមែងឃើញដោយចក្ខុវិញ្ញាណ ឬដោយមនោវិញ្ញាណ ដោយហេតុនោះ ពាក្យនេះ បណ្ឌិតគួរពិចារណាមើល ។ រូបនោះរមែងប្រាកដដូចលោកពោលទុកថា គប្បីដឹងបានដោយមនោវិញ្ញាណប៉ុណ្ណោះ ដូចរូបដែលប្រាកដដល់លោកអ្នកបានទិព្វចក្ខុ ។ ដែលឈ្មោះថា **វិបស្សនាវិថី** បានដល់ វិបស្សនាដែលប្រព្រឹត្តទៅដោយលំដាប់នោះឯង ។ ឈ្មោះថា **ជាការអាក់ខានទៅ** ព្រោះព្រះយោគីបានបោះបង់ទៅ ដោយសម្គាល់ខុសថា **អាត្មាអញ ជាអ្នកសម្រេចមគ្គហើយ** ។ ម្យ៉ាងទៀត វិបស្សនារបស់ព្រះយោគីនោះ រមែងឈ្មោះថា ជាការឃានចេញទៅអំពីវិថី ព្រោះសម្គាល់ខុសនោះឯង ។ លោកអាចារ្យពោលដល់វិបស្សនានោះឯងថា **មូលកម្មដ្ឋាន** ។

ពាក្យថា **របស់ការមានប្រមាណផ្សេងគ្នា** គឺរបស់ការមិនដូចគ្នា ដោយអំណាចឱកាសមានតិច និងច្រើន បទថា **អស្ស យោគ ឱកាសស្ស** ។ ផ្ទះដែលកំណត់ដោយជញ្ជាំង ២ ជាន់ ឈ្មោះថា **ផ្ទះជញ្ជាំង ២ ជាន់** ។ បានឮថា ទាំងល្វែងក្នុង ទាំងល្វែងក្រៅនៃផ្ទះនោះ មានជញ្ជាំង ១ ក្នុងចន្លោះ ២ ល្វែង មានផ្លូវព័ទ្ធជុំវិញក្នុងពេលល្ងាច **ប្រាកដផ្កាបញ្ចពណ៌** ក្រាលទុកលើសីហាសនៈនោះ និងប្រាកដរូបក្នុងទីដែលឱកាសនៃញាណស្គាល់ជំនាញផ្សាយទៅ ដូច **ប្រាកដ** ដល់លោកអ្នកមានទិព្វចក្ខុ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ទានប្រុស ប្រាកដដល់ខ្ញុំ** ដូច្នេះជាដើម ។

លោកអាចារ្យ កាលសម្តែងរឿងរបស់ការមានប្រមាណផ្សេងគ្នា នៃឱកាសយ៉ាងនេះហើយ មានបំណងនឹងសម្តែងរឿងក្នុងការជាប់ស្អិតទុកអស់កាលដ៏យូរ ទើបពោលពាក្យជាដើមថា **ឯវិបស្សនូបក្កិលេសនេះ** ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ឯវិបស្សនូបក្កិលេសនេះ** លោកអាចារ្យពោលសំដៅយកប្រការដែលនឹងពោលដល់ខាងមុខ មិនបានសំដៅយកដល់ទាំងអស់ ។ បទថា **សោ** សេចក្តីថា សមថវិបស្សនាលាភីបុគ្គលនោះ ដែលមានអធិមានះ ។

បទថា **ទិវាសនេ** សេចក្តីថា លើអាសនៈដែលគប្បីអង្គុយក្នុងពេលថ្ងៃ ។ ព្រះធម្មទិន្នត្ថេរពោលថា **ទានប្រុស ខ្ញុំមកដើម្បីនឹងសួរបញ្ហា** ព្រោះលោកបានគិតទុកថា **អាត្មាអញនឹងសួរបញ្ហា** មុន ។

ព្រះធម្មទិន្នត្ថេរបានពោលថា **ខ្ញុំមកដោយតាំងចិត្តថា នឹងជាទីពឹងអាស្រ័យរបស់លោកម្ចាស់នោះឯង** ដូច្នេះ ព្រោះលោកបានគិតថា អញនឹងឲ្យអាចារ្យដឹងថាខ្លួនលោកនៅជាបុថុជ្ជនដោយឧបាយ ហើយនឹងដឹកនាំក្នុងកម្មដ្ឋានក្នុង កាលជាខាងក្រោយ ឯលោកពោលធ្វើឲ្យជាពាក្យមានអវធារណៈ ព្រោះពាក្យនោះជាប្រធាន ។

ពាក្យថា **ធម៌នេះ** លោកអាចារ្យពោលដោយអំណាចអធ្យាស្រ័យរបស់ព្រះថេរៈថា ធម៌ គឺបដិសម្ភិទានេះ មានមកហើយដោយអរិយមគ្គ ។ ពាក្យថា **សមាធិ** បានដល់ អភិញ្ញាសមាធិ ។ ពាក្យថា **មានស្លឹកត្រចៀកទៅក្រោយ** គឺមានត្រចៀកមិនកម្រើក ។ ពាក្យថា **មានអាកប្បកិរិយានឹងគេច** ព្រោះការខ្លាច ។ ដោយហេតុនោះ ទើបលោក អាចារ្យពោលថា **បានឮថា ព្រះថេរៈជាបុគ្គលទោសចរិត** ។ ព្រោះថា បុគ្គលទោស ចរិត សូម្បីជាបុគ្គលក្លាហានក៏កើតការខ្លាចបានមួយរំពេច ។ ដោយហេតុនោះ ទើប ព្រះថេរៈទីណាស្រពដឹងអធ្យាស្រ័យរបស់លោក បានឲ្យធ្វើការនិម្មិតដំរីជាដើម ដោយ គិតថា **អាត្មាអញនឹងឲ្យលោកអាចារ្យដឹងថា លោកជាបុថុជ្ជន ដោយឧបាយនេះ** ។ ព្រោះភាពជាបុគ្គលទោសចរិត ទើបព្រះថេរៈ ចាក់ធ្លុះបានឆាប់រហ័ស ។ ព្រោះថា បុគ្គលទោសចរិតប្រែប្រួលបានរហ័ស ។

បទថា **តស្ស យោគ ឧទយព្វយញ្ញាណំ មត្ថកំ បាបេន្តស្ស យោគិនោ** ប្រែថា ដល់យោគីនោះ ដែលញុំាងឧទយព្វយញ្ញាណឲ្យដល់ចំណុចកំពូល ។ ក្នុងទីនេះគប្បី ជ្រាបការពិនិត្យ និងការពិចារណា គឺការពិចារណាឃើញការកើតឡើង និងការ វិនាសទៅ ដោយន័យជាដើមថា **រូបកើតឡើងយ៉ាងនេះខ្លះ រូបរលត់ទៅយ៉ាងនេះខ្លះ** ។ វជិរាវុធដែលស្តេចទេវតាលែងទៅជារបស់មិនឥតប្រយោជន៍ នឹងមិនមានអ្វីរាំងបាន យ៉ាងណា សូម្បីញាណនេះក៏ល្អិតក្នុងការឃើញការកើតឡើង និងការរលត់ទៅ ព្រោះ ហេតុនោះ ទើបលោកអាចារ្យពោលថា **ដូចវជិរាវុធរបស់ព្រះឥន្ទ្រដែលលែងចេញទៅ ហើយ ដូច្នោះ** ។ ក្នុងពាក្យនោះ ពាក្យថា **មុត** គឺមិនរិល ។ ពាក្យថា **ខ្លាំង** គឺមាន តេជះ ។ ពាក្យថា **មុតស្រួចក្រៃលែង** គឺញាណដែលជាក់ច្បាស់ក្រៃលែង លើស ដែលនឹងប្រៀបបាន ដោយភាពជាញាណ ដែលមុតស្រួចហើយ រមែងកើតឡើង ។ ពិតហើយ ព្រះយោគីរមែងសម្គាល់ថា **អាត្មាអញ ជាអ្នកសម្រេចមគ្គហើយ** ដោយ

ញាណនេះ ។

ពាក្យថា **វិបស្សនាបីតិ** បានដល់ បីតិដែលសម្បយុត្តដោយវិបស្សនាចិត្ត ។ បីតិទាំងឡាយមានខុទ្ទកាបីតិជាដើមខ្ញុំបានពណ៌នាទុកហើយខាងដើមនោះឯង ។ព្រោះកាលឧទយព្វយានុបស្សនាប្រព្រឹត្តទៅកាន់វិថីហើយ រមែងកើតបីតិ ៥ ប្រការ ដោយលំដាប់ ដូច្នោះ ទើបលោកអាចារ្យពោលថា **បីតិទាំង ៥ យ៉ាងនេះ ។បេ។ រមែងកើតឡើង** ដូច្នេះ ។ ចំណែកផរុណាបីតិតែម្យ៉ាង រមែងមាន ព្រមជាមួយឧទយព្វយ-ញាណដែលដល់ចំណុចកំពូល ។ ឯផរុណាបីតិ រមែងមាន បានដូចគ្នា សូម្បីក្នុងកាលដទៃអំពីខណៈឧបចារៈ និងអប្បនា ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងកើតពេញសរីរៈ** ។ យុគលធម៌ទាំង ៦ មានបស្សទ្ធិជាដើម រមែងមិនប្រាសគ្នានឹងគ្នា ព្រោះហេតុនោះ កាលបស្សទ្ធិកើតឡើង សូម្បីធម៌ក្រៅអំពីនេះក៏កើតឡើងផងដូចគ្នា ព្រោះហេតុនោះ លោកអាចារ្យពោលធម្មជាតិទាំងអស់នោះ ដោយមាតិកាគឺការសម្ដែងកិច្ច ទើបពោលពាក្យជាដើមថា **ការរសាប់រសល់នៃកាយ និងចិត្ត ក៏រមែងមិនមានឡើយ ការធ្ងន់នៃកាយ និងចិត្ត ក៏រមែងមិនមាន** ។ ក្នុងពាក្យនោះដោយស័ព្ទថា **កាយ** គប្បីជ្រាបការកាន់យក សូម្បីរូបកាយ មិនមែនកាន់យកខន្ធ ៣ មានវេទនាជាដើមទេ ។ ព្រោះថា ធម៌ទាំងឡាយ មានកាយបស្សទ្ធិជាដើម ញុំាញីការរសាប់រសល់ជាដើមសូម្បីនៃរូបកាយ ។ **កាយ និងចិត្ត** ឈ្មោះថា **រមែងស្ងប់រម្ងាប់ស្រាលទន់ គួរដល់ការងារផ្សេងផងត្រង់** ព្រោះវិបស្សនាចិត្តុប្បាទប្រព្រឹត្តទៅក្នុងវេលានោះ ដោយអំណាចការទម្លាយបង់នូវសង្កិលេសធម៌ មានឧទ្ធច្ចៈជាដើម មានថីនមិទ្ធៈជាដើម មានទិដ្ឋិមានៈជាដើម មាននីវរណៈដ៏សេសជាដើម មានអស្សទ្ធិយជាដើម មានមាយា និងសាថេយ្យជាដើម ទើបជាហេតុនៃភាពដែលកាយ និងចិត្តទាំងនោះជាធម្មជាតិមិនស្ងប់រម្ងាប់ជាដើម ពាក្យថា **ក្នុងសម័យនោះ** គឺក្នុងសម័យដែល

ឧទយព្វយញ្ញាណកើតឡើងនោះ ។ ការត្រេកអរនេះរបស់មនុស្សទាំងឡាយ ហេតុនោះទើបឈ្មោះថា **មានុសី** បានដល់ ការត្រេកអរក្នុងកាមសុខ ដែលគួរដល់មនុស្ស សូម្បីសេចក្តីត្រេកអរដែលជាទិព្វ ក៏សង្គ្រោះចូលផង ព្រោះមិនប្រព្រឹត្តទៅកន្លងការៈដែលមនុស្សដ៏វិសេសទាំងឡាយ ដូច្នោះ នឹងគប្បីសោយ ម្យ៉ាងទៀត សូម្បីការត្រេកអរដែលជាទិព្វ ក៏សង្គ្រោះចូលដោយភាពជាកាមសុខ ព្រោះដូចជាការត្រេកអររបស់មនុស្ស សេចក្តីត្រេកអរមិនមែនរបស់មនុស្ស ព្រោះឈានកន្លងសេចក្តីត្រេកអររបស់មនុស្សនោះ ហេតុនោះ ទើបឈ្មោះថា **អមានុសី** ប្រែថា មិនមែនរបស់មនុស្ស ។ ពាក្យថា **កាន់សុញ្ញាគារ** បានដល់ កាន់សេនាសនៈដ៏ស្ងាត់កន្លែងណាទីមួយ ឬកាន់វិបស្សនានោះឯង ។ ឯវិបស្សនានោះ រមែងបានការៈដែលនឹងគប្បីពោលបានថា **សុញ្ញាគារ** ព្រោះជាគុណជាតិទទេចាកភាពជារបស់ទៀងជាដើម និងព្រោះភាពជាទីអាស្រ័យជាសុខរបស់ព្រះយោគី ។ ឈ្មោះថា **បុគ្គលមានចិត្តស្ងប់** ព្រោះការប្រាសចាកកិលេស ដែលធ្វើការមិនចូលទៅស្ងប់នៃចិត្ត ។ ឈ្មោះថា **ដល់ភិក្ខុ** ព្រោះការឃើញភ័យក្នុងសង្សារ ។ ឈ្មោះថា **ឃើញច្បាស់** ដោយអំណាចការពិចារណាឃើញការកើតឡើង និងការសូន្យទៅជាដើមនៃរូបធម៌ និងអរូបធម៌ **ដោយប្រពៃ** គឺដោយត្រឹមត្រូវ ។ សេចក្តីត្រេកអរ ឈ្មោះថា **មិនមែនរបស់មនុស្ស** ព្រោះមិនមែនជាវិស័យរបស់មនុស្សទាំងឡាយ ដែលមិនបានប្រារព្ធវិបស្សនា រមែងមានដល់ភិក្ខុកំពុងពិចារណា ។ សេចក្តីត្រេកអរ ដែលតែងស្គាល់ថា បីតិ និងសុខ ក្នុងវិបស្សនា **រមែងមាន** អត្ថដូចពោលមកនេះ ជាការសង្ខេបនៃគាថា ក្នុងអធិការនេះ ។ ចំណែកគាថាទី ២ លោកអាចារ្យពោលសំដៅយកឧទយព្វយញ្ញាណតែម្យ៉ាង ។ ក្នុងគាថាទី ២ នោះ ពីរបទថា **យតោ យតោ យោគ រូបតោ វា អរូបតោ វា** ប្រែថា ផ្លូវរូបក្ខន្ធ ឬផ្លូវអរូបក្ខន្ធណាមួយ ។

ពាក្យថា **វិបស្សនាសុខ** បានដល់ សុខផ្លូវចិត្តដែលសម្បយុត្តដោយវិបស្សនាចិត្ត ។ ព្រោះកាយទាំងអស់ រមែងជាសភាវៈដែលរូបទាំងឡាយប្រណីតក្រៃលែង ដែលតាំងឡើងអំពីសុខផ្លូវចិត្តនោះ សម្ផស្សដោយជុំវិញ និងចម្រើនដោយជុំវិញហើយ ដូច្នោះ ទើបលោកអាចារ្យពោលថា **ដែលផ្សាយទៅពេញរាងកាយ** ។

ពាក្យថា **អធិមោក្ខ** បានដល់ **សទ្ធា** អធិប្បាយថា មិនមែនអធិមោក្ខដែលជាយេវាបនកចេតសិកទេ ។ ឯក្នុងទីនេះ សទ្ធានោះមិនប្រព្រឹត្តទៅដោយអំណាចការជឿកម្ម និងផលនៃកម្ម ឬដោយអំណាចការជឿព្រះរតនត្រ័យឡើយ ដោយពិតនោះជាហេតុផូរផង់ហួសពណ៌នាដល់សម្បយុត្តធម៌ទាំងឡាយ ដោយប្រាសចាកការល្អក់កករ គឺកិលេស ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **សទ្ធាដែលសម្បយុត្តជាមួយវិបស្សនា ។បេ។ រមែងកើតឡើង** ដូច្នេះ ។

វីរិយៈដែលប្រព្រឹត្តទៅស្មើ សម្រេចព្រមហើយ ដោយកម្លាំងការនាំដែលកើតឡើងមុន ឈ្មោះថា **បគ្គាហៈ** ព្រោះផ្គងចាកកោសជ្ជៈ ដែលជាចំណែករបស់សង្កិលេសនៃសម្បយុត្តធម៌ទាំងឡាយ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា ពាក្យថា **បគ្គាហ** បានដល់ **វីរិយៈ** ជាដើម ។

ពាក្យថា **ដែលចូលទៅតាំងនៅយ៉ាងល្អ** គឺដែលចូលទៅតាំងនៅដោយល្អក្នុងអារម្មណ៍ ដោយការកំណត់សភាវៈ ។ ពាក្យថា **តាំងនៅយ៉ាងមាំទាំ** គឺតាំងនៅដោយល្អ ព្រោះជាធម្មជាតិដែលអារម្មណ៍នោះ គប្បីឲ្យញាប់ញ័រមិនបាន ដោយការប្រាសចាកបដិបក្ខ ។ ព្រោះហេតុនោះឯង ទើបដូចគ្នានឹងសសរគោល **មិនញាប់ញ័រ** ។ ឈ្មោះថា **ដូចជាស្តេចភ្នំ** ព្រោះជាការមិនញាប់ញ័រនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យសម្តែងសតិដែលចូលទៅតាំងនៅយ៉ាងល្អនោះឯង ដោយបទទាំង ៣ ។ បទថា **សោ យោគ យោគាវចរោ** ។ ពាក្យថា **ឋានៈណាមួយ** បានដល់ ឋានៈ

ដែលចូលទៅតាំងនៅរបស់ខ្លួន ជារូបខ្ធះ ជាអរូបខ្ធះ ។ បទថា **ឱក្កន្ទិត្វា** ប្រែថា ហួរចូលទៅ ។ បទថា **បក្ខន្ទិត្វា** ជាវេវចនៈរបស់បទថា **ឱក្កន្ទិត្វា** នោះ ។

លោកអាចារ្យពោលថា **ដូចបរលោកប្រាកដដល់ទិព្វចក្ខុ ដូច្នោះ** ។ សំដៅយកពួកសត្វដែលសន្ទតថា បរលោកប្រាកដដល់ទិព្វចក្ខុ គឺដល់យថាកម្មុបគញ្ញាណ ដែលជាគ្រឿងប្រើប្រាស់ ។ លោកកាន់យកវិស័យ គឺវណ្ណាយតនៈ ព្រោះភាពដែលទិព្វចក្ខុ មានលោកដទៃជាវិស័យ ។ សតិ **រមែងប្រាកដ** អធិប្បាយថា រមែងជាក់ច្បាស់ ឬអធិប្បាយថា រមែងចូលទៅតាំងទៅ **ដល់ព្រះយោគីនោះ** ។ សតិហួរចូលទៅកាន់អារម្មណ៍ តាំងនៅដោយចំណែកណា សូម្បីអារម្មណ៍លោកក៏ហៅថា ហួរចូលទៅតាំងទៅដល់យោគីនោះ ដោយចំណែកនោះ ។

**វិបស្សនូបេក្ខា** តាំងនៅដោយភាពជាកណ្តាល ក្នុងការពិចារណាសង្ខារទាំងឡាយ ព្រោះមានអារម្មណ៍ដែលបានពិចារណាហើយ ។ ឯវិបស្សនូបេក្ខានោះ ដោយអត្ថ បានដល់ តត្រមជ្ឈត្តុបេក្ខាដែលប្រព្រឹត្តទៅយ៉ាងនោះឯង ។ចេតនាដែលសម្បយុត្តជាមួយមនោទ្វារាវជ្ជនចិត្ត លោកហៅថា **អាវជ្ជនុបេក្ខា** ព្រោះប្រព្រឹត្តទៅ ដោយអំណាចការព្រងើយក្នុងអាវជ្ជនៈ ។ ឧបេក្ខាដែលជាកណ្តាលក្នុងការពិចារណាឃើញការកើតឡើង និងការសូន្យទៅ ព្រោះការកើតឡើង និងការសូន្យទៅប្រាកដ ដោយល្អក្រៃលែង ឈ្មោះថា **វិបស្សនូបេក្ខា** ក្នុងទីនេះ ។ ឯការកើតឡើង និងការសូន្យទៅទាំងនោះ ជារបស់សង្ខារទាំងពួង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដែលជាកណ្តាល** ( គឺព្រងើយ ) ក្នុងសង្ខារទាំងពួង ។ គប្បីឃើញអាវជ្ជនាការដូចជាវជិរាវុធរបស់ព្រះឥន្រ្ទ និងលំពែងដែលក្តៅ និងអាវជ្ជនុបេក្ខាជាធម្មជាតិខ្ទាំងក្លា ដោយសភាពយ៉ាងនោះនៃញាណ ដែលត្រាច់ទៅតាមឧបេក្ខានោះ ដូចអាវជ្ជនុបេក្ខា ដែលមានសព្វញ្ញុតញ្ញាណជាទីត្រាច់ទៅខាងមុខ ដូច្នោះ ។

ពាក្យថា **វិបស្សនានិកន្តិ** ប្រែថា ការពេញចិត្ត គឺការសម្លឹងនៅក្នុងវិបស្សនា វិបស្សនូបក្កិលេសទាំងឡាយ មានឱភាសជាដើម ជាការសម្តែងអាកប្បកិរិយានៃវិបស្សនា រមែងដូចជាគ្រឿងប្រដាប់របស់វិបស្សនានោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដែលដេរដាស់ទៅដោយវិបស្សនូបក្កិលេស** មានឱភាសជាដើម ។ ពាក្យថា **ការអាល័យ** បានដល់ ការសម្លឹង ។ ពាក្យថា **យ៉ាងសុខុម មានអាការស្ងប់** គឺមានអាការសុខុម និងមានអាការស្ងប់ ឯការដែលពេញចិត្តនោះ ជារឿងសុខុមមានអាការស្ងប់នោះ ក៏ព្រោះការនាប្រព្រឹត្តទៅ មានសភាពដ៏លើស ព្រោះការពេញចិត្តនោះជាកិលេស ជារឿងដែលគប្បីដឹងបានលំបាក ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ជាវត្ថុដែលលោកមិនអាចកំណត់បានថា នុ៎ះជាកិលេស** ។

បទថា **ឯតេសុបិ យោគ យថាទស្សិតេសុ ញាណាទីសុបិ** ប្រែថា បណ្តាវិបស្សនូបក្កិលេស មានញាណជាដើម តាមដែលបានសម្តែងហើយទាំងនេះ ។ ពាក្យថា **កាលវិបស្សនូបក្កិលេសឯណានីមួយកើតឡើង** នេះ លោកអាចារ្យពោលទុកដើម្បីសម្តែងការប្រកាន់ថា **អាត្មាអញជាអ្នកសម្រេចមគ្គហើយ** ជាដើម ក្នុងកាលវិបស្សនូបក្កិលេសឯណានីមួយកើតឡើង មិនមែនពោលព្រោះវិបស្សនូបក្កិលេសឯណាមួយប៉ុណ្ណោះកើតឡើងទេ ។ ព្រោះឧបក្កិលេសទាំងឡាយ នឹងកើតឡើងក្នុងខណៈមួយជាមួយគ្នាមិនមាន ម្យ៉ាងទៀត ការពិចារណាសោត ក៏រមែងមានជាផ្នែកៗទៅ ។ ពាក្យថា **មុនអំពីនេះ និកន្តិបែបនេះ មិនធ្លាប់កើតឡើងដល់អាត្មាអញឡើយ** នេះ លោកពោលទុកដោយអំណាចការសម្តែងសភាវៈនៃធម៌ តែមិនបានពោលដោយអំណាចការប្រព្រឹត្តទៅនៃចិត្តយ៉ាងនោះ របស់ព្រះយោគីក្នុងវេលានោះឡើយ ។ព្រោះថា ព្រះយោគីនោះដឹងនិកន្តិនោះថា ជានិកន្តិក្នុងវេលានោះក៏ទេ កាលបើដូច្នោះ ក៏មិនមានការប្រកាន់ថា **អាត្មាអញជាអ្នកសម្រេចមគ្គ** ដែលមាននិកន្តិនោះជាវិស័យនោះ

ឯង ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រះយោគីនោះគប្បីមានការគិតយ៉ាងនេះថា **ការត្រេកអរក្រៃលែងក្នុងការនាបែបនេះ មិនធ្លាប់កើតឡើងដល់អាត្មាអញឡើយ អាត្មាអញ ជាអ្នកសម្រេចមគ្គ ពិតហើយ** ។

ពាក្យថា **ព្រោះជាវត្ថុនៃឧបក្កិលេស** សេចក្តីថា ទិដ្ឋិ មានះ និងតណ្ហា ជាតួឧបក្កិលេសក្នុងទីនេះ ដោយនិប្បរិយាយ ព្រោះជាវត្ថុ គឺព្រោះជាទីតាំងនៃការកើតឡើងនៃឧបក្កិលេសទាំងនោះ មិនមែនកើតព្រោះសភាវៈ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **មិនមែនព្រោះជាអកុសល** ។ ដូចជាវិបស្សនូបក្កិលេសទាំងឡាយមានឱភាសជាដើម ជាទីតាំងយ៉ាងណា សូម្បីនិកន្តិក៏ជាទីតាំងនៃទិដ្ឋិគាហៈជាដើម ដូច្នេះ ហេតុនោះ ទើបលោកអាចារ្យពោលថា **ជាវត្ថុនៃឧបក្កិលេសផង** ។ ពាក្យថា **ពោលដោយជាវត្ថុតែម្យ៉ាង** គឺពោលដោយភាពជាវត្ថុនៃគាហៈតែម្យ៉ាង មិនបានប្រារព្ធដល់គាហៈ ។ អត្តាដែលពួកអត្តវាទីទាំងឡាយគិតដោយកថា **ទាក់ទងជាមួយអាត្មាអញ និងពុទ្ធិ ( ការដឹង )** ដូច្នេះ ជាម្ចាស់របស់ឱភាស បានកាន់យកដោយភាពជាវិស័យនៃឆដ្ឋីវិភត្តិថា **មម** ដែលប្រែថា របស់អញ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក៏កាលកាន់យកថា ឱភាសរបស់អាត្មាអញកើតហើយ ដូច្នេះ ជាទិដ្ឋិគាហៈ** ។ ព្រះយោគីរមែងដាក់ខ្លួនថា ប្រសើរជាងគេជាដើម ដោយឱភាសនោះ ដោយមាតិកា គឺការកាន់យកឱភាស ជាវត្ថុដែលគួរពេញចិត្ត ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **កាលប្រកាន់ថា ឱភាស គួរពេញចិត្តហ្ន៎ កើតឡើងហើយ** ដូច្នេះ ជា**មានះគាហៈ** ។ ពាក្យថា **កាលត្រេកត្រអាល** គឺកាលពេញចិត្ត បទថា **តេសំ** សេចក្តីថា ដោយអំណាចនៃឧបក្កិលេសដែលមានឈ្មោះថា គាហៈ មានទិដ្ឋិគាហៈជាដើម ។ បទថា **ឱភាសាទីសុ** ប្រែថា និមិត្តឧបក្កិលេស មានឱភាសជាដើម ។ លោកអាចារ្យកាលសម្តែងថា ការញាប់ញ័រក៏បានដល់ការមិនតាំងនៅក្នុងវិបស្សនា តាមដែលបាន

ផ្តើមទុកហើយ ដល់ការរាយមាយ និងការដល់ការរាយមាយនោះ ក៏ជាគាហៈ មាន តណ្ហាគាហៈជាដើម ក្នុងឧបក្កិលេស មានឱភាសជាដើម ទើបពោលថា **យោគាវចរ មិនឈ្លាស រមែងញាប់ញ័រ រាយមាយទៅក្នុងឧបក្កិលេស មានឱភាសជាដើម ។បេ។ រមែងឃើញតាមឧបក្កិលេស មានឱភាសជាដើម** ដូច្នេះ ។

ក្ខាប់សេចក្តីថា ចិត្តរមែងញាប់ញ័រទៅផ្សេងៗ ព្រោះហេតុនៃឱភាស ។ ម្យ៉ាង ទៀត ពាក្យប្រកបថា ចិត្តរមែងញាប់ញ័រទៅផ្សេងៗ ព្រោះឧបក្កិលេសទាំងឡាយ ក្នុងឱភាសដែលជាវិស័យ ។ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា **ចិត្តរមែង ញាប់ញ័រព្រោះឧបក្កិលេសពួកណា** ដូច្នេះ ។ សូម្បីក្នុងពាក្យដ៏សេសក៏មានន័យនេះ ឯង ។ បទថា **ឧបដ្ឋានេ** សេចក្តីថា ព្រោះសតិ ។ បទថា **ឧបេក្ខាយ ច** សេចក្តីថា ព្រោះវិបស្សនូបេក្ខាផង ។

# វិសុទ្ធិមគ្គ

## ឧបក្កិលេស ១០ ចែកជា ៣០ កំចាត (ត)

ចំណែកព្រះយោគាវចរដែលឈ្លាស ជាបណ្ឌិត ទ្រទ្រង់បរិយត្តិ ដល់ព្រមដោយពុទ្ធិ កាលឧបក្កិលេស មានឱភាសជាដើមកើតឡើងហើយ រមែងកំណត់ពិចារណាឃើញឱភាសដោយបញ្ញាយ៉ាងនេះថា ឱភាសនេះកើតឡើងដល់អាត្មាអញហើយហ្ន៎ តែឱភាសនេះមិនទៀង ជារបស់ដែលត្រូវតាក់តែងឡើង អាស្រ័យបច្ច័យកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតា មានការរលត់ទៅជាធម្មតា ដូច្នេះខ្លះ ។ ឬបើមិនដូច្នោះទេ ការពិចារណាឃើញយ៉ាងនេះ រមែងមានដល់លោកថា បើឱភាសគប្បីជាអត្តាសោត នឹងគួរកាន់យកថា ឱភាសជាអត្តាក៏គួរ តែនេះ ឱភាសជាអនត្តាពិត មកប្រកាន់ថា ឱភាសជាអត្តា ព្រោះហេតុនោះ ទើបឱភាសនោះជាអនត្តា ដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ( របស់បុគ្គលណាមួយ ) ជារបស់មិនទៀង ដោយអត្ថថា មានហើយ ក៏មិនមាន ជាទុក្ខ ដោយអត្ថថា ត្រូវការកើត និងការរលត់បៀតបៀន ដូច្នេះខ្លះ ។

ពាក្យពណ៌នាទាំងពួង គប្បីឲ្យពិស្តារដោយន័យដែលពោលហើយក្នុងអរូបសត្តកៈចុះ ។ ម្យ៉ាងទៀត ពាក្យពណ៌នាក្នុងឱភាសយ៉ាងណា សូម្បីក្នុងឧបក្កិលេសដ៏សេស ក៏ដូច្នោះ ។

ព្រះយោគាវចរនោះ កាលពិចារណាឃើញយ៉ាងនោះហើយ ក៏រមែងយល់ឱភាសបានថា នុ៎ះមិនមែនរបស់អញ អញមិនមែនជានុ៎ះ នុ៎ះមិនមែនខ្លួនរបស់អញ

រមែងយល់ញាណ ។បេ។ និកន្តិបានថា នុ៎ះមិនមែនរបស់អញ អញមិនមែនរបស់នុ៎ះ នុ៎ះមិនមែនខ្លួនរបស់អញ កាលយល់បានយ៉ាងនោះ ក៏មិនញាប់ញ័រ មិនកម្រើករំពើក ព្រោះឧបក្កិលេស មានឱភាសជាដើម ហេតុនោះ ទើបព្រះបោរាណាចារ្យទាំងឡាយ ពោលទុកថា

បញ្ញារបស់ព្រះយោគាវចរអង្គណា មុតស្រួច ( គឺដឹង ) ឋានៈ ( ទីតាំងដែលកើតឧបក្កិលេស ) ១០ នេះ ព្រះយោគាវចរនោះ រមែងជាអ្នកឈ្លាសក្នុងធម្មុទ្ធច្ចៈ និងរមែងមិនដល់នូវការរាយមាយឡើយ ។

# សរុបសេចក្ដី

ព្រះយោគាវចរនោះ កាលមិនដល់នូវភាពរាយមាយយ៉ាងនេះ ក៏ក្ការព្រៃស្ទុក គឺឧបក្កិលេស ៣០ ប្រការនោះបានហើយ កំណត់ផ្លូវ និងមិនមែនផ្លូវបានថា ធម៌ទាំងឡាយ មានឱភាសជាដើម មិនមែនផ្លូវ ចំណែកវិបស្សនាញាណដែលផុតអំពីឧបក្កិលេស ប្រព្រឹត្តទៅតាមវិថី ( របស់វិបស្សនា ) ជាផ្លូវ ។

ញាណរបស់ព្រះយោគាវចរនោះ ដែលដឹងផ្លូវ និងមិនមែនផ្លូវថា នេះជាផ្លូវ នេះមិនមែនផ្លូវ តាំងនៅយ៉ាងនេះ គប្បីជ្រាបថា ឈ្មោះថា មគ្គាមគ្គញាណទស្សនៈ-វិសុទ្ធិ ។

ដោយវិសុទ្ធិត្រឹមប៉ុណ្ណេះ ដែលព្រះយោគាវចរនោះ បានធ្វើការកំណត់សច្ចៈបាន ៣ ហើយ កំណត់បានដូចម្ដេច ដំបូង ក្នុងទិដ្ឋិវិសុទ្ធិ ដោយការកំណត់នាមរូប ក៏បានធ្វើការកំណត់ទុក្ខសច្ចក្នុងកង្ខាវិតរណវិសុទ្ធិ ដោយការកំណត់បច្ច័យ ( របស់

នាមរូប ) ក៏ត្រូវបានធ្វើការកំណត់សមុទយសច្ច ក្នុងមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនេះ ដោយការជ្រើសរើសយកតែផ្លូវត្រូវ ក៏ត្រូវបានធ្វើការកំណត់មគ្គសច្ច ការកំណត់សច្ចៈ ៣ ត្រូវព្រះយោគាវចរនោះធ្វើបានដោយញាណ ដែលជាលោកិយនេះឯង ដូចពោលមកដូច្នេះមុន ។

បរិច្ឆេទទី ២០

ឈ្មោះមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា

ក្នុងបករណ៍វិសុទ្ធិមគ្គដែល

ខ្ញុំធ្វើដើម្បីប្រយោជន៍

ដល់បាមោជ្ជនៃ

សាធុជន

ដូច្នេះ

# មហាដីកា

## កថាពណ៌នាពោលដោយការកំណត់ថា ជាផ្លូវ និង មិនមែនផ្លូវ

នឹងវិនិច្ឆ័យពាក្យថា ចំណែកព្រះយោគាវចរដែលឈ្លាស ជាដើមតទៅ ឈ្មោះថា **អ្នកឈ្លាស** ព្រោះប្រកបដោយភាពជាបុគ្គលឈ្លាសក្នុងកម្មដ្ឋាន ។ ឈ្មោះថា **បណ្ឌិត** ព្រោះជាអ្នកមានញាណដែលចាស់ក្លា ។ ឈ្មោះថា **មាំទាំដល់ការសិក្សា** ព្រោះមាំទាំក្នុងព្រះបរិយត្តិ ។ ឈ្មោះថា **ដល់ព្រមដោយពុទ្ធិ ( ការដឹង )** ព្រោះប្រកបដោយការពិចារណាដឹងទោសក្នុងការសៅហ្មង និងគុណក្នុងការជម្រះសេចក្ដីសៅហ្មងនោះឲ្យបរិសុទ្ធ ។ ពាក្យថា **ឱភាសនេះឯង** សេចក្ដីថា លោកអាចារ្យកាលសម្ដែងការកំណត់ភាពជាវត្ថុនៃឧបក្កិលេសថា ឱភាសណា ដែលអាចារ្យបានពោលទុកក្នុងវេលាឲ្យកម្មដ្ឋានថា នឹងកើតឡើងក្នុងសម័យដែលឧទយព្វយញ្ញាណកើតឡើង ឱភាសនោះឯងកើតហើយ ដូច្នេះ ឥឡូវនេះ កាលនឹងសម្ដែងវិធីនាំឱភាសនោះ ចូលទៅកាន់ភាពជាអារម្មណ៍របស់វិបស្សនា ទើបពោលពាក្យជាដើមថា **ឯឱភាសនោះឯង** ដូច្នេះ ។ ក្នុងពាក្យនោះ លោកអាចារ្យបានសម្ដែងការអធិប្បាយអនិច្ចលក្ខណៈតែម្យ៉ាង ក្នុងន័យដំបូង កាលអនិច្ចលក្ខណៈនោះសម្រេចហើយ សូម្បីលក្ខណៈ ២ ក្រៅអំពីនេះក៏បានសម្រេចដូចគ្នា ។ ចំណែកក្នុងន័យទី ២ លោកអាចារ្យមានបំណងសម្ដែងវិធីធ្វើមនសិការទាក់ទងនឹងការកើតចក្រទ្រាក់ ការដក ការសង្កត់សង្កិនគាហៈ មានទិដ្ឋិគាហៈជាដើម ដែលកើតឡើងព្រោះអាស្រ័យឧបក្កិលេស មានឱភាសជាដើម ទើបពោលពាក្យជាដើមថា **បើឱភាសគប្បីជាអត្តាសោត** ដូច្នេះ ។ ពាក្យថា **បើសង្ខារទាំងឡាយគប្បីជាអត្តាសោត** ជាដើម ក្នុងអរូបសត្តកៈ លោកអាចារ្យពោលទុកដោយស្មើគ្នា

ទាក់ទងនឹង ការប្រមូលសង្ខារទាំងឡាយក្នុងទីនេះ លោកពោលការចែកសង្ខារទាំងឡាយ ដោយជាឧបក្កិលេស មានឱភាសជាដើម ។ វិធីធ្វើមនសិការដ៏សេស ក៏មានន័យដូច ដែលបានពោលទុកហើយ ក្នុងអរូបសត្តកៈនោះឯង ព្រោះហេតុនោះ ទើបលោក អាចារ្យពោលថា **ពាក្យពណ៌នាទាំងពួង គប្បីនាំមកពោលឲ្យពិស្តារ ដោយន័យដែល ពោលហើយ ក្នុងអរូបសត្តកៈចុះ** ។

ព្រះយោគី កាលពិចារណាឃើញឱភាសថា **នុ៎ះមិនមែនរបស់អញ** ដូច្នេះ រមែងធ្វើចិត្តឲ្យបរិសុទ្ធអំពីតណ្ហាគាហៈ កាលពិចារណាឃើញថា **អញមិនជានុ៎ះ** ដូច្នេះ រមែងធ្វើចិត្តឲ្យបរិសុទ្ធអំពីមានគាហៈ កាលពិចារណាឃើញថា **នុ៎ះមិនមែន ជាខ្លួន របស់អញ** ដូច្នេះ រមែងធ្វើចិត្តឲ្យបរិសុទ្ធអំពីទិដ្ឋិគាហៈ ។ ដោយហេតុនោះ ទើប លោកអាចារ្យពោលថា **ពិចារណាឃើញឱភាសថា នុ៎ះមិនមែនជារបស់អញ** ដូច្នេះ ជាដើម ។ សូម្បីក្នុងឧបក្កិលេសដទៃ មានញាណជាដើម ក៏មានន័យនេះ ។

**ពាក្យថា ឋានៈ ១០ នេះ** បានដល់ ហេតុនៃឧបក្កិលេស ១០ នេះ គឺមាន ឱភាសជាដើមតាមដែលពោលហើយ ។ ពាក្យថា **បញ្ញានៃព្រះយោគាវចរណាជំនាញ** សេចក្ដីថា បញ្ញានៃព្រះយោគីណាមានការជំនាញ គឺកំណត់ពិចារណា តាំងនៅដោយ អំណាចការកាន់យកថា ជារបស់មិនទៀងជាដើម ក្នុងឧបក្កិលេស មានឱភាសជា ដើម ។ ព្រះយោគីនោះ **រមែងជាបុគ្គលឈ្លាសក្នុងធម្មុទ្ធច្ចៈ** ដោយការដឹងការដល់ ព្រមនៃធម្មុទ្ធច្ចៈ ។

ពាក្យថា **ប្រព្រឹត្តទៅតាមវិថី** គឺដំណើរទៅតាមវិថីនៃវិបស្សនា ដោយអំណាច ការពិចារណាឃើញការកើតឡើង និងការវិនាសទៅ ។

បទថា **ទិដ្ឋិវិសុទ្ធិយំ** សេចក្ដីថា ក្នុងទិដ្ឋិវិសុទ្ធិដែលបានសម្រេចហើយ ម្យ៉ាង ទៀត ដោយការញុំាងទិដ្ឋិឲ្យបរិសុទ្ធ ដោយទិដ្ឋិវិសុទ្ធិញាណ រមែងបានធ្វើការកំណត់

ទុក្ខសច្ច ព្រោះការកំណត់នាមរូបនោះ ទាក់ទងដោយឧទ្ទេសៈ ។ ដែលឈ្មោះថា **បច្ច័យនៃនាមរូប** ប្រព្រឹត្តទៅក្នុងចំណែកនៃសមុទយៈ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងកង្ខាវិតរណវិសុទ្ធិ ដោយការកំណត់បច្ច័យនៃនាមរូប ក៏ត្រូវបានធ្វើការកំណត់សមុទយសច្ច** ដូច្នេះ ។ បើពោលដោយន័យនៃព្រះអភិធម្ម កិលេសទាំងពួង និងកម្ម ជាសមុទយសច្ច ។ បទថា **ឥមិស្សំ** សេចក្ដីប៉ុនគ្នានឹង **ឥមាយំ** ។ ពាក្យថា **ដែលត្រឹមត្រូវ** គឺមិនខុស ។ ពាក្យថា **ផ្លូវ** បានដល់ **ផ្លូវ** ដែលជាឧបាយនៃអរិយមគ្គ ។

ពណ៌នាមគ្គាមគ្គញាណទស្សនវិសុទ្ធិនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ២០ ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## បដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស

ចំណែកវិបស្សនា ដែលដល់កំពូលដោយអំណាចញាណ ៨ និងញាណទី ៩ គឺសច្ចានុលោមិកញ្ញាណនេះឯង ឈ្មោះថា **បដិបទាញាណទស្សនវិសុទ្ធិ** ។

ឯក្នុងពាក្យថា ( នៃញាណ ) ៨ នោះ គប្បីជ្រាប ( ថា បានដល់ ) ញាណ ៨ នេះ គឺ **ឧទយព្វយានុបស្សនាញាណដែលផុតអំពីកិលេស** រាប់ថា ជាវិបស្សនាដែលប្រព្រឹត្តទៅតាមវិថី ភង្គានុបស្សនាញាណ ភយតុបដ្ឋានញ្ញាណ អាទីនវានុបស្សនាញាណ និព្វិទានុបស្សនាញាណ មុញ្ចិតុកម្យតាញាណ បដិសង្ខានុបស្សនាញាណ សង្ខារុបេក្ខាញាណ ពាក្យថា **ញាណទី ៩** គឺសច្ចានុលោមិកញ្ញាណ ជាពាក្យហៅអនុលោមញ្ញាណ ព្រោះហេតុនោះ ព្រះយោគាវចរដែលប្រាថ្នានឹងធ្វើបដិបទាញាណទស្សនវិសុទ្ធិនោះឲ្យដល់ព្រម ទើបគួរធ្វើសេចក្តីព្យាយាម ក្នុងញាណទាំងនោះ ដោយធ្វើឧទយព្វយញ្ញាណដែលផុតអំពីឧបក្កិលេស ឲ្យជាប្រការដើម ។

## បំពេញឧទយព្វយញ្ញាណដដែលទៀត

បើមានពាក្យសួរថា ធ្វើសេចក្តីព្យាយាមក្នុងឧទយព្វយញ្ញាណដដែលមានប្រយោជន៍ដូចម្តេច ? ដូច្នេះសោត គប្បីឆ្លើយថា មានប្រយោជន៍ដែលនឹងបានកំណត់ត្រៃលក្ខណ៍ឲ្យជាក់ច្បាស់ឡើង ព្រោះឧទយព្វយញ្ញាណខាងដើម ជាញាណសៅហ្មងទៅដោយឧបក្កិលេស ១០ មិនអាចកំណត់ត្រៃលក្ខណ៍ ឲ្យច្បាស់តាមសភាវៈពិតបាន លុះផុតអំពីឧបក្កិលេសហើយ ទើបអាច ព្រោះហេតុនោះ ទើបគួរធ្វើសេចក្តីព្យាយាមក្នុងឧទយព្វយញ្ញាណនេះដដែលទៀត ដើម្បីកំណត់ត្រៃលក្ខណ៍ឲ្យច្បាស់ឡើង ។

ឯលក្ខណៈទាំងឡាយ រមែងមិនប្រាកដ ព្រោះមានអ្វីបិទបាំងទុក ព្រោះមិនធ្វើមនសិការដល់អ្វី ? លំដាប់ដំបូង អនិច្ចលក្ខណៈ មិនប្រាកដ ព្រោះត្រូវសន្តតិបិទបាំងទុក ព្រោះមិនធ្វើមនសិការដល់ការកើតឡើង និងការសូន្យទៅ ទុក្ខលក្ខណៈមិនប្រាកដ ព្រោះត្រូវឥរិយាបថបិទបាំងទុក ព្រោះមិនធ្វើមនសិការដល់ការបៀតបៀនរឿយៗ អនត្តលក្ខណៈមិនប្រាកដ ព្រោះឃនៈបិទបាំងទុក ព្រោះមិនធ្វើមនសិការដល់ការបែកអំពីគ្នាបាននៃធាតុផ្សេងៗ លុះត្រាតែសន្តតិត្រូវដកទៅ ព្រោះកំណត់ការកើតឡើង និងការសូន្យទៅបាន ទើបអនិច្ចលក្ខណៈប្រាកដ តាមសភាវៈពិតបាន កាលឥរិយាបថត្រូវដក ព្រោះមនសិការដល់ការត្រូវបៀតបៀនរឿយៗ ទើបទុក្ខលក្ខណៈប្រាកដតាមសភាវៈពិតបាន កាលធ្វើឃនវិនិព្ភោគ ( បំបែក ដុំចេញ ) បាន ព្រោះចែកធាតុផ្សេងៗ ចេញ ទើបអនត្តលក្ខណៈប្រាកដតាមសភាវៈ ពិតបាន ។

## វិភាគត្រៃលក្ខណ៍

ម្យ៉ាងទៀត ក្នុងត្រៃលក្ខណ៍នេះ គប្បីជ្រាបវិភាគដូច្នេះ គឺវត្ថុដែលមិនទៀង លក្ខណៈរបស់ការមិនទៀង វត្ថុដែលជាទុក្ខ លក្ខណៈរបស់ទុក្ខ វត្ថុដែលជាអនត្តា លក្ខណៈរបស់អនត្តា ។

វិភាគនោះ ខន្ធ ៥ ឈ្មោះថា **របស់ដែលមិនទៀង** ព្រោះអ្វី ព្រោះភាវៈ គឺខន្ធមានការកើតឡើង ការសូន្យទៅ និងការប្រែប្រួលទៅ ឬព្រោះខន្ធមានហើយ ក៏ទៅជាមិនមាន ការកើតឡើង ការវិនាសទៅ និងការប្រែប្រួលទៅ ឬការប្រែប្រួលទៅនៃអាការ ពោល គឺការមានហើយទៅជាមិនមាន ជាលក្ខណៈរបស់ការមិនទៀង ។ ម្យ៉ាងទៀត ខន្ធ ៥ នោះឯង ឈ្មោះថា ជាទុក្ខ ព្រោះបាលីថា **យទនិច្ចំ តំ ទុក្ខំ** របស់ណាមិនទៀង របស់នោះរមែងជាទុក្ខ, ព្រោះអ្វី ? ព្រោះត្រូវបៀតបៀនជានិច្ច ។ អាការ គឺការត្រូវបៀតបៀនជានិច្ច ជាលក្ខណៈរបស់ទុក្ខ ។

ម្យ៉ាងទៀត ខន្ធ ៥ នោះឯង ឈ្មោះថា **ជាអនត្តា** ព្រោះបាលីថា **យំ ទុក្ខំ តទនត្តា** របស់ណាជាទុក្ខ របស់នោះជាអនត្តា, ព្រោះអ្វី ? ព្រោះការមិនប្រព្រឹត្តទៅក្នុងអំណាច ( របស់បុគ្គលណា ) ។ អាការ គឺការមិនប្រព្រឹត្តទៅក្នុងអំណាច ( របស់បុគ្គលណា ) ជាលក្ខណៈរបស់អនត្តា ។

ព្រះយោគាវចរអង្គនេះ រមែងកំណត់ចំណាំលក្ខណៈ ៣ និងខន្ធ ៥ ទាំងពួងនោះ តាមសភាវៈពិតបាន ដោយឧទយព្វយានុបស្សនាញាណ ដែលផូរផង់ផុតអំពីឧបក្កិលេសហើយ រាប់ជាវិបស្សនាដែលប្រព្រឹត្តទៅតាមវិថី កាលលោកកំណត់ចំណាំបានយ៉ាងនោះហើយ ពិនិត្យពិចារណារូបធម៌ និងអរូបធម៌ទាំងឡាយថា មិនទៀង ជាទុក្ខ ជាអនត្តា ដដែលហើយដដែលទៀត ញាណនោះ រមែងប្រព្រឹត្តទៅ មុតស្រួច សង្ខារទាំងឡាយក៏ប្រាកដ ( ដោយកើតរលត់ ) រហ័ស កាលញាណប្រព្រឹត្តទៅមុតស្រួច កាលសង្ខារទាំងឡាយប្រាកដរហ័ស ញាណរមែងមិនមានជួប ( គឺមិនប្រកាន់ ) នូវការកើតឡើង ឬការតាំងនៅ ឬការប្រព្រឹត្តទៅ ឬនិមិត្តក៏ដោយ សតិតាំងមាំតែក្នុងការអស់ ការវិនាស ការបែក ការរលត់ប៉ុណ្ណោះ ។

# មហាដីកា

## កថាពណ៌នាបដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស

## កថាពណ៌នាដោយឧទយព្វយញ្ញាណ

## ដែលផុតអំពីឧបក្កិលេស

សង្ខារុបេក្ខាញាណ ឈ្មោះថា **វិបស្សនាដែលដល់កំពូល** ព្រោះដល់លំដាប់កំពូលនៃការត្រាច់ទៅរបស់វិបស្សនា ។ ឯការដល់កំពូលនៃសង្ខារុបេក្ខាញាណនោះ កើតដោយអំណាចញាណទាំងឡាយ មានឧទយព្វយញ្ញាណជាដើម ដែលមានលំដាប់ទី ៨ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ចំណែកវិបស្សនាដែលដល់កំពូលដោយអំណាចនៃញាណ ៨** ។ លោកអាចារ្យពោលអនុលោមញ្ញាណថា **សច្ចានុលោមិកញ្ញាណ** ព្រោះសមគួរដល់ការចាក់ធ្លុះសច្ចៈ ដោយការប្រាសចាកមោហៈដែលបិទបាំងសច្ចៈ ដែលគ្រោតគ្រាត ។ លោកអាចារ្យមានបំណងសម្ដែងញាណទាំងនោះ ដោយសរុប ទើបផ្ដើមពាក្យជាដើមថា **ក្នុងពាក្យថា នៃញាណ ៨** ។ ក្នុងពាក្យនោះ អាចារ្យទាំងឡាយពួកខ្លះពោលថា **លោកអាចារ្យពោលថា ឧទយព្វយានុបស្សនាញាណរាប់ថា ជាវិបស្សនាដែលប្រព្រឹត្តទៅតាមវិធី** ដូច្នេះ ព្រោះធ្វើអធិប្បាយថា ឧទយព្វយានុបស្សនា រមែងប្រព្រឹត្តទៅ ញ៉ាំងអនិច្ចលក្ខណៈនៃសង្ខារទាំងឡាយឲ្យជាក់ច្បាស់ ដោយឃើញការកើតឡើង និងការសូន្យទៅ និងញ៉ាំងលក្ខណៈក្រៅអំពីនេះឲ្យជាក់ច្បាស់ ដោយទំនងនៃការឃើញការកើតឡើង និងការសូន្យទៅនោះ ។ ឧទយព្វយានុបស្សនាញាណនេះ អាចារ្យទាំងឡាយដែលសម្គាល់នូវញាណនោះជាតីរណបរិញ្ញាប៉ុណ្ណោះ ដោយប្រការទាំងពួង ដូចបានពោលទុក ។ សេចក្ដីពិត

ឧទយព្វយញ្ញាណក៏ឈោងចុះខាងក្នុងតីរណបរិញ្ញាប៉ុណ្ណោះ ដោយពិត សូម្បីយ៉ាងនោះ ញាណទាំងឡាយ មានឧទយព្វយញ្ញាណជាដើម ឈ្មោះថា **ញាណ** ដោយអត្ថថា ដឹងការកើតឡើង និងការសូន្យទៅជាដើម និងឈ្មោះថា **ទស្សនៈ** ដោយអត្ថថា ឃើញទោសប្រចក្ស ។ ឧទយព្វយញ្ញាណជាដើមនោះឯង ឈ្មោះថា **ញាណទស្សនវិសុទ្ធិ** ព្រោះបរិសុទ្ធអំពីធម៌ដែលជាបដិបក្ខ ញាណទស្សនវិសុទ្ធិនោះឯង ជាអរិយមគ្គ និងជាបដិបទាព្រោះមានអត្ថថាជាគ្រឿងប្រព្រឹត្តទៅព្រោះហេតុនោះទើបលោកពោលថា **បដិបទាញាណទស្សនវិសុទ្ធិ** ។ លោកពោលសំដៅដល់ឧទយព្វយញ្ញាណនោះដែលកើតឡើងមិនទាន់ស្ទាត់ជំនាញ ។ ព្រោះថា ឧទយព្វយញ្ញាណដែលស្ទាត់ជំនាញជាទីធ្លាក់ចុះ នៃបហានបរិញ្ញា ព្រោះសម្រេចការលះនិច្ចសញ្ញាជាដើម ។ ព្រោះថា ដោយការសម្រេចឧទយព្វយញ្ញាណនោះ រមែងបានសម្រេចមហាវិបស្សនាចំណែកខ្លះនោះឯង ក្នុងបណ្តាមហាវិបស្សនាទាំង ១៨ ។ ព្រោះថា កាលលះធម៌ដែលជាបដិបក្ខបានជាសមុច្ឆេទ ដោយត្រឹមតែពិចារណាអាការសាមញ្ញ វៀរការចាក់ធ្លុះដោយប្រចក្សនូវការកើតឡើង និងការសូន្យទៅ មិនមានឡើយ ។ កាលមិនមានការលះបង់ធម៌ដែលជាបដិបក្ខ ញាណជាដើម ជាធម្មជាតិមិនមានកម្លាំងណាមួយរាំងបាន ដូចវជិរាវុធ ឬញាណជាដើម ជាធម្មជាតិមុតស្រួចជាដើម នឹងមានមកអំពីណា ។ ព្រោះហេតុនោះ ឧទយព្វយញ្ញាណដែលដល់នូវការស្ទាត់ជំនាញ គប្បីឃើញថា ប្រព្រឹត្តទៅក្នុងចំណែកនៃបហានបរិញ្ញាប៉ុណ្ណោះ ។ ការពិចារណាឃើញការរលត់តែម្យ៉ាងនៃសង្ខារទាំងពួង ឈ្មោះថា **ភង្គានុបស្សនា** ញាណដែលពិចារណាឃើញ ការរលត់នៃសង្ខារនោះឯង ឈ្មោះថា **ភង្គានុបស្សនាញាណ** ។ បុគ្គលដែលមានប្រក្រតីឃើញតាមសេចក្តីពិត រមែងខ្លាចអំពីធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះ ឈ្មោះថា **ភ័យ** ប្រែថា ជាដែនខ្លាច បានដល់ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ញាណដែលកាន់យកដោយអាការដែល

គប្បីខ្លាច ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ដែលប្រាកដដោយជាភ័យ ឈ្មោះថា **ភយតូបដ្ឋានញ្ញាណ** ។ ធម្មជាតិណា រមែងប្រាថ្នានឹងផុតទៅ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **មុញ្ចិតុកម្យំ** ប្រែថា ការប្រាថ្នានឹងផុតទៅ បានដល់ ចិត្ត ឬបុគ្គល ភាវៈនៃចិត្ត ឬបុគ្គលដែលប្រាថ្នានឹងរួចផុតនោះ ឈ្មោះថា **មុញ្ចិតុកម្យតាញាណ** គឺជាធម្មជាតិប្រាថ្នានឹងរួចផុតនោះ ឈ្មោះថា **មុញ្ចិតុកម្យតាញាណ** ។ ញាណដែលប្រព្រឹត្តទៅដោយអាការពិចារណាទៀត ឈ្មោះថា **បដិសង្ខានុបស្សនាញាណ** ញាណដែលប្រព្រឹត្តទៅដោយអំណាចការព្រងើយក្នុងសង្ខារទាំងឡាយ ព្រោះមិនមានការសម្ងឹង ឈ្មោះថា **សង្ខារុបេក្ខាញាណ** ។ ពាក្យថា **ព្រោះហេតុនោះ** សេចក្ដីថា ញាណ ៩ យ៉ាង មានឧទយព្វយញ្ញាណជាដើម ដែលផុតចាកឧបក្កិលេស ឈ្មោះថា **បដិបទាញាណទស្សនវិសុទ្ធិ** ហេតុណា ព្រោះហេតុនោះ ។

អាចារ្យអ្នកចោទ ដែលមិនពិចារណាដឹងអត្ថដែលធ្វើឲ្យជាក់ច្បាស់ ដោយពាក្យវិសេសនៈថា **ដែលផុតអំពីឧបក្កិលេស** ដូច្នេះ បានសួរថា **ធ្វើសេចក្ដីព្យាយាមក្នុងឧទយព្វយញ្ញាណដដែល មានប្រយោជន៍អ្វី** ។ ក្នុងពាក្យនោះ បទថា **កិមត្ថិយោ** ប្រែថា មានប្រយោជន៍អ្វី គឺមិនមានប្រយោជន៍ អធិប្បាយថា ប្រៀបដូចចម្អិនបបរដែលឆ្អិនហើយ មិនមានប្រយោជន៍ ព្រោះជាវត្ថុដែលកើតឡើងហើយមុននោះឯង ។ ម្យ៉ាងទៀត លោកអាចារ្យកាលប្រាថ្នានឹងឲ្យយល់សេចក្ដីនោះ ដោយអំណាចការទទួលយកហេតុនៃការកំណត់លក្ខណៈជាដើមនោះឯង ទើបសួរថា **មានប្រយោជន៍អ្វី** ដោយអំណាចត្រូវការនឹងឆ្លើយ ។ ពាក្យថា **មានប្រយោជន៍ ដែលនឹងបានកំណត់លក្ខណៈ** សេចក្ដីថា មានប្រយោជន៍ដែលនឹងបានពិចារណា ដោយត្រឹមត្រូវនូវលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ លោកអាចារ្យកាលនឹងសម្ដែងហេតុក្នុងពាក្យនោះ ទើបពោលពាក្យជាដើមថា **ព្រោះឧទយព្វយញ្ញាណ** ដូច្នេះ ។ បើមានអ្នកសង្ស័យ

សួរថា ឈ្មោះថា **ឧទយព្វយញ្ញាណ** រមែងឃើញការកើតឡើង និងការសូន្យទៅរបស់សង្ខារទាំងឡាយប៉ុណ្ណោះ មិនឃើញលក្ខណៈ ៣ មានអនិច្ចលក្ខណៈជាដើមឡើយ ការកំណត់លក្ខណៈ ៣ មានអនិច្ចលក្ខណៈជាដើម នឹងមានបានដោយឧទយ-ព្វយញ្ញាណនោះបានដូចម្តេច ? ឆ្លើយថា សេចក្តីនេះ មិនគប្បីឃើញយ៉ាងនេះថា **ឧទយព្វយញ្ញាណ មានត្រៃលក្ខណ៍ជាអារម្មណ៍ឡើយ** ។ កាលចាក់ចុះការកើតឡើងនិងការសូន្យទៅហើយ អនិច្ចលក្ខណៈរមែងជាធម្មជាតិជាក់ច្បាស់ប្រាកដ ។ បន្ទាប់អំពីនោះ សូម្បីលក្ខណៈក្រៅអំពីនេះ ក៏ជាធម្មជាតិជាក់ច្បាស់ប្រាកដ ព្រោះវត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ វត្ថុនោះជាអនត្តា ។ មួយវិញទៀត អាការដែលមានហើយ ទៅជាមិនមាន អាការដែលត្រូវបៀតបៀនរឿយៗ និងអាការដែលមិនធ្លាក់នៅក្នុងអំណាច រមែងជាការជាក់ច្បាស់ក្រៃលែង ដោយការចាប់យកការកើតឡើងនិងការសូន្យទៅ ។ ព្រោះហេតុនោះ គប្បីជ្រាបថា ការប្រកបនៅក្នុងឧទយព្វយញ្ញាណមានប្រយោជន៍ដែលនឹងកំណត់លក្ខណៈ ៣ ដោយជាហេតុ មិនគប្បីជ្រាបដោយការដល់ព្រម ។ ពាក្យថា **ក្នុងខាងដើម** គឺក្នុងខាងដើមអំពីមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ។ ព្រោះថា ឧទយព្វយញ្ញាណនោះ ជាធម្មជាតិមុតស្រួច ប្រព្រឹត្តទៅហើយ ព្រោះភាពជាហេតុ កើតឡើងនៃឧបក្កិលេស មានឱភាសជាដើម ក៏ជាធម្មជាតិដែលមិនមុតស្រួចឡើយ ព្រោះសៅហ្មងទៅដោយឧបក្កិលេស មានទិដ្ឋិជាដើម ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ជាញាណសៅហ្មងទៅដោយឧបក្កិលេស ១០ មិនអាចកំណត់លក្ខណៈ ៣ តាមសេចក្តីពិតបាន** ។

បទថា **អមនសិការា** ជាបញ្ចមីវិភត្តិ ចុះក្នុងហេតុ ។ ឯពាក្យថា **ព្រោះមិនបានធ្វើមនសិការដល់អ្វី** នេះ ជាពាក្យសួរដល់ហេតុនៃរឿងដែលបិទបាំង ដែលបានសួរថា ព្រោះអ្វីបិទបាំងទុក ។ ឯអនិច្ចលក្ខណៈមិនប្រាកដ ព្រោះអនិច្ចលក្ខណៈនោះត្រូវសន្តតិ

បិទបាំងទុក ។ និងសន្តតិនោះដែលបិទបាំងទុក ក៏ដោយមិនបានធ្វើមនសិការការកើតឡើង និងការសូន្យទៅ ។ ទុក្ខលក្ខណៈមិនប្រាកដ ក៏ព្រោះត្រូវឥរិយាបថបិទបាំងទុកហើយ ឥរិយាបថទាំងនោះដែលបិទបាំងទុក ក៏ព្រោះមិនបានធ្វើមនសិការកាលដែលត្រូវបៀតបៀនរឿយៗ ។ អនត្តលក្ខណៈមិនប្រាកដ ព្រោះត្រូវឃនៈបិទបាំងទុក ។ ហើយឃនៈ ទាំងនោះដែលបិទបាំងទុក ក៏ព្រោះមិនបានធ្វើមនសិការ ការញែកធាតុផ្សេងៗចេញ ។ កាលឃើញការកើតឡើង និងការសូន្យទៅ កិរិយាដែលកំណត់ការកើតឡើង ក៏នឹងមិនដល់កិរិយាដែលកំណត់ការសូន្យទៅ ឬកិរិយា ដែលកំណត់ការសូន្យទៅក៏មិនដល់កិរិយាដែលកំណត់ការកើតឡើង ។ ខណៈកើតឡើងក៏ម្យ៉ាង ខណៈសូន្យទៅក៏ម្យ៉ាង ព្រោះហេតុនោះ ធម៌សូម្បីតែ ១ ក៏រមែងប្រាកដដោយការផ្សេងគ្នាដោយអំណាចខណៈ នឹងពោលថ្វីដល់ធម៌ដែលជាអតីតជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលកថា **កាលសន្តតិត្រូវជកទៅ ព្រោះកំណត់ការកើតឡើង និងការសូន្យទៅបាន ទើបអនិច្ចលក្ខណៈប្រាកដ តាមសភាពពិតបាន** ។ ក្នុងពាក្យនោះពាក្យថា **កាលសន្តតិត្រូវជកទៅ** សេចក្តីថា កាលសន្តតិត្រូវជកបានដោយការកំណត់ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅ ដោយមុន និងក្រោយគ្នា ជាធម៌មួយផ្នែកម្យ៉ាងៗ ។ ឯកាលព្រះយោគីធ្វើការកំណត់សេចក្តីកើតឡើង និងការសូន្យទៅ ដោយត្រឹមត្រូវនោះឯង ធម៌ទាំងឡាយ រមែងប្រាកដ ដោយការសម្ពន្ធគ្នា ក៏មិនមែន ដោយពិត រមែងប្រាកដដោយការមិនសម្ពន្ធគ្នា ដូចចម្រៀកដែក ព្រោះហេតុនោះ ទើបអនិច្ចលក្ខណៈជាធម្មជាតិជាក់ច្បាស់ដោយល្អក្រៃលែង ។

ពាក្យថា **ព្រោះមនសិការដល់ការបៀតបៀនជានិច្ច** សេចក្តីថា ព្រោះមនសិការដល់សង្ខារទាំងឡាយ ដែលកំពុងបៀតបៀន គឺត្រូវបៀនបៀនគ្រប់ពេល ដោយអំណាចការកើតឡើង និងការសូន្យទៅតាមដែលកំណត់ហើយ ។ ពាក្យថា **កាលឥរិយាបថ**

ត្រូវដក សេចក្ដីថា កាលឥរិយាបថ គឺកាលជាសភាវៈបិទបាំងទុក ដែលត្រូវបានបើក ។ ពិតហើយ ឥរិយាបថដទៃដែលបន្ទាបង់សេចក្ដីទុក្ខ ដែលកើតឡើងក្នុងឥរិយាបថ ១ រមែងដូចជាបិទបាំងទុក្ខនោះ សូម្បីឥរិយាបថដ៏សេស ក៏ដូច្នេះ ព្រោះហេតុនោះ កាលដឹងឥរិយាបថទាំងឡាយ បិទបាំងទុក្ខនោះៗ តាមការពិត រមែងឈ្មោះថា ជាការបើកឥរិយាបថទាំងនោះ បិទបាំងទុក្ខ ព្រោះសង្ខារទាំងឡាយជាសភាពជាក់ច្បាស់ ដោយភាវៈដែលត្រូវទុក្ខចាក់ដោតអស់កាលជានិច្ច ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ទុក្ខលក្ខណៈ ទើបប្រាកដតាមសេចក្ដីពិតបាន** ។ ពាក្យថា **ធាតុផ្សេងៗ** បានដល់ ធាតុ មានបឋវីធាតុជាដើមមានបែបផ្សេងៗ គឺសភាវធម៌ទាំងឡាយ មានបែបផ្សេងៗ ។ ពាក្យថា **ផ្នែក** សេចក្ដីថា ធ្វើជាផ្នែកៗ ដោយន័យជាដើមថា **បឋវីធាតុម្យ៉ាង អាបោធាតុម្យ៉ាង** និងដោយន័យជាដើមថា **ផស្សៈម្យ៉ាង វេទនាម្យ៉ាង** ។ ពាក្យថា **កាលធ្វើឃនវិនិព្ភោគ** សេចក្ដីថា កាលបែកឃនៈ គឺក្រុម និងដុំ គឺកិច្ច និងអារម្មណ៍ ។ ឯឃនៈនេះ គឺ **ភាពជាឃនៈ** គឺក្រុម ដែលបុគ្គលមិនបានពិចារណាសង្ខារទាំងឡាយ ប្រកាន់ដោយអំណាចការប្រកាន់មាំថា ជាការដូចគ្នាក្នុងរូបធម៌ និងអរូបធម៌ ដែលឧបត្ថម្ភគ្នានឹងគ្នាជាក្រុម ម្យ៉ាងទៀត សូម្បីប្រភេទនៃកិច្ចរបស់ធម៌ទាំងឡាយនោះ ជាសភាពពិតប្រាកដដោយចំពោះ **ភាពជាឃនៈ** គឺកិច្ចដែលប្រកាន់ដោយភាពដូចគ្នា ហើយម្យ៉ាងទៀត សូម្បីភាពផ្សេងគ្នានៃការធ្វើឲ្យជាអារម្មណ៍របស់សភាវធម៌ ដែលទទួលអារម្មណ៍បានទាំងឡាយ **ឃនៈ** គឺអារម្មណ៍ ដែលប្រកាន់ដោយជារបស់មួយជាមួយគ្នា ភាពជាឃនៈទាំងនោះ ដែលញាណបែកក្នុងធាតុទាំងឡាយកំពុងប្រាកដ រមែងដល់នូវការទ្រុឌទ្រោមទៅដូចដុំពពុះទឹកដែលត្រូវប្របាច់ដោយដៃដូច្នោះ អនត្តលក្ខណៈ រមែងជាធម្មជាតិជាក់ច្បាស់ក្រៃលែងថា **ធម៌ទាំងឡាយ** នេះប្រព្រឹត្តទៅតាមបច្ច័យ សោះសូន្យទទេ ត្រឹមតែជាធម៌ប៉ុណ្ណោះ ដោយហេតុនោះ ទើប

លោកអាចារ្យពោលថា **កាលចែកធាតុផ្សេងៗ ។បេ។ ទើបអនត្តលក្ខណៈប្រាកដតាមសភាពពិតបាន** ។

វត្ថុដែលមិនទៀង ព្រោះបដិសេធការស្ថិតស្ថេរ ព្រោះហេតុនោះ ទើបឈ្មោះថា **វត្ថុមិនទៀង** បានដល់ ខន្ធ ៥ ។ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភជៈ រូបមិនទៀង វេទនា... សញ្ញា... សង្ខារ... វិញ្ញាណមិនទៀង ។ លោកអាចារ្យកាលពោលហេតុក្នុងពាក្យនោះ ពោលថា **ព្រោះភាវៈ** គឺខន្ធ មានការកើតឡើង ការសូន្យទៅ និងការប្រែប្រួលទៅ ។ **ការកើតឡើង** បានដល់ លក្ខណៈដែលកើតឡើង **ការសូន្យទៅ** បានដល់ លក្ខណៈដែលប្រែប្រួល **ការប្រែប្រួលទៅ** បានដល់ ជរា ព្រោះមានការកើតឡើង និងការសូន្យទៅនោះ ។ ពាក្យថា **ព្រោះខន្ធមានហើយ ក៏ទៅជាមិនមាន** គឺព្រោះខន្ធកើតឡើងហើយវិនាសទៅ ។ ឯក្នុងទីនេះ ដោយពាក្យជំបូងលោកសម្ដែងថា **មិនទៀង** ព្រោះមានការកើត ការចាស់ និងការស្លាប់ ដោយពាក្យទី ២ លោកសម្ដែងថា **មិនទៀង** ព្រោះមានការឆ្អិន និងការខ្ចាត់ខ្ចាយទៅ ។ ខន្ធ ៥ លោកហៅថា **មិនទៀង** ដោយភាវៈនៃធម្មជាតិណា ដើម្បីនឹងសម្ដែងធម្មជាតិនោះថា **ជាលក្ខណៈរបស់ការមិនទៀង** ទើបលោកអាចារ្យពោលថា **ការកើតឡើង ការសូន្យទៅ និងការប្រែប្រួលទៅ** ។ ដោយភាវៈនោះឯង ទើបធម្មជាតិនោះ លោកកំណត់ថា **មិនទៀង** ។ ពាក្យថា **ការប្រែប្រួលទៅនៃអាការ** បានដល់ ការប្រែប្រួលទៅនៃអាការ ។ ឯអាការដែលមិនមាន រមែងបានដោយរូបរបស់ការប្រែប្រួល ព្រោះការខុសប្រក្រតីទៅ រមែងមិនបានអាការ គឺការកើតឡើង ។ ម្យ៉ាងទៀត ពាក្យថា **ការប្រែប្រួលទៅនៃអាការ** បានដល់ ការផ្សេងទៅនៃអាការ ។ ឯភាពដែលខន្ធមានហើយ ក៏ទៅជាមិនមាន ព្រោះជាការឆ្អិន បែកធ្លាយទៅ ព្រោះជាវត្ថុភត់ភយទៅ ហើយក្នុងសេចក្ដីនោះ លក្ខណៈរបស់ការមិនទៀង ក៏ជាពាក្យជាប់មាត់ ។ ឯអាការរបស់ការ

មិនទៀង ផ្សេងអំពីអាការរបស់ការកើតឡើងដូចគ្នា ផ្សេងអំពីអាការរបស់ភាពជាទុក្ខ និងអនត្តា ។ ពិតហើយ ភាវៈដែលខ្ចាត់ខ្ចាយទៅរបស់សំឡេង ក៏ឲ្យសម្រេចបាន សូម្បីដោយភាវៈដែលត្រូវបច្ច័យតាក់តែងឡើង ។

**ភាវៈដែលជាវត្ថុត្រូវបច្ច័យប្រជុំតាក់តែងឡើង** ដោយអត្ថ បានដល់ កិរិយាដែលមានការកើតឡើង ។ ហើយ **ការកើតឡើង** ក៏គឺកិរិយាកំណត់ដែលទ្រទ្រង់ឲ្យសម្រេចដោយភាវៈដែលធ្អិន ។ គប្បីជ្រាបលក្ខណៈរបស់ទុក្ខ និងអនត្តា ដោយន័យនេះ ។ ម្យ៉ាងទៀត គប្បីឃើញថា វត្ថុដែលឈ្មោះថា មិនទៀង ក៏ព្រោះបដិសេធការទៀង ព្រោះហេតុនោះ អាការដែលមិនទៀង ពោល គឺអាការដែលមិនមានតាមដែលពោលហើយ ព្រោះបដិសេធអាការដែលទៀង ទើបឈ្មោះថា **លក្ខណៈរបស់ការមិនទៀង** យ៉ាងណា វត្ថុដែលឈ្មោះថាទុក្ខ ក៏ព្រោះបដិសេធការសុខ ព្រោះហេតុនោះ អាការដែលជាទុក្ខ ពោល គឺការបៀតបៀនជានិច្ច ព្រោះបដិសេធអាការដែលជាសុខ ទើបឈ្មោះថា **លក្ខណៈរបស់ទុក្ខ** ដូច្នោះ ម្យ៉ាងទៀត វត្ថុដែលឈ្មោះថា ជាអនត្តា ក៏ព្រោះបដិសេធអត្តា ព្រោះហេតុនោះ អាការដែលជាអនត្តា ពោល គឺអាការដែលមិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះបដិសេធអាការដែលជាអត្តា ទើបឈ្មោះថា **លក្ខណៈរបស់អនត្តា** ។ អាការទាំង ៣ នេះ មិនបានជាសភាវៈ ដែលទាក់ទងដោយខន្ធ ព្រោះមិនជាសភាវធម៌ ។ ទាំងមិនបានជាខន្ធវិមុត្តិ ព្រោះគប្បីវៀរចាកខន្ធទាំងឡាយមិនបាន ។ តែអាស្រ័យខន្ធទាំងឡាយ ក៏បានដោយអំណាចវោហារ គប្បីជ្រាបថាជាបញ្ញត្តិពិសេសដែលកើតអំពីខន្ធ គប្បីជាហេតុពិសេសនៃការសម្តែងទោសរបស់ខន្ធនោះ ។

ពាក្យថា **ទាំងពួងនេះ** បានដល់ លក្ខណៈ ៣ តាមដែលបានពោលហើយ និងខន្ធ ៥ ដែលគប្បីកំណត់ ។ ពាក្យថា **រមែងកំណត់ចាំតាមសភាវៈដែលពិតបាន**

ដោយឧទយព្វយានុបស្សនាញាណ នេះ លោកអាចារ្យពោលទុក ដោយអំណាចបញ្ញត្តិលក្ខណៈ នៃខន្ធនោះ ក្នុងអត្ថនៃលក្ខណៈ នៃខន្ធនោះ ។ ឯវិបស្សនាដែលមានលក្ខណៈជាដើមជាអារម្មណ៍ ដើម្បីការកើតឡើង និងការសូន្យទៅ លោកពោលថា ឈ្មោះឧទយព្វយញ្ញាណ ។ ព្រោះថា ឧទយព្វយញ្ញាណមិនមានលក្ខណៈ មានទុក្ខលក្ខណៈជាដើមជាវិស័យបានឡើយ ។ ម្យ៉ាងទៀត ឧទយព្វយញ្ញាណនោះឯងមិនគប្បីមានទៅក្នុងលក្ខណៈ មានទុក្ខលក្ខណៈជាដើមនោះជាវិស័យឡើយ តែព្រះយោគាវចរដែលប្រាថ្នានឹងធ្វើឧទយព្វយញ្ញាណឲ្យមុត និងឲ្យមុតស្រួច គប្បីធ្វើការពិចារណាលក្ខណៈទាំង ៣ នោះឯង ។ ឯការពិចារណាលក្ខណៈ ៣ នេះ ក៏ដូចគ្នានឹងបរិកម្មរបស់ឧទយព្វយញ្ញាណនោះ ។ សូម្បីក្នុងញាណដ៏សេសក៏មានន័យនេះ ។

# វិសុទ្ធិមគ្គ

## ភង្គានុបស្សនាញាណ

*កាលព្រះយោគាវចរនោះ ឃើញថា* ***វត្ថុដែលកើតឡើង ជាសង្ខារ ឈ្មោះដូច្នេះ ហើយរមែងរលត់ទៅយ៉ាងនេះ*** *វិបស្សនាញាណឈ្មោះភង្គានុបស្សនា រមែងកើតឡើងក្នុងឋានៈនោះ ( គឺក្នុងកាលលែងខាងការកើតចោល ធ្វើទុកក្នុងចិត្តតែខាងរលត់តែម្យ៉ាង ) ដែលលោកពោលសំដៅទុក ( ក្នុងបដិសម្ភិទាមគ្គ ) ថា សួរថា បញ្ញាក្នុងការពិចារណាអារម្មណ៍ហើយ តាមឃើញការបែកធ្លាយ ឈ្មោះថា វិបស្សនាញាណដូចម្ដេច ? ចិត្តមានរូបជាអារម្មណ៍កើតឡើងហើយ រមែងបែកធ្លាយ ភិក្ខុពិចារណាអារម្មណ៍នោះហើយ រមែងតាមឃើញការបែកធ្លាយនៃចិត្តនោះ ពាក្យថា* ***តាមឃើញ*** *គឺតាមឃើញដូចម្ដេច ? គឺតាមឃើញដោយការមិនទៀង មិនមែនដោយការទៀង តាមឃើញដោយជាទុក្ខ មិនមែនដោយជាសុខ តាមឃើញដោយជាអនត្តា មិនមែនដោយអត្តា រមែងនឿយណាយ មិនមែនត្រេកអរ រមែងប្រាសចាកតម្រេក មិនមែនតម្រេក រមែងរំលត់ មិនមែនឲ្យកើតឡើង រមែងរលាស់ មិនមែនប្រកាន់ទុក កាលតាមឃើញដោយការមិនទៀង រមែងលះនិច្ចសញ្ញាបាន កាលតាមឃើញដោយជាទុក្ខ រមែងលះសុខសញ្ញាបាន កាលតាមឃើញដោយភាពជាអនត្តា រមែងលះអត្តសញ្ញាបាន កាលនឿយណាយ រមែងលះនន្ទិ គឺការភ្លើតភ្លើនត្រេកអរបាន កាលប្រាសចាកតម្រេក រមែងលះរាគៈបាន កាលរលត់ រមែងលះសមុទយៈបាន កាលរលាស់ចោល រមែងលះការប្រកាន់បាន ។ ចិត្តមានវេទនាជាអារម្មណ៍... មានសញ្ញាជាអារម្មណ៍... មានសង្ខារជាអារម្មណ៍...មានវិញ្ញាណជាអារម្មណ៍...មានចក្ខុជាអារម្មណ៍ ។បេ។ មានជរាមរណៈជាអារម្មណ៍កើតឡើងហើយ រមែងបែកធ្លាយ ។បេ។ កាលរលាស់ចោល*

រមែងលះសេចក្តីប្រកាន់បាន ។

ការពិចារណា ( អារម្មណ៍ ) ដែលរំកិលវត្ថុ ( គឺអារម្មណ៍ ) បានផង បូរសញ្ញា ( គឺការកំណត់ចំណាំ ) បានផង មានកម្លាំងក្នុងការនឹកភាវរកបានផង ឈ្មោះថា បដិសង្ខាវិបស្សនា ( ឃើញច្បាស់ដោយការពិចារណា ) ។

ការពិចារណា ដែលកំណត់អារម្មណ៍ទាំង ២ ចំណែក ( គឺទាំងដែលឃើញហើយ ទាំងដែលមិនបានឃើញ ព្រោះជាអតីត អនាគត ) ថា មានសភាពដូចគ្នាតាមបែបអារម្មណ៍ ( បច្ចុប្បន្នដែលពិចារណាឃើញ ) គឺការនឹកបង្អោនចុះទៅក្នុងនិរោធ គឺការរលត់នោះឯង ឈ្មោះថា វយលក្ខណវិបស្សនា គឺឃើញច្បាស់ក្នុងលក្ខណៈសូន្យទៅ ។

ពិចារណាអារម្មណ៍ ( ដំបូង ) ហើយ តាមឃើញការរលត់ផង ការប្រាកដដោយភាពទទេផង ឈ្មោះថា អធិបញ្ញាវិបស្សនា ។

ភិក្ខុដែលឈ្លាសក្នុងអនុបស្សនា ៣ និងក្នុងវិបស្សនា ៤ រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ ព្រោះមានការឈ្លាសក្នុងឧបដ្ឋាន ៣ ដូច្នេះ ។

ការពិចារណានោះ ចាត់ជាញាណ ព្រោះការពិចារណានោះ មានអត្ថថា ដឹង ចាត់ជាបញ្ញា ព្រោះមានអត្ថថា ដឹងទូទៅ ព្រោះហេតុនោះ ទើបពោលទុកថា បញ្ញាក្នុងការពិចារណាអារម្មណ៍ ហើយតាមឃើញ តែការដែលបែកធ្លាយ ឈ្មោះថា វិបស្សនាញាណ ដូច្នេះ ។

## អធិប្បាយ បាលី

អធិប្បាយក្នុងបាលីនោះ គប្បីជ្រាបដូច្នេះ ពាក្យថា **អារម្មណបដិសង្ខា** ពិចារណាអារម្មណ៍ សេចក្តីថា ពិចារណាហើយ គឺដឹងហើយ បានដល់ ឃើញ ហើយនូវអារម្មណ៍ឯណានីមួយ ដោយការអស់ទៅ ដោយការសូន្យទៅ ពាក្យថា **កង្គានុបស្សនេ**

**បញ្ញា** បញ្ញាក្នុងការតាមឃើញការបែកធ្លាយជាដើម សេចក្តីថា បញ្ញាក្នុងការតាមឃើញការបែកធ្លាយនៃការដឹង ដែលពិចារណាអារម្មណ៍ ដោយការអស់ទៅ ការសូន្យទៅកើតឡើងនោះឯណា នេះហៅថា **វិបស្សនាញាណ** សួរថា ញាណនោះដូចម្តេច ? នេះជាសេចក្តី ( អធិប្បាយ ) នៃកថេតុកម្យតាបុច្ឆា ជាលំដាប់ដំបូង ។

លំដាប់តអំពីនោះ ញាណនោះ ជាប្រការណា នឹងសម្តែងប្រការនោះ ទើបលោកពោលពាក្យថា **រូបារម្មណតា** មានរូបជាអារម្មណ៍ជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **រូបារម្មណតា ចិត្តំ ឧប្បជ្ជិត្វា ភិជ្ជតិ** សេចក្តីថា ចិត្តមានរូបជាអារម្មណ៍កើតឡើងហើយ រមែងបែកធ្លាយទៅ ឬន័យម្យ៉ាងទៀតថា ចិត្តកើតឡើងក្នុងភាពជាចិត្តមានរូបជាអារម្មណ៍ហើយ រមែងបែកធ្លាយទៅ ។

ពាក្យថា **តំ អារម្មណំ បដិសង្ខា** ពិចារណាអារម្មណ៍នោះហើយ សេចក្តីថា ពិចារណាហើយ គឺដឹងហើយ បានដល់ ឃើញហើយនូវរូបារម្មណ៍នោះ ដោយការអស់ទៅ ដោយការសូន្យទៅ ។

ពាក្យថា **តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ** រមែងតាមឃើញការបែកធ្លាយនៃចិត្តនោះ សេចក្តីថា រូបារម្មណ៍នោះ ដែលចិត្តដួងណាឃើញហើយ ដោយការអស់ទៅ ការសូន្យទៅ ភិក្ខុរមែងតាមឃើញការបែកធ្លាយនៃចិត្តដួងនោះ ដោយចិត្ត ១ ដួងទៀត ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា **ញាតញ្ច ញាណញ្ច ឧភោបិ វិបស្សតិ** ព្រះយោគាវចររមែងឃើញច្បាស់នូវវត្ថុដែលត្រូវ ដឹង គឺអារម្មណ៍ផង នូវវត្ថុដឹង គឺអនុបស្សនាញាណផង ទាំង ២ យ៉ាង ដូច្នេះ ។

ឯពាក្យថា **អនុបស្សតិ** រមែងតាមឃើញ ក្នុងពាក្យនេះ បានដល់ ឃើញរឿយៗ ទៅ ដោយអត្ថថា ឃើញរឿយៗ ដោយអាការច្រើនយ៉ាង ព្រោះហេតុនោះ ទើបលោកពោលទុកថា **ពាក្យថា តាមឃើញ** គឺតាមឃើញដូចម្តេច ? គឺតាមឃើញដោយការ

មិនទៀង ដូច្នេះជាដើម ។

ក្នុងអាការទាំងនោះ ហេតុណា ដែលការបែកធ្លាយ រមែងជាទីបំផុតនៃអនិច្ចតា ព្រោះហេតុនោះ ព្រះយោគាវចរដែលជាកង្ខានុបស្សកៈនោះ ទើបតាមឃើញសង្ខារទាំងពួង ដោយភាពមិនទៀង មិនមែនដោយភាពទៀង លំដាប់នោះ ព្រោះវត្ថុដែលមិនទៀង ក៏ជាទុក្ខ និងព្រោះវត្ថុដែលជាទុក្ខ ក៏ជាអនត្តា ទើបតាមឃើញសង្ខារទាំងឡាយនោះឯង ដោយជាទុក្ខ មិនមែនដោយជាសុខ តាមឃើញសង្ខារទាំងពួងនោះឯង ដោយភាពជាអនត្តា មិនមែនដោយភាពជាអត្តា ។ ម្យ៉ាងទៀត ហេតុណា វត្ថុណាមិនទៀង ជាទុក្ខ ជាអនត្តា វត្ថុនោះ ក៏មិនគប្បីត្រេកអរ ហើយវត្ថុណា មិនគប្បីត្រេកអរ ក៏មិនគប្បីមានតម្រេកក្នុងវត្ថុនោះ ព្រោះហេតុនោះ ទើបព្រះយោគាវចរនោះនឿយណាយ មិនមែនត្រេកអរ ទើបប្រាសចាកតម្រេក មិនមានតម្រេកក្នុងសង្ខារដែលឃើញហើយ ថាមិនទៀង ជាទុក្ខ ជាអនត្តា តាមគន្លងកង្ខានុបស្សនានោះ ។

លោកមិនត្រេកត្រអាលយ៉ាងនោះ ក៏ឈ្មោះថា ញុំាងរាគៈឲ្យរលត់ មិនមែនឲ្យកើតឡើង ដោយអត្ថថា មិនធ្វើឲ្យជាសមុទយៈ ( កើតឡើង ) បាន ដោយញាណដែលជាលោកិយនោះឯងមុន ។ ឬម្យ៉ាងទៀត លោកជាអ្នកប្រាសចាកតម្រេក យ៉ាងនោះ លោកញុំាងសង្ខារដែលឃើញហើយ គឺដែលប្រាកដឥឡូវនេះ ឲ្យរលត់ មិនមែនឲ្យកើតឡើង យ៉ាងណា ក៏ញុំាងសង្ខារដែលមិនបានឃើញ គឺជាអតីតអនាគតឲ្យរលត់ មិនមែនឲ្យកើតឡើយ ដោយអំណាចអន្វយញ្ញាណ គឺដឹងដោយអនុលោម ឬអនុមានតាមដែលប្រាកដហើយ ដូច្នោះ ដោយសេចក្តីថា ធ្វើក្នុងចិត្តតែខាងរលត់ មើលតែការរលត់របស់សង្ខារតែម្យ៉ាង មិនមើលការកើត ។

លោកបដិបត្តិយ៉ាងនោះហើយ ក៏ឈ្មោះថា រលាស់ចោល ( សង្ខារ ) បាន មិនមែនកាន់យក សេចក្តីនេះ មានអធិប្បាយដូចម្តេច ? អធិប្បាយថា សូម្បីអនុបស្សនា

មានអនិច្ចានុបស្សនាជាដើមនេះ ក៏ហៅបានថា ជាបរិច្ចាគបដិនិស្សគ្គ ( លះបង់ចោល ដោយការលះបង់ ) និងជាបក្ខន្ទនបដិនិស្សគ្គ ( លះបង់ចោលដោយស្ទុះទៅ ) ព្រោះលះបង់កិលេសទាំងឡាយ ព្រមទាំងខន្ធ និងអភិសង្ខារ គឺកម្ម ដោយអំណាចតទង្គ-ប្បហាន និងព្រោះការឃើញទោសក្នុងសង្ខតធម៌ ទើបស្ទុះទៅក្នុងព្រះនិព្វាន ដែលផ្ទុយគ្នាជាមួយសង្ខតធម៌នោះ ដោយកិរិយាដែលបង្អោនចិត្តទៅក្នុងព្រះនិព្វាននោះ ហេតុនោះ ភិក្ខុដែលប្រកបព្រមដោយអនុបស្សនា មានអនិច្ចានុបស្សនាជាដើមនោះ ទើបលះបង់កិលេសទាំងឡាយបាន និងស្ទុះទៅ ក្នុងព្រះនិព្វានបានផងដែរ ដោយន័យដូចពោលមកហើយ ទាំងមិនប្រកាន់យកកិលេសទាំងឡាយទុក ដោយធ្វើឲ្យកិលេសកើតឡើងឡើយ មិនប្រកាន់យកអារម្មណ៍ដែលជាសង្ខតធម៌ទុក ដោយភាពដែលមិនឃើញទោស ព្រោះហេតុនោះ ទើបលោកពោលថា **បដិនិស្សជ្ជតិ នោ អាទិយតិ** លះបង់ចោល មិនមែនប្រកាន់ទុក ។

ឥឡូវនេះ ការលះធម៌ទាំងឡាយណា បានដោយញាណទាំងនោះ រមែងមានដល់ព្រះយោគាវចរនោះ និងសម្តែងការលះធម៌ទាំងឡាយនោះ ទើបលោកពោលថា **កាលតាមឃើញដោយភាពមិនទៀង រមែងលះនិច្ចសញ្ញាបាន** ដូច្នេះជាដើម ក្នុងពាក្យទាំងនោះ ពាក្យថា **នន្ទី** សេចក្តីត្រេកត្រអាល បានដល់ តណ្ហា ដែលប្រព្រឹត្តទៅជាមួយបីតិ ( ការឆ្អែតចិត្ត ) ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អធិប្បាយ គាថា

ចំណែកក្នុងគាថាទាំងឡាយ ពាក្យថា **វត្ថុសង្កមនា** វិកិលវត្ថុ សេចក្តីថា ការពិចារណាដែលឃើញការរលត់នៃរូបហើយ វិកិលទៅកាន់វត្ថុដទៃ អំពីវត្ថុដំបូង ដោយអំណាចការឃើញការរលត់ សូម្បីនៃចិត្តដូងដែលឃើញការរលត់ ( ដំបូង ) នោះទៀត ។ ពាក្យថា **សញ្ញាយ ច វិវដ្ដនា** ឬសញ្ញាបានផង គឺការពិចារណាតែខាងការ

កើត ហើយតាំងនៅតែក្នុងខាងការរលត់ ។ ពាក្យថា **អាវជ្ជនាពលញ្ចេវ** មានកម្លាំងក្នុងការនឹកភាវរកបានផង អធិប្បាយថា ឃើញការរលត់នៃរូបហើយ អាចក្នុងការនឹកភាវរក ( អារម្មណ៍ ) មិនដាច់ខ្សែ ដើម្បីឃើញការរលត់នៃចិត្តដួងដែលមានការរលត់ ( របស់រូប ) ជាអារម្មណ៍ទៀត ។ ពាក្យថា **បដិសង្ខា វិបស្សនា** សេចក្តីថា ការពិចារណា អារម្មណ៍នោះ ឈ្មោះថា **កង្ខានុបស្សនា** ។

ពាក្យថា **អារម្មណានុវយេនេវ ឧភោ ឯកវវត្ថនា** ការពិចារណាដែលកំណត់អារម្មណ៍ទាំង ២ ចំណែក មានសភាពដូចគ្នាតាមបែបនៃអារម្មណ៍នោះឯង សេចក្តីថា កំណត់អារម្មណ៍ទាំង ២ ចំណែក ដោយមានសភាវៈដូចគ្នាយ៉ាងនេះថា សង្ខារ ( បច្ចុប្បន្ន ) នេះ បែកធ្លាយ យ៉ាងណា សូម្បីសង្ខារក្នុងអតីតក៏បែកធ្លាយមកហើយ សង្ខារក្នុងអនាគតសោត ក៏នឹងបែកធ្លាយយ៉ាងនោះ តាមបែបអារម្មណ៍ដែលឃើញហើយ ដោយប្រចក្សនោះឯង សេចក្តីនេះ ព្រះបុរាណាចារ្យទាំងឡាយ ក៏បានពោលទុកថា

***ព្រះយោគាវចរដែលមានការឃើញបរិសុទ្ធហើយ ក្នុងសង្ខារដែលមាន ( គឺដែលជាបច្ចុប្បន្ន ) រមែងនាំការឃើញតាមបែបការឃើញនោះទៅ ក្នុងសង្ខារដែលជាអតីត និងអនាគតផងថា សង្ខារទាំងពួង មានការបែកធ្លាយទៅជាប្រក្រតី ដូចតំណក់ទឹកសន្សើម ត្រូវពន្លឺព្រះអាទិត្យ ដូច្នោះ ។***

ពាក្យថា **និរោធេ អធិមុត្តា** ការនឹកបង្អោនទៅក្នុងការរលត់ សេចក្តីថា ធ្វើការកំណត់សង្ខារទាំង ២ ចំណែក ជាបែបដូចគ្នា ដោយអំណាចការបែកធ្លាយយ៉ាងនោះហើយ នឹកបង្អោនចុះទៅក្នុងការរលត់ ពោល គឺការបែកធ្លាយនោះប៉ុណ្ណោះ សេចក្តីថា ធ្ងន់ទៅក្នុងការរលត់នោះ លំអៀងទៅក្នុងការរលត់នោះ ជម្រាលទៅក្នុងការរលត់នោះ ទេរទៅក្នុងការរលត់នោះ ។ ពាក្យថា **វយលក្ខណវិបស្សនា** អធិប្បាយ

ថា ការពិចារណានោះ ឈ្មោះថា វយលក្ខណវិបស្សនា ( ឃើញច្បាស់ក្នុងលក្ខណៈរលត់ ។

ពាក្យថា **អារម្មណញ្ច បដិសង្ខា** ពិចារណាអារម្មណ៍ផង គឺដឹងអារម្មណ៍ មានរូបជាដើម ដែលជាអារម្មណ៍ដំបូងផង ។ ពាក្យថា **ភង្គញ្ច អនុបស្សតិ** តាមឃើញការរលត់ផង គឺឃើញការរលត់នៃអារម្មណ៍ ( ដំបូង ) នោះ ហើយតាមឃើញការរលត់នៃចិត្តដួងដែលមានអារម្មណ៍ ( ដំបូង ) នោះ ជាអារម្មណ៍ផង ។ ពាក្យថា **សុញ្ញតោ ច ឧបដ្ឋានំ** ការប្រាកដដោយភាពសោះសូន្យផង គឺកាលលោកតាមឃើញការរលត់នៃសង្ខារនោះយ៉ាងនោះ ការប្រាកដ ដោយភាពសោះសូន្យថា **សង្ខារទាំងឡាយនោះឯងបែកធ្លាយ** ការបែកធ្លាយនៃសង្ខារទាំងឡាយនោះ ហៅថា **ការស្លាប់មិនមាន ( អត្តា ) ណាមួយដទៃ ( អំពីខន្ធ ) ឡើយ** ដូច្នេះ រមែងចម្រើនឡើង ហេតុនោះ ទើបព្រះបុរាណាចារ្យទាំងឡាយពោលទុកថា

**ខន្ធទាំងឡាយរលត់ វត្ថុដទៃមិនមានឡើយ ការបែកធ្លាយនៃខន្ធទាំងឡាយ ហៅថា ស្លាប់** ព្រះយោគាវចរដែលមិនប្រមាទ រមែងឃើញការអស់ទៅនៃខន្ធទាំងឡាយនោះ ដូចបុគ្គលចោះកែវដោយពេជ្រ ដោយឧបាយ ( គឺដោយវិធីដែលត្រឹមត្រូវ រមែងឃើញការអស់ទៅនៃកែវដែលត្រូវចោះ ) ដូច្នោះ ។

ពាក្យថា **អធិប្បញ្ញាវិបស្សនា** អធិប្បាយថា ការពិចារណាដឹងអារម្មណ៍ឯណាផង បញ្ញាតាមឃើញការបែកធ្លាយឯណាផង ការប្រាកដដោយភាពសោះ សូន្យឯណាផង នេះឈ្មោះថា **អធិប្បញ្ញាវិបស្សនា** ។

ពាក្យថា **កុសលោ តីសុ អនុបស្សនាសុ** កិក្ខុដែលឈ្លាសក្នុងអនុបស្សនា ៣ គឺកិក្ខុដែលឈ្លាសក្នុងអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ។ ពាក្យថា **ចតស្សោ ច វិបស្សនាសុ** ក្នុងវិបស្សនា ៤ ផង គឺក្នុងវិបស្សនា ៤ មាននិព្វិទានុបស្សនាជាដើម

ផង ។ ពាក្យថា **តយោ ឧបដ្ឋានេ កុសលតា** ហេតុដែលមានការឈ្លាសក្នុងឧបដ្ឋាន ៣ គឺព្រោះជាអ្នកឈ្លាសក្នុងការប្រាកដ ៣ ស្ថាននេះ គឺដោយការអស់ ដោយការវិនាស ដោយការសោះសូន្យផង ។ ពាក្យថា **នានាទិដ្ឋីសុ ន កម្បតិ** រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ គឺរមែងមិនញាប់ញ័រក្នុងទិដ្ឋិទាំងឡាយ មានប្រការផ្សេងៗ មានសស្សតទិដ្ឋិជាដើម ។

ព្រះយោគាវចរនោះ មិនគប្បីញាប់ញ័រយ៉ាងនោះ មានមនសិការប្រព្រឹត្តទៅដោយន័យថា **វត្ថុដែលមិនទាន់រលត់នោះឯង កំពុងរលត់ វត្ថុដែលកំពុងបែកធ្លាយ** រមែងលែងនិមិត្តនៃការកើត ការតាំងនៅ និងការប្រព្រឹត្តទៅនៃសង្ខារទាំងពួងចោល ហើយសម្លឹងតែការបែកធ្លាយតែម្យ៉ាង ដូចមើលការបែកធ្លាយរបស់កាជនៈចាស់ៗ ដែលបុគ្គលកំពុងវាយ ដូចមើលការបែក ( ខ្ចាយ ) របស់ធូលីល្អិត ដែលបុគ្គលកំពុងរោយ ដូចមើលការបែកធ្លាយរបស់គ្រាប់ល្ងទាំងឡាយ ដែលបុគ្គលកំពុងលីង ដូច្នោះ ព្រះយោគាវចរនោះ រមែងឃើញថា **សង្ខារទាំងពួងកំពុងបែកធ្លាយៗ** ដូចបុរសដែលមានភ្នែកល្អ ឈរនៅត្រង់មាត់ស្រះបោក្ខរណី ឬត្រង់ប្រាំងស្ទឹង កាលភ្លៀងមេធំធ្លាក់ចុះមក នឹងគប្បីឃើញពពុះទឹកធំៗ លើផ្ទៃទឹកដែលកើតឡើងហើយ ហើយបែកធ្លាយទៅដោយឆាប់រហ័ស ដូច្នោះ ពិតហើយ ព្រះមានជោគទ្រង់ក៏សំដៅដល់ព្រះយោគាវចរបែបនេះត្រាស់ទុកថា

*មច្ចុរាជ រមែង ( រកខ្លួន ) មិនឃើញនូវបុគ្គលដែលមើលនូវលោក ( គឺខន្ធ ) ដូចមើលពពុះទឹក ដូចមើលថ្ងៃបណ្តើរកូន ។*

## អានិសង្សភង្គានុបស្សនាញាណ

កាលឃើញរឿយៗ ថា **សង្ខារទាំងពួងបែកធ្លាយៗ** យ៉ាងនោះ ភង្គានុបស្សនា

ញាណដែលមានអានិសង្ស ៨ ជាបរិវារ រមែងជាញាណមានកម្លាំង នេះជាអានិសង្ស ៨ ក្នុងពាក្យនោះ គឺ

| | |
|---|---|
| ភវទិដ្ឋិប្បហានំ | លះភវទិដ្ឋិបាន |
| ជីវិតនិកន្តិបរិច្ចាគោ | លះបង់ការជាប់ជំពាក់ក្នុងជីវិតបាន |
| សទា យុត្តបយុត្តតា | ប្រកប ( ភាវនា ) ដ៏ប្រពៃគ្រប់កាល |
| វិសុទ្ធាជីវិតា | មានអាជីវៈបរិសុទ្ធ |
| ឧស្សុក្កប្បហានំ | លះសេចក្តីក្រវល់ក្រវាយ (ក្នុងកិច្ចានុកិច្ចខាងក្រៅ) បាន |
| វិគតភយតា | ជាអ្នកប្រាសចាកសេចក្តីតក់ស្លុត |
| ខន្តិសោរច្ចបដិលាភោ | បានចំពោះនូវខន្តិសោរច្ចៈ |
| អរតិរតិសហនតា | អត់សង្កត់នូវការមិនត្រេកអរក្នុង ( អធិកុសល ) និងសេចក្តីត្រេកអរ ( ក្នុងកាមគុណ ) បាន |

ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា

មុនីដែល ( សម្គាល់ខ្លួន ) ដូចបុគ្គលមានសំពត់ទទូរក្បាលត្រូវឆេះហើយ ឃើញគុណដ៏កំពូល ៨ ប្រការនេះហើយ ពិចារណាក្នុងភង្គានុបស្សនានោះរឿយៗ ទៅ រមែង ( សម្រេច ) ជាភង្គានុបស្សីបុគ្គល ដើម្បីសម្រេចអមតធម៌បាន ។

កង្គានុបស្សនាញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយភង្គានុបស្សនាញាណ

បទថា **វហតិ** ប្រែថា រមែងប្រព្រឹត្តទៅ ។ ការៈដែលញាណជាធម្មជាតិមុតស្រួចក៏ដោយការនាស្មាត់ជំនាញ ។ និងការនាដែលស្ទាត់ជំនាញហើយ រមែងប្រព្រឹត្តទៅដូចអែបស្និទ្ធនៅក្នុងអារម្មណ៍ ព្រោះមិនមានការរាយមាយ ព្រោះហេតុនោះ ទើបលោកសម្ដែងសង្ខារទាំងឡាយប្រាកដរហ័ស ដោយការៈដែលញាណមុតស្រួច ។ ម្យ៉ាងទៀត **កាលសង្ខារទាំងឡាយប្រាកដយ៉ាងរហ័ស** ដោយអំណាចការកើតឡើង និងការរលត់ទៅ និងការឃើញការកើតឡើងថា **វត្ថុដែលមានការកើតឡើង ក៏មានការវិនាសទៅ** ដូច្នេះ ក៏ត្រឹមតែដើម្បីឃើញការសូន្យទៅ ព្រោះនាំមកនូវការនឿយណាយដល់ព្រះយោគាវចរនោះ ព្រោះហេតុនោះ មនសិការដែលប្រមូលការទឹកគិត តែក្នុងការបែកធ្លាយទៅ រមែងប្រព្រឹត្តទៅដល់ព្រះយោគាវចរនោះ ព្រោះហេតុនោះ ទើបញាណកើតឡើងប្រារព្ធតែការបែកធ្លាយទៅតែម្យ៉ាង លែងចោលការកើតឡើងជាដើម ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ឧប្បាទំ វា** ប្រែថា **ញាណរមែងមិនជួបនូវការកើតឡើង** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ បទថា **ឧប្បាទំ** បានដល់ការប្រែប្រួលទៅនៃការកើតឡើង ។ បទថា **ឋិតឹ** បានដល់ ធម្មជាតិដែលដល់នូវការតាំងនៅ អធិប្បាយថា ជរា ។ បទថា **បវត្តំ** បានដល់ ការប្រព្រឹត្តទៅនៃសង្ខារដែលកម្មក្កិលេសគ្រប់គ្រង ។ បទថា **និមិត្តំ** បានដល់ សង្ខារនិមិត្ត ។ ធម្មជាតិណាប្រាកដដល់សង្ខារទាំងឡាយ ដូចជាប្រាកដដល់វត្ថុដែលមានរាងកាយ ដោយអំណាចជាដុំមានហេតុកើតឡើងជាដើម និងដោយកំណត់ដោយកិច្ចរបស់ខ្លួន ធម្មជាតិនោះ ឈ្មោះ

ថា **សង្ខារនិមិត្ត** ចំណែក អាចារ្យពួកខ្លះរមែងពោលថា ការប្រព្រឹត្តទៅ គឺការកើតឡើងដោយមិនដាច់ខ្សែនៃ សង្ខារទាំងឡាយ ឈ្មោះថា **បវត្ត** ការមាន គឺការបន្តៗគ្នានៃទីតាំងរបស់ធម៌ ដែលកើតឡើងហើយទាំងឡាយ ឈ្មោះថា **និមិត្ត** ព្រោះហេតុនោះ បើញាណកាន់ឧប្បាទ ( ការកើតឡើង ) តែម្យ៉ាង ឈ្មោះថា រមែងកាន់យកបវត្តៈ ( ការប្រព្រឹត្តទៅផងដែរ ) ។ បើកាន់យកឋិតិតែម្យ៉ាង ឈ្មោះថា **រមែងកាន់យកនិមិត្តផងដែរ** ដូច្នេះ ពាក្យនោះ រមែងខុសអំពីពាក្យជាដើមថា **ញាណមិនជួបនូវការកើតឡើង** ដូច្នេះជាដើម ។ ព្រោះថា កាលការបែកគ្នាមិនមាន ការវិកប្បគឺបែកគ្នា មិនត្រូវមានឡើយ ។ ញាណ ឈ្មោះថា **មិនជួប** ព្រោះការមិនកាន់យក ។ លោកអាចារ្យពោលថា **សតិចុះស៊ប់នៅតែក្នុងការអស់ ការសូន្យ ការបែកធ្លាយ ការរលត់ប៉ុណ្ណោះ** ដូច្នេះ ដើម្បីចៀសវាងនូវពាក្យសួរថា **ញាណមិនជួបអ្វី** ។ ក្នុងពាក្យនោះ សព្ទថា **និរោធ** រមែងប្រាកដក្នុងអត្ថថា ការមិនកើតឡើង ព្រោះហេតុនោះ ទើបលោកធ្វើឲ្យផ្សេងទុកដោយសព្ទថា **ភេទ** ( ការបែក ) សព្ទថា **ភេទ** ជាពាក្យប្រាប់ដ៏វិសេស ( ភាពផ្សេង ) ក៏មាន ព្រោះហេតុនោះ ទើបលោកធ្វើឲ្យផ្សេងទុកដោយសព្ទថា **វយ** ( ការសូន្យ ) សព្ទថា **វយ** នោះ ជាពាក្យប្រាប់ដល់អត្ថថា រលត់ក៏មាន ព្រោះហេតុនោះ ទើបលោកធ្វើឲ្យផ្សេងទុកដោយសព្ទថា **ខយ** ( ការអស់ទៅ ) សួរថា ក្នុងការអស់ទៅមួយជួរខណៈ ពោល គឺការអស់ ការសូន្យ ការបែក និងការរលត់ ។ ពាក្យថា **សតិតាំងនៅ** លោកអាចារ្យពោលដល់ញាណដោយសព្ទដែលជាប្រធាន គឺសតិ ។ ពាក្យថា **ក្នុងឋានៈនេះ** គឺក្នុង កាលដែលឧទយព្វយញ្ញាណ ដែលផុតអំពីឧបក្កិលេស លែងចោលនូវការកើតឡើង ដោយន័យដែលពោលមកហើយ មនសិការតែការសូន្យទៅតែម្យ៉ាងក្នុងការដល់នូវភាវៈដែលមុតស្រួច ។

បទថា **អារម្មណបដិសង្ខា** សេចក្តីថា ពិចារណាអារម្មណ៍ មានរូប និងវេទនាជាដើម ដោយអំណាចការអស់ទៅ និងការសូន្យទៅនោះឯង ។ លោកសម្តែងទុកដោយការលុប **យ** អក្ខរៈ ដូចក្នុងពាក្យថា **សយំ អភិញ្ញា** ជាដើម ។ ម្យ៉ាងទៀត ពិចារណាអារម្មណ៍តាមដែលពោលហើយ ដោយអំណាចការអស់ទៅ ការសូន្យទៅ និងការបែកធ្លាយទៅ ឈ្មោះថា **អារម្មណបដិសង្ខា** ប្រែថា ពិចារណាអារម្មណ៍ ។ បទថា **ភង្គានុបស្សនេ** សេចក្តីថា ការបែកធ្លាយនៃចិត្ត ដែលមានរូប និងវេទនាជាដើមជាអារម្មណ៍ណា ក្នុងការតាមឃើញតែការបែកធ្លាយនោះ ។ ការដឹងដោយប្រការ ឈ្មោះថា **បញ្ញា** ។ ពាក្យណាគប្បីពោលក្នុងទីនេះ ពាក្យនោះ កំពុងពណ៌នានាឥឡូវនេះ នោះឯង ។

លោកអាចារ្យពោលដល់សង្ខារទាំងពួង ដែលកាន់យកដោយការៈ ដែលគប្បីឃើញច្បាស់ថា រូប រហូតដល់ជរាមរណៈថា **នូវអារម្មណ៍ឯណានីមួយ** ។ ការដឹងឈ្មោះថា **ការពិចារណា** ហើយការដឹងនោះក៏គឺការឃើញដោយការបែកធ្លាយនោះឯង ព្រោះលោកបំណងយកភង្គានុបស្សនា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សេចក្តីថា ដឹងហើយ គឺឃើញហើយ ដោយការអស់ ដោយការសូន្យ** ដូច្នេះ។ ភ្ជាប់សេចក្តីបាលីថា **តស្ស ញាណស្ស** នៃការដឹងនោះ ។

លោកអាចារ្យពោលថា **រូបារម្មណំ ចិត្តំ** ដូច្នេះ ដើម្បីនឹងសម្តែងអត្ថនេះថា **រូបារម្មណំ** នោះឯង ជា **រូបារម្មណតា** ដូចពាក្យថា **ទេវោ** នោះឯង ជា **ទេវតា** ។ លោកអាចារ្យកាលនឹងសម្តែងថា ម្យ៉ាងទៀត ក្នុងបទថា **រូបារម្មណតា** ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ទើបពោលថា **អថ វា រូបារម្មណភាវេ** ។ លោកអាចារ្យពោលដល់ភង្គានុបស្សនា ដែលមានវិបស្សនាជាវិស័យថា **ភិក្ខុរមែងតាមឃើញការបែកធ្លាយដោយចិត្ត ១ ដួងទៀត** ។ ឯភង្គានុបស្សនា រមែងជាធម្មជាតិស្ទាត់ជំនាញ

ហើយ ដោយអាការយ៉ាងនេះ ហើយអារម្មណ៍ក៏រមែងជាធម្មជាតិជាក់ច្បាស់ក្រៃលែងប្រាកដដល់ព្រះយោគីនោះ ។ លោកអាចារ្យពោលដល់អារម្មណ៍ថា **វត្ថុដែលត្រូវដឹង** ព្រោះជាវត្ថុដែលត្រូវដឹង ដោយអំណាចនៃការតាមឃើញ ។ ពោលដល់អនុបស្សនាញាណថា **ជាគ្រឿងដឹង** ។ ពាក្យថា **រមែងឃើញច្បាស់ទាំង ២ យ៉ាង** គឺរមែងឃើញច្បាស់ទាំងវត្ថុដែលត្រូវដឹង និងធាតុដឹងទាំង ២ នោះ ដោយការអស់ទៅ ដោយការសូន្យទៅ ដូច្នេះ ។ ឯសេចក្តីសង្ខេបក្នុងទីនេះ មានដូច្នេះ

បញ្ញាទី ២ គឺការឃើញរូប ដោយការអស់ទៅ ដោយការសូន្យទៅ រហូតដល់ជរា និងមរណៈ ឈ្មោះថា **ការពិចារណាអារម្មណ៍** ការឃើញញាណ ធាតុដែលឃើញដោយការអស់ទៅ ដោយការសូន្យទៅ ឈ្មោះថា **ការពិចារណាអារម្មណ៍ ឃើញការបែកធ្លាយ** ។ ម្យ៉ាងទៀត បញ្ញាប្រការក្រោយប៉ុណ្ណោះឯង ជាវិបស្សនាញាណ ព្រោះបន្ថែមបញ្ញាដំបូងចូលក្នុងបញ្ញាក្រោយ ។ ព្រោះកាលបញ្ញាដំបូងនោះ មិនមានបញ្ញាក្រោយក៏មិនមាន ដូច្នេះឯង ។

បទថា **ឯត្ថ** សេចក្តីថា ក្នុងពាក្យនេះថា **រមែងតាមឃើញការបែកធ្លាយ ។បេ។ របស់ចិត្តនោះ** ។ ពាក្យថា **ដោយអាការច្រើនយ៉ាង** គឺដោយអាការច្រើនយ៉ាង មានការតាមឃើញដោយជារបស់មិនទៀងជាដើម ។ **អនុ-ស័ព្ទ** រមែងប្រព្រឹត្តទៅ ក្នុងអត្ថនេះថា **កិយ្យោ** ដោយក្រៃលែង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បុនប្បុនំ បស្សតិ** ឃើញរឿយៗ ។

ឈ្មោះថា **សង្ខតធម៌ក្នុងទីនេះ** មានការកើត ការចាស់ និងការស្លាប់ជាប្រក្រតី សង្ខតធម៌នោះមានការកើតជាចំណុចខាងដើម ការចាស់ជាចំណុចកណ្តាល ការស្លាប់ជាចំណុចខាងចុង ។ ក្នុងប្រការនោះ វត្ថុទាំង ៣ ប្រការ មានការកើតឡើងជាដើម ឈ្មោះថា **អនិច្ចលក្ខណៈ** ព្រោះជាលក្ខណៈរបស់វត្ថុដែលត្រូវបច្ច័យតាក់តែងឡើង

ក៏ពិត សូម្បីយ៉ាងនោះ កាលបានឃើញការកើត និងការចាស់ហើយ អនិច្ចលក្ខណៈ ក៏មិនជាធម្មជាតិប្រាកដជាក់ច្បាស់ ដូចក្នុងខណៈសូន្យទៅឡើយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ឈ្មោះថា ការបែកធ្លាយ រមែងជាចំណុចចុងបំផុតនៃអនិច្ចតា** ។ សេចក្តីថា ជាចំណុចខាងចុង គឺជាចំណុច ចុងបញ្ចប់ ។ ដូចជាវត្ថុដែលមានការចាស់ជាធម្មតា និងមានការស្លាប់ជាធម្មតានោះឯង រមែងកើត ព្រោះហេតុនោះ **ជាតិ** ទើបជាចំណុចខាងដើមរបស់អនិច្ចតា យ៉ាងណា វត្ថុដែលមានការកើតជាធម្មតា និងមានការស្លាប់ជាធម្មតានោះឯង រមែងចាស់ទៅ ព្រោះហេតុនោះ **ការចាស់** ទើបជាចំណុចកណ្តាល វត្ថុដែលមានការកើតជាធម្មតា និងមានការចាស់ជាធម្មតានោះឯង រមែងបែកធ្លាយទៅ ព្រោះហេតុនោះ **ការបែកធ្លាយ** ទើបជាចំណុចចុងបំផុត ក៏ដូច្នោះឯង ។ ពាក្យថា **រមែងតាមឃើញដោយភាពមិនទៀង** សេចក្តីថា មិនមែនតាមឃើញដោយអំណាចការអនុមាន ( ដៅស្មាន ) ថា ឈ្មោះថា **មិនទៀងដោយអត្ថថា អស់ទៅ** ដូចជាពិចារណាដោយកលាបៈ ទាំងមិនមែនតាមឃើញដោយអំណាចការឃើញការសូន្យទៅ ដែលមានការប្រកាន់យកការកើតឡើងជាខាងដើម ដូចជាព្រះយោគាវចរដែលផ្តើមធ្វើវិបស្សនា ដោយពិតនោះ រមែងតាមឃើញដោយភាពមិនទៀង ដោយអំណាចការឃើញការបែកធ្លាយតែម្យ៉ាង អនុលោមតាមការកើតឡើង តាមន័យដែលពោល ហើយក្នុងការកើតឡើង និងការសូន្យទៅ ដែលប្រាកដហើយដោយប្រចក្ស ដោយអានុភាពនៃឧទយព្វយញ្ញាណ កាលព្រះយោគាវចរនោះតាមឃើញយ៉ាងនេះ ការប្រកាន់ថា ទៀង រមែងមិនមាន សូម្បីតែបន្តិចបន្តួច ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **នោ និច្ចតោ** ដោយការមិនទៀង ។ ពិតហើយព្រះយោគាវចរនេះ លោកហៅថា **រមែងលះនិច្ចសញ្ញា** ។ ក្នុងទីនេះ **ឯវ** អក្ខរៈក្នុងពាក្យថា **អនិច្ចតោ ឯវ អនុបស្សតិ** សម្តែងថា ត្រូវលុបទៅ ព្រោះហេតុនោះ

ដើម្បីនឹងសម្ដែងអត្ថដែលបដិសេធទុកដោយ ឯវ អក្ខរៈនោះ ទើបលោកអាចារ្យពោលថា **នោ និច្ចតោ** មិនមែនដោយការទៀង ក្នុងទីនេះ បណ្ឌិតមិនត្រូវសង្ស័យការបដិសេធ ការតាមឃើញដោយជាទុក្ខជាដើម ព្រោះមានការបដិសេធ ដែលមានការប្រកប ចំពោះទុកជាខាងមុខ និងព្រោះការតាមឃើញទាំងនោះ បានលើកយក **ឯវ** អក្ខរៈ ឡើងកាន់ទេសនាទុកខាងមុខ សូម្បីក្នុងពាក្យទាំងឡាយថា **ទុក្ខតោ អនុបស្សតិ** ជាដើម ក៏មានន័យនេះ ។

លោកអាចារ្យពោលថា **ព្រោះវត្ថុដែលមិនទៀង ក៏ជាទុក្ខ** ដូច្នេះជាដើម ដើម្បីនឹងចៀសវាងនូវពាក្យសួរថា ការតាមឃើញដោយជារបស់មិនទៀង សមគួរដល់ព្រះយោគាវចរដែលជាកង្ខានុបស្សកៈមុនថា **ឯការបែកធ្លាយ រមែងជាខាងចុងនៃអនិច្ចតា** ដូច្នេះ ឯការតាមឃើញជាទុក្ខជាដើម នឹងសមគួរដូចម្ដេច ។ ដោយហេតុនេះ របស់ណាមិនទៀង របស់នោះក៏ជាទុក្ខ ជាអនត្តា ដោយចំណែកមួយ ។ ព្រោះហេតុនោះឯង ទើបជារបស់ដែលមិនគួរត្រេកអរជាដើម ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រះយោគាវចររមែងតាមឃើញ ដោយអំណាចអនុបស្សនាទាំង ៦ ក្រៅអំពីនេះ ដើម្បីនឹងបរិកម្មញ្ញាណ ព្រោះនឹងត្រូវធ្វើឲ្យកើតឡើងតទៅ ។ ក្នុងអធិការនេះ អាចារ្យពួកខ្លះរមែងពោលពាក្យជាដើមថា **រមែងតាមឃើញដោយជារបស់មិនទៀង មិនមែនដោយការទៀង** ដូច្នេះ មិនមានកិច្ចដោយការឃើញជាផ្នែកមួយ ដោយការឃើញការបែកធ្លាយប៉ុណ្ណោះ រមែងឃើញគ្រប់យ៉ាង ដូច្នេះ ពាក្យរបស់អាចារ្យពួកខ្លះនោះត្រឹមត្រូវ ក្នុងការដល់លំដាប់កំពូល នៃកង្ខានុបស្សនា តែក្នុងខាងដើមអំពីនោះ ចាំបាច់តាមឃើញនូវការលាយឡំដោយអាការដ៏ច្រើន ។ កាលកាន់យកសេចក្ដីដោយប្រការដទៃ ព្រះបាលីជាដើមថា **រមែងតាមឃើញដោយជារបស់មិនទៀង** និងអដ្ឋកថានៃព្រះបាលីនោះ ដែលមកហើយថា **រមែងឃើញរឿយៗ ដោយអាការមិនមែនតិច**

ដូច្នេះ ក៏គប្បីខុសទៅ ។ សង្ខារទាំងពួង យោគាវចរឃើញហើយ ដោយជារបស់មិនទៀង នោះឯង ។

ពាក្យថា **វត្ថុនោះ មិនគប្បីត្រេកអរ** សេចក្តីថា វត្ថុនោះ បានដល់ សង្ខារមិនគប្បីត្រេកអរថា **នុ៎ះរបស់អញ នុ៎ះអត្តារបស់អញ** ដូច្នេះ ដោយអំណាចការត្រេកអរ គឺតណ្ហា និងទិដ្ឋិ ។ពាក្យថា **មិនគប្បីមានតម្រេកក្នុងវត្ថុនោះ** សេចក្តីថា មិនគប្បីប្រព្រឹត្តទៅដោយអំណាចការត្រេកត្រអាល អធិប្បាយថា មិនគប្បីញុំាងកាមរាគៈ ឬភវរាគៈឲ្យប្រព្រឹត្តទៅក្នុងវត្ថុនោះ គឺក្នុងសង្ខារ ។ ពាក្យថា **ញុំាងរាគៈឲ្យរលត់** គឺញុំាងរាគៈឲ្យដល់នូវការរលត់ គឺសង្កត់ទុក អធិប្បាយថា សង្កត់រាគៈទុក ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយញាណដែលជាលោកិយនោះឯងមុន** ។ លោកអាចារ្យពោលថា **មិនមែនឲ្យកើត គឺមិនធ្វើឲ្យកើតសមុទយៈឡើង** ដូច្នេះ ដើម្បីចៀសវាងពាក្យសួរថា **កាលមានការសង្កត់ទុកនឹងកើតឡើងបាន ដូចម្តេច** ។

ពាក្យថា **លោកជាបុគ្គលប្រាសចាកតម្រេកយ៉ាងនោះ** គឺជាបុគ្គលប្រាសចាកតម្រេកយ៉ាងនោះ បានដល់ តាមគន្លងនៃភង្គានុបស្សនា ។ លោកញុំាងសង្ខារដែលឃើញហើយ គឺដែលប្រាកដក្នុងឥឡូវនេះឲ្យរលត់ គឺធ្វើមនសិការតែការរលត់ យ៉ាងណា ក៏ញុំាងសង្ខារដែលមិនបានឃើញ គឺដែលជាអតីត និងអនាគតឲ្យរលត់ដោយអំណាចអព្វយញ្ញាណ កាលអនុមានថា សង្ខារក្រៅអំពីនេះក៏រលត់ទៅ ដូចសង្ខារក្នុងបច្ចុប្បន្ន ដូច្នេះ គឺរមែងធ្វើការរលត់នៃសង្ខារ ដែលបានធ្វើមនសិការហើយ ។ សូម្បីក្នុងពាក្យថា **មិនមែនឲ្យកើតឡើង** នេះ ក៏មានន័យនេះដូចគ្នា អធិប្បាយថា មិនធ្វើមនសិការការ កើតឡើង ។

ពាក្យថា **លោកបដិបត្តិបានយ៉ាងនោះហើយ** សេចក្តីថា បដិបត្តិបានយ៉ាងនោះ គឺដោយអំណាចអនិច្ចានុបស្សនាជាដើម ដោយប្រការដែលបានពោលហើយ។

ច្រើនបទថា **សទ្ធឹ ខន្ធាភិសង្ខារេហិ កិលេសានំ បរិច្ចជនតោ** សេចក្តីថា ព្រោះលះបង់កិលេសទាំងឡាយ ព្រមទាំងខន្ធ និងអភិសង្ខារ ។ កាលលះកិលេសទាំងឡាយបាន ឈ្មោះថា **រមែងលះកម្មដែលមានកិលេសនោះជាហេតុ** និងខន្ធទាំងឡាយដែលកើតឡើងអំពីកម្មនោះ ។ ពាក្យថា **ដោយការឃើញទោសក្នុងសង្ខតធម៌** បានដល់ ដោយការឃើញទោស មានជារបស់មិនទៀង និងជាទុក្ខ ក្នុងសង្ខតធម៌ទាំងឡាយ ។ ពាក្យថា **ដែលផ្ទុយជាមួយសង្ខតធម៌នោះ** គឺមានសភាពទៀង និងជាសុខជាដើម ។ បទថា **តន្និន្នតាយ** ប្រែថា ដោយកិរិយាដែលបង្អោនទៅក្នុងនិព្វាននោះ ។ លោកអាចារ្យពោលបដិនិស្សគ្គមានអត្ថ ២ យ៉ាងថា **បដិស្សគ្គ**-ស័ព្ទ មានអត្ថថា **បរិច្ចាគ** ប្រែថា លះបង់ និងមានអត្ថថា **បក្ខន្ទន** ប្រែថា ស្ទុះទៅ ។ ក្នុងអត្ថ ២ យ៉ាងនោះ **បក្ខន្ទន** ក៏គឺការបង្អោនទៅ ។ បទថា **យថាវុត្តេន** សេចក្តីថា មានប្រការនៃបហាន មានតទង្គប្បហានជាដើម និងមានការបង្អោនទៅក្នុងនិព្វាននោះ ។ ពាក្យថា **និព្វត្តនវសេន** ប្រែថា ដោយអំណាចធ្វើឲ្យកិលេសកើតឡើង ។ ឯបុគ្គលកាលធ្វើកិលេសឲ្យកើតឡើង រមែងប្រកាន់យកកិលេសទាំងឡាយទុក ព្រោះហេតុនោះ កាលមិនធ្វើកិលេសទាំងនោះឲ្យកើតឡើង ទើបឈ្មោះថា មិនប្រកាន់យកកិលេសទាំងឡាយទុក ។ បទថា **អទោសទស្សិតាវសេន** ប្រែថា ដោយមិនឃើញទោស ។ មានពាក្យប្រកបថា រមែងប្រកាន់យកអារម្មណ៍ដែលជាសង្ខតធម៌ទុក ។ បុគ្គលរមែងប្រកាន់យកសង្ខារទាំងឡាយទុកដោយភាពជាបុគ្គលឃើញទោស ព្រោះហេតុនោះ ទើបភិក្ខុមិនកាន់យក គឺមិនកាន់យកសង្ខារទាំងនោះដោយជាបុគ្គលមិនឃើញទោស ។

បទថា **អស្ស យោគ យោគិនោ** ប្រែថា ដល់ព្រះយោគីនោះ ។ ពាក្យថា **ដោយញាណទាំងនោះ** គឺដោយញាណ មានអនិច្ចានុបស្សនាជាដើម ។ បទថា **តំ យោគ បហានំ** ប្រែថា ការលះនោះ ។ ពាក្យថា **អនិច្ចសញ្ញា** បានដល់ ប្រកាន់មាំ

លោកនិទ្ទេសទុក ដោយលើកយកសញ្ញាជាប្រធាន ។ សូម្បីក្នុងពាក្យថា **សុខសញ្ញា អត្តសញ្ញា** នេះ ក៏មានន័យនេះឯង ។ ពាក្យថា **តណ្ហាដែលប្រព្រឹត្តទៅជាមួយបីតិ** បានដល់ ការប្រាថ្នាក្រៃលែង ព្រមទាំងការរំភើបញាប់ញ័រ ។ លោកអាចារ្យកាលសម្តែងថា ក្នុងបទថា **វត្ថុសង្កមនា** រំកិលវត្ថុនេះ អារម្មណ៍ មានរូបជាដើម លោកមានបំណងយក **វត្ថុ** ព្រោះជាទីតាំងនៃការប្រព្រឹត្តទៅរបស់វិបស្សនា ។ ទើបពោលពាក្យជាដើមថា **នៃរូប** ដូច្នេះ ។ ក្នុងពាក្យនោះ បទថា **សង្កមនា** ការរំកិល លោកពោលទុកដោយន័យតែម្យ៉ាង ព្រោះជាវិបស្សនាស្មើគ្នា កាលកាន់យកអត្ថដោយប្រការដទៃ ញាណដែលមានការរលត់នៃរូបជាវិស័យ ក៏ម្យ៉ាង ញាណដែលមានការរលត់នៃចិត្តដែលមានអារម្មណ៍នោះជាវិស័យ ក៏ម្យ៉ាង ព្រោះហេតុនោះ ការរំកិលនឹងមានមកអំពីណា ។ សូម្បីក្នុងសញ្ញាវិវដ្តនា គឺការប្តូរសញ្ញា ក៏មានន័យនេះដូចគ្នា ។ ពាក្យថា **សញ្ញា** បានដល់ សញ្ញាក្នុងវិបស្សនា ដែលប្រព្រឹត្តទៅដោយអំណាចការឃើញការកើតឡើង និងការវិនាសទៅ ។ ការប្តូរអំពីភាពកើតឡើង ក៏ដោយអំណាចការទាញយកតែការសូន្យទៅតែម្យ៉ាង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា គឺ **ការពិចារណាតែម្ខាងកើតឡើង តាំងនៅតែក្នុងខាងការវិនាស** ដូច្នេះ ។ ដោយពាក្យថា **ការអាចក្នុងការនឹកការរក ( អារម្មណ៍ ) មិនជាចរយៈ** នេះ លោកអាចារ្យពោលដល់កង្ខានុបស្សនា ជាធម្មជាតិស្ទាត់ជំនាញ មានកម្លាំង ។

បទថា **ឧភោ** ប្រែថា អារម្មណ៍ទាំង ២ ចំណែក ដោយជាអារម្មណ៍ដែលឃើញហើយ និងដែលមិនបានឃើញ ។ បទថា **ឯកវវត្ថនា** ការពិចារណាដែលកំណត់ថាមានសភាពដូចគ្នា គឺការពិចារណាដែលកំណត់អារម្មណ៍ថា **ស្មើគ្នា** ដោយភាពជាសភាវៈ មានការបែកធ្លាយទៅគ្រប់ខណៈ ។

ពាក្យថា **ក្នុងសង្ខារដែលមាន** គឺក្នុងសង្ខារដែលជាបច្ចុប្បន្ន ដែលបានដោយ

ប្រេចក្ស ។ ពាក្យថា **ដែលមានការឃើញបរិសុទ្ធហើយ** គឺដែលមានញាណបរិសុទ្ធ អធិប្បាយថា បុគ្គលមានការឃើញការបែកធ្លាយបរិសុទ្ធល្អ ដោយការកម្ចាត់បង់បាន នូវការរារាំងការឃើញការបែកធ្លាយ ។ ពាក្យថា **នាំការឃើញតាមបែបការឃើញនោះទៅ** សេចក្តីថា ញ៉ាំងញាណតាមបែប គឺទៅតាមញាណនោះ ដែលឃើញការបែកធ្លាយនៃសង្ខារបច្ចុប្បន្នឲ្យប្រព្រឹត្តទៅ ។ លោកអាចារ្យពោលថា **ក្នុងសង្ខារដែលជាអតីត និងអនាគត** ដូច្នេះ ដើម្បីចៀសវាងពាក្យសួរថា ក៏ឲ្យប្រព្រឹត្តទៅក្នុងទីណាវិញ ។ បទថា **អតីតានាគតេ** ប្រែថា ក្នុងសង្ខារដែលជាអតីត និងអនាគត ។ ពាក្យថា **សង្ខារទាំងពួង** ជាដើម ជាពាក្យសម្តែងអាការដែលនឹងញ៉ាំងញាណឲ្យប្រព្រឹត្តទៅរបស់យោគាវចរនោះ ។

**ក្នុងការរលត់ ពោល គឺការបែកធ្លាយ** អធិប្បាយថា មិនមែនពោល គឺនិព្វាន ។ ពាក្យថា **នោះ** សេចក្តីថា ការពិចារណាកំណត់សង្ខារទាំង ២ ដែលបានឃើញ និងមិនបានឃើញដោយអនុលោមតាមអារម្មណ៍ ដោយជាសភាវៈដូចគ្នា ព្រោះមានការបែកធ្លាយទៅគ្រប់ខណៈ យ៉ាងណា នោះជា **ការឃើញច្បាស់** លក្ខណៈសូន្យទៅលក្ខណៈប្រែប្រួលទៅ ឈ្មោះថា **កង្ខានុបស្សនា** ។

ពាក្យថា **អារម្មណញ្ច បដិសង្ខា** ពិចារណាអារម្មណ៍ជាដើម ជាពាក្យធ្វើអត្ថដែលបានពោលហើយនោះឯងឲ្យមាំទាំ ព្រោះកង្ខានុបស្សនាជារឿងដែលចាក់ធ្លុះបានលំបាក ។ លោកអាចារ្យកាលសម្តែងកង្ខានុបស្សនានោះថា ការឃើញការបែកធ្លាយនេះ ក៏ដើម្បីការចាក់ធ្លុះអនត្តលក្ខណៈ ដោយការឈោងចុះក្នុងការដឹងថា សង្ខារទាំងឡាយមិនប្រព្រឹត្តទៅក្នុងអំណាច ទើបពោលថា **សុញ្ញតោ ច ឧបដ្ឋានំ** ការប្រាកដដោយការសោះសូន្យ (មានឡើង) ផង ដូច្នេះ ។ កាលព្រះយោគីនោះតាមឃើញការបែកធ្លាយនៃអារម្មណ៍ និងនៃចិត្តដែលមានការបែកធ្លាយជាអារម្មណ៍ សង្ខារទាំងឡាយ

រមែងប្រាកដជារបស់សោះសូន្យ ដោយពិសេស ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **កាលលោកតាមឃើញការបែកធ្លាយនៃសង្ខារនោះយ៉ាងនោះ** ដូច្នេះ ។

ក្នុងពាក្យថា **វត្ថុដទៃមិនមានឡើយ** នេះ សេចក្តីថា វត្ថុដទៃឈ្មោះថា **អត្តាផុតទៅអំពីខន្ធណាមួយមិនមានឡើយ ក្នុងលោកនេះ** ។ ពាក្យថា **រមែងឃើញការអស់ទៅនៃខន្ធទាំងឡាយនោះ** សេចក្តីថា រមែងឃើញការបែកធ្លាយដែលប្រាកដគ្រប់ៗ ខណៈនៃធម៌ទាំងនោះ ។ ឈ្មោះថា **បុគ្គលមិនប្រមាទ** ព្រោះការបដិបត្តិអប្បមាទធម៌ តាមដែលពោលហើយ ។ សេចក្តីនេះដូចម្តេច ? **ដូចបុគ្គលចោះកែវដោយពេជ្រ ដោយឧបាយ** ។ អធិប្បាយថា បុរសអ្នកឈ្លាស កាលចោះកែវដោយឧបាយ រមែងមើល គឺដាក់ចិត្តចំពោះប្រហោងរបស់កែវប៉ុណ្ណោះ មិនមើល គឺដាក់ចិត្តត្រង់ពណ៌ជាដើមរបស់កែវឡើយ យ៉ាងណា ព្រះយោគាវចរ ក៏រមែងធ្វើមនសិការដោយឧបាយ ដល់នូវការបែកធ្លាយមិនដាច់រយៈនៃសង្ខារទាំងឡាយប៉ុណ្ណោះ ។មិនធ្វើមនសិការក្នុងសង្ខារទាំងឡាយឡើយ ក៏ដូច្នោះ ។ម្យ៉ាងទៀត កាលប្រើពេជ្រចោះកែវត្រង់ទីដែលចោះហើយ រមែងមិនដុះឡើងវិញ យ៉ាងណា កាលព្រះយោគាវចរបានឃើញការបែកធ្លាយដោយភង្គានុបស្សនាញាណ ដែលដូចគ្នានឹងពេជ្រ ក៏ប្រកាន់យកថា ទៀង រមែងមិនដុះឡើងទៀត ក៏ដូចគ្នាដូច្នោះ អធិប្បាយថា ព្រះយោគាវចររមែងឃើញតែការបែកធ្លាយប៉ុណ្ណោះ យ៉ាងនេះ ។

ពីរបទថា **យា ច អារម្មណបដិសង្ខា ការពិចារណា ( ដឹង ) អារម្មណ៍ឯណាផង** សេចក្តីថា ការពិចារណាដឹងអារម្មណ៍ឯណា ដែលមកហើយយ៉ាងនេះថា **ចិត្តមានរូបជាអារម្មណ៍កើតឡើងហើយ រមែងបែកធ្លាយទៅ យោគាវចរពិចារណាដឹងអារម្មណ៍នោះ** ដូច្នេះផង **ភង្គានុបស្សនាឯណា** ដែលលោកពោលទុកយ៉ាងនេះ

ថា **រមែងតាមឃើញការរលត់ទៅនៃចិត្តនោះ** ដូច្នេះផង **ការប្រាកដដោយជារបស់សោះសូន្យឯណា** ដែលលោកពោលទុកយ៉ាងនេះថា **សង្ខារទាំងឡាយនោះឯងបែកធ្លាយ ការបែកធ្លាយនៃសង្ខារទាំងឡាយនោះ ហៅថា ការស្លាប់ មិនមានអ្វីដទៃៗ ឡើយ** ដូច្នេះផង សរុបទាំង ៣ ប្រការដែលពោលមកយ៉ាងនេះ ឈ្មោះថា **អធិប្បញ្ញាវិបស្សនា** ។

ពាក្យថា **ក្នុងអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម** បានដល់ ក្នុងអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ។ ពាក្យថា **ក្នុងវិបស្សនាមាន និព្វិទានុបស្សនា** ជាដើម បានដល់ ក្នុងនិព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា និងបដិនិស្សគ្គានុបស្សនា ។ ពាក្យថា **ក្នុងឧបដ្ឋាន ៣** គឺក្នុងឧបដ្ឋាន ៣ យ៉ាង ដោយអំណាចការប្រាកដជារបស់មិនទៀងជាដើម ។ ឯការប្រាកដដោយការអស់ទៅ ដោយការសូន្យទៅ ជាការប្រាកដជារបស់មិនទៀង ការប្រាកដជារបស់គួរខ្លាច ជាការប្រាកដជាទុក្ខ ការប្រាកដជារបស់សោះសូន្យ ជាការប្រាកដជាអនត្តា ដូច្នេះឯង ។ ពាក្យថា **ក្នុងទិដ្ឋិទាំងឡាយ** គឺ **រមែងមិនញាប់ញ័រ** ព្រោះទិដ្ឋិជាហេតុ ។ ពិតហើយ ព្រះយោគាវចររមែងមិនញាប់ញ័រ ព្រោះជាបុគ្គលមិនវៀចដោយទិដ្ឋិទាំងនោះ ។

បទថា **ទុព្វលភាជនស្ស វិយ** ក្លាប់សេចក្តីថា ដូចមើលការបែកតែម្យ៉ាងនៃភាជនៈដីឆៅ ដែលកំពុងសើម ។ ឯក្នុងអធិការនេះ **ឧបមាដោយភាជនៈចាស់ៗ** គប្បីឃើញថា ដើម្បីនឹងសម្តែងដល់សង្ខារ មានការបែកធ្លាយទៅដោយសភាវៈ **ឧបមាដោយធូលីល្អិត** ដែលបុគ្គលបាចសាច គប្បីឃើញថា កាលនឹងសម្តែងសង្ខារទាំងឡាយ មិនមានការសម្ពន្ធគ្នានឹងគ្នា **ឧបមាដូចគ្រាប់ល្ងបុគ្គលដែលកំពុងលីង** គប្បីឃើញថា ដើម្បីសម្តែងសង្ខារ មានការបែកទៅគ្រប់ៗ ខណៈ ។ ពាក្យថា

ការបែកតែម្យ៉ាង សេចក្តីថា **មើល** តែការវិនាសតែម្យ៉ាង ព្រោះមិនកាន់យកការកើតឡើងជាដើម ។ បទថា **ឯវមេវ** សេចក្តីថា ព្រះយោគាវចររមែងឃើញការបែកធ្លាយតែម្យ៉ាងថា ពពុះទឹកទាំងឡាយ អាស្រ័យបច្ច័យ មានផ្ទៃទឹកជាដើមកើតឡើងហើយ មិនមានការតាំងនៅបានយូរ រមែងបែកធ្លាយទៅយ៉ាងរហ័ស យ៉ាងណា រូបធម៌ និងអរូបធម៌ទាំងឡាយ អាស្រ័យបច្ច័យ មានកម្មជាដើមកើតឡើងហើយ មានការតាំងនៅមួយជួរខណៈ រមែងបែកធ្លាយទៅយ៉ាងរហ័ស ដូច្នោះ ។ លោកពោលពាក្យដដែលថា **ភិជ្ជន្តិ ភិជ្ជន្តិ** កំពុងបែកៗ ដូច្នេះ ដើម្បីសម្តែងដល់ការបែកធ្លាយនៃសង្ខារទាំងនោះភ្លាមៗ ។

ថ្ងៃបណ្តើរកូន ក៏នៅបានមួយជួរកាលតិចតួចប៉ុណ្ណោះ តែការប្រាកដបានយូរក្រៃលែងដោយអំណាចការទាក់ទងរបស់ទីអាស្រ័យ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ដូចជាមើលថ្ងៃបណ្តើរកូន** ដូច្នេះ មិនបានត្រាស់ព្រោះការប្រាកដជារបស់មិនពិត ។ ពាក្យថា **លោក** បានដល់ ខន្ធលោក ។ **មច្ចុរាជ ឈ្មោះថារកខ្លួនមិនឃើញ** ព្រោះមិនមានភពថ្មី ដោយការសម្រេចអរហត្តផល ។

ពាក្យថា **ការលះភវទិដ្ឋិបាន** គឺការសង្កត់សស្សតទិដ្ឋិបាន ។ កាលឃើញតែការរលត់តែម្យ៉ាងនៃសង្ខារទាំងឡាយមិនដាច់រយៈ សស្សតទិដ្ឋិក៏មិនមានឱកាស ។ ព្រោះហេតុនោះឯង **ក៏មានការលះបង់ការជាប់ជំពាក់ក្នុងជីវិតបាន** ព្រោះមិនមានអាល័យក្នុងជីវិត ។ ពាក្យថា **គ្រប់កាល** គឺគ្រប់កាលទាំងពួង បានដល ទាំងថ្ងៃ និងយប់ ។ **មានការប្រកបហើយ ក្រវល់ក្រវាយហើយ** ដោយភាវនា ។ ឈ្មោះថា **ការមានអាជីវៈបរិសុទ្ធ** ព្រោះប្រព្រឹត្តទៅដោយការចង់បានក្នុងទីឆ្ងាយ ។ **ការលះសេចក្តីក្រវល់ក្រវាយ** បានដល់ ដែលមិនខ្វល់ខ្វាយក្នុងកិច្ចតូច-ធំ ព្រោះជាបុគ្គលមានការសង្វេគយ៉ាងខ្លាំងក្លា ។ **ភាពជាបុគ្គលប្រាសចាកការខ្លាច** បានដល់ ភាពជាអ្នកមិនខ្លាច

ក្នុងទីណាមួយ ព្រោះមិនមានសិនេហៈក្នុងខ្លួន ។ **ការបានចំពោះនូវខន្តិ និងសោរច្ចៈ** ព្រោះជាអ្នកឃើញល្អហើយនូវសង្ខារជារបស់មិនទៀង ។ **ការអត់សង្កត់នូវការមិនត្រេកអរ និងការត្រេកអរ** ព្រោះការអត់សង្កត់ គឺការគ្របសង្កត់ការមិនត្រេកអរក្នុងសេនាសនៈដ៏ស្ងាត់ និងក្នុងអធិកុសលទាំងឡាយ និងព្រោះអត់សង្កត់ គឺគ្របសង្កត់សេចក្ដីត្រេកអរក្នុងកាមគុណទាំងឡាយ ។

ពីរបទថា **ឥមានិ អដ្ឋគុណមុត្តមានិ** លោកពោលទុកដោយលិង្គវិបល្លាស ។ ឯ **ម** អក្ខរៈ ធ្វើបទសន្ធិ សេចក្ដីថា អានិសង្សឧត្ដម ៨ ប្រការនេះ មានការលះភវទិដ្ឋិជាដើម ។ បទថា **តហឹ** សេចក្ដីប៉ុនគ្នានឹង **តត្ថ យោគ** ភង្គានុបស្សនាយំ ប្រែថា ក្នុងភង្គានុបស្សនានោះ ។

ភង្គានុបស្សនាញាណ ចប់ ។

# វិសុទ្ធិមគ្គ

## ភយតុបដ្ឋានញ្ញាណ

កាលព្រះយោគាវចរនោះសេពដោយអើពើចម្រើន ធ្វើឲ្យច្រើននូវភង្គានុបស្សនា ដែលមានការអស់ទៅ សូន្យទៅ បែកធ្លាយទៅនៃសង្ខារទាំងពួងជាអារម្មណ៍ យ៉ាងនោះ សង្ខារទាំងឡាយ ដែលកំពុងបែកធ្លាយតាមសភាវៈនៅក្នុងភព កំណើត គតិ ឋិតិ និងសត្តាវាសទាំងពួង រមែងប្រាកដជាវត្ថុគួរខ្លាចយ៉ាងធំ ដូចវត្ថុដែលគួរខ្លាចទាំងឡាយ មានសីហៈ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន យក្ស អារក្សទឹក គោកាច ឆ្កែកាច ដំរីចុះប្រេង ពស់កាច រន្ទះ ព្រៃខ្មោច លានចម្បាំង និងរណ្តៅរងើកភ្លើង ដែលកំពុងឆេះជាដើម រមែងប្រាកដជាវត្ថុគួរខ្លាចក្រៃលែង សម្រាប់បុគ្គលល្ងង់ខ្លៅ ដែលស្រឡាញ់ជីវិតដោយងាយ ( គឺឃើញជារបស់គួរខ្លាច និងគួរខ្លាចងាយៗ ) ដូច្នោះ កាលលោកឃើញថា សង្ខារទាំងឡាយ ដែលជាអតីតក៏រលត់ទៅហើយ ដែលជាបច្ចុប្បន្នក៏កំពុងរលត់ សូម្បីសង្ខារទាំងឡាយដែលនឹងកើតក្នុងអនាគត ក៏នឹងរលត់យ៉ាងនេះដូចគ្នា ដូច្នេះ ញាណ ឈ្មោះថា **ភយតុបដ្ឋានញ្ញាណ** រមែងកើតឡើងក្នុងខណៈ ( គឺក្នុងឱកាស ) នោះ ។

តទៅនេះ ជាឧបមាក្នុងការកើតឡើងនៃភយតុបដ្ឋានញ្ញាណនោះ ឧបមាដូចកូន ៣ នាក់ របស់ស្ត្រីម្នាក់ ធ្វើខុសចំពោះព្រះរាជាៗ ដាក់ព្រះរាជអាជ្ញាកាត់ក្បាល ជនទាំង ៣ នាក់ ស្ត្រីនោះបានទៅកាន់ផ្លូវបែកជា ៤ ព្រមគ្នានឹងកូន ពេលនោះ ពួករាជបុរសកាត់ក្បាលកូនច្បងរបស់គាត់ហើយ ក៏ផ្តើមនឹងកាត់ក្បាលកូនកណ្តាល ស្ត្រីនោះឃើញក្បាលកូនច្បងដាច់ទៅហើយ ក្បាលកូនកណ្តាលកំពុងដាច់ ក៏ដកសេចក្តីអាល័យក្នុងកូនពៅ ដោយឃើញថា សូម្បីកូនពៅនេះក៏នឹងដូចកូន ២ នាក់ នោះដូចគ្នា ។

ក្នុងទស្សនកិច្ចទាំងនោះ ការឃើញការរលត់នៃសង្ខារ ដែលជាអតីតទាំងឡាយ របស់ព្រះយោគី ប្រៀបដូចការឃើញក្បាលដែលដាច់ហើយរបស់កូនច្បងនៃស្ត្រីនោះ ការឃើញការរលត់នៃសង្ខារទាំងឡាយ ដែលជាបច្ចុប្បន្នរបស់ព្រះយោគី ប្រៀបដូចការឃើញក្បាលដែលកំពុងដាច់ របស់បុត្រកណ្ដាលនៃស្ត្រីនោះ ការឃើញការរលត់នៃសង្ខារទាំងឡាយដែលជាអនាគត ដោយឃើញថា **សូម្បីសង្ខារទាំងឡាយ ដែលនឹងកើតក្នុងអនាគត ក៏នឹងរលត់យ៉ាងនេះដូចគ្នា** របស់ព្រះយោគី ដូចការដកអាល័យក្នុងកូនពៅ ដោយឃើញថា **សូម្បីកូនពៅនេះ ក៏នឹងដូចកូន ២ នាក់នោះ ដូចគ្នា** របស់ស្ត្រីនោះ ។

កាលលោកឃើញយ៉ាងនោះ ភយតុបដ្ឋានញ្ញាណ រមែងកើតឡើងក្នុងឋានៈ គឺក្នុងឱកាសនោះ ឧបមាដទៃទៀតក៏មាន ឧបមាថា ស្ត្រីម្នាក់ ជាស្ត្រី ( បូតិបជាអារីសកូន ) មានកូនស្លាប់ ប្រសូតទារកចេញមក ១០ នាក់ហើយ ក្នុងទារក ១០ នាក់នោះ ៩ នាក់ស្លាប់ទៅហើយ ម្នាក់នៅក្នុងដៃកំពុងស្លាប់ ម្នាក់នៅក្នុងផ្ទៃ ស្ត្រីនោះឃើញទារក ៩ នាក់ស្លាប់ទៅហើយ ហើយកូនទី ១០ កំពុងស្លាប់ ក៏ដកអាល័យក្នុងទារកដែលនៅក្នុងផ្ទៃ ដោយឃើញថា **សូម្បីកូនដែលនៅក្នុងផ្ទៃនោះ** ក៏ដូចគ្នានឹងកូន ១០ នាក់នោះដែរ ។

ក្នុងទស្សនកិច្ចទាំងនោះ ការឃើញការរលត់នៃសង្ខារដែលជាអតីតទាំងឡាយ របស់ព្រះយោគី ប្រៀបដូចការរឭក គឺការស្លាប់របស់ទារក ៩ នាក់របស់ស្ត្រីនោះ ការឃើញការរលត់នៃសង្ខារ ដែលជាបច្ចុប្បន្នទាំងឡាយរបស់ព្រះយោគី ប្រៀបដូចការឃើញទារកនៅក្នុងដៃកំពុងស្លាប់របស់ស្ត្រីនោះ ការឃើញការរលត់នៃសង្ខារដែលជាអនាគតទាំងឡាយរបស់ព្រះយោគី ប្រៀបដូចការដកអាល័យក្នុងកូនដែលនៅក្នុងផ្ទៃរបស់ស្ត្រីនោះ ។

កាលលោកឃើញយ៉ាងនោះ ភយតុបដ្ឋានញ្ញាណរមែងកើតឡើងក្នុងខណៈនោះ ។

## ញាណនេះមានការខ្លាចដែរ ឬទេ

សួរថា ឯភយតុបដ្ឋានញ្ញាណនេះ ខ្លាច ឬមិនបានខ្លាច ឆ្លើយថា មិនបានខ្លាចទេ ព្រោះថា **ភយតុបដ្ឋានញ្ញាណនោះ** ក៏ត្រឹមតែជាការពិចារណាថា **សង្ខារទាំងឡាយដែលជាអតីតក៏រលត់ទៅហើយ ដែលជាបច្ចុប្បន្នក៏កំពុងរលត់ ដែលជាអនាគត ក៏នឹងរលត់** ប៉ុណ្ណោះ ព្រោះហេតុនោះ ទើបប្រៀបដូចជាបុគ្គលមានភ្នែកសម្លឹងមើលរណ្តៅរងើកភ្លើង ៣ រណ្តៅ ក្នុងទីជិតទ្វារក្រុង ខ្លួនឯងមិនបានខ្លាច គ្រាន់តែពិចារណាថា **សត្វណាមួយនឹងធ្លាក់ចុះទៅក្នុងរណ្តៅរងើកភ្លើង ៣ រណ្តៅនេះ ក៏នឹងបានទទួលទុក្ខមិនតិចគ្រប់គ្នា** ដូច្នេះ ប៉ុណ្ណោះឯង យ៉ាងណា ឬបើមិនដូច្នោះ ប្រៀបដូចបុគ្គលមានភ្នែកល្អ សម្លឹងមើលលំពែង ៣ ដើមដែលគេដោតទុករៀងគ្នា គឺលំពែងដើមគគីរ លំពែងដែក លំពែងមាស ខ្លួនឯងក៏មិនបានខ្លាច គ្រាន់តែពិចារណាថា **សត្វណាមួយនឹងធ្លាក់ចុះទៅត្រង់លំពែង ៣ ដើមនេះ ក៏នឹងបានទទួលទុក្ខ មិនតិចគ្រប់គ្នា** ដូច្នេះ ប៉ុណ្ណោះឯង យ៉ាងណា ភយតុបដ្ឋានញ្ញាណ ក៏ដូច្នោះដូចគ្នា ខ្លួនឯងមិនបានខ្លាច គ្រាន់តែមានការពិចារណាថា **សង្ខារទាំងឡាយក្នុងភព ៣ ដូចជារណ្តៅរងើកភ្លើង ៣ រណ្តៅ និងលំពែង ៣ ដើមដែលជាអតីត ក៏រលត់ទៅហើយ ដែលជាបច្ចុប្បន្នក៏កំពុងរលត់ ដែលជាអនាគតក៏នឹងរលត់** ដូច្នេះប៉ុណ្ណោះឯង តែព្រោះសង្ខារទាំងឡាយ ដែលទៅកាន់ក្នុងភព កំណើត គតិ ឋិតិ និងនិវាសទាំងពួង ជាសភាវៈដែលដល់នូវការវិនាស មានភ័យចំពោះមុខ ប្រាកដដល់ញាណនោះ ដោយជារបស់គួរខ្លាចតែម្យ៉ាង ព្រោះហេតុនោះ ទើបញាណនោះហៅថា **ភយតុបដ្ឋាន** ( ឃើញសង្ខារប្រាកដជារបស់គួរភ័យ ) ។

## បាលី ភយតុបដ្ឋានញ្ញាណ

ឯបាឋៈតទៅនេះ ជាបាលីក្នុងការប្រាកដដោយជារបស់គួរខ្លាច ដូចពោលមកនេះនៃញាណនោះថា សួរថា កាលភិក្ខុធ្វើទុកក្នុងចិត្តដោយការមិនទៀង វត្ថុណាប្រាកដដោយជារបស់គួរខ្លាច កាលភិក្ខុធ្វើទុកក្នុងចិត្តដោយភាពជាទុក្ខ វត្ថុណាប្រាកដដោយជារបស់គួរខ្លាច កាលភិក្ខុធ្វើទុកក្នុងចិត្តដោយភាពជាអនត្តា វត្ថុណាប្រាកដដោយជារបស់គួរខ្លាច ? ឆ្លើយថា កាលភិក្ខុធ្វើទុកក្នុងចិត្តដោយភាពមិនទៀង និមិត្តរមែងប្រាកដដោយជារបស់គួរខ្លាច កាលភិក្ខុធ្វើទុកក្នុងចិត្តដោយជាទុក្ខ បវត្តរមែងប្រាកដដោយជារបស់គួរខ្លាច កាលភិក្ខុធ្វើទុកក្នុងចិត្តដោយជាអនត្តា ទាំងនិមិត្ត និងបវត្តរមែងប្រាកដដោយជារបស់គួរខ្លាច ។

## អធិប្បាយ អត្ថបាលី ភយតុបដ្ឋានញ្ញាណ

ក្នុងបាឋៈទាំងនោះ បាឋៈថា **និមិត្ត** បានដល់ សង្ខារនិមិត្ត ។ ពាក្យថា **និមិត្ត** នោះ ជាឈ្មោះនៃសង្ខារទាំងឡាយ ទាំងជាអតីត អនាគត និងបច្ចុប្បន្ន ពិតហើយ ភិក្ខុធ្វើទុកក្នុងចិត្តដោយភាពមិនទៀង រមែងឃើញតែមរណៈ ( គឺសេចក្តីបែកធ្លាយ ) នៃសង្ខារទាំងឡាយប៉ុណ្ណោះ ព្រោះ ( ដែលឃើញតែការបែកធ្លាយ ) នោះ និមិត្ត ( គឺសង្ខារ ) ទើបប្រាកដដោយជារបស់គួរខ្លាចដល់ភិក្ខុនោះ ។

បាឋៈថា **បវត្ត** បានដល់ ការវិលទៅក្នុងរូបភព និងអរូបភព ពិតហើយ ភិក្ខុដែលធ្វើទុកក្នុងចិត្តដោយភាពជាទុក្ខ រមែងឃើញភាវៈ គឺការត្រូវបៀតបៀនរឿយៗ ប៉ុណ្ណោះនៃការវិលទៅ សូម្បីដែលសន្មតគ្នាថា ជាសុខ ព្រោះ ( ឃើញតែការត្រូវបៀតបៀន ) នោះ **បវត្ត** ( សូម្បីក្នុងរូបភព អរូបភព ) ទើបប្រាកដដោយជារបស់គួរខ្លាចដល់ភិក្ខុនោះ ។

ចំណែកភិក្ខុធ្វើទុកក្នុងចិត្តដោយជាអនត្តា រមែងឃើញនិមិត្ត និងបវត្តទាំង ២ នោះ ជាវត្ថុទំនេរ សូន្យ ស្ងាត់ មិនមានម្ចាស់ មិនមានប្រធាន ដូចផ្ទះស្ងាត់ និងដូចវត្ថុ ( បោកបញ្ឆោត ) ទាំងឡាយ មានថ្ងៃបណ្តើរកូន និងក្រុងគន្ធព្វជាដើម ព្រោះ ( ឃើញតែវត្ថុសោះសូន្យទទេ ) នោះ និមិត្ត និងបវត្តទាំង ២ ទើបប្រាកដជារបស់គួរភ័យដល់ភិក្ខុនោះឯង ។

ភយតុបដ្ឋានញ្ញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយភយតុបដ្ឋានញ្ញាណ

បទថា **សព្វសង្ខារានំ** ប្រែថា នៃសង្ខារទាំងពួង ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ឯ **សព្វ**-ស័ព្ទ ក្នុងទីនេះ មានសព្វចំពោះចំណែកជាវិស័យ ដោយអំណាចនៃអធិការ ។ បទថា **អាសេវន្តស្ស** ប្រែថា សេព គឺឲ្យប្រព្រឹត្តទៅដោយអើពើ ។ បទថា **ភាវេន្តស្ស** ប្រែថា កំពុងចម្រើន គឺកំពុងចម្រើន ។ បទថា **ពហុលី ករោន្តស្ស** សេចក្តីថា កំពុងធ្វើប្រកប គឺប្រកបរឿយៗ ។ បទថា **សភេទកា** សេចក្តីថា ដែលមានការបែកធ្លាយ ដោយអំណាចការបែកធ្លាយទៅគ្រប់ៗ ខណៈ ។ កាលវត្ថុដែលគួរខ្លាច ក៏រមែងមិនប្រាកដដោយជារបស់គួរខ្លាច ព្រោះជារបស់គួរខ្លាចដល់បុគ្គលដែលត្រូវការនឹងស្លាប់ ព្រោះលំបាកក្នុងការរកស៊ី និងមានរោគជាដើម ជាហេតុមិនប្រាកដដោយភាពជារបស់គួរខ្លាចដល់បុគ្គលក្លាហាន ដែលមិនត្រូវការនឹងស្លាប់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដល់បុគ្គលខ្លាចដែលត្រូវការរស់នៅដោយសប្បាយ** ។ វត្ថុដែលគួរខ្លាចទាំងឡាយ មានសីហៈជាដើម ប្រាកដជានិមិត្តដែលគួរស្រៀវខ្លាចដល់បុគ្គលកម្លាច ព្រោះនាំមកតែការគួរខ្លាច យ៉ាងណា សង្ខារទាំងឡាយ ក៏ប្រាកដដោយភាពជារបស់បែកធ្លាយដល់ព្រះយោគី ដូច្នោះដែរ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដូចវត្ថុដែលគួរខ្លាច មានសីហៈ ។បេ។ ប្រាកដដូច្នេះ** ។ ពាក្យថា **សង្ខារដែលជាបច្ចុប្បន្ន** គឺដែលជាបច្ចុប្បន្ន ដោយអទ្ធា ដែលគ្រោតគ្រាត មានការទាក់ទងគ្នា អស់កាលយូរក្រៃលែង ដែលជាបច្ចុប្បន្ន ដោយខណៈ និងល្អិតក្រៃលែង មានកាលតិចតួច ដែលជាបច្ចុប្បន្ន ដោយសន្តតិ ជាខាងកណ្តាល គប្បីកំណត់កាន់យកបានអំពីដើមក្នុងទីនេះ ។ ញាណក្នុងសង្ខារទាំងឡាយ

ដែលប្រាកដជាវត្ថុគួរខ្លាច គឺជាវត្ថុគប្បីខ្លាច ឈ្មោះថា **ភយតុបដ្ឋានញ្ញាណ** ។

លោកអាចារ្យពោលពាក្យថា **ឧបមាដូចកូន ៣ នាក់របស់ស្ត្រីម្នាក់ ដូច្នេះ** ជាដើម កាលនឹងសម្តែងថា ភាវៈដែលក្បាលរបស់កូន ៣ នាក់ របស់ស្ត្រីម្នាក់ ដាច់ទៅហើយ កំពុងដាច់ នឹងដាច់តទៅ ដែលស្ត្រីកំពុងកាន់យកជារឿងនាំមកនូវការខ្លាចរបស់ស្ត្រីនោះ យ៉ាងណា ការរលត់នៃសង្ខារទាំងឡាយ ដែលនៅក្នុងអទ្ធាទាំង ៣ ដែលព្រះយោគីកាន់យក ក៏ដូច្នោះ ។

បាយច្ឆិនជាដើមដែលផ្អមមិនតាំងនៅដោយសភាវៈ វិនាសទៅ យ៉ាងណា កូនទាំងឡាយរបស់ស្ត្រីណាប្រសូតហើយ មិនទៅ ស្លាប់តែម្យ៉ាង ស្ត្រីនោះ លោកហៅថា **បូតិបជា** ប្រែថា មានកូនអាក្រិស ក៏ដូច្នោះ ។ លោកប្រើស័ព្ទថា **បូតិបជា** ( ស្ត្រីមានកូនអាក្រិស ) ក្នុងទីនេះ ដើម្បីនឹងសម្តែងប្រការដែលព្រះយោគី សន្និដ្ឋានការបែកធ្លាយនៃសង្ខារក្នុងអនាគត ដោយការគិត និងឃើញការស្លាប់នៃសត្វដែលនៅក្នុងគភ៌ដោយពិសេស ព្រោះការរលត់នៃសង្ខារក្នុងអតីត និងបច្ចុប្បន្ន ជាក់ច្បាស់ល្អហើយនោះឯង ព្រោះហេតុនោះ ការរលត់នៃសង្ខារក្នុងអតីត និងបច្ចុប្បន្ននោះ ទើបមិនចាំបាច់សាធកៈដោយឧបមា ។ មួយទៀតសោត លោកអាចារ្យសម្តែងឧបមាស្ត្រីមានកូនស្រដៀងគ្នានោះឯង ដើម្បីចង្អុលដល់ព្រះយោគី ដែលមានភពចុងក្រោយ និងដែលជាសោតាបន្ន ជាសត្តក្ខត្តុបរមជាដើម ជាអ្នកមានទុក្ខច្រើនក្នុងអតីត នឹងជាអ្នកមានទុក្ខតិច ក្នុងអនាគត ។

ក្នុងការឧបមេយ្យនោះ គប្បីឃើញសង្ខារទាំងឡាយ ដែលជាអតីត មានប្រភេទជាខាងក្នុងជាដើម ឬសត្តាវាស ៩ ដែលធ្លាប់អាស្រ័យនៅ ប្រៀបដូចកូន ៩ នាក់របស់ស្ត្រីនោះ ដែលស្លាប់ទៅ ។ គប្បីឃើញសង្ខារទាំងឡាយ ដែលជាបច្ចុប្បន្ន ឬសត្តាវាសដែលកំពុងប្រព្រឹត្តទៅ ប្រៀបដូចកូនដែលកំពុងស្លាប់ ។ គប្បី

ឃើញសង្ខារទាំងឡាយ ដែលជាអនាគត ឬសត្តាវាស ដែលនឹងមានតទៅ ប្រៀបដូចកូន ដែលមិនទាន់កើតក្នុងឧបមាដែលតាំងចុះយ៉ាងនេះ ពាក្យណាដែលអាចារ្យពួកមួយ ពោលទុកថា ការប្រើស័ព្ទថា សូម្បីមានកូន ៩ នាក់ ជាពាក្យដែលមានប្រយោជន៍ ដោយមិនកាន់យក សូម្បីមានកូន ១០ នាក់ឡើយ ពាក្យនោះ រមែងជាពាក្យដែលបានទាញមកហើយ ។ លោកពោលថា **ការរឭកដល់សេចក្តីស្លាប់** ព្រោះការស្លាប់របស់ពួកទារក ជារឿងដែលមាននៅរហូតអស់កាលយូរ លោកអាចារ្យពោលដល់កូនដែលនៅក្នុងពោះថា ក្នុងឋានៈជាសង្ខារដែលជាអនាគត ដោយអធិប្បាយថា ម្ចាស់នៃកូនដែលនៅក្នុងគភ៌ និងតាំងនៅក្នុងចំណែកដែលនឹងមាននោះឯង ព្រោះការដែលនៅជាបុគ្គលមិនប្រចក្ស ។ ពាក្យថា **ក្នុងខណៈនោះ** គឺក្នុងខណៈដែលប្រាកដដោយជាសង្ខារទាំងឡាយ ជារបស់គួរខ្លាច ដោយមាតិកាដែលសម្តែងដល់ការបែកធ្លាយ ។ ឈ្មោះថា **មិនបានខ្លាច** ក៏ព្រោះញាណមិនបានប្រព្រឹត្តទៅដោយអាការខ្លាច ។ ឯការខ្លាចក៏ដោយអំណាចចិត្តុប្បាទ ដែលជាបដិឃៈ ចំណែកញាណ រមែងដឹងតាមសេចក្តីពិតថា វត្ថុដែលគួរខ្លាច គប្បីខ្លាច ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះថា ភយតុបដ្ឋានញ្ញាណនោះ ក៏ត្រឹមតែពិចារណា សង្ខារទាំងឡាយ ដែលជាអតីត ។បេ។** ដូច្នេះ អធិប្បាយថា រណ្តៅរងើកភ្លើងទាំង ៣ ដែលមានប្រភេទយ៉ាងខ្លាំងក្លា យ៉ាងកណ្តាល និងយ៉ាងទន់ ក៏ដោយការក្តៅក្រៃលែង ។ ឯលោកកាន់យករណ្តៅរងើកភ្លើងទាំងនោះ ជាឧបមារបស់ភពទាំង ៣ មានកាមភពជាដើម ព្រោះភាពដែលលំពែងទាំង ៣ មានលំពែងគគីរជាដើមជា របស់មិនប្រណីតជាដើមនោះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រះយោគីមានតែការពិចារណាតែម្យ៉ាងប៉ុណ្ណោះ** ដូច្នេះជាដើម ។ បទថា **អស្ស យោគ ញាណស្ស** ប្រែថា ដល់ញាណនោះ ។ ពាក្យថា **ដែលដល់នូវការវិនាស** គឺធ្លាក់ទៅក្នុងការវិនាសសន្ទឹកសន្ធាប់

មានប្រការផ្សេងៗ ។ ពាក្យថា **ជារបស់គួរខ្លាច** គឺជារបស់គប្បីខ្លាច ។

ពាក្យថា **សង្ខារនិមិត្ត** លោកពោលអត្ថទុកដូច្នេះនោះឯងថា បានដល់ ការប្រាកដនៃសង្ខារទាំងឡាយដែលដូចគ្នា មានរាងកាយដោយអំណាចជាក្រុម មានប្រជុំរួមគ្នាជាដើម និងព្រោះមានដែនកំណត់នៃកិច្ច ។ ឯការប្រាកដយ៉ាងនោះនៃសង្ខារទាំងឡាយមិនជារឿងដែលផុតអំពីសង្ខារឡើយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ពាក្យថា និមិត្តនោះ ជាឈ្មោះនៃសង្ខារទាំងឡាយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន** ដូច្នេះ ។ ពាក្យថា **មរណៈប៉ុណ្ណោះ** បានដល់ ការបែកធ្លាយប៉ុណ្ណោះ ។ បទថា **តេន យោគ ភគ្គទស្សនេន** ប្រែថា ដោយឃើញការបែកធ្លាយនោះ ។ កាលភិក្ខុនោះឃើញតែការបែកធ្លាយតែម្យ៉ាងគ្រប់ៗ ខណៈ សង្ខារដែលមានឈ្មោះថា **និមិត្ត** រមែងប្រាកដជារបស់មានភ័យចំពោះមុខ តាមន័យដែលបានពោលទុកហើយ ក្នុងអនិច្ចតា ។ លោកអាចារ្យពោលពាក្យថា **បវត្ត បានដល់ ការវិលទៅក្នុងរូបភព និងអរូបភព** ដូច្នេះ ដើម្បីនឹងសម្តែងថា **បវត្ត** បានដល់ ការវិលទៅក្នុងភពទាំងពួងក៏ពិតយ៉ាងនោះ ព្រោះការត្រូវបៀតបៀនក្នុងឥឡូវនោះ រឿយៗ ក្នុងភពទាំងពួង ក៏ប្រាកដជាក់ច្បាស់ល្អក្រៃលែង ដល់គន្ថានុបស្សនាដែល ដល់លំដាប់កំពូលភពទាំងឡាយ សូម្បីតែងសរសើរថា សុខស្ងប់ ក៏រមែងប្រាកដ ជារបស់គួរខ្លាច ព្រោះមានទុក្ខជាសភាវៈ ។ ពាក្យថា **ទាំង ២** បានដល់ និមិត្ត និងបវត្ត ។ ពិតហើយ និមិត្ត និងបវត្តទាំង ២ នោះ រមែងប្រាកដជារបស់ទទេចាកអត្តានោះ ដូច្នេះឯង ។

ភយតុបដ្ឋានញ្ញាណ ចប់ ។

# វិសុទ្ធិមគ្គ

## អាទីនវានុបស្សនាញាណ

កាលព្រះយោគាវចរនោះ សេពដោយអើពើ ចម្រើន ធ្វើឲ្យច្រើន នូវភយ-តុបដ្ឋានញ្ញាណនោះ ទីជ្រកកោនមិនប្រាកដ ទីពួនក៏មិនប្រាកដ ទីទៅក៏មិនប្រាកដទីពឹងអាស្រ័យក៏មិនប្រាកដ ក្នុងភព កំណើត គតិ ឋិតិ និងសត្តាវាសទាំងពួង ការធ្វើសំណូមពរបាន ឬការប្រកាន់យកបានក្តី ក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភព កំណើត គតិ ឋិតិ និងនិវាសទាំងពួង សូម្បីតែសង្ខារមួយក៏មិនមានភព ៣ ប្រាកដដូចជារណ្តៅរងើកភ្លើង ដែលពេញទៅដោយរងើកប្រាសចាកអណ្តាត មហាភូត ៤ ប្រាកដដូចអាសិរពិស ដែលមានពិសសាហាវ ខន្ធ ៥ ប្រាកដដូចពេជ្ឈឃាតដែលងាដាវ អាយតនៈខាងក្នុង ៦ ប្រាកដដូចជាភូមិស្ងាត់ អាយតនៈ ខាងក្រៅ ៦ ប្រាកដដូចពួកចោរចូលប្លន់ភូមិ ។ ម្យ៉ាងទៀត វិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ៩ ត្រូវភ្លើង ១១ កងឆេះ ប្រាកដដូចជាសន្ធោសន្ធៅ សង្ខារទាំងពួង ប្រាកដបីដូចបូស ដូចរោគដូចសរ ដូចគ្រឿងទុក្ខក្តៅ និងដូចជំងឺតម្កាត់ ទើបជាអាទីនវរាសី គឺគំនរទោសដ៏ធំមិនមានគុណដែលគួរពេញចិត្ត ប្រាសចាកវិស័យដែលគួរត្រេកអរ សួរថា ដូចជាអ្វី? ឆ្លើយថា ដូចព្រៃស្ទុក សូម្បីតាំងនៅ ដោយអាការគួរត្រេកអរ តែមានសត្វកាច ដូចគុហាមានខ្លា ដូចទឹកមានគាហៈ ( របស់ដែលឃ្មាំចាំគប់ស៊ីមនុស្សដែលចុះទឹក មានក្រពើជាដើម ) និងអារក្សទឹក ដូចសត្រូវយារដាវ ដូចភោជនមានជាតិពុល និងដូចផ្លូវមានចោរ ដូចផ្ទះភ្លើងឆេះ ដូចលានចម្បាំង មានកងទាហានដែលគេបញ្ជូនចេញទៅច្បាំង រមែងប្រាកដជារបស់គួរខ្លាចដល់បុរសកម្សាច ដែលស្រឡាញ់ជីវិតដោយងាយ ។ ពិតហើយ បុរសនោះ មកដល់វត្ថុគួរខ្លាច មានព្រៃស្ទុកដែលមានសត្វកាច

ជាដើមទាំងនោះហើយ រមែងជាអ្នកខ្លាចញ័រខ្លួន រហូតព្រឺរោម នៅជុំវិញខ្លួន យ៉ាងណា ព្រះយោគាវចរនេះក៏ដូច្នោះដូចគ្នា កាលសង្ខារទាំងពួងប្រាកដដោយជារបស់គួរខ្លាច ដោយអំណាចភយតូបដ្ឋានបស្សនាហើយ ក៏រមែងឃើញតែទោសដែលគ្មានគុណគួរពេញចិត្ត ប្រាសចាកវិស័យដែលគួរត្រេកអរដោយជុំវិញ កាលលោកឃើញយ៉ាងនោះ ញាណឈ្មោះ **អាទីនវញ្ញាណ** រមែងកើតឡើង ដែលលោកសំដៅដល់ពាក្យនេះទុកថា

## បាលីអាទីនវានុបស្សនាញាណ

សួរថា បញ្ញាក្នុងភយតូបដ្ឋាន ជាអាទីនវញ្ញាណដូចម្តេច ?

ឆ្លើយថា បញ្ញាក្នុងភយតូបដ្ឋានថា **ឧប្បាទ** ( ការកើតឡើង ) ជាភ័យ ជា **អាទីនវញ្ញាណ** ( ការដឹងក្នុងអាទីនវៈ ) បញ្ញាក្នុងភយតូបដ្ឋានថា **បវត្ត** ជាភ័យ...ថា **និមិត្ត** គឺសង្ខារជាភ័យ... ថា **អាយូហនា** គឺកម្ម ជាភ័យ... ថា បដិសន្ធិ ជាភ័យ... ថា គតិជាភ័យ...ថា **និព្វត្តិ** ( ការកើតប្រាកដឡើង ) ជាភ័យ...ថា **ឧប្បត្តិ** ( ការចូលដល់ ) ជាភ័យ...ថា ជាតិជាភ័យ...ថា ជរាជាភ័យ...ថា ព្យាធិជាភ័យ...ថា មរណៈ ជាភ័យ...ថា សោកជាភ័យ...ថា បរិទេវៈជាភ័យ...ថា ឧបាយាសជាភ័យ ជាអាទីនវញ្ញាណ ។

បញ្ញាថា **អនុប្បាទ** ជាធម៌ក្សេម ជាសន្តិបទញ្ញាណ បញ្ញាថា **អប្បវត្ត** គឺធម៌ដែលមិនមានការវិលទៅ ។បេ។ **អនុប្បាយាស** គឺធម៌ដែលមិនមានឧបាយាស ជាធម៌ក្សេម ជាសន្តិបទញ្ញាណ ។

បញ្ញាថា **ឧប្បាទ** ជាភ័យ **អនុប្បាទ** ជាធម៌ក្សេម ជាសន្តិបទញ្ញាណ បញ្ញាថា **បវត្ត** ជាភ័យ **អប្បវត្ត** ជាធម៌ក្សេម ។បេ។ **ឧបាយាស** ជាភ័យ **អនុបាយាស** ជាធម៌ក្សេម ជាសន្តិបទញ្ញាណ ។

បញ្ញាក្នុងកយត្ថុបដ្ឋានថា **ឧប្បាទ** ជាទុក្ខ ជាអាទីនវញ្ញាណ បញ្ញាក្នុងកយត្ថុ-បដ្ឋានថា **បវត្ត** ជាទុក្ខ ។បេ។ **ឧបាយាស** ជាទុក្ខ ជាអាទីនវញ្ញាណ ។

បញ្ញាថា **អនុប្បាទ** ជាសុខ ជាសន្តិបទញ្ញាណ បញ្ញាថា **អប្បវត្ត** ។បេ។ **អនុបាយាស** ជាសុខ ជាសន្តិបទញ្ញាណ ។

បញ្ញាថា **ឧប្បាទ** ជាទុក្ខ **អនុប្បាទ** ជាសុខ ជាសន្តិបទញ្ញាណ បញ្ញាថា **បវត្ត** ជាទុក្ខ **អប្បវត្ត** ជាសុខ ។បេ។ **ឧបាយាស** ជាទុក្ខ **អនុបាយាស** ជាសុខ ជាសន្តិបទញ្ញាណ ។

បញ្ញាក្នុងកយត្ថុបដ្ឋានថា **ឧប្បាទ** ជាសាមិស ជាអាទីនវញ្ញាណ បញ្ញាក្នុងកយត្ថុបដ្ឋានថា **បវត្ត** ។បេ។ **ឧបាយាស** ជាសាមិស ជាអាទីនវញ្ញាណ ។

បញ្ញាថា **អនុប្បាទ** ជានិរាមិស ជាសន្តិបទញ្ញាណ បញ្ញាថា **អប្បវត្ត** ។បេ។ **អនុបាយាស** ជានិរាមិស ជាសន្តិបទញ្ញាណ ។

បញ្ញាថា **ឧប្បាទ** ជាសាមិស **អនុប្បាទ** ជានិរាមិស ជាសន្តិបទញ្ញាណ បញ្ញាថា **បវត្ត** ជាសាមិស **អប្បវត្ត** ជានិរាមិស ។បេ។ **ឧបាយាស** ជាសាមិស **អនុបាយាស** ជានិរាមិស ជាសន្តិបទញ្ញាណ ។

បញ្ញាក្នុងកយត្ថុបដ្ឋានថា **ឧប្បាទ** ជាសង្ខារ ជាអាទីនវញ្ញាណ បញ្ញាក្នុងកយត្ថុបដ្ឋានថា **បវត្ត** ។បេ។ **ឧបាយាស** ជាសង្ខារ ជាអាទីនវញ្ញាណ ។

បញ្ញាថា **អនុប្បាទ** ជានិព្វាន ជាសន្តិបទញ្ញាណ បញ្ញាថា **អប្បវត្ត** ។បេ។ **អនុបាយាស** ជានិព្វាន ជាសន្តិបទញ្ញាណ ។

បញ្ញាថា **ឧប្បាទ** ជាសង្ខារ **អនុប្បាទ** ជានិព្វាន ជាសន្តិបទញ្ញាណ បញ្ញាថា **បវត្ត** ជាសង្ខារ **អប្បវត្ត** ជានិព្វាន ។បេ។ **ឧបាយាស** ជាសង្ខារ **អនុបាយាស** ជានិព្វាន ជាសន្តិបទញ្ញាណ ។

ភិក្ខុរមែងឃើញឧប្បាទ បវត្ត និមិត្ត អាយូហន និងបដិសន្ធិថា ជាទុក្ខ ការឃើញ ( វត្ថុ ៥ នេះ ) ជាអាទីនវញ្ញាណ ។ ម្យ៉ាងទៀត ឃើញអនុប្បាទ អប្បវត្ត អនិមិត្ត អាយូហន និងអប្បដិសន្ធិ ថាជាសុខ ( ការឃើញ ៥ ស្ថាន ) នេះ ជាសន្តិបទញ្ញាណ អាទីនវញ្ញាណនេះ រមែងកើតក្នុងស្ថាន ៥ សន្តិបទញ្ញាណ ក៏កើតក្នុងស្ថាន ៥ ទើបឈ្មោះថា ដឹងញាណ ១០ ព្រោះជាបុគ្គលឈ្លាសក្នុងញាណ ២ ទើបភិក្ខុនោះ មិនញាប់ញ័រ ព្រោះទិដ្ឋិផ្សេង ដូច្នេះ ។

ការឃើញនោះ ចាត់ជាញាណដោយអត្ថថា ដឹង ចាត់ជាបញ្ញា ដោយអត្ថថា ដឹងទូទៅ ហេតុនោះ ទើបបានពោលទុកថា បញ្ញាក្នុងភយតុបដ្ឋានញ្ញាណ ជាអាទីនវញ្ញាណ ។

## អធិប្បាយ អត្ថបាលីអាទីនវញ្ញាណ

ក្នុងបាឋៈទាំងនោះ បាឋៈថា **ឧប្បាទ** បានដល់ ការឧប្បត្តិឡើងក្នុងភពនេះ ព្រោះបច្ច័យ គឺកម្មក្នុងភពមុន ។ បាឋៈថា **បវត្ត** បានដល់ ការវិលទៅ ( ក្នុងបវត្តិកាល ) នៃសង្ខារធម៌ដែលកើតឡើងហើយយ៉ាងនោះ ។ បាឋៈថា **និមិត្ត** បានដល់ និមិត្ត គឺសង្ខារទាំងពួង ។ បាឋៈថា **អាយូហនា** បានដល់ កម្ម (ក្នុងភពនេះ) ដែលជាហេតុនៃបដិសន្ធិ (ក្នុងភព) តទៅ ។ បាឋៈថា **បដិសន្ធិ** បានដល់ ការឧប្បត្តិឡើង(ក្នុងភព ) តទៅ ។ បាឋៈថា **គតិ** បានដល់ គតិ ដែលបដិសន្ធិឡើង ។ បាឋៈថា **និព្វត្តិ** បានដល់ ការកើតឡើងនៃខន្ធទាំងឡាយ ។ បាឋៈថា **ឧប្បត្តិ** បានដល់ ការប្រព្រឹត្តទៅនៃវិបាកដែលពោលទុកយ៉ាងនេះថា **វិបាករមែងមានដល់បុគ្គលដល់ព្រមខ្លះ ដល់បុគ្គលចូលដល់ខ្លះ** ។ បាឋៈថា **ជាតិ** បានដល់ ជាតិដែលមានព្រោះបច្ច័យ គឺភពជាបច្ច័យនៃទុក្ខទាំងឡាយ មានជរាជាដើម ធម៌ទាំងឡាយ មានជរា និងមរណៈជាដើម ( មានការ ) ប្រាកដ ( ច្បាស់ ) ហើយទាំងអស់ ឯក្នុងធម៌នេះ ធម៌ ៥ មានឧប្បាទ

ជាដើមប៉ុណ្ណោះ លោកពោលដោយជាវត្ថុ ( ទីតាំង ) នៃអាទីនវញ្ញាណ ធម៌ដ៏សេស លោកពោលដោយជា វេវចនៈរបស់ធម៌ ៥ នោះ ៗ ពិតហើយ ពាក្យ ២ ម៉ាត់ គឺ **និព្វត្តិ ជាតិ** នេះជាវេវចនៈរបស់ឧប្បាទ និងរបស់បដិសន្ធិនោះឯង ពាក្យ ២ ម៉ាត់ គឺ **គតិ ឧប្បត្តិ** នេះជាវេវនៈរបស់បវត្ត ជរាជាដើមជាវេវចនៈរបស់និមិត្ត ដូច្នេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា

**ភិក្ខុរមែងឃើញឧប្បាទ បវត្ត និមិត្ត អាយូហន និងបដិសន្ធិ ថាជាទុក្ខ ការឃើញ ( មានវត្ថុ ៥ ) នេះ ជាអាទីនវញ្ញាណ** និងថា **អាទីនវញ្ញាណនេះ រមែងកើតក្នុងស្ថាន ៥** ដូច្នេះ ។

ចំណែកពាក្យថា បញ្ញាថា **អនុប្បាទជាធម៌ក្សេម** ជាសន្តិបទញ្ញាណជាដើម លោកពោលដើម្បីសម្តែងញាណ ដែលផ្ទុយអំពីអាទីនវញ្ញាណ ។ ន័យម្យ៉ាងទៀត ពាក្យនោះ លោកពោលដើម្បីញ៉ាំងការធូរចិត្តឲ្យកើតដល់ព្រះយោគាវចរទាំងឡាយ ដែលមានហទយៈស្រៀវខ្លាច ព្រោះឃើញអាទីនវៈដោយភយតុបដ្ឋានថា **វត្ថុដែលមិនគួរខ្លាច ផុតភ័យ មិនមានទោសក៏មាន** ដូច្នេះក៏បាន ឬថា ព្រោះធម៌ទាំងឡាយមានឧប្បាទជាដើម ប្រាកដឡើង ( ប្រាកដឲ្យឃើញ ) ដោយជារបស់គួរខ្លាចដល់ព្រះយោគាវចរនោះ ទើបចិត្តរបស់លោកបង្អោនទៅក្នុងធម៌ ដែលជាបដិបក្ខរបស់ធម៌នោះ ព្រោះហេតុនោះ គប្បីជ្រាបថា ពាក្យនោះលោកពោលដើម្បីសម្តែងអានិសង្ស នៃអាទីនវញ្ញាណ ដែលសម្រេចដោយអំណាចការប្រាកដជារបស់គួរខ្លាចផង ។

ម្យ៉ាងទៀត ក្នុងធម៌ចំណែកដែលជាទោសនេះ ហេតុណា វត្ថុណា ជារបស់គួរខ្លាច វត្ថុនោះ រមែងជាទុក្ខដោយពិត វត្ថុណាជាទុក្ខសោត វត្ថុនោះក៏រមែងជាសាមិស ប៉ុណ្ណោះ ព្រោះមិនផុតទៅអំពីវដ្ដាមិស គឺឧបាទិន្នក្ខន្ធ លោកាមិស គឺបញ្ចកាមគុណ និងកិលេសាមិស ។ មួយទៀតសោត វត្ថុណាជាសាមិស វត្ថុនោះ រមែងជាសង្ខារ

ប៉ុណ្ណោះឯង ហេតុនោះ ទើបលោកពោលតទៅថា **បញ្ញាក្នុងភយតុបដ្ឋានថា ឧប្បាទ ជាទុក្ខ ជាអាទីនវញ្ញាណ** ដូច្នេះជាដើម សូម្បីយ៉ាងនោះ ក៏គប្បីជ្រាបការផ្សេងគ្នា ក្នុងធម៌ចំណែកដែលជាទោសនេះ ដោយអំណាចប្រព្រឹត្តទៅ ដោយមានអាការ ផ្សេងគ្នាយ៉ាងនេះ គឺដោយមានអាការជារបស់គួរខ្លាច ដោយមានអាការជាទុក្ខ ដោយ មានអាការជាសាមិស ។

ពាក្យថា **ទស ញាណេ បជានាតិ** ដឹងញាណ ១០ អធិប្បាយថា ភិក្ខុនោះ កាលដឹងទូទៅនូវអាទីនវញ្ញាណ ឈ្មោះថា **រមែងដឹងទូទៅ** គឺចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ **នូវញាណ ១០** គឺញាណដែលមានចំណែកអាទីនវៈ មានឧប្បាទជាដើម ជាទីតាំង ៥ ញាណមានធម៌ចំណែកផ្សេង មានអនុប្បាទជាដើមជាទីតាំង ៥ ។

ពាក្យថា **ទ្វិន្នំ ញាណានំ កុសលតា** ព្រោះជាបុគ្គលឈ្លាសក្នុងញាណ ២ សេចក្តី ថា ព្រោះជាបុគ្គលឈ្លាសក្នុងញាណ ២ នេះ គឺអាទីនវញ្ញាណ ១ សន្តិបទញ្ញាណ ១។

ពាក្យថា **នានាទិដ្ឋីសុ ន កម្បតិ** មិនញាប់ញ័រព្រោះទិដ្ឋិផ្សេងៗ សេចក្តីថា រមែង មិនញាប់ញ័រទៅក្នុងទិដ្ឋិទាំងឡាយ ដែលប្រព្រឹត្តទៅដោយអំណាចការប្រកាន់ខុស មានប្រកាន់ទិដ្ឋធម្មនិព្វានជាបរមធម៌ជាដើម ។

ពាក្យដ៏សេសក្នុងបាលីនេះ មានន័យរាក់ទាំងអស់ ដូច្នេះ ។

អាទីនវានុបស្សនាញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយអាទីនវានុបស្សនាញាណ

ពាក្យថា **ទីជ្រកកោន** បានដល់ ទីរក្សាអំពីអនត្ថៈ ដែលមានសង្ខារជាហេតុ ។ ឈ្មោះថា **មិនប្រាកដ** ព្រោះភពទាំងពួងជាដើម ដូចគ្នាដោយជាសភាវៈដែលមានទោស ។ ពាក្យថា **ទីពួន** បានដល់ ដែលចូលទៅពួន ដោយជាទីគោចរ និងពួនអំពីទោសនោះ ។ ពាក្យថា **ទីទៅ** បានដល់ ដែលគប្បីទៅដើម្បីកិច្ចការនោះ ។ ពាក្យថា **ទីពឹងអាស្រ័យ** បានដល់ ទីស្ថានគប្បីអាស្រ័យរបស់ព្រះយោគាវចរនោះឯង ។ ពាក្យថា **ការប្រាថ្នា** បានដល់ ការសង្ឃឹមរមែងមិនមាន ។ ដោយពាក្យនេះ លោកពោលដល់ការមិនមានការប្រកាន់ គឺតណ្ហាថា នុ៎ះមិនមែនរបស់អញ ។ ពាក្យថា **ការប្រកាន់ទុក** បានដល់ ការប្រកាន់ទុក គឺទិដ្ឋិ ។ ដោយពាក្យនេះ លោកអាចារ្យពោលដល់ការមិនមានការប្រកាន់ គឺទិដ្ឋិថា នុ៎ះខ្លួនរបស់អញ ។ ក្នុងទីនេះ ដោយការមិនមានការប្រកាន់ គឺតណ្ហានោះឯង រមែងត្រូវបានលោកពោលដល់ការមិនមានការប្រកាន់ គឺមានះថា នុ៎ះជាអញ ម្យ៉ាងទៀត ដោយការកាន់យក វា-ស័ព្ទ ក៏ត្រូវបានលោកពោលទុក ។

ឥឡូវនេះ លោកអាចារ្យមានបំណងសម្តែងហេតុក្នុងការមិនមានការប្រាថ្នាជាដើម ទើបពោលពាក្យថា **ភពទាំង ៣** ជាដើម ។ ក្នុងពាក្យនោះ **ភពទាំង ៣ ឈ្មោះថា ដូចរណ្តៅរងើកភ្លើង** ព្រោះមានការក្តៅក្រៃលែង ដោយជាទីតាំងនៃទុក្ខ មានជាតិទុក្ខជាដើម ។ **មហាភូតរូបទាំង ៤ ឈ្មោះថា ដូចអាសិរពិសមានពិសពន្លឹក** ពោលគឺអាសិរពិស ឈ្មោះថា **កដ្ឋមុខ** ( ពស់មាត់ឈើ ) **បូតិមុខ** ( ពស់មាត់ស្អុយ ) **អគ្គិមុខ** ( ពស់មាត់ភ្លើង ) និង **សត្ថមុខ** ( ពស់មាត់សស្ត្រា ) ដោយផ្សេងគ្នា ព្រោះ

ធ្វើសេចក្តីទុក្ខ គឺការរឹង កាយស្អុយ ក្តៅក្រហាយ និងដាច់ជាកំណាត់ៗ តែដោយមិនផ្សេងគ្នា ដោយទីកើត ដោយការផ្លាស់ប្តូរនៃពិស ដោយឲ្យការវិនាស ដោយការចូលទៅជិតបានលំបាក ដោយការមកដល់បានលំបាក ដោយការមិនដឹងគុណដែលធ្វើទុក ដោយធ្វើការមិនផ្សេងគ្នា និងដោយមានទោស និងអន្តរាយដ៏ច្រើន ។ សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាសិរពិសមានតេជះខ្ពស់ មានពិសពន្លឹកនេះ ជាឈ្មោះនៃធាតុទាំង ៤ ។ ខន្ធទាំង ៥ ព្រោះខន្ធដទៃ មិនតាំងចុះក្នុងប្រភេទនៃខន្ធ ១ ។ ឈ្មោះថា ដូចពេជ្ឈឃាតយារដាវ ព្រោះមកសម្លាប់នូវគ្នានឹងគ្នា និងព្រោះនាំមកនូវទុក្ខ គឺសេចក្តីស្លាប់ ។ សេចក្តីនេះសមដូចព្រះបាលីដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពេជ្ឈឃាតយារដាវនេះ ជាឈ្មោះនៃឧបាទានក្ខន្ធទាំង ៥ ដូច្នេះ អាយតនៈខាងក្នុង ៦ សូម្បីបុគ្គលកាន់យកថាខ្លួន និងរបស់ខ្លួន ក៏ប្រាកដ ដូចស្រុកស្ងាត់ ព្រោះទទេចាកខ្លួន និងជារបស់ខ្លួននោះ គឺដូចជាស្រុកស្ងាត់ ដែលបុគ្គលចូលទៅ ដោយគិតថា ក្នុងស្រុកនេះមានវត្ថុដែលចូលដល់ការគប្បីកាន់យក មានភោជនាហារជាដើម ។ ពិតហើយ ព្រះមានព្រះភាគបានត្រាស់ព្រះពុទ្ធវចនៈនេះទុកថា

ម្នាលភិក្ខុទាំងឡាយ ពាក្យថា ស្រុកស្ងាត់នេះ ជាឈ្មោះនៃអាយតនៈខាងក្នុងទាំង ៦ ម្នាលភិក្ខុទាំងឡាយ សូម្បីបណ្ឌិតដែលឈ្លាស មានបញ្ញាពិនិត្យពិចារណាអាយតនៈខាងក្នុង ៦ នោះ តាមផ្លូវភ្នែក ក៏នឹងប្រាកដថា ជារបស់សោះសូន្យទទេទាំងនោះ ដូច្នេះជាដើម ។ ឯអាយតនៈខាងក្រៅ ៦ ប្រាកដ ដូចពួកចោរសម្លាប់អ្នកស្រុក ព្រោះជាអ្នកសម្លាប់ដោយប្រការទាំងពួង ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពួកចោរសម្លាប់អ្នកស្រុកនេះជាឈ្មោះអាយតនៈខាងក្រៅ ៦ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុរមែងក្តៅក្រហាយ ព្រោះ

រូបជាទីពេញចិត្ត និងមិនពេញចិត្ត ដូច្នេះជាដើម ។ ព្រោះភ្លើង ១១ កង មានភ្លើងគឺរាគៈជាដើម ។ សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកថា

**ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់ក្តៅ ក្តៅព្រោះអ្វី ? ក្តៅព្រោះភ្លើង គឺរាគៈ ទោសៈ មោហៈ ជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស** ដូច្នេះជាដើម ។ សង្ខារទាំងឡាយ ជារបស់ដូចបូសជាដើម ខ្ញុំពោលហើយខាងដើមនោះឯង ។ ពាក្យថា **ឥតគុណតម្លៃដែលគួរពេញចិត្ត** គឺវៀរចាកគុណតម្លៃដែលគួរត្រេកអរ ព្រោះមានទុក្ខជាសភាវៈ ។ ពាក្យថា **ប្រាសចាកវិស័យដែលគួរត្រេកអរ** គឺវៀរចាកសម្បត្តិ ព្រោះមានវិបត្តិជាទីបំផុត ។ គ្រប់បទ មានការភ្ជាប់សេចក្តីថា សង្ខារទាំងឡាយ រមែងប្រាកដជាគំនរទោសដ៏ធំ ឥតគុណគាប់ ដែលគួរពេញចិត្ត ប្រាសចាកវិស័យដែលគួរត្រេកអរខាងដើម យ៉ាងណា ក្នុងពាក្យថា **សវាឡកមិវ វនគ្គហនំ វនគ្គ** ដូចជាព្រៃស្តុក មានតែសត្វកាចជាដើមតទៅ ក៏គប្បីនាំយកពាក្យនោះមកភ្ជាប់ចូល ដូច្នោះ ។

បទថា **សសទ្ទូលា** ប្រែថា មានខ្លា ។ **គាហៈទាំងឡាយ** បានដល់ សត្វទាំងឡាយ មានក្រពើជាដើម ។ **អារក្ស** ប្រែថា ខ្មោចទឹក ។ ដោយពាក្យថា **ឥតគុណតម្លៃដែលគួរពេញចិត្ត ប្រាសចាកវិស័យដែលគួរត្រេកអរនេះ** លោកអាចារ្យរមែងសម្តែងអាទីនវៈ ជាសភាវៈដេរដាស ។ ពិតហើយ សង្ខារទាំងឡាយ ក្នុងភពជាដើម រមែងប្រាកដជាវត្ថុដែលមានភ័យចំពោះដល់ព្រះយោគីនោះឯង មិនដាច់ខ្សែដោយមិនរារាំង ។ វត្ថុណា មានភ័យចំពោះមុខ វត្ថុនេះក៏មានទោស ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **កាលលោកឃើញយ៉ាងនេះ** ដូច្នេះ ជាដើម ។

បទថា **យំ យោគ អាទីនវញ្ញាណំ** ។ ពីរបទថា **ឥទំ វុត្តំ** សេចក្តីថា បទកាជនៈនៃអាទីនវញ្ញាណនោះឯង មានវត្ថុ ១០ ប្រដាប់ដោយវារៈ ១២ ព្រះធម្មសេនាបតី

ពោលទុកក្នុង **បដិសម្ភិទា** ដោយអំណាច **វយ** និង **ព្យតិរេក** ( ភាពពិសេស )។

ពាក្យថា **ឧប្បាទជាភ័យ** សេចក្តីថា ឧប្បាទនៃសង្ខារទាំងឡាយ ឈ្មោះថាជាភ័យ ព្រោះជាទីតាំងនៃភ័យ ដោយអត្ថថា មិនក្សេម ។ ពិតហើយ វត្ថុដែលមានឧប្បាទជាមូលទាំងអស់នោះ ក៏មានវត្ថុទាំងអស់ជាវត្ថុ ព្រោះហេតុនោះ ទើបមានសេចក្តីវិនាស ។ សូម្បីក្នុងពាក្យថា **បវត្តជាភ័យ** ជាដើម ក៏មានន័យនេះឯង ។ ការកើតឡើងមិនមានដល់ធម៌នេះ ឬកាលសម្រេចធម៌នោះហើយ ការកើតឡើងនៃសង្ខារទាំងឡាយតទៅ ក៏មិនមាន ហេតុនោះ ធម៌នេះឈ្មោះថា **អនុប្បាទ** ( មិនមានការកើតឡើង ) បានដល់ និព្វាន ។ និព្វាននោះ ឈ្មោះថា **ជាធម៌ក្សេម** ដោយអត្ថថា មិនមានភ័យ ព្រោះជាការក្សេមយ៉ាងក្រៃលែង ព្រោះថា មិនមានភ័យ ដោយប្រការទាំងពួង ។ ពាក្យថា **ក្នុងសន្តិបទ** បានដល់ ក្នុងអមតបទ ដែលជាទីចូលទៅស្ងប់សង្ខារទាំងពួង ។ សូម្បីដោយពាក្យថា **អប្បវត្ត** ជាដើម ព្រះធម្មសេនាបតីសារីបុត្រក៏ពោលដល់និព្វាននោះឯង ដោយមាតិកា គឺការបដិសេធបវត្តជាដើម ។ ព្រះធម្ម-សេនាបតីសារីបុត្របានពោលវារៈទី ៣ ថា **ឧប្បាទជាភ័យ អនុប្បាទជាធម៌ក្សេម** ដូច្នេះ ដោយអំណាចភិក្ខុទាំងឡាយ ដែលញ៉ាំងវិបស្សនាឲ្យបោះជំហានយ៉ាងរហ័ស ដោយអំណាចការឃើញទោសក្នុងបវត្តិ គឺការវិលទៅ និងឃើញអានិសង្សក្នុងនិវត្តិក្នុងលំដាប់នោះៗ ឯង ។ ក្នុងវារៈទាំងឡាយ មានវារៈ ទី ៦ ជាដើម ក៏មានន័យដូច្នេះឯង ។ ក្នុងអធិការនេះ **ឧប្បាទ** ជាភាពវិសេស **ភយ** ជាវត្ថុធ្វើឲ្យវិសេសអំពីភាពជាធម៌ស្មើគ្នា ព្រោះហេតុនោះ កាលបទទាំង ២ មានអធិករណ៍ស្មើគ្នា លោកក៏កាន់យកភាពវិសេសនៃលិង្គ ។ ដូចពាក្យថា **ទុក្ខសមុទយោ អរិយសច្ចំ** ប្រែថា ទុក្ខសមុទយអរិយសច្ច ។ សូម្បីក្នុងពាក្យជាដើមថា **គតិជាភ័យ** ក៏មានន័យនេះ ។

ចំណែកក្នុងពីរបទនេះថា **ឧប្បាទោ សង្ខារា** ឧប្បាទជាសង្ខារ ព្រះធម្មសេនាបតី

កាន់យកការកើតឡើងនៃសង្ខារទាំងឡាយ ដោយការស្មើគ្នា ហើយកាន់យកដោយការផ្សេងគ្នា ព្រោះសង្ខារទាំងនោះជាសភាវៈ ដែលព្រះយោគីកំពុងឃើញច្បាស់ដោយវិភាគគ្រប់កន្លែងនោះឯង ព្រោះហេតុនោះ ទើបលោកធ្វើការផ្សេងគ្នានៃវចនៈទុក ។

ក្នុងបទថា **អាយូហនំ បដិសន្ធឹ ទុក្ខន្តិ បស្សតិ** ប្រែថា រមែងឃើញអាយូហនបដិសន្ធិថា **ជាទុក្ខ** ។ ពាក្យថា **នេះជាអាទីនវញ្ញាណ** សេចក្ដីថា គប្បីជ្រាបញាណដែលមានវត្ថុ ៥ ប្រការនេះ ក្នុងទោសដែលជាអារម្មណ៍ ។ ពាក្យថា **នេះជាសន្តិបទញ្ញាណ** សេចក្ដីថា ញាណនេះតាំងនៅដោយជាធម៌បង្អោនទៅក្នុងសន្តិបទជាដើម ។

ការកើតឡើងនៃសង្ខារទាំងឡាយ ដែលកើតឡើងនៅក្នុងបច្ចុប្បន្នភព ព្រោះកម្មជាបច្ច័យរមែងប្រាកដច្បាស់ក្រៃលែង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ការឧប្បត្តិឡើងក្នុងភពនេះ ព្រោះកម្មក្នុងភពមុនជាបច្ច័យ** ។ ដែលឈ្មោះថា **បវត្ត** បានដល់ ការប្រព្រឹត្តទៅតាមធម៌ក្នុងបវត្តិកាល ក្នុងភពនេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ការវិលទៅនៃសង្ខារធម៌ដែលកើតហើយ** ។ ពាក្យថា **ទាំងពួង** បានដល់ រូប និងអរូប ដែលនៅក្នុងអទ្ធាទាំង ៣ មានវិភាគជាខាងក្នុង និងខាងក្រៅជាដើមទាំងពួង ។ ពាក្យថា **កម្ម** បានដល់ កម្មដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ។ ក្នុងអធិការនេះ លោកកាន់យកសង្ខារទាំងឡាយ ដែលទាក់ទងក្នុងបច្ចុប្បន្នអទ្ធា ដោយស័ព្ទថា **ឧប្បាទ បវត្ត** និង **អាយូហន** កាន់យកសង្ខារទាំងឡាយ ដែលទាក់ទងក្នុងអនាគតអទ្ធា ដោយស័ព្ទថា **បដិសន្ធិ** ។ ហើយប្រកាសកម្មសង្ខារទាំងឡាយ ដែលទាក់ទងក្នុងអតីតអទ្ធា ដោយស័ព្ទថា **ឧប្បាទ** ។ តែលោកកាន់យកសង្ខារទាំងអស់ដោយស័ព្ទថា **និមិត្ត** ។ **បដិសន្ធិនោះ រមែងមានដោយគតិណា** គតិនោះ ឈ្មោះថា **គតិ** ដែលផ្សេងដោយនរកជាដើម ព្រោះគប្បីទៅដោយអំណាចសុចរិត និងទុច្ចរិត

ពោលដោយអត្ថ គតិនោះ កំណត់ដោយកម្មនោះៗ គប្បីជ្រាបថា ឈ្មោះថា **វិបាកក្ខន្ធ** គួរដល់ឈ្មោះថា **ភព** និងឈ្មោះថា **កដត្តារូប** ។ ពាក្យថា **ការកើតឡើងនៃខន្ធទាំងឡាយ** គឺការកើតឡើងនៃខន្ធទាំងពួង ។ **ប្រាកដច្បាស់ហើយនោះឯង** ក្នុងសច្ចវិភង្គ ព្រោះលោកបាននិទ្ទេសទុក ដោយអំណាចបកិណ្ណកៈ មានលក្ខណៈជាដើម ។ ពាក្យថា **ដោយអំណាចវត្ថុ** គឺដោយអំណាចទីតាំងនៃការប្រព្រឹត្តទៅ ពោល គឺអារម្មណ៍ ។ លោកអាចារ្យពោលថា **ធម៌ដ៏សេស លោកពោលដោយវេវចនៈរបស់ធម៌ ៥ នោះ** ដូច្នេះ ដើម្បីចៀសវាងពាក្យសួរថា បើធម៌ ៥ យ៉ាង លោកមានបំណងយកជាវត្ថុសោត កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបលោកពោលធម៌ដ៏សេសទុកផងទៅវិញ ។ ដោយហេតុនោះ ទើបលោកអាចារ្យសម្ដែងថា **ទេសនា** បានចម្រើនឡើង ដើម្បីបន្ថែមអារម្មណ៍ នៃការផ្សាយទៅនៃញាណរបស់លោកដែលចម្រើនវិបស្សនាទាំងឡាយ ។

**ការសម្ដែងញាណចំណែកផ្ទុយគ្នា** ថា ក្នុងធម៌ណាមិនមានការកើត ក្នុងធម៌នោះ ក៏មិនមានភ័យទាំងពួង ដោយប្រការទាំងពួង ដូច្នេះ ក៏ដើម្បីសម្ដែងព្យតិរេក គឺដោយពិសេសនូវព្រះអាទីនវញ្ញាណដែលបានសម្ដែងហើយ ដោយអន្វយន័យ គឺបណ្ដោយតាម ។ លោកអាចារ្យរមែងសម្ដែងថា ការសម្ដែងការប្រព្រឹត្តទៅ ដោយពាក្យជាដើមថា **ដោយប្រាកដជារបស់គួរខ្លាចខ្លះ** ដូច្នេះហើយ សម្ដែងការឈប់នេះ ព្រះមានជោគទាំងឡាយ និងព្រះអនុពុទ្ធទាំងឡាយ បានប្រព្រឹត្តជាបវេណីមកហើយ ដូចជាការសម្ដែងសច្ចៈ ២ ប្រការខាងដើម ហើយសម្ដែងនិរោធសច្ច លោកអាចារ្យពោលពាក្យថា **ឬព្រោះធម៌ទាំងឡាយ មានឧប្បាទជាដើម** ដូច្នេះជាដើម ដើម្បីសម្ដែងសេចក្ដីនេះថា ការសម្ដែងទោស សូម្បីជារឿងមិនមានប្រយោជន៍ ដល់បុគ្គលខ្លះក្នុងលោកឯណា ការសម្ដែងទោសនេះ មិនដូច្នោះឡើយ ឯការសម្ដែងទោសនេះ មាន

ប្រយោជន៍នោះឯង ។ ចិត្ត ឈ្មោះថា ជាធម្មជាតិបង្អោនទៅក្នុងធម៌ ដែលផ្ទុយគ្នារបស់ធម៌ដែលខ្ពាចនោះ ព្រោះជាធម្មជាតិមានការប្រាថ្នានឹងរួចផុត ដោយចំណែកមួយអំពីទោសដែលបានឃើញហើយយ៉ាងល្អ ដូចបុគ្គលដែលត្រូវកម្ដៅគ្របសង្កត់ក៏បង្អោនទៅក្នុងសភាពត្រជាក់ ដូច្នោះ ។

ពាក្យថា **ជារបស់គួរខ្ពាច** គឺជារបស់គប្បីខ្ពាច ។ ដោយពាក្យថា **ជាទុក្ខដោយពិត** នេះ លោកអាចារ្យរមែងសម្ដែងថា វត្ថុដែលគួរខ្ពាចនោះ ជារបស់ដែលគប្បីខ្ពាច ដោយជាទុក្ខ ដូច្នោះ របស់ដែលគប្បីខ្ពាច ទើបមិនគ្របដណ្ដប់ទៅដល់ទុក្ខផង ។ អាចារ្យទាំងឡាយ រមែងពោលថា **វដ្ដាមិស** ( អាមិស គឺវដ្ដៈ ) បានដល់ឧបាទិន្នក្ខន្ធទាំងឡាយ ។ វដ្ដៈទាំង ៣ យ៉ាង និងវត្ថុដែលអាស្រ័យវដ្ដៈ ឈ្មោះថា **វដ្ដាមិស** ។ ឈ្មោះថា **លោកាមិស** ព្រោះកិលេសទាំងឡាយ គប្បីពាល់ត្រូវ បានដល់កាមគុណ ៥ ។ កិលេសនោះឯង ឈ្មោះថា **កិលេសាមិស** ។ ដោយ **ឯវ**-ស័ព្ទ ក្នុងបទថា **សង្ខារមត្តមេវ** លោកអាចារ្យរមែងបដិសេធវិសង្ខារ ។ ព្រោះថា ក្នុងវិសង្ខារនោះ ភាពជាសាមិសតែបន្តិចបន្តួចមិនមានឡើយ ដូច្នេះ ។ ដោយ **មត្ត**-ស័ព្ទ លោកអាចារ្យរមែងសម្ដែងជារបស់មិនគ្រប់ចំនួន ។ ព្រោះថា សង្ខារទាំងអស់ជាសាមិសក៏ទេ ។ ពាក្យថា **ព្រោះហេតុនោះ** សេចក្ដីថា ព្រោះពាក្យដែលពោលទុកថា **ជារបស់គួរខ្ពាច** ដូច្នេះ ជាពាក្យដែលពិតដោយភាពជាទុក្ខជាដើម ។ លោកអាចារ្យបានដាក់ចិត្តដល់ការសាកសួរថា បើវត្ថុណាជារបស់គួរខ្ពាច វត្ថុនោះ បើមានសេចក្ដីទុក្ខជាដើម ជាសភាវៈនោះឯង កាលបើដូច្នោះ ក្នុងរឿងនៃការខ្ពាចជាដើម ក៏សម្រេចដោយអាការដូចគ្នានោះឯង ។ ព្រោះហេតុអ្វី ទើបលោកកាន់យកទាំងអស់ទៅវិញទើបពោលថា **សូម្បីយ៉ាងនោះ** ដូច្នេះជាដើម ។ ភាពផ្សេងគ្នានៃការពិចារណាឃើញដោយភាពផ្សេងគ្នានៃអាការ ដោយអំណាចការប្រព្រឹត្តទៅ ដោយភាពមិនទៀង ជាទុក្ខ

ជាអនត្តា ក្នុងសង្ខារទាំងនោះឯង យ៉ាងណា **ការផ្សេងគ្នា** នៃញាណ **ក្នុងធម៌ចំណែកដែលជាទោសនេះ ដោយអំណាចការប្រព្រឹត្តទៅ** ដោយភាពផ្សេងគ្នានៃអាការ មានអាការជារបស់គួរខ្លាចជាដើម ក៏ដូច្នោះ ។ ក្នុងការផ្សេងគ្នានៃអាការនោះ ញាណដែលប្រព្រឹត្តទៅ ដោយអាការជារបស់គួរខ្លាច គប្បីឃើញថា ឈ្មោះថា **ភយតុ-បដ្ឋានញ្ញាណ** ញាណដែលប្រព្រឹត្តទៅដោយអាការក្រៅអំពីនេះ គប្បីឃើញថា ឈ្មោះអាទីនវញ្ញាណ ។

ព្រោះអត្ថទាំង ១៥ យ៉ាង ដែលលោកពោលទុកជាអារម្មណ៍នៃអាទីនវញ្ញាណ ជាអត្ថឈោងចុះខាងក្នុង ក្នុងធម៌ ៥ យ៉ាង មានឧប្បាទជាដើមនោះឯង និងញាណក្នុងធម៌ទាំង ៥ នោះ ក៏ជា ១០ យ៉ាង ព្រោះប្រព្រឹត្តទៅដោយអំណាចអន្វយន័យ ( អនុលោមតាម ) និងព្យតិរេកន័យ ( ពិសេស ) ។ ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្រពោលថា **រមែងដឹងទូទៅក្នុងញាណ ១០** ដូច្នេះ ។ ឯការដឹងទូទៅ លោកពោលទុក ព្រោះធ្វើអធិប្បាយថា ដូចដឹងទូទៅនូវខ្លួនឯង ព្រោះមិនវង្វេងដោយប្រាសចាកសម្មោហៈ ក្នុងអារម្មណ៍ដ៏កំពូល ទាំងមិនវង្វេងក្នុងខ្លួនឯងនោះ ដូច្នេះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងចាក់ធ្លុះ រមែងធ្វើឲ្យជាក់ច្បាស់** ដូច្នេះ បទថា **ទ្វិន្នំ** សេចក្តីប៉ុនគ្នានឹង **ទ្វីសុ** ឯបទនេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ព្រោះប្រកបដោយកុសលស័ព្ទ ដូចពាក្យថា **កុសលា នច្ចគីតស្ស** ប្រែថា ភាពជាអ្នកឆ្លាតក្នុងការរាំ និងច្រៀង ។ បទថា **កុសលតា** ជាបឋមាវិភត្តិ ចុះក្នុងតតិយាវិភត្តិ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទ្វិន្នំ កុសលតាយ** ព្រោះជាបុគ្គលឈ្លាសក្នុងញាណទាំង ២ ។ ម្យ៉ាងទៀត បទថា **ទ្វិន្នំ** សេចក្តីថា ដោយអំណាចនៃញាណទាំង ២ ។ សន្ធិបទ រមែងប្រាកដជាធម៌ដែលវិនិច្ឆ័យបានត្រឹមត្រូវនោះឯង ដោយញាណចំណែកផ្ទុយគ្នារបស់អាទីនវញ្ញាណនោះ ព្រោះបានឃើញតាម

សេចក្តីពិតនូវការប្រព្រឹត្តទៅ ។ ដោយហេតុនោះ ទើបចិត្តរបស់ព្រះយោគាវចរនោះ មិនញាប់ញ័រ ដោយអំណាចការប្រកាន់ខុស មានប្រកាន់ក្នុងទិដ្ឋធម្មនិព្វានជាបរមធម៌ជាដើម ។ ព្រោះព្រះយោគីជាអ្នកឃើញទោសជាក់ច្បាស់ហើយ ក្នុងសង្ខារនោះ ហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្រ ពោលថា **មិនញាប់ញ័រ** ព្រោះទិដ្ឋិផ្សេងៗ ដូច្នេះជាដើម ពាក្យដ៏សេសក្នុងអធិការនេះ មានអត្ថងាយហើយ ។

អាទីនវានុបស្សនាញាណ ចប់ ។

# វិសុទ្ធិមគ្គ

## និព្វិទានុបស្សនាញាណ

ព្រះយោគាវចរនោះ ឃើញកងសង្ខារដោយជាទោសយ៉ាងនោះ រមែងនឿយណាយ ខ្ពាចរអា មិនត្រេកអរយ៉ាងក្រៃលែងក្នុងសង្ខារ ដែលបែកធ្លាយនៅក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួង ប្រៀបដូចសុវណ្ណរាជហង្សដែលអភិរម្យនៅឯជើងភ្នំចិត្រកូដ (ក្នុងហិមពាន្ត) រមែងមិនត្រេកអរក្នុងអណ្តូង (ទឹកជ្រាំ) ស្មោកគ្រោក ជិតទ្វារភូមិនៃមនុស្សចណ្ឌាល ត្រេកអរក្រៃលែងតែក្នុងមហាស្រះទាំង ៧ ប៉ុណ្ណោះ យ៉ាងណា សូម្បីព្រះយោគីរាជហង្សនេះ ក៏ដូច្នោះដែរ រមែងមិនត្រេកអរក្នុងសង្ខារ ដែលបែកធ្លាយទូទៅ ដែលមានទោស ដែលបុគ្គលឃើញច្បាស់ហើយ រមែងត្រេកអរតែក្នុងអនុបស្សនា ៧ ប៉ុណ្ណោះ ព្រោះប្រកបដោយជាបុគ្គលមានភាវនាជាទីត្រេកអរ ដោយការត្រេកអរក្នុងភាវនា ។ មួយវិញទៀត ប្រៀបដូចសីហមិគរាជសូម្បីដាក់ក្នុងទ្រុងមាស ក៏មិនបានត្រេកអរ រមែងត្រេកអរតែក្នុងព្រៃហិមពាន្ត ដែលមានទំហំ ៣ ពាន់យោជន៍ប៉ុណ្ណោះ យ៉ាងណា ព្រះយោគីសីហៈនេះ ក៏ដូច្នោះ រមែងមិនត្រេកអរក្នុងសុគតិភពទាំង ៣ រមែងត្រេកអរតែក្នុងអនុបស្សនា ៣ ប៉ុណ្ណោះ ។ មួយវិញទៀត ឧបមាដូចស្តេចដំរីឆទ្ទន្ត ដែលជាដំរីសសុទ្ធ ជាដំរីសត្តប្បតិដ្ឋ (មានអវយវៈដល់ផែនដី ៧ យ៉ាង) មានឫទ្ធិដើរក្នុងអាកាសបាន រមែងមិនត្រេកអរនៅក្នុងកណ្តាលក្រុង ត្រេកអរក្រៃពេក តែក្នុងស្រះឆទ្ទន្ត និងព្រៃហិមពាន្តប៉ុណ្ណោះ យ៉ាងណា ព្រះយោគីវរវារណៈនេះ ក៏ដូច្នោះ រមែងមិនត្រេកអរក្នុងសង្ខារទាំងពួង

ត្រេកអរក្រៃលែងតែក្នុងសន្តិបទ ដែលខ្លួនឃើញហើយ ដោយន័យថា **អនុប្បាទោ ខេមំអនុប្បាទ** ជាធម៌ក្សេម, ដូច្នេះជាដើម ជាបុគ្គលមានចិត្តបង្អោនទៅក្នុងសន្តិបទនោះ ជម្រាលទៅក្នុងសន្តិបទនោះ លំអៀងទៅក្នុងសន្តិបទនោះឯង ។

និព្វិទានុបស្សនាញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយនិព្វិទានុបស្សនាញាណ

ពាក្យថា **ក្នុងសង្ខារ** គឺក្នុងសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងឡាយ ។ ពាក្យថា **រមែងនឿយណាយ** គឺរមែងដល់នូវការនឿយណាយ ដោយការនឿយណាយ គឺញាណ ។ ឯព្រះយោគីជាបុគ្គលយ៉ាងនោះ ឈ្មោះថា **រមែងខ្ពើមរអើ** **និងមិនត្រេកអរ** **នៅក្នុងសង្ខារនោះ** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងខ្ពើមរអើ** **មិនត្រេកអរក្រៃលែង** ដូច្នេះ ។

ក្នុងពាក្យនោះ ដើម្បីសម្ដែងឧបមា នៃការមិនត្រេកអរ ទើបលោកអាចារ្យពោលពាក្យថា **សេយ្យថាបិ** ជាដើម ។ បណ្ដាមហាកំពូលនៃភ្នំហិមពាន្តទាំង ៥ ដែលផ្សេងដោយឈ្មោះថា គន្ធមាទន៍ កាឡបព៌ត កៃលាស សុទស្សនៈ និងចិត្រកូដ ដែលសម្រេចដោយកែវឆ្នូត រ៉ែ ត្បូង ប្រាក់ មាស និងរតនៈទាំង ៧ តាមលំដាប់ កម្ពស់បាន ២០០ យោជន៍ ព័ទ្ធជុំវិញអនោតត្តស្រះ **ភ្នំឈ្មោះចិត្រកូដ ជាកំពូលចុងក្រោយ ក្នុងមហាស្រះទាំង ៧ មានមហាស្រះឈ្មោះសីហបបាតៈ** ជាដើម ។

ពាក្យថា **ក្នុងទ្រុងមាស** គឺក្នុងសីហបញ្ជរ ដែលធ្វើដោយមាស ។ ពាក្យថា **ឃាំងទុក** គឺត្រូវរាំងទុក ។ ពាក្យថា **ក្នុងសុគតិភពទាំង ៣** គឺក្នុងសម្បត្តិភព ៣ យ៉ាង មានកាមសុគតិភពជាដើម ។

ឈ្មោះ **សត្តបតិដ្ឋ** ព្រោះអត្ថថា មានអវយវៈទល់ផែនដី ៧ យ៉ាង គឺប្រមោយ ១ ជើង ៤ កន្ទុយ ១ ស្រោមលិង្គ ១ ឈ្មោះថា **រមែងមិនត្រេកអរក្នុងក្រុង** ព្រោះខ្ពើម

ការបៀតបៀន ដោយបន្ទោះទ្រុងនៃទ្វារ ។ ពាក្យថា **ដែលខ្លួនឃើញហើយ** គឺដែលខ្លួនឃើញហើយ ដោយការឃើញការអនុលោមតាម ដែលមានអធិមុត្តិជាខាងដើម ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ជាអ្នកមានចិត្តបង្អោនទៅក្នុងសន្តិបទនោះ ជម្រាលទៅក្នុងសន្តិបទនោះ លំអៀងទៅក្នុងសន្តិបទនោះ** ។

និព្វិទានុបស្សនាញាណ ចប់ ។

# វិសុទ្ធិមគ្គ

## មុញ្ចិតុកម្យតាញាណ

ឯនិព្វិទានុបស្សនាញាណនេះ ដោយអត្ថក៏ជាការដូចគ្នានឹងញាណ ២ ខាងដើម ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា ភយតុបដ្ឋានញ្ញាណ តែមួយនោះឯង បានឈ្មោះ ៣ គឺឈ្មោះថា ភយតុបដ្ឋាន ព្រោះបានឃើញសង្ខារទាំងពួងជារបស់គួរខ្លាច បានឈ្មោះថា អាទីនវានុបស្សនា ព្រោះញុំាំងការឃើញទោសក្នុងសង្ខារទាំងនោះឯងឲ្យកើតឡើង បានឈ្មោះថា និព្វិទានុបស្សនា ក៏ព្រោះនឿយណាយសង្ខារទាំងនោះឯងកើតឡើង សូម្បីក្នុងព្រះបាលីក៏ពោលទុកថា ការដឹងទូទៅក្នុងភយតុបដ្ឋានឯណាក្តី ការឈោងចុះក្នុងអាទីនវៈឯណាក្តី និព្វិទាឯណាក្តី ធម៌ទាំងនេះមានអត្ថតែមួយ ផ្សេងគ្នាតែព្យញ្ជនៈ ដូច្នេះ ។

កាលកុលបុត្រនឿយណាយ ខ្លាចរអា មិនត្រេកអរយ៉ាងក្រៃលែង ដោយនិព្វិទាញាណនេះ ចិត្តរមែងមិនជាប់ មិនជំពាក់ មិនចងច្បាក់នៅក្នុងសង្ខារទាំងឡាយដែលបែកធ្លាយទូទៅក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាសទាំងពួង ជាចិត្តប្រាថ្នានឹងដោះទៅ ប្រាថ្នានឹងចេញទៅអំពីសង្ខារទាំងឡាយ សេចក្តីនេះប្រៀបដូចអ្វី ? ប្រៀបដូចសត្វ ដូចជាត្រីដែលធ្លាក់នៅក្នុងសំណាញ់ កង្កែបនៅក្នុងមាត់ពស់ មាន់ព្រៃត្រូវឃាំងទុកក្នុងទ្រុង ម្រឹគនៅក្នុងអំណាចអន្ទាក់ដ៏មាំ ពស់នៅក្នុងដៃអាលម្ពាយ ដំរីធ្លាក់នៅក្នុងរណ្តៅធំ ស្តេចនាគនៅក្នុងមាត់គ្រុឌ ព្រះចន្ទធ្លាក់ចូល មាត់រាហ៊ូ បុរសត្រូវសត្រូវហ៊ុំមព័ទ្ធ យ៉ាងនេះជាដើម រមែងជាអ្នកប្រាថ្នានឹងដោះខ្លួនទៅ ប្រាថ្នានឹង

ចេញទៅអំពីទីដែលជាប់នៅនោះ យ៉ាងណា ចិត្តរបស់ព្រះយោគីនោះ ក៏ជាចិត្តប្រាថ្នានឹងដោះទៅ ប្រាថ្នានឹងចេញទៅអំពីសង្ខារទាំងពួង ដូច្នោះ កាលបើយ៉ាងនោះ ទើបមុញ្ចិតុកម្យតាញាណកើតឡើងដល់លោក ដែលប្រាសចាកអាល័យ ក្នុងគំនរសង្ខារ ប្រាថ្នានឹងផុតទៅអំពីសង្ខារទាំងពួង ដូចពោលមកដូច្នេះឯង ។

មុញ្ចិតុកម្យតាញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយមុញ្ចិតុកម្យតាញាណ

លោកអាចារ្យពោលនិព្វិទាញាណថា ឯនិព្វិទានុបស្សនាញាណនេះ ។ ពាក្យថា **ដោយញាណទាំង ២** គឺដោយភយតុបដ្ឋានញ្ញាណ និងអាទីនវានុបស្សនាញាណទាំង ២ ។ ព្រោះសង្ខារទាំងឡាយដែលប្រាកដជារបស់គួរខ្លាចនោះឯង រមែងប្រាកដជាសភាវៈដែលមានទោសច្រើន និងគួរនឿយណាយ ដូច្នោះ ញាណនោះ សូម្បីតែមួយ ក៏ប្រកបដោយការផ្សេងគ្នានៃអាការដែលតាំងចុះ ព្រោះការដល់នូវកម្លាំងនៃភាវនាយ៉ាងនោះ រមែងជាធម្មជាតិមានសមត្ថភាពក្នុងកិច្ច ៣ យ៉ាង ព្រោះហេតុនោះទើបលោកអាចារ្យពោលថា **ដោយអត្ថក៏ដូចគ្នា** ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **សង្ខារទាំងពួង** ដូច្នេះជាដើម និព្វិទាញាណនេះ លោកពោលដោយអំណាចការដល់កំពូលនៃអនុបស្សនាទាំងនោះ ឯអនុបស្សនាដែលមានសភាពផ្សេងគ្នានោះឯង រមែងប្រព្រឹត្តទៅខាងដើម ។ ពាក្យថា **ឲ្យកើតឡើង** គឺធ្វើឲ្យប្រាកដ អធិប្បាយថា ធ្វើឲ្យជាក់ច្បាស់ ។

ឈ្មោះថា **មិនជាប់** ព្រោះបានឃើញសង្ខារមានទោសច្រើន ។ ឈ្មោះថា **ជាចិត្តប្រាថ្នានឹងដោះទៅ ប្រាថ្នានឹងចេញទៅ** ព្រោះកំណត់ដឹងនូវខន្ធ ដែលប្រព្រឹត្តទៅក្នុងកាលមិនមានទីបំផុតខាងដើម ។ **ចិត្តប្រាថ្នានឹងដោះទៅ** បានដល់ ចិត្តប្រាថ្នានឹងញាំងខ្លួន ឲ្យចៀសចេញអំពីសង្ខារនោះ ចិត្តប្រាថ្នានឹងរលាស់ចេញជាចិត្តប្រាថ្នានឹងប្រាសចេញទៅ ។ ពាក្យថា **ត្រូវឃាំងក្នុងទ្រុង** គឺត្រូវទ្រុងរាំងទុក ។ ដោយ

**អាទិ-**ស័ព្ទ ក្នុងពាក្យថា **ឯវមាទយោ** គប្បីឃើញការសង្គ្រោះយករងើកភ្លើងដែលភ្លើងឆេះទូទៅហើយ ទីដែលរាំរាំងព្រៃស្ងួត ដែលដេរដាសទៅដោយអន្តរាយយ៉ាងសាហាវជាដើម ។

មុញ្ចិតុកម្យតាញាណ ចប់ ។

# វិសុទ្ធិមគ្គ

## បដិសង្ខានុបស្សនាញាណ

ព្រះយោគាវចរនោះ កាលប្រាថ្នានឹងដោះទៅអំពីសង្ខារទាំងឡាយដែលកំពុងបែកទូទៅក្នុងភព កំណើត គតិ ឋិតិ និងនិវាសទាំងពួងយ៉ាងនោះ ទើបកំណត់សង្ខារទាំងនោះឯងទៀត លើកឡើងកាន់ត្រៃលក្ខណ៍ ដោយបដិសង្ខានុបស្សនាញាណ លោករមែងឃើញបានថា **សង្ខារមិនទៀង** ដោយហេតុទាំងឡាយ ដូចជា

| | |
|---|---|
| អនច្ចន្តិកតោ | ជាវត្ថុមិនមាននៅរហូតទៅ |
| តាវកាលិកតោ | ជារបស់មានកាល |
| ឧប្បាទវយបរិច្ឆិន្នតោ | ជារបស់ត្រូវកំណត់ទុកដោយការកើតនិងការសូន្យ |
| បលោកតោ | ជារបស់ត្រូវវិនាស |
| ខណិកតោ | ជារបស់មានខណៈ |
| ចលតោ | ជារបស់កម្រើកញាប់ញ័រ |
| បភង្គុតោ | ជារបស់ត្រូវបែកធ្លាយ |
| អធុវតោ | ជារបស់មិនស្ថិតស្ថេរ |
| វិបរិណាមធម្មតោ | ជារបស់មានការប្រែប្រួលទៅជាធម្មតា |
| អសារកតោ | ជារបស់មិនមានខ្លឹម |
| វិភវតោ | ជារបស់ប្រាសចាកសេចក្តីចម្រើន |
| សង្ខតតោ | ជារបស់តាក់តែងឡើង |
| មរណធម្មតោ | ជារបស់មានមរណៈជាធម្មតា |

រមែងឃើញបានថា **សង្ខារជាទុក្ខ** ដោយហេតុទាំងឡាយ ដូចជា

| | |
|---|---|
| អភិណ្ហប្បដិបីឡនតោ | ត្រូវបៀតបៀនជានិច្ច |
| ទុក្ខមតោ | ជារបស់អត់ធន់លំបាក |
| ទុក្ខវត្ថុតោ | ជាទីតាំងរបស់ទុក្ខ |
| រោគតោ | ជារោគ |
| គណ្ឌតោ | ជាបូស |
| សល្លតោ | ជាសរ |
| អឃតោ | ជារបស់លំបាក |
| អាពាធតោ | ជាអាពាធ |
| ឦតិតោ | ជាចង្រៃ |
| ឧបទ្ទវតោ | ជាឧបទ្រព |
| ភយតោ | ជាភ័យ |
| ឧបសគ្គតោ | ជាឧបសគ្គ |
| អតាណតោ | មិនមានទីជ្រកកោន |
| អលេណតោ | មិនមានទីពួន |
| អសរណតោ | មិនមានទីពឹង |
| អាទីនវតោ | ជាទោស |
| អឃមូលតោ | ជាឫសគល់នៃសេចក្ដីលំបាក |
| វធកតោ | ជាអ្នកសម្លាប់ |
| សាសវតោ | ជារបស់ប្រព្រឹត្តទៅជាមួយអាសវៈ |
| មារាមិសតោ | ជាអាមិសរបស់មារ |
| ជាតិធម្មតោ | ជារបស់មានជាតិជាធម្មតា |

| | |
|---|---|
| ជរាធម្មតោ | ជារបស់មានជរាជាធម្មតា |
| ព្យាធិធម្មតោ | ជារបស់មានព្យាធិជាធម្មតា |
| មរណធម្មតោ | ជារបស់មានមរណៈជាធម្មតា |
| សោកធម្មតោ | ជារបស់មានសោកជាធម្មតា |
| បរិទេវធម្មតោ | ជារបស់មានការខ្សឹកខ្សួលជាធម្មតា |
| ឧបាយាសធម្មតោ | ជារបស់មានការចង្អៀតចង្អល់ជាធម្មតា |
| សង្កិលេសិកធម្មតោ | ជារបស់មានការសៅហ្មងជាធម្មតា |

រមែងឃើញបាន **ជារបស់មិនស្អាត** ដែលជាបរិវារនៃទុក្ខលក្ខណៈ ដោយហេតុទាំងឡាយ ដូចជា

| | |
|---|---|
| អជញ្ញតោ | ជារបស់មិនស្អាត |
| ទុគន្ធតោ | ជារបស់មានក្លិនស្អុយ |
| ជេគុច្ឆតោ | ជារបស់គួរខ្ពើម |
| បដិកូលតោ | ជារបស់គួរបដិកូល |
| អមណ្ឌនហតតោ | ជារបស់មិនកម្ចាត់ ( ការបដិកូល ) បានដោយការស្អិតស្អាង |
| វិរូបតោ | ជារបស់គួរស្អប់ |
| វិភច្ឆតោ | ជារបស់គួររង្កៀស |

រមែងឃើញបាន ជា **អនត្តា** ដោយហេតុទាំងឡាយ ដូចជា **បរតោ** ជារបស់ដទៃ **រិត្តតោ** ជាទីវាល **តុច្ឆតោ** ជារបស់ទទេ **សុញ្ញតោ** ជារបស់សោះសូន្យ **អស្សាមិកតោ** ជារបស់មិនមានម្ចាស់ **អនិស្សរតោ** ជារបស់មិនមានឥស្សរៈ **អវសវត្តិតោ** ជារបស់មិននៅក្នុងអំណាច ។

ឯសង្ខារទាំងឡាយ ឈ្មោះថា ត្រូវបានព្រះយោគាវចរដែលឃើញយ៉ាងនោះ បានកំណត់លើកឡើងកាន់ត្រៃលក្ខណ៍ហើយ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះយោគីនេះកំណត់សង្ខារទាំងឡាយយ៉ាងនោះ ? ឆ្លើយថា កំណត់យ៉ាងនោះ ដើម្បីញ៉ាំងឧបាយនៃការដោះឲ្យសម្រេច នេះជាឧបមាក្នុងឧបាយនោះ

ឧបមាដូចបុរសម្នាក់ គិតនឹងចាប់ត្រី ទម្លាក់អង្រុតចាប់ត្រីទៅក្នុងទឹក ( លុះដឹងថា រុតត្រូវត្រី ) ទើបលូកដៃចូលទៅតាមមាត់អង្រុត ចាប់ត្រូវពស់ (វែក) ត្រង់ក នៅក្នុងទឹក យល់ថា ខ្លួនចាប់បានត្រី ក៏ត្រេកអរ គិតថា **អញបានត្រីធំហ្ន៎** ហើយ លើកឡើងមកមើល លុះដឹងថា ពស់ ដោយឃើញសវត្ថិក ៣ ធ្នូត ( ធ្នូតរាងដូចផ្កាចន្ទន៍ ) ក៏ខ្លាច សម្លឹងឃើញផលអាក្រក់ ធុញថប់ក្នុងការចាប់ប្រាថ្នាលែងចោល កាលនឹងធ្វើឧបាយលែង ទើបដោះដៃ ( ដែលពស់រុំ ) តាំងអំពីកន្ទុយចេញហើយ លើកដៃឡើង គ្រវី ( ពស់ ) លើក្បាល ២-៣ ជុំ ធ្វើពស់ឲ្យទន់ខ្សោយ ហើយបណ្ដេញថា **ទៅចុះអាពស់កាច** ( ពោលហើយលែងដៃ ) វលាស់ ( ពស់ ) ទៅ ហើយប្រញាប់ប្រញាល់ឡើងមាត់បឹង ឈរមើលផ្លូវដែល ( កករឡើង ) មកនឹក រំពឹងក្នុងថា **អាត្មាអញរួចអំពីមាត់ពស់ធំមកបាន ម្ចាស់ថ្លៃអើយ** ។

កាលព្រះយោគីនេះ បានអត្តភាពហើយ ត្រេកអរអំពីដំបូង ( កាលដឹងសេចក្ដី ) នោះឯង ប្រៀបដូចពេលដែលបុរសនោះ ចាប់ត្រូវពស់ត្រង់ក ហើយសប្បាយចិត្ត ដោយសម្គាល់ថា ត្រីដូច្នោះ ការធ្វើវិនិព្ភោគរហូតឃើញត្រៃលក្ខណ៍ក្នុងសង្ខារទាំងឡាយ នៃព្រះយោគីនោះ ប្រៀបដូចការទាញក្បាល ( ពស់ ) ចេញអំពីមាត់អង្រុតហើយ ហើយឃើញសវត្ថិក ៣ ធ្នូត នៃបុរសនោះ ភយតុបដ្ឋានញ្ញាណនៃព្រះយោគីនេះ ប្រៀបដូចពេល ( កើត ) ការខ្លាចឡើងនៃបុរសនោះ តអំពីនោះ អាទីនវានុបស្សនាញ្ញាណ ប្រៀបដូចការឃើញផលអាក្រក់ និព្វិទានុបស្សនាញ្ញាណ ប្រៀបដូចការធុញ

ចប់ក្នុងការចាប់ ( ពស់ទុក ) មុញ្ចិតុកម្យតាញាណ ប្រៀបដូចការប្រាថ្នានឹងលែងពស់ ការលើកឡើងកាន់ត្រៃលក្ខណ៍ក្នុងសង្ខារទាំងឡាយ ដោយបដិសង្ខានុបស្សនាញាណ ប្រៀបដូចការធ្វើឧបាយដើម្បីលែង ដូចជាបុរសនោះគ្រវីពស់ ធ្វើឲ្យពស់ទន់ខ្សោយ ឲ្យពស់ដល់នូវការមិនអាចនឹងត្រឡប់មកចឹកបាន ហើយលែងទៅយ៉ាងល្អ យ៉ាងណា ព្រះយោគាវចរនេះ ក៏គ្រវីសង្ខារទាំងឡាយ លើកឡើងកាន់ត្រៃលក្ខណ៍ ធ្វើឲ្យខ្សោយកម្លាំង ឲ្យដល់នូវការមិនអាចនឹងមានមុខ ដោយអាការទៀង ជាសុខ ស្អាត និងជាអត្តាបានទៀត ហើយដោះទៅយ៉ាងល្អ ដូច្នោះ ព្រោះហេតុនោះ ទើបពោលទុកថា ព្រះយោគាវចរកំណត់ ( សង្ខារ ) យ៉ាងនោះ ដើម្បីញុំាងឧបាយនៃការដោះឲ្យសម្រេច ដូច្នេះ ។

ដោយការពិចារណា ( ដឹង ) ត្រឹមប៉ុណ្ណេះ បដិសង្ខាញាណត្រូវបានកើតឡើង ដល់ព្រះយោគាវចរនោះហើយ ដែលលោកសំដៅយក ពោលទុក ( ក្នុងបដិសម្ភិទាមគ្គ ) ថា កាលភិក្ខុធ្វើមនសិការដោយការមិនទៀង ញាណពិចារណា ( ដឹង ) អ្វីកើតឡើង កាលភិក្ខុធ្វើមនសិការដោយអាការជាទុក្ខ... ដោយអាការជាអនត្តា ញាណពិចារណា ( ដឹង ) អ្វីកើតឡើង ? កាលភិក្ខុធ្វើមនសិការ ដោយអាការមិនទៀង ញាណពិចារណានិមិត្ត កើតឡើង កាលភិក្ខុធ្វើមនសិការ ដោយអាការជាទុក្ខ ញាណពិចារណាបវត្តកើតឡើង កាលភិក្ខុធ្វើមនសិការ ដោយអាការជាអនត្តា ញាណពិចារណា ទាំងនិមិត្តទាំងបវត្ត កើតឡើង ។

ឯពាក្យថា និមិត្តំ បដិសង្ខា ក្នុងបាលីនេះ មានអត្ថថា ដឹងសង្ខារនិមិត្តដោយអំណាចអនិច្ចលក្ខណៈថា សង្ខារនិមិត្ត ជារបស់មិនស្ថិតស្ថេរប្រព្រឹត្តទៅម្តងម្កាលពិតហើយ ដឹងមុនហើយ ទើបញាណកើតតាមក្រោយ ដោយពិត សូម្បីយ៉ាងនោះ លោកពោល ( ជាសមានកាលកិរិយា ) យ៉ាងនោះ ក៏ដោយអំណាចវោហារ ដូចពាក្យ

ថា មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ មនោវិញ្ញាណអាស្រ័យមនៈ និង ធម្មារម្មណ៍ទាំងឡាយកើតឡើង ដូច្នេះជាដើម ។ ន័យម៉្យាងទៀត គប្បីជ្រាបថា លោក ពោលយ៉ាងនោះ ព្រោះធ្វើពាក្យនាំមុខ និងពាក្យក្រោយឲ្យត្រូវគ្នា ដោយឯកត្តន័យ សូម្បីអត្ថក្នុងពីរបទក្រៅអំពីនេះ ក៏គប្បីជ្រាបដូច្នេះឯង ។

បដិសន្ធានុបស្សនាញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយបដិសង្ខានុបស្សនាញាណ

កាលដែលលោកអាចារ្យពោលថា **សព្វករ ។បេ។ មុញ្ចិតុកាមោ** ដូច្នេះ ហើយកាន់យក **សព្វ** ថា **សព្វេស្មា សង្ខារគតា** ទៀត ជាពាក្យដែលជំក្រៃលែង ដើម្បីនឹងសម្ដែងដល់ការរួចផុត យ៉ាងវិសេសក្រៃលែង រមែងធ្វើឲ្យអ្នកជំទៃយល់សេចក្ដីបាន ។ ឯការរួចផុតនៃការមិនចងខ្ទាក់ដោយសង្ខារទាំងឡាយឯណា ការរួចផុតនោះ ជាការរួចផុតដោយមានភាពវិសេសក្រៃលែង ។ ហើយការរួចផុតនោះ រមែងមានបានដោយបដិសង្ខានុបស្សនាដែលកំពុងពោល ហេតុនោះ ដើម្បីសម្ដែងបដិសង្ខានុបស្សនានោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **បុន តេ ឯវំ សង្ខារេ** ដូច្នេះ ។ ការលើកឡើងកាន់ត្រៃលក្ខណ៍ កំណត់សង្ខារ បានធ្វើទុកស្ទួយក្នុងកាលមុន ព្រោះហេតុនោះ ទើបលោកប្រើសព្ទថា **បុន** ។ លោកអាចារ្យពោលថា **តេ** ព្រោះមិនមានសង្ខារ ដែលនៅក្នុងភពជាដើម ដែលមិនបានកំណត់ពិចារណា ។ លោកអាចារ្យពោលថា **ឯវំ** ក៏ព្រោះមានអាការ គឺការតាមពិចារណា ដែលមិនទាន់ធ្លាប់មានមកអំពីមុន ។ មានអធិប្បាយថា ដោយអាការដែលពោល ក្នុងឥឡូវនេះ ឈ្មោះថា **ការកំណត់កាន់យកសង្ខារទាំងឡាយ** រមែងមានបានដោយអំណាចលក្ខណៈដែលបរិបូណ៌នោះឯង ព្រោះហេតុនោះ ទើបអាចារ្យពោលថា **លើកឡើងកាន់ត្រៃលក្ខណ៍** ។

ពាក្យណាដែលគួរពោល ក្នុងពាក្យជាដើមថា **អនច្ចន្តិកតោ** ពាក្យនោះ ខ្ញុំបានពោលទុកខាងដើមហើយនោះឯង ។ ដោយ **អាទិ**-សព្ទទី ១ សង្គ្រោះពាក្យទាំងឡាយមានជាដើមយ៉ាងនេះ គឺ **អាទិអន្តវន្តតោ** ដោយមានខាងដើម និងទីបំផុត **និច្ចបដិក្ខេបតោ** ដោយបដិសេធការទៀង ។

ដោយ **អាទិ**-ស័ព្ទ ២ សង្គ្រោះពាក្យទាំងឡាយជាដើមយ៉ាងនេះ គឺ **ឧទយ-វយបដិបីឡនតោ** ដោយត្រូវការកើតឡើង និងការសូន្យទៅបៀតបៀន ចំពោះ **សុខបដិក្ខេបតោ** ដោយបដិសេធសេចក្តីសុខ ។

បទថា **អជញ្ញតោ** ប្រែថា ជាវត្ថុមិនចម្រើនចិត្ត ឬប្រែថា ជារបស់មិនស្អាត បទថា **ជេគុច្ឆតោ** សេចក្តីថា ជាវត្ថុគួរខ្ពើមថា ទុគ ។ បទថា **បដិក្កូលតោ** សេចក្តីថា ជារបស់បដិកូល ព្រោះបដិបក្ខចំពោះរបស់ពេញចិត្តក្រៃលែង ។ សង្ខារទាំងឡាយ មិនមែនកម្ចាត់ ( របស់បដិកូល ) ដោយការស្អិតស្អាង អធិប្បាយថា កម្ចាត់ការស្អាត របស់សង្ខារទាំងនោះបាន ដោយការមិនស្អិតស្អាង ទើបឈ្មោះថា **អមណ្ឌនហតា** មិនមែនកម្ចាត់ ( ការបដិកូល ) បានដោយការស្អិតស្អាង ។ ម្យ៉ាងទៀត របស់មិនស្អាត នៃសង្ខារទាំងនោះ រមែងប្រាកដបានដោយការមិនស្អិតស្អាង ហេតុនោះ ទើបសង្ខារ ទាំងនោះ ឈ្មោះថា **អមណ្ឌនហតា** មានការមិនស្អាត ប្រាកដដោយការមិនស្អិត ស្អាង ។ សង្ខារទាំងឡាយ មានការមិនគប្បីកម្ចាត់បាន ដោយអាការស្អិតស្អាង ដូចពាក្យថា **អសូរិយបស្សា** បុគ្គលដែលព្រះអាទិត្យមើលមិនឃើញ ហេតុនោះ ទើប សង្ខារទាំងនោះ ឈ្មោះថា **អមណ្ឌនហតា** មិនមែនមានសភាវៈដែលគប្បីកម្ចាត់ដោយ ការស្អិតស្អាង ។ ព្រោះភាវៈដែលសង្ខារមានសភាព មិនគប្បីកម្ចាត់បានដោយការ ស្អិតស្អាង ហេតុនោះ ទើបលោកអាចារ្យពោលសំដៅយករូបសង្ខារទាំងឡាយ ។ បទ ថា **វិរូបតោ** សេចក្តីថា ជារបស់មិនល្អ ។ របស់ណារមែងចងអ្នកឃើញទាំងឡាយ ទុកក្នុងខ្លួន ដោយជាទីតាំងនៃបដិឃសំយោជនៈ ហេតុនោះ វត្ថុនោះ ឈ្មោះ **វិភច្ឆំ** ប្រែថា វត្ថុដែលគួររង្កៀស បានដល់ វត្ថុដែលស្អប់យ៉ាងក្រៃលែង កាលឃើញហើយ ក៏ជាហេតុកើតឡើងនៃទោមនស្ស ។ ម្យ៉ាងទៀត វត្ថុណាដែលគប្បីលះ ដូចលាមក ព្រោះជាវត្ថុមិនស្អាត និងជារបស់គួរខ្ពើមជាដើម របស់នោះឈ្មោះថា **វិភច្ឆំ** គួររង្កៀស ។

ដោយ **អាទិ**-ស័ព្ទក្នុងទីនេះ លោកសង្គ្រោះយកពាក្យទាំងឡាយ មានពាក្យយ៉ាងនេះ គឺ **អសុចិតោ** ជារបស់មិនស្អាត **អមនាបតោ** ជារបស់មិនគួរពេញចិត្ត ។ ដោយ **អាទិ**-ស័ព្ទទី ៤ លោកសង្គ្រោះពាក្យទាំងឡាយយ៉ាងនេះ គឺ **អបរិណាយកតោ** ដោយជារបស់មិនមាន អ្នកនាំ **អត្តបដិក្ខេបតោ** ដោយបដិសេធអត្តា ។

បទថា **អយំ យោគ យោគាវចរោ** ។ បទថា **មុញ្ចនស្ស** បានដល់ នៃការដោះ ដែលដោះល្អហើយ ដើម្បីមិនឲ្យតាមចងបានទៀត ។ បទថា **ឧបាយសម្បាទនត្ថំ** សេចក្ដីថា ការកំណត់បច្ច័យ ការពិចារណាដោយល្អ ដោយជារបស់មិនទៀងជាដើម ឈ្មោះថា **ឧបាយ** ដើម្បីញុំាងឧបាយនោះឲ្យសម្រេច ។

អ្នកប្រមង់ទាំងឡាយ រមែងបង់វត្ថុនេះចុះក្នុងទីនោះៗ ក្នុងទឹកដើម្បីចាប់ត្រី ហេតុនោះ វត្ថុនេះឈ្មោះថា **ខិប្បំ** បានដល់ អង្រុតជាគ្រឿងចាប់ត្រី ។ បទថា **ឱសាបេសិ** ប្រែថា រុតចុះទៅ អធិប្បាយថា រុតចុះ ។ ពាក្យថា **ពស់** បានដល់ ពស់វែក ។ ពាក្យថា **ក្នុងការចាប់** គឺក្នុងការចាប់មិនលែងពស់ តាមដែលចាប់ទុក ពាក្យថា **ដោះដៃ** បានដល់ ពន្លា គឺលែងចំណែករបស់ដៃដែលពស់ប្រើរង្វេលរបស់ខ្លួនរុំទុក **គ្រវី** គឺ បង្វិល ដោយការធ្វើឲ្យវិលទៅមក ។ ពាក្យថា **រលាស់** គឺចោលទៅ ។

ពាក្យថា **ក្នុងឧបមានោះជាដើម** ជាពាក្យប្រៀបធៀបដោយឧបមា ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **អំពីដំបូង** គឺក្នុងកាលដែលដល់នូវភាពជាអ្នកដឹងក្ដី ។ ពាក្យថា **ធ្វើយនវិនិព្ភោគ** គឺទទួលកម្មដ្ឋាន ហើយទម្លាយការប្រកាន់យក **ឃន:** មានភាពជាក្រុម ជាដុំជាដើម ។ បទថា **សុមុត្តំ** សម្ដែងភាវៈនបុំសក: ដូចក្នុងប្រយោគទាំងឡាយជាដើមថា **វិសមំ ចន្ទិមសុរិយា បរិវត្តន្តិ** ប្រែថា ព្រះចន្ទ និងព្រះអាទិត្យរមែងវិលទៅជុំវិញមិនស្មើគ្នា ។ ការដែលសង្ខារទាំងឡាយ ជាសភាវៈមិនអាចប្រាកដ ដោយអាការជារបស់ទៀងជាដើម ក៏ព្រោះវិបស្សនា ដែលមានប្រភេទជាអនិច្ចសញ្ញា

ជាដើម ដល់នូវភាពជាធម្មជាតិមានកម្លាំងដ៏កំពូល ។ និងភាពដែលមិនអាចប្រាកដនោះ ក៏ដោយការកំណត់ដ៏ល្អក្រៃលែងនូវអាការ មានមិនទៀងជាដើមនៃសង្ខារទាំងឡាយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **គ្រវី សង្ខារទាំងឡាយដោយលើកឡើងកាន់ត្រៃលក្ខណ៍ ធ្វើឲ្យខ្សោយកម្លាំង ឲ្យដល់នូវការមិនអាចប្រាកដដោយអាការទៀង ជាសុខ ស្អាត និងជាអត្តាបានទៀត** ដូច្នេះ ។ ឧបមាដូចក្នុងការប្រដាល់កីឡាជាគូបដិបក្ខគ្នា ដែលមានកម្លាំងជាង ញាំញីកាតីប្រដាល់ម្នាងទៀត ដោយការទាត់ ការដាល់ជាដើមក្នុងទីនោះៗ ធ្វើឲ្យគូបដិបក្ខដល់នូវភាពជាអ្នកមិនអាចនឹងទ្រាំដោយការទាត់ ការដាល់ជាដើមនោះ ។ មិនមែនធ្វើឲ្យគូបដិបក្ខដល់នូវភាពជាអ្នកអស់សមត្ថភាពតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត គូបដិបក្ខរមែងដល់នូវសេចក្តីទុក្ខស្មើរស្លាប់ ឬស្លាប់ សេចក្តីនេះយ៉ាងណា សូម្បីសង្ខារទាំងឡាយទាំងនេះ ក៏ដូច្នោះ កាលព្រះយោគីឲ្យដល់នូវភាពខ្សោយកម្លាំងយ៉ាងនោះ រមែងដល់នូវភាពជាសភាវៈមិនមានការសេពខុស និងរលត់ដោយប្រការទាំងពួង ដោយអានុភាពនៃញាណជាន់ខ្ពស់ ដូច្នេះ ។

បទថា **ឯត្តាវតា** សេចក្តីថា ដោយការពិចារណាដែលប្រព្រឹត្តទៅ ដោយអំណាចការកំណត់សង្ខារទាំងឡាយជារបស់មិនទៀងជាដើម ដោយអាការជាង ៤០ ដោយពាក្យថា **អនច្ចន្តិកតោ** ដោយមិនជាវត្ថុមាននៅរហូតទៅជាដើមយ៉ាងនេះ ។

ពាក្យណា ដែលគប្បីពោលក្នុងពាក្យទាំងឡាយ មានជាដើមថា **អនិច្ចតោ មនសិករោតោ** កាលមនសិការជារបស់មិនទៀង ដូច្នេះ ពាក្យនោះ មានន័យបានពោលទុកហើយ ក្នុងកថាដោយកយតុបដ្ឋានញាណនោះឯង ។

ចំណែកសេចក្តីផ្សេងគ្នា មានដូចតទៅនេះ

លោកអាចារ្យពោលអត្ថនៃបទថា **បដិសង្ខា** ថា **ជានិត្វា** ហើយសម្តែងថា ព្រះធម្មសេនាបតីសារីបុត្រពោលទុកយ៉ាងនេះ ដោយត្រឹមតែជាសទ្ទវោហារ ព្រោះ

សូម្បីកាលមិនមានភាពជាបុព្វកាល និងអបរកាល កិរិយា គឺ **បដិសន្ធាន** និង **ឧប្បជ្ជន** ក៏មានឋានៈស្មើគ្នា ទើបពោលពាក្យថា **ដោយពិត** ជាដើម ។ ដោយហេតុនោះ ប្រយោគនៃសព្ទនេះ ទើបមានដោយអំណាចសមានកាល ដូចក្នុងប្រយោគទាំងឡាយជាដើមយ៉ាងនេះ គឺ **កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា** ប្រែថា កុសលធម៌អាស្រ័យកុសលធម៌កើតឡើង ព្រោះហេតុប្បច្ច័យ និង **និហន្ត្វា តិមិរំ សព្វំ ឧគ្គតោយំ ទិវាករោ** ព្រះអាទិត្យនេះ ទម្លាយងងឹតទាំងពួងផុសឡើងហើយ ។ ម្យ៉ាងទៀត លោកអាចារ្យពោលពាក្យថា **មនញ្ច បដិច្ច** អាស្រ័យមនៈ ដូច្នេះជាដើម ដើម្បីសម្តែងថា អាស្រ័យមនៈ និងធម៌ទាំងឡាយមុនហើយ ចំណែកក្រោយ ទើបកើតមនោវិញ្ញាណក៏ទេ សូម្បីក្នុងអធិការនេះក៏យ៉ាងនោះ ។ ប្រយោគនៃសព្ទ ដូច្នេះ ឃើញបានដោយបុព្វកាលនោះឯង ក្នុងផ្លូវលោកដោយច្រើន ព្រោះហេតុនោះ ដើម្បីនឹងសម្តែងសេចក្តីនោះ សូម្បីក្នុងអធិការនេះ ដោយជាបុព្វកាលនោះឯង ទើបលោកអាចារ្យពោលថា **ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលយ៉ាងនោះ ព្រោះធ្វើពាក្យមុខ និងពាក្យក្រោយឲ្យជាពាក្យដូចគ្នា ដោយឯកត្តន័យ** ។ អត្ថនៃពាក្យនោះថា

ក្នុងបណ្តាញាណទាំងឡាយដែលកើតឡើងរឿយៗ គប្បីប្រកបកិរិយា គឺការពិចារណាដោយអំណាចញាណដំបូង និងគប្បីប្រកបកិរិយា គឺការកើតឡើងដោយអំណាចញាណដទៃអំពីនោះ មិនគប្បីសម្លឹងញាណទាំងនោះ ដោយការផ្សេងគ្នា ព្រោះការកាន់យកដោយអំណាចឯកត្តន័យ ព្រោះជាញាណធ្លាក់ទៅក្នុងការបន្តជាមួយគ្នា ។ ពាក្យថា **ក្នុងពីរបទក្រៅអំពីនេះ** គឺក្នុងពីរបទនេះថា **បវត្តំ បដិសង្ខា និមិត្តញ្ច បវត្តញ្ច បដិសង្ខា** ។

បដិសង្ខានុបស្សនាញាណ ចប់ ។

# វិសុទ្ធិមគ្គ

## សង្ខារុបេក្ខាញាណ

### កំណត់សុញ្ញតា ២ ចំណុច

ព្រះយោគាវចរនោះ កាលកំណត់បានថា សង្ខារទាំងពួងជារបស់សូន្យ ដោយបដិសង្ខានុបស្សនាញាណយ៉ាងនេះហើយ ទើបកំណត់សុញ្ញតា ( ភាពទទេ ) ជា ២ ចំណុចទៀតថា **សង្ខារនេះសោះសូន្យចាកអត្តក្តី ចាកអត្តនិយក្តី ។**

### កំណត់សុញ្ញតា ៤ ចំណុច

ព្រះយោគាវចរនោះ កាលមិនឃើញតួខ្លួន មិនឃើញសត្វ សង្ខារដទៃណាមួយ តាំងនៅក្នុងភាពជាបរិក្ខារ (បរិវារ ឬគ្រឿងចោមរោម) របស់ខ្លួនឡើយ យ៉ាងនេះហើយ កំណត់សុញ្ញតា ៤ ចំណុច ដែលពោលទុកក្នុងអធិការសុញ្ញតានុបស្សនានេះទៀតថា **លោកមិនឃើញថា ខ្លួនអញមាន ១ ក្នុងទីណាមួយ ១ ក្នុងភាពជាអ្វីរបស់បុគ្គលណា និងមិនឃើញថា ខ្លួនរបស់អ្នកដទៃមាន ១ ក្នុងទីណាមួយ ១ ក្នុងភាពជាអ្វីរបស់ខ្លួនយើងទីណាៗ ឡើយ** ដូច្នេះ ។

សួរថា អធិប្បាយសុញ្ញតា ៤ ចំណុចមានដូចម្តេច ? ឆ្លើយថា អធិប្បាយមានយ៉ាងនេះ ពាក្យថា **នាហំ ក្វចនិ** គឺព្រះយោគាវចរនេះ មិនឃើញតួខ្លួន ( មាន ) ក្នុងទីណាមួយ ។ ពាក្យថា **កស្សចិ កិញ្ចនតស្មឹ** គឺមិនឃើញខ្លួនរបស់ខ្លួន ដែលគប្បីនាំចូលទៅក្នុងភាពជាអ្វីមួយ របស់បុគ្គលណាម្នាក់ គឺរបស់បុគ្គលដទៃ ពង្រីកសេចក្តីថា មិនឃើញតួខ្លួនរបស់ខ្លួន ដែលគប្បីនាំចូលទៅរាប់យកជាបងប្អូនក្នុងឋានៈដែលគួរជាបងប្អូន ឬជាសម្លាញ់ក្នុងឋានៈដែលគួរជាសម្លាញ់ ឬជាបរិក្ខារ (បរិវារ) ក្នុង

ឋានៈដែលគួរជាបរិក្ខារ ។ ក្នុងពាក្យថា ន ច មម ក្វចនិ នេះ លើក មម-ស័ព្ទ ទុកសិន ពាក្យដ៏សេសថា ន ច ក្វចនិ សេចក្តីថា នឹងមិនឃើញតួខ្លួនរបស់អ្នកដទៃ ក្នុងទីណាមួយឡើយ នឹងនាំ មម-ស័ព្ទមក ( ប្រកបជាក្រោយ ) ថា មម កិស្មិញ្ចិ កិញ្ចនតត្ថិ សេចក្តីថា មិនឃើញថា ជាតួខ្លួន របស់បុគ្គលដទៃនោះ មានក្នុងភាព ជាអ្វីមួយរបស់ខ្លួនយើង ក្នុងឋានៈណាមួយឡើយ ពង្រីកសេចក្តីថា មិនឃើញតួខ្លួន របស់អ្នកដទៃ ដែលគប្បីនាំចូលទៅដោយភាពជាអ្វីមួយនេះ ក្នុងឋានៈណាមួយឡើយ គឺជាបងប្អូនក្នុងឋានៈដែលគួរ ជាបងប្អូន ឬជាសម្លាញ់ក្នុងឋានៈដែលគួរជាសម្លាញ់ ឬជាបរិក្ខារក្នុងឋានៈដែលគួរជាបរិក្ខាររបស់ខ្លួនឡើយ ។

ហេតុណា ព្រះយោគាវចរនេះ ១ មិនឃើញតួខ្លួនក្នុងទីណាមួយ ១ មិនឃើញ តួខ្លួននោះដែលគប្បីនាំចូលទៅក្នុងភាពជាអ្វីមួយរបស់អ្នកដទៃ ១ មិនឃើញខ្លួនរបស់ អ្នកដទៃ ( ក្នុងទីណាមួយ ) ១ មិនឃើញខ្លួនរបស់អ្នកដទៃដែលគប្បីនាំចូលមកក្នុង ភាពជាអ្វីមួយ របស់ខ្លួនឡើយ ដូចពោលមកដូច្នេះ ព្រោះហេតុនោះ សុញ្ញតា ៤ ចំណុច ឈ្មោះថា ព្រះយោគាវចរនេះបានកំណត់ហើយ ដូច្នេះ ។

## កំណត់សុញ្ញតាដោយអាការ ៦

ព្រះយោគាវចរកាលកំណត់សុញ្ញតា ៤ចំណុចយ៉ាងនេះហើយកំណត់សុញ្ញតា ដោយអាការ ៦ ទៀត កំណត់ដូចម្តេច ? កំណត់ថា ចក្ខុជារបស់ទទេចាកតួខ្លួនក្តី ចាករបស់នៃខ្លួនក្តី ចាកភាពពិតប្រាកដក្តី ចាកភាពស្ថិតស្ថេរ ចាកភាពទៀងពិតក្តី ចាកភាពជារបស់មិនមានការប្រែប្រួលជាធម្មតាក្តី សោត... ឃានៈ... ជិវ្ហា... កាយ... មនៈជារបស់ទទេ... រូបជារបស់ទទេ... ។បេ។ ធម្មារម្មណ៍ទាំងឡាយជារបស់ទទេ... ចក្ខុវិញ្ញាណជារបស់ទទេ... ។បេ។ មនោវិញ្ញាណជារបស់ទទេ... ចក្ខុសម្ផស្សជារបស់

*ទទេ... ។បេ។ មានោសម្មស្សជារបស់ទទេ... គប្បីនាំន័យទៅដូចពោលមក ដូច្នេះឯង រហូតដល់ ( បទ ) ជរា មរណៈ ។*

## កំណត់សុញ្ញតា ដោយអាការ ៨

*កាលកំណត់សុញ្ញតា ដោយអាការ ៦ យ៉ាងនេះហើយ កំណត់ដោយអាការ ៨ ទៀត កំណត់ដូចម្ដេចខ្លះ ? កំណត់ថា រូបមិនមានសារៈ រកសារៈមិនមានប្រាសចាកសារៈ ដោយសារៈ គឺនិច្ចសារៈ ( ជាសារៈដោយជារបស់ពិតប្រាកដ ) ក្ដី ដោយសារៈ គឺធុវសារៈក្ដី ដោយសារៈ គឺសុខសារៈក្ដី ដោយសារៈ គឺអត្តសារៈក្ដី ដោយភាពជារបស់ពិតប្រាកដក្ដី ដោយភាពជារបស់ស្ថិតស្ថេរក្ដី ដោយភាពជារបស់ទៀងពិតក្ដី ដោយភាពជារបស់មិនមានការប្រែប្រួលជាធម្មតាក្ដី វេទនា... សញ្ញា... សង្ខារ... វិញ្ញាណ... ចក្ខុ ។បេ។ ជរាមរណៈ មិនមានសារៈ រកសារៈមិនមាន ប្រាសចាកសារៈ ដោយសារៈ គឺនិច្ចសារៈក្ដី ដោយសារៈ គឺធុវសារៈក្ដី ដោយសារៈ គឺសុខសារៈក្ដី ដោយសារៈ គឺអត្តសារៈក្ដី ដោយជារបស់ពិតប្រាកដក្ដី ដោយជារបស់ស្ថិតស្ថេរក្ដី ដោយជារបស់ទៀងពិតក្ដី ដោយភាពជារបស់មិនមាន ការប្រែប្រួលជាធម្មតាក្ដី ប្រៀបដូចដើមបបុសមិនមានខ្លឹម រកខ្លឹមមិនមាន ប្រាសចាកខ្លឹម យ៉ាងណា ដូចដើមល្ហុង ... ដើមល្វា... ដើមថ្ងាន់... ដើមចារ... និងដូចដុំពពុះទឹក... ដូចក្រពេញទឹក... ដូចថ្ងៃបណ្ដើរកូន... ដូចដើមចេក... ដូចកលមាយា មិនមានសារៈ រកសារៈមិនមាន ប្រាសចាកខ្លឹមសារ យ៉ាងណា រូប ។បេ។ ជរាមរណៈ ក៏ដូច្នោះឯង មិនមានសារៈ រកសារៈមិនមាន ប្រាសចាកសារៈ ដោយសារៈគឺនិច្ចសារៈក្ដី ។បេ។ ជារបស់មានការប្រែប្រួលជាធម្មតា ។*

## កំណត់សុញ្ញតាដោយអាការ ១០

ព្រះយោគាវចរនោះ កាលកំណត់សុញ្ញតាដោយអាការ ៨ យ៉ាងនេះហើយ កំណត់ដោយអាការ ១០ ទៀត កំណត់ដោយអាការ ១០ ដូចម្ដេច ? កំណត់ដោយអាការ ១០ យ៉ាងនេះ គឺឃើញរូបជារបស់ទំនេរ... ដោយភាពជារបស់ទទេ... ដោយភាពជារបស់សូន្យ... ដោយភាពជាអនត្តា... ដោយភាពមិនមាន ( បុគ្គលណាគ្រប់គ្រង ) ភាពជាធំ... ជាវត្ថុមិនគប្បីធ្វើ ( ឲ្យជាអ្វីបាន ) ដូចត្រូវការ... ជាវត្ថុមិនគប្បីបាន ( ដូចប្រាថ្នា )... ដោយជាវត្ថុមិនប្រព្រឹត្តទៅក្នុងអំណាច... ជាចំណែកដទៃ ( គឺមិនស្ដាប់បង្គាប់ )... ជារបស់ឯក ( គឺមិននៅក្នុងអាណត្តិរបស់បុគ្គលណា មានព្រះជាម្ចាស់អ្នកសាង ) ឃើញវេទនា ។បេ។ វិញ្ញាណជារបស់ទំនេរ ។បេ។ ឃើញ... ជារបស់ឯក ។

## កំណត់សុញ្ញតា ១២

កាលកំណត់សង្ខារដោយអាការ ១០យ៉ាងនេះហើយ កំណត់ដោយអាការ ១២ ទៀត កំណត់ដោយអាការ ១២ ដូចម្ដេច ? គឺកំណត់ថា រូបមិនមែនសត្វ មិនមែនជីវៈ មិនមែននរៈ ( មនុស្ស ) មិនមែនមាណព ( កំលោះ ) មិនមែនស្ត្រី មិនមែនបុរស មិនមែនអត្តា មិនមែនអត្តនិយ មិនមែនអញ មិនមែនរបស់អញ មិនមែនរបស់អ្នកដទៃ មិនមានរបស់បុគ្គលណាម្នាក់ វេទនា ។បេ។ វិញ្ញាណ ។បេ។ មិនមែនរបស់បុគ្គលណាម្នាក់ឡើយ ។

## កំណត់សុញ្ញតាដោយអាការ ៤២

កាលកំណត់សុញ្ញតាដោយអាការ ១២ យ៉ាងនេះហើយ កំណត់សុញ្ញតា ដោយអាការ ៤២ ដោយអំណាចតីរណបរិញ្ញាទៀត គឺឃើញរូប

| | |
|---|---|
| អនិច្ចតោ | ជារបស់មិនទៀង |
| ទុក្ខតោ | ជាទុក្ខ |
| រោគតោ | ជារោគ |
| គណ្ឌតោ | ជាបូស |
| សល្លតោ | ជាសរ |
| អឃតោ | ជារបស់លំបាក |
| អាពាធតោ | ជាអាពាធ |
| បរតោ | ជារបស់ដទៃ |
| បលោកតោ | ជារបស់វិនាស |
| ឦតិតោ | ជាចង្រៃ |
| ឧបទ្ទវតោ | ជាឧបទ្រព |
| ភយតោ | ជាភ័យ |
| ឧបសគ្គតោ | ជាឧបសគ្គ |
| ចលតោ | ជារបស់ញាប់ញ័រ |
| បភង្គុតោ | ជារបស់បែកធ្លាយ |
| អទ្ធុវតោ | ជារបស់មិនស្ថិតស្ថេរ |
| អតាណតោ | មិនមានទីជ្រកកោន |
| អលេណតោ | មិនមានទីពួន |
| អសរណតោ | មិនមានទីពឹង |
| អសរណីភូតតោ | ជារបស់មិន ( គួរកាន់យក ) ជាទីពឹង |
| រិត្តតោ | ជាទីវាល |

| | |
|---|---|
| តុច្ឆតោ | ជារបស់ទទេ |
| សុញ្ញតោ | ជារបស់សូន្យ |
| អនត្តតោ | ជាអនត្តា |
| អនស្សាទតោ | ជារបស់មិនមានអ្វីគួរត្រេកអរ |
| អាទីនវតោ | ជាទោស |
| វិបរិណាមធម្មតោ | ជារបស់មានការប្រែប្រួលជាធម្មតា |
| អសារកតោ | ជារបស់មិនមានសារៈ |
| អឃមូលតោ | ជាឫសគល់នៃសេចក្ដីលំបាក |
| វធកតោ | ជាអ្នកសម្លាប់ |
| វិភវតោ | ជារបស់ប្រាសចាកសេចក្ដីចម្រើន |
| សាសវតោ | ជារបស់ប្រព្រឹត្តទៅជាមួយអាសវៈ |
| សង្ខតតោ | ជារបស់បច្ច័យតាក់តែងឡើង |
| មារាមិសតោ | ជាអាមិសរបស់មារ |
| ជាតិធម្មតោ | ជារបស់មានជាតិជាធម្មតា |
| ជរាធម្មតោ | ជារបស់មានជរាជាធម្មតា |
| ព្យាធិធម្មតោ | ជារបស់មានព្យាធិជាធម្មតា |
| មរណធម្មតោ | ជារបស់មានមរណៈជាធម្មតា |

សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ ជារបស់មានសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសជាធម្មតា

| | |
|---|---|
| សមុទយតោ | ដោយការកើតឡើង |
| អត្ថង្គមតោ | ដោយសេចក្ដីវិនាសទៅ |

និស្សរណតោ ដោយការចេញទៅ

ឃើញវេទនា ។បេ។ វិញ្ញាណដោយភាពជារបស់មិនទៀង ។បេ។ ដោយការចេញទៅ ។

ពិតហើយ ពាក្យសម្ដែងការកំណត់សុញ្ញតានេះ ក៏ពោលទុក ( ក្នុងចូឡនិទ្ទេស ខុទ្ទកនិកាយ ) ថា ភិក្ខុកាលឃើញរូប ដោយភាពជារបស់មិនទៀង ។បេ។ ដោយការចេញទៅ ឈ្មោះថា ឃើញលោកជារបស់សូន្យ កាលឃើញវេទនា ។បេ។ វិញ្ញាណជារបស់មិនទៀង ។បេ។ ដោយការចេញទៅ ឈ្មោះថា ឃើញលោកជារបស់សូន្យ ( និងត្រាស់ដល់ព្រះមោឃរាជ ) ថា

**ម្នាលមោឃរាជ អ្នកចូរមានសតិ ឃើញលោក ជារបស់សូន្យគ្រប់កាល ដកអត្តានុទិដ្ឋិចេញ ការឆ្លងផុតមច្ចុ គប្បីមានបាន ដោយអាការយ៉ាងនេះ ( ព្រោះថា ) មច្ចុរាជរមែង (មើល) មិនឃើញបុគ្គលដែលឃើញលោក (ជារបស់សូន្យ) យ៉ាងនោះ ។**

## សង្ខារុបេក្ខាញាណកើត

ព្រះយោគាវចរ កាលឃើញជារបស់សូន្យយ៉ាងនោះហើយ កំណត់សង្ខារលើកឡើងកាន់ត្រៃលក្ខណ៍ រមែងលះបង់ទាំងការខ្លាច និងការត្រេកអរចេញបានហើយជាបុគ្គលកណ្ដាល ព្រងើយក្នុងសង្ខារទាំងឡាយ មិនកាន់យកថា ជាអញក្ដី ថាជារបស់អញក្ដី ដូចបុរសដែលមានកិរិយាលែងគ្នាហើយដូច្នោះ ឧបមាថា កិរិយារបស់បុរសម្នាក់ គប្បីជាស្ត្រីគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត បុរសនោះ មិនអាចអត់ធន់ចំពោះការព្រាត់ប្រាសអំពីនាងបាន សូម្បីតែមួយរយៈ បុរសនោះ ហួងហែងនាងពន់ពេក ( ថៃជន្យ ) បុរសនោះ ឃើញស្ត្រីនោះឈរក្ដី អង្គុយក្ដី ( ដេកក្ដី )

និយាយក្តី នក់ក្បាលក្តី ជាមួយបុរសដទៃ បុរសនោះ ក៏អាក់អន់តូចចិត្ត ខូចចិត្តយ៉ាង ក្រៃលែង តមក បុរសនោះឃើញអំពើអាក្រក់របស់ស្រីនោះហើយ គិតនឹងលែងទៅ ទើបលែងស្រីនោះចោល មិនប្រកាន់ស្រីនោះថាជារបស់គាត់ តាំងអំពីនោះទៅ សូម្បី នឹងបានឃើញស្រីនោះ ធ្វើកិរិយាឯណានីមួយជាមួយបុរសណាមួយ ក៏មិនអាក់អន់ មិនគប្បីខូចចិត្តឡើយ គប្បីជាបុគ្គលកណ្តាល ព្រងើយកន្តើយបាន ដោយពិត យ៉ាង ណា ព្រះយោគីនេះ ក៏ដូច្នោះដូចគ្នា ជាអ្នកប្រាថ្នានឹងរួចផុត ទៅអំពីសង្ខារទាំងពួង ទើបកំណត់សង្ខារទាំងឡាយ ដោយបដិសង្ខានុបស្សនាទៅ រហូតមិនឃើញសង្ខារ ទាំងពួង ជាវត្ថុដែលគួរកាន់យកថាជាយើង ជារបស់យើង ហើយក៏លះការភ័យខ្លាច និងការត្រេកអរចេញបាន រមែងជាបុគ្គលកណ្តាល ព្រងើយកន្តើយក្នុងសង្ខារទាំង ពួងបាន ។ កាលលោកដឹងយ៉ាងនោះ ចិត្តរមែងរា ថយ រមែងរួញ រមែងត្រឡប់ មិនលូតទៅក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ។ ឧបេក្ខា ឬបាដិកូលយតា រមែងតាំងមាំ ប្រៀបដូចតំណក់ទឹកទាំងឡាយ លើស្លឹកឈូកដែល ផ្អៀងបន្តិច រមែងធ្លាក់ចុះ មិនជាប់ ( លើស្លឹកឈូក ) យ៉ាងណា ក៏ដូច្នោះដូចគ្នា... ។ ម្យ៉ាងទៀត ប្រៀបដូចរោមមាន់ ឬសរសៃ និងស្បែកស្ងួត ត្រូវភ្លើង រមែងរួញ រមែង អែនត្រឡប់ មិនលាតទៅ ( ក្នុងភ្លើង ) យ៉ាងណា ចិត្តរបស់ព្រះយោគាវចរនោះ រមែងថយ រមែងរួញ រមែងត្រឡប់ មិនលូតទៅក្នុងភព ៣... ឧបេក្ខា ឬបាដិកូលយតា រមែងតាំងមាំ ដូច្នោះ ។

ឯសង្ខារុបេក្ខាញាណ រមែងបានកើតឡើង ដល់ព្រះយោគាវចរនោះ ដោយ ប្រការដូច្នេះ ។

## សង្ខារុបេក្ខាញាណដូចក្អែកប្រាប់ទិស

តែសង្ខារុបេក្ខាញាណនេះ បើឃើញព្រះនិព្វាន ដែលជាសន្តិបទ ព្រោះជាធម៌មានសោត រមែងលះបវត្ត ចំណែកសង្ខារទាំងពួង ស្ទុះទៅកាន់ព្រះនិព្វានតែម្យ៉ាង បើមិនឃើញព្រះនិព្វាន ជាធម៌មានសោត ក៏រមែងមានតែសង្ខារជាអារម្មណ៍ប្រព្រឹត្តទៅហើយ ប្រព្រឹត្តទៅទៀតនោះឯង ដូចក្អែករបស់ពួកពាណិជសមុទ្រ ដូច្នោះ បានឮមកថា ពាណិជសមុទ្រ កាលឡើងទូក រមែងនាំយកក្អែកប្រាប់ទិស ( ទៅដែរ ) កាលណាទូកត្រូវព្យុះបក់បោកទៅខុសទិសដៅ ប្រាំងមិនប្រាកដ កាលនោះ ពួកគេក៏លែងក្អែកប្រាប់ទិស ក្អែកនោះ ទំត្រង់សសរក្តោង ហោតឡើងកាន់អាកាស ( ហើរសម្លឹង ) ទៅទិសធំ និងទិសតូចគ្រប់ទិស បើឃើញប្រាំង ( ក្នុងទិសណា ) ក៏ហើរបែរមុខទៅទិសនោះតែម្តង បើមិនឃើញក៏មកទំសសរក្តោង សញ្ចប់សញ្ចឹងនោះឯង ( យ៉ាងណា ) សង្ខារុបេក្ខាញាណ ក៏ដូច្នោះដូចគ្នា បើឃើញព្រះនិព្វាន ដែលជាសន្តិបទ ជាធម៌មានសោត រមែងលះបង់បវត្ត ចំណែកសង្ខារទាំងពួងស្ទុះទៅកាន់ព្រះនិព្វាន នោះឯង បើមិនឃើញ ក៏រមែងមានតែសង្ខារជាអារម្មណ៍ ប្រព្រឹត្តទៅហើយ ប្រព្រឹត្តទៅទៀតនោះឯង ។

វិបស្សនាញាណនេះ ដូចម្សៅក្នុងកាជនៈ ដែលត្រូវប្របាច់ ដូចកប្បាស ដែលបកសម្បក ហើយត្រូវធ្វើឲ្យខ្ចាត់ខ្ចាយ ។ កំណត់សង្ខារទាំងឡាយ ដោយប្រការផ្សេងៗ រហូតលះសេចក្តីខ្លាច និងសេចក្តីត្រេកអរបាន ហើយក៏ដាក់ខ្លួនជាកណ្តាលក្នុងការត្រួតពិនិត្យសង្ខារ ឈប់នៅដោយអំណាចអនុបស្សនា ៣ កាលឈប់យ៉ាងនោះ រមែងដល់នូវភាពជាមុខ ( ផ្លូវ ) នៃវិមោក្ខ ៣ ហើយជាបច្ច័យ ដើម្បីចែកព្រះអរិយបុគ្គល ៧ ពួក ។

## វិមោក្ខមុខ ៣

ក្នុងការដល់នូវភាពជាមុខនៃវិមោក្ខ និងក្នុងភាពជាបច្ច័យ ដើម្បីបែកព្រះអរិយបុគ្គលនោះ វិបស្សនាញាណនេះ ឈ្មោះថា **ដល់នូវភាពជាមុខនៃវិមោក្ខ ៣** ក៏ដោយជាអធិបតីនៃឥន្ទ្រិយ ៣ ( គឺសទ្ធិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ) ព្រោះប្រព្រឹត្តទៅដោយអំណាចនៃអនុបស្សនា ៣ ។ ពិតហើយ អនុបស្សនា ៣ លោកហៅថា **វិមោក្ខ ៣** ដូចព្រះបាលីថា **ឯវិមោក្ខមុខ ៣ នេះ រមែងប្រព្រឹត្តទៅដើម្បីការចេញទៅអំពីលោក** គឺរមែងប្រព្រឹត្តទៅដើម្បីការៈ គឺពិចារណាឃើញសង្ខារទាំងពួងដោយបរិច្ឆេទ និងដោយជុំវិញ និងដើម្បីការស្ទុះចូលទៅនៃចិត្តក្នុងអនិមិត្តធាតុ ១ ដើម្បីការៈ គឺកម្តៅចិត្តក្នុងសង្ខារទាំងពួង និងដើម្បីការស្ទុះចូលទៅ នៃចិត្តក្នុងអប្បណិហិតចិត្ត ១ ដើម្បីការៈ គឺការពិចារណាឃើញធម៌ទាំងពួង ជារបស់ដទៃ និងដើម្បីការស្ទុះចូលទៅនៃចិត្តក្នុងសុញ្ញតធាតុ ១ វិមោក្ខមុខ ៣ នេះ ប្រព្រឹត្តទៅ ដើម្បីការចេញចាកលោក ។

## អធិប្បាយ សេចក្តីបាលី

ក្នុងបាឋៈទាំងនោះ បាឋៈថា **បរិច្ឆេទបរិវដុមតោ** ដោយបរិច្ឆេទ និងដោយជុំវិញ គឺទាំងដោយបរិច្ឆេទ ទាំងដោយជុំវិញ ដោយអំណាចការកើត និងការរលត់ ពង្រីកសេចក្តីថា អនិច្ចានុបស្សនាកំណត់បរិច្ឆេទថា **មុនអំពីកើត សង្ខារទាំងឡាយមិនមាន** ដូច្នេះហើយ តាមពិចារណាគតិរបស់សង្ខារទាំងនោះទៅ ក៏ពិចារណាឃើញដោយជុំវិញថា **តអំពីរលត់ សង្ខារក៏មិនទៅណា បាត់ទៅក្នុងទីនេះឯង** ដូច្នេះ

បាឋៈថា **មនោសមុត្តេជនតាយ** ដើម្បីការៈ គឺការកម្តៅចិត្ត អត្ថថា ដើម្បីសេចក្តីសង្វេគនៃចិត្ត ពិតហើយ ចិត្តរមែងសង្វេគក្នុងសង្ខារទាំងឡាយ ដោយ

ទុក្ខានុបស្សនា ។

បាឋៈថា **បរតោសមនុបស្សនតាយ** ដើម្បីការៈ គឺការពិចារណាឃើញ ( ធម៌ទាំងពួង ) ជាចំណែកដទៃ អត្ថថា ដើម្បីពិចារណាឃើញដោយភាពជាអនត្តាថា **សង្ខារមិនមែនជាអញ មិនជារបស់អញ** ដូច្នេះ ។

បទទាំង ៣ ដូចពោលនេះ គប្បីជ្រាបថា លោកពោលដោយអំណាចអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ព្រោះហេតុនោះឯង ក្នុងកាលវិសជ្ជនា បញ្ហាក្នុងលំដាប់នោះទៅ ទើបលោកពោលថា **កាលភិក្ខុធ្វើមនសិការជារបស់មិនទៀង សង្ខារទាំងឡាយ រមែងប្រាកដដោយការអស់ កាលធ្វើមនសិការជាទុក្ខ សង្ខារទាំងឡាយ រមែងប្រាកដជារបស់គួរខ្លាច កាលធ្វើមនសិការជាអនត្តា សង្ខារទាំងឡាយ រមែងប្រាកដជារបស់សូន្យ** ដូច្នេះ ។

## វិមោក្ខ ៣ សំដៅយកអរិយមគ្គ

សួរថា **វិមោក្ខដែលមានអនុបស្សនានេះជាមុខនោះ គឺអ្វីខ្លះ ?** ឆ្លើយថា **វិមោក្ខ ៣ នោះ គឺអនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតវិមោក្ខ** ។ ពិតហើយ ពាក្យតទៅនេះ ក៏បានពោលទុក ( ក្នុងបដិសម្ភិទាមគ្គ ) ថា ភិក្ខុធ្វើមនសិការជារបស់មិនទៀង ជាបុគ្គលច្រើនដោយអធិមោក្ខ រមែងបានចំពោះនូវអនិមិត្តវិមោក្ខ ធ្វើមនសិការជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ រមែងបានចំពោះនូវអប្បណិហិតវិមោក្ខ ធ្វើមនសិការជាអនត្តា ជាអ្នកច្រើនដោយវេទ ( បញ្ញា ) រមែងបានចំពោះនូវសុញ្ញតវិមោក្ខ ដូច្នេះ ។

ឯក្នុងវិមោក្ខ ៣ នេះ អរិយមគ្គ ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅដោយអាការមិនមាននិមិត្ត ឈ្មោះថា **អនិមិត្តវិមោក្ខ** ពិតណាស់ អរិយមគ្គនោះ ឈ្មោះថា អនិមិត្ត ព្រោះកើតឡើងដោយធាតុដែលមិនមាននិមិត្ត និងឈ្មោះថា វិមោក្ខ

ព្រោះផុតអំពីកិលេសទាំងឡាយ ដោយន័យនោះ ឈ្មោះថា អនិមិត្ត ព្រោះកើតឡើងដោយធាតុដែលមិនមាននិមិត្ត និងឈ្មោះថា វិមោក្ខ ព្រោះផុតអំពីកិលេសទាំងឡាយដោយន័យដូចគ្នានោះដែរ អរិយមគ្គ ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅដោយអាការមិនមានបណិធិ គប្បីជ្រាបថា ឈ្មោះ **អប្បណិហិតវិមោក្ខ** អរិយមគ្គដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ដោយអាការទទេ គប្បីជ្រាបថា ឈ្មោះ **សុញ្ញតវិមោក្ខ** ។

## វិមោក្ខ ២ សំដៅយកវិបស្សនាញាណ

ចំណែកវិមោក្ខ ត្រឹមតែ ២ ឯណា ពោលទុកនៅក្នុងអភិធម្ម ដូច្នេះថា ក្នុងសម័យណា ភិក្ខុចម្រើនលោកុត្តរជ្ឈាន ដែលជានិយ្យានិក ជាអបចយគាមី ( ញុំាងការកបុគ្គលឲ្យដល់នូវការមិនសន្សំកិលេស ) ដើម្បីលះទិដ្ឋិ ដើម្បីសម្រេចបឋមភូមិ លោកស្ងាត់ចាកកាមទាំងឡាយ...ចូលដល់បឋមជ្ឈាន ដែលជាអប្បណិហិត ជាសុញ្ញតដូច្នេះ ។ វិមោក្ខ ២ នោះ លោកពោលសំដៅដល់ទីមកនៃវិបស្សនា ដោយនិប្បរិយាយពិតហើយ វិបស្សនាញាណ លោកហៅថា សុញ្ញតវិមោក្ខ ដោយអំណាចការដោះសេចក្តីប្រកាន់មាំបាន តាមន័យបាលីក្នុងបដិសម្ភិទាមគ្គដូច្នេះថា អនិច្ចានុបស្សនាញាណ ឈ្មោះថា សុញ្ញតវិមោក្ខ ព្រោះដោះ (អភិនិវេស) ការប្រកាន់មាំជារបស់ទៀងបាន ទុក្ខានុបស្សនាញាណ ឈ្មោះថា សុញ្ញតវិមោក្ខ ព្រោះដោះការប្រកាន់មាំជាសុខបាន អនត្តានុបស្សនាញាណ ឈ្មោះថា សុញ្ញតវិមោក្ខ ព្រោះដោះការប្រកាន់មាំជាអត្តាបាន ដូច្នេះ ហើយហៅអនិមិត្តវិមោក្ខ ដោយអំណាចការដោះនិមិត្តបាន តាមន័យបាលី ( ក្នុងបដិសម្ភិទាមគ្គនោះ ) ដូច្នេះ ថា អនិច្ចានុបស្សនាញាណ ឈ្មោះថា អនិមិត្តវិមោក្ខ ព្រោះដោះនិមិត្តជារបស់ទៀងបាន ទុក្ខានុបស្សនាញាណ ឈ្មោះថា អនិមិត្តវិមោក្ខ

ព្រោះដោះនិមិត្តជាសុខបាន អនត្តានុបស្សនាញាណ ឈ្មោះថា អនិមិត្តវិមោក្ខ ព្រោះដោះនិមិត្តជាអត្តាបាន ដូច្នេះ និងហៅថា អប្បណិហិតវិមោក្ខដោយអំណាចការដោះ ( បណិធិ ) សេចក្តីប្រាថ្នា តាមន័យបាលី ( ក្នុងបដិសម្ភិទាមគ្គនោះ ) ដូច្នេះថា អនិច្ចានុបស្សនាញាណ ឈ្មោះថា អប្បណិហិតវិមោក្ខ ព្រោះដោះសេចក្តីប្រាថ្នាជារបស់ទៀងបាន ទុក្ខានុបស្សនា ឈ្មោះថា អប្បណិហិតវិមោក្ខ ព្រោះដោះសេចក្តីប្រាថ្នាជាសុខបាន អនត្តានុបស្សនាញាណ ឈ្មោះថា អប្បណិហិតវិមោក្ខ ព្រោះដោះសេចក្តីប្រាថ្នាជាអត្តាបាន ដូច្នេះផង ពិតហើយ សូម្បីយ៉ាងនោះ វិបស្សនាញាណនោះក៏មិនជាអនិមិត្តដោយនិប្បរិយាយឡើយ ព្រោះមិនទាន់លះសង្ខារនិមិត្តបាន តែជាសុញ្ញត និងជាអប្បណិហិតដោយនិប្បរិយាយបានពិត ។ ម្យ៉ាងទៀត វិមោក្ខ លោកលើកឡើង ( ហៅ ) ក្នុងខណៈនៃអរិយមគ្គ ក៏ដោយអំណាចទីមកនៃវិបស្សនាញាណនោះ គប្បីជ្រាបថា ( ក្នុងអភិធម្ម ) លោកពោលតែវិមោក្ខ ២ គឺអប្បណិហិត និងសុញ្ញត ក៏ព្រោះ ( ដោយនិប្បរិយាយ ) នោះ ។

នេះជាវិមោក្ខកថា ក្នុងវិបស្សនាធិការនេះ ជាបឋម ។

## ព្រះអរិយបុគ្គល ៧

ក្នុងពាក្យដែលខ្ញុំពោលទុកទៀតថា វិបស្សនាញាណនេះ ជាបច្ច័យដើម្បីចែកព្រះអរិយបុគ្គល ៧ ប្រភេទ គប្បីជ្រាបអធិប្បាយដូច្នេះ ជាបឋម ( គប្បីជ្រាបថា ) បុគ្គលទាំងនេះ គឺ **សទ្ធានុសារី សទ្ធាវិមុត្តិ កាយសក្ខី ឧភតោភាគវិមុត្តិ ធម្មានុសារី ទិដ្ឋិប្បត្ត បញ្ញាវិមុត្តិ** ឈ្មោះថា **ព្រះអរិយបុគ្គល ៧** សង្ខារុបេក្ខាញាណនេះ រមែងជាបច្ច័យដើម្បីចែកព្រះអរិយបុគ្គល ៧ នោះ ។

ពង្រីកសេចក្តីថា បុគ្គលណាធ្វើមនសិការទៅដោយភាពជារបស់មិនទៀង ជា

អ្នកច្រើនទៅ ដោយអធិមោក្ខ រមែងបានចំពោះនូវសទ្ធិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា **សទ្ធានុសារី** ក្នុងខណៈនៃសោតាបត្តិមគ្គ ។ ឈ្មោះថា **សទ្ធាវិមុត្ត** ក្នុងស្ថាន ៧ ដ៏សេស ( គឺតាំងអំពីសោតាបត្តិផលដល់អរហត្តផល ) ចំណែកបុគ្គលណា ធ្វើមនសិការទៅ ដោយភាពជាទុក្ខ ជាបុគ្គលច្រើនទៅដោយបស្សទ្ធិ រមែងបានចំពោះនូវសមាធិន្ទ្រិយ បុគ្គលនោះឈ្មោះថា **កាយសក្ខី** ក្នុងគ្រប់ស្ថាន ( គឺតាំងអំពីសោតាបត្តិមគ្គរហូតដល់អរហត្តផល ) តែបុគ្គលណាបានអរូបជ្ឈានហើយ ទើបសម្រេចអគ្គផល ( គឺអរហត្តផល ) បាន ឈ្មោះថា **ឧភតោភាគវិមុត្ត** ចំណែកបុគ្គលណាធ្វើមនសិការទៅ ដោយភាពជាអនត្តា ជាបុគ្គលច្រើនទៅដោយវេទ រមែងបានចំពោះនូវបញ្ញិន្ទ្រិយ បុគ្គលនោះ ឈ្មោះថា **ធម្មានុសារី** ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា **ទិដ្ឋិប្បត្ត** ក្នុងទី ៦ ស្ថាន ឈ្មោះថា **បញ្ញាវិមុត្ត** ក្នុងអគ្គផល ។

ពិតហើយ ពាក្យនេះ លោកពោលទុក ( ក្នុងបដិសម្ភិទាមគ្គ ) ថា កាលភិក្ខុធ្វើមនសិការទៅជារបស់មិនទៀង សទ្ធិន្ទ្រិយរមែងជាឥន្ទ្រិយមានប្រមាណក្រៃលែង ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែង លោកបានសោតាបត្តិមគ្គ ហេតុនោះ ទើបហៅថា **សទ្ធានុសារី** ដូច្នេះ ន័យដូចគ្នានោះដែរ ពោលថា កាលភិក្ខុធ្វើមនសិការទៅដោយភាពជារបស់មិនទៀង សទ្ធិន្ទ្រិយ រមែងជាឥន្ទ្រិយមានប្រមាណក្រៃលែង ព្រោះសទ្ធិន្ទ្រិមានប្រមាណក្រៃលែង សោតាបត្តិផល ត្រូវបានលោកធ្វើឲ្យជាក់ច្បាស់បាន ហេតុនោះ ទើបហៅថា **សទ្ធាវិមុត្ត** ដូច្នេះជាដើម មួយឃ្លាទៀតពោលថា ភិក្ខុជឿរួចផុតបានហើយ ហេតុនោះ ទើបឈ្មោះថា **សទ្ធាវិមុត្ត** ធ្វើឲ្យជាក់ច្បាស់ហើយក្នុងលំដាប់នៃឈានដែលខ្ទួនបាន ហេតុនោះ ទើបឈ្មោះថា **កាយសក្ខី** សម្រេចហើយក្នុងលំដាប់នៃការឃើញ ( គឺសោតាបត្តិមគ្គ ) ហេតុនោះ ទើបឈ្មោះថា **ទិដ្ឋិប្បត្ត** ( ពង្រីកសេចក្តីទៀតថា ) ភិក្ខុជឿ ទើបរួចផុត ហេតុនោះ ទើបឈ្មោះថា **សទ្ធាវិមុត្តិ**

ពាល់ត្រូវ ( គឺបាន ) ឈានផស្សៈមុន ទើបធ្វើឲ្យជាក់ច្បាស់នូវនិរោធ គឺព្រះនិព្វាន ជាក្រោយ ហេតុនោះ ទើបឈ្មោះថា **កាយសក្ខី** ញាណដែលពិចារណាថា **សង្ខារ ទាំងឡាយជាទុក្ខ និរោធជាសុខ** គឺលោកដឹងហើយ ឃើញហើយ ជួបហើយ ធ្វើឲ្យ ជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា ហេតុនោះ ទើបឈ្មោះថា **ទិដ្ឋិប្បត្ត** ដូច្នេះ ។

ចំណែកក្នុង ៤ បទក្រៅអំពីនេះ គប្បីជ្រាបពាក្យដូច្នេះថា ព្រះអរិយបុគ្គល ដែលឈ្មោះថា **សទ្ធានុសារី** ព្រោះអត្ថថា ស្ទុះទៅតាមសទ្ធា ឬថា ស្ទុះទៅ គឺដើរទៅ ដោយសទ្ធា ន័យដូចគ្នានោះ ដែលឈ្មោះថា **ធម្មានុសារី** ព្រោះអត្ថថា ស្ទុះទៅតាម ធម៌ ពោល គឺបញ្ញា ឬស្ទុះទៅដោយធម៌ ដែលឈ្មោះថា **ឧភតោភាគវិមុត្ត** ព្រោះ អត្ថថា រួចផុតដោយចំណែកទាំង ២ គឺទាំងអរូបជ្ឈាន ទាំងអរិយមគ្គ ដែលឈ្មោះថា **បញ្ញាវិមុត្ត** ព្រោះអត្ថថា ដឹងទូទៅ ( នូវអរិយសច្ចដោយមិនបានឈាន ) រួចផុត ហើយ ។

( ខណៈនេះកំពុងពណ៌នា ) សង្ខារុបេក្ខាញាណ

ឯសង្ខារុបេក្ខាញាណនោះ ដោយអត្ថ ក៏ដូចគ្នានឹងញាណ ២ ខាងដើម ( គឺ មុញ្ចិតុកម្យតាញាណ និងបដិសង្ខារុបេក្ខាញាណ ) ព្រោះហេតុនោះ ទើបបុរាណាចារ្យ ទាំងឡាយពោលទុកថា សង្ខារុបេក្ខាញាណនេះដូចគ្នាពិត តែបានឈ្មោះ ៣ គឺកើត ឈ្មោះថា មុញ្ចិតុកម្យតាញាណក្នុងខាងដើម ប្រាកដឈ្មោះថា បដិសង្ខានុបស្សនា ញាណត្រង់កណ្ដាល និងបានឈ្មោះថា សង្ខារុបេក្ខាញាណ ដែលដល់កំពូលត្រង់ ខាងចុង សូម្បីក្នុងព្រះបាលីក៏ពោលទុកថា សួរថា បញ្ញា គឺ **មុញ្ចិតុកម្យតា** ការប្រាថ្នា នឹងដោះ **បដិសង្ខា** ការពិចារណាដឹង **សន្តិដ្ឋនា** ការព្រងើយកន្តើយ ជាញាណក្នុង សង្ខារុបេក្ខា ( ការព្រងើយក្នុងសង្ខារ ) ទាំងឡាយដូចម្ដេច ? ឆ្លើយថា បញ្ញាក្នុងការ

ប្រាថ្នានឹងដោះ ការពិចារណាដឹង ការព្រងើយកន្តើយនូវឧប្បាទ ( ការកើត គឺសង្ខារ ) ជាញាណក្នុងសង្ខារុបេក្ខាញាណទាំងឡាយ បញ្ញា គឺការប្រាថ្នានឹងដោះការពិចារណាដឹង ការព្រងើយកន្តើយនូវបវត្ត នូវនិមិត្ត ។បេ។ នូវឧបាយាស ជាញាណក្នុងសង្ខារុបេក្ខា ទាំងឡាយ បញ្ញា គឺការប្រាថ្នានឹងដោះ ការពិចារណាដឹង ការព្រងើយកន្តើយ ថាជាទុក្ខ ។បេ។ ថា ឧប្បាទ ជាភ័យ ថាឧប្បាទ ជាសាមិស ។បេ។ ថាឧប្បាទជាសង្ខារ ។បេ។ ឧបាយាសជាសង្ខារ ជាញាណក្នុងសង្ខារុបេក្ខាទាំងឡាយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទសមាសថា **មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា** មានវិគ្គហៈថា **មុញ្ចិតុកម្យតា** និង **បដិសង្ខា** និង **សន្តិដ្ឋនា** ព្រោះដូច្នេះ ការប្រាថ្នានឹងលះបង់នូវឧប្បាទជាដើមនៃព្រះយោគាវចរ ដែលជាអ្នកនឿយណាយ ដោយនិព្វិទាញាណខាងដើម ឈ្មោះថា **មុញ្ចិតុកម្យតា** ការពិចារណាជាកណ្តាល ដើម្បីធ្វើឧបាយនៃការរើខ្លួន ឈ្មោះថា **បដិសង្ខា** ភាពដែលដោះបានហើយ ព្រងើយកន្តើយក្នុងខាងចុងឈ្មោះថា **សន្តិដ្ឋនា** ដែលលោកសំដៅដល់ពោលទុកថា ឧប្បាទជាសង្ខារ កិច្ចព្រងើយកន្តើយនូវសង្ខារទាំងនោះ ហេតុនោះ ទើបឈ្មោះថា **សង្ខារុបេក្ខា** ដូច្នេះ ជាដើម ញាណនេះជាញាណតែមួយពិត ដូចពោលមកដូច្នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថាញាណនេះតែមួយពិត តាមព្រះបាលីនេះក៏បាន ពិតហើយ ពាក្យនោះ លោកបានពោលទុកថា មុញ្ចិតុកម្យតាតិ្ត បដិសង្ខានុបស្សនាតិ្ត សង្ខារុបេក្ខាតិ្ត ធម៌ទាំងនេះ មានអត្ថតែមួយ ផ្សេងគ្នាតែព្យញ្ជនៈ ដូច្នេះ ។

## វុដ្ឋានគាមិនីវិបស្សនា

វិបស្សនារបស់កុលបុត្រនេះ ដែលមានឧបេក្ខាញាណ បានសម្រេចហើយយ៉ាងនេះ រមែងជា **សិខាប្បត្ត** ( ដល់កំពូល ) ជា**វុដ្ឋានគាមិនី** ( ទៅកាន់ការចេញ ) ។

ពាក្យថា **សិខាប្បត្តវិបស្សនា** ក្តី ពាក្យថា **វុដ្ឋានគាមិនី** ក្តី នុ៎ះជាឈ្មោះរបស់ញាណ ៣ មានសង្ខារុបេក្ខាញាណជាដើមនោះឯង ឯវិបស្សនានោះ ឈ្មោះថា **សិខាប្បត្ត** ព្រោះដល់កំពូល គឺខ្ពស់បំផុត ( នៃលោកិយញ្ញាណ ) ឈ្មោះថា **វុដ្ឋានគាមិនី** ព្រោះទៅកាន់ការចេញមគ្គ ឈ្មោះថា **វុដ្ឋាន** ព្រោះចេញអំពីវត្ថុដែលប្រកាន់ ដែលជានិមិត្ត ( គឺអារម្មណ៍ ) ខាងក្រៅ និងអំពីបវត្ត ( គឺសង្ខារ ) ខាងក្នុងផង វិបស្សនានេះទៅកាន់វុដ្ឋាន គឺមគ្គនោះ ហេតុនោះ ទើបបានឈ្មោះថា **វុដ្ឋានគាមិនី** សេចក្តីថា បន្តគ្នាជាមួយមគ្គ ។

# មាតិកានៃវុដ្ឋាន

នេះជាមាតិកាដើម្បីប្រយោជន៍ ដល់ការជាក់ច្បាស់នៃការចេញចាកការប្រកាន់ក្នុងពាក្យដែលពោលមកដោយសង្ខេបនោះ គឺ

**អជ្ឈត្តំ អភិនិវិសិត្វា អជ្ឈត្តា វុដ្ឋាតិ** ប្រកាន់ ( គឺផ្តើមធ្វើវិបស្សនា ) ក្នុង ( សង្ខារទាំងឡាយ ) ខាងក្នុង ហើយចេញអំពី ( សង្ខារទាំងឡាយ ) ខាងក្នុង ។

**អជ្ឈត្តំ អភិនិវិសិត្វា ពហិទ្ធា វុដ្ឋាតិ** ប្រកាន់ក្នុង... ខាងក្នុង ហើយចេញចាក ... ខាងក្រៅ ។

**ពហិទ្ធា អភិនិវិសិត្វា ពហិទ្ធា វុដ្ឋាតិ** ប្រកាន់ក្នុង... ខាងក្រៅ ហើយចេញចាក... ខាងក្រៅ ។

**ពហិទ្ធា អភិនិវិសិត្វា អជ្ឈត្តា វុដ្ឋាតិ** ប្រកាន់ក្នុង... ខាងក្រៅ ហើយចេញចាក... ខាងក្នុង ។

**រូបេ អភិនិវិសិត្វា រូបា វុដ្ឋាតិ** ប្រកាន់ក្នុងរូប ហើយចេញចាករូប ។

**រូបេ អភិនិវិសិត្វា អរូបា វុដ្ឋាតិ** ប្រកាន់ក្នុងរូប ហើយចេញចាកអរូប ( គឺ

នាម ) ។

អរូបេ អភិនិវិសិត្វា អរូបា វុដ្ឋាតិ ប្រកាន់ក្នុងអរូប ហើយចេញចាកអរូប ។

អរូបេ អភិនិវិសិត្វា រូបា វុដ្ឋាតិ ប្រកាន់ក្នុងអរូប ហើយចេញចាករូប ។

ឯកប្បហារេន បញ្ចហិ ខន្ធេហិ វុដ្ឋាតិ ចេញចាកខន្ធទាំង ៥ ព្រមគ្នាតែម្តង ។

អនិច្ចតោ អភិនិវិសិត្វា អនិច្ចតោ វុដ្ឋាតិ ប្រកាន់ដោយភាពមិនទៀង ហើយចេញដោយភាពមិនទៀង ។

អនិច្ចតោ អភិនិវិសិត្វា ទុក្ខតោ... អនត្តតោ វុដ្ឋាតិ ប្រកាន់ដោយភាពមិនទៀង ហើយចេញដោយភាពជាទុក្ខ... ដោយភាពជាអនត្តា ។

ទុក្ខតោ អភិនិវិសិត្វា ទុក្ខតោ... អនិច្ចតោ... អនត្តតោ វុដ្ឋាតិ ប្រកាន់ដោយភាពជាទុក្ខ ហើយចេញដោយភាពជាទុក្ខ... ដោយភាពមិនទៀង... ដោយភាពជាអនត្តា ។

អនត្តតោ អភិនិវិសិត្វា អនត្តតោ... អនិច្ចតោ... ទុក្ខតោ វុដ្ឋាតិ ប្រកាន់ដោយភាពជាអនត្តា ហើយចេញដោយភាពជាអនត្តា... ដោយភាពមិនទៀង...ដោយភាពជាទុក្ខ ។

## អធិប្បាយ សេចក្តីនៃមាតិកា

អធិប្បាយនៃមាតិកានេះដូចម្តេច ? ព្រះយោគាវចរអង្គខ្លះ ក្នុងព្រះសាសនានេះ ដំបូងកាន់យក (គឺផ្តើមវិបស្សនា) ក្នុងសង្ខារខាងក្នុង (របស់ខ្លួន) កាលកាន់យកហើយ ក៏ ( ពិចារណា ) មើលសង្ខារខាងក្នុងទាំងនោះទៅ តែព្រោះមគ្គវុដ្ឋាន ( ការចេញ គឺមគ្គ ឬការចេញដោយមគ្គ ) មិនបានមានត្រឹមតែដោយ ( ការពិចារណា ) មើលសង្ខារខាងក្នុងសុទ្ធៗ ត្រឹមប៉ុណ្ណោះឡើយ ត្រូវ ( ពិចារណា ) មើលសង្ខារ

ខាងក្រៅផងដូចគ្នា ព្រោះដូច្នោះ ទើបព្រះយោគាវចរនោះ ឃើញខន្ធរបស់អ្នកដទៃក្ដី អនុបាទិន្នកសង្ខារទាំងឡាយក្ដី ថាមិនទៀង ជាទុក្ខ ជាអនត្តាផង លោករមែងពិចារណា (សង្ខារ) ខាងក្នុងតាមកាល ពិចារណា (សង្ខារ) ខាងក្រៅតាមកាល កាលលោកពិចារណាយ៉ាងនោះ វិបស្សនា (ប្រព្រឹត្តទៅ) តគ្នានឹងមគ្គចូលក្នុងកាលដែលពិចារណា (សង្ខារ) ខាងក្នុង លោកក៏ឈ្មោះថា ប្រកាន់ក្នុង... ខាងក្នុង ហើយចេញចាក... ខាងក្នុង តែបើវិបស្សនា (ប្រព្រឹត្តទៅ) តជាមួយមគ្គក្នុងកាលដែលលោកពិចារណា (សង្ខារ) ខាងក្រៅសោត លោកក៏ឈ្មោះថា ប្រកាន់ក្នុង... ខាងក្នុង ហើយចេញចាក... ខាងក្រៅ សូម្បីក្នុងការប្រកាន់ខាងក្រៅ ហើយចេញចាកខាងក្រៅ និងខាងក្នុងក៏មានន័យនេះ ។

ព្រះយោគាវចរអង្គខ្លះ ដំបូងកាន់យក (កំណត់) ក្នុងរូប កាលកាន់យកហើយ ក៏ (ពិចារណា) មើលដោយធ្វើភូតរូប និងឧបាទាយរូប ឲ្យជាគំនរមួយ (គឺរួមរូបទាំង ២ យ៉ាង ចូលជាមួយគ្នា កំណត់ត្រឹមតែជារូប) តែព្រោះវុដ្ឋានមិនមានត្រឹមតែដោយ (ពិចារណា) មើលរូបសុទ្ធៗ ត្រឹមប៉ុណ្ណោះនោះឡើយ ត្រូវ (ពិចារណា) មើលអរូបផងដូចគ្នា ព្រោះដូច្នោះ ព្រះយោគាវចរនោះធ្វើរូបនោះឲ្យជាអារម្មណ៍ហើយ ទើបឃើញអរូប គឺវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលកើតឡើងថា នេះជាអរូប លោករមែងពិចារណារូបតាមកាល ពិចារណាអរូបតាមកាល កាលលោកពិចារណាយ៉ាងនោះ វិបស្សនា (ប្រព្រឹត្តទៅ) តជាមួយមគ្គ ចូលក្នុងកាលដែលលោកពិចារណារូប លោកក៏បានឈ្មោះថា កាន់យកក្នុងរូប ហើយចេញចាករូប តែបើវិបស្សនា (ប្រព្រឹត្តទៅ) តគ្នាជាមួយមគ្គ ក្នុងកាលដែលលោកពិចារណាអរូបសោត លោកក៏បានឈ្មោះថា ប្រកាន់ក្នុងរូប ហើយចេញចាកអរូប សូម្បីក្នុងការកាន់យកក្នុងអរូប ហើយចេញចាកអរូប និងចេញចាករូប ក៏មានន័យនេះ ។

ចំណែកក្នុងកាលដែលកាន់យក ដោយកំណត់ថា **យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ** ធម្មជាតិឯណានីមួយ មានការកើតជាធម្មតា ធម្មជាតិទាំងអស់នោះ រមែងមានការរលត់ជាធម្មតា ដូច្នេះ ហើយចេញ ដោយកំណត់ដូចគ្នានោះ ឈ្មោះថា ចេញចាកខន្ធទាំង ៥ ព្រមគ្នានោះឯង ។ ព្រះយោគាវចរណាមួយ ដំបូងពិចារណាសង្ខារទាំងឡាយ ថាមិនទៀង តែព្រោះវុដ្ឋានមិនមាន ព្រោះពិចារណា ថាមិនទៀង ត្រឹមប៉ុណ្ណោះក៏ទេ ត្រូវពិចារណាថាជាទុក្ខ ជាអនត្តាផងដែរ ព្រោះដូច្នោះ ទើបលោកពិចារណា ថាជាទុក្ខខ្លះ ជាអនត្តាខ្លះ កាលលោកបដិបត្តិយ៉ាងនោះ វុដ្ឋានមានឡើងក្នុងកាលដែលពិចារណាថា មិនទៀង លោកក៏បានឈ្មោះថា កាន់យកថាមិនទៀង ហើយចេញដោយភាពមិនទៀង តែវុដ្ឋាន មានឡើងក្នុងកាលដែលលោកពិចារណាថាជាទុក្ខ ថាជាអនត្តាសោត លោកក៏បាន ឈ្មោះថា កាន់យកដោយភាពមិនទៀង ហើយចេញដោយភាពជាទុក្ខ ដោយភាព ជាអនត្តា សូម្បីក្នុងការកាន់យកភាពជាទុក្ខ ដោយភាពជាអនត្តាហើយចេញដោយលក្ខណៈដ៏សេសក៏មានន័យនេះៗឯក្នុងជនដែលចេញចាកការកាន់យកទាំងនេះ បុគ្គលដែលកាន់យកដោយភាពមិនទៀងក្តី បុគ្គលដែលកាន់យកដោយភាពជាទុក្ខក្តី បុគ្គលដែលកាន់យកដោយភាពជាអនត្តាក្តី តែក្នុងពេលចេញ វុដ្ឋានមានឡើង ដោយភាពមិនទៀង ជនទាំង ៣ នេះ ជាអ្នកច្រើនដោយអធិមោក្ខ បានសទ្ធិន្ទ្រិយ រួចផុតដោយអនិមិត្តវិមោក្ខ រមែងជាសទ្ធានុសារី ក្នុងខណៈនៃបឋមមគ្គ ជាសទ្ធាវិមុត្តិក្នុង ៧ ស្ថាន តែបើវុដ្ឋានមានឡើងដោយភាពជាទុក្ខសោត ជនទាំង ៣ នោះ ក៏ជាអ្នកច្រើនដោយបស្សទ្ធិ បានសមាធិន្ទ្រិយ រួចផុតដោយអប្បណិហិតវិមោក្ខ រមែងជាកាយសក្ខីក្នុងទីគ្រប់ស្ថាន តែក្នុងជនទាំងនោះបុគ្គលណាមានអរូបជ្ឈានជាបាទ បុគ្គលនោះ រមែងជាឧភតោភាគវិមុត្តិក្នុងអគ្គផល ដូច្នេះ វុដ្ឋានដោយភាពជាអនត្តា មានឡើងដល់ជនទាំង ៣ នោះ ជនទាំង ៣ ក៏ជាអ្នកច្រើន

ដោយវេទ ( គឺការដឹង ) បានបញ្ញិន្ទ្រិយ រួចផុតដោយសុញ្ញតវិមោក្ខ រមែងជាធម្មានុសារី ក្នុងខណៈនៃបឋមមគ្គ ជាទិដ្ឋិប្បត្តក្នុងទី ៦ ស្ថាន ជាបញ្ញាវិមុត្តិក្នុងអគ្គផល ដូច្នេះ ។

# ឧបមានៃវុដ្ឋានគាមិនីវិបស្សនា ១២

ឥឡូវនេះ គប្បីជ្រាបឧបមា ១២ ប្រការ ដើម្បីភាពជាក់ច្បាស់នៃវុដ្ឋានគាមិនីវិបស្សនានេះ ព្រមទាំងញាណមុន ( មានភយតុបដ្ឋានញាណជាដើម ) និងញាណក្រោយ ( មានគោត្រភូញាណជាដើម ) នេះ ជាឧទាន ( មាតិការឿង ) នៃឧបមាទាំងឡាយនោះ គឺ

**ប្រចៀវ ពស់វែក ផ្ទះ គោ យក្ខិនី ទារក ការឃ្លាន ការស្រេក រងា ក្ដៅ ងងឹត ជា ១២ ទាំងថ្នាំពិស ។**

ឯឧបមាទាំងនេះ លោកពោលទុក ( ក្នុងវិសុទ្ធិកថា ) ថា តាំងនៅក្នុងញាណណានីមួយ តាំងអំពីភយតុបដ្ឋានញាណមក នឹងនាំមក ( ពោល ) ក៏គួរ តែកាលនាំមក ( ពោល ) ក្នុងទីនេះ ញាណទាំងពួង តាំងអំពីភយតុបដ្ឋានញាណ រហូតដល់ផលញាណ រមែងប្រាកដ ( ជាក់ច្បាស់ទាំងអស់ ) ព្រោះដូច្នោះ ទើបគួរនាំមកទុកក្នុងទីនេះឯង ។

## ប្រចៀវ

ក្នុងឧបមាថា ប្រចៀវ ឧបមាថា ប្រចៀវមួយគិតថា នឹងបានផ្កា ឬផ្លែ ត្រង់ដើមឈើនេះ ទើបទំត្រង់ដើមស្រគំ មានមែក ៥ ហើយស្ទួមើលគ្រប់មែកនីមួយៗ មិនបានជួបវត្ថុដែលល្មមនឹងកាន់យក ទោះជាផ្កា ឬផ្លែក៏ដោយ សូម្បីត្រឹមតែមួយត្រង់មែកនោះ កាលស្ទួមែកមួយ ហើយមិនបានជួប ( វត្ថុដែលល្មមកាន់យក ) យ៉ាងណា ក៏ស្ទួមែកទី ២-៣-៤ សូម្បីមែកទី ៥ ហើយ ក៏មិនបានជួប ដូច្នោះ ទើប

ប្រចៀវគិតថា ដើមឈើនេះ មិនមានផ្លែហ្ន៎ វត្ថុដែលល្មមកាន់យកបានត្រឹមតែមួយ ត្រង់ដើមឈើនេះ មិនមានឡើយ ទើបដកអាល័យក្នុងដើមឈើនោះ ប្រវាឡើង តាមមែកដែលត្រង់ អើតក្បាលចេញ ( ត្រង់ប្រឡោះ ) ក្នុងរវាងប្រគាបងើយមើល ខាងលើ ហើរឡើងទៅក្នុងអាកាស ទៅទំត្រង់ដើមឈើមានផ្លែដទៃ ។

## ប្រៀបធៀបសេចក្តី

ក្នុងការឧបមានោះ ព្រះយោគាវចរបណ្ឌិតគប្បីឃើញដូចប្រចៀវ ឧបាទានក្ខន្ធ ៥ មានមែក ៥ ការកាន់យក ( គឺផ្តើមតាំងវិបស្សនា ) ក្នុងខន្ធ ៥ នៃព្រះយោគី ដូចការ ទំត្រង់ដើមស្រគំនៃប្រចៀវនោះ ការពិចារណារូបក្ខន្ធ មិនជួបរបស់ដែលគួរកាន់យក ត្រឹមតែមួយក្នុងរូបក្ខន្ធនោះ ទើបពិចារណាក្នុងខន្ធដ៏សេសនៃព្រះយោគី ដូចការស្ទាបមើល គ្រប់មែកនីមួយៗ ហើយ មិនជួបវត្ថុដែលល្មមកាន់យកសូម្បីមួយ ទើបស្ទាបមើលមែក ដ៏សេស ( តទៅ ) នៃប្រចៀវនោះ ញាណ ៣ មានមុញ្ចិតុកម្យតាញាណជាដើម នៃព្រះយោគីដែលនឿយណាយក្នុងខន្ធទាំង ៥ ដោយអំណាចការឃើញត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ដូចការគិតថា ដើមឈើនេះ មិនមានផ្លែហ្ន៎ ហើយដក អាល័យក្នុងដើមឈើនៃប្រចៀវនោះ អនុលោមញ្ញាណនៃព្រះយោគី ដូចការស្រវា ឡើងខាងលើតាមមែកត្រង់នៃប្រចៀវនោះ គោត្រភូញាណ ដូចការអើតក្បាលចេញ ងើយមើលខាងលើ មគ្គញ្ញាណ ដូចការហើរឡើងក្នុងអាកាស ផលញ្ញាណ ដូចការ ទៅទំត្រង់ដើមឈើមានផ្លែដទៃ ។

## ពស់វែក

ក្នុងឧបមាដោយពស់វែក មានពោលមកហើយ ក្នុងវគ្គបដិសង្ខាញាណ តែក្នុង ការប្រៀបសេចក្តីឧបមាក្នុងទីនេះទៅដូច្នេះគោត្រភូញាណ ឧបមាដូចការលោសពស់ទៅ

មគ្គញ្ញាណ ដូចការឈប់ឈរនៃបុរសដែលដោះលែងពស់ ហើយសម្លឹងមើលផ្លូវដែល ( កករឡើងមក ) ផលញ្ញាណ ដូចការអាស្រ័យនៅក្នុងទីមិនមានភ័យ ។

## ផ្ទះ

សេចក្តីឧបមាអំពីផ្ទះ ឧបមាថា ម្ចាស់ផ្ទះបរិភោគអាហារល្ងាចហើយ ឡើងដេកលក់ទៅ ផ្ទះត្រូវភ្លើងឆេះឡើង ម្ចាស់ផ្ទះភ្ញាក់ឡើង ឃើញភ្លើង ក៏ភ័យគិតថាជាការល្អ ដែលអញមិនទាន់ត្រូវភ្លើងឆេះ សម្លឹង ( រកផ្លូវចេញ ) លុះឃើញផ្លូវហើយ ក៏ចេញទៅកាន់ទីផុតភ័យ ដោយរហ័ស ហើយឈប់នៅ ។

## ប្រៀបធៀបសេចក្តី

ក្នុងការឧបមានោះ ការប្រកាន់ក្នុងខន្ធ ៥ ថាជាអញ ជារបស់អញនៃបុថុជ្ជនល្ងង់ខ្លៅ ដូចការបរិភោគអាហារ ហើយឡើងដេកលក់ទៅនៃម្ចាស់ផ្ទះ ការបដិបត្តិសម្មាបដិបទា រហូតឃើញត្រៃលក្ខណ៍ ហើយពិចារណាសង្ខារប្រាកដជារបស់គួរខ្លាច ( គឺភយតុបដ្ឋានញ្ញាណ ) ដូចម្ចាស់ផ្ទះភ្ញាក់ឡើង ឃើញភ្លើងហើយភ័យ មុញ្ចិតុកម្យតាញាណ ដូចការរកផ្លូវចេញ អនុលោមញ្ញាណ ដូចការឃើញផ្លូវ គោត្រភូញាណ ដូចការចេញទៅ មគ្គញ្ញាណ ដូចការទៅដោយរហ័ស ផលញ្ញាណ ដូចការសម្រាកសម្រាន្តនៅ ក្នុងទីដែលផុតភ័យ ។

## គោ

ឧបមារឿងគោ ឧបមាថា កាលអ្នកស្រែម្នាក់កំពុងដេកលក់ពេលរាត្រី គោទាំងឡាយ ហែកក្រោលចេញទៅ ពេលជិតភ្លឺ អ្នកស្រែទៅមើលត្រង់ក្រោលនោះដឹងភាពដែលគោទាំងនោះចេញទៅ ក៏តាមស្នាមជើងទៅ បានជួបហ្វូងគោរបស់ព្រះ

រាជា អ្នកស្រែស្មានថា គោទាំងនោះជាគោរបស់ខ្លួន ក៏កៀងនាំមក លុះភ្លឺឡើងស្គាល់ថា គោមិនមែនរបស់ខ្លួនជាគោរបស់ព្រះរាជា ទើបគិតថា ចាំបាច់គេចទៅសិន មុនពួករាជបុរសមកចាប់ ដោយចោទថា ជាចោរ ហើយ ( ដាក់ទោស ) ឲ្យដល់នូវការវិនាស ( គិតហើយកើតការ ) ភ័យ លះបង់ហ្វូងគោ ប្រញាប់គេចទៅទីដែលមិនមានភ័យ ។

## ប្រៀបធៀបសេចក្តី

ក្នុងការឧបមានោះ ការប្រកាន់ខន្ធទាំងឡាយ ថាជាអញ ជារបស់អញនៃបុថុជ្ជនល្ងង់ខ្លៅ ដូចការប្រកាន់យកគោរបស់ស្តេចថា ជាគោរបស់ខ្លួន ការស្គាល់ខន្ធទាំងឡាយថា មិនទៀង ជាទុក្ខ ជាអនត្តា ដោយអំណាចត្រៃលក្ខណ៍នៃព្រះយោគី ដូចការស្គាល់ថា ជាគោស្តេច ក្នុងពេលភ្លឺឡើង ភយតុបដ្ឋានញ្ញាណ ដូចវេលាដែល ( កើតការ ) ភ័យឡើង មុញ្ចិតុកម្យតា ដូចការដែលចង់លះបង់ ( គោស្តេច ) គេចទៅ គោត្រភូ ដូចការលះបង់ ( គោស្តេច ) មគ្គ ដូចការគេច ផល ដូចការគេចទៅក្នុងទីក្សេម ។

## យក្ខិនី

ឧបមាអំពីយក្ខិនី ឧបមាបុរសម្នាក់ សម្រេចការនៅរួមជាមួយយក្ខិនី ពេលរាត្រី ( យប់ជ្រៅ ) យក្ខិនីនោះដឹងថា បុរសនោះដេកលក់ហើយ ក៏ទៅកាន់ព្រៃខ្មោចស្រស់ស៊ីសាច់មនុស្ស បុរស ( ដឹងខ្លួនឡើង ) មិនឃើញយក្ខិនី ចាំបែងចិត្តថា នាងទៅណាហ្ន៎ ទើបតាមរក ជួបនាងកំពុងស៊ីសាច់មនុស្ស ដឹងកាពដែលនាងជាអមនុស្សហើយ ទើបគិតថា នឹងត្រូវគេចទៅសិន ទាន់នាងមិនទាន់បរិភោគខ្លួន ( គិតហើយកើតការ ) ខ្លាច ប្រញាប់គេចទៅ ឈប់នៅក្នុងទីផុតភ័យ ។

## ប្រៀបធៀបសេចក្តី

ក្នុងការឧបមានោះ ការប្រកាន់ខន្ធទាំងឡាយ ថាជាអញ ជារបស់អញ ដូចជា

ការនៅរួមជាមួយនាងយក្ខិនី ការឃើញត្រៃលក្ខណ៍ ហើយដឹងភាពដែលខន្ធទាំងឡាយ ជារបស់មិនទៀងជាដើម ដូចការឃើញ ( យក្ខកាឡាខ្លួន ) ដែលកំពុងស៊ីសាច់មនុស្ស ក្នុងព្រៃខ្មោច ហើយដឹងថា នាងជាយក្ខ **ភយតុបដ្ឋាន** ដូចការ ( កើត ) ខ្លាចឡើង **មុញ្ចិតុកម្យតា** ដូចការប្រាថ្នានឹងគេច **គោត្រភូ** ដូចការបោះបង់ព្រៃខ្មោច **មគ្គ** ដូចការប្រញាប់ប្រញាល់គេចទៅ **ផល** ដូចការសម្រាកសម្រាន្តនៅ ក្នុងទីមិនមានភ័យ ។

## ទារក

ឧបមាអំពីទារក ឧបមាថា ស្រីម្នាក់ ជាអ្នកស្រឡាញ់កូន ស្រីនោះអង្គុយនៅលើប្រាសាទជាន់លើ បានឮសំឡេងក្មេង ( យំ ) ត្រង់កណ្ដាលថ្នល់ គិតស្មានថា កូនរបស់ខ្លួន ត្រូវបុគ្គលណាម្នាក់ ធ្វើឲ្យយំ ប្រញាប់ប្រញាល់ ( ចុះអំពីប្រាសាទ ) ទៅស្រវាយកកូនអ្នកដទៃ ដោយសម្គាល់ថា កូនរបស់ខ្លួន ( មកបីព ) លុះស្គាល់ថា ទារកជាកូនអ្នកដទៃ នាងក៏ភ័យរន្ធត់ ខ្លាច ( ខុស ) ក្រឡេក ខាងនោះ ខាងនេះ គិតថា បុគ្គលណា កុំចោទខ្ញុំថាជាអ្នកលួចក្មេងឡើយ ( គិតហើយក៏ ) ដាក់ក្មេងចុះត្រង់ថ្នល់នោះឯង ប្រញាប់ប្រញាល់ឡើងប្រាសាទ ហើយអង្គុយចុះ ។

## ប្រៀបធៀបសេចក្ដី

ក្នុងការឧបមានោះ ការប្រកាន់ខន្ធ ៥ ថាជាអញ ជារបស់អញ ដូចការស្រវាយកកូនអ្នកដទៃ ដោយសម្គាល់ថា ជាកូនរបស់ខ្លួន ការស្គាល់ថា ខន្ធមិនមែនអញ មិនមែនរបស់អញ ដោយអំណាចត្រៃលក្ខណ៍ ដូចការស្គាល់ថា នេះជាកូនអ្នកដទៃ ភយតុបដ្ឋានញ្ញាណ ដូចការភ័យខ្លាច ( កំហុស ) មុញ្ចិតុកម្យតាញ្ញាណ ដូចការសម្លឹងមើលខាងនោះ ខាងនេះ អនុលោមញ្ញាណ ដូចការដាក់ទារកចុះត្រង់កណ្ដាលថ្នល់នោះឯង គោត្រភូញ្ញាណ ដូចការដែលដាក់ចុះហើយ ឈរនៅកណ្ដាលថ្នល់

មគ្គញ្ញាណ ដូច ( ការត្រឡប់ ) ឡើងប្រាសាទ ផលញ្ញាណ ដូចឡើងទៅ ហើយអង្គុយចុះ ។

## ឃ្លាន ស្រេក រងា ក្តៅ ងងឹត ថ្នាំពិស

ចំណែកឧបមា ៦ ប្រការនេះ គឺឃ្លាន ស្រេក ត្រជាក់ ក្តៅ ងងឹត និងថ្នាំពិស លោកពោលដើម្បីសម្តែងភាព ដែលបុគ្គលតាំងនៅក្នុងវុដ្ឋានគាមិនីវិបស្សនាហើយ ជាអ្នកបង្អោន ឱន លំអៀង បែរមុខ ទៅកាន់លោកុត្តរធម៌ ។

ពិតហើយ បុគ្គលដែលត្រូវសេចក្តីឃ្លានគ្របសង្កត់ហើយ ជាអ្នកឃ្លានខ្លាំង ជាអ្នកប្រាថ្នាភោជនដែលមានរសល្អ យ៉ាងណា ព្រះយោគាវចរដែលត្រូវការឃ្លានសង្សារវដ្ត គឺសង្សារវដ្តប៉ះខ្ទប់ហើយ ក៏រមែងប្រាថ្នាភោជន គឺកាយគតាសតិ ដែលមានរសជាអមតៈ ដូច្នោះដូចគ្នា ។

ម្យ៉ាងទៀត បុគ្គលដែលស្រេកហើយ មាន-ក និងមាត់ក្រៀមស្ងួត រមែងប្រាថ្នាបានៈ ដែលមានគ្រឿងតាក់តែងច្រើនយ៉ាង យ៉ាងណា ព្រះយោគាវចរដែលត្រូវស្រេក គឺសង្សារវដ្តប៉ះខ្ទប់ហើយនេះ រមែងប្រាថ្នាបានៈ គឺអដ្ឋង្គិកមគ្គ ដែលជាអរិយៈ ដូច្នោះដូចគ្នា ។ ម្យ៉ាងទៀត បុគ្គលត្រូវរងាគ្របសង្កត់ហើយ រមែងប្រាថ្នាកម្តៅ យ៉ាងណា ព្រះយោគាវចរដែលត្រូវរងា គឺតណ្ហាសិនេហៈ ( ជ័រ គឺតណ្ហា ) ក្នុងសង្សារវដ្តប៉ះខ្ទប់ហើយ រមែងប្រាថ្នាភ្លើង គឺមគ្គ ដែលដុតកិលេសបាន ដូច្នោះដូចគ្នា ។

ម្យ៉ាងទៀត បុគ្គលដែលត្រូវកម្តៅប៉ះខ្ទប់ហើយ រមែងប្រាថ្នាត្រជាក់ យ៉ាងណា ព្រះយោគាវចរដែលត្រូវកម្តៅនៃភ្លើង ១១ កង ក្នុងសង្សារវដ្តពេលហើយ ក៏រមែងប្រាថ្នាព្រះនិព្វាន ដែលជាទីចូលទៅរំលត់នៃភ្លើង ១១ កង ដូច្នោះដូចគ្នា ។

ម្យ៉ាងទៀត បុគ្គលត្រូវងងឹតគ្របសង្កត់ហើយ រមែងប្រាថ្នាពន្លឺ យ៉ាងណា ព្រះយោគាវចរដែលត្រូវងងឹត គឺអវិជ្ជាគ្របដណ្ដប់ហើយ ក៏រមែងប្រាថ្នាមគ្គភាវនា ដែលមានពន្លឺសម្រេចដោយញាណ ដូច្នោះដូចគ្នា ។

ម្យ៉ាងទៀត បុគ្គលដែលត្រូវថ្នាំពិសហើយ រមែងប្រាថ្នាថ្នាំកម្ចាត់ពិស យ៉ាងណា ព្រះយោគាវចរដែលត្រូវពិស គឺកិលេសហើយ ក៏រមែងប្រាថ្នាព្រះនិព្វាន ដែលជាឱសថអមតៈ ទម្លាយពិស គឺកិលេសបាន ដូច្នោះដូចគ្នា ។

ព្រោះហេតុនោះ ទើបខ្ញុំពោលទុកថា កាលលោកដឹងយ៉ាងនោះ ឃើញយ៉ាងនោះ ទើបរមែងថយ រមែងរួញ រមែងត្រឡប់ មិនលូតទៅក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ឧបេក្ខា ឬបាដិកុលយតា ( ការគួរខ្ពើមនៃសង្ខារទាំងឡាយ ) រមែងតាំងមាំ ប្រៀបដូចតំណក់ទឹកទាំងឡាយដែលធ្លាក់ចុះអំពីស្លឹកឈូកដែលផ្អៀងបន្តិច ដូច្នេះជាដើម ពាក្យទាំងពួងគប្បីជ្រាបដោយន័យ ដែលពោលមកអំពីមុនហើយ ។

## បុគ្គលបានសង្ខារុបេក្ខាញាណ បានឈ្មោះថា បដិលីនចរ

ដោយបដិបទាប៉ុណ្ណេះ ព្រះយោគាវចរនោះ រមែងបានឈ្មោះថា ជាបដិលីនចរ ដែលព្រះមានព្រះភាគទ្រង់សំដៅដល់ត្រាស់ទុកថា

បដិលីនចរស្ស ភិក្ខុនោ ភជមានស្ស វិវិត្តមាសនំ
សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ ។

បើភិក្ខុណា មិនសម្តែងខ្លួនក្នុងភព ( គឺទីលំនៅ ) ព្រះអរិយៈទាំងឡាយ ពោលការមិនសម្តែងខ្លួននោះ នៃភិក្ខុនោះ ដែលជាបដិលីនចរ សេពតែអាសនៈដ៏ស្ងាត់ថាជាសាមគ្គិយ ( ដំណើរប្រពៃ ) ។

## សង្ខារុបេក្ខាញាណកំណត់សេចក្តីប្លែកគ្នានៃពោជ្ឈង្គជាដើម

សង្ខារុបេក្ខាញាណ កំណត់ភាពជាបដិលីនចរនៃព្រះយោគី ដូចពោលនេះហើយ នៅកំណត់ការប្លែកគ្នានៃពោជ្ឈង្គ ការប្លែកគ្នានៃអង្គមគ្គ ការប្លែកគ្នានៃអង្គឈាន ការប្លែកគ្នានៃអង្គបដិបទា ការប្លែកគ្នានៃវិមោក្ខ សូម្បីនៃអរិយមគ្គតទៅទៀតផងដែរ ។

តែព្រះថេរៈអង្គខ្លះពោលថា បាទកជ្ឈាន ( គឺឈានដែលជាបាទនៃវុដ្ឋានគាមិនីវិបស្សនាដែលប្រព្រឹត្តទៅជិតចំពោះមគ្គ ) កំណត់ការប្លែកគ្នានៃពោជ្ឈង្គ នៃអង្គមគ្គ និងនៃអង្គឈាន អង្គខ្លះពោលថា ខន្ធដែលជាអារម្មណ៍នៃវិបស្សនា កំណត់ ( សេចក្តីប្លែកគ្នា ) អង្គខ្លះក៏ពោលថា អជ្ឈាស្រ័យរបស់បុគ្គល ( ដែលបំពេញវិបស្សនា ) កំណត់ក្នុងវាទៈរបស់ព្រះថេរៈទាំង ៣ ពួកនោះ ក៏គប្បីជ្រាបចុះថា វុដ្ឋានគាមិនីវិបស្សនាដែលជាបុព្វភាគនេះឯងកំណត់ ( ការប្លែកគ្នានោះ ) ។

នេះជាអនុបុព្វីកថា ក្នុងការកំណត់ការប្លែកគ្នានៃពោជ្ឈង្គជាដើមនោះ ពោលដោយការកំណត់នៃវិបស្សនា មគ្គដែលកើតឡើងដល់សុខវិបស្សកភិក្ខុក្តី មគ្គដែលបានធ្វើឈានឲ្យជាបាទកើតឡើងដល់សមាបត្តិលាភីភិក្ខុក្តី មគ្គដែលលោកបំពេញវិបស្សនាធ្វើបឋមជ្ឈានឲ្យជាបាទហើយ ពិចារណាបកិណ្ណកសង្ខារ ( គឺសង្ខារដទៃៗ ក្រៅអំពីតួឈានដែលជាបាទ ) ឲ្យកើតឡើងក្តី ក៏ជាបឋមជ្ឈានិកនោះឯង ពោជ្ឈង្គក៏មានអង្គ ៧ មគ្គអង្គ ៨ ឈានអង្គ ៥ ក្នុងគ្រប់មគ្គ សូម្បីបុព្វភាគវិបស្សនានៃមគ្គទាំងនោះសោត និងជាសោមនស្សសហគតៈខ្លះ ឧបេក្ខាសហគតៈខ្លះ ( តែ ) ក្នុងកាលនៃវុដ្ឋានដល់នូវភាពជាសង្ខារុបេក្ខាហើយ ក៏ជាសោមនស្សសហគតៈ ។

ក្នុងមគ្គទាំងឡាយ ដែលអ្នកបំពេញវិបស្សនា ធ្វើទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងបញ្ចកន័យឲ្យជាបាទហើយ ធ្វើឲ្យកើតឡើង ឈានរមែងមានអង្គ ៤

អង្គ ៣ អង្គ ២ តាមលំដាប់ពិត ចំណែកអង្គមគ្គមាន ៧ ក្នុងគ្រប់មគ្គ ពោជ្ឈង្គមាន ៦ ក្នុងមគ្គទី ៤ ការប្លែកគ្នានេះ រមែងមានទាំងដោយការកំណត់នៃបាទកជ្ឈានទាំងដោយការកំណត់នៃវិបស្សនា បុព្វភាគវិបស្សនា សូម្បីនៃមគ្គ ( ដែលធ្វើទុតិយតតិយ-ចតុត្ថជ្ឈានឲ្យជាបាទកើតឡើង ) ទាំងនោះសោត ក៏ជាសោមនស្សសហគតៈក៏មាន ជាឧបេក្ខាសហគតៈក៏មាន ( តែ ) វុដ្ឋានគាមិនីវិបស្សនាត្រូវតែជាសោមនស្សសហគតៈដូចគ្នា ។

ចំណែកក្នុងមគ្គ ដែលកើតឡើងដោយធ្វើបញ្ចមជ្ឈានឲ្យជាបាទ អង្គឈានមាន ២ ជាឧបេក្ខា និងចិត្តេកគ្គតា ពោជ្ឈង្គ និងអង្គមគ្គ មាន ៦ និង ៧ សូម្បីការប្លែកគ្នានេះ ក៏មានដោយអំណាចនិយមទាំង ២ ( ទាំងបាទកជ្ឈាន និងវិបស្សនា ) តែក្នុងន័យនោះ បុព្វភាគវិបស្សនាជាសោមនស្សសហគតៈ ឬជាឧបេក្ខាសហគតៈខ្លះ ( តែ ) វុដ្ឋានគាមិនីវិបស្សនាជាឧបេក្ខាសហគតៈប៉ុណ្ណោះ ។

សូម្បីក្នុងមគ្គ ដែលបុគ្គលបំពេញវិបស្សនា ធ្វើអរូបជ្ឈានទាំងឡាយឲ្យជាបាទហើយ ធ្វើឲ្យកើតឡើងហើយ ក៏មានន័យនេះឯង ។

សមាបត្តិដែលចេញក្នុងទីជិតនៃមគ្គ ដែលកើតឡើងដោយចេញចាកបាទកជ្ឈានហើយពិចារណាសង្ខារឯណានីមួយ ដូច្នោះ រមែងធ្វើមគ្គនោះស្រដៀងខ្លួន ដូចផែនដីធ្វើពណ៌របស់ទន្សងស្រដៀងពណ៌របស់ខ្លួន ដូច្នោះ ។ ចំណែកក្នុងថេរវាទទី ២ ( គប្បីជ្រាបថា ) ជាមគ្គដែលកើតឡើង ដោយចេញចាកសមាបត្តិណាមួយ ហើយពិចារណាសមាបត្តិ ធម៌ទាំងឡាយណាមួយ ក៏រមែងស្រដៀងនឹងសមាបត្តិនោះឯង ដោយអត្ថថា ស្រដៀងនឹងសមាបត្តិធម៌ ដែលបុគ្គលបំពេញវិបស្សនាពិចារណា កាមាវចរធម៌ទាំងឡាយ ក៏ជាបឋមជ្ឈានិកប៉ុណ្ណោះ ឯការកំណត់ ( ការប្លែកគ្នានៃអង្គឈានជាដើម ) របស់វិបស្សនា សូម្បីក្នុងថេរវាទទី ២ នោះ ក៏គប្បីជ្រាបដោយន័យដែលពោល

ហើយនោះចុះ ។

ចំណែកក្នុងថេរវាទទី ៣ ( គប្បីជ្រាបថា ) ជាមគ្គដែលកើតឡើង ដោយធ្វើឈានណាមួយឲ្យជាបាទ ហើយពិចារណាឈានធម៌ណាមួយ តាមគួរដល់អជ្ឈាស្រ័យរបស់ខ្លួន ក៏រមែងស្រដៀងនឹងឈាននោះឯង តែមគ្គដែលកើតឡើងស្រដៀងនឹងឈាននោះៗ វៀរឈានដែលជាបាទ ឬឈានដែលពិចារណាចេញមិនសម្រេច ដោយត្រឹមតែអជ្ឈាស្រ័យ ( របស់ខ្លួន ) តែម្យ៉ាងបានឡើយ សេចក្តីនេះ គប្បីចង្អុលបង្ហាញដោយនន្ទកោវាទកសូត្រ ( រឿងព្រះនន្ទកៈឲ្យឱវាទភិក្ខុនី ) ។

ពិតហើយ ព្រះមានព្រះភាគ ក៏បានត្រាស់ព្រះវចនៈនេះទុក ( ក្នុងសូត្រនោះ ) ថា ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចក្នុងថ្ងៃឧបោសថ ១៥ កើត សេចក្តីសង្ស័យ ឬការស្រពេចស្រពិលថា **ព្រះចន្ទផត ឬពេញហើយ** មិនមានដល់មហាជនឡើយ ដែលពិតរមែងមានការដាក់ចិត្តថា **ដួងចន្ទពេញវង់** ដូចគ្នាទាំងអស់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងនោះ ក៏ជាអ្នកត្រេកអរ និងមានគំនិត ដែលប្រៀបដោយធម៌ទេសនារបស់នន្ទកៈដូច្នោះដូចគ្នា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុនីប្រមាណ ៥០០ រូបនោះ ភិក្ខុនីអង្គដែលមានគុណធម៌យ៉ាងទាប ក៏ជាសោតាបន្ន មានការមិនធ្លាក់ ( អបាយ ) ជាធម្មតា ជាអ្នកទៀងពិតប្រាកដចំពោះការត្រាស់ដឹង ដូច្នេះ ។

ក្នុងភិក្ខុនីទាំងនោះ ភិក្ខុនីអង្គណាមានឧបនិស្ស័យនៃសោតាបត្តិផល ភិក្ខុនីអង្គនោះ ក៏បានជាអ្នកមានគតិ ពេញប្រៀបដោយសោតាបត្តិផលនោះឯង អង្គណា មានឧបនិស្ស័យនៃសកទាគាមិផល...អនាគាមិផល...។បេ។មានឧបនិស្ស័យនៃអរហត្តផល អង្គនោះ ក៏បានជាបុគ្គលមានគំនិត ពេញប្រៀបដោយអរហត្តផលនោះឯង ។

មគ្គ ដែលបំពេញវិបស្សនា ធ្វើឈានណាមួយ ឲ្យជាបាទហើយ ពិចារណាឈានធម៌ណាមួយ ឲ្យកើតឡើង តាមគួរដល់អជ្ឈាស្រ័យរបស់ខ្លួន ក៏រមែងស្រដៀង

នឹងឈានទោះឯង តែមគ្គដែលកើតឡើងស្រដៀងនឹងឈាននោះៗ វៀរឈានដែលជាបាទ ឬឈានដែលពិចារណាចេញ មិនសម្រេចដោយត្រឹមតែអជ្ឈាស្រ័យ (នៃខ្លួន) តែម្យ៉ាងបានឡើយ ដូចពោលមកដូច្នេះឯង ឯការកំណត់ ( ការប្លែកគ្នានៃអង្គឈានជាដើម ) នៃវិបស្សនា សូម្បីក្នុងថេរវាទទី ៣ នេះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយដូចគ្នា ។

គប្បីជ្រាបថា សង្ខារុបេក្ខារមែងកំណត់ ( ការប្លែកគ្នានៃ ) ពោជ្ឈង្គ អង្គមគ្គ និងអង្គឈាន ដូចពោលមក ដូច្នេះ ជាលំដាប់ដំបូង ។

## សង្ខារុបេក្ខាញាណ

### កំណត់ការប្លែកគ្នានៃបដិបទា

បើសង្ខារុបេក្ខានេះ ដំបូង កាលសង្កត់កិលេស សង្កត់បានដោយលំបាក ត្រូវប្រើបយោគ ( គឺឧស្សាហ៍ ) ប្រើសង្ខារ ( គឺសេចក្ដីព្យាយាម ) សោត រមែងបានឈ្មោះថា ទុក្ខាបដិបទា ( បដិបត្តិលំបាក ) ដោយវិបរិយាយ ( គឺផ្ទុយគ្នា ) ក៏ឈ្មោះថា សុខាបដិបទា ( បដិបត្តិស្រួល ) តែកាលសង្កត់កិលេសបានហើយ ក៏សន្សឹមៗ ធ្វើការសង្កត់វិបស្សនាទៅ ឲ្យមគ្គប្រាកដ ឈ្មោះថា ទន្ធាភិញ្ញា ( ដឹងបានយឺតយូរ ) ដោយវិបរិយាយ ក៏ឈ្មោះថា ខិប្បាភិញ្ញា ( ដឹងបានរហ័ស ) សង្ខារុបេក្ខានេះតាំងនៅក្នុងអាគមនីយដ្ឋាន ( ជាដែនកើត ) ឲ្យនាម ដល់មគ្គរបស់ខ្លួន រៀងៗ ខ្លួន ដូច្នេះ ទើបមគ្គបាននាម ៤ យ៉ាងតាមនាមនោះ ។

ឯបដិបទានេះ រមែងមានផ្សេងៗ គ្នា ដល់ភិក្ខុអង្គខ្លះ សម្រាប់ភិក្ខុអង្គខ្លះ មានបដិបទា ១ ក្នុងមគ្គទាំង ៤ ចំណែកមគ្គទាំង ៣ របស់ព្រះសម្ពុទ្ធទាំងឡាយ ជាសុខាបដិបទាខិប្បាភិញ្ញាទាំងអស់ របស់ព្រះធម្មសេនាបតីក៏ដូច្នោះ តែសម្រាប់

ព្រះមហាមោគ្គល្លានត្ថេរ បឋមមគ្គជាសុខាបដិបទាខិប្បាភិញ្ញា មគ្គ ៣ ខាងលើជាទុក្ខាបដិបទាទន្ធាភិញ្ញា ម្យ៉ាងទៀត បដិបទាយ៉ាងណា សូម្បីអធិបតីទាំងឡាយ ( មានឆន្ទាធិបតីជាដើម ) ក៏ដូច្នោះ រមែងមានផ្សេងៗ គ្នា ក្នុងមគ្គ ៤ ដល់ភិក្ខុអង្គខ្លះ សម្រាប់អង្គខ្លះក៏មានអធិបតី ១ ក្នុងមគ្គទាំង ៤ ។

សង្ខារុបេក្ខា រមែងកំណត់ការប្លែកគ្នានៃបដិបទាដូចពោលមក ដូច្នេះ ។

ចំណែកសង្ខារុបេក្ខា កំណត់ការប្លែកគ្នានៃវិមោក្ខដូចម្តេច សេចក្តីនោះ ខ្ញុំបានពោលអំពីមុនមកហើយ ដូច្នេះ ។

## សង្ខារុបេក្ខាកំណត់ការប្លែកគ្នានៃវិមោក្ខន័យម្យ៉ាងទៀត

ន័យម្យ៉ាងទៀត មគ្គ រមែងបានឈ្មោះដោយហេតុ ៥ គឺដោយរសរបស់ខ្លួន ( គឺដោយសភាវៈ ) ខ្លះ ដោយបច្ចនិកធម៌ ( ធម៌ដែលជាសត្រូវ ) ខ្លះ ដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ ដោយអាគមនៈ ( ទីមក ) ខ្លះ ។

បើសង្ខារុបេក្ខាចេញ ( អំពីអារម្មណ៍ដែលកាន់យក ) ព្រោះពិចារណាសង្ខារទាំងឡាយថា មិនទៀងសោត មគ្គ ( ឬមគ្គសមង្គីបុគ្គល ) រមែងរួចផុតដោយអនិមិត្តវិមោក្ខ បើចេញព្រោះពិចារណាជាទុក្ខសោត រមែងរួចផុតដោយអប្បណិហិតវិមោក្ខ បើចេញព្រោះពិចារណាជាអនត្តាសោត រមែងរួចផុតដោយសុញ្ញតវិមោក្ខ នេះឈ្មោះថា បានឈ្មោះដោយរសរបស់ខ្លួន ។

ចំណែកមគ្គនោះ ឈ្មោះថា អនិមិត្តមគ្គ ក៏ព្រោះធ្វើយនវិនិព្ភោគ ( ញែកដុំ ) នៃសង្ខារទាំងឡាយ ហើយលះនិច្ចនិមិត្ត ធុវនិមិត្ត សស្សតនិមិត្តទាំងឡាយ ដោយអនិច្ចានុបស្សនា ( សម្រេច ) មក ។ ម្យ៉ាងទៀត ឈ្មោះថា អប្បណិហិតមគ្គ ក៏ព្រោះលះសុខសញ្ញា ញុំាងបណិធិ គឺការប្រាថ្នាឲ្យហួតហែងដោយទុក្ខានុបស្សនា (សម្រេច)

មក ឈ្មោះថា សុញ្ញតមគ្គ ក៏ព្រោះលះអត្តសញ្ញា សត្តសញ្ញា បុគ្គលសញ្ញា ហើយឃើញថាជារបស់ទទេនៃសង្ខារទាំងឡាយ ដោយអនត្តានុបស្សនា នេះឈ្មោះថា នាមដោយបច្ចនិកធម៌ ។

ចំណែកមគ្គនោះ ឈ្មោះថា សុញ្ញតមគ្គ ព្រោះទទេចាកកិលេស មានរាគៈជាដើម ឈ្មោះថា អនិមិត្តមគ្គ ព្រោះមិនមាននិមិត្តទាំងឡាយ មានរូបនិមិត្តជាដើម ឬនៃនិមិត្តទាំងឡាយ មានរាគនិមិត្តជាដើមនោះឯង ឈ្មោះថា អប្បណិហិតមគ្គ ព្រោះមិនមានបណិធិទាំងឡាយ មានរាគបណិធិជាដើម នេះជានាមដោយគុណរបស់ខ្លួន ។

មគ្គនេះ បានឈ្មោះថា សុញ្ញតមគ្គ អនិមិត្តមគ្គ អប្បណិហិតមគ្គ ព្រោះធ្វើព្រះនិព្វានដែលជាធម៌ទទេ ជាធម៌មិនមាននិមិត្ត ជាធម៌មិនមានបណិធិឲ្យជាអារម្មណ៍បាន នេះជានាមដោយអារម្មណ៍នៃមគ្គនោះ ។

ចំណែកអាគមមាន ២ គឺវិបស្សនាគមនៈ និងមគ្គាគមនៈ ក្នុងអាគមនៈ ២ យ៉ាងនោះ វិបស្សនាគមនៈ រមែងបានក្នុងមគ្គ មគ្គាគមនៈ រមែងបានក្នុងផល ព្រោះថា (ដោយវិបស្សនាគមនៈ) អនត្តានុបស្សនា ឈ្មោះថា សុញ្ញតវិបស្សនា មគ្គនៃសុញ្ញតវិបស្សនា ឈ្មោះថា សុញ្ញតមគ្គ អនិច្ចានុបស្សនា ឈ្មោះថា អនិមិត្តវិបស្សនា មគ្គនៃអនិមិត្តវិបស្សនា ទើបឈ្មោះថា អនិមិត្តមគ្គ តែឈ្មោះ (អនិមិត្តមគ្គ) នេះមិនមានតាមព្រះអភិធម្ម មានតែតាមផ្លូវព្រះសូត្រ ព្រោះក្នុងព្រះសូត្រនោះ អាចារ្យទាំងឡាយពោលថា គោត្រភូញាណធ្វើព្រះនិព្វាន ដែលជាធម៌មិនមាននិមិត្តឲ្យជាអារម្មណ៍ ជាញាណមាននាមថា អនិមិត្ត ខ្លួនតាំងនៅក្នុងអាគមនីយដ្ឋានហើយ ទើបឲ្យនាមដល់មគ្គ ដូច្នេះ ហេតុនោះ ទើបមគ្គបានឈ្មោះថា អនិមិត្ត ។

តែពោលដោយមគ្គាគមនៈ ផលបានឈ្មោះថា អនិមិត្ត ក៏ប្រពៃដូចគ្នា ទុក្ខានុបស្សនា ឈ្មោះថា អប្បណិហិតវិបស្សនា ព្រោះញុំាងបណិធិ (ការប្រាថ្នា) ក្នុង

សង្ខារទាំងឡាយឲ្យហួតហែងហើយ ( សម្រេច ) មក មគ្គនៃអប្បណិហិតវិបស្សនា ទើបឈ្មោះថា អប្បណិហិតមគ្គ ផលរបស់អប្បណិហិតមគ្គ ទើបឈ្មោះ អប្បណិហិតផល ។

វិបស្សនាឲ្យនាមរបស់ខ្លួនដល់មគ្គ មគ្គឲ្យនាមរបស់ខ្លួនដល់ផល ដោយន័យដូចពោលមកដូច្នេះឯង នេះជានាមដោយអាគមនៈ ។

សង្ខារុបេក្ខានេះ កំណត់ការប្លែកគ្នានៃវិមោក្ខ ដូច្នេះឯង ។

សង្ខារុបេក្ខាញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយសង្ខារុបេក្ខាញាណ

បដិសង្ខានុបស្សនាញាណ ប្រព្រឹត្តទៅដោយអំណាចការកំណត់អាការមិនទៀង ជាទុក្ខជាដើមនៃសង្ខារទាំងឡាយ តែដោយពិសេស ក៏មានការកំណត់អាការជាអនត្តា ជាប្រធាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **កាលកំណត់បានថា សង្ខារទាំងពួងជារបស់សូន្យ** ដូច្នេះ កាលមានការកំណត់ អាការជាអនត្តា នោះ ការចាក់ធ្លុះសច្ចៈ រមែងសម្រេច កាលការកំណត់អាការជាអនត្តាមិនមាន ការចាក់ធ្លុះសច្ចៈ ក៏មិនសម្រេច ។ ពិតហើយ ពាក្យប្រៀនប្រដៅរបស់សាស្តាទាំងឡាយ **មានសរភង្គសាស្តា** ជាដើមសូម្បីបញ្ញត្តអនិច្ចលក្ខណៈ និងទុក្ខលក្ខណៈទុក ក៏មិនបាន ជានិយ្យានិកធម៌បានឡើយ ព្រោះមិនមានអាការជាអនត្តានោះ ។ ម្យ៉ាងទៀត លោកអាចារ្យពោលថា **កាលកំណត់បានថា សង្ខារទាំងឡាយ ជារបស់សូន្យ** ដូច្នេះ ក៏សំដៅដល់សង្ខារទាំងនោះជារបស់សោះសូន្យចាកសារៈ មាននិច្ចសារៈជាដើម ។ ពិតហើយ វត្ថុណាសោះសូន្យចាកវត្ថុណា វត្ថុនោះ ក៏សូន្យទៅចាកវត្ថុនោះឯង ។ ព្រោះភាវៈដែលសង្ខារទាំងឡាយជារបស់សូន្យចាកអត្ត ជារឿងដែលគប្បីដឹងបានលំបាក ទើបលោកអាចារ្យផ្ដើមពាក្យថា **បុន សុញ្ញមិទំ** ជាដើម ដើម្បីញុំាងការតាមឃើញសុញ្ញតា បានចាក់ធ្លុះហើយច្រើនដង ឲ្យដល់នូវការមាំទាំឡើង ។ ក្នុងសេចក្ដីនោះ សង្ខារទាំងឡាយ គឺភាវៈជាអនត្តា ដោយចំណែកណា ក៏ជាអនត្តនិយដោយចំណែកនោះ ។ ព្រោះកាលមានអត្តា ក៏ត្រូវមានអត្តនិយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សង្ខារនេះសោះសូន្យចាកអត្តខ្លះ ចាកអត្តនិយ ( របស់ខ្លួន ) ខ្លះ** ដូច្នេះ ។ បទថា **ទ្វិកោដិកំ** ប្រែថា ២ ចំណុច អធិប្បាយថា ព្រោះមិនបានឃើញអត្តាប្រចក្សដោយញាណចក្ខុ

និងព្រោះមិនបានញាណចក្ខុនោះ ដោយអនុមាន ។ ប្រកបសេចក្តីថា មិនឃើញសត្វដទៃៗ ឬសង្ខារដែលតាំងនៅក្នុងភាពជាបរិក្ខារ គឺក្នុងភាវៈដែលញុំាង សុខ និងទុក្ខរបស់ខ្លួនឲ្យសម្រេច ។ ភ្ជាប់សេចក្តីថា ការកំណត់ទុកទៀត ។ បទថា **ឯត្ថ** ប៉ុនគ្នានឹង **ឯតស្មឹ យោគ សុញ្ញតានុបស្សនាធិការេ** ប្រែថា ក្នុងអធិការពោលដោយសុញ្ញតា-នុបស្សនានេះ ។

បទថា **ក្វចិ** សេចក្តីប៉ុនគ្នានឹង **កត្ថចិ យោគ ឋានេ** ប្រែថា ក្នុងទីណាមួយខ្លះ **យោគ កាលេ** ប្រែថា ក្នុងកាលណាមួយខ្លះ **យោគ ធម្មេ** ប្រែថា ក្នុងធម៌ណាមួយខ្លះ ។ន័យម៉្យាងទៀត បទថា **ក្វចិ** ប្រែថា ខាងក្នុងខ្លះ ខាងក្រៅខ្លះ ។ ពីរបទថា **អត្តនោ អត្តានំ** ប្រែថា ខ្លួនរបស់ខ្លួន ។ លោកអាចារ្យកាលសម្តែងថា ព្រះយោគាវចររមែងមិនឃើញអត្តាដែលជនដទៃបានកំណត់ទុកដោយន័យជាដើម បុគ្គលនេះជាព្រហ្មជាទេវមហាព្រហ្ម ។បេ។ ជាបុគ្គលប្រសើរបំផុត ជាអ្នករៀបចំជាអ្នកទ្រទ្រង់អំណាចជាបិតារបស់ពួកសត្វ ដែលជាភូតទាំងឡាយ ដូច្នេះជាដើម ថាជាអ្វី **របស់បុគ្គលណាម្នាក់** ។ ក្នុងបណ្តាពាក្យទាំងនោះ បទថា **បរស្ស** របស់បុគ្គលដែលត្រូវប្រកាន់យ៉ាងនេះថា **ជាតិដទៃ និងបុរសដទៃ ។ មម-ស័ព្ទ** ក្នុងពាក្យថា **ន ច មម ក្វចនិ** នេះប្រកបក្នុងឋានៈដែលមិនគួរ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **លើកមមស័ព្ទទុកសិន** ។ បទថា **បរស្ស ច** សេចក្តីថា របស់អ្នកដទៃក្រៅអំពីខ្លួន ។ លោកអាចារ្យកាលសម្តែងថា អត្ថយ៉ាងនេះ ក្នុងពាក្យថា **បុរសដទៃ** ដូច្នេះ តាំងនៅដើម្បីប្រយោជន៍ដល់យើងគ្រប់យ៉ាង រមែងសម្រេចដល់យើង ដោយអំណាចសេចក្តីនោះព្រោះហេតុនោះ ទើបព្រះយោគាវចរមិនឃើញតួខ្លួនដទៃ ដោយអំណាចការកំណត់របស់បុគ្គលដែលមានទិដ្ឋិណាមួយយ៉ាងនេះ និងមិនឃើញតួខ្លួននោះជាអ្វីដល់ខ្លួន ទើបពោលពាក្យជាដើមថា **ន ច ក្វចនិ** មិនឃើញថា តួខ្លួនមាននៅក្នុងទីណាមួយឡើយ ។

ក្នុងអធិការនេះ បទថា **នាហំ ក្វចនិ** សេចក្ដីថា រមែងឃើញការមិនមាននៃខ្លួនរបស់ខ្លួន ។ ពាក្យថា **ន កស្សចិ កិញ្ចនតស្មឹ** សេចក្ដីថា រមែងឃើញបុគ្គលណាម្នាក់មិនមែនជារបស់ខ្លួននៃខ្លួនរបស់ខ្លួននោះឯង ។ ពីរបទថា **ន ច មម** នេះ គប្បីភ្ជាប់ចូលតាមគួរ ។ បទថា **អត្ថិ** គប្បីភ្ជាប់ចូលគ្រប់បទ ។ រមែងឃើញការមិនមាននៃតួខ្លួនរបស់អ្នកដទៃថា **តួខ្លួនរបស់អ្នកដទៃមិនមាននៅក្នុងទីណាមួយឡើយ** ។ រមែងឃើញតួខ្លួនរបស់អ្នកដទៃជារបស់មិនមែនរបស់តួខ្លួនថា **តួខ្លួនរបស់បុគ្គលដទៃនោះ ជារបស់ណាមួយ ដល់អញក៏មិនមាន** ។ ខន្ធទាំងឡាយខាងក្នុង និងខាងក្រៅ ជារបស់ទទេចាកតួខ្លួន និងរបស់ខ្លួន ជាគំនរនៃសង្ខារសុទ្ធៗ គឺព្រះយោគាវចរបានឃើញហើយ ដោយការកំណត់សុញ្ញតា ៤ ចំណុច ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ឯវំ មយំ** ជាដើម ។

ដោយពាក្យថា **ដោយអាការ ៦** ជាដើម លោកអាចារ្យរមែងសម្ដែងប្រការដែលមកហើយក្នុងទីនោះ ក្នុងបណ្ដានិទ្ទេសជាដើម សង្គ្រោះចូលកាន់ការកពូន ដោយសុញ្ញតានុបស្សនា ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ដោយអាការ ៦** បានដល់ ដោយអាការដែលកាន់យក ឬដោយអាការដែលគប្បីកាន់យក ៦ ។ បទថា **និច្ចំ** សេចក្ដីថា អំពីអ្វីមួយដែលខ្លួនឯង ឬអ្នកដទៃកំណត់ទុកថា **ពិតប្រាកដ** ។ម្យ៉ាងទៀត បទថា **និច្ចំ** ប្រែថា អំពីភាពជារបស់ពិតប្រាកដ ។ អាការទាំងឡាយ មានការស្ថិតស្ថេរជាដើម ជាអាការដែលគប្បីកាន់យករបស់វត្ថុ ដែលបុគ្គលកាន់យកថា **ពិតប្រាកដ** នោះឯង ។ការៈដែលពាក្យនេះមាន ៦ ប្រការ ក៏ព្រោះការចែកអាការនោះៗ ។ ក្នុងអាការទាំង ៦ យ៉ាងនោះ ដែលឈ្មោះថា របស់ពិតប្រាកដ បានដល់ ភាពជារបស់មិនញាប់ញ័រ ។ របស់ស្ថិតស្ថេរ បានដល់ របស់មាំទាំ ។ របស់មានគ្រប់កាល បានដល់ របស់ទៀងពិត ។ របស់មិនមានការផ្លាស់ប្ដូរ បានដល់ របស់មិនមានការប្រែប្រួល

ជាធម្មតា ។ ពាក្យថា **រហូតដល់** បទថា **ជរា និងមរណៈ** លោកអាចារ្យសម្តែងបទចុងក្រោយ មិនបានធ្វើបេយ្យាលទុក ។ រូបណាមិនមានសារៈ ហេតុនោះ រូបនោះឈ្មោះថា **អសារំ** ប្រែថា មិនមានសារៈ សារៈមិនមានដល់រូបនេះ ហេតុនោះ រូបនេះឈ្មោះថា **និស្សារំ** ប្រែថា **មិនមានសារៈ** ។ រូបណាប្រាសចាកសារៈ ឬសារៈទៅប្រាសចាករូបនោះ ហេតុនោះ រូបនោះឈ្មោះថា **សារាបគតំ** ប្រែថា ប្រាសចាកសារៈ ។ ក្នុងសេចក្តីនេះ អាចារ្យពួកខ្លះរមែងពោលថា បីបទថា **អសារំ និស្សារំ សារាបគតំ** ជាអាការកំណត់សុញ្ញតាមយ៉ាង ដោយបំណងថា មានបាលីថា **និច្ចសារេន វា** ដោយសារៈ គឺនិច្ចសារៈ **សុខសារេន វា** ដោយសារៈ គឺសុខសារៈក្តី **អត្តសារេន វា** ដោយសារៈ គឺអត្តសារៈក្តី ។ កាលកាន់យកដោយប្រការដទៃ គប្បីមានអាការ ៧ យ៉ាងប៉ុណ្ណោះ មិនមែន ៨ យ៉ាង ។ អាចារ្យមួយពួកទៀត រមែងពោលថា មានបទបាលីថា **សុភសារេន** ដូច្នេះខ្លះ ព្រោះហេតុនោះ បីបទក្នុងពាក្យថា **អសារំ និស្សារំ សារាបគតំ** នេះ គប្បីប្រកបជាមួយបទក្នុងបទទាំងឡាយជាដើមថា **និច្ចសារសារេន** ដូច្នេះ ។ បទថា **សេតវច្ឆោ** ប្រែថា ដើមថ្វាន់ ។ អាចារ្យទាំងឡាយ រមែងហៅថា **មិនរុក្ខោ** ដូច្នេះក៏មាន ។ បទថា **បាលិភទ្ទកោ** ប្រែថា ដើមចារ ។

ឈ្មោះថា **ឃើញរូបដោយជារបស់ទទេ** ព្រោះការមិនមាននិច្ចសារៈជាដើម ។ ឈ្មោះថា **ដោយភាពជារបស់ទទេ** ព្រោះជារបស់បន្តិចបន្តួច ឬព្រោះជារបស់ថោកទាប ។ ឈ្មោះថា **ជារបស់សូន្យ** ព្រោះមិនមានអត្តសារៈ ។ ឈ្មោះថា **ជាអនត្តា** ព្រោះជារបស់មិនមែនតួខ្លួន ។ ឈ្មោះថា **មិនមាន** (បុគ្គលណាគ្រប់គ្រង) **ភាពជាឥស្សរៈ** ព្រោះមិនមានភាពជាធំ និងព្រោះបុគ្គលណា មិនគប្បីអាចគ្រប់គ្រងភាពជាធំ ។ រូបនោះ រមែងសម្រេចដល់បុគ្គលដែលប្រាថ្នាធ្វើភាពដែលរូបជារបស់ពិតប្រាកដជាដើម ដូចជាមិនសម្រេចដល់បុគ្គលដែលប្រាថ្នាធ្វើភាជនៈជាដើម ដោយដុំពពុះទឹក

ម្យ៉ាងទៀត ការធ្វើខ្លះ រមែងមិនមានដោយអំណាចការប្រាថ្នារបស់ខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថា **ឃើញរូប ជារបស់មិនគប្បីធ្វើ ឲ្យជាអ្វីបានតាមត្រូវការ** ។ ឈ្មោះថា **ឃើញរូបជារបស់មិនគប្បីបាន** ( ដូចប្រាថ្នា ) ថា រូបចូរជាយ៉ាងនេះប៉ុណ្ណោះ កុំទៅជាយ៉ាងនេះ ។ ឈ្មោះថា **ឃើញរូបជារបស់មិនប្រព្រឹត្តទៅក្នុងអំណាច** ព្រោះខ្លួនឯងមិនប្រព្រឹត្តទៅក្នុងអំណាចរបស់បុគ្គលដទៃ ទាំងមិនញ៉ាំងអ្នកដទៃឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ឈ្មោះថា **ឃើញរូបដោយចំណែកដទៃ** ( គឺមិនស្តាប់បង្គាប់បុគ្គលណា ) ព្រោះខ្លួននៅក្នុងសន្តានណា សន្តាននោះ បុគ្គលណាម្នាក់ គប្បីរៀបចំមិនបាន ដូចជារបស់ដទៃ ។ ឈ្មោះថា **ឃើញរូបជារបស់ឯក** ដោយហេតុទាំងឡាយនិងដោយផល ដូចព្រះអាទិទេពអ្នកសាងជាដើម ។ ពិតហើយ ផលរមែងតាំងនៅបានដោយហេតុ ឬហេតុមានគតិ ( ផល ) តាំងនៅបានដោយផលក៏ទេ ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យនេះ ។

សូម្បីក្នុងពាក្យថា **រូបំ ន សត្តោ** រូបមិនមែនសត្វជាដើម ក៏មានវិនិច្ឆ័យថា សត្វ ដោយលោកវោហារឯណា រូបមិនមែនសត្វនោះ ហេតុនោះ ទើបសេចក្តីនេះលោកមិនសំដៅយកក្នុងទីនេះ ព្រោះសេចក្តីនោះ លោកមិនបានពោលទុក និងសម្រេចទៅហើយ ។ អ្នកស្រុករមែងហៅសភាវៈត្រឹមតែរូបថា **សត្វ** ក៏ទេ តែអត្តាដែលពួកលទ្ធិក្រៅអំពីពុទ្ធសាសនាកំណត់គ្នាទុក លោកមានបំណងយកថា **សត្វ** ។ អត្តានោះលោកពោលថា **ជាសត្វ** ព្រោះអត្ថថា ជាទីសម្គាល់ដល់ជនដទៃ ព្រោះជនដទៃនោះរាយមាយទៅហើយ រាយមាយទៅផ្សេងៗ ហើយ ក្នុងអារម្មណ៍ មានរូបជាដើម ។ អធិប្បាយថា **អត្តានោះ រមែងមិនជារូប** ។ ក្នុងសេចក្តីនេះជាការកំណត់សុញ្ញតាដូច្នេះ ។ សូម្បីក្នុងពាក្យថា **ន ជីវោ** មិនមែនជីវៈជាដើម ក៏មានន័យនេះ ។ ក្នុងពាក្យថា **ជីវៈនោះ** ឈ្មោះថា **ជីវៈ** ដោយអត្ថថា **រស់នៅ** ។ ឈ្មោះថា **នរៈ** ដោយអត្ថ

គឺ **នរនៈ** ការនាំទៅ គឺដោយការៈជាអ្នកនាំទៅ ។ ឈ្មោះថា **មាណវ** ដោយអត្ថថា **ជាទីទៅ** គឺប្រព្រឹត្តទៅ ព្រោះជាទីតាំងនៃការកើតឡើងនៃមានះថា **អហមស្មិ** អញជាទុំះ ជានេះ ។ ឈ្មោះថា **ស្ត្រី** ដោយអត្ថថា **ជាទីរួមគ្នារបស់សត្វដែលទៅក្នុងគតិ** ។ ឈ្មោះថា **បុរិស** ដោយអត្ថថា **អ្នកប្រព្រឹត្តទៅមុនជាប្រធាន** ។ ឈ្មោះថា **អត្តា** ដោយអត្ថថា **ជាទីមកតាំងចុះនៃមានះថា ជាអញ** ។ ពួកមេលទិ្ធទាំងឡាយ រមែងហៅអត្តាថា **អហំ** ( អញ ) ព្រោះជាទីតាំងនៃអហង្ការរបស់អត្តានោះៗ ចំពោះខ្លួន ផ្សេងៗ ខ្លួន តែរូបមិនទៅជាដូច្នោះឡើយ ព្រោះហេតុនោះ លោកអាចារ្យមានបំណងសម្តែងវិធីកំណត់សុញ្ញតា ទើបពោលពាក្យថា **រូបមិនមែនសត្វ** ជាដើម ។ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្តែងរូបជារបស់សោះសូន្យចាកខ្លួន ដោយបទទាំង ៨ ។ ដោយបទទាំង ៤ ក្រៅអំពីនេះ លោកអាចារ្យសម្តែងការមិនមានការៈដែលរូបនោះជាអ្វីមួយឡើយ ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **មិនមែនរបស់យើង** គឺមិនមែនរបស់នៃខ្លួន នៃយើង មិនមែនជារបស់នៃខ្លួន នៃអ្នកដទៃដូចគ្នា មិនមែនជារបស់នៃខ្លួន សូម្បីនៃបុគ្គលណាម្នាក់ ព្រោះមិនមានខ្លួននោះឯង ។ អត្ថដូចគ្នានេះ មិនបានប្រកាសទុក ដោយបទថា **មិនមែនអត្តនិយ** បានប្រកាសហើយ ដោយបទទាំង ៣ ដែលជាបរិយាយដទៃ ។ សូម្បីក្នុងវេទនាជាដើមក៏មានន័យនេះ ។

លោកអាចារ្យកាលសម្តែងថា **សូម្បីន័យនៃសម្មសនៈ** ដែលបានពោលទុកដើម្បីការរឹងមាំ នៃកលាបសម្មសនៈខាងដើម រមែងប្រព្រឹត្តទៅដើម្បីភាពរឹងមាំនៃសុញ្ញតានុបស្សនា ទើបពោលពាក្យជាដើមថា **ដោយអំណាចតីរណបរិញ្ញា** ដូច្នេះៗ ក្នុងបណ្តាពាក្យទាំងនោះ ឈ្មោះថា **អសរណតោ** ដោយមិនមានទីពឹង ព្រោះមិនកម្ចាត់ភ័យ ។ ឈ្មោះថា **អសរណីភូតតោ** ដោយជារបស់មិនជាទីពឹង ព្រោះមិនគួរដល់ការកាន់យកថា **ជាទីពឹង** ។ បទថា **អនស្សាទតោ** ដោយជារបស់មិនមានអ្វី

គួរត្រេកអរនេះ មិនមាននៅក្នុងព្រះបាលី កាលមានក៏គប្បីមានអាការ ៤៣ ទៅ ។ ឈ្មោះថា **អាទីនវតោ** ជាទោស ព្រោះបានទោសទាំងពួង ក្នុងកាលរូបនៅប្រព្រឹត្តទៅ ។ ពីរបទថា **សមុទយតោ** ដោយការកើតឡើង **អត្ថង្គមតោ** ដោយការវិនាសទៅនេះ លោកអាចារ្យពោលទុក ព្រោះធ្វើអធិប្បាយថា ជាការធ្វើសុញ្ញតាឲ្យជាក់ច្បាស់ ដូចជាការឃើញជារបស់មិនទៀង ដោយផ្ទុវទឹកហូរ ឬដោយការសម្តែង វៀកចាកនិច្ចសារៈ ក៏ជាការធ្វើសុញ្ញតាឲ្យជាក់ច្បាស់ ដូច្នោះ ។ ដូចគ្នានោះដែរ ការឃើញថា **សុខសោ-មនស្សណា អាស្រ័យរូបកើតឡើង ជាគុណរបស់រូប** ដូច្នេះ ជាការធ្វើសុញ្ញតាឲ្យជាក់ច្បាស់ ដោយការញុំាងភាពជាបច្ចយធម៌ និងបច្ចយុប្បន្នធម៌ឲ្យជាក់ច្បាស់ ។ និងការឃើញថា រូបណាមិនទៀង ជាទុក្ខ មានការប្រែប្រួលជាធម្មតា នេះជាទោសរបស់រូប ដូច្នេះ ព្រោះធ្វើឲ្យទទេអំពីរបស់ទៀងជាដើម ។ មួយវិញទៀត គប្បីឃើញការកើតឡើងជាដើម និងការឃើញក្រៅអំពីនេះ ជាការតាមចម្រើនសុញ្ញតានុបស្សនា តាមគួរយ៉ាងនេះថា **ការកម្ចាត់ឆន្ទរាគៈ ការលះឆន្ទរាគៈក្នុងរូបចេញបាន នេះជាគ្រឿងរលាស់ចេញនៃរូប** ដូច្នេះ ។ មួយវិញទៀត ការឃើញទោសឯណា ដែលបានពោលទុកមុនហើយពោលទៀត ក៏គប្បីជ្រាបថា លោកពោលសំដៅដល់អាការឃើញ ដោយបន្ថែមភាពគួរត្រេកអរទុកផង ។ ពាក្យដ៏សេស ក៏មានន័យដូចពោលហើយខាងដើមនោះឯង ។ សូម្បីក្នុងវេទនាជាដើម ក៏គប្បីនាំយកអាការ ៤២ ចូលទៅប្រើផង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ឃើញវេទនា ។បេ។ វិញ្ញាណជាដើម ជារបស់មិនទៀង ។បេ។ ដោយការចេញទៅ** ។

មួយវិញទៀត សូម្បីការចង្អុលបង្ហាញកថា ពោលដោយការកំណត់សុញ្ញតា **មួយប្រការ** ក្នុងនិទ្ទេស ព្រះធម្មសេនាបតីសារីបុត្រ **បានពោលទុក** ដើម្បីសម្តែងថា **និទ្ទេសនេះ សម្រាប់ព្រះបាលីនោះ** ។ និងដើម្បីចង្អុលបង្ហាញផលរបស់និទ្ទេសនោះ ។

លោកអាចារ្យកាលសម្តែងថា កាលព្រះយោគាវចរកំណត់ជារបស់សូន្យ ដោយអាការ ៤២ យ៉ាង ក្នុងខន្ធទាំងឡាយ ចំពោះតែខន្ធ ១ ដោយអំណាចតីរណបរិញ្ញាយ៉ាងនេះ ប្រកបរឿយៗ នូវការនាដោយអំណាចអនុបស្សនា ៣ យ៉ាងនោះឯង រមែងមានការកើតឡើង នៃសង្ខារុបេក្ខាញាណបាន ទើបពោលពាក្យថា **ជារបស់សូន្យយ៉ាងនេះ** ដូច្នេះជាដើម ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **កំណត់** គឺពិចារណា ពាក្យថា **លះការខ្លាច និងការត្រេកអរចេញបានហើយ** សេចក្តីថា លះការខ្លាចដែលកើតឡើង ព្រោះអាស្រ័យវិបត្តិនៃសង្ខារទាំងឡាយ និងបីតិដែលកើតឡើង ព្រោះអាស្រ័យសម្បត្តិ នៃសង្ខារទាំងនោះចេញបាន ព្រោះជាបុគ្គលព្រងើយកន្តើយ ។ ម្យ៉ាងទៀត សេចក្តីថា លះការខ្លាចដោយញាណដែលកើតឡើង ដោយអំណាចភយតុបដ្ឋានញ្ញាណ និងការត្រេកអរ ពោល គឺបីតិដែលកើតឡើងដោយអំណាចសម្មសនញ្ញាណ ក៏ដើម្បីបានឃើញភាពជារបស់ទទេដោយប្រការទាំងពួង ហើយការខ្លាច និងការត្រេកអរ នឹងមានឱកាសឈោងចុះក៏ទេ ដោយពិត ឧបេក្ខាប៉ុណ្ណោះរមែងតាំងនៅ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងជាបុគ្គលព្រងើយក្នុងសង្ខារទាំងឡាយ** ។ ក្នុងពាក្យនោះ ការព្រងើយគប្បីមានបានដោយការប្រកាន់ខុសណា លោកអាចារ្យកាលសម្តែងការមិនមានការប្រកាន់ខុសនោះ ទើបពោលថា **មិនប្រកាន់ថា ជាអញ ឬជារបស់អញ** ដូច្នេះ ។ ឥឡូវនេះ លោកអាចារ្យកាលសម្តែងឧបមានៃព្រះយោគាវចរនោះ ជាអ្នកព្រងើយ ទើបពោលថា **ដូចបុរសដែលមានភរិយាដែលលែងគ្នាហើយ ដូច្នោះ** ដូច្នេះជាដើម ។

ក្នុងបណ្តាពាក្យទាំងនោះ លោកអាចារ្យពោលពាក្យថា **គប្បីជាស្រីគួរប្រាថ្នាគួរស្រឡាញ់** ដូច្នេះជាដើម ដើម្បីសម្តែងថា ជាអ្នកព្រងើយ មានភាពជាអ្នកមិនព្រងើយជាខាងដើម ដែលកំពុងពោល រមែងផ្សាយទៅដើម្បីជាឧបមាក្នុងទីនេះ ។ ឈ្មោះថា

គេហួងហែងនាងពន់ពេក ព្រោះមិនដឹងជាបុគ្គលអួតអាង បុគ្គលវៀចវេរ និងបុគ្គលក្បត់ជាដើមរបស់ស្រីទាំងឡាយ ។ ពីរបទថា **មុញ្ចិតុកាមោ ហុត្វា** អធិប្បាយថា បំណងនឹងលែងទៅ ទើបលែងស្រីនោះចោលដោយអំណាចនៃការមិនហួងហែងនោះឯង **អយំ យោគ យោគាវចរោ** ប្រែថា ព្រះយោគាវចរនេះ ។ ផុតមុញ្ចិតុកម្យតាញាណទៅ វិបស្សនាដែលប្រព្រឹត្តទៅគ្រប់ពេល ដែលសង្ខារុបេក្ខាញាណមិនទាន់កើតជាបដិសង្ខានុបស្សនាតែម្យ៉ាង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ទើបកំណត់សង្ខារទាំងឡាយ ដោយបដិសង្ខានុបស្សនា** ដូច្នេះ ។

ពាក្យថា **រមែងថយ** សេចក្តីថា រមែងអែបទៅ គឺហាក់ដូចជាអែបទៅម្ខាង ។ ពាក្យថា **រមែងរួញ** គឺរមែងអែន ។ ពាក្យថា **រមែងត្រឡប់** គឺរមែងប្តូរទៅ ។ ពាក្យថា **មិនលូតទៅ** គឺមិនរាយមាយទៅ អធិប្បាយថា មិនស្ទុះទៅដោយអំណាចការត្រេកអរក្រៃលែង ។

បទថា **ឥច្ចស្ស** កាត់បទជា **ឥតិ អស្ស, ឥតិ** ប៉ុនគ្នានឹង **ឯវំ, អស្ស យោគយោគិនោ** ប្រែថា ដល់ព្រះយោគីនោះ ដោយប្រការដូច្នេះ ។

ឯការព្រងើយក្នុងសង្ខារទាំងឡាយ សម្រេចជាធម៌រឹងមាំ ស្ទាត់ជំនាញ និងក្លាហាន សង្ខារុបេក្ខាញាណ **នេះ** ប្រព្រឹត្តទៅច្រើនដង ដល់នូវភាពជាបច្ច័យដល់អនុលោមញ្ញាណ ដោយដល់នូវការចាស់ក្លា ឈ្មោះថា **រមែងឃើញនិព្វាន ជាធម៌មាន** ។ សង្ខារុបេក្ខាញាណយ៉ាងនោះ ឈ្មោះថា **រមែងលះបង់បវត្តខាងសង្ខារស្ទុះទៅកាន់និព្វាននោះឯង** ។ ឯញាណក្នុងទីនេះ លោកពោលដោយអំណាចឯកត្តន័យនាំទៅកាន់ភាពតែមួយ និងអនុលោមញ្ញាណ និងគោត្រភូញ្ញាណ លោកអាចារ្យពោលសង្ខារុបេក្ខាញាណថា ជាធម្មជាតិមិនទាន់ចាស់ក្លានោះឯងមុនថា **បើមិនទាន់ឃើញព្រះនិព្វាន ថាជាធម៌មានសោត** ដូច្នេះ ។ ជនពួកណា រមែងឆ្លងសមុទ្រ ហេតុនោះ

ជនទាំងនោះ ឈ្មោះថា **សមុទ្ទិកា** អ្នកចូងសមុទ្រ ( សមុទ្រពាណិជ្ជ ) គឺបុគ្គល មានការបន្សាត់ទូកទៅជាទីបំផុត ។ ក្អែកដែលស្គាល់ទិស ឈ្មោះថា **ទិសាកាកោ** ( ក្អែកដែលស្គាល់ទិស ) ពាក្យនេះត្រឹមតែជាការកំណត់ គប្បីជ្រាបដល់បក្សីនោះ ប្រភេទណានីមួយ ។ ពាក្យថា **ខុសទិសដៅ** គឺមិនមែនទិសដៅ បានដល់ ទីដែល មិនធ្លាប់ស្គាល់ក្នុងសមុទ្រ ។ ពាក្យថា **ហើរពិនិត្យ** គឺហើរទៅតាមលំដាប់ៗ ។

**តយិទំ យោគ វិបស្សនាញាណំ** ប្រែថា វិបស្សនាញាណនេះ ។ ពាក្យថា **ដូចម្សៅដែលត្រូវបុក** គឺដូចលម្អិតម្សៅដែលល្អិតៗ ដែលត្រូវបុកបំបែកអំពីម្សៅ ដែលគ្រើមៗ ។ បទថា **និព្វដ្ដិ តកប្បាសំ** ប្រែថា កប្បាសដែលបកគ្រាប់ចេញហើយ ។ ពាក្យថា **ដូចត្រូវហែក** គឺដូចធ្វើឲ្យបាយខ្ទេចចេញដោយធ្នូតូចៗ ឧបមាទាំង ២ ប្រការ លោកអាចារ្យពោលការដល់នូវភាព ដែលវិបស្សនាញាណជាញាណ ដែលល្អិត ក្រៃលែង ដោយការពិចារណាហើយ ពិចារណាទៀត ។ ឯអនុបស្សនា រមែងជា ធម្មជាតិមុត ជំនាញ និងក្លាហាន ដោយកម្លាំងនៃវិបស្សនាភាវនា ដោយប្រការណាមួយ ក៏រមែងជាធម្មជាតិល្អិតក្រៃលែង ដោយប្រការនោះឯង ។ ពាក្យថា **ក្នុងការពិនិត្យ ពិច័យសង្ខារ** សេចក្ដីថា ជាញាណព្រងើយកន្តើយក្នុងការពិនិត្យពិច័យសង្ខារទាំងនោះ តាំងនៅដោយអនុបស្សនា ៣ យ៉ាង ព្រោះមិនមានប្រការដទៃ ដូចជាការពិចារណា ដល់ចុងបំផុតក្នុងសង្ខារទាំងឡាយ ឯប្រការនៃអនុបស្សនាចែកទុកដោយពាក្យជាដើម ថា **៧ ប្រការ ១៨ ប្រការ** ដូច្នេះ ក៏ឈោងចុះក្នុងអនិច្ចានុបស្សនាជាដើមនោះឯង ព្រោះ ហេតុនោះ ទើបវិបស្សនាដែលដល់កំពូល តាំងនៅដោយអំណាចនៃអនិច្ចានុបស្សនា ជាដើមនោះឯង ។

បទថា **តត្រ** សេចក្ដីប៉ុនគ្នានឹង **តស្មឹ យោគ វិមោក្ខមុខភាវំ បដ្ឋេន អរិយបុគ្គលវិភាគបច្ចយត្តេ ច** ប្រែថា ក្នុងការដល់នូវភាពជាមុខនៃវិមោក្ខ និងក្នុង

បច្ច័យ ដើម្បីចែកព្រះអរិយបុគ្គលនោះ ។ **ឥទំ យោគ វិបស្សនាញាណំ** ប្រែថា វិបស្សនាញាណនេះ ។ ពាក្យថា **នៃឥន្ទ្រិយ ៣** គឺនៃសទ្ធិន្ទ្រិយ សមាធិន្ទ្រិយ និង បញ្ញិន្ទ្រិយ ។ បទថា **អធិបតេយ្យវសេន** សេចក្តីថា ដោយអំណាចអធិបតីនៃ សម្បយុត្តធម៌ទាំងឡាយ ។ ពិតហើយ បុគ្គលចម្រើនអនិច្ចានុបស្សនាច្រើន សទ្ធិន្ទ្រិយ រមែងមានកម្លាំង បុគ្គលចម្រើនទុក្ខានុបស្សនាច្រើន សមាធិន្ទ្រិយរមែងមានកម្លាំង បុគ្គលចម្រើនអនត្តានុបស្សនាច្រើន បញ្ញិន្ទ្រិយរមែងមានកម្លាំង ព្រោះហេតុនោះ ឥន្ទ្រិយ ៣ នេះ ដែលដល់នូវការមានកម្លាំងច្រើនជាង ដោយអំណាចនៃអនុបស្សនា ទើបដល់នូវភាពជាវិមោក្ខមុខបាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ឈ្មោះ ថា ដល់នូវភាពជាវិមោក្ខមុខ ៣ បាន** ព្រោះប្រព្រឹត្តទៅ ដោយអំណាចនៃអនុបស្សនា ៣ លោកអាចារ្យកាលសម្តែងវិមោក្ខមុខមុន ព្រោះការសម្រេចវិមោក្ខ ក៏អាស្រ័យ វិមោក្ខមុខ ក្នុងកាលការសាកសួរទើបនូវខាងក្នុងថា ឯវិមោក្ខ ៣ អ្វីខ្លះ ឬវិមោក្ខ ៣ អ្វីខ្លះ ក្នុងពាក្យថា **វិមោក្ខមុខ ៣** នេះ ទើបពោលថា **ពិតហើយ អនុបស្សនា ៣ លោកហៅថា វិមោក្ខមុខ ៣** ។ ដូច្នេះហើយ កាលសម្តែងថា សេចក្តីនេះ រមែង ដឹងបានដោយព្រះបាលីនោះឯង ទើបពោលពាក្យថា **យថាហ** ជាដើម ។

បទថា **លោកនេយ្យានាយ** ប្រែថា ដើម្បីការចេញទៅអំពីលោក ឬសេចក្តីថា ដើម្បីការចេញទៅអំពីវដ្តទុក្ខរបស់សត្វលោក ។ បទថា **បរិច្ឆេទបរិវដុមតោ** សេចក្តីថា កំណត់ជុំវិញដោយអំណាចការកើត និងការរលត់ ។ បទថា **សមនុបស្សនតាយ** ក្ខាប់សេចក្តីថា រមែងប្រព្រឹត្តទៅដើម្បីពិចារណាឃើញដោយលំដាប់ៗ ដោយប្រពៃ នោះឯង ពិតហើយ អនិច្ចានុបស្សនា រមែងឃើញសង្ខារទាំងឡាយ កំណត់អំពីខាង ដើមដោយការកើតឡើង ខាងចុងដោយការរលត់ ។ ព្រោះសង្ខារទាំងនោះ ឈ្មោះថា មិនទៀង ព្រោះជាធម្មជាតិមានខាងដើម និងខាងចុង ។ ពាក្យថា **ក្នុងអនិមិត្តធាតុ**

បានដល់ ក្នុងអសង្ខតធាតុ ដែលបានឈ្មោះថា **អនិមិត្ត** ព្រោះវៀរចាកសង្ខារនិមិត្តទាំងពួង ។ ពាក្យថា **ដើម្បីការស្ទុះចូលទៅនៃចិត្ត** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការកំណត់ការស្ទុះចូលទៅនៃអធិចិត្តដោយប្រពៃ ដោយជាអនុលោមញ្ញាណជាដើម ។ ពាក្យថា **ក្នុងអប្បណិហិតធាតុ** គឺក្នុងធាតុដែលបាន ឈ្មោះថា **អប្បណិហិត** ព្រោះមិនមានបណិធិទាំងឡាយ មានរាគបណិធិជាដើម ។ ពាក្យថា **ក្នុងសុញ្ញតធាតុ** គឺក្នុងធាតុដែលបានឈ្មោះថា **សុញ្ញត** ព្រោះសោះសូន្យចាកតួខ្លួន ។

ពាក្យថា **គតិ** សេចក្តីថា ការកើតឡើង ។ចិត្តដែលសង្វេគដោយការជាក់ច្បាស់នៃសភាវៈរបស់សង្ខារទាំងឡាយ រមែងឈ្មោះថា ជាធម្មជាតិត្រូវដុតកម្តៅ ក្នុងសម្មាបដិបត្តិ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **មនោសមុត្តេជនតាយ ដើម្បីដុតកម្តៅចិត្ត** បានដល់ **ដើម្បីញ៉ាំងសង្វេគនៃចិត្ត** ។ អត្តាដែលជាម្ចាស់នៃវត្ថុដែលតែងសន្មតថា អត្តនិយ ( របស់នៃខ្លួន ) ដោយមមង្ការ រមែងត្រូវប្រកាន់មាំមុនបន្តអំពីនោះ ទើបប្រកាន់អត្តនិយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដើម្បីពិចារណាឃើញជាអនត្តា យ៉ាងនេះថា មិនមែនអញ មិនមែនរបស់អញ** ដូច្នេះ ។ ពាក្យថា **បីបទ** អាចារ្យទាំងឡាយ រមែងពោលថា បានដល់បទថា **បរិច្ឆេទបរិវដុម** ( កំណត់ដោយជុំវិញ ) បទថា **មនោសមុត្តេជន** ( ការកម្តៅចិត្ត ) និងបទថា **សមនុបស្សន** ( ការពិចារណាឃើញ ) ចំណែកពាក្យទាំង ៣ មានពាក្យថា **សព្វសង្ខារេ** ជាដើម គប្បីជ្រាបថា ឈ្មោះថា បទទាំង ៣ ។ ពាក្យថា **ព្រោះហេតុនោះឯង** សេចក្តីថា ព្រោះបទទាំង ៣ នោះលោកពោលទុកដោយអំណាចអនិច្ចា-នុបស្សនាជាដើមនោះឯង ។ ពាក្យថា **ក្នុងពេលវិសជ្ជនាបញ្ហា** សេចក្តីថា ក្នុងកាលវិសជ្ជនាបញ្ហាថា កាលភិក្ខុធ្វើមនសិការដោយរបស់មិនទៀង សង្ខារទាំងឡាយ រមែងប្រាកដដូចម្តេច ដូច្នេះ ។

លោកអាចារ្យកាលសម្ដែងវិមោក្ខមុខជាដើម យ៉ាងនេះហើយ ឥឡូវនេះ បំណងសម្ដែងវិមោក្ខទាំងឡាយ ទើបពោលពាក្យជាដើមថា **កតមេ បន** ដូច្នេះ ពាក្យថា **ភិក្ខុធ្វើមនសិការទៅដោយភាពជារបស់មិនទៀង** គឺប្រកបរឿយៗ នូវអនិច្ចានុបស្សនា ។ ពាក្យថា **ជាបុគ្គលច្រើនដោយអធិមោក្ខ** គឺជាអ្នកច្រើនដោយសទ្ធិន្ទ្រិយ ។ ពោលដោយពិសេស អនិច្ចានុបស្សនារបស់ភិក្ខុណា ជាធម្មជាតិរឹងមាំ ក្លាហាន សទ្ធិន្ទ្រិយរបស់ភិក្ខុនោះ រមែងមានប្រមាណក្រៃលែង ។ ព្រោះកាលលោកបដិបត្តិដោយត្រឹមតែមានសទ្ធាអំពីដើមថា **សង្ខារទាំងឡាយមិនទៀង** ដូច្នេះ ឃើញដោយប្រចក្សយ៉ាងកំពូលនូវសង្ខារទាំងនោះ សូម្បីក្នុងវត្ថុ មានកែវ និងមាសជាដើម ក៏ជារបស់មិនទៀងដូចក្នុងស្លឹកឫរបស់ដើមឈើជាដើម ដោយវិបស្សនាថ្នាក់ឧក្រិដ្ឋ សទ្ធាក្នុងព្រះសាស្ដាថា **ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាព្រះសម្មាសម្ពុទ្ធហ្ន៎** ដូច្នេះ រមែងប្រព្រឹត្តទៅដ៏មានកម្លាំង ព្រោះហេតុនោះ ទើបលោកជាអ្នកច្រើនដោយអធិមោក្ខ និងជាអ្នកមានសទ្ធាមានប្រមាណក្រៃលែង ។ វុដ្ឋាន ( ការចេញចាកសង្ខារប្បវត្ត ) ដោយអាការជារបស់មិនទៀង រមែងមានព្រោះលោកជាបុគ្គលច្រើនទៅដោយអនិច្ចានុបស្សនា ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីពោលថា **លោករមែងបានចំពោះនូវអនិមិត្តវិមោក្ខ** ។ ពាក្យថា **ជាបុគ្គលច្រើនដោយបស្សទ្ធិ** សេចក្ដីថា ប្រកបរឿយៗ នូវទុក្ខានុបស្សនា បង្អោនចិត្តទៅកាន់ព្រះនិព្វាន ជាធម៌ស្ងប់ ប្រណីតជាសុខ ដោយអំណាចការធ្វើមនសិការថា **សង្ខារទាំងឡាយជាទុក្ខ និរោធជាសុខ ព្រោះជាបដិបក្ខចំពោះសង្ខារនោះ** ដូច្នេះ រមែងជាអ្នកច្រើនទៅដោយបស្សទ្ធិ ព្រោះប្រកបដោយបីតិ និងបាមោជ្ជរឿយៗ ។ តអំពីនោះ ការជួបអប្បណិហិតវិមោក្ខ ក៏រមែងសម្រេច ព្រោះរាគបណិធិនៅឆ្ងាយ ព្រោះការបានសមាធិន្ទ្រិយដែលមានប្រមាណក្រៃលែង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មនសិការទៅជាទុក្ខ ជាអ្នកច្រើនទៅដោយ**

បស្សទ្ធិ រមែងបានចំពោះនូវអប្បណិហិតវិមោក្ខ ។ ពាក្យថា **ជាអ្នកច្រើនដោយវេទ** ( គឺការដឹង ) សេចក្ដីថា កាលប្រកបរឿយៗ នូវអត្តានុបស្សនា រមែងជាអ្នកច្រើនដោយញាណ ព្រោះជាបុគ្គលមានញាណល្អិតជាវិស័យ ដោយអត្តសុញ្ញតា ។តអំពីនោះការជួបសុញ្ញតវិមោក្ខ ក៏រមែងសម្រេច ព្រោះមោហៈនៅឆ្ងាយ ដោយការបានបញ្ញិន្ទ្រិយដែលមានប្រមាណក្រៃលែង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មនសិការជាអនត្តា ជាអ្នកច្រើនដោយវេទ រមែងបានចំពោះនូវសុញ្ញតវិមោក្ខ** ដូច្នេះ ។

ភិក្ខុណា កំណត់សង្ខារទាំងឡាយ ដោយអំណាចនិមិត្តនៃអនិច្ចានុបស្សនា ប្រកបរឿយៗ នូវវិបស្សនា បង្អោនចិត្តទៅដោយអាការមិនមាននិមិត្តថា សង្ខារនិមិត្តនេះ មិនមានដោយប្រការទាំងពួង ក្នុងធម្មជាតិណា ធម្មជាតិនោះ **ជានិព្វាន មិនមាននិមិត្ត** ផ្សារភ្ជាប់ទៅជាមួយមគ្គ ដែលជាវុដ្ឋានគាមិនី ។ មគ្គរបស់ភិក្ខុនោះ លោកពោលថា រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយមិនមាននិមិត្ត ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **អរិយមគ្គ ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ដោយអាការមិនមាននិមិត្ត** ដូច្នេះ ។ អាការដែលមិនមាននិមិត្តនៃព្រះនិព្វាននេះ មិនមែនមគ្គធ្វើឡើង មិនមែនវិបស្សនាធ្វើឡើង ដោយពិតនោះ សម្រេចហើយដោយសភាវៈ ។ លោកអាចារ្យកាលសម្តែងថា មគ្គ លោកហៅថា និមិត្ត ព្រោះមាននិព្វាននោះជាអារម្មណ៍ ទើបពោលថា **មគ្គ** ឈ្មោះថា **អនិមិត្ត ព្រោះកើតឡើងដោយធាតុដែលមិនមាននិមិត្ត** ដូច្នេះ គប្បីប្រកបសេចក្ដី ដោយពាក្យថា **ភិក្ខុណា បង្អោនចិត្តទៅកាន់អប្បណិហិត ដោយការធ្វើបណិធិឲ្យឆ្ងាយ ដោយអំណាចទុក្ខានុបស្សនា** ដូច្នេះជាដើម និងដោយពាក្យថា **ភិក្ខុណា បង្អោនចិត្តទៅកាន់សុញ្ញត ដោយធ្វើការចូលទៅ បាននូវអត្តាឲ្យឆ្ងាយ ដោយអំណាចអត្តានុបស្សនា** ដូច្នេះជាដើម ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយន័យនេះឯង** ដូច្នេះ ។

លោកអាចារ្យពោលពាក្យថា **យំ បន** ជាដើម សំដៅដល់ការចោទសួរថា បើអរិយមគ្គបានឈ្មោះថា វិមោក្ខទាំង ៣ យ៉ាង កាលបើយ៉ាងនោះ ព្រោះហេតុអ្វី **ទើបក្នុងព្រះអភិធម្ម** មានតែវិមោក្ខ ២ ប៉ុណ្ណោះ ។ ក្នុងបណ្តាពាក្យទាំងនោះ បទថា **តំ យោគ អភិធម្មេ វិមោក្ខ ទ្វយវចនំ** ប្រែថា ការពោលវិមោក្ខ ២ យ៉ាង ក្នុងព្រះអភិធម្មនោះ ពាក្យថា **សំដៅដល់ទីមកនៃវិបស្សនា ដោយនិប្បរិយាយ** សេចក្តីថា លោកពោលទីមករបស់ឈ្មោះមគ្គដោយត្រង់នោះឯង គឺដោយវិបស្សនា ។ ព្រោះហេតុអ្វី ? ព្រោះអនិមិត្តវិបស្សនាតាំងនៅក្នុងឋានៈដែលជាទីមក រមែងមិនអាចឲ្យឈ្មោះដល់មគ្គរបស់ខ្លួនបាន ។ **ក្នុងព្រះសូត្រ** ព្រះមានព្រះភាគត្រាស់អនិមិត្តវិបស្សនាទុកថា **អ្នកចូរចម្រើនអនិមិត្តវិបស្សនា លះមានានុស័យ** ដូច្នេះក៏ពិត សូម្បីយ៉ាងនោះ អនិមិត្តវិបស្សនានោះ សូម្បីបើកនិច្ចនិមិត្ត ធុវនិមិត្ត អត្តនិមិត្ត ខ្លួនឯងក៏នៅត្រាច់ទៅក្នុងនិមិត្តធម៌ទាំងឡាយនោះឯង ព្រោះហេតុនោះ ទើបជាធម្មជាតិមាននិមិត្តនោះឯង ដូច្នេះ ។ ប្រការមួយទៀត ធម្មតាព្រះអភិធម្ម ជាបរមត្ថទេសនា ឯមគ្គដែលមិនមាននិមិត្ត ពោលដោយបរមត្ថ នៅមានការខ្វះហេតុនោះឯង ។ លោកពោល **អនិមិត្តវិមោក្ខ** ដោយអំណាចអនិច្ចានុបស្សនា ។ និងក្នុងអនិមិត្តវិមោក្ខនោះ សទ្ធិន្ទ្រិយមានប្រមាណក្រៃលែង សទ្ធិន្ទ្រិយនោះសូម្បីមិនបានជាអង្គមួយក្នុងអរិយមគ្គ ក៏មិនអាចឲ្យឈ្មោះដល់មគ្គរបស់ខ្លួនបាន ព្រោះមិនមែនជាអង្គរបស់មគ្គ ។ ក្នុងបណ្តាវិមោក្ខក្រៅអំពីនេះ **អប្បណិហិតវិមោក្ខ** មានដោយអំណាចទុក្ខានុបស្សនា **សុញ្ញតវិមោក្ខ** មានដោយអំណាចអនត្តានុបស្សនា ។

អាចារ្យពួកខ្លះរមែងពោលថា ក្នុងបណ្តាវិមោក្ខទាំង ២ នោះ សមាធិន្ទ្រិយរមែងមានប្រមាណក្រៃលែង ដោយអប្បណិហិតវិមោក្ខ បញ្ញិន្ទ្រិយរមែងមានប្រមាណក្រៃលែង ដោយសុញ្ញតវិមោក្ខ ព្រោះហេតុនោះ ទើបឥន្ទ្រិយទាំងនោះអាចឲ្យឈ្មោះ

ដល់មគ្គរបស់ខ្លួនបាន ព្រោះជាអង្គនៃអរិយមគ្គ មិនជាអនិមិត្តមគ្គ ព្រោះមិនមានអង្គនោះ ។ ចំណែកអាចារ្យពួកណារមែងពោលថា **អនិមិត្តមគ្គ** សូម្បីកាលមិនបានឈ្មោះដោយទីមក ក៏រមែងបានឈ្មោះដោយគុណរបស់ខ្លួន និងដោយអារម្មណ៍ តាមមតិរបស់អាចារ្យទាំងនោះ សូម្បីអប្បណិហិតមគ្គ និងសុញ្ញតមគ្គ ក៏គប្បីបានឈ្មោះដោយគុណរបស់ខ្លួននោះឯង និងដោយអារម្មណ៍នោះឯង ដូច្នេះឬ ? ពាក្យនោះមិនត្រឹមត្រូវ ។ ព្រោះហេតុអ្វី ? ព្រោះមគ្គរមែងបានឈ្មោះដោយហេតុ ២ យ៉ាង គឺដោយកិច្ចរបស់ខ្លួន និងដោយសត្រូវ អធិប្បាយថា ដោយសភាវៈ និងដោយបដិបក្ខ ។ ពិតហើយ **អប្បណិហិតមគ្គ** រួចផុតហើយអំពីបណិធិទាំងឡាយ មានរាគបណិធិជាដើម **សុញ្ញតមគ្គ** ក៏សោះសូន្យអំពីកិលេសទាំងឡាយ មានរាគៈជាដើមនោះឯង ព្រោះហេតុនោះ ទើបមគ្គទាំងនោះបានឈ្មោះដោយកិច្ចរបស់ខ្លួន ។ ម្យ៉ាងទៀត **អប្បណិហិតមគ្គ** ជាបដិបក្ខចំពោះបណិធិ **សុញ្ញតមគ្គ** ក៏ជាបដិបក្ខចំពោះអត្តាភិនិវេស ( ការប្រកាន់មាំដោយអត្តា ) ព្រោះហេតុនោះ ទើបមគ្គទាំងនោះបានឈ្មោះដោយសត្រូវ ម្យ៉ាងទៀត **អនិមិត្តមគ្គ** ក៏រមែងបានឈ្មោះដោយកិច្ចរបស់ខ្លួននោះឯង ព្រោះការមិនមាននៃនិមិត្តមានរាគៈជាដើម ឬនិមិត្ត មាននិមិត្ត ថាទៀងជាដើម មិនបានឈ្មោះដោយសត្រូវឡើយ ។ ព្រោះថា អនិមិត្តមគ្គនោះ ជាបដិបក្ខចំពោះអនិច្ចានុបស្សនា ដែលមានសង្ខារនិមិត្តជាអារម្មណ៍ក៏មិនមាន ម្យ៉ាងទៀត អនិច្ចានុបស្សនានោះ ក៏តាំងនៅក្នុងអនុលោមដល់អនិមិត្តមគ្គនោះ ព្រោះហេតុនោះ ទើបអនិមិត្តមគ្គមិនបានដោយបរិយាយនៃព្រះអភិធម្ម ដោយប្រការទាំងពួង ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **វិមោក្ខ ២ នោះ លោកពោលសំដៅដល់ទីមកនៃវិបស្សនា ដោយនិប្បរិយាយ ។**

លោកលើកវិមោក្ខទាំង ៣ ទុកក្នុងទីនេះ ព្រោះធ្វើអធិប្បាយថា ព្រោះអនិមិត្តមគ្គរមែងបានដោយបរិយាយនៃព្រះសូត្រ ។ ព្រោះថា វុដ្ឋានគាមិនីវិបស្សនាពិចារណា

មគ្គណាមួយ រមែងដល់នូវការចេញទៅ តាំងនៅក្នុងឋានៈជាទីមក ដោយអំណាចនៃមគ្គនោះៗ រមែងឲ្យឈ្មោះដល់មគ្គរបស់ខ្លួន ក្នុងបណ្តាមគ្គទាំងនោះ មគ្គរបស់ព្រះយោគាវចរ ដែលចេញដោយភាពជារបស់មិនទៀង ជាអនិមិត្តមគ្គ មគ្គរបស់ព្រះយោគាវចរ ដែលចេញដោយភាពជាទុក្ខ ជាអប្បណិហិតមគ្គ មគ្គរបស់ព្រះយោគាវចរ ដែលចេញដោយភាពជាអនត្តា ជាសុញ្ញតមគ្គ ដូច្នោះ នេះទើបជាការពណ៌នាដោយព្រះសូត្រ ។ លោកអាចារ្យពោលពាក្យថា **ពិតហើយ វិបស្សនាញាណ** ដូច្នេះជាដើម ដើម្បីសម្តែងថា **ក្នុងគម្ពីរបដិសម្ភិទាមគ្គ** ការដោះសេចក្តីប្រកាន់និមិត្ត និងបណិធិឯណា ដែលព្រះធម្មសេនាបតីសារីបុត្រ បានអាស្រ័យសម្តែងលម្អិតអនុបស្សនាទាំង ៣ និងមគ្គ ដែលអនុលោមតាមអនុបស្សនា ទាំង ៣ នោះ ដោយអំណាចការមក ហើយអនុបស្សនាទាំង ៣ នោះ ជាអនុបស្សនា ហើយមគ្គដែលឈ្មោះថា សុញ្ញតវិមោក្ខជាដើម មិនមានពាក្យដែលគប្បីពោលក្នុងបរិយាយ នៃការដោះសេចក្តីប្រកាន់មាំក្នុងនិមិត្ត និងបណិធិនោះឡើយ ។ ក្តាប់សេចក្តីបាលីថា **វិបស្សនាញាណំ បដិសម្ភិទាមគ្គេ អប្បណិហិតោ វិមោក្ខោ តិ ច កិញ្ចាបិ វុត្តំ** ប្រែថា វិបស្សនាញាណ ព្រះធម្មសេនាបតីសារីបុត្រពោលទុក ក្នុងបដិសម្ភិទាមគ្គថា **ឈ្មោះអប្បណិហិតវិមោក្ខដោយពិត** ។ ពាក្យថា **អនិច្ចានុបស្សនា** បានដល់ ញាណដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាឃើញថា **សង្ខារទាំងឡាយមិនទៀង** ដូច្នេះ ។ ពាក្យថា **ដោះការប្រកាន់មាំ ដោយជារបស់ទៀង** សេចក្តីថា ដោះដោយអំណាចការទម្លាយការប្រកាន់ខុស ដែលប្រព្រឹត្តទៅ ដោយអាការថា ទៀង ថា **សង្ខារទាំងឡាយទៀង** ដូច្នេះ ចំណែកមគ្គញ្ញាណ ដែលអនុលោមតាមអនុបស្សនាញាណនោះ រមែងដោះដោយអំណាចកាត់បានជាសមុច្ឆេទ ។ បទថា **ឥតិ** សេចក្តីប៉ុនគ្នានឹង **តស្មា** ប្រែថា ព្រោះហេតុនោះ ។ ឈ្មោះថា **សុញ្ញតវិមោក្ខ** ព្រោះទទេ និងព្រោះការរួចផុត ចាកការ

ប្រកាន់មាំដោយការៈជារបស់មិនទៀង សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

បទថា **តំ យោគ តិវិធំ វិបស្សនាញាណំ** ប្រែថា វិបស្សនាញាណទាំង ៣ យ៉ាងនោះ ។ ក្នុងវិបស្សនាញាណទាំង ៣ យ៉ាងនោះ ដើម្បីសម្ដែងវិបស្សនាញាណ ដែលមានការបានឈ្មោះដោយបរិយាយ និងវិបស្សនាញាណដែលមានការបាន ឈ្មោះដោយនិប្បរិយាយ ទើបលោកអាចារ្យពោលពាក្យថា ( ព្រោះលះមិនទាន់បាន ) នូវ **សង្ខារនិមិត្ត** ដូច្នេះជាដើម ។ អធិប្បាយថា **មិនជាអនិមិត្តដោយនិប្បរិយាយឡើយ** ត្រឹមតែដោយបរិយាយ ។ បទថា **តស្មា យោគ និប្បរិយាយកថា ភាវតោ** ប្រែថា ព្រោះជាការពោលដោយនិប្បរិយាយនោះ ។ អធិប្បាយថា ក្នុងព្រះអភិធម្ម ត្រាស់ទុក **វិមោក្ខ ២ ប៉ុណ្ណោះ** ។ បទថា **ឯត្ថ** សេចក្ដីប៉ុនគ្នានឹង **ឯតស្មឹ យោគ វិបស្សនាធិការេ** ប្រែថា ក្នុងវិបស្សនាធិការនេះ ។ ម្យ៉ាងទៀត សេចក្ដីប៉ុនគ្នានឹង **ឯតស្មឹ យោគ តិវិធ វិមោក្ខមុខភាវំ អាបជ្ជិត្វា តិ ឧទ្ទេសវចនេ** ប្រែថា ក្នុងពាក្យឧទ្ទេសនេះ ពាក្យថា ការដល់មុខនៃវិមោក្ខទាំង ៣ យ៉ាង ដូច្នេះ ។

ពីរបទថា **តេសំ វិភាគាយ** សេចក្ដីថា ដើម្បីការៈដែលបានចែកព្រះអរិយបុគ្គល ៧ តាមដែលពោលហើយនោះ មានសទ្ធានុសារីជាដើម ។

ពាក្យថា **រមែងបានចំពោះនូវសទ្ធិន្ទ្រិយ** សេចក្ដីថា រមែងបានចំពោះសទ្ធិន្ទ្រិយ មានប្រមាណក្រៃលែងដែលជាហេតុនៃសទ្ធានុសារីជាដើម ហេតុនៃបុគ្គលច្រើនទៅដោយអធិមោក្ខ និងនៃបុគ្គលមានសទ្ធិន្ទ្រិយ មានប្រមាណក្រៃលែង ខ្ញុំពោលទុកខាងដើមនោះឯង ។ ម្យ៉ាងទៀត សេចក្ដីសង្ខេបក្នុងអធិការនេះ មាន ដូច្នេះ

ព្រោះការកំណត់អាការមិនទៀងជាឧបនិស្ស័យដល់ការដឹងក្រៃលែងដោយសទ្ធា សទ្ធាក្នុងមគ្គដែលប្រព្រឹត្តតាមសង្ខារុបេក្ខាញាណនោះ ទើបជាធម្មជាតិរឹងមាំក្រៃលែង ដោយហេតុនោះ ទើបព្រះអរិយបុគ្គលទី ៨ ឈ្មោះថា **សទ្ធានុសារី** ។ ពាក្យថា

**ក្នុងឋានៈ ៧ ដ៏សេស** បានដល់ ក្នុងឋានៈ ៧ តាំងអំពីផលទី ១ ( សោតាបត្តិផល ) រហូតដល់អគ្គផល ( អរហត្តផល ) ។ មានពាក្យសួរ ជ្រៀតចូលមកថា ព្រោះហេតុអ្វី ទើបលោកអាចារ្យពោលថា **ក្នុងឋានៈ ៧** ព្រះអរិយបុគ្គលក៏ជាសទ្ធាវិមុត្តិក្នុងឋានៈ ៦ ដ៏សេស មិនមែនឬ បើព្រះអរិយបុគ្គល នេះជាអ្នកបានអរូបជ្ឈានក្នុងអគ្គផល ក៏ជាឧភតោភាគវិមុត្តិ មិនមែនជាបុគ្គលបានអរូបជ្ឈាន ក៏ជាបញ្ញាវិមុត្តិ មិនមែនជា សទ្ធាវិមុត្តិឡើយ ។ ពិតហើយ រមែងដឹងសទ្ធាវិមុត្តិជាសេក្ខបុគ្គល មិនមែនជាអសេក្ខ បុគ្គលឡើយ ព្រោះក្នុងអភិធម្ម បានត្រាស់ការអស់ទៅនៃអាសវៈខ្លះទុកថា

បុគ្គលជា **សទ្ធាវិមុត្តិ** ដូចម្តេច ? បុគ្គលពួកខ្លះក្នុងលោកនេះ រមែងដឹងច្បាស់ តាមសេចក្តីពិតថា **នេះទុក្ខ** រមែងដឹងច្បាស់តាមសេចក្តីពិតថា **នេះជាហេតុកើតទុក្ខ** រមែងដឹងច្បាស់តាមសេចក្តីពិតថា **នេះការរលត់ទុក្ខ** រមែងដឹងច្បាស់តាមសេចក្តីពិត ថា **នេះផ្លូវបដិបត្តិឲ្យដល់ការរំលត់ទុក្ខ** ។ ម្យ៉ាងទៀត ធម៌ទាំងឡាយ ដែលព្រះតថាគត ប្រកាសហើយ ដែលបុគ្គលនោះឃើញច្បាស់ដោយបញ្ញា ប្រព្រឹត្តទៅដោយល្អដោយ បញ្ញា ម្យ៉ាងទៀត អាសវៈខ្លះរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញា តែមិនមែនដូចបុគ្គលដែលជាទិដ្ឋិប្បត្តឃើញ ។ បុគ្គលនេះហៅថា បុគ្គលជាសទ្ធាវិមុត្តិ ដូច្នេះ ។ និងព្រោះក្នុងអដ្ឋកថាពោលទុកថា **ធុរៈ ២ អភិនិវេស ២** ដូច្នេះ សទ្ធាវិមុត្តិ ទើបមិនមានដល់ព្រះអរហន្ត មិនមែនឬ ? ឆ្លើយថា សេចក្តីនេះ ដោយនិប្បរិយាយ ។ ឯព្រះអភិធម្មជានិប្បរិយាយកថា តែក្នុងទីនេះ លោកពោលទុកយ៉ាងនេះដោយបរិយាយ បើព្រះអរហន្តជាសទ្ធាវិមុត្តិដោយបរិយាយសោត បរិយាយនោះដូចម្តេច ? និងជាការ អនុលោមតាមសទ្ធាវិមុត្តិ ។ ព្រោះថា ព្រះអរិយបុគ្គលណា ជាសទ្ធាវិមុត្តិក្នុងខណៈ នៃអគ្គមគ្គ ព្រះអរិយបុគ្គលនោះក៏ជាសទ្ធាវិមុត្តិ ព្រោះជាអ្នកអនុលោមតាមព្រះអរិយ បុគ្គលក្នុងខណៈនៃមគ្គនោះ សូម្បីក្នុងខណៈនៃអគ្គផល ព្រោះហេតុនោះ **ក្នុងបដិ-**

**សម្មាទិដ្ឋិ**មគ្គ ព្រះធម្មសេនាបតីសារីបុត្រ បានពោលទុកដោយបរិយាយ ព្រោះហេតុនោះ ក្នុងទីនេះ លោកអាចារ្យក៏បានពោលទុកយ៉ាងនោះដូចគ្នា ។ ប្រការមួយទៀត ព្រះអរហន្ត ឈ្មោះថា **ជាសទ្ធាវិមុត្តិ** ព្រោះជាបុគ្គលដូចគ្នានឹងសទ្ធាវិមុត្តិ ។ ក្នុងសេចក្ដីនេះ ការដូចគ្នាដូចម្ដេច ? ការអស់កិលេសរបស់សេក្ខបុគ្គលដែលជាសទ្ធាវិមុត្តិ ក៏ដូចគ្នានឹងការកាត់ដើមចេក ដោយដាវដែលរិល ព្រោះមានព្រះបាលីថា **តែមិនមែនដូចបុគ្គលដែលជាទិដ្ឋិប្បត្តឡើយ** សេចក្ដីនេះយ៉ាងណា សូម្បីការអស់កិលេសរបស់ព្រះអរហន្ត ដែលអនុលោមតាមសេក្ខបុគ្គលនោះ ក៏ដូច្នោះ ព្រោះហេតុនោះ ទើបក្នុងទីនេះមានការដូចគ្នា ដូច្នេះ សួរថា ឯការផ្សេងគ្នាក្នុងការលះកិលេសរបស់សេក្ខបុគ្គល និងព្រះអរហន្តទាំងនោះ មានឬ ? ឆ្លើយថា មិនមាន ។ សួរថា បើដូច្នោះ ព្រោះហេតុអ្វី ព្រះអរិយបុគ្គល ដែលជាសទ្ធាវិមុត្តិ ទើបមិនដល់ព្រះអរិយបុគ្គលដែលជាទិដ្ឋិប្បត្តទៅវិញ ? ឆ្លើយថា ព្រោះការផ្សេងគ្នានៃឋានៈដែលជាទីមក ។ ព្រោះថា ព្រះអរិយបុគ្គលកាលសង្កត់កិលេសទាំងឡាយ ព្រោះការមកដល់មិនលំបាក ដោយសេចក្ដីបន្តិចបន្តួច រមែងអាចសង្កត់បាន ព្រះអរិយបុគ្គល ដែលជាសទ្ធាវិមុត្តិ រមែងអាចសង្កត់បាន ដោយការលំបាក ។ ប្រការមួយទៀត ការផ្សេងគ្នារបស់សេក្ខបុគ្គល និងព្រះអរហន្តទាំងនោះ សូម្បីដោយបញ្ញា ។ អាចារ្យទាំងឡាយ រមែងពោលថា ការផ្សេងគ្នានោះរមែងបានតាមការកំណត់ទុក ។ ព្រោះធ្វើអធិប្បាយយ៉ាងនេះ សូម្បីកាលមានការស្មើគ្នានៃឥន្ទ្រិយក្នុងមគ្គទី ១ ជាដើម សូម្បីការពោលឥន្ទ្រិយ មានសទ្ធាជាដើម ជាធម៌រឹងមាំ ក៏រមែងបានសម្រេចប្រយោជន៍ដោយល្អ ។

បទថា *សោ យោគ ទុក្ខតោ វុដ្ឋិតោ* ប្រែថា បុគ្គលដែលចេញដោយអាការជាទុក្ខនោះ ។ បទថា *សព្វត្ថ* សេចក្ដីថា ក្នុងឋានៈទាំង ៨ ។ ព្រោះក្នុងអដ្ឋកថាបានកំណត់ទុកថា **ធុរៈ ២ យ៉ាង** ដូច្នេះ ក្នុងខណៈនៃមគ្គទី ១ បុគ្គលគួរជាសទ្ធានុសារី

ឬជាធម្មានុសារី មិនមែនឬ ? ឆ្លើយថា ក្នុង ២ នេះ ជាសទ្ធានុសារីសមគួរហើយ ក៏ទេ សូម្បីព្រះអរហន្តជាកាយសក្ខី ក៏មិនមាន ។ ព្រោះ **ក្នុងអភិធម្ម** បានត្រាស់ការអស់អាសវៈចំណែកខ្លះទុកថា

បុគ្គលជា **កាយសក្ខី** ( នាមកាយ ) ដូចម្តេច ? បុគ្គលខ្លះក្នុងលោកនេះ ពាល់ត្រូវវិមោក្ខ ៨ ដោយកាយ សម្រេចឥរិយាបថ សម្រាកសម្រាន្តនៅ ហើយអាសវៈខ្លះរបស់បុគ្គលនោះ ក៏អស់ហើយ ព្រោះឃើញដោយបញ្ញា ។ បុគ្គលនោះ ហៅថា **កាយសក្ខីបុគ្គល** ( នាមកាយ ) ដូច្នេះ ។ ក៏រមែងដឹងកាយសក្ខីជាសេក្ខបុគ្គលនោះឯងឬ ? ឆ្លើយថា សេចក្តីនេះ ពិតដោយនិប្បរិយាយ តែក្នុងទីនេះ លោកពោលដោយបរិយាយ ។ សួរថា បរិយាយនោះដូចម្តេច ? ឆ្លើយថា គឺការៈដូចសក្ខី ។ ពិតហើយ ការកើតដែលបានសម្ផស្សអរូបសមាធិដ៏វិសេសក្រៃលែង ដោយសមាធិនៅក្នុងរូបជ្ឈានថ្នាក់ឧបចារៈ ព្រោះហេតុនោះ **ក្នុងបដិសម្ភិទាមគ្គ** ព្រះធម្មសេនាបតីសារីបុត្រ បានពោលដល់ព្រះអរហន្តថា ប្រៀបដូចកាយសក្ខី ដោយសម្លឹងដល់ការស្មើគ្នា ដោយការអស់ទៅនៃអាសវៈ ដោយការតាំងមាំនៃកាយសក្ខីនោះ ដោយការពាល់ត្រូវសមាធិដ៏វិសេសក្រៃលែង និងបុគ្គលដែលគប្បីពោលថា កាយសក្ខី ប្រៀបធៀបការអស់ទៅនៃអាសវៈចំណែកខ្លះ ទើបឈ្មោះថា **កាយសក្ខី** ព្រោះហេតុនោះ សូម្បីក្នុងទីនេះ លោកក៏កាន់យកន័យនោះឯង ពោលសូម្បីព្រះអរហន្តជាកាយសក្ខី ។ នេះជាការពិពណ៌នាន័យព្រះសូត្រ ដូច្នេះ ។ តែដោយនិប្បរិយាយ ព្រះអរិយបុគ្គលរមែងឈ្មោះថា ជាកាយសក្ខីក្នុងឋានៈទាំង ៦ តាំងអំពីផលទី ១ ទៅ ហើយកាយសក្ខីនោះឯង ជាអ្នកបានសមាបត្តិ ៨ មិនមែនជាសុខវិបស្សកៈដែលជាវិបស្សនាយានិក ដែលបានត្រឹមតែឧបចារជ្ឈាន ឬត្រឹមតែអ្នកបានរូបជ្ឈានឡើយ ។ ពាក្យថា **ជាអ្នកច្រើនដោយបស្សទ្ធិ** លោកពោលដល់សមាធិ ដោយលើកបស្សទ្ធិជាប្រធាន ព្រោះ

ហេតុនោះ ទើបលោកមានបំណងយកបុគ្គលដែលជាសមថយានិក ដែលបានសមាធិមានភាពពិសេសក្រៃលែងប៉ុណ្ណោះឯបុគ្គលដែលជាសមថយានិកនោះឯងជាកាយសក្ខី បានពោលទុក ហើយខាងដើម ។ ពាក្យថា **អរូបជ្ឈាន** បានដល់ អរូបជ្ឈាន ៤ យ៉ាង ។ ក្នុងអរូបជ្ឈាន ៤ យ៉ាងនោះ លោកអាចារ្យពោលថា **អរូបជ្ឈានប៉ុណ្ណោះ** ដើម្បីសម្តែងប្រការនេះថា បុគ្គលដែលបានអរូបជ្ឈានសូម្បីតែម្យ៉ាង ហើយសម្រេចអរហត្តផល ក៏ជាឧភតោភាគវិមុត្តិដូចគ្នា មិនមែន **ត្រូវបានអរូបជ្ឈានទាំង ៤ ឡើយ** ។ ដោយហេតុនោះ ទើបឧភតោភាគវិមុត្តិនេះមាន ៥ ប្រភេទ គឺចាត់តាមអរូបសមាបត្តិទាំង ៤ និងនិរោធសមាបត្តិ ។ សូម្បីក្នុងកាយសក្ខីក៏មានន័យនេះ ។ ព្រះអរិយបុគ្គលណារួចផុត ហើយអស់ភារៈទាំង ២ ដោយចំណែកទាំង ២ ហេតុនោះ ព្រះអរិយបុគ្គលនោះ ឈ្មោះថា **ឧភតោភាគវិមុត្តិ** ។

អត្ថទាំងឡាយដែលល្អិតក្រៃលែង និងជ្រាលជ្រៅ រមែងជាសភាវៈច្បាស់ប្រាកដដល់បុគ្គលដែលមានបញ្ញា ព្រោះហេតុនោះទើបលោកពោលបុគ្គលដែលធ្វើមនសិការជាអនត្តា ជាអ្នកច្រើនដោយវេទ ( ការដឹង ) និងពោលការបានចំពោះនូវបញ្ញិន្ទ្រិយ ។ បុគ្គល **ឈ្មោះថា ធម្មានុសារី** ព្រោះបញ្ញិន្ទ្រិយមានប្រមាណក្រៃលែង ។ បញ្ញាលោកមានបំណងយកថាជា **ធម៌** ក្នុងទីនេះ ដូចក្នុងព្រះបាលីជាដើម ថា **សច្ចំ ធម្មោ ធិតិ ចាគោ** សច្ចៈ ធម្មៈ ( បញ្ញា ) ធិតិ ចាគៈ ។

លោកអាចារ្យពោលព្រះអរិយបុគ្គល ជាសទ្ធាវិមុត្តិជាដើម ក្នុងទីនេះ ដោយអំណាចនៃព្រះបាលីណា ដើម្បីសម្តែងព្រះបាលីនោះ ទើបលោកអាចារ្យផ្តើមពាក្យថា **សេចក្តីនេះ សមដូចពាក្យដែលលោកពោលទុក** ដូច្នេះជាដើម ពាក្យនោះ ជាពាក្យយល់បានងាយនោះឯង ។

លោកពោលពាក្យដទៃទៀតទុក ជាគ្រឿងសាធក អត្ថមានជាដើមយ៉ាងនេះ

ថា ព្រោះសទ្ធិន្ទ្រិយ មានប្រមាណក្រៃលែង ទើបបុគ្គលជាសទ្ធាវិមុត្តិ ។ ដោយពាក្យថា **ភិក្ខុជឿរួចផុតបានហើយ** នេះ លោកអាចារ្យរមែងអធិប្បាយសទ្ធាវិមុត្តិជាសេក្ខបុគ្គលតែម្យ៉ាង ដោយការសម្តែងបុគ្គលដែលបង្អោនចិត្តជឿ ដោយប្រការទាំងពួងជាអ្នករួចផុតហើយ ដោយធម៌ត្រឹមតែសទ្ធា ។ ម្យ៉ាងទៀត ពាក្យថា **សទ្ធាវិមុត្តិ** ប្រែថា រួចផុតហើយដោយសទ្ធា ។

ពីរបទថា **ផុដ្ឋន្តំ សច្ឆិកតោ** សេចក្តីថា លំដាប់នៃឈានដែលខ្ញុំទពាល់ត្រូវ អធិប្បាយថា កាលជាលំដាប់នៃអរូបជ្ឈានទាំងឡាយដែលខ្ញុំទពាល់ត្រូវ ឈ្មោះថា **ផុដ្ឋន្តោ** ( លំដាប់នៃឈានដែលខ្ញុំទបានពាល់ត្រូវ ) បទនេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថអច្ចន្តសំយោគ មានអធិប្បាយថា ធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយឧបាយនៃការធ្វើឲ្យជាក់ច្បាស់ ក្នុងកាលដែលជាលំដាប់នៃឈាន ដែលខ្ញុំទបានពាល់ត្រូវនោះឯង ។ ម្យ៉ាងទៀត បទនេះជាភាវនបុំសកៈ ដូចជាពាក្យថា **ឯកមន្តំ** ។ បុគ្គលណា រួចផុតហើយ ដោយវិក្ខម្ភនវិមោក្ខខាងរូបកាយ និងខាងនាមកាយចំណែកខ្លះ ដោយអរូបជ្ឈាន វិមោក្ខ ពោល គឺនិរោធ រមែងត្រូវបុគ្គលនោះលើកឡើង ហាក់ដូចប្រកាសហើយ តែមិនបានធ្វើឲ្យជាក់ច្បាស់ដោយកាយឡើយ ម្យ៉ាងទៀត កាលបានធ្វើនិរោធឲ្យជាអារម្មណ៍ហើយ ញុំាងអាសវៈទាំងឡាយចំណែកខ្លះឲ្យអស់ទៅ វិមោក្ខនោះរមែងត្រូវបុគ្គលនោះ ធ្វើឲ្យជាក់ច្បាស់ ហើយនោះឯង ។ ព្រោះហេតុនោះ បុគ្គលនោះបានធ្វើឲ្យជាក់ច្បាស់នូវវិក្ខម្ភនវិមោក្ខ ដែលគប្បីធ្វើឲ្យជាក់ច្បាស់តាមដែលបានលើកឡើងហើយ ដោយនាមកាយ ព្រោះហេតុនោះ ទើបហៅថា **កាយសក្ខី** តែមិនមែនជាអ្នករួចផុតហើយ ព្រោះអាសវៈទាំងឡាយចំណែកខ្លះ មិនទាន់អស់ទៅនោះឡើយ ។

ពីរបទថា **ទិដ្ឋន្តំ បត្តោ** មានអធិប្បាយថា សម្រេចហើយក្នុងលំដាប់នៃសោតាបត្តិមគ្គញាណ ពោល គឺទស្សនៈ សេចក្តីពិត បុគ្គលឈ្មោះថា **ទិដ្ឋិប្បត្ត** តាំងអំពីផលទី

១ ទៅរហូតដល់អគ្គមគ្គ ( អរហត្តមគ្គ ) ។ម្យ៉ាងទៀត បាឋៈថា **ទិដ្ឋិតាបត្តោ** ដូច្នេះ មានសេចក្តីថា សម្រេចនិរោធដោយទិដ្ឋិ ពោល គឺឃើញសច្ចៈ ៤ ។ព្រះអរិយបុគ្គល ទាំង ៣ មានសទ្ធាវិមុត្តិជាដើមនេះ ពោលដោយបរមត្ថ មានញាណកិច្ចមិនទាន់ចប់ ព្រោះហេតុនោះ ដើម្បីសម្តែងន័យនោះ ទើបលោកអាចារ្យពោលថា **ភិក្ខុជឿ ទើប រួចផុត** ដូច្នេះជាដើម ។ពាក្យថា **ឈានសម្ផស្ស** បានដល់ ឈានសម្ផស្សដ៏វិសេស ក្រៃលែង ។ ដោយពាក្យនោះ ត្រូវបានលោកអាចារ្យសង្គ្រោះយកអរូបជ្ឈានសម្ផស្ស ។

ដោយពាក្យថា **ញាណថា សង្ខារទាំងឡាយជាទុក្ខ** នេះ លោកអាចារ្យពោល ដល់ការចាក់ធ្លុះទុក្ខសច្ច ដោយពាក្យថា **ញាណដែលដឹងថា និរោធជាសុខ** នេះ លោក អាចារ្យពោលដល់ការចាក់ធ្លុះនិរោធសច្ច ។និងដោយពាក្យទាំង ២នោះ លោកអាចារ្យ ពោលដល់ការចាក់ធ្លុះសមុទយសច្ច និងមគ្គសច្ច ព្រោះជាធម៌ ដែលមិនមានអ្វីខណ្ឌ ក្នុងរវាងចន្លោះ ។ ដោយពាក្យថា **រមែងត្រូវលោកដឹងហើយ** នេះ លោកអាចារ្យ ពោលដល់មគ្គកិច្ចទី ២ ។ ដោយពាក្យថា **រមែងត្រូវលោកឃើញហើយ** នេះ លោក អាចារ្យពោលដល់មគ្គកិច្ចទី ៣ ដោយពាក្យថា **រមែងត្រូវលោកជួបប្រទះហើយ** នេះ លោកអាចារ្យពោលដល់មគ្គកិច្ចទី ៤ ដោយពាក្យថា **ធ្វើឲ្យជាក់ច្បាស់ហើយ** នេះ លោកអាចារ្យពោលដល់ផលកិច្ចទី ១ ដោយពាក្យថា **ពាល់ត្រូវហើយ** នេះ លោក អាចារ្យពោលដល់ផលកិច្ចទាំង ២ ដ៏សេស លោកអាចារ្យទាំងឡាយរមែងពោលថា បទទាំងនេះ សម្តែងកិច្ចនៃមគ្គញាណ និងផលញាណរបស់ទិដ្ឋិប្បត្តបុគ្គល ដោយ ប្រការដូច្នេះ ។

បទថា **ឥតរេសុ យោគ សទ្ធានុសារីអាទិបទេសុ** ប្រែថា ក្នុងបទ មានបទ ថា **សទ្ធានុសារី** ជាដើមក្រៅអំពីនេះ ។ ពាក្យថា **ស្ទុះទៅតាមសទ្ធា** សេចក្តីថា ទៅតាមសទ្ធាដែលតាំងនៅក្នុងឋានៈ ដែលគួរមកដល់ ។ អធិប្បាយថា សទ្ធានោះ

បានជាធម្មជាតិរឹងមាំក្លាហានដោយប្រការណា រមែងញ៉ាំងសទ្ធាដែលគួរដល់ប្រការនោះៗ ឯង ឲ្យប្រព្រឹត្តទៅ សូម្បីក្នុងខណៈនៃមគ្គ ។ ពាក្យថា **ម្យ៉ាងទៀត ស្ទុះទៅតាមសទ្ធា** សេចក្ដីថា ស្ទុះទៅ គឺទៅ បានដល់ ប្រព្រឹត្តទៅសមគួរដល់ការចាក់ធ្លុះសច្ចៈដោយសទ្ធា ដែលជាហេតុ ។ ក្នុងអត្ថវិកប្បទាំង ២ លោកអាចារ្យរមែងអធិប្បាយដល់សទ្ធាជាធម្មជាតិមានប្រមាណក្រៃលែងនោះឯង សូម្បីក្នុងពាក្យថា **ធម្មានុសារី** នេះ ក៏មានន័យនេះដូចគ្នា ពាក្យថា **ឧភតោភាគវិមុត្ត** សេចក្ដីថា ព្រះអរិយបុគ្គលឈ្មោះថា **ឧភតោភាគវិមុត្ត** ព្រោះជាអ្នករួចផុតហើយអស់ ២ វារៈ ដោយចំណែកទាំង ២ អធិប្បាយថា រួចផុតហើយដោយអំណាចវិក្ខម្ភនវិមុត្តិ និងដោយអំណាចសមុច្ឆេទវិមុត្តិតាមរូបកាយ និងនាមកាយ គឺរួចផុតហើយ ដោយអរូបជ្ឈាន ផ្នែករូបកាយ និងផ្នែកនាមកាយចំណែកខ្លះ រួចផុតហើយដោយអរិយមគ្គខាងនាមកាយព្រោះហេតុនោះ ទើបឈ្មោះថា **ឧភតោភាគវិមុត្ត** ព្រោះរួចផុត អស់វារៈទាំង ២ ដោយចំណែកទាំង ២ ។ ពាក្យថា **ដឹងទូទៅ រួចផុតហើយ** សេចក្ដីថា ដឹង គឺចាក់ធ្លុះអរិយសច្ច ៤ ដោយប្រការ មានការកំណត់ដឹងជាដើម វៀរចាកការពោល់ត្រូវបឋមជ្ឈានរួចផុតហើយដោយវិសេស ព្រោះជាអ្នកមានកិច្ច ដែលសម្រេចហើយ ដោយការដល់នូវទីបំផុតនៃកិច្ចទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **រួចផុតហើយ** ។

ចំណែកកថាដោយសង្ខេប ដោយនិប្បរិយាយក្នុងអធិការនេះ មានដូច្នេះ

បុគ្គលណា មានវុដ្ឋានដោយអាការមិនទៀង បុគ្គលនោះជាអ្នកច្រើនដោយអធិមោក្ខ ឈ្មោះថា **ជាសទ្ធានុសារី** ក្នុងខណៈនៃមគ្គទី ១ ដោយសទ្ធិន្ទ្រិយជាធម្មជាតិរឹងមាំ **ជាសទ្ធាវិមុត្ត** ក្នុងឋានៈទាំង ៦ នាចំណែកកណ្ដាល ។ ឈ្មោះថា **បញ្ញាវិមុត្ត** ក្នុងខណៈនៃអគ្គផល ។ ទំនងដូចគ្នានោះដែរ បុគ្គលណា មានវុដ្ឋាន ដោយអាការជាទុក្ខ ព្រោះបុគ្គលនោះ ជាអ្នកច្រើនដោយបស្សទ្ធិ ទើបសមាធិន្ទ្រិយ មានប្រមាណ

ក្រៃលែង ព្រោះសទ្ធាដែលអាស្រ័យទុក្ខ ជាធម្មជាតិខ្លាំងក្លាក្រៃលែង និងព្រោះភាពពិតប្រាកដនៃធុរៈ ។ បុគ្គលនោះ **ជាសទ្ធានុសារីតែម្យ៉ាង** ក្នុងខណៈនៃមគ្គទី ១ ជា **សទ្ធាវិមុត្តិ** ក្នុងឋានៈទាំង ៦ ត្រង់កណ្ដាល និង **ជាបញ្ញាវិមុត្តិ** ក្នុងទីបំផុត ចំណែកបុគ្គលណា មានវុដ្ឋានដោយអាការជាអនត្តា បុគ្គលនោះ ជាអ្នកច្រើនដោយវេទ ជា **ធម្មានុសារី** ម្យ៉ាងទៀត ក្នុងខណៈនៃមគ្គទី ១ ដោយបញ្ញិន្ទ្រិយជាធម្មជាតិរឹងមាំ ជា **ទិដ្ឋិប្បត្ត** ក្នុងឋានៈទាំង ៦ នាចំណែកកណ្ដាល **ជាបញ្ញាវិមុត្តិតែម្យ៉ាង** ក្នុងទីបំផុត ។ ព្រះអរិយបុគ្គលទាំងនេះ មិនជាអ្នកបានវិមោក្ខ ៨ ក៏បានវិមោក្ខ ៨ គប្បី ជា **សទ្ធានុសារី ឬ ធម្មានុសារី** ក្នុងខណៈនៃមគ្គទី ១ ។ **ជាកាយសក្ខី** ក្នុងឋានៈទាំង ៦ ត្រង់កណ្ដាល **ជាឧភតោភាគវិមុត្តិ** ក្នុងទីបំផុត ដូច្នេះ ។

( ខណៈនេះកំពុងពណ៌នា ) សង្ខារុបេក្ខាញាណ

ឯសង្ខារុបេក្ខាញាណ ដែលលោកពោលថា ដល់នូវភាពជាវិមោក្ខមុខហើយ រមែងជាបច្ច័យដល់ការចែកព្រះអរិយបុគ្គល ៧ **នេះ** ។ ពាក្យថា **និងញាណ ២ ខាងដើម** អធិប្បាយថា ដូចគ្នានឹងមុញ្ចិតុកម្យតាញាណ និងបដិសង្ខានុបស្សនាញាណទាំង ២ ដោយអត្ថ ផ្សេងគ្នាដោយប្រភេទនៃអាការប្រព្រឹត្តទៅ ។ ដើម្បីញ៉ាំងអត្ថតាមដែលពោលហើយឲ្យសម្រេចដោយអដ្ឋកថា និងព្រះបាលី ទើបលោកអាចារ្យពោលថា **ដោយហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុក** ដូច្នេះ ។ មុញ្ចិតុកម្យតាញាណ និងញាណដែលធ្វើឧបាយនៃការរួចផុត ក៏ជាឈ្មោះរបស់សង្ខារុបេក្ខាញាណដូចគ្នា ព្រោះប្រព្រឹត្តទៅដោយភាពព្រងើយកន្តើយក្នុងសង្ខារទាំងឡាយនោះឯង ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា **សង្ខារុបេក្ខាញាណនេះតែមួយបានឈ្មោះ ៣** ដូច្នេះ ។ ដោយហេតុនោះ ទើបលោកអាចារ្យសម្ដែងថា វោហារថាសង្ខារុបេក្ខាមានប្រជុំនៃញាណ មានមុញ្ចិតុកម្យតាញាណជាដើមជាវិស័យ ។

ពាក្យថា **នូវឧប្បាទជាដើម** បានដល់ សង្ខារទាំងឡាយ ដែលលោកពោលទុកដោយអាស្រ័យដល់ឧប្បាទ និងបវត្តជាដើម ។ ពាក្យថា **ការប្រាថ្នានឹងលះបង់** បានដល់ការប្រាថ្នានឹងលែង ដោយការលះឆន្ទរាគៈ ដែលទាក់ទងក្នុងសង្ខារនោះ ។ បទថា **បដិសង្ខានំ** សេចក្ដីថា ការពិចារណារឿយៗ ។ ពាក្យថា **ដោះបានហើយ** សេចក្ដីថា លែងទៅបានហើយ ដោយអំណាចការលែងទៅ ដោយមិនសម្លឹង ព្រោះដល់នូវការមិនមានអាល័យ ។ បទថា **ក្នុងអវសាន** គឺក្នុងកាលខាងលើនៃការធ្វើយ៉ាងនោះ ។ លោកអាចារ្យពោលថា **ការព្រងើយកន្ដើយ ឈ្មោះថា សន្តិដ្ឋនា** ដូច្នេះ សំដៅដល់ការប្រព្រឹត្តទៅដោយអំណាចការបន្តគ្នានៃញាណ ព្រោះជាបុគ្គលព្រងើយជាកណ្ដាលក្នុងការគិតគូរអស់កាលដែលការស្ទុះទៅកាន់ព្រះនិព្វាន មិនទាន់សម្រេច ។ បទថា **ឯវំ** សេចក្ដីថា ដោយអាការដែលពោលទុកថា **មុញ្ចិតុកម្យតា ច សាសន្តិដ្ឋនា ច** ការប្រាថ្នានឹងលះបង់នោះផង ការព្រងើយផង ដូច្នេះ ដោយស្មើគ្នានៃអាការ គឺការព្រងើយ ។

ពាក្យថា **ធម៌ទាំងនេះ** បានដល់ ធម៌ គឺញាណទាំងនេះ ម្យ៉ាងទៀត ធម្មស័ព្ទក្នុងទីនេះ ជាបរិយាយនៃញាណ ព្រោះហេតុនោះ ទើបមានសេចក្ដីថា ញាណទាំងនេះ ។ ពាក្យថា **មានអត្ថដូចគ្នា** គឺមានសភាវៈដូចគ្នា ។

ឈ្មោះថា **ជាវុដ្ឋានគាមិនី** ព្រោះទៅកាន់ការចេញ ។ ពាក្យថា **របស់ញាណ ៣ មានសង្ខារុបេក្ខាញាណជាដើម** បានដល់ របស់ញាណ ៣ ដែលមានឈ្មោះថា សង្ខារុបេក្ខាញាណ អនុលោមញ្ញាណ និងគោត្រភូញាណ ។ លោកអាចារ្យពោលថា **ព្រោះដល់នូវឧត្តមភាព** ព្រោះតាំងនៅខាងលើនៃលោកិយញ្ញាណទាំងឡាយ ដោយអំណាចជាទីតាំងនៃការប្រព្រឹត្តទៅ ដោយអំណាចកិច្ច ។ ពាក្យថា **ជានិមិត្ត** គឺបាកខន្ធបញ្ចកៈដែលជាអារម្មណ៍នៃវិបស្សនា ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **បាកវត្ថុដែលកាន់យក** ។ ឯខន្ធបញ្ចកៈនោះ លោកហៅថា វត្ថុដែលកាន់យកដោយ

ការទាញយក ពោល គឺការធ្វើឲ្យជាអារម្មណ៍នៃវិបស្សនា ។ ម្យ៉ាងទៀត ខន្ធបញ្ចកៈនេះ សូម្បីទាក់ទងហើយ ដោយសន្តតិរបស់ខ្លួន លោកក៏ហៅថា **ខាងក្រៅ** ព្រោះជាការឃើញដោយជាចំណែកដទៃ ។ ពិតហើយ ខន្ធបញ្ចកៈនោះឯង លោកពោលទុកក្នុងទីនោះៗ ថា **និមិត្តទាំងពួងខាងក្រៅ** ។ ពាក្យថា **ចាកបវត្តខាងក្នុង** បានដល់ ចាកការប្រព្រឹត្តទៅនៃមិច្ឆាទិដ្ឋិជាដើមក្នុងសន្តាននៃខ្លួន និងចាកកងកិលេសដែលប្រព្រឹត្តទៅតាមការប្រព្រឹត្តទៅនៃមិច្ឆាទិដ្ឋិជាដើម ។ ឯបវត្ត ( គឺខន្ធ ) ខាងក្នុងនោះ លោកពោលយ៉ាងនោះ ព្រោះការប្រព្រឹត្តទៅនៃកិលេសក្នុងការបន្តរបស់ខ្លួន និងព្រោះភាវៈ គឺការប្រព្រឹត្តទៅនៃខន្ធ ដែលកម្ម និងកិលេសគ្រប់គ្រងដែលកើតឡើងកាលមិនទាន់មានមគ្គភាវនា ព្រោះមានការប្រព្រឹត្តទៅនៃកិលេសនោះជានិមិត្ត ។ ការចេញជាការមិនធ្វើឲ្យជាអារម្មណ៍របស់ធម៌ទាំងនោះ និងធ្វើឲ្យដល់នូវវិវត្តដែលមិនកើតតទៅជាធម្មតា ។ ឈ្មោះថា **បន្ត** ព្រោះកើតឡើងព្រមគ្នានៃមគ្គក្នុងលំដាប់របស់ខ្លួននោះឯង ។

បទថា **តត្រ** សេចក្តីប៉ុនគ្នានឹង **តស្មឹ** យោគ **អភិនិវិដ្ឋវត្ថុតោ វុដ្ឋហនតោតិ សាធ្វេបវចនេ** ប្រែថា ក្នុងពាក្យដែលពោលដោយបង្រួញថា ព្រោះចេញចាកវត្ថុ ដែលប្រកាន់មាំ ដូច្នេះនោះ ។ ពាក្យតទៅនេះជា **មាតិកា** គឺជាឧទ្ទេស ទាក់ទងជាមួយរូបអរូប ខន្ធ ៥ និងលក្ខណៈ ៣ ដែលជាខាងក្នុង និងខាងក្រៅ ។ ពីរបទថា **អជ្ឈត្តំ អភិនិវិសិត្វា** កាន់យកខាងក្នុង គឺផ្តើមធ្វើវិបស្សនាក្នុងខន្ធទាំងឡាយ ដែលទាក់ទងដោយសន្តតិរបស់ខ្លួន ។ ពីរបទថា **អជ្ឈត្តា វុដ្ឋាតិ** ចេញចាក ( សង្ខារទាំងឡាយ ) ខាងក្នុងនេះ លោកពោលដោយបរិយាយ ព្រោះវុដ្ឋានគាមិនីមានធម៌ខាងក្នុងជាអារម្មណ៍ តែមគ្គរមែងចេញដោយប្រការទាំងពួង ដោយនិប្បរិយាយ ។ សូម្បីក្នុងពាក្យថា **ចេញ** ( អំពីសង្ខារទាំងឡាយ ) **ខាងក្រៅ** ជាដើម ក៏មានន័យនេះ ។ បទថា **ឯកប្បហារេន** ប្រែថា ព្រមគ្នា ឯពាក្យនោះ បណ្ឌិតគប្បីជ្រាបទាក់ទងនឹងការប្រព្រឹត្តទៅនៃវុដ្ឋានគាមិនី

ដោយមិនចែកថា **វត្ថុណានីមួយមានការកើតឡើងជាធម្មតា ធម្មជាតិនោះ មានការរលត់ទៅវិញជាធម្មតា** ដូច្នេះ ព្រោះមិនបានធ្វើការចែកធម៌ខាងក្នុងជាដើម ។ អាចារ្យទាំងឡាយ រមែងពោលថា ញាណនេះ រមែងមានដល់បុគ្គលដែលមានញាណកំពូល ដែលបញ្ជូនញាណទៅតាមគន្លងព្រះធម្មទេសនាចំពោះព្រះភក្ត្រព្រះសាស្តា ។

**មគ្គវុដ្ឋានមិនមានដោយត្រឹមតែមើលសង្ខារខាងក្នុងសុទ្ធៗ ប៉ុណ្ណោះឡើយ** ព្រោះវត្ថុនៃមគ្គនោះជារឿងដែលគប្បីកំណត់ដឹង ការចេញ គឺមគ្គ ឬការចេញដោយមគ្គ ឈ្មោះ ថា **មគ្គវុដ្ឋាន** ។

ពាក្យថា **ធ្វើឲ្យជាគំនរដូចគ្នា** គឺកាន់យកនូវរូបទាំង ២ យ៉ាង គឺភូតរូប និងឧបាទាយរូប មានប្រភេទមិនមែនតិច ដោយប្រភេទមិនមានទីបំផុតនោះឯង រួមគ្នាថា **ឈ្មោះថា រូប ដោយអត្ថថា បែកធ្លាយ** ។ ការទាញវិបស្សនាក្នុងរូប រមែងមានដល់ព្រះយោគាវចរដែលជាវិបស្សនាយានិក ដោយច្រើន យ៉ាងណា ការទាញយកវិបស្សនា ក្នុងអរូបក៏មានដល់ព្រះយោគាវចរដែលជាសមថយានិកដោយច្រើន យ៉ាងនោះ ។ ការកំណត់នាមរូបដែលគប្បីធ្វើខាងដើមនៃវិបស្សនា គប្បីជ្រាបថា ឈ្មោះថា **ការទាញយក** ។ ព្រោះហេតុនោះ ការកំណត់រូបដំបូង ឈ្មោះថា **ការកាន់យកក្នុងរូប** ។ សូម្បីក្នុងពាក្យដ៏សេស ក៏មានន័យនេះ ។ ការកំណត់ការកើត និងការរលត់ថា **យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ** ធម៌ណានីមួយ មានការកើតឡើងជាធម្មតា ធម៌ទាំងអស់នោះ មានការរលត់ជាធម្មតា លោកសម្តែងថា ជាការកាន់យកដោយពិត សូម្បីយ៉ាងនោះ ព្រះយោគាវចរកំណត់រូបធម៌ អរូបធម៌តាមដែលប្រាកដហើយ ហើយបច្ច័យរបស់រូបធម៌ និងអរូបធម៌ទាំងនោះ ញ៉ាំងវិបស្សនាញាណឲ្យត្រាច់ទៅ ដោយសង្ខេបនោះឯង ជាបុគ្គលមានញាណដ៏កំពូល អន្ទុយនៅតាមប្រក្រតីចាក់ធ្លុះសច្ចៈ រួសរាន់នោះឯងតាមលំដាប់នៃញាណ ឈ្មោះថា ចេញចាកខន្ធទាំង ៥

ព្រមគ្នា ។ ព្រោះមិនមានការកំណត់ និងកំណត់ដឹងជាដើមនូវខន្ធទាំង ៥ ដោយលោកិយចិត្ត ១ ដួងប៉ុណ្ណោះ ដោយប្រការដទៃ ។ បុគ្គលណាម្នាក់ មិនអាចធ្វើធម៌ដែលមានការឃើញបាន និងធម៌ ដែលមានការប៉ះខ្ទប់ បានជាដើមឲ្យជាអារម្មណ៍ពួកដូចគ្នា ។ អាចារ្យទាំងឡាយរមែងពោលថា ឯធម្មជាតិណាមានការពោលត្រូវបានដោយញាណមួង ធម្មជាតិនោះគួរពោលត្រូវបានទៀតនោះឯង លោកពោលទុកទាក់ទងនឹងធម្មជាតិ ដូច្នោះ ។

ក្នុងអធិការនេះ ការកាន់យកមិនមែនហេតុសំខាន់ វុដ្ឋាននោះឯង ជាប្រមាណព្រោះហេតុនោះ ដើម្បីសម្ដែងថា ការបែកវិមោក្ខ និងព្រះអរិយបុគ្គលដែលបានពោលហើយខាងដើម ក៏រមែងមានដោយអំណាចនៃវុដ្ឋាន ទើបលោកអាចារ្យផ្ដើម ពាក្យថា **ឯត្ថ ច យោបិ** ជាដើម ប្រែថា ក្នុងបណ្ដាជនដែលចេញចាកការកាន់យកទាំងនេះសូម្បីជនណាមួយ ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ជនទាំង ៣** លោកអាចារ្យពោលទុកដោយកាន់យកការផ្សេងគ្នា ដែលបានដោយអំណាចការកាន់យកនោះឯងកាលមិនទាន់មានការផ្សេងគ្នា ដោយអំណាចវុដ្ឋាន ។

ពាក្យថា **ព្រមទាំងញាណមុន និងញាណក្រោយ** សេចក្ដីថា ព្រមជាមួយញាណមុន មានភយតុបដ្ឋានជាដើម និងញាណក្រោយ មានគោត្រភូញាណជាដើម បទថា **ឧទ្ទានំ** បានដល់ ឧទ្ទេស ។

ឧបមាទាំងនេះ **តាំងនៅក្នុងញាណណានីមួយ និងនាំមកក៏គួរ** ព្រោះបានរឿងនៃឧបមាដែលគួរដល់ឋានៈរបស់ញាណនោះៗ ។ ពាក្យថា **តែក្នុងទីនេះ** គឺក្នុងចំណែកនៃវុដ្ឋានគាមិនីវិបស្សនានេះ ។ បទថា **សព្វំ** សេចក្ដីថា ញាណទាំងពួង ឬកិច្ចនៃញាណទាំងពួង រមែងត្រូវប្រាកដ ព្រោះតាំងនៅក្នុងកណ្ដាល ធ្វើឲ្យជាក់ច្បាស់ ។ **លោកពោលទុក** ក្នុងវិសុទ្ធិកថា ។

បទថា **និលីយិត្វា** សេចក្តីថា ចូលទៅ ។ បទថា **បរិមំសិត្វា** សេចក្តីថា ពិចារណា ។ ពាក្យថា **មិនជួបវត្ថុដែលគួរកាន់យក** គឺមិនឃើញវត្ថុដែលគួរដល់ការកាន់យក បានដល់ វត្ថុដែលជាសារៈ គឺការទៀងជាដើម ។ អនុលោមញ្ញាណ ដូចមែកដែលត្រង់ដោយការសង្កត់យ៉ាងល្អនូវឧបក្កិលេស មានមាយាជាដើមដែលធ្វើការវៀចនៃចិត្ត ។ គោត្រភូញាណ ដូចការអើតមើលខាងលើ ព្រោះការសម្លឹងមើលព្រះនិព្វាន ។ មគ្គញ្ញាណ ដូចការហើរទៅក្នុងអាកាស ព្រោះតាំងនៅក្នុងនិព្វាន ដែលមិនមានទីតាំង ។

**គោត្រភូញាណ ឈ្មោះថា ឧបមាដូចការលោតពីទៅ** ព្រោះលែងសង្ខារទាំងពួង ទាញយកនិព្វាន ។ **មគ្គញ្ញាណ ឈ្មោះថា** ដូចការឈរនៃបុរសសម្លឹងមើលផ្លូវដែលទៅ ព្រោះឃើញអត្ថា ដោយអំណាចការចាក់ធ្លុះដោយអសម្មោហៈ លោកអាចារ្យពោលដល់ស្ថានទី ដែលមិនមានភ័យ ដែលមកដល់ហើយថា **ស្ថិតនៅក្នុងទីមិនមានភ័យ** មិនបានពោលដល់ការប្រព្រឹត្តទៅដល់ស្ថានទីមិនមានភ័យ ។

ការប្រកាន់ថា **អញ របស់អញ** ព្រោះមិនពិចារណាដឹងអត្តថា ខ្លួនជាដើម ដូចគ្នានឹងការដេកលក់ទៅ ។ លោកកាន់យកការពិចារណា ហើយព្រងើយដោយស័ព្ទថា **មុញ្ចិតុកម្យតា** នោះឯង ។ កិរិយាទាំង ៣ ( គឺការត្រូវការដោះការពិចារណា រកផ្លូវ និងការព្រងើយ ) នោះ ដូចជាការរកផ្លូវចេញ ព្រោះបង្អោនទៅក្នុងការចេញអំពីសង្ខារ ។ កាលអនុលោមញ្ញាណសម្រេចហើយ មគ្គក៏សម្រេចនោះឯង ប្រៀបដូចកាលឃើញផ្លូវហើយ ក៏ដើរផ្លូវបាន ព្រោះហេតុនោះ ទើបអនុលោមញ្ញាណដូចជាការឃើញផ្លូវ ។ **គោត្រភូញាណ ដូចការចេញ** អំពីផ្ទះដែលត្រូវភ្លើងឆេះ ព្រោះជាការចេញអំពីសង្ខារនិមិត្ត ។ **មគ្គញ្ញាណ ប្រៀបដូចការទៅដោយរហ័ស** ព្រោះប្រកបដោយការផ្សេងគ្នានៃកិច្ចដែលធ្វើឲ្យសម្រេច ក្នុងចំណែកដែលគួរលះបង់ និងគួរកាន់យក ។

ការប្រកាន់ខន្ធទាំងឡាយដែលគប្បីឃើញជារបស់អ្នកដទៃនិងមិនមែនដោយគប្បីប្រកាន់ថា ជារបស់យើង ថាជាអញ ជារបស់អញ ដូច្នេះ លោកពោលថា ប្រៀបដូចកាន់យកគោរបស់ស្តេច ថាជារបស់ខ្លួន ។

ការប្រកាន់ខន្ធទាំងឡាយថា ជាអញ ជារបស់អញ ។ ព្រោះមានការឃើញក្នុងវត្ថុដែលមានភ័យថា មិនមានភ័យជាហេតុ ប្រៀបដូចការនៅរួមជាមួយយក្ខិនី ។ **គោត្រភូញាណ** ដែលលះបង់ព្រៃខ្មោច គឺសង្ខារប្រព្រឹត្តទៅដោយអំណាចមានព្រះនិព្វានជាអារម្មណ៍ **ប្រៀបដូចការលះបង់ព្រៃខ្មោច** ។

បទថា **បុត្តគិទ្ធិនី** ប្រែថា ជាអ្នកស្រឡាញ់កូន ។ បទថា **ឧត្តប្បមានា** ប្រែថា ភ័យខ្លាច ។ អនុលោមញាណ ប្រៀបដូចការដាក់ក្មេងទុកកណ្តាលថ្នល់នោះឯង ព្រោះលះសង្ខារបានដោយការសង្កត់គំនរលោភៈ ដែលគ្រោតគ្រាតៗ ជាដើម

**លោកពោលដើម្បីសម្តែងបុគ្គលតាំងនៅក្នុងវដ្តានគាមិនីវិបស្សនា ហើយជាអ្នកបង្អោន ឱន លំអៀងទៅកាន់លោកុត្តរធម៌** អធិប្បាយថា មិនមែនដើម្បីសម្តែងអាការ មានការភ័យខ្លាចជាដើម របស់បុគ្គលតាំងនៅក្នុងភយតុបដ្ឋានញ្ញាណជាដើម ដូចក្នុងញាណមុន ។ សេចក្តីទុក្ខ គឺការឃ្លាន ប្រៀបដូចវដ្តទុក្ខ ព្រោះកើតឡើងរឿយៗ ព្រោះជាប់តាមទៅយូរ និងព្រោះអត់ធន់បានលំបាក ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ត្រូវការឃ្លាន គឺសង្សារវដ្ត** ដូច្នេះ ។ ភោជន គឺកាយគតាសតិ ឈ្មោះថា **កាយគតាសតិ ភោជនំ** ប្រែថា ភោជន គឺកាយគតាសតិ ។ ឯកាយគតាសតិនោះ ក្នុងទីនេះ បានដល់ សម្មាសតិសម្បយុត្តដោយមគ្គ លោកពោលថា **ភោជន គឺកាយគតាសតិ មានរសជាអមតៈ** ដោយអំណាចជម្រះកិច្ចនៃកាយានុបស្សនាជាដើម និងការបរិភោគរសជាអមតៈ ។ ដោយហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ ជនពួកណា បរិភោគកាយគតាសតិ ជនទាំងនោះ ឈ្មោះថា**

**បរិភោគអមតៈ** ដូច្នេះជាដើម ។

**បានៈ** មានគ្រឿងតាក់តែងច្រើនយ៉ាង មានរសផ្លែឈើ កន្ទួតព្រៃ មើមខ្ទឹសណ្តែកបាយ និងសណ្តែករាជមាសជាដើម ។

តណ្ហាសិនេហៈ ( ជ័រ គឺតណ្ហា ) ប្រៀបដូចការរងា ព្រោះធ្វើភាពមិនជាសិរីដ៏គួរអាណិតជាដើម ។ ពាក្យថា **ភ្លើង គឺមគ្គ** បានដល់ ភ្លើងដែលជាធំ ពោល គឺអរិយមគ្គ ។

ភ្លើង ១១ កង មានរាគៈជាដើម រមែងចូលទៅរម្ងាប់ធម្មជាតិនេះ ហេតុនោះធម្មជាតិនេះ ឈ្មោះថា **ឯកាទសគ្គិវូបសមំ** ជាទីចូលទៅពន្លត់ភ្លើង ១១ កង បានដល់ព្រះនិព្វាន ។

ពាក្យថា **ត្រូវងងឹតគ្របសង្កត់ហើយ** គឺត្រូវងងឹតដែលប្រកបដោយអង្គ ៤ គ្របសង្កត់ហើយ ដោយការៈដែលមិនគប្បីធ្វើប្រយោជន៍ខ្លួន ឬប្រយោជន៍អ្នកដទៃណាមួយបាន ។ ពន្លឺដែលសម្រេចដោយញាណរបស់ធម្មជាតិនោះមាន ហេតុនោះធម្មជាតិនេះ ឈ្មោះថា **ញាណាលោកា** ប្រែថា មានពន្លឺដែលសម្រេចដោយញាណបានដល់ មគ្គភាវនា ។

ឱសថដែលជាអមតៈ ឬដែលឲ្យសម្រេចភាពជាអមតៈ ឈ្មោះថា **ឱសថអមតៈ** បានដល់ ព្រះនិព្វាន ។ លោកអាចារ្យកាលសម្តែងកិច្ចនៃសង្ខារុបេក្ខាញាណ ដែលបានពោលទុកហើយខាងដើម ដោយអំណាចពាក្យខាងចុង ទើបពោលពាក្យថា **តេន វុត្តំ** ជាដើម ។

ភិក្ខុណា ជាបុគ្គលមានអធ្យាស្រ័យមិនរាយមាយទៅ ក្នុងភពជាដើម ដោយអំណាចតណ្ហា ព្រោះជាបុគ្គលមិនមានអាល័យ ជាអ្នកមានចិត្តរួញរាអំពីភពជាដើមនោះ រមែងត្រាច់ទៅ គឺរមែងប្រព្រឹត្តដោយភាពជាអ្នកចៀសវាង ហេតុនោះ ភិក្ខុនោះ

ឈ្មោះថា **បដិលីនចរោ** ជាអ្នកត្រាច់ទៅ ដោយជាអ្នកចៀសវាង **នៃភិក្ខុដែលត្រាច់ទៅដោយភាពជាអ្នកចៀសវាង** នោះ ។ ឈ្មោះថា **នៃភិក្ខុ** ព្រោះជាអ្នកឃើញភ័យក្នុងសង្សារ ។ ឈ្មោះថា **បុគ្គលសេពអាសនៈដ៏ស្ងាត់** ព្រោះសម្រេចកាយវិវេក និងចិត្តវិវេក ។ បទថា **សាមគ្គិយំ** ប្រែថា សមគួរ អធិប្បាយថា សមគួរ ។ បទថា **ភវនេ** សេចក្តីថា ក្នុងភពទាំង ៣ មានកាមភពជាដើម ។ ឯភពទាំង ៣ នោះ លោកពោលថា **ភព** ដោយអត្ថថា ជាលំនៅក្នុងទីនេះ ។ បទថា **ន ទស្សយេ** ប្រែថា មិនសម្តែងដោយអំណាចការមិនកើតឡើង ។ ពាក្យប្រកបថា ព្រះអរិយៈទាំងឡាយមានព្រះសម្ពុទ្ធជាដើម **ពោល** ការមិនសម្តែង **នោះរបស់ភិក្ខុនោះ** ថា សមគួរ ។ ពាក្យថា **កំណត់** បានដល់ ធ្វើឲ្យពិតប្រាកដ គឺឲ្យប្រព្រឹត្តទៅដោយចំណែកមួយ ។ បណ្ឌិតគប្បីប្រកបវិសេសស័ព្ទទៅត្រង់បទថា **ពោជ្ឈង្គវិសេសំ** ការប្លែកគ្នានៃពោជ្ឈង្គ **មគ្គង្គវិសេសំ** ការប្លែកគ្នានៃអង្គមគ្គ **ឈានង្គវិសេសំ** ការប្លែកគ្នានៃអង្គឈាន **បដិបទាវិសេសំ** ការប្លែកគ្នានៃបដិបទា **វិមោក្ខវិសេសំ** ការប្លែកគ្នានៃវិមោក្ខ ។ ពាក្យថា **ការប្លែកគ្នា** បានដល់ ការផ្សេងគ្នា ដែលបានក្នុងអរិយមគ្គនៃពោជ្ឈង្គជាដើមតាមលំដាប់ ដូច្នេះ គឺជា ៦-៧ ជា ៧-៨ ជា ៥ ជាដើម ។ ពាក្យថា **បាទកជ្ឈាន** បានដល់ ឈានដែលជាបទដ្ឋាន នៃវុដ្ឋានគាមិនីវិបស្សនា ដែលជិតចំពោះមគ្គ ។ ពាក្យថា **ដែលជាអារម្មណ៍នៃវិស្សនា** គឺដែលជាអារម្មណ៍នៃវុដ្ឋានគាមិនីវិបស្សនា ដែលជិតចំពោះមគ្គនោះឯង ដែលបានឃើញច្បាស់ហើយ ។ ពាក្យថា **អធ្យាស្រ័យរបស់បុគ្គល** សេចក្តីថា កាលមានការផ្សេងគ្នានៃធម៌ទាំង ២ ឯអធ្យាស្រ័យរបស់បុគ្គលអ្នកបំពេញវិបស្សនា ( កំណត់ ) ។ ក្នុងអធិការនេះ ព្រះចុល្លនាគត្ថេរដែលទ្រទ្រង់ព្រះត្រៃបិដក លោកអាចារ្យពោលថា **កេចិអាចារ្យ** ជាលំដាប់ទី ១ ។ ព្រះមហាទត្តត្ថេរក្នុងសម្នាក់មោរវាបិ លោកអាចារ្យពោលថា **កេចិអាចារ្យ** ជាលំដាប់ទី ២ ។ ព្រះចូឡាភយៈ

ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក លោកអាចារ្យពោលថា **កេចិអាចារ្យ** ជាលំដាប់ទី ៣ ។

**ក្នុងវាទៈរបស់ព្រះថេរៈទាំង ៣ អង្គនោះ គប្បីជ្រាបថា វុដ្ឋានគាមិនីវិបស្សនាដែលជាបុព្វភាគនេះ កំណត់នោះឯង** ។ ព្រោះហេតុអ្វី ? ព្រោះថា ដោយកំណត់នៃវិបស្សនាក្នុងវាទៈរបស់ព្រះថេរៈទី ១ មគ្គដែលមានបឋមជ្ឈានជាបាទមិនមានបាទក៏ប្រកបដោយបឋមជ្ឈាននោះឯង ចំណែកមគ្គដែលប្រកបដោយទុតិយជ្ឈានជាដើមក្រៅអំពីនេះ ក៏ប្រកបទៅដោយឈាននោះៗ ដោយការកំណត់នៃវិបស្សនា ដែលមានឈានជាបាទ ព្រោះសង្ខារុបេក្ខាញាណដែលកើតអំពីឈានដែលជាបាទ មានទុតិយជ្ឈានជាដើមនោះៗ ជាវិភតការនា គឺជាធម៌ដែលមិនត្រូវការនឹងចូលសមាបត្តិនៃអង្គទាំងឡាយ ដែលឈានកន្លងឈានដែលជាបាទ និងព្រោះញាណក្រៅអំពីនេះមិនមានអង្គនោះ ។ ដូចជា មគ្គ ជាធម៌ប្រកបដោយឈាន មានបឋមជ្ឈានជាដើម រមែងមានបានព្រោះវិបស្សនាដែលជិតចំពោះមគ្គ ជាធម៌សហគតៈដោយសោមនស្ស ហើយមគ្គជាធម៌ប្រកបដោយបញ្ចមជ្ឈាន រមែងមានបានព្រោះវិបស្សនាដែលជិតចំពោះមគ្គ ជាធម៌សហគតៈដោយឧបេក្ខា និងព្រោះហេតុនោះ ទើបជាការផ្សេងគ្នារបស់ធម៌ទាំងឡាយ មានពោជ្ឈង្គជាដើម ព្រោះហេតុនោះ វុដ្ឋានគាមិនីវិបស្សនា ដែលជាហេតុជិត និងជាហេតុប្រធាន ក្នុងការកំណត់ធម៌ទាំងនោះ សេចក្ដីនេះ យ៉ាងណាធម៌ទាំងឡាយ មានឈានដែលជាបាទជាដើម មិនដូច្នោះឡើយ ។ ម្យ៉ាងទៀត ព្រោះវិបស្សនា វៀរឈានដែលជាបាទនោះហើយ រមែងមិនអាចកំណត់ការផ្សេងគ្នា តាមដែលពោលហើយនេះបាន តែរមែងជាហេតុ ប្រធានបានតែម្យ៉ាង តាមន័យដែលពោលហើយ ដូច្នោះ ទើបលោកអាចារ្យមិនពោលថា **វុដ្ឋានគាមិនីវិបស្សនាប៉ុណ្ណោះ រមែងកំណត់** តែពោលថា **វុដ្ឋានគាមិនីវិបស្សនាកំណត់នោះឯង** ដូច្នេះ ។ ការកំណត់វិបស្សនាក្នុងវាទៈដ៏សេស បណ្ឌិតគប្បីប្រកបតាមគួរ ដោយប្រការដូច្នេះ ។ ដូចជា

វុដ្ឋានគាមិនីវិបស្សនា ដែលជាវិរាគការនា គឺធម៌ដែលមិនត្រូវការនឹងចូលសមាបត្តិនៃអង្គទាំងឡាយ ដែលឈានកន្លងបាទកជ្ឈាន មានការផ្សេងគ្នានៃឈានដែលជាបាទដែលជាទីតាំងមកតាំងទុកហើយ រមែងជាធម៌កំណត់ការផ្សេងគ្នានៃធម៌ មានពោជ្ឈង្គជាដើមរបស់មគ្គ យ៉ាងណា វុដ្ឋានគាមិនីវិបស្សនា ដែលជាវិរាគការនា មានការរឿសអង្គទាំងឡាយ ដែលឈានកន្លងឈាន ដែលពិចារណាជាអារម្មណ៍ មានការផ្សេងអំពីឈានដែលពិចារណាហើយ មកតាំងទុកហើយ និងមានការផ្សេងគ្នាដែលធម៌ឯណានីមួយអំពីនោះ មកតាំងទុកដោយអំណាចអធ្យាស្រ័យ ព្រោះការមាននៃធម៌ទាំង ២ រមែងកំណត់ការផ្សេងគ្នានៃធម៌ មានពោជ្ឈង្គជាដើមរបស់មគ្គ ក៏ដូច្នោះឯង ។

បទថា **តត្រ** សេចក្តីប៉ុនគ្នានឹង **តស្មឹ យោគ ពោជ្ឈង្គាទិវិសេសនិយមនេ** ប្រែថា ក្នុងការកំណត់សេចក្តីផ្សេងគ្នានៃធម៌ មានពោជ្ឈង្គជាដើមនោះ ។ ព្រះខីណាស្រពដែលមិនបានឈាន ជាវិបស្សនាយានិកសុទ្ធតែម្យ៉ាង ឈ្មោះថា **សុក្ខវិបស្សកៈ** ។ ឯព្រះខីណាស្រពនោះ ហៅថា **សុក្ខវិបស្សកៈ** ព្រោះអត្ថថា មានវិបស្សនាដែលសម្លឹងគឺមើល ព្រោះវិបស្សនាជាធម្មជាតិមិនចុះសើប់តែម្យ៉ាង គឺឈាន ។ ពាក្យថា **បកិណ្ណកសង្ខារ** បានដល់ សង្ខារដទៃក្រៅអំពីឈានដែលជាបាទ ។ ដោយពាក្យនោះ លោកអាចារ្យរមែងសម្តែងថា កាលបានពិចារណាសង្ខារ គឺឈានដែលជាបាទហើយ ក៏រមែងមិនមានពាក្យដែលគប្បីពោលនោះឯង ។ សមដូចពាក្យដែលលោកអាចារ្យពោលទុកថា **ធ្វើបឋមជ្ឈានឲ្យជាបាទហើយ** ។ ឯសព្ទថា **សុក្ខវិបស្សកៈជាដើម** ដើម្បីសម្តែងការកំណត់នៃវិបស្សនា ជារឿងមានការប្រព្រឹត្តទៅដោយចំណែកមួយ ។ ព្រោះថាវៀរវុដ្ឋានគាមីនីចេញ ក៏មិនឃើញហេតុនៃការកំណត់ មានឈានជាបាទជាដើមតែម្យ៉ាង តែវុដ្ឋានគាមិនីសូម្បីកាលមិន មានឈានដែលជាបាទជាដើម ក៏ជាហេតុនៃមគ្គរបស់ព្រះសុក្ខវិបស្សកៈជាដើម ជាធម៌ប្រកបដោយបឋមជ្ឈាន ព្រោះហេតុនោះ ទើបវុដ្ឋាន-

គាមិនីនោះ ជាហេតុប្រព្រឹត្ត ដោយចំណែកមួយក្នុងការកំណត់ការផ្សេងគ្នានៃធម៌ មានពោជ្ឈង្គជាដើមដូច្នេះៗឥឡូវនេះដើម្បីនឹងធ្វើអត្ថតាមដែលពោលហើយឲ្យជាក់ច្បាស់ក្រៃលែងឡើង ទើបលោកអាចារ្យពោលពាក្យថា **តេសំ ហិ** ជាដើម ។ ពាក្យថា **ការផ្សេងគ្នានេះ** បានដល់ ការផ្សេងគ្នា មានប្រកបដោយអង្គ ៤ ជាដើមនៃធម៌ទាំងឡាយមានឈានជាដើមនេះ រមែងមានដោយការកំណត់នៃវិបស្សនាតែម្យ៉ាង ដូចអំពីមុនក៏មិនមែន ដោយពិតនោះ រមែងមានដោយការកំណត់ឈានដែលជាបាទ និងដោយការកំណត់នៃវិបស្សនា ។ បទថា **តេសម្បិ យោគ បញ្ចកនយេ ទុតិយ តតិយ-ចតុត្ថជ្ឈានានិ បាទកានិ កត្វា ឧប្បាទិ តមគ្គានម្បិ** ប្រែថា នៃមគ្គ ដែលព្រះយោគីធ្វើឲ្យកើតឡើង ដោយធ្វើទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានក្នុងបញ្ចកន័យឲ្យជាបាទ ។ ដោយពាក្យថា **ក្នុងទីជិត** នេះ លោកអាចារ្យរមែងសម្តែងថា ការផ្សេងគ្នានេះរមែងមិនមានដោយអំណាចសមាបត្តិ ដែលអ្នកបំពេញវិបស្សនាចូលក្នុងចន្លោះៗ ។

បទថា **តត្រាបិ ច យោគ ទុតិយត្ថេរវាទេបិ** ប្រែថា សូម្បីក្នុងថេរវាទទី ២ នោះ ។ ភាពដែលស្រដៀងគ្នានៃសមាបត្តិនោះ រមែងមានដោយការកំណត់នៃវិបស្សនាដែលមានសង្ខារបានពិចារណាហើយនោះ ។ ពិតហើយ ក្នុងថេរវាទ ២ នោះ ក៏គប្បីជ្រាបការកំណត់នៃវិបស្សនា តាមន័យដែលបានពោលហើយនោះឯង យ៉ាងនោះថា វិបស្សនា ជាធម៌សហគតៈដោយសោមនស្ស និងសហគតៈដោយឧបេក្ខា ដោយភាវៈដែលជាវិរាគភាវនា និងអវិរាគភាវនានោះៗ រមែងធ្វើការកំណត់អង្គឈានជាដើមដល់មគ្គ ។

បទថា **តំ យោគ តំតំ ឈានសទិសកវំ** ប្រែថា មគ្គដែលកើតឡើង ស្រដៀងគ្នានឹងឈាននោះៗ ។ **សេចក្តីនេះ** គឺការមិនសម្រេចដោយត្រឹមតែអជ្ឈាស្រ័យ វៀរចាកឧបនិស្ស័យ គឺឈានដែលជាបាទ និងឈានដែលពិចារណា **គប្បីចន្ទុលបង្ហាញដោយ**

នន្ទកោវាទសូត្រ ដែលសម្តែងដល់ការមិនសម្រេចនៃសកទាគាមិផលជាដើម ដោយត្រឹមតែការត្រិះរិះ វៀរចាកឧបនិស្ស័យ ។ ពិតហើយ ក្នុងនន្ទកោវាទសូត្រនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដល់ភិក្ខុនីជាសោតាបន្ន ជាអ្នកមានតម្រិះត្រូវត្រង់បានសម្តែងសេចក្តីនេះទុកថា **បុគ្គលណាម្នាក់ មានឧបនិស្ស័យ អធ្យាស្រ័យរបស់បុគ្គលនោះៗឯង ជាគ្រឿងកំណត់ មិនមែនរបស់បុគ្គលដទៃ** ដូច្នេះ បុគ្គលមានតម្រិះពេញបរិបូណ៌ ទើបមានដោយឧបនិស្ស័យនោះៗ មិនក្រៃលែងទៅជាងនោះ ព្រោះសម្បីកាលមានសភាពនៃតម្រិះ ក៏មិនសម្រេចឡើយ សេចក្តីនេះ យ៉ាងណា សម្បីក្នុងវាទៈនេះ ក៏ដូច្នោះ ។ សេចក្តីនេះ យ៉ាងណា សម្បីក្នុងវាទៈនេះ ក៏ដូច្នោះ ឧបនិស្ស័យតាមដែលពោលហើយនៃមគ្គ ដែលប្រកបដោយឈាន មានទុតិយជ្ឈានជាដើមរបស់បុគ្គលណាម្នាក់ អធ្យាស្រ័យរបស់បុគ្គលនោះឯង ជាគ្រឿងកំណត់ មិនមែនរបស់បុគ្គលដទៃឡើយ ព្រោះកាលឧបនិស្ស័យនោះមាន ក៏មិនសម្រេចឡើយ ។ តែក្នុងវាទៈនេះ អធ្យាស្រ័យក្នុងការមាននូវឧបនិស្ស័យនៃឈានដែលជាបាទ និងដែលពិចារណាដូចគ្នានឹងការគិត ( តម្រិះ ) នោះៗ ក្នុងការមាននូវឧបនិស្ស័យរបស់ផលនោះៗ ដោយពិតប្រាកដ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **អធ្យាស្រ័យរមែងកំណត់** ព្រោះការមាន និងការមិនមាននៃអធ្យាស្រ័យនោះៗ ។ បទថា **ឯត្ថាបិ យោគ តតិយត្ថេរវាទេបិ** ប្រែថា សម្បីក្នុងថេរវាទទី ៣ នោះ ។ ពាក្យថា **ដោយន័យដែលពោលហើយដូចគ្នា** សេចក្តីថា ដោយន័យដែលពោលហើយ មានពាក្យថា **ចេញអំពីសមាបត្តិណាមួយ** ដូច្នេះជាដើម ។ ព្រោះហេតុនោះ គប្បីជ្រាបអត្ថនោះ តាមន័យដែលពោលហើយ ក្នុងទីនេះ មានពាក្យថា **តត្រាបិ ហិ វិបស្សនា** ដូច្នេះជាដើម ។

លោកអាចារ្យកាលសម្តែងវិបស្សនាជាគ្រឿងកំណត់ធម៌ មានពោជ្ឈង្គជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលសម្តែងវិបស្សនាជាគ្រឿងកំណត់បដិបទាជាដើម ទើប

ពោលពាក្យថា **បើសង្ខារុបេក្ខានេះ** ដូច្នេះជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **នេះ** លោកពោលដល់សង្ខារុបេក្ខា ។ ពិតហើយ សូម្បីសង្ខារុបេក្ខានោះ ក៏ចាត់ជាទុក្ខាបដិបទាគ្រប់វារៈ គឺបដិបទាដែលលំបាកដោយការសង្កត់ដល់ ៣ វារៈ នូវវិបស្សនូបក្កិលេសដែលកើតឡើង ក្នុងកាលឧទយព្វយានុបស្សនាប្រព្រឹត្តទៅ ខាងចុងនៃកលាបសម្មសនៈ ក្នុងពាក្យថា **អាចារ្យទាំងឡាយលើកឡើងកាន់វារៈនេះ** នេះព្រោះហេតុនោះ ទើបអាចារ្យទាំងឡាយពោលថា លើកឡើងហើយ ដូច្នេះ ដោយពិតសូម្បីយ៉ាងនោះ ព្រោះ **ក្នុងអដ្ឋកថា** លោកពោលទុកថា **កាលវិបស្សនាញាណរឹងមាំក្លាហាន ផូរផង់ ប្រព្រឹត្តទៅ ព្រះយោគាវចរលំបាក រមែងសង្កត់ការត្រេកអរនៃវិបស្សនាដែលកើតឡើង ដោយការកម្រ ដោយការលំបាក** ដូច្នេះ សង្ខារុបេក្ខាដែលប្រព្រឹត្តទៅដោយញាណត្រូវការនឹងដោះជាដើម ក្នុងបុព្វភាគ កាលសង្កត់ធម៌ទាំងឡាយ ដែលជាបដិបក្ខដល់ខ្លួន ដោយកម្រ ដោយលំបាក រមែងតាំងនៅក្នុងចំណែកទុក្ខាបដិបទានោះឯង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដំបូង កាលសង្កត់កិលេស** ដូច្នេះជាដើម ។ ចំណែកអាចារ្យពួកខ្លះ រមែងពោលថា វិបស្សនូបក្កិលេសទាំងឡាយ ត្រូវញាណណាសង្កត់ទុកហើយ ញាណនេះ និងញាណនោះលោកពោលថា **ដំបូង កាលសង្កត់កិលេស** ព្រោះធ្វើឲ្យជាញាណ ១ ដោយអំណាចឯកត្តន័យ ។ ពាក្យថា **ព្រមទាំងបយោគ** គឺព្រមទាំងឧស្សាហ៍ ពោល គឺចិត្តប្បយោគ ។ ពាក្យថា **ព្រមទាំងសង្ខារ** ជាវេវចនៈរបស់ពាក្យថា **ព្រមទាំងបយោគនោះឯង** ។ ដោយពាក្យទាំង ២ លោកអាចារ្យ រមែងពោលការសម្រេចកិច្ចនោះឯងនៃការសង្កត់ទុកបាន ។ ពាក្យថា **ដោយវិបរិយាយ** គឺដោយមិនលំបាក ដោយមិនចាំបាច់ព្យាយាម ដោយមិនចាំបាច់ប្រើសង្ខារ ។ បុគ្គលចូលដល់ស្ថានទីដែលប្រាថ្នាហើយ ដែលមានឈ្មោះថាមគ្គ ទើបនៅដោយជុំវិញ គឺនៅប្រាថ្នាបានក្នុងធម៌នេះ ហេតុនោះ ធម៌នេះ ឈ្មោះថា

**បរិវាសោ** ប្រែថា ជាទីនៅជុំវិញ វិបស្សនាដែលជាទីនៅជុំវិញ មានដល់ធម៌នេះ ហេតុនោះ ធម៌នេះ ឈ្មោះថា **វិបស្សនាបរិវាសោ** វិបស្សនាដែលនៅជុំវិញ គឺការប្រាកដនៃមគ្គ ។ ឯសង្ខារុបេក្ខាធ្វើការប្រាកដនៃមគ្គរហ័ស ទើបឈ្មោះថា ជាខិប្បាភិញ្ញា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សន្សឹមៗ** ដូច្នេះ ។ ប្រកបសេចក្តីថា សង្ខារុបេក្ខានេះកំពុងធ្វើ ។ មគ្គមកអំពីទីណា ហេតុនោះ ទីនោះឈ្មោះថា **អាគមនីយដ្ឋាន** ប្រែថា ជាទីផុសមក **ក្នុងអាគមនីយដ្ឋាន** នោះ ។ ភ្ជាប់សេចក្តីថា ឯ (សង្ខារុបេក្ខា) តាំងនៅក្នុងទីកើតរបស់មគ្គ ទើបឲ្យឈ្មោះ ។ វិបស្សនាន័យ មានទុក្ខាបដិបទាទន្ធាភិញ្ញាជាដើម ១ មគ្គ ១ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដល់មគ្គរបស់ខ្លួនរៀងៗ ខ្លួន** ដូច្នេះ ។ ទើបមគ្គ បានឈ្មោះ ៤ យ៉ាង **មានទុក្ខាបដិបទាខិប្បាភិញ្ញា** ជាដើមតាមឈ្មោះដែលបានមកអំពីទីមក **នោះ** ។ ឯនាម ដូច្នេះ មិនមានដោយកិច្ចរបស់មគ្គឡើយ ។

**ឯបដិបទា** មានប្រភេទដូចពោលហើយ **នេះ** ។ ពាក្យថា **រមែងមានផ្សេងៗ គ្នា** គឺរមែងមានជាផ្នែកៗ ។ សម្រាប់ភិក្ខុមួយអង្គ **មានបដិបទា ១ ក្នុងមគ្គទាំង ៤** ព្រោះហេតុនោះ ទើបការពិតប្រាកដមិនមានព្រោះការញាប់ញ័រ ។ លោកអាចារ្យពោលថា **អហេសុំ** តែគួរពោលថា **ហោន្តិ** សំដៅយកព្រះមានព្រះភាគនៃយើង ។ ឯមគ្គទាំង ៤ របស់ព្រះសម្មាសម្ពុទ្ធគ្រប់អង្គ ជាសុខាបដិបទាខិប្បាភិញ្ញាទាំងអស់ ដូច្នេះ លោកអាចារ្យមានបំណងនឹងសម្តែងសូម្បីអធិបតី ដោយការទាក់ទងនឹងបដិបទា ទើបពោលពាក្យថា **យថា ច** ជាដើម ។ ពាក្យថា **អធិបតីទាំងឡាយ** បានដល់ អធិបតី មានឆន្ទៈជាដើម ។ ឯមគ្គ មានឆន្ទៈជាអធិបតីក៏មាន មានបណ្តាធម៌ទាំងឡាយ មានវិរិយៈជាដើមឯណានីមួយ ជាអធិបតីក៏មាន ចំពោះតែមួយតាមសមគួរដល់អភិសង្ខារខាងដើម មិនមានការកំណត់ដល់បុគ្គលណាម្នាក់ឡើយ ។ ដោយហេតុនោះ ទើបលោក

អាចារ្យពោលថា **ដល់ភិក្ខុអង្គខ្លះ** ដូច្នេះជាដើម ។

លោកអាចារ្យមានបំណងនឹងសម្ដែងហេតុក្នុងការបានឈ្មោះនៃមគ្គ ដោយមិនសេសសល់ ធ្វើឲ្យមានភាពពិសេសក្រៃលែង ដោយប្រការដែលពោលហើយអំពីមុន ទើបពោលពាក្យថា **ម្យ៉ាងទៀត** ជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ដោយរសរបស់ខ្លួន** បានដល់ ដោយសភាវៈ គឺដោយការផ្សេងគ្នានៃការប្រព្រឹត្តទៅរបស់ខ្លួន ។ ពាក្យថា **ដោយបច្ចនិកធម៌** គឺដោយអំណាចធម៌ដែលជាសត្រូវ ។ ពាក្យថា **ដោយគុណរបស់ខ្លួន** គឺដោយអំណាចគុណរបស់ខ្លួន លោកអាចារ្យពោល **វា**-ស័ព្ទមានអត្ថជាអនិយម ក្នុងទីគ្រប់កន្លែង ដោយពាក្យថា **សរសេន វា** ដូច្នេះជាដើម ដើម្បីសម្ដែងថា ក្នុងអធិការនេះ ការបានឈ្មោះរបស់មគ្គ កំណត់ដោយគុណរបស់ខ្លួន និងដោយអារម្មណ៍ វៀរចាកអារម្មណ៍ដែល ( ប្រាកដមក ) ដោយប្រការណា ការបានឈ្មោះកំណត់ចុះដោយរសរបស់ខ្លួនប៉ុណ្ណោះ វៀរចាកធម៌ដែលជាសត្រូវ ដោយប្រការនោះ ដោយពិត សូម្បីយ៉ាងនោះ ធម៌ទាំងឡាយ មានរសរបស់ខ្លួនជាដើម ក៏ជាហេតុនៃការបានឈ្មោះអំពីមគ្គ ១ នោះឯង ។ ដើម្បីសម្ដែងមគ្គនោះដោយមិនលាយឡំគ្នា ទើបលោកអាចារ្យផ្ដើមពាក្យថា **សចេ ហិ** ជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ បទថា **សម្មសិត្វា** សេចក្ដីថា ព្រោះការពិចារណាជាហេតុ ។ ឯ **ត្វា**-ស័ព្ទនេះមានអត្ថថា ហេតុដូចក្នុងពាក្យថា **យតំ បិវិត្វា ពលំ ហោតិ** កម្លាំងមាន ព្រោះផឹកទឹកដោះជូរ **សីហំ ទិស្វា ភយំ ហោតិ** ការខ្លាច រមែងមានព្រោះឃើញសីហៈ ។ សង្ខារុបេក្ខាដែលជាហេតុប្រព្រឹត្តទៅដោយចំណែកមួយនៃកិរិយា គឺការចេញ ដែលជាកត្តុរបស់មគ្គ លោកពោលថា **វុដ្ឋាតិ** ដោយពោលដល់ផល ។ ម្យ៉ាងទៀត ព្រោះពាក្យថា **សង្ខារុបេក្ខានេះ** ចូលទៅកំណត់វុដ្ឋានគាមិនីវិបស្សនា និងគោត្រភូញាណដែលឈោងចុះក្នុងសង្ខារុបេក្ខានោះ រមែងចេញចាកនិមិត្ត ដូច្នោះ ទើបលោកអាចារ្យ

ពោលថា **រមែងចេញព្រោះពិចារណា** ដូច្នេះ ដោយឯកត្តន័យ ។ ពាក្យថា **រមែងរួចផុតដោយអនិមិត្តវិមោក្ខ** សេចក្តីថា រមែងរួចផុត ដោយការរួចផុតដែលមានឈ្មោះថា **អនិមិត្ត** ។ គប្បីនាំពាក្យថា **មគ្គ** មកភ្ជាប់ផង ។ម្យ៉ាងទៀត ពាក្យថា **រមែងរួចផុត** បានដល់ ព្រះអរិយបុគ្គលដែលមានការដល់ព្រមដោយមគ្គនោះ ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះឯង ។ ពាក្យថា **នេះ ឈ្មោះថា នាម ដោយរសរបស់ខ្លួន** សេចក្តីថា នេះ គឺឈ្មោះទាំង ៣ យ៉ាង គឺ **អនិមិត្ត អប្បណិហិត សុញ្ញត** ព្រោះវៀរចាកនិមិត្តជាដើម ឈ្មោះថា **នាម** សម្រេចដោយការៈនៃមគ្គ ។

បទថា **ឯស យោគ មគ្គោ** ។ ឯមគ្គនោះឯង លោកពោលដោយឯកត្តន័យ ព្រោះធ្វើឲ្យតែមួយដូចគ្នានឹងមគ្គក្នុងបុព្វភាគ ។ ពាក្យថា **នេះ** ឈ្មោះថា នាម ដោយបច្ចនិកធម៌ សេចក្តីថា នេះ គឺឈ្មោះទាំង ៣ មានអនិមិត្តជាដើមនៃមគ្គ ដែលបានដោយអំណាចការលះបណិធិ នៃនិច្ចនិមិត្តជាដើម និងនៃអត្តសញ្ញា ឈ្មោះថា នាម ដែលសម្រេចដោយធម៌ដែលជាបដិបក្ខ ។

បទថា **សុញ្ញតា** ប្រែថា ព្រោះទទេ ។ ព្រោះថា កិលេសទាំងឡាយ មានរាគៈជាដើម មិនមានក្នុងមគ្គ ។ បទថា **រូបនិមិត្តាទីនំ** អធិប្បាយថា នៃនិមិត្តទាំងឡាយមានរូបនិមិត្ត និងវេទនានិមិត្តជាដើម ដែលគប្បីកាន់យក ។ សូម្បីក្នុងបទថា **រាគ-និមិត្តាទីនំ** នេះ ក៏មានន័យនេះដូចគ្នា ។ ឯការប្រោកដលោកមានបំណងយកថា **និមិត្ត** ក្នុងទីនេះ ដូចជាការប្រោកដរបស់វត្ថុដែលមានកាយទាំងឡាយ ។ ពាក្យថា **នេះជានាមដោយគុណរបស់ខ្លួននៃមគ្គនោះ** សេចក្តីថា នេះជានាមដែលសម្រេច ដោយគុណរបស់ខ្លួននៃមគ្គនោះ ដោយអំណាចការមិនមានទូវរូបនិមិត្តជាដើម និងបណិធិជាដើម ព្រោះជាការទទេចាកកិលេស មានរាគៈជាដើម ។

បទថា **ស្វាយំ** កាត់ជា **សោ អយំ យោគ មគ្គោ** ប្រែថា មគ្គនេះ ។ បទថា

**សុញ្ញតំ** សេចក្តីថា ឈ្មោះថា **ជាធម៌ទទេ** ព្រោះទទេចាកសង្ខារទាំងពួង និងទទេចាកអត្តា ។ ឈ្មោះថា **អនិមិត្ត** ព្រោះការមិនមានសង្ខារនិមិត្តទាំងពួង ។ ឈ្មោះថា **អប្បណិហិត** ព្រោះមិនមាននូវបណិធិ មានតណ្ហាបណិធិជាដើម ។ ពាក្យថា **នេះជានាមដោយអារម្មណ៍របស់មគ្គនោះ** សេចក្តីថា រូបដែលមានសុខជាអារម្មណ៍ លោកហៅថា **សុខ** ណា នេះ គឺនាមដែលផ្សេងដោយសុញ្ញតជាដើម ជានាមដែលសម្រេចដោយអារម្មណ៍របស់មគ្គនោះ ព្រោះធ្វើព្រះនិព្វាន ដែលមាន ឈ្មោះថា **សុញ្ញត** ជាដើមឲ្យជាអារម្មណ៍ ដូច្នោះ ។

**អនត្តានុបស្សនា** ឈ្មោះថា **សុញ្ញតាវិបស្សនាដោយរសរបស់ខ្លួន** ព្រោះបានឃើញភាពជាធម៌ទទេចាកអត្តា ។ មគ្គនៃសុញ្ញតាវិបស្សនានោះ ឈ្មោះថា **សុញ្ញត** ដោយវិបស្សនាគមនៈ ។ អនិច្ចានុបស្សនា ឈ្មោះថា **អនិមិត្តាវិបស្សនា** ព្រោះដកចោលនូវនិមិត្តទាំងឡាយ មាននិច្ចនិមិត្តជាដើម ។ តែ ឈ្មោះថា **អនិមិត្តរបស់មគ្គនេះ** មិនបានតាមបែបព្រះអភិធម្ម ។ ព្រោះហេតុអ្វី ? ព្រោះក្នុងព្រះអភិធម្មមិនបានប្រារព្ធរសរបស់ខ្លួន បានឈ្មោះដោយធម៌ដែលជាសត្រូវ ។ ឯការបានឈ្មោះដោយគុណរបស់ខ្លួន និងអារម្មណ៍ណា ការបានឈ្មោះនោះ មានរសរបស់ខ្លួនជាប្រធាន និងដោយរសរបស់ខ្លួននោះឯង ក៏មិនគប្បីមានការកំណត់ថា មគ្គទាំងពួងជាសុញ្ញតជាដើម ព្រោះការបានឈ្មោះ ។ ព្រោះហេតុនោះ កាលមានការបានឈ្មោះអនិមិត្តដោយហេតុទាំង ២ ក្នុងព្រះអភិធម្ម លោកក៏កាន់យកការធ្វើការកំណត់ឈ្មោះ ដោយធម៌ដែលជាសត្រូវតែម្យ៉ាង ព្រោះហេតុនោះ ទើបមិនបាន ព្រោះមិនមានការកំណត់នោះ ។ ម្យ៉ាងទៀត ពាក្យថា **មិនបាន** សេចក្តីថា មិនបានដោយគុណរបស់ខ្លួន និងអារម្មណ៍ មិនមែនសម្ដីងដល់ធម៌ដទៃ ។ ព្រោះហេតុអ្វី ? ព្រោះក្នុងព្រះអភិធម្មបានឈ្មោះដោយរសរបស់ខ្លួន និងធម៌ដែលជាសត្រូវប្រកបគ្នា ។ ពិតហើយ ភាវៈដែលរសរបស់ខ្លួនសុទ្ធៗ ជាហេតុនៃឈ្មោះដោយមិនបានសម្ដីងដល់ការធ្វើការកំណត់

ដែលជាសត្រូវ មិនមានក្នុងព្រះអភិធម្ម ព្រោះត្រូវការកំណត់ចុះ ។ ព្រោះហេតុនោះ មគ្គទាំងឡាយដែលអនុលោមចូលជាមួយវិបស្សនាដែលជាបដិបក្ខចំពោះអត្តាភិនិវេស និងបណិធិ កាលមានរសរបស់ខ្លួនដទៃ ក៏បានឈ្មោះដោយរសរបស់ខ្លួនដែលប្រកប ដោយធម៌ជាសត្រូវ ។ ចំណែកវិបស្សនានៃអនិមិត្តមគ្គ មិនបានជាបដិបក្ខចំពោះនិមិត្ត ទាំងមិនបានបដិសេធការកាន់យកនិមិត្ត ព្រោះកាន់យកនិមិត្តដោយខ្លួនឯង ព្រោះហេតុ នោះ សូម្បីមគ្គដែលជាអនុលោមចូលជាមួយវិបស្សនានោះ ក៏មិនបានជាបដិបក្ខចំពោះ និមិត្ត ។ ឧបមាថា គប្បីកើតសោត មគ្គក៏នឹងជាបដិបក្ខចំពោះវិបស្សនា ដែលទៅក្នុង និមិត្ត ព្រោះហេតុនោះ រសរបស់ខ្លួន សូម្បីមាន លោកក៏មិនបានកាន់យកថាជាអ្នកឲ្យ ឈ្មោះថា **អនិមិត្ត** ក្នុងព្រះអភិធម្ម ព្រោះមិនមានធម៌ដែលជាសត្រូវ ដែលធ្វើការ កំណត់ ដូច្នេះ សួរថា បើយ៉ាងនោះ មគ្គនេះ អនុលោមចូលជាមួយអនិច្ចានុបស្សនា ក៏មិនគប្បីសង្គ្រោះចូលក្នុងព្រះអភិធម្មឬ ? ឆ្លើយថា មិនមែន ព្រោះមគ្គដែលអនុលោម ចូលជាមួយអនិច្ចានុបស្សនានោះ លោកសង្គ្រោះចូលក្នុងន័យនៃសុទ្ធិបដិបទា ព្រោះ ហេតុនោះឯង ទើបលោកពោលមគ្គនោះទុក ។ តែព្រោះក្នុងព្រះសូត្រជាទេសនាដោយ បរិយាយ ទើបមគ្គបានឈ្មោះដោយត្រឹមតែគុណរបស់ខ្លួន និងអារម្មណ៍ ព្រោះហេតុ នោះ ទើបលោកអាចារ្យពោលថា **បានដោយបរិយាយនៃព្រះសូត្រ** ។ ឯពាក្យណា ដែលគប្បីពោលក្នុងអធិការនេះ ពាក្យនោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។ លោកអាចារ្យបំណងសម្ដែងថា ឈ្មោះថា **អនិមិត្តនៃមគ្គ** រមែងបានដោយអំណាច អាគមនៈ ( នោះឯង ) ទើបពោលពាក្យជាដើមថា **តាមព្រះសូត្រ** ។ ពាក្យថា **ក្នុង អាគមនីយដ្ឋាន** គឺក្នុងឋានៈនៃបដិបទាជាទីមក ។ ពាក្យដ៏សេសរាក់ទាំងអស់ ព្រោះ មានន័យបានពោលទុកហើយ ដូច្នេះ ។

សង្ខារុបេក្ខាញាណ ចប់

# វិសុទ្ធិមគ្គ

## អនុលោមញ្ញាណ

កាលព្រះយោគាវចរនោះសេព ចម្រើន ធ្វើឲ្យច្រើន នូវសង្ខារុបេក្ខាញាណនោះ **អធិមោក្ខសទ្ធា** រមែងមានកម្លាំងក្រៃលែងឡើង វីរិយៈក៏ត្រូវផ្គងទុកយ៉ាងល្អ សតិក៏ចូលទៅតាំងនៅយ៉ាងល្អ ចិត្តក៏តាំងមាំយ៉ាងល្អ សង្ខារុបេក្ខារឹងមាំក្រៃលែងកើតឡើង ។ កាលព្រះយោគាវចរនោះ រំពឹងថា **មគ្គនឹងកើតក្នុងឥឡូវនេះ** សង្ខារុបេក្ខាពិចារណាសង្ខារទាំងឡាយ ដោយអាការថា មិនទៀង ឬជាទុក្ខ ឬជាអនត្តាក្តី ហើយចុះកាន់ភវង្គក្នុងលំដាប់នៃភវង្គ មនោទ្វារាវជ្ជនៈ ធ្វើសង្ខារទាំងឡាយ ឲ្យជាអារម្មណ៍ដោយអាការថា មិនទៀង ឬជាទុក្ខ ឬជាអនត្តា ដោយន័យដែលសង្ខារុបេក្ខាធ្វើហើយនោះឯងកើតឡើង តអំពីនោះ ជវនចិត្តដួងដំបូង ដែលបន្តសន្តតិមិនមានចន្លោះក្នុងលំដាប់នៃកិរិយាចិត្ត ( គឺមនោទ្វារាវជ្ជនៈ ) ដួងនោះ ដែលញុំាងភវង្គឲ្យវិលត្រឡប់ ( គឺមិនឲ្យប្រព្រឹត្តទៅដោយអំណាចភវង្គ ) ធ្វើសង្ខារទាំងឡាយឲ្យជាអារម្មណ៍យ៉ាងនោះដូចគ្នាកើតឡើង ដែលលោកហៅថា **បរិកម្ម** គឺតាក់តែងមគ្គឡើង លំដាប់នោះជវនចិត្តដួងទី ២ ធ្វើសង្ខារទាំងឡាយឲ្យជាអារម្មណ៍យ៉ាងនោះឯងកើតឡើង ដែលលោកហៅថា **ឧបចារៈ** ( គឺជិតមគ្គ ) ក្នុងលំដាប់នោះ ជវនចិត្តដួងទី ៣ ក៏ធ្វើសង្ខារទាំងឡាយឲ្យជាអារម្មណ៍យ៉ាងនោះដូចគ្នាកើតឡើង ដែលលោកហៅថា **អនុលោម** ( គឺសមគួរដល់ធម៌គ្រប់ចំណែក ឬគួរធ្វើមគ្គឲ្យកើតបាន ) នេះជានាមញែកគ្នាម្នាក់មួយចំណែកនៃចិត្តទាំងនោះ តែនឹងហៅចិត្តទាំង ៣ យ៉ាងនោះថា **អាសេវន** ខ្លះ ថា

បរិកម្ម ខ្លះ ថា ឧបចារៈ ខ្លះ ថា អនុលោម ខ្លះ ដោយមិនប្លែកគ្នាក៏គួរ ។

សួរថា អនុលោមដល់អ្វី ? ឆ្លើយថា អនុលោមដល់ធម៌ទាំងឡាយ ទាំងចំណែកខាងដើម ទាំងចំណែកខាងចុង ព្រោះថា អនុលោមញ្ញាណនោះ ឈ្មោះថា អនុលោមដល់វិបស្សនាទាំង ៨ ព្រោះមានកិច្ចយ៉ាងនោះ ( គឺមានកិច្ចពិចារណាកំណត់ត្រៃលក្ខណ៍ ដូចវិបស្សនាទាំងពួង ) និងឈ្មោះថា អនុលោមដល់ពោធិបក្ខិយធម៌ ៣៧ ខាងចុងផង ។ ពិតហើយ អនុលោមញ្ញាណនោះ ព្រោះប្រារព្ធសង្ខារទាំងឡាយដោយគន្លងត្រៃលក្ខណ៍កាលអនិច្ចលក្ខណៈជាដើមប្រព្រឹត្តទៅទើបឈ្មោះថាអនុលោមដល់ញាណ ៨ នេះ ព្រោះមានកិច្ចដូចជា ( ញាណ ៨ ) នោះ ដូចចន្លុលប្រាប់ដោយសេចក្តីថា ឧទយព្វយញ្ញាណបានឃើញការកើតឡើង និងការសូន្យទៅនៃធម៌ទាំងឡាយ ដែលមានការកើត និងការវិនាស ពិតហ្ន៎ និងថា ភង្គានុបស្សនាញាណបានឃើញការបែកធ្លាយនៃធម៌ទាំងឡាយ ដែលមានការបែកធ្លាយ ពិតហ្ន៎ និងថា វត្ថុដែលប្រព្រឹត្តទៅជាមួយភ័យ ពិតហ្ន៎ បានប្រាកដជារបស់គួរខ្លាចដល់ភយតុបដ្ឋានញ្ញាណ និងថា អាទីនវានុបស្សនាញាណបានឃើញទោស ក្នុងរបស់ដែលប្រព្រឹត្តទៅដោយទោស ពិតហ្ន៎ និងថា និព្វិទាញាណបាននឿយណាយក្នុងវត្ថុដែលគួរនឿយណាយ ពិតហ្ន៎ និងថា មុញ្ចិតុកម្យតាញាណបានកើត មានដល់ការប្រាថ្នានឹងដោះក្នុងវត្ថុដែលគួរដោះ ពិតហ្ន៎ និងថា វត្ថុដែលគួរពិចារណា ( រកផ្លូវដោះ ) ពិតហ្ន៎ បដិសង្ខាញាណពិចារណា ( ដឹងផ្លូវ ) ហើយ និងថា វត្ថុដែលគួរចូលទៅសម្លឹង ( ព្រងើយ ) ពិតហ្ន៎ សង្ខារុបេក្ខាញាណចូលទៅសម្លឹង ( ព្រងើយ ) ហើយ ដូច្នេះ និងញុំាំងអនុលោមដល់ពោធិបក្ខិយធម៌ ៣៧ ខាងចុងផង ព្រោះពោធិបក្ខិយធម៌ទាំងនោះ ជាធម៌ដែលគប្បីដល់បាន ដោយការបដិបត្តិ ( គឺការសង្កត់កិលេសដែលបាំងសច្ចៈនៃអនុលោមញ្ញាណ ) នោះ ។

## ឧបមានៃអនុលោមញ្ញាណ

ឧបមាដូចព្រះរាជាដែលទ្រង់ធម៌ប្រថាប់គង់ ( ជាប្រធាន ) ក្នុងទីលានវិនិច្ឆ័យ ទ្រង់បានស្តាប់ ( ពាក្យ ) វិនិច្ឆ័យរបស់វោហារិកមហាមាត្យទាំង ៨ ហើយ ទ្រង់លះបង់នូវសេចក្តីលំអៀង ដាក់ព្រះអង្គជាកណ្តាល កាលទ្រង់អនុមោទនា ( គឺព្រះរាជទានរាជានុមតិ ) ទៅថា ចូរដូចជាការវិនិច្ឆ័យនោះចុះ ក៏ឈ្មោះថា ទ្រង់អនុលោមដល់ ( ពាក្យ ) វិនិច្ឆ័យរបស់វោហារិកមហាមាត្យទាំងនោះផង ដល់បុរាណរាជធម៌ផង យ៉ាងណា ការឧបមេយ្យនេះបណ្ឌិតគប្បីជ្រាប ដូច្នោះ ។

## ប្រៀបធៀបសេចក្តី

ឯអនុលោមញ្ញាណ ប្រៀបដូចព្រះរាជា ញាណ ៨ ( មានឧទយព្វយានុបស្សនាញាណជាដើម ) ប្រៀបដូចវោហារិកមហាមាត្យទាំង ៨ ពោធិបក្ខិយធម៌ ៣៧ ប្រៀបដូចបុរាណរាជធម៌ ។ ក្នុងឧបមានោះ ព្រះរាជានោះ កាលបញ្ជាថា ចូរដូចជាការវិនិច្ឆ័យនោះចុះ ឈ្មោះថា ទ្រង់អនុលោមដល់ ( ពាក្យ ) វិនិច្ឆ័យរបស់វោហារិកមហាមាត្យទាំងឡាយផង និងដល់រាជធម៌ផង យ៉ាងណា អនុលោមញ្ញាណនេះ កាលប្រារព្ធសង្ខារទាំងឡាយ ដោយគន្ធនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើមកើតឡើង ក៏ឈ្មោះថា អនុលោមដល់ញាណទាំង ៨ ព្រោះមានកិច្ចដូចជា ( ញាណ ៨ ) នោះផង ដល់ពោធិបក្ខិយធម៌ ៣៧ ខាងចុងផង ដូច្នោះ ព្រោះហេតុនោះឯង ទើបញ្ញាណនេះលោកហៅថា **សច្ចានុលោមិកញ្ញាណ** ( ព្រោះអនុលោមដល់មគ្គសច្ច ) ដូច្នេះ ។

អនុលោមញ្ញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយអនុលោមញ្ញាណ

ពាក្យថា **អធិមោក្ខសទ្ធា** បានដល់ ការកាត់សម្រេច គឺសម្រេចចិត្ត ដែលទៅក្នុងវត្ថុជាការជ្រះថ្លា ។ ព្រោះហេតុនោះ អធិមោក្ខសទ្ធាយ៉ាងនោះ ទើបកើតមានកម្លាំងក្រៃលែងឡើង ព្រោះមានប្រមាណក្រៃលែងដោយកិច្ច ដោយផ្សេងគ្នានៃការនា ។ ពាក្យថា **ផ្គងទុកយ៉ាងល្អ** គឺផ្គងទុកដោយល្អ ។ វីរិយៈដែលមិនធូរថយ អាចញ៉ាំញីធម៌ដែលជាបដិបក្ខដោយការៈដែលជាក់ច្បាស់ក្រៃលែងឡើង ។ ពាក្យថា **ចូលទៅតាំងនៅយ៉ាងល្អ** សេចក្ដីថា សតិជាធម៌ចូលទៅតាំងនៅដោយល្អ ជាធម៌ដែលបែរមុខត្រង់ចំពោះអារម្មណ៍ ព្រោះជាធម្មជាតិរឹងមាំក្រៃលែង ។ ពាក្យថា **តាំងមាំយ៉ាងល្អ** គឺតាំងមាំដោយល្អ ព្រោះសុខដែលកើតអំពីបស្សទ្ធិជាធម្មជាតិ មានការវិសេសក្រៃលែង បានដល់ តាំងនៅដោយប្រពៃក្នុងអារម្មណ៍នោះឯង ហាក់ដូចបានអប្បនា ។ ពាក្យថា **រឹងមាំក្រៃលែង** សេចក្ដីថា ក្លាហានដោយវិសេស ក្រៃលែងដោយការៈដែលអាចជាបច្ច័យដល់ការកើតឡើង ដោយអនុលោមញ្ញាណ ។ **សង្ខារុបេក្ខា** ដែលជាក់ខ្លួនជាកណ្ដាល សូម្បីក្នុងការពិចារណាសង្ខារទាំងឡាយ បានដល់ បញ្ញា **រមែងកើតឡើង** ។ ពាក្យថា **សង្ខារុបេក្ខាពិចារណាសង្ខារទាំងឡាយ ដោយអាការថា មិនទៀង ឬជាទុក្ខ ឬជាអនត្តាក្ដី ហើយចុះកាន់ភវង្គ** សេចក្ដីថា សង្ខារុបេក្ខាពិចារណាដោយអាការតែម្យ៉ាង ក្នុងបណ្ដាអាការទាំងឡាយ មានអាការមិនទៀងជាដើមប្រព្រឹត្តទៅ ៧ ខណៈ ហើយក៏រលត់ ឈ្មោះថា **ជាការចុះកាន់ភវង្គ** ព្រោះធ្វើអធិប្បាយថា តអំពីនោះ ជាវារៈរបស់ភវង្គ ។ ពាក្យថា **ដោយន័យដែលសង្ខារុបេក្ខាធ្វើហើយនោះឯង** សេចក្ដីថា ដោយន័យដែលធ្វើឲ្យជាអារម្មណ៍ ដោយអាការមិនទៀងជាដើមនោះឯង មិនមែន

ដោយន័យដែលបានពិចារណា ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ធ្វើឲ្យជាអារម្មណ៍** ។ ពាក្យថា **ញ៉ាំងភវង្គឲ្យវិលត្រឡប់** សេចក្តីថា បញ្ឈប់ គឺមិនឲ្យចិត្តប្រព្រឹត្តទៅដោយភវង្គ ។ សន្តតិនៃចិត្ត ឈ្មោះថា **មិនមានចន្លោះ** ព្រោះការមិនមានចន្លោះ ពោល គឺការប្រព្រឹត្តទៅនៃចិត្តដែលផ្សេងគ្នា ។ កាលមនោធាតុដែលជាកិរិយាញ៉ាំងភវង្គឲ្យវិលត្រឡប់ហើយ សន្តតិនៃចិត្តក៏នៅមានចន្លោះ គឺនៅមានប្រហោង ព្រោះការកើតឡើងនៃវិបាកចិត្ត ដោយការប្រព្រឹត្តទៅនៃចិត្ត ដែលសម្រេចដោយកិរិយា កាលមនោទ្វារាវជ្ជនៈញ៉ាំងភវង្គឲ្យត្រឡប់ហើយ មិនដូច្នោះឡើយ ហេតុនោះ ទើបលោកអាចារ្យពោលថា ជវនចិត្តដួងដំបូង **ដែលបន្តសន្តតិចិត្តដែលមិនមានចន្លោះ** ដូច្នេះ ។ ពាក្យថា **យ៉ាងនោះដូចគ្នា** សេចក្តីថា សង្ខារុបេក្ខាក្នុងជវនវិថី ៣២ ដែលជាអតីត បានធ្វើសង្ខារទាំងឡាយឲ្យជាអារម្មណ៍ថា **មិនទៀង** ក្តី ថា **ជាទុក្ខ** ក្តី ថា **ជាអនត្តា** ក្តី ( ជវនចិត្តដួងដំបូងក៏ធ្វើសង្ខារទាំងឡាយឲ្យជាអារម្មណ៍ ) យ៉ាងនោះដូចគ្នា ។ ឈ្មោះថា **លោកហៅថា បរិកម្ម** ព្រោះជាបរិកម្ម គឺព្រោះជាការតាក់តែងមគ្គឡើង ។ ឈ្មោះថា **លោកហៅថា ឧបចារៈ** ព្រោះជាធម្មជាតិជិត ឬព្រោះជាធម្មជាតិប្រព្រឹត្តទៅក្នុងទីជិតចំពោះមគ្គ ។ អត្ថថា អនុលោម លោកអាចារ្យក៏ពោលខ្ទង់នោះឯង ។

លោកអាចារ្យពោលថា **តែដោយមិនផ្សេងគ្នា** ដូច្នេះជាដើម ដើម្បីសម្តែងថា ន័យនេះលោកពោលទុកថា ជវនចិត្តដួងទី ១ ក្នុងមគ្គវិថី មានអត្ថថា តាក់តែងជវនចិត្តដួងទី ២ មានអត្ថថា ជិតជាងនោះ និងជវនចិត្តដួងទី ៣ មានអត្ថថា អនុលោម ចូលគ្នាបានជាមួយជវនចិត្តដួងខាងដើម និងដួងតទៅ ទើបសមគួរដោយពិត សូម្បីយ៉ាងនោះ ឈ្មោះទាំងនេះក៏រមែងមានដល់ចិត្តគ្រប់ដួង ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **អាសេវន** ប្រែថា សេពដោយអើពើ ។ បទថា **បុរិមភាគបច្ចិមភាគានំ**

ប្រែថា ដល់ចំណែកនៃធម៌ទាំងឡាយ ទាំងខាងដើម និងខាងចុង ។ ពាក្យថា **ទាំង ៨** គឺដល់វិបស្សនាញាណទាំង ៨ មានឧទយព្វយញ្ញាណជាដើម ។ វិបស្សនាទាំងអស់ មានកិច្ច គឺពិចារណាលក្ខណៈទាំង ៣ នោះឯង សូម្បីអនុលោមញ្ញាណនេះ ក៏យ៉ាង នោះដូចគ្នា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះមានកិច្ចដូច្នោះ** ។ ពាក្យថា **ខាងចុង** បានដល់ ក្នុងមគ្គ ។ ឈ្មោះថា **អនុលោមដល់ពោធិបក្ខិយធម៌** ព្រោះមានកិច្ចយ៉ាងនោះ គឺព្រោះកម្ចាត់ធម៌ដែលជាបដិបក្ខ មានការរាយមាយជាដើម ។ ឥឡូវនេះ លោកអាចារ្យពោលថា **ពិតហើយ អនុលោមញ្ញាណនោះ** ដូច្នេះជាដើម ដើម្បីសម្តែងការអនុលោមចំពោះកិច្ច ទាំង ២ យ៉ាងនោះនៃអនុលោមញ្ញាណដោយ ពិស្តារ ។ ក្នុងពាក្យនោះ អនុលោមញ្ញាណក្នុងជាន់ខ្ពស់បំផុត ជាទីបំផុតក្នុងពពួក លោកិយញ្ញាណ ដោយការកម្ចាត់ ដោយភាពពិសេសក្រៃលែងនូវធម៌ដែលជាបដិបក្ខ ទាំងឡាយ មានគំនរមោហៈ ដែលបិទបាំងសច្ចៈជាដើម ។ កិច្ច សូម្បីនៃញាណទាំងឡាយ មានឧទយព្វយញ្ញាណជាដើម ដែលឲ្យកើតឡើងហើយខាងក្រោមអំពីអនុលោមញ្ញាណ នោះឯង ដោយអត្ថ ក៏ជាកិច្ចដែលធ្វើឲ្យសម្រេចជាធម៌ឆ្ងាយអំពីធម៌ដែលជាបដិបក្ខ ប្រព្រឹត្តទៅ និងកិច្ចនៃញាណទាំងនោះ ដែលប្រព្រឹត្តទៅយ៉ាងនោះ រមែងដូចជា អនុលោមចូលគ្នា ហេតុនោះ ទើបលោកអាចារ្យពោលថា **ទើបឈ្មោះអនុលោម ព្រោះមានកិច្ច ដូចយ៉ាងនោះ ដូចចន្លុលប្រាប់ថា ឧទយព្វយញ្ញាណបានឃើញការ កើតឡើង និងការសូន្យទៅនៃធម៌ទាំងឡាយ មានការកើត និងការសូន្យទៅ ពិតហ្ន៎** ។បេ។ ដូច្នេះ ។ ក្នុងបណ្តាពាក្យទាំងនោះ ដោយពាក្យថា **បានប្រាកដជារបស់គួរខ្លាច** នេះ លោកអាចារ្យរមែងពោលកិច្ចរបស់ញាណ ដោយលើកអារម្មណ៍ជាធំព្រោះសម្តែង ការឃើញសភាវៈតាមសេចក្តីពិតនៃសង្ខារទាំងឡាយ ដែលមានភ័យចំពោះមុខ ។ លោកអាចារ្យបានសម្តែងកិច្ចរបស់ញាណដូចគ្នា ក្នុងឋានៈទាំង ៧ ដ៏សេស ។ ព្រោះ

អនុលោមញ្ញាណនេះ ប្រារព្ធសង្ខារទាំងឡាយ ដោយគន្ធងលក្ខណៈឯណានីមួយ បណ្ដាលក្ខណៈ មានអនិច្ចលក្ខណៈជាដើមប្រព្រឹត្តទៅ ដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះបានប្រារព្ធសង្ខារទាំងឡាយ ដោយគន្ធងលក្ខណៈ មានអនិច្ចលក្ខណៈជាដើមប្រព្រឹត្តទៅ** ។ ពាក្យថា **ដោយការបដិបត្តិនោះ** សេចក្ដីថា ការបដិបត្តិសង្កត់សង្កិលេស ដែលបិទបាំងសច្ចៈគ្រោតគ្រាតនៃអនុលោមញ្ញាណនោះ ដោយការបដិបត្តិនោះ ។ កាលអនុលោមញ្ញាណមិនទាន់កើតឡើងយ៉ាងនោះ គោត្រភូញាណ រមែងមិនអាចទាញព្រះនិព្វានឲ្យជាអារម្មណ៍ ឬកាលគោត្រភូញាណមិនទាន់កើតឡើង មគ្គញ្ញាណមិនកើតឡើងបានឡើយ ដូច្នេះ ។

ដើម្បីធ្វើអត្ថដែលបានពោលហើយឲ្យជាក់ច្បាស់ក្រៃលែងឡើង ដោយឧបមា ទើបលោកអាចារ្យផ្ដើមពាក្យថា **យថា ហិ** ជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ លះធម៌ដែលជាការបដិបត្តិតាមគួរដល់ខ្លួន ហើយបដិបត្តិចំពោះការកើតឡើង និងការសូន្យទៅជាដើម ក្នុងសង្ខារទាំងឡាយនៃញាណទាំង ៨ ប្រៀបដូច **ការលះការលំអៀង** ហើយធ្វើការវិនិច្ឆ័យក្ដីនោះ **នៃមហាមាត្យអ្នកពិភាក្សា** ទាំង ៨ នាក់ អនុលោមញ្ញាណអនុកូលដល់ចំណែកនៃធម៌មុន និងក្រោយ ប្រៀបដូចព្រះរាជា ទ្រង់ដាក់ព្រះអង្គជាកណ្ដាល ។ ពាក្យថា **ព្រោះហេតុនោះឯង** សេចក្ដីថា ព្រោះអនុលោមដល់ពោធិបក្ខិយធម៌ខាងដើម ដោយមាតិកា គឺអនុលោមដល់ញាណខាងដើមនោះឯង ។ ទើបលោកហៅថា **សច្ចានុលោមិកញ្ញាណ** ព្រោះអនុលោមដល់មគ្គសច្ច ។

អនុលោមញ្ញាណ ចប់ ។

# វិសុទ្ធិមគ្គ

## វុដ្ឋានគាមិនីវិបស្សនា

*ឯអនុលោមញ្ញាណនេះ ជាញាណចុងក្រោយនៃវុដ្ឋានគាមិនីវិបស្សនា ដែលមានសង្ខារជាអារម្មណ៍ បើពោលដោយប្រការទាំងពួង គោត្រភូញាណជាទីបំផុតនៃវុដ្ឋានគាមិនីវិបស្សនា ។*

## ឈ្មោះផ្សេងៗ នៃអនុលោមញ្ញាណ

*ឥឡូវនេះ ដើម្បីកុំឲ្យវង្វេង ( យល់ខុស ) ក្នុងវុដ្ឋានគាមិនីវិបស្សនានោះឯង ទើបគួរជ្រាបការប្រៀបធៀប ( សេចក្តីក្នុង ) ព្រះសូត្រ ( តទៅ ) នេះ សេចក្តីនេះដូចម្តេច ? គឺវុដ្ឋានគាមិនីវិបស្សនានេះ ក្នុងសឡាយតនវិភង្គសូត្រ ត្រាស់ហៅថា* **អតម្មយតា** *មិនមានតណ្ហា ដោយសុត្តបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរពឹងផ្អែកអតម្មយតា អាស្រ័យអតម្មយតា លះបង់ឈានកន្លងបង់នូវឧបេក្ខាដែលជាឯកត្ត ( មានសភាវៈ ១ ) ជាឯកត្តសិត ( អាស្រ័យអារម្មណ៍ ១ ) នេះ ដូច្នេះ ក្នុងអលគទ្ទូបមសូត្រត្រាស់ហៅថា* **និព្វិទា** *ដោយសុត្តបទដូច្នេះថា ភិក្ខុកាលនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក រមែងរួចផុត ក្នុងសុសិមសូត្រ ( និទានវគ្គ ) ត្រាស់ហៅថា* **ធម្មដ្ឋិតិញ្ញាណ** *ដឹងការតាំងនៅ គឺតាមសេចក្តីពិតនៃធម៌ ដោយសុត្តបទដូច្នេះថា ម្នាលសុសិមៈ ធម្មដ្ឋិតិញ្ញាណកើតមុន រមែងឈោងចុះក្នុងនិព្វាន ទើបកើតខាងក្រោយ ក្នុងបោដ្ឋបាទសូត្រត្រាស់ហៅថា* **សញ្ញគ្គ** *កំពូលសញ្ញា ក្នុងសុត្តបទដូច្នេះថា ម្នាលបោដ្ឋបាទ សញ្ញានេះកើតឡើងមុន ទើបញ្ញាណកើតខាងក្រោយ ក្នុងទសុត្តរសូត្រ ត្រាស់ហៅថា* **បារិសុទ្ធិបធានិយង្គ** *អង្គរបស់អ្នកប្រកប*

សេចក្ដីព្យាយាមដើម្បីសេចក្ដីបរិសុទ្ធ ដោយសុត្តបទដូច្នេះថា **បារិសុទ្ធិបធានិយង្គ** គឺបដិបទាញាណទស្សនវិសុទ្ធិ ក្នុងបដិសម្ភិទាមគ្គពោលដោយនាម ៣ យ៉ាង ដោយសុត្តបទដូច្នេះថា មុញ្ចិតុកម្យតាឯណាក្ដី បដិសង្ខានុបស្សនាឯណាក្ដី សង្ខារុបេក្ខាឯណាក្ដី ធម៌ទាំងនេះ មានអត្ថតែ ១ ផ្សេងគ្នាតែព្យញ្ជនៈ ក្នុងបដ្ឋានក៏ពោលទុក ដោយឈ្មោះ ៣ យ៉ាង ដូច្នេះថា ញាណដែលអនុលោមដល់គោត្រភូ អនុលោមដល់វោទាន ក្នុងរថវិនីតសូត្រ ហៅថា **បដិបទាញាណទស្សនវិសុទ្ធិ** ដោយសុត្តបទដូច្នេះថា ម្នាលអាវុសោ ( ប្រព្រឹត្ត ) ព្រហ្មចរិយៈក្នុងព្រះមានព្រះភាគ ដើម្បីបដិបទាញាណទស្សនវិសុទ្ធិឬ ។

វុដ្ឋានគាមិនីវិបស្សនាណាស្ងប់ស្ងាត់ ដែលព្រះមហេសី ត្រាស់សរសើរទុកដោយឈ្មោះច្រើនយ៉ាង ដូចពោលមកដូច្នេះ បុគ្គលដែលមានជាតិជាបណ្ឌិត ប្រាថ្នានឹងចេញចាកសមុទ្រភក់ គឺសង្សារទុក្ខ ដែលជាដែនមហាភ័យ គប្បីធ្វើយោគៈក្នុងវិបស្សនានោះរឿយៗ ហោង ។

បរិច្ឆេទទី ២១

ឈ្មោះបដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា

ក្នុងបករណ៍វិសុទ្ធិមគ្គ

ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយវុដ្ឋានគាមិនីវិបស្សនា

លោកអាចារ្យធ្វើវិសេសនៈថា **សង្ខារារម្មណាយ** មានសង្ខារជាអារម្មណ៍ ដូច្នេះ ព្រោះធ្វើអធិប្បាយថា សូម្បីញាណដែលមានអសង្ខតធម៌ជាអារម្មណ៍ខ្លះ ក៏រួមចូលជាមួយវុដ្ឋានគាមិនីវិបស្សនា ។ ញាណនោះ ដោយពិសេសរមែងបានការៈ ដែលគប្បីពោលថា វុដ្ឋានគាមិនី ព្រោះអត្ថថា ដល់ គឺចូលដល់វុដ្ឋាន គឺអរិយមគ្គ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ពោលដោយប្រការទាំងពួង ញាណទាំងអស់** ដូច្នេះជាដើម ។ ពាក្យថា **ដើម្បីកុំឲ្យវង្វេង** សេចក្តីថា ដើម្បីមិនមានការវង្វេងក្នុងវិបស្សនាដែលមានមកហើយ ដោយបរិយាយដទៃក្នុងព្រះសូត្រក្នុងទីនោះៗ ។ ពាក្យថា **ការប្រៀបធៀបព្រះសូត្រ** បានដល់ ការតាមប្រៀបធៀបព្រះសូត្រទាំងឡាយ គឺ បទ ព្រះសូត្រទាំងឡាយនោះៗ ។

វុដ្ឋានគាមិនីវិបស្សនា ដែលមានអនុលោមញ្ញាណជាទីបំផុតប្រារព្ធសង្ខារទាំងឡាយ ដែលជាលោកិយណា រមែងប្រព្រឹត្តទៅ តណ្ហាដែលអាស្រ័យសង្ខារទាំងនោះ ទាក់ទងដោយសង្ខារទាំងនោះ ឈ្មោះថា **តម្មយ** ព្រោះវៀរចាកសង្ខារទាំងនោះ ក៏មិនប្រព្រឹត្តទៅ **តម្មយា** នោះឯង ជា **តម្មយតា** ម្យ៉ាងទៀត **តម្មយា** គឺខន្ធទាំងឡាយ ដែលសម្បយុត្តដោយតណ្ហា ភាវៈនៃតម្មយទាំងនោះ ឈ្មោះថា **តម្មយតា** ។ តណ្ហា គឺ **តម្មយា** នោះឯង ។ វុដ្ឋានគាមិនីវិបស្សនា ដែលជាបដិបក្ខចំពោះតណ្ហានោះ ឈ្មោះថា **អតម្មយតា** ។ ដោយហេតុនោះ ទើបលោកពោលទុក **ក្នុងអដ្ឋកថា** ថា តណ្ហា ឈ្មោះថា **តម្មយតា** វុដ្ឋានគាមិនីវិបស្សនា ហៅថា **អតម្មយតា** ព្រោះទម្លាយតណ្ហានោះ ។ បទថា **និស្សាយ** សេចក្តីថា ធ្វើអធិប្បាយថា ចម្រើន **អតម្មយតា** នោះ

ឲ្យជាទីអាស្រ័យ ក្នុងបទថា **ឯកត្តា** នេះ មានព្រះបាលីដូច្នេះ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាដែលមានក្នុងរូប ។បេ។ ក្នុងផោដ្ឋព្វៈ នេះចាត់ជាឧបេក្ខា ដែលមានប្រភេទផ្សេងគ្នា ដែលអាស្រ័យអារម្មណ៍ផ្សេងគ្នា សេចក្តីថា ឧបេក្ខានេះ ក៏មានសភាពផ្សេងគ្នា អាស្រ័យអារម្មណ៍ផ្សេងគ្នា ឯឧបេក្ខានោះ គប្បីជ្រាបថា ជាឧបេក្ខាក្នុងវិបស្សនា សម្បយុត្តដោយសមាធិ ។ ម្នាមភិក្ខុទាំងឡាយ ឧបេក្ខាដែលអាស្រ័យអាកាសានញ្ចាយតនៈក៏មាន ។បេ។ ឧបេក្ខាដែលអាស្រ័យនេវសញ្ញានាសញ្ញាយតនៈក៏មាន ម្នាលភិក្ខុទាំងឡាយ នេះចាត់ជាឧបេក្ខា ដែលមានអត្តម្យ៉ាង ដែលអាស្រ័យអារម្មណ៍ម្យ៉ាង ។ អាចារ្យទាំងឡាយ រមែងពោលថា ឯឧបេក្ខាដែលទាក់ទងក្នុងអរូបចិត្តុប្បាទនោះៗ ឧបេក្ខានោះ ហៅថា ឧបេក្ខាដែលមានអត្តម្យ៉ាង និងអាស្រ័យអារម្មណ៍ម្យ៉ាង ព្រោះជាឧបេក្ខាដែលមានសភាវៈ ១ និងព្រោះមានអារម្មណ៍ ១ ។ ម្យ៉ាងទៀត ឧបេក្ខានោះ ចាត់ជាឧបេក្ខាវេទនាដែលសហគតៈដោយឈាននោះៗ និងជាឧបេក្ខាក្នុងវិបស្សនា ដែលមានអារម្មណ៍នោះ ។ ពាក្យថា **ចូរលះឧបេក្ខានោះ** សេចក្តីថា ចូរលះដោយការលះកិលេស ដែលមានឧបេក្ខានោះជាអារម្មណ៍ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ចូរលះឧបេក្ខានោះ** ។

ពាក្យថា **និព្វិទា** បានដល់ **វុដ្ឋានគាមិនី** ។ លោកអាចារ្យពោលដល់កិច្ចនៃមគ្គថា **រមែងប្រាសចាកតម្រេក** ក្នុងព្រះសូត្រនោះ ។ ពោលដល់កិច្ចនៃផលថា **រមែងរួចផុត** ។

**សុសិមសូត្រ** ក្នុងនិទានវគ្គ ក្នុងសុសិមសូត្រនោះ **ត្រាស់ហៅថា ធម្មដ្ឋិតិញ្ញាណ** បានដល់ វុដ្ឋានគាមិនី ព្រោះប្រព្រឹត្តទៅដោយអំណាចការមិនវង្វេងក្នុងការតាំងនៅនៃធម៌ ក្នុងបដិច្ចសមុប្បាទ ។ ព្រះមានព្រះភាគត្រាស់មគ្គញាណថា ការឈោងចុះក្នុងនិព្វាន ។ ព្រះមានព្រះភាគត្រាស់ថា **សញ្ញា** ដូច្នេះប៉ុណ្ណោះ ក្នុងពាក្យថា **ម្នាល**

បោដ្ឋបាទ **សញ្ញា** ដូច្នេះ នេះដោយពិត សូម្បីយ៉ាងនោះ ព្រោះបានត្រាស់ទុកថា ព្រះយោគាវចររមែងចាក់ធ្លុះកំពូលនៃសញ្ញា មុន ទើបលោកអាចារ្យពោលថា ត្រាស់ហៅថា **សញ្ញគ្គ** កំពូលសញ្ញា ដូច្នេះ ។

វុដ្ឋានគាមិនី ដែលជាចំណែក ១ នៃបដិបទាញាណទស្សនវិសុទ្ធិនោះ ត្រាស់ហៅថា **បដិបទាញាណទស្សនវិសុទ្ធិ** ។ ពិតហើយ វោហារទាំងឡាយដែលប្រព្រឹត្តទៅក្នុងចំណែករួម រមែងប្រព្រឹត្តទៅសូម្បីក្នុងចំណែកបន្តិចបន្តួច ដូច្នេះ ពាក្យថា **បារិសុទ្ធិបធានិយង្គ** បានដល់ ហេតុដែលជាប្រធាននៃសេចក្តីបរិសុទ្ធិ ។

ពាក្យថា **ដោយនាម ៣ យ៉ាង** សេចក្តីថា ដោយនាម ៣ យ៉ាង គឺអនុលោម គោត្រភូ និងវោទាន ។ ពាក្យថា **ត្រាស់សរសើរ** គឺទ្រង់លើកតម្កើង ដោយវុដ្ឋាន-គាមិនីវិបស្សនា ជាទីតាំងនៃអរិយមគ្គ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា **ព្រះមហេសី** ដោយអត្ថថា ទ្រង់ស្វែងរកគុណទាំងឡាយ មានសីលក្ខន្ធជាដើមដ៏ធំ ។ ឈ្មោះថា **ស្ងប់** ព្រោះមានកិលេសស្ងប់ហើយ ។ ពាក្យថា **យោគៈ** បានដល់ ភាវនា ឬការប្រកបក្រៃលែងក្នុងភាវនា ។

ពណ៌នាបដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ២១ ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ញាណទស្សនវិសុទ្ធិនិទ្ទេស

ខាងមុខអំពីអនុលោមញ្ញាណនេះទៅ ក៏ជាគោត្រភូញាណៗ នោះ មិនជិតបដិបទាញាណទស្សនវិសុទ្ធិ មិនជិតញាណទស្សនវិសុទ្ធិនោះឯង ព្រោះជាញាណតាំងនៅក្នុងឋានៈជាអាវជ្ជនៈនៃមគ្គ ជាអព្វោហារិកញ្ញាណក្នុងចន្លោះ ( វិសុទ្ធិទាំង ២ នោះ) នោះឯង តែព្រោះធ្លាក់នៅក្នុងក្រសែនៃវិបស្សនា ទើបរាប់ថា ជាវិបស្សនា (ដែរ) ចំណែកញាណក្នុងមគ្គ ៤ នេះ គឺសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ឈ្មោះថា ញាណទស្សនវិសុទ្ធិ ។

## បឋមមគ្គញាណ

ក្នុងមគ្គញាណ ៤ នោះ ឈ្មោះថា កិច្ចណាមួយដទៃ ដែលព្រះយោគាវចរប្រាថ្នានឹងញុំាងបឋមមគ្គញាណឲ្យដល់ព្រម នឹងត្រូវធ្វើជាលំដាប់ដំបូងមិនមាន ព្រោះថា កិច្ចណាដែលលោកគប្បីធ្វើ កិច្ចនោះ លោកជាអ្នកញុំាងវិបស្សនា មានអនុលោម-ញ្ញាណជាទីបំផុតឲ្យកើតឡើងបានសម្រេចហើយ ។ ពិតហើយ ចិត្តរបស់លោកដែលមានអនុលោមញ្ញាណកើតហើយយ៉ាងនេះ កាលងងឹតគ្រោតគ្រាតដែលបិទបាំងសច្ចៈត្រូវអនុលោមញ្ញាណទាំង ៣ នោះ ធ្វើឲ្យអន្តរធានទៅហើយ តាមគួរដល់កម្លាំងរបស់ខ្លួន រមែងមិនស្ទុះទៅ មិនឈប់នៅ មិនបង្អោនទៅ មិនជាប់ មិនជំពាក់ មិនពាក់ព័ន្ធនៅក្នុងសង្ខារទាំងពួង រមែងថយ រួញត្រឡប់វិលត្រឡប់ ដូចទឹករមៀលធ្លាក់អំពីស្លឹកឈូក ដូច្នោះ សូម្បីនិមិត្តារម្មណ៍ទាំងពួង បវត្តារម្មណ៍ទាំងពួង ក៏ប្រាកដជាគ្រឿងកង្វល់ ។

## គោត្រភូញាណ

លំដាប់នោះ កាលនិមិត្តារម្មណ៍ និងបវត្តារម្មណ៍ទាំងពួងប្រាកដជាគ្រឿងកន្លល់ដល់លោកហើយ ក្នុងទីបំផុតអំពីអាសេវនៈ នៃអនុលោមញាណ ( គឺក្នុងលំដាប់នៃអនុលោមញាណ ដែលបានមកអំពីការសេពរហូតថ្មីក ) គោត្រភូញាណ ធ្វើព្រះនិព្វានដែលមិនមាននិមិត្ត មិនមានបវត្ត ប្រាសចាកសង្ខារ ជានិរោធ ( ទីរំលត់ ) ឲ្យជាអារម្មណ៍ ក៏ឈានកន្លងបង់នូវបុថុជ្ជនគោត្រ ឈ្មោះបុថុជ្ជនទាម បុថុជ្ជនភូមិ ឈានចុះកាន់អរិយគោត្រ អរិយនាម អរិយភូមិ ជាបឋមអាវជ្ជនៈ បឋមអាភោគ (ការជញ្ជឹងគ្រាដំបូង) បឋមសមន្នាហារ (ការប្រមូលចិត្តគ្រាដំបូង) ក្នុងនិព្វានារម្មណ៍ ញុំាំងភាពជាបច្ច័យនៃមគ្គដោយអាការ ៦ ដោយអំណាចអនន្តរប្បច្ច័យ សមនន្តរ-ប្បច្ច័យ អាសេវនប្បច្ច័យ ឧបនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ឲ្យសម្រេចជាញាណដល់កំពូល ជាសីសៈនៃវិបស្សនា មិនត្រឡប់មកទៀត ( ព្រោះកើតឡើងម្ដង ) កើតឡើងដែលលោកសំដៅដល់ការពោលទុក (ក្នុងបដិសម្ភិទាមគ្គ) ថា ការដឹងក្នុងការវិលត្រឡប់ គឺចេញចាកវត្ថុខាងក្រៅ ( គឺសង្ខារ ) បានឈ្មោះថា គោត្រភូញាណដូចម្ដេច ? ការដឹងណា គ្របសង្កត់បាននូវឧប្បាទ ហេតុនេះ ការដឹងនោះ ទើបឈ្មោះថា **គោត្រភូ** ការដឹងណា គ្របសង្កត់បាននូវបវត្ត ។បេ។ នូវឧបាយាស ហេតុនោះ ការដឹងនោះ ទើបឈ្មោះ **គោត្រភូ** ការដឹងណា គ្របសង្កត់បាននូវវត្ថុខាងក្រៅ គឺសង្ខារនិមិត្ត ហេតុនេះ ការដឹងនោះ ទើបឈ្មោះថា **គោត្រភូ** ការដឹងណា ស្ទុះទៅកាន់ធម៌ដែលមិនមានឧប្បាទ ហេតុនេះ ការដឹងនោះ ទើបឈ្មោះថា **គោត្រភូ** ការដឹងណា ស្ទុះទៅកាន់ធម៌ដែលមិនមានបវត្ត ។បេ។ មិនមានឧបាយាស ជាទីរំលត់ គឺព្រះនិព្វាន ហេតុនេះ ការដឹងនោះ ទើបឈ្មោះថា **គោត្រភូ** ការដឹងណា គ្របសង្កត់

នូវឧប្បាទហើយ ស្ទុះទៅកាន់ធម៌ដែលមិនមានឧប្បាទ ហេតុនេះ ការដឹងនោះ ទើបឈ្មោះថា គោត្រភូ ដូច្នេះជាដើម សុត្តបទទាំងពួងគប្បី ( នាំមកពោល ) ឲ្យពិស្ដារចុះ ។

## ឧបមាតំណាងនៃអនុលោមញ្ញាណ និង គោត្រភូ

ក្នុងការធ្វើកិច្ចនៃអនុលោមញ្ញាណ និងគោត្រភូញាណនោះ នេះជាឧបមាសម្ដែងអាការប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ នៃអនុលោមញ្ញាណ និងគោត្រភូញាណ ដែលប្រព្រឹត្តទៅក្នុងវិថីដូចគ្នា ដោយអាវជ្ជនៈដូចគ្នា ( ដូចតទៅនេះ ) ឧបមាថា បុរសម្នាក់ប្រាថ្នានឹងលោតឆ្លងអន្លង់ធំ ( ទៅ ) ឈរត្រង់ត្រើយនាយ រត់មកដោយកម្លាំងដ៏រហ័សស្រវាខ្សែ ដែលចងសំយុងទុកត្រង់មែកឈើ ឬសសរ ( ដែលបោះទុក ) ត្រង់ត្រើយអាយនៃអន្លង់ យោលខ្លួនឡើង ហើយមានកាយ បង្អោនទៅកាន់ត្រើយនាយ រហូតដល់ចំណែកខាងលើរបស់ត្រើយនាយ ទើបលែងខ្សែនោះ មានខ្លួនញ័រ ធ្លាក់ចុះត្រង់ត្រើយនាយ ហើយទើបឈរឡើងសន្សឹមៗ យ៉ាងណា សូម្បីព្រះយោគាវចរនេះ ក៏ដូច្នោះដូចគ្នា ជាអ្នកប្រាថ្នានឹងតាំងមាំក្នុងព្រះនិព្វាន ដែលជាត្រើយនាយនៃភព កំណើត គតិ ឋិតិ និងនិវាសទាំងឡាយ ស្ទុះមកដោយកម្លាំង មានឧទយព្វយានុបស្សនាជាដើម ស្រវាខ្សែ គឺរូប (ខន្ធ) ដែលចងសំយុងនៅត្រង់មែកឈើ គឺអត្តភាព ឬត្រង់សសរ គឺនាមក្ខន្ធ មានវេទនាខន្ធជាដើមឯណានីមួយ ដោយអាវជ្ជនៈនៃអនុលោម-ញ្ញាណថា មិនទៀង ឬថា ជាទុក្ខ ឬថា ជាអនត្តា ហើយមិនទាន់លែងខ្សែ គឺរូប និងសសរ គឺនាមនោះ លោតឡើងដោយអនុលោមចិត្តដួងដំបូង ជាអ្នកមានចិត្តបង្អោនត្រង់ទៅកាន់ព្រះនិព្វាន ដោយអនុលោមចិត្តដួងទី ២ ដូចបុរសនោះ មានកាយបង្អោនត្រង់ទៅកាន់ត្រើយនាយ ដូច្នោះ ហើយក៏ជាអ្នកជិតចំពោះព្រះនិព្វានដែលគប្បីដល់ឥឡូវនេះ ដោយអនុលោមចិត្តដួងទី ៣ ដូចបុរសនោះ ( យោលខ្លួនទៅ ) ដល់ចំណែក

ខាងលើនៃត្រើយនាយ ដូច្នោះ ព្រោះការរលត់ទៅនៃចិត្តនោះ លែងអារម្មណ៍ដែលជាសង្ខារនោះ ហើយធ្លាក់ចុះទៅក្នុងព្រះនិព្វាន ដែលប្រាសចាកសង្ខារជាត្រើយនាយ ( ដោយទាញព្រះនិព្វានជាអារម្មណ៍ ) ដោយគោត្រភូចិត្ត តែព្រោះមិនទាន់មានការស៊ាំស្ទាត់ក្នុងអារម្មណ៍ ដែលទើបតែទាញយកគ្រាដំបូង ទើបមិនតាំងមាំដោយល្អ ដូចបុរសនោះញ័រខ្លួន ដូច្នោះ តអំពីនោះ ទើបតាំងមាំដោយមគ្គញាណ ដូច្នេះ ។

## ឧបមាការធ្វើកិច្ចនៃអនុលោមញាណ និងគោត្រភូញាណ

ក្នុងញាណ ២ នោះ អនុលោមញាណ អាចបន្ទោបង់ងងឹត គឺកិលេសដែលបិទបាំងសច្ចៈបាន ( តែ ) មិនអាចធ្វើព្រះនិព្វានឲ្យជាអារម្មណ៍បាន គោត្រភូញាណអាចធ្វើព្រះនិព្វានឲ្យជាអារម្មណ៍បានពិត ( តែ ) មិនអាចបន្ទោបង់ងងឹត ដែលបិទបាំងសច្ចៈបាន ( តទៅ ) នេះជាឧបមាក្នុងការធ្វើកិច្ចនៃញាណទាំង ២ នោះ ។

មានបុរសភ្នែកល្អម្នាក់ ប្រាថ្នានឹងជ្រាបនក្ខត្តយោគ ( ការជួបគ្នានៃព្រះចន្ទ និងផ្កាយ ) ចេញទៅសម្លឹងមើលព្រះចន្ទក្នុងរាត្រី ព្រះចន្ទមិនប្រាកដដល់បុរស ព្រោះត្រូវវលាហកៈបិទបាំង លុះខ្យល់មួយដុំតាំងឡើង កម្ចាត់វលាហកៈក្រាស់ទៅ ខ្យល់មួយដុំទៀត កម្ចាត់វលាហកៈកណ្តាលទៅ ខ្យល់មួយដុំទៀត កម្ចាត់វលាហកៈស្តើងៗទៅទាំងអស់ ពេលនោះ បុរសនោះ កាលផ្ទៃមេឃប្រាសចាកវលាហកៈហើយ ក៏ឃើញព្រះចន្ទជ្រាបនក្ខត្តយោគបាន ។

ក្នុងឧបមា និងឧបមេយ្យនោះ ងងឹត គឺកិលេសថ្នាក់កណ្តាល គ្រោតគ្រាត និងល្អិត ដែលបិទបាំងសច្ចៈ ប្រៀបដូចពពក ៣ ជាន់ អនុលោមចិត្ត ៣ ដូចខ្យល់ ៣ ដុំ គោត្រភូញាណ ដូចបុរសភ្នែកល្អ ព្រះនិព្វាន ដូចព្រះចន្ទ ការបន្ទោបង់ងងឹតបាំងសច្ចៈនៃអនុលោមចិត្ត ១ ដួងៗ ដូចការកម្ចាត់ពពក ៣ ជាន់ តាមលំដាប់នៃ

ខ្យល់នីមួយៗ ការដែលងងឹតបិទបាំងសច្ចៈប្រាសទៅហើយ ឃើញព្រះនិព្វានដែលបរិសុទ្ធិបាននៃគោត្រភូញាណ ដូចកាលដែលផ្ទៃមេឃប្រាសចាកពពកហើយ ឃើញព្រះចន្ទដ៏ត្រចះត្រចង់បាននៃបុរសនោះ ឯខ្យល់ ៣ ដុំ អាចកម្ចាត់តែពពកដែលបិទបាំងព្រះចន្ទបានប៉ុណ្ណោះ មិនអាចឃើញព្រះចន្ទឡើយ យ៉ាងណា អនុលោមចិត្តទាំងឡាយ ក៏អាចបន្ទោបង់តែងងឹតដែលបិទបាំងសច្ចៈបានប៉ុណ្ណោះ មិនអាចឃើញព្រះនិព្វានបានឡើយ ក៏ដូច្នោះ បុរសនោះ អាចឃើញបានតែព្រះចន្ទ តែមិនអាចកម្ចាត់ពពកបាន យ៉ាងណា គោត្រភូញាណក៏អាចឃើញព្រះនិព្វានបានប៉ុណ្ណោះ មិនអាចបន្ទោបង់ងងឹត គឺកិលេសបាន ដូច្នោះ ព្រោះហេតុនោះឯង គោត្រភូញាណនោះ ទើបលោកហៅថា **អាវជ្ជនៈនៃមគ្គ** ។

## ឧបមាមគ្គញាណអាស្រ័យសញ្ញាអំពីគោត្រភូញាណ

ពិតហើយ គោត្រភូញាណនោះ សូម្បីជាអនាវជ្ជនៈ ( គឺមិនមែនអាវជ្ជនៈ ) តែតាំងនៅក្នុងឋានៈនៃអាវជ្ជនៈ ហាក់បីដូចឲ្យសញ្ញាដល់មគ្គថា **លោកចូរកើតយ៉ាងនេះ** ហើយទើបរលត់ទៅ ។ ចំណែកមគ្គ ក៏មិនបានបោះបង់សញ្ញា ដែលគោត្រភូញាណនោះឲ្យឡើយ ជាប់តាមញាណនោះទៅ ដោយអំណាចសន្តតិមិនដាច់ខ្សែ ទម្លុះទៅទម្លាយទៅ នូវគំនរលោភៈ គំនរទោសៈ គំនរមោហៈ ដែលមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយ កើតឡើង ( តទៅ ) នេះ ជាឧបមាក្នុងសេចក្តីនោះ ។

មាននាយខ្មាន់ធ្នូម្នាក់ឲ្យរៀបចំក្តារប៉ាយទុក ១០០ បន្ទះ ក្នុងទីឆ្ងាយប្រមាណ ៨ ឧសភៈ ហើយចង ( បិទ ) មុខដោយសំពត់ ស៊កព្រួញឈរនៅលើក្តារយន្ត បុរសម្នាក់ទៀត ( ធ្វើកិច្ច ) បង្វិលក្តារយន្ត ( ចាំ ) ឲ្យសញ្ញាដោយដំបង ( គោះ ) ត្រង់ក្តារយន្តនោះ កាលបន្ទះក្តារប៉ាយនៅចំពីមុខនាយខ្មាន់ធ្នូ នាយខ្មាន់ធ្នូក៏មិនបោះ

បង់សញ្ញាដំបងចោល បាញ់ព្រួញទៅ ( មួយរំពេច ) ទម្លុះក្តារប៉ោយ ( ត្រូវ ) ទាំង ១០០ ក្នុងឧបមា និងឧបមេយ្យនោះ គោត្រភូញាណដូចសញ្ញាដំបង មគ្គញ្ញាណដូចនាយខ្មាន់ធ្នូ ការដែលមគ្គញ្ញាណមិនបោះបង់សញ្ញា ដែលគោត្រភូញាណ ផ្តល់ឲ្យធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ទម្លុះ និងទម្លាយ គំនរលោភៈ ទោសៈ មោហៈដែលមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយបាន ដូចការដែលនាយខ្មាន់ធ្នូមិនបោះបង់ សញ្ញាដំបងចោល ( បាញ់ព្រួញ ) ទម្លុះក្តារប៉ោយទាំង ១០០ ដូច្នោះ ។

## អនេកានិសង្សនៃមគ្គ

ឯមគ្គនោះ មិនត្រឹមតែធ្វើការទម្លុះគំនរកិលេស មានលោភៈជាដើមប៉ុណ្ណោះទេ តែនៅធ្វើសមុទ្រ គឺវដ្តទុក្ខក្នុងសង្សារ ដែលមានខាងដើម ខាងចុងមិនប្រាកដ ឲ្យហួតហែងទៅ បិទទ្វារអបាយទាំងពួងបាន ធ្វើការដល់ព្រមនៃអរិយទ្រព្យ ៧ បាន លះមិច្ឆាមគ្គមានអង្គ ៨ បាន ញុំាងពៀរទាំងពួងឲ្យស្ងប់រម្ងាប់បាន ថ្វាយខ្លួនជាឱរស ( កើតអំពីទ្រូង ) ដល់ព្រះសម្មាសម្ពុទ្ធបាន ហើយនៅប្រព្រឹត្តទៅ ដើម្បីបានទទួលអានិសង្សដទៃៗ ច្រើនរយ ដោយប្រការដូច្នេះ ។

ញាណដែលសម្បយុត្តនឹងសោតាបត្តិមគ្គ ដែលឲ្យអានិសង្សជាអនេក ដូចពោលមកនេះ ជាញាណក្នុងសោតាបត្តិមគ្គ ដូច្នេះ ។

បឋមមគ្គញ្ញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាញាណទស្សនវិសុទ្ធិនិទ្ទេស

## កថាពណ៌នាដោយបឋមមគ្គញ្ញាណ

ឥឡូវនេះ ដើម្បីដល់នូវលំដាប់ញាណទស្សនវិសុទ្ធិនិទ្ទេស ហើយញាណទស្សនវិសុទ្ធិនោះ រមែងកើតក្នុងលំដាប់នៃញាណណា លោកអាចារ្យកាលសម្តែងញាណនោះមុន ទើបពោលថា **ខាងមុខអំពីនេះទៅ** ក៏ជាគោត្រភូញាណ ។ ពាក្យថា **ខាងមុខអំពីនេះទៅ** គឺបន្ទាប់អំពីអនុលោមញ្ញាណនេះទៅ ។ បទថា **តំ យោគ គោត្រភុញាណំ** ប្រែថា គោត្រភូញាណនោះ ។ ឈ្មោះថា **មិនជិតបដិបទាញាណទស្សនវិសុទ្ធិ** ព្រោះមិនកាន់យកសង្ខារទាំងឡាយ ដោយអាការជារបស់មិនទៀងជាដើម ។ ឈ្មោះថា **មិនជិតញាណទស្សនវិសុទ្ធិ** ព្រោះសូម្បីកាលមាននិព្វានជាអារម្មណ៍ ក៏មិនធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ។ ព្រោះហេតុនោះឯង គោត្រភូញាណនេះ ទើបលោកពោលថា **តាំងនៅក្នុងឋានៈជាអាវជ្ជនៈនៃមគ្គ** ដូចជាកិរិយាមនោធាតុដែលធ្វើកិច្ច គឺទស្សនៈសម្តែងអារម្មណ៍នៃវិញ្ញាណធាតុទាំងឡាយ ។ ពាក្យថា **ក្នុងរវាង** គឺក្នុងកណ្តាលនៃវិសុទ្ធិទី ៦ និងទី ៧ ។ ឈ្មោះថា **ជាអព្វោហារិកញ្ញាណនោះឯង** ព្រោះការៈគឺលក្ខណៈនៃវិសុទ្ធិទាំង ២ ។ សូម្បីយ៉ាងនោះ ក៏ប្រព្រឹត្តទៅក្នុងចំណែកនៃវិបស្សនា ព្រោះជាទីបំផុតនៃវុដ្ឋានគាមិនីវិបស្សនា ។ ដោយហេតុនោះឯង គោត្រភូញាណនោះជាធម្មជាតិ ធ្លាក់នៅក្នុងក្រសែនៃវិបស្សនានោះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **តែព្រោះធ្លាក់នៅក្នុងក្រសែនៃវិបស្សនា ទើបរាប់ថា ជាវិបស្សនាដែរ** ។ ដោយពាក្យនេះ លោកអាចារ្យរមែងសម្តែងការជិតបដិបទាញាណទស្សនវិសុទ្ធិនៃគោត្រភូញាណនោះ ។ ការដល់អំពីដើមនូវអរិយមគ្គ ឈ្មោះថា **សោត** ឈ្មោះថា **សោតាបត្តិ**

សោតាបត្តិនោះឯងជាមគ្គ ម្យ៉ាងទៀត ព្រះអរិយបុគ្គលទី ១ ក៏ឈ្មោះថា **សោតាបត្តិ** ព្រោះមានអត្ថថា ដល់ គឺសម្រេចខាងដើមនូវអរិយៈ ឈ្មោះថា **សោត** ។ មគ្គរបស់ព្រះអរិយបុគ្គលទី ១ ដែលឈ្មោះថា **សោតាបត្តិនោះ** ឈ្មោះថា **សោតាបត្តិមគ្គ** ។ ព្រះអរិយបុគ្គលណា រមែងមកកាន់មនុស្សលោកនេះម្តងប៉ុណ្ណោះ ដោយអំណាចបដិសន្ធិ ហេតុនោះ ព្រះអរិយបុគ្គលនោះ ឈ្មោះថា **សកទាគាមី** មគ្គរបស់ព្រះសកទាគាមីនោះ ឈ្មោះថា **សកទាគាមិមគ្គ** ។ ព្រះអរិយបុគ្គលណា រមែងមិនមកកាន់កាមភព ដោយអំណាចបដិសន្ធិ ហេតុនោះ ព្រះអរិយបុគ្គលនោះ ឈ្មោះថា **អនាគាមី** មគ្គរបស់ព្រះអនាគាមីនោះ ឈ្មោះថា **អនាគាមិមគ្គ** ។ ព្រះអរិយបុគ្គលឈ្មោះថា អរហន្ត ព្រោះទម្លាយនូវកិលេសជាដើម បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គដ៏លើស ។ ភាវៈនៃព្រះអរហន្តនោះ ឈ្មោះថា **អរហត្ត** ។ ភាវៈនោះឯង ក៏គឺមគ្គ ហេតុនោះ ទើបឈ្មោះថា **អរហត្តមគ្គ** ។ **ញាណក្នុងមគ្គទាំង ៤ ឈ្មោះថា ញាណទស្សនវិសុទ្ធិ** ព្រោះរួមតែមួយ ។

ពីរបទថា **តេហិ តីហិបិ** លោកពោលទុក ព្រោះអនុលោមញ្ញាណទាំង ៣ លោកបានពោលទុកខាងដើម ឬព្រោះអនុលោមញ្ញាណទាំង ២ ឈោងចុះខាងក្នុងក្នុងអនុលោមញ្ញាណទាំង ៣ នោះ ។ ម្យ៉ាងទៀត **បិ**-ស័ព្ទ ក្នុងពាក្យថា **តីហិបិ** មានអត្ថរួមដល់វិកប្បដទៃទុកផង ដោយហេតុនោះ ទើបមានអធិប្បាយថា **តីហិបិ ទ្វីហិបិ** ដែលអនុលោមញ្ញាណទាំង ៣ ខ្លះ ទាំង ២ ខ្លះ ដូច្នេះ ។ ពាក្យថា **តាមគួរដល់កម្លាំងរបស់ខ្លួន** សេចក្តីថា អនុកូលដល់អានុភាពរបស់ខ្លួន រៀងៗ ខ្លួន ។ ឯអនុលោមញ្ញាណដួងទី ១ គ្រោតគ្រាតជាងគ្រប់ដួង អនុលោមញ្ញាណដួងទី ២ មិនគ្រោតគ្រាតក្រៃលែងជាងដួងទី ១ នោះ អនុលោមញ្ញាណដួងទី ៣ មិនគ្រោតគ្រាតក្រៃលែងជាងដួងទី ២ នោះ រមែងញុំាំងងងឹតឲ្យអន្តរធានទៅ ។ ម្យ៉ាងទៀត ពាក្យ

ថា **តាមគួរដល់កម្លាំង** សេចក្តីថា តាមគួរដល់កម្លាំងដែលសង្ខារុបេក្ខាកាន់យកខាងដើម ។ ភាពផ្សេងគ្នា គឺការទន់ និងការរឹងនៃអនុលោមញ្ញាណ ដោយអំណាចការតាក់តែងដំបូង ដែលសម្រេចដោយអាការប្រព្រឹត្តទៅនៃបុគ្គល ដែលជាសទ្ធាវិមុត្តិ និងទិដ្ឋិប្បត្ត ក៏មានដូចគ្នានឹងមគ្គញ្ញាណនោះឯង ។ ឈ្មោះថា **ក៏ប្រាកដជាគ្រឿងកន្លង** ព្រោះធ្វើងងឹតដែលបិទបាំងកន្លងឲ្យអន្តរធានទៅ ។ ដោយពាក្យថា **ក្នុងទីបំផុតនៃអាសេវនៈ** នេះ លោកអាចារ្យរមែងសម្តែងថា គោត្រភូញាណកើតឡើងក្នុងលំដាប់នៃអនុលោមញ្ញាណដួងទី ២ ឬដួងទី ៣ មិនមែនដួងទី ១ ព្រោះអនុលោមញ្ញាណដួងទី ១ នោះ មិនមានអាសេវនៈ ។ អនុលោមញ្ញាណ ដែលមិនបានអាសេវនៈ មិនអាចញ៉ាំងគោត្រភូញាណឲ្យកើតឡើងបានឡើយ ។ និព្វាន លោកអាចារ្យធ្វើឲ្យផ្សេងទុកដោយពាក្យថា **មិនមាននិមិត្ត** ជាដើម ព្រោះវៀរចាកនិមិត្តជាដើម និងព្រោះឆ្ងាយចាកនិមិត្តជាដើមនោះ ។ ពាក្យថា **បុថុជ្ជនគោត្រ** បានដល់ ឈ្មោះថា **បុថុជ្ជន** មិនលាយឡំជាមួយព្រះអរិយៈទាំងឡាយ ។ ពាក្យថា **គោត្រ** បានដល់ ឈ្មោះដែលស្មើគ្នារបស់មនុស្សទាំងឡាយ ដែលកើតក្នុងវង្សដូចគ្នា សូម្បីក្នុងទីនេះក៏ដូច្នោះឯង ។ ពាក្យថា **បុថុជ្ជននាម** ជាវេវចនៈរបស់ពាក្យថា **បុថុជ្ជនគោត្រ** នោះឯង ពាក្យថា **បុថុជ្ជនភូមិ** បានដល់ ទីតាំងនៃបុថុជ្ជន ។ ឈ្មោះថា **មិនវិលត្រឡប់មកទៀត** ព្រោះជាញាណដែលប្រព្រឹត្តទៅដោយចំណែកមួយ និងព្រោះកើតឡើងម្តងប៉ុណ្ណោះ ។

ពាក្យថា **ពហិទ្ធា វុដ្ឋានវិវដ្ដនេ** សេចក្តីថា បញ្ញាក្នុងការវិលត្រឡប់ដែលសម្រេចជាការចេញចាកសង្ខារ ដែលមានឈ្មោះថា **ខាងក្រៅ** ព្រោះជាខាងក្រៅនៃអសង្ខតធាតុ ។ បទថា **អភិកុយ្យតិ** ប្រែថា រមែងគ្របសង្កត់ ។ ពាក្យថា **រមែងស្ទុះទៅ** គឺរមែងចូលទៅ ។ ក្នុងអធិការនេះ ដោយពាក្យថា **គ្របសង្កត់ឧប្បាទ** ជាដើម លោកអាចារ្យពោលដល់ការគ្របសង្កត់បុថុជ្ជនគោត្រ គឺការឈានកន្លងបុថុជ្ជនគោត្រនោះ ។

ដោយពាក្យថា **ស្មុះទៅកាន់ធម៌ដែលមិនមានឧប្បាទ** ជាដើម លោកអាចារ្យពោល ដល់ការញ៉ាំងអរិយគោត្រឲ្យកើត ព្រោះជាការគ្របសង្កត់ ទាំង ២ នោះ ។

ញាណទាំងឡាយ ដែលមានអាវជ្ជនៈដូចគ្នា ជាញាណមានវិថីផ្សេងគ្នា មិនមាន ព្រោះហេតុនោះ លោកប្រើសព្ទថា វិថីដូចគ្នា ដើម្បីបដិសេធគោត្រភូញាណនោះក៏ទេ ដោយពិតនោះ គប្បីឃើញថា ដើម្បីសម្តែងថា ញាណទាំងឡាយ សូម្បីមានអារម្មណ៍ ផ្សេងគ្នា មានអាវជ្ជនៈតែមួយ ជាញាណមានវិថីផ្សេងគ្នា រមែងមិនមាន ។ ពាក្យថា **អន្លង់ធំ** បានដល់ ជ្រោះទឹកធំ ។ ពាក្យថា **លោតឆ្លង** គឺឆ្លងទៅ មិនឈប់នោះឯង ។ ពាក្យថា **យោលខ្លួនឡើង** គឺលោតទៅដោយចំណែកខាងលើនោះឯង ។ ភាពជាអ្នក បង្អោនទៅ ឱនទៅ និងតម្រង់ទៅ បានដល់ ភាពជាអ្នកបង្អោនទៅ ដែលមានភាព វិសេសក្រៃលែងឡើងៗ នោះឯង ។

អនុលោមញ្ញាណ មានភាពវិសេសដែលញាណទាំង ៨ មកតាំងហើយ ដោយ លំដាប់ អាចជាបច្ច័យដល់ញាណ មាននិព្វានជាអារម្មណ៍បាន ហេតុនោះ ទើបលោក អាចារ្យពោលថា **ស្មុះមកដោយកម្លាំង មានឧទយព្វយានុបស្សនាជាដើម** រូបជា ធម្មជាតិប្រៀបដូចខ្សែដែលវេញទុកដោយធ្ងន់មិនមែនតិច ព្រោះមានការសម្ពន្ធ ដោយ សន្តតិមិនមែនតិច ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ខ្សែ គឺរូប** ។ ព្រោះ អត្តភាព លោកបានពោលទុកដោយគួរជាទីតាំងរបស់ដើមឈើ ការគួរជាទីតាំងនៃ សសរ ដែលមានសម្ពន្ធជាមួយអត្តភាពនោះ ទើបសមគួរដល់នាមក្ខន្ធ ១ ប៉ុណ្ណោះ ក្នុងបណ្តានាមក្ខន្ធទាំងឡាយ មានវេទនាខន្ធជាដើម មិនសមគួរដល់ប្រជុំនៃនាមក្ខន្ធ មានវេទនាខន្ធជាដើមឡើយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សសរ គឺ នាមក្ខន្ធ មានវេទនាខន្ធជាដើម ខន្ធណាទីមួយ** ដូច្នេះ ។ បទថា **អនុលោមាវជ្ជនេន** ប្រែថា ដោយអាវជ្ជនៈនៃអនុលោមញ្ញាណ ។ អនុលោមញ្ញាណរមែងកើតឡើងដោយ

អាវជ្ជនៈណា នូវអារម្មណ៍នោះ ដោយអាវជ្ជនៈនោះ ។ ពាក្យថា **លោតឡើងដោយអនុលោមចិត្តដួងដំបូង** នេះ លោកពោលទុក ព្រោះអនុលោមចិត្តដួងដំបូងនោះ ជាធម្មជាតិផ្ដើមឈានកន្លងសក្កាយ ។ ពាក្យថា **ជាបុគ្គលមានចិត្តបង្អោនត្រង់ទៅកាន់ព្រះនិព្វាន ដោយអនុលោមចិត្តដួងទី ២** នេះ លោកពោលទុក ព្រោះអនុលោមចិត្តដួងទី ២ នោះ ជាធម្មជាតិមិនជាប់យ៉ាងវិសេសក្រៃលែងអំពីសង្ខារទាំងពួង តែទៅជាប់ក្នុងព្រះនិព្វានដែលប្រាសចាកសង្ខារ ។ ព្រះយោគាវចរ **រមែងធ្លាក់ចុះទៅក្នុងព្រះនិព្វាន ដោយអំណាចធ្វើឲ្យមកជាអារម្មណ៍** ។ បទថា **ឯការម្មណេ** ប្រែថា ក្នុងអារម្មណ៍ដែលទើបតែទាញយកគ្រាដំបូង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះមិនមានការស្និទ្ធស្នាល** ។ដោយពាក្យនោះ លោកអាចារ្យរមែងសម្ដែងថា ការស្និទ្ធស្នាលមានឧបការៈក្នុងអារម្មណ៍ដែលទើបតែទាញយកលើកទី ១ មិនមែនក្នុងអារម្មណ៍ផ្សេងៗ យ៉ាងនោះឡើយ ។

បទថា **តត្រ យោគ អនុលោមគោត្រភូនំ ឥតរីតរកិច្ចាករណេ** ប្រែថា ក្នុងការមិនធ្វើកិច្ចក្រៅអំពីនេះនៃអនុលោមញាណ និងគោត្រភូញាណនោះ ។ បទថា **នក្ខត្តយោគំ** ប្រែថា ការជួបគ្នានៃព្រះចន្ទ និងផ្កាយ ឬមានសេចក្ដីថា កាល គឺថ្ងៃដែលគប្បីធ្វើឲ្យជាក់ច្បាស់បាន ដោយការជួបនៃផ្កាយ ។

បទថា **តត្ថ** ជាដើម ជាពាក្យប្រៀបធៀបដោយឧបមា ។

ពីរបទថា **ឯវំ និព្វត្តាហិ** លោកអាចារ្យពោលសំដៅយកការ ដែលមគ្គមិនបោះបង់សញ្ញា ដែលគោត្រភូញាណឲ្យទុកថា លោកកុំទាញយកសង្ខារទាំងឡាយដូចអនុលោមញាណចូលទៅក្នុងអារម្មណ៍ គឺនិព្វានដូចជាយើង និងការជាប់តាម គឺការធ្វើនិព្វានឲ្យជាអារម្មណ៍នោះឯង ។

បទថា តត្រ សេចក្ដីប៉ុនគ្នានឹង តស្មិំ យោគ គោត្រភុនា ទិន្នសញ្ញំ អមុញ្ចិត្វា

វិយ តេន គហិតារម្មណេយេវ វត្តិត្វា មគ្គស្ស លោកក្ខន្ធាទិនិព្វិជ្ឈនេ ប្រែថា ក្នុងការដែលមគ្គដូចជាមិនបោះបង់សញ្ញា ដែលគោត្រភូញាណឲ្យទុក ប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលគោត្រភូញាណនោះទទួលទុកនោះឯង ហើយទម្លុះគំនរលោភៈជាដើមនោះ ។ បុគ្គលណា រមែងបន្សាត់ទៅ គឺរមែងបាញ់ទៅនូវព្រួញបែបនោះ បុគ្គលនោះ ឈ្មោះថា **ឥស្សាសោ** ប្រែថា អ្នកបន្សាត់ទៅនូវព្រួញ បានដល់ នាយខ្មាន់ធ្នូ ដែលឈ្មោះថា **ទីគោចររបស់ព្រួញ** បានដល់ ទីប្រមាណ ៨ ឧសភៈ ។ ប្រមាណ ៨ ឧសភៈនោះឯង មានអធិប្បាយថា ២០ យដ្ឋិ ដោយ ១ យដ្ឋិ ប៉ុនគ្នានឹង ៤ ហត្ថ ទាក់ទងនឹងមជ្ឈិមបុរស ដែលធ្វើឲ្យរបស់ធ្លាក់ទៅក្នុងទីជិតបាន ជា ១ ឧសភៈ **ក្នុងទីចម្ងាយប្រមាណ ៨ ឧសភៈ** បានដល់ ក្នុងទីចម្ងាយប្រមាណ ៦៤០ ហត្ថ ទាក់ទងដោយហត្ថនោះ ។ បទថា **ផលកសតំ** ប្រែថា ផែនក្តារ ១០០ បន្ទះ ដែលធ្វើដោយខ្លឹមឈើទ្វារ ។ **លើក្តារយន្ត** ដូចគ្នានឹងយន្តនៃជាងធ្នាំង ។ បទថា **អាវិជ្ឈិត្វា** ប្រែថា វិល ។ សំឡេងដែលគប្បីធ្វើឲ្យកើតឡើងដោយការគោះដំបង ឈ្មោះថា **សញ្ញាដំបង** ។ **គោត្រភូញាណ ប្រៀបដូចសញ្ញាដំបង** ដែលជាបច្ច័យដល់ការបាញ់ទម្លុះក្តារប៉ុយទាំង ១០០ ព្រោះជាបច្ច័យដល់មគ្គញាណ ដែលទម្លុះគំនរលោភៈជាដើម ។ **មគ្គញាណ ប្រៀបដូចនាយខ្មាន់ធ្នូ** ព្រោះទម្លុះគំនរកិលេសដែលគប្បីទម្លុះ ។

**រមែងញុំាងសមុទ្រ គឺវដ្តទុក្ខក្នុងសង្សារ** ដែលមានខាងដើម និងខាងចុងមិនប្រាកដ ដែលធ្វើឲ្យកើតតាំងអំពីភពទី ៨ ទៅ **ឲ្យរីងស្ងួតបាន** ។ ពាក្យថា **នៃអរិយទ្រព្យ ៧** នេះ ទ្រព្យ គឺសទ្ធា ១ ទ្រព្យ គឺសីល ១ ទ្រព្យ គឺហិរិ ១ ទ្រព្យ គឺឱត្តប្ប: ១ ទ្រព្យ គឺសុតៈ ១ ទ្រព្យ គឺចាគៈ ១ ទ្រព្យ គឺបញ្ញា ១ ។ ពាក្យថា **ចំពោះមុខ** គឺការសម្រេចដោយប្រចក្ស ។ ឈ្មោះថា **ពៀរវេរាទាំងពួង** គឺពៀរ ៥ យ៉ាង មានបាណាតិបាតជាដើម និងភ័យធំ ២៥ ។ **និងអានិសង្សដទៃៗ** បានដល់

អានិសង្ស មានសទ្ធាជាដើម ដែលតាំងមាំក្នុងព្រះរតនត្រ័យ ។ សព្ទថា សោតាបត្តិមគ្គ ដែលប្រព្រឹត្តទៅក្នុងការរួម រមែងប្រព្រឹត្តទៅក្នុងចំណែក ១ នៃសោតាបត្តិមគ្គនោះបាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ញាណដែលសម្បយុត្តដោយសោតាបត្តិមគ្គ ដូច្នេះ ។

បឋមមគ្គញាណ ចប់ ។

# វិសុទ្ធិមគ្គ

## ទុតិយមគ្គញ្ញាណ

ឯក្នុងលំដាប់នៃញាណ ( ទី ១ ) នេះ ផលចិត្ត ២-៣ ដួង ដែលជាវិបាករបស់សោតាបត្តិមគ្គចិត្តនោះឯងរមែងកើតឡើង ក៏ព្រោះលោកុត្តរកុសលទាំងឡាយមានវិបាកក្នុងលំដាប់ ( នៃខ្លួន គឺឲ្យផលភ្លាមៗ មិនមានអ្វីរារាំងបាន ) នោះឯង ទើបព្រះសាស្តាត្រាស់ទុកថា **សមាធិមានន្តរិកញ្ញមាហុ** បណ្ឌិតទាំងឡាយ ពោលសមាធិ ( ក្នុងមគ្គ ) ណាថា ជាអានន្តរិក ( ឲ្យផលក្នុងលំដាប់នៃខ្លួន) និងត្រាស់ទុកថា **ទន្ធំ អានន្តរិកំ បាបុណាតិ អាសវានំ ខយាយ** បុគ្គលណា សម្រេចអានន្តរិកសមាធិ ដើម្បីការអស់អាសវៈយឺតយូរ ដូច្នេះជាដើម ។

ចំណែកអាចារ្យពួកខ្លះពោលថា ផលចិត្ត ១-២-៣ ឬ ៤ ដួង (កើតឡើង) ពាក្យនោះ មិនគួរកាន់យក ព្រោះថា គោត្រភូញាណរមែងកើតឡើង ក្នុងទីបំផុតអំពីអាសេវនៈនៃអនុលោមញ្ញាណ ហេតុនោះ ដោយកំណត់យ៉ាងទាបបំផុត អនុលោមចិត្តត្រូវមាន ២ ដួង ព្រោះ ១ ដួង រមែងមិនបានអាសេវនប្បច្ច័យ និងអាវជ្ជនវិថី ១ រមែងមានចិត្ត ៧ ដួងយ៉ាងច្រើន ព្រោះដូច្នោះ ញាណណាមានអនុលោមចិត្ត ២ ដួង ចិត្តដួងទី ៣ នៃញាណនោះ ក៏ជាគោត្រភូ ដួងទី ៤ ជាមគ្គចិត្ត ៣ ដួងទៀតជាផលចិត្ត ញាណណាមានអនុលោមចិត្ត ៣ ដួង ចិត្តដួងទី ៤ របស់ញាណនោះក៏ជាគោត្រភូ ដួងទី ៥ ជាមគ្គចិត្ត ២ ដួងទៀតជាផលចិត្ត ព្រោះហេតុនោះ ទើបខ្ញុំពោលទុកថា ផលចិត្ត ២-៣ ដួង... រមែងកើតឡើង ។

ចំណែកអាចារ្យពួកខ្លះក៏ពោលថា ញាណណាមានអនុលោមចិត្ត ៤ ដួង ចិត្តដួងទី ៥ របស់ញាណនោះជាគោត្រភូ ដួងទី ៦ ជាមគ្គចិត្ត ១ ដួងទៀតជាផលចិត្ត

ឯពាក្យនោះ ក៏មិនគួរកាន់យកជាសារៈ ព្រោះជំទាស់បានថា ចិត្តដួងទី ៤-៥ រមែង ជាអប្បនា មិនច្រើនជាងនោះ ព្រោះជិតភវង្គ ដូច្នេះ ។

ដោយការកើតឡើងនៃផលក្នុងលំដាប់បឋមមគ្គប៉ុណ្ណេះ ព្រះយោគាវចរនោះ ក៏ជាព្រះអរិយបុគ្គលទី ២ ឈ្មោះសោតាបន្ន សូម្បីនៅជាបុគ្គលប្រមាទច្រើន ត្រាច់ទៅ ក្នុងពួកទេវតា និងពួកមនុស្ស ៧ ជាតិ ហើយក៏ជាអ្នកមានសមត្ថភាព ក្នុងការធ្វើ ទីបំផុតទុក្ខបាន ។

## បច្ចវេក្ខណៈ ១៩

តែក្នុងទីបំផុតនៃផលចិត្តរបស់ព្រះសោតាបន្ននោះ រមែងចុះកាន់ភវង្គ តអំពី នោះ ទើបមនោទ្វារាវជ្ជនៈផ្តាច់ភវង្គកើតឡើង ដើម្បីប្រយោជន៍ដល់មគ្គប្បច្ចវេក្ខណៈ ( គឺពិចារណាមគ្គ ) កាលមនោទ្វារាវជ្ជនៈនោះរលត់ហើយ ជវនសម្រាប់មគ្គប្បច្ច-វេក្ខណៈ ៧ ដួង ទើបកើតឡើងតាមលំដាប់ នៃអាវជ្ជនៈជាដើម ចុះកាន់ភវង្គទៀត ហើយកើតឡើង ដើម្បីប្រយោជន៍ដល់ការពិចារណាផលជាដើម ដោយន័យនោះៗ ឯង ព្រោះការកើតឡើងនៃអាវជ្ជនៈ និងជវនចិត្តណាសោត ទើបព្រះសោតាបន្ននោះ ពិចារណាមគ្គ ពិចារណាផល ពិចារណាកិលេសដែលលះបានហើយ ពិចារណា កិលេសដែលនៅសល់ ពិចារណានិព្វានបាន ។

ឯព្រះសោតាបន្ននោះ រមែងពិចារណាមគ្គ (ដោយន័យ) ថា អាត្មាអញមក បានដោយមគ្គនេះហ្ន៎ តអំពីនោះ ទើបពិចារណាផលថា អានិសង្សនេះ អាត្មាអញ បានហើយ តអំពីនោះ ទើបពិចារណាកិលេសដែលលះបានហើយថា កិលេសទាំង ឡាយ ឈ្មោះនេះៗ អាត្មាអញលះបានហើយ លំដាប់នោះ ទើបពិចារណាកិលេស ដែលមគ្គខាងលើ ៣ គប្បីកម្ចាត់ថា កិលេសទាំងឡាយ ឈ្មោះនេះៗ របស់អាត្មា

អញនៅសល់ និងក្នុងទីបំផុតទើបពិចារណាអមតមហានិព្វានថា ធម៌នេះ អាត្មាអញ (ដឹងច្បាស់) ចាក់ធ្លុះហើយដោយ (ធ្វើឲ្យ) ជាអារម្មណ៍ បច្ចវេក្ខណៈ ៥ រមែងមានដល់ព្រះអរិយសាវកសោតាបន្ន ដូច្នេះ បច្ចវេក្ខណៈ ៥ នោះ មានដល់ព្រះសោតាបន្ន យ៉ាងណា ក៏មានដល់ព្រះសកទាគាមី និងព្រះអនាគាមី ដូច្នោះ តែសម្រាប់ព្រះអរហន្តការពិចារណាកិលេសដែលនៅសល់មិនមានឡើយ ដោយប្រការដូច្នេះ ទាំងអស់ដូចគ្នា ទើបរាប់ជាបច្ចវេក្ខណៈ ១៩ ។ តអំពីនោះ ការកំណត់យ៉ាងខ្ពស់នោះឯងថា ការពិចារណាកិលេសដែលលះបានហើយ និងកិលេសដែលនៅសល់ រមែងមានខ្លះ មិនមានខ្លះ ដល់ព្រះសេក្ខបុគ្គលទាំងឡាយ ព្រោះមិនមានបច្ចវេក្ខណៈនោះៗ ឯង ទើបព្រះបាទមហានាមទូលសួរព្រះមានព្រះភាគថា ធម៌ (គឺកិលេស) ឈ្មោះអ្វីហ្ន៎ ដែលខ្ញុំព្រះអង្គលះមិនទាន់បានខាងក្នុង ដែលជាហេតុឲ្យលោភធម៌ទាំងឡាយ ទាញចិត្តរបស់ខ្ញុំព្រះអង្គបានក្នុងកាលខ្លះ ដូច្នេះជាដើម សុត្តបទទាំងពួង (ក្នុងសូត្រនេះ) បណ្ឌិតគួរជ្រាបដោយពិស្តារ ។

# មហាដីកា

## កថាពណ៌នាដោយសោតាបន្នបុគ្គល

*តស្សេវ យោគ សោតាបត្តិមគ្គ ចិត្តស្ស ប្រែថា របស់សោតាបត្តិមគ្គចិត្ត នោះឯង ។ ក្នុងរឿងនេះសម្រាប់បុគ្គលដែលមានបញ្ញាមិនចាស់ក្លាពេក រមែងមាន ផលចិត្ត ២ ដួង សម្រាប់បុគ្គលដែលមានបញ្ញាចាស់ក្លា រមែងមានផលចិត្ត ៣ ដួង ដោយពិត ព្រោះហេតុនោះ លោកអាចារ្យពោលថា* ***ផលចិត្ត ២-៣ ដួង*** *ដោយ អំណាចមគ្គដែលកាន់យកដោយមិនផ្សេងគ្នា ។ ពាក្យថា* ***បណ្ឌិតទាំងឡាយពោល សមាធិណាថា ជាអានន្តរិយ*** *សេចក្ដីថា ពោលសមាធិណាថា ជាអានន្តរិយសមាធិ ព្រោះឲ្យផលដោយពិតប្រាកដក្នុងលំដាប់នៃការប្រព្រឹត្តទៅរបស់ខ្លួននោះឯង ។ផល ដែលឲ្យប្រព្រឹត្តទៅក្នុងលំដាប់នោះឯង ឈ្មោះអនន្តរ ធម៌ដែលប្រកបក្នុងផលដែល ជាអនន្តរនោះ ហេតុនោះ ធម៌នោះ ឈ្មោះថា* ***អនន្តរិក*** *( ប្រកបក្នុងផល ដែលជា លំដាប់ ) ម្យ៉ាងទៀត ផលដែលជាអនន្តរនោះជាប្រយោជន៍ដល់ធម៌នេះ ហេតុនោះ ធម៌នេះ ទើបឈ្មោះថា* ***អនន្តរិក*** *( មានផលជាលំដាប់ជាប្រយោជន៍ ) បានដល់ មគ្គ ។ បទថា* ***អាសេវនន្តេ*** *ប្រែថា ក្នុងទីបំផុតអំពីអាសេវនៈ សេចក្ដីថា ក្នុង លំដាប់នៃអនុលោមញ្ញាណដែលបានអាសេវនប្បច្ច័យ ។ អនុលោមញ្ញាណដែលបាន អាសេវនប្បច្ច័យនោះឯង រមែងញ៉ាំងគោត្រភូញាណឲ្យកើតឡើង ។ បុគ្គលណាម្នាក់ ក៏គប្បីពោលបានថា តទៅ ជវនចិត្ត ៦-៧ ដួង រមែងប្រព្រឹត្តទៅ ហេតុនោះ ទើប មានផលចិត្ត ៤ ដួង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា* ***អាវជ្ជនវិថី ១ រមែងមានចិត្ត ៧ ដួងយ៉ាងច្រើន*** *ដូច្នេះ ។*

*ប្រកបសេចក្ដីថា ពាក្យនោះ មិនគួរជឿយកជាសារៈ ។ ឯពាក្យណាដែលគប្បី*

ពោលក្នុងទីនេះ ពាក្យនោះ ខ្ញុំបានពោលហើយក្នុងខាងដើមនោះឯង ។ បទថា **ឯតាវតា** ប្រែថា ដោយត្រឹមតែកើតឡើងនៃផលក្នុងលំដាប់បឋមមគ្គ ។ ពាក្យថា **សូម្បីនៅជាបុគ្គលប្រមាទច្រើន** សេចក្តីថា សូម្បីនៅជាបុគ្គលប្រមាទច្រើន ព្រោះអាស្រ័យឋានៈនៃការប្រមាទ មានជាទេវរាជ និងជាស្តេចចក្រពត្តិជាដើម ។ អធិប្បាយថា ព្រះសោតាបន្ន **នេះ** ឈ្មោះថា **បច្ចវេក្ខណៈ ព្រោះការកើតឡើង** នៃអាវជ្ជនៈ និងជវនចិត្តតាមដែលពោលហើយ **ណា** ។

ដើម្បីសម្តែងបច្ចវេក្ខណៈរបស់ព្រះអរិយៈទាំងឡាយដ៏សេស ដោយការទាក់ទងនេះឯង ទើបលោកអាចារ្យពោលថា **ឯបច្ចវេក្ខណៈ ៥ នោះ មានដល់ព្រះសោតាបន្នយ៉ាងណា** ដូច្នេះជាដើម ។

សេចក្តីថា ការសម្តែងបច្ចវេក្ខណៈ ៥ និង ៤ **នោះ ជាការកំណត់យ៉ាងខ្ពស់នោះឯង** ។ ដោយពាក្យថា **ព្រោះការមិនមាន** នេះ លោកអាចារ្យសម្តែងថា ភាពជាបុគ្គលអាចក្នុងការពិចារណាកិលេសដែលលះបានហើយ និងដែលនៅសល់ រមែងមានដល់ព្រះអរិយបុគ្គលអង្គខ្លះ មិនមានដល់ព្រះអរិយបុគ្គលអង្គខ្លះ ។ ការលោកនោះឯង ឈ្មោះថា **លោកធម៌** ។

# វិសុទ្ធិមគ្គ

## ១៣០៥ដ្ឋានភូមិ

កាលពិចារណាយ៉ាងនោះហើយ ព្រះអរិយសាវកសោតាបន្នោះ អង្គុយនៅក្នុងអាសនៈនោះឯង ឬដោយសម័យដទៃទៀត រមែងធ្វើយោគៈដើម្បីសម្រេចភូមិទី ២ **ដើម្បីការស្រាលស្តើងនៃកាមរាគៈ និងព្យាបាទ** លោកញុំាងឥន្ទ្រិយ ពល ពោជ្ឈង្គឲ្យប្រជុំគ្នា ហើយញុំាញីនូវសង្ខារដែលផ្សេងដោយរូប វេទនា សញ្ញា សង្ខារ វិញ្ញាណនោះឯង ដោយញាណ ( កំណត់ត្រៃលក្ខណ៍ ) ថា មិនទៀង ជាទុក្ខ ជាអនត្តា **បរិវត្ត** ( ការកំណត់ ) ទៅមក ( រហូត ) ឈានចុះកាន់វិបស្សនាវិថី កាលលោកបដិបត្តិទៅយ៉ាងនោះ កាលអនុលោមញាណ និងគោត្រភូញាណកើតឡើង ដោយអាវជ្ជនៈ ១ ក្នុងទីបំផុតនៃសង្ខារុបេក្ខាញាណ ដោយន័យដែលពោលហើយនោះឯង សកទាគាមិមគ្គ រមែងកើតឡើងក្នុងលំដាប់នៃគោត្រភូញាណ ញាណដែលសម្បយុត្តដោយសកទាគាមិមគ្គនោះ ឈ្មោះថា **មានក្នុងសកទាគាមិមគ្គ** ដូច្នេះ ។

ទុតិយញ្ញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយទុតិយមគ្គញ្ញាណ

ពាក្យថា ដើម្បីការស្រាលស្តើងនៃកាមរាគៈ និងព្យាបាទ គឺដើម្បីការស្រាលស្តើងនៃកិលេសទាំងនេះ ។ ក្នុងពាក្យនោះ ការស្រាលស្តើងរមែងមានដោយហេតុ ២ យ៉ាង គឺដោយការកើតឡើងរឿយៗ ១ ដោយជាអ្នកមានការបោមរោមតិច ១ ។ ពិតហើយ កិលេសទាំងឡាយ រមែងមិនកើតឡើងរឿយៗ ដល់ព្រះសកទាគាមី ដូចជាការកើតឡើងដល់បុគ្គលដ៏ច្រើន ដែលស្ទុះទៅតាមវដ្ដៈ រមែងកើតឡើងជាអាការប្រយោលៗ ម្ដងម្កាល ។ សូម្បីកាលកើតឡើងយ៉ាងនោះ ក៏មិនកើតឡើង ញុំាញីបិទបាំងធ្វើឲ្យងងឹត ក៏ព្រោះលោកលះកិលេសបានដោយមគ្គទាំង ២ ទើបកើតឡើងតិចៗ ជាអាការស្រាលស្តើង ។ ចំណែកអាចារ្យពួកខ្លះពោលថា សូម្បីព្រះសកទាគាមី កិលេសទាំងឡាយ រមែងកើតឡើងយឺតយូរ កាលកើតឡើង ក៏កើតឡើងក្រាស់ដូចគ្នា ។ និងឃើញបានដូចបុត្រធីតា គង់ប្រាកដមានដល់ព្រះសកទាគាមីនោះ ពាក្យខ្លះរបស់អាចារ្យពួកនោះ មិនមែនហេតុ ព្រោះវៀរចាកការសេពវត្ថុ ក៏គង់មានការតាំងគភ៌បាន ។ ព្រោះហេតុនោះ គប្បីជ្រាបកាមរាគៈ និងព្យាបាទស្រាលស្តើងដោយហេតុ ២ យ៉ាង តាមន័យដែលពោលហើយនោះឯង ។ ពាក្យថា ទី ២ បានដល់ ភូមិទី ២ ទាក់ទងនឹងចំនួនខ្លះ ភូមិទី ២ ទាក់ទងនឹងការកើតឡើងខ្លះ ។ ពាក្យថា ដើម្បីសម្រេច គឺដើម្បីបានសាមញ្ញផល ។ ឯសាមញ្ញផលនោះ ឈ្មោះថា ភូមិ ព្រោះអត្ថថាជាទីមាននៃធម៌ទាំងនោះ ដោយការៈជាទីអាស្រ័យ នៃសម្បយុត្តទាំងឡាយ ។ ម្យ៉ាងទៀត លោកហៅថា ភូមិ ព្រោះកាលលោកុត្តរមាន ក៏មាន គឺកើតឡើងដោយខ្លួនឯង មិនមែនជារបស់មិនប្រាកដ ដូចជាព្រះនិព្វាន ។ ពាក្យថា រមែងធ្វើយោគៈ គឺរមែងធ្វើការប្រកបក្រៃលែងនូវវិបស្សនា ។ លោករមែងញុំាងឥន្ទ្រិយទាំងឡាយចាស់ក្លាឲ្យដល់

ព្រមដោយចំណែកណា តាមន័យដែលបានពោលហើយ ដោយពាក្យជាដើមថា **ឥន្ទ្រិយទាំងឡាយជាធម្មជាតិចាស់ក្លា រមែងមានដោយអាការ ៩ យ៉ាង** ដូច្នេះ ។ កាលញ៉ាំងពលទាំងឡាយ និងពោជ្ឈង្គទាំងឡាយ ឲ្យដល់ភាពជាធម្មជាតិប្រាកដច្បាស់ក្រៃលែងឡើង ដោយចំណែកនោះ ឈ្មោះថា **ញ៉ាំងឥន្ទ្រិយ ពល និងពោជ្ឈង្គឲ្យប្រជុំគ្នាហើយ ញ៉ាំញីដោយញាណ ដោយអំណាចពិចារណាត្រៃលក្ខណ៍** ។ កាលញ៉ាំងញាណឲ្យត្រាច់ទៅក្នុងត្រៃលក្ខណ៍នោះទៅមក ឈ្មោះថា **បរិវត្ត** ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ឈានចុះកាន់វិបស្សនាវិថី** ពាក្យថា **ដោយន័យដែលពោលហើយនោះឯង** គឺតាមន័យដែលពោលហើយ ក្នុងការញ៉ាំងឧទយព្វយញ្ញាណជាដើមឲ្យកើតឡើង ។ ក្នុងពាក្យថា **ក្នុងលំដាប់នៃគោត្រភូញាណ** នេះ ញាណដូចគោត្រភូញាណ ឈ្មោះថា **គោត្រភូញាណ** ។ ឯគោត្រភូញាណដែលជាបុរេចរិកញ្ញាណនៃបឋមមគ្គ ហៅថា **គោត្រភូដោយត្រង់** ព្រោះគ្របសង្កត់បុថុជ្ជនគោត្រ និងព្រោះញ៉ាំងអរិយគោត្រឲ្យកើតមាន ចំណែកគោត្រភូញាណនេះ ឈ្មោះថា **គោត្រភូដោយអម** ព្រោះដូចគ្នានឹងគោត្រភូញាណនោះ ។ ម្យ៉ាងទៀត ហៅថា **វោទាន** ព្រោះបរិសុទ្ធនៃសង្កិលេសចំណែកខ្លះ និងព្រោះធ្វើការបរិសុទ្ធយ៉ាងពិតប្រាកដឲ្យជាអារម្មណ៍ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកក្នុង **បដ្ឋាន** ថា អនុលោមជាបច្ច័យដោយអនន្តរបច្ច័យដល់វោទាន ។ ព្រោះ **ក្នុងបដិសម្ភិទាមគ្គ** ញាណនេះមកហើយដោយឈ្មោះថា **គោត្រភូដូចគ្នា** ដូចក្នុងពាក្យថា **គោត្រភូធម៌ ៨ កើតឡើង ដោយអំណាចសមាធិ គោត្រភូធម៌ ១០ កើតឡើង ដោយអំណាចវិបស្សនា** ដូច្នេះជាដើម អាស្រ័យអត្ថថា គ្របសង្កត់ឧប្បាទជាដើម ដូច្នោះ ។ សូម្បីក្នុងទីនេះ គប្បីឃើញថា លោកអាចារ្យបានពោលទុកថា **ក្នុងលំដាប់នៃគោត្រភូញាណ** ដូច្នេះ ។

ទុតិយញ្ញាណ ចប់ ។

# វិសុទ្ធិមគ្គ

## តតិយមគ្គញ្ញាណ

ផលចិត្តក្នុងលំដាប់នៃញាណនេះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយដូចគ្នា ឯការកើតឡើងនៃផលក្នុងលំដាប់ទុតិយមគ្គត្រឹមប៉ុណ្ណេះ លោកក៏ជាព្រះអរិយបុគ្គលទី ៤ ឈ្មោះសកទាគាមីមកកាន់លោក **នេះម្តងទៀត** ក៏អាចធ្វើទីបំផុតទុក្ខបាន កាលពិចារណាតអំពីនោះទៅ ក៏មានន័យដូចពោលហើយនោះឯង ។ កាលពិចារណាយ៉ាងនោះហើយព្រះអរិយសាវកសកទាគាមីនោះអង្គុយក្នុងអាសនៈនោះឯងឬដោយសម័យដទៃទៀត រមែងធ្វើយោគៈដើម្បីត្រាស់ដឹងភូមិទី ៣ ដើម្បីលះកាមរាគៈ និងព្យាបាទមិនឲ្យសេសសល់ ។ លោកញ៉ាំងឥន្ទ្រិយ ពល និងពោជ្ឈង្គឲ្យប្រជុំគ្នាហើយញ៉ាំញីនូវសង្ខារនោះឯង ដោយញាណ ( កំណត់ត្រៃលក្ខណ៍ ) ថា សង្ខារមិនទៀងជាទុក្ខ ជាអនត្តា **បរិវត្ត** ទៅមក រហូតចុះកាន់វិបស្សនាវិថី កាលលោកបដិបត្តិទៅយ៉ាងនោះ កាលអនុលោមញ្ញាណ និងគោត្រភូញាណកើតឡើង ដោយអាវជ្ជនៈ ១ ក្នុងទីបំផុតនៃសង្ខារុបេក្ខាញាណ ដោយន័យដែលពោលហើយនោះឯង ។ អនាគាមិមគ្គរមែងកើតឡើងក្នុងលំដាប់នៃគោត្រភូញាណ ញាណដែលសម្បយុត្តដោយអនាគាមិមគ្គចិត្តនោះ ឈ្មោះថា **ញាណក្នុងអនាគាមិមគ្គ** ដូច្នេះ ។

តតិយញ្ញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយតតិយមគ្គញ្ញាណ

ពាក្យថា **ម្តងប៉ុណ្ណោះ** គឺម្តងប៉ុណ្ណោះ ។ ដោយពាក្យថា **មកកាន់លោកនេះ** នេះ លោកវៀរព្រះសកទាគាមី ៤ ពួក ក្នុងបណ្តាព្រះសកទាគាមី ៥ ពួក ហើយកាន់យកព្រះសកទាគាមីមួយពួកប៉ុណ្ណោះ ។ ព្រះសកទាគាមីអង្គខ្លះ សម្រេចសកទាគាមិផលក្នុងលោកនេះ ហើយបរិនិព្វានក្នុងលោកនេះនោះឯង ១ អង្គខ្លះ សម្រេចក្នុងលោកនេះហើយ បរិនិព្វានក្នុងទេវលោក ១ អង្គខ្លះ សម្រេចក្នុងទេវលោកហើយបរិនិព្វានក្នុងទេវលោកនោះឯង ១ អង្គខ្លះ សម្រេចក្នុងទេវលោក ហើយមកកើតក្នុងលោកនេះហើយ ទើបបរិនិព្វាន ១ ។ ទាំង ៤ ពួកនេះ លោកមិនកាន់យកក្នុងទីនេះ ។ ចំណែកព្រះសកទាគាមីណា សម្រេចក្នុងលោកនេះ ហើយនៅរហូតអស់អាយុក្នុងទេវលោក ហើយមកកើតក្នុងលោកនេះទៀត ទើបបរិនិព្វាន ព្រះសកទាគាមីនេះមួយពួកប៉ុណ្ណោះ គប្បីជ្រាបថា លោកកាន់យកក្នុងទីនេះ ។ ពាក្យថា **ដើម្បីលះកាមរាគៈ និងព្យាបាទមិនឲ្យសេសសល់** សេចក្តីថា ដើម្បីលះសំយោជនៈ ដែលបានធ្វើឲ្យស្រាលស្តើង ដោយសកទាគាមិមគ្គទាំងនោះឯង មិនឲ្យនៅសល់ ។ ឈ្មោះថា **អនាគាមី** ព្រោះមិនមកកាន់កាមភពដោយអំណាចបដិសន្ធិឡើយ ។

តតិយញ្ញាណ ចប់ ។

# វិសុទ្ធិមគ្គ

## ចតុត្ថមគ្គញ្ញាណ

ផលចិត្តក្នុងលំដាប់នៃញាណនេះ គប្បីជ្រាបដោយន័យដែលពោលហើយដូចគ្នា ឯដោយការកើតឡើងនៃផលក្នុងលំដាប់តតិយមគ្គត្រឹមប៉ុណ្ណេះ លោកក៏ជាព្រះអរិយបុគ្គលទី ៦ ឈ្មោះ **ព្រះអនាគាមី** ( មានកំណើតតទៅ ) ជាឱបបាតិក បរិនិព្វានក្នុងលោក ( សុទ្ធាវាស ) ដែលឧប្បត្តិនោះ មានការមិនត្រឡប់មកអំពីលោកនោះជាធម្មតា មិនមកកាន់លោកទៀត ដោយអំណាចបដិសន្ធិ ការពិចារណាតអំពីនោះទៅក៏មានន័យដូចពោលហើយនោះឯង កាលពិចារណាយ៉ាងនោះហើយ ព្រះអរិយសាវកអនាគាមីនោះ អង្គុយក្នុងអាសនៈនោះឯង ឬដោយសម័យដទៃទៀត រមែងធ្វើយោគៈដើម្បីត្រាស់ដឹងភូមិទី ៤ ដើម្បីលះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មិនឲ្យសេសសល់ លោកញ៉ាំងឥន្ទ្រិយ ពល និងពោជ្ឈង្គឲ្យប្រជុំគ្នាហើយ បំបាក់នូវសង្ខារនោះឯងដោយញាណ ( កំណត់ត្រៃលក្ខណ៍ ) ថា សង្ខារមិនទៀង ជាទុក្ខ ជាអនត្តា **បរិវត្ត** ទៅមក ( រហូត ) ចុះកាន់វិបស្សនាវិថី កាលលោកបដិបត្តិទៅយ៉ាងនោះ កាលអនុលោមញ្ញាណ និងគោត្រភូញាណ កើតឡើងដោយអាវជ្ជនៈ ១ ក្នុងទីបំផុតនៃសង្ខារុបេក្ខាញាណ ដោយន័យដែលពោលហើយនោះឯង អរហត្តមគ្គរមែងកើតឡើងក្នុងលំដាប់នៃគោត្រភូញាណ ញាណដែលសម្បយុត្តដោយអរហត្តមគ្គនោះ ឈ្មោះថា **ញាណក្នុងអរហត្តមគ្គ** ដូច្នេះ ។

ចតុត្ថមគ្គញ្ញាណ ចប់ ។

# មហាដីកា

## កថាពណ៌នាដោយចតុត្ថមគ្គញាណ

ពាក្យថា **ជាឱបបាតិក** គឺមានការផុសឡើងជាកំណើត ។ ដោយពាក្យនេះ លោកបដិសេធកំណើតដែលដេកក្នុងគភ៌ ដល់ព្រះអនាគាមីនោះ ។ ពាក្យថា **បរិនិព្វានក្នុងលោក ដែលឧប្បត្តិនោះ** គឺបរិនិព្វានក្នុងសុទ្ធាវាសនោះ ។ ពាក្យថា **មានការមិនត្រឡប់អំពីលោកនោះជាធម្មតា** គឺមានការមិនត្រឡប់អំពីលោកនោះ មកក្នុងលោកនេះជាសភាវៈ ដោយអំណាចការបដិសន្ធិ តែការមកដើម្បីប្រយោជន៍គាល់ព្រះសម្ពុទ្ធ និងស្តាប់ធម៌ រមែងមាននោះឯង ។

ពាក្យថា **ដើម្បីលះរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ និងអវិជ្ជាមិនឲ្យសេសសល់** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការលះឧទ្ធម្ភាគិយសំយោជនៈទាំង ៥ នេះ មិនឲ្យសេសសល់ ក្នុងបណ្តាឧទ្ធម្ភាគិយសំយោជនៈទាំង ៥ នោះ ឆន្ទរាគៈក្នុងរូបភព ឈ្មោះថា **រូបរាគៈ** ។ ឆន្ទរាគៈក្នុងអរូបភព ឈ្មោះថា **អរូបរាគៈ** ។ **មានៈ** បានដល់ មានៈដែលអរហត្តមគ្គគប្បីប្រហារ ។ **ឧទ្ធច្ចៈ និងអវិជ្ជា** ក៏ដូចគ្នា ។

ចតុត្ថមគ្គញាណ ចប់ ។

# វិសុទ្ធិមគ្គ

## អរហន្តបុគ្គល

ផលចិត្តក្នុងលំដាប់នៃញាណនេះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយដូចគ្នា ឯដោយការកើតឡើងនៃផលក្នុងលំដាប់ចតុត្ថមគ្គត្រឹមប៉ុណ្ណោះ លោកក៏ជាព្រះអរិយបុគ្គលទី ៨ ឈ្មោះព្រះអរហន្ត **ជាព្រះមហាខីណាសវៈ** ទ្រទ្រង់ទុកនូវរាងកាយចុងក្រោយ មានភារៈដាក់ចុះហើយ មានប្រយោជន៍បានសម្រេចហើយ ដោយលំដាប់មានកិលេស ជាគ្រឿងចងទុកក្នុងភពអស់ទៅហើយ ដឹងដោយប្រពៃ រួចផុតហើយជាទក្ខិណេយ្យដ៏លើសរបស់លោក ព្រមទាំងទេវលោក ដូច្នេះ ។

ដោយប្រការដូចពោលនេះ ពាក្យណាដែលខ្ញុំពោលទុក ( ដើមនិទ្ទេសនេះ ) ថា ចំណែកញាណក្នុងមគ្គ ៤ នេះ គឺសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ឈ្មោះថា **ញាណទស្សនវិសុទ្ធិ** ដូច្នេះ ពាក្យនោះ ខ្ញុំពោលសំដៅយកញាណ ៤ នេះ ដែលគប្បីសម្រេចដោយលំដាប់ ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយអរហន្តបុគ្គល

ពាក្យថា **ជាព្រះមហាខីណាសវៈ** នេះ ជាពាក្យបូជាដែលទាក់ទងដោយបុគ្គលមានអានុភាពច្រើន មិនមែនជាពាក្យប្រៀបធៀប ដូចពាក្យថា **មហាមោគ្គល្លាន** ។ ព្រោះព្រះអរិយបុគ្គល ឈ្មោះថា ចូឡខីណាសវៈមិនមានឡើយ ។ ឈ្មោះថា **ទ្រទ្រង់ទុកនូវរាងកាយចុងក្រោយ** ព្រោះអត្ថថា ទ្រទ្រង់ទុកនូវរាងកាយ មានក្នុងទីបំផុត ។ ឈ្មោះថា **មានភារៈដាក់ចុះហើយ** ព្រោះដាក់ចុះហើយ គឺព្រោះដាក់ហើយនូវភារៈ គឺខន្ធ កិលេស និងអភិសង្ខារ ។ ឈ្មោះថា **មានប្រយោជន៍ ដែលបានសម្រេចហើយដោយលំដាប់** ព្រោះអត្ថថា សម្រេចដោយលំដាប់នូវ *សទត្ថ* គឺ *សក្កត្ថ* ប្រែថា ប្រយោជន៍របស់ខ្លួន ។ ពាក្យថា *សទត្ថ* ប្រយោជន៍របស់ខ្លួន គប្បីជ្រាបថា បានដល់អរហត្តផល ។ ប្រយោជន៍របស់ខ្លួន គឺប្រយោជន៍របស់ខ្លួន ហៅថា *សក្កត្ថ* ដោយអត្ថថា ចូលទៅចងទុកនូវខ្លួន ដោយអត្ថថា មិនលះបង់ខ្លួន និងដោយអត្ថថា ជាប្រយោជន៍យ៉ាងកំពូលរបស់ខ្លួន ។ ឈ្មោះថា **មានកិលេសជាគ្រឿងចងទុកក្នុងភពអស់ហើយ** ព្រោះមានអត្ថថា មានភវសំយោជនៈទាំង ១០ អស់ទៅជុំវិញហើយ ។ ឈ្មោះថា **ដឹងប្រពៃ រួចផុតហើយ** ព្រោះមានអត្ថថា ដឹងដោយប្រពៃនូវអត្ថថា គំនរជាដើមនៃធម៌ទាំងឡាយ មានខន្ធជាដើម រួចផុតហើយ ។ ឈ្មោះថា **ជាព្រះទក្ខិណេយ្យដ៏លើស** ព្រោះមានអត្ថថា ជាព្រះទក្ខិណេយ្យដ៏លើស ឬព្រោះមានអត្ថថា គួរដល់ទក្ខិណាដ៏លើស ។

# វិសុទ្ធិមគ្គ

## អានុភាពនៃមគ្គញ្ញាណ

ឥឡូវនេះ ដើម្បីជ្រាបច្បាស់នូវអានុភាពនៃញាណ ៤ ដែលឈ្មោះថា ញាណទស្សនវិសុទ្ធិនេះឯង ។

## មាតិកា

ទើបបណ្ឌិតគួរជ្រាប ( មគ្គ ) មានពោធិបក្ខិយធម៌បរិបូណ៌ គួរជ្រាបវុដ្ឋាន ( ការចេញចាកនិមិត្ត និងបវត្ត ) និងពលសមាយោគៈ ( ការប្រកបស្មើគ្នានៃសមថពល និងវិបស្សនាពល ) គួរជ្រាបការលះធម៌ទាំងឡាយ មានញាណណាគប្បីលះ និងគួរជ្រាបកិច្ច មានបរិញ្ញាកិច្ចជាដើម ដែលលោកពោល ( ថា មានឡើង ) ក្នុងកាលដែលត្រាស់ដឹងតាមសភាវៈគ្រប់ប្រការ ដូច្នេះ ។

## ពង្រីកសេចក្តី

## ពោធិបក្ខិយធម៌

ក្នុងសេចក្តីនោះ ពាក្យថា **ការមានពោធិបក្ខិយធម៌បរិបូណ៌** គឺពោធិបក្ខិយធម៌ទាំងឡាយពេញប្រៀប ។ ឯធម៌ ៣៧ នេះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គមានអង្គ ៨ ឈ្មោះថា **ពោធិបក្ខិយ** ព្រោះជាធម៌មានក្នុងចំណែកនៃអរិយមគ្គ ដែលបានឈ្មោះថា **ពោធិ** ព្រោះអត្ថថា ជាហេតុត្រាស់ដឹង ។ ពាក្យថា **ព្រោះ... មានក្នុងចំណែក** អត្ថថា ព្រោះតាំងនៅក្នុងភាពជាធម៌ឧបការៈ ។

## អត្ថនៃសតិប្បដ្ឋាន

ក្នុងពោធិបក្ខិយធម៌ទាំងនោះ ធម៌ ឈ្មោះថា **បដ្ឋាន** ព្រោះស្ទុះចូលទៅតាំងនៅក្នុងអារម្មណ៍ទាំងឡាយ ( មានកាយជាដើម ) បដ្ឋាន គឺសតិនោះឯង ទើបបានឈ្មោះថា **សតិប្បដ្ឋាន** ។ សតិនោះ ចែកជា ៤ ប្រការ ព្រោះប្រព្រឹត្តទៅ ដោយកាន់យកអសុភាការ ( អាការមិនស្អាត ) ទុក្ខាការ អនិច្ចាការ អនត្តាការ ក្នុងកាយ វេទនា ចិត្ត ធម៌ និងដោយញុំាងកិច្ច គឺការលះសុភសញ្ញា (សម្គាល់ ថាស្អាត) សុខសញ្ញា សម្គាល់ថាជាសុខ និច្ចសញ្ញា ( សម្គាល់ថាទៀង ) អត្តសញ្ញា ( សម្គាល់ថាជាខ្លួន ) ក្នុងកាយ វេទនា ចិត្ត ធម៌នោះឲ្យសម្រេច ទើបចែកជា ៤ ប្រការ ព្រោះដូច្នោះ ទើបលោកពោលថា **អត្ថនៃសតិប្បដ្ឋាន ៤** ។

## អត្ថនៃសម្មប្បធាន ៤

ធម៌ ឈ្មោះបធាន ព្រោះជាហេតុព្យាយាម បធានដ៏ស្អាត ឈ្មោះថា **សម្មប្បធាន** ន័យម្យ៉ាងទៀត ធម៌ឈ្មោះសម្មប្បធាន ព្រោះជាហេតុព្យាយាមដោយប្រពៃ ន័យម្យ៉ាងទៀត ធម្មជាតិនោះ ឈ្មោះថា ស្អាត ព្រោះវៀរចាកវត្ថុមិនស្អាត ព្រោះកិលេស និងឈ្មោះថា **បធាន** ព្រោះនាំមកនូវភាពជាបុគ្គលប្រសើរ និងព្រោះធ្វើភាពជាប្រធានដោយអត្ថថា ញុំាងប្រយោជន៍ឲ្យសម្រេចបាន ហេតុនោះ ទើបបានឈ្មោះថា **សម្មប្បធាន** ពាក្យថា សម្មប្បធាននោះ ជាឈ្មោះរបស់វីរិយៈ សម្មប្បធាននេះ មាន ៤ ប្រការ ព្រោះញុំាងកិច្ច គឺការលះ និងមិនឲ្យកើតឡើងនៃអកុសលទាំងឡាយដែលកើតឡើងហើយ និងដែលមិនទាន់បានកើត និងញុំាងកិច្ច គឺឲ្យកើតឡើង និងតាំងនៅ ( មិនឲ្យសាបសូន្យទៅ ) នៃកុសលទាំងឡាយ ដែលនៅមិនទាន់បានកើត និងកើតហើយឲ្យសម្រេច ហេតុនោះ ទើបលោកពោលថា **សម្មប្បធាន ៤** ។

## អត្ថនៃឥទ្ធិបាទ

គុណជាតិឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថ គឺសម្រេច ដែលពោលហើយក្នុងកាលមុន ( គឺក្នុងឥទ្ធិវិធនិទ្ទេស ) ធម៌ណាជាបាទនៃឥទ្ធិ ដោយអត្ថ គឺជាប្រធាន ( គឺជាអធិបតី ) នៃសម្បយុត្តធម៌របស់ឥទ្ធិនោះ និងដោយអត្ថ គឺជាហេតុចំណែកខាងដើមនៃឥទ្ធិដែលជាផល ហេតុនេះ ធម៌នោះ ទើបឈ្មោះឥទ្ធិបាទ ។ ឥទ្ធិបាទនោះ មានវិភាគជា ៤ ដោយអំណាចធម៌ ( ដែលជាបាទ ) មានឆន្ទៈជាដើម ហេតុនោះ ទើបលោកពោលថា **ឥទ្ធិបាទ ៤** ដូចបាលីថា **ចត្តារោ ឥទ្ធិបាទា ឆន្ទិទ្ធិបាទោ វីរិយិទ្ធិបាទោ ចិត្តិទ្ធិប្បាទោ វិមំសិទ្ធិបាទោ** ឥទ្ធិបាទ ៤ គឺឥទ្ធិបាទ គឺឆន្ទៈ ឥទ្ធិបាទ គឺវីរិយៈ ឥទ្ធិបាទ គឺចិត្ត ឥទ្ធិបាទ គឺវិមំសា ដូច្នេះ ។ ធម៌ មានឆន្ទៈជាដើម នេះជាលោកុត្តរពិត ចំណែកដែលជាលោកិយ សូម្បីជាធម៌ ( ដូចជាផស្សៈ ) ដែលបានដោយអំណាចឆន្ទាធិបតីជាដើម ក៏រាប់ជាឥទ្ធិបាទ ដោយបាលីថា បើភិក្ខុនាំឆន្ទៈឲ្យជាអធិបតី បានសមាធិ បានឯកគ្គតាចិត្តសោត នេះហៅថា **ឆន្ទសមាធិ** ដូច្នេះជាដើម ។

## អត្ថនៃឥន្ទ្រិយ និង ពល

ធម៌ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថ គឺជាធំ បានដល់ គ្របសង្កត់ ( អកុសល ) បាន ព្រោះគ្របសង្កត់នូវអស្សទ្ធិយ គឺការមិនជឿ **កោសជ្ជៈ** គឺការខ្ជិលច្រអូស **បមាទៈ** គឺការខ្វះសតិ **វិក្ខេបៈ** គឺការរាយមាយ និង **សម្មោហៈ** គឺការវង្វេងមិនដឹងសេចក្ដីពិត ។ ម្យ៉ាងទៀត **ធម៌** ឈ្មោះពល ព្រោះអត្ថ គឺមិនគប្បីញាប់ញ័រ ព្រោះអកុសលមានអស្សទ្ធិយជាដើម មិនគប្បីគ្របសង្កត់បាន ទាំង ២ យ៉ាងនោះ មានវិភាគជា ៥ ដោយអំណាចធម៌ មានសទ្ធាជាដើម ហេតុនោះ ទើបលោកពោលថា **ឥន្ទ្រិយ ៥ ពល ៥** ។

## អត្ថនៃពោជ្ឈង្គ និង អង្គមគ្គ

ធម៌ ៧ មានសតិជាដើម ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃសត្វដែលត្រាស់ដឹង ( អរិយសច្ច ៤ ) ម្យ៉ាងទៀត ធម៌ ៨ មានសម្មាទិដ្ឋិជាដើម ឈ្មោះថាជាអង្គមគ្គ ព្រោះអត្ថ គឺជានិយ្យានិក ( នាំចេញចាកសង្សារវដ្ត ) ហេតុនោះ ទើបលោកពោលថា ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ ។

## ពោធិបក្ខិយធម៌មានក្នុងចិត្តផ្សេងៗ គ្នា និងក្នុងចិត្ត ១ ដួង

ពោធិបក្ខិយធម៌ ៣៧ ដូចពោលមកនេះ រមែងមានបានក្នុងចិត្តផ្សេងៗ ក្នុងបុព្វភាគដូច្នេះ គឺកាលលោកិយវិបស្សនាកំពុងប្រព្រឹត្តទៅ កាយានុបស្សនាសតិប្បដ្ឋាន រមែងមានដល់ព្រះយោគាវចរ ដែលកំណត់កាយដោយអាការ ១៤ វេទនានុបស្សនាសតិប្បដ្ឋាន រមែងមានដល់បុគ្គលដែលកំណត់វេទនា ដោយអាការ ៩ ចិត្តានុបស្សនាសតិប្បដ្ឋាន រមែងមានដល់បុគ្គលដែលកំណត់ចិត្ត ដោយអាការ ១៦ និងធម្មានុបស្សនាសតិប្បដ្ឋាន រមែងមានដល់បុគ្គល ដែលកំណត់ធម៌ទាំងឡាយ ដោយអាការ ៥ សម្មប្បធានទី ១ រមែងមានក្នុងកាលដែលឃើញអកុសល ដែលមិនធ្លាប់កើត ( ដល់ខ្លួន ) ក្នុងអត្តភាពនេះ (តែ) កើតដល់បុគ្គលដទៃ ទើបគិតថា អកុសលនោះកើតដល់បុគ្គលដទៃដែលបដិបត្តិ យ៉ាងណា អាត្មាអញនឹងមិនបដិបត្តិយ៉ាងនោះ កាលបើដូច្នោះអកុសល ក៏នឹងមិនកើតដល់អញដូច្នេះហើយ ព្យាយាមដើម្បីមិនឲ្យអកុសលនោះកើតឡើង សម្មប្បធានទី ២ រមែងមានក្នុងកាលដែលឃើញអកុសល ដែលដល់នូវការកើតឡើងដល់ខ្លួនហើយ ព្យាយាមលះអកុសលនោះចេញ សម្មប្បធានទី ៣ រមែងមានដល់បុគ្គលព្យាយាម ដើម្បីញុំាងឈាន ឬវិបស្សនាជាដើម ដែលមិនធ្លាប់កើតក្នុងអត្តភាពនេះឲ្យកើតឡើង សម្មប្បធានទី ៤ រមែងមានដល់បុគ្គលញុំាងឈាន

ឬវិបស្សនាដែលកើតឡើងហើយឲ្យកើតឡើងរឿយៗ មិនឲ្យវិនាសទៅ ។ ឥទ្ធិបាទមានឆន្ទិទ្ធិបាទជាដើម រមែងមានក្នុងកាលដែលធ្វើឥទ្ធិបាទ មានឆន្ទិទ្ធិបាទជាដើមនោះៗឲ្យជាធុរៈ ញ៉ាំងកុសលឲ្យកើតឡើង សម្មាវាចាជាដើម រមែងមានក្នុងការដែលវៀរចាកមិច្ឆាវាចាជាដើម ( នេះពោធិបក្ខិយធម៌ មានក្នុងចិត្តផ្សេងៗ ) តែក្នុងកាលដែលញាណ ៤ នេះ ( មានសោតាបត្តិមគ្គញាណជាដើម ) កើតឡើង ធម៌ទាំងនោះ មានក្នុងចិត្ត ១ ដួង វៀរសម្មប្បធាន ៤ នៅសល់ ៣៣ រមែងមានក្នុងខណៈនៃផលចិត្ត ។ ក្នុងធម៌ទាំងនោះ ដែលមានក្នុងចិត្ត ១ ដួងយ៉ាងនេះ សតិដែលមានព្រះនិព្វានជាអារម្មណ៍ ក៏ដូចគ្នានោះឯង លោកហៅថា សតិប្បដ្ឋាន ៤ ក៏ព្រោះញ៉ាំងកិច្ច គឺការលះសុភសញ្ញាជាដើមក្នុងអារម្មណ៍ មានកាយជាដើមឲ្យសម្រេច វិរិយៈក៏ដូចគ្នានោះឯង លោកហៅថា សម្មប្បធាន ៤ ក៏ដោយធ្វើកិច្ច មានញ៉ាំងអកុសលទាំងឡាយដែលមិនទាន់កើត មិនឲ្យកើតឡើងជាដើមឲ្យសម្រេច តែក្នុងចំណែកដ៏សេស ( ៥ មានឥទ្ធិបាទជាដើម ) ការបន្ថយ ( ដោយសង្ខេបចូលគ្នា ដូចការដែលសង្ខេប ហៅថា សតិប្បដ្ឋាន សម្មប្បធាន ) និងការបន្ថែម ( ដោយបំបែកចេញទៅ ដូចចែកជាកាយានុបស្សនាជាដើម ) ក៏ទេ ។

## វិភាគពោធិបក្ខិយធម៌ ៦ ប្រការ

វិភាគម្យ៉ាងទៀត ក្នុងពោធិបក្ខិយធម៌ ៣៧ នោះ ដូច្នេះ

**ធម៌ទាំងឡាយនោះ ជា ៦ ប្រការ គឺធម៌ ៩ ជាប្រការ ១ ធម៌ ១ ជាពីរយ៉ាង ម្យ៉ាងទៀត ធម៌ ១ ជាបួនយ៉ាង ជាប្រាំយ៉ាង ជាប្រាំបីយ៉ាង និងជាប្រាំបួនយ៉ាង ។** ពាក្យថា ធម៌ ៩ យ៉ាង ជាប្រការ ១ អធិប្បាយថា ធម៌ ៩ នេះ គឺឆន្ទៈ ចិត្ត បីតិ បស្សទ្ធិ ឧបេក្ខា សង្កប្ប វាចា កម្មន្តៈ អាជីវៈ ជាម្យ៉ាងប៉ុណ្ណោះ ព្រោះ

( ធន្ទៈក៏ ) ជាធន្ទិទ្ធិបាទ ( តែម្យ៉ាង ) ជាដើម មិនចូលក្នុងចំណែកដទៃ ( គឺមិនជាដទៃទៀត ) ពាក្យថា ធម៌ ១ ជាពីរយ៉ាង បានដល់ សទ្ធាតាំងនៅក្នុងតំណែង ២ យ៉ាង ជាឥន្ទ្រិយ និងពល ។

ពាក្យថា ម្យ៉ាងទៀត ធម៌ ១ ជាបួនយ៉ាង ជាប្រាំយ៉ាង ដោយអត្ថថា ម្យ៉ាងទៀត ធម៌ ១ តាំងនៅក្នុងឋានៈ ៤ យ៉ាង ន័យម្យ៉ាងទៀត តាំងនៅក្នុងឋានៈ ៥ យ៉ាង ក្នុងឋានៈទាំង ២ នោះ សមាធិតែ ១ តាំងនៅក្នុងឋានៈ ៤ យ៉ាង ដោយជាឥន្ទ្រិយ ពល ពោជ្ឈង្គ និងជាអង្គមគ្គ, បញ្ញាតាំងនៅក្នុងឋានៈ ៥ យ៉ាង ៤ យ៉ាង ដូចពោលហើយ និង ១ ចំណែក ( ទៀត ) ជាឥទ្ធិបាទ ។

ពាក្យថា ធម៌តែ ១ មានឋានៈ ៨ យ៉ាង និង ៩ យ៉ាង ដោយអត្ថថា ម្យ៉ាងទៀត ធម៌ ១ តាំងនៅក្នុងឋានៈ ៨ យ៉ាង មួយទៀត តាំងនៅក្នុងឋានៈ ៩ យ៉ាង គឺសតិតាំងនៅក្នុងឋានៈ ៨ យ៉ាង ជាសតិប្បដ្ឋាន ៤ ឥន្ទ្រិយ ពល ពោជ្ឈង្គ អង្គមគ្គ, វិរិយៈ តាំងនៅក្នុងឋានៈ ៩ យ៉ាង ដោយជាសម្មប្បធាន ៤ ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ អង្គមគ្គ ដូច្នេះ ។ ដោយន័យដែលពោលមកនេះ

**ពោធិបក្ខិយធម៌ទាំងនោះ ដែលមិនលាយឡំគ្នា មាន ១៤ ប៉ុណ្ណោះ** ( ពោល ) **ពោលដោយចំណែកជា ៧,** ( ពោល ) **ដោយប្រភេទ មាន ៣៧ ធម៌ទាំងអស់នោះ ដូចគ្នា រមែងមានព្រមក្នុងខណៈអរិយមគ្គកើតផង** ( ធ្វើ ) **កិច្ចរបស់ខ្លួន រៀងៗ ខ្លួនឲ្យសម្រេច និងដោយប្រព្រឹត្តទៅ មានរូបស្មើគ្នា** ( គឺធម៌សាមគ្គី ) **ដូច្នេះ ។**

មគ្គ មានពោធិបក្ខិយធម៌បរិបូណ៌ ក្នុងញាណទស្សនវិសុទ្ធិនេះ គប្បីជ្រាបដោយប្រការដូចពោលមកនេះជាលំដាប់ដំបូង ។

# មហាដីកា

## កថាពណ៌នាដោយពោធិបក្ខិយធម៌

ឈ្មោះថា មានញាណ ៤ ដោយអំណាចមគ្គញ្ញាណទាំង ៤ ។ ពាក្យថា គប្បីជ្រាបច្បាស់នូវអានុភាព ដើម្បីឲ្យដឹងអានុភាព មានសម្បូរនៃសតិប្បដ្ឋានជាដើម ។ ពោធិបក្ខិយធម៌ទាំងឡាយរបស់ធម៌នេះ បរិបូណ៌ ហេតុនោះ ធម៌នេះ ឈ្មោះថា **មានពោធិបក្ខិយធម៌បរិបូណ៌** បានដល់ មគ្គ ។ ភាវៈនៃមគ្គ ដែលមានពោធិបក្ខិយធម៌បរិបូណ៌នោះ ឈ្មោះថា **ការមានពោធិបក្ខិយធម៌បរិបូណ៌** ។ ភាពជាធម៌ដែលប្រកបដោយវុដ្ឋាន និងពល ឈ្មោះថា **វុដ្ឋានពលសមាយោគ** **ធម៌ពួកណា** គឺធម៌ទាំងឡាយមានសំយោជនៈជាដើម **ដែលញាណណា** គឺដែលបឋមមគ្គញ្ញាណជាដើម **គប្បីលះ**។

ម្យ៉ាងទៀត ការកើតឡើងនៃមគ្គចិត្ត ឈ្មោះថា **ពោធិ** ព្រោះអត្ថថា ជាគ្រឿងត្រាស់ដឹង ។ ធម៌ទាំងឡាយ មានក្នុងចំណែកនៃការកើតឡើងនៃមគ្គចិត្តនោះ ព្រោះជាគុណដ៏សមគួរដល់ការត្រាស់ដឹង ហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា **ពោធិបក្ខិយ** ។

**តេសុ** **យោគ** **ពោធិបក្ខិយេសុ** ប្រែថា ក្នុងពោធិបក្ខិយធម៌ទាំងនោះ ។ ពាក្យថា **ក្នុងអារម្មណ៍ទាំងឡាយ** បានដល់ ក្នុងអារម្មណ៍ មានកាយជាដើម ។ បទថា **ឱក្កន្ទិត្វា** ប្រែថា ចូលទៅ ។ បទថា **បក្ខន្ទិត្វា** ជាវេវចនៈរបស់បទថា **ឱក្កន្ទិត្វា** នោះ ។ ពាក្យថា **ព្រោះចូលទៅតាំងនៅ** គឺព្រោះចូលទៅតាំងចុះ ដោយអំណាចកាន់យកអាការមិនស្អាតជាដើម ។ការកាន់យកអាការមិនស្អាតជាដើមក្នុងអារម្មណ៍ មានកាយជាដើម គប្បីជ្រាបការទាក់ទងគ្នាជាសតិប្បដ្ឋាន ដែលជាបុព្វភាគការញុំាងកិច្ច គឺការលះសុភសញ្ញាជាដើម គប្បីជ្រាបការទាក់ទងជាសតិប្បដ្ឋាន ដែលជាមគ្គ ។ ក្នុងសតិប្បដ្ឋាននោះ សតិតែម្យ៉ាងនោះឯង រមែងប្រព្រឹត្តទៅដោយអំណាចការញុំាងកិច្ច

៤ យ៉ាងឲ្យសម្រេច ។

បទថា **បទហន្តិ** ប្រែថា រមែងព្យាយាម ឬសេចក្តីថា ផ្គងកាយ និងចិត្ត ។ ឈ្មោះថា **ស្អាត** ព្រោះលះបាននូវសង្កិលេសធម៌ទាំងឡាយ ដែលជាហេតុនៃការមិនស្អាត ព្រោះញ៉ាំងវោទានធម៌ទាំងឡាយ ដែលជាហេតុនៃការស្អាត ឲ្យកើតនោះឯង ដោយអត្ថថា ល្អ ។ ពាក្យថា **ព្រោះនាំមកនូវភាពជាបុគ្គលប្រសើរឧត្តម** គឺព្រោះឲ្យសម្រេចជាបុគ្គលគួរសរសើរពន់ពេក ។ ពាក្យថា **ព្រោះជាហេតុនៃភាពជាប្រធាន** គឺ ព្រោះជាហេតុនៃភាពជាបុគ្គលឧត្តម ។

ពាក្យថា **ដែលពោលហើយពីមុន** គឺដែលពោលហើយ ក្នុងឥទ្ធិវិធញ្ញាណនិទ្ទេស ។ **ឥជ្ឈន្តដ្ឋោ** ប្រែថា អត្ថ គឺសម្រេច ឬបានដល់ ការដល់ព្រមនៃការបានចំពោះ ម្យ៉ាងទៀត សត្វទាំងឡាយរមែងចម្រើន គឺជាបុគ្គលចម្រើនរុងរឿងជាបុគ្គលឧត្តមដោយគុណជាតិណា គុណជាតិនោះ ឈ្មោះថា **ឥជ្ឈន្តំ** ប្រែថា ជាហេតុចម្រើន ។ មគ្គធម៌ទាំងឡាយដែលមានសមាធិបធានសង្ខារជាប្រធាន លោកបំណងយកថា **ឥទ្ធិ** ក្នុងទីនេះ ។

**អត្ថ គឺជាប្រធាន** បានដល់ ជាអធិបតិប្បច្ច័យ ។ ព្រោះហេតុនោះ ទើបសោតាបត្តិមគ្គ ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច ព្រោះហេតុនោះ ធម៌ទាំងឡាយមានឆន្ទៈជាដើម ដែលសម្បយុត្តគ្នា ឈ្មោះថា **ជាបាទ ដោយអត្ថ គឺជាប្រធាន** ។ ធម៌ទាំងឡាយ មានឆន្ទៈជាដើមនៃវុដ្ឋានគាមិនីវិបស្សនា ឈ្មោះថា **ជាបាទ ដោយអត្ថ គឺជាហេតុចំណែកខាងដើមនៃឥទ្ធិដែលជាផល** នោះៗ ឯង ។ បទថា **សោ យោគ ឥទ្ធិបាទោ** ប្រែថា ឥទ្ធិបាទនោះ ។ ពាក្យថា **ធម៌ មានឆន្ទៈជាដើមនេះ ជាលោកុត្តរពិត** សេចក្តីថា ធម៌ មានឆន្ទៈជាដើម តាមដែលពោលមក ហើយនេះ គប្បីជ្រាបថា ជាលោកុត្តរពិត តាមន័យដែលពោលមកហើយ ក្នុងឧត្តរចូឡភាជនីយ ។ សេចក្តីថា

សូម្បីធម៌ដែលបានដោយអំណាចអធិបតី មានឆន្ទាធិបតីជាដើម គឺធម៌ មានផស្សៈជាដើម ក៏ជាឥទ្ធិបាទ ។ ក្នុងអធិការនេះ ឥទ្ធិបាទមិនជាអធិបតី ឬអធិបតីមិនឈ្មោះថាជាឥទ្ធិបាទ រមែងមិនមានដោយពិត សូម្បីយ៉ាងនោះ ឧបមាដូចក្នុងការសោយរាជ្យមួង បណ្ដារាជកុមារទាំង ៤ អង្គ ដែលគួរដល់រាជសម្បត្តិក្នុងកាលមួង ក៏គ្រងរាជ្យតែមួយអង្គប៉ុណ្ណោះ មិនមែនគ្រប់អង្គ យ៉ាងណា ក្នុងចិត្តុប្បាទ ១ ដួង ក៏គប្បីជ្រាបថា មានអធិបតី និងឥទ្ធិបាទតែ ១ ដូចគ្នា ដូច្នោះ ។

**អស្សទ្ធិយ** បានដល់ អកុសលធម៌ទាំងឡាយ ដែលជាបដិបក្ខចំពោះសទ្ធា ឬបានដល់ មិច្ឆាធិមោក្ខ ដែលជាការជ្រះថ្លាក្លែងក្លាយ ដែលមិនប្រព្រឹត្តទៅក្នុងវត្ថុ ។ **កោសជ្ជៈ** បានដល់ អកុសលចិត្តុប្បាទ មានថីនមិទ្ធៈជាប្រធាន ។ **បមាទៈ** បានដល់ការភ្លេចសតិ គឺអកុសលក្ខន្ធទាំងឡាយ ដែលប្រព្រឹត្តទៅដោយប្រការនោះ ។ ពាក្យថា **ដោយអត្ថ គឺភាពជាធំ** បានដល់ ការគ្របសង្កត់បាន ដោយអត្ថ គឺជាធំ ក្នុងសម្បយុត្តធម៌ទាំងឡាយ ដែលមានលក្ខណៈដូចគ្នានឹងអធិមោក្ខ ( សទ្ធា ) **បគ្គហៈ** ( សេចក្ដីព្យាយាម ) **ឧបដ្ឋាន** ( សតិ ) **អវិក្ខេប** ( សមាធិ ) និង **បជានន** ( បញ្ញា ) ដែលគប្បីពោលបានថា គ្របសង្កត់ ព្រោះគ្របសង្កត់អកុសលធម៌ទាំងឡាយ មានអស្សទ្ធិយជាដើម ច-ស័ព្ទ ក្នុងពាក្យថា **អស្សទ្ធិយាទីហិ ច** ជា **សមុច្ចយដ្ឋ** ជា **អង្គានប្បយុត្ត** ព្រោះហេតុនោះ គប្បីជ្រាបអធិប្បាយក្នុងពាក្យនេះ យ៉ាងនេះថា ធម៌ឈ្មោះថា **ពល** ព្រោះអត្ថ គឺមិនគប្បីញាប់ញ័រ និងព្រោះភាវៈដែលមាំទាំក្នុងសម្បយុត្តធម៌ទាំងឡាយ ។

ពាក្យថា **នៃសត្វដែលត្រាស់ដឹង** គឺនៃសត្វដែលចាក់ធ្លុះអរិយសច្ច ៤ ។ ពិតហើយ ព្រះអរិយសាវក លោកហៅថា **ពោធិ** ព្រោះមានអត្ថថា **ភ្ញាក់** គឺក្រោកឡើងអំពីការនិទ្រា គឺកិលេសសន្តាន ឬព្រោះមានអត្ថថា ត្រាស់ដឹង គឺចាក់ធ្លុះអរិយសច្ច

៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ដោយសាមគ្គីធម៌ មានសតិជាដើម ដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គដែលជាហេតុ ធម៌ទាំងឡាយដែលជាអង្គនៃព្រះអរិយសាវក ដែលឈ្មោះថា **ពោធិ** នោះ ឈ្មោះថា នៃសត្វដែលត្រាស់ដឹង ហេតុនោះធម៌ទាំងនោះឈ្មោះថា **ពោជ្ឈង្គ** ។ ពាក្យថា **ដោយអត្ថ គឺជានិយ្យានិក** ដោយអត្ថ គឺរលាស់ចេញទៅអំពីវដ្ដៈ ។

ក្នុងសេចក្ដីថា **បុព្វភាគេ នានាចិត្តេសុ លព្ភន្តិ** ប្រែថា រមែងបានក្នុងចិត្តផ្សេងៗ ក្នុងបុព្វភាគ ។ ពាក្យថា **ដោយអាការ ១៤** គឺដោយអាការ ១៤ យ៉ាងនេះ គឺអានាបានបព្វៈ ឥរិយាបថបព្វៈ ចតុសម្បជញ្ញបព្វៈ បដិកូលមនសិការបព្វៈ ធាតុមនសិការបព្វៈ និងនវសីវថិកាបព្វៈ ។ **ឯកាយានុបស្សនាសតិប្បដ្ឋាន** រមែង បានដល់ **ព្រះយោគាវចរដែលកំណត់កាយ** មិនមែនបានដល់ព្រះយោគាវចរដែលកំណត់វេទនាជាដើមឡើយ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។ **ដោយអាការ ៩ យ៉ាងនេះ** គឺដោយអាការជាដើមថា **អញសោយសុខវេទនា** ជាដើម ឬថា ដោយអាការថា **អញសោយវេទនាមានអាមិស** ជាដើម ឬដោយអាការថា **អញសោយសុខវេទនាមិនមានអាមិស** ជាដើម ។ **ដោយអាការ ១៦** គឺ **សរាគបទ** ក្នុងពាក្យថា ដោយចិត្តមានរាគៈ **សទោសបទ** ក្នុងបទថា ដោយចិត្តមានទោសៈ **សមោហបទ** ក្នុងបទថា ដោយចិត្តមានមោហៈ **សង្ខិត្តបទ** ក្នុងបទថា ដោយចិត្តរួញរា **មហគ្គតបទ** ក្នុងបទថា ដោយចិត្តជាមហគ្គតៈ **សមាហិតបទ** ក្នុងបទថា ដោយចិត្តជាសមាធិ **សឧត្តរបទ** ក្នុងបទថា ចិត្តមានចិត្តដទៃក្រៃលែងជាង និង **វិមុត្តិបទ** ក្នុងបទថា ចិត្តរួចផុត ព្រមទាំងបទដែលជាបដិបក្ខគ្នា ។ **ដោយអាការ ៥** គឺនីវរណបព្វៈ ឧបាទានក្ខន្ធបព្វៈ អាយតនបព្វៈ ពោជ្ឈង្គបព្វៈ និងសច្ចបព្វៈ ។ ពាក្យថា **ក្នុងអត្តភាពនេះ** គឺក្នុងអត្តភាពបច្ចុប្បន្ន ។ ពាក្យថា **ដែលមិនធ្លាប់កើតឡើង** គឺដែលមិនធ្លាប់មានដល់ខ្លួន ។ **ឃើញអកុសលដែលកើតឡើង**

ដល់អ្នកដទៃ អធិប្បាយថា អកុសលធម៌មានទោសដែលគួរដល់ការសម្លាប់ និងការដាក់ទោសជាដើម ដែលមានអកុសលនោះជាហេតុ ។ បទថា **តស្ស** សេចក្តីប៉ុនគ្នានឹង **តាទិសស្ស** ប្រែថា អកុសលដែលមានសភាពដូច្នោះ ។ ឯអាហារទាក់ទងនឹងសត្វ រមែងចុះក្នុងអត្តប៉ុនគ្នានឹង **តំ សទិស** ប្រែថា ដូចគ្នានឹងរឿងនោះក៏បាន ដូចពាក្យថា **តានិ យេវ ឱសថានិ** ប្រែថា ថ្នាំទាំងឡាយ ដូចជាថ្នាំបន្ទុះនោះឯង ។ សូម្បីក្នុងពីរបទថា **តស្ស បហានាយ** នេះ ក៏មានន័យនេះដូចគ្នា ។ ឈាន និងវិបស្សនា សូម្បីធ្លាប់កើតឡើងក្នុងអត្តភាពដទៃអំពីអត្តភាពនេះ ក៏គប្បីមាន ហេតុនោះ ទើបលោកអាចារ្យពោលថា **ដែលមិនធ្លាប់កើតឡើងក្នុងអត្តភាពនេះ** ដូច្នេះ លោកកាន់យកឆន្ទិទ្ធិបាទ និងសម្មាវាចានោះឯង ។ កាលពោលដល់ឥទ្ធិបាទទាំងនោះហើយ ក៏រមែងជាការពោលដល់ឥទ្ធិបាទដ៏សេស និងវិរតិដ៏សេស ដោយអត្ថផងដែរ ព្រោះហេតុនោះគប្បីជ្រាបអត្ថនេះ ទាក់ទងនឹងលក្ខណៈអាហារ ។ សតិប្បដ្ឋាន សម្មប្បធាន និងឥទ្ធិបាទទាំងនេះ ក្នុងបុព្វភាគ **រមែងមានបានក្នុងចិត្តផ្សេងៗ យ៉ាងនេះ** ។ ពាក្យថា **ញាណ** ៤ បានដល់ ញាណ ក្នុងអរិយមគ្គទាំង ៤ ។ ពោធិបក្ខិយធម៌ទាំងនោះ ទាក់ទងដោយចិត្តុប្បាទក្នុងមគ្គនោះឯង ដោយពិត សូម្បីយ៉ាងនោះ កិច្ចនៃសម្មប្បធានដែលមានការពិសេសក្រៃលែង មាននៅក្នុងខណៈនៃមគ្គ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងខណៈនៃផលវៀរសម្មប្បធានទាំង ៤** ដូច្នេះ ។ **ពោធិបក្ខិយធម៌ ៣៣ ដ៏សេស រមែងមានបាន** អធិប្បាយថា ឯពោធិបក្ខិយធម៌ទាំងនោះ មានបានដោយអមមិនមែនដោយត្រង់ឡើយ ។

ពាក្យថា **សូម្បីក្នុងចំណែកដ៏សេស** គឺក្នុងចំណែកទាំង ៥ មានឥទ្ធិបាទជាដើម ។ អធិប្បាយថា បណ្តាសតិ និងវីរិយៈ ការបន្ថយដោយសង្ខេបថា **សតិប្បដ្ឋាន សម្មប្បធាន** ដូច្នេះ ការបន្ថែមដោយសម្តែងវិភាគជាដើមថា **កាយានុបស្សនា** ដូច្នេះ មាន

យ៉ាងណា ការបន្ថយ និងការបន្ថែម ដូច្នេះមិនមាន ។

ឥឡូវនេះ លោកអាចារ្យបានផ្ដើមពាក្យថា **អបិ ច** ន័យម្យ៉ាងទៀត ដូច្នេះជាដើម ដើម្បីសម្ដែងវិភាគដែលបានតាមគួរ ក្នុងពោធិបក្ខិយធម៌ទាំងអស់នោះឯង ។ បណ្ដាបទទាំងនោះ បទថា **តេសុ ឯវ សត្តតឹសាយ ពោធិបក្ខិយធម្មេសុ** ប្រែថា ក្នុងពោធិបក្ខិយធម៌ ៣៧ នោះ ។ បទថា **ធម្មា** សេចក្ដីថា **ធម៌ទាំងនោះ មាន ៦** ប្រការយ៉ាងនេះ គឺធម៌ ១ ធម៌ ២ យ៉ាង ធម៌ ៤ យ៉ាង ធម៌ ៥ យ៉ាង ធម៌ ៨ យ៉ាង ធម៌ ៩ យ៉ាង ។ ពាក្យថា **ជាឆន្ទិទ្ធិបាទ** ជាដើម សេចក្ដីថា **ធម៌ ៩ យ៉ាង ជាធម៌ម្យ៉ាង** យ៉ាងនេះ គឺឆន្ទៈ ជាឆន្ទិទ្ធិបាទតែម្យ៉ាង ចិត្ត ជាចិត្តិទ្ធិបាទតែម្យ៉ាង បីតិ បស្សទ្ធិ និងឧបេក្ខា ក៏ជាពោជ្ឈង្គតែម្យ៉ាង ធម៌ទាំងឡាយ មានសង្កប្បជាដើមក៏ជាមគ្គតែម្យ៉ាង ។

ពាក្យថា **ដែលមានការលាយឡំគ្នា មាន ១៤ ប៉ុណ្ណោះ** សេចក្ដីថា ពោធិបក្ខិយធម៌ទាំងនេះ គឺសតិ វីរិយៈ ឆន្ទៈ ចិត្ត បញ្ញា សទ្ធា សមាធិ បីតិ បស្សទ្ធិ ឧបេក្ខា សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ មិនលាយឡំគ្នា ជាសភាវធម៌ ១៤ ប៉ុណ្ណោះ ដែលលោកកាន់យកធម៌ ដែលមិនបានកាន់យក វៀរចាកការលាយឡំនឹងបទដទៃ ។ ឯពាក្យថា ១៤ លោកពោលដោយកំណត់យ៉ាងខ្ពស់ ។ ឯពាក្យនោះឯង ទាក់ទងនឹងមគ្គចិត្តុប្បាទដែលប្រកបដោយបឋមជ្ឈាន ចំណែកក្នុងមគ្គចិត្តុប្បាទ ដែលប្រកបដោយទុតិយជ្ឈាន មានពោធិបក្ខិយធម៌ ១៣ ព្រោះមិនមានសម្មាសង្កប្ប ក្នុងមគ្គចិត្តុប្បាទ ដែលប្រកបដោយតតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន មានពោធិបក្ខិយធម៌ ១២ ព្រោះមិនមានបីតិសម្ពោជ្ឈង្គ ។ សូម្បីពាក្យថា **ដោយប្រភេទ មាន ៣៧** នេះ លោកក៏ពោលទុកដោយកំណត់យ៉ាងខ្ពស់ដូចគ្នា តែបើកំណត់យ៉ាងទាប គប្បីជ្រាបថា ពោធិបក្ខិយធម៌ មាន ៣៦ និង ៣៥ ក្នុងខណៈ ១ តាមន័យដែលបានពោលហើយ និងមាន ៣២ ព្រោះឥទ្ធិបាទ ១ ប៉ុណ្ណោះ មាន

ក្នុងខណៈ ១ ព្រោះអធិបតីទាំង ៤ មិនកើតឡើងព្រមគ្នា ។

លោកអាចារ្យពោលថា **ដោយធ្វើកិច្ចរបស់ខ្លួនឲ្យសម្រេច** ដូច្នេះជាដើម អធិប្បាយថា ដោយធ្វើកិច្ចនោះៗ មានកាយានុបស្សនាជាដើម ដែលសមគួរដល់អានុភាពរបស់ខ្លួន នៃពោធិបក្ខិយធម៌ ១ ឲ្យសម្រេចតាមសភាវៈរបស់ពោធិបក្ខិយធម៌ខ្លះៗ ដូច្នេះ ដើម្បីចៀសវាងនូវពាក្យសួរថា ពោធិបក្ខិយធម៌ ៣៧ ពោលដោយប្រភេទដូចម្តេច ។ ពាក្យថា **និងដោយប្រព្រឹត្តទៅ មានរូបស្មើគ្នា** គឺដោយប្រព្រឹត្តទៅមានរូបស្មើគ្នានោះឯង នៃធម៌ មានចិត្តុប្បាទជាដើម ដែលមិនផ្សេងគ្នា ។

បទថា **ឯត្ថ យោគ ញាណទស្សនវិសុទ្ធិយំ** ប្រែថា ក្នុងញាណទស្សនវិសុទ្ធិនោះ ។ សួរថា ព្រោះហេតុអ្វី ទើបក្នុងពោធិបក្ខិយធម៌ទាំងឡាយ លោកមិនបានកាន់យកចំណែកនៃឈានទុកដោយអរិយមគ្គ វៀរចាកឈានមិនមាន មិនមែនឬ ? ឆ្លើយថា ពិត មិនមាន ព្រោះហេតុនោះឯង ទើបសេចក្តីនេះ មិនគួរឃើញយ៉ាងនេះថា **ក្នុងពោធិបក្ខិយធម៌ លោកមិនបានកាន់យកឈានទុក** ព្រោះឈានដែលមានលក្ខណៈចូលទៅសម្លឹងលក្ខណៈ លោកកាន់យកដោយស័ព្ទថា មគ្គនោះឯង ។ ទ្រង់សំដៅយកពាក្យនោះ ទើបត្រាស់ពាក្យជាដើមថា **ភិក្ខុរមែងចម្រើនឈានដែលជាលោកុត្តរ ក្នុងសម័យណា** ដូច្នេះ ។ ក្នុងទីនេះ ការកើតឡើងនៃឈានដែលមានលក្ខណៈចូលទៅសម្លឹងអារម្មណ៍នោះឯង មិនមាន ។ ន័យម្យ៉ាងទៀត

បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបលោកមិនបានកាន់យកចំណែកនៃឈានទុកក្នុងពោធិបក្ខិយធម៌ អរិយមគ្គ វៀរចាកឈានមិនមាន មិនមែនឬ ម្យ៉ាងទៀត ឈាននោះប្រព្រឹត្តទៅក្នុងចំណែកខាងដើម ១ ដូចគ្នានឹងបដិបទាក៏ទេ ទាំងចំណែកនៃឈាន និងផលនៃមគ្គ ដូចជាបដិសម្ភិទាខ្លះក៏ទេ ដោយពិតនោះ ចំណែកនៃឈានទាក់ទងដោយមគ្គចិត្តុប្បាទ ព្រោះព្រះសាស្តាបានត្រាស់ទុកថា **ភិក្ខុរមែងចម្រើនឈាន**

ដែលជាលោកុត្តរ ដូច្នេះ និងធម៌ គឺមគ្គ និងជាបរិវាររបស់មគ្គ ចាត់ជាពោធិបក្ខិយធម៌ ដូច្នេះឬ ? សេចក្តីនេះ ចម្លើយដូច្នេះ

ពាក្យណា ដែលលោកពោលទុកអំពីមុនថា **អរិយមគ្គ វៀរចាកឈានមិនមាន** ដូច្នេះ ក្នុងពាក្យនោះ រមែងមិនបានភាពដែលឈានជាពោធិបក្ខិយធម៌ ដោយត្រឹមតែការប្រកបដោយអរិយមគ្គ ព្រោះការទាក់ទងគ្នាយ៉ាងក្រៃលែង ។ ព្រោះសូម្បីធម៌ទាំងឡាយ មានអាហារជាដើម ក៏ត្រូវជាពោធិបក្ខិយធម៌ ។ ដោយពាក្យនេះ រមែងត្រូវសម្តែងថា ការទាក់ទងដោយមគ្គចិត្តុប្បាទ មិនមែនព្រោះពោធិបក្ខិយធម៌ ។ ចំណែកពាក្យណា ដែលលោកពោលទុកថា **ធម៌ គឺមគ្គផង ដែលជាបរិវារ របស់មគ្គផង ចាត់ជាពោធិបក្ខិយធម៌** ដូច្នេះ ក្នុងពាក្យនោះ សួរថា អត្ថនៃពាក្យថា បរិវារ មានអត្ថថា ប្រព្រឹត្តទៅរួមគ្នា ឬមានអត្ថថា តាក់តែង ? បើជាចំណែកដំបូង ចំណែកដំបូងនោះក៏អស់រឿងដែលពោលមុន បើជាចំណែកទី ២ សេចក្តីនេះ គួរពិចារណា ។ ឈានដែលប្រព្រឹត្តទៅដូចម្តេច ទើបតាក់តែងមគ្គ ។ បើប្រព្រឹត្តទៅ ជាបច្ច័យ មានសហជាតប្បច្ច័យជាដើម កាលបើយ៉ាងនេះ ធម៌ទាំងឡាយ មានផស្សៈជាដើម ក៏ត្រូវជាគ្រឿងតាក់តែងមគ្គ ។ បើប្រព្រឹត្តទៅដោយការកម្ចាត់ធម៌ដែលជាបដិបក្ខ ធម៌ គឺឈានទាំងអស់ អាចក្នុងការកម្ចាត់ធម៌ដែលជាបដិបក្ខក៏ទេ ព្រោះវិចារៈ និងវេទនា ក៏រមែងប្រព្រឹត្តទៅជាបដិបក្ខចំពោះសង្កិលេសធម៌ខ្លះៗ ក៏ទេ ។ម្យ៉ាងទៀត ពាក្យណា ដែលព្រះមហាកច្ចានៈពោលទុកក្នុងគម្ពីរ **បេដកោបទេស** ថា សុខ ជាបដិបក្ខចំពោះឧទ្ធច្ចៈ និងកុក្កុច្ចៈ វិចារៈ ជាបដិបក្ខចំពោះវិចិកិច្ឆា ដូច្នេះ ពាក្យនោះ លោកពោលទុកដោយអម ។ ព្រោះថា សុខ ជាបដិបក្ខចំពោះ ឧទ្ធច្ចៈ កុក្កុច្ចៈ ក៏មិនមែន តែជាបដិបក្ខជាបច្ច័យចំពោះសមាធិដែលជាបដិបក្ខគ្នា ។ វិចារៈ ជាបដិបក្ខចំពោះវិចិកិច្ឆា ដូចជាបញ្ញា ឬដូចជាអធិមោក្ខក៏ទេ តែលោកពោលថា ជាបដិបក្ខ ព្រោះជាធម៌សមគួរ

ដល់ធម៌ដែលជាបដិបក្ខគ្នា ។ សូម្បីបីតិ ក៏ដូចគ្នា មិនមែនជាបដិបក្ខចំពោះព្យាបាទ ដូចជាអទោសៈឡើយ តែលោកពោលថា ជាបដិបក្ខ ព្រោះប្រកបដោយអទោសៈ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ពាក្យនោះ លោកពោលទុកដោយអម** ។ ម្យ៉ាងទៀត វិតក្ក និងសមាធិនោះឯង អាចកម្ចាត់ធម៌ដែលជាបដិបក្ខ ដោយត្រង់ក្នុងធម៌ គឺឈានទាំងឡាយ ព្រោះហេតុនោះ ទើបលោកមិនធ្វើការសង្គ្រោះឈាននោះទុកក្នុងពោធិបក្ខិយធម៌ ព្រោះមិនមានចំណែកនៃឈានបរិបូណ៌ ដែលអាចកម្ចាត់ធម៌ដែលជាបដិបក្ខបាន ។ ព្រោះសម្មាសង្កប្ប និងសម្មាសមាធិ ជាធម៌ គឺឈានដែលទាក់ទងនៅក្នុងមគ្គ ដូច្នោះ ទើបទ្រង់សំដៅយកសម្មាសង្កប្ប និងសម្មាសមាធិទាំងនោះ ឬព្រោះជាធម៌សម្បយុត្តដោយសម្មាសង្កប្ប និងសម្មាសមាធិនោះ ទើបទ្រង់បានកាន់យកធម៌ក្រៅអំពីនេះ ត្រាស់ដោយអម **ក្នុងព្រះបាលី** ជាដើមថា ក្នុងសម័យណា ភិក្ខុចម្រើនឈាន ដែលជាលោកុត្តរ នាំចេញចាកសង្សារវដ្ត ដូច្នេះ ។

# វិសុទ្ធិមគ្គ

## វុដ្ឋាន និង ពលសមាយោគ

បទថា វុដ្ឋានពលសមាយោគ ប្រែថា វុដ្ឋាន ( ការចេញ ) និងពលសមាយោគ ( ការប្រកបព្រមដោយពល ) ។

## វុដ្ឋាន

ព្រោះថា លោកិយវិបស្សនាមិនទាន់បានចេញអំពីនិមិត្ត ព្រោះនៅមាននិមិត្ត ( គឺសង្ខារ ) ជាអារម្មណ៍ និងមិនទាន់បានចេញអំពីបវត្ត ព្រោះនៅកាត់សមុទយៈដែលជាហេតុនៃបវត្តដាច់ គោត្រភូក៏មិនទាន់បានចេញអំពីបវត្ត ព្រោះមិនទាន់កាត់សមុទយៈដាច់ តែចេញចាកនិមិត្តបាន ព្រោះមានព្រះនិព្វានជាអារម្មណ៍ ហេតុនេះទើបគោត្រភូញាណនោះ ជាឯកតោវុដ្ឋាន ( ចេញដោយចំណែកមួយ ) ព្រោះដូច្នោះទើបលោកពោលទុក ( ក្នុងបដិសម្ភិទាមគ្គ ) ថា បញ្ញាក្នុងការបរិវត្ត ដោយចេញចាកអារម្មណ៍ខាងក្រៅ ជាគោត្រភូញាណ ដូចគ្នានោះដែរ ពាក្យបាលីទាំងពួងជាដើមថា ព្រោះបរិវត្តចាកការកើតឡើង ស្ទុះទៅកាន់ការមិនកើតឡើង ទើបឈ្មោះគោត្រភូ ព្រោះបរិវត្តចាកបវត្ត... ដូច្នេះ ក៏គួរជ្រាបផងដែរ ។

ចំណែកញាណទាំង ៤ នេះ ឈ្មោះថា ចេញអំពីនិមិត្តបាន ព្រោះមិនបានមាននិមិត្តជាអារម្មណ៍ ឈ្មោះថា ចេញចាកបវត្តបាន ព្រោះកាត់សមុទយៈដាច់ ហេតុនេះញាណទាំង ៤ នេះ ទើបជាឧភតោវុដ្ឋាន ( ចេញទាំង ២ ចំណែក ) ព្រោះដូច្នោះទើបលោកពោលទុក ( ក្នុងបដិសម្ភិទាមគ្គ ) ថា បញ្ញាក្នុងការបវត្ត ដោយចេញចាកចំណែកទាំង ២ ជាញាណក្នុងមគ្គ ដូចម្តេច ? ក្នុងខណៈសោតាបត្តិមគ្គ ធម៌

ឈ្មោះសម្មាទិដ្ឋិ ដោយអត្ថ គឺការដឹង ( អរិយសច្ច ) រមែងចេញចាកមិច្ឆាទិដ្ឋិ រមែងចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះ និងចាកខន្ធទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះផង ទាំងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ ទើបបានពោលថា បញ្ញាក្នុងការបដិវត្ត ដោយចេញចាកចំណែកទាំង ២ ជាញាណក្នុងមគ្គ ធម៌ ឈ្មោះសម្មាសង្កប្ប ដោយអត្ថ គឺការដោត ( ចិត្ត ) ចុះទៅចំពោះ រមែងចេញចាកមិច្ឆាសង្កប្ប... ធម៌ ឈ្មោះសម្មាវាចា ដោយអត្ថ គឺការពោលត្រូវ (នៃវាចា) រមែងចេញចាកមិច្ឆាវាចា... ធម៌ ឈ្មោះសម្មាកម្មន្ត: ដោយអត្ថ គឺការតាំងឡើងល្អ ( នៃការងារ) រមែងចេញចាកមិច្ឆាកម្មន្ត:... ធម៌ ឈ្មោះសម្មាអាជីវ: ដោយអត្ថ គឺការស្អាត ( នៃអាជីវ: ) រមែងចេញចាកមិច្ឆាជីវ:... ធម៌ ឈ្មោះសម្មាវាយាម: ដោយអត្ថ គឺការផ្គង ( ចិត្ត ) ទុក រមែងចេញចាកមិច្ឆាវាយាម:... ធម៌ ឈ្មោះសម្មាសតិ ដោយអត្ថ គឺការតាំងមាំ ( នៃសតិ ) រមែងចេញចាកមិច្ឆាសតិ... ធម៌ ឈ្មោះសម្មាសមាធិ ដោយអត្ថ គឺការមិនរាយមាយទៅ រមែងចេញចាកមិច្ឆាសមាធិ រមែងចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាសមាធិនោះ និងអំពីខន្ធទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាសមាធិនោះផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ ទើបបានពោលថា បញ្ញាក្នុងការបដិវត្ត ដោយចេញចាកចំណែកទាំង ២ ជាញាណក្នុងមគ្គ ។

ក្នុងឋាន:នៃសកទាគាមិមគ្គ ធម៌ ឈ្មោះសម្មាទិដ្ឋិ ដោយអត្ថ គឺការឃើញ ( អរិយសច្ច )...ធម៌ ឈ្មោះសម្មាសមាធិ ដោយអត្ថ គឺការមិនរាយមាយទៅ ( នៃចិត្ត ) រមែងចេញចាកកាមរាគសំយោជន: ដែលគ្រោតគ្រាតអំពីបដិឃសំយោជន: ដែលគ្រោតគ្រាតចាកកាមរាគានុស័យ ដែលគ្រោតគ្រាតចាកបដិឃានុស័យ ដែលគ្រោតគ្រាត... ក្នុងខណ:នៃអនាគាមិមគ្គ ធម៌ ឈ្មោះសម្មាទិដ្ឋិ ដោយអត្ថ គឺការឃើញ

( អរិយសច្ច )... ធម៌ ឈ្មោះសម្មាសមាធិ ដោយអត្ថ គឺការមិនរាយមាយទៅ ( នៃចិត្ត ) រមែងចេញចាកកាមរាគសំយោជនៈដែលល្អិត ចាកបដិឃសំយោជនៈដែលល្អិត ចាកកាមរាគានុស័យដែលល្អិត ចាកបដិឃានុស័យ ដែលល្អិត... ក្នុងខណៈនៃអរហត្តមគ្គ ធម៌ ឈ្មោះសម្មាទិដ្ឋិ ដោយអត្ថ គឺការឃើញ ( អរិយសច្ច )... ធម៌ ឈ្មោះសម្មាសមាធិ ដោយអត្ថ គឺការមិនរាយមាយទៅ ( នៃចិត្ត ) រមែងចេញចាករូបរាគៈ ចាកអរូបរាគៈ ចាកមានះ ចាកឧទ្ធច្ចៈ ចាកអវិជ្ជា ចាកមានានុស័យ ចាកភវរាគានុស័យ ចាកអវិជ្ជានុស័យ រមែងចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអវិជ្ជានុស័យនោះ និងចាកខន្ធទាំងឡាយដែលប្រព្រឹត្តទៅតាមអវិជ្ជានុស័យនោះផង ទាំងចេញចាកនិមិត្តទាំងពួង ខាងក្រៅផង ព្រោះហេតុនោះ ទើបបានពោលថា បញ្ញាក្នុងការបដិវត្ត ដោយចេញចាកចំណែកទាំង ២ ជាញាណក្នុងមគ្គ ដូច្នេះ ។

## ពលសមាយោគៈ

ក្នុងកាលដែលបំពេញសមាបត្តិ ៨ ដែលជាលោកិយ សមថពល រមែងមានកម្លាំងក្រៃលែង ក្នុងកាលដែលបំពេញវិបស្សនា មានអនិច្ចានុបស្សនាជាដើម វិបស្សនាពល រមែងមានកម្លាំងក្រៃលែង តែក្នុងខណៈនៃមគ្គ ធម៌ ( ទាំង ២ ) នោះ ឈ្មោះថា ជាគូគ្នាប្រព្រឹត្តទៅ ( ដូចនឹង ) ព្រោះអត្ថថា មិនប្រព្រឹត្តទៅលើសខ្វះគ្នានឹងគ្នា ហេតុនោះ ពលសមាយោគៈទាំង ២ ទើបមានក្នុងញាណទាំង ៤ នេះ ដូចបាលីថា កាលមគ្គចេញចាកកិលេសទាំងឡាយ ដែលសហគតៈនឹងឧទ្ធច្ចៈ និងចាកខន្ធទាំងឡាយ សមាធិ គឺឯកគ្គតានៃចិត្ត ការមិនរាយមាយនៃចិត្ត រមែងមាននិរោធជាគោចរ (គឺមាននិព្វានជាអារម្មណ៍) កាលមគ្គចេញចាកកិលេសទាំងឡាយ ដែលសហគតៈជាមួយអវិជ្ជា និងចាកខន្ធទាំងឡាយ វិបស្សនា ដោយអត្ថ គឺពិចារណា

ឃើញ ( តាមសេចក្ដីពិត ) ក៏មាននិរោធជាគោចរ ( គឺមាននិព្វានជាអារម្មណ៍ដូចគ្នា ) ដូច្នេះ សមថៈ និងវិបស្សនា ទើបជាធម៌មានដូចគ្នា ( មានកិច្ចស្មើគ្នា ) ដោយអត្ថថា ចេញ ( អំពីនិមិត្ត និងបវត្តដូចគ្នា ) ជាធម៌គូគ្នា មិនប្រព្រឹត្តទៅលើសខ្វះគ្នា ដូច្នេះ ហេតុនោះ ទើបបានពោលថា ព្រះយោគាវចរចម្រើនសមថៈ និងវិបស្សនាឲ្យជាគូគ្នា ដោយអត្ថ គឺចេញ ( អំពីនិមិត្ត និងបវត្តដូចគ្នា ) ។

វុដ្ឋាន និងពលសមាយោគៈ ក្នុងញាណទស្សនវិសុទ្ធិនេះ គប្បីជ្រាបដូចពោលមក ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយវុដ្ឋាន

## និងពលសមាយោគៈ

***វុដ្ឋាន*** *បានដល់ ការចេញអំពីនិមិត្ត និងបវត្ត ។* ***ពលសមាយោគៈ*** *បានដល់ ការប្រកបដោយសមថពល និងវិបស្សនាពល ។ សូម្បីមគ្គប្បញ្ញា លោកក៏ហៅថា វិបស្សនា ព្រោះអត្ថថា ឃើញដោយវិសេសក្នុងអរិយសច្ច មានទុក្ខជាដើម ដោយ អំណាចការត្រាស់ដឹង ដោយការកំណត់ដឹងជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យ ពោលឲ្យផ្សេងទៅថា* ***លោកិយវិបស្សនា*** *។ ដោយហេតុនោះឯង ទើបព្រះធម្ម-សេនាបតីសារីបុត្រពោលថា* ***ភិក្ខុចម្រើនសមថវិបស្សនាជាគូគ្នា ដោយអត្ថ គឺការចេញ*** *ដូច្នេះ ។ មានពាក្យប្រកបថា មិនទាន់ចេញចាកនិមិត្ត ព្រោះមាននិមិត្តជា អារម្មណ៍ មិនទាន់ចេញចាកអំពីបវត្ត ព្រោះមិនទាន់កាត់បានជាសមុច្ឆេទនូវសមុទយៈ ដែលជាហេតុនៃបវត្ត ។ ក្នុងការចេញ ២ យ៉ាងនោះ ការចេញចាកនិមិត្ត បានដល់ ការលែងនិមិត្ត គឺសង្ខារ ហើយធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ។ ការចេញចាកបវត្ត បានដល់ ការញ៉ាំងបវត្តដែលជាវិបាកតទៅ ឲ្យដល់នូវការមិនកើតឡើងជាធម្មតា ដោយការរំលត់ហេតុ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា* ***មិនទាន់ចេញចាកបវត្ត ព្រោះមិនទាន់កាត់បានជាសមុច្ឆេទនូវសមុទយៈ*** *ដូច្នេះ ។*

*បទថា* ***ទុភតោ*** *សេចក្ដីប៉ុនគ្នានឹង* ***ឧភតោ*** *លោកពោលទុកយ៉ាងនេះ ដោយ ទ អាគម ។ម្យ៉ាងទៀត បទថា* ***ទុភ*** *នេះ ជាបទពិសេស មានអត្ថប៉ុនគ្នានឹង* ***ឧភយ***-*ស័ព្ទ ។ ពាក្យថា* ***ដោយអត្ថ គឺការឃើញ*** *បានដល់ ដោយអត្ថ គឺការឃើញអរិយសច្ច ៤ ដែល មានការត្រាស់ដឹង ដោយកំណត់ដឹងជាដើមជាលក្ខណៈ ។ ពាក្យថា* ***ចាកមិច្ឆាទិដ្ឋិ***

គឺចាកមិច្ឆាទិដ្ឋិទាំង ៦២ ប្រភេទ ។ បទថា **តទនុវត្តកកិលេសេហិ** ចាកកិលេសដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះ គឺចាកកិលេស មានវិចិកិច្ឆាជាដើមទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះ ព្រោះជាកិលេសដែលគប្បីដល់អបាយ ។ សូម្បីក្នុងបទថា **ខន្ធេហិ** ក៏គប្បីនាំយក **តទនុវត្តក**-ស័ព្ទមកភ្ជាប់ផងដែរ ។ គប្បីជ្រាបខន្ធទាំងនោះ ដែលគួរកើតឡើងបាន ព្រោះមានមិច្ឆាទិដ្ឋិជាដើមជាបច្ច័យ ។ សូម្បីក្នុងពាក្យថា **ចាកមិច្ឆាសង្កប្ប** ជាដើម ក៏មានសេចក្តីថា រមែងចេញចាកកិលេសទាំងឡាយដែលប្រព្រឹត្តទៅតាមមិច្ឆាសង្កប្បនោះ និងចាកខន្ធទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាសង្កប្បនោះ ។ ព្រះបាលីថា **ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ** រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ដូច្នេះ លោកបង្រួញទុក ។ មិច្ឆាទិដ្ឋិ និងមិច្ឆាសង្កប្បយ៉ាងណា សូម្បីមិច្ឆាវាចាជាដើម ក៏គប្បីជ្រាបថា ជាហេតុញ៉ាំងសត្វឲ្យដល់អបាយនោះឯង ដូច្នោះ ។ **មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ** មានចេតនាជាសភាវៈ ។ **មិច្ឆាសតិ** បានដល់ ខន្ធ ៤ ដែលប្រព្រឹត្តទៅយ៉ាងនោះ ។ សម្មាទិដ្ឋិក្នុងមគ្គទាំង ៣ ខាងលើ រមែងចេញចាកមានះដែលមគ្គនោះៗ គប្បីសម្លាប់ ព្រោះថា មានះនោះតាំងនៅក្នុងឋានរបស់ទិដ្ឋិ ព្រោះការប្រព្រឹត្តទៅថា **អហមស្មិ** នុ៎ះជាអញ ដូច្នេះ ក្នុងទីនេះ លោកមិនបានលើកការចេញចាកមិច្ឆាមគ្គ លើកការចេញចាកសំយោជនៈ និងអនុស័យ ដែលមគ្គនោះៗ គប្បីប្រហារប៉ុណ្ណោះ ។

បទថា **អណុសហគតា** សេចក្តីថា ដែលដល់ហើយ គឺទៅហើយកាន់ភាពជាធម្មជាតិតិចតួច អធិប្បាយថា ជារបស់ល្អិត ។

លោកអាចារ្យកាលសម្តែងវុដ្ឋានការចេញយ៉ាងនេះហើយ ឥឡូវនេះមានបំណងនឹងសម្តែងពលសមាយោគៈ ទើបពោលពាក្យជាដើមថា **លោកិយានញ្ច** ដូច្នេះ **សមថពល** ឈ្មោះថា **រមែងមានកម្លាំងក្រៃលែង** ព្រោះជាការបំពេញសមាធិ ។

**វិបស្សនាពល** ឈ្មោះថា **រមែងមានកម្លាំងច្រើន** ព្រោះការបំពេញវិបស្សនា មានញាណដ៏ប្រសើរ ។ ធម៌ទាំងនោះ រមែងដូចជាចូលគ្នា គឺចងគ្នាជាគូ ដោយភាវៈដែលស្មើគ្នា ហេតុនោះ ទើបឈ្មោះថា **យុគនទ្ធា** គូគ្នា ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះអត្ថថា មិនប្រព្រឹត្តលើសខ្វះគ្នានឹងគ្នា** អធិប្បាយថា ព្រោះភាវៈដែលមិនតិចមិនច្រើនដោយកិច្ច ។ ព្រោះហេតុនោះៗ ឯង ទើបឈ្មោះថា **សមាយោគៈ** ដែលមានអត្ថថា ប្រកបគ្នាដោយការកំណត់ស្មើ ។

ដើម្បីសម្តែងធម៌ ដែលជាបដិបក្ខចំពោះសមាធិ ទើបលោកអាចារ្យពោលថា **ចាកកិលេសដែលសហគតៈជាមួយឧទ្ធច្ចៈទាំងឡាយ** អធិប្បាយថា ចាកកិលេសទាំងឡាយ ដែលមានឧទ្ធច្ចៈជាប្រធាន ។ ពាក្យថា **សមាធិ គឺការមិនរាយមាយ** បានដល់សមាធិដែលជាបដិបក្ខចំពោះការរាយមាយ និងកាត់បានជាសមុច្ឆេទ ។ ពាក្យថា **មាននិរោធជាគោចរ** គឺមាននិព្វានជាអារម្មណ៍ ។ ពាក្យថា **ដោយអត្ថថា ចេញ** គឺដោយអំណាចដែលចេញចាកនិមិត្ត និងបវត្ត ដោយភាវៈដែលចេញទៅ ។ ពាក្យថា **មានរសតែមួយ** គឺមានកិច្ចស្មើគ្នា ។

# វិសុទ្ធិមគ្គ

## បហាន

*បទថា គួរជ្រាបការលះធម៌ទាំងឡាយ ដែលញាណណាគប្បីលះ សេចក្ដីថា ឯ* ***ធម៌ពួកណា*** *ដែលញាណណាក្នុងញាណ ៤ នេះគប្បីលះ គួរជ្រាបការលះ ធម៌ ( គឺកិលេស ) ទាំងនោះផង ឯញាណទាំង ៤ នោះ ជាម្ចាស់នាទីលះធម៌ទាំងឡាយ ដែលហៅថា* ***សំយោជនៈ កិលេស មិច្ឆត្ត លោកធម៌ មច្ឆរិយៈ វិបល្លាស គន្ថៈ អគតិ អាសវៈ ឱឃៈ យោគៈ នីវរណៈ បរាមាស ឧបាទាន អនុស័យ មលៈ អកុសលកម្មបថ និងអកុសលចិត្តុប្បាទ*** *តាមសមគួរដល់យោគៈ ។*

## សំយោជនៈ

*ក្នុងធម៌ទាំងនោះ ធម៌ ១០ មានរូបរាគៈជាដើម ហៅថា* ***សំយោជនៈ*** *ព្រោះជាធម៌ចងខន្ធទាំងឡាយ ( ក្នុងបរលោក ) ទុកជាមួយខន្ធទាំងឡាយ ( ក្នុងឥធលោក ) ចងកម្មទុកនឹងផល ឬចងសត្វទាំងឡាយទុកនឹងទុក្ខ ។ ពិតហើយ ធម៌ មានរូបរាគៈជាដើមនោះ មានដរាបណា ខន្ធ ផល និងទុក្ខទាំងឡាយនោះ ក៏មិនដាច់ទៅដរាបនោះឯង ។ ក្នុងធម៌ ១០ នោះសោត ធម៌ ៥ នេះ គឺរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា ឈ្មោះឧទ្ធម្ភាគិយសំយោជនៈ ព្រោះចងខន្ធដែលកើតខាងលើ ( គឺក្នុងរូបភព និងអរូបភព ) ជាដើមទុក ធម៌ ៥ នេះ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស កាមរាគៈ បដិឃៈ ឈ្មោះ* ***អធោភាគិយសំយោជនៈ*** *ព្រោះចងខន្ធដែលកើតខាងក្រោម ( គឺក្នុងកាមភព ) ជាដើម ។*

## កិលេស

ធម៌ ១០ នេះ គឺលោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ឈ្មោះថា កិលេស ព្រោះខ្លួនឯងក៏សៅហ្មង និងព្រោះញ៉ាំង សម្បយុត្តធម៌ទាំងឡាយឲ្យសៅហ្មងផង ។

## មិច្ឆត្តៈ

ធម៌ ៨ នេះ គឺមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ ឬជា ១០ ទាំងមិច្ឆាវិមុត្តិ និងមិច្ឆាញាណ ឈ្មោះ មិច្ឆត្តៈ ព្រោះប្រព្រឹត្តទៅខុស ។

## លោកធម៌

ធម៌ ៨ នេះ គឺលាភ វិនាសលាភ យស វិនាសយស សុខ ទុក្ខ និន្ទា សរសើរ ឈ្មោះថា លោកធម៌ ព្រោះជាធម៌ កាលមានការប្រព្រឹត្តទៅនៃលោកមាន ក៏មានមិនដាច់ខ្សែ តែពាក្យថា លោកធម៌ក្នុងទីនេះនោះ គប្បីជ្រាបថា លោកធ្វើការ កាន់យកការត្រេកអរ ដែលមានឥដ្ឋារម្មណ៍ មានលាភជាដើមជាទីតាំង និងការមិន ត្រេកអរ ដែលមានអនិដ្ឋារម្មណ៍ មានវិនាសលាភជាដើមជាទីតាំង ដោយលោកធម៌ ស័ព្ទ ដោយឧបចារៈនៃហេតុ ( គឺដោយទាក់ទងជាហេតុ ) ។

## មច្ឆរិយៈ

ការកំណាញ់ ៥ នេះ គឺកំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់ធម៌ និងកំណាញ់វណ្ណៈ ដែលប្រព្រឹត្តទៅដោយអាការអត់ធន់មិនបាននូវភាព ( ដែលជារបស់ខ្លួន ) ជារបស់សាធារណៈដល់ជនដទៃ ក្នុងអាវាសជាដើម ឈ្មោះថា

មច្ឆរិយៈ ។

## វិបល្លាស

*វិបល្លាស ៣ គឺសញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ដែលប្រព្រឹត្តទៅ ដោយសម្គាល់គិតឃើញ ដូច្នេះថា ទៀង ថាសុខ ថាជាអត្តា ថាស្អាត ក្នុងវត្ថុទាំងឡាយ ដែលមិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាត ឈ្មោះថា វិបល្លាស ។*

## គន្ថៈ

*សង្កិលេសិកធម៌ ៤ មានអភិជ្ឈាជាដើម ឈ្មោះថា **គន្ថៈ** ព្រោះរួបរឹតនាមកាយ និងរូបកាយទុក ។ ពិតហើយ សង្កិលេសិកធម៌ទាំងនោះ លោកពោលទុកដូច្នេះថា អភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ ។*

## អគតិ

*ពាក្យថា **អគតិ** ជាពាក្យហៅការធ្វើវត្ថុដែលមិនគួរធ្វើ និងមិនធ្វើវត្ថុដែលគួរធ្វើ ព្រោះការស្រឡាញ់ ការស្អប់ ការល្ងង់ ការខ្លាច ។ ពិតហើយ ការធ្វើវត្ថុ ដែលមិនគួរធ្វើ និងមិនធ្វើវត្ថុដែលគួរធ្វើនោះ លោកហៅថា **អគតិ** ព្រោះព្រះអរិយបុគ្គលមិនប្រព្រឹត្ត ។*

## អាសវៈ ឱឃៈ យោគៈ

*ពាក្យថា **អាសវៈ** នោះ ជាពាក្យហៅកាមរាគៈ ភវរាគៈ មិច្ឆាទិដ្ឋិ និងអវិជ្ជា ព្រោះហូរតែ **អា** គឺគោត្រភូ ( ចុះមក ) ជាអារម្មណ៍ និងអំពី **អា** គឺភវគ្គ ( ភពខ្ពស់បំផុត ) ជាឱកាស ( គឺទីកើត ) ។ ន័យម្យ៉ាងទៀត ព្រោះហូរតាមទ្វារទាំងឡាយ*

ដែលមិនសង្រួម ដោយអត្ថ គឺហូរចេញជានិច្ច ដូចទឹកហូរអំពីឆ្នាំងធ្លុះ ន័យម្យ៉ាងទៀត ព្រោះជាហេតុកកើតសង្សារទុក្ខ ។

សូម្បីពាក្យថា **ឱឃៈ** ក៏ជាពាក្យហៅធម៌ មានកាមរាគៈជាដើមនោះឯង ព្រោះអត្ថថា ជន់ទៅក្នុងសាគរ គឺភព និងព្រោះអត្ថថា ឆ្លងផុតបានលំបាក ។

ពាក្យថា **យោគៈ** សោត ក៏ជាពាក្យហៅធម៌ទាំងនោះដូចគ្នា ព្រោះមិនឲ្យព្រាត់ប្រាសអំពីអារម្មណ៍ និងព្រាត់ប្រាសអំពីទុក្ខទៅបាន ។

## នីវរណៈ

ធម៌ ៥ មានកាមច្ឆន្ទៈជាដើម ហៅថា **នីវរណៈ** ព្រោះអត្ថ គឺរាំងចិត្តទុក គ្រៀកចិត្តទុក បិទបាំងចិត្តទុក ។

## បរាមាស

ពាក្យថា **បរាមាស** នោះ ជាពាក្យហៅការយល់ខុស ព្រោះប្រព្រឹត្តទៅ ដោយការឈានកន្លងនូវសភាវៈនៃធម៌នោះៗ ហើយទៅបបោសអង្អែលយកសភាវៈ ដែលមិនពិតដទៃទៅវិញ ។

## ឧបាទាន

ពាក្យថា **ឧបាទាន** ក៏បានដល់ឧបាទាន ៤ មានកាមុបាទានជាដើម ដែលពោលក្នុងបដិច្ចសមុប្បាទនិទ្ទេស ដោយអាការទាំងពួង ។

## អនុស័យ

ធម៌ ៧ មានកាមរាគៈជាដើម ដែលពោលទុកដូច្នេះថា **អនុស័យ** គឺកាមរាគៈ បដិឃៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ភវរាគៈ អវិជ្ជា ឈ្មោះថា អនុស័យ ព្រោះអត្ថថា

កម្លាំងខ្លាំង ។ ពិតហើយ ធម៌ទាំងនោះ ព្រោះមានកម្លាំងខ្លាំង ទើបដេកត្រាំនៅ ដោយជាកាមរាគៈជាដើម ជាឧប្បត្តិហេតុរឿយៗ នោះឯង ហេតុនេះ ទើបបានឈ្មោះថា អនុស័យ ។

## មលៈ

ធម៌៣ គឺលោភៈ ទោសៈ មោហៈ ឈ្មោះថា មលៈ ( មន្ទិល ) ព្រោះខ្លួនឯងក៏មិនស្អាតផង ព្រោះធ្វើការមិនស្អាតដល់ធម៌ដទៃៗ ផង ដូចប្រេង ថ្នាំបន្តក់ភ្នែក និងភក់ ។

## អកុសលកម្មបថ

ធម៌ ១០ នេះ គឺបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណវាចា ផរុសវាចា សម្ផប្បលាប អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ឈ្មោះថា **អកុសលកម្មបថ** ព្រោះជាអកុសលកម្មផង ព្រោះជាផ្លូវនៃទុគ្គតិទាំងឡាយផង ។

## អកុសលចិត្តុប្បាទ

ធម៌ ១២ នេះ គឺលោភមូល ៨ ទោសមូល ២ មោហមូល ២ ឈ្មោះថា **អកុសលចិត្តុប្បាទ** ។

ញាណ ៤ នោះ ជាម្ចាស់នាទីលះធម៌ទាំងឡាយ មានសំយោជនៈជាដើមនេះ ដូចពោលមកតាមគួរដល់យោគៈ ។

## ញាណណាលះអ្វី

លះដូចម្ដេច ? ពោលក្នុងសំយោជនៈទាំងឡាយមុន ធម៌ ៥ នេះ គឺ **សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស កាមរាគៈ និងបដិឃៈ** ដែលជាអបាយគមនីយ ( គឺ

ជាឋានៈទៅអបាយ ) ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះ **កាមរាគៈ បដិឃៈ** ដ៏សេស ( ដែលមិនជាអបាយគមនីយ ) ចំណែកដែលគ្រោតគ្រាត ជាធម៌ដែល **ទុតិយញ្ញាណ** គប្បីលះ ចំណែកដែលល្អិត ជាធម៌ដែល **តតិយញ្ញាណ** គប្បីលះ ធម៌ មានរូបរាគៈជាដើមទាំង ៥ ជាធម៌ដែល **ចតុត្ថញ្ញាណ** គប្បីលះ តែម្យ៉ាង ។

តទៅនេះ ក្នុងទីណាខ្ញុំមិនធ្វើការកំណត់សេចក្ដីទុក ដោយ **ឯវ**-ស័ព្ទ គឺពាក្យថា តែម្យ៉ាង ក្នុងទីនោះ ខ្ញុំនឹងពោលធម៌ណាមួយថា ជាធម៌ដែលញាណខាងលើគប្បីលះ ធម៌នោះៗ ក៏គប្បីជ្រាបចុះថា ជាធម៌ដែលមានភាពជាអបាយគមនីយជាដើម ដែលញាណខាងដើមៗ លះហើយនោះឯង ទើបជាធម៌ដែលញាណខាងលើគប្បីលះ ។

ក្នុងកិលេសទាំងឡាយ **ទិដ្ឋិ វិចិកិច្ឆា** ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះ **ទោសៈ** ជាធម៌ដែល **តតិយញ្ញាណ** គប្បីលះ **លោភៈ មោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ** ដែល **ចតុត្ថញ្ញាណ** គប្បីលះ ។

ក្នុងមិច្ឆត្តៈទាំងឡាយ ធម៌ទាំងនេះ គឺ **មិច្ឆាទិដ្ឋិ មុសាវាទ មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ** ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះ ធម៌ទាំងនេះ គឺ **មិច្ឆាសង្កប្ប បិសុណាវាចា ផរុសវាចា** ដែល **តតិយញ្ញាណ** គប្បីលះ ចេតនាប៉ុណ្ណោះ គប្បីជ្រាបថា **វាចា** ក្នុងទីនេះ **សម្ផប្បលាបៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាវិមុត្តិ មិច្ឆាញាណ** ដែល **ចតុត្ថញ្ញាណ** គប្បីលះ ។

ក្នុងលោកធម៌ទាំងឡាយ **ការមិនត្រេកអរ** ជាធម៌ដែល **តតិយញ្ញាណ** គប្បីលះ **ការត្រេកអរ** ដែល **ចតុត្ថញ្ញាណ** គប្បីលះ អាចារ្យមួយពួកពោលថា ការត្រេកអរក្នុងយស និងក្នុងការសរសើរ ជាធម៌ដែលចតុត្ថញ្ញាណគប្បីលះ ។

មច្ឆរិយៈទាំងឡាយ ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះតែម្យ៉ាង ។

ក្នុងវិបល្លាសទាំងឡាយ វិបល្លាស គឺ **សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិ**

វិបល្លាស ថាទៀង ក្នុងរបស់ដែលមិនទៀង ថាជាអត្តា ក្នុងរបស់ដែលជាអនត្តាក្តី **ទិដ្ឋិវិបល្លាស** ថា ជាសុខក្នុងរបស់ដែលជាទុក្ខ ថាស្អាតក្នុងរបស់ដែលមិនស្អាតក្តី ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះ **សញ្ញាវិបល្លាស ចិត្តវិបល្លាស** ថាស្អាត ក្នុងរបស់ដែលមិនស្អាត **តតិយញ្ញាណ** គប្បីលះ **សញ្ញាវិបល្លាស ចិត្តវិបល្លាស** ថា ជាសុខ ក្នុងរបស់ដែលជាទុក្ខ ដែល **ចតុត្ថញ្ញាណ** គប្បីលះ ។

ក្នុងគន្ថៈទាំងឡាយ **កាយគន្ថៈ** គឺសីលព្វតបរាមាស និង **ឥទំសច្ចាភិនិវេស** ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះ **កាយគន្ថៈ** គឺព្យាបាទ ដែល **តតិយញ្ញាណ** គប្បីលះ កាយគន្ថៈក្រៅអំពីនេះ ( គឺអភិជ្ឈា ) ជាធម៌ដែល **ចតុត្ថញ្ញាណ** គប្បីលះ ។

**អគតិ** ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះប៉ុណ្ណោះ ។

ក្នុងអាសវៈទាំងឡាយ **ទិដ្ឋាសវៈ** ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះ **កាមាសវៈ** ដែល **តតិយញ្ញាណ** គប្បីលះ, អាសវៈ ២ ក្រៅអំពីនេះ ( គឺភវាសវៈ អវិជ្ជាសវៈ ) គឺ **ចតុត្ថញ្ញាណ** គប្បីលះ, សូម្បីក្នុង **ឱឃៈ** និង **យោគៈ** ទាំងឡាយក៏ន័យនេះដូចគ្នា ។

ក្នុងនីវរណៈទាំងឡាយ **វិចិកិច្ឆានីវរណៈ** ជាធម៌ដែល **បឋមញ្ញាណ** គប្បីលះ, នីវរណៈ ៣ គឺ **កាមច្ឆន្ទៈ ព្យាបាទ កុក្កុច្ចៈ** គឺ **តតិយញ្ញាណ** គប្បីលះ **ថីនមិទ្ធៈ** និង **ឧទ្ធច្ចៈ** គឺ **ចតុត្ថញ្ញាណ** គប្បីលះ ។

**បរាមាស** ជាធម៌ដែល **បឋមញ្ញាណ** គប្បីកម្ចាត់តែម្យ៉ាង ។

ក្នុង **ឧបាទាន** ទាំងឡាយ សូម្បី **រូបរាគៈ** និង **អរូបរាគៈ** ក៏ចាត់ថា ធ្លាក់នៅក្នុង **កាមុបាទាន** ព្រោះលោកិយធម៌ទាំងអស់ រាប់បានថាជាកាម ដោយជាវត្ថុកាម ព្រោះហេតុនោះឯង **កាមុបាទាន** នោះ ទើបជាធម៌ដែល **ចតុត្ថញ្ញាណ** គប្បីលះឧបាទានដ៏សេស គឺ **បឋមញ្ញាណ** គប្បីលះ ។

ក្នុង **អនុស័យ** ទាំងឡាយ **ទិដ្ឋានុស័យ** និង **វិចិកិច្ឆានុស័យ** ជាធម៌ដែល

បឋមញ្ញាណ គប្បីលះ កាមរាគានុស័យ និង បដិឃានុស័យ គឺ តតិយញ្ញាណ គប្បីលះ មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ គឺ ចតុត្ថញ្ញាណ គប្បីលះ ។

ក្នុង មលៈ ទាំងឡាយ ទោសមលៈ ជាធម៌ដែល តតិយញ្ញាណ គប្បីកម្ចាត់ មលៈក្រៅអំពីនេះ គឺ ចតុត្ថញ្ញាណ គប្បីលះ ។

ក្នុង អកុសលកម្មបថ ទាំងឡាយ ធម៌ទាំងនេះ គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ មិច្ឆាទិដ្ឋិ ជាធម៌ដែល បឋមញ្ញាណ គប្បីលះ ធម៌ ៣ គឺ បិសុណាវាចា ផរុសវាចា ព្យាបាទ គឺ តតិយញ្ញាណ គប្បីលះ សម្ផប្បលាប និង អភិជ្ឈា គឺ ចតុត្ថញ្ញាណ គប្បីលះ ។

ក្នុង អកុសលចិត្តុប្បាទ ទាំងឡាយ អកុសលចិត្តុប្បាទ ៥ គឺ ទិដ្ឋិសម្បយុត្ត ៤ និង វិចិកិច្ឆាសម្បយុត្ត ១ ជាធម៌ដែល បឋមញ្ញាណ គប្បីលះ បដិឃសម្បយុត្ត ២ គឺ តតិយញ្ញាណ គប្បីលះ អកុសលចិត្តុប្បាទដ៏សេស គឺ ចតុត្ថញ្ញាណ គប្បីលះ ដូច្នេះ ។

ឯរបស់ណា ដែលញាណគប្បីលះរបស់នោះ ក៏ឈ្មោះថា ដែលញាណនោះ គប្បីលះ ហេតុនោះ ទើបខ្ញុំពោលទុកថា ញាណ ៤ នោះ ជាម្ចាស់នាទីលះធម៌ ទាំងឡាយ មានសំយោជនៈជាដើមនេះ ដូចពោលមកតាមគួរដល់យោគៈ ដូច្នេះ ។

## បញ្ហាថា មគ្គញ្ញាណលះកិលេសក្នុងកាលណា

សួរថា ឯញាណ ៤ នោះ លះធម៌ទាំងនោះ ដែលជាអតីត អនាគត ឬជា បច្ចុប្បន្ន ? ឆ្លើយថា ក្នុងសេចក្ដីនេះ ដំបូងឧបមាថា ញាណទាំងនោះលះធម៌ ដែល ជាអតីត អនាគតសោត សេចក្ដីព្យាយាម ក៏ទៅជាការមិនមានផល ព្រោះអ្វី ព្រោះធម៌ ដែលគប្បីលះទាំងឡាយមិនមាន តែបើលះធម៌ដែលជាបច្ចុប្បន្នសោត សូម្បីដូច្នោះ

ការព្យាយាមក៏មិនមានផល ព្រោះធម៌ដែលគប្បីលះ និងសេចក្តីព្យាយាមនៅមាន ( គឺព្យាយាមលះបានម្យ៉ាងហើយ និងត្រូវព្យាយាមលះម្យ៉ាងទៀត ) ទាំងមគ្គភាវនាក៏នឹងក្លាយជាសង្កិលេសិកធម៌ទៅ ( គឺមិនបរិសុទ្ធ ព្រោះរបស់ដែលគប្បីលះ និងអ្នកលះនៅលាយឡំគ្នា ) ឬក្លាយជាកិលេសទាំងឡាយ ជាវិប្បយុត្ត ( គឺមិនប្រកបជាមួយចិត្ត ) ទៅ ឯបច្ចុប្បន្នកិលេស ឈ្មោះថា មិនវិប្បយុត្តជាមួយចិត្តឡើយ ។

ពាក្យចោទនេះ មិនមែនជាពាក្យពិសេស ព្រោះក្នុងព្រះបាលីលោកក៏បានពោលថា បុគ្គលនោះ រមែងលះកិលេសទាំងឡាយដែលជាអតីតឬ លះកិលេសទាំងឡាយដែលជាអនាគតឬ លះកិលេសទាំងឡាយដែលជាបច្ចុប្បន្នឬ ។ និងពោលទៀតថា បើលះកិលេសទាំងឡាយដែលជាអតីតសោត បើដូច្នោះ ក៏ឈ្មោះថា ញុំាងវត្ថុដែលអស់ទៅហើយ ឲ្យអស់ ញុំាងវត្ថុរលត់ទៅហើយ ឲ្យរលត់ វត្ថុដែលប្រាសទៅហើយ ឲ្យប្រាសទៅ វត្ថុដែលធ្លាក់ទៅហើយ ឲ្យធ្លាក់ទៅ លះវត្ថុដែលកន្លងទៅហើយជាវត្ថុដែលមិនមានហ្ន៎ ហើយទើបបដិសេធថា **មិនមែនលះកិលេសទាំងឡាយ ដែលជាអតីតទេ ។**

ន័យដូចគ្នានោះដែរ ពោលថា បើលះកិលេសទាំងឡាយ ដែលជាអនាគតសោត បើដូច្នោះ ក៏ឈ្មោះថា លះរបស់ដែលមិនទាន់កើត ។ លះរបស់ដែលមិនទាន់ផុសឡើង លះរបស់ដែលមិនទាន់ឧប្បត្តិ លះរបស់ដែលមិនទាន់ប្រាកដ លះរបស់ដែលមិនទាន់មកដល់ ទើបជារបស់ដែលមិនមានហ្ន៎ ហើយទើបបដិសេធថា **មិនមែនលះកិលេសទាំងឡាយ ដែលជាអនាគតទេ ។**

ន័យដូចគ្នានោះដែរ ពោលថា បើលះកិលេសដែលជាបច្ចុប្បន្នសោត បើដូច្នោះ បុគ្គលអ្នកមានតម្រេកក៏លះរាគៈ បុគ្គលអាក់អន់ក៏លះទោសៈ បុគ្គលវង្វេងក៏លះមោហៈ បុគ្គលរឹងត្អឹងក៏លះមានះ បុគ្គលប្រកាន់ម៉ាំក៏លះទិដ្ឋិ បុគ្គលមានចិត្តរាយមាយ

ក៏លះឧទ្ធច្ចៈ បុគ្គលចុះចិត្តមិនស៊ប់ក៏លះវិចិកិច្ឆា បុគ្គលមានកិលេសខ្លាំងក្លាក៏លះអនុស័យ ធម៌ខ្មៅ និងធម៌ស ជាគូគ្នាទៅហើយ មគ្គភាវនាក៏ជាសង្កិលេសិកធម៌ទៅ ។ ហើយ ទើបបដិសេធទាំងអស់ មិនមែនលះកិលេសទាំងឡាយដែលជាអតីត មិនមែនលះកិលេសទាំងឡាយដែលជាអនាគត មិនមែនលះកិលេសទាំងឡាយ ដែលជាបច្ចុប្បន្នទេ ដូច្នេះ ។ កាលបញ្ហាចុងក្រោយថា បើដូច្នោះ មគ្គភាវនាក៏ឈ្មោះថា មិនមានការនាំផលឲ្យជាក់ច្បាស់ឡើយ ការលះកិលេលក៏មិនមាន ការត្រាស់ដឹងធម៌ក៏មិនមានទៅហើយ ? លោកទទួលដោយពាក្យថា មិនមែនមគ្គភាវនាមិនមាន ។បេ។ មិនមានការត្រាស់ដឹងធម៌មិនមាន ហើយពោលថា ប្រៀបដូចអ្វី ? ទើបពោលពាក្យនេះថា ឧបមាដូចឈើជំទង់មិនទាន់មានផ្លែ បុរសកាត់វាត្រង់ឫស ផ្លែណាជាផ្លែដែលមិនទាន់កើតនៃដើមឈើនោះ ផ្លែនោះក៏មិនទាន់កើត ដែលមិនទាន់ចេញក៏មិនចេញ ដែលមិនទាន់ឧប្បត្តិ ក៏មិនឧប្បត្តិ មិនទាន់ប្រាកដក៏មិនប្រាកដ យ៉ាងណា ឧប្បាទ ( វត្តដែលមានការកើត គឺខន្ធ ) ជាហេតុ ឧប្បាទជាបច្ច័យ ដើម្បីការកើតនៃកិលេសទាំងឡាយ ព្រោះឃើញទោសក្នុងឧប្បាទ ទើបចិត្តស្ទុះទៅក្នុងអនុប្បាទ ( គឺនិព្វាន ) ព្រោះចិត្តស្ទុះទៅក្នុងអនុប្បាទ កិលេសពួកណាគប្បីកើត ព្រោះបច្ច័យគឺឧប្បាទ កិលេស ទាំងនោះដែលមិនទាន់កើត ក៏មិនកើត ។បេ។ មិនទាន់ប្រាកដ ក៏មិនប្រាកដ ការរលត់នៃទុក្ខរមែងមាន ព្រោះការរលត់នៃហេតុ ដូច្នេះ ។

បវត្ត ( ការវិលទៅនៃឧបាទិន្នក ) ជាហេតុ បវត្តជាបច្ច័យ... និមិត្ត ( គឺសង្ខារ ) ជាហេតុ និមិត្តជាបច្ច័យ... អាយូហនា ( ការព្យាយាមជាហេតុ ) អាយូហនាជាបច្ច័យ ដើម្បីការកើតនៃកិលេសទាំងឡាយ ព្រោះឃើញទោសក្នុងអាយូហនា ទើបចិត្តស្ទុះទៅក្នុងអនាយូហនៈ ( គឺព្រះនិព្វាន ) ព្រោះចិត្តស្ទុះទៅក្នុងអនាយូហនៈ កិលេសពួកណាគប្បីកើត ព្រោះបច្ច័យ គឺអាយូហនា កិលេសទាំងនោះ ដែលមិនទាន់កើត

*ក៏មិនកើត ។បេ។ មិនទាន់ប្រាកដក៏មិនប្រាកដ ការរលត់នៃទុក្ខរមែងមាន ព្រោះការរលត់នៃហេតុ ដូច្នេះ ដូច្នោះឯង ។*

*មគ្គភាវនា រមែងមានយ៉ាងនេះ ផល គឺសច្ឆិកិរិយា រមែងមានយ៉ាងនេះ កិលេសប្បហាន រមែងយ៉ាងនេះ ធម្មាភិសម័យ ( ការត្រាស់ដឹងធម៌ ) រមែងមានយ៉ាងនេះ ( មិនមែនមិនមាន ) ។*

## ភូមិលទ្ធកិលេស និង ឧប្បន្ន ៤

*សួរថា ដោយពាក្យថា កិលេសទាំងឡាយមិនទាន់កើត ក៏មិនកើតជាដើមនោះ លោកសម្តែងដល់អ្វី ? ឆ្លើយថា លោកសម្តែងការលះកិលេសទាំងឡាយ ដែលជាភូមិលទ្ធបានភូមិ សួរថា ឯកិលេសទាំងឡាយដែលជាភូមិលទ្ធ ជាអតីត អនាគតឬឬជាបច្ចុប្បន្ន ? ឆ្លើយថា កិលេសទាំងនោះក៏ឈ្មោះថា ភូមិ-លទ្ធុប្បន្ន-កើតឡើងដោយបានភូមិប៉ុណ្ណោះឯង ( មិនមែនអតីត អនាគត បច្ចុប្បន្ន ) ។*

*ពិតហើយ ឧប្បន្ន វត្ថុដែលកើតឡើងមានច្រើនប្រភេទ ជាវត្តមាន ( នៅប្រព្រឹត្តទៅ ) ជា* ***ភូតាបគត*** *( មានហើយប្រាសទៅ ) ជា* ***ឱកាសកត*** *( ធ្វើឱកាស ) និងជា* ***ភូមិលទ្ធ*** *។ ក្នុងឧប្បន្នទាំងនោះ វត្ថុដែលរាប់បានថា ប្រកបដោយការកើតឡើង ការទ្រុឌទ្រោម និងការបែកធ្លាយទៅទាំងពួង ឈ្មោះថា* ***វត្តមានុប្បន្ន*** *កើតឡើងដោយនៅប្រព្រឹត្តទៅ ។*

*កុសល អកុសលដែលសោយរសអារម្មណ៍ ហើយរលត់ទៅ ដែលហៅបានថា* ***អនុភូតាបគត*** *សោយហើយ ប្រាសទៅក្តី, កុសល អកុសល ដែលជាសង្ខតៈដ៏សេស ដែលដល់លក្ខណៈ ៣ មានការកើតឡើងជាដើម ដោយលំដាប់ ហើយរលត់ទៅ ដែលរាប់ជា* ***ភូតាបគត*** *មានហើយប្រាសទៅក្តី ( រួម ) បានឈ្មោះថា*

**ភូតាបគតុប្បន្ន** កើតឡើង ដោយមានហើយ ប្រាសទៅ ។

កម្មដែលពោលដោយន័យថា កម្មទាំងឡាយនោះ ជាកម្មដែលបុគ្គលនោះធ្វើទុកក្នុងកាលមុន ដូច្នេះជាដើម សូម្បីជាកម្មអតីត ក៏ឈ្មោះថា **ឱកាសកតុប្បន្ន** កើតឡើងដោយធ្វើឱកាស ព្រោះឃាត់វិបាកដទៃ ហើយធ្វើឱកាសដល់វិបាកនៃខ្លួនតាំងនៅ ន័យដូចគ្នានោះដែរ វិបាកដែលមានឱកាស ដែលកម្មធ្វើឲ្យហើយ ជាវិបាកដែលមិនទាន់កើតឡើង ក៏ឈ្មោះថា **ឱកាសកតុប្បន្ន** កើតឡើង ដោយមានឱកាសដែលកម្មធ្វើឲ្យ ព្រោះកាលឱកាសដែលកម្មធ្វើឲ្យហើយយ៉ាងនោះ ក៏ជាការកើតឡើងពិតប្រាកដ ។

អកុសល ដែលមិនទាន់បានដកឡើង ក្នុងភូមិទាំងឡាយនោះៗ ឈ្មោះថា **ភូមិលទ្ធុប្បន្ន** កើតឡើងដោយបានភូមិ ។

## ភូមិ និង ភូមិលទ្ធផ្សេងគ្នា

ម្យ៉ាងទៀត **ក្នុងប្រការនេះ** គប្បីជ្រាបការផ្សេងគ្នានៃភូមិ និងភូមិលទ្ធ ឯបញ្ចក្ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាអារម្មណ៍នៃវិបស្សនា ឈ្មោះថា **ភូមិ** កិលេសជាតិដែលប្រព្រឹត្តទៅ ដោយកើតឡើងក្នុងខន្ធទាំងឡាយនោះ ឈ្មោះថា **ភូមិលទ្ធ** ព្រោះភូមិនោះ រាប់ថា ជាកិលេសជាតិនោះបាន ហេតុនោះឯង ទើបកិលេសជាតិនោះហៅថា **ភូមិលទ្ធ** បានភូមិ ។

តែភូមិនោះ មិនមែនបានដោយ ( ធ្វើឲ្យ ) ជាអារម្មណ៍ ពិតហើយ ព្រោះប្រារព្ធខន្ធទាំងឡាយ ដែលជាអតីត អនាគតទាំងពួង និងខន្ធរបស់ព្រះខីណាស្រពទាំងឡាយ ជាខន្ធដែលលោកកំណត់ដឹងហើយ ដោយ ( ធ្វើឲ្យ ) ជាអារម្មណ៍ កិលេសទាំងឡាយ រមែងកើតឡើងបាន ដូចកិលេស ដែលកើតឡើងដល់សោរេយ្យសេដ្ឋីនិងនន្ទមាណពជាដើម ព្រោះប្រារព្ធខន្ធរបស់ព្រះមហាកច្ចាយនត្ថេរ និងព្រះនាង

ឧប្បលវណ្ណាជាដើម ដូច្នោះ ។ ម្យ៉ាងទៀត ឧបមាថា កិលេសជាតិ ( ដែលប្រព្រឹត្ត ទៅក្នុងសន្តានអ្នកដទៃ ) នោះ គប្បីបានឈ្មោះថា ជាភូមិលទ្ធសោត បុគ្គលណាម្នាក់ ក៏មិនគប្បីលះមូលនៃភពបាន ព្រោះកិលេសជាតិ ( ក្នុងសន្តានអ្នកដទៃ ) នោះ មិនជា វត្ថុដែលខ្លួនគប្បីលះបាន ។

តែភូមិលទ្ធ កិលេសជាតិបានភូមិ គប្បីជ្រាបជាវត្ថុ ( គឺជាទីកើត ) សេចក្តីថា ខន្ធទាំងឡាយ ដែលមិនបានកំណត់ដឹងដោយវិបស្សនា កើតឡើងក្នុងភពណាមួយ ចាប់ផ្តើមអំពីការកើតឡើង ( នៃខន្ធទាំងនោះ ) ក្នុងភពនោះៗ កិលេសជាតិដែលជា មូលនៃវដ្ដៈ ក៏ដេកត្រាំនៅក្នុងខន្ធទាំងឡាយនោះ កិលេសជាតិនោះ គប្បីជ្រាបថា ជាភូមិលទ្ធ បានភូមិ ដោយអត្ថ គឺលះមិនទាន់បាន ។ ម្យ៉ាងទៀត ក្នុងខន្ធទាំងឡាយ ដែលជាភូមិនោះ កិលេសទាំងឡាយ ដែលដេកត្រាំនៅ ដោយអត្ថ គឺលះមិនទាន់បាន ក្នុងខន្ធទាំងឡាយណា របស់បុគ្គលមានខន្ធទាំងឡាយ នោះរបស់បុគ្គលនោះប៉ុណ្ណោះ ជាវត្ថុរបស់កិលេសទាំងនោះ ខន្ធទាំងឡាយដែលជារបស់អ្នកដទៃ មិនជាវត្ថុឡើយ ។ ម្យ៉ាងទៀត អតីតក្ខន្ធទាំងឡាយប៉ុណ្ណោះ ជាវត្ថុនៃកិលេសទាំងឡាយ ដែលដេកត្រាំ ដោយលះមិនទាន់បាន ក្នុងអតីតក្ខន្ធទាំងឡាយ ខន្ធក្រៅអំពីនេះ មិនជាវត្ថុឡើយ ក្នុង អនាគតក្ខន្ធជាដើម ក៏មានន័យនេះ ។ ន័យដូចគ្នានោះដែរ កាមាវចរក្ខន្ធទាំងឡាយ ប៉ុណ្ណោះ ជាវត្ថុកិលេសទាំងឡាយដែលដេកត្រាំ ដោយមិនទាន់លះបានក្នុងកាមាវចរក្ខន្ធ ទាំងឡាយ ខន្ធក្រៅអំពីនេះ មិនជាវត្ថុឡើយ ក្នុងរូបាវចរក្ខន្ធ និងអរូបាវចរក្ខន្ធទាំងឡាយ ក៏មានន័យនេះ ។

ចំណែកក្នុងព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម កិលេសជាតិដែល ជាមូលនៃវដ្ដៈនោះៗ ក្នុងខន្ធទាំងឡាយរបស់ព្រះអរិយបុគ្គលណាម្នាក់ លោកលះបាន ហើយ ដោយមគ្គនោះៗ ខន្ធទាំងឡាយនោះៗ របស់ព្រះអរិយបុគ្គលនោះៗ ទើប

មិនបានឈ្មោះថា ភូមិ ព្រោះមិនជាវត្ថុនៃកិលេស ដែលជាមូលនៃវដ្តៈទាំងឡាយនោះៗ ដែលលោកលះបានហើយ ។

ព្រោះកិលេសដែលជាមូលនៃវដ្តៈទាំងឡាយ បុថុជ្ជនមិនទាន់លះបាន ដោយប្រការទាំងពួង កម្មដែលបុថុជ្ជនធ្វើគ្រប់យ៉ាង ទើបជាកុសល ឬអកុសល វដ្តៈនៃបុថុជ្ជននោះរមែងវិល ព្រោះបច្ច័យ គឺកម្ម និងកិលេស ដូច្នេះ ។

កិលេសជាតិ ដែលជាមូលនៃវដ្តៈនោះរបស់បុថុជ្ជននោះ មិនគួរពោលថា កិលេសដេកត្រាំនៅក្នុងរូបក្ខន្ធប៉ុណ្ណោះ មិនបានដេកត្រាំនៅក្នុងខន្ធដទៃ មានវេទនាខន្ធជាដើម ។បេ។ ឬកិលេសដែលត្រាំនៅក្នុងវិញ្ញាណក្ខន្ធប៉ុណ្ណោះ មិនបានដេកត្រាំនៅក្នុងខន្ធដទៃ មានរូបក្ខន្ធជាដើម ដូច្នេះឡើយ ។ ព្រោះអ្វី ? ព្រោះកិលេសដេកត្រាំនៅក្នុងខន្ធទាំង ៥ ដោយមិនប្លែកគ្នា សេចក្តីនេះ មានឧបមាដូចម្តេច ? ឧបមាដូចរសផែនដីជាដើម ក្នុងដើមឈើ ដូចជាកាលដើមឈើធំដុះផ្ទាល់ផែនដី អាស្រ័យរសផែនដី និងរសទឹក ព្រោះមានរសដី និងរសទឹកនោះជាបច្ច័យ ក៏ចម្រើនដោយឫសដើម មែកតូច មែកធំ ពន្លក ស្លឹក ផ្កា និងផ្លែ ( រហូត ) ដល់ត្រឈឹងត្រឈៃ បន្តពូជដើមឈើ ដោយបន្តគ្នានៃពូជ តាំងនៅ រហូតកប្បាវសាន ។ រសផែនដីជាដើមនោះ មិនគួរពោលថា ជ្រាបនៅក្នុងឫសប៉ុណ្ណោះ មិនបានជ្រាបនៅអវយវៈដទៃ មានដើមជាដើម ។បេ។ ឬថា ជ្រាបនៅក្នុងផ្លែប៉ុណ្ណោះ មិនបានជ្រាបនៅក្នុងអវយវៈដទៃ មានឫសជាដើម ដូច្នេះឡើយ ។ ព្រោះអ្វី ? ព្រោះរសជ្រាបនៅក្នុងអវយវៈរបស់ដើមឈើ មានឫសជាដើមទាំងអស់ ដូច្នេះ ។

ម្យ៉ាងទៀត ប្រៀបដូចបុរសម្នាក់ ដែលនឿយណាយក្នុងផ្កា និងផ្លែជាដើម របស់ដើមឈើនោះឯង គប្បីបោះអណ្តាតពិស ឈ្មោះ **មណ្ឌូកកណ្តក** ចូលក្នុងទិស ទាំង ៤ បន្ទាប់មក ដើមឈើនោះ ត្រូវសម្ផស្សពិសនោះពាល់ត្រូវហើយ ក៏ដល់នូវការមិនអាចបញ្ចេញផ្លែជាធម្មតា មិនគប្បីញ៉ាំងការបន្តឲ្យកើតបានទៀត ព្រោះរសដី និងរសទឹក អស់កម្លាំងហើយ យ៉ាងណា កុលបុត្រដែលនឿយណាយក្នុងខន្ធប្បវត្ត ក៏ដូច្នោះដូចគ្នា រមែងផ្តើមការចម្រើនមគ្គ ៤ ឡើង ក្នុងសន្តានរបស់ខ្លួន ដូចការផ្សំពិសចូលក្នុងដើមឈើទាំង ៤ ទិសនៃបុរសនោះ ពេលនោះខន្ធសន្តាននៃកុលបុត្រនោះ ដែលសម្ផស្សពិស គឺមគ្គ ៤ នោះពាល់ត្រូវហើយ ក៏ជាសន្តាន មានការបែកចេញទៅនៃកម្មទាំងពួង មានកាយកម្មជាដើម ដោយចូលដល់ភាវៈត្រឹមតែជាកិរិយា ដល់នូវការដែលមិនកើតក្នុងភពថ្មីតទៅជាធម្មតា មិនអាចញ៉ាំងការបន្តទៅ ព្រោះកិលេសដែលជាមូលនៃវដ្តៈទាំងឡាយអស់កម្លាំងហើយ ដោយប្រការទាំងពួង ព្រោះរលត់ទៅនៃវិញ្ញាណចុងក្រោយ ក៏ជាបុគ្គលមានពូជរលត់អស់ហើយ ដូចភ្លើងអស់ពូជរលត់ទៅ ដូច្នោះ ។

ការផ្សេងគ្នានៃភូមិ និងភូមិលទ្ធ គប្បីជ្រាបដូចពោលមក ដូច្នេះ ។

## ឧប្បន្ន ៤ ទៀត

ម្យ៉ាងទៀត មានឧប្បន្ន ៤ ប្រការទៀត ជាសមុទាចារ ( ប្រព្រឹត្តទៅ ) **អារម្មណាធិគហិត** ( បានអារម្មណ៍ទុក ) **អវិក្ខម្ភិត** ( មិនបានសង្កត់ទុក ) និង **អសមូហត** ( មិនទាន់បានដកឡើង ) ។

ក្នុងឧប្បន្ន ៤ នោះ **សមុទាចារុប្បន្ន** កើតឡើងដោយប្រព្រឹត្តទៅ គឺ **វត្តមានុប្បន្ន** ( ក្នុងន័យមុននោះឯង ) ។

ចំណែកកិលេសជាតិ ដែលមិនទាន់កើតឡើង ព្រោះអារម្មណ៍ដែលមកកាន់គន្លងទ្វារ មានចក្ខុជាដើមក្នុងគ្រាដំបូង ក៏ហៅបានថា **អារម្មណាធិគហិតុប្បន្ន** កើតឡើងដោយបានអារម្មណ៍ ព្រោះហេតុដែលបានអារម្មណ៍នោះឯង កិលេសក៏កើតឡើងដោយពិត ក្នុងពេលក្រោយ ដូចកិលេសជាតិដែលកើតឡើងដល់ព្រះមហាតិស្សត្ថេរ ដែលត្រាច់បិណ្ឌបាតនៅក្នុងស្រុកកល្យាណគាម ព្រោះឃើញរូបដែលជាវិសភាគៈ ដូច្នោះ ។

កិលេសជាតិ ដែលមិនបានសង្កត់សង្កិនទុក ដោយអំណាចសមថៈ និងវិបស្សនា ឯណាមួយ សូម្បីមិនទាន់បានឡើងកាន់ចិត្តសន្តតិ ក៏បានឈ្មោះថា **អវិក្ខម្ភិតុប្បន្ន** កើតឡើងដោយមិនបានសង្កត់សង្កិនទុក ព្រោះមិនបានហេតុដែលរារាំងការកើតឡើង ( របស់កិលេសបាន ) ។ តែសូម្បីសង្កត់សង្កិនទុកបានដោយអំណាចសមថៈ និងវិបស្សនាហើយ ក៏ហៅបានថា **អសមូហតុប្បន្ន** កើតឡើង ដោយមិនទាន់បានដកឡើង ព្រោះមិនទាន់បានដកឡើងដោយអរិយមគ្គ ក៏មិនទាន់កន្លងការកើតជាធម្មតាទៅបាន ដូចកិលេសជាតិដែលកើតឡើងដល់ព្រះថេរៈ ដែលបានសមាបត្តិ ៨ ដែលកំពុងទៅតាមអាកាស ព្រោះបានឮសំឡេងច្រៀងរបស់មាតុគ្រាម ដែលបេះផ្កានៅត្រង់ដើមឈើក្នុងព្រៃជិត ( ស្រុក ) ច្រៀងបណ្តើរ ដោយសំឡេងដ៏ពីរោះ ដូច្នោះ ។

ឯ **អារម្មណាធិគហិតុប្បន្ន អវិក្ខម្ភិតុប្បន្ន** និង **អសមូហតុប្បន្ន** ទាំង ៣

ប្រការនេះ គប្បីជ្រាបថា ដល់នូវការសង្គ្រោះជាមួយភូមិលទ្ធនោះឯង ក្នុងឧប្បន្ន មានប្រភេទដូចពោលមកដូច្នេះនោះ ឧប្បន្ន ៤ ប្រការ ពោល គឺ **វត្តមានុប្បន្ន ភុត្វាបគតុប្បន្ន ឱកាសកតុប្បន្ន សមុទាចារុប្បន្ន** នោះ ឧប្បន្ន ៤ នេះ មិនជារបស់ដែលញាណណាត្រឹមតែ ១ គប្បីលះឡើយ ព្រោះមិនមែនរបស់ដែលមគ្គគប្បីលះ ចំណែក **អប្បន្ន** ៤ ពោល គឺ **ភូមិលទ្ធុប្បន្ន អារម្មណាធិគហិតុប្បន្ន អវិក្ខម្ភិតុប្បន្ន** និង **អសមូហតុប្បន្ន** ឧប្បន្នទាំង ៤ នោះ ជារបស់ដែលញាណ គប្បីលះ ព្រោះលោកិយញាណ និងលោកុត្តរញ្ញាណនោះៗ រមែងញ៉ាំងឧប្បន្ននោះៗ នៃឧប្បន្ន ៤ នោះឲ្យអស់ទៅ កើតឡើង ដូច្នេះ ។

បណ្ឌិតគួរជ្រាបការលះធម៌ទាំងឡាយ ដែលញាណណាគប្បីលះផង ក្នុងញាណទស្សនវិសុទ្ធិនេះ ដូចពោលមក ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយការលះបហាតព្វធម៌

ពាក្យថា **ធម៌ពួកណា** បានដល់ ធម៌ គឺសង្កិលេសពួកណា ។ បណ្ដាធម៌ទាំងឡាយ មានសំយោជនៈជាដើម ធម៌ទាំងឡាយឈ្មោះថា **សំយោជនៈ** ព្រោះអត្ថថា ប្រកបទុក គឺព្រោះអត្ថថា ចងទុក, ឈ្មោះថា **កិលេស** ព្រោះអត្ថថា បៀតបៀន ឬព្រោះអត្ថថា ធ្វើឲ្យក្ដៅក្រហាយ ។ ឈ្មោះថា **មិច្ឆត្ត:** ព្រោះអត្ថថា ជាសភាវៈខុស, ឈ្មោះថា **លោកធម៌** ព្រោះអត្ថថា ធម៌ក្នុងលោក គឺធម៌ដែលទាក់ទងដោយលោក ។ ឈ្មោះថា **មច្ឆរិយៈ** ព្រោះអត្ថថា ភាវៈ ឬកម្មនៃបុគ្គលកំណាញ់, ឈ្មោះថា **វិបល្លាស** ព្រោះអត្ថថា វិបរិត, ឈ្មោះថា **គន្ថៈ** ព្រោះអត្ថថា រួបរឹត, ការប្រព្រឹត្តមិនសមគួរ ឈ្មោះថា **អគតិ**, ឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ហូរទូទៅ, ឈ្មោះថា **ឱឃៈ** ព្រោះអត្ថថា ជោរជន់, ឈ្មោះថា **យោគៈ** ព្រោះអត្ថថា ប្រកបទុក, ឈ្មោះថា **នីវរណៈ** ព្រោះអត្ថថា រារាំង, ឈ្មោះថា **បរាមាស** ព្រោះអត្ថថា ឈានកន្លងសភាវៈនៃធម៌ ហើយកាន់យកខុស ។ ឈ្មោះថា **ឧបាទាន** ព្រោះអត្ថថា ប្រកាន់យ៉ាងមាំ, ឈ្មោះថា **អនុស័យ** ព្រោះអត្ថថា ដេកត្រាំនៅក្នុងសន្ដានដោយភាវៈដែលមិនទាន់លះបាន, ឈ្មោះថា **មលៈ** ព្រោះអត្ថថា ធ្វើភាវៈឲ្យសៅហ្មង, អកុសលកម្មទាំងនោះជាផ្លូវនៃសុគតិ និងទុគ្គតិ នៃសុខ និងទុក្ខ ដែលកើតឡើងក្នុងសុគតិ និងទុគ្គតិនោះផង ហេតុនោះ ទើបឈ្មោះថា **អកុសលកម្មបថ**, ចិត្តរមែងកើតឡើងក្នុងសភាវៈនេះ ហេតុនោះ សភាវៈនេះ ឈ្មោះថា **ចិត្តុប្បាទ** បានដល់ គំនរនៃចិត្ត និងចេតសិក, គប្បីនាំយកអកុសលស័ព្ទមកភ្ជាប់ចូលថា ចិត្តុប្បាទនោះផង ជាអកុសលផង ហេតុនោះ ឈ្មោះថា **អកុសលចិត្តុប្បាទ** ។

ពាក្យថា **ខន្ធទាំងឡាយទុកជាមួយខន្ធទាំងឡាយ** គឺខន្ធក្នុងបរលោកទាំងឡាយទុកជាមួយខន្ធក្នុងឥធលោកទាំងឡាយ ។ ពាក្យថា **ពិតហើយ ធម៌ មានរូបរាគៈជាដើមនោះ ទៅមានជរាបណា** សេចក្តីថា ធម៌ មានរូបរាគៈជាដើមនោះ នៅប្រព្រឹត្តទៅគឺមិនទាន់ដាច់សូន្យជរាបណា ខន្ធ គឺផល និងទុក្ខ **ទាំងនេះ ក៏មិនទាន់ដាច់** គឺមិនកាត់ផ្តាច់ **ជរាបនោះ** ។ ដោយពាក្យនេះ លោកអាចារ្យរមែងធ្វើអត្ថថា ចងទុករបស់ធម៌មានរូបរាគៈជាដើមនោះ ឲ្យជាក់ច្បាស់ ។ ពាក្យថា **ខាងលើ** បានដល់ ក្នុងរូបភព និងអរូបភព ឬក្នុងខាងលើនៃការកើតរបស់មគ្គទី ៣ ។ រូបភព និងអរូបភព ឈ្មោះថា **ឧទ្ធំភាគ** ព្រោះអត្ថថា សមាគមនៅក្នុងខាងលើ, ឯសំយោជនៈទាំងនោះ ឈ្មោះថា **ឧទ្ធម្ភាគិយ** ព្រោះជាហេតុមិនដាច់នៃរូបភព និងអរូបភពទាំងនោះ ។

លោកអាចារ្យកាលសម្តែងអត្ថទាំង ២ យ៉ាង គឺរមែងសៅហ្មងខ្លួនឯង និងរមែងធ្វើសម្បយុត្តធម៌ទាំងឡាយឲ្យសៅហ្មង ទើបពោលពាក្យជាដើមថា **ព្រោះខ្លួនឯងក៏សៅហ្មង** ដូច្នេះ ។

**មិច្ឆាវិមុត្តិ** បានដល់ មិច្ឆាវិមោក្ខ ដែលប្រព្រឹត្តទៅថា **មោក្ខមានត្រង់កំពូលនៃលោកជាដើម** ។ ឈ្មោះថា **មិច្ឆាញាណ** ព្រោះប្រព្រឹត្តទៅខុស គឺវិបរិត មិនត្រឹមត្រូវដោយអំណាចការប្រកាន់មាំជាដើម បានដល់ មោហៈនោះឯង ។

ពាក្យថា **កាលការប្រព្រឹត្តទៅនៃលោក** គឺកាលការប្រព្រឹត្តទៅនៃខន្ធមាន ។ ពាក្យថា **ព្រោះជាធម៌មានមិនដាច់ខ្សែ** គឺព្រោះមិនដាច់ខ្សែរឿយៗ ដោយអំណាចបុណ្យ និងបាប ។ ដោយវោហារដែលពោលពឹងផ្អែកដល់ហេតុ ដោយន័យជាដើមថា **លាភហេតុកោ លាភោ** ធម៌មានលាភជាហេតុ ឈ្មោះថា **លាភ** ។

ការកំណាញ់ក្នុងអាវាស ឬការកំណាញ់ មានអាវាសជាហេតុ ឈ្មោះថា **អាវាសមច្ឆរិយ** កំណាញ់អាវាស ។

ពាក្យថា ៣ លោកពោលទុកដោយមិនចែកវត្ថុ តែកាលចែក ពោលក៏ជាវិបល្លាស ១២ ។

ការចង បានដល់ ការធ្វើការៈដែលទាក់ទងគ្នាជាហេតុ ឈ្មោះថា **ការចងធ្វាក់** ព្រោះហេតុនោះ ការចងធ្វាក់នោះ រមែងបានក្នុងរូបកាយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **នាមកាយ និងរូបកាយ** ដូច្នេះ ក្នុងពាក្យនោះ គប្បីជ្រាបអត្ថថា ចងធ្វាក់នៃព្យាបាទ ព្រោះប្រព្រឹត្តទៅដោយអំណាចការចាប់យកយ៉ាងណែន និងការចូលទៅចងទុក ព្រោះលោកពោលព្យាបាទនោះ ជា **បដិឃសំយោជនៈ** ។

ពាក្យថា **ព្រោះការស្រឡាញ់ ការស្អប់ ការវង្វេង និងការខ្លាច** សេចក្ដីថា ព្រោះមានការស្រឡាញ់ ការស្អប់ ការវង្វេង និងការខ្លាចជាហេតុ ។ បទថា **តញ្ហិ យោគ អកត្តព្វករណំ កតព្វាករណញ្ច** ប្រែថា ពិតហើយ ការធ្វើរបស់ដែលមិនគួរធ្វើ និងការមិនធ្វើរបស់ដែលគួរធ្វើ ។

បទថា **សវនា** ប្រែថា ព្រោះប្រព្រឹត្តទៅ ។ បទថា **សវនតោ** សេចក្ដីថា ព្រោះការហូរទៅ ដោយការៈដែលមិនស្អាត គឺកិលេស ។ បទថា **សវនតោ** មួយស័ព្ទទៀត សេចក្ដីថា ព្រោះជួប ។

ដោយពាក្យថា **ព្រោះអត្ថ គឺការទាញមក និងព្រោះអត្ថ គឺធ្វើងផុតបានលំបាក** នេះ លោកអាចារ្យរមែងសម្ដែងថា ធម៌ទាំងឡាយ ដូចអន្លង់ទឹក ឈ្មោះថា **ឱឃៈ** ។ លោកអាចារ្យរមែងសម្ដែងថា ធម៌ទាំងឡាយ ឈ្មោះថា **យោគៈ** ព្រោះអត្ថគឺប្រកបទុក ពោល គឺមិនឲ្យការព្រាត់ប្រាសទៅអំពីអារម្មណ៍ និងអំពីទុក្ខ អធិប្បាយថា **ព្រោះអត្ថ គឺធ្វើការសៅហ្មង** ។ បទថា **តេសំយេវ យោគ កាមរាគាទីនំយេវ** ប្រែថា នៃធម៌ទាំងឡាយ មានកាមរាគៈជាដើមនោះឯង ។ ពិតហើយ ធម៌ទាំងឡាយមានកាមរាគៈជាដើមនោះ កាលប្រព្រឹត្តទៅដោយអំណាចខ្សែ រមែងញ៉ាំងសត្វទាំង

ឡាយដែលធ្លាក់ទៅក្នុងក្រសែ ឲ្យដល់សមុទ្រ គឺអបាយ ដូចខ្សែទឹក រមែងមិនឲ្យងើបក្បាលឡើងបានអំពីសមុទ្រ គឺសង្សារ រមែងមិនលែងអារម្មណ៍តាមដែលទទួលទុកហើយផង សត្វទាំងឡាយ ធ្វើបាបណាផង ជាអ្នកបានទទួលទុក្ខ រមែងប្រកបសត្វទុកដោយបាប ដូច្នោះទៀត ។

ពាក្យថា **ចិត្ត** បានដល់ កុសលចិត្ត ដោយពិសេស បានដល់ ឈានចិត្ត ។ ការរារាំងអំពីខាងដើម ឈ្មោះថា **អាវរណំ** ។ ការនាំយកកិលេស និងវាសនាមករារាំងទុក ឈ្មោះថា **នីវរណំ** ។ ការបិទ ដូចបិទដោយជញ្ជាំង និងសន្ទះទ្វារជាដើម ឈ្មោះថា **បដិច្ឆាទនំ** ការរា ការរាំង និងការបិទនោះ គប្បីឃើញដោយអំណាចការមិនឲ្យដើម្បីនឹងរួបរួម ដើម្បីនឹងកំណត់ដឹង និងដើម្បីដឹងកុសលជាដើម ។

ពាក្យថា **នូវសភាវៈនៃធម៌នោះៗ** គឺនូវសភាវៈ មានការមិនស្អាតជាដើមនៃធម៌នោះៗ មានកាយជាដើម ។ ពាក្យថា **សភាវៈដែលមិនពិត** បានដល់ ភាវៈមានការស្អាតជាដើម ។

ពាក្យថា **ព្រោះអត្ថថា ខ្ជាំងក្លា** សេចក្តីថា ព្រោះភាវៈដែលខ្ជាំងក្លា ។ ឯពាក្យថា **កម្លាំង** គប្បីឃើញសភាវៈនៃធម៌ទាំងឡាយ មានកាមរាគៈជាដើម មិនទូទៅដល់ធម៌ដទៃ ជាហេតុដែលព្រះមានព្រះភាគ ត្រាស់ហៅធម៌ទាំងនោះឯងថា **អនុស័យ** ។ ឯអនុស័យទាំងឡាយ គួរដល់ការកើតឡើង ក្នុងកាលមានការដល់ព្រមនៃបច្ច័យ ដោយភាវៈដែលមិនទាន់លះបានដោយមគ្គ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដេកត្រាំ ទៅដោយភាវៈដែលកាមរាគៈជាដើមជាហេតុកើតរឿយៗ នោះឯង** ។

លោកអាចារ្យពោលថា **ដូចប្រេង ថ្នាំបន្តក់ភ្នែក និងកក់** ដូច្នេះ សំដៅយកការប្រព្រឹត្តទៅដោយភាវៈដែលជម្រះបានលំបាក ។

ពាក្យថា **ដ៏សេស** បានដល់ កាមរាគៈ និងបដិឃៈ ដែលមិនជាឋានៈទៅ

អបាយ ។ ក្ខាប់សេចក្ដីថា កាមរាគ: និងបដិឃ: ចំណែកដែលល្អិត ។ ដោយ **អវធារណ** ថា **ចតុត្ថញ្ញាណវជ្ឈា ឯវ** ជាធម៌ដែលចតុត្ថញ្ញាណគប្បីប្រហារ លោកបដិសេធធម៌ដែលញាណដទៃ មានបឋមញ្ញាណជាដើមគប្បីប្រហារ ។ លោកអាចារ្យកាលសម្ដែងថា ការសម្ដែងការកម្ចាត់សេចក្ដីនេះ គប្បីនាំទៅប្រើសូម្បីក្នុងទីដទៃផង ទើបពោលពាក្យជាដើមថា **តទៅ** ។ ក្នុងបណ្ដាពាក្យទាំងនោះ ដោយពាក្យថា **ខ្ញុំនឹងមិនធ្វើការកំណត់សេចក្ដី** នេះ រមែងត្រូវព្រមទទួលសូម្បីធម៌ដែលមគ្គជាន់ទាបគប្បីប្រហារ ក្នុងកាលមិនបានធ្វើការកំណត់សេចក្ដីទុកនោះឯង ដូច្នេះឯង ។

ក្នុងពាក្យថា **លោភ: មោហ: មាន: ថីន: ឧទ្ធច្ច: អហិរិក: អនោត្តប្ប: ដែលចតុត្ថញ្ញាណគប្បីប្រហារ** ជាដើម គប្បីជ្រាបអធិប្បាយថា ធម៌ មានឋាន:ទៅអបាយ ដែលញាណទាំងឡាយ មានបឋមញ្ញាណជាដើមបានលះហើយជាដើម ។ ដោយ **អាទិ-ស័ព្ទ** លោកកាន់យកធម៌ចំណែកដែលគ្រោតគ្រាត និងចំណែកដែលល្អិត ។ ពាក្យថា **ក្នុងយស** គឺក្នុងបរិវារ ។

ធម៌ទាំងឡាយ មានឆន្ទ:ជាដើម ក្នុងអគតិទាំងឡាយ ដែលមគ្គខាងលើគប្បីប្រហារដោយពិត សូម្បីយ៉ាងនោះ ក៏ឈ្មោះថា ដែលបឋមមគ្គគប្បីប្រហារ ព្រោះធ្វើវត្ថុដែលមិនគួរធ្វើ និងមិនធ្វើវត្ថុដែលគួរធ្វើ ដែលមានឆន្ទ:ជាដើមនោះ ជាមូលដ្ឋានទៅអបាយ ។

កុក្កុច្ច:ណា ដែលជាវិប្បដិសារ: មានកុសល និងអកុសលដែលបានធ្វើហើយ និងមិនបានធ្វើជាវិស័យ កុក្កុច្ច:នោះ លោកពោលថា **គឺតតិយញ្ញាណ គប្បីប្រហារ** ក្នុងទីនេះ ។ ចំណែកកុក្កុច្ច:ណា ដែលលោកពោលទុកថា **ភិក្ខុរមែងត្រូវអាបត្តិ ព្រោះជាអ្នកត្រូវកុក្កុច្ច:គ្របសង្កត់** លោកសំដៅយកកុក្កុច្ច:នោះ ពោលទុក **ក្នុងអដ្ឋសាលិនី** ថា កុក្កុច្ច: និងវិចិកិច្ឆា ដែលសោតាបត្តិមគ្គរមែងលះបាន ដូច្នេះ ព្រោះហេតុនោះ

បណ្ឌិតគប្បីជ្រាបអធិប្បាយនៃពាក្យទាំង ២ ទុក ។ គប្បីស្វែងរកអធិប្បាយក្នុងឋានៈដូច្នេះ ក្នុងទីដទៃផងចុះ មិនគប្បីប្រកាន់ជឿទៅយ៉ាងខុស ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលកុក្កុច្ចៈជាធម៌ដែលបឋមញ្ញាណ និងតតិយញ្ញាណគប្បីប្រហារ សំដៅដល់ការលះកុក្កុច្ចៈគ្រោតគ្រាត និងការលះ ដោយមិនមានសេសសល់ ។ ឯកុក្កុច្ចៈមកហើយក្នុងព្រះបាលីថា ព្រះសារីបុត្ររង្កៀសថា ព្រះមានព្រះភាគ ទ្រង់បដិសេធការនៅធាន់អាហារក្នុងរោងទានជាប្រចាំ ដូច្នេះ ទើបមិនទទួលនិមន្ត ដូច្នេះ ។ ការរង្កៀសនោះ មិនមែនជានីវរណៈ ព្រោះកើតឡើងដល់ព្រះអរហន្ត តែប្រៀបបាននឹងនីវរណៈ ឈ្មោះថា **ជាកុក្កុច្ចៈក្នុងព្រះវិន័យ** ដែលពិចារណាថា **គួរ ឬមិនគួរ** កុក្កុច្ចៈក្នុងព្រះវិន័យនោះ ក៏គឺការកើតឡើងនៃចិត្តដែលប្រព្រឹត្តទៅយ៉ាងនោះ ។

**កាមរាគានុស័យ** និង **បដិឃានុស័យ** ចំណែកដែលល្អិត **ដែលតតិយញ្ញាណគប្បីប្រហារ** ។ ចំណែកកាមរាគានុស័យ និងបដិឃានុស័យដែលគ្រោតគ្រាតជាធម៌ដែលទុតិយញ្ញាណគប្បីប្រហារ មានន័យដូចបានពោលមកហើយខាងដើមនោះឯង ។

ដោយស័ព្ទថា **ចិត្តុប្បាទ** ក្នុងទីនេះ គប្បីឃើញថា លោកធ្វើការសង្គ្រោះ សូម្បីឧបក្កិលេសទាំងឡាយ មានមក្ខៈ បលាសៈ មាយា សាថេយ្យ បមាទៈ ថម្ភៈ និងសារម្ភៈជាដើមផងដែរ ។

ក្នុងពាក្យថា **ការព្យាយាម ក៏ត្រូវឥតផល** នេះ គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះ ក្នុងការលះធម៌ដែលជាអតីត ការព្យាយាមដែលឥតផល ចូរលើកទុកសិន ព្រោះធម៌ដែលជាអតីត បានរលត់ទៅហើយ តែការលះធម៌ដែលជាអនាគត ដូចម្តេចហ្ន៎ ព្រោះហេតុនោះ បុគ្គលដែលមិនដឹងការមិនវិបរិត ដែលនឹងពោលដល់តទៅនៃធម៌ដែលជាអតីត និងអនាគតនោះ ក៏បានកាន់យកត្រឹមតែការមិនមាន មកចោទសួរឡើង សូម្បីយ៉ាងនោះ ក៏បានធ្វើការចោទសួរភាវៈដែលមិនមាននៃធម៌ទាំងឡាយ ដែលគប្បី

លះមុនថា **មិនមានផល** ឥឡូវនេះ ក៏មកសួរដល់ការលះ ។ បើការលះ មានធម៌ទាំងឡាយ ដែលគប្បីលះនឹងមានដូចម្តេច ? បើធម៌ទាំងឡាយដែលគប្បីលះ មានការលះនឹងមានបានដូចម្តេច ? រមែងមានធម៌ទាំងឡាយ ដែលគប្បីលះ និងរមែងមានទាំងការលះ ព្រោះហេតុនោះ សេចក្តីនេះ ទើបជាការជំទាស់គ្នា ។ ព្រោះហេតុអ្វី ? ព្រោះកាលមានធម៌ទាំងឡាយ ដែលគប្បីលះ ការលះមិនមាន ការព្យាយាមដ៏សមគួរដល់ការលះនោះ ក៏ឥតផល ប្រៀបដូចកាលមានការតាំងចុះ រួមគ្នានៃពន្លឺ និងងងឹត ពន្លឺក៏ជាវត្ថុដែលឥតផល ដូច្នោះ ។ ប្រសិនបើការលះ គប្បីមាន តើមានដូចម្តេចខ្លះ ? **ឯមគ្គភាវនា ក៏នឹងក្លាយជាសង្កិលេសិកធម៌ទៅហើយ** ព្រោះវត្ថុដែលគប្បីលះ និងបុគ្គលលះនៅរួមគ្នា ។ អធិប្បាយថា **ឬក្លាយជាកិលេសទាំងឡាយជាវិប្បយុត្តទៅ** ដូចជាសង្ខារដែលជាវិប្បយុត្តរបស់ពួកអាចារ្យដែលមានលទ្ធិថា សង្ខារជាចិត្តវិប្បយុត្តទាំងឡាយ ។ លោកអាចារ្យកាលសម្តែងថា ឯពាក្យនោះ ត្រឹមតែជាមតិរបស់ពួកមេលទ្ធិប៉ុណ្ណោះ យ៉ាងណា សូម្បីក្នុងទីនេះ ក៏យ៉ាងនោះ ទើបពោលថា **ឯបច្ចុប្បន្នកិលេសមិនឈ្មោះថា ជាចិត្តវិប្បយុត្តទេ** ដូច្នេះ ។ សេចក្តីពិត អរូបធម៌ទាំងឡាយ ប្រព្រឹត្តទៅជាធម្មជាតិមានវត្ថុដូចគ្នា ទាក់ទងនៅក្នុងខណៈទាំង ៣ ចាត់ជាបច្ចុប្បន្ន អរូបធម៌ទាំងនោះ គប្បីឈ្មោះថា **វិប្បយុត្ត** ( មិនប្រកប ) ដោយចិត្តដូចម្តេច ព្រោះហេតុនោះ កិលេសទាំងឡាយជាវិប្បយុត្ត ទើបមិនមាននោះឯង ។ បទថា **អាវេណិកា** ( ជាពាក្យពិសេស ) គឺមិនទូទៅ អធិប្បាយថា ជាព្រះបាលីដែលធ្វើឲ្យកើតឡើងខ្លួនឯង មិនត្រូវបានលើកឡើង ។ ភ្ជាប់សេចក្តីបាលីថា **បាឡិយំយេវ ហិ បដិក្ខិត្តំ** ដោយព្រះបាលី លោក... បដិសេធទុក ។ **ស្វាយំ យោគ បុគ្គលោ** ប្រែថា បុគ្គលនេះ ។ ស័ព្ទថា **ហញ្ចិ** សេចក្តីប៉ុនគ្នានឹង **យទិ** ប្រែថា ឧបមាថា ។

បទថា **វិនិពន្ធោ** ( បុគ្គលក្បាលរឹង ) បានដល់ បុគ្គលដែលមានចិត្តរឹងត្អឹង

ដោយមានះ ។ បទថា **បរាមដ្ឋោ** ( បុគ្គលប្រកាន់មាំ ) បានដល់ បុគ្គលដែលប្រកាន់មាំដោយយល់ខុស ។ បទថា **ថាមគតោ** ប្រែថា បុគ្គលមានកិលេសខ្លាំងក្លា គឺបុគ្គលមានអនុស័យដែលដល់នូវភាពជាធម្មជាតិមាំទាំ ។ ពាក្យថា **បើយ៉ាងនោះមគ្គភាវនាក៏ឈ្មោះថា មិនមាន** សេចក្ដីថា ព្រោះការលះកិលេសក្នុងកាលទាំង ៣ និងកិលេសមាន ៣ កាល មិនត្រឹមត្រូវ ដូច្នោះ មគ្គភាវនាក៏មិនមាន អធិប្បាយថា កិច្ចដែលគប្បីឲ្យសម្រេចដោយមគ្គភាវនានោះ មិនមាន ។ ដោយពាក្យថា **មិនមែនមគ្គភាវនា មិនមាន** ជាដើម លោកបដិសេធពាក្យបដិសេធដែលពោលហើយ ៤ វារៈ ។ **ឥទំ វុត្តំ** នាំយកពាក្យថា **បាឡិយំយេវ ហិ** ជាដើម មកភ្ជាប់ចូល ។

បទថា **ឯវមេវ** គប្បីជ្រាបការប្រៀបធៀបដោយឧបមាថា កាលឫសត្រង់ដើមឈើជំទង់ ដែលមានផ្លែមិនទាន់កើត ត្រូវកាត់ទៅ ផ្លែដែលគួរនឹងកើតតទៅ កាលការកាត់មិនមាន ក៏មិនកើតឡើង ព្រោះការកាត់ជាបច្ច័យ រមែងឈ្មោះថា ត្រូវវិនាសទៅហើយយ៉ាងណា កាលមគ្គភាវនាមិនមាន កិលេសទាំងឡាយដែលគួរកើតឡើងក៏មិនកើតឡើង ដោយមគ្គភាវនា លោកហៅថា **លះទៅហើយ** ក៏មានឧបមេយ្យដូច្នោះ ។ ពាក្យថា **ឧប្បាទ** លោកពោលដល់ខន្ធទាំងឡាយដោយលើកយកស័ព្ទថា **ឧប្បាទ** ជាប្រធាន ។ ពាក្យថា **ក្នុងឧប្បាទ** គឺក្នុងនិព្វាន ។ **កិលេសទាំងនោះមិនទាន់កើត ក៏មិនកើត** ព្រោះហេតុនោះ ទើបឈ្មោះថា ជាការលះបានហើយ ព្រោះហេតុនោះ ការបដិសេធដែលបរវាទីបានធ្វើទុកថា **ការលះកិលេសមិនមាន** ដូច្នេះ ទើបត្រូវបានបដិសេធទុកថា **ន ហិ** ដូច្នេះ ។ ឯកិលេសទាំងនោះ មិនមែនកើតឡើងហើយទៅប្រាសឡើយ ហើយមិនមានតទៅឡើយ និងកើតឡើងហើយទេ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្ដែងថា ពាក្យថា **រមែងលះកិលេសទាំងឡាយដែលកន្លងទៅហើយ** ដូច្នេះជាដើម មិនគួរពោល ។ ពាក្យថា **ព្រោះការរលត់នៃហេតុ** គឺព្រោះ

ការរលត់នៃកិលេសទាំងឡាយដែលជាហេតុនៃទុក្ខ ។ ពាក្យថា **ការរំលត់ទុក្ខ** បានដល់ការរំលត់ទុក្ខដែលនឹងកើតឡើងតទៅ ។ ឧប្បាទ បវត្ត និមិត្ត និងអាយូហនា លោកកាន់យកដោយអំណាចបច្ចុប្បន្នភព ។

បទថា **ឯតេន យោគ អជាតាយេវ ន ជាយន្តីតិ អាទិវចនេន** ប្រែថា ដោយពាក្យថា កិលេសទាំងឡាយ ដែលមិនទាន់កើតក៏មិនកើតជាដើមនោះ ។ កិលេសទាំងឡាយ មានការបាននូវស្ថានទីប្រព្រឹត្តទៅនៃភូមិ ពោល គឺឧបាទានក្ខន្ធ ៥ ដែលជាអារម្មណ៍នៃវិបស្សនា ឈ្មោះថា **ភូមិលទ្ធា** ប្រែថា បានភូមិ ដូចជាពាក្យថា **អគ្គិអាហិតោ** អ្នកបូជាភ្លើង សេចក្ដីប៉ុនគ្នានឹង **លទ្ធភូមិកា** ប្រែថា មានភូមិដែលបានហើយ ។ លោកអាចារ្យពោលថា **កិលេសទាំងនោះ ឈ្មោះថា ភូមិលទ្ធុប្បន្នា** ប្រែថា កើតឡើងដោយបានភូមិ ព្រោះជាកិលេស ដែលផ្សេងអំពីកិលេស ដែលកើតឡើងដោយកាល មានបច្ចុប្បន្នជាដើម ។

វត្ថុដែលសោយហើយ ប្រាសទៅ និងមានហើយ ប្រាសទៅ ឈ្មោះថា **ភូតា-បគត** ប្រែថា សោយហើយ និងមានហើយ ប្រាសទៅ ។ ពិតហើយ ធម៌ទាំងឡាយដែលសោយហើយ និងមានហើយ លោកពោលដោយ **ភូត-ស័ព្ទ** ព្រោះជាវត្ថុដែលមានហើយស្មើគ្នា ។ ឯការស្មើគ្នានោះឯង លោកធ្វើឲ្យផ្សេងទុក ដោយឧបសគ្គ ។ ឯ **អនុភូត-ស័ព្ទ** គប្បីឃើញថា ប្រាប់ដល់អ្នកសោយ ព្រោះមិនមានបំណងដល់ការពោលដោយកម្ម ។ ទាក់ទងនឹងការកាន់យកអត្ថ ដែលវិកប្បទុក អកុសល និងកុសលរមែងសោយនូវរសនៃអារម្មណ៍ ដោយកិលេស មានរាគៈជាដើម និងដោយធម៌ដែលជាចំណែកដទៃអំពីកិលេស មានរាគៈជាដើមនោះ វិបាកមិនមែនសោយរសនៃអារម្មណ៍ឡើយ ព្រោះត្រូវកម្លាំងកម្មបន្សាត់ឡើងហើយ ទាំងកិរិយាក៏មិនមែនសោយរសនៃអារម្មណ៍ឡើយ ព្រោះជាធម៌ដែលជាអហេតុកៈទាំងឡាយ ជាធម៌មានកម្លាំងទុព្វលពន់

ពេក និងព្រោះធម៌ ដែលជាសហេតុកៈទាំងឡាយ ដែលកើតឡើងដល់លោក ដែលមានកិលេសអស់ហើយ ដែលមានឧទ្ធច្ចបេក្ខា ជាធម៌ដែលមានការប្រព្រឹត្តទៅល្អិតក្រៃលែង ។ ក្នុងអធិការនេះ លោកអាចារ្យពោលថា **ភូតាបគតំ** ( របស់ដែលកើតឡើង ហើយប្រាសទៅ ) ដោយមានបំណងនឹងពោលកុសល និងអកុសលតែម្យ៉ាងក្នុងន័យមុន ដែលលោកអាចារ្យបានកាន់យកថា **ជារបស់ដែលកើតឡើង** ហើយពោលការលះ និងការចម្រើនធម៌ ដែលដូចគ្នាជាមួយកុសល និងអកុសលនោះ ក្នុងពាក្យនេះថា **ដើម្បីលះអកុសលធម៌ទាំងឡាយដែលកើតឡើង ដើម្បីការតាំងនៅនៃកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ** ។ ដោយ ច-ស័ព្ទ ក្នុងន័យក្រោយ លោកអាចារ្យទាញយកកុសល និងអកុសល មកពោលជាសង្ខតៈទាំងអស់ ដោយបំណងយកឈ្មោះថា ជា **ភុត្វាបគត** ( មានហើយប្រាសទៅ ) ។ កម្មអតីតដែលកើតឡើង ដោយអំណាចធ្វើឱកាសដើម្បីឲ្យផល និងវិបាកដែលផ្តើមកើតឡើងអំពីអតីតកម្មនោះ ដែលមិនទាន់មកដល់ លោកហៅថា **ឱកាសកតុប្បន្ន** ( ប្រែថា កើតឡើងដោយឱកាស ឬកើតឡើងដោយមានឱកាស ដែលកម្មធ្វើឲ្យ ) ។ ដោយអំណាចអត្ថទាំង ២ គឺឱកាសដែលកម្មនេះធ្វើហើយ និងឱកាសដែលធ្វើហើយអំពីវិបាកនេះ ដែលជាវត្ថុកើតឡើងបាន យល់បាន វៀរចាក **ឧប្បន្ន**-ស័ព្ទ ដែលព្រះមានព្រះភាគ ទ្រង់សំដៅដល់ត្រាស់ទុកថា **នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ** ម្នាលភិក្ខុទាំងឡាយ តថាគតមិនដឹងហើយ រមែងមិនពោលការអស់ទីបំផុតនៃកម្ម ដែលសត្វតាំងចិត្តធ្វើសន្សំឡើង ដូច្នេះជាដើម ។

ពាក្យថា **ក្នុងភូមិនោះៗ** បានដល់ ក្នុងឧបាទានក្ខន្ធទាំងឡាយ ពោល គឺអត្តភាពរបស់មនុស្ស និងទេវតាជាដើម ។ ឈ្មោះថា **មិនទាន់បានដកឡើង** ព្រោះជាភាវៈដែលមិនបានធ្វើឲ្យដល់នូវសភាព ដែលមិនកើតឡើងក្នុងសន្តាននោះៗ ជាធម្មតា ។

ក៏ព្រោះអកុសលនោះមិនទាន់បានដកឡើង ទើបអកុសលរមែងមាន ហេតុនោះ រៀបការថា **ឧប្បន្ន** ( របស់ដែលកើតឡើង ) នឹងមាន ក៏ដោយភាពជាពាក្យដែលមិនគួរពោល ។ គប្បីបដិសេធការសង្ស័យថា **ភូមិ គឺអ្វី ឬភូមិលទ្ធ គឺអ្វី** ទើបលោកអាចារ្យផ្ដើមពាក្យថា **ឯក្នុងប្រការនេះ** ដូច្នេះជាដើម ដោយពាក្យថា **ដែលជាអារម្មណ៍របស់វិបស្សនា** នេះ លោកអាចារ្យរមែងសម្ដែងខន្ធទាំងឡាយ ដែលព្រះយោគីមិនទាន់បានកំណត់ដឹង មិនមែនសម្ដែងត្រឹមតែជាអារម្មណ៍ប៉ុណ្ណោះឡើយ ព្រោះត្រឹមតែជាអារម្មណ៍នោះ សម្រេចបានដោយស័ព្ទថា **ដែលប្រព្រឹត្តទៅក្នុងភូមិ ៣** ។ ពិតហើយ ខន្ធទាំងឡាយ ដែលមិនទាន់បានកំណត់ដឹង លោកមានបំណងយកថា ជាភូមិនៃកិលេសទាំងឡាយ ។ **ក្នុងខន្ធទាំងឡាយ** ដែលជាទីតាំង ។ ពាក្យថា **ដោយអំណាចអារម្មណ៍** គឺដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ អធិប្បាយថា **ខន្ធដែលជាអតីត និងអនាគត** នឹងពោលថ្វីដល់ខន្ធទាំងឡាយដែលជាបច្ចុប្បន្ន ។ បទថា **តំ** សេចក្ដីថា **តំ យោគ អញ្ញសន្តានគតំ កិលេសជាតំ** ប្រែថា កិលេសជាតិដែលប្រព្រឹត្តទៅក្នុងសន្តានរបស់អ្នកដទៃនោះ ។ ភ្ជាប់សេចក្ដីថា ឧបមាថា កិលេសជាតិនឹងគប្បីឈ្មោះថា **ភូមិលទ្ធ** ដោយត្រឹមតែធ្វើឲ្យជាអារម្មណ៍ក្នុងសន្តានដទៃក្រៅអំពីនោះសោត ។ បទថា **តស្ស យោគ កិលេសជាតស្ស** ប្រែថា នៃកិលេសជាតិនោះ ។ **បុគ្គលណាម្នាក់ ក៏មិនគប្បីលះមូលនៃភពបាន** ព្រោះកិលេសជាតិនោះ **មិនជារបស់ដែលខ្លួនលះបាន** ព្រោះធ្លាក់ទៅក្នុងសន្តានអ្នកដទៃ ។ អធិប្បាយថា ឯភូមិលទ្ធរមែងឈ្មោះថា ជាកិលេសជាតិដែលដេកត្រាំ ។ ពាក្យថា **ដោយអំណាចវត្ថុ** គឺដោយអំណាចទីកើត ។ **យត្ថ យត្ថ យោគ ភវេ** ប្រែថា ក្នុងភព **ណាមួយ ឬ យោគ សន្តានេ** ប្រែថា ក្នុងសន្តាន **ណាមួយ** ។ លោកពោលថា **ខន្ធទាំងឡាយ ដែលមិនបានកំណត់ដឹង** ព្រោះខន្ធទាំងឡាយដែលកំណត់ដឹងហើយ មិនមែនជាភូមិ ។ ពាក្យថា **ចាប់ផ្ដើមអំពីការ**

**កើតឡើង** គឺតាំងអំពីការកើតឡើងនៃខន្ធទាំងនោះ ។ **កិលេសជាតិ** រមែងដេកត្រាំក្នុងខន្ធទាំងឡាយ **ទាំងនោះ** ព្រោះមិនមានហេតុដទៃ វៀរកិលេសទាំងឡាយ ដែលមិនទាន់លះបាន ដូច្នោះ កិលេសជាតិដែលកំពុងដេកត្រាំនោះ **គប្បីជ្រាបថា ជាភូមិលទ្ធដោយអត្ថ គឺមិនទាន់លះបាន** ពោល គឺការដេកត្រាំនោះឯង ។

ក្នុងបណ្ដាខន្ធទាំងឡាយ ដែលជាភូមិនោះ ខន្ធទាំងអស់មិនមែនជាវត្ថុរបស់បុគ្គលទាំងអស់ឡើយ ដោយពិត មានការផ្សេងគ្នា ព្រោះហេតុនោះ លោកអាចារ្យកាលសម្ដែងការផ្សេងគ្នានោះ ទើបពោលពាក្យថា **យស្ស យេសុ** ដូច្នេះជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ បទថា **យស្ស** សេចក្ដីថា **យស្ស យោគ បុគ្គលស្ស** ប្រែថា របស់បុគ្គលណា ។ បទថា **យេសុ** សេចក្ដីថា ក្នុងខន្ធទាំងឡាយណា គឺដែលផ្សេងដោយប្រភេទ មានខន្ធដែលជាអតីតជាដើម និងខន្ធដែលជាកាមាវចរជាដើម កាលមានភាពស្មើគ្នា ដោយភាពជាខាងក្នុង ។ **ខន្ធទាំងឡាយ** តាមដែលដេកត្រាំហើយ **នោះប៉ុណ្ណោះ** ។ សួរថា កិលេសទាំងនេះ រមែងកំណត់ ការដេកត្រាំ ដូចជាធ្វើឲ្យជាអារម្មណ៍ឬ ? ឆ្លើយថា ព្រោះខន្ធទាំងឡាយនោះប៉ុណ្ណោះ លោកពោលថា ជាវត្ថុនៃកិលេសទាំងនោះការប្រព្រឹត្តទៅដោយកំណត់វត្ថុនៃអនុស័យទាំងឡាយមិនមាន ។ ឯអត្ថថា មិនទាន់លះបាននូវកិលេសទាំងឡាយឯណា ក្នុងវត្ថុតាមដែលកំណត់ដោយអំណាចជាអតីតជាដើម និងជាកាមាវចរជាដើម អត្ថថា មិនទាន់លះបាននោះ រមែងដូចជាកំណត់ប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងអតីតក្ខន្ធទាំងឡាយ** ជាដើម ព្រោះហេតុនោះ ទើបភូមិលទ្ធ មានដោយអំណាចវត្ថុ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្ដែងថា ការផ្សេងគ្នានៃភូមិលទ្ធនោះ គប្បីមានដោយការផ្សេងគ្នានៃវត្ថុ ។ ក៏ព្រោះបានកំណត់ទុកយ៉ាងនោះៗ ឯង ដោយពាក្យជាដើមថា **បុគ្គលម្នាក់ ប្រើម្រាមដៃលិទ្ធរសផែនដីនោះ** ដូច្នេះ រមែងអធិប្បាយដល់តណ្ហាទាំង

ឡាយ មានរសតណ្ហាជាដើម ដែលដេកត្រាំក្នុងកាមាវចរក្ខន្ធទាំងឡាយ បានឈានកន្លងរូបាវចរក្ខន្ធ និងអរូបាវចរក្ខន្ធទៅជាវត្ថុកាមាវចរក្ខន្ធទៀត ដោយហេតុនោះ ទើបលោកអាចារ្យសម្តែងថា **ក្នុងកាមាវចរក្ខន្ធទាំងឡាយ ក៏យ៉ាងនោះ** ជាដើម ។ ក្នុងសេចក្តីនេះ ការឈានកន្លងរូបាវចរក្ខន្ធ និងអរូបាវចរក្ខន្ធប្រព្រឹត្តទៅ យ៉ាងណា ការឈានកន្លងកាមាវចរក្ខន្ធទាំងឡាយប្រព្រឹត្តទៅ ក៏រមែងមាន ដូច្នោះ ព្រោះហេតុនោះទើបលោកអាចារ្យសម្តែងថា **ក្នុងរូបាវចរក្ខន្ធ និងអរូបាវចរក្ខន្ធទាំងឡាយ ក៏មានន័យនេះ** ។

ឯអត្ថថា ដេកត្រាំនៃកិលេសទាំងឡាយ រមែងអនុមានបានដោយអំណាចការបិទបាំង និងគ្របសង្កត់ ព្រោះកាលកិលេសនោះមិនមាន ការបិទបាំង និងការគ្របសង្កត់ក៏មិនមាន ។ អនុស័យទាំងឡាយណា ដែលព្រះអរិយបុគ្គលណាលះបានហើយ វត្ថុនៃអនុស័យទាំងនោះ ព្រះអរិយបុគ្គលនោះ ឈានកន្លងហើយ ព្រោះកំណត់ដឹងហើយ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្តែងថា **ចំណែកក្នុងព្រះអរិយបុគ្គលមានព្រះសោតាបន្នជាដើម** ដូច្នេះជាដើម ដើម្បីសម្តែងថា ឈ្មោះថា ភូមិរបស់ខន្ធទាំងនោះ នឹងមានមកអំពីណា ។ អនុស័យទាំងឡាយ លោកមានបំណងយក **កិលេសដែលជាមូលនៃវដ្ដៈ** ក្នុងទីនេះ មិនមែនអវិជ្ជា និងភវតណ្ហា ។ **កម្មឯណានីមួយ** គឺកម្មដែលជាប្រភេទចេតនាចេតសិក ឬកម្ម មានប្រភេទជាដើមថា កម្មផ្លូវកាយ ។ បទថា **ឥតិ** សេចក្តីប៉ុនគ្នានឹង **ឯវំ** ប្រែថា យ៉ាងនេះ អធិប្បាយថា ព្រោះជាបុគ្គលមានអនុស័យមិនទាន់លះបាន ។ បទថា **អស្ស យោគ បុថុជ្ជនស្ស** ប្រែថា របស់បុថុជ្ជននោះ ។ លោកអាចារ្យកាលសម្តែងថា អនុស័យទាំងឡាយទាំងនេះ សូម្បីកាលដេកត្រាំនៅក្នុងវត្ថុនោះ តាមដែលបានកំណត់ទុក ដោយអំណាចអតីតជាដើម និងជាកាមាវចរជាដើម ក៏រមែងដេកត្រាំ ធ្វើឧបាទានក្ខន្ធ ៥ នោះៗ ឲ្យជាវត្ថុដោយមិនញែកគ្នានោះឯង

ទើបពោលពាក្យជាដើមថា **កិលេសជាតិដែលជាមូលនៃវដ្ដៈនោះ របស់បុថុជ្ជនទោះ** ដូច្នេះ ។ ឥឡូវនេះ លោកអាចារ្យមានបំណងនឹងញ៉ាំងអត្ថនោះ ឲ្យជាក់ច្បាស់ដោយឧបមា ដោយជាពាក្យអនុលោមតាម និងជាពាក្យពិសេស ទើបពោលពាក្យជាដើមថា **ឧបមាដូចរសដីជាដើម** ដូច្នេះ ។ រសដីដែលមានគ្រឿងតាក់តែង ដែលជាបច្ច័យដល់ដើមឈើ និងគុម្ពឈើជាដើម ឈ្មោះថា **រសផែនដី** ។ សូម្បីក្នុង **រសទឹក** ក៏មានន័យនេះឯង ។ មែកតូច ឈ្មោះថា **សាខា** ។ **មែកធំ** បានដល់ ប្រគាប ។ ពាក្យថា **ពូជនៃដើមឈើ** បានដល់ ការបន្តគ្នានៃដើមឈើ ។ ពាក្យថា **បន្ត** គឺជាប់តាមតៗគ្នាទៅ ។

ពាក្យថា **មណ្ឌូកកណ្ដក** អាចារ្យទាំងឡាយពោលថា ជាធុងត្រីមួយប្រភេទ ។ ពាក្យថា **មិនមានឧបាទាន** គឺជាបុគ្គលមានឧបាទានទាំង ៤ លះបានហើយ ឬមិនប្រកាន់អ្វីមួយក្នុងរូបជាដើម ។

ភាពជាបុគ្គលមានលាភ គឺខ្លួនដែលបានហើយ ឈ្មោះថា **សមុទាចារ** ( ប្រព្រឹត្តទៅ ) ក្នុងទីនេះ ព្រោះហេតុនោះ **សមុទាចារុប្បន្ន** ( កើតឡើងដោយប្រព្រឹត្តទៅ ) ក៏មានការដល់ព្រមដោយខណៈទាំង ៣ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្ដែងថា **សមុទាចារុប្បន្នកើតឡើង ដោយប្រព្រឹត្តទៅ ក៏គឺវត្តមានុប្បន្ន** ។ ពាក្យថា **សូម្បីមិនទាន់កើតឡើងក្នុងកាលដំបូង** គឺដែលមិនទាន់កើតឡើងក្នុងជវនវារៈដែលប្រព្រឹត្តទៅអំពីខាងដើមក្នុងអារម្មណ៍ ដែលដល់គន្លងនៃទ្វារនោះ ។ ពាក្យថា **ព្រោះបានអារម្មណ៍ទុក** គឺព្រោះឡើងកាន់អារម្មណ៍ទទួលទុក ដោយអយោនិសោមនសិការ អធិប្បាយថា ព្រោះប្រកាន់ទុក ។ ពាក្យថា **ក្នុងពេលក្រោយ** គឺក្នុងចំណែកកាលដទៃ បានដល់ ក្នុងកាលដទៃ ។ ពាក្យថា **ព្រោះកើតឡើងពិតប្រាកដ** សេចក្ដីថា ព្រោះកើតឡើងពិតៗ ព្រោះកាលមានការដល់ព្រមនៃបច្ច័យ អយោនិសោមនសិការក៏កើតឡើង

ក្នុងអារម្មណ៍នោះ យ៉ាងនោះ ។ ពាក្យថា **ក្នុងកល្យាណគាម** បានដល់ ក្នុងស្រុកដែលមានឈ្មោះយ៉ាងនោះ ។ បានឮថា ក្នុងរោហណជនបទ គេហៅស្រុកនោះយ៉ាងនោះ ព្រោះជាទឹកដីជាទីកើតនៃស្រីស្អាតទាំងឡាយ ។ ពាក្យថា **សូម្បីមិនទាន់បានឡើងកាន់ចិត្តសន្តតិ** លោកអាចារ្យរមែងបដិសេធបច្ចុប្បន្នភាព ។ ដោយពាក្យថា **ព្រោះមិនមានហេតុ ដែលនឹងរាំងការកើតឡើង** នេះ លោកអាចារ្យរមែងសម្តែងថា កាលមានបច្ច័យ ក៏មានបរិយាយថា កិលេសដែលមិនបានសង្កត់ទុក ជាកិលេសដែលកើតឡើងបាន ដោយភាវៈដែលគួរនឹងកើតឡើងបាន ព្រោះការដល់ព្រមនៃបច្ច័យ ។ សូម្បីសមុហតុប្បន្ន ( កិលេសជាតិដែលកើតឡើងដោយមិនទាន់បានដកឡើង ) កាលមានបច្ច័យ ក៏គួរនឹងកើតឡើងបាននោះឯង មិនមែនឬ ? សេចក្តីនេះពិត តែការបែកធ្លាយនៃកិលេសទាំងនោះ ត្រូវភាពផ្សេងនៃការលះធ្វើហើយ ។ **អវិក្ខម្ភិតុប្បន្ន សមូហតុប្បន្ន** និង **ភូមិលទ្ធុប្បន្ន** កាលមានការដល់ព្រមដោយបច្ច័យ ក៏គួរនឹងកើតឡើងបាន យ៉ាងណា សូម្បី **អារម្មណាធិគហិតុប្បន្ន** ក៏ដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលឧប្បន្នទាំង ៣ ប្រការ សង្គ្រោះចូលជាមួយគ្នានឹងភូមិលទ្ធ ។

សូម្បីអកុសលដែលជា **ភូតាបគតុប្បន្ន** ញាណណាមួយ ក៏មិនគប្បីលះ ព្រោះជាអតីតកម្ម ដែលជាឱកាសកតុប្បន្នចំណែកខ្លះក៏ដូចគ្នា ឱកាសកតុប្បន្នក្រៅអំពីនេះ ញាណណាមួយ ក៏មិនគប្បីលះ ព្រោះមិនជាឧប្បន្ន ដែលញាណណាមួយគប្បីលះ ឧប្បន្នទាំង ២ ដ៏សេសក៏ដូចគ្នា ព្រោះជាឧប្បន្នដែលមានការដល់ព្រមដោយខណៈទាំង ៣ ព្រោះហេតុនោះ ទើបលោកអាចារ្យសម្តែងថា **ព្រោះមិនមែនវត្ថុដែលមគ្គគប្បីលះ** ។ ពាក្យថា **ញាណណាមួយ** បានដល់ ញាណណាមួយ ក្នុងបណ្តាមគ្គញាណ ៤ ។ បទថា **តស្ស យោគ យថា វុត្តស្ស ចតុព្វិធស្សបិ ឧប្បន្នស្ស** ប្រែថា នៃឧប្បន្នទាំង ៤ យ៉ាង តាមដែលពោលហើយនោះ ។ ពាក្យថា **ញ៉ាំងភាពជាឧប្បន្ននោះៗ**

**ឲ្យវិនាសអស់ទៅ** គឺញុំាងភាពជាឧប្បន្នដែលគួរកើតឡើងឲ្យវិនាសអស់ទៅ ដោយការឲ្យដល់នូវការមិនកើតឡើងជាធម្មតា ។ លោកអាចារ្យធ្វើសំពួចថា **លោកិយញ្ញាណ** ព្រោះលោកុត្តរញ្ញាណ រមែងលះវត្ថុដែលលោកិយញ្ញាណលះបានហើយ តាមកម្លាំងនោះឯងមុន ។

# វិសុទ្ធិមគ្គ

## កិច្ចក្នុងអរិយសច្ច

ពាក្យថា ហើយគួរជ្រាបកិច្ច មានបរិញ្ញាកិច្ចជាដើម ដែលលោកពោល ក្នុងកាលដែលត្រាស់ដឹងតាមសភាវៈគ្រប់ប្រការ សេចក្ដីថា កិច្ចបួនៗ មានបរិញ្ញាកិច្ចជាដើមនោះ គឺ **បរិញ្ញា** កំណត់ដឹង **បហាន** លះ **សច្ឆិកិរិយា** ធ្វើឲ្យជាក់ច្បាស់ **ភាវនា** ធ្វើឲ្យមានឡើង ដែលលោកពោលដោយខណៈដូចគ្នា ក្នុងញាណ ៤ នោះ តែ ១ ញាណ ក្នុងកាលដែលត្រាស់ដឹងសច្ចៈ កិច្ចនោះ បណ្ឌិតគួរជ្រាបតាមសភាវៈ ។

## មគ្គញាណធ្វើកិច្ចដូចប្រទីប

ពិតហើយ សេចក្ដីនេះ បុរាណាចារ្យទាំងឡាយ ក៏បានពោលទុកថា **ប្រទីប** រមែងធ្វើកិច្ច ៤ យ៉ាង ក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ គឺ **ឆេះប្រឆេះកម្ចាត់ងងឹត ជះពន្លឺ ស៊ីប្រេង** យ៉ាងណា មគ្គញាណក៏ត្រាស់ដឹងសច្ចៈ ៤ ដោយខណៈ ដូចគ្នា មិនមុនមិនក្រោយ ដូច្នោះដូចគ្នា គឺដឹងទុក្ខ ដោយបរិញ្ញាភិសម័យ ( ដឹងដោយកំណត់ដឹង ) ដឹងសមុទយៈ ដោយបហានាភិសម័យ ( ដឹងដោយលះ ) ដឹងមគ្គ ដោយភាវនាភិសម័យ ( ដឹងដោយធ្វើឲ្យមានឡើង ) ដឹងនិរោធ ដោយសច្ឆិកិរិយាភិសម័យ ( ដឹងដោយធ្វើឲ្យជាក់ច្បាស់ ) ។ សួរថា **មានអធិប្បាយដូចម្ដេច ?** ឆ្លើយថា មានអធិប្បាយថា ព្រះយោគាវចរធ្វើនិរោធឲ្យជាអារម្មណ៍ហើយ រមែងដល់ គឺរមែងឃើញ រមែងដឹងច្បាស់នូវសច្ចៈទាំង ៤ បាន ដូច្នេះ ។ ពិតហើយ សូម្បីព្រះមានព្រះភាគក៏បានត្រាស់ព្រះពុទ្ធវចនៈនេះទុកថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះ រមែងឃើញទុក្ខសមុទយៈ រមែងឃើញទុក្ខនិរោធ រមែងឃើញទុក្ខនិរោធគាមិនីបដិបទាផងដែរ ដូច្នេះជាដើម ពុទ្ធវចនៈទាំងអស់ (ក្នុងសូត្រនេះ) បណ្ឌិតគួរជ្រាប

ពាក្យបាលីដទៃទៀត ក៏ពោលទុកថា ញាណ រមែងមានដល់បុគ្គលដែលដល់ព្រម ដោយមគ្គ ញាណនោះ ជាញាណសូម្បីក្នុងទុក្ខ ញាណនោះ ជាញាណសូម្បីក្នុងទុក្ខសមុទយៈ ញាណនោះ ជាញាណសូម្បីក្នុងទុក្ខនិរោធ ញាណនោះ ជាញាណសូម្បីក្នុងទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ។

គប្បីជ្រាបការប្រៀបធៀបឧបមា ក្នុងសេចក្ដីឧបមានោះ ដូច្នេះ គឺមគ្គញ្ញាណ រមែងកំណត់ទុក្ខ ឧបមាដូចប្រទីបឆេះប្រឆេះ រមែងលះសមុទយៈ ដូចប្រទីបកម្ចាត់ងងឹត រមែងញ៉ាំងមគ្គ ពោល គឺធម៌ មានសម្មាសង្កប្បជាដើមឲ្យមានឡើង ដោយភាពជាបច្ច័យ មានសហជាតប្បច្ច័យជាដើម ដូចប្រទីបជះពន្លឺ រមែងធ្វើនិរោធ គឺការអស់ទៅនៃកិលេសឲ្យជាក់ច្បាស់ ដូចប្រទីបបឺតប្រេង ( ឲ្យអស់ទៅ ) ។

## មគ្គញ្ញាណធ្វើកិច្ចដូចព្រះអាទិត្យ

ន័យម្យ៉ាងទៀត ព្រះអាទិត្យរះឡើង រមែងធ្វើកិច្ច ៤ យ៉ាងព្រមជាមួយការប្រាកដ ( ខ្ទួន ) មិនមុនមិនក្រោយ គឺធ្វើវត្ថុដែលជារូបទាំងឡាយ ឲ្យប្រាកដច្បាស់ ១ កម្ចាត់ងងឹត ១ ជះពន្លឺ ១ ញ៉ាំងភាពត្រជាក់ឲ្យស្ងប់រម្ងាប់ ១ យ៉ាងណា មគ្គញ្ញាណ... ក៏ដូច្នោះដូចគ្នា ។បេ។ រមែងត្រាស់ដឹងនិរោធដោយសច្ឆិកិរិយាភិសម័យ សូម្បីក្នុងឧបមានេះ ក៏គប្បីជ្រាបការប្រៀបធៀបឧបមា ដូច្នេះ គឺមគ្គញ្ញាណ រមែងកំណត់ដឹងទុក្ខ ដូចព្រះអាទិត្យធ្វើវត្ថុដែលជារូបទាំងឡាយឲ្យប្រាកដ លះសមុទយៈ ដូចព្រះអាទិត្យកម្ចាត់ងងឹត ញ៉ាំងមគ្គឲ្យកើតឡើង ដោយភាពជាបច្ច័យ មានសហជាតប្បច្ច័យជាដើម ដូចព្រះអាទិត្យជះពន្លឺ ធ្វើនិរោធ គឺការស្ងប់រម្ងាប់ទៅនៃកិលេសឲ្យជាក់ច្បាស់ ដូចព្រះអាទិត្យ ញ៉ាំងភាពត្រជាក់ឲ្យស្ងប់រម្ងាប់ ដូច្នោះ ។

## មគ្គញ្ញាណធ្វើកិច្ចដូចទូកជំនិញ

ន័យម្យ៉ាងទៀត ទូករមែងធ្វើកិច្ច ៤ យ៉ាង ក្នុងខណៈដូចគ្នា មិនមុន មិនក្រោយ គឺលះច្រាំងអាយទៅ កាត់ក្រសែទឹក នាំទំនិញទៅ ទៅកាន់ត្រើយនាយ យ៉ាងណា មគ្គញ្ញាណ... ក៏ដូច្នោះដូចគ្នា ។បេ។ រមែងធ្វើនិរោធឲ្យជាក់ច្បាស់ ដោយសច្ចិកិរិយា-ភិសម័យ សូម្បីក្នុងការឧបមានេះ ក៏គប្បីជ្រាបការប្រៀបធៀបឧបមា ដូច្នេះ គឺមគ្គញ្ញាណ រមែងកំណត់ដឹងទុក្ខ ដូចទូកលះត្រើយអាយទៅ រមែងលះសមុទយៈ ដូចទូកកាត់ក្រសែទឹក រមែងញុំាងមគ្គឲ្យមានឡើង ដោយភាពជាបច្ច័យ មានសហជាតប្បច្ច័យជាដើម ដូចទូកនាំទំនិញទៅ រមែងធ្វើនិរោធដែលជាត្រើយនាយឲ្យជាក់ច្បាស់ ដូចទូកទៅកាន់ត្រើយនាយ ដូច្នោះ ។

## ដឹងច្បាស់អរិយសច្ចដោយអាការ ១៦

កាលមគ្គនោះ មានញាណដែលប្រព្រឹត្តទៅដោយអំណាចកិច្ច ៤ យ៉ាង ដោយខណៈដូចគ្នា ក្នុងកាលដែលត្រាស់ដឹងសច្ចៈ ដូចពោលមកនេះ សច្ចៈទាំង ៤ នោះ រមែងជាឯកបដិវេធ ( មានអាការដែលគប្បីដឹងច្បាស់ដូចគ្នា ) ដោយអត្ថ គឺយ៉ាងនោះ ដោយអាការ ១៦ ដូចបាលីថា សច្ចៈ ៤ ជាឯកបដិវេធ ដោយអត្ថ គឺយ៉ាងនោះ ដូចម្តេច ? សច្ចៈ ៤ ជាឯកបដិវេធ ដោយអត្ថ គឺយ៉ាងនោះ ដោយអាការ ១៦ គឺអត្ថ គឺបៀតបៀន អត្ថ គឺវត្ថុត្រូវតាក់តែងឡើង អត្ថ គឺដុតរោល អត្ថ គឺប្រែប្រួលទៅ ( ៤ នេះ ) ជាអត្ថ គឺយ៉ាងនោះនៃទុក្ខ អត្ថ គឺប្រមូលមក អត្ថ គឺបង្កហេតុទុក អត្ថ គឺចងទុក អត្ថ គឺរាំង ( ៤ នេះ ) ជាអត្ថ គឺយ៉ាងនោះ នៃសមុទយៈ អត្ថ គឺចេញទៅ អត្ថ គឺរលាស់ទៅ អត្ថ គឺជាវត្ថុមិនត្រូវតាក់តែង អត្ថ គឺវត្ថុមិនស្លាប់ ( ៤ នេះ ) ជាអត្ថ គឺយ៉ាងនោះនៃនិរោធ អត្ថ គឺលែងទៅ អត្ថ គឺជាហេតុ អត្ថ គឺជាកែវភ្នែក អត្ថ គឺជា

អធិបតី ( ៤ នេះ ) ជាអត្ថ គឺយ៉ាងនោះនៃមគ្គ ។ សច្ចៈ ៤ សង្គ្រោះចូលតែ ១ ដោយអត្ថ គឺយ៉ាងនោះ ដោយអាការ ១៦ ទាំងនេះ ។ វត្ថុណាសង្គ្រោះចូលតែ ១ បានវត្ថុនោះ ក៏ជាឯកត្តៈ វត្ថុណាជាឯកត្តៈ ក៏រមែងដឹងច្បាស់វត្ថុនោះ ដោយញាណតែ ១ បាន ព្រោះហេតុនោះ ទើបសច្ចៈ ៤ ជាឯកបដិវេធ ដូច្នេះ ។

ក្នុងសេចក្តីនោះ បើមានពាក្យសួរថា ដោយអត្ថដទៃៗ ទៀត ដូចជាពេគជាបូសនៃទុក្ខសច្ចជាដើម មាន បើដូច្នោះ ហេតុអ្វី ទើបលោកពោលអត្ថ ( សច្ចៈ ១ ) តែ ៤ ប៉ុណ្ណោះ ? ក្នុងសេចក្តីនេះ ខ្ញុំសូមដោះស្រាយថា ព្រោះអត្ថ ( ក្នុងសច្ចៈ ១ ) ប្រាកដច្បាស់បានដោយអំណាចការឃើញសច្ចៈដទៃ ព្រោះថា សច្ចញ្ញាណ លោកពោលទុកដោយមានសច្ចៈតែ ១ ប្រការជាអារម្មណ៍ ដោយន័យថា ក្នុងញាណទាំងនោះ ញាណក្នុងទុក្ខដូចម្តេច បញ្ញា ការដឹងទូទៅ ឯណាប្រារព្ធទុក្ខកើតឡើង ( ការដឹងនោះ ឈ្មោះថា ញាណក្នុងទុក្ខ ) ដូច្នេះជាដើម ក៏មានពោលទុកដោយធ្វើសច្ចៈ ១ ឲ្យជាអារម្មណ៍ សម្រេចកិច្ចក្នុងសច្ចៈដ៏សេសផង ដោយន័យថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ឃើញទុក្ខ បុគ្គលនោះរមែងឃើញទុក្ខសមុទយៈផងដែរ ដូច្នេះជាដើមក៏មាន ។ ក្នុងការឃើញសច្ចៈ ២ ន័យនោះ កាលណាព្រះយោគាវចរធ្វើសច្ចៈតែ ១ ឲ្យជាអារម្មណ៍ កាលនោះ ព្រោះហេតុដែលទុក្ខនោះ ដែលសមុទយៈ មានការប្រមូលមកជាលក្ខណៈ ប្រមូលមកតាក់តែងទុក រួមគំនរទុក អត្ថ គឺជាវត្ថុត្រូវតាក់តែងនៃទុក្ខសច្ច សូម្បីដោយសភាវៈ មានការបៀតបៀនជាលក្ខណៈក្នុងលំដាប់ដំបូងនោះ ក៏ប្រាកដច្បាស់ដោយការឃើញសមុទយសច្ច ។ មយ៉ាងទៀត ព្រោះមគ្គជាធម៌នាំទៅកន្លងបង់នូវការក្តៅក្រហាយដោយអំណាចកិលេស ជាធម៌ត្រជាក់ អត្ថ គឺការក្តៅក្រហាយ នៃទុក្ខសច្ចនោះ ក៏ប្រាកដច្បាស់បាន ដោយការឃើញមគ្គសច្ច ដូចស្រីមិនស្អាត នៃនាងសុន្ទរី ប្រាកដច្បាស់ដល់នន្ទមាណព ដោយបានឃើញនាងទេពអប្សរ

ដូច្នោះ ។ ម្យ៉ាងទៀត អត្ថ គឺការប្រែប្រួលទៅនៃទុក្ខសច្ច រមែងប្រាកដច្បាស់បាន ដោយការឃើញនិរោធសច្ច ដែលមានការមិនប្រែប្រួលជាធម្មតា ពាក្យដែលនឹងត្រូវពោលដល់ ( អ្វីទៀត ) ក្នុងសេចក្តីនេះ មិនមានឡើយ ។

ន័យដូចគ្នានោះ អត្ថ គឺការបន្តហេតុនៃសមុទយសច្ច ដែលមានការប្រមូលមកជាលក្ខណៈ ដោយសភាវៈក៏រមែងប្រាកដច្បាស់បាន ដោយការឃើញទុក្ខសច្ច ដូចចំណីទាស់ ជាហេតុនៃជំងឺ ប្រាកដច្បាស់បាន ដោយការឃើញការឈឺចាប់ ដែលកើតឡើង ព្រោះចំណីទាស់ ដូច្នោះ ។ អត្ថ គឺចងទុកនៃសមុទយសច្ច ក៏ប្រាកដច្បាស់ ដោយការឃើញនិរោធសច្ច ដែលជាធម៌ប្រាសចាកចំណង ។ ម្យ៉ាងទៀត អត្ថ គឺការរារាំងនៃសមុទយសច្ច ក៏ប្រាកដច្បាស់ ដោយការឃើញមគ្គសច្ច ដែលជាធម៌លែងទៅដូច្នេះ ។

ន័យដូចគ្នានោះ អត្ថ គឺការរលាស់ចោលទៅនៃនិរោធ ដែលមានការចេញទៅជាលក្ខណៈ ក៏រមែងប្រាកដច្បាស់បាន ដោយការឃើញសមុទយសច្ច ដែលជាធម៌មិនមានការរលាស់ចោលទៅ ។ អត្ថ គឺរបស់មិនត្រូវតាក់តែងនៃនិរោធសច្ច ក៏ប្រាកដច្បាស់ ដោយការឃើញមគ្គសច្ច ព្រោះមគ្គជាធម៌ដែលព្រះយោគាវចរនេះ មិនធ្លាប់ឃើញមកអំពីមុន ក្នុងសង្សារ ដែលមិនមានខាងដើម និងខាងចុង ។ ម្យ៉ាងទៀត មគ្គនោះ ក៏នៅជាសង្ខតធម៌ពិត ព្រោះជាធម៌នៅប្រព្រឹត្តទៅជាមួយបច្ច័យ ហេតុនោះ និរោធសច្ចដែលជាធម៌មិនមានបច្ច័យ ជាអសង្ខតធម៌ ទើបឃើញច្បាស់ក្រៃលែងពេក ។ ម្យ៉ាងទៀត អត្ថ គឺការមិនស្លាប់នៃនិរោធនោះ ក៏ប្រាកដច្បាស់បាន ដោយការឃើញទុក្ខសច្ច ព្រោះទុក្ខជាពិស ( ដែលធ្វើឲ្យស្លាប់ ) និព្វាន ( គឺនិរោធ ) មិនស្លាប់ដូច្នេះ ។

ន័យដូចគ្នានោះ អត្ថ គឺជាហេតុនៃមគ្គសច្ច ដែលមានការលែងទៅជាលក្ខណៈ

រមែងប្រាកដច្បាស់ ដោយការឃើញសមុទយសច្ច ដោយពិចារណាឃើញថា **សមុទយៈនេះ មិនមែនហេតុ មគ្គនេះជាហេតុនៃការដល់និព្វាន** ។ អត្ថ គឺជាកែវភ្នែកនៃមគ្គសច្ច ក៏ប្រាកដច្បាស់បាន ដោយការឃើញនិរោធសច្ច ( ដែលជាធម៌សុខុមជ្រាលជ្រៅក្រៃពេក ) ដូចការថ្វានៃចក្ខុ ប្រាកដច្បាស់ដល់អ្នកឃើញរូបទាំងឡាយ ដែលល្អិតក្រៃលែងបាន ដោយពិចារណាដឹងថា **ភ្នែករបស់អញថ្វាហ្ន៎** ។ អត្ថ គឺអធិបតីនៃមគ្គសច្ច ក៏ប្រាកដច្បាស់បាន ដោយការឃើញទុក្ខសច្ច ដូចឱឡារិកភាពនៃឥស្សរជនប្រាកដច្បាស់ ដោយការឃើញបុគ្គលក្រីក្ររស់នៅដោយរោគច្រើនយ៉ាង ដូច្នោះឯង ។

ក្នុងមគ្គញ្ញាណនិទ្ទេសនេះ ជាការពោលអត្ថនៃសច្ចៈ ១ ជាបួនៗ ដោយអត្ថឯណានីមួយ ប្រាកដច្បាស់ដោយអំណាចជាលក្ខណៈរបស់ខ្លួន និងអត្ថ ៣ ក្រៅអំពីនោះ ប្រាកដច្បាស់ដោយអំណាចការឃើញសច្ចៈប្រការដទៃ ដូចពោលមក ដូច្នេះតែក្នុងខណៈមគ្គ ( កើត ) អត្ថទាំងអស់នោះ រមែងដល់នូវបដិវេធ ដោយញាណដែលមានកិច្ច ៤ ក្នុងទុក្ខសច្ចជាដើម តែ ១ ប៉ុណ្ណោះ ដូច្នេះ ។

ចំណែកវាទិនពួកណា ( ត្រូវការឲ្យជា ) នានាភិសម័យ ( ដឹងអរិយសច្ច ៤ ដោយញាណផ្សេងៗ គ្នា ) ចម្លើយវាទិនទាំងនោះ លោកពោលទុក ក្នុងគម្ពីរកថាវត្ថុក្នុងអភិធម្មបិដកហើយ ។

# មហាដីកា

## កថាពណ៌នាដោយកិច្ច មានបរិញ្ញាកិច្ចជាដើម

ពាក្យថា **ក្នុងការត្រាស់ដឹងសច្ចៈ** គឺក្នុងខណៈដែលចាក់ធ្លុះអរិសច្ចទាំង ៤ ។ ពាក្យថា **ដែលត្រាស់ទុក** គឺដែលត្រាស់ទុក ដោយន័យជាដើមថា **ទុក្ខ ជារបស់ដែលគប្បីកំណត់ដឹង** និងដោយន័យជាដើមថា **ម្នាលភិក្ខុទាំងឡាយ បុគ្គលណា រមែងឃើញទុក្ខ** ដូច្នេះ ។ ពាក្យថា **តាមសភាវៈ** គឺតាមសភាវៈដែលមិនវិបរិត ។ លោកអាចារ្យពោលថា **គួរជ្រាប** ដូច្នេះហើយ ពោលពាក្យថា **ពិតហើយ** សេចក្តី **នេះព្រះបុរាណាចារ្យទាំងឡាយ បានពោលទុក** ដូច្នេះជាដើម ដើម្បីសម្តែងវិធីជ្រាបកិច្ចទាំងនោះ តាមន័យដែលបានពោលទុកហើយ ក្នុងអដ្ឋកថា ទាក់ទងនឹងឧបមាមុន ។

ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ប្រទីប យ៉ាងណា** ជាដើម សេចក្តីថា កិច្ច ៤ យ៉ាង ក្នុងខណៈជាមួយគ្នានៃញាណ ១ នឹងមានបានដូចម្តេច ។ លោកអាចារ្យពោលថា **ដោយបរិញ្ញាភិសម័យ** ( ដឹងដោយកំណត់ដឹង ) ដូច្នេះ ព្រោះធ្វើទុកក្នុងចិត្តនូវការចោទសួរ ដែលកំបាំងនៅខាងក្នុងថា ឯកិច្ចដូច្នោះណាមួយ ដែលឃើញបានក្នុងលោកមិនមានឡើយ និងពាក្យពោល ក៏មានមិនបាន ។ **រមែងដឹង** ដោយការចាក់ធ្លុះ ពោល គឺការកំណត់ដឹង ដោយមិនសេសសល់ **រមែងចាក់ធ្លុះ** ដោយអំណាចអសម្មោហៈ ។ ពាក្យថា **ដោយបហានាភិសម័យ** ( ដឹងដោយលះ ) គឺ **រមែងដឹង** ដោយអសម្មោហៈ ដោយការចាក់ធ្លុះ ពោល គឺសមុច្ឆេទប្បហាន ។ ពាក្យថា **ដឹងមគ្គដោយភាវនាភិសម័យ** ( ដឹងដោយធ្វើឲ្យមានឡើង ) សេចក្តីថា ដឹងមគ្គញាណ គឺមគ្គដ៏សេស មានសម្មាសង្កប្បជាដើម ដោយភាវនាភិសម័យ ពោល គឺជាបច្ច័យមានសហជាតបច្ច័យជាដើម ។ **រមែងដឹង** គឺរមែងដឹង ដោយការចាក់ធ្លុះ ពោល គឺ

ការញ៉ាំងអរិយមគ្គឲ្យមានឡើង ដែលកើតអំពីការនៅក្នុងបុព្វភាគ រមែងចាក់ធ្លុះមគ្គមានអង្គ ៨ ដោយអសម្មោហៈ ។ ពិតហើយ មគ្គញ្ញាណ កាលទម្លាយមោហៈក្នុងសម្បយុត្តធម៌ទាំងឡាយ ក៏រមែងទម្លាយសម្មោហៈសូម្បីខាងដើមនោះឯង ។ ពាក្យថា **និរោធ** បានដល់ និព្វាន ។ ពាក្យថា **ដោយសច្ឆិកិរិយាភិសម័យ** បានដល់ ដោយការចាក់ធ្លុះ ពោល គឺការធ្វើឲ្យប្រចក្ស ។ ពាក្យថា **រមែងដល់** គឺរមែងចាក់ធ្លុះ ។ ការសម្រេចនេះ បានដល់ ការឃើញ និងការចាក់ធ្លុះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងឃើញ រមែងចាក់ធ្លុះ** ដូច្នេះ ។

ដោយពាក្យថា **ព្រះយោគាវចរធ្វើនិរោធឲ្យជាអារម្មណ៍ហើយ រមែងដល់ រមែងឃើញ រមែងចាក់ធ្លុះសច្ចៈទាំង ៤** នេះ សេចក្ដីថា មគ្គញ្ញាណ រមែងចាក់ធ្លុះនិរោធសច្ច ១ ដោយការចាក់ធ្លុះអារម្មណ៍ រមែងចាក់ធ្លុះសច្ចៈទាំង ៤ ដោយការចាក់ធ្លុះដោយអសម្មោហៈ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ពិតហើយ សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ព្រះពុទ្ធវចនៈនេះទុក** ដូច្នេះជាដើម ដើម្បីញ៉ាំងការចាក់ធ្លុះដូចគ្នា ឲ្យជាក់ច្បាស់ហើយ ដោយអំណាចយុត្តិឲ្យសម្រេច សូម្បីដោយព្រះពុទ្ធវចនៈដែលមក ។ ដោយពាក្យថា **ព្រះពុទ្ធវចនៈទាំងអស់ បណ្ឌិតគួរជ្រាប** នេះ លោកអាចារ្យរមែងសង្គ្រោះពាក្យប្រកប មានសមុទយសច្ចជាដើមជាមូល ដែលមកហើយដោយន័យជាដើមថា **បុគ្គលណាឃើញទុក្ខសមុទយៈ បុគ្គលនោះ រមែងឃើញទុក្ខ** ដូច្នេះ ។

លោកអាចារ្យកាលសម្ដែងថា ឯសេចក្ដីនេះលោកពោលសំដៅដល់ការឃើញក្នុងកាលដទៃក៏ទេ ដោយពិតនោះ ជាការចាក់ធ្លុះសច្ចៈ ១ នោះឯង ដូច្នេះ បាននាំយកបទព្រះសូត្រដទៃទៀតមក ដោយន័យជាដើមថា **ញាណរបស់លោកដែលមានការដល់ព្រមដោយមគ្គនេះ ឈ្មោះថា ទុក្ខញ្ញាណ** ។ ពិតហើយ **ព្រះគវម្បតិត្ថេរ** បាន

ពោលទុក ដើម្បីញុំាងសេចក្តីនោះ ឲ្យសម្រេចក្នុងការពិចារណា សេចក្តីដែលបុគ្គលមានការដល់ព្រមដោយការឃើញសច្ចៈ ១ ក៏ជាអ្នកមានការដល់ព្រមដោយការឃើញសច្ចៈប្រការដទៃថា នៃ អាវុសោ បុគ្គលណាឃើញទុក្ខ បុគ្គលនោះ រមែងឃើញទុក្ខសមុទយៈ ។បេ។ បុគ្គលនោះ រមែងឃើញសូម្បីទុក្ខនិរោធគាមិនីបដិបទា ហើយព្រះថេរៈក៏បានធ្វើពាក្យប្រកបក្នុងការឃើញសច្ចៈទាំង ៣ តែក្នុងសច្ចៈ ១ ។កាលកាន់យកអត្ថ ដោយប្រការដទៃ ព្រោះបានឃើញថ្មីនូវសច្ចៈដែលបានឃើញអំពីមុនហើយ ការឃើញទុក្ខជាដើមនៃបុគ្គល ដែលឃើញសមុទយៈជាដើម ក៏មិនគួរពោលទៀត ហើយកាលពោលការឃើញសច្ចៈទាំងអស់ ក៏មានការឃើញដទៃយ៉ាងច្រើន ហេតុនោះ ការឃើញមិនដាច់ ការឃើញនោះឯង គួរមាន ដូច្នេះ ។

លោកពោលការកំណត់ដឹងទុក្ខ ដូចជាការដុតប្រឆេះប្រទីបឲ្យឆេះ ព្រោះជាហេតុនៃនិស្សយប្បច្ច័យ លោកពោលការលះសមុទយៈ ដូចជាការកម្ចាត់ងងឹត ព្រោះជាការកម្ចាត់ធម៌ដែលជាបដិបក្ខ លោកពោលការធ្វើមគ្គឲ្យមានឡើង ដូចប្រទីបជះពន្លឺ ព្រោះជាការបន្ថែមពន្លឺ គឺញាណ ការធ្វើនិរោធឲ្យជាក់ច្បាស់ ដោយប្រការណាមួយ ការអស់ប្រេង គឺកិលេស រមែងមាន ដោយប្រការនោះៗ ដោយមគ្គនោះៗ ព្រោះហេតុនោះ ទើបលោកពោលការធ្វើនិរោធឲ្យជាក់ច្បាស់ ដូចជាការអស់ប្រេង ដោយវោហារអាស្រ័យហេតុ ។

ពាក្យថា **ធ្វើឲ្យភ្លឺច្បាស់** គឺធ្វើឲ្យប្រាកដ ។ ពាក្យថា **ដែលជាការរម្ងាប់ទៅនៃកិលេស** គឺជាការស្ងប់រម្ងាប់ទៅនៃកិលេសទាំងឡាយ ព្រោះជាការចូលទៅស្ងប់ ការស្ងប់សេចក្តីក្រវល់ក្រវាយ និងការក្តៅក្រហាយ គឺកិលេសទាំងពួង ។

ពាក្យថា **អប្បេតិ** ប្រែថា រមែងដល់ ។ លោកពោលមគ្គញាណ ដូចទូកលះច្រាំង ព្រោះឈានកន្លងច្រាំង គឺសក្កាយ ដោយការកំណត់ដឹងទុក្ខ លោកពោលមគ្គញាណ

ដូចទូកដឹកទំនិញ ព្រោះនាំមកនូវពោធិបក្ខិយធម៌ ៣៧ ប្រការ ដោយការញ៉ាំងមគ្គឲ្យមានឡើង ។

ញាណប្រព្រឹត្តទៅហើយ ដល់មគ្គនោះ ហេតុនោះ មគ្គនោះ ឈ្មោះថា **បវត្តញ្ញាណោ** ប្រែថា មានញាណដែលប្រព្រឹត្តទៅហើយ **អស្ស យោគ មគ្គស្ស** ។

ពាក្យថា **ដោយអត្ថ គឺយ៉ាងនោះ** គឺដោយសភាពយ៉ាងនោះ អធិប្បាយថា ដោយសភាវៈដែលមិនវិបរិត មានការបៀតបៀនជាដើម ។ បទថា **ឯកបដិវេធានិ** ប្រែថា ជាអាការគប្បីចាក់ធ្លុះរួមគ្នា ។

ពាក្យណាដែលគប្បីពោលក្នុងពាក្យថា អត្ថថា **គ្របសង្កត់នៃទុក្ខ** ជាដើម ពាក្យនោះ ខ្ញុំបានពោលហើយ **ក្នុងវណ្ណនានៃពុទ្ធានុស្សតិ** ខាងដើមនោះឯង ។ ពាក្យថា **សង្គ្រោះចូលតែ ១** គឺរួមចូលទុកដោយប្រការ ១ នោះឯង ។ ដោយអត្ថ គឺយ៉ាងនោះដូចម្តេច ? អធិប្បាយថា ដោយអត្ថ គឺសច្ចៈ ។ ពាក្យថា **វត្ថុណាសង្គ្រោះចូលតែ ១ បាន** ជាដើម ជាពាក្យសម្តែងឯកបដិវេធរបស់ញាណ ។ ពិតហើយ មគ្គញ្ញាណសូម្បីធ្វើនិរោធតែម្យ៉ាងឲ្យជាអារម្មណ៍ ក៏រមែងចាក់ធ្លុះនិរោធនោះតាមសេចក្តីពិត ដោយការកម្ចាត់សម្មោហៈដែលបិទបាំងអត្ថនៃសច្ចៈ ពោល គឺជារបស់ពិត មិនវិបល្លាសក្នុងសច្ចៈ មានទុក្ខជាដើមនោះ ធ្វើឲ្យប្រចក្សនោះឯង ប្រព្រឹត្តទៅ ។ ព្រោះអត្ថ គឺសច្ចៈទាំង ១៦ ប្រការ មានការបៀតបៀនជាដើម រមែងប្រាកដតាមសេចក្តីពិត ដល់ព្រះអរិយៈ ដូចជាកន្ទួតព្រៃក្នុងដៃ ក្នុងកាលដទៃ ។ ពាក្យថា **អត្ថ** បានដល់ អាការដែលបានឈ្មោះថា **អត្ថ** ព្រោះគប្បីប្រព្រឹត្តទៅដោយញាណ ។

ពាក្យថា **ដោយអំណាចការឃើញសច្ចៈដទៃ** គឺដោយអំណាចការឃើញសច្ចៈដទៃ មានសមុទយៈជាដើម ។ ពាក្យថា **ព្រោះប្រាកដច្បាស់** គឺព្រោះជាក់ច្បាស់ ។ សេចក្តីនេះ មានអធិប្បាយថា

អាការពួកណា រមែងប្រាកដច្បាស់ ដោយអំណាចសភាវៈក្នុងសច្ចៈ មានទុក្ខជាដើម និងដោយអំណាចការឃើញសច្ចៈដទៃ អត្ថទាំងនោះជា ៤ ប្រការ មានការបៀតបៀនជាដើមនោះឯង ព្រោះហេតុនោះ ទើបលោកពោលទុក ១៦ ប្រការនោះឯង មិនមែនអត្ថដទៃ ។ សេចក្តីនេះ លោកមានបំណងយកក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងញាណទាំងនោះ ញាណក្នុងទុក្ខដូចម្តេច** ដូច្នេះជាដើម ដើម្បីចៀសវាងការសង្ស័យថា ប្រការនេះ នឹងដឹងបានដូចម្តេច ។ ដោយហេតុនោះ ទើបលោកអាចារ្យសម្តែងសេចក្តីនេះថា

ព្រោះក្នុងព្រះបាលី ត្រាស់សច្ចញាណទុក ដោយអំណាចការធ្វើឲ្យជាអារម្មណ៍ខ្លះ ដោយអំណាចការសម្រេចកិច្ចជាផ្នែកៗ ខ្លះ ដូច្នោះ ទើបដឹងបានថា **អាការនៃសច្ចៈទាំងឡាយ រមែងប្រាកដច្បាស់ ដោយសភាវៈ និងដោយការឃើញសច្ចៈដទៃ** ។ ការឃើញដោយអំណាចការសម្រេចកិច្ច ក៏ដូចគ្នានឹងការឃើញ ព្រោះប្រាកដច្បាស់ ព្រោះហេតុនោះលោកអាចារ្យសម្តែងចំពោះការឃើញ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ក្រៅអំពីនេះ មិនបានប្រារព្ធដល់ការឃើញ ដោយអំណាចការសម្រេចកិច្ចនោះ ទើបពោលពាក្យថា **តត្ថ** ជាដើម ។ បទថា **តត្ថ** សេចក្តីប៉ុនគ្នានឹង **តេសុ យោគ ទ្វីសុ ទស្សនេសុ** ប្រែថា ក្នុងការឃើញន័យ ២ នោះ ។ បទថា **អាយូហិតំ** សេចក្តីថា ដែលសមុទយៈឲ្យកើតឡើង ជាដុំ ជាក្រុម ។ ពិតហើយ វត្ថុណានីមួយ ដែលឈ្មោះថា **បច្ចុប្បន្ន** ( កើតអំពីបច្ច័យ ) វត្ថុទាំងអស់នោះ ដែលសមុទយៈឲ្យកើតឡើង ឈ្មោះថា **រមែងកើតឡើង** ។ បទថា **សង្ខតំ** សេចក្តីថា ដែលបច្ច័យដទៃរួមបូលគ្នា កើតព្រមគ្នាធ្វើ ។ បទថា **រាសិកតំ** ប្រែថា ធ្វើឲ្យជាគំនរទុក ។ ពិតហើយ វត្ថុដែលជាបច្ចុប្បន្នសន្និកសន្ទាប់នោះឯង កាលកើតរួមបូលគ្នា រមែងដូចជាត្រូវបច្ច័យរបស់ខ្លួន ធ្វើឲ្យជាគំនរទុក ដូច្នេះ ។ បទថា **តស្មា យោគ សមុទយេន អាយូហិតត្តា**

ប្រែថា ព្រោះទុក្ខត្រូវសមុទយៈប្រមូលទុកនោះ ។ បទថា **អស្ស យោគ ទុក្ខសច្ចស្ស** ប្រែថា នៃទុក្ខសច្ចនោះ ។ មគ្គកើតឡើងក្នុងសន្តានណា **ក៏នាំទៅ កន្ទុងបង់នូវការក្តៅក្រហាយ គឺកិលេស** ក្នុងសន្តាននោះ ។ ឈ្មោះថា **ជាធម៌ត្រជាក់** ព្រោះមិនមានកម្តៅ គឺកិលេស សូម្បីដោយខ្លួនឯង ។ លោកអាចារ្យកាលសម្តែងថា **អត្ថ គឺការក្តៅក្រហាយ រមែងប្រាកដច្បាស់** ក៏ដូចគ្នានឹងវត្ថុដទៃអំពីវត្ថុនោះ ជារបស់មិនសំខាន់ ដោយបានឃើញរបស់ដែលសំខាន់ជាង ទើបពោលពាក្យថា **ដូចព្រះនន្ទ** ជាដើម ។ **និរោធដែលមានការមិនប្រែប្រួលជាធម្មតា** មានសភាពទៀង **ក៏មិនមានពាក្យដែលត្រូវពោលឡើយ** ព្រោះអាការដែលប្រាកដច្បាស់ ជាបដិបក្ខគ្នា សម្រេចបានដោយងាយ ។

**អត្ថ គឺការបន្តហេតុ រមែងប្រាកដច្បាស់ថា របស់នេះ រមែងជាហេតុដល់របស់នេះ** ។ លោកអាចារ្យកាលសម្តែងថា **អត្ថ** គឺចងទុក និង**អត្ថ** គឺបលិពោធ ជាអាការប្រាកដច្បាស់ ដោយអំណាចធម៌ដែលជាបដិបក្ខ ទើបពោលពាក្យជាដើមថា **និរោធសច្ចដែលជាធម៌ប្រាសចាកគ្រឿងចង** ។ **អត្ថ** គឺប្រកបទុកដោយកិលេស និងទុក្ខ ឈ្មោះថា **អត្ថ គឺចងទុក** ។ **អត្ថ** គឺឃាំងទុកក្នុងគុក គឺសង្សារ ឈ្មោះថា **អត្ថ គឺរាំងទុក** ។ សមុទយសច្ច **ជាធម៌មិនមានការចោលទៅ** ដោយអំណាចការស្មុគស្មាញ គឺកិលេសជាដើម ។ **អត្ថ គឺការចោលទៅ** បានដល់ ភាវៈដែលស្ងាត់ចាកឧបធិ ។ សភាវៈស្ងាត់ចាកសង្ខារទាំងពួង ឈ្មោះថា **អសង្ខតៈ** ព្រោះហេតុនោះ អរិយមគ្គ សូម្បីមានសភាវៈអស្ចារ្យ ដែលមិនធ្លាប់មានមកយ៉ាងនេះ ក៏ជាសង្ខតៈនោះឯង ចំណែកនិរោធនេះប៉ុណ្ណោះ ជាធម៌ឯក ដែលជាអសង្ខតៈ ព្រោះហេតុនោះ ទើបនិរោធ ជាអសង្ខតៈ ជាភាវៈដែលប្រាកដល្អ ។ ទុក្ខ ជាពិស ព្រោះមានការស្លាប់ជាធម្មតា ធម្មជាតិ ជាឱសថបន្សាបពិសនោះ ទើបឈ្មោះថា **អមតនិព្វាន** ។

សមុទយៈនេះ ដែលដល់នូវភាវៈគប្បីលើកតម្កើងថា **ជាផ្លូវ** ប្រាកដជាធម៌ដែល

ល្អិតសុខុម ជាការត្រេកអរ ក៏មិនមែនជាហេតុនៃការដល់ព្រះនិព្វាន ។ អរិយមគ្គនេះជាហេតុ ព្រោះហេតុនោះ **អត្ថ គឺហេតុ** នៃមគ្គ តាមន័យដែលពោលហើយ រមែងប្រាកដច្បាស់ ដោយការឃើញមគ្គាមគ្គញ្ញាណ ។ ពាក្យថា **ដោយការឃើញនិរោធ** គឺដោយការឃើញនិរោធសច្ចដ៏ក្រៃលែង ល្អិតពន់ពេក ហួសនឹងប្រៀបបាន ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **រូបទាំងឡាយ ដែលល្អិតយ៉ាងក្រៃលែង** ដូច្នេះជាដើម ។ ពាក្យថា **ដោយការឃើញទុក្ខ** សេចក្តីថា ដោយការឃើញទុក្ខសច្ចដែលមានទោសច្រើនក្រៃលែង ព្រោះដល់នូវភាពជាទោស ។ **អត្ថ គឺអធិបតី** ព្រោះជាបដិបក្ខចំពោះទុក្ខសច្ចនោះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ប្រៀបដូចឱឡារិកភាពនៃឥស្សរជន ប្រាកដច្បាស់ដោយការឃើញទុគ្គតភាពបុគ្គល ដែលច្រើនដោយរោគ ដូច្នោះ** ។ អាការប្រាកដច្បាស់ក្នុងសច្ចៈទាំងឡាយ ដោយការអនុលោមតាម និងដោយភាពវិសេសក្រៃលែងតាមសមគួរនេះ រមែងជាក់ច្បាស់ហើយដោយប្រការដូច្នេះ ។

បទថា **ឯកស្ស** ប្រែថា អត្ថឯណានីមួយ ។ លោកពោលសំដៅដល់ អត្ថ គឺការបៀតបៀន អត្ថ គឺប្រមូលទុក អត្ថ គឺលែងទៅ ។ ពីរបទថា **តិណ្ណំ តិណ្ណំ** បានដល់ អត្ថ គឺពាក្យរបស់ដែលត្រូវតាក់តែងឡើងជាដើម **យេ បន យោគ វាទិនោ** ប្រែថា ចំណែកមេលទ្ធិពួកណា ។ ពាក្យថា **នានាភិសម័យ** ប្រែថា ដឹង ដោយញាណផ្សេងៗគ្នា អធិប្បាយថា ចាក់ធ្លុះសច្ចៈ ៤ ដោយញាណផ្សេងៗ គ្នា ក្នុងខណៈផ្សេងៗ គ្នា ។ បើ **នានាភិសម័យ** ក្នុងសច្ចៈ ៤ គប្បីមានដល់មគ្គញ្ញាណសោត សំយោជនៈ ៣ ជាដើម ដែលមគ្គទី ១ គប្បីលះ ដោយការឃើញទុក្ខជាដើម ក៏ត្រូវជាការលះដោយឯកទេស ។ ហើយកាលបើដូច្នោះ ក៏ទាក់ទងជាមួយ នឹងបុគ្គលតាំងនៅក្នុងសោតា-

បត្តិមគ្គ ដោយឯកទេសជាដើម ។ ហើយផលនោះៗ ក៏គប្បីមានក្នុងលំដាប់នៃការឃើញនៃញាណនោះៗ ក៏គប្បីមាន ដែលផលទាំងឡាយ ជាការស្ងប់រម្ងាប់កិលេសត្រង់មគ្គនោះៗ ដែលមគ្គនោះៗ គប្បីលះជា ៤ ពួក ដូចគ្នានឹងមគ្គទាំងឡាយ ។ កាលប្រព្រឹត្តទៅយ៉ាងនោះ គប្បីមានការទាក់ទងនឹងព្រះសោតាបន្ន ដោយឯកទេសជាដើម ។ នៅមានប្រការដែលគប្បីពោលខ្វះ យ៉ាងច្រើនតទៅ

បើ **នានាភិសម័យ** គប្បីមានដល់មគ្គញ្ញាណសោត បុគ្គលក៏រមែងឃើញទុក្ខដោយញាណឯណានីមួយ ។ ឃើញសមុទយៈដោយញាណ ១ ឃើញនិរោធដោយញាណ ១ ឃើញមគ្គដោយញាណ ១ បើយ៉ាងនេះ កិច្ចរបស់មគ្គក៏គប្បីជាកិច្ចមិនគ្រប់ចំនួននោះឯង ។ ព្រោះការឃើញមគ្គ ក៏មានគតិ ២ គឺការឃើញមគ្គនោះ ដោយញាណនោះៗ ឯង ឬដោយញាណដទៃ ដូច្នេះ ។ ក្នុងគតិ ២ ប្រការនោះ ចំណែកដំបូងមិនត្រឹមត្រូវមុន ព្រោះមិនមានការប្រព្រឹត្តទៅក្នុងខ្លួន ។ ព្រោះថា បុគ្គលណាម្នាក់ មិនអាចពាល់ត្រូវចំណែកដំបូងនោះឯង ដោយចុងម្រាមនោះឯងបាន ។ បើដូច្នោះ ក៏នឹងមានការទាក់ទងជាមួយនឹងការមិនកំណត់ ដោយចំណែកដទៃថា បុគ្គលរមែងឃើញមគ្គដោយធម៌ណា សូម្បីធម៌នោះ ក៏ជាមគ្គ ។ បុគ្គលរមែងឃើញធម៌នោះដោយមគ្គណា សូម្បីធម៌នោះ ក៏ជាមគ្គ ដូច្នេះ ។ ព្រោះហេតុនោះ ការចាក់ធ្លុះដោយអសម្មោហៈតាមដែលពោលហើយ ដោយឯកាភិសម័យ ( ដឹងអរិយសច្ច ៤ ដោយញាណដូចគ្នា ) នោះឯង ទើបត្រឹមត្រូវ ។ ប្រការមួយទៀត ការកំណត់ និងការកាត់បានជាសមុច្ឆេទនៃមគ្គញ្ញាណដែលប្រព្រឹត្តទៅ ប្រារព្ធសច្ចៈ ទាំង ២ ដែលគប្បីកំណត់

ដូច្នេះ គប្បីកាត់បានជាសមុច្ឆេទ រមែងមិនមាន ព្រោះមិនបានចេញទៅអំពីសច្ចៈទាំង ២ នោះ ។ ឯការកំណត់ដឹងទុក្ខ និងការលះសមុទយៈ បុគ្គលណាម្នាក់ មិនអាចធ្វើដោយញាណ ដែលមានទុក្ខសច្ចជាអារម្មណ៍ និងមានសមុទយសច្ចជាអារម្មណ៍បានឡើយ ។ តែបុគ្គលដែលទម្លាយសម្មោហៈក្នុងទុក្ខសច្ច និងសមុទយសច្ចនោះ និងក្នុងសច្ចៈ ២ ក្រៅអំពីនេះ ដោយញាណដែលមាននិព្វានជាអារម្មណ៍ ក៏អាចធ្វើបាន ព្រោះហេតុនោះ **ឯកាភិសម័យ** ( ដឹងសច្ចៈ ៤ ដោយញាណតែមួយ ) នោះឯង ទើបត្រឹមត្រូវ ។ ឯសេចក្ដីនេះ មកហើយក្នុងព្រះបាលីនោះឯង ព្រោះហេតុនោះ **ការឆ្លើយតបរបស់មេលទ្ធិទាំងនោះ** លោកបានពោលហើយ ក្នុងកថាវត្ថុ ក្នុងព្រះអភិធម្ម ដូច្នេះ ។

# វិសុទ្ធិមគ្គ

## កិច្ច ៤ ក្នុងអរិយសច្ច

ឥឡូវនេះ កិច្ច ៤ មានបរិញ្ញាកិច្ចជាដើមនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងកិច្ចទាំងនោះ គឺ

**បរិញ្ញា មាន ៣ យ៉ាង សូម្បីបហាន សូម្បីសច្ឆិកិរិយា ក៏យ៉ាងនោះ ( គឺមាន ៣ ដូចគ្នា ) ភាវនាជ្រាបចំពោះថា មាន ២ គប្បីជ្រាបវិនិច្ឆ័យក្នុងកិច្ចទាំងនោះ ។**

## បរិញ្ញាកិច្ច

ពាក្យថា **បរិញ្ញាមាន ៣ យ៉ាង** សេចក្តីថា បរិញ្ញាមាន ៣ យ៉ាងដូច្នេះ គឺ ញាតបរិញ្ញា តីរណបរិញ្ញា បហានបរិញ្ញា ។

## ញាតបរិញ្ញា

ក្នុងបរិញ្ញា ៣ នោះ ការកំណត់ដឹង ដែលលោកសម្តែងឡើងថា **អភិញ្ញាបញ្ញា** ឈ្មោះថា ញាណដោយអត្ថថា ដឹង ដូច្នេះហើយ ពោលដោយសង្ខេប ដូច្នេះថា ធម៌ទាំងឡាយណាមួយ ជាធម៌ដែលព្រះយោគាវចរដឹងដោយបញ្ញាដ៏ក្រៃលែងហើយ ធម៌ទាំងឡាយនោះៗ ក៏ឈ្មោះថា លោកដឹងហើយ ដោយពិស្តារ តាមន័យថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងគប្បីដឹងក្រៃលែងដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ចក្ខុជាវត្ថុគប្បីដឹងក្រៃលែង ដូច្នេះជាដើម ឈ្មោះថា ញាតបរិញ្ញា ការដឹងក្រៃលែងនូវនាមរូបព្រមទាំងបច្ច័យជាភូមិ ១ ដោយចំពោះនៃញាតបរិញ្ញានោះ ។

## តីរណបរិញ្ញា

ចំណែកការកំណត់ដឹងដែលលោកសម្តែងឡើងថា បរិញ្ញាបញ្ញា ឈ្មោះថា ញាណ

ដោយអត្ថថា ពិចារណាដូច្នេះហើយ ពោលដោយសង្ខេបដូច្នេះថា ធម៌ទាំងឡាយណាមួយ ជាធម៌ដែលព្រះយោគាវចរកំណត់ដឹងហើយ ធម៌ទាំងឡាយនោះ ក៏ឈ្មោះថា លោកពិចារណាហើយដោយពិស្តារ តាមន័យថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងគប្បីកំណត់ដឹង វត្ថុទាំងពួងគប្បីដឹងដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់គប្បីកំណត់ដឹង ដូច្នេះជាដើម ឈ្មោះថា **តីរណបរិញ្ញា** ( កំណត់ដឹងដោយពិចារណា ) ការកំណត់ដឹងដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាថា មិនទៀង ជាទុក្ខ ជាអនត្តា តាំងអំពីកលាបសម្មសនៈ រហូតដល់អនុលោមជាភូមិ ១ ដោយចំពោះនៃតីរណបរិញ្ញានោះ ។

## បហានបរិញ្ញា

ចំណែកការកំណត់ដឹង ដែលលោកសម្តែងឡើងថា បហានបរិញ្ញា ឈ្មោះថា ញាណ ដោយអត្ថថា លះបង់បាន ដូច្នេះហើយ ពោលឡើងដោយសង្ខេប ដូច្នេះថា ធម៌ទាំងឡាយណាមួយ ជាធម៌ដែលព្រះយោគាវចរលះបានហើយ ធម៌ទាំងឡាយនោះ ក៏ឈ្មោះថា លោកលះបង់ហើយ ប្រព្រឹត្តទៅដោយន័យបាលីថា **លះនិច្ចសញ្ញាបាន ដោយអនិច្ចានុបស្សនា** ជាដើម ឈ្មោះថា **បហានបរិញ្ញា** ការកំណត់ដឹងតាំងអំពីភង្គានុបស្សនា រហូតដល់មគ្គញាណ ជាភូមិនៃបហានបរិញ្ញានោះ បហានបរិញ្ញានេះ លោកមានបំណងយកក្នុងបរិញ្ញាកិច្ចនេះ ឬបើមិនដូច្នោះ ព្រោះហេតុថា សូម្បីញាតបរិញ្ញា និងតីរណបរិញ្ញា ក៏មានមគ្គជាគោលដៅនោះឯង ។ ម្យ៉ាងទៀត ព្រោះហេតុថា ព្រះយោគាវចរលះធម៌ពួកណាបាន ធម៌ទាំងនោះ ឈ្មោះថា លោកបានដឹងហើយ និងពិចារណាហើយ ដោយពិត ព្រោះដូច្នោះ គប្បីជ្រាបចុះថា ដោយបរិយាយនេះ បរិញ្ញាទាំង ៣ ក៏ជាកិច្ចនៃមគ្គញាណ ដូចគ្នា ។

## បហានកិច្ច

ពាក្យថា **សម្បីបហានក៏យ៉ាងនោះ** សេចក្ដីថា សម្បីបហាន ក៏មាន ៣ យ៉ាង ដូចបរិញ្ញា ដូចគ្នា គឺវិក្ខម្ភនប្បហាន តទង្គប្បហាន សមុច្ឆេទប្បហាន ។

## វិក្ខម្ភនប្បហាន

ក្នុងបហាន ៣ នោះ ការសង្កត់បច្ចនិកធម៌ទាំងឡាយ មាននីវរណៈជាដើម ទុកដោយលោកិយសមាធិនោះៗ ដូចសង្កត់ចកដោយឆ្នាំងទទេ ( សង្កត់ ) ចុះក្នុងទឹកដែលមានចក យ៉ាងណា នេះឈ្មោះថា **វិក្ខម្ភនប្បហាន** ។ តែក្នុងបាលីពោលតែការសង្កត់នីវរណៈប៉ុណ្ណោះថា ម្យ៉ាងទៀត ការលះដោយសង្កត់នីវរណៈទាំងឡាយទុកនៃកិក្ខុដែលចម្រើនបឋមជ្ឈាន ដូច្នេះជាដើម គប្បីជ្រាបថា ពាក្យបាលីនោះ លោកពោលព្រោះការសង្កត់នីវរណៈនោះ ជាការប្រាកដ ព្រោះថា នីវរណៈទាំងឡាយ រមែងមិនគ្របសង្កត់ចិត្តយ៉ាងខ្លាំងក្លា ទាំងក្នុងពេលមុន ទាំងក្នុងពេលក្រោយនៃឈាន ធម៌ដទៃមានវិតក្កជាដើម រមែងស្ងប់រម្ងាប់ តែក្នុងខណៈ អប្បនា ( នៃទុតិយជ្ឈានជាដើម ) ប៉ុណ្ណោះ ព្រោះហេតុនោះ ការសង្កត់នីវរណៈ ទើបជាការប្រាកដ ( ដល់អ្នកដទៃ )។

## តទង្គប្បហាន

ចំណែកការលះបហាតព្វធម៌នោះៗ ដោយអង្គ គឺញាណជាអវយវៈ នៃវិបស្សនានោះៗ ជាបដិបក្ខគ្នា ( គឺផ្ទុយគ្នានឹងធម៌ដែលគប្បីលះ ) នោះឯង ដូចលះងងឹត ដោយប្រទីបដែលឆេះសន្ធោសន្ធៅក្នុងរាត្រីកាល ដូច្នោះ យ៉ាងណា យ៉ាងនេះ ឈ្មោះថា តទង្គប្បហាន ។

## តទង្គប្បហានតាមគន្លងវិសុទ្ធិ

តទង្គប្បហាននេះ គឺដូចម្ដេច ?

លំដាប់ដំបូង គឺការលះសក្កាយទិដ្ឋិ ដោយនាមរូបបរិច្ឆេទញ្ញាណ លះអហេតុវិសមហេតុទិដ្ឋិ ( ការឃើញថា មិនមានហេតុ និងឃើញថា មានហេតុមិនស្មើគ្នា ) លះមន្ទិល គឺការកង្ខាដោយបច្ចយបរិគ្គហញ្ញាណ លះសម្មូហគាហៈថា ជាអញ ជារបស់អញ ដោយកលាបសម្មសនញ្ញាណ លះអមគ្គេមគ្គសញ្ញា ដោយមគ្គាមគ្គវវត្ថានញ្ញាណ លះសមុច្ឆេទទិដ្ឋិ ដោយឧទយទស្សនញ្ញាណ (ឃើញការកើត) លះសស្សតទិដ្ឋិ ដោយវយទស្សនញ្ញាណ ( ឃើញការរលត់ ) លះសភយេអភយសញ្ញា ( សម្គាល់ថាមិនភ័យក្នុងរបស់ដែលគួរភ័យ ) ដោយភយតុបដ្ឋានញ្ញាណ លះអស្សាទសញ្ញា ( សម្គាល់ថា គួរពេញចិត្ត ) ដោយអាទីនវទស្សនញ្ញាណ លះអភិរតិសញ្ញា ( សម្គាល់ថា គួរត្រេកអរ ) ដោយនិព្វិទានុបស្សនាញ្ញាណ លះអមុញ្ចិតុកាមតាវៈ ( ភាវៈបុគ្គលប្រាថ្នាមិនរួចផុត ) ដោយមុញ្ចិតុកម្យតាញ្ញាណ លះអប្បដិសង្ខាន ( ការមិនពិចារណារកផ្លូវ ) ដោយបដិសង្ខាញ្ញាណ លះអនុបេក្ខន (ការមិនព្រងើយ) ដោយឧបេក្ខាញ្ញាណ លះសច្ចបដិលោមគាហៈ ( ការប្រកាន់បញ្ច្រាស់សច្ចៈ ) ដោយអនុលោមញ្ញាណ ។

## តទង្គប្បហានតាមគន្លងមហាវិបស្សនា ១៨

ម្យ៉ាងទៀត ក្នុងមហាវិបស្សនា ១៨ លះនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា លះសុខសញ្ញា ដោយទុក្ខានុបស្សនា លះអត្តសញ្ញា ដោយអនត្តានុបស្សនា លះនន្ទិ ដោយនិព្វិទានុបស្សនា លះរាគៈ ដោយវិរាគានុបស្សនា លះសមុទយៈ ដោយនិរោធានុបស្សនា លះអាទាន ដោយបដិនិស្សគ្គានុបស្សនា លះឃនសញ្ញា ដោយខយានុបស្សនា លះអាយូហនៈ (ការប្រមូល) ដោយវយានុបស្សនា លះធុវសញ្ញា (ស្ថិតស្ថេរ) ដោយវិបរិណាមានុបស្សនា លះនិមិត្ត ( ក្នុងសង្ខារ ) ដោយអនិមិត្តានុបស្សនា លះបណិធិ (ការប្រាថ្នា) ដោយអប្បណិហិតានុបស្សនា (មិនគួរប្រាថ្នា) លះអភិនិវេស

( ប្រកាន់មាំថាខ្ជួន ) ដោយសុញ្ញតានុបស្សនា លះសារាទានាភិនិវេស ( ប្រកាន់ជាខ្លឹម ) ដោយអធិប្បញ្ញាធម្មវិបស្សនា ( គឺដឹងការបែកធ្លាយមិនមានសារៈ ) លះសម្មោហា-ភិនិវេស ដោយយថាភូតញ្ញាណទស្សនៈ លះអាលយាភិនិវេស ( អាល័យ ) ដោយអាទីនវានុបស្សនា លះអប្បដិសង្ខា ( មិនពិចារណា ) ដោយបដិសង្ខានុបស្សនា លះសំយោគាភិនិវេស ( ជាប់ជំពាក់ក្នុងវដ្តៈ ) ដោយវិវដ្តានុបស្សនា ( ពិចារណាឃើញវិវដ្តៈ គឺព្រះនិព្វាន ) យ៉ាងណា នេះក៏ជាតទង្គប្បហានដូចគ្នា ។

## អធិប្បាយ មហាវិបស្សនាប្រការខ្លះ

ក្នុងមហាវិបស្សនាទាំងនោះ ការលះនិច្ចសញ្ញាជាដើម ដោយមហាវិបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ដូចម្តេច ការលះនោះ បានពោលទុកក្នុងភង្គានុបស្សនានិទ្ទេសហើយ ។

ចំណែកពាក្យថា **ខយានុបស្សនា** បានដល់ ញាណនៃព្រះយោគាវចរ ដែលធ្វើឃនវិនិព្ភោគ ( ញែកក្រុម ញែកដុំ ) ហើយឃើញការអស់ទៅយ៉ាងនេះថា **សង្ខារមិនទៀង ដោយសេចក្តីថា អស់ទៅ** ការលះឃនសញ្ញា រមែងមានបាន ដោយញាណនោះ ។

ពាក្យថា **វយានុបស្សនា** បានដល់ ឃើញការបែកធ្លាយនៃសង្ខារទាំងឡាយ ដោយពិចារណាឃើញ និងដោយ ( ត្រិះរិះឃើញ ) តាមប្រភេទ ( អារម្មណ៍ដែលបែកធ្លាយហើយ ) បង្អោនចិត្តចុះទៅក្នុងនិរោធ គឺការបែកធ្លាយនោះឯង ដែលពោលទុក ដូច្នេះថា

**ការពិចារណា ដែលកំណត់អារម្មណ៍ទាំង ២ ចំណែក ( ទាំងដែលឃើញហើយ ទាំងដែលមិនបានឃើញ ព្រោះជាអតីត អនាគត ) ថា មានសភាពដូចគ្នា**

តាមប្រភេទអារម្មណ៍ គឺការដែលទឹកបង្អោនចុះទៅក្នុងនិរោធនោះឯង ឈ្មោះថា វយលក្ខណវិបស្សនា ។

ការលះការប្រមូល រមែងមានបាន ដោយវយានុបស្សនា ព្រោះកាលព្រះយោគាវចរឃើញច្បាស់ថា សង្ខារទាំងនោះ មានការវិនាសជាធម្មតា យ៉ាងនោះ ចិត្តក៏រមែងមិនបង្អោនទៅក្នុងការប្រមូលមក ។

ពាក្យថា **វិបរិណាមានុបស្សនា** បានដល់ ការឃើញការប្រព្រឹត្តទៅដទៃកន្លងបង់នូវការកំណត់ទុកនោះៗ ជាកលាបៈ មានរូបសត្តកៈជាដើម ឬការឃើញការប្រែប្រួលទៅដោយអាការ ២ គឺជរា និងមរណៈនៃវត្ថុដែលកើតឡើងហើយ ការលះធុវសញ្ញា រមែងមានបានដោយវិបរិណាមានុបស្សនានោះ ។

ពាក្យថា **អនិមិត្តានុបស្សនា** ក៏គឺអនិច្ចានុបស្សនានោះឯង ការលះនិច្ចនិមិត្តទើបមានបាន ដោយអនិមិត្តានុបស្សនានោះ ។

ពាក្យថា **អប្បណិហិតានុបស្សនា** ក៏គឺទុក្ខានុបស្សនា ការលះការប្រាថ្នាសុខទើបមានបាន ដោយអប្បណិហិតានុបស្សនា ។

ពាក្យថា **សុញ្ញតានុបស្សនា** ក៏គឺអនត្តានុបស្សនា ការលះការប្រកាន់ថា អត្តាមាន ទើបមានបាន ដោយសុញ្ញតានុបស្សនានោះ ។

ពាក្យថា **អធិប្បញ្ញាធម្មវិបស្សនា** បានដល់ ការឃើញច្បាស់ ដែលប្រព្រឹត្តទៅដោយដឹងអារម្មណ៍ មានរូបជាដើម ហើយឃើញការបែកធ្លាយនៃអារម្មណ៍នោះ និងនៃចិត្តដែលមានអារម្មណ៍នោះ ជាអារម្មណ៍ផង ហើយកាន់យកសុញ្ញតាវៈ ដោយអំណាចការបែកធ្លាយថា សង្ខារទាំងឡាយប៉ុណ្ណោះបែកធ្លាយ មរណៈក៏មានដល់សង្ខារទាំងឡាយ បុគ្គលណាម្នាក់ដទៃ មិនមាន ដែលពោលទុក ( ជាគាថា ) ដូច្នេះថា

ពិចារណា ( ដឹង ) អារម្មណ៍ផង ហើយតាមឃើញការបែកធ្លាយផង ការប្រាកដដោយសុញ្ញតាវៈផង ឈ្មោះថា អធិប្បញ្ញាវិបស្សនា ។

ការឃើញច្បាស់នោះ លោកហៅថា **អធិប្បញ្ញាធម្មវិបស្សនា** ព្រោះធ្វើវិគ្គហៈជាអធិប្បញ្ញាផង ជាការឃើញច្បាស់ក្នុងធម៌ទាំងឡាយផង ការលះសារាទានាភិនិវេសរមែងមានបាន ដោយអធិប្បញ្ញាធម្មវិបស្សនានោះ ព្រោះឃើញដោយល្អ នូវការមិនមាននៃនិច្ចសារៈ និងការមិនមាននៃអត្តសារៈ ។

ពាក្យថា **យថាភូតញ្ញាណទស្សនៈ** បានដល់ ការកំណត់នាមរូប ព្រមទាំងបច្ច័យការលះសម្មោហាភិនិវេសដែលប្រព្រឹត្តទៅ ដោយអំណាចការសង្ស័យថា **អាត្មាអញបានមានមកហើយ ក្នុងអតីតកាលឬហ្ន៎** ជាដើម និងដោយអំណាចការដឹងខុសថា **លោកកើតមានឡើងដោយព្រះឥស្សរ** ជាដើមបាន ដោយយថាភូតញ្ញាណទស្សនៈនោះ ។

ពាក្យថា **អាទីនវានុបស្សនា** បានដល់ ញាណឃើញទោសក្នុងសង្ខារធម៌ទាំងឡាយ មានភពទាំងពួងជាដើម ដែលកើតឡើង ដោយអំណាចភយតុបដ្ឋានញ្ញាណការលះអាលយាភិនិវេស ដោយឃើញថា **វត្ថុណាមួយ ដែលគួរជាប់ជំពាក់ មិនប្រាកដឡើយ** រមែងមានបាន ដោយអាទីនវានុបស្សនាញាណនោះ ។

ពាក្យថា **បដិសង្ខានុបស្សនា** ក៏បានដល់ ញាណពិចារណា ( ដឹង ) ការធ្វើឧបាយ ( គឺរកផ្លូវ ) នៃការរួចផុតទៅ ការលះការមិនពិចារណា រមែងមានបាន ដោយបដិសង្ខាញាណនោះ ។

ពាក្យថា **វិវដ្ដានុបស្សនា** បានដល់ សង្ខារុបេក្ខាញាណ និងអនុលោមញ្ញាណផង ព្រោះក្នុងខណៈនោះ ចិត្តរបស់ព្រះយោគាវចរនោះ លោកពោលថា រមែងថយក្រោយ រួញត្រឡប់ វិលត្រឡប់ចាកសង្ខារទាំងពួង ដូចតំណក់ទឹកលើស្លឹកឈូក

ដែលផ្ទៀងបន្តិច រមែងហូរចុះ ដូច្នោះ ហេតុនោះ ទើបការលះសំយោគាភិនិវេស ទើបមានបាន ដោយវិវដ្ដានុបស្សនានោះ សេចក្ដីថា ការលះកិលេសាភិនិវេស ( អភិនិវេស គឺកិលេស ) មានកាមសំយោគៈជាដើម រមែងមានបាន ដោយការវិលទៅ នៃកិលេស ( គឺកិលេសមិនវិលទៅ ក៏ជាការលះកិលេសបាន ) ។

តទង្គប្បហានដោយពិស្ដារ គប្បីជ្រាបដូចពោលមក ដូច្នេះ ចំណែកក្នុងបាលី ពោលទុកដោយសង្ខេបថា ឯតទង្គប្បហាន រមែងមានដល់ព្រះយោគាវចរដែលចម្រើនសមាធិ ដែលប្រព្រឹត្តទៅក្នុងចំណែកទម្លុះនូវទិដ្ឋិទាំងឡាយ ដូច្នេះ ។

## សមុច្ឆេទប្បហាន

ចំណែកការលះធម៌ទាំងឡាយ មានសំយោជនៈជាដើម ដោយអរិយមគ្គញាណ ដែលវិលទៅទៀតមិនបាន ដូចការលះ ( គឺការទម្លាយទៅ ) នៃដើមឈើដែលត្រូវរន្ទះបាញ់ ( មិនដុះទៀត ) យ៉ាងណា យ៉ាងនេះឈ្មោះថា សមុច្ឆេទប្បហាន ដែលបាលីសំដៅយកពោលទុកថា ឯសមុច្ឆេទប្បហាន រមែងមានដល់ព្រះយោគាវចរ ដែលចម្រើនខយគាមិមគ្គ ដែលជាលោកុត្តរ ។

ក្នុងបហាន ៣ តាមដែលពោលមកនេះ សមុច្ឆេទប្បហានតែម្យ៉ាងប៉ុណ្ណោះ លោកបំណងយកក្នុងបហានកិច្ចនេះ អំពីហេតុណា សូម្បីវិក្ខម្ភនប្បហាន និងតទង្គប្បហាន ក្នុងចំណែកខាងដើមរបស់ព្រះយោគីនោះ ក៏មានមគ្គនោះ ជាគោលដៅនោះឯង ហេតុនោះ គប្បីជ្រាបចុះថា ដោយបរិយាយនេះ បហានទាំង ៣ ក៏ជាកិច្ច នៃមគ្គញាណដូចគ្នា ដូចជាវត្ថុណាដែលលោកអ្នកផ្ដាច់ព្រះជន្មព្រះរាជា ដែលជាសត្រូវហើយបានរាជសម្បត្តិ ធ្វើទុកមុនអំពីបានរាជសម្បត្តិ វត្ថុនោះៗ ទាំងពួង ក៏ពោលបានថា ព្រះរាជាទ្រង់ធ្វើដូចគ្នា ដូច្នោះ ។

# សច្ឆិកិរិយាកិច្ច

ពាក្យថា **សូម្បីសច្ឆិកិរិយា** ( ក៏យ៉ាងនោះ ) សេចក្តីថា សច្ឆិកិរិយាចែកជា ២ ចំណែក គឺលោកិយសច្ឆិកិរិយា លោកុត្តរសច្ឆិកិរិយា ( តែ ) សម្រាប់លោកុត្តរសច្ឆិកិរិយា មាន ៣ យ៉ាង ផ្សេងដោយអំណាចទស្សនៈ និងភាវនា ។

ក្នុងសច្ឆិកិរិយា ២ នោះ ការបានពាល់ត្រូវនូវឈាន មានបឋមជ្ឈានជាដើម ដែលមកដោយន័យថា អាត្មាអញ ជាអ្នកបានបឋមជ្ឈាន អាត្មាអញ ជាអ្នកជំនាញក្នុងបឋមជ្ឈាន បឋមជ្ឈាន អាត្មាអញធ្វើឲ្យជាក់ច្បាស់ហើយជាដើម ឈ្មោះថា **លោកិយសច្ឆិកិរិយា** ។

ពាក្យថា **ផស្សនា** បានសម្ផស្ស គឺសម្រេចហើយ បានពាល់ត្រូវដោយញាណផស្សៈ ដូចជាដឹងប្រចក្សថា **របស់នេះ អញបានសម្រេចហើយ** ។ ពិតហើយ ព្រះបាលីក៏សំដៅយកសេចក្តីនេះឯង ទើបពោលថា សច្ឆិកិរិយាជាញាណ ដោយអត្ថ គឺបានពាល់ត្រូវដោយបញ្ញា ហើយពោលពង្រីកសេចក្តីសច្ឆិកិរិយាថា ធម៌ទាំងឡាយណាមួយ ជាធម៌ដែលព្រះយោគាវចរបានធ្វើឲ្យជាក់ច្បាស់ហើយ ធម៌ទាំងឡាយនោះក៏ត្រូវបានលោកពាល់ត្រូវហើយ ដូច្នេះ ។ ម្យ៉ាងទៀត ធម៌ទាំងឡាយណា សូម្បីព្រះយោគាវចរមិនបានធ្វើឲ្យកើតឡើងក្នុងសន្តានខ្លួន ( ដូចជាឈាន និងមគ្គផល ) តែដឹងដោយញាណ ដែលមិនបានមានអ្នកដទៃឧបការៈតែម្យ៉ាង ធម៌ទាំងឡាយនោះក៏ឈ្មោះថា ត្រូវបានលោកធ្វើឲ្យជាក់ច្បាស់ហើយដូចគ្នា ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួង ដែលភិក្ខុគប្បីធ្វើឲ្យជាក់ច្បាស់ វត្ថុទាំងពួង ភិក្ខុគប្បីធ្វើឲ្យច្បាស់ គឺអ្វី គឺចក្ខុ ភិក្ខុគប្បីធ្វើឲ្យច្បាស់ជាដើម ។ ពាក្យបាលីដទៃទៀត ក៏បានពោលទុកថា ភិក្ខុកាលឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវរូប

ភិក្ខុកាលឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវវេទនា ។បេ។ នូវវិញ្ញាណ ភិក្ខុកាលឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវចក្ខុ... នូវជរា មរណៈ ភិក្ខុកាលឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលឈោងចុះកាន់អមតៈ ហេតុនោះ ធម៌ទាំងឡាយណាជាធម៌ដែលព្រះយោគាវចរ ធ្វើឲ្យជាក់ច្បាស់ហើយ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា ត្រូវបានលោកពាល់ត្រូវហើយ ។

ចំណែកការឃើញព្រះនិព្វាន ក្នុងខណៈនៃបឋមមគ្គ ជាទស្សនសច្ឆិកិរិយា ការឃើញព្រះនិព្វានក្នុងខណៈនៃមគ្គដ៏សេស ជាភាវនាសច្ឆិកិរិយា សច្ឆិកិរិយាទាំង ២ យ៉ាងនោះ លោកមានបំណងយកក្នុងសច្ឆិកិរិយាកិច្ចនេះ ព្រោះដូច្នោះ គប្បីជ្រាបថា ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយអំណាចទស្សនៈ និងភាវនា ជាកិច្ចនៃញាណនេះ ។

## ភាវនាកិច្ច

ពាក្យថា ភាវនា ជ្រាបចំពោះថាមាន ២ សេចក្តីថា ភាវនា មានបំណងយកភាវនា ២ ប៉ុណ្ណោះ គឺលោកិយភាវនា លោកុត្តរភាវនា ក្នុងភាវនា ២ នោះ ការញុំាងសីល សមាធិ បញ្ញា ដែលជាលោកិយឲ្យកើតឡើង និងការអប់រំសន្តាន ដោយលោកិយសីល សមាធិ បញ្ញា ទាំងនោះឈ្មោះថា លោកិយភាវនា ការញុំាងសីល សមាធិ បញ្ញា ដែលជាលោកុត្តរឲ្យកើតឡើង និងការអប់រំសន្តាន ដោយលោកុត្តរសីល សមាធិ បញ្ញា ទាំងនោះ ឈ្មោះថា លោកុត្តរភាវនា ក្នុងភាវនា ២ នោះ ក្នុងញាណទស្សនវិសុទ្ធិនេះ លោកមានបំណងយកលោកុត្តរភាវនា ព្រោះថា ញាណទាំង ៤ យ៉ាងនោះ ញុំាងលោកុត្តរសីលជាដើមឲ្យកើតឡើង ព្រោះញាណទាំង ៤ នោះ ជាបច្ច័យ មានសហជាតបច្ច័យជាដើម នៃលោកុត្តរសីលជាដើមនោះ និងអប់រំសន្តានដោយលោកុត្តរសីលជាដើមនោះ ហេតុនោះ ទើបលោកុត្តរភាវនាតែម្យ៉ាង ជាកិច្ចនៃ ( មគ្គ )

ញាណនោះ ដោយប្រការដូច្នេះ ។

**គួរជ្រាបកិច្ច មានបរិញ្ញាកិច្ចជាដើម ដែលលោកពោលក្នុងកាលដែលត្រាស់ដឹងតាមសភាវៈគ្រប់ប្រការ ដោយន័យដូចពោលមក ដូច្នេះឯង ។**

ឯដោយកថាត្រឹមប៉ុណ្ណេះ ពាក្យណាដែលខ្ញុំពោលទុកថា បញ្ញា ដែលព្រះយោគីអ្នកញុំាងវិសុទ្ធិ ២ ដែលជាមូល ( គឺសីលវិសុទ្ធិ ចិត្តវិសុទ្ធិ ) ឲ្យដល់ព្រមហើយ ញុំាងវិសុទ្ធិ ៥ ( មានទិដ្ឋិវិសុទ្ធិជាដើម ) ដែលជាតួ ( បញ្ញា ) ឲ្យដល់ព្រមគប្បីបំពេញ ( ឲ្យមានឡើង ) បាន ដូច្នេះ ដើម្បីសម្តែងវិធីបំពេញបញ្ញា ដែលមកដោយសរុបយ៉ាងនេះថា ភិក្ខុដែលជាអ្នកមានបញ្ញា តាំងនៅក្នុងសីល ហើយចម្រើនចិត្ត និងបញ្ញា ពាក្យនោះ ខ្ញុំធ្វើឲ្យពិស្តារហើយ និងបញ្ហាថា បញ្ញានោះ គប្បីចម្រើនដូចម្តេច នេះខ្ញុំក៏បានដោះស្រាយហើយ ដូច្នេះ ។

បរិច្ឆេទទី ២២ ឈ្មោះញាណទស្សនវិសុទ្ធិនិទ្ទេស
ក្នុងអធិការនៃបញ្ញាភាវនា ក្នុងបករណ៍វិសុទ្ធិមគ្គ
ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជ
នៃសាធុជន ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយប្រភេទនៃបរិញ្ញាជាដើម

អត្ថរបស់ពាក្យទាំងឡាយ មាន **អភិញ្ញាបញ្ញា** ជាដើម បានពោលហើយខាងដើមនោះឯង ។ ម្យ៉ាងទៀត ធម៌ទាំងឡាយ ដែលព្រះយោគាវចរដឹងហើយ ដោយបញ្ញាដ៏វិសេសក្រៃលែង ដែលសម្រេចដោយការស្តាប់ សម្រេចដោយការគិត និងសម្រេចដោយការនាខ្វះ ឈ្មោះថា **ធម៌ដែលព្រះយោគាវចរដឹងហើយ** ដោយបញ្ញាដ៏ក្រៃលែង ។ ឈ្មោះថា **ជាភូមិ ១ ដោយចំពោះ** ព្រោះមិនជាវិស័យនៃបរិញ្ញាដទៃ ។ ព្រោះថា ការប្រព្រឹត្តទៅនៃតីរណបរិញ្ញាជាដើម ដោយអំណាចការកំណត់នាមរូប និងការកំណត់បច្ច័យ មិនមានឡើយ ។

សូម្បីអនុលោមញ្ញាណ ក៏រមែងប្រព្រឹត្តទៅប្រារព្ធសង្ខារទាំងឡាយ ជារបស់មិនទៀងជាដើមនោះឯង នឹងពោលថ្វីដល់បដិសង្ខានុបស្សនាជាដើម ព្រោះហេតុនោះទើបលោកអាចារ្យពោលថា **រហូតដល់អនុលោមជាភូមិ ១ ដោយចំពោះ** ដូច្នេះ ។ ក្នុងអធិការនេះ សូម្បីញាតបរិញ្ញា និងបហានបរិញ្ញា ក៏បានឱកាសក្នុងភូមិនៃតីរណបរិញ្ញា ដោយពិត សូម្បីយ៉ាងនោះ ក្នុងបណ្តាបរិញ្ញាទាំង ៣ នោះ ញាតបរិញ្ញា និងបហានបរិញ្ញាក្រៅអំពីនេះ ក៏មិនដូចតីរណបរិញ្ញា ដែលធ្វើកិច្ចវិសេសក្រៃលែង ព្រោះហេតុនោះ ទើបលោកប្រើស័ព្ទថា ដោយចំពោះទុក ។

ពោលដោយនិប្បរិយាយ មគ្គញ្ញាណ ឈ្មោះថា **បហានបរិញ្ញា** ព្រោះហេតុនោះទើបលោកអាចារ្យពោលថា **រហូតដល់មគ្គញ្ញាណជាភូមិ** ( នៃបហានបរិញ្ញានោះ ) ដូច្នេះ ។ ពាក្យថា **អយំ ឥធ អធិប្បេតា** សេចក្តីថា បហានបរិញ្ញានេះ លោកមានបំណងយកក្នុងវេលាត្រាស់ដឹង និងក្នុងការពិចារណាកិច្ចនេះ ព្រោះបរិញ្ញាដ៏សេស ក៏មាន

មគ្គនេះជាគោលដៅ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **យស្មា វា** ជាដើម ។

ម្យ៉ាងទៀត បទថា **តទត្ថាយេវ** ប្រែថា មានការលះជាគោលដៅនោះឯង ។ ម្យ៉ាងទៀត បទថា **តទត្ថាយេវ** ប្រែថា មានមគ្គជាទិសដៅនោះឯង ។ ព្រោះញាតបរិញ្ញា និងតីរណបរិញ្ញាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ការសម្រេចមគ្គ ។ ធម៌ទាំងនោះ **ក៏ត្រូវបានលោកដឹងហើយ និងពិចារណាហើយ ដោយពិត** ព្រោះវៀរចាកធម៌ដែលលោកដឹងហើយ និងពិចារណាហើយ ការលះក៏មិនមាន និងព្រោះកាលការលះសម្រេចបាន ធម៌ដែលដឹងហើយ និងពិចារណាហើយ ក៏សម្រេចបាន ពិតហើយ មគ្គញាណប្រព្រឹត្តទៅដោយអំណាចការដឹង ដោយការកំណត់ដឹងក្នុងទុក្ខ លោកហៅថា ចាក់ធ្លុះសាមញ្ញលក្ខណៈ ដូចសភាវលក្ខណៈរបស់ទុក្ខនោះ ព្រោះទម្លាយសម្មោហៈដែលបិទបាំងទុក្ខនោះ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **គប្បីជ្រាបដោយបរិយាយនេះ បរិញ្ញាទាំង ៣ ក៏ជាកិច្ចរបស់មគ្គ** ដូច្នេះ ។

ពាក្យថា **ដូចបរិញ្ញា** លោកអាចារ្យរមែងសម្តែងដល់ការស្មើគ្នា ដោយបហាន ៣ យ៉ាង មិនមែនសម្តែងភាពស្មើគ្នានៃធម៌ដែលគប្បីលះ ដោយបរិញ្ញាឡើយ ព្រោះវិក្ខម្ភនប្បហាន មិនមែនជាកិច្ចនៃបរិញ្ញាទេ ។ នីវរណធម៌ទាំងឡាយ មានកាមច្ឆន្ទៈជាដើម មិនទាន់បិទបាំងចិត្តតាំងនៅដោយប្រការណា ការរារាំងទុក គឺធ្វើការមិនប្រព្រឹត្តទៅនៃការបិទបាំងដោយប្រការនោះ ឈ្មោះថា **ការសង្កត់** ការលះ គឺការសង្កត់ឈ្មោះថា **វិក្ខម្ភនប្បហាន** ។ ពាក្យថា **ព្រោះការសង្កត់នីវរណៈនោះ ជាការប្រាកដ** សេចក្តីថា ព្រោះជាការប្រាកដដល់បុគ្គលដទៃ ដោយន័យជាដើមថា **បុគ្គលនេះ មានចិត្តមិនព្យាបាទ បុគ្គលនេះ ប្រាសចាកថីនមិទ្ធៈ** ។ ពាក្យថា **នីវរណៈទាំងឡាយរមែងមិនគ្របសង្កត់ចិត្ត ដោយខ្វាំងក្លា** នេះ លោកអាចារ្យពោលដោយអំណាច

ឈានដែលបានចំពោះហើយ ចំណែកក្នុងឈានដែលបានល្មមចំពោះហើយ ចំណែកក្នុងឈានដែលស្ទាត់ជំនាញ ដែលព្រះយោគីចម្រើនល្អហើយ រមែងមិនគ្របសង្កត់ឡើយ រហូតដល់ចិត្តជួនចុងក្រោយ ។ ម្យ៉ាងទៀត ពាក្យថា **ទាំងក្នុងពេលមុននៃឈាន** បានដល់ ក្នុងពេលបដិបត្តិចំណែកខាងដើម ដើម្បីប្រយោជន៍ដល់ការសម្រេចឈាន ។ ពាក្យថា **ទាំងក្នុងពេលខាងក្រោយឈាន** បានដល់ ទាំងក្នុងពេលដែលបានឈានហើយ ទៅខ្វល់ខ្វាយកិច្ចដទៃ ។ ពាក្យថា **ធម៌ដទៃ មានវិតក្កជាដើម** បានដល់ ធម៌ដទៃមានវិតក្ក វិចារៈ បីតិ សុខ និងរូបសញ្ញាជាដើម ។ ធម៌ដែលជាបដិបក្ខចំពោះទុតិយជ្ឈានជាដើម កាលទុតិយជ្ឈានជាដើម អែបស្និទ្ធហើយ ក៏រមែងសង្កត់ទុក តែកាលចេញចាកទុតិយជ្ឈានជាដើមនោះៗ ក៏រមែងប្រព្រឹត្តទៅ ព្រោះចេញទៅដោយអំណាចកាមាវចរចិត្តនោះឯង ។

ពាក្យថា **ដូចលះងងឹត ដោយប្រទីប** នេះ លោកអាចារ្យពោលដើម្បីសម្តែងភាពជាធម៌ ដែលធម៌ជាបដិបក្ខលះហើយ ។ ពិតហើយ **ប្រទីប** ជាបដិបក្ខចំពោះងងឹត ចំណែកការសង្កត់ដោយថ្នាំង មិនមែនជាបដិបក្ខចំពោះចក រមែងធ្វើត្រឹមតែការឃាត់ការប្រព្រឹត្តទៅតែម្យ៉ាងប៉ុណ្ណោះឯង ។ ព្រោះហេតុនោះ សូម្បីកាលមិនមានទុតិយជ្ឈានជាដើម ជាសត្រូវដោយត្រង់ការសម្តែងលម្អិតនូវការសង្កត់ធម៌ មានវិតក្កជាដើមនោះ ក៏រមែងសមគួរល្អក្រៃលែង ។ ពាក្យថា **ជាអវយវៈនៃវិបស្សនា** នេះ លោកពោលទុកដើម្បីសម្តែងតទង្គប្បហាន ដែលធ្វើក្រៃលែងទុកក្នុងទីនេះ ។ ពិតហើយ តទង្គប្បហាន រមែងសម្រេចនោះឯង សូម្បីដោយការធ្វើសីលឲ្យបរិសុទ្ធជាដើម ដូច្នេះ ។ ពាក្យថា **ដោយអង្គ គឺញាណ** បានដល់ ដោយហេតុ ពោល គឺញាណ ។ ការលះអង្គនោះដោយអង្គនោះ ឈ្មោះថា **តទង្គប្បហាន** ។ ការឃើញក្នុងកាយ ពោល គឺខន្ធ ៥ ដែលមាន គឺដែលប្រាកដ ឬការឃើញក្នុងកាយ ពោល គឺខន្ធ ៥ នោះ ដែលមានឯង

ឈ្មោះថា **សក្កាយទិដ្ឋិ** បានដល់ អត្តានុទិដ្ឋិ ( ការឃើញតាមខ្លួន ) ដែលត្រាស់ទុក ដោយន័យជាដើមថា **រមែងពិចារណាឃើញរូបជាខ្លួន** ដូច្នេះ ។ មន្ទិល គឺការសង្ស័យ ដែលមានវត្ថុ ១៦ និងមានវត្ថុ ៨ ឈ្មោះថា **មន្ទិល គឺការសង្ស័យ** ។ បទថា **សមូហ-គាហស្ស** សេចក្ដីថា ការលះសេចក្ដីប្រកាន់ថា ជាក្រុម ជាដុំ ដែលប្រព្រឹត្តទៅយ៉ាង នេះថា **ជាខ្លួន ជារបស់ខ្លួន** ព្រោះឃើញខន្ធទាំងឡាយ ដោយអំណាចការបំបែកដាក់ ទុកក្នុងឱកាស ១១ យ៉ាង ដោយកលាបសម្មសនញ្ញាណ ។ បទថា **អសុភសញ្ញាយ** សេចក្ដីថា ការសម្គាល់ខុស ដែលប្រព្រឹត្តទៅដោយអំណាចការត្រេកអរក្នុងខន្ធ ៥ ។ បទថា **អប្បដិសង្ខានស្ស** បានដល់ មោហៈដែលជាបដិបក្ខចំពោះការពិចារណា រកផ្លូវ ។ បទថា **អនុបេក្ខនស្ស** បានដល់ ធម្មជាតិដែលមិនព្រងើយ ។ ការប្រកាន់ថា ទៀងជាដើមក្នុងសង្ខារទាំងឡាយ ឈ្មោះថា **សច្ចបដិលោមគាហ** ការប្រកាន់បញ្ច្រាស់ សច្ចៈ ព្រោះប្រឆាំងចំពោះការយល់មគ្គសច្ច ។ ឯអាចារ្យទាំងឡាយពោលថា បុគ្គល មានការសម្គាល់ក្នុងទោសទាំងឡាយថា មិនមានទោស និងបុគ្គលមានការសម្គាល់ ក្នុងវត្ថុដែលមិនមែនទោសថា មានទោស ឈ្មោះថា **សច្ចបដិលោមគាហ** ការប្រកាន់ ផ្ទុយអំពីសច្ចៈ ។

លោកអាចារ្យកាលសម្ដែងតទង្គប្បហាន តាមលំដាប់វិសុទ្ធិយ៉ាងនេះហើយ ឥឡូវនេះ មានបំណងសម្ដែងតទង្គប្បហាននោះ ដោយអំណាចមហាវិបស្សនា ១៨ យ៉ាង ទើបពោលពាក្យថា **យំ វា បន** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្ដីថា **យំ វា បហានំ** ឬការលះណា ។

**បានពោលទុកហើយ** ដោយពាក្យជាដើមថា **រមែងតាមឃើញសង្ខារទាំងពួង ជារបស់មិនទៀង** ដូច្នេះ ។

ការប្រកាន់ថា ជាក្រុម ជាដុំ ទាក់ទងនឹងធម៌ដែលមានការបន្តគ្នា និងជាប្រជុំ

ជាកិច្ច និងជាអារម្មណ៍ ឈ្មោះថា **ឃនសញ្ញា** នូវឃនសញ្ញានោះ ។

ពាក្យថា **និរោធេ អធិមុត្តតា តាយ** សេចក្ដីថា បញ្ញាដែលប្រព្រឹត្តទៅដោយអំណាចឃើញការរលត់នោះឯង នៃសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ ហើយបង្អោនទៅក្នុងការរលត់នោះ ដោយបញ្ញានោះ ។ បទថា **អាយូហនស្ស** បានដល់ ការតាក់តែង ។

ពាក្យថា **ប្រការដែលកំណត់ទុកនោះៗ** បានដល់ ប្រការដែលកំណត់ទុកនោះៗ មានការកាន់យក និងការលះបង់ចោលទៅជាដើម ។ ពាក្យថា **ការឃើញការប្រព្រឹត្តទៅដទៃ** បានដល់ ការឃើញការប្រព្រឹត្តទៅដោយអាការដទៃមុន និងក្រោយអំពីការកំណត់ដែលពោលហើយ ឬឃើញការប្រព្រឹត្តទៅ ដោយផ្សេងអំពីកិរិយាដែលតាំងចុះ ។ ពាក្យថា **ធុវសញ្ញា** បានដល់ ការប្រកាន់ថា ស្ថិតស្ថេរ ។

ពាក្យថា **សារាទានាភិនិវេសស្ស** បានដល់ ការប្រកាន់មាំ ដោយការប្រកាន់ថាជាសារៈ ក្នុងវត្ថុដែលមិនជាសារៈទាំងឡាយ ។

ការវង្វេងព្រមដោយអំណាចការសង្ស័យ និងការដឹងខុស ឈ្មោះថា **សម្មោហៈ** ការប្រកាន់មាំ គឺសម្មោហៈនោះ ហេតុនោះ ទើបឈ្មោះថា **សម្មោហាភិនិវេស** ។ ការប្រកាន់ថា ជាទីពួន ជាទីជ្រកកោនបាន ក្នុងសង្ខារទាំងឡាយ ឈ្មោះថា **អាលយាភិនិវេស** ដោយអត្ថ បានដល់ ការត្រេកអរក្នុងភព ។

ចិត្តលះសង្ខារទាំងឡាយ ហើយរមែងស្ទុះទៅកាន់ព្រះនិព្វាន ដែលប្រាសចាកវដ្ដៈ យ៉ាងណា សង្ខារុបេក្ខា និងអនុលោមញ្ញាណ លោកពោលថា **វិវដ្ដានុបស្សនា** ព្រោះឲ្យប្រព្រឹត្តទៅ ដូច្នោះ ។ កិលេស មានសំយោជនៈជាដើម ដែលប្រព្រឹត្តទៅដោយការឈោងចុះជាសភាវៈដែលមាននោះឯង ឈ្មោះថា **កិលេសាភិនិវេស** ។ លោកអាចារ្យពោលវិបស្សនាសមាធិថា **និព្វេធភាគិយសមាធិ** ( សមាធិដែលប្រព្រឹត្ត

ទៅក្នុងចំណែកនៃការជ្រែកកិលេស ) ។

**អសនិវិចក្កំ** ប្រែថា រន្ទះ ។ ពាក្យថា **ការលះយ៉ាងនោះ** លោកអាចារ្យពោលដល់ការធ្វើឲ្យដល់នូវការកើតឡើងមិនបានជាធម្មតា ។ មគ្គណា រមែងដល់នូវការអស់ទៅ គឺការរលត់ទៅនៃកម្ម និងកិលេស ឬនៃសង្ខារទាំងឡាយទាំងពួង ហេតុនោះ មគ្គនោះ ឈ្មោះថា **ខយគាមី** ( ដល់នូវការអស់ទៅ ) បានដល់ អរិយមគ្គ ។ កាលអត្ថសម្រេចដោយស័ព្ទថា លោកុត្តរ លោកប្រើស័ព្ទថា **ខយគាមី** ដើម្បីពណ៌នាដល់គុណ អវធារណៈថា **សមុច្ឆេទប្បហានមេវ** លោកពោលកាន់យកសេចក្ដីដោយត្រង់ ។ បទថា **តទគ្គានេវ** ប្រែថា មានសមុច្ឆេទប្បហាននោះ ជាគោលដៅនោះឯង ។ ដោយបទនោះ លោកអាចារ្យពោលវិក្ខម្ភនប្បហាន និងតទង្គប្បហានជាអង្គនៃមគ្គ ព្រោះវៀរចាកវិក្ខម្ភនប្បហាន និងតទង្គប្បហាននោះ មគ្គក៏មិនសម្រេច ។ម្យ៉ាងទៀត បទថា **តទគ្គានេវ** សេចក្ដីថា មានមគ្គជាគោលដៅនោះឯង ។ ដោយបទនោះ លោកអាចារ្យរមែងសម្ដែងវិក្ខម្ភនប្បហាន និងតទង្គប្បហានទាំងនោះ ជាកិច្ចនៃមគ្គនោះ ព្រោះមានមគ្គនោះជាគោលដៅ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **ព្រោះហេតុនោះ** ដូច្នេះជាដើម ។ លោកអាចារ្យមានបំណងសម្ដែងអត្ថនោះឯង ដោយឧបមា ទើបពោលពាក្យជាដើមថា **លោកអ្នកផ្ដាច់ព្រះជន្មព្រះរាជាដែលជាសត្រូវ** ដូច្នេះ ។ ប្រើនបទថា **យម្បិ តតោ បុព្វេ កតំ** ប្រែថា របស់ណាដែលបានធ្វើទុកមុនបានរាជសម្បត្តិជាដើមថា ការដណ្ដើមដាយដែនសម្រេច និងការទម្លាយប៉មការពារជាដើម ។ គប្បីជ្រាបថា **វត្ថុនេះៗ ក៏ពោលបានថា ព្រះរាជាទ្រង់បានធ្វើហើយ** យ៉ាងណា វិក្ខម្ភនប្បហាន និងតទង្គប្បហានដែលលោកិយញ្ញាណឲ្យសម្រេចហើយ លោកក៏ពោលជាកិច្ចនៃមគ្គ ដែលប្រព្រឹត្តទៅ ដោយអំណាចសមុច្ឆេទប្បហាន យ៉ាងនោះ ព្រោះមគ្គនោះ ជាគោលដៅ និងព្រោះវិក្ខម្ភនប្បហាន និងសមុច្ឆេទប្បហានទាំងនោះ

ធ្លាក់ទៅក្នុងការបន្តនៃមគ្គនោះ ។

ការធ្វើឲ្យជាក់ច្បាស់នូវលោកិយ ឬធ្វើឲ្យជាក់ច្បាស់ដែលជាលោកិយ ឈ្មោះថា **លោកិយសច្ឆិកិរិយា** ។ គប្បីជ្រាប **លោកុត្តរសច្ឆិកិរិយា** យ៉ាងនេះ ។ បទថា **លាភិម្ហិ** កាត់ជា **លាភី អម្ហិ** ប្រែថា អញជាអ្នកបាន ។ សូម្បីក្នុងបទថា **វសិម្ហិ នេះ** ក៏យ៉ាងនោះ ។ ពាក្យថា **ដោយញាណផស្សៈដ៏ប្រចក្ស** គឺដោយញាណផស្សៈ ពោល គឺការធ្វើឲ្យជាអារម្មណ៍ដ៏ប្រចក្ស ដោយពាក្យថា **ដ៏ប្រចក្ស** នេះ លោកអាចារ្យ រមែងបដិសេធការធ្វើឲ្យជាអារម្មណ៍ ដោយអនុមាន ព្រោះថា ការដឹងដ៏ប្រចក្សដោយ អំណាចការពិចារណាថា **របស់នេះកើត** ដូច្នេះ លោកមានបំណងយកពាក្យថា **ញាណផស្សៈ** ។ បទថា **ផុសិតា** សេចក្តីថា ដែលលោកពាល់ត្រូវ ហើយដោយញាណ ។

ញាណដែលប្រព្រឹត្តទៅ ដោយការកម្ចាត់យ៉ាងនោះ ដោយអំណាចកម្ចាត់ សម្មោហៈ ដែលបិទបាំងសច្ចៈនោះ សូម្បីមិនឲ្យកើតឡើងក្នុងសន្តានខ្លួន ដូចឈាន និងមគ្គផល ឈ្មោះថា **ញាណដែលមិនមានអ្នកដទៃឧបការៈ** ។

**កាលឃើញ** គឺដឹងដោយប្រចក្ស ។ ពាក្យថា **ដែលឈោងចុះកាន់អមតៈ** គឺ ដែលទាក់ទងក្នុងអមតៈ អធិប្បាយថា ពោល គឺអមតៈ ។

សោតាបត្តិមគ្គ ឈ្មោះថា **ទស្សនៈ** ព្រោះឃើញនិព្វានមុន **ការធ្វើឲ្យជាក់ច្បាស់** ដោយទស្សនៈនោះ ឈ្មោះថា **ទស្សនសច្ឆិកិរិយា** ។ គោត្រភូញាណឃើញព្រះនិព្វាន មុនសោតាបត្តិមគ្គនោះ ដោយពិត សូម្បីយ៉ាងនោះ ក៏មិនហៅថា **ទស្សនៈ** ឡើយ ព្រោះមិនបានធ្វើកិច្ចដែលគប្បីឃើញ ដោយការធ្វើឲ្យជាអារម្មណ៍ ហើយទើបធ្វើ ។ ពាក្យថា **សច្ឆិកិរិយាទាំង ២ យ៉ាង** បានដល់ សច្ឆិកិរិយាទាំង ២ យ៉ាង គឺទស្សនៈ និងភាវនា ។ ពាក្យថា **គឺទស្សនៈ និងភាវនា** បានដល់ គឺទស្សនមគ្គ និងភាវនាមគ្គ ។ ដោយពាក្យនោះ លោកអាចារ្យរមែងបដិសេធការធ្វើឲ្យជាក់ច្បាស់ដោយការពិចារណា

និព្វាន ដែលប្រព្រឹត្តទៅដោយអំណាចធម៌ ដែលមិនមែនជាមគ្គ ។ ចំណែកពាក្យថា **នូវព្រះនិព្វាន** នេះ លោកអាចារ្យមែងបដិសេធ ការធ្វើឲ្យជាក់ច្បាស់ ដោយការពិចារណាក្នុងមគ្គ និងផល ។ ពាក្យថា **នៃញាណនេះ** សេចក្ដីថា នៃលោកុត្តរញ្ញាណនេះ គឺតាមដែលបានសម្រេចហើយ ។

បទថា **អភិមតា** ប្រែថា លោកមានបំណងហើយ ។ ការធ្វើឲ្យកើតឡើង និងការអប់រំសន្ដាន ឈ្មោះថា **ភាវនា** ព្រោះហេតុនោះ លោកអាចារ្យកាលសម្ដែងភាវនាទាំង ២ នោះ ទើបពោលពាក្យថា **ញុំាងសីល សមាធិ និងបញ្ញា ដែលជាលោកិយ** ដូច្នេះជាដើម ឯធម៌ទាំងឡាយ មានកុសលជាដើម ជាលោកិយ ដែលព្រះយោគីឲ្យកើតហើយ និងចម្រើនហើយ ដោយចំណែកណា សីលភាវនា កាយភាវនា ចិត្តភាវនា និងបញ្ញាភាវនា ត្រូវបានព្រះយោគីនោះឲ្យសម្រេច ជាលោកិយដោយចំណែកនោះ និងសូម្បីសន្ដាន ក៏ត្រូវបានព្រះយោគីអប់រំហើយ ដោយភាវនានោះឯង ។ **តាសុ យោគលោកិយលោកុត្តរភាវនាសុ ឥធ យោគ ញាណទស្សនវិសុទ្ធិកថាយំ** ប្រែថា បណ្ដាលោកិយភាវនា និងលោកុត្តរភាវនានោះ ក្នុងញាណទស្សនវិសុទ្ធិនេះ **លោកមានបំណងយកលោកុត្តរភាវនា** មិនមែនលោកិយភាវនាក្រៅអំពីនេះឡើយ ព្រោះលោកុត្តរភាវនានោះជាអត្ថ ។ ពាក្យថា **ញាណទាំង ៤ យ៉ាងនោះ** សេចក្ដីថា អរិយមគ្គញ្ញាណទាំង ៤ យ៉ាងនោះ **រមែងញុំាងសីលជាដើម** ដែលផ្សេងគ្នាដោយសម្មាវាចាជាដើម ដែលជាលោកុត្តរ **ឲ្យកើតឡើង** ។ សេចក្ដីនេះដូចម្ដេច ? ព្រោះញាណទាំង ៤ ជាបច្ច័យ មានសហជាតបច្ច័យជាដើម ។ ដោយ **អាទិ-ស័ព្ទ** ក្នុងបទថា **សីលាទីនិ** នេះ លោកកាន់យកសមាធិ មិនមែនកាន់យកបញ្ញា ។ ឯញាណទាំង ៤ នោះឯង រមែងញុំាងបញ្ញានោះឲ្យកើតឡើងក៏ទេ តែមគ្គចិត្តុប្បាទរមែងឲ្យកើតឡើង ។ បានដល់ សម្មាសង្កប្ប ព្រោះជាធម៌ឈោងចុះខាងក្នុងបញ្ញានោះ ។ អាចារ្យទាំងឡាយ

រមែងពោលថា សម្មាសង្កប្បនោះ សង្គ្រោះចូលក្នុងបញ្ញក្ខន្ធ ។ ម្យ៉ាងទៀត លោកកាន់យកសម្បីសីលក្នុងផលជាដើមថា **សីលាទីនិ** ព្រោះហេតុនោះ ការកាន់យកបញ្ញាក៏គួរដូចគ្នា ។ ដោយ **អាទិ-ស័ព្ទ** ក្នុងបទថា **សហជាតប្បច្ចយាទិតាយ** នេះ គប្បីឃើញការសង្គ្រោះសម្បីអនន្តរប្បច្ច័យជាដើមផងដែរ ។ ពាក្យថា **នឹងអប់រំសន្តាន ដោយសីលជាដើម ដែលជាលោកុត្តរនោះ** សេចក្តីថា ព្រះអរិយបុគ្គល រមែងអប់រំសន្តានរបស់ខ្លួន ដែលលោកអាចារ្យទាំងឡាយពោលថា ជាទីអាស្រ័យវិលមកខាងមុខ ដោយធម៌ទាំងឡាយ មានសីលជាដើម ដែលជាលោកុត្តរប្រព្រឹត្តទៅ ដោយអំណាចការកាត់បានជាសមុច្ឆេទ និងការរម្ងាប់ទុកនោះ ។ បរិញ្ញាទាំង ៣ បហានទាំង ៣ លោកពោលដោយអធិប្បាយថា ជាកិច្ចនៃមគ្គញាណ យ៉ាងណា ក្នុងទីនេះមិនពោលដូច្នោះឡើយ ។ ក្នុងទីនេះ **លោកុត្តរភាវនាតែម្យ៉ាង ជាកិច្ច** នៃមគ្គញាណនោះ ។ ឯពាក្យបរិយាយក្នុងភាវនាមិនមានក្នុងទីនេះ ហេតុនោះ ទើបលោកចុះអវធារណៈ ។ ដោយអវធារណៈនោះ លោកអាចារ្យរមែងបដិសេធលោកិយភាវនា ។

ពាក្យថា **ដែលមកហើយដោយសរុបយ៉ាងនេះ** សេចក្តីថា បញ្ញាដែលមកហើយដោយសរុបនោះឯង យ៉ាងនេះថា **បញ្ញំ ភាវយំ** កាលអប់រំបញ្ញា មិនបានមកដោយលើកចិត្តជាប្រធាន ដូចជាសមាធិ ក្នុងពាក្យថា **ចិត្តំ ភាវយំ** កាលអប់រំចិត្ត ។ **ពាក្យណាដែលលោកអាចារ្យពោលហើយ** តាមឧទ្ទេស ។ ដោយ **លំដាប់នៃពាក្យត្រឹមប៉ុណ្ណេះ ពាក្យនោះ ត្រូវបានខ្ញុំធ្វើឲ្យពិស្តារហើយ** ។ ភ្ជាប់សេចក្តីថា បញ្ហានេះ ក៏ខ្ញុំបានវិសជ្ជនាហើយ ។

ពណ៌នាញាណទស្សនវិសុទ្ធិនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ២២ ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## បញ្ញាភាវនានិសំសនិទ្ទេស

បញ្ហាកម្មណា ដែលខ្ញុំពោលទុកថា អ្វីជាអានិសង្សនៃការចម្រើនបញ្ញា ខ្ញុំនឹងពោលដោះស្រាយក្នុងបញ្ហាកម្មប្រការនោះតទៅ

ឯបញ្ញាភាវនានេះ មានអានិសង្សច្រើនរយយ៉ាង ដែលនឹងប្រកាសអានិសង្សនៃបញ្ញាភាវនានោះ ដោយពិស្តារមិនមែនងាយ សូម្បីដោយវេលាយូរក្តី តែពោលដោយសង្ខេប គប្បីជ្រាប ( ថា ) នេះជាអានិសង្សនៃបញ្ញាភាវនានោះ គឺ

១- នានាកិលេសវិទ្ធំសនៈ កម្ចាត់កិលេសផ្សេងៗ បាន

២- អរិយផលរសានុភវនៈ បានសោយរសនៃអរិយផល

៣- និរោធសមាបត្តិសមាបជ្ជនសមត្ថតា ជាអ្នកអាចក្នុងការចូលនិរោធសមាបត្តិ

៤- អាហុនេយ្យភាវាទិសិទ្ធិ សម្រេចជាបុគ្គលទ្រទ្រង់អរិយគុណ ជាអាហុនេយ្យបុគ្គលជាដើម ។

# មហាដីកា

## ពណ៌នាបញ្ញាភាវនានិសង្សនិទ្ទេស

## ពណ៌នាពាក្យប្រកាសអានិសង្ស

ឈ្មោះថា **មានអានិសង្សច្រើនយ៉ាង** ព្រោះនាំមកនូវគុណវិសេសដ៏បរិបូណ៌ និងឧឡារិក មានសាវកភូមិជាដើម ។ ពាក្យថា **ដោយពិស្តារ** សេចក្តីថា ដែលប្រកាសដោយពិស្តារ ដោយអំណាចការមិនធ្វើការសម្តែងន័យ ហើយសម្តែងតាមលំដាប់បទថា **បញ្ញាភាវនាមានអានិសង្សនេះ មានអានិសង្សនោះ** ដូច្នេះ មិនមែនធ្វើបានងាយ ព្រោះអានិសង្សមានច្រើនក្រៃលែង ។ បទថា **អស្សា យោគ បញ្ញាភាវនាយ** ប្រែថា នៃបញ្ញាភាវនានោះ ។ ពាក្យថា **កម្ចាត់កិលេសផ្សេងៗ បាន** សេចក្តីថា លះបាន ដោយអំណាចតទង្គប្បហានជាដើម ដែលកិលេសធម៌ទាំងឡាយ មានបែបផ្សេងៗ ជាសក្កាយទិដ្ឋិ និងវិចិកិច្ឆាជាដើម ។ ពាក្យថា **បានសោយរសនៃអរិយផល** សេចក្តីថា បានសោយចំពោះនូវសុខដែលកើតអំពីផល មានសោតាបត្តិផលជាដើម ។

# វិសុទ្ធិមគ្គ

## នានាកិលេសវិទ្ធំសនៈ

ក្នុងអានិសង្សទាំងនោះ ការកម្ចាត់កិលេសផ្សេងៗ មានសំយោជនៈ សក្កាយទិដ្ឋិជាដើម ដែលលោកពោលទុកតាំងអំពីការកំណត់នាមរូបទៅ យ៉ាងណា យ៉ាងនេះ គប្បីជ្រាបថា ជាអានិសង្សនៃបញ្ញាភាវនា ជាលោកិយ ការកម្ចាត់កិលេសផ្សេងៗ មានសំយោជនៈជាដើម ដែលលោកពោលទុកក្នុងខណៈនៃអរិយមគ្គ យ៉ាងណា យ៉ាងនេះ គប្បីជ្រាបថា ជាអានិសង្សនៃបញ្ញាភាវនា ជាលោកុត្តរ ។

ពិតហើយ បញ្ញា ដែលព្រះយោគាវចរធ្វើឲ្យមានឡើងហើយ រមែងទម្លាយសំណាញ់ គឺកិលេសដែលគ្របសង្កត់ ( សន្តាន ) មកអស់កាលដ៏យូរ ធ្វើអនត្ថៈគ្រប់យ៉ាងឲ្យវិនាសបាន ដូចរន្ទះធ្លាក់ចុះដោយកម្លាំងដ៏ខ្លាំង គួរភ័យខ្លាច ត្រង់ផ្ទាំងថ្មបំបែកថ្ម ( ឲ្យបែកខ្ចាយទៅ ) ដូចភ្លើង ( ព្រៃ ) ឆាបឆេះដោយកម្លាំងខ្យល់ កម្ទេចព្រៃ ( ឲ្យរាបទៅ ) ដូចព្រះអាទិត្យចាំងចែងកម្តៅរបស់ខ្លួន កម្ចាត់ងងឹត ដូច្នោះ បណ្ឌិតគប្បីជ្រាបអានិសង្សនេះ ជាអានិសង្សដែលព្រះយោគាវចរ គប្បីឃើញបានដោយខ្លួនឯង ក្នុងបញ្ញាភាវនានេះ ។

# មហាដីកា

## កថាពណ៌នាដោយការកម្ចាត់កិលេសផ្សេងៗ ចាន

ការលះដោយការសម្លាប់នូវកិលេសទាំងឡាយ លោកសម្តែងទុកដោយពាក្យថា **បានសោយរសនៃអរិយផល** នេះនោះឯង ព្រោះហេតុនោះ ទើបមានពាក្យផ្សេងទុកថា **ក្នុងខណៈនៃអរិយមគ្គ** ឬព្រោះជាបដិបស្សទ្ធិប្បហាននោះ ។ ពិតហើយ កាលសមុច្ឆេទប្បហានសម្រេចហើយ បដិបស្សទ្ធិប្បហាន ក៏បានសម្រេច ហើយដូច្នេះដែរ ។

បទថា **ភីមវេគានុបតិតា** សេចក្តីថា ធ្លាក់ចុះដោយរហ័ស ដោយកម្លាំងដ៏គួរភ័យខ្លាច គឺនាំមកនូវការខ្លាច ដូចជាកំពុងបំផ្លាញលោកទាំងមូល ។ បទថា **សិលុច្ចយេ** សេចក្តីថា ត្រង់ភ្នំថ្មសុទ្ធដ៏ក្រាស់ ។ បទថា **សតេជុជ្ជលមណ្ឌលោ** សេចក្តីថា ជាពន្លឺចែងចាំងដោយកម្តៅរបស់ខ្លួន ដែលសម្រេចក្នុងសរទកាល ។ **ធ្វើអនត្ថៈឲ្យគ្រប់យ៉ាង** មានការសម្លាប់ ការចាប់ចងជាដើម មានការសៅហ្មងដោយជុំវិញ ក្នុងទុគ្គតិ និងមានការកើតជាដើម ។ បទថា **សន្និដ្ឋិកំ** សេចក្តីថា ជាទីប្រចក្ស ។ បទថា **ជញ្ញា** ប្រែថា គប្បីដឹង ។ បទថា **ឥធ** សេចក្តីប៉ុនគ្នានឹង **ឥមិស្មិំ យោគ បញ្ញាភាវយំ** ប្រែថា ក្នុងបញ្ញាភាវនានេះ ។

# វិសុទ្ធិមគ្គ

## អរិយផលសានុភាវៈ

អានិសង្សប្រការថា **អរិយផលសានុភាវៈ** សេចក្ដីថា ម្យ៉ាងទៀត មិនមែនត្រឹមតែទម្លាយកិលេសផ្សេងៗ បានប៉ុណ្ណោះឡើយ សូម្បីការបានសោយរសនៃអរិយផល ក៏ជាអានិសង្សរបស់បញ្ញាភាវនា ឯសាមញ្ញផល មានសោតាបត្តិផលជាដើម លោកហៅថា **អរិយផល** ការសោយរសរបស់អរិយផលនោះ រមែងមានដោយអាការ ២ គឺក្នុងបវត្តិ ក្នុងមគ្គវិថី ១ ក្នុងបវត្តិ ដោយអំណាចផលសមាបត្តិ ១ ក្នុងអាការ ២ នោះ បវត្តិក្នុងមគ្គវិថី និងអរិយផលនោះ បានសម្ដែងមកហើយ ។

អើ អាចារ្យពួកណាពោលថា គុណ គឺការលះសំយោជនៈបានត្រឹមប៉ុណ្ណោះឯង ឈ្មោះថា **ផល** មិនមែនមានធម៌ណាមួយដទៃឡើយ ដូច្នេះ ដើម្បីការត្រេកអរ ចំពោះអាចារ្យទាំងនោះ គប្បីសម្ដែងសូត្រនេះក៏បានថា **បយោគប្បដិបស្សទ្ធិប្បញ្ញា** ( បញ្ញាក្នុងការរម្ងាប់បយោគ គឺមគ្គ ) ឈ្មោះថា **ផលញ្ញាណ** ដូចម្ដេច ? **សម្មាទិដ្ឋិ** ដោយអត្ថ គឺឃើញក្នុងខណៈនៃសោតាបត្តិមគ្គ រមែងចេញចាកមិច្ឆាទិដ្ឋិ រមែងចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិទាំងនោះផង ចាកខន្ធទាំងឡាយ ( ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិ ) ផង ចាកនិមិត្ត ( គឺសង្ខារ ) ទាំងពួងខាងក្រៅផង រមែងកើតឡើងព្រោះការស្ងប់រម្ងាប់ទៅនៃបយោគ ការដឹងប្រពៃ ( ដែលជាវិបាក ) នោះ ជាផលនៃសម្មាទិដ្ឋិមគ្គ ពាក្យក្នុងព្រះសូត្រ ( តទៅនេះ ) គប្បីឲ្យពិស្ដារចុះ ។

ម្យ៉ាងទៀត សូម្បីពាក្យបាលីទាំងឡាយ មានពាក្យថា **ធម៌ទាំងនេះ គឺអរិយមគ្គ ៤ និងសាមញ្ញផល ៤ ជាអប្បមាណារម្មណ៍ ។ មហគ្គតធម៌ ជាបច្ច័យ ដោយអនន្តរប្បច្ច័យនៃអប្បមាណធម៌** ដូច្នេះជាដើម ក៏ជាសាធកៈក្នុងសេចក្ដីនេះបាន ។

# បវត្តិក្នុងផលសមាបត្តិ

ចំណែកពាក្យថា ដើម្បីសម្តែងបវត្តិក្នុងផលសមាបត្តិនៃអរិយផលនោះ មានបញ្ហាកម្មដូចតទៅនេះ គឺផលសមាបត្តិ គឺអ្វី ? បុគ្គលពួកណាចូលផលសមាបត្តិនោះបាន បុគ្គលណាចូលមិនបាន ? ចូលព្រោះអ្វី ? ហើយការចូលផលសមាបត្តិនោះដូចម្តេច ? ( ចូលហើយ ) ស្ថិតនៅដូចម្តេច ? ចេញដូចម្តេច ? អ្វីមានក្នុងលំដាប់នៃផល ហើយផលមានក្នុងលំដាប់នៃអ្វី ?

# ផលសមាបត្តិគឺអ្វី

ក្នុងបញ្ហាកម្មទាំងឡាយនោះ បញ្ហាកម្មថា **ផលសមាបត្តិ គឺអ្វី** ? ឆ្លើយថា គឺការអែបស្និទ្ធនៅក្នុងនិរោធនៃអរិយផល ។

## បុគ្គលណាចូលផលសមាបត្តិបាន បុគ្គលណាចូលមិនបាន

បញ្ហាកម្មថា **បុគ្គលពួកណា ចូលផលសមាបត្តិនោះបាន ពួកណា ចូលមិនបាន** ? ឆ្លើយថា បុថុជ្ជនទាំងពួងចូលមិនបាន ព្រោះអ្វី ព្រោះមិនទាន់សម្រេច ( អរិយផល ) ចំណែកព្រះអរិយៈទាំងពួងចូលបាន ព្រោះអ្វី ព្រោះបានសម្រេច ( អរិយផល ) ហើយ តែព្រះអរិយបុគ្គលជាន់ខ្ពស់ រមែងមិនចូលផលសមាបត្តិជាន់ទាប ព្រោះផលជាន់ទាបស្ងប់រម្ងាប់ទៅហើយ ដោយការចូលដល់ភាពជាបុគ្គលដទៃ ព្រះអរិយបុគ្គលជាន់ទាបសោត ក៏ចូលផលសមាបត្តិជាន់ខ្ពស់មិនបាន ព្រោះមិនទាន់បានសម្រេច តែព្រះអរិយៈទាំងឡាយ រមែងចូលផលសមាបត្តិរៀងៗខ្លួនប៉ុណ្ណោះ នេះជាសន្និដ្ឋានក្នុងបញ្ហាកម្មនេះ ។

តែអាចារ្យពួកខ្លះ ពោលថា ( សូម្បីព្រះសោតាបន្ន និងព្រះសកទាគាមី ក៏ចូលមិនបាន ព្រះអរិយៈ ២ ពួកប៉ុណ្ណោះ ទើបចូលបាន ) ដូច្នេះ នេះជាហេតុនៃកេចិអាចារ្យទាំងនោះ គឺព្រោះអរិយៈជាន់ខ្ពស់ ២ ពួកនោះ ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសមាធិ ហេតុ

ដែលគេចិអាចារ្យពោលនោះ ជាហេតុមិនប្រពៃឡើយ ព្រោះសូម្បីបុថុជ្ជន ក៏ចូលលោកិយសមាធិដែលខ្លួនបានហើយ តែប្រយោជន៍អ្វីដោយការគិតថា មិនជាហេតុក្នុងសេចក្តីនេះនោះ ក្នុងព្រះបាលីលោកក៏បានពោលទុកហើយ មិនមែនឬថា គោត្រភូធម៌ ១០ អ្វីខ្លះ រមែងកើតឡើង ដោយអំណាចវិបស្សនា ? ញាណណាគ្របសង្កត់នូវឧប្បាទ...នូវបវត្តៈ ។បេ។...នូវឧបាយាស...នូវសង្ខារនិមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់ការបានសោតាបត្តិមគ្គ ហេតុនេះ ទើបញាណនោះ ឈ្មោះគោត្រភូ ញាណណាគ្របសង្កត់នូវឧប្បាទ ។បេ។ នូវសង្ខារនិមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់ការចូលសោតាបត្តិផលសមាបត្តិ... សកទាគាមិផលសមាបត្តិ... អនាគាមិផលសមាបត្តិ... អរហត្តផលសមាបត្តិ... សុញ្ញត វិហារសមាបត្តិ អនិមិត្តវិហារសមាបត្តិ ហេតុនេះ ទើបញាណនោះ ឈ្មោះគោត្រភូ ដូច្នេះ ព្រោះហេតុនោះ ទើបគួរដល់ការកំណត់ក្នុងបញ្ហាកម្មនេះបានថា ព្រះអរិយៈទាំងពួង ( គ្រប់ថ្នាក់ ) រមែងចូលផលសមាបត្តិរៀងៗ ខ្លួនបាន ។

## ចូលដើម្បីអ្វី

បញ្ហាកម្មប្រការថា ចូលព្រោះ ( ដើម្បី ) អ្វី ? ឆ្លើយថា ដើម្បីទិដ្ឋធម្មសុខវិហារធម៌ ដូចជាព្រះរាជា សោយរជ្ជសុខ ទេវតាទាំងឡាយ សោយទិព្វសុខយ៉ាងណា ព្រះអរិយៈទាំងឡាយគិតថា យើងទាំងឡាយ នឹងសោយអរិយលោកុត្តរសុខ ធ្វើអទ្ធានបរិច្ឆេទ ( កំណត់កាល ) ហើយក៏ចូលផលសមាបត្តិ គ្រប់ខណៈដែលត្រូវការ ដូច្នោះ ។

## ចូលដូចម្តេច ស្ថិតនៅដូចម្តេច ចេញដូចម្តេច

បញ្ហាកម្មប្រការថា ហើយការចូលផលសមាបត្តិនោះ ដូចម្តេច តាំងនៅដូចម្តេច

ចេញដូចម្តេច ? ឆ្លើយថា លំដាប់ដំបូង ការចូលផលសមាបត្តិនោះ រមែងមានដោយអាការ ២ គឺព្រោះមិនធ្វើមនសិការដល់អារម្មណ៍ដទៃក្រៅអំពីព្រះនិព្វាន ១ ព្រោះធ្វើមនសិការដល់តែព្រះនិព្វាន ១ ដូចព្រះធម្មទិន្នាថេរីពោល ( ដល់វិសាខឧបាសក ) ថា នែអាវុសោ បច្ច័យនៃការចូលអនិមិត្តាចេតោវិមុត្តិមាន ២ គឺមិនធ្វើមនសិការដល់និមិត្តទាំងពួង ១ ធ្វើមនសិការដល់តែធាតុដែលមិនមាននិមិត្ត ( គឺព្រះនិព្វាន ) ១ ដូច្នេះ ។

ចំណែកតទៅនេះ ជាលំដាប់ការចូលផលសមាបត្តិនេះ សេចក្តីថា ព្រះអរិយសាវកដែលមានបំណងដោយផលសមាបត្តិ គប្បីទៅក្នុងទីស្ងាត់ គេចខ្ទង់ហើយ សម្លឹងពិចារណាសង្ខារដោយវិបស្សនាញាណ មានឧទយព្វយញ្ញាណជាដើម ចិត្តរបស់ព្រះអរិយសាវកដែលមានវិបស្សនាញាណតាមលំដាប់ប្រព្រឹត្តទៅហើយ រមែងអែបស្និទ្ធក្នុងនិរោធ ជាផលសមាបត្តិ ក្នុងលំដាប់នៃគោត្រភូញាណ ដែលមានសង្ខារជាអារម្មណ៍ ។ ឯក្នុងការចូលផលសមាបត្តិនេះ ព្រោះព្រះអរិយសាវកនោះ បង្អោនចិត្តទៅដើម្បីផលសមាបត្តិ ទើបផលប៉ុណ្ណោះកើតឡើង សូម្បីដល់ព្រះសេក្ខៈ មគ្គមិនកើតឡើងឡើយ ចំណែកអាចារ្យពួកណាពោលថា ព្រះសោតាបន្នមានបំណងថានឹងចូលផលសមាបត្តិ តាំងធ្វើវិបស្សនាទៅ ក៏ជាព្រះសកទាគាមី ព្រះសកទាគាមីសោត... តាំងធ្វើវិបស្សនាទៅ ក៏ជាព្រះអនាគាមី ដូច្នេះ អាចារ្យទាំងនោះ ក៏គួរពោលថែមទៀតថា កាលបើយ៉ាងនោះ ព្រះអនាគាមី ( តាំងធ្វើវិបស្សនាទៅ ) ក៏នឹងជាព្រះអរហន្ត ព្រះអរហន្ត... ក៏នឹងជាព្រះបច្ចេកពុទ្ធ ហើយព្រះបច្ចេកពុទ្ធ... ក៏នឹងជាព្រះសម្មាសម្ពុទ្ធបាន ។ ព្រោះហេតុនោះ ទើបពាក្យអាចារ្យទាំងនោះ មិនគួរកាន់យកសូម្បីបន្តិចបន្តួច ។ មួយវិញទៀត ពាក្យនៃអាចារ្យទាំងនោះត្រូវតែបដិសេធ ដោយអំណាចព្រះបាលី ( អំពីគោត្រភូធម៌ ១០ ដែលពោលហើយ ដែលញែកវិបស្សនា សម្រាប់មគ្គ និងសម្រាប់ផល ម្នាងមួយៗ )

ផង ព្រោះហេតុនេះ ទើបមិនគួរកាន់យក គួរកាន់យកប៉ុណ្ណោះប៉ុណ្ណោះ គឺផលប៉ុណ្ណោះ កើតឡើងដល់ព្រះសេក្ខៈ មគ្គមិនកើតឡើងឡើយ ផលសោត បើមគ្គដែលព្រះអរិយបុគ្គលនោះបានសម្រេចជាបឋមជ្ឈានិកមគ្គ ( មគ្គមានបឋមជ្ឈាន ) ក៏ជាបឋមជ្ឈានិកផលដូចគ្នា កើតឡើងដល់ព្រះអរិយបុគ្គលនោះ បើមគ្គជាទុតិយជ្ឈានិកជាដើម ឈានិកណានីមួយ ផលក៏ជាទុតិយជ្ឈានិកជាដើម ឈានិកណាមួយ ដូចគ្នា ។

ការចូលផលសមាបត្តិនោះ រមែងមានដោយអាការយ៉ាងនេះជាលំដាប់ដំបូង ។ ចំណែកការស្ថិតនៅនៃផលសមាបត្តិនោះ រមែងមានដោយអាការ ៣ តាមពាក្យ ( ព្រះនាងធម្មទិន្នាថេរី ) ថា នែ អាវុសោ បច្ច័យរបស់ការស្ថិតនៅនៃអនិមិត្តាចេតោវិមុត្តិមាន ៣គឺមិនធ្វើមនសិការដល់និមិត្តទាំងពួង ១ធ្វើមនសិការដល់ធាតុដែលមិនមាននិមិត្ត ១ រៀបចំទុកមុន ១ ដូច្នេះ ក្នុងពាក្យទាំងនោះ ពាក្យថា **បុព្វេ ច អភិសង្ខារោ** រៀបចំទុកមុន ១ ដោយអត្ថថា កំណត់កាលទុកមុន នឹងចូលសមាបត្តិ អធិប្បាយថា កំណត់ទុកថា **អាត្មាអញនឹងចេញក្នុងកាលឈ្មោះនោះ** កាលនោះមិនទាន់មកដល់ដរាបណា ការស្ថិតនៅនៃផលសមាបត្តិនោះ ក៏នៅមានដរាបនោះ ការតាំងនៅនៃផលសមាបត្តិនោះ រមែងមានដោយអាការយ៉ាងនេះឯង ។

ចំណែកការចេញនៃផលសមាបត្តិនោះ រមែងមានដោយអាការ ២ តាមពាក្យ ( ព្រះនាងធម្មទិន្នាថេរី ) ថា អើ អាវុសោ បច្ច័យរបស់ការចេញនៃអនិមិត្តាចេតោវិមុត្តិមាន ២ គឺធ្វើមនសិការដល់និមិត្តទាំងពួង ១ មិនធ្វើមនសិការដល់ធាតុដែលមិនមាននិមិត្ត ១ ដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **និមិត្តទាំងពួង** បានដល់ រូបនិមិត្ត វេទនានិមិត្ត សញ្ញានិមិត្ត សង្ខារនិមិត្ត វិញ្ញាណនិមិត្ត ព្រះអរិយៈ ( ដែលចេញ ) មិនបានធ្វើមនសិការដល់និមិត្តទាំងនោះ ជាមួយគ្នានោះឯងក៏ពិត តែពាក្យថា **និមិត្តទាំងពួងនោះ** លោកពោលជាសព្វសង្គាហិក ( រួមទុកចូលគ្នាទាំងអស់ ) ព្រោះដូច្នោះ

និមិត្តណាជាអារម្មណ៍នៃកវត្តបាន កាលធ្វើមនសិការដល់និមិត្តនោះ ការចេញចាកផលសមាបត្តិ ក៏មានបាន ដូច្នេះ ។

ការចេញនៃផលសមាបត្តិនោះ គប្បីជ្រាបដូចពោលមក ដូច្នេះ ។

## អ្វីមានក្នុងលំដាប់នៃផល

បញ្ហាកម្មប្រការថា អ្វីមានក្នុងលំដាប់នៃផល ហើយផលមានក្នុងលំដាប់នៃអ្វី ឆ្លើយជាដំបូងថា ផលនោះឯង ឬកវត្តខ្លះ រមែងមានក្នុងលំដាប់នៃផល ( ឆ្លើយជាក្រោយថា ) ចំណែកផលមានក្នុងលំដាប់នៃមគ្គក៏មាន ក្នុងលំដាប់នៃផលក៏មាន ក្នុងលំដាប់នៃគោត្រភូក៏មាន ក្នុងលំដាប់នៃនេវសញ្ញានាសញ្ញាយតនៈក៏មាន ក្នុងផលទាំងនោះ ផលក្នុងលំដាប់នៃមគ្គ រមែងមានក្នុងមគ្គវិថី ផលក្រោយៗ រមែងមានក្នុងលំដាប់នៃផលមុនៗ ផលមុនៗ ក្នុងផលសមាបត្តិទាំងឡាយ រមែងមានក្នុងលំដាប់នៃគោត្រភូ ពាក្យថា គោត្រភូ ក្នុងទីនេះ គប្បីជ្រាបថា បានដល់ អនុលោមញ្ញាណសមដូចពាក្យដែលពោលទុកក្នុងគម្ពីរបដ្ឋានថា អនុលោមញ្ញាណរបស់ព្រះអរហន្ត រមែងជាបច្ច័យដោយអនន្តរបច្ច័យនៃផលសមាបត្តិ ( របស់ព្រះអរហន្ត ) អនុលោមញ្ញាណរបស់ព្រះសេក្ខៈទាំងឡាយ រមែងជាបច្ច័យដោយអនន្តរបច្ច័យ នៃផលសមាបត្តិ ( របស់ព្រះសេក្ខៈទាំងឡាយ ) ដូច្នេះ ការចេញចាកនិរោធរមែងមានដោយផលណា ផលនោះ ជាផលមានក្នុងលំដាប់នៃនេវសញ្ញានាសញ្ញាយតនៈ ។

ក្នុងផលទាំងនោះ វៀរផលដែលកើតក្នុងមគ្គវិថីចេញ ផលដ៏សេស រាប់ថាជាផលដែលប្រព្រឹត្តទៅដោយអំណាចផលសមាបត្តិទាំងអស់ ដោយអំណាចដែលកើតឡើងក្នុងមគ្គវិថីខ្លះ ក្នុងផលសមាបត្តិខ្លះ ដូចពោលមក ដូច្នេះ ផលនោះ

ទើបជាសាមញ្ញផលដ៏ឧត្តម មានការក្តៅក្រហាយ ស្ងប់រម្ងាប់ហើយ មាន

អមតធម៌ជាអារម្មណ៍ ជាផលដែលស្ងប់ប្រណីត ខ្ជាក់ចោលនូវលោកាមិសហើយ ជាផលដែលជ្រួតជ្រាបទៅដោយសេចក្តីសុខដ៏ស្អាត មានឱជាដ៏ជាអមតសុខ ( មានរស ) ផ្អែមត្រជាក់ជាងរសផ្អែម ប្រៀបដូចទឹកឃ្មុំ ហេតុណា បណ្ឌិតញុាំងបញ្ញាឲ្យកើតហើយ ទើបបានជួបសេចក្តីសុខនោះ ដែលរាប់ថា ជារសដ៏កំពូលនៃអរិយផលនោះ ហេតុនោះ ការបានសោយរសនៃអរិយផលនោះ ទើបពោលថា ជាអានិសង្ស របស់វិបស្សនាភាវនា ក្នុងបញ្ញាភាវនាធិការនេះ ។

# មហាដីកា

## កថាពណ៌នាដោយផលសមាបត្តិ

ផលនៃអរិយមគ្គ ឈ្មោះថា **អរិយផល** ផលនោះជាអរិយៈ ព្រោះជាការបរិសុទ្ធផង ព្រោះហេតុនោះ ទើបឈ្មោះថា **អរិយផល** ។ **រស** នៃអរិយផលនោះ បានដល់ សុខដែលកើតអំពីបស្សទ្ធិវិមុត្តិ **ការសោយ** បានដល់ ការសេពចំពោះនូវអរិយផលនោះ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ បទថា **តត្រ** សេចក្តីប៉ុន្មានទឹង **តេសុ** យោគ **ទ្វីសុ អាការេសុ** ប្រែថា ក្នុងបណ្តាអាការ ២ យ៉ាងនោះ ។ បទថា **អស្ស** យោគ **អរិយផលស្ស** ប្រែថា នៃអរិយផលនោះ ។

ការលះសំយោជនៈបានហើយ រមែងបានលះកិលេសទាំងអស់នោះឯង ព្រោះហេតុនោះ ទើបលោកកាន់យកសំយោជនៈប៉ុណ្ណោះ ។ អធិប្បាយថា **គុណជាតិត្រឹមតែការលះសំយោជនៈប៉ុណ្ណោះ** ទើប **ឈ្មោះថា ជាផល** នៃអរិយមគ្គ មិនមានការពិសេសអ្វីដទៃជាវិបាកឡើយ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ឈ្មោះថា ផល មិនមានធម៌ណាមួយដទៃឡើយ** ដូច្នេះ ។ សួរថា អាចារ្យពួកណាពោលយ៉ាងនេះ ? ឆ្លើយថា អាចារ្យអ្នកអន្ធកៈជាដើម ពិតហើយ អាចារ្យជែនអន្ធកៈជាដើមនោះ កាន់យកសេចក្តីដោយប្រការដទៃនៃបទព្រះសូត្រថា នែ សារីបុត្រ ដែលហៅថា អរហត្ត អរហត្ត នេះ អរហត្តដូចម្តេច ? ព្រះសារីបុត្រឆ្លើយថា អើ អាវុសោ ធម៌ដែលជាទីអស់រាគៈ ។បេ។ ធម៌ដែលជាទីអស់មោហៈ ហៅថា **អរហត្ត** ដូច្នេះ កាលពោលថា អ្វីៗ ឈ្មោះថា អរហត្តមិនមានការលះកិលេសនោះឯង លោកហៅយ៉ាងនោះ ដោយនិប្បរិយាយ រមែងបដិសេធក្នុងផលដ៏សេស ។ លោកអាចារ្យពោលដល់ព្រះបាលីបដិសម្ភិទាមគ្គថា **សុមិ្បសូត្រនេះ** ។ ការប្រកបជាន់ខ្ពស់ គឺខ្ពស់បំផុត

ហេតុនោះ ទើបឈ្មោះថា **បយោគ** បានដល់ អរិយមគ្គ ការរម្ងាប់កិលេសដែលកើតឡើង ព្រោះបយោគជាហេតុ ឈ្មោះថា **បយោគបស្សទ្ធិ** ។ ចំណែកបញ្ញាណាបានចំពោះ ញុំាងអរិយមគ្គឲ្យកើត កាលបញ្ញាដែលជាវិបាកណាសម្រេចចុះ ក៏រមែងសម្រេច បញ្ញានោះមានក្នុងកាលការ រម្ងាប់គប្បីសម្រេច ហេតុនោះ ទើបលោកអាចារ្យហៅថា **បដិបស្សទ្ធិប្បញ្ញា** ។ ពាក្យថា **សម្មាទិដ្ឋិ រមែងចេញចាកមិច្ឆាទិដ្ឋិ** សេចក្ដីថា លោកអាចារ្យកាលពោល ដោយអំណាចការឃើញជាសត្រូវដោយត្រង់ចំពោះសម្មាទិដ្ឋិហើយ បានពោលថា **ចាកកិលេសដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះទាំងឡាយ** ដូច្នេះ ដើម្បីសម្ដែងការចេញទៅអំពីកិលេសដទៃ អំពីមិច្ឆាទិដ្ឋិនោះ ព្រោះមិច្ឆាទិដ្ឋិនោះប្រកបផង និងព្រោះជាឧបនិស្ស័យដោយកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាម ។ ដោយហេតុនោះ ទើបព្រះសារីបុត្រពោលការលះកិលេស ដែលតាំងនៅដូចគ្នានឹងមិច្ឆាទិដ្ឋិនោះ ។ ពាក្យថា **ចាកខន្ធទាំងឡាយ** បានដល់ ចាកខន្ធដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះ អធិប្បាយថា ចាកខន្ធដែលសម្បយុត្តជាមួយមិច្ឆាទិដ្ឋិនោះ និងចាកខន្ធដែលកើតឡើងតទៅ ព្រោះមានមិច្ឆាទិដ្ឋិនោះជាបច្ច័យ ។ ពាក្យថា **ចាកនិមិត្តទាំងពួងខាងក្រៅផង** សេចក្ដីថា ចាកនិមិត្ត គឺសង្ខារទាំងពួង ដែលជាខាងក្រៅចាកគំនរកិលេសតាមដែលពោលហើយ ដែលជាអារម្មណ៍នៃវិបស្សនា ។

លោកអាចារ្យ កាលសម្ដែងកិច្ច នៃមគ្គយ៉ាងនេះហើយ ឥឡូវនេះ មានបំណងសម្ដែងផល ដោយអំណាចកិច្ចនៃមគ្គនោះ ទើបពោលពាក្យថា **ព្រោះការរម្ងាប់ទៅនៃបយោគនោះ** ដូច្នេះជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ព្រោះការរម្ងាប់ទៅនៃបយោគទាំងនោះ** សេចក្ដីថា ព្រោះបយោគ មានការចេញចាកខាងក្នុងខាងក្រៅជាដើមនោះរម្ងាប់ទៅហើយ ។ ពិតហើយ មគ្គកាលចេញចាកនិមិត្ត និងបវត្ត: រមែងលះកិលេសទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា ធ្វើបយោគនោះ ក្នុងខណ:

របស់ខ្លួន តែក្នុងខណៈនៃផល បយោគរបស់មគ្គនោះ រម្ងាប់ទៅ ទើបឈ្មោះថា បានចូលទៅស្ងប់ហើយ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះការរម្ងាប់ទៅនៃបយោគនោះ ។ ពាក្យថា **កើតឡើង** សេចក្តីថា កើតឡើង ២ ឬ ៣ ខណៈក្នុងលំដាប់របស់មគ្គ ។ តែក្នុងកាលចូលផលសមាបត្តិ កើតឡើងច្រើនខណៈ កាលចេញចាកនិរោធក៏កើតឡើង ២ ខណៈ ។ ព្រះសារីបុត្រពោលថា កើតឡើងព្រោះការរម្ងាប់ទៅនៃបយោគនោះ ដូច្នេះ ព្រោះកើតឡើងមានការរម្ងាប់ទៅនៃបយោគតាមដែលពោលហើយ ជានិមិត្តទាំងពួង ។ ពាក្យថា **នុះជាផលនៃមគ្គ** សេចក្តីថា ឈ្មោះថា **សម្មាទិដ្ឋិ** តាមដែលពោលហើយជាវិបាកនោះ គប្បីជ្រាបថា ជាផលរបស់អរិយមគ្គ ។ ពាក្យថា **គប្បីឲ្យពិស្តារចុះ** សេចក្តីថា គប្បីជ្រាបដោយពិស្តារ ទាក់ទងជាមួយនឹងសង្កប្បជាដើម ដោយន័យជាដើមថា ក្នុងខណៈសោតាបត្តិមគ្គ សម្មាសង្កប្ប ព្រោះអត្ថថា លើកឡើង រមែងចេញចាកមិច្ឆាសង្កប្ប និងទាក់ទងជាមួយមគ្គដ៏សេស ។

ពាក្យថា **ធម៌ទាំងនេះ គឺសាមញ្ញផល ៤ ដែលជាអប្បមាណារម្មណ៍** ព្រះសារីបុត្រពោលទុក ព្រោះសាមញ្ញផលមិនមានការផ្សេងទៅអំពីមគ្គ ព្រោះអប្បមាណារម្មណ៍ ។ អធិប្បាយថា **សូម្បីពាក្យជាដើមយ៉ាងនេះថា** ពាក្យសម្តែងភាពជាអនន្តរប្បច្ច័យដល់អរិយផលថា ម្យ៉ាងទៀត មហគ្គតធម៌ ពោល គឺនេវសញ្ញានាសញ្ញាយតនៈជាបច្ច័យ ដោយអនន្តរប្បច្ច័យដល់អប្បមាណធម៌ ក្នុងពេលចេញចាកនិរោធ ដូច្នេះ **ក៏ជាសាធកៈក្នុងសេចក្តីនេះបាន** ដោយអរិយផល ជាសភាវធម៌ មានអធិប្បាយថា មិនមែនព្រះបាលីបដិសម្ភិទាមគ្គ តាមដែលបានសម្តែងហើយប៉ុណ្ណោះ ជាសាធកៈឡើយ ។

ពាក្យថា **ក្នុងផលសមាបត្តិ** បានដល់ ក្នុងសមាបត្តិ ពោល គឺការប្រព្រឹត្តទៅនៃផល ។ បទថា **អស្ស យោគ អរិយផលស្ស** ប្រែថា នៃអរិយផលនោះ ។ បញ្ហា

កម្មនេះ ទាក់ទងនឹង **សរូប កត្តុ ហេតុ អាការ** ការស្ថិតនៅ ការចេញ និងលំដាប់ ។

ពាក្យថា **រមែងអែបស្និទ្ធនៅក្នុងនិរោធនៃអរិយផល** បានដល់ ការប្រព្រឹត្តទៅដោយអាការចុះណែនទៅក្នុងនិព្វាន ដែលជាអារម្មណ៍របស់ផលជ្ឈាន ដែលជាអរិយៈ។

ពាក្យថា **បុថុជ្ជនទាំងពួង** សេចក្តីថា បុថុជ្ជនទាំងឡាយ សូម្បីបានឈានសមាបត្តិ ក៏ចូលមិនបាន បុថុជ្ជនក្រៅអំពីនេះ មិនចាំបាច់និយាយដល់ ។ ពាក្យថា **ព្រះអរិយៈទាំងពួងចូល** ផលសមាបត្តិបាន ជាពាក្យធ្វើបញ្ចាំងភាពស្មើគ្នាដោយពិតសូម្បីយ៉ាងនោះ ពាក្យធ្វើបញ្ចាំងការស្មើគ្នានោះ ក៏ជាពាក្យតាំងនៅក្នុងភាពផ្សេងគ្នានោះឯង ។ ចំណែកពាក្យថា **ព្រោះបានសម្រេចហើយ** ជាពាក្យប្រាប់ដល់ហេតុ ។ ការចូលសមាបត្តិ ដូចជាការចូលលោកិយសមាបត្តិជាន់ទាប ក៏តាំងនៅបានសូម្បីដល់ព្រះអរិយៈជាន់ខ្ពស់ទាំងឡាយ ដូចជាធ្វើឲ្យសម្រេចបាន ហេតុនោះ លោកអាចារ្យកាលបដិសេធសេចក្តីនោះ ទើបពោលពាក្យជាដើមថា **តែព្រះអរិយៈជាន់ខ្ពស់** ដូច្នេះ ។ ក្នុងពាក្យនោះ ពាក្យថា **ជាន់ខ្ពស់** បានដល់ ព្រះអរិយៈទាំងឡាយ មានព្រះសកទាគាមីជាដើម ។ ពាក្យថា **ផលសមាបត្តិជាន់ទាប** បានដល់ សោតាបត្តិផលជាដើម ។ **រមែងមិនចូល** សូម្បីកាលមានផលសមាបត្តិ ដែលខ្លួនបានសម្រេចហើយ ។ សួរថា ព្រោះហេតុអ្វី លោកអាចារ្យពោលហេតុថា **ព្រោះផលជាន់ទាបស្ងប់រម្ងាប់ទៅហើយ**ដោយការចូលដល់ភាពជាបុគ្គលដទៃ ។ ដោយពាក្យនេះ លោកអាចារ្យរមែងពោលអាងដល់ហេតុ ដែលប្រព្រឹត្តទៅដោយទំនង ដូចជាព្រះអរិយៈជាន់ខ្ពស់ រមែងចូលផលសមាបត្តិជាន់ទាប ព្រោះជាផលដែលខ្លួនបានសម្រេចហើយ ដូចជាលោកិយសមាបត្តិ ។ ព្រោះដែលបានឈ្មោះថា ការចូលដល់ភាពជាបុគ្គលដទៃក្នុងលោកិយជ្ឈានទាំងឡាយ រមែងមិនមាន ព្រោះមិនមានការផ្សេងគ្នា ។ តែក្នុងទីនេះ ព្រះអរិយៈជាន់ខ្ពស់ មានព្រះសកទាគាមីជាដើម មានការចូលដល់ភាពជាបុគ្គលដទៃអំពីព្រះ

អរិយៈជាន់ទាប មានព្រះសោតាបន្នជាដើមបាន ដូចជាព្រះសោតាបន្ន មានការចូលដល់ភាពជាបុគ្គលដទៃអំពីបុថុជ្ជនទាំងឡាយ ព្រោះរលត់កម្មក្កិលេស ដែលមិនទាន់កើតកន្ទ្រាក់បាន ព្រោះធម៌ គឺផលទាំងឡាយ ជាន់ទាបៗ ត្រូវធម៌ គឺមគ្គជាន់ខ្ពស់បដិសេធ គ្របសង្កត់ ដូចធម៌ដែលជាបដិបក្ខគ្នា ដល់នូវភាពជាសភាវៈ មានការមិនប្រព្រឹត្តទៅជាធម្មតានោះឯង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះផលជាន់ទាបរម្ងាប់ទៅហើយ** ។

ប្រការមួយទៀត ធម្មតាការប្រព្រឹត្តទៅរបស់កុសល និងកិរិយាមយ៉ាង និងការប្រព្រឹត្តទៅនៃវិបាកក៏មយ៉ាង និងព្រោះលោកុត្តរកុសលទាំងឡាយ មានផលក្នុងលំដាប់គ្នា ព្រះអរិយៈជាន់ខ្ពស់ ទើបដូចជានៅក្នុងភពដទៃអំពីព្រះអរិយៈជាន់ទាប ។ សេចក្ដីពិត ការបានឈ្មោះថា សោតាបន្នជាដើមរបស់ព្រះអរិយៈទាំងឡាយ ក៏ដោយអំណាចនៃផលនោះឯង ។ បើព្រះអរិយៈទាំងនោះ សូម្បីជាបុគ្គលមានការដល់ព្រមដោយផលដទៃ សូម្បីឈ្មោះថា សោតាបន្នជាដើម ក៏គប្បីជាឈ្មោះដែលតាំងចុះបានដល់ ព្រះអរិយៈទាំងនោះ ក៏ដូចជាបុគ្គលដែលមានបដិសន្ធិ កាន់យកដោយឈាននោះ ព្រោះហេតុនោះ ផលនោះៗ របស់ព្រះអរិយៈនោះៗ ក៏ដូចជាភវង្គ ព្រោះហេតុនោះ ក៏គប្បីឃើញបានថា ក្នុងព្រះអរិយៈជាន់ខ្ពស់ ជាអ្នកមានការដល់ព្រមដោយផលជាន់ទាប សូម្បីការអាងដល់ ក៏មិនទាន់មានបាន ព្រះអរិយៈជាន់ខ្ពស់ នឹងចូលផលសមាបត្តិជាន់ទាបនោះ នឹងមានមកអំពីណា ។ ពីរបទថា **ហេដ្ឋិមា ច ឧបរិមំ** ក្នុងសេចក្ដីថា ព្រះអរិយៈទាំងឡាយជាន់ទាប មានព្រះសោតាបន្នជាដើម ក៏មិនចូលផលសមាបត្តិជាន់ខ្ពស់ មានសកទាគាមិផលជាដើម ។ ក្នុងសេចក្ដីនោះ លោកអាចារ្យពោលហេតុទុកថា **ព្រោះមិនទាន់បានសម្រេច** ។ ពិតហើយ សមាបត្តិដែលមិនទាន់បានសម្រេច បុគ្គលណាម្នាក់ មិនអាចចូលបានឡើយ ។

ដោយពាក្យថា ឯព្រះអរិយៈទាំងឡាយ រមែងចូលផលសមាបត្តិ រៀងៗ ខ្លួនប៉ុណ្ណោះ នេះ កាលដល់អត្ថថា ព្រះអរិយៈទាំងឡាយទាំងពួង រមែងចូលផលសមាបត្តិរបស់ខ្លួន រៀងៗខ្លួនបាន ដូច្នេះលោកអាចារ្យមានបំណងនឹងសម្តែងការផ្សេងគ្នានៃមតិរបស់កេចិអាចារ្យក្នុងសេចក្តីនោះ ទើបពោលពាក្យថា **ចំណែកអាចារ្យពួកខ្លះ** ដូច្នេះជាដើម ។ ពាក្យថា **ព្រោះព្រះអរិយៈជាន់ខ្ពស់ ២ ពួកនោះ ជាបុគ្គលធ្វើឲ្យបរិបូណ៌ក្នុងសមាធិ** សេចក្តីថា ព្រោះព្រះអនាគាមី និងព្រះអរហន្ត ដែលលោកពោលថា **ព្រះអរិយៈជាន់ខ្ពស់ ២ ពួក** នោះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ។ ចំណែកព្រះអរិយៈក្រៅអំពីនេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ដូច្នោះ ទើបព្រះអរិយៈជាន់ខ្ពស់ ២ ពួកប៉ុណ្ណោះ ចូលសមាបត្តិបាន ។ អធិប្បាយថា វៀរចាកការធ្វើសមាធិឲ្យបរិបូណ៌ចេញ ការប្រើប្រាស់សមាបត្តិមិនមាន ។ បទថា **តំ យោគ សមាធិស្មឹ បរិបូរីការិនោតិ តេហិ វុត្តការណំ** ប្រែថា ហេតុដែលកេចិអាចារ្យទាំងនោះពោលថា **ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសមាធិនោះ** ។ ពាក្យថា **មិនជាហេតុឡើយ** គឺមិនគួរឡើយ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ? ឆ្លើយថា លោកអាចារ្យពោលពាក្យថា **សូម្បីបុថុជ្ជន** ដូច្នេះជាដើម ។ អត្ថនៃពាក្យនោះ ថា

សូម្បីបុថុជ្ជនដែលមានកិលេស មិនទាន់កាត់បានជាសមុច្ឆេទ ដោយប្រការទាំងពួង ក៏គង់ចូលលោកិយសមាធិ ដែលខ្លួនបានចំពោះហើយ នឹងពោលទៅថ្វីដល់ព្រះអរិយៈទាំងឡាយជាន់ទាបៗ បុគ្គលមានកិលេសចំណែកខ្លះ ដែលកាត់បានសមុច្ឆេទហើយសោត ព្រោះហេតុនោះ បុគ្គលមិនធ្វើឲ្យបរិបូណ៌ក្នុងសមាធិរបស់ព្រះអរិយៈជាន់ទាបទាំងនោះ ទើបមិនមែនហេតុ នៃការមិនចូលផលសមាបត្តិរបស់ខ្លួន ។ ធម្មតាថា ការគិតសេចក្តីសមគួរប្រកបក្នុងអត្ថ ដែលមិនបានឡើងកាន់ព្រះបាលី តែសេចក្តីនេះ ជាប្រការដែលឡើងកាន់ព្រះបាលី ព្រោះហេតុនោះ លោកអាចារ្យកាលសម្តែង

ព្រះបាលី ដោយមាតិកា គឺការធ្វើការមិនអើពើក្នុងការអោងដល់ហេតុ ទើបពោលពាក្យថា **កិញ្ចត្ថ** ជាដើម ។ ពាក្យថា **ដើម្បីប្រយោជន៍ដល់ការបានសោតាបត្តិមគ្គ** គឺ ដើម្បីការសម្រេចសោតាបត្តិមគ្គ ។ បទថា **សោតាបត្តិផលសមាបត្តត្ថាយ** ប្រែថា ដើម្បីប្រយោជន៍ដល់ការចូលសោតាបត្តិផលសមាបត្តិ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។

ក្នុងអធិការនេះ ព្រោះលោកលើកទុកដោយសរុប ដោយពាក្យជាដើមថា ដើម្បីប្រយោជន៍ដល់ការចូលសុញ្ញតវិហារសមាបត្តិ ដើម្បីប្រយោជន៍ដល់ការចូលអនិមិត្តវិហារសមាបត្តិ ទើបលោកពោលវារៈថា ដោយមគ្គ និងផលដែលមកមុនអំពីនោះ ដោយអំណាចអប្បណិហិត ។ ក្នុងធម៌ទាំងនោះ គោត្រភូធម៌ដែលជា **បុរេចរ** របស់ផលសមាបត្តិដែលប្រព្រឹត្តទៅ ដោយមាតិកាអនត្តានុបស្សនា និងមាតិកាអនិច្ចានុ-បស្សនា គប្បីជ្រាបថា លោកពោលទុកជា ៩ មាតិកា ជា ១០ មាតិកា ។ តែដោយពាក្យថា ដើម្បីប្រយោជន៍ដល់ការចូលសោតាបត្តិផលសមាបត្តិ ដូច្នេះជាដើម រមែងដឹងបានថា សូម្បីព្រះសោតាបន្ន និងព្រះសកទាគាមី ក៏រមែងចូលផលសមាបត្តិរបស់ខ្លួន ព្រោះទេសនាមកហើយដូចគ្នាក្នុងផលទាំង៤ ។ ឯសេចក្តីនោះ លោកពោលដោយអំណាចផលក្នុងលំដាប់របស់មគ្គ ព្រោះហេតុនោះ ទើបមិនអាចនឹងពោលបានព្រោះទេសនាផ្តើមដោយអំណាចការឃើញរបស់គោត្រភូធម៌ទាំង ១០ ដោយអំណាចវិបស្សនា និងព្រោះប្រយោជន៍នោះសម្រេចដោយវារៈនៃមគ្គនោះឯង ។ ផលក្នុងលំដាប់នៃមគ្គ ហៅថា **ផលសមាបត្តិ** ក៏ទេ ព្រោះមិនមានបរិកម្មមួយផ្នែក ។ ព្រោះហេតុនោះការចូលផលសមាបត្តិរបស់ព្រះអរិយៈ មានព្រះសោតាបន្នជាដើមក៏សម្រេច ដោយពាក្យថា ផលសមាបត្តិតែម្យ៉ាង ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **ព្រោះហេតុនោះ** ដូច្នេះជាដើម ។

ប្រយោជន៍ក៏ជាហេតុ នៃការបដិបត្តិដើម្បីប្រយោជន៍ដល់ការចូលផលសមាបត្តិនោះ ព្រោះព្រះអរិយៈបដិបត្តិហេតុ មានផលសមាបត្តិនោះជានិមិត្ត ព្រោះហេតុនោះ ទើបលោកអាចារ្យសួរហេតុថា **ចូលដើម្បីអ្វី ហើយវិសជ្ជនាប្រយោជន៍ ថា ដើម្បីទិដ្ឋធម្មសុខវិហារ** ។ ម្យ៉ាងទៀត បទថា **កស្មា** ជាបញ្ចមីវិភត្តិ ចុះក្នុងសម្បទាន ។ មានអធិប្បាយថា ដើម្បីអ្វី ។ ពាក្យថា **ដើម្បីទិដ្ឋធម្មសុខវិហារ** សេចក្តីថា ដើម្បីនៅជាសុខដ៏ស្ងប់ នូវគ្រឿងចូលទៅស្ងប់សេចក្តីក្រវល់ក្រវាយ និងការក្តៅក្រហាយ គឺកិលេសក្នុងទិដ្ឋធម៌ ។ ធម៌ គឺផលសមាបត្តិទាំងឡាយ មានការប្រព្រឹត្តទៅ ដោយអំណាចការពេញចិត្តរបស់ព្រះអរិយៈនោះ នុ៎ះឯង ព្រោះកាលមានភាពជាវិបាក វៀរចាកការបរិកម្មចោល ក៏មិនកើតឡើង ទាំងនេះ ព្រោះធម៌ គឺផលសមាបត្តិទាំងនោះ មានភាពជាអធិបតី ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រះអរិយៈទាំងឡាយ ធ្វើការកំណត់កាលហើយ ទើបចូលផលសមាបត្តិ** ដូច្នេះ ។

ពាក្យថា **ខាងដើមការចូលផលសមាបត្តិ មានដោយអាការ ២** គឺដោយហេតុ ២ យ៉ាង ។ ប្រៀបដូចជាការសម្រេចលោកិយជ្ឈានទាំងឡាយ ដែលសម្រេចដោយព្រះយោគី ជាអ្នកមានការដល់ព្រមដោយសម្បយោគ លោកក៏ហៅដោយមាតិកា គឺការឈានកន្លងអង្គមួយ ព្រោះជាធម៌ដែលគប្បីសម្រេច ដោយអាការយ៉ាងនោះ យ៉ាងណា សូម្បីការចូលផលសមាបត្តិ ក៏យ៉ាងនោះ សម្រេចដោយការធ្វើមនសិការនិព្វាន ក៏ហៅដោយមាតិកា គឺការមិនធ្វើមនសិការអារម្មណ៍ដទៃក្រៅអំពីនិព្វាននោះ ព្រោះសម្រេចដោយអំណាចដែលព្រះយោគីជាអ្នកដកទៅអំពីសង្ខារទាំងពួង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **អំពីព្រះនិព្វាន** ជាដើម ។ ពិតហើយ ផលចិត្ត ដែលមានព្រះនិព្វាន ដែលរលាស់ចេញចាកសង្ខារទាំងពួងនោះជាអារម្មណ៍ រមែងប្រព្រឹត្តទៅដល់បុគ្គលដែលមានចិត្តនឿយណាយធ្លាយតម្រេក ដោយប្រការទាំងពួងអំពីសង្ខារទាំង

ពួង ដោយអំណាចការបន្តគ្នានៃញាណ មានឧទយព្វយញ្ញាណជាដើម ។ ឯផលចិត្ត នោះដែលប្រព្រឹត្តទៅយ៉ាងនេះ លោកពោលថា រមែងប្រព្រឹត្តទៅ **ព្រោះមិនធ្វើមនសិការដល់អារម្មណ៍ដទៃក្រៅអំពីព្រះនិព្វាន ១ និងព្រោះធ្វើមនសិការតែព្រះនិព្វាន ១** ។

ពាក្យថា **អនិមិត្តាចេតោវិមុត្តិ** គឺបានដល់ ផលសមាបត្តិ គឺអនិមិត្តវិមោក្ខទាំង ២ ឬបានដល់ ផលសមាបត្តិដែលគប្បីចូលដោយមាតិកា គឺអនិច្ចានុបស្សនា ។ បទថា **សមាបត្តិយា** ប្រែថា ដើម្បីប្រយោជន៍ដល់ការចូល ។ ពាក្យថា **និមិត្តទាំងពួង** បានដល់ សង្ខារនិមិត្តទាំងពួង មានរូបជាដើម ។ ពាក្យថា **មិនធ្វើមនសិការ** គឺមិននឹកដល់ ព្រោះជាអ្នកឃើញជាទោស ហើយលែងទៅ បានដល់ ការមិនដាក់ចិត្ត ។ ពាក្យថា **មនសិការដល់ធាតុដែលមិនមាននិមិត្ត** បានដល់ ការធ្វើទុកក្នុងចិត្តដោយមនសិការ ដែលកើតព្រមជាមួយផលសមាបត្តិនូវធាតុ ដែលឈ្មោះថា មិនមាននិមិត្ត ព្រោះការមិនមានសង្ខារនិមិត្តទាំងពួង ។ និងនូវធាតុដែលជាអសង្ខតៈ ដែលបានឈ្មោះថា អសង្ខតៈ ព្រោះមិនបានត្រូវបច្ច័យពួកខ្លះតាក់តែង ឬបានដល់ការធ្វើមនសិការនូវធាតុនោះ ក្នុងចំណែកនៃចិត្ត ដែលជាផលសមាបត្តិ ។

ពាក្យថា **ដោយអំណាចញាណ មានឧទយព្វយញ្ញាណជាដើម** លោកអាចារ្យរមែងពោលដល់កិច្ចរបស់ញាណទាំង ៩ ដែលប្រព្រឹត្តទៅ ដោយអំណាចឧទយព្វយ-ញ្ញាណ ភង្គញ្ញាណ និងភយតុបដ្ឋានញ្ញាណជាដើម ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **របស់ព្រះអរិយសាវ័ក ដែលមានវិបស្សនាញាណតាមលំដាប់ប្រព្រឹត្តទៅហើយ** ។ ពាក្យថា **ក្នុងលំដាប់នៃគោត្រភូញាណ ដែលមានសង្ខារជាអារម្មណ៍** គឺក្នុងលំដាប់នៃគោត្រភូញាណ ដែលបានឈ្មោះថា **វោទាន** ដែលមានសង្ខារជាអារម្មណ៍ ។ សួរថា ព្រោះហេតុអ្វី គោត្រភូញាណក្នុងផលធម៌ទាំងនេះ ទើបមិនបានមានព្រះនិព្វានជាអារម្មណ៍ដូចជាបុរេចារិករបស់មគ្គញ្ញាណទៅវិញ ? ឆ្លើយថា

ព្រោះផលធម៌ទាំងឡាយ មិនមែនជានិយ្យានិកធម៌ ។ ពិតហើយ ធម៌ គឺអរិយមគ្គប៉ុណ្ណោះ ជានិយ្យានិកធម៌ ។ សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកដូច្នេះថា ធម៌ជានិយ្យានិកដូចម្តេច ? មគ្គ ៤ ដែលជាលោកុត្តរ ដូច្នេះ ។ ព្រោះហេតុនោះ ញាណដែលជាអនន្តរប្បច្ច័យដល់មគ្គញាណ ដែលប្រព្រឹត្តទៅជាធម៌ ចេញទៅអំពីចំណែកទាំងពីរនៃធម៌ ដែលមានភាពជានិយ្យានិកធម៌ ជាសភាវៈដោយចំណែកមួយ ទើបគប្បីជាធម្មជាតិចេញទៅអំពីនិមិត្តនោះឯង ព្រោះហេតុនោះ ញាណដែលជាអនន្តរប្បច្ច័យនៃមគ្គញាណនោះ មានព្រះនិព្វានជាអារម្មណ៍ ទើបត្រឹមត្រូវហើយ តែញាណដែលជាបុរេចារិករបស់ផលញាណ ដែលមានសភាវៈមិនចេញទៅ ព្រោះមិនមែនជានិយ្យានិកធម៌ ព្រោះមិនកាត់កិលេសទាំងឡាយ ដែលប្រព្រឹត្តទៅជាវិបាករបស់អរិយមគ្គនោះ ព្រោះធ្វើអរិយមគ្គឲ្យកើតហើយ និងមានព្រះនិព្វានជាអារម្មណ៍ សូម្បីក្នុងកាលខ្លះ ក៏មិនត្រឹមត្រូវ ព្រោះអនុលោមញាណក្នុងធម៌ទាំង ២ យ៉ាង មានអាការមិនស្មើគ្នា ។ ពិតហើយ អនុលោមញាណក្នុងវិថីនៃអរិយមគ្គ ដែលដល់នូវភាពជាបារមីដ៏កំពូល ក្នុងលោកិយញ្ញាណទាំងឡាយ ព្រោះទម្លាយបានដោយសមុច្ឆេទនូវគំនរកិលេស មានគំនរលោភៈជាដើម ដែលគ្រោតគ្រាត ដែលមិនធ្លាប់ត្រូវទម្លាយមកអំពីមុន ក៏រមែងកើតឡើងសមគួរដល់មគ្គញាណ ។ តែអនុលោមញាណទាំងនោះ ក្នុងវិថីនៃផលសមាបត្តិ ក៏មិនមានការខ្វល់ខ្វាយក្នុងការសង្កត់កិលេស ក្នុងផលសមាបត្តិនោះ ព្រោះកិលេសទាំងនោះ ដែលមគ្គនោះៗ កាត់បានជាសមុច្ឆេទហើយ ទើបកើតឡើង ត្រឹមតែជាបរិកម្មនៃធម៌ ដែលមានការជឹងព្រមដោយសេចក្តីសុខក្នុងផលសមាបត្តិរបស់ព្រះអរិយៈទាំងឡាយតែម្យ៉ាង ព្រោះហេតុនោះ អនុលោមញាណក្នុងផលសមាបត្តិទាំងនោះ ទើបមិនមានការចេញទៅអំពីទីណាមួយ ទាំងនេះ ព្រោះញាណដែលជាទីបំផុតរបស់ញាណទាំងនោះ ឈ្មោះថា គប្បីមានព្រះនិព្វានជាអារម្មណ៍

ក៏ព្រោះចេញទៅអំពីសង្ខារនិមិត្ត ។

និងព្រោះធ្វើអធិប្បាយយ៉ាងនេះ ពាក្យក្នុងអដ្ឋកថាថា កាលព្រះសេក្ខៈពិចារណាសង្ខារទាំងឡាយ ដោយអំណាចឧទយព្វយញ្ញាណជាដើម ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ផលសមាបត្តិរបស់ខ្លួន ផលប៉ុណ្ណោះ រមែងកើតឡើង តាមលំដាប់នៃវិបស្សនាញាណ មគ្គមិនកើតឡើងឡើយ ដូច្នេះ រមែងជាពាក្យដែលមានការយល់បាន ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ផលប៉ុណ្ណោះ រមែងកើតឡើងដល់ព្រះសេក្ខៈ មគ្គមិនកើតឡើងឡើយ** ដូច្នេះ ការប្រព្រឹត្តទៅ គឺការចូលនៃផលចិត្តនោះឯង មិនមានចន្លោះអស់កាលតាមដែលកំណត់ ដោយអំណាចអប្បនាឈានក្នុងអារម្មណ៍ គឺនិព្វាន ឈ្មោះថា ផលសមាបត្តិ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ចិត្តរមែងចុះស៊ប់នៅក្នុងនិរោធ ដោយអំណាចផលសមាបត្តិ** ។ លោកអាចារ្យពោលពាក្យថា **ព្រោះព្រះអរិយសាវកនោះ បង្អោនចិត្តទៅក្នុងផលសមាបត្តិ** ដូច្នេះជាដើម សំដៅដល់ការសោកសួរថា បើការចូលផលសមាបត្តិដោយអំណាចវិបស្សនា ដោយលំដាប់សោត សូម្បីមគ្គខាងលើរបស់ព្រះសេក្ខៈ ក៏គប្បីមានដោយទំនងនោះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា ការប្រព្រឹត្តទៅរបស់វិបស្សនា ដែលនាំអរិយមគ្គមកម្យ៉ាង ដែលនាំផលសមាបត្តិមកម្យ៉ាងនោះឯង ការបែកវិបស្សនានេះ លោកអាចារ្យបានពោល ហើយនោះឯង ។

លោកអាចារ្យពោលសំដៅយកអាចារ្យក្នុងអភយគិរីវិហារថា **យេ បន** ។ ព្រោះអាចារ្យក្នុងអភយគិរីវិហារទាំងនោះ ពោលវិបស្សនាក្នុងមគ្គ និងផល លាយឡំគ្នាស្មុគស្មាញទៅ ។ ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលពាក្យថា **កាលបើយ៉ាងនោះ** ដូច្នេះជាដើម ។ **ព្រះអរហន្ត ក៏នឹងទៅជាព្រះបច្ចេកពុទ្ធ** អធិប្បាយថា បើវិបស្សនាសូម្បីក្នុងបុគ្គលក្រៅអំពីនេះ ក៏គប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍ជាព្រះបច្ចេកពុទ្ធ និង

ព្រះសម្ពុទ្ធនោះបាន ។ ពាក្យថា **ម្យ៉ាងទៀត ពាក្យរបស់អាចារ្យទាំងនោះ ត្រូវបដិសេធដោយអំណាចព្រះបាលី** សេចក្ដីថា ពាក្យរបស់អាចារ្យទាំងនោះ ត្រូវបដិសេធដោយអំណាចព្រះបាលីដែលប្រព្រឹត្តទៅ ដោយចែកវិបស្សនាសម្រាប់បុគ្គលដែលនៅក្នុងមគ្គ សម្រាប់បុគ្គលដែលនៅក្នុងផល ជាម្នាក់មួយចំណែកថា គោត្រភូធម៌ ១០ រមែងកើតឡើងដោយអំណាចវិបស្សនា ព្រោះហេតុនោះ ទើបមិនគួរកាន់យក កាលកាន់យកអត្ថដោយប្រការដទៃ ពាក្យថា **គោត្រភូធម៌ ១០** ក៏គប្បីខុសទៅ ។ ពាក្យថា **ក៏គួរកាន់យកពាក្យនេះប៉ុណ្ណោះ** ជាពាក្យចុងក្រោយនៃអត្ថដែលពោលហើយនោះឯង ។ បទថា **ផលញ្ចស្ស** ជាដើម ជាពាក្យសម្ដែងលោកុត្តរវិបាកទាំងឡាយ ជាសភាវៈដែលគប្បីឃើញជានិច្ច ដោយកុសល ដូចគ្នានឹងមហគ្គតវិបាកទាំងឡាយ ។ គប្បីជ្រាបថា ក្នុងអធិការនេះ លោកសម្ដែងសភាវៈដែលគប្បីឃើញស្មើគ្នា សូម្បីដោយពោជ្ឈង្គ និងអង្គមគ្គ ដោយការសម្ដែងសភាវៈដែលគប្បីឃើញស្មើគ្នាដោយឈាន ។

ពាក្យថា **នៃការស្ថិតនៅ** គឺរបស់ការស្ថិតនៅដោយបន្តគ្នា ។ ឯការតាំងចុះដោយអំណាចការបន្តជាប់គ្នានៃសមាបត្តិ អស់កាលតាមដែលកំណត់ទុក ឈ្មោះថា **ការស្ថិតនៅ** ក្នុងទីនេះ ។ ការចូលសមាបត្តិ គឺការប្រុងប្រៀបចិត្តទុកមុន ដោយអំណាចការកាន់យកកំណត់ពេលទុកថា កាលព្រះចន្ទ ឬព្រះអាទិត្យដល់ទីត្រឹមនេះ អាត្មាអញនឹងចេញ ដូច្នេះ ឈ្មោះថា **ការប្រុងប្រៀប** ។

ពាក្យថា **និមិត្តទាំងអស់នេះ** សេចក្ដីថា ព្រះយោគាវចរមិនបានធ្វើមនសិការនិមិត្តទាំងឡាយ មានរូបនិមិត្តជាដើម ទាំងអស់នេះព្រមគ្នា ព្រោះមិនមានដោយពិត ។ ពាក្យថា **ដោយអំណាចសព្វសង្គាហិកន័យ** សេចក្ដីថា ដោយអំណាចការកំណត់កាន់យកមិនមានចំណែកដ៏សេសសល់ ។ ពិតហើយ សព្វដែលសម្រេចដោយការសង្គ្រោះ ក៏រមែងប្រព្រឹត្តទៅក្នុងការបន្ថយទាំងឡាយបាន និងការសង្គ្រោះវិញ ក៏រមែង

មិនបានដោយការបន្ទុយ និងការបន្ថែមវិសេស ព្រោះហេតុនោះ កិច្ចសូម្បីនៅក្នុងការបន្ទុយ លោកក៏ពោលទុកដោយអំណាចការសង្គ្រោះ ។ ពាក្យថា **ព្រោះដូច្នោះ** សេចក្តីថា ព្រោះមិនមានការធ្វើមនសិការរួមគ្នានូវសង្ខារនិមិត្តទាំងពួង ព្រោះកាលភវង្គចិត្តកើតឡើងហើយ ព្រះយោគាវចររមែងឈ្មោះថា ផលសមាបត្តិ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **និមិត្តណាជាអារម្មណ៍នៃភវង្គបាន** ដូច្នេះជាដើម ។ **ដែលឈ្មោះថា អារម្មណ៍របស់ភវង្គ** បានដល់ ធម្មជាតិ មានកម្មជាដើម ។ ពាក្យថា **កាលធ្វើមនសិការ** គឺកាលធ្វើមនសិការ ដោយការធ្វើមនសិការដែលសហគតៈដោយភវង្គ ឬកាលមនសិការអារម្មណ៍នោះឲ្យជាភវង្គ ។

**ផលនោះឯងរមែងមានក្នុងលំដាប់** គឺផលក្រោយៗ រមែងមានក្នុងលំដាប់នៃផលមុនៗ ។ ឬភវង្គរមែងមានក្នុងលំដាប់នៃផលចុងក្រោយ ។ **ក្នុងលំដាប់នៃផល** គឺក្នុងមគ្គវិថី និងក្នុងផលសមាបត្តិ ។ ពាក្យថា **ចេញចាកនិរោធ រមែងមានដោយផលឯណា** នេះ លោកអាចារ្យពោលទុក ព្រោះជាការចេញចាកនិរោធ ដោយការកើតនៃផល ។ ពាក្យថា **ផលនោះ** បានដល់ អនាគាមិផល ឬអរហត្តផល ដែលលោកពោលទុកដោយការចេញចាកនិរោធ ។ ពាក្យថា **ក្នុងលំដាប់នៃនេវសញ្ញានាសញ្ញាយតនៈ** បានដល់ ក្នុងលំដាប់នៃនេវសញ្ញានាសញ្ញាយតនៈដែលជាកុសល ឬជាកិរិយា ព្រោះសូម្បីកាលមានការកន្លង ៧ ថ្ងៃទៅ ក៏មិនត្រូវអ្វីរាំងដោយការផ្សេងជាតិគ្នា ។

ពាក្យថា **មានការក្តៅក្រហាយដែលរម្ងាប់ហើយ** គឺមានការក្តៅក្រហាយ គឺកិលេសដែលរម្ងាប់ហើយ ដោយប្រការទាំងពួង ។ បទថា **អមតារម្មណំ** ប្រែថា មាននិព្វានជាអារម្មណ៍ ។ បទថា **សុភំ** សេចក្តីថា ឈ្មោះថា ស្អាត ព្រោះមិនមានកិលេស ព្រោះកិលេសជាវត្ថុមិនស្អាត ។ លោកាមិស ពោល គឺតណ្ហា ដែលផលខ្ជាក់ចោលហើយ គឺលោះចោលហើយ ហេតុនោះ ផលនោះ ឈ្មោះថា **វន្តលោ-**

**កាមិសំ** មានលោកាមិសខ្ជាក់ចោលហើយ ។ ឈ្មោះថា **ស្ងប់** ព្រោះមានសង្កិលេសដែលចូលទៅស្ងប់ហើយ និងព្រោះជាធម្មជាតិដែលស្ងប់ល្អហើយ ។ បុគ្គលឈ្មោះថាជាសមណៈ ព្រោះប្រកបដោយធម៌ណា ផលនៃភាពជាសមណៈ ពោល គឺអរិយមគ្គនោះ ហេតុនោះ ឈ្មោះថា **សាមញ្ញផល** ។ ពាក្យថា **មានឱជៈ** គឺដឹងព្រមហើយដោយសភាវៈ ។ ពាក្យថា **ស្អាត** គឺបរិសុទ្ធ ព្រោះវៀរចាកការស្មោកគ្រោក គឺកិលេស ។ ពាក្យថា **ដោយសេចក្ដីសុខ** គឺដោយសុខដ៏កំពូល ។ ពាក្យថា **ជ្រួតជ្រាប** គឺមានជ័រប្រាសចាកសេចក្ដីសៅហ្មងដោយប្រការទាំងពួង ។ ពាក្យថា **ផ្អែមត្រជាក់ក្រៃលែងជាងគ្រឿងផ្អែម** សេចក្ដីថា ផ្អែម គឺឆ្ងាញ់ហួសពណ៌នា ព្រោះជាការផ្អែមរបស់មហគ្គតៈ និងព្រោះជាការផ្អែមនៃលោកុត្តរ ។ ពិតហើយ សុខដែលកើតអំពីផលប្រណីតក្រៃលែងជាងសុខដែលកើតអំពីមគ្គ ព្រោះជាធម្មជាតិស្ងប់ក្រៃលែង ។ រីករាយហើយ **ដោយអមតៈ** ។ ដោយពាក្យថា **ប្រៀបដូចទឹកឃ្មុំ** នេះ លោកអាចារ្យរមែងធ្វើឲ្យជាក់ច្បាស់ភាពជាផល ដែលផ្អែមក្រៃលែងជាងទឹកផ្អែមនោះឯង ។

ពាក្យប្រកបថា បណ្ឌិតញ៉ាំងបញ្ញាឲ្យកើតហើយ រមែងជួប គឺបានចំពោះនូវសុខនោះ ដែលជារសរបស់ផលដែលជាអរិយៈនោះ ។

# វិសុទ្ធិមគ្គ

## និរោធសមាបត្តិសមាបជ្ជនសមត្ថតា

អានិសង្សប្រការថា និរោធសមាបត្តិសមាបជ្ជនសមត្ថតា សេចក្តីថា ម្យ៉ាងទៀត មិនមែនគ្រាន់តែការបានសោយរសនៃអរិយផលប៉ុណ្ណោះទេ តែជាអ្នកអាចក្នុងការចូលនិរោធសមាបត្តិនេះ ក៏គប្បីជ្រាបថា ជាអានិសង្សរបស់បញ្ញាភាវនានេះដែរ ។ នេះជាបញ្ហាកម្ម ដើម្បីពង្រីកសេចក្តីនិរោធសមាបត្តិ ក្នុងពាក្យថា **ភាពជាអ្នកអាចក្នុងការចូលនិរោធសមាបត្តិ** នោះ និរោធសមាបត្តិ គឺអ្វី ? បុគ្គលណា ចូលនិរោធសមាបត្តិនោះបាន បុគ្គលណាចូលមិនបាន ? ចូលបានក្នុងភពណា ចូលព្រោះអ្វី ? ម្យ៉ាងទៀត ការចូលនិរោធសមាបត្តិនោះ មានដូចម្តេច ? ស្ថិតនៅបានដូចម្តេច ? ចេញដូចម្តេច ? ចិត្តនៃបុគ្គលចេញហើយ ជាចិត្តបង្អោនទៅកាន់អ្វី ? បុគ្គលស្លាប់ និងអ្នកចូលនិរោធសមាបត្តិផ្សេងគ្នាដូចម្តេច ? និរោធសមាបត្តិជាសង្ខតៈ ឬអសង្ខតៈ ជាលោកិយ ឬលោកុត្តរ ជានិប្ផន្ន ( សម្រេច ) ឬអនិប្ផន្ន ?

## និរោធសមាបត្តិ គឺអ្វី

ក្នុងបញ្ហាកម្មទាំងនោះ បញ្ហាកម្មថា **និរោធសមាបត្តិ គឺអ្វី** ដោះស្រាយថា និរោធសមាបត្តិ គឺការមិនប្រព្រឹត្តទៅនៃចិត្តចេតសិកធម៌ទាំងឡាយ ដោយអំណាចការរលត់ទៅដោយលំដាប់ ។

## បុគ្គលណាចូលនិរោធបាន បុគ្គលណាចូលមិនបាន

បញ្ហាកម្មថា បុគ្គលពួកណាចូលនិរោធសមាបត្តិនោះបាន ពួកណាចូលមិនបាន ដោះស្រាយថា បុថុជ្ជនទាំងអស់ ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងអស់

និងព្រះអនាគាមី ព្រះអរហន្តទាំងឡាយដែលជាសុខវិបស្សកៈ ចូលមិនបាន តែព្រះអនាគាមី និងព្រះអរហន្តទាំងឡាយដែលបានសមាបត្តិ ៨ ចូលបាន ព្រោះលោកពោលទុក ( ក្នុងបដិសម្ភិទាមគ្គ ) ថា ព្រោះប្រកបដោយពលៈ ២ និងព្រោះការរម្ងាប់ទៅនៃសង្ខារ ៣ ការដឹងទូទៅក្នុង ( វសីភាវតា ) ភាពជាបុគ្គលមានអំណាចដោយញាណចរិយា ១៦ ដោយសមាធិចរិយា ៩ ជាញាណក្នុងការចូលនិរោធសមាបត្តិ ដូច្នេះ ។ ឯសម្បទា ( គឺសម្បត្តិ ) នេះ វៀរព្រះអនាគាមី និងព្រះខីណាស្រពទាំងឡាយដែលបានសមាបត្តិ ៨ ហើយ មិនមានដល់បុគ្គលដទៃឡើយ ព្រោះហេតុនោះ ព្រះអនាគាមី និងព្រះខីណាស្រពដែលបានសមាបត្តិ ៨ នោះប៉ុណ្ណោះ ទើបចូលបាន បុគ្គលដទៃចូលមិនបាន ។

មានបញ្ហាថា ក្នុងពាក្យបាលីនោះ ពលៈ ២ គឺអ្វីខ្លះ សង្ខារ ៣ គឺអ្វីខ្លះ ញាណចរិយា ១៦ គឺអ្វីខ្លះ សមាធិចរិយា ៩ គឺអ្វីខ្លះ វសីភាវតា ដូចម្តេច ? ក្នុងបញ្ហានោះ ពាក្យដោះស្រាយណា ដែលខ្ញុំត្រូវពោលមិនមានឡើយ ពាក្យដោះស្រាយទាំងអស់នេះ លោកពោលទុកក្នុងនិទ្ទេស នៃឧទ្ទេសនោះហើយ ដូចបាលីថា

## ពលៈ ២

## សមថពលៈ

ពាក្យថា **ដោយពលៈ ២** សេចក្តីថា ពលៈមាន ២ គឺសមថពលៈ វិបស្សនាពលៈ សមថពលៈដូចម្តេច ការមិនរាយមាយទៅ គឺការមានអារម្មណ៍តែមួយនៃចិត្តដោយអំណាចនេក្ខម្មៈ ឈ្មោះថា **សមថពលៈ** ការមិនរាយមាយ គឺការមានអារម្មណ៍តែមួយនៃចិត្ត ដោយអំណាចអព្យាបាទ ( វិតក្ក )... ដោយអំណាចអាលោកសញ្ញា... ដោយអំណាចការមិនរាយមាយ ។បេ។... ដោយអំណាចជាបុគ្គលពិចារណាឃើញ

រលាស់ចោល ដកដង្ហើមចូល... ដោយអំណាចបុគ្គលពិចារណាឃើញរលាស់ចោល ដកដង្ហើមចេញ ឈ្មោះថា **សមថពលៈ** ។ ក្នុងពាក្យថា **សមថពលៈ** សួរថា ឈ្មោះថា សមថពលៈ ព្រោះអត្ថដូចម្ដេច ? ឆ្លើយថា ឈ្មោះថា សមថពលៈ ព្រោះអត្ថគឺមិនញាប់ញ័រ ព្រោះនីវរណៈដោយបឋមជ្ឈាន ឈ្មោះថា សមថពលៈ ព្រោះអត្ថគឺមិនញាប់ញ័រ ព្រោះវិតក្ក វិចារៈ ដោយទុតិយជ្ឈាន ។បេ។ ឈ្មោះថា សមថពលៈ ព្រោះអត្ថគឺមិនញាប់ញ័រព្រោះអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា សមថពលៈ ព្រោះអត្ថ គឺមិនកម្រើក មិនញាប់ញ័រ មិនរង្គើ ព្រោះឧទ្ធច្ចៈ ព្រោះកិលេស ដែលសហគតៈជាមួយឧទ្ធច្ចៈ និងព្រោះខន្ធ ( ដែលសម្បយុត្តជាមួយឧទ្ធច្ចៈ ) នេះជាសមថពលៈ ។

## វិបស្សនាពលៈ

វិបស្សនាពលៈ ដូចម្ដេច ? អនិច្ចានុបស្សនា ឈ្មោះថា វិបស្សនាពលៈ ទុក្ខានុបស្សនា... អនត្តានុបស្សនា... និព្វិទានុបស្សនា... វិរាគានុបស្សនា... និរោធានុបស្សនា... បដិនិស្សគ្គានុបស្សនា ឈ្មោះថា **វិបស្សនាពលៈ** ការពិចារណាឃើញថា មិនទៀងក្នុងរូប...ពិចារណាដោយរលាស់ចោលនូវរូប ពិចារណាឃើញថា មិនទៀង...ពិចារណាដោយរលាស់ចោលក្នុងវេទនា... ក្នុងសញ្ញា... ក្នុងសង្ខារ... ក្នុងវិញ្ញាណ ។បេ។ ក្នុងចក្ខុ... ក្នុងជរាមរណៈ ឈ្មោះថា វិបស្សនាពលៈ ក្នុងពាក្យថា វិបស្សនាពលៈ ព្រោះអត្ថដូចម្ដេច ? ឆ្លើយថា ឈ្មោះថា វិបស្សនាពលៈ ព្រោះអត្ថ គឺមិនញាប់ញ័រ ព្រោះនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ឈ្មោះថា វិបស្សនាពលៈ ព្រោះអត្ថ គឺមិនញាប់ញ័រ ព្រោះសុខសញ្ញា ដោយទុក្ខានុបស្សនា... ព្រោះអត្ថ គឺមិនញាប់ញ័រ ព្រោះអត្តសញ្ញា ដោយអនត្តានុបស្សនា... ព្រោះអត្ថ គឺមិនញាប់ញ័រ ព្រោះនន្ទិ ដោយ

និព្វិទានុបស្សនា... ព្រោះអត្ថ គឺមិនញាប់ញ័រ ព្រោះរាគៈ ដោយវិរាគានុបស្សនា... ព្រោះអត្ថ គឺមិនញាប់ញ័រ ព្រោះសមុទយៈ ដោយនិរោធានុបស្សនា... ព្រោះអត្ថ គឺមិនញាប់ញ័រ ព្រោះអាទាន ដោយបដិនិស្សគ្គានុបស្សនា ឈ្មោះថា វិបស្សនាពលៈ ព្រោះអត្ថ គឺមិនកម្រើក មិនញ័រ មិនរង្គើទៅ ព្រោះអវិជ្ជា ព្រោះកិលេសដែលសហគតៈជាមួយអវិជ្ជា និងព្រោះខន្ធ (ដែលសម្បយុត្តជាមួយអវិជ្ជា) នេះជាវិបស្សនាពលៈ ។

## ការរម្ងាប់នៃសង្ខារ ៣

ក្នុងពាក្យថា និងព្រោះការរម្ងាប់ទៅនៃសង្ខារ ៣ សួរថា ព្រោះការរម្ងាប់ទៅនៃសង្ខារ ៣ ពួកណា ? ឆ្លើយថា វចីសង្ខារ គឺវិតក្ក វិចារៈ របស់បុគ្គលចូលទុតិយជ្ឈាន រមែងរម្ងាប់ កាយសង្ខារ គឺខ្យល់ដង្ហើមចេញចូលរបស់អ្នកចូលចតុត្ថជ្ឈាន រមែងរម្ងាប់ចិត្តសង្ខារ គឺសញ្ញា និងវេទនារបស់អ្នកចូលសញ្ញាវេទយិតនិរោធ រមែងរម្ងាប់ ព្រោះការរម្ងាប់ទៅនៃសង្ខារទាំង ៣ នេះ ។

## ញាណចរិយា ១៦

ក្នុងពាក្យថា ដោយញាណចរិយា ១៦ សួរថា ដោយញាណចរិយាពួកណា ? ឆ្លើយថា អនិច្ចានុបស្សនា ឈ្មោះថា ញាណចរិយា ទុក្ខានុបស្សនា... អនត្តានុបស្សនា... និព្វិទានុបស្សនា... វិរាគានុបស្សនា... និរោធានុបស្សនា... បដិនិស្សគ្គានុបស្សនា... វិវដ្ដានុបស្សនា ឈ្មោះថា ញាណចរិយា សោតាបត្តិមគ្គ ឈ្មោះថា ញាណចរិយា សោតាបត្តិផលសមាបត្តិ ឈ្មោះថា ញាណចរិយា សកទាគាមិមគ្គ... សកទាគាមិផលសមាបត្តិ... អនាគាមិមគ្គ... អនាគាមិផលសមាបត្តិ... អរហត្តមគ្គ... អរហត្តផលសមាបត្តិ ឈ្មោះថា ញាណចរិយា ដោយញាណចរិយាទាំង ១៦ នេះ ។

## សមាធិចរិយា ៩

ក្នុងពាក្យថា ដោយសមាធិចរិយា ៩ សួរថា ដោយសមាធិចរិយា ៩ ពួកណា ? ឆ្លើយថា បឋមជ្ឈាន ឈ្មោះថា សមាធិចរិយា ទុតិយជ្ឈាន ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា សមាធិចរិយា ( រួមជា ៨ ) វិតក្កក្តី វិចារៈក្តី បីតិក្តី សុខក្តី ចិត្តេកគ្គតាក្តី ដើម្បីប្រយោជន៍ដល់ការបានបឋមជ្ឈាន ។បេ។ វិតក្កក្តី វិចារៈ បីតិក្តី សុខក្តី ចិត្តេកគ្គតាក្តី ដើម្បីប្រយោជន៍ដល់ការបាននេវសញ្ញានាសញ្ញាយតន សមាបត្តិ ( មួយទៀត ) ដោយសមាធិចរិយាទាំង ៩ នេះ ។

## វសី ៥

ពាក្យថា វសី សេចក្តីថា វសីមាន ៥ គឺអាវជ្ជនវសី សមាបជ្ជនវសី អធិដ្ឋានវសី វុដ្ឋានវសី បច្ចវេក្ខណវសី ។

នឹកទាញយកបឋមជ្ឈានបាន ក្នុងទីដែលត្រូវការតាមដែលត្រូវការត្រឹមប៉ុនដែលត្រូវការ ការយឺតយូរក្នុងការនឹករាវរកមិនមាន ហេតុនេះ ទើបឈ្មោះថា អាវជ្ជនវសី ។

ចូលបឋមជ្ឈានបានក្នុងទីដែលត្រូវការ តាមដែលត្រូវការ ត្រឹមវេលាដែលត្រូវការការយឺតយូរក្នុងការចូលមិនមាន ហេតុនេះ ទើបឈ្មោះថា សមាបជ្ជនវសី ។

កំណត់ ( បឋមជ្ឈាន ) ទុកបាន ក្នុងទីដែលត្រូវការ តាមដែលត្រូវការត្រឹមវេលាដែលត្រូវការការយឺតយូរក្នុងការស្ថិតនៅ មិនមាន ហេតុនេះ ទើបឈ្មោះថា អធិដ្ឋានវសី ។

ចេញ ( អំពីបឋមជ្ឈាន ) បានក្នុងទីដែលត្រូវការ តាមដែលត្រូវការត្រឹមវេលាដែលត្រូវការការយឺតយូរក្នុងការចេញ មិនមាន ហេតុនេះ ទើបឈ្មោះថា វុដ្ឋានវសី ។

បច្ចវេក្ខណៈ ( បឋមជ្ឈាន ) បានក្នុងទីដែលត្រូវការ តាមដែលត្រូវការ ត្រឹម

វេលាដែលត្រូវការ ការឃើតយូរក្នុងការពិចារណា មិនមាន ហេតុនេះ ទើបឈ្មោះថា បច្ចវេក្ខណវសី ។

នឹកភវេក ។បេ។ បច្ចវេក្ខណទុតិយជ្ឈាន ។បេ។ នេវសញ្ញានាសញ្ញាយតនៈ បានក្នុងទីដែលត្រូវការ តាមដែលត្រូវការ ត្រឹមវេលាដែលត្រូវការ ការឃើតយូរក្នុងការនឹកភវេក ។បេ។ ក្នុងការបច្ចវេក្ខណៈ មិនមាន ហេតុនេះ ទើបឈ្មោះថា អាវជ្ជនវសី ។បេ។ បច្ចវេក្ខណវសី ។

ឯនិទ្ទេសនៃពាក្យថា **ដោយញាណចរិយា ១៦** ក្នុងបាលីនេះ ជានិទ្ទេស យ៉ាងឧត្តម ព្រោះថា សម្រាប់ព្រះអនាគាមី វសីភាវតាបញ្ញា មានដោយញាណចរិយា ១៤ បើមានពាក្យសួរថា បើដូច្នោះ សម្រាប់ព្រះសកទាគាមី មិនមែនមានញាណចរិយា ១២ និងសម្រាប់ព្រះសោតាបន្ន មិនមែនមានញាណចរិយា ១០ ទៅហើយឬ?ដូច្នេះ គប្បីដោះស្រាយថា ( សម្រាប់ព្រះសេក្ខៈជាន់ទាប ២ ជំពូកនោះ ) វសីភាវតាបញ្ញា មិនមាន ព្រោះរាគៈដែលមានបញ្ចកាមគុណ ជាវត្ថុអន្តរាយចំពោះសមាធិ លោកលះមិនទាន់បាន ក៏ព្រោះរាគៈនោះលោកមិនទាន់លះបាន ហេតុនោះ សមថពលៈ ( របស់លោក ) ទើបមិនបរិបូណ៌ កាលសមថពលៈនោះ មិនបរិបូណ៌ហើយ ទើបលោកមិនអាចចូលនិរោធសមាបត្តិដែលត្រូវ ចូលដោយពលៈ ២ បាន ព្រោះមានកម្លាំងតិចតួច តែរាគៈនោះ ព្រះអនាគាមីលះបានហើយ ព្រោះដូច្នោះ ទើបលោកជាបុគ្គលមានពលៈបរិបូណ៌ ព្រោះជាអ្នកមាន ពលៈបរិបូណ៌ ទើបលោកអាច ( ចូលនិរោធសមាបត្តិបាន ) ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកថា នេវសញ្ញានា-សញ្ញាយតនកុសល ជាបច្ច័យដោយអនន្តរប្បច្ច័យនៃផលសមាបត្តិ ដូច្នេះ ឯពាក្យនេះព្រះមានព្រះភាគត្រាស់ក្នុងមហាបករណប្បដ្ឋាន សំដៅដល់ការចេញអំពីនិរោធនៃព្រះអនាគាមីប៉ុណ្ណោះឯង ។

## ចូលបានក្នុងភពណា

បញ្ហាកម្មថា ចូលបានក្នុងភពណា ? ឆ្លើយថា ក្នុងបញ្ចវោការភព ព្រោះអ្វី ? ព្រោះនិរោធសមាបត្តិនោះ មានការត្រូវចូលទៅតាមលំដាប់ជាសភាវៈ តែក្នុងចតុវោ-ការភព ការកើតឡើងនៃរូបសមាបត្តិ មានបឋមជ្ឈានជាដើម មិនមាន ព្រោះហេតុនោះ ទើបមិនអាចចូលក្នុងចតុវោការភពនោះបាន ដូច្នេះ ចំណែកអាចារ្យពួកខ្លះពោលថា ( ចូលមិនបាន ) ព្រោះមិនមានហទយវត្ថុ ។

## ចូលព្រោះអ្វី

បញ្ហាកម្មថា ចូលព្រោះអ្វី ? ឆ្លើយថា លោកនឿយណាយក្នុងការប្រព្រឹត្តទៅផ្សេងៗ នៃសង្ខារទាំងឡាយ ទើបចូលដោយបំណងថា អាត្មាអញនឹងជាអ្នកមិនមានចិត្ត ដល់និរោធ គឺ ( ហាក់ដូច ) និព្វានហើយ ជាសុខ ក្នុងទិដ្ឋធម៌នេះឯង ដូច្នេះ។

## ចូលដូចម្តេច

បញ្ហាកម្មថា ម្យ៉ាងទៀត ការចូលនិរោធសមាបត្តិនោះ មានបានដូចម្តេច ? ឆ្លើយថា ការចូលនិរោធសមាបត្តិនោះ រមែងមានបានដល់បុគ្គលដែលមានសេចក្តីព្យាយាម ដោយអំណាចនៃសមថៈ និងវិបស្សនា ធ្វើបុព្វកិច្ចហើយ ធ្វើនេវសញ្ញានាសញ្ញាយតនៈឲ្យរលត់ទៅ ការចូលនិរោធសមាបត្តិនោះ មានបានយ៉ាងនេះ ។

ឯសេចក្តីនេះ ជាការសង្ខេបក្នុងការចូលនិរោធសមាបត្តិនោះ គឺបុគ្គលណាព្យាយាម ដោយអំណាចសមថៈតែម្យ៉ាង បុគ្គលនោះ បានសម្រេចនេវសញ្ញានាសញ្ញាយតនសមាបត្តិ ហើយក៏ឈប់ ចំណែកបុគ្គលណា ព្យាយាមដោយអំណាចវិបស្សនាតែម្យ៉ាង បុគ្គលនោះ សម្រេចផលសមាបត្តិហើយក៏ឈប់ តែបុគ្គលណា

ព្យាយាម ដោយអំណាចសមថៈ និងវិបស្សនាទាំង ២ នោះឯង ធ្វើបុព្វកិច្ចហើយ ធ្វើនេវសញ្ញានាសញ្ញាយតនៈឲ្យរលត់ទៅ បុគ្គលនោះ រមែងចូលនិរោធសមាបត្តិនោះបាន ។

ចំណែកសេចក្តីនេះ ជាភាពពិស្តារ គឺភិក្ខុក្នុងព្រះធម្មវិន័យនេះ ប្រាថ្នាចូលនិរោធ ធ្វើភត្តកិច្ច លាងដៃ និងជើងល្អហើយ អង្គុយនាអាសនៈដែលក្រាលទុកល្អ ហើយក្នុងឱកាសដែលស្ងាត់ ពត់ភ្នែក តាំងកាយឲ្យត្រង់ តម្រង់សតិទុកចំពោះមុខ លោកចូលបឋមជ្ឈាន ចេញហើយ ( ធ្វើវិបស្សនា ) ពិចារណាសង្ខារទាំងឡាយក្នុងបឋមជ្ឈាននោះ ដោយការមិនទៀង ដោយភាពជាទុក្ខ ដោយភាពជាអនត្តា ។

## វិបស្សនា ៣

ឯវិបស្សនានោះ មាន ៣ យ៉ាង គឺសង្ខារបរិគណ្ហណកវិបស្សនា ( វិបស្សនាដែលកំណត់សង្ខារ ) ផលសមាបត្តិវិបស្សនា ( វិបស្សនាសម្រាប់ចូលផលសមាបត្តិ ) និរោធសមាបត្តិវិបស្សនា ( វិបស្សនាសម្រាប់ចូលនិរោធសមាបត្តិ ) ក្នុងវិបស្សនា ៣ នោះ សង្ខារបរិគណ្ហណកវិបស្សនាដ៏ទន់ ឬយ៉ាងខ្លាំងក្តី ក៏ស្រេចតែជាបទដ្ឋាននៃមគ្គនោះឯង ផលសមាបត្តិវិបស្សនាយ៉ាងខ្លាំងក្តី ទើបគួរ ដូចគ្នានឹងមគ្គភាវនា ចំណែកនិរោធសមាបត្តិវិបស្សនា ត្រូវតែមិនទន់ពេក មិនខ្លាំងក្លាពេក ទើបគួរ ព្រោះហេតុនោះ អ្នកចូលនិរោធសមាបត្តិនោះ ឈ្មោះថា ( ធ្វើវិបស្សនា ) ពិចារណាសង្ខារទាំងឡាយនោះ ដោយវិបស្សនាដែលមិនទន់ពេក មិនខ្លាំងពេក ។

## លំដាប់ការចូលតទៅ

លំដាប់នោះ ចូលទុតិយជ្ឈាន ចេញហើយ ( ធ្វើវិបស្សនា ) ពិចារណាសង្ខារទាំងឡាយក្នុងទុតិយជ្ឈាននោះ ដូចដែលពោលហើយនោះឯង តអំពីនោះ ចូល

តតិយជ្ឈាន ។បេ។ តអំពីនោះ ចូលវិញ្ញាណញ្ចាយតនៈ ចេញហើយ ពិចារណាសង្ខារទាំងឡាយ ក្នុងវិញ្ញាណញ្ចាយតនៈនោះ យ៉ាងនោះឯង ស្រេចហើយ ចូលអាកិញ្ចញ្ញាយតនៈ ចេញហើយ ធ្វើបុព្វកិច្ច ៤ យ៉ាង គឺ **នានាពទ្ធអវិកោបន** មិនញុំាងកស្តុដែលទាក់ទងជាមួយភិក្ខុអន្តផ្សេងឲ្យកម្រើក **សង្ឃបដិមានន** ( ទទឹង ) ការរង់ចាំនៃសង្ឃ **សត្ថុបកោសន** ( ទទឹង ) ការត្រាស់ឲ្យរកនៃព្រះសាស្តា **អទ្ធានបរិច្ឆេទ** ( ពិចារណាដល់ ) កំណត់កាលនៃជីវិត ។

## នានាពទ្ធអវិកោបន

ក្នុងបុព្វកិច្ច ៤ នោះ ពាក្យថា **នានាពទ្ធអវិកោបន** មិនញុំាងកស្តុដែលទាក់ទងដោយភិក្ខុអន្តផ្សេងឲ្យកម្រើក មានអធិប្បាយថា របស់ឯណាដែលមិនមែនជារបស់ទាក់ទងនឹងភិក្ខុនេះតែមួយ តែជារបស់ទាក់ទងជាមួយភិក្ខុអន្តផ្សេង ( ប្រើជាមួយគ្នា ) ជាបាត្រ ចីវរក្តី គ្រែ តាំងក្តី ជាកុដិក្តី ឬរបស់ជាបរិក្ខារណាមួយដទៃក្តី កស្តុនោះមិនកម្រើក គឺមិនបាត់បង់ទៅ ដោយអំណាចអន្តរាយទាំងឡាយ មានភ្លើង ទឹក ខ្យល់ចោរ និងកណ្តុរជាដើម ដោយប្រការណា ក៏គប្បីអធិដ្ឋាន ដោយប្រការនោះ នេះជាវិធីអធិដ្ឋានក្នុងសេចក្តីនោះ គឺអធិដ្ឋានថា កស្តុនេះៗ ក្នុងរយៈ ៧ ថ្ងៃនេះ ចូរកុំត្រូវភ្លើងឆេះ ចូរកុំត្រូវទឹកបន្សាត់ទៅ ចូរកុំត្រូវបំផ្លាញ ចូរកុំត្រូវចោរលួច ចូរកុំត្រូវសត្វមានកណ្តុរជាដើមកកេរឡើយ កាលអធិដ្ឋាន យ៉ាងនេះហើយ អន្តរាយណាមួយរមែងមិនមានដល់កស្តុនោះ រហូត ៧ ថ្ងៃ តែកាលមិនអធិដ្ឋាន កស្តុរមែងវិនាសបានដោយអន្តរាយទាំងឡាយ មានភ្លើងជាដើម ដូចកស្តុរបស់ព្រះមហានាគត្ថេរ ដូច្នោះ ។

មានរឿងថា ព្រះថេរៈចូលទៅកាន់ផ្ទះរបស់ឧបាសិកាដែលជាញោម ដើម្បីបិណ្ឌបាត ឧបាសិកាថ្វាយយាគូ ហើយនិមន្តឲ្យគង់ក្នុងរោងភត្ត ព្រះថេរៈគង់ចូលនិរោធ

កាលលោកគង់ហើយ ពេលអាហារភ្លើងឆេះឡើង ភិក្ខុក្រៅអំពីនោះ នាំស្រវាអាសនៈដែលខ្លួនគង់គេចទៅ ពួកអ្នកស្រុក ( មក ) ប្រជុំ ( ជួយរំលត់ភ្លើង ) ឃើញព្រះថេរៈ ( អង្គុយបិទភ្នែកព្រងើយ មិនដឹងថា លោកចូលនិរោធ ) ក៏នាំគ្នាថា លោកជាសមណៈកំជិល ( សូម្បីតែភ្លើងឆេះជុំវិញខ្លួន ក៏មិនក្រោកគេច ) ភ្លើងឆេះឈើ ស្មៅ ឬស្សី និងសសរទាំងឡាយហើយ ជុំវិញព្រះថេរៈ ( មិនធ្វើអន្តរាយដល់លោក ) មនុស្សទាំងឡាយ ( ឃើញអស្ចារ្យកើតជ្រះថ្លា ) ទើបប្រើថ្នាំងមកដួសទឹកពន្លត់ ហើយបោសរងើកភ្លើង ធ្វើជារង្វង់រោយផ្កាឈើចុះ ហើយនាំគ្នាឈរនមស្ការ ព្រះថេរៈ ( ចេញអំពីនិរោធ ) ដោយអំណាចកាល ដែលកំណត់ទុក ឃើញមនុស្សទាំងឡាយនោះក៏គិតថា អាត្មាអញជាបុគ្គល ប្រាកដហើយហ្ន៎ ទើបហោះឡើងកាន់វេហាស៍ទៅកាន់កោះដែលមានដើមប្រយង្គុ ។

( ការអធិដ្ឋាន មិនឲ្យកស្តុវិនាសក្នុងពេលចូលនិរោធ ) នេះ ឈ្មោះថា **នានា-ពទ្ធអវិកោបន** មិនញ៉ាំងកស្តុដែលទាក់ទងដោយភិក្ខុអង្គដទៃឲ្យកម្រើក ឯកស្តុណាជារបស់ទាក់ទងដោយខ្លួនលោក ជាស្បង់ ចីវរក្តី អាសនៈដែលលោកគង់ក្តី កិច្ចដែលត្រូវអធិដ្ឋានទុកជាចំណែកមួយក្នុងកស្តុនោះមិនមាន អ្នកចូលនិរោធ រមែងការពារកស្តុនោះទុកបាន ដោយអំណាចសមាបត្តិនោះឯង ដូចកស្តុរបស់ព្រះសញ្ជីវៈ ( ដែលពោលក្នុងឥទ្ធិកថា ) ពិតហើយ សូម្បីពាក្យបាលីនេះ ក៏បានពោលទុកថា ឫទ្ធិផ្សាយទៅដោយអំណាចសមាធិនៃព្រះសញ្ជីវៈឫទ្ធិផ្សាយទៅ ដោយអំណាចសមាធិរបស់ព្រះសារីបុត្រ ដូច្នេះ ។

## សង្ឃបដិមានន

ការរង់ចាំ គឺការទន្ទឹងនៃសង្ឃ ឈ្មោះថា *សង្ឃបដិមានន* ដោយអត្ថថា កាល

ដែលភិក្ខុអង្គណាមួយមិនទាន់មកត្រឹមណា ក៏មិនធ្វើសង្ឃកម្មត្រឹមនោះ ។ ក្នុងសេចក្តីនេះ ការរង់ចាំបានជាបុព្វកិច្ចនៃភិក្ខុដែលចូលនិរោធនោះក៏ទេ តែការរំពឹងដល់ការរង់ចាំនោះ ជាបុព្វកិច្ច ព្រោះដូច្នោះ ភិក្ខុដែលនឹងចូលនិរោធ គប្បីអធិដ្ឋាន យ៉ាងនេះថា បើអាត្មាអញ អង្គុយចូលនិរោធ ៧ ថ្ងៃ សង្ឃប្រាថ្នានឹងធ្វើកម្មឯណានីមួយ ក្នុងបណ្តាសង្ឃកម្ម មានញត្តិកម្មជាដើមសោត អាត្មាអញនឹងចេញ ( ភ្ញាក់ ) មិនចាំបាច់ភិក្ខុសូម្បីត្រឹមតែមួយរូបមកហៅអាត្មាអញឡើយ ព្រោះថា ធ្វើយ៉ាងនេះហើយ ទើបលោករមែងចេញបានភ្ញាក់ ក្នុងវេលានោះ ។ ចំណែកភិក្ខុណាមិនធ្វើយ៉ាងនោះ សង្ឃប្រជុំគ្នាហើយ មិនឃើញភិក្ខុនោះ សួរថា ភិក្ខុអង្គនោះទៅណា កាលភិក្ខុមួយអង្គប្រាប់ថា លោកចូលនិរោធ សង្ឃនឹងបញ្ជូនភិក្ខុមួយអង្គទៅ ដោយប្រាប់ថា អ្នកចូរទៅហៅភិក្ខុអង្គនោះតាមពាក្យរបស់សង្ឃ លុះកាលភិក្ខុនោះឈរក្នុងសវនូបចារៈ ( ទីជិតល្មមហៅឮបាន ) ហើយប្រាប់ថា **អាវុសោ សង្ឃរង់ចាំលោក** នោះឯង ទើបលោកចេញ ព្រោះឈ្មោះថា **អាណា** ( ពាក្យប្រើ ) របស់សង្ឃ រមែងជាការធ្ងន់យ៉ាងនេះ ហេតុនោះ ទើបភិក្ខុដែលចូលនិរោធគួរពិចារណាដល់ការរង់ចាំនៃសង្ឃនោះ ហើយទើបចូលដូចដែលនឹងចេញខ្លួនឯងនោះឯង ( មិនបាច់ឲ្យហៅ ) ។

## សត្ថុបក្កោសនៈ

សូម្បីក្នុងពាក្យថា **សត្ថុបក្កោសនៈ** នេះ ឯការពិចារណាដល់ការត្រាស់ឲ្យរកនៃព្រះសាស្តានោះឯង ជាបុព្វកិច្ចរបស់លោក ( ដែលចូលនិរោធ ) នេះ ព្រោះហេតុនោះ ការត្រាស់ឲ្យរកនៃព្រះសាស្តានោះ លោកក៏គួរអធិដ្ឋានយ៉ាងនេះថា បើអាត្មាអញអង្គុយចូលនិរោធ ៧ ថ្ងៃ ព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទក្នុងករណី ដែលវត្ថុធ្លាក់ចុះ ( គឺកើតរឿងឡើង ) ក្តី ទ្រង់សម្តែងធម៌ព្រោះអត្ថុប្បត្តិ ( គឺរឿងដែលកើតឡើង )

យ៉ាងនោះក្តីសោត អាត្មាអញនឹងចេញ ( ក្លាម ) មិនចាំបាច់បុគ្គលណាមកហៅអាត្មាអញឡើយ ព្រោះថា ធ្វើយ៉ាងនេះហើយ ទើបអង្គុយ ( ចូលនិរោធ ) លោករមែងចេញបានក្លាមក្នុងវេលានោះ ចំណែកភិក្ខុណា មិនធ្វើយ៉ាងនោះចំពោះព្រះសាស្តាកាលសង្ឃប្រជុំគ្នាហើយ ទ្រង់ទតមិនឃើញភិក្ខុនោះ ទ្រង់ត្រាស់សួរកថា ភិក្ខុអង្គនោះទៅណា កាលភិក្ខុមួយអង្គក្រាបទូលថា លោកចូលនិរោធ ទ្រង់ប្រាប់ភិក្ខុមួយអង្គទៅ ដោយត្រាស់ថា អ្នកចូរទៅហៅភិក្ខុនោះ តាមពាក្យរបស់តថាគត លុះកាលភិក្ខុនោះឈរក្នុងសវនូបចារៈ ហើយប្រាប់ថា ព្រះមានជោគត្រាស់ឲ្យរកលោក ទើបលោកចេញ ព្រោះការត្រាស់ឲ្យរកនៃព្រះសាស្តាជាការៈ ( គឺចាំបាច់ត្រូវគោរព ) យ៉ាងនេះ ហេតុនោះ ទើបភិក្ខុដែលចូលនិរោធគួរអធិដ្ឋានដល់ការត្រាស់ឲ្យរកនៃព្រះសាស្តានោះ ហើយទើបចូល ដូចដែលនឹងចេញបានខ្លួនឯងនោះឯង ( មិនចាំបាច់ឲ្យត្រាស់ ហៅរក ) ។

## អទ្ធានបរិច្ឆេទ

ការកំណត់កាលនៃជីវិត ឈ្មោះថា **អទ្ធានបរិច្ឆេទ** ឯភិក្ខុនេះត្រូវឈ្លាសយ៉ាងល្អក្នុងអទ្ធានបរិច្ឆេទ ត្រូវពិចារណាមើលនូវកាលវេលាថា អាយុសង្ខាររបស់ខ្លួននឹងប្រព្រឹត្តទៅ មិនប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ហើយទើបចូល ព្រោះបើពិចារណាមើលអាយុសង្ខារដែលនឹងត្រូវរលត់ក្នុងខាងក្នុង ៧ ថ្ងៃ ហើយទើបចូលសោត និរោធសមាបត្តិរបស់លោក រមែងមិនអាចការពារសេចក្តីស្លាប់បាន លោកនឹង ( ត្រូវ ) ចេញចាកសមាបត្តិក្នុងចន្លោះ ( មិនគ្រប់ ៧ ថ្ងៃ ) នោះឯង ព្រោះសេចក្តីស្លាប់ ក្នុងនិរោធមិនមាន ព្រោះហេតុនោះ ត្រូវពិចារណាមើល កំណត់កាលនៃជីវិតនោះហើយទើបចូល ព្រោះថា សូម្បីមិនពិចារណាបុព្វកិច្ចដ៏សេស ( ក្រៅអំពីនេះ ) ក៏គង់បាន

តែកំណត់កាលនៃជីវិតនេះ លោកពោលថា ត្រូវតែពិចារណានោះឯង ។

# ចូលនិរោធ

ភិក្ខុនោះ កាលចូលអាកិញ្ចញ្ញាយតនៈ ចេញហើយ ធ្វើបុព្វកិច្ចនេះយ៉ាងនេះ ហើយទើបចូលនេវសញ្ញានាសញ្ញាយតនៈ តអំពីនោះ កន្លងទៅវារៈចិត្ត ១-២ លោកក៏ជាអ្នកមិនមានចិត្ត បានសម្ផស្សនិរោធ ។

សួរថា ព្រោះហេតុអ្វី ទើបចិត្តទាំងឡាយរបស់លោកមិនប្រព្រឹត្តទៅលើចិត្ត ២ ដួង ? ឆ្លើយថា ព្រោះ ( ការប្រព្រឹត្តទៅយ៉ាងនោះ ) ជាប្រយោគនៃនិរោធ ពិតហើយ ការធ្វើធម៌ ២ យ៉ាង គឺសមថវិបស្សនាឲ្យជាយុគនទ្ធៈហើយ ឡើងកាន់សមាបត្តិ ៨ នៃភិក្ខុនេះ នេះជាបយោគនៃអនុបុព្វនិរោធ មិនមែនជាប្រយោគនៃនេវសញ្ញានាសញ្ញាយតនសមាបត្តិ ព្រោះហេតុនោះ ទើបចិត្តទាំងឡាយរបស់ភិក្ខុនោះមិនប្រព្រឹត្តទៅលើចិត្ត ២ ដួង ព្រោះ ( ការប្រព្រឹត្តទៅយ៉ាងនោះ ) ជាប្រយោគនៃនិរោធ ចំណែកភិក្ខុណាចេញអំពីអាកិញ្ចញ្ញាយតនៈហើយ មិនធ្វើបុព្វកិច្ចនេះ ចូលនេវសញ្ញានាសញ្ញាយតនៈ ភិក្ខុនោះ រមែងមិនអាចជាអ្នកមិនមានចិត្តតទៅបាន តែនឹងវិលត្រឡប់មកតាំងនៅក្នុងអាកិញ្ចញ្ញាយតនៈវិញនោះឯង ឯការឧបមាដូចបុរសដែលមិនធ្លាប់ដើរផ្លូវ គួរ ( នាំមក ) ពោលក្នុងសេចក្តីនេះ ។ ឧបមាថា បុរសម្នាក់មិនធ្លាប់ដើរផ្លូវ មកដល់ស្ទឹង ឬជុំថ្មដ៏ក្តៅ ព្រោះកម្តៅថ្ងៃខ្លាំង ដែលគេដាក់ទុកចន្លងអន្លង់ក្នុងរវាងផ្លូវ មិនទាន់បានរៀបចំសំពត់ស្លៀក សំពត់ដណ្តប់ ចុះកាន់អន្លង់នោះ ក៏រមែង ( ថយត្រឡប់មក ) ឈរត្រង់ច្រាំងនោះឯង ព្រោះខ្លាចបរិក្ខារសើម ។ ម្យ៉ាងជើងក្តៅ ព្រោះជាន់ផ្ទាំងថ្មនោះ បុរសនោះរមែង ( ថយចុះមក ) ឈរត្រង់ត្រើយអាយទៀតនោះឯង ។

ក្នុងសេចក្តីឧបមានោះ ដូចជាបុរសនោះ ព្រោះមិនទាន់បានរៀបចំសម្លៀក

បំពាក់ ( លុះចុះទឹកទៅបន្តិច ) និងលុះជាន់ផ្លាំងថ្មក្តៅ ( ទៅបន្តិច ) ប៉ុណ្ណោះ ក៏ថយត្រឡប់មកឈរត្រង់ត្រើយអាយ ( ទៀត ) នោះ យ៉ាងណា សូម្បីព្រះយោគាវចរក៏ដូច្នោះ ព្រោះមិនទាន់បានធ្វើបុព្វកិច្ច លុះចូលនៅសញ្ញានាសញ្ញាយតនៈ ( ទៅបន្តិច ) ប៉ុណ្ណោះ ក៏ថយត្រឡប់មកតាំងនៅក្នុងអាកិញ្ចញ្ញាយតនៈ ។ ចំណែកបុរសដែលធ្លាប់ដើរផ្លូវនោះ មកអំពីមុន មកដល់ទីនោះ ស្លៀកសំពត់មួយផ្លាំងឲ្យណែន កាន់សំពត់មួយផ្លាំងទៀតដោយដៃ ( ម្ខាង ) ហើយចុះទឹក ឬធ្វើការដើរជាន់ផែនថ្មក្តៅ តែល្មមប្រមាណ ( គឺជាន់ថ្មៗ ) ដើរទៅបាន យ៉ាងណា ភិក្ខុដែលធ្វើបុព្វកិច្ច ចូលនៅ-សញ្ញានាសញ្ញាយតនៈនោះឯង ទើបជាអ្នកមិនមានចិត្ត សម្មស្ស ( ដល់នូវ ) និរោធតទៅបាន ក៏ដូច្នោះដូចគ្នា ។

## ចូលហើយស្ថិតនៅបានដូចម្តេច

បញ្ហាកម្មថា ស្ថិតនៅបានដូចម្តេច ? ឆ្លើយថា ឯការស្ថិតនៅនៃនិរោធសមាបត្តិដែលចូលហើយយ៉ាងនេះ រមែងមានបានដោយអំណាចការកំណត់កាលទុក និងដោយមិនមានការអស់អាយុ ការរង់ចាំនៃសង្ឃ និងត្រាស់ឲ្យរកនៃព្រះសាស្តា ក្នុងចន្លោះផងដែរ ។

## ចេញដូចម្តេច

បញ្ហាកម្មថា ចេញដូចម្តេច ? ឆ្លើយថា ការចេញ មាន ២ បែប ដូច្នេះ គឺសម្រាប់ព្រះអនាគាមី ការចេញមានដោយការកើតឡើងនៃអនាគាមិផល ១ ខណៈ សម្រាប់ព្រះអរហន្ត ការចេញមានដោយការកើតឡើងនៃអរហត្តផល ១ ខណៈ ។

## ចិត្តរបស់លោកដែលចេញហើយបង្អោនទៅកាន់អ្វី

បញ្ហាកម្មថា ចិត្តរបស់បុគ្គលដែលចេញហើយ ជាចិត្តបង្អោនទៅកាន់អ្វី ? ឆ្លើយថា បង្អោនទៅកាន់ព្រះនិព្វាន សមដូចបាលីដែល ( ព្រះនាងធម្មទិន្នាថេរី ) ពោលទុកក្នុងចូឡវេទល្លសូត្រថា នែ អាវុសោ វិសាខ ចិត្តនៃភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធហើយ រមែងជាចិត្តបង្អោនទៅកាន់វិវេក ឈមទៅកាន់វិវេក ទេរទៅកាន់វិវេក ។

### អ្នកស្លាប់ និងបុគ្គលចូលនិរោធ ផ្សេងគ្នាដូចម្តេច

បញ្ហាកម្មថា អ្នកស្លាប់ និងបុគ្គលចូលនិរោធផ្សេងគ្នាដូចម្តេច ? សូម្បីសេចក្តីនេះ លោកក៏បានពោលទុកក្នុងសូត្រ ( ដូចគ្នានោះ ) ដូចគ្នា ដូចបាលីថា នែអាវុសោ បុគ្គលដែលធ្វើកាលកិរិយាស្លាប់ហើយនោះ កាយសង្ខារទាំងឡាយរបស់បុគ្គលនោះរលត់ទៅ វចីសង្ខារទាំងឡាយ... ចិត្តសង្ខារទាំងឡាយ ក៏រម្ងាប់រលត់ទៅ អាយុក៏អស់ ភ្លើងធាតុក៏ស្ងប់ ឥន្ទ្រិយទាំងឡាយ ក៏បែកធ្លាយ ( ចំណែក ) ភិក្ខុចូលសញ្ញាវេទយិត-និរោធនេះ កាយសង្ខារទាំងឡាយរបស់ភិក្ខុនោះរម្ងាប់ទៅ វចីសង្ខារទាំងឡាយ... ចិត្តសង្ខារទាំងឡាយ ក៏រម្ងាប់ទៅ ( ដូចគ្នា ) តែអាយុនៅមិនទាន់អស់ ភ្លើងធាតុនៅមិនទាន់អស់ ឥន្ទ្រិយទាំងឡាយ នៅមិនទាន់បែកធ្លាយ ដូច្នេះ ។

## និរោធសមាបត្តិ ជាសង្ខតៈ ឬអសង្ខតៈ ។ល។

ចំណែកក្នុងពាក្យសួរថា និរោធសមាបត្តិ ជាសង្ខតៈ ឬអសង្ខតៈ ជាដើម មិនគួរពោលឆ្លើយថា និរោធសមាបត្តិជាសង្ខតៈក្តី ថាជាអសង្ខតៈក្តី ថាជាលោកិយក្តី ថាជាលោកុត្តរក្តី ព្រោះអ្វី ? ព្រោះនិរោធសមាបត្តិនោះ មិនមានដោយសភាវៈ

ហេតុណា និរោធសមាបត្តិនោះ រាប់ថា ជាការដែលបានចូលដល់ហើយ ក៏ដោយអំណាចរបស់ព្រះអរិយបុគ្គលដែលចូល ហេតុនោះ នឹងពោលថា ជាកិរិយាសម្រេចក៏គួរ មិនមែនមិនសម្រេច ។

បណ្ឌិតទាំងឡាយ ចម្រើនអរិយប្បញ្ញាហើយ ទើបចូលសមាបត្តិដ៏ល្អិត ( សុខុម ) ដែលព្រះអរិយៈសេព ដល់នូវការរាប់ថា ជានិព្វាន ក្នុងទិដ្ឋធម្មនេះបាន ដូចពោលមកដូច្នេះ ហេតុណា ព្រោះហេតុនោះ សូម្បីការអាចចូលនិរោធសមាបត្តិនេះ ទើបលោកពោលថា ជាអានិសង្សរបស់បញ្ញាក្នុងអរិយមគ្គទាំងឡាយដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយនិរោធសមាបត្តិ

បទថា **តត្រ** សេចក្តីប៉ុនគ្នានឹង **តស្មឹ យោគ** **និរោធសមាបត្តិសមាបជ្ជនសមត្ថតាតិ សង្ខិត្តវចនេ** ប្រែថា ក្នុងពាក្យដែលបង្រួញទុកថា ភាពជាអ្នកអាចក្នុងការចូលនិរោធសមាបត្តិនោះ ។ **នេះជាបញ្ហាកម្ម** ដោយអំណាចពាក្យសរុបជាដើម ។ បទថា **កត្ថ** សេចក្តីប៉ុនគ្នានឹង **កស្មឹ យោគ ភវេ** ប្រែថា ក្នុងភពណា ។ ពាក្យថា **ដោយអំណាចការរលត់ទៅដោយលំដាប់** សេចក្តីថា ដោយអំណាចការរលត់ទៅដោយលំដាប់នៃសង្ខារទាំង ៣ ដោយមាតិកា គឺការរលត់ធម៌ ដែលជាបដិបក្ខចំពោះសមាបត្តិ ៨ នោះៗ ដែលឡើងកាន់សមាបត្តិ ៨ ប្រព្រឹត្តទៅតាមវិបស្សនា ។ សេចក្តីថា ការមិនប្រព្រឹត្តទៅនៃចិត្ត និងចេតសិកឯណាអស់ កាលតាមដែលកំណត់ នេះឈ្មោះថា **និរោធសមាបត្តិ** ។ ពាក្យថា **បុគ្គលពួកណា ចូលនិរោធសមាបត្តិនោះបាន ពួកណាចូលមិនបាន** សេចក្តីថា លោកអាចារ្យបានសួរដល់បុគ្គលដែលអាចចូលនិរោធសមាបត្តិនោះបានមុន ព្រោះជាប្រធានដោយពិតសូម្បីយ៉ាងនោះ លោកអាចារ្យកាលសម្តែងដល់បុគ្គលដែលចូលមិនបានមុន ដើម្បីវិសជ្ជនាពាក្យវិសជ្ជនាបុគ្គល ដែលអាចចូលនិរោធសមាបត្តិនោះ ក្នុងកាលខាងក្រោយព្រោះសេចក្តីសំខាន់ ទើបពោលថា **បុថុជ្ជនទាំងអស់ ។បេ។ ចូលមិនបាន** ដូច្នេះដូចជាពោលពាក្យថា **ចូរលះផ្លូវខាងឆ្វេង ចូរកាន់យកផ្លូវខាងស្តាំ** ដូច្នោះ ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ទាំងអស់** នេះ ជាពាក្យវិសេសនៈរបស់បុគ្គល ទាំង ៣ មានបុថុជ្ជនជាដើម ។ ព្រោះថា បុគ្គលទាំងនោះ សូម្បីជាបុគ្គលបានសមាបត្តិ ៨ ក៏មិនអាចចូលនិរោធបាន ព្រោះជាបុគ្គលមិនធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ដូចគ្នានឹងបុគ្គល

ដែលមិនបានសមាបត្តិ ៨ ។ ព្រោះថា បុគ្គលធ្វើឲ្យបរិបូណ៌ក្នុងសមាធិ រមែងមានបាន ដោយការកាត់នីវរណៈ មានកាមច្ឆន្ទៈជាដើមបានជាសមុច្ឆេទ មិនមែនមានដោយត្រឹមតែការសម្រេចឈានឡើយ ។ ក្នុងពីរបទថា **អនាគាមិនោ អរហន្តោ** នេះ គប្បីប្រកប **សុខវិបស្សក-ស័ព្ទ** ចូលត្រង់បទនីមួយៗ ថា **សុខវិបស្សកា ច អនាគាមិនោ សុខវិបស្សកា ច អរហន្តោ** ប្រែថា ទាំងព្រះអនាគាមី ដែលជាសុខវិបស្សកៈ និងព្រះអរហន្ត ដែលជាសុខវិបស្សកៈ ។ ឯបុគ្គលទាំង ២ ពួកនេះ សូម្បីកាលមានវិបស្សនាពលៈ ក៏ចូលនិរោធមិនបាន ព្រោះមិនមានសមាធិពលៈ ។ ក្នុងការចូលនិរោធសមាបត្តិនេះ ចាំបាច់ត្រូវតែមានសមាធិពលៈរបស់បុគ្គលដែលមានអនុបុព្វវិហារធម៌ប៉ុណ្ណោះ ។ ចំណែកបុគ្គលទាំង ៣ ខាងដើម កាលមានសមាធិពលៈ ក៏មិនអាចនឹងចូលនិរោធសមាបត្តិបាន ព្រោះមិនមានវិបស្សនាពលៈ និងព្រោះវិបស្សនាពលៈមិនគ្រប់គ្រាន់ ។ ឯវិបស្សនាពលៈនោះ មិនគ្រប់គ្រាន់ ព្រោះមិនបានពិចារណាសង្ខារទាំងឡាយ ដោយត្រឹមត្រូវ ។

ចំណែកអាចារ្យកាលពោលថា **តែព្រះអនាគាមី និងព្រះអរហន្តទាំងឡាយដែលបានសមាបត្តិ ៨ ចូលបាន** ដូច្នេះហើយ ពោលពាក្យថា **ដោយពលៈ ២** ដូច្នេះជាដើម ដើម្បីសម្តែងហេតុក្នុងការចូលនិរោធសមាបត្តិនោះ ដោយអំណាចនៃព្រះបាលីនោះឯង ។ បទថា **តយោ** ក្នុងពីរបទនេះថា **តយោ ច សង្ខារានំ** ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ សេចក្តីប៉ុនគ្នានឹង **តិណ្ណំ** ។ ពាក្យថា **ដោយញាណចរិយា** គឺដោយការប្រព្រឹត្តទៅនៃញាណ ។ បទថា **និរោធសមាបត្តិយា** សេចក្តីថា ជាញាណក្នុងការចូលនិរោធសមាបត្តិ ។ ពាក្យថា **ឯសម្បទានេះ** សេចក្តីថា សមាបត្តិដែលនាំមកនូវនិរោធសមាបត្តិ តាមដែលពោលហើយ មានការប្រកបដោយពលៈទាំង ២ ជាដើមនេះ ។ បទថា **អនាគាមិខីណាសវេ** ប្រែថា ព្រះអនាគាមី

និងព្រះទីណាស្រេចទាំងឡាយ ។

ពាក្យថា **សមថពលៈ** អធិប្បាយថា ឈ្មោះថា សមថៈ ព្រោះអត្ថថា ស្ងប់ធម៌ដែលជាសត្រូវទាំងឡាយ មានកាមច្ឆន្ទៈជាដើម សមថៈនោះឯង ឈ្មោះថា **ជាពលៈ** ដោយអត្ថថា ដែលធម៌ជាបដិបក្ខទាំងឡាយឲ្យញាប់ញ័រមិនបាន ។ ឈ្មោះថា **វិបស្សនា** ព្រោះអត្ថថា ឃើញដោយអាការផ្សេងៗ ដោយអំណាចលក្ខណៈ មានអនិច្ចលក្ខណៈជាដើម វិបស្សនានោះឯង ឈ្មោះថា **ជាពលៈ** តាមន័យដែលបានពោលហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **វិបស្សនាពលៈ** ។ ក្នុងពាក្យថា **ដោយអំណាចនៃនេក្ខម្មៈ** ជាដើម មានពាក្យប្រកបសេចក្ដីថា ការមិនរាយមាយឯណា ពោល គឺការមានអារម្មណ៍តែមួយនៃចិត្ត ដោយអំណាចនេក្ខម្មសង្កប្ប ការសង្កត់កាមច្ឆន្ទៈ ឬដោយអំណាចកុសលចិត្តុប្បាទដែលប្រព្រឹត្តទៅយ៉ាងនោះ ដែលមានអលោភៈជាប្រធាន នុ៎ះឈ្មោះថា **សមថពលៈ** ។ ការមិនរាយមាយឯណា ពោល គឺការមានអារម្មណ៍តែមួយនៃចិត្ត ដោយអំណាចអព្យាបាទវិតក្ក ដែលសង្កត់ព្យាបាទ ឬដោយអំណាចកុសលចិត្តុប្បាទ ដែលប្រព្រឹត្តទៅយ៉ាងនោះ ដែលមានអទោសៈជាប្រធាន នុ៎ះឈ្មោះថា **សមថពលៈ** ។ការមិនរាយមាយឯណា ពោល គឺការមានអារម្មណ៍តែមួយនៃចិត្ត ដោយអំណាចអាលោកសញ្ញា ដែលប្រាកដដោយការធ្វើមនសិការឲ្យជាក់ច្បាស់ ដែលសង្កត់ថីនមិទ្ធៈ នុ៎ះឈ្មោះថា **សមថពលៈ** ។ ការរាយមាយឯណា ពោល គឺការមានអារម្មណ៍តែមួយនៃចិត្ត ដោយអំណាចការមិនរាយមាយ គឺការឃុំគ្រងទុកដែលសង្កត់ឧទ្ធច្ចៈ នុ៎ះឈ្មោះថា **សមថពលៈ** ។ ការមិនរាយមាយឯណា ពោល គឺការមានអារម្មណ៍តែមួយនៃចិត្ត ដោយអំណាចនៃការពិចារណាឃើញការលះបង់ខ្យល់ដង្ហើមចេញចូល ដែលសម្រេចអានាបានស្សតិ ដែលដល់កំពូលនៃការសង្កត់មិច្ឆាវិតក្កទាំងអស់ នុ៎ះឈ្មោះថា **សមថពលៈ** ។

លោកអាចារ្យកាលសម្ដែងសមថពលៈ ដោយអំណាចឧបចារជ្ឈានយ៉ាងនេះហើយ ឥឡូវនេះ មានបំណងនឹងសម្ដែងសមថពលៈនោះ ដោយអំណាចសមាបត្តិ ៨ និងដោយការសម្រេចពលៈ ព្រោះធម៌ដែលជាបដិបក្ខទាំងឡាយគ្របសង្កត់មិនបាន ទើបពោលពាក្យថា **ដោយបឋមជ្ឈាន** ជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ព្រោះនីវរណៈ** គឺមាននីវរណៈជានិមិត្ត បានដល់ ព្រោះនីវរណៈជាបច្ច័យ បុគ្គលដែលមានការដល់ព្រមដោយឈាន ឬសមាធិដែលសម្បយុត្តដោយឈាន **រមែងមិនញាប់ញ័រ** ។ ឯសមាធិដែលសម្បយុត្តដោយឈាននោះ លោកមានបំណងយក **សមថពលៈ** ក្នុងទីនេះ ដោយពិសេស ។ ពិតហើយ ពាក្យថា **ឈ្មោះថា សមថពលៈ ដោយអត្ថដូចម្ដេច** សេចក្ដីថា លោកសួរដល់អត្ថរបស់ពលៈ ។ ពាក្យថា **ព្រោះឧទ្ធច្ចៈ** គឺមានឧទ្ធច្ចៈជានិមិត្ត ។ ពាក្យថា **ព្រោះកិលេសដែល សហគតៈជាមួយឧទ្ធច្ចៈ** គឺព្រោះកិលេសដែលមានមោហៈ និងអហិរិកៈជាដើម ដែលសម្បយុត្តជាមួយឧទ្ធច្ចៈជាហេតុ ។ ពាក្យថា **ព្រោះខន្ធ** គឺមានខន្ធ ៤ ដែលសម្បយុត្តជាមួយឧទ្ធច្ចៈជានិមិត្ត ។ បទថា **ន កម្បតិ** ជាដើម ជាវេវចនៈនៃគ្នានឹងគ្នា ។ ម្យ៉ាងទៀត **ការកម្រើក** បានដល់ការឃ្លាតចាកឋាន ។ **ការញាប់ញ័រ** បានដល់ ការវិលទៅដោយជុំវិញ **ការរង្គើ** បានដល់ ការស្ទុះទៅ ។ គប្បីប្រកបសេចក្ដីថា រមែងមិនកម្រើក **ព្រោះឧទ្ធច្ចៈ** រមែងមិនញ័រ ព្រោះកិលេស ដែលសហគតៈដោយឧទ្ធច្ចៈ ឬរមែងមិនរង្គើ ព្រោះខន្ធដែលសហគតៈដោយឧទ្ធច្ចៈ ។ ក្នុងអធិការនេះ ស័ព្ទថា **ឧទ្ធច្ច** ក៏ដើម្បីសម្ដែងការសម្រេចផល ដោយការគ្របសង្កត់ឧទ្ធច្ចៈនោះ ព្រោះជាបដិបក្ខដោយត្រង់ចំពោះសមថៈ ។ ដោយហេតុនោះ សេចក្ដីនេះ គប្បីឃើញថា ការសម្ដែងភាពពិសេសនៃកិច្ចដោយទូទៅដល់សមាបត្តិ ទាំង ៨ ។ ពាក្យថា **នេះសមថពលៈ** សេចក្ដីថា បដិបក្ខធម៌មាននីវរណៈជាដើម គប្បីឲ្យញាប់ញ័រមិនបាន ព្រោះចិត្តមានអារម្មណ៍តែមួយ ដែល

បានដោយអំណាចនៃកម្មៈជាដើមណា ឯការតាំងចុះដោយគ្របសង្កត់នីវរណៈជាដើមទាំងនោះ នេះឈ្មោះថា **សមថពលៈ** ។

ឥឡូវនេះ លោកអាចារ្យកាលសម្ដែងលម្អិតវិបស្សនាពលៈតទៅ ព្រោះវិបស្សនាពោលដោយសង្ខេប លោកសង្គ្រោះដោយអនុបស្សនា ៧ យ៉ាង ដូច្នោះ យោគាវចរគប្បីចេញចាកសមាបត្តិនោះៗហើយ ធ្វើការពិចារណាឃើញដោយអំណាចអនុបស្សនាទាំង ៧ នោះ និងកិច្ចនៃអនុបស្សនាក្នុងទីនេះ រមែងគ្រប់គ្រាន់បានដោយអាការត្រឹមប៉ុណ្ណោះឯង ហេតុនោះ លោកអាចារ្យកាលសម្ដែងដោយសរុបថា **អនិច្ចានុបស្សនាឈ្មោះថា វិបស្សនាពលៈ ។បេ។ បដិនិស្សគ្គានុបស្សនា ឈ្មោះថា វិបស្សនាពលៈ** ដូច្នេះហើយមានបំណងនឹងសម្ដែងអនុបស្សនាទាំងនោះដោយចែកអារម្មណ៍តាមន័យដែលបានពោលហើយខាងដើមតទៅ ទើបផ្ដើមពាក្យថា **ការពិចារណាឃើញការមិនទៀងក្នុងរូប** ដូច្នេះជាដើម ។ សូម្បីក្នុងទីនេះ ដើម្បីសម្ដែងថា ភាវៈជាធម្មជាតិដែលធម៌ ជាបដិបក្ខទាំងឡាយគ្របសង្កត់មិនបាន ជាអត្ថរបស់ពលៈ ដូច្នោះ ទើបលោកអាចារ្យផ្ដើមពាក្យថា ឈ្មោះថា **វិបស្សនាពលៈ** ព្រោះអត្ថដូចម្ដេច ដូច្នេះជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ព្រោះអវិជ្ជា** គឺព្រោះអវិជ្ជាជានិមិត្តក្នុងអកុសលចិត្តុប្បាទ ១២ ដួង ។ពាក្យថា **ព្រោះកិលេសដែលសហគតៈជាមួយអវិជ្ជា** គឺព្រោះមានវត្ថុនៃកិលេស មានលោភៈ ទោសៈជាដើម ដែលសម្បយុត្តជាមួយអវិជ្ជាជានិមិត្ត ។ ពាក្យដ៏សេស គប្បីដឹងបាន ដោយងាយនោះឯង ព្រោះមានន័យដូចបានពោលហើយខាងដើម ។ ឯសព្ទថា **អវិជ្ជា** ក្នុងទីនេះ ដើម្បីសម្ដែងការសម្រេចពលៈដោយការគ្របសង្កត់អវិជ្ជានោះ ព្រោះអវិជ្ជា ជាបដិបក្ខដោយត្រង់ចំពោះវិបស្សនា ។ ដោយហេតុនោះ សេចក្ដីនេះ គប្បីឃើញថា ជាការសម្ដែងភាពវិសេសនៃកិច្ចដោយទូទៅ ដល់អនុបស្សនាទាំង ៧ ។ ពាក្យថា **នេះវិបស្សនាពលៈ** សេចក្ដីថា វិបស្សនា

ញាណដែលបានដោយអំណាចអនិច្ចានុបស្សនាជាដើម ដែលធម៌ជាបដិបក្ខឲ្យញាប់ញ័រមិនបាន ព្រោះមាននិច្ចសញ្ញាជាដើមជានិមិត្ត ព្រោះការគ្របសង្កត់និច្ចសញ្ញាជាដើមនោះ តាំងចុះបាន នេះឈ្មោះថា **វិបស្សនាពលៈ** ។

**វិតក្ក វិចារៈ** ឈ្មោះថា **វចីសង្ខារ** ព្រោះធ្វើពាក្យអធិប្បាយថា តាក់តែងវាចាគឺញុំាំងវាចាឲ្យប្រព្រឹត្តទៅ ។ ដោយហេតុនោះ ទើបព្រះនាងធម្មទិន្នាថេរីពោលថា អើ អាវុសោ វិសាខ បុគ្គលត្រិះរិះមុនហើយ ទើបបន្លឺវាចាក្នុងកាលខាងក្រោយ ព្រោះហេតុនោះ ទើបវិតក្ក វិចារៈ ឈ្មោះថា **វចីសង្ខារ** ដូច្នេះ ។ ឯវិតក្ក វិចារៈទាំងនោះ រមែងចូលទៅស្ងប់ក្នុងទុតិយជ្ឈាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **វិតក្ក វិចារៈ** គឺវចីសង្ខាររបស់អ្នកចូលទុតិយជ្ឈានរមែងស្ងប់រម្ងាប់ ។ ខ្យល់ដង្ហើមចេញ-ចូល ឈ្មោះថា **កាយសង្ខារ** ព្រោះអត្ថថា ដែលកាយតាក់តែងឡើង ។ ពិតហើយ ព្រះនាងធម្មទិន្នាថេរីបានពោលទុកថា អើ អាវុសោ វិសាខ ខ្យល់ដង្ហើមចេញ-ចូល ជាធម៌ប្រព្រឹត្តទៅតាមផ្លូវកាយ ជារបស់ទាក់ទងដោយកាយ ព្រោះហេតុនោះ ទើបខ្យល់ដង្ហើមចេញ-ចូល ឈ្មោះថា **កាយសង្ខារ** ។ ព្រោះខ្យល់អស្សាសៈ និងខ្យល់បស្សាសៈទាំងនោះ រមែងត្រូវបានចូលទៅស្ងប់ ក្នុងចតុត្ថជ្ឈាន ដូច្នោះ ទើបលោកអាចារ្យពោលថា **កាយសង្ខារ គឺខ្យល់អស្សាសៈ និងខ្យល់បស្សាសៈ** របស់អ្នកចូលចតុត្ថជ្ឈានរមែងស្ងប់រម្ងាប់ ដូច្នេះ ។ សញ្ញា វេទនា ឈ្មោះថា **ចិត្តសង្ខារ** ព្រោះចិត្តតាក់តែងឡើង ។ ពិតហើយ ព្រះធម្មទិន្នាថេរីបានពោលទុកថា សញ្ញា និងវេទនា ចេតសិកធម៌ទាំងនេះ ទាក់ទងដោយចិត្ត ព្រោះហេតុនោះ ទើបសញ្ញា និងវេទនា ឈ្មោះថា **ចិត្តសង្ខារ** ដូច្នេះ ចិត្តសង្ខារទាំងនោះ ព្រោះកាលបុគ្គលចូលនិរោធ រមែងចូលទៅស្ងប់ ដូច្នោះ ទើបលោកអាចារ្យពោលថា **ចិត្តសង្ខារ គឺសញ្ញា និងវេទនារបស់អ្នកចូលសញ្ញាវេទយិតនិរោធស្ងប់រម្ងាប់** ដូច្នេះ ។

ដោយការកាន់យកវិវដ្ដានុបស្សនា ក្នុងញាណចរិយាទាំងឡាយនោះឯង រមែងត្រូវបានកាន់យកសូម្បីអនុបស្សនាដ៏សេស ដែលជាខាងដើមរបស់វិបស្សនាពលៈនោះ ព្រោះមិនវៀរអនុបស្សនាដ៏សេសនោះ ទើបវិវដ្ដានុបស្សនាមានបាន ។ ពាក្យថា **មគ្គ ឈ្មោះថា ញាណចរិយា ផលសមាបត្តិ ឈ្មោះថា ញាណចរិយា** លោកអាចារ្យពោលទុកយ៉ាងនោះ ព្រោះធ្វើអធិប្បាយថា ការពោលមគ្គ និងផលសមាបត្តិ ថាជាញាណចរិយា ព្រោះធម៌ គឺមគ្គ និងផល មានញាណជាប្រធាន ម្យ៉ាងទៀត ធម៌គឺមគ្គ និងផលដ៏សេស ឯញាណដែលជាបច្ច័យ មានភាពវិសេសក្រៃលែងឲ្យប្រព្រឹត្តទៅហើយ គឺឲ្យមានដំណើរទៅហើយ ដោយអំណាចជាឥន្ទ្រិយប្បច្ច័យ អធិបតិប្បច្ច័យ ហេតុប្បច្ច័យ និងមគ្គប្បច្ច័យជាដើម ។ សូម្បីក្នុងសមាធិចរិយា ក៏មានន័យនេះ។ ពាក្យថា **ដោយញាណចរិយា ១៦** ទាំងនេះ បានដល់ ដោយការប្រព្រឹត្តទៅ នៃញាណ ១៦ គឺអនុបស្សនា ៨ និងមគ្គញ្ញាណ ផលញ្ញាណ ៨ ។

ពាក្យថា **ដោយសមាធិចរិយា ៩** សេចក្ដីថា ដោយសមាធិចរិយា ៩ យ៉ាងនេះ គឺសមាបត្តិ ៨ រាប់ជាសមាធិចរិយា ៨ ឧបចារសមាធិនៃសមាបត្តិទាំងនោះ រាប់ជាសមាធិចរិយា ១ ជាឧបចារសមាធិការនៅស្មើគ្នា ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **បឋមជ្ឈាន ឈ្មោះថា ជាសមាធិចរិយា** ដូច្នេះជាដើម ។ ពាក្យថា **វិតក្កត្តិ ដើម្បីប្រយោជន៍ដល់ការបានបឋមជ្ឈាន** ជាដើម គប្បីឃើញថា លោកអាចារ្យពោលទុក ដោយអំណាចឧបចារសមាធិ ដែលមានអាវជ្ជនៈផ្សេងគ្នា ព្រោះសូម្បីឧបចារៈនៃសមាធិជាន់ខ្ពស់ឡើងទៅ លោកក៏ពោលទុកយ៉ាងនោះ ។ ឯធម៌ទាំងឡាយ មានបីតិជាដើម រមែងកើតក្នុងឧបចារៈនៃចតុត្ថជ្ឈានជាដើម ក្នុងអាវជ្ជនៈតែមួយ ក៏មិនមែន ។ ក្នុងទីនេះ ដោយពាក្យថា **ដើម្បីប្រយោជន៍ដល់ការបានបឋមជ្ឈាន** ជាដើម លោកអាចារ្យរមែងសម្ដែងថា បំណងយកភាពបរិបូណ៌ សូម្បី

នៃឧបចារសមាធិ ។ មានពាក្យសួរថា ឯក្នុងទីនេះ អ្វីជាការផ្សេងគ្នារបស់សមថពលៈ និងសមាធិចរិយា ឬអ្វីជាការផ្សេងគ្នារបស់វិបស្សនាពលៈ និងញាណចរិយា ដែលជាលោកិយ ។ លោកបានពោលអប្បនាសមាធិតែម្យ៉ាង ទុកក្នុងសមាបត្តិ ៨ ជាមួយឧបចារសមាធិ ដោយពាក្យថា **ដោយអំណាចនេក្ខម្មៈ** ជាដើម សូម្បីក្នុងសមថពលៈយ៉ាងណា លោកក៏បានពោលវិបស្សនាតែម្យ៉ាង ទុកក្នុងសមាធិចរិយា និងក្នុងវិបស្សនាពលៈ និងញាណចរិយាដែលជាលោកិយទុក ដូច្នេះឬ ? សេចក្តីនេះ ឆ្លើយថា លោកពោលទុកក៏ពិតយ៉ាងនោះ វិវដ្ដានុបស្សនា ដែលមិនបានពោលទុកឡើងក្នុងវិបស្សនាពលៈ មានញាណដែលជាបុរេចរជាដើម ក៏បានពោលទុកហើយក្នុងញាណចរិយាទាំងឡាយ ។ ប្រការមួយទៀត អត្ថដែលធម៌ជាបដិបក្ខទាំងឡាយឲ្យញាប់ញ័រមិនបានជាដើម ជា **អត្ថនៃពលៈ** ភាពជាបុគ្គលសន្សំល្អហើយ ដោយអំណាចភាពជាបុគ្គលមានវសី ៥ យ៉ាង ជា **អត្ថនៃចរិយា** ព្រោះហេតុនេះឯង គប្បីជ្រាបថា លោកបានពណ៌នាផ្សេងគ្នានៃសមថពលៈ និងសមាធិចរិយាហើយ ។

ក្នុងពាក្យថា **វសីភាវតាបញ្ញា** នេះ មានវិគ្គហៈដូច្នេះ ការជំនាញមានដល់បុគ្គលនេះ ហេតុនោះ បុគ្គលនេះឈ្មោះថា **វសី** ភាវៈនៃបុគ្គលដែលមានការជំនាញនោះ ឈ្មោះថា **វសីភាវោ** គឺ **វសីភាវតា** នោះឯង ។ ព្រោះក្នុងព្រះបាលី លោកពោលទុកជាឥត្ថីលិង្គថា **វសិយោ** ទើបលោកអាចារ្យពោលថា **វសីតិ បញ្ច វសិយោ** ពាក្យថា **វសី** បានដល់ វសី ៥ ប្រការ ដូច្នេះ ដើម្បីសម្តែងវសីទាំងនោះឯង ។ ក្នុងវសីទាំង ៥ នោះ ភាពជាអ្នកអាចក្នុងការញ៉ាំងចិត្តឲ្យដំណើរក្នុងអង្គឈាន មិនមានចន្លោះនៃបុគ្គលដែលនឹកកាវរកឈាន ឈ្មោះថា **អាវជ្ជនវសី** ។ ភាពជាអ្នកអាចចូលឈានបាន ដោយរហ័សនៃបុគ្គល ដែលប្រាថ្នានឹងចូលឈាន ឈ្មោះថា **សមាបជ្ជនវសី** ។ ភាពជាអ្នកអាចនឹងញ៉ាំងឈានបានរហូតខណៈ ១ ផ្ទាត់ម្រាមដៃ ឬ ១ ផ្ទូរ

២-៣ ផ្ចាត់ម្រាមដៃ ឈ្មោះថា **អធិដ្ឋានវសី** ។ ភាពជាអ្នកអាចនឹងចេញបានយ៉ាងរហ័សយ៉ាងនោះឯង ឈ្មោះថា **វុដ្ឋានវសី** ។ ចំណែក **បច្ចវេក្ខណវសី** រមែងសម្រេចដោយអាវជ្ជនវសីនោះឯង ។ ព្រោះថា បច្ចវេក្ខណៈទាំងឡាយនោះឯង ជាលំដាប់ដូច្នេះ ។ នេះជាការបង្រួញក្នុងទីនេះ ។ ចំណែកសេចក្ដីពិស្ដារបានមកហើយ ក្នុងខាងដើមនោះឯង ។ឯវសីភាវៈនេះបានពោលទុកដោយអំណាចសមាធិចរិយាទាំងឡាយ ។ ម្យ៉ាងទៀត ក្នុងបណ្ដាញាណចរិយាទាំងឡាយ ដែលឈ្មោះថា កិច្ចដែលនឹងធ្វើដល់វសីភាវៈនៃញាណចរិយាទាំងឡាយ ដែលជាលោកុត្តរមិនមាន ។ វសីភាវៈក្នុងញាណចរិយា ដែលជាលោកុត្តរទាំងនោះ សម្រេចដោយសភាវៈ ព្រោះកម្ចាត់ធម៌ដែលជាបដិបក្ខបានជាសមុច្ឆេទហើយ ចំណែកសម្រាប់ញាណចរិយាដែលជាលោកិយទាំងឡាយ រមែងបានវសីភាវៈដោយការឲ្យដល់នូវភាពជាធម៌ស្ទាត់ជំនាញ និងមានកម្លាំងនោះឯង ។

ពាក្យថា **ជានិទ្ទេសយ៉ាងខ្ពង់ខ្ពស់** គឺជានិទ្ទេសដែលមិនមានចំណែកសល់ ។ ឈ្មោះថា **រមែងមានដោយញាណចរិយាទាំង ១៤** ព្រោះព្រះអនាគាមីមិនទាន់បានសម្រេចអគ្គមគ្គផល ។ ពាក្យថា **បើយ៉ាងនោះ** អធិប្បាយថា បើលោកពោលថា **ដោយញាណចរិយា ១៦** ដូច្នេះ ដោយអំណាចជានិទ្ទេសយ៉ាងខ្ពស់ ក៏មានបំណងយកសូម្បីទាក់ទងជាមួយនិទ្ទេសយ៉ាងទាបជាងនោះ កាលបើ **យ៉ាងនោះ** ការចូលនិរោធ **ក៏នឹងមិនមានឬ** ? កាមគុណ ៥ ដែលជាវត្ថុមានដល់កាមរាគៈនោះ ហេតុនោះ កាមរាគៈនេះ ឈ្មោះថា **បញ្ចកាមគុណិកោ** ( មានបញ្ចកាមគុណ ) ។ **ព្រោះលោកមិនទាន់លះបាន** គឺព្រោះលោកមិនទាន់កាត់បានជាសមុច្ឆេទ ។ ព្រោះត្រឹមតែការលះដោយការសង្កត់កាមរាគៈ រមែងមិនអាចដើម្បីនឹងជាការស្ថិតនៅនៃនិរោធបាន ។ពាក្យថា **ព្រោះហេតុនោះ** គឺព្រោះលះកាមរាគៈ ដែលជាសត្រូវចំពោះសមាធិបានល្អហើយ ។

ដោយពាក្យនេះ លោកអាចារ្យរមែងសម្តែងថា ញាណចរិយាក្នុងមគ្គ និងផល រមែងមិនប្រកបដោយរូបរបស់ខ្លួន ក្នុងការចូលនិរោធសមាបត្តិ ព្រោះមិនទាន់ប្រព្រឹត្តទៅក្នុងពេលនោះ ដូចគ្នានឹងសមាធិចរិយា ក្នុងលោកិយញ្ញាណដោយពិត សូម្បីយ៉ាងនោះការស្ថិតនៅក្នុងនិរោធសមាបត្តិ ក៏រមែងមានបាន ព្រោះពលៈ និងចរិយា ជាបច្ច័យពិសេស ដោយការលះកាត់ធម៌ ដែលជាសត្រូវនោះៗ បានជាសមុច្ឆេទ ។ បទថា **ឯស យោគ អនាគាមី** ។ ឯពាក្យថា **របស់បុគ្គលចេញអំពីនិរោធសមាបត្តិ** ជាដើមនេះ ត្រាស់សំដៅដល់ការចេញចាកនិរោធរបស់ព្រះអនាគាមីតែម្យ៉ាង ព្រោះព្រះបាលីថា **នេវសញ្ញានាសញ្ញាយតនកុសល** កាលកាន់យកសេចក្តីដទៃ ក៏គួរត្រាស់ថា **នេវសញ្ញានាសញ្ញាយតនកិរិយា** ។

សួរថា លោកពោលថា **ក្នុងបញ្ចវោការភព** ដូច្នេះទុក ព្រោះអ្វី សូម្បីក្នុងចតុវោការភព ក៏បានអនុបុព្វសមាបត្តិតាមគួរ ដោយអំណាចអរូបជ្ឈានមិនមែនឬ ? ឆ្លើយថា បានក៏ពិត តែការចូលនិរោធនោះ មិនហៅថា **អនុបុព្វសមាបត្តិ** ព្រោះត្រឹមតែជាឯកទេស ។ លោកអាចារ្យកាលសម្តែងថា លោកហៅថា **អនុបុព្វសមាបត្តិ** ដោយអំណាចសមាបត្តិ ៨ នោះឯង ទើបពោលថា **ការកើតឡើងនៃរូបជ្ឈាន មានបឋមជ្ឈានជាដើម** ក៏មិនមាន ។ ពាក្យថា **ព្រោះមិនមានវត្ថុ** សេចក្តីថា លោកអាចារ្យទាំងឡាយរមែងពោលថា ព្រោះមិនមានហទយវត្ថុ អធិប្បាយថា ព្រោះមិនមានវត្ថុ ពោល គឺករជកាយ ។ បើបុគ្គលគប្បីចូលនិរោធសមាបត្តិបានក្នុងអរូបភពសោត បុគ្គលក៏គប្បីជាអ្នកមិនមានបញ្ញត្តិ ដូចគ្នានឹងបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ព្រោះមិនមានចិត្ត និងចេតសិក និងព្រោះមិនមានធម៌ណាមួយដទៃ ។ បុគ្គលនេះ គប្បីត្រូវហៅថា **ចូលនិរោធសមាបត្តិ** ព្រោះអាស្រ័យអ្វីទៅ ឬសម្រាប់និរោធសមាបត្តិនេះនឹងគិតរឿងវត្ថុអ្វីទៅ ។ ព្រោះការខ្វះខាតនៃអវយវៈនោះឯង ទើបមិនមានការចូល

និរោធសមាបត្តិក្នុងអរូបភព ។

ពីរបទថា **សង្ខារានំ បវត្តិភេទេ** សេចក្តីថា ក្នុងការកើតឡើង និងក្នុងការបែកធ្លាយទៅគ្រប់ៗ ខណៈនៃសង្ខតធម៌ទាំងឡាយ ម្យ៉ាងទៀត សេចក្តីថា ក្នុងការបែកការប្រព្រឹត្តទៅនៃសង្ខតធម៌ទាំងនោះ ដែលផ្សេងដោយប្រភេទ មានកុសលជាដើម ដែលត្រូវទុក្ខ ៣ ប្រការបៀតបៀនហើយតាមសមគួរ ។ ភាពជាទុក្ខនៃសង្ខារសូម្បីបានក្នុងរូបធម៌ទាំងឡាយក៏រមែងដល់នូវភាពជាអវោហារិកព្រោះប្រាសចាកចិត្តនិងចេតសិក ។ ពាក្យថា **ខ្វាច** គឺនឿយណាយ ។ ពាក្យថា **ដល់និព្វាន** គឺដូចសម្រេចអនុបាទិសេសនិព្វាន ។ ពាក្យថា **ជាសុខ** គឺមិនមានទុក្ខ ។

ពាក្យថា **ដោយអំណាចសមថៈ និងវិបស្សនា** សេចក្តីថា ដោយអំណាចសមថៈ និងវិបស្សនាដែលប្រព្រឹត្តទៅរួមគ្នា ព្រោះជាធម៌មានឧបការៈដល់គ្នានឹងគ្នាដូចរបស់ដែលចងជាគូគ្នាទុក ។ ពាក្យថា **ព្យាយាម** គឺដំណើរទៅកាន់ទីខ្ពស់ឡើងដល់នេវសញ្ញានាសញ្ញាយតនៈ និងដល់អនុលោមញ្ញាណ ។ បទថា **និរោធយតោ** សេចក្តីថា ចូលនេវសញ្ញានាសញ្ញាយតនៈ ហើយធ្វើនេវសញ្ញានាសញ្ញាយតនៈនោះឲ្យរលត់ទៅ ។ **ការចូលនិរោធសមាបត្តិនោះ រមែងមានបានយ៉ាងនេះ** ព្រោះការមិនកើតឡើងនៃចិត្តសូម្បីដួងណាមួយដទៃឡើយ ។ ដោយពាក្យថា **ឯបុគ្គលណា** ជាដើម លោកអាចារ្យរមែងបើកផ្សារអត្ថ ដែលលោកពោលទុកថា **ដោយអំណាចសមថៈ និងវិបស្សនា** ដោយមាតិកាដែលជាព្យតិរេក ( គឺសេចក្តីពិសេស ) ។ **សម្រេចនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ក៏ឈប់** ព្រោះមិនមានសមថៈ និងវិបស្សនាសុទ្ធៗ ខ្ពស់ទៅជាងនោះ ។ **បុគ្គលណាប្រឹងប្រែងព្យាយាមដោយអំណាចវិបស្សនាតែម្យ៉ាង** បើជាព្រះអរិយៈមានសេចក្តីត្រូវការផលសមាបត្តិ បុគ្គលនោះ**សម្រេចផលសមាបត្តិ របស់ខ្លួន ហើយក៏ឈប់** ។ បើបុថុជ្ជន ឬព្រះសេក្ខៈ មាន

សេចក្តីត្រូវការមគ្គ បើសម្រេចមគ្គ ដោយវិបស្សនានោះហើយ តាំងនៅក្នុងផល សូម្បីបុគ្គលនោះ លោកក៏ហៅថា **សម្រេចផលសមាបត្តិហើយ ឈប់ដូចគ្នា** ។ បទថា **សោ យោគ ឧភយវសេន បដិបន្នោ** ( ប្រែថា បុគ្គលបដិបត្តិដោយអំណាចសមថៈ និងវិបស្សនាទាំង ២ នោះ ) ។ បទថា **តំ យោគ និរោធសមាបត្តិ** ប្រែថា និរោធសមាបត្តិនោះ ។

បុគ្គលជាអ្នកអាចចូលនិរោធសមាបត្តិបាន ដោយវិធីណា មានការប្រកបដោយផលទាំង ២ ជាដើម វិធីនោះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយពីមុននោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យកាលសម្តែងអាការចូលសមាបត្តិតែម្យ៉ាង ពោលពាក្យថា **ធ្វើភត្តកិច្ចហើយ** ដូច្នេះជាដើម ។ ឯកិច្ចនោះ ជាបុព្វកិច្ចទូទៅនៃការនាទាំងពួង ។ ពីរបទថា **តត្ថ សង្ខារេ** ប្រែថា សង្ខារទាំងឡាយក្នុងបឋមជ្ឈានទោះ ឬក្នុងចិត្តុប្បាទដែលសម្បយុត្តជាមួយបឋមជ្ឈាននោះ ។

លោកពោលថា **វិបស្សតិ** រមែងពិចារណា ដូច្នេះ ក្នុងទីនេះ គួរប្រាប្តាវិបស្សនាដូចម្តេចវិញ ព្រោះហេតុនោះ លោកអាចារ្យរមែងសម្តែងចែកវិបស្សនានោះៗ ឯងជា ៣ យ៉ាង ដោយពាក្យថា **ឯវិបស្សនានោះ** ដូច្នេះជាដើម ដើម្បីអធិប្បាយវិបស្សនានោះ ។ វិបស្សនា **បើយ៉ាងទន់ ក៏រមែងញ៉ាំងមគ្គដែលជាទន្ធាភិញ្ញាឲ្យសម្រេចបាន** ។ **បើយ៉ាងខ្លាំងក្លា** ក៏រមែងញ៉ាំងមគ្គ ដែលជាខិប្បាភិញ្ញាឲ្យសម្រេចបាន ដែលពោលមកនេះ ជាការផ្សេងគ្នារបស់វិបស្សនាយ៉ាងទន់ និងយ៉ាងខ្លាំងក្លា ។ វិបស្សនាដែលចូលលក្ខណៈ រមែងជាបច្ច័យដល់មគ្គនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យកាលសម្តែងសេចក្តីនេះ ពោលថា **សង្ខារបរិគណ្ហណកវិបស្សនាយ៉ាងទន់ ឬយ៉ាងខ្លាំងក្លាក៏ដោយ រមែងជាបទដ្ឋាននៃមគ្គនោះឯង** ដូច្នេះ ។ ផលសមាបត្តិវិបស្សនាយ៉ាងខ្លាំងក្លាប៉ុណ្ណោះ **ទើបគួរ** ព្រោះកាលអារម្មណ៍ គឺសង្ខារ មានក៏ប្រព្រឹត្តទៅ

ដោយអាការវិលត្រឡប់អំពីសង្ខារទាំងពួង និងព្រោះជាបច្ច័យដល់ផលដែលជាវិសង្ខារ បានដូចគ្នានឹងមគ្គ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដូចគ្នានឹងមគ្គភាវនា** ។ ព្រោះនិរោធសមាបត្តិវិបស្សនាទន់ខ្ចីពន់ពេក ក្រៃលែងទៅដោយសមាធៈ មិនអាចញ៉ាំងសង្ខារទាំងឡាយឲ្យរលត់បាន ក៏ជាការចប់សព្វគ្រប់ ដោយសមថៈខ្លាំងក្លាច្រើនក្រៃលែងទៅដោយញាណ ក៏ជាការចប់សព្វគ្រប់ ដោយផលសមាបត្តិ ព្រោះឃើញទោសក្នុងសង្ខារទាំងឡាយដ៏កំពូល ដូច្នោះ ទើបលោកអាចារ្យពោលថា **មិនទន់ពេក មិនខ្លាំងក្លាពេក ទើបគួរ** ។ ឯស **យោគ និរោធសមាបជ្ជនកោ** ប្រែថា បុគ្គលចូលនិរោធនោះ ។ ពាក្យថា **សង្ខារទាំងឡាយនោះ** សង្ខារក្នុងបឋមជ្ឈានទាំងឡាយនោះ ។

ដោយពាក្យថា **យ៉ាងនោះឯង** នេះ លោកអាចារ្យរមែងទាញយកសេចក្តីនេះថា **ដោយវិបស្សនាមិនទន់ពេក មិនខ្លាំងក្លាពេក** មក ។ សូម្បីក្នុងបទដ៏សេសទាំងឡាយក៏មានន័យនេះ ។ លោកអាចារ្យពួកខ្លះរមែងពោលថា គួរពោលថា ចូលអាកិញ្ចញ្ញា-យតនៈ ចេញហើយពិចារណាសង្ខារទាំងឡាយ ក្នុងអាកិញ្ចញ្ញាយតនៈនោះ យ៉ាងនោះឯង តែលោកអាចារ្យមិនបានពោលពាក្យនោះទុក ពោលថា **ធ្វើបុព្វកិច្ច ៤ យ៉ាង** ដូច្នេះប៉ុណ្ណោះ ព្រោះមានន័យដូចបានពោលហើយខាងដើម ពាក្យនោះត្រឹមតែជាមតិរបស់លោក ។ ព្រោះថា ការប្រព្រឹត្តទៅនៃសមាធិ ក៏ដោយការប្រព្រឹត្តទៅនៃវិបស្សនា ដូច្នោះ ទើបគួរចេញចាកសមាបត្តិហើយ ធ្វើបុព្វកិច្ច ពិតយ៉ាងនោះ លោកអាចារ្យពោលពាក្យជាដើមថា **ចូលអាកិញ្ចញ្ញាយតនៈហើយចេញ ធ្វើបុព្វកិច្ចនេះ** ដូច្នេះតទៅ តែមិនពោលថា **ពិចារណាសង្ខារទាំងឡាយក្នុងអាកិញ្ចញ្ញាយតនៈនោះយ៉ាងនោះឯង** ។ ពាក្យថា **នានាពទ្ធ អវិកោបន** សេចក្តីថា មិនញ៉ាំងបរិក្ខារដែលមិនទាក់ទងជាមួយខ្លួនឲ្យវិនាស ។ គឺអធិដ្ឋានដោយប្រការ ដែលរបស់នោះនឹងមិនវិនាស ។ ពាក្យ

ថា **សង្ឃបដិមានន** បានដល់ រំពឹងដល់ការរង់ចាំនៃសង្ឃ ។ ពាក្យថា **សត្ថុបក្កោសនៈ** គឺរំពឹងដល់ការត្រាស់ឲ្យរករបស់ព្រះសាស្តា ។ ពាក្យថា **អទ្ធានបរិច្ឆេទ** ក្តាប់សេចក្តីថា ធ្វើបុព្វកិច្ច មានកាលនៃជីវិត ជាកំណត់ ។

ពាក្យថា **គប្បីអធិដ្ឋាន** គឺគប្បីធ្វើចិត្តឲ្យកើតឡើង ។ ឯការធ្វើចិត្តឲ្យកើតឡើងដោយប្រការនោះឯង ជាការអធិដ្ឋានក្នុងទីនេះ ។

អាចារ្យទាំងឡាយ រមែងពោលថា សរីរៈ រមែងប្រព្រឹត្តទៅបានយ៉ាងនោះអស់ ៧ ថ្ងៃប៉ុណ្ណោះ ហួសទៅជាងនោះរមែងលំបាក ព្រោះរូបទាំងឡាយ មានចិត្តជរូបជាដើមមិនកើតឡើង និងព្រោះមិនមានការឧបត្ថម្ភ មានបច្ឆាជាតប្បច្ច័យជាដើម ព្រោះហេតុនោះ ទើបចូលនិរោធមានកំណត់ ៧ ថ្ងៃប៉ុណ្ណោះ ។

ពាក្យថា **ដោយអំណាចសមាបត្តិនោះឯង** គឺដោយអំណាចនិរោធសមាបត្តិនោះឯង ។ អធិប្បាយថា បុគ្គលចូលនិរោធ **រមែងការពារ** អន្តរាយ មានភ្លើងជាដើមនោះ ដោយអំណាចការអធិដ្ឋាន ។ ពាក្យណា ដែលគួរពោលក្នុងពាក្យថា **របស់ព្រះសញ្ជីវៈ** ជាដើម ពាក្យនោះ ខ្ញុំបានពោលទុកហើយ **ក្នុងឥទ្ធិកថា** ខាងដើមនោះឯង ។

បទថា **ឯតស្ស យោគ និរោធំ សមាបជ្ជន្តស្ស** ប្រែថា របស់ភិក្ខុដែលចូលនិរោធនោះ ឬ **យោគ និរោធសមាបជ្ជនស្ស** ប្រែថា នៃការចូលនិរោធនោះ ។ ពាក្យថា **ក្នុងវេលានោះ** សេចក្តីថា រមែងចេញបានក្នុងពេលដែលភិក្ខុនោះ ចូលទៅរកនោះឯង ។ ពាក្យនេះ ដូចជាកំណត់ពេលទុក ។

ពាក្យថា **ជាការធ្ងន់យ៉ាងនេះ** អធិប្បាយថា ព្រោះ ដែលឈ្មោះថា **អាណារបស់សង្ឃ** ជាការធ្ងន់យ៉ាងនេះ ព្រោះញ៉ាំងបុគ្គលដែលចូលនិរោធ ដែលអន្តរាយទាំងឡាយ មានភ្លើងជាដើមគ្របសង្កត់មិនបាន ឲ្យចេញចាកសមាបត្តិបាន ព្រោះហេតុនោះ បុគ្គលប្រាថ្នាប្រយោជន៍សុខរបស់ខ្លួន មិនគប្បីកន្លងល្មើសអាណារបស់សង្ឃ

សូម្បីព្រោះហេតុនៃជីវិត ។

**មិនចាំបាច់បុគ្គលណាមកហៅថា** អាវុសោ ព្រះមានជោគត្រាស់ឲ្យរកលោក ដូច្នេះ ។ ក្នាប់សេចក្តីថា គប្បីរំពឹងថា **អញនឹងចេញ** ។

បទថា **ជីវិតទ្ធានស្ស** ប្រែថា កាលនៃជីវិត បានដល់ ការប្រព្រឹត្តទៅនៃជីវិតរបស់ខ្លួន ។ អាយុនោះឯង ឈ្មោះថា **អាយុសង្ខារ** ។ ឯអាចារ្យទាំងឡាយរមែងពោលថា **បានដល់ អាយុ ភ្លើងធាតុ និងវិញ្ញាណ** ឯសភាវធម៌ទាំងនោះ ជាអារម្មណ៍របស់ចិត្តប្រក្រតីនៃអ្នកចូលនិរោធនោះ ។ ការស្លាប់ **ក្នុងនិរោធ** មិនមាន ព្រោះសត្វស្លាប់ដោយកវគ្គដួងចុងក្រោយ ។ **ត្រូវពិចារណាមើលហើយ ទើបចូល** ដោយបំណងថា **ការស្លាប់ដោយឆាប់រហ័ស កុំបីមានឡើយ** ដូច្នេះ ។ ព្រោះថា ព្រោះសេចក្តីស្លាប់ដោយឆាប់រហ័ស បុគ្គលគប្បីជាអ្នកមិនជាធំ ព្យាករមគ្គផល ការឲ្យឱវាទដល់ភិក្ខុ និងសម្តែងអានុភាពនៃព្រះសាស្តា ឬមិនសម្រេចអរហត្តមគ្គ ក៏គប្បីមានដល់ព្រះអនាគាមីបាន ។ ពាក្យថា **បុព្វកិច្ចដ៏សេស** បានដល់ បុព្វកិច្ច ទាំង ៣ យ៉ាង មាន **នានាពទ្ធអវិកោបន** ជាដើម ។ **លោកពោលទុក** ក្នុងអដ្ឋកថា ។

លោកពោលទុកហាក់បីដូចជាមិនពិតប្រាកដថា **វារៈចិត្ត ១ ឬ ២** ដូច្នេះក៏ពិតសូម្បីយ៉ាងនោះ អាចារ្យទាំងឡាយរមែងពោលទុកដោយពិតប្រាកដនូវវារៈ ២ នោះឯង ។ ពាក្យថា **វារៈចិត្ត** បានដល់ វារៈចិត្តនៃវសញ្ញានាសញ្ញាយតនៈ ។ លោកអាចារ្យពោលដល់បុគ្គលមិនមានចិត្តនោះឯងថា **សម្មស្សនិរោធ** ។ ពាក្យថា **ព្រោះជាប្រយោគនៃនិរោធ** សេចក្តីថា ព្រោះជាប្រយោគនៃចិត្តនិរោធ គឺការរំលត់ចិត្ត អធិប្បាយថា ព្រោះប្រយោគ មានការសង្គ្រោះពលៈទាំង ២ ជាដើម ជាចិត្តនិរោធ គឺការរលត់ចិត្ត ។ ឯការប្រកបដោយសមថពលៈ និងវិបស្សនាពលៈ និងជាអ្នកជំនាញក្នុងញាណចរិយា និងសមាធិចរិយា ក៏មានបំណងយកក្នុងទីនេះ ដោយអំណាច

មិនលើសខ្វះគ្នានឹងគ្នា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ធ្វើធម៌ គឺសមថៈ និងវិបស្សនាទាំង ២ ឲ្យជាយុគនទ្ធ គឺចងគ្នាជាគូ** ។ ពាក្យថា **បយោគ នៃអនុ-បុព្វនិរោធ** គឺនេះជាបយោគនៃការរលត់ទៅ ដោយលំដាប់របស់ធម៌ទាំងឡាយ មានបឋមជ្ឈានជាដើម និងរបស់ការតាមឃើញធម៌នោះ ។ មានពាក្យប្រកបសេចក្ដីថា **ការឡើងកាន់សមាបត្តិ ៨** តាមន័យដែលពោលហើយ **នេះមិនមែន** ជាបយោគរបស់ការចូល **នេវសញ្ញានាសញ្ញាយតនសាមបត្តិ** ។ ព្រោះហេតុនោះ ទើបចិត្តទាំងឡាយមិនប្រព្រឹត្តទៅលើចិត្ត ២ ដួង ។

ពាក្យថា **រមែងមិនអាចជាអ្នកមិនមានចិត្តតទៅបាន** សេចក្ដីថា រមែងមិនអាចជាអ្នកមិនមានចិត្តអស់កាលតាមដែលកំណត់ទាំងអស់ ។ ឯការដែលមិនអាចទៅជាដូច្នោះ ព្រោះមិនបានធ្វើការពិចារណាដល់ការទន្ទឹងនៃសង្ឃ ការត្រាស់ឲ្យរកនៃព្រះសាស្ដា និងការកំណត់កាលនៃជីវិត មិនមែនព្រោះមិនបានធ្វើ ការមិនញុំាងកស្តុដែលទាក់ទងជាមួយភិក្ខុអង្គដទៃឲ្យកម្រើក ។ ព្រោះថា ដោយការមិនធ្វើការ មិនញុំាងកស្តុដែលទាក់ទងជាមួយភិក្ខុដទៃឲ្យកម្រើកនោះ គ្រាខ្វះ ក៏នឹងមិនគប្បីមានការញុំាងបរិក្ខារដូច្នោះឲ្យវិនាសតែម្យ៉ាង ទាំងមិនជាការជំទាស់ដល់ការចូលនិរោធសមាបត្តិ ។ សេចក្ដីនេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយដោយរឿង **ព្រះមហានាគត្ថេរ** នោះឯង កាលបើដូច្នេះ រមែងពោលថា ការចេញអំពីនិរោធសមាបត្តិ រមែងមានដោយអាការ ៣ យ៉ាង ព្រោះហេតុនោះ ពាក្យនោះមិនគប្បីជឿទុកជាគោល ដោយពាក្យថា **តែនឹងវិលត្រឡប់មកតាំងនៅក្នុងអាកិញ្ចញ្ញាយតនៈនោះឯង** នេះ លោកអាចារ្យរមែងសម្ដែងថា កាលការរារាំងការចូលសមាបត្តិកើតហើយ សភាពយ៉ាងនេះ ក៏រមែងមានបាន ព្រោះផលចិត្តកើតឡើង ព្រោះការហួស វេលាតាមដែលកំណត់ទុក ។ អាចារ្យពួកខ្វះរមែងពោលថា ព្រោះធ្វើអធិប្បាយ យ៉ាងនេះ ឧបមាដូចបុរសចុះកាន់ស្ទឹងដ៏ជ្រៅ និងចុះ

ជាន់ថ្នាំងថ្មដ៏ក្តៅ រមែងជាឧបមា ដែលយល់បាន ។ ចំណែកអាចារ្យមួយពួកទៀត រមែងពោលថា ការចូលនិរោធសមាបត្តិ រមែងមិនសម្រេចឡើយ ព្រោះការខ្វះអង្គ ដោយការមិនធ្វើបុព្វកិច្ចខ្លះ មានការត្រូវការរបស់សង្ឃជាដើម ព្រោះលោកអាចារ្យ បានពោលទុកថា ព្រះយោគាវចរ លុះចូលនេវសញ្ញានាសញ្ញាយតនៈប៉ុណ្ណោះ រមែង នឹងថយត្រឡប់មកតាំងនៅក្នុងអាកិញ្ចញ្ញាយតនៈ ព្រោះមិនបានធ្វើបុព្វកិច្ចទុក ។ ឯការ ធ្វើបុព្វកិច្ចនេះ ដូចជាទំនៀមរបស់និរោធសមាបត្តិ ។ អាចារ្យមួយពួកទៀតពោលថា របស់ណាជាគ្រឿង សំខាន់ក្រៃលែងក្នុងបុព្វកិច្ចនៃនិរោធសមាបត្តិនោះ ការមិនធ្វើ របស់នោះ រមែងជំទាស់ដល់ការចូលនិរោធសមាបត្តិ ។ ពាក្យនោះ គួរពិចារណា ហើយកាន់យក ។ ចំណែកពាក្យថា **តាំងនៅក្នុងអាកិញ្ចញ្ញាយតនៈ** នេះ លោកអាចារ្យ ពោលទុក ព្រោះនឹងត្រូវចូលអាកិញ្ចញ្ញាយតនៈ ។ ព្រោះថា ត្រូវចូល ហើយទើបចេញ ចេញហើយ ទើបធ្វើបុព្វកិច្ច ។

បទថា **យថា បន** ជាដើម ជាពាក្យប្រៀបធៀបដោយឧបមាជាបុព្វកិច្ចដែល បានធ្វើហើយស្មើគ្នា ។

បទថា **អស្សា យោគ និរោធសមាបត្តិយា** ប្រែថា នៃនិរោធសមាបត្តិ នោះ ។ ដោយពាក្យថា **ដោយអំណាចការកំណត់កាលទុក** ជាដើម លោកអាចារ្យ រមែងសម្តែងការញុំាងនិរោធសមាបត្តិ ដោយអាការ ៤ យ៉ាង ។

ពាក្យថា **បង្អោនទៅកាន់វិវេក** គប្បីជ្រាបថា បង្អោនទៅកាន់វិវេក ព្រោះជាការ បែរមុខចាកសង្ខារ និងព្រោះការកើតឡើងនៃផលចិត្តមុននោះឯង ។

ពាក្យសួរថា **បុគ្គលស្លាប់ និងអ្នកចូលនិរោធផ្សេងគ្នាដូចម្តេច** ព្រោះកាន់យក ការមិនផ្សេងគ្នានៃអ្នកស្លាប់ និងអ្នកចូលនិរោធ ព្រោះការរម្ងាប់នៃសង្ខារទាំង ៣ និង ព្រោះសល់ត្រឹមតែរូបធម៌ ដោយមិនមានចេតសិក និងវិញ្ញាណដ៏សេស ។ ដើម្បី

សម្តែងថា អ្នកស្តាប់ និងអ្នកចូលនិរោធទាំងនោះ មិនផ្សេងគ្នាដោយហេតុទាំងឡាយមានការស្ងប់រម្ងាប់នៃសង្ខារ ៣ ជាដើមដោយពិត សូម្បីយ៉ាងនោះ ការទៅប្រាស និងការមិនទៅប្រាសនៃអាយុ ភ្លើងធាតុ និងឥន្ទ្រិយ ជាការសល់ត្រឹមតែរូបធម៌ ជាការផ្សេងគ្នា ទើបលោកអាចារ្យពោលពាក្យថា **យ្វាយំ** ជាដើម ។

ពាក្យថា **ដោយសភាវៈ** បានដល់ ដោយសភាវធម៌ អធិប្បាយថា ដោយបរមត្ថ ។ ពិតហើយ វត្ថុដែលមានដោយបរមត្ថ រមែងបានភាវៈដែលគប្បីពោលដោយកាពជាសង្ខតៈជាដើម មិនមែនវត្ថុដែលមិនមានឡើយ ។ ពាក្យថា **ដោយអំណាចនៃព្រះអរិយៈដែលចូល** សេចក្តីថា ព្រោះការចូលនិរោធសមាបត្តិ ដោយការកើតឡើងនៃបយោគ គឺការរម្ងាប់សង្ខារទាំងឡាយរបស់ព្រះអរិយៈដែលចូល ដែលធ្វើធម៌ គឺសមថៈ និងវិបស្សនាឲ្យជាគូគ្នា ឡើងកាន់សមាបត្តិទាំង ៨ រមែងជាកិរិយា ឈ្មោះថា **សម្រេច** ដូច្នោះ អាស្រ័យការកើតឡើងនៃបយោគនោះ **និងពោលថា ជាកិរិយាសម្រេច** ក៏គួរ ។

ឈ្មោះថា **ស្ងប់** ព្រោះចូលទៅស្ងប់សង្ខារ និងព្រោះប្រកបដោយធម៌ដែលស្ងប់ ។ ឈ្មោះថា **ព្រះអរិយសេព** ព្រោះព្រះអរិយៈទាំងឡាយនោះឯង សេពអាស្រ័យហើយ ។ ឈ្មោះថា **ដល់នូវការរាប់ថា និព្វាន** ព្រោះទុក្ខទាំង ៣ ប្រការ រលត់ទៅ ។ ពាក្យថា **អរិយបញ្ញា** បានដល់ មគ្គបញ្ញា និងផលបញ្ញា ដែលបរិសុទ្ធល្អហើយ ។ បទថា **ឥមិស្សាបិ យោគ និរោធសមាបត្តិយា** ប្រែថា និរោធសមាបត្តិនេះ ។ ពាក្យថា **អាចក្នុងការចូល** បានដល់ អាចចូល ។

# វិសុទ្ធិមគ្គ

## អាហុនេយ្យភាវាទិសិទ្ធិ

អានិសង្សប្រការថា **អាហុនេយ្យភាវាទិសិទ្ធិ** សេចក្ដីថា មិនមែនត្រឹមតែការអាចក្នុងការចូលនិរោធសមាបត្តិប៉ុណ្ណោះទេ តែការសម្រេចនៃភាពជាបុគ្គលទ្រទ្រង់អរិយគុណ មានជាអាហុនេយ្យបុគ្គលជាដើមនេះ ក៏គប្បីជ្រាបថា ជាអានិសង្សនៃលោកុត្តរបញ្ញាភាវនានេះដែរ ។ ឯបុគ្គលឈ្មោះថា មានបញ្ញាចម្រើនហើយ ព្រោះធ្វើលោកុត្តរបញ្ញាទាំង ៤ ថ្នាក់នោះឲ្យកើតហើយ រមែងជាបុគ្គលដែលគួរបូជា ជាបុគ្គលគួរក្រោកទទួល ជាបុគ្គលគួរដល់បុញ្ញក្ខេត្ត ជាបុគ្គលគួរធ្វើអញ្ជលីនៃសត្វលោកព្រមទាំងទេវតា ជាបុញ្ញក្ខេត្តដ៏កំពូលរបស់លោក ដោយមិនប្លែកគ្នា ( ទាំង ៤ ជាន់)។

## ប្រភេទព្រះអរិយបុគ្គល

តែដោយប្លែកគ្នាក្នុងលោកុត្តរបញ្ញា ៤ ថ្នាក់នោះ ថ្នាក់ដំបូង បុគ្គលដែលធ្វើមគ្គបញ្ញាខាងដើមឲ្យកើតហើយ មកដោយវិបស្សនាដ៏ទន់ ជាបុគ្គលមានឥន្ទ្រិយទន់ខ្សោយ ក៏ជាព្រះអរិយបុគ្គលឈ្មោះ **សត្តក្ខត្តុបរម** ត្រាច់ទៅក្នុងសុគតិភព ៧ ជាតិ ក៏ធ្វើទីបំផុតទុក្ខបាន បុគ្គលមកដោយវិបស្សនាយ៉ាងកណ្ដាល មានឥន្ទ្រិយល្មមប្រមាណ ក៏ជាព្រះអរិយបុគ្គលឈ្មោះ **កោលំកោលៈ** ស្ទុះអន្ទោលទៅកាន់ត្រកូល ២-៣ ត្រកូល ក៏ធ្វើទីបំផុតទុក្ខបាន ។ ដែលមកដោយវិបស្សនាដ៏ខ្លាំង មានឥន្ទ្រិយចាស់ក្លា ក៏ជាព្រះអរិយបុគ្គលឈ្មោះ **ឯកពីជី** ញ៉ាំងភពដែលជារបស់មនុស្សឲ្យកើត ១ ជាតិ ប៉ុណ្ណោះហើយ ក៏ធ្វើទីបំផុតទុក្ខបាន ។

បុគ្គលធ្វើមគ្គបញ្ញាជាន់ទី ២ ឲ្យកើតហើយ រមែងជាព្រះអរិយបុគ្គលឈ្មោះ

**សកទាគាមី** មកកាន់លោកនេះម្ដងប៉ុណ្ណោះ ហើយធ្វើទីបំផុតទុក្ខបាន ។

បុគ្គលធ្វើមគ្គប្បញ្ញាជាន់ទី ៣ ឲ្យកើតហើយ រមែងជាព្រះអរិយបុគ្គលឈ្មោះ **អនាគាមី** ព្រះអនាគាមីនោះ ដោយអំណាចការផ្សេងគ្នានៃឥន្ទ្រិយ រមែងជាបុគ្គលលះលោកនេះទៅហើយ ទើបសម្រេច ( គឺបរិនិព្វាន ) ដោយចែកជា ៥ ប្រភេទ គឺ **អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតាអកនិដ្ឋគាមី** ។

ក្នុង ៥ ប្រភេទនោះ លោកដែលកើតក្នុងសុទ្ធាវាសកពណាទីមួយ មិនទាន់ដល់ពាក់កណ្ដាលអាយុក៏បរិនិព្វាន ឈ្មោះថា **អន្តរាបរិនិព្វាយី** បុគ្គលដែលបរិនិព្វានហួសអំពីពាក់កណ្ដាលអាយុទៅ ឈ្មោះថា **ឧបហច្ចបរិនិព្វាយី** លោកដែលញ៉ាំងមគ្គខាងលើឲ្យកើតបាន ដោយមិនចាំបាច់តាក់តែង គឺមិនចាំបាច់ប្រកបសេចក្ដីព្យាយាមឈ្មោះថា **អសង្ខារបរិនិព្វាយី** លោកដែលញ៉ាំងមគ្គខាងលើឲ្យកើត ដោយត្រូវតាក់តែងគឺត្រូវប្រកបព្យាយាមតឹងតែង ឈ្មោះថា **សសង្ខារបរិនិព្វាយី** លោកដែល ( បដិសន្ធិ ) ខ្ពស់ឡើងទៅអំពីភព ដែលកើតរហូតដល់អកនិដ្ឋកភពហើយ ទើបបរិនិព្វានក្នុងអកនិដ្ឋកភពនោះ ឈ្មោះថា **ឧទ្ធំសោតាអកនិដ្ឋគាមី** ។

បុគ្គលធ្វើមគ្គប្បញ្ញាទាំង ៤ ថ្នាក់ឲ្យកើតហើយ អង្គខ្លះជាព្រះអរហន្តប្រភេទសទ្ធាវិមុត្តិ អង្គខ្លះ ជាព្រះអរហន្តប្រភេទបញ្ញាវិមុត្តិ អង្គខ្លះ ជាព្រះអរហន្តប្រភេទឧភតោភាគវិមុត្តិ អង្គខ្លះ ជាព្រះអរហន្តប្រភេទតេវិជ្ជ ( បានវិជ្ជា ៣ ) អង្គខ្លះ ជាព្រះអរហន្តប្រភេទឆឡភិញ្ញា ( បានអភិញ្ញា ៦ ) អង្គខ្លះ ជាព្រះអរហន្តប្រភេទ បដិសម្ភិទប្បភេទប្បត្ត ជាព្រះមហាខីណាស្រព ដែលខ្ញុំសំដៅដល់សេចក្ដីបានពោលទុក ( ក្នុងចុងបករណ៍ ) ថា ឯព្រះខីណាស្រពនោះ ឈ្មោះថា **ភ្ញាវដ្ដៈនោះបានក្នុងខណៈនៃមគ្គ ឈ្មោះថា ជាបុគ្គលមានជដៈដែលភ្ញាសម្រេចហើយ ក្នុងខណៈនៃផល រមែងជា**

ទក្ខិណេយ្យ បុគ្គលដ៏លើសនៃសត្វលោក និងទេវតា ) ដូច្នេះ ។

ការចម្រើនអរិយប្បញ្ញា មានអានិសង្សច្រើន ដូចពោលមក ដូច្នេះ ហេតុណា ហេតុនោះ បុគ្គលមានបញ្ញា គប្បីធ្វើសេចក្តីត្រេកអរក្នុងការចម្រើនអរិយប្បញ្ញានោះ ហោង ។

ឯបញ្ញាភាវនា ព្រមទាំងអានិសង្សក្នុងវិសុទ្ធិមគ្គ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយមុខ គឺសីល សមាធិ បញ្ញា ក្នុងគាថានេះថា

សីលេ បតិដ្ឋាយ នរោ សប្បញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ

ភិក្ខុជាអ្នកឈ្លាស មានសេចក្តីព្យាយាម មានបញ្ញា រក្សាខ្លួនតាំងនៅក្នុងសីល ហើយអប់រំចិត្ត និងបញ្ញានោះ គប្បីស្រាវជដ:នេះបាន ដូច្នេះ ។

ដែលបានសម្តែងសព្វគ្រប់ហើយ ដោយពាក្យពណ៌នាត្រឹមប៉ុណ្ណេះ ។

បរិច្ឆេទទី ២៣

ឈ្មោះបញ្ញាភាវនានិសង្សនិទ្ទេស

ក្នុងបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

ដែលធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយការសម្រេចភាពជាអរិយបុគ្គល មានអាហុនេយ្យបុគ្គលជាដើម

ពាក្យថា ការសម្រេចភាពជាអរិយបុគ្គល មានអាហុនេយ្យបុគ្គលជាដើម បានដល់ ជាអ្នកសម្រេចជាអាហុនេយ្យបុគ្គល ភាពជាបាហុនេយ្យបុគ្គល ភាពជាទក្ខិណេយ្យបុគ្គល ជាអញ្ជលិករណីយបុគ្គល និងជាបុញ្ញក្ខេត្តដ៏កំពូល ។ ពាក្យថា **ដោយមិនប្លែកគ្នា** គឺវៀរការប្លែកគ្នានៃទស្សនៈ និងមគ្គប្បញ្ញា ។ បទថា **ឯតិស្សា យោគ លោកុត្តរប្បញ្ញាយ** ប្រែថា របស់លោកុត្តរប្បញ្ញានេះ ។ គ្រឿងសក្ការៈ ដែលនាំមកបូជា ហេតុនោះ ទើបឈ្មោះថា **អាហុន** បានដល់ ទានដែលបុគ្គល គប្បីនាំមកអំពីទីឆ្ងាយ ហើយបូជា បុគ្គលគួរដើម្បីទទួលអាហុនៈ គឺគ្រឿងសក្ការៈ ដែលនាំមកបូជា ហេតុនោះ ទើបឈ្មោះ **អាហុនេយ្យោ** បុគ្គលគួរទទួលគ្រឿងសក្ការៈដែលគប្បីនាំមកបូជា ។ ទានដែលគប្បីឲ្យដល់ភ្ញៀវដែលមកដល់ ឈ្មោះថា **បាហុនៈ** បុគ្គលគួរដើម្បីទទួលបាហុនៈ គឺរបស់ទទួលភ្ញៀវនោះ ហេតុនោះ ទើបឈ្មោះថា **បាហុនេយ្យោ** បុគ្គលគួរទទួលរបស់ទទួលភ្ញៀវ ។ បុគ្គលរមែងគួរដល់ទក្ខិណា ហេតុនោះ ទើបឈ្មោះថា **ទក្ខិណេយ្យោ** បុគ្គលគួរដល់ទក្ខិណាទាន ការធ្វើអញ្ជលី ឈ្មោះអញ្ជលិកម្ម បុគ្គលរមែងគួរដល់អញ្ជលិកម្មនោះ ហេតុនោះ ទើបឈ្មោះថា **អញ្ជលិករណីយោ** បុគ្គលគួរធ្វើអញ្ជលិកម្ម ។ បុគ្គលជាស្ថានទីដុះដាលនៃបុណ្យរបស់សត្វទាំងឡាយដ៏កំពូល គឺឧត្តម ហេតុនោះ ទើបឈ្មោះថា **ជាបុញ្ញក្ខេត្តដ៏កំពូលរបស់លោក** ដែលពោលមកនេះ ជាការសង្ខេបក្នុងទីនេះ ។ ឯសេចក្តីពិស្តារ ខ្ញុំបានពោលហើយខាងដើមនោះឯង ។

ពាក្យថា **មកដោយវិបស្សនាដ៏ទន់** សេចក្តីថា ចម្រើនមគ្គប្បញ្ញាថ្នាក់ដំបូង ដោយអំណាចវិបស្សនាដែលមិនខ្លាំងក្លា មកកាន់ភាពជាព្រះសោតាបន្ន ។ **សូម្បីជាអ្នកមានឥន្ទ្រិយទន់ខ្សោយ** ដោយអំណាចឥន្ទ្រិយទាំងឡាយដ៏ទន់ មានសទ្ធាជាដើម ។ ពាក្យថា **សត្តក្ខត្តុបរម** អធិប្បាយថា ការចូលដល់ភព គឺការកាន់យកអត្តភាព មាន ៧ ដងយ៉ាងក្រៃលែង ព្រះសោតាបន្នណា រមែងមិនកាន់យកភពទី ៨ ក្រៃលែងជាងនោះ ហេតុនោះ ព្រះសោតាបន្ននោះ ឈ្មោះថា **សត្តក្ខត្តុបរម** ។ ពាក្យថា **អន្ទោលទៅ** គឺទៅកាន់ភពដទៃអំពីភពដទៃ ដោយអំណាចបដិសន្ធិ ។ ពាក្យថា **រមែងធ្វើទីបំផុតនៃទុក្ខបាន** គឺរមែងធ្វើទីបំផុតដោយជុំវិញ បានដល់ ការអស់នៃវដ្តទុក្ខបាន ។ ព្រះសោតាបន្នសត្តក្ខត្តុបរមប្រភេទនេះ លោកអាចារ្យពោលថា **អន្ទោលទៅក្នុងសុគតិភព ៧ ជាតិ** ដោយអំណាចភពដែលលាយឡំគ្នា គឺជួន កាលទេវលោក ជួនកាលមនុស្សលោក ។ ព្រះសោតាបន្នប្រភេទណា រមែងទៅ អំពីត្រកូលកាន់ត្រកូល ហេតុនោះ ព្រះសោតាបន្នប្រភេទនោះ ឈ្មោះថា **កោលំកោលៈ** ( ទៅអំពីត្រកូលកាន់ត្រកូល ) ។ ចាប់ផ្តើមអំពីការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា **ការកើតក្នុងត្រកូលទាប រមែងមិនមាន** អធិប្បាយថា ព្រះសោតាបន្ន រមែងកើតក្នុងត្រកូលខ្ពស់ មានភោគៈច្រើនតែម្យ៉ាង ។ ពាក្យថា **កាន់ត្រកូល ២-៣ ត្រកូល** សេចក្តីថា កាន់ភព ២-៣ ភព ដោយអំណាចជាទេវតា និងមនុស្ស ។ ព្រះសោតាបន្នកោលំកោលៈនេះ លោកពោលដោយអំណាចភពដែលលាយឡំគ្នានោះឯង ដោយប្រការដូច្នេះ ។ ឯពាក្យថា **២-៣ ត្រកូល** នេះ ត្រឹមតែជាទេសនាប៉ុណ្ណោះ ។ សូម្បីកាលអន្ទោលទៅរហូតដល់ភពទី ៦ ក៏ចាត់ថា ជាកោលំកោលៈនោះឯង ។ ពូជ គឺខន្ធមួយប៉ុណ្ណោះ ពោល គឺការកាន់យកអត្តភាព មានដល់ព្រះសោតាបន្ននេះ ហេតុនោះ ព្រះសោតាបន្នប្រភេទនេះ ឈ្មោះថា **ឯកពីជី** ( មានពូជមួយ ) ។ សូម្បីពាក្យថា **ញុំាងភពដែលជារបស់**

មនុស្ស នេះ ក៏ត្រឹមតែជាទេសនា ។ សូម្បីនឹងពោលថា **ញ៉ាំងគតិរបស់ទេវតាឲ្យកើត** ក៏គួរដូចគ្នា ។ សួរថា នរណាកំណត់ប្រភេទរបស់ព្រះសោតាបន្ន ទាំងនេះ? ឆ្លើយថា វិបស្សនានៃមគ្គទាំង ៣ ថ្នាក់កំណត់ ។ បើវិបស្សនានៃមគ្គ ទាំង ៣ ខាងលើជាធម្មជាតិមានកម្លាំង ព្រះសោតាបន្នក៏ឈ្មោះថា **ជាឯកពីជី** ។ ព្រះសោតាបន្នជា **កោលំកោលៈ** ដោយវិបស្សនាដែលទន់ជាងនោះ ជា **សត្តក្ខត្តុបរម** ដោយវិបស្សនាដែលទន់ក្រៃលែងជាងនោះ ។

ព្រះអរិយបុគ្គលប្រភេទណា រមែងមកម្ដង ដោយអំណាចការបដិសន្ធិ ហេតុនោះ ព្រះអរិយបុគ្គលប្រភេទនោះ ឈ្មោះថា **សកទាគាមី** (មកម្ដងទៀត) ។ ពាក្យថា **ម្ដងទៀតប៉ុណ្ណោះ** គឺមួយវារៈទៀតប៉ុណ្ណោះ ។ ដោយពាក្យថា **មកកាន់លោកនេះ** លោកវៀរព្រះសកទាគាមី ៤ ប្រភេទ ក្នុងបណ្ដាព្រះសកទាគាមី ៥ ប្រភេទ ហើយកាន់យកតែប្រភេទមួយប៉ុណ្ណោះ ។ ពិតហើយ ព្រះសកទាគាមី ប្រភេទសម្រេចសកទាគាមិផលក្នុងលោកនេះហើយ បរិនិព្វានក្នុងលោកនេះឯង ។ ប្រភេទសម្រេចក្នុងលោកនេះហើយ បរិនិព្វានក្នុងទេវលោក ប្រភេទខ្លះសម្រេចក្នុងទេវតា បរិនិព្វានក្នុងទេវលោកនោះឯង ប្រភេទខ្លះសម្រេចក្នុងទេវលោក កើតក្នុងមនុស្សលោកនេះទើបបរិនិព្វាន ។ ព្រះសកទាគាមីទាំង ៤ ប្រភេទនេះ មិនបានកាន់យកក្នុងទីនេះ ។ ព្រះសកទាគាមីប្រភេទណា សម្រេចក្នុងមនុស្សលោកនេះ ហើយនៅរហូតអស់អាយុក្នុងទេវលោក ហើយត្រឡប់មកកើតក្នុងមនុស្សលោកនេះទៀត ទើបបរិនិព្វាន ព្រះសកទាគាមីប្រភេទនេះ លោកកាន់យកក្នុងទីនេះ ។

ព្រះអរិយបុគ្គលឈ្មោះថា **អនាគាមី** ព្រោះមិនមកក្នុងលោកនេះ ដោយអំណាចបដិសន្ធិ ។ ពាក្យថា **ដោយអំណាចការផ្សេងនៃឥន្ទ្រិយ** គឺដោយការតិច និងច្រើននៃឥន្ទ្រិយ ដែលបន្ទុំវិមុត្តិ មានសទ្ធាជាដើម ។ ពាក្យថា **រមែងជាបុគ្គលលះអត្តភាព**

ក្នុងលោកនេះទៅហើយ ដោយប្រការ ៥ ទើបសម្រេច សេចក្តីថា ព្រះអនាគាមីនោះរមែងជាអ្នកលះលោកនេះ ដោយប្រការទាំង ៥ ជាប្រភេទ អន្តរាបរិនិព្វាយីជាដើម ហើយទើបបរិនិព្វាន ។ ព្រះអនាគាមីឈ្មោះថា **អន្តរាបរិនិព្វាយី** ព្រោះបរិនិព្វានដោយកិលេស បរិនិព្វានក្នុងរវាងពាក់កណ្តាលអាយុនោះឯង ។ ម្យ៉ាងទៀត ពាក្យថា **ឧបហច្ច** ប្រែថា ចូលទៅធ្វើកាល ។ ពាក្យថា **ដោយមិនចាំបាច់ប្រកបសេចក្តីព្យាយាមពេក** សេចក្តីថា ដោយវៀរចាកការប្រកបសេចក្តីព្យាយាម ដែលមានប្រមាណក្រៃលែង មានសេចក្តីលំបាកត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះនោះឯង ព្រោះជាបុគ្គលមានឥន្ទ្រិយចាស់ក្លា ។ ក្នុងពាក្យថា **ដោយត្រូវប្រកបសេចក្តីព្យាយាមខ្លាំងក្លា** នេះ ក៏គប្បីជ្រាបអត្ថតាមបរិយាយផ្ទុយអំពីដែលពោលហើយ ។ ព្រះអនាគាមីឈ្មោះ **ឧទ្ធំសោតោ** ព្រោះអត្ថថា មានក្រសែ គឺតណ្ហា ឬក្រសែ គឺវដ្ដៈ ក្នុងខាងលើ ព្រោះភាវៈដែលនាំទៅខាងលើ ។ ម្យ៉ាងទៀត ឈ្មោះថា **ឧទ្ធំសោតោ** ព្រោះអត្ថថា មានក្រសែ គឺមគ្គក្នុងខាងលើ ព្រោះត្រូវទៅខាងលើ ហើយទើបបានចំពោះ ។ ឈ្មោះថា **អកនិដ្ឋគាមី** ព្រោះអត្ថថា ទៅកាន់អកនិដ្ឋកភព ដោយអំណាចបដិសន្ធិ ។

បទថា **យត្ថុប្បន្នោ** សេចក្តីថា កើតក្នុងភពណាមួយ ក្នុងបណ្តាភពទាំងឡាយមានអវិហាជាដើម ។ ដើម្បីការយល់ប្រភេទរបស់ព្រះអនាគាមីទាំងនេះ គប្បីជ្រាបព្រះឧទ្ធំសោតអកនិដ្ឋគាមីទាំង ៤ ប្រភេទទុក ។

គឺព្រះអនាគាមីប្រភេទណា ញុំាងទេវលោកទាំង ៤ ជាន់ គឺអវិហាទៅឲ្យបរិសុទ្ធ ហើយទៅកាន់អកនិដ្ឋកភព ហើយបរិនិព្វាន ព្រះអនាគាមីប្រភេទនេះ ឈ្មោះថា **ឧទ្ធំសោតអកនិដ្ឋគាមី** ប្រែថា បុគ្គលមានខ្សែក្នុងខាងលើ ទៅកាន់អកនិដ្ឋកភព ។ ចំណែកព្រះអនាគាមីប្រភេទណា ញុំាងទេវលោក ៣ ជាន់ដែលទាបឲ្យបរិសុទ្ធ ហើយតាំងនៅក្នុងទេវលោកជាន់សុទស្សី ហើយបរិនិព្វាន ព្រះអនាគាមី ប្រភេទនេះ ឈ្មោះ

ថា **ឧទ្ធំសោតនអកនិដ្ឋគាមី** ប្រែថា បុគ្គលមានខ្សែក្នុងខាងលើ មិនទៅកាន់អកនិដ្ឋកភព ។ ព្រះអនាគាមីប្រភេទណា ទៅកាន់អកនិដ្ឋកភពតែម្តង អំពីមនុស្សលោកនេះ ហើយបរិនិព្វាន ព្រះអនាគាមីប្រភេទនេះ ឈ្មោះថា **នឧទ្ធំសោតនអកនិដ្ឋគាមី** ប្រែថា មិនមានខ្សែក្នុងខាងលើទៅកាន់អកនិដ្ឋកភព ។ ចំណែកព្រះអនាគាមីប្រភេទណា បរិនិព្វានក្នុងទេវលោកនោះៗ ឯង ក្នុងបណ្តាទេវលោក ទាំង ៤ ជាន់ខាងក្រោម ព្រះអនាគាមីប្រភេទនេះ ឈ្មោះថា **នឧទ្ធំសោតនអកនិដ្ឋគាមី** ប្រែថា មិនមានខ្សែក្នុងខាងលើ មិនទៅកាន់អកនិដ្ឋកភព ។ ឯព្រះអនាគាមី ទាំងនេះ ចាត់ជា ៥ គឺជាអន្តរាបរិនិព្វាយី ៣ ប្រភេទ ដោយអំណាចមិនទាន់ដល់ពាក់កណ្តាលអាយុ និងដល់ហើយក្នុងលំដាប់ដែលកើតឡើងក្នុងជាន់អវិហា ហើយបរិនិព្វានជាឧបហច្ចបរិនិព្វាយីមួយប្រភេទ ជាឧទ្ធំសោតមួយប្រភេទ ។ ទាំង ៥ ប្រភេទនោះ ចាត់ជា ១០ ដោយចែកជាអសង្ខារបរិនិព្វាយី និងសសង្ខារបរិនិព្វាយី ។

ក្នុងជាន់អតប្បា សុទស្សា សុទស្សី ក៏ដូចគ្នា ទើបរួមជា ១០ ប្រភេទ ៤ ជាន់ ចាត់ជា ៤០ ប្រភេទ ។ ចំណែកក្នុងអកនិដ្ឋកភព មិនមានព្រះអនាគាមី ប្រភេទឧទ្ធំសោត ។ ព្រះអនាគាមីអន្តរាបរិនិព្វាយី ៣ ប្រភេទ ឧបហច្ចបរិនិព្វាយី ១ ប្រភេទ រួមជា ៤ ប្រភេទ ។ ព្រះអនាគាមីទាំង ៤ ប្រភេទនោះ ចាត់ជា ៨ ដោយចែកជាអសង្ខារបរិនិព្វាយី និងសសង្ខារបរិនិព្វាយី ដូច្នោះ ទើបរួមជាព្រះអនាគាមី ៤៨ ប្រភេទ ។

ចំណែកព្រះសោតាបន្នទាំងឡាយ ពោលដោយប្រភេទបដិបទា ជាសត្តក្ខត្តុបរម ៤ ប្រភេទ ជាកោលំកោល: ៤ ប្រភេទ ជាឯកពីជី ៤ ប្រភេទ រួមជាអ្នកបដិបត្តិដោយសទ្ធាធុរ: ១២ ប្រភេទ ដោយបញ្ញាធុរៈក៏ ១២ ប្រភេទដូចគ្នា ដូច្នោះ ទើបរួមព្រះសោតាបន្នបាន ២៤ ប្រភេទ ។

ព្រះសកទាគាមីទាំងឡាយ ចាត់ជា ៤ ប្រភេទ ដោយអំណាចបដិបទាដែលរួចផុតបាន ដោយសុញ្ញតវិមោក្ខ ចាត់មួយៗ ជា ៤ ដូចគ្នា ដោយអំណាចបដិបទាដែលរួចផុតបាន ដោយអនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ដូច្នោះ ទើបរួមបាន ជា ១២ ប្រភេទ ។

ព្រះអរហន្តទាំងឡាយ ក៏យ៉ាងនោះ ។ ព្រះអរហន្តទាំងនោះ ប្រភេទបញ្ញាវិមុត្តិ ( រួចផុតដោយបញ្ញា ) មាន ១២, ប្រភេទ **ឧភតោភាគវិមុត្តិ** ( រួចផុត ដោយចំណែកទាំង ២ ) មាន ១២, ប្រភេទ **តេវិជ្ជ** មាន ១២, ប្រភេទ **ឆឡភិញ្ញ** មាន ១២, ប្រភេទ **បដិសម្ភិទប្បត្ត** មាន ១២ ដូច្នោះ ទើបរួមជា ៦០ ។ ព្រះអរិយបុគ្គលទាំងនេះ រួមគ្នាជាមួយព្រះបច្ចេកពុទ្ធ និងព្រះសម្មាសម្ពុទ្ធ ក៏ជាព្រះអរិយៈ ១៤៦ ប្រភេទ ។ ព្រោះការសម្រេចជាអរិយគុណរបស់ព្រះអរិយៈទាំងនោះ ក៏ដោយការចម្រើនអរិយប្បញ្ញា ដោយហេតុនោះ ទើបលោកអាចារ្យពោលថា ការសម្រេចនៃភាពជាអរិយបុគ្គល មានអាហុនេយ្យបុគ្គលជាដើម ក៏ជាអានិសង្សរបស់លោកុត្តរ-ប្បញ្ញាភាវនានេះ ។ ព្រះអរហន្តប្រភេទឧភតោភាគវិមុត្តិ សូម្បីវៀរចាកវិជ្ជា និងអភិញ្ញា ដែលជាលោកិយ ក៏រមែងមានបាន ព្រោះហេតុនោះ ទើបព្រះអរហន្តប្រភេទឧភតោ-ភាគវិមុត្តិ លោកកាន់យកមួយផ្នែក ។ ពាក្យថា **ដែលខ្ញុំសំដៅដល់ពោលទុក** សេចក្តីថា លោកអាចារ្យសំដៅការចម្រើន មគ្គប្បញ្ញាថ្នាក់ទី ៤ ណា ពោលទុកក្នុងការពណ៌នាគាថា ដោយបទ្រព្យក្នុងខាងដើម ក៏ដើម្បីសម្តែងការចម្រើនមគ្គប្បញ្ញាថ្នាក់ទី ៤ នោះ ដែលមានអាការបានពោលហើយ ដោយអំណាចពាក្យនិគម ទើបលោកអាចារ្យពោលថា **ក្នុងខណៈនៃមគ្គ** ដូច្នេះជាដើម ។ ភិក្ខុឈ្មោះថា កំពុងគ្រារជដៈនោះក្នុងខណៈនៃមគ្គទាំង ៤ ជាបុគ្គលមានជដៈគ្រារបានហើយតាមគួរ សូម្បីក្នុងខណៈនៃផល ក៏ពិតសូម្បីយ៉ាងនោះ ក្នុងខណៈនៃអគ្គផលនោះឯង ឈ្មោះថា មានជដៈគ្រារបានហើយ

ដោយប្រការទាំងពួង ព្រោះមិនមានជជះដែលត្រូវធ្ការក្រៃលែងជាងនោះ ។ ដោយហេតុនោះ អត្ថ ទាក់ទងជាមួយការចម្រើនមគ្គប្បញ្ញាលំដាប់ទី ៤ បានពោលហើយ ព្រោះបានពោលអានិសង្សនៃការចម្រើនមគ្គប្បញ្ញាថ្នាក់ទាបខាងដើម ក្នុងទីនេះឯង ។

ពាក្យថា **សេចក្តីត្រេកអរ** បានដល់ សេចក្តីត្រេកអរក្រៃលែង អធិប្បាយថា ការពេញចិត្តក្រៃលែង ។ បទថា **តត្ថ យោគ អរិយាយ បញ្ញាភាវនាយ** ប្រែថា ក្នុងការចម្រើនបញ្ញាដែលជាអរិយៈនោះ ។

ពីរបទថា **ឥមិស្សា គាថាយ** ប្រែថា ក្នុងគាថានេះ ។ សេចក្តីពិត គាថាលោកអាចារ្យបានពោលទុកដោយភាវៈ ជាអាធាររបស់វិសុទ្ធិមគ្គ ដែលជាអត្ថនៃខ្ទួនម្យ៉ាងទៀត ពីរបទនេះ ជាឆដ្ឋីវិភត្តិ ព្រោះ **អត្ថ** មានការសម្ពន្ធជាគាថានោះ ។

ពណ៌នាបញ្ញាភាវនានិសង្សនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ២៣ ចប់

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## គាថាចុងបករណ៍នៃវិសុទ្ធិមគ្គ

ខ្ញុំតាំងគាថានេះ គឺ

សីលេ បតិដ្ឋាយ នរោ សប្បញ្ញោ ។បេ។ សោ ឥមំ វិជដយេ ជដំ ទុកហើយ បានពោលពាក្យណាទុកថា

ឥឡូវនេះ ខ្ញុំកាលពណ៌នាអត្ថដែលផ្សេងដោយគុណ មានសីលជាដើម ក្នុងគាថានេះ ភិក្ខុអ្នកស្វែងរកគុណធំ សម្តែងទុកតាមសេចក្តីពិត ( គឺតាមត្រឹមត្រូវ ) នឹងពោលវិសុទ្ធិមគ្គដែលអាស្រ័យន័យ នៃទេសនារបស់ព្រះថេរៈខាងមហាវិហារទាំងឡាយ ដែលមានវិនិច្ឆ័យដ៏បរិសុទ្ធល្អ ជាគ្រឿងបណ្តុះបាមោជ្ជដល់ពួកព្រះយោគីក្នុងព្រះធម្មវិន័យនេះ ដែលបានបព្វជ្ជាក្នុងសាសនាព្រះជិនស្រី ដ៏លំបាកក្រៃលែងដែលបានហើយ កាលមិនដឹងវិសុទ្ធិមគ្គដ៏ត្រង់ ដ៏ក្សេម ដែលរួបរួមគុណ មានសីលជាដើមទុក តាមសេចក្តីពិត សូម្បីប្រាថ្នាសេចក្តីបរិសុទ្ធ សូម្បីកំពុងព្យាយាម ក៏រមែងមិនសម្រេចដល់វិសុទ្ធិបាន ។ ហៃ សាធុជនទាំងឡាយ កាលខ្ញុំពោលវិសុទ្ធិមគ្គ ដោយគោរព សូមអ្នកទាំងឡាយទាំងពួង ដែលប្រាថ្នាវិសុទ្ធិ ចូរតាំងចិត្តស្តាប់វិសុទ្ធិមគ្គនោះដោយគោរពហោង ដូច្នេះ ។

វិសុទ្ធិមគ្គដែលខ្ញុំនឹងប្តេជ្ញាថា នឹងពោលក្នុងពាក្យនេះ គឺខ្ញុំព្រះអង្គបានពោលហើយ ដោយអត្ថពណ៌នាត្រឹមប៉ុណ្ណេះឯង ក្នុងវិសុទ្ធិមគ្គនោះ ។

វិនិច្ឆ័យនៃអត្ថទាំងឡាយ ដែលផ្សេងដោយគុណ មានសីលជាដើមទាំងនោះ ជាវិនិច្ឆ័យដែលលោកពោលទុកក្នុងអដ្ឋកថានៃ នៃនិកាយទាំង ៥ វិនិច្ឆ័យនោះផុតចាកទោស គឺការលាយឡំ និងវាទៈនៃនិកាយដទៃទាំងអស់ ខ្ញុំនាំយកវិនិច្ឆ័យ

ទាំងពួងនោះ មកប្រកាសទុកជាចំណែកច្រើន ហេតុណា ព្រោះហេតុនោះ សេចក្តីអើពើក្នុងវិសុទ្ធិមគ្គនោះ ព្រះយោគីទាំងឡាយ ដែលមានបញ្ញាបរិសុទ្ធ ប្រាថ្នាវិសុទ្ធិ ទើបគួរធ្វើពិត ដូច្នេះ ។

## ឧទ្ទិសកុសល

គំនរបុណ្យឯណា ដែលខ្ញុំប្រាថ្នាការតាំងនៅនៃព្រះសទ្ធម្ម បានទទួលនិមន្តរបស់លោកម្ចាស់សង្ឃបាល ដែលកើតក្នុងវង្សគណៈភិក្ខុមហាវិហារ ដែលជាចំណែកថេរវាទ មានកេរ្តិ៍ឈ្មោះជាវិភជ្ជវាទីប្រសើរបំផុត ជាព្រះមហាថេរៈដ៏រុងរឿង មានការប្រព្រឹត្តស្អាត ជាសល្លេខ ដល់ព្រមដោយវិន័យ និងអាចារៈ ប្រកប ( សេចក្តីព្យាយាម ) ក្នុងការបដិបត្តិ មានចិត្តប្រដាប់ ដោយគុណ មានខន្តិសោរច្ចៈ និងមេត្តាជាដើម ហើយធ្វើបករណ៍វិសុទ្ធិមគ្គនេះឡើង បានទទួលហើយ ។ ដោយតេជះនៃគំនរបុណ្យនោះ សូមសត្វទាំងឡាយ ទាំងពួង ដល់នូវសេចក្តីសុខចុះ បករណ៍វិសុទ្ធិមគ្គនេះឯង ចប់ដោយព្រះបាលី ៥៨ ភាណវារ វៀរបង់នូវអន្តរាយក្នុងទីនេះឯណា សូមមនោរថទាំងឡាយ ដែលដល់នូវភាពផូរផង់គ្រប់យ៉ាង របស់សត្វលោក ចូររួចចាកអន្តរាយ សម្រេចដោយរួសរាន់ ដូច្នោះ ដូចគ្នាហោង ។

បករណ៍វិសុទ្ធិមគ្គ ចប់ហើយ

# មហាដីកា

## កថាពណ៌នាគាថាចុងបករណ៍

*អត្ថនៃគាថាទាំងឡាយ មានពាក្យថា* ***ឥមិស្សាទានិ គាថាយ*** *ខ្ញុំបានពោលហើយក្នុងខាងដើមនោះឯង ។ ភ្ជាប់សេចក្តីថា វិសុទ្ធិមគ្គដែលខ្ញុំបានប្តេជ្ញាទុកថា* ***ខ្ញុំនឹងពោលវិសុទ្ធិមគ្គ*** *ដូច្នេះនេះ ដែលខ្ញុំបានពោលហើយ ដោយលំដាប់នៃពាក្យត្រឹមប៉ុណ្ណេះ ។*

*ក្នុងបទទាំងឡាយ មានបទថា* ***តត្ថ*** *ជាដើម មានសេចក្តីសង្ខេបព្រមជាមួយការភ្ជាប់បទដូចតទៅនេះ*

*ព្រោះ* ***វិនិច្ឆ័យនៃអត្ថទាំងឡាយ*** *ដែលផ្សេងដោយគុណ មានសីលជាដើម ដែលព្រះមានព្រះភាគត្រាស់ក្នុងព្រះគាថាថា* ***សីលេ បតិដ្ឋាយ*** *នោះ ជាវិនិច្ឆ័យដែល* ***លោកពោលក្នុងអដ្ឋកថាន័យ*** *គឺក្នុងបែបផែននៃអដ្ឋកថា* ***នៃនិកាយធំទាំង ៥*** *ក្នុងទីនោះៗ ។* ***វិនិច្ឆ័យនោះ*** *ផុតចាកការលាយឡំដោយទោស គឺវាទៈនៃនិកាយរបស់និកាយដទៃ ខ្ញុំនឹង* ***រួបរួម*** *គឺនាំយកវិនិច្ឆ័យ* ***ទាំងអស់នោះ ដោយច្រើនមកប្រកាសទុក ដូច្នោះ ការអើពើក្នុងវិសុទ្ធិមគ្គនោះ ដែលព្រះយោគីទាំងឡាយ ប្រាថ្នាវិសុទ្ធិ គួរធ្វើ*** *ដូច្នេះ ។*

## គាថាចុងបករណ៍នៃបរមត្ថមញ្ជូសា

***ព្រះពុទ្ធឃោសាចារ្យ*** *ជាអ្នកស្វែងរកនូវគុណដ៏ធំ មានសមាចារបរិសុទ្ធដោយល្អ មានចិត្តដែលជាកម្ទាំងនៃករុណាឲ្យឧស្សាហ៍ល្អហើយ មានការបែកធ្លាយនៃបញ្ញាដ៏បរិបូណ៌ឱឡារិក និងបរិសុទ្ធ បានភាសិត* ***វិសុទ្ធិមគ្គ*** *ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធណា ដើម្បីសេចក្តីបរិសុទ្ធពិតប្រាកដដល់លោក ។* ***ការពណ៌នាអត្ថ*** *ឯណា*

ដែលខ្ញុំត្រូវព្រះថេរៈមាននាមថា **ទាឋនាគ** ដែលមានអចារៈដ៏បរិសុទ្ធ មានបញ្ញា ជាអ្នកស្នាក់នៅក្នុងបរិវេណនៃសិទ្ធគាម បានអារាធនាហើយ បានអាស្រ័យកថាមគ្គ ដែលមានមកអំពីមុន ប្រារព្ធដោយល្អ ដើម្បីប្រកាសអត្ថនៃគម្ពីរ **វិសុទ្ធិមគ្គ** នោះ ។ **ការពណ៌នាអត្ថ** នេះ ដោយឈ្មោះ ឈ្មោះថា **បរមត្ថមញ្ជូសា** ព្រោះផ្ទុកបរមត្ថធម៌ ទុកក្នុងទីនោះៗ តាមគួរ ។ មានវិនិច្ឆ័យមិនរាត់រាយ ដល់នូវការសម្រេចដោយជុំវិញ ដោយព្រះបាលីប្រមាណ ៨៨ ភាណវារ ។ បុណ្យនោះ ដែលខ្ញុំរចនាពណ៌នាអត្ថនោះ បានទទួលហើយ ដោយអានុភាពនៃបុណ្យនោះ សូមសព្វសត្វទាំងឡាយ ឈមចុះ ក្នុងព្រះសាសនា របស់ព្រះលោកនាថ ដោយការបដិបត្តិសីលគុណជាដើមដ៏បរិសុទ្ធ ចូរជាអ្នកមានចំណែកនៃវិមុត្តិរស ។ សូមព្រះសាសនារបស់ព្រះសម្ពុទ្ធ តាំងនៅក្នុង លោកអស់កាលយូរ សូមសព្វសត្វទាំងឡាយ មានសេចក្ដីគោរពក្នុងព្រះសាសនា របស់ព្រះសម្មាសម្ពុទ្ធនោះ ជានិរន្តរ សូមភ្លៀង ធ្លាក់ត្រូវតាមរដូវកាល សូមព្រះរាជា ដែលជាធំក្នុងផែនដី ជាអ្នកត្រេកអរជានិច្ច ក្នុងព្រះសទ្ធម្ម ចូរគ្រប់គ្រងលោកដោយ ធម៌ហោង ។

វិសុទ្ធិមគ្គមហាដីកា ឈ្មោះ បរមត្ថមញ្ជូសា

អាចារ្យធម្មបាល សម្នាក់ពទរតិត្ថវិហារ រចនាហើយ

ចប់ បរិបូណ៌ ។

# វិសុទ្ធិមគ្គ

## ពាក្យអធិដ្ឋាន

## គុណសម្បត្តិរបស់ព្រះពុទ្ធឃោសៈ ១១ ប្រការ

*សូមបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ ដែលព្រះថេរៈគួរនឹងហៅ ( ទាមតាមសីហឡភាសា ) ថា មុរណ្ឌខេដកៈ មាននាម គេយ្យ ដែលគ្រូទាំងឡាយតាំងឲ្យថា ពុទ្ធឃោសៈ ដែល ( ប្រកបដោយគុណសម្បត្តិ ) គឺ*

*១- បរមសុទ្ធ សទ្ធា ពុទ្ធិ វីរិយបដិមណ្ឌិតេន ប្រដាប់ដោយសទ្ធា ពុទ្ធិ និងវីរិយៈ ដែលបរិសុទ្ធក្រៃលែង ។*

*២- សីលាចារជ្ជវមទ្ទវាទិគុណសមុទយសមុទិតេន ប្រាកដដោយគុណសមុទយៈ មានសីល អាចារៈ និងអាជ្ជវៈ មទ្ទវៈជាដើម ។*

*៣- សកសមយ សមយន្តរ គហនជ្ឈោគាហណ សមត្ថេន អាចក្នុងការឈមចុះកាន់ព្រៃស្តុក ( គឺដោះស្រាយប្រស្នាដែលលំបាក ) បានទាំងក្នុងលទ្ធិរបស់ខ្លួន និងក្នុងលទ្ធិដទៃ ។*

*៤- បញ្ញាវេយ្យត្តិយសមន្នាគតេន ប្រកបព្រមទៅដោយការក្លៀវក្លាងនៃបញ្ញា*

*៥- តិបិដកបរិយត្តិប្បភេទេ សាដ្ឋកថេ សត្ថុ សាសនេ អប្បដិហតញាណប្បភេទ មានអំណាចនៃញាណដែលមិនទើសទាក់ក្នុងសត្ថុសាសនាប្រភេទបរិយត្តិ គឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ។*

*៦- មហាវេយ្យាករណេន ជាអ្នកវេយ្យាករណ៍ធំ ។*

*៧- ករណសម្បត្តិជនិតសុខវិនិគ្គតមធុរោទារវចនលាវណ្ណយុត្តេន ប្រកប*

ដោយភាពស្អាតនៃពាក្យសម្ដីដ៏ពីរោះ ដ៏លើស ដែលការដល់ព្រមនៃករណៈ ( គឺគ្រឿងធ្វើសំឡេង ) ធ្វើឲ្យសំនៀងបន្លឺចេញមកបានស្អាត់ ។

៨- យុត្តមុត្តភាទិនា ភាទីវរេន ជាអ្នកនិយាយជាន់ខ្ពស់ និយាយបានទាំងចងទាំងដោះស្រាយ ។

៩- មហាកវិនា ជាមហាកវី ។

១០- បភិន្នបដិសម្ភិទាបរិវារេ ឆឡភិញ្ញាទិភេទគុណបដិមណ្ឌិតេ ឧត្តរិមនុស្សធម្មេ អប្បដិហតពុទ្ធិនំ ថេរវំសប្បទីបានំ ថេរានំ មហាវិហារវាសីនំ វំសាលង្ការភូតេន ជាអលង្ការនៃវង្សរបស់ពួកព្រះថេរៈមហាវិហារ ដែលជាប្រទីបនៃថេរវង្ស មានការដឹងមិនទើសទាក់ ក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ទៅដោយគុណផ្សេៗ មាន អភិញ្ញា ៦ ជាដើម មានបដិសម្ភិទាបែកធ្លាយជាបរិវារ ។

១១- វិបុលវិសុទ្ធពុទ្ធិនា មានការដឹងបរិសុទ្ធ ទូលំទូលាយ ធ្វើទុកហើយ ។

ចូរតាំងនៅក្នុងលោក សម្ដែងន័យ នៃវិសុទ្ធិ មានសីលជាដើមដល់កុលបុត្រទាំងឡាយ ដែលស្វែងរកធម៌ ជាគ្រឿងរលាស់ខ្លួនចេញចាកលោក ទៅដរាបប៉ុនដែលថ្វាយព្រះនាមថា ពុទ្ធោ របស់អង្គព្រះលោកជេដ្ឋមហាឥសី ដែលមានព្រះហឫទ័យបរិសុទ្ធ មិនញាប់ញ័រ នៅប្រព្រឹត្តទៅក្នុងលោកហោង ។

# ប្រវត្តិព្រះពុទ្ធឃោសៈ

កាល ( ពុទ្ធសាសនាយុកាល ) រាប់អំពីកាលបរិនិព្វាននៃព្រះមានព្រះភាគកន្លងទៅហើយ ៩៥៦ ព្រះវស្សា ព្រះរាជាទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យក្នុង លង្កាទ្វីប ។ បានឮមកថា ក្នុងសម័យនោះ មានព្រាហ្មណ៍កំលោះម្នាក់ កើតក្នុងត្រកូលព្រាហ្មណ៍មួយ ក្នុងទីជិត ពោធិមណ្ឌល ( ទីត្រាស់ដឹង ) ក្នុង មជ្ឈិមប្រទេស

នាជម្ពូទ្វីប ។ មាណពនោះជំនាញក្នុងសិល្បៈទាំងពួង ចប់ត្រៃវេទ ត្រាច់ទៅរហូតតាមជនបទ និគម រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។ សមណព្រាហ្មណ៍ដែលជាបណ្ឌិតនៅក្នុងទីណាមួយ ក៏ទៅធ្វើសាកច្ឆាក្នុងទីនោះ បណ្ឌិតដទៃៗ មិនអាចពោលដោះស្រាយបញ្ហា ដែលមាណពនោះសួរបាន តែមាណពនោះដោះស្រាយបញ្ហា ដែលបណ្ឌិតដទៃៗសួរបាន ។ មាណពនោះគ្រប់គ្រងសកលជម្ពូទ្វីប ដោយអាការយ៉ាងនេះ រហូតមកដល់វិហារមួយកន្លែង ( អាស្រ័យស្នាក់នៅក្នុងបរិវេណវិហារនោះ ) ។

ក្នុងវិហារនោះ មានភិក្ខុនៅច្រើនរយអង្គ ។ ព្រះថេរៈ **រេវតសង្ឃត្ថេរ** របស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានបដិសម្ភិទា ( អាច ) ញ៉ាំញីបរប្បវាទបាន ។ កាលនោះពេលកណ្ដាលយប់ ព្រាហ្មណ៍កំលោះបរិវត្ត **បាតញ្ជលីមន្ត** ឲ្យមានបទដ៏សម្បូរ និងជាបរិមណ្ឌល ។ ព្រះថេរៈស្ដាប់សំឡេងព្រាហ្មណ៍ស្វាធ្យាយមន្ត ក៏ជ្រាបថា ព្រាហ្មណ៍ម្នាក់នេះមានបញ្ញាច្រើន គិតថា ទូន្មាន ( គឺសង្កត់ និងទាញឲ្យមក រាប់អានព្រះសាសនា ) បាន នឹងជាការល្អ ទើបហៅព្រាហ្មណ៍នោះមកសួរពើឡើង ថា **ព្រាហ្មណ៍ ! នរណាហ្នឹ៎ ស្រែកជាសំឡេងលា** ព្រាហ្មណ៍សួរថា **បព្វជិតដ៏ចម្រើន ! លោកម្ចាស់ដឹងសំឡេងស្រែករបស់ពួកលាឬ ?** ព្រះថេរៈទទួលថា **ដឹង** ទើបព្រាហ្មណ៍នោះសួរព្រះថេរៈក្នុង **គណ្ឋិឋាន** ( គឺប្រស្នាដែលជំពាក់ស្មុគស្មាញ ) ទាំងឡាយ ក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសៈ ជាគម្ពីរទី ៥ ដែលខ្លួនឯងសម្រឹង មិនឃើញអត្ថឡើយ ទាំងអាចារ្យរបស់ខ្លួនក៏មិនឃើញមកហើយដែរ ។ ឯព្រះថេរៈ ដោយប្រក្រតីក៏ជាអ្នកចប់ត្រៃវេទស្រេចហើយ សមឥឡូវនេះ មកបានបដិសម្ភិទា ថែមទៀតនោះ ហេតុនោះ ភារៈក្នុងការដោះស្រាយប្រស្នាទាំងនោះ ទើបមិនមានការលំបាកដល់លោកឡើយ ព្រោះដូច្នោះ ទើបលោកដោះស្រាយបញ្ហាទាំងនោះបានភ្លាមៗ ហើយ ពោលនឹងព្រាហ្មណ៍ថា **ព្រាហ្មណ៍ដ៏ចម្រើន ! អាត្មាត្រូវអ្នកសួរច្រើនហើយ ឥឡូវនឹងសួរបញ្ហា**

អ្នកត្រឹមប្រស្នា ១ អ្នកនឹងដោះស្រាយបញ្ហារបស់អាត្មាវិញទេ ? ព្រាហ្មណ៍ទទួលនឹងដោះស្រាយ និមន្តឲ្យសួរ ទើបព្រះថេរៈសួរបញ្ហាក្នុងគម្ពីរ ( យមកវគ្គ ) ចិត្តយមកៈថា យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ ចិត្តរបស់បុគ្គលណា កើតនៅមិនទាន់រលត់ ចិត្ត របស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឬ ឬក៏ថា ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត ចិត្តរបស់បុគ្គលនោះ កើតនៅមិនទាន់រលត់ឬ ? ជាដើម ។ ព្រាហ្មណ៍ កំលោះមិនអាចចាំ ( ប្រស្នា ) បាន មិនថាលើ ឬក្រោម ទើបសួរថា បព្វជិតដ៏ចម្រើន ! នេះឈ្មោះអ្វី ? ព្រះថេរៈប្រាប់ថា នេះឈ្មោះពុទ្ធមន្តណាព្រាហ្មណ៍ ព្រាហ្មណ៍សួរថា លោកម្ចាស់ដ៏ចម្រើន ឲ្យមន្តនេះដល់ខ្ញុំខ្លះបានឬទេ ? ព្រះថេរៈប្រាប់ថា ព្រាហ្មណ៍ ! អាត្មាឲ្យដល់បុគ្គលដែលកាន់ភេទបព្វជ្ជាដូចអាត្មា ទើបបាន ។ ទើបព្រាហ្មណ៍មាណពសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ។ ព្រះថេរៈឲ្យព្រាហ្មណ៍មាណពបព្វជ្ជាឧបសម្បទាហើយ ឲ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុអង្គនោះ ( តមក ) ក៏បានជាអ្នកប្រាកដក្នុងលោក ដោយនាមថា ពុទ្ធឃោសៈ ។

ព្រះពុទ្ធឃោសៈនោះ កាលនៅក្នុងវិហារនោះ បានរចនាបករណ៍ ឈ្មោះ ញាណោទយ ទុកក្នុងវិហារហើយ ផ្ដើមនឹងតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់តូច ឈ្មោះ អដ្ឋសាលិនី ។ ព្រះថេរៈឃើញដូច្នោះ ទើបពោលណែនាំថា នែ អាវុសោ ពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ ( គឺពាក្យដែលព្រះថេរៈយុគសម័យសង្គីតិពោលទុក ) មិនមានឡើយ តែអដ្ឋកថាក្នុងភាសាសីហឡៈដែលឡើងកាន់សង្គីតិទាំង ៣ ដង ដែលព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមធ្វើទុក ព្រះមហិន្ទ

ពិនិត្យមើលកថាមគ្គ ហើយតែងទុកដោយសីហឡភាសា នៅប្រព្រឹត្តទៅក្នុងសីហឡទ្វីប បើអ្នកទាំងឯសីហឡទ្វីបនោះ ពិនិត្យមើលឲ្យទូទៅ ហើយបរិវត្ត ( ប្រែ ) មកក្នុងមគធភាសាបាន អដ្ឋកថានោះ ក៏នឹងនាំប្រយោជន៍មកឲ្យដល់លោកទាំងពួង ។ កាលព្រះថេរៈណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈក៏កើតបីតិសោមនស្ស ថ្វាយបង្គំលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ ធ្វើដំណើរទៅដល់កំពង់ទូក ដោយលំដាប់ ឡើងទូកទៅជួបព្រះពុទ្ធទត្តត្ថេរ ត្រង់កណ្ដាលមហាសមុទ្របាន ពោលចរចាប្រាស្រ័យគ្នាហើយ ធ្វើដំណើរតទៅ ដល់កំពង់ក្រុងលង្កា ។ ក្នុងកាលនោះ **ព្រះបាទមហានាម** សោយរាជ្យក្នុងលង្កាទ្វីប ។ ព្រះពុទ្ធឃោសៈទៅជួបភិក្ខុសង្ឃក្នុងមហាវិហារ នាក្រុងអនុរាធបុរីហើយ ទើបទៅកាន់សម្នាក់ព្រះ **សង្ឃបាលត្ថេរ** ត្រង់ **មហាបធានឃរៈ** បានស្ដាប់ ( ជ្រាបសេចក្ដី ) **អដ្ឋកថាសីហឡភាសា** និងថេរវាទទាំងពួងហើយ ក៏កាត់សម្រេច ( ដាក់ចិត្តជឿថា ព្រះពុទ្ធាធិប្បាយរបស់អង្គព្រះធម្មសាមិសារៈ ) ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ សូមគម្ពីរដើម្បីធ្វើអដ្ឋកថាព្រះត្រៃបិដក ។

ដើម្បីសាកល្បងសមត្ថភាពរបស់លោក ទើបភិក្ខុសង្ឃឲ្យគាថា ២ បទ ហើយពោលថា **លោកម្ចាស់ចូរបង្ហាញសមត្ថភាពក្នុងគាថា ២ បទនេះ ខ្ញុំព្រះករុណាទាំងឡាយ បានឃើញសមត្ថភាពរបស់លោកម្ចាស់ហើយ នឹងប្រគល់គម្ពីរឲ្យទាំងអស់** ។ ព្រះពុទ្ធឃោសៈមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ បានរួបរួមរចនាបករណ៍ ឈ្មោះ **វិសុទ្ធិមគ្គ** ឡើង ។

គ្រានោះ ទេវតានឹងប្រកាសការមានថ្វីដៃរបស់លោកឲ្យប្រាកដទៅក្នុងមហាជន ទើបបណ្ដាលគម្ពីរច្បាប់ ( ដែលលោកសរសេរចប់ហើយ ) នោះ ឲ្យអន្តរធានទៅ ទើបលោកសរសេរឡើងជាថ្មីមួយចប់ទៀត ទេវតាក៏បណ្ដាលឲ្យអន្តរធានទៅម្ដងទៀត លោកក៏សរសេរឡើងទៀត ជាគ្រាទី ៣ ( លុះស្រេចហើយ ) ទេវតាក៏នាំគម្ពីរ ២

ចប់នោះ មកប្រគេនក្នុងខណៈនោះ ទើបកើតជាគម្ពីរ ( វិសុទ្ធិមគ្គ ) ៣ ចប់ឡើង ក្នុងគ្រានោះ ។ ព្រះពុទ្ធឃោសៈប្រគល់គម្ពីរទាំង ៣ ចប់ ដល់ភិក្ខុសង្ឃ ភិក្ខុសង្ឃ ឲ្យអានគម្ពីរទាំង ៣ ចប់ ព្រមគ្នា ការខុសឃ្លៀងឃ្លាតក្នុងគម្ពីរ ៣ ចប់នោះ ដោយគណ្ឋៈ ( មាតិកា ) ក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយកេណ្ឌមុនក្រោយក្តី ដោយវាទៈទាំងឡាយ មានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើសម្រេចយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នា ធ្វើសាធុការ ។ សម័យនោះ ភិក្ខុច្រើនពាន់ប្រជុំគ្នានៅក្នុងមហាវិហារ ឃើញភាពមហស្ចារ្យនោះហើយ គ្រប់អង្គក៏សរសើរ ឲ្យសាធុការ ប្រកាសប្រាប់គ្នាតៗ ទៅថា **នេះព្រះពោធិសត្វមេត្តេយ្យមក ( កើត ) មិនចាំបាច់សង្ស័យ** ។

ចំណែកព្រះរាជាទ្រង់បានព្រះសណ្តាប់ដំណឹងនោះ ក៏ព្រមដោយរាជបរិវារ ទ្រង់ចេញអំពីព្រះនគរ ទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តភិក្ខាហារក្នុងព្រះរាជវាំងជាប្រចាំ ទម្រាំការរចនាគម្ពីរព្រះធម៌នឹងសម្រេច លោកក៏ទទួលនិមន្តដោយតុណ្ហីភាព ។

ភិក្ខុសង្ឃឃើញសមត្ថភាពរបស់លោកហើយ ទើបប្រគល់គម្ពីរព្រះត្រៃបិដកបាលី ព្រមទាំង **គម្ពីរអដ្ឋកថាសីហឡ** ឲ្យលោក ។ លោកទទួលយកគម្ពីរទាំងអស់ទៅស្នាក់នៅឯប្រាសាទមួយ ឈ្មោះថា **បធានឃរៈ** នាទិសទក្សិណនៃមហាវិហារ **បរិវត្តអដ្ឋកថាសីហឡ** ទាំងអស់ ធ្វើជាអដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈដែលជាមូល ភាសា ( គឺភាសាដើម ) ។

អដ្ឋកថាសីហឡនោះ មាន ៣ ភាគ គឺ **មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១** ។

អដ្ឋកថាដែលបានឡើងកាន់មហាសង្គីតិ ព្រះមហិន្ទនាំមករចនាទុកក្នុងសីហឡភាសា ឈ្មោះថា **មហាអដ្ឋកថា** ។

ផ្ទះលើទឹក មាន ១ ខ្នង ឈ្មោះក្នុងសីហឡភាសា ហៅថា **បច្ចរិយអដ្ឋកថា** ដែលការកកិក្ខុគង់ប្រជុំគ្នាធ្វើត្រង់ផ្ទះលើទឹកនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះថា **កុរុន្ទីវេឡុវិហារ** អដ្ឋកថាដែលការកកិក្ខុគង់ប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលព្រះថេរៈកាលមុន មានព្រះថេរិកាចារ្យជាដើម កាន់យកន័យព្រះបាលីរចនាទុក ឈ្មោះ **ថេរវាទ** ។

ដំបូង ព្រះពុទ្ធឃោសៈបរិវត្តកុរុន្ទីអដ្ឋកថាអំពីសីហឡភាសា ធ្វើអដ្ឋកថា ព្រះវិនយបិដក ឈ្មោះ **សមន្តបាសាទិកា** ក្នុងភាសាមគធៈហើយ តអំពីនោះ ក្នុងព្រះសុត្តន្តបិដកបរិវត្តមហាអដ្ឋកថាអំពីសីហឡភាសា តាំងជាអដ្ឋកថាទីឃនិកាយ ឈ្មោះ **សុមង្គលវិលាសិនី** ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះ **បបញ្ចសូទនី** ជាអដ្ឋកថា សំយុត្តនិកាយ ឈ្មោះ **សារត្ថប្បកាសិនី** និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះ **មនោរថបូរណី** តអំពីនោះ ក្នុងព្រះអភិធម្មបិដកបរិវត្តបច្ចរិយអដ្ឋកថាអំពីសីហឡភាសា តាំងជាអដ្ឋកថាបករណធម្មសង្គណី ឈ្មោះ **អដ្ឋសាលិនី** ក្នុងមគធភាសា ជាអដ្ឋកថាបករណវិភង្គ ឈ្មោះ **សម្មោហវិនោទនី** និងអដ្ឋកថា ៥ បករណ៍ ឈ្មោះ **បរមត្ថទីបនី** ។

ព្រះពុទ្ធឃោសៈបានធ្វើអដ្ឋកថាសីហឡទាំងអស់ ឲ្យជាអដ្ឋកថាព្រះត្រៃបិដកក្នុងមគធភាសា ដែលជាមូលភាសាដូចពោលមក ដូច្នេះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍ដល់អ្នកប្រទេសដទៃទាំងពួង ( រហូតមក ) ។

កាលការបរិវត្តអដ្ឋកថា ព្រះត្រៃបិដកសម្រេចហើយ ផែនដីក៏បានញ័រ ( ជាអស្ចារ្យ ) អដ្ឋកថាព្រះត្រៃបិដក ដែលលោកធ្វើដូចពោលមកនេះ មួយឆ្នាំនោះឯង

ទើបសម្រេច ។

កាលសម្រេចកិច្ចហើយ ព្រះពុទ្ធឃោសៈ ប្រាថ្នានឹងថ្វាយបង្គំព្រះមហាពោធិ៍ ទើបថ្វាយបង្គំលាភិក្ខុសង្ឃ ត្រឡប់ទៅជម្ពូទ្វីបនោះឯង ។

ព្រះបាទមហានាម ទ្រង់គ្រប់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យសព្វគ្រប់ប្រការហើយ ក៏យាងទៅ ( កាន់បរលោក ) តាមកម្ម ។

ប្រវត្តិព្រះពុទ្ធឃោសៈនេះ ខ្ញុំរៀបរៀងតាមន័យដែលបានពោលទុក ក្នុងគម្ពីរ **សទ្ធម្មសង្គហៈ** និងក្នុងគម្ពីរ **មហាវង្សបុរាណ** វិញ្ញូជនដែលប្រាថ្នានឹងជ្រាបសេចក្តីដែលប្លែក ក៏គប្បីជ្រាបបានក្នុងគម្ពីរនោះៗ តាមគួរ គឺក្នុង **ពុទ្ធឃោសនិទាន** ឬក្នុងវិសមាលិនី ឬក្នុងបករណ៍វិសេស ឈ្មោះ **ញាណោទយ** ចុះ ។

ឯបុញ្ញមហាណ្ណវគ្គ ដែលខ្ញុំបានធ្វើហើយដោយការជម្រះ បករណ៍វិសុទ្ធិមគ្គមកត្រឹមប៉ុណ្ណេះ សូមទេវតា និងមនុស្សទាំងពួង អនុមោទនាបុណ្យនោះ ដើម្បីសេចក្តីសម្រេចនៃសម្បត្តិទាំងពួងចុះ សូមសត្វទាំងឡាយ រក្សាសីល ចម្រើនចិត្តភាវនាដោយសទ្ធា និងចូរកុំប្រមាទបញ្ញា ព្រោះថា ទុះជាផ្លូវនៃវិសុទ្ធិ សូមសត្វទាំងឡាយដែលត្រូវទុក្ខ ចូរនិទ្ទុក្ខផង ដែលត្រូវភ័យ ចូរនិរភ័យផង ដែលត្រូវសោក ចូរនិរសោកផង និងសាធុជនទាំងឡាយ ចូរដល់នូវសេចក្តីបរិសុទ្ធ ហោង ។

## បរិយោសានកថា

ព្រះថេរៈ មានឈ្មោះដែលគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោសៈ** ជាអ្នកមានភាពបរិសុទ្ធបរិបូណ៌ ប្រដាប់ដោយសទ្ធា វិជ្ជា និងសេចក្តីព្យាយាមដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាបុគ្គលរុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្តីល្អ មានសីលាចារៈការទៀងត្រង់ និងការឱនលំទោនជាដើម អាចឈោងចុះកាន់ជដៈ គឺលទ្ធិរបស់ខ្លួន

និងលទ្ធិរបស់បុគ្គលដទៃ ប្រកបដោយការមុតស្រួចនៃបញ្ញា មានចំណេះដឹង មិនទើស ទាក់ក្នុងសត្ថុសាសនៈ ដោយបរិយត្តិផ្សេងៗ គឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ជាមហាវេយ្យាករណ៍ ប្រកបដោយភាពវិចិត្រនៃពាក្យសម្ដី ទាំងទន់ភ្លន់ ទូលំទូលាយ បន្លឺចេញបាន ស្ទាត់ជំនាញ សន្សំឲ្យកើតករណសម្បត្តិ មានវាទៈប្រសើរត្រឹមត្រូវ បុគ្គលដទៃយល់បានងាយ ជាមហាកវី ហែហមដោយបដិសម្ភិទាដែលបែកធ្លាយ ជាអលង្ការនៃវង្ស ព្រះថេរៈដែលនៅក្នុងមហាវិហារទាំងឡាយ ដែលជាប្រទីបនៃថេរវង្ស មានការដឹងតាំងមាំល្អហើយ ក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ដោយគុណផ្សេងៗ មានអភិញ្ញា ៦ ជាដើម ហែហមដោយបដិសម្ភិទា បានរចនាវិសុទ្ធិមគ្គនេះចប់ហើយ ។

វិសុទ្ធិមគ្គនេះ តាំងនៅក្នុងលោក សម្ដែងន័យដល់កុលបុត្រទាំងឡាយ ដែលស្វែងរកធម៌ ជាគ្រឿងដកចេញនូវលោក ដរាបប៉ុនដែលព្រះនាមថា ពុទ្ធោ របស់ព្រះលោកជេដ្ឋៈ ដែលស្វែងរកគុណដ៏ធំ មានព្រះទ័យដ៏បរិសុទ្ធ ជាតាទិបុគ្គល ប្រព្រឹត្តទៅក្នុងលោក ។

បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

ចប់ ដោយបរិបូណ៌

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានកុំព្យូទ័រជាដើម ក្នុងកិច្ចការនេះជាធម្មទាន

❋ឧបាសិកា ហម យិម

ឧបាសក អ៊ុង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីផូ ឧបាសិកា បៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អ៊ុង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ួ ហោនាង ឧបាសិកា អ៊ុង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទបូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៊ុលីន ស៊ីមប៊ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សាវ៉ុយ ឧបាសិកា រ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ុង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❋ឧបាសក ឈុំ គឹម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមថៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងនិម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ជៀន ឧបាសិកា សឺន ចន្ទា
ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី
ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា
ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់រ៉ារី
❋ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ូន ព្រមទាំងបុត្រ
ញោម ឥន្ទុទ្ទីនិងជូ ញោម ហាន ញោម រ៉ន ញោម ភ័ណ្ឌ ញោម
សុមនា ញោម ជោត ញោម មាស សុភា ញោម ខ្មៅ លី កញ្ញា
នា ញោម ឆាង ញោម ធីង ឡេង ញោម អៀម ញោម កួង
ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ឆាលី លីណា
ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម
ស៊ិន ញោម ភាព សារឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ
ញោម យក់ រ៉ាន់ថា ។
❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី
លោក ដែង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ
❋ឧបាសក អ៊ឹង ហ្គេចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ
លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ
លោក ភួ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ
លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ
លោក ប៊ី ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ
ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ
❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្ដាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវទាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អៀន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ុ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ៃ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នៀង+យាយ ធឹង+គួង ភាង+សើន គា+សៀង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាហ្វ៉ៃឡេន+ ហ៊ុង+ ប៉ៃ ង៉ា+ រី វុត្ថ

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណោរ អ៊ុំ វីរៈ

ញោមប៉ៃ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត

ញោម ហ៊ុង+នាង មៀន+អូន ប៊ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+ តាំង វេន+ យុន+ យាយ ធុច + យាយ យន

ញោម ហ៊ិន ស៊ិម ញោម អៀន ភី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវ៉ាមី

ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី

ញោម ណោ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណាវ៉ា

ញោម ធារ៉ា+ឃឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី
ញោម អៀប សាន្ទូន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+ឃឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន
លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

| | |
|---|---|
| ឧបាសិកា ធីក ស្រ៊ីន | ព្រមទាំងកូនប្រុស អ៊ុឹង រិទ្ធី និងភរិយា |
| ឧបាសក ប៊ូហោ នាង | ឧបាសិកា អ៊ុឹង រិទ្ធារី ព្រមទាំងបុត្រធីតា |
| ឧបាសក យេម សំណាង | ឧបាសិកា យេម ឡាវ៉ា ព្រមទាំងបុត្រ |
| ឧបាសក សៅ ហ៊ាន | ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ |
| ឧបាសក ឃៀងសាវឿន | ឧបាសិកា ឈុំ ឆដា ព្រមទាំងបុត្រធីតា |
| ឧបាសក ម៉ៅ វង្ស | ឧបាសិកា ឆាន់ កាន់ជួង ព្រមទាំងបុត្រ |
| ឧបាសក និន ហាក់ | ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ |
| ឧបាសិកា ម៉ី ចាន់រ៉ាវី | ព្រមទាំងបុត្រធីតា |
| ឧបាសិកា យ៉ក់ ស៊ីមូរ៉ា | ព្រមទាំងបុត្រ |
| ឧបាសិកា វ៉ាន់ចាន់ | ព្រមទាំងបុត្រធីតា |
| ឧបាសិកា ខៀវ ណាត | ព្រមទាំងបុត្រធីតា |

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គឹមសែ កូន+ចៅ

ឧបាសិកា យូ ស៊ាងទន្ទលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង

ឧបាសិកា ជុំ សុខុម

ឧបាសិកា ហេង ស្រីជា

ឧបាសិកា ហេង ស្រីចន្ទ

ឧបាសិកា ហេង គន្ធា

ឧបាសក ហេង សុកត្រ

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គឹមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន

ឧបាសក អ៊ឹង ហ៊្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ

ឧបាសក វៀម ឈឺន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ

ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក នាង ៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ

ឧបាសក សៅ ស៊ុទ្ធរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វេង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលៀម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធវី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមឃក់ ឧបាសិកា អ៊ុម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡេា សាយហ៊ួច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ុម ព្រមទាំងបុត្រ ធីតា និងចៅ

លោក លី ហុង អ្នកស្រី ជាណារី ព្រមទាំងបុត្រ ធីតា

លោក ជូ ចាន់ថន អ្នកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លីម ចាន់ឌី អ្នកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា អ្នកស្រី លីម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអូន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា អ្នកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័ត អ្នកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រ ធីតា និងចៅ

លោក រស់ ប៊ុនឡេង អ្នកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀង ងីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

អ្នកស្រី ជុន បូណ៌មី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនចៅ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា រ៉ូចទៀង ព្រមទាំងកូនចៅ

ឧបាសក ជី សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជី ញ៉េ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហ៊ុន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី ប៊ួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ អ្នកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា ស៊ិន ឡាច ព្រមទាំងកូនចៅ

ឧបាសក ប៊ុន បួន ឧបាសិកា ឃុត សួរ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និងប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី អ្នកស្រី អួន សារ៉េត ព្រមទាំងបុត្រ

លោក ឌិម ឡូត អ្នកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន អ្នកស្រី ម៉ម សុជា ព្រមទាំងបុត្រ

លោក ស៊ឹម សារ៉ាន់ អ្នកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេងវណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គឹមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧបាសិកា ប៉េ សារ៉ា ឧបាសក ម៉ុី ធារី ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ៃ ស៊ីថា ឧបាសិកា ងួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង រ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ

ឧបាសក ជូ ប៉ូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃៀក ម៉ាន ឧបាសិកា ផូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា ម៉ៅ សុផានី ព្រមទាំងកូនចៅ

លោក លឹម លី អ្នកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុជធារី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ហ៊ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគីម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុជី +បុត្រ ហែម តុលា

# នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទរួមមានឧបការៈក្នុងការវេរធម្មទាន

| | |
|---|---|
| ១- ឧបាសក ប៉េង តាំងហៃ | ឧបាសិកា ហ៊ួ គឹមហៀក |
| ២- ឧបាសក ស្រេង ស្រ៊ាង | ឧបាសិកា គិម ចន្ថា |
| ៣- ឧបាសក ឡាយ សុខុម | ឧបាសិកា គី គឹមហាប់ |
| ៤- ឧបាសិកា បូ ម៉ាឡា | ឧបាសក បញ្ញា |
| ៥- ឧបាសិកា ង៉ែង យូអេង | ឧបាសិកា មាស ម៉ូនីកា |
| ៦- ឧបាសក លឹម ខូង | ឧបាសិកា កែវ អុន |
| ៧- ឧបាសិកា កែវ កល្យាណ | ឧបាសិកា ឡឹក ពេញចិត្ត |
| ៨- ឧបាសិកា ស៊ឺន ចន្ថា | លោក ឡាំ ដាវណ្ណ |
| ៩- ឧបាសិកា គួ ប៊ុនគាង | ឧបាសិកា ឈុំ គីមហួយ |
| ១០- ឧបាសិកា នេត្រ នរិទ្ធ | ឧបាសិកា តាំង ប៉ោងជីង ( ហៅ ទន់ ) |
| ១១-ឧបាសិកា ឱម លក្ខណា | ឧបាសិកា ហេង ច័ន្ទបុញ្ញវន្តី |
| ១២-ឧបាសិកា គី យក់បួយ | ឧបាសិកា ឈុន ណាត |
| ១៣-ឧបាសិកា អ៊ុឹង រិទ្ធារី | ឧបាសិកា សៀក ឆាយគីម |
| ១៤-ឧបាសិកា វៀម ចុល | ឧបាសិកា ម៉ៅ នី |

| | |
|---|---|
| ១៥-ឧបាសិកា សន ឈៀត | ឧបាសក ឡាន សុខុម |
| ១៦-ឧបាសិកា គី វណ្ណហាក់ | ឧបាសិកា ប៉ាន ណម |
| ១៧-ឧបាសិកា ស្ងួន កល្យាណ | ឧបាសិកា ភួង ភក្តី |
| ១៨-ឧបាសក អ៊ឹង វ៉ៃយ៉ា | ឧបាសក កុយ សាមន |
| ១៩-ឧបាសក ហុង សុវណ្ណារិទ្ធ | ឧបាសក ហុង សុវណ្ណារ៉េត |

តម្លៃបោះពុម្ពក្នុង ១ ក្បាល ២$ × ១០០០ ក្បាល = ២០០០ $

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០៧៧ ៦៦ ៦៦ ៣៨, ០៨៨៨ ៧៧ ៩៩ ៦៦, ០១២ ៣០៥ ៧៦៦ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

**-គម្ពីរអភិធម្មត្ថសង្គហៈ** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៦៥០ ទំព័រជាង ។

**-អភិធម្មត្ថសង្គហៈ** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-គម្ពីរអភិធម្មាវតា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-មិលិន្ទបញ្ហា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងរាបចំធ្វើ គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយ កុំព្យូទ័រចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ ភាគ

-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ

-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ

-គម្ពីរអង្គុត្តរនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១៣ ភាគ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៣៧ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះ បានចំនួន ៩០ ក្បាលជាងហើយ ។

## សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
## ខ្ញុំព្រះករុណា អាត្មាភាព
## ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មាន ១ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស មាន ៣ ភាគ

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១-២

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

## នាមពុទ្ធបរិស័ទដែលមានសទ្ធាបរិច្ចាគប្រាក់នៅសហរដ្ឋអាមេរិក ជួយបោះពុម្ពសៀវភៅនេះ

ឧបាសក ជឹម អេងស្រ៊ន ឧបាសិកា រ៉ា សុខគីន ព្រមទាំងបុត្រ
លោក ជឹម មុនីបុត្រ អ្នកស្រី មាស ច័ន្ទនារី ព្រមទាំងបុត្រ
លោក ជឹម កុលវុឌ្ឍ អ្នកស្រី ម៉ាង សូលីដា ព្រមទាំងបុត្រ
លោក ជឹម សុភពោ អ្នកស្រី ប៉េង វិចិត្តា ព្រមទាំងបុត្រ
អ្នកស្រី ជឹម ពន្ធរក្ខ ព្រមទាំងបុត្រ
អ្នកស្រី ជឹម ពុទ្ធារី លោក ឈុន ហ៊ី ព្រមទាំងបុត្រ
អ្នកស្រី ជឹម ឧសភា លោក ឡៅ ជួយ ព្រមទាំងបុត្រ
លោក តាន់ សុផាណា អ្នកស្រី លី គន្ធា ព្រមទាំងបុត្រ
... ២១០០ $

ឧបាសក ឡឹក ច័ន្ទដេត ព្រមទាំងបុត្រ
ឧបាសិកា ឡឹក ពេញចិត្ត
ឧបាសិកា អ៊ាប គីមអ៊ីន ព្រមទាំងបុត្រ
ឧបាសក អ៊ាប ហៃសាន និងភរិយា ព្រមទាំងបុត្រ
ឧបាសិកា សៀក ឆាយគីម
ឧបាសក អ៊ាប គីមស៊ីន ព្រមទាំងបុត្រ
.... ១៥០០ $

ឧបាសិកា យី គីមលាង ព្រមទាំងកូនចៅ
លោក ធន គីមហួន ព្រមទាំងកូនចៅ
... ១៥០០ $

ឧបាសិកា គីម ឡុំ ព្រមទាំងបុត្រ ............................................ ៥០០ $

ឧបាសិកា គីម ប៊ុម ព្រមទាំងបុត្រ ...................................... ១០០ $

ឧបាសិកា ព្រាម ណៃទាង ព្រមទាំងបុត្រ ........................... ១០០ $

ឧបាសិកា រ៉ាយ យ៉ាទីន ព្រមទាំងបុត្រវណ្ណ ធន ....................... ៦០ $

ឧបាសិកា វ៉ា សុខគីន ឧបាសក ជឹម អេងស្រ៊ីន ព្រមទាំងបុត្រ .... ៥០ $

ឧបាសិកា អ៊ូន ញ៉ៃ ព្រមទាំងបុត្រ ........................................... ៥០ $

ឧបាសិកា វង់ គីមឆេង ព្រមទាំងបុត្រ ...................................... ៥០ $

ឧបាសិកា ព្រាម ទាង ព្រមទាំងបុត្រ ......................................... ៥០ $

ឧបាសិកា គីម ឡុំ ព្រមទាំងបុត្រ ............................................ ៥០ $

ឧបាសិកា អ៊ុំ ច័ន្ទជួង ( អប្សរា ) ព្រមទាំងបុត្រ ......................... ៥០ $

ឧបាសិកា ឱន ទូច ព្រមទាំងកូនចៅ ........................................ ៥០ $

ឧបាសក មុត សក់ ឧបាសិកា សន្ធា វីនមាសសុខ+ក្រុមគ្រួសារ . ៥០ $

ឧបាសិកា ង៉ូវ មួយឡាយ ព្រមទាំងបុត្រ .................................. ៣០ $

ឧបាសិកា សួស កន ព្រមទាំងបុត្រ ......................................... ៣០ $

ឧបាសិកា គឹម ឡាង ព្រមទាំងបុត្រ ........................................ ៣០ $

ឧបាសិកា គឹម ម៉ាលីស ព្រមទាំងបុត្រ ..................................... ២០ $

ឧបាសិកា សា អ៊ុត ព្រមទាំងបុត្រ ......................................... ១០ $


**បោះពុម្ពជាធម្មទាន ១000 ក្បាល**

**ក្នុងតម្លៃ ១ ក្បាល ២ ដុល្លារ**

**រោងពុម្ព រមណីយ**

TEL : 012597431

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត